# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Oct-2011, 13:45
CMS/CFO: Kauv Keoratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ-កោសលប់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦
## (សាធារណៈ-កោសលប់)

---

**<u>អ្នកដាក់ឯកសារ:</u>**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**<u>អ្នកទទួលឯកសារ:</u>**
សហចៅក្រមស៊ើបអង្កេត:
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE

មេធាវីការពារក្ដី: នួន ជា
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE

មេធាវីការពារក្ដី: អៀង សារី
លោក អាង ឧត្តម
លោក Michael G.KARNAVAS

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:
លោក នី ចាន់ឌី
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
លោក គឹម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Elizabeth-Joelle RABESANDRATANA
លោកស្រី Annie DELAHAIE
លោក Philippe CANONNE
លោកស្រី Martine JACQUIN
លោកស្រី Fabienne

**មេធាវីការពារក្តីៈ អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Dianna ELLIS

**មេធាវីការពារក្តីៈ ខៀវ សំផន**
លោក ស សូវាន
លោក Jacques VERGÈS

**មេធាវីការពារក្តីៈ កាំង ហ្គេកអ៊ាវ**
លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

TRUSSES-NAPROUS
លោក Françoise Gautry
លោក Isabelle Durand
លោក Christine Martineau
លោក Laure Desfroges
លោក Ferdinand Djammen-Nzepa
លោក ឡោ ជុនធី
លោកស្រី ស៊ិន ស៊ុំន
លោក សំ សូគង់
លោក ហុង គីមសួន
លោក គង់ ពិសី
លោក គង់ ហេង
កញ្ញា SILKE Studzinsky
លោក Olivier BAHOUGNE
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក ចិត្ត វ៉ាន់លី
លោក ពេជ្រ អង្គ
លោក Julien Rivet
លោក Pascal Auboin
លោក យុង ផានិត

## កំណត់សំគាល់ការពន្យល់

នេះគឺជាដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ជាទំរង់កោសលប់នៃសំណុំរឿងលេខ០០២ ដែលបានចេញផ្សាយដោយមានការយល់ព្រមពីអង្គជំនុំជម្រះសាលាដំបូងនៃអវតក និង អនុលោម តាមវិធាន៥៤នៃវិធានផ្ទៃក្នុង អវតក ដើម្បីធានាថាសាធារណជនត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីនីតិវិធីដែលកំពុងបន្តនៅចំពោះមុខតុលាការ។

ដីកាសន្និដ្ឋានស្ថាពរបានដាក់ជូនទៅចៅក្រមស៊ើបសួរ អវតក កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។នៅក្នុងនោះមានការវិភាគរបស់សហព្រះរាជអាជ្ញាយ៉ាងលំអិត អំពីភស្តុតាងដែលទាក់ទងទៅនឹងសិទ្ធិអំណាច និងរចនាសម្ព័ន្ធទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ(ភាគIV(ខ)) ផែនការឧក្រិដ្ឋកម្មរួម(ភាគIV(គ)) ទីតាំងឧក្រិដ្ឋកម្ម/ព្រឹត្តិការណ៍ឧក្រិដ្ឋកម្មនានា(ភាគIV(ឃ)) ក៏ដូចជាការចូលរួមពាក់ព័ន្ធនីមួយៗរបស់ជនជាប់ចោទទាំងបួនរូបដែរ(ភាគIV(ច))។ ដីកាសន្និដ្ឋានស្ថាពរ ក៏បានសរសេរបញ្ចូលផងដែរនូវការពិនិត្យរបស់សហព្រះរាជអាជ្ញា អំពីច្បាប់ដែលអាចអនុវត្តបានចំពោះមុខតុលាការ(ភាគV) និងការកំណត់បទល្មើសចំពោះអង្គហេតុនានាដែលបានចោទប្រកាន់(ភាគVI)។

នៅក្នុងទម្រង់ច្បាប់ដើមនៃដីកាសន្និដ្ឋានស្ថាពរ មានលេខយោងជើងទំព័រចំនួន៦១១ដែលរួមមានឯកសារយោងជាង១៨០០០ ហើយក៏មានឧបសម្ព័ន្ធមួយចំនួនផងដែរ។ នៅក្នុងឯកសារជាសាធារណនេះ រាល់លេខយោងជើងទំព័រ ភស្តុតាង ឧបសម្ព័ន្ធ ក៏ដូចជាខ្លឹមសារដែលអាចជាការសម្ងាត់ត្រូវបានកោសលប់ ដើម្បីឲ្យស្របទៅនឹងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ថ្នាក់ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង។

មាតិកា

I. **សេចក្តីផ្តើម**......29
II សេចក្តីសង្ខេបរឿងក្តី......31
III. ប្រវត្តិនីតិវិធី......37
IV. **អង្គហេតុជាក់ស្តែង**......43
**ក**- ជម្លោះប្រដាប់អាវុធ......43
**ខ**- រចនាសម្ពន្ធគ្រប់គ្រង......76
**គ**- ផែនការឧក្រិដ្ឋកម្មរួម......114
**ឃ**- **បទឧក្រិដ្ឋនានា**......134
**ង**- **ការដឹងឮអំពីឧក្រិដ្ឋកម្ម**......474
**ច**- **តួនាទីរបស់ជនជាប់ចោទ**......502
V. ច្បាប់......705
**ក**- **បទឧក្រិដ្ឋ**......705
**ខ**- **ការទទួលខុសត្រូវជាបុគ្គល**......747
VI. **ការកំណត់បទល្មើស**......776
**ក**- **បទឧក្រិដ្ឋ**......776
**ខ**-ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល......867
VII. បទចោទ......937
ឧបសម្ពន្ធ ៥: សន្ទានុក្រម......941

## មាតិកាលម្អិត

I. សេចក្តីផ្តើម ........ 29
II សេចក្តីសង្ខេបរឿងក្តី ........ 31
III. ប្រវត្តិនីតិវិធី ........ 37
ការបើកកិច្ចស៊ើបសួរ ........ 37
ការចាប់ខ្លួន ........ 38
បទចោទ ........ 39
ការឃុំខ្លួនបណ្តោះអាសន្ន ........ 39
ការបំបែកសំណុំរឿង០០១ ........ 40
ការបិទកិច្ចស៊ើបសួរ ........ 40
ទំហំនៃសំណុំរឿង ........ 41
ការចូលរួមរបស់ជនរងគ្រោះ និងពាក្យបណ្តឹងរបស់ជនរងគ្រោះ ........ 41
IV. អង្គហេតុជាក់ស្តែង ........ 43
ក- ជម្លោះប្រដាប់អាវុធ ........ 43
ទិដ្ឋភាពទូទៅ ........ 43
ឆ្នាំ១៩៧៥ ........ 47
ឆ្នាំ១៩៧៦ ........ 49
ឆ្នាំ១៩៧៧ ........ 53
ការវាយលុកចូលទឹកដីវៀតណាម ........ 54
ការវាយលុកចូលកម្ពុជា និងការវាយលុកជាទ្រង់ទ្រាយធំលើកដំបូងរបស់វៀតណាមមកលើកម្ពុជា. 55
ឆ្នាំ១៩៧៨-១៩៧៩ ........ 65
ទិដ្ឋភាពទូទៅ ........ 65
ការប្រឈមមុខដាក់គ្នាបន្ថែមទៀត និងការវាយលុកចុងក្រោយរបស់ប្រទេសវៀតណាម ........ 68
ខ- រចនាសម្ពន្ធគ្រប់គ្រង ........ 76
បក្សកុម្មុយនីស្តកម្ពុជា ........ 76
ប្រវត្តិសាស្ត្រមុនខែមេសា ឆ្នាំ១៩៧៥ ........ 76
មហាសន្និបាតបក្ស ........ 83
គណៈកម្មាធិការមជ្ឈិម ........ 84

គណៈកម្មាធិការអចិន្ត្រៃយ៍ ........ 85
មន្ទីរ ៨៧០ ........ 89
រដ្ឋកម្ពុជាប្រជាធិបតេយ្យ ........ 92
ការបែងចែកភូមិសាស្ត្រសរដ្ឋបាលរបស់ ប.ក.ក ........ 98
កងទ័ពបដិវត្តកម្ពុជា ........ 100
បណ្ដាញទំនាក់ទំនង ........ 106
ទិដ្ឋភាពទូទៅ ........ 106
បណ្ដាញវិទ្យុទាក់ទង [ក-១៨ និង ក-១] ........ 107
ទូរស័ព្ទ ........ 109
ការទាក់ទងរវាងថ្នាក់លើ និងថ្នាក់ក្រោម ........ 109
រវាងស្ថានទូត និងស្ថានទូត ........ 112
ឯកសារបោះពុម្ពផ្សាយ និងទំនាក់ទំនងផ្ទៃក្នុង ........ 112
ការតាមដានរបាយការណ៍អន្តរជាតិ ........ 113
គ- ផែនការឧក្រិដ្ឋកម្មរួម ........ 114
គោលដៅ ........ 114
សមាជិកភាព ........ 116
ការអនុវត្ត ........ 117
ទិដ្ឋភាពជាទូទៅដោយសង្ខេបអំពីសហកម្មឧក្រិដ្ឋកម្មរួម ........ 118
គោលដៅទី១៖ ការធ្វើឱ្យទៅជាទាសករ ........ 118
ការជម្លៀសដោយបង្ខំ ........ 118
ពលកម្មដោយបង្ខំ ........ 121
គោលដៅទី២៖ ការលុបបំបាត់សិទ្ធិមនុស្ស ........ 123
គោលដៅទី៣៖ ការបោសសម្អាតខ្មាំង ........ 127
ផលប៉ះពាល់ ........ 133
ឃ- បទឧក្រិដ្ឋនានា ........ 134
ការជម្លៀសដោយបង្ខំ ........ 134
ដំណាក់កាលទី១៖ ពីភ្នំពេញ ........ 134
ការជម្លៀស ........ 134

ស្ថានភាពអមនុស្សធម៌ ..... 139
សេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការជម្លៀសដោយបង្ខំ ..... 140
ការប្រហារជីវិតជាទ្រង់ទ្រាយធំទៅលើទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ..... 143
ទីកន្លែងប្រហារជីវិត "ទួលពោធិជ្រៃ" ..... 143
ទីតាំង ..... 143
ការសម្លាប់ដោយខុសច្បាប់ ..... 144
រចនាសម្ពន្ធគ្រប់គ្រង ..... 147
ស្រុកកំពង់ត្រឡាចលើ ..... 147
សេចក្តីផ្តើម ..... 147
ការសម្លាប់ដោយខុសច្បាប់ ..... 148
រចនាសម្ពន្ធគ្រប់គ្រង ..... 151
ដំណាក់កាលទី២៖ ទៅកាន់ភូមិភាគឧត្តរ និងពាយ័ព្យ ..... 151
ការជម្លៀស ..... 151
ស្ថានភាពអមនុស្សធម៌ និងពលកម្មដោយបង្ខំ ..... 152
ការសម្លាប់ក្នុងទ្រង់ទ្រាយធំនៅភូមិភាគពាយ័ព្យ ..... 155
សេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការជម្លៀសដោយបង្ខំ ..... 156
ការធ្វើពលកម្មដោយបង្ខំ ..... 156
សហករណ៍ត្រាំកក់ ..... 156
ទីតាំង និងប្រតិបត្តិការ ..... 156
រចនាសម្ពន្ធគ្រប់គ្រង ..... 157
ការគ្រប់គ្រងលើការដ្ឋាន ..... 157
រចនាសម្ពន្ធក្នុងការដ្ឋាន ..... 158
ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស ..... 159
ពីបញ្ជាការជាន់ខ្ពស់ ប.ក.ក ទៅការដ្ឋាន ..... 160
ពីការដ្ឋានទៅបញ្ជាការជាន់ខ្ពស់ ប.ក.ក ..... 161
ការធ្វើពលកម្មដោយបង្ខំ ..... 162
ស្ថានភាពអមនុស្សធម៌ ..... 163
ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់ ..... 166

ស្រែអំបិល ..... 167
ទីតាំង និងប្រតិបត្តិការ ..... 167
រចនាសម្ព័ន្ធគ្រប់គ្រង ..... 168
    ការគ្រប់គ្រងលើការដ្ឋាន ..... 168
    នៅក្នុងការដ្ឋាន ..... 169
ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស ..... 169
ការធ្វើពលកម្មដោយបង្ខំ ..... 170
ស្ថានភាពអមនុស្សធម៌ ..... 172
ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់ ..... 175
ការសម្លាប់ដោយខុសច្បាប់ ..... 176
ទំនប់១ មករា ..... 177
ទីតាំង និងប្រតិបត្តិការ ..... 177
រចនាសម្ព័ន្ធគ្រប់គ្រង ..... 178
    ការគ្រប់គ្រងលើការដ្ឋាន ..... 178
    រចនាសម្ព័ន្ធនៅក្នុងការដ្ឋាន ..... 179
ការប្រាស្រ័យទាក់ទងជាមួយនឹងមជ្ឈិមបក្ស ..... 180
ការធ្វើពលកម្មដោយបង្ខំ ..... 181
ស្ថានភាពអមនុស្សធម៌ ..... 182
ការឃុំឃាំង និងការចាប់ខ្លួនដោយខុសច្បាប់ ..... 183
ការសម្លាប់ដោយខុសច្បាប់ ..... 185
ទំនប់ទឹកត្រពាំងថ្ម ..... 186
ទីតាំង និងប្រតិបត្តិការ ..... 186
រចនាសម្ព័ន្ធគ្រប់គ្រង ..... 187
    ការគ្រប់គ្រងពីលើការដ្ឋាន ..... 187
    ការគ្រប់គ្រងនៅក្នុងការដ្ឋាន ..... 188
ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស ..... 190
    បញ្ជាជាន់ខ្ពស់របស់ ប.ក.ក មកលើការដ្ឋាន ..... 190
    ការគ្រប់គ្រងពីការដ្ឋានទៅកាន់បញ្ជាការជាន់ខ្ពស់ ប.ក.ក ..... 191

ការធ្វើពលកម្មដោយបង្ខំ ........................................ 191
ស្ថានភាពអមនុស្សធម៌ ........................................ 193
ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់ ........................................ 194
ការសម្លាប់ដោយខុសច្បាប់ ........................................ 195
អាកាសយានដ្ឋានកំពង់ឆ្នាំង ........................................ 197
ទីតាំង និងប្រតិបត្តិការ ........................................ 197
រចនាសម្ព័ន្ធគ្រប់គ្រង ........................................ 198
ការគ្រប់គ្រងពីលើការដ្ឋាន ........................................ 198
ការគ្រប់គ្រងក្នុងការដ្ឋាន ........................................ 199
ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស ........................................ 200
ពលកម្មដោយបង្ខំ ........................................ 201
ស្ថានភាពអមនុស្សធម៌ ........................................ 204
ការចាប់ខ្លួន និងឃុំឃាំងដោយខុសច្បាប់ ........................................ 205
ការសម្លាប់ដោយខុសច្បាប់ ........................................ 206
អាពាហ៍ពិពាហ៍ដោយបង្ខំ ........................................ 207
សេចក្តីផ្តើម ........................................ 207
ការបង្កើតគោលនយោបាយ ........................................ 207
ការប្រាស្រ័យទាក់ទងនៃគោលនយោបាយ ........................................ 210
អំពីការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ ........................................ 212
មន្ទីរសន្តិសុខ ........................................ 218
មន្ទីរសន្តិសុខស-២១ ........................................ 218
ទីតាំង និងប្រតិបត្តិការ ........................................ 218
បរិវេណកណ្តាលនៅស-២១ ........................................ 221
ជើងឯក ........................................ 224
ស-២៤ (ព្រៃស) ........................................ 225
រចនាសម្ព័ន្ធគ្រប់គ្រង ........................................ 225
ការគ្រប់គ្រងពីលើមន្ទីរសន្តិសុខនេះ ........................................ 225
នៅក្នុងមន្ទីរសន្តិសុខ ........................................ 226

ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា 231
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ 236
សមាសភាពអ្នកទោស 236
ដំណើរការចាប់ខ្លួន 241
ការចូលរួមក្នុងការសម្រិតសម្រាំង 245
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ 248
លក្ខណៈអមនុស្សធម៌ 248
ពលកម្មដោយបង្ខំ 256
ការសួរចម្លើយ និងទារុណកម្ម 257
គោលបំណង 257
វិធីសាស្ត្រ និងទម្រង់ 259
ការសម្លាប់មនុស្សក្រៅច្បាប់ 263
បរិវេណកណ្ដាលស-២១ 265
ជើងឯក 267
មន្ទីរសន្តិសុខកោះខ្សែង 268
ទីតាំង និងប្រតិបត្តិការ 268
រចនាសម្ពន្ធគ្រប់គ្រង 268
ការគ្រប់គ្រងមន្ទីរសន្តិសុខ 268
នៅក្នុងមន្ទីរសន្តិសុខ 270
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា 270
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ 272
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ 275
លក្ខណៈអមនុស្សធម៌ 275
ពលកម្មដោយបង្ខំ 275
ការសួរចម្លើយ និងទារុណកម្ម 276
ការសម្លាប់មនុស្សក្រៅច្បាប់ 277
មន្ទីរសន្តិសុខព្រៃដំរីស្រុត 278
ទីតាំង និងប្រតិបត្តិការ 278

រចនាសម្ព័ន្ធគ្រប់គ្រង ........ 279
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ........ 279
រចនាសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ ........ 280
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ........ 281
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ........ 282
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ........ 284
លក្ខណៈអមនុស្សធម៌ ........ 284
ពលកម្មដោយបង្ខំ ........ 285
ការសួរចម្លើយ និងទារុណកម្ម ........ 286
ការសម្លាប់មនុស្សក្រៅច្បាប់ ........ 287
មន្ទីរសន្តិសុខក្រាំងតាចាន់ ........ 288
ទីតាំង និងប្រតិបត្តិការ ........ 288
រចនាសម្ព័ន្ធគ្រប់គ្រង ........ 289
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ........ 289
រចនាសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ ........ 290
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ........ 291
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ........ 294
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ........ 295
លក្ខណៈអមនុស្សធម៌ ........ 295
ពលកម្មដោយបង្ខំ ........ 296
ការសួរចម្លើយ និងការធ្វើទារុណកម្ម ........ 297
ការសម្លាប់មនុស្សក្រៅច្បាប់ ........ 298
មន្ទីរសន្តិសុខសង់ ........ 301
ទីតាំង និងប្រតិបត្តិការ ........ 301
រចនាសម្ព័ន្ធគ្រប់គ្រង ........ 302
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ........ 302
រចនសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ ........ 302
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ........ 303

ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ..... 303
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ..... 304
លក្ខណៈអមនុស្សធម៌..... 305
ពលកម្មដោយបង្ខំ ..... 305
ការសួរចម្លើយ និងការធ្វើទារុណកម្ម..... 306
ការសម្លាប់មនុស្សក្រៅច្បាប់ ..... 307
មន្ទីរសន្តិសុខគោកក្ដួច..... 309
ទីតាំង និងប្រតិបត្តិការ..... 309
រចនាសម្ពន្ធគ្រប់គ្រង ..... 311
ការគ្រប់គ្រងលើមន្ទីរសន្តិសុខនេះ ..... 311
រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ ..... 312
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា..... 313
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ..... 315
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ..... 317
លក្ខណៈអមនុស្សធម៌..... 317
ពលកម្មដោយបង្ខំ ..... 318
ការសួរចម្លើយ និងការធ្វើទារុណកម្ម..... 319
ការសម្លាប់មនុស្សក្រៅច្បាប់ ..... 321
មន្ទីរសន្តិសុខភ្នំក្រោល..... 322
ទីតាំង និងប្រតិបត្តិការ..... 322
រចនាសម្ពន្ធគ្រប់គ្រង ..... 323
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ..... 323
រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ ..... 323
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា..... 324
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ..... 325
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ..... 330
លក្ខណៈអមនុស្សធម៌..... 330
ពលកម្មដោយបង្ខំ ..... 331

ការសួរចម្លើយ និងការទារុណកម្ម ................ 331
ការសម្លាប់មនុស្សខុសច្បាប់ ................ 332
មន្ទីរសន្តិសុខវត្តធ្លក ................ 334
ទីតាំង និងប្រតិបត្តិការ ................ 334
រចនាសម្ពន្ធគ្រប់គ្រង ................ 335
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ................ 335
រចនាសម្ពន្ធនៅក្នុងមន្ទីរសន្តិសុខ ................ 337
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ................ 337
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ................ 338
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ................ 339
លក្ខណៈអមនុស្សធម៌ ................ 339
ពលកម្មដោយបង្ខំ ................ 339
ការសួរចម្លើយ និងការធ្វើទារុណកម្ម ................ 339
ការសម្លាប់មនុស្សក្រៅច្បាប់ ................ 340
មន្ទីរសន្តិសុខអូរកន្សែង(ភូមិ៣) ................ 342
ទីតាំង និងប្រតិបត្តិការ ................ 342
រចនាសម្ពន្ធគ្រប់គ្រង ................ 343
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ................ 343
រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ ................ 344
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ................ 344
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ................ 345
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ................ 347
លក្ខណៈអមនុស្សធម៌ ................ 347
ពលកម្មដោយបង្ខំ ................ 348
ការសួរចម្លើយ និងការធ្វើទារុណកម្ម ................ 349
ការសម្លាប់មនុស្សក្រៅច្បាប់ ................ 351
មន្ទីរសន្តិសុខវត្តគីរីរម្យ ................ 353
ទីតាំង និងប្រតិបត្តិការ ................ 353

មន្ទីរសន្តិសុខ និងទីពិឃាតវត្តគីរីរម្យ ........ 354
មន្ទីរសន្តិសុខចន្លោះក្តោង ........ 354
រចនាសម្ពន្ធគ្រប់គ្រង ........ 354
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ........ 354
រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ ........ 356
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ........ 356
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ........ 358
វត្តគីរីរម្យ ........ 358
ចន្លោះក្តោង ........ 358
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ........ 359
លក្ខណៈអមនុស្សធម៌-វត្តគីរីរម្យ ........ 359
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ - ចន្លោះក្តោង ........ 359
ការសួរចម្លើយ និងទារុណកម្ម ........ 360
ការសម្លាប់មនុស្សក្រៅច្បាប់ ........ 360
វត្តគីរីរម្យ ........ 360
ចន្លោះក្តោង ........ 361
តា ឆាំ - ការសម្លាប់នៅក្នុងស្រុក ........ 362
មន្ទីរសន្តិសុខ សៀមរាប ........ 363
ទីតាំង និងប្រតិបត្តិការ ........ 363
រចនាសម្ពន្ធគ្រប់គ្រង ........ 365
ការគ្រប់គ្រងលើមន្ទីរសន្តិសុខ ........ 365
រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ ........ 366
ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ........ 366
ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់ ........ 367
លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ ........ 370
លក្ខណៈអមនុស្សធម៌ ........ 370
ពលកម្មដោយបង្ខំ ........ 371
ការសួរចម្លើយ និងទារុណកម្ម ........ 372

ការសម្លាប់មនុស្សក្រៅច្បាប់ ............ 373
ការសម្រិតសម្រាំងនៅភូមិភាគឧត្តរ ............ 375
សេចក្តីផ្តើម ............ 375
ការចាប់ខ្លួន និងចម្លើយសារភាពរបស់ កុយ ធួន ............ 376
កងពល៣១០ ............ 379
កងពល៤៥០ ............ 380
កងពល១៧៤ ............ 380
ក្រសួងពាណិជ្ជកម្ម ............ 381
ភូមិភាគកណ្តាល (ឧត្តរចាស់) ............ 384
ភូមិភាគឧត្តរថ្មី ............ 387
កងពល និងក្រសួងផ្សេងទៀតដែល កុយ ធួន បានឆ្លើយដាក់ ............ 390
ការសម្រិតសម្រាំងនៅភូមិភាគបូព៌ា ............ 392
សេចក្តីផ្តើម ............ 392
ការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា ............ 393
កន្លែងប្រហារជីវិតនៅស្ទឹងតូច ............ 404
ទីតាំង ............ 404
ការសម្លាប់មនុស្សដោយខុសច្បាប់ ............ 405
ការជម្លៀសមនុស្សពីភូមិភាគបូព៌ា ............ 408
ការសម្លាប់រង្គាលជាទ្រង់ទ្រាយធំទៅលើអ្នកដែលត្រូវគេជម្លៀសពីភូមិភាគបូព៌ា ............ 412
ឧក្រិដ្ឋកម្មប្រឆាំងពុទ្ធសាសនិក ............ 414
សេចក្តីផ្តើម ............ 414
ប្រភពដើមនៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ............ 415
គោលនយោបាយរបស់ ប.ក.ក កំណត់ចំពោះពុទ្ធសាសនិកជន និងព្រះពុទ្ធសាសនា ............ 416
ការអនុវត្តន៍គោលនយោបាយរបស់ ប.ក.ក ក្នុងការលុបបំបាត់ព្រះពុទ្ធសាសនា ............ 418
វត្តសំរោងក្នុង (ខេត្តបាត់ដំបង) ............ 419
វត្តដំណាក់ត្រយឹង (ខេត្តកំពត) ............ 421
វត្តអន្ទង់វៀន (ខេត្តក្រចេះ) ............ 422
វត្តជ័យមង្គល (ខេត្តស្ទឹងត្រែង) ............ 423

វត្តចំបក់ធំ (ខេត្តស្វាយរៀង) ..... 423
វត្តតាគត់មង្គល (ខេត្តកណ្តាល) ..... 424
ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម ..... 425
សេចក្តីផ្តើម ..... 425
ប្រភពដើមរបស់ជនជាតិចាមនៅកម្ពុជា ..... 426
គោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់គោលដៅលើប្រជាជនចាម ..... 427
ការអនុវត្តន៍គោលនយោបាយរបស់ ប.ក.ក ក្នុងការកម្ទេចជនជាតិចាម ..... 429
នៅក្នុងស្រុកកងមាស (ភូមិភាគកណ្តាល) ..... 430
នៅស្រុកក្រូចឆ្មារ (ភូមិភាគបូព៌ា) ..... 433
ក្នុងតំបន់៥ (ភូមិភាគពាយ័ព្យ) ..... 435
គោលបំណងកម្ទេចជនជាតិចាម ..... 436
ការបំផ្លិចបំផ្លាញជនជាតិចាម ..... 441
ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម ..... 442
សេចក្តីផ្តើម ..... 442
ឧប្បត្តិដ្ឋាននៃក្រុមជនជាតិវៀតណាមនៅកម្ពុជា ..... 444
ជនជាតិវៀតណាម ជាក្រុមជាតិ/ជាតិពន្ធុដាច់ដោយឡែកមួយនៅកម្ពុជា ..... 446
គោលនយោបាយសម្លាប់រង្គាលលើជនជាតិវៀតណាមរបស់បក្សកុម្មុយនីស្តកម្ពុជា ..... 449
ការអនុវត្តគោលនយោបាយចំពោះជនជាតិវៀតណាម ..... 453
ការសម្លាប់នៅព្រៃវែង និងស្វាយរៀង ..... 458
ព្រៃវែង ..... 459
ស្វាយរៀង ..... 462
អំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធជាមួយវៀតណាម ..... 462
ការពិពណ៌នាជាទូទៅគ្រួសៗអំពីឧក្រិដ្ឋកម្មនានា ..... 462
ភស្តុតាងជាសាក្សីផ្ទាល់ភ្នែក ..... 467
របាយការណ៍ស្តីពីឧក្រិដ្ឋកម្ម ដាក់ជូនទៅគណៈមជ្ឈិមបកក និងសេចក្តីរាយការណ៍អន្តរជាតិ... 470
ង- ការដឹងឮអំពីឧក្រិដ្ឋកម្ម ..... 474
ទិដ្ឋភាពទូទៅ ..... 474
ឯកសារកម្ពុជាប្រជាធិបតេយ្យ ..... 476

ទំនាក់ទំនងនៅក្នុងរដ្ឋាភិបាល ..... 476
របាយការណ៍ពីភូមិភាគ កងពលយោធា និងក្រសួងនានា ..... 476
ការប្រជុំ ..... 476
របាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ ..... 478
ទូរលេខ ..... 480
បញ្ហានានាដែលរាយការណ៍ទៅមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ..... 482
ឯកសារបោះពុម្ពផ្សាយ និងការផ្សាយតាមវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា ..... 488
សន្ទរកថា និងការសម្ភាសន៍ ..... 489
ឯកសារអន្តរជាតិ ..... 491
រដ្ឋាភិបាលនានា អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ..... 491
សារព័ត៌មានអន្តរជាតិ ..... 496
ការត្រួតពិនិត្យការចេញផ្សាយសារព័ត៌មាន និងការឆ្លើយតបរបស់ ប.ក.ក ..... 499
ច- តួនាទីរបស់ជនជាប់ចោទ ..... 502
នួន ជា ..... 502
ទិដ្ឋភាពទូទៅ ..... 502
តួនាទីនៅមុនឆ្នាំ១៩៧៥ ..... 506
តួនាទី និងសិទ្ធិអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ..... 509
ការចូលរួម និងការរួមចំណែក ..... 512
ការចូលរួមជាទូទៅក្នុងផែនការឧក្រិដ្ឋកម្ម ..... 512
ការជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា ..... 512
វគ្គបំពាក់បំប៉ន និងវគ្គរៀនសូត្រនយោបាយ ..... 514
សុន្ទរកថា ..... 515
ការចូលរួមក្នុងហេតុការណ៍ឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ..... 517
ការជម្លៀសដោយបង្ខំ ..... 517
ការធ្វើពលកម្មដោយបង្ខំ ..... 521
អាពាហ៍ពិពាហ៍ដោយបង្ខំ ..... 523
មន្ទីរសន្តិសុខ ..... 524
ការបោសសម្អាតកម្មាភិបាលភូមិភាគ ..... 541

ឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនិក ..... 546
ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម និងប្រជាជនវៀតណាម..... 547
ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ..... 550
សកម្មភាព និងតួនាទី..... 551
ការដឹងឮ និងការបដិសេធឧក្រិដ្ឋកម្ម..... 554
អៀង សារី..... 556
ទិដ្ឋភាពទូទៅ ..... 556
តួនាទីមុនឆ្នាំ១៩៧៥ ..... 560
មុខតំណែង និងអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ..... 565
ការចូលរួម និងការរួមចំណែក ..... 571
ការចូលរួមជាទូទៅក្នុងផែនការឧក្រិដ្ឋកម្មរួម ..... 571
ការចូលរួមក្នុងអង្គប្រជុំនានា ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងៗទៀត..... 571
ការបំពាក់បំប៉នននយោបាយ និងវគ្គសិក្សារៀនសូត្រផ្សេងៗ ..... 573
សុន្ទរកថា ..... 575
ការចូលរួមចំណែកក្នុងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មជាក់ស្ដែងនានា ..... 578
ការជម្លៀសដោយបង្ខំ ..... 578
ការធ្វើពលកម្មដោយបង្ខំ..... 580
មន្ទីរសន្តិសុខតាមតំបន់ ..... 582
ការបោសសម្អាតទៅលើក្រសួងការបរទេស មន្ត្រីការទូត និងកម្មាភិបាលផ្សេងៗទៀត (ស២១)..... 583
ការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក ..... 593
ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម..... 594
រយៈកាលក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ..... 596
សកម្មភាព និងតួនាទី..... 597
ការដឹងឮ និងការបដិសេធឧក្រិដ្ឋកម្ម..... 599
ខៀវ សំផន ..... 600
ទិដ្ឋភាពទូទៅ ..... 600
មុនឆ្នាំ១៩៧៥ ..... 604

តំណែង និងអំណាចក្នុងកម្ពុជាប្រជាធិបតេយ្យ ........ 610
រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងតំណែងជាគណៈប្រធានរដ្ឋ ........ 610
ជាសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា.... 612
ក្នុងឋានៈជាប្រធានមន្ទីរនយោបាយ៨៧០ ........ 616
ផ្នែកពាណិជ្ជកម្ម ........ 619
ឥទ្ធិពលផ្ទាល់ខ្លួននៅក្នុងជួរថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា ........ 621
ការចូលរួម និងការរួមចំណែក ........ 622
ការចូលរួមជាទូទៅក្នុងផែនការឧក្រិដ្ឋកម្ម........ 622
ការជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា ........ 623
ការជួបប្រជុំ និងការត្រួតពិនិត្យកម្មាភិបាលថ្នាក់ក្រោម ........ 624
វគ្គសិក្សា និងបំពាក់បំប៉ននយោបាយ........ 626
សុន្ទរកថា ........ 630
ការចូលរួមក្នុងហេតុការណ៍ឧក្រិដ្ឋកម្មជាក់លាក់ ........ 634
ការជម្លៀសដោយបង្ខំ ........ 634
ពលកម្មដោយបង្ខំ ........ 636
ការបោសសម្អាតកម្មាភិបាល ........ 642
ឧក្រិដ្ឋកម្មទៅលើប្រជាជនវៀតណាម........ 650
ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ........ 651
សកម្មភាពនានា និងតួនាទី........ 652
ការដឹងឮ និងការបដិសេធអំពើឧក្រិដ្ឋ........ 656
អៀង ធីរិទ្ធ........ 662
ទិដ្ឋភាពទូទៅ ........ 662
តួនាទីនៅមុនឆ្នាំ១៩៧៥ ........ 666
មុខតំណែង និងសិទ្ធិអំណាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ........ 671
ការចូលរួមពាក់ព័ន្ធក្នុងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ ........ 671
មុខតំណែងនៃសិទ្ធិអំណាចផ្លូវការ ........ 671
ដំណើរការនយោបាយ និងអំណាចទូលំទូលាយ........ 673
មុខតំណែងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ........ 675

មុខងារជារដ្ឋមន្ត្រី ..... 675
ការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច ..... 676
រចនាសម្ព័ន្ធ និងអង្គការចាត់តាំងរបស់ក្រសួងសង្គមកិច្ច ..... 677
គណៈកម្មាធិការក្រសួងសង្គមកិច្ច ..... 677
មន្ទីរនានានៃក្រសួងសង្គមកិច្ច ..... 678
មន្ទីរពេទ្យ និងកន្លែងផលិតឱសថនានាដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច 679
ការគ្រប់គ្រងមិនត្រឹមត្រូវរបស់ក្រសួងសង្គមកិច្ច ..... 680
ការចូលរួម និងការរួមចំណែក ..... 682
ការចូលរួមជាទូទៅនៅក្នុងផែនការឧក្រិដ្ឋកម្ម ..... 682
ការជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ បកក ដទៃទៀត និងជាមួយមន្ត្រីការទូតនានា ..... 682
ការជួបប្រជុំនានាជាមួយ ឬការចាត់ចែងគ្រប់គ្រងកម្មាភិបាលថ្នាក់ក្រោម ..... 684
ទស្សនកិច្ចតាមមន្ទីរពេទ្យ ការចុះពិនិត្យតាមរោងចក្រ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ..... 684
ទស្សនៈកិច្ចតាមការដ្ឋាន ..... 685
ការបំពាក់បំប៉នគោលនយោបាយ និងវគ្គអប់រំគោលនយោបាយ ..... 686
ការចូលរួមប្រព្រឹត្តិនៅក្នុងព្រឹត្តិការណ៍ឧក្រិដ្ឋជាក់លាក់ ..... 689
ការជម្លៀសដោយបង្ខំ ..... 689
ពលកម្មដោយបង្ខំ ..... 689
ការធ្វើឱ្យទៅជាទាសករ និងលក្ខខណ្ឌអមនុស្សធម៌ ..... 690
អាពាហ៍ពិពាហ៍ដោយបង្ខំ ..... 693
ការបោសសម្អាតកម្មាភិបាល ..... 694
តួនាទីក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ..... 698
តួនាទី និងសកម្មភាព ..... 699
ការទទួលដឹងឮ និងការបដិសេធអំពីឧក្រិដ្ឋកម្ម ..... 702
V. ច្បាប់ ..... 705
ក- បទឧក្រិដ្ឋ ..... 705
អំពើប្រល័យពូជសាសន៍ [ច្បាប់ អ.វ.ត.ក មាត្រា ៤] ..... 705
ធាតុផ្សំអត្តនោម័ត ..... 706
ចេតនាបំផ្លិចបំផ្លាញ ..... 706

ទាំងស្រុង ឬមួយផ្នែក ........ 708
ក្រុមដែលត្រូវទទួលបានការការពារ ........ 709
ដូចជា (SUCH AS/ AS SUCH) ........ 710
អំពើជាក់លាក់មួយចំនួន ........ 712
ការសម្លាប់សមាជិកក្រុម ........ 712
ការបង្កព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយ ឬផ្លូវចិត្ត ដល់សមាជិកក្រុម ........ 712
ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក ........ 713
ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតដល់ទារកក្នុងក្រុម 714
ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយ ទៅឲ្យក្រុមមួយផ្សេងទៀត ........ 714
បទល្មើសដែលអាចផ្តន្ទាទោសបាន ........ 715
សេចក្តីផ្តើមទាក់ទិននឹងទម្រង់នៃការចូលរួម ........ 715
ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ........ 716
ការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ........ 716
ការចូលរួមក្នុងអំពើប្រល័យពូជសាសន៍ ........ 717
ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ [មាត្រា ៥ នៃច្បាប់ អ.វ.ត.ក] ........ 719
លក្ខខណ្ឌតម្រូវទូទៅ ........ 720
ការវាយប្រហារ ........ 720
ជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ ........ 720
សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ........ 721
មូលហេតុរើសអើង ........ 723
អំពើរបស់ជនជាប់ចោទត្រូវផ្សំបានជាផ្នែកមួយនៃការវាយប្រហារ ........ 723
បទល្មើសជាក់លាក់មួយចំនួន ........ 724
ការធ្វើមនុស្សឃាត ........ 724
ការសម្លាប់រង្គាល ........ 724
ការធ្វើឲ្យទៅជាទាសករ ........ 726
ការដាក់ក្នុងមន្ទីរឃុំឃាំង ........ 727
ការធ្វើទារុណកម្ម ........ 728

ការរំលោភសេពសន្ថវៈ ... 729
ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា ... 730
អំពើអមនុស្សធម៌ផ្សេងទៀត ... 732
អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ [អ.វ.ត.ក មាត្រា៦] ... 734
លក្ខខណ្ឌទូទៅ ... 735
ជម្លោះប្រដាប់អាវុធជាអន្តរជាតិ ... 735
ជនដែលទទួលការការពារ ... 737
ការដឹងអំពីកាលៈទេសៈជាក់ស្តែង ... 738
បទល្មើសជាក់លាក់ ... 739
ការធ្វើមនុស្សឃាតដោយចេតនា ... 739
ការធ្វើទារុណកម្ម ... 739
ការធ្វើបាបដោយអមនុស្សធម៌ ... 739
ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ... 740
ការដកហូតនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយ យុត្តិធម៌ និង ទៀងទាត់ ... 740
ការនិរទេស ឬការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ... 741
ការនិរទេស ឬការជម្លៀសដោយខុសច្បាប់ ... 741
ការឃុំខ្លួនដោយខុសច្បាប់ ... 742
ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ [អ.វ.ត.ក មាត្រា៣] ... 744
បទល្មើសជាក់លាក់ ... 744
មនុស្សឃាត ... 744
ទារុណកម្ម ... 745
ការប្រឆាំងនឹងសាសនា ... 746
ខ- ការទទួលខុសត្រូវជាបុគ្គល ... 747
យុត្តាធិការទៅលើមនុស្ស [អ.វ.ត.ក មាត្រា២] ... 747
ទម្រង់នៃការទទួលខុសត្រូវ ... 748
មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ... 748
បានប្រព្រឹត្ត ... 748
ការប្រព្រឹត្តិ ឬការខកខានស្តែង ... 748

សហកម្មឧក្រិដ្ឋកម្មរួម ........ 749
បានធ្វើផែនការ ........ 756
បានញុះញង់ ........ 759
បានចេញបញ្ជា ........ 762
ការជួយ និងជម្រុញ ........ 765
ការទទួលខុសត្រូវរបស់ ថ្នាក់លើ ........ 771
ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ [ច្បាប់ អ.វ.ត.ក មាត្រា៣] ........ 775
ការចូលរួមដោយផ្ទាល់ ........ 775
ការរួមប្រព្រឹត្តិដោយប្រយោល ........ 775
VI. ការកំណត់បទល្មើស ........ 776
ក- បទឧក្រិដ្ឋ ........ 776
អំពើប្រល័យពូជសាសន៍ ........ 776
អំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ........ 777
អំពើ ........ 778
ការសម្លាប់សមាជិកនៅក្នុងក្រុមនេះ ........ 778
ចេតនា ........ 781
អំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាម ........ 784
អំពើ ........ 784
ការសម្លាប់សមាជិកនៅក្នុងក្រុមនេះ ........ 784
ចេតនា ........ 786
ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ........ 788
យុត្តាធិការ ........ 789
ការវាយប្រហារ ........ 789
ជាទូទៅ ឬ ជាប្រព័ន្ធ ........ 789
សំដៅទៅលើប្រជាជនស៊ីវិល ........ 791
មូលហេតុនៃការរើសអើង ........ 792
មូលហេតុនយោបាយ ........ 792
មូលហេតុសាសនា និង ជាតិពន្ធុ ........ 795

ការដឹងឮអំពីការវាយប្រហារ ... 795
បទឧក្រិដ្ឋជាក់លាក់ ... 796
ការធ្វើមនុស្សឃាត ... 796
អំពើសកម្ម និងអំពើអកម្ម ... 796
ចេតនា ... 804
ការសម្លាប់រង្គាល ... 806
អំពើសកម្ម និង អំពើអកម្ម ... 806
ចេតនា ... 808
ការធ្វើឲ្យទៅជាទាសករ ... 809
អំពើសកម្ម និងអំពើអកម្ម ... 810
ចេតនា ... 812
ការឃុំខ្លួន ... 813
អំពើសកម្ម និងអំពើអកម្ម ... 813
ចេតនា ... 819
ការធ្វើទារុណកម្ម ... 819
អំពើសកម្ម ... 820
គោលបំណង ... 823
ការរំលោភផ្លូវភេទ ... 825
អំពើសកម្ម និងអំពើអកម្ម ... 825
ចេតនា ... 828
ការធ្វើទុក្ខបុកម្នេញ ... 829
ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ... 829
ការធ្វើទុក្ខបុកម្នេញសាសនា ... 832
ការធ្វើទុក្ខបុកម្នេញទៅលើជាតិពន្ធុ ... 834
អំពើអមនុស្សធម៌ផ្សេងៗទៀត ... 836
អំពើសកម្ម និងអំពីអកម្ម ... 836
ចេតនា ... 848
ការបំពារបំពានផ្ទាល់ធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ... 848

យុត្តាធិការ ........ 849
ជម្លោះប្រដាប់អាវុធអន្តរជាតិ ........ 849
ជនដែលត្រូវទទួលបានការការពារ ........ 851
ការដឹងឮអំពីជម្លោះប្រដាប់អាវុធ ........ 852
បទល្មើសជាក់លាក់មួយចំនួន ........ 853
ការសម្លាប់ដោយចេតនា ........ 853
អំពើសកម្ម និង អំពើអកម្ម ........ 853
ចេតនា ........ 855
ការធ្វើទារុណកម្ម ........ 855
អំពើ ........ 855
ចេតនា ........ 855
គោលបំណង ........ 856
ស្ថានភាពអមនុស្សធម៌ ........ 856
អំពើ និងការខកខាន ........ 856
ចេតនា ........ 857
ការបង្កឱ្យមានទុក្ខវេទនា ឬរបួសធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព ........ 857
ការដកហូតដោយចេតនានូវការកាត់សេចក្ដីដោយយុត្តិធម៌ និងទៀងទាត់ ........ 858
អំពើ និងការខកខាន ........ 858
ចេតនា ........ 859
ការជម្លៀស ឬការបង្ខាំងប្រជាជនស៊ីវិលដោយខុសច្បាប់ ........ 859
អំពើសកម្ម និងអកម្ម ........ 859
ចេតនា ........ 860
ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ........ 860
អំពើមនុស្សឃាត ........ 861
អំពើមនុស្សឃាតថ្នាក់ទី៣ ........ 861
អំពើសកម្ម និងអកម្ម ........ 861
អំពើមនុស្សឃាតថ្នាក់ទី២ ........ 862
អំពើសកម្ម និងអកម្ម ........ 862

ចេតនា ........ 863

អំពើមនុស្សឃាតថ្នាក់ទី១ ........ 863

អំពើ និងការខកខាន ........ 863

ចេតនា ........ 864

ការធ្វើទារុណកម្ម ........ 864

អំពើសកម្ម និងអំពើអកម្ម ........ 865

ចេតនា ........ 865

គោលបំណង ........ 865

ខ-ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ........ 867

នួន ជា ........ 867

សេចក្តីសង្ខេប ........ 867

ទម្រង់នៃការទទួលខុសត្រូវ ........ 868

ការប្រព្រឹត្តិតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ........ 868

សហកម្មឧក្រិដ្ឋកម្មរួម ១ (មូលដ្ឋាន) ........ 868

សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ) ........ 876

ការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជម្រុញ ........ 877

សេចក្តីផ្តើម ........ 877

ការធ្វើផែនការ ........ 877

ការញុះញង់ ........ 880

ការបញ្ជា ........ 881

ការជួយ និងជម្រុញ ........ 884

តាមរយៈការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ........ 886

ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់ ........ 887

ការដឹងឮ ........ 888

ការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្ម ........ 889

អៀង សារី ........ 890

សេចក្តីសង្ខេប ........ 890

ទម្រង់នៃការទទួលខុសត្រូវ ........ 890

តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ..... 890
សហកម្មឧក្រិដ្ឋកម្មរួម ១ (មូលដ្ឋាន) ..... 890
សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ) ..... 895
តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា ..... 895
និងការជួយជ្រោមជ្រែង ព្រមទាំងការជួយជម្រុញ ..... 895
សេចក្ដីផ្ដើម ..... 895
ការរៀបចំផែនការ ..... 896
ការញុះញង់ ..... 898
ការបញ្ជា ..... 899
ការជួយជ្រោមជ្រែង និងការជួយជម្រុញ ..... 901
តាមរយៈការទទួលខុសត្រូវក្នុងនាមថ្នាក់ដឹកនាំ ..... 902
ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់ ..... 903
ការដឹងឮ ..... 904
ការខកខានមិនបានរារាំង ឬដាក់ទណ្ឌកម្ម ..... 905
ខៀវ សំផន ..... 906
សេចក្ដីសង្ខេប ..... 906
ទម្រង់នៃការទទួលខុសត្រូវ ..... 906
តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ..... 906
សហកម្មឧក្រិដ្ឋកម្មរួម ១ (មូលដ្ឋាន) ..... 906
សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ) ..... 911
តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយជ្រោមជ្រែង
ព្រមទាំងការជួយជម្រុញ ..... 911
សេចក្ដីផ្ដើម ..... 911
ការរៀបចំផែនការ ..... 912
ការញុះញង់ ..... 914
ការបញ្ជា ..... 915
ការជួយ និងការជម្រុញ ..... 918
ការទទួលខុសត្រូវក្នុងនាមថ្នាក់ដឹកនាំ ..... 920

ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ ........ 920
ការដឹងឮ ........ 922
ការខកខានមិនបានរារាំង ឬដាក់ទណ្ឌកម្ម........ 923
អៀង ធីរិទ្ធ........ 923
សេចក្តីសង្ខេប........ 923
ទម្រង់នៃការទទួលខុសត្រូវ ........ 924
ការប្រព្រឹត្តិតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម........ 924
សហកម្មឧក្រិដ្ឋកម្មរួម ១(មូលដ្ឋាន)........ 924
ការរួមចំណែក........ 924
ចេតនា ........ 927
សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ)........ 928
តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងជម្រុញ ........ 928
សេចក្តីផ្តើម ........ 928
ការរៀបចំផែនការ ........ 929
ការញុះញង់........ 930
ការបញ្ជា........ 931
ការជួយ និងជម្រុញ........ 933
ការទទួលខុសត្រូវក្នុងនាមថ្នាក់លើ........ 934
ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់ ........ 935
ការដឹងឮ ........ 936
ការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្ម........ 937
VII. បទចោទ ........ 937
ឧបសម្ព័ន្ធ ៥: សទ្ទានុក្រម........ 941

# I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន៦៦.៥ នៃវិធានផ្ទៃក្នុង ("វិធាន") និងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ពិចារណាឃើញថា កិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ:00២/១៩-0៩-២០០៧/អវតក-កសចស បានបញ្ចប់ហើយ ។ អាស្រ័យហេតុនេះសហព្រះរាជអាជ្ញា ដាក់ជូនដីកាសន្និដ្ឋានស្ថាពរ("ដីកាសន្និដ្ឋាន") និងបង្វិលសំណុំរឿងទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញ។ នៅក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាស្នើឲ្យសហចៅក្រមស៊ើបអង្កេត ចោទប្រកាន់ជនត្រូវចោទឈ្មោះ **នួន ជា** **អៀង សារី** **ខៀវ សំផន** និង **អៀង ធីរិទ្ធ** និងបញ្ជូនពួកគេទៅជំនុំជម្រះ ទៅតាមអង្គហេតុ បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវនានា ដូចដែលបានកំណត់ក្នុងដីកាសន្និដ្ឋាននេះ ។

២- លើសពីនេះ សហព្រះរាជាអាជ្ញា សូមស្នើឲ្យសហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ **កាំង ហ្កេកអ៊ាវ** *ហៅ* **ឌុច** ។ មូលហេតុគឺបានគូសបញ្ជាក់យ៉ាងល្អិតល្អន់ នៅក្នុងដីកាសន្និដ្ឋានដែលបានដាក់ជូនដាច់ដោយឡែកមួយ ដែលបង្កើតបានជាផ្នែកសំខាន់មួយនៃ ដីកាសន្និដ្ឋានបច្ចុប្បន្ននេះដែលមានចំណងជើងថា **ដីកាសន្និដ្ឋានបន្ថែមស្តីពី ឌុច**។

៣- ដីកាសន្និដ្ឋាននេះមានចំនួនប្រាំពីរ(០៧)ជំពូក។ ដូចជាកញ្ចក់មួយនៃលក្ខខណ្ឌតម្រូវនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដូចដែលបានរៀបរាប់នៅក្នុងវិធាន៦៧.២ នៃវិធានផ្ទៃក្នុងដូច្នេះដែរជំពូក ដំបូងៗនៃដីកាសន្និដ្ឋាននេះមានដូចតទៅ៖ **អង្គហេតុសំខាន់ៗ ច្បាប់ ការកំណត់បទល្មើស**

និង**បទចោទ**។ បញ្ហាដំបូងៗជាក់លាក់មួយចំនួន គឺមានដាក់ទៅក្នុងជំពូកស្តីពី**ប្រវត្តិនៃដំណើរការនីតិវិធី** និងសេចក្តីសង្ខេបខ្លឹមសារខ្លីមួយស្តីពីការយល់ឃើញរបស់សហព្រះរាជអាជ្ញា ទៅលើសំណុំរឿង អាចត្រូវបានរកឃើញនៅក្នុងជំពូកដែលមានចំណងជើងថា **ទិដ្ឋភាពរួមនៃសំណុំរឿង**។ ជំពូកនានានៃដីកាសន្និដ្ឋាននេះ គឺត្រូវបានបំពេញបន្ថែមដោយ**ឧបសម្ព័ន្ធ**នានា ដែលមាន**សទ្ទានុក្រម**មួយ ហើយនិងប្រភពភស្តុតាងនានា ដែលគាំទ្រអង្គហេតុសំខាន់ៗទាំងនោះ(កំណត់សម្គាល់ជើងទំព័រ) ក៏ដូចជាដីកាសន្និដ្ឋានបន្ថែមស្តីពី ឌុច ដូចដែលបានពោលនៅខាងដើមផងដែរ។

៤- ប្រភពភស្តុតាងគាំទ្រអង្គហេតុជាក់ស្តែងនានាដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះ ត្រូវបានធ្វើឡើងដោយផ្អែកលើឯកសារនានាដែលមាននៅក្នុងសំណុំរឿង។ ប៉ុន្តែប្រសិនបើ សហព្រះរាជអាជ្ញាបានយោងឯកសារដែលគេអាចរកបានជាសាធារណៈ តែមិនមាននៅក្នុងសំណុំរឿង (ដាក់សញ្ញាសំគាល់ “NCFPD”) ដូចជា សៀវភៅ ឬរបាយការណ៍សារព័ត៌មានផ្សេងៗ (មិនធ្លាប់បានច្រានចោលពីមុននោះទេ) ដែលបានធ្វើឡើងទៅតាមការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលថា “សៀវភៅ គឺជាឯកសារសាធារណៈ ការដាក់នៅក្នុងសំណុំរឿង គឺមិនចាំបាច់ដាច់ខាតទេ” ។ ហេតុដូចនេះ គូភាគីនានាអាចយោងទៅលើឯកសារសាធារណៈណាមួយដែលមិនមាននៅក្នុងសំណុំរឿង “ពេលណាក៏បានតាមចិត្តចង់” ។

៥- សហព្រះរាជអាជ្ញា ក៏បានយោងទៅដល់ឯកសារអសាធារណៈមួយចំនួនផងដែរ ដែលពីពេលមុនពុំទាន់បានដាក់ចូលទៅក្នុងសំណុំរឿង (មាន “NCF” ជាសម្គាល់)។ ពេលឥឡូវ គេត្រូវពឹងផ្អែកលើឯកសារទាំងនេះ ក្នុងគោលបំណងដើម្បីផ្តល់ជាសេចក្តីជូនដំណឹងឲ្យបានទាន់ពេលវេលាជាមុនដល់ភាគីនានា ដែលសហព្រះរាជអាជ្ញានឹងស្វែងរកនូវការអនុញ្ញាតពីអង្គជំនុំជម្រះ

សាលាដំបូង ដើម្បីដាក់ឯកសារទាំងនេះចូលទៅក្នុងសំណុំរឿង និងបង្ហាញជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះនោះ។ ក្នុងការពឹងផ្អែកលើឯកសារទាំងនេះ សហព្រះរាជអាជ្ញា នឹងយកចិត្តទុកដាក់ស្តាប់ តាមអង្គហេតុដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេច និងអង្គបុរេជំនុំជម្រះបានយល់ព្រម អង្គជំនុំជម្រះសាលាដំបូងមិនត្រូវបានភ្ជាប់កាតព្វកិច្ចដោយសារតែសេចក្តីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះទេ។ សហព្រះរាជអាជ្ញាក៏យល់ឃើញផងដែរថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលថាសិទ្ធិនានារបស់ភាគីណាមួយ ក្នុងការទទួលបានមកនូវភស្តុតាងត្រូវបាន"រក្សាទុក" មុនពេលដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ អះអាងពីសិទ្ធិរបស់ពួកគេក្នុងការស្វែងរកនូវការអនុញ្ញាតនេះ។ ឯកសាររបស់ NCF និង NCFPD បានធ្វើជាតារាងដាក់បញ្ចូលនៅក្នុងឧបសម្ពន្ធទី៧ សម្រាប់សម្រួលដល់ឯកសារយោង និងដើម្បីផ្តល់ដំណឹងគ្រប់គ្រាន់ដល់ភាគីផ្សេងៗ។

# II សេចក្តីសង្ខេបរឿងក្តី

៦- ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ រួមជាមួយនឹងមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក)ផ្សេងៗទៀត បានប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈផែនការឧក្រិដ្ឋមួយ ដែលបានប៉ះពាល់ជីវិតពលរដ្ឋកម្ពុជាគ្រប់រូបនៅទូទាំងប្រទេស។ ចាប់តាំងពីថ្ងៃដំបូងដែល ប.ក.ក ចូលគ្រប់គ្រងប្រទេស ប្រជាជនបីលាននាក់ ដែលរស់នៅក្នុងទីក្រុងភ្នំពេញ និងតាមទីប្រជុំជននានា ត្រូវបានគេជម្លៀសចេញពីផ្ទះសម្បែងរបស់ខ្លួន និងបណ្តើរដោយបង្ខំចេញទៅតាមទីជនបទជាទីកន្លែងប្រជាជនទាំងអស់ ត្រូវបានបង្ខំងឱ្យធ្វើការងារកសិកម្មនៅក្នុងសហករណ៍ និងការដ្ឋានផ្សេងៗទៀត។

៧- ជនត្រូវចោទ និង ប.ក.ក បានបន្តបង្កើតសង្គមថ្មីមួយ ដែលបានប្រែក្លាយប្រជាពលរដ្ឋកម្ពុជាឱ្យទៅជាទាសករ បានអនុវត្តការគ្រប់គ្រងទាំងស្រុងលើជីវិតប្រជាពលរដ្ឋកម្ពុជា និងបានដកហូតស្ទើរគ្រប់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់ប្រជាពលរដ្ឋ។ ទ្រព្យសម្បត្តិឯកជនត្រូវបានរឹបអូស រូបិយវត្ថុត្រូវបានលុបបំបាត់ចោល ទីផ្សារ អាជីវកម្ម សាលារៀន និងវត្តអារាមត្រូវបានបិទទ្វារ។ ប្រជាពលរដ្ឋកម្ពុជាលែងត្រូវបានអនុញ្ញាតឱ្យរួមរស់ជាមួយនឹងគ្រួសារនៅក្នុងផ្ទះសម្បែង ឬគោរពសាសនារបស់ខ្លួនទៀតឡើយ ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមគោលនយោបាយនៃការគាបសង្កត់ផ្លូវភេទដែលពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការបង្ខំឱ្យមានផ្ទៃពោះ។ ប្រជាពលរដ្ឋកម្ពុជាមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីប្រទេស ឬដើរហើរនៅក្នុងប្រទេស ហើយបានទទួលរងនូវការបំពានផ្លូវចិត្ត តាមរយៈការបំពាក់បំប៉ន ការទិតៀន និងស្វ័យទិតៀន ដែលគេអនុវត្តក្រោមការគម្រាមកំហែងដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។ ប.ក.ក បានបង្កើតរដ្ឋមួយ គឺរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលពុំមានសភា ឬប្រព័ន្ធតុលាការដំណើរការ និងជារដ្ឋមួយដែល ប.ក.ក បានអនុវត្តការគ្រប់គ្រងដោយគ្មានក្តីមេត្តា។

៨- ក្នុងអំឡុងពេលជម្លៀសលើកដំបូង កងកម្លាំងរបស់ ប.ក.ក បានពិនិត្យមើលអ្នកដែលត្រូវបានគេជម្លៀស ហើយបំបែកប្រជាជន ដែលបក្សបានកំណត់មុខសញ្ញាចេញជាក្រុម ដូចជាក្រុមមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានផ្តួលរំលំ និងក្រុម “ខ្មាំងវណ្ណៈ” របស់បក្ស គឺពួកនាយទុន ពួកសក្តិភូមិ និងពួកអនុធន។ ក្រុមទាំងនេះត្រូវបានសម្លាប់ចោលដោយ មិនទទួលបានការជំនុំជម្រះ ហើយអ្នកដែលត្រូវបានជម្លៀសដែលនៅសល់ (ដោយកំណត់ថាជា “ប្រជាជនថ្មី”) ត្រូវបានគេដាក់ឱ្យទៅជាទាសករនៅក្នុងសហករណ៍ជាមួយនឹងប្រជាជនមូលដ្ឋាន និងក្រោយមកនៅតាមគម្រោងជីកប្រឡាយធំៗ និងគម្រោងកសាងហេដ្ឋារចនាសម្ពន្ធនៅក្នុង របបនេះ។ ក្នុងពេលដែលត្រូវបានគេដាក់ឱ្យទៅជាទាសករ ប្រជាពលរដ្ឋកម្ពុជាបានទទួលរង ស្ថានភាពអមនុស្សធម៌ ដោយរួមមាន ពលកម្មបាក់កម្លាំង ការបដិសេធមិនឱ្យមានការសម្រាក ការមិនផ្តល់អាហារគ្រប់គ្រាន់ ការមិនផ្តល់ការថែទាំសុខភាពគ្រប់គ្រាន់ ការមិនផ្តល់ជម្រកសមរម្យ និងការរំលោភផ្លូវកាយ និងផ្លូវចិត្ត។ អ្នកដែលត្រូវបានចោទប្រកាន់ថាមិនគោរពតាម មិនថាប្រភេទ ណាក៏ដោយ បានទទួងរងទណ្ឌកម្មធ្ងន់ធ្ងរ

រួមមាន ការធ្វើឱ្យស្ថានភាពការងារកាន់តែធ្ងន់ធ្ងរឡើង ការវាយដំ ការដកហូតរបបអាហារ ការលត់ដំខ្លួន ការចាប់ខ្លួន ការរងទារុណកម្ម និងការសម្លាប់ចោល។

៩- នៅសរទរដូវ ក្នុងឆ្នាំ១៩៧៥ យោងតាមសេចក្តីសម្រេចរបស់មេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក យ៉ាងហោចណាស់ ប្រជាពលរដ្ឋកម្ពុជា៥០០០០០នាក់ ដែលភាគច្រើនជាប្រជាជនថ្មីត្រូវបានដកចេញ និងជម្លៀសដោយបង្ខំម្តងទៀតទៅភូមិភាគពាយ័ព្យ និងតំបន់ដទៃទៀត។ នៅពេលជម្លៀសទៅតាមទីប្រជុំជនលើកដំបូង មេដឹកនាំ ប.ក.ក ខកខានមិនបានផ្តល់ម្ហូបអាហារគ្រប់គ្រាន់សម្រាប់អ្នកដែលត្រូវបានជម្លៀសរាប់ម៉ឺននាក់ ហើយដាក់ពួកគេឱ្យទទួលរងស្ថានភាពអមនុស្សធម៌ក្រៃលែង ដែលបណ្តាលឱ្យមានការស្លាប់ជាច្រើនដោយសារការអត់អាហារ ការបាក់កម្លាំង ការខ្វះការថែទាំសុខភាព និងការដាក់ឱ្យនៅហាលខ្យល់ហាលភ្លៀង។

១០- នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ប.ក.ក បានបង្កើត និងដំណើរការជំរំអប់រំកែប្រែ និងមន្ទីរសន្តិសុខជាង២៦០កន្លែង ដែលបង្កើតជាយន្តការដ៏សំខាន់នៃផែនការឧក្រិដ្ឋរបស់បក្សក្នុងការកំណត់ បង្ក្រាប និងកម្ទេច "ខ្មាំង" នៃរបបនេះ។ ខ្មាំងទាំងនេះ រួមមានបុគ្គលទាំងឡាយដែលមានជាប់ប្រវត្តិសង្ស័យ និងបុគ្គលទាំងឡាយដែលបក្សមើលឃើញថាមិនស្មោះត្រង់។ "ខ្មាំង" សំខាន់ៗត្រូវបានកំណត់តាមមធ្យោបាយពីរជាចម្បង។ ប្រជាជនដែលរស់នៅក្នុងសហករណ៍ ឬការដ្ឋាន ត្រូវបាន ប.ក.ក តាមដានយ៉ាងស្អិត តាមរយៈការធ្វើប្រវត្តិរូប និង "វគ្គទិតៀន" ប្រចាំថ្ងៃ។ បន្ថែមពីនេះ បុគ្គលដែលត្រូវបានយកទៅមន្ទីរសន្តិសុខ ត្រូវបានសួរចម្លើយដោយប្រើទារុណកម្មដើម្បីទាញយកចម្លើយសារភាពលម្អិត ដែលចោទប្រកាន់អ្នកផ្សេងថាជា "ខ្សែ" ខ្មាំង។ ប្រជាពលរដ្ឋរាប់ម៉ឺននាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់ចោលដោយខុសច្បាប់ នៅតាមមន្ទីរសន្តិសុខទាំងនេះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

១១- នៅក្នុងអំឡុងពេលនៃរបបនេះ មេដឹកនាំរបស់ ប.ក.ក ចាប់ផ្តើមជឿថា ខ្មាំង និងជនក្បត់ផ្ទៃក្នុងកំពុងបំផ្លាញលើរបបគ្រប់គ្រងរបស់បក្ស ហេតុដូច្នេះហើយ ទើបបញ្ជា និងបើកឱ្យមានការបោសសម្អាតក្នុងទ្រង់ទ្រាយធំនៅក្នុងជួរបក្ស។ ចាប់ពីដើមឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៨ ការបោសសម្អាតក្នុងទ្រង់ទ្រាយធំ បានធ្វើឡើងនៅទូទាំងប្រទេសនៅស្ទើរតែគ្រប់អង្គភាពរដ្ឋបាល និងយោធា។ ការបោសសម្អាតដែលមានទ្រង់ទ្រាយធំបំផុត គឺការបោស

សម្អាតភូមិភាគបូព៌ា ដែលប្រជាជននៃភូមិភាគនេះត្រូវបានសង្ស័យថាស្មោះស្ម័គ្រនឹងវៀតណាម និងមិនស្មោះត្រង់។ បន្ថែមលើការបោសសម្អាតកម្មាភិបាលភាគច្រើនរបស់ ប.ក.ក នៅក្នុងភូមិភាគបូព៌ានោះ មេដឹកនាំ ប.ក.ក បានបង្គាប់ឱ្យមានការសម្លាប់ប្រជាជនមូលដ្ឋានជាទាំងក្រុមៗ ហើយឱ្យជម្លៀសប្រជាជនដែលនៅសល់ ទៅតំបន់ដទៃទៀតដោយបង្ខំ។ នៅថ្ងៃចុងក្រោយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនភូមិភាគបូព៌ាដែលត្រូវបានជម្លៀសភាគច្រើន ត្រូវបានឡោមព័ទ្ធ ហើយសម្លាប់ចោល *ទាំងក្រុមៗ*។

១២- ប.ក.ក ក៏បានកំណត់មុខសញ្ញាប្រជាជនភាគតិចនៅក្នុងផែនការឧក្រិដ្ឋរបស់ខ្លួន។ ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ យ៉ាងហោចណាស់មានជនជាតិវៀតណាមចំនួន១៥០០០០នាក់ត្រូវបានគេបញ្ជូនចេញ ខណៈពេលដែលភូមិចាមនានាត្រូវបានបំផ្លិចបំផ្លាញ ហើយភាសានិងការគោរពសាសនាអ៊ីស្លាម ត្រូវបានហាមឃាត់។ ចាប់តាំងពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ មេដឹកនាំ ប.ក.ក បានទទួលខុសត្រូវលើយុទ្ធនាការប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងជនជាតិចាម ដោយតាមរយៈយុទ្ធនាការនេះ ក្រុមជនជាតិទាំងនេះត្រូវបានកំណត់មុខសញ្ញាថាឱ្យកម្ទេចចោល។ នៅទីកន្លែងសំខាន់ៗរបស់សហគមន៍ចាមក្នុងខេត្តកំពង់ចាម ប្រជាជនចាមដែលនៅសល់ទាំងអស់ត្រូវបានកម្មាភិបាល ប.ក.ក ដាក់បញ្ចូលក្នុងបញ្ជី ឬកំណត់អត្តសញ្ញាណជាលក្ខណៈប្រព័ន្ធ ដើម្បីប្រមូលចេញពីផ្ទះនៅតាមមូលដ្ឋានរបស់ពួកគេ យកទៅសម្លាប់ចោលទាំងក្រុមៗ នៅតាមមន្ទីរសន្តិសុខ និងការដ្ឋានដទៃទៀត។

១៣- គ្រប់ជាតិពន្ធុវៀតណាមទាំងអស់ និងបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងជាមួយវៀតណាម ដូចជាខ្មែរក្រោមជាដើម គឺជាគោលដៅនៃការសម្លាប់។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានបញ្ជា និងអនុម័តឱ្យប្រព្រឹត្តបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប្រឆាំងនឹងឈ្លើយសឹកវៀតណាម និងប្រជាជនស៊ីវិលវៀតណាមដែលត្រូវបានចាប់ខ្លួននៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ដែលកើតឡើងតាំងពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

១៤- បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនកម្ពុជាក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គឺមានទំហំគួរឱ្យរន្ធត់។ ប្រជាជនចំនួន១,៧ រហូតដល់២,២លាននាក់ បានស្លាប់ដោយសារតែ

គោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលនោះ។ ចំនួនពាក់កណ្តាលនៃជនរងគ្រោះ ត្រូវបានសម្លាប់ដោយការវាយប្រហារយ៉ាងឃោរឃៅ។ ទីកន្លែងដែលជាប្រពៃណីរបស់ជនជាតិខ្មែរ ដូចជាគ្រួសារ ភូមិ និងវត្តអារាម ត្រូវបានបំផ្លិចបំផ្លាញដោយបក្សកុម្មុយនីស្តកម្ពុជា។ ជនជាតិវៀតណាមជាច្រើន ត្រូវបានសម្លាប់ ខណៈពេលដែលប្រជាជនវៀតណាមស្ទើរតែទាំងមូល ត្រូវបានជម្លៀសចេញ ឬត្រូវបានសម្លាប់ចោល។ សហគមន៍ខ្មែរក្រោមត្រូវបានចាប់ខ្លួនជាទ្រង់ទ្រាយធំ និងត្រូវបានសម្លាប់ចោល។

១៥- នៅក្នុងក្របខ័ណ្ឌនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបន្តបន្ទាប់ដែលត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា បានកំណត់អត្តសញ្ញាណព្រឹត្តិហេតុឧក្រិដ្ឋដែលសង្ស័យ និងកន្លែងឧក្រិដ្ឋជាច្រើន ដែលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតរបស់តុលាការ។ ការវិភាគភ័ស្តុតាង បានបង្ហាញនៅក្នុងផ្នែកភ័ស្តុតាងជាក់ស្តែងនៃដីកាសន្និដ្ឋាននេះ ដូចមាននៅក្នុងផ្នែកដូចតទៅៈ (i) ការជម្លៀសដោយបង្ខំ (ដែលរួមបញ្ចូលទាំងការជម្លៀសចេញពីទីក្រុងភ្នំពេញ និងទីក្រុងផ្សេងទៀតនៅខែមេសា ឆ្នាំ១៩៧៥ ការសម្លាប់មន្ត្រី និងទាហានរបស់សាធារណរដ្ឋខ្មែរ ដែលប្រព្រឹត្តឡើងក្នុងអំឡុង និងភ្លាមៗបន្ទាប់ពីការជម្លៀសទាំងនោះ និងការជម្លៀសដោយបង្ខំក្នុងទ្រង់ទ្រាយធំទៅកាន់ភូមិភាគពាយ័ព្យ) (ii) ការធ្វើពលកម្មដោយបង្ខំ (ដែលរួមបញ្ចូលកន្លែងធំៗចំនួនប្រាំ) (iii) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (iv) មន្ទីរសន្តិសុខ (ដែលរួមបញ្ចូលមន្ទីរសន្តិសុខចំនួន១១ និងកន្លែងឧក្រិដ្ឋបន្ថែមជាច្រើនដែលវណបជាមួយមន្ទីរទាំងនោះ) (v) ការបោសសម្អាតភូមិភាគឧត្តរ (vi) ការបោសសម្អាតភូមិភាគបូព៌ា (ដែលរួមមានការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា ការសម្លៀសភូមិភាគបូព៌ា និងការសម្លាប់អ្នកត្រូវបានគេជម្លៀសនៅក្នុងទ្រង់ទ្រាយធំ) (vii) ឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនិក (viii) ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម និង (ix) ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម។ ឧក្រិដ្ឋកម្មទាំងនេះដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើមនុស្សឃាត និងអំពើទារុណកម្មផ្អែកតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ បន្ថែមលើភ័ស្តុតាងជាច្រើនដែលមាននៅក្នុងសំណុំរឿង ការរងទុក្ខវេទនារបស់ប្រជាជន

កម្ពុជាទូទាំងប្រទេស ត្រូវបានបញ្ជាក់ដោយពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងចំនួនជាង៨០០០ ដែលដាក់ជូនតុលាការ។

១៦- ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានរៀបចំជាប្រព័ន្ធ ដោយមានការចាត់តាំងពីថ្នាក់មជ្ឈិម និងការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាព។ ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃគោល នយោបាយដាក់ឲ្យទៅជាទាសករទាំងស្រុង ការលុបបំបាត់សិទ្ធិមនុស្ស និងសិទ្ធិសេរីភាពជាមូលដ្ឋាន និងការកំចាត់ខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា។ គោលនយោបាយទាំងនេះ មិនមែនជាគោលនយោបាយថ្មីនោះទេ។ គោលនយោបាយទាំងនេះមានដើមកំណើតពីមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ដែលមានមុនកម្ពុជាប្រជាធិបតេយ្យ និងអនុលោមតាមការរំលោភបំពានស្រដៀងគ្នា ដែលត្រូវបានប្រព្រឹត្តឡើងដោយសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ដែលផ្នែកមួយចំនួននៃប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយបក្សមុនខែមេសា ឆ្នាំ១៩៧៥។

១៧- ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងសមាជិកអចិន្ត្រៃយ៍ជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ជនត្រូវចោទ នួន ជា (អនុលេខាបក្សកុម្មុយនីស្តកម្ពុជា) អៀង សារី (ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស) ខៀវ សំផន (ប្រមុខរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ) និង អៀង ធីរិទ្ធ (រដ្ឋមន្ត្រីនៃក្រសួងសង្គមកិច្ច) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើត ការអនុវត្ត និងការថែរក្សាគោលនយោបាយឧក្រិដ្ឋទាំងនេះ។ ជនត្រូវចោទទាំងបួនរូបនេះ គឺជាក្រុមនៃបុគ្គលជួរមុខបក្សដែលមានសិទ្ធិអំណាចខ្លាំងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

១៨- ពេញរយៈកាលកម្ពុជាប្រជាធិបតេយ្យ ជនត្រូវចោទនានានៅតែប្តេជ្ញានឹងគោលនយោបាយឧក្រិដ្ឋរបស់បក្ស ចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយទាំងនេះ និងបានដឹងយ៉ាងច្បាស់អំពីឧក្រិដ្ឋកម្មនានាដែលខ្លួនបានប្រព្រឹត្ត។ ជនត្រូវចោទទាំងនេះ បានចូលរួមនៅក្នុងកិច្ចប្រជុំដែលសកម្មភាពឧក្រិដ្ឋនានាត្រូវបានរៀបចំ បានគ្រប់គ្រងលើកម្មាភិបាលដែលពាក់ព័ន្ធនឹងអំពីឧក្រិដ្ឋកម្មនានា និងបានបំពាក់បំប៉នគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដល់កម្មាភិបាលទាំងនោះ។ ជនត្រូវចោទបានចុះទៅពិនិត្យកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មនានា និងបានទំនាក់ទំនងជាមួយចារីផ្ទាល់នានា ដោយថែមទាំងលើកទឹកចិត្ត និងបានផ្តល់ភាពស្របច្បាប់

ចំពោះសកម្មភាពរបស់ចារីទាំងនោះទេ។ ជនត្រូវចោទបានពង្រឹងការអនុវត្តផែនការឧក្រិដ្ឋ តាមរយៈការរៀបចំ ការគ្រប់គ្រង និង/ឬការយល់ព្រមឱ្យមានការចាប់ខ្លួន និងការសម្លាប់ជនដែលប្រឆាំង ដែលរួមមាន សមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលគេសង្ស័យថាប្រឆាំងនឹងបទបញ្ជារបស់បក្ស។ ចំពោះការងារជាអ្នកតំណាងរបស់ប្រទេសនានា ព្រមទាំងភ្នាក់ងារអន្តរជាតិផ្សេងៗ ជនត្រូវចោទបានបដិសេធអំពីអត្ថិភាពនៃឧក្រិដ្ឋកម្ម និងស្វែងរកការការពារចំពោះសកម្មភាព និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្រោយពីជនត្រូវចោទទាំងនេះបានចេញពីអំណាច ជនត្រូវចោទបានស្វែងរកវិធីផ្សេងៗ ដើម្បីបង្ខូចរបាយការណ៍ស្តីពីឧក្រិដ្ឋកម្ម បានចោទប្រកាន់ប្រទេសវៀតណាមថាបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ និងបានស្វែងរកការកាត់បន្ថយជាអប្បបមាចំពោះការពាក់ព័ន្ធផ្ទាល់ខ្លួន។

១៩- ជនត្រូវចោទទាំង៤រូបនេះ ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសនានា ដែលបានស៊ើបអង្កេត ហើយជនត្រូវចោទទាំង៤រូបនេះ ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ដូចការស្នើសុំនៅក្នុងដីកាសន្និដ្ឋាននេះ។

# III. ប្រវត្តិនីតិវិធី

## ការបើកកិច្ចស៊ើបសួរ

២០- នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ អនុលោមតាមវិធាន៥០ សហព្រះរាជអាជ្ញា បានចាប់ផ្តើមកិច្ចស៊ើបសួរបឋម ដោយមានគោលបំណងដើម្បីកំណត់ថាតើ ភស្តុតាងដែលបានចង្អុលបង្ហាញថាបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្ត ឬយ៉ាងណា និងដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីសំខាន់ៗ។

២១- នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ដោយបានរកឃើញថា មានហេតុផលនាំឱ្យជឿជាក់ថា បទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្ត សហព្រះរាជអាជ្ញាបានបើក

កិច្ចស៊ើបសួរនេះ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅសហចៅក្រមស៊ើបអង្កេត។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតទៅលើអង្គហេតុមួយចំនួន និងបទឧក្រិដ្ឋទាំងឡាយ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តក្នុងអំឡុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ និងដើម្បីចាប់ខ្លួន និងឃុំខ្លួនបណ្ដោះអាសន្ន លើ នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និង ឌុច។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រួមមានសេចក្ដីសង្ខេបនៃ អង្គហេតុ ប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់ បទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធដែលបានចែង និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋ និងឈ្មោះរបស់បុគ្គលដែលត្រូវស៊ើបអង្កេត។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ មានអមទៅដោយសំណុំរឿង ដែលរួមមានទាំងភ័ស្ដុតាងដាក់បន្ទុក និងភ័ស្ដុតាងដោះបន្ទុក។ សំណុំរឿងដែលគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រួមមានជាង ១000ឯកសារ។

២២- សហព្រះរាជអាជ្ញាបានដាក់ជូននូវឯកសារជាច្រើន ដើម្បីពង្រីក និង/ឬបញ្ជាក់លក្ខណៈសម្បត្តិចំពោះវិសាលភាពនៃកិច្ចស៊ើបសួរទាក់ទិនទៅនឹងទីកន្លែង /ព្រឹត្តិការណ៍មួយចំនួនដូចខាងក្រោម៖ (១)មន្ទីរសន្តិសុខភូមិភាគឧត្តរ (២)អាពាហ៍ពិពាហ៍ដោយបង្ខំ (៣)អំពើប្រល័យពូជសាសន៍លើជនជាតិចាម (៤)មន្ទីរសន្តិសុខចំនួន៥កន្លែង និងទីកន្លែងប្រហារជីវិត និង(៥)ខ្មែរក្រោម និងស្រុកបាកាន។

## ការចាប់ខ្លួន

២៣- នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាបង្គាប់ឲ្យនាំខ្លួន ឌុច។ ដីកាបង្គាប់ឲ្យនាំខ្លួនជនសង្ស័យ៤នាក់ទៀត ត្រូវបានចេញនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ (នួន ជា) ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ (**អៀង សារី** និង **អៀង ធីរិទ្ធ**) និងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ (**ខៀវ សំផន**)។ ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានអនុវត្តម្តងមួយៗបន្ទាប់ពីការចេញដីកាទាំងនោះ។

## បទចោទ

២៤- ភ្លាមៗបន្ទាប់ពីការចាប់ខ្លួនជនសង្ស័យ(ពេលនោះ)រួចមក សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ជនសង្ស័យនីមួយៗ អំពីបទចោទ អនុលោមតាមវិធាន៥៧។ **នួន ជា អៀង សារី** និង **ខៀវ សំផន** ពីដំបូងត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដោយឡែក **អៀង ធីរិទ្ធ** និង **ឌុច** ពីដំបូងត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់បន្ថែម លើ **នួន ជា** នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ **អៀង សារី** នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ **ខៀវ សំផន** នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ និង **អៀង ធីរិទ្ធ** នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ (និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវទាក់ទិននឹង **អៀង ធីរិទ្ធ**) ។

## ការឃុំខ្លួនបណ្តោះអាសន្ន

២៥- បន្ទាប់ពីសវនាការសួរដេញដោលនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន អនុលោមតាមវិធាន៦៣។ ដីកាឃុំខ្លួនបឋមទាំងនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (**ឌុច**) ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ (**នួន ជា**) ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ (**អៀង សារី** និង **អៀង ធីរិទ្ធ**) និងថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ (**ខៀវ សំផន**)។ ចាប់ពីពេលនោះមក ការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទត្រូវបានពន្យារ២ដង ដោយសហចៅក្រមស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះ បានបដិសេធបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបឋម និងបានបដិសេធបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ។

## ការបំបែកសំណុំរឿង០០១

២៦- នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ អនុលោមតាមអនុវិធាន ២១(៤) សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឲ្យបំបែកការស៊ើបអង្កេតទៅលើការទទួលខុសត្រូវរបស់ **ឌុច** ចំពោះ "អង្គហេតុដែលត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌមន្ទីរ ស២១" (សំណុំរឿង ០០១/១៨-០៧-២០០៧) ចេញពីការស៊ើបអង្កេតទៅលើការទទួលខុសត្រូវរបស់ **នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ** ទាក់ទិនទៅនឹងអង្គហេតុទាំងអស់ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងទៅលើការទទួលខុសត្រូវរបស់ **ឌុច** ទាក់ទិនទៅនឹងអង្គហេតុនៅខាងក្រៅក្របខ័ណ្ឌមន្ទីរស២១ (សំណុំរឿង០០២/១៩-០៩-២០០៧) ។

## ការបិទកិច្ចស៊ើបសួរ

២៧- នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ អនុលោមតាមវិធាន៦៦ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់សហព្រះរាជអាជ្ញាថា ខ្លួនមានបំណងបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០២។ សំណើសុំបំពេញកិច្ចស៊ើបសួរជាច្រើន ត្រូវបានដាក់ដោយភាគីនានានៅក្នុងរយៈពេល៣០ថ្ងៃ ដែលត្រូវបានពន្យារ ហើយសំណើសុំទាំងនោះត្រូវបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត។ ដីកាសម្រេចមួយចំនួនក្នុងចំណោមដីកាសម្រេចទាំងអស់នេះ ត្រូវបានប្ដឹងឧទ្ធរណ៍ដោយភាគីនានា អនុលោមតាមវិធាន ៦៦(៣) នៃវិធានផ្ទៃក្នុង និងក្រោយមកទៀត ត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ។ យោង តាមអនុវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿងទៅ សហព្រះរាជអាជ្ញា កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានស្ថាពរ។

## ទំហំនៃសំណុំរឿង

២៨- ក្នុងពេលស៊ើបអង្កេត ការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការស្ដាប់យកចម្លើយសាក្សីជាង៨០០នាក់ និងបានប្រមូល ព្រមទាំងបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារជាង ១១៥០០ឯកសារ ដែលទាក់ទិនទៅនឹងការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បន្ទាប់ពីមានសំណើពីសហព្រះរាជអាជ្ញា កំណត់ហេតុអង្គសេចក្ដីនៃសំណុំរឿងលេខ០០១ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២។

## ការចូលរួមរបស់ជនរងគ្រោះ និងពាក្យបណ្ដឹងរបស់ជនរងគ្រោះ

២៩- សហព្រះរាជអាជ្ញាបានបញ្ជូនពាក្យបណ្តឹងចំនួន៤២០២ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់ចូលទៅក្នុងសំណុំរឿង៖ គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ អ្នកដាក់ពាក្យបណ្តឹងចំនួន៦៩នាក់ ក្នុងចំណោមអ្នកដាក់ពាក្យបណ្តឹងនានា បានស្នើសុំផ្លាស់ប្តូរសំណើសុំរបស់ខ្លួនទៅជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រីឯអ្នកដាក់ពាក្យបណ្តឹងចំនួន២រូបបានស្លាប់ នាំឱ្យពាក្យបណ្តឹងនៅសល់សរុបមានចំនួន៤១៣១។ បែបបទនៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសរុបមានចំនួន៤១២១ ត្រូវបានដាក់ជូនផ្នែកគាំពារជនរងគ្រោះ ដែលក្នុងនោះ ១៦២៧ពាក្យបណ្តឹងត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០។ បន្ទាប់ពីមានចំនួនកំណត់នៃការដកពាក្យបណ្តឹង ការដកចេញនូវពាក្យបណ្តឹងដែលជាន់គ្នាដដែលៗ និងសំណើសុំចាត់ថ្នាក់ដាក់ពាក្យសុំនានាទៅជាពាក្យបណ្តឹងវិញ នៅសល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សរុបចំនួនតែ៣៩៨៧ប៉ុណ្ណោះ។ គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ពាក្យសុំចំនួន១៥ អាចទទួលយកបាន និងបានប្រកាសថា ពាក្យសុំចំនួន២៨ផ្សេងទៀត មិនអាចទទួលយកឡើយ។ ទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី ទាំងពាក្យបណ្តឹងនានា បានផ្តល់ជាប្រភពនៃភ័ស្តុតាងដ៏មានតម្លៃ និងសមហេតុផល ដល់សហចៅក្រមស៊ើបអង្កេត។ ឧទាហរណ៍ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានលើកឡើងអំពីការវិភាគផ្លូវច្បាប់ ដែលបានកំណត់ លក្ខណៈនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងពួកគេ និងបានកំណត់អត្តសញ្ញាណជនត្រូវចោទ **អៀង សារី នួន ជា ខៀវ សំផន** និង **អៀង ធីរិទ្ធ** ថាជាចារីដែលដល់នៃបទឧក្រិដ្ឋទាំងអស់នោះ។

# IV. អង្គហេតុជាក់ស្តែង

## ក- ជម្លោះប្រដាប់អាវុធ

### ទិដ្ឋភាពទូទៅ

៣០- ជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ស.ស.វ) បានកើតមានឡើងនៅរវាងខែឧសភា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ ក្នុងអំឡុងពេលនេះ កម្លាំងប្រដាប់អាវុធនៃប្រទេសទាំងពីរបានធ្វើការវាយប្រហារ និងវាយបកដាក់គ្នាជាច្រើនលើកច្រើនសារដោយបានប្រើប្រាស់ធនធានយោធាដ៏ច្រើនសន្ធឹកសន្ធាប់ និងបានកាន់កាប់ទឹកដីគ្នាទៅវិញទៅមក។ តាមរយៈការប៉ះទង្គិចគ្នាខាងយោធា និងការវាយលុកក្នុងអំឡុងឆ្នាំ១៩៧៥ ជម្លោះកាន់តែមាន សភាពធ្ងន់ធ្ងរទៅចាប់ពីឆ្នាំ១៩៧៦ ហើយទីបំផុតបានឈានដល់ការវាយលុកកម្ពុជាក្នុងទ្រង់ទ្រាយធំពីសំណាក់កងទ័ពវៀតណាមនៅខែធ្នូ ឆ្នាំ១៩៧៨។

៣១- បុព្វហេតុនៃជម្លោះប្រដាប់អាវុធ គឺជាប់ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ និងមានភាពស្មុគស្មាញ ប៉ុន្តែភាគច្រើនបង្កមកពីការទាមទារទឹកដីរវាងប្រទេសទាំងពីរ។ នៅឆ្នាំ១៩៧៥ ប.ក.ក មានការបារម្ភ យ៉ាងខ្លាំងចំពោះអ្វីដែលខ្លួនបានចាត់ទុកថាជាគោលនយោបាយវាតទីនិយម និងមហិច្ឆតារបស់វៀតណាមក្នុងការបង្កើតសហព័ន្ធឥណ្ឌូចិនសារជាថ្មី ដែលនឹងអាចប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជា។ មូលហេតុផ្សេងៗទៀតនៃភាពតានតឹងនៅឆ្នាំ១៩៧៥ រវាងរបបកុម្មុយនីស្ត ទាំងពីរ គឺៈ

(១) ជម្លោះទឹកដីដែលបណ្តាលមកពីការគូសខ្សែបន្ទាត់ប្រេវីយេនៅឆ្នាំ១៩៣៩ ដែលបានកំណត់ព្រំដែនសមុទ្ររវាងកម្ពុជា និងវៀតណាម។

(២)ការចូលរួមរបស់វៀតណាម ក្នុងការចរចាលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ដែលបានបញ្ចប់សង្គ្រាមឥណ្ឌូចិនទីមួយ និងបានប្រគល់អធិបតេយ្យភាពពេញបរិបូរមកឱ្យកម្ពុជាវិញក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចនរោត្តមសីហនុ និងបានបន្ថយសកម្មភាពចលនាកុម្មុយនីស្តរបស់កម្ពុជា។

(៣)ការចុះហត្ថលេខារបស់វៀតណាមលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស ជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ១៩៧៣ ដែល ប.ក.ក យល់ថាសន្ធិសញ្ញានេះបានអនុញ្ញាតឱ្យកងកម្លាំងអាកាសរបស់សហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកក្នុងទ្រង់ទ្រាយធំមកលើទឹកដីកម្ពុជា។

៣២- នៅក្នុងសំណុំរឿង០០១ សាក្សីអ្នកជំនាញឈ្មោះ Nayan Chanda បានផ្តល់សក្ខីកម្មថា កម្ពុជា និងវៀតណាម “បានធ្វើសង្គ្រាមចាប់ពីឆ្នាំ១៩៧៥” ។ តាមបទពិសោធន៍របស់គាត់ ជាអ្នកសារព័ត៌មានធ្វើសេចក្តីរាយការណ៍ស្តីពីជម្លោះនេះ និងក្នុងនាមជាអ្នកជំនាញស្រាវជ្រាវ និងអ្នកសរសេរអត្ថបទជាច្រើនស្តីពីទំនាក់ទំនងអាស៊ីអាគ្នេយ៍ (និងពិសេស ទំនាក់ទំនង រវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ) បានធ្វើឱ្យគាត់ក្លាយខ្លួនជាអ្នកជំនាញអន្តរជាតិ ម្នាក់គេលើបញ្ហានេះ។ លោក Chanda បានឃើញដោយផ្ទាល់ភ្នែកនូវភាពយង់ឃ្នងនៃ ជម្លោះប្រដាប់អាវុធ ក្នុងអំឡុង ពេលទស្សនកិច្ចរបស់គាត់ទៅកាន់ប្រទេសវៀតណាម និងបានសម្ភាសន៍ជាមួយមន្ត្រីជាន់ខ្ពស់ជា ច្រើននាក់នៃប្រទេសទាំងពីរ និងបានតាមដានជម្លោះនេះយ៉ាងកៀកនៅពេលដែលវារីកធំ។

៣៣- ភស្តុតាងបញ្ជាក់នេះ មានសង្គតិភាពជាមួយនឹងសក្ខីកម្មរបស់លោក Chanda ហើយបង្ហាញថា យ៉ាងហោចណាស់មានរបាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយចំនួន១៤២ ស្តីពីជម្លោះ

ប្រដាប់អាវុធនេះ ដែលត្រូវបានចុះផ្សាយនៅចន្លោះពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៧។ បើទោះជា មានការចុះផ្សាយជាសាធារណៈអំពីជម្លោះព្រំដែននេះក្តី ក៏ប្រទេសទាំងពីរខិតខំលាក់បញ្ហាជម្លោះនេះទុកជាសម្ងាត់រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នៅពេលដែលកម្ពុជាប្រជាធិបតេយ្យ បានផ្តាច់ទំនាក់ទំនងជាផ្លូវការជាមួយវៀតណាម ដោយបានលើកឡើងអំពីការចូលត្រួតត្រាទឹកដីមួយចំនួនរបស់កម្ពុជា ពីសំណាក់កងកម្លាំងវៀតណាម។ ចាប់ពីពេលនោះមក អត្ថិភាពនៃជម្លោះប្រដាប់អាវុធទ្រង់ទ្រាយធំ ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងចំណោមសាស្ត្រាចារ្យ បញ្ញវន្ត និងអ្នកជំនាញ។

៣៤- ភស្តុតាងបន្ថែមបញ្ជាក់អំពីជម្លោះប្រដាប់អាវុធ ដែលបានមកពីប្រភពសាធារណៈ រួមមានដូចជា ១)សន្ទរកថា និងការប្រកាសជាផ្លូវការរបស់ប្រទេសទាំងពីរ ពាក់ព័ន្ធនឹងជម្លោះ និង២)ការឃោសនារបស់ ប.ក.ក ប្រឆាំងនឹងវៀតណាម ដូចជាការចាក់ផ្សាយចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ដូចដែលបានរៀបរាប់ក្នុងផ្នែកឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម។ ក្នុងសំណុំរឿងនេះ ក៏មានឯកសារផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ ឬ ប.ក.ក ជាច្រើនផងដែរ ដូចជា របាយការណ៍ សារទូរលេខ និងកំណត់ហេតុកិច្ចប្រជុំ ដែលបញ្ជាក់អះអាង អំពីលក្ខណៈ ទំហំ និងកម្រិតនៃជម្លោះប្រដាប់អាវុធ។ ជាក់ស្តែងភស្តុតាងទាំងនេះបញ្ជាក់ថា កម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យបានរាយការណ៍ជូនមជ្ឈិមបក្ស ប.ក.ក អំពីការប្រឈមមុខគ្នាជាមួយទ័ព ស.ស.វ យ៉ាងហោចណាស់ចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥។ ការចរចារបស់ ប.ក.ក ជាមួយវៀតណាមបញ្ជាក់ថា មជ្ឈិមបក្សក៏បានដឹងអំពីការប្រឈមមុខដាក់គ្នាពីពេលមុន កាលពីខែឧសភា ឆ្នាំ១៩៧៥ មកម្ល៉េះ។

៣៥- បទបញ្ជាទៅកាន់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យដែលបានចូលប្រយុទ្ធ ត្រូវបានផ្សព្វផ្សាយតាមខ្សែសង្វាក់បញ្ជាការតាមរយៈវិទ្យុទាក់ទង។ ក្នុងអំឡុងពេលប្រយុទ្ធគ្នានៅភូមិភាគបូព៌ា វិទ្យុទាក់ទងរបស់សហរដ្ឋអាមេរិកដែលគេរឹបអូសបាន ត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនងរវាង អង្គភាពបញ្ជាការសមរភូមិមុខ និងភ្នំពេញ។ ដោយហេតុថាកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំងរបស់ ស.ស.វ ប្រើប្រាស់វិទ្យុទាក់ទងផលិតនៅសហរដ្ឋអាមេរិកដូចគ្នា ហើយវិទ្យុទាក់ទងមួយចំនួនរបស់កងកម្លាំង ស.ស.វ ត្រូវបានកងកម្លាំងកម្ពុជាប្រជាធិបតេយ្យដណ្តើមយកបាន ទើបកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ អាចមានលទ្ធភាពស្តាប់ការឆ្លើយឆ្លង ហើយនៅពេលមួយចំនួន បានដឹងពីចេតនារបស់គូបដិបក្ខ។

៣៦- ភស្តុតាងស្តីពីវិសាលភាព និងការបន្តជាប់ជាហូរហែរនៃជម្លោះប្រដាប់អាវុធ ក៏ត្រូវបានប្រទះឃើញតាមរយៈការចាត់ចែងព្យាបាលកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលបានត្រូវរបួសក្នុងការវាយប្រយុទ្ធជាមួយវៀតណាម។ យុទ្ធជនរបួសស្រាលបានទទួលការព្យាបាលនៅមូលដ្ឋាននៅក្នុងមន្ទីរពេទ្យភូមិភាគនោះ។ យុទ្ធជនរបួសធ្ងន់ត្រូវដឹកយកទៅព្យាបាលនៅភ្នំពេញ ភាគច្រើននៅមន្ទីរពេទ្យ ព-១៧។ ចាប់ពីឆ្នាំ១៩៧៦មក មានការកើនឡើងនៃចំនួនអ្នកជម្ងឺ "ចាប់ពីភាគព្រៃសាន ដល់ឆ្នេរសមុទ្រ" ដែលនេះឆ្លុះបញ្ចាំងឲ្យឃើញអំពីកំណើនភាពតានតឹងនៃជម្លោះនេះ។ នៅឆ្នាំ១៩៧៨ មានការកើនឡើងចំនួនអ្នកស្លាប់ និងរបួសដែលត្រូវបានដឹកចូលមកមន្ទីរពេទ្យព-១៧ និងមន្ទីរពេទ្យផ្សេងៗ ដូចជាមន្ទីរពេទ្យ ព-៦ ជាដើម។

៣៧- ផ្នែកឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម គួសបញ្ជាក់អំពីការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលកងទ័ពបដិវត្តន៍កម្ពុជា បានប្រព្រឹត្តអំឡុងពេលដែលខ្លួនបានវាយលុកចូលទឹកដីវៀតណាម។

## ឆ្នាំ១៩៧៥

៣៨- បន្ទាប់ពីធ្លាប់បានផ្តល់ជំនួយជាច្រើនសន្ធឹកសន្ធាប់ ដល់កងកម្លាំងខ្មែរក្រហមក្នុងអំឡុងសង្គ្រាមស៊ីវិលក្នុងឆ្នាំ១៩៧៣ អង្គភាពយោធាវៀតណាមខាងជើង បានដកខ្លួនពីជម្លោះនៅសមរភូមិមុខ និងដកថយមកនៅត្រឹមតំបន់តាមព្រំដែន ដោយទុកបន្ទុកប្រយុទ្ធទៅឲ្យ ប.ក.ក។ វាពុំទំនងថាមូលដ្ឋានសំខាន់ៗរបស់យោធាវៀតណាមខាងជើង នៅបន្តមានក្នុងទឹកដីកម្ពុជា ក្រោយពីការដកថយនោះ។ បើទោះបីជាយ៉ាងដូច្នេះក្តី នៅចុងខែមេសា ឆ្នាំ១៩៧៥ របបថ្មីនៅភ្នំពេញបានចេញសេចក្តីប្រកាសហាមប្រាមវត្តមានរបស់ទ័ព និងមូលដ្ឋានយោធាបរទេសនៅលើទឹកដីកម្ពុជា។ បើទោះបីជាសេចក្តីប្រកាសនោះពុំបានបញ្ជាក់ឲ្យច្បាស់ក៏ដោយ ក៏គេមើលឃើញថាការប្រកាសនោះសំដៅសំខាន់ទៅលើកងកម្លាំងវៀតណាម។ សេចក្តីប្រកាសព័ត៌មានដែលត្រូវបានចេញដោយអង្គសមាជជាតិពិសេសរបស់កម្ពុជាក្នុងខែមេសា ឆ្នាំ១៩៧៥ ដែលអានដោយ **ខៀវ សំផន** បានប្រកាសថា កម្ពុជា “ហាមឃាត់ជាដាច់ខាតមិនឲ្យប្រទេសណាមួយ បង្កើតមូលដ្ឋានយោធានៅកម្ពុជាឡើយ” និងប្រឆាំង“រាល់គ្រប់រូបភាពនៃការជ្រៀតជ្រែករបស់បរទេសចូលក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា” ។ ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិបានរាយការណ៍ថាតាមពិតមានជម្លោះរវាងកងកម្លាំងខ្មែរក្រហម និងកងទ័ពវៀតណាមខាងជើងប្រាកដមែនចាប់ពីខ្ទង់ឆ្នាំ១៩៧២ ពេលដែលកងកម្លាំងខ្មែរក្រហមចង់មានឥទ្ធិពលគ្របដណ្តប់ធំធេង ទៅលើ

មូលដ្ឋាននានា និងឧបករណ៍ ដែលវៀតណាមខាងជើងបានប្រើប្រាស់ និងការព្យាយាមក្តោបក្តាប់ចលនាកងកម្លាំងវៀតណាមខាងជើងក្នុងទឹកដីកម្ពុជា។ ជម្លោះរវាងកងកម្លាំងខ្មែរក្រហម និងកងកម្លាំងវៀតណាម នៅខេត្តកំពតតាំងពីឆ្នាំ១៩៧៣ ក៏ត្រូវបានគេរាយការណ៍ផងដែរ។

៣៩- ជម្លោះប្រដាប់អាវុធបានចាប់ផ្តើមនៅដើមខែឧសភា ឆ្នាំ១៩៧៥ នៅពេលកងកម្លាំងខ្មែរក្រហមបានវាយប្រហារលើកោះសំខាន់ៗចំនួនពីរ គឺកោះត្រល់ ( Phu-Quoc ) និងកោះក្រចកសេះ (Poulo Panjang ឬ Tho Chu) ដែល ប.ក.ក បានអះអាងថាជាទឹកដីរបស់កម្ពុជា។ ពីរសប្តាហ៍បន្ទាប់ កងកម្លាំងខ្មែរក្រហមត្រូវបានវៀតណាមវាយឲ្យដកថយ ក្នុងការវាយប្រហារធំមួយ ក្នុងនោះទាហានកម្ពុជាចំនួន៣០០នាក់ត្រូវបានវៀតណាមចាប់ជាឈ្លើយសឹក។ នៅក្នុងអំឡុងពេលនេះ កងកម្លាំងខ្មែរក្រហមហាក់ដូចជាបានបើកការវាយលុកចូលទៅក្នុងទឹកដីវៀតណាមតាមបណ្តោយព្រំដែន ចន្លោះទីប្រជុំជនហា ទៀង(Ha Tien) និងតៃ និញ(Tay Ninh) ។

៤០- ក្នុងការតបតចំពោះការវាយប្រហាររបស់ខ្មែរក្រហម វៀតណាមបានដណ្តើមកាន់កាប់កោះមួយរបស់កម្ពុជាឈ្មោះកោះពូលូវៃ នៅចំ ឬនៅខ្ទង់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៧៥។ មនុស្សប្រមាណ៨០នាក់ បានស្លាប់ក្នុងការវាយប្រហារនេះ។ កងកម្លាំងវៀតណាមបានដណ្តើមកាន់កាប់កោះនេះអស់រយៈពេលពីរទៅបីខែ មុនពេលប្រគល់មកឲ្យកម្ពុជាវិញ។ នៅខែមិថុនា ឆ្នាំ១៩៧៥ ការប្រយុទ្ធគ្នារប៉េះរប៉ោះរវាងកងកម្លាំងប្រទេសទាំងពីរ បានកើតមាននៅតំបន់ចំពុះទា ក្នុងទឹកដីកម្ពុជា នៅខេត្តស្វាយរៀង (ភូមិភាគបូព៌ាកាលជំនាន់កម្ពុជាប្រជាធិបតេយ្យ) ។

៤១- នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៧៥ "គណៈប្រតិភូជាន់ខ្ពស់" មួយក្រុមរបស់គណៈមជ្ឈិមបក្ស ប.ក.ក ដែលរួមមាន ប៉ុល ពត **នួន ជា** និង **អៀង សារី** បានធ្វើទស្សនកិច្ចទៅកាន់ទីក្រុងហាណូយដើម្បីជួបចរចាជាមួយរដ្ឋាភិបាលវៀតណាម។ ក្នុងអំឡុងពេលនៃកិច្ចចរចា ប៉ុល ពត បានពន្យល់ថា ការវាយលុករបស់ខ្មែរក្រហម និងការចូលកាន់កាប់ទឹកដីវៀតណាម គឺដោយសារមកពី "ការមិនស្គាល់ភូមិសាស្ត្រ"របស់ទ័ពមូលដ្ឋាន។ បើទោះបីជាយ៉ាងដូច្នេះក្តី បើពិចារណាអំពីការត្រួតត្រាដ៏តឹងតែងរបស់មជ្ឈិមបក្ស ប.ក.ក មកលើអង្គភាពក្រោមឱវាទរបស់ខ្លួន ឃើញថាសកម្មភាពយោធាប្រឆាំងនឹងវៀតណាមអាចកើតមានបាន លុះត្រាតែមានការអនុញ្ញាត និងការណែនាំពីថ្នាក់ដឹកនាំ ប.ក.ក។

៤២- សារទូរលេខមួយចុះខែវិច្ឆិកា ឆ្នាំ១៩៧៥ ផ្ញើជូនមជ្ឈិមបក្ស បានរៀបរាប់លម្អិតអំពីឧប្បត្តិហេតុមួយចំនួនដែលកងកម្លាំងរបស់ ស.ស.វ បានទន្ទ្រានចូលទឹកដីកម្ពុជានៅតំបន់២៣ ភូមិភាគបូព៌ា។ របាយការណ៍នេះ រៀបរាប់លម្អិតពាក់ព័ន្ធនឹងការរៀបចំចាត់តាំងអង្គភាពឈ្លបនិងកងកម្លាំងធម្មតាសម្រាប់ការពារខ្លួនពីការវាយលុកណាមួយរបស់ ស.ស.វ។

៤៣- ការវាយប្រយុទ្ធគ្នារវាងកងទ័ពប្រទេសទាំងពីរបានចាប់ផ្តើមបន្តនៅខែធ្នូ ឆ្នាំ១៩៧៥ ក្នុងនោះមានការប្រយុទ្ធគ្នារប៉េះរប៉ោះមួយចំនួននៅតាមព្រំដែន ក្នុងខេត្ត Kontum និង Daklak ដែលជាតំបន់ភ្នំ នៅវៀតណាមខាងត្បូង។

## ឆ្នាំ១៩៧៦

៤៤- កំណត់ហេតុកិច្ចប្រជុំចំនួន៥របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅចន្លោះពីថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ បញ្ជាក់អំពីការបញ្ជា និងការតាមដានរបស់

គណៈកម្មាធិការអចិន្ត្រៃយ៍ របស់ ប.ក.ក ស្តីពីការប្រឈមមុខគ្នាដោយអាវុធ ដែលកាន់តែតានតឹងឡើង រវាងកងកម្លាំងកម្ពុជា និងសមភាគីវៀតណាមក្នុងអំឡុងពេលនោះ។ នៅខែមករា ឆ្នាំ ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍ បានណែនាំឲ្យកម្មាភិបាលថ្នាក់ក្រោមរបស់ ប.ក.ក ទាក់ទងជាមួយសមភាគីវៀតណាម និងបើកកិច្ចចរចាថ្នាក់មូលដ្ឋានតាមការណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ក្នុងខែដដែល ការចរចាពាក់ព័ន្ធនឹងឧប្បត្តិហេតុនានាតាមបណ្តោយព្រំដែន ត្រូវបានធ្វើឡើងរវាងមន្ត្រី ប.ក.ក មកពីភូមិភាគឦសាន និងសមភាគីវៀតណាមមកពីតំបន់យោធា៥។ ក្នុងការចរចានោះ មានការឈានដល់ការឯកភាពគ្នា ដំណាក់កាលដំបូងទៅលើការកំណត់តំបន់ព្រំដែនដែលមានជម្លោះ ដោយរង់ចាំការឯកភាពពីសំណាក់គណៈកម្មាធិការមជ្ឈិមបក្សនៃប្រទេសទាំងពីរ។

៤៥- បើទោះបីជាយ៉ាងដូច្នេះក្តី នៅខែកុម្ភៈ ឆ្នាំ១៩៧៦ មានឧប្បត្តិហេតុមួយចំនួន និងសកម្មភាពចូលទន្ទ្រានទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ ពីសំណាក់វៀតណាម ពិសេស ក្នុងខេត្តរតនគិរី និងខេត្តស្វាយរៀង។ យោងតាមរបាយការណ៍កម្ពុជាប្រជាធិបតេយ្យ ក្នុងកិច្ចពិភាក្សាថ្នាក់ មូលដ្ឋានរវាងភាគីទាំងពីរ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានទាមទារឲ្យវៀតណាមដកកងកម្លាំងរបស់ខ្លួន ប៉ុន្តែវៀតណាមពុំព្រម ដោយវៀតណាមបានគូសបញ្ជាក់ថា ខ្លួនពុំទទួលស្គាល់ព្រំប្រទល់ ដែលកម្ពុជាប្រជាធិបតេយ្យបានកំណត់ឡើយ។

៤៦- នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍ ប.ក.ក បានចេញសេចក្តីណែនាំស្តីពីបញ្ហាយោធា ដូចជាការផលិតគ្រាប់រំសេវ និងការបណ្តុះបណ្តាល និងការសង់ព្រលានយន្តហោះ មន្ទីរពេទ្យយោធា និងរោងចក្រផលិតអាវុធយុទ្ធភណ្ឌ។ របាយការណ៍មួយរបស់កងទ័ព បដិវត្តន៍កម្ពុជា

ដែលត្រូវបានផ្ញើនៅថ្ងៃបន្ទាប់ មានរៀបរាប់អំពីការវាយប្រហាររបស់កងទ័ពវៀតណាម នៅក្បែរភ្នំ Pou Nhak O Vay ភូមិភាគឦសាន ដែលក្នុងនោះយ៉ាងហោចណាស់បានបណ្ដាលឱ្យកម្មាភិបាលវៀតណាមម្នាក់ស្លាប់ និងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ រងរបួសមួយ ចំនួន។

៤៧- នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៦ មជ្ឈិមបក្ស ប.ក.ក បានទទួលរបាយការណ៍មួយទៀតពីកងកម្លាំងកងទ័ពបដិវត្តន៍កម្ពុជានៅភូមិភាគឦសាន ដោយបានបញ្ជាក់ថា ការប៉ះទង្គិចគ្នាជាមួយកងកម្លាំង ស.ស.វ មួយចំនួន បានកើតមាននៅចន្លោះថ្ងៃទី១៥ ដល់ថ្ងៃទី២៤ ខែកុម្ភៈ ដែលក្នុងនោះបានធ្វើឱ្យ កងទ័ពវៀតណាមស្លាប់ និងរបួស។ បន្ទាប់ពីការប៉ះទង្គិចគ្នាទាំងនេះ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានបើកការវាយប្រហារមកលើកងកម្លាំងវៀតណាមនៅថ្ងៃទី២៥ ខែកុម្ភៈ ដែលបានបង្កឱ្យកងកម្លាំង ស.ស.វ ស្លាប់ និងរបួស។

៤៨- នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ ឈ្មោះ ណៃ សារ៉ាន់ *ហៅ* យ៉ា លេខាភូមិភាគឦសានបានផ្ញើរបាយការណ៍ជូនមជ្ឈិមបក្សពាក់ព័ន្ធនឹងបញ្ហាកំណត់ព្រំដែន។ គាត់បានរាយការណ៍អំពីការដកបង្គោលព្រំដែនរបស់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និង“ការបំបាត់រាល់តម្រុយបង្គោលព្រំដែនចាស់ទាំងអស់”។ នៅចន្លោះពីថ្ងៃទី៧ ដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៦ មានការចរចាមួយចំនួន នៅភូមិភាគឦសាន ដោយនៅពេលនោះ ឈ្មោះ យ៉ា បានរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ពីបញ្ហាមួយចំនួន។ ប៉ុន្តែ កំណត់ហេតុអង្គប្រជុំរបស់គណៈកម្មាធិការចិន្ត្រៃយ៍ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ បានបញ្ជាក់យ៉ាងច្បាស់ថា ការចរចា គឺគ្រាន់តែជាឧបាយកលពន្យារពេល ដើម្បីពង្រឹងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យឱ្យបានគ្រប់គ្រាន់តែប៉ុណ្ណោះ។ តាមការពិត

គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចជ្រើសរើសយកការប្រឈមមុខខាងយោធា ចំពោះការទន្ទ្រានចូលរបស់វៀតណាម មកក្នុងខេត្តរតនគិរី តាកែវ និងក្រចេះ។

៤៩- ស្ថានភាពអរិភាពដែលចេះតែតានតឹងឡើងនៅខែមីនា ឆ្នាំ១៩៧៦ ត្រូវបានបញ្ជាក់អះអាងតាមរយៈរបាយការណ៍របស់យោធាកម្ពុជាប្រជាធិបតេយ្យ ស្តីពីការប៉ះទង្គិចជាមួយកងកម្លាំងវៀតណាមនៅតាមបណ្តោយព្រំដែន។ របាយការណ៍មួយចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៦ បានរៀបរាប់អំពីកងទ័ពសមរភូមិមុខរបស់វៀតណាមដែលមានកងកម្លាំងចំនួន២៤០នាក់ក្នុងទឹកដីកម្ពុជា និងគូសបញ្ជាក់អំពីផែនការបើកការវាយប្រហារទៅលើពួកគេ។ របាយការណ៍មួយដែលបានផ្ញើជូន ប៉ុល ពត ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦ បានគូសបញ្ជាក់ អំពីឧប្បត្តិហេតុមួយចំនួននៅចន្លោះថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៦ ដែលក្នុងនោះទាហានវៀតណាមមួយចំនួនត្រូវបានចាប់ខ្លួននៅតំបន់២៤ នៃភូមិភាគបូព៌ា។ ទូរលេខមួយចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ជូនចំពោះមជ្ឈិមបក្សបានរាយការណ៍អំពីសភាពការណ៍នៅតំបន់២៥ ភូមិភាគនិរតី ក្បែរព្រំដែនដែលគេបានចោទប្រកាន់ថា កម្ពុជាបានបង្កវិនាសកម្មដល់កងទ័ពវៀតណាម។ មតិយោបល់របស់ នួន ជា ដែលបានលើកឡើងក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៦ ក៏បានបញ្ជាក់អះអាងអំពីទំហំនៃជម្លោះផងដែរ។ ក្នុងចំណោមចំណុចផ្សេងៗ នួន ជា បានរៀបរាប់អំពីការប្រើប្រាស់ចម្ការមីននៅតាមផ្លូវដែលមានជម្លោះ និងការពន្លិចទូកនេសាទរបស់វៀតណាម នៅក្នុងតំបន់ទឹកដែលមានជម្លោះ។

៥០- នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ គណៈរដ្ឋមន្ត្រីរបស់កម្ពុជាប្រជាធិបតេយ្យបានពិភាក្សាអំពីការវាយលុកកាត់ព្រំដែនពីសំណាក់កងកម្លាំង ស.ស.វ និងការចរចារវាងកម្ពុជាប្រជាធិប

តេយ្យជាមួយនឹង ស.ស.វ ដោយបានលើកឡើងថា ស.ស.វ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហភាពសូវៀត និងមានជំហរទន់ខ្សោយជាងកម្ពុជាប្រជាធិបតេយ្យ។

៥១- នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៧៦ មាស មុត លេខាកងពលធំលេខ១៦៤ នៃកងទ័ពបដិវត្តន៍កម្ពុជា បានជួបប្រជុំជាមួយ ប៉ុល ពត វន វ៉េត សុន សេន និងមនុស្សផ្សេងទៀត ដើម្បីពិភាក្សាអំពីទីតាំងការពារនៅតំបន់កំពង់សោម និងកោះនៅសមុទ្រខាងក្រៅ។ មាស មុត ជាអ្នកធ្វើរបាយការណ៍អំពីជម្លោះជាមួយប្រទេសថៃ និង ស.ស.វ ខណៈពេលដែល ប៉ុល ពត ជាអ្នកផ្តល់ឱវាទណែនាំពាក់ព័ន្ធនឹងការដាក់ទីតាំងការពារខ្លួន និងការផលិត និងការថែទាំនាវាចម្បាំង។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ មាស មុត បានរាយការណ៍អំពីការប្រយុទ្ធគ្នារវាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំង ស.ស.វ។

៥២- ការប៉ះទង្គិចគ្នាដែលកាន់តែញឹកញាប់ និងខ្លាំងក្លានៅតំបន់ព្រំដែនស្រុករមាសហែក ខេត្តស្វាយរៀង(តំបន់២៣ ភូមិភាគបូព៌ា) ក៏ត្រូវបានរាយការណ៍ផងដែរ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦។

៥៣- នៅក្នុងសន្ទរកថាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៦ អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ បានទទួលស្គាល់ជាសាធារណៈជាលើកដំបូងអំពីជម្លោះ ដោយបានលើកឡើងថាការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា នឹងត្រូវទទួលការវាយតបតវិញ។

## ឆ្នាំ១៩៧៧

៥៤- ចាប់ពីដើមឆ្នាំ១៩៧៧មក ជម្លោះប្រដាប់អាវុធកាន់តែមានសភាពធ្ងន់ធ្ងរឡើងថែមទៀត ហើយទំនាក់ទំនងរវាងប្រទេសទាំងពីរបានធ្លាក់ចុះយ៉ាងឆាប់រហ័ស។ ជាក់ស្តែង ជម្លោះរវាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំង ស.ស.វ ដែលបានប្រឈមមុខដាក់គ្នាតាមបណ្តោយ

ព្រំដែនភូមិភាគបូព៌ានៅស្រុកពាមជរ(ខេត្តព្រៃវែង) បានកើតមានស្ទើររាល់ថ្ងៃ។ ការវាយប្រយុទ្ធគ្នានៅស្រុកចន្ទ្រា(ខេត្តស្វាយរៀង) បានចាប់ផ្តើមពីខែកក្កដា ឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨។

## ការវាយលុកចូលទឹកដីវៀតណាម

៥៥- ចាប់ផ្តើមក្នុងខែមេសា និងចាប់ផ្តើមម្តងទៀតក្នុងខែកញ្ញា ឆ្នាំ១៩៧៧ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានបើកការវាយប្រហារទ្រង់ទ្រាយធំជាបន្តបន្ទាប់ទៅលើទីប្រជុំជនវៀតណាម និងបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រជាជនមូលដ្ឋាន រួមទាំងការសម្លាប់ប្រជាជនស៊ីវិលរាប់ពាន់នាក់ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន។ ខេត្តរបស់វៀតណាមដែលជាគោលដៅនៃការវាយប្រហារទាំងនេះ មានដូចជា ខេត្តកៀន យ៉ាង(Kien Giang) ចូវ ដុក (Chau Doc) អាន យ៉ាង(An Giang) និងតៃ និញ(Tay Ninh)។ ឧក្រិដ្ឋកម្មដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តអំឡុងពេលវាយលុកនោះ គឺជាកម្មវត្ថុនៃកិច្ចស៊ើបសួរ និងត្រូវបានលើកយកបរិយាយនៅក្នុងផ្នែកឧក្រិដ្ឋកម្មប្រឆាំងនឹង ជនជាតិវៀតណាម។

៥៦- ដូចដែលបានពិភាក្សានៅក្នុងផ្នែក ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម មជ្ឈិមបក្ស ប.ក.ក បានទទួលការតវ៉ាជាផ្លូវការពីសំណាក់ ស.ស.វ ព្រមទាំងរបាយការណ៍មួយចំនួនពី ស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅក្រុងហាណូយ ដែលបានរៀបរាប់លម្អិតពីការចោទប្រកាន់ អំពីឧក្រិដ្ឋកម្មដ៏ច្រើនសន្ធឹកសន្ធាប់ ដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្ត។ តាមការសង្កេត ការវាយប្រហារធំៗ និងការចូលលុកលុយទឹកដីកម្ពុជាពីសំណាក់ ស.ស.វ ចាប់ពី

ខែកញ្ញា ឆ្នាំ១៩៧៧ (នឹងលើកយកមកពិភាក្សាខាងក្រោម) គឺជាការសងសឹក ចំពោះអំពើឧក្រិដ្ឋកម្មដែលកងទ័ពបដិវត្តន៍កម្ពុជាបានប្រព្រឹត្តក្នុងទឹកដីវៀតណាម។

**ការវាយលុកចូលកម្ពុជា និងការវាយលុកជាទ្រង់ទ្រាយធំលើកដំបូងរបស់វៀតណាមមកលើកម្ពុជា**

៥៧- យោងតាមស្ថានភាពជម្លោះដែលចេះតែធ្ងន់ធ្ងរ និងកាន់តែមានទំហំធំទៅ នៅខែកក្កដា ឆ្នាំ ១៩៧៧ មជ្ឈិមបក្ស ប.ក.ក បានចេញបញ្ជាឲ្យបង្កើតសមរភូមិថ្មីចំនួន២។ សមរភូមិផ្លូវជាតិលេខ១ ចាប់ពីផ្លូវជាតិលេខ១ ដល់ផ្នែកខាងត្បូងភូមិភាគបូព៌ា ពីអ្នកលឿង តំបន់២៤ ដល់ព្រំដែនវៀតណាមនៅស្វាយរៀង តំបន់២៣ ។ សមរភូមិនេះស្ថិតក្រោមការបញ្ជាផ្ទាល់របស់ សុន សេន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការពារជាតិ និងជាប្រធានអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា។ សមរភូមិផ្លូវជាតិលេខ៧ ចាប់ពីផ្លូវជាតិលេខ៧ កាត់ផ្នែកខាងជើងភូមិភាគបូព៌ា ពីប៉ែកខាងកើតទន្លេមេគង្គ ក្រុងកំពង់ចាម កាត់តំបន់២០ និង២១ និងតំបន់ស្វយ័ត៥០៥ ចូលទៅភូមិភាគឦសាន។ តាមការប៉ាន់ស្មាន សមរភូមិនេះស្ថិតនៅក្រោមការបញ្ជារបស់ សោ ភឹម លេខាភូមិភាគបូព៌ា និងមានលេខាភូមិភាគកណ្តាលឈ្មោះ កែ ពក ជាអនុប្រធាន។ មន្ទីរបញ្ជាការប្រតិបត្តិការរួមត្រូវបានបង្កើតនៅស្នួង។

៥៨- នៅខែមិថុនា ឆ្នាំ១៩៧៧ ការប្រឈមមុខដាក់គ្នារវាងកងកម្លាំងប្រទេសទាំងពីរបានកើតមាននៅភូមិភាគឦសានរបស់កម្ពុជាប្រជាធិបតេយ្យ។ ថ្ងៃទី២០ ខែមិថុនា មជ្ឈិមបក្សបានទទួលរបាយការណ៍ អំពីការប៉ះទង្គិចគ្នាមួយចំនួននៅដាក់ដាំ។

៥៩- ចាប់ពីខែមិថុនា ឆ្នាំ១៩៧៧ មានការប៉ះទង្គិចគ្នាធំៗនៅភូមិភាគបូព៌ា ហើយនៅខែកញ្ញា ឬតុលា ការប៉ះទង្គិចគ្នាមានសភាពកាន់តែធ្ងន់ធ្ងរទៅ។ ហេតុការណ៍ទាំងនេះ ត្រូវបានបញ្ជាក់ភស្តុតាង

តាមរយៈការទាក់ទងគ្នាជាច្រើនពីសមរភូមិ ក្នុងនោះរួមមានរបាយការណ៍មួយចំនួនដែលត្រូវបានសរសេរដោយ សោ ភឹម ឬក្នុងនាម សោ ភឹម (ឈ្មោះ ផុន ជាអ្នកចុះហត្ថលេខា)៖

(១) នៅខែមិថុនា ឆ្នាំ១៩៧៧ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានប៉ះទង្គិចគ្នាជាមួយទ័ព ស.ស.វ ដែលបានបើកការវាយលុកចូលតំបន់ ២៣។ ទូរលេខមួយច្បាប់ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៧៧ ជូនចំពោះមន្ទីរ ៨៧០ បានរាយការណ៍អំពីការវាយលុកមួយទៀតចូលតំបន់ ២៣ ពីសំណាក់កងកម្លាំងវៀតណាម ហើយបន្ទាប់មកពួកគេបានរងការបាញ់ផ្ដោងពីសំណាក់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ។

(២) របាយការណ៍មួយមកពីតំបន់ ២០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៧ បានរៀបរាប់អំពីការប្រឈមមុខដាក់គ្នាមួយចំនួនរវាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំង ស.ស.វ ពីថ្ងៃទី១៧ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៧ ដែលភាគីទាំងពីរសុទ្ធតែបានរងការស្លាប់ និងរបួស។

(៣) នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៧ មជ្ឈិមបក្ស បានទទួលដំណឹងស្ដីពីការវាយឆ្មក់ចំនួនពីរដងទៅលើកងកម្លាំងកម្ពុជាប្រជាធិបតេយ្យនៅក្បែរ អង្គម្ដេញ(Ang Mdenh) ពីសំណាក់អង្គភាពកងកម្លាំង ស.ស.វ ជាមួយនឹងរបាយការណ៍ដែលថាកងកម្លាំង ស.ស.វ ចំនួន១៥ស្លាប់ ចំណែកខាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យស្លាប់ម្នាក់ និងរបួស៥នាក់។

(៤) នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៧ មជ្ឈិមបក្សបានទទួលរបាយការណ៍លម្អិតមួយស្ដីអំពីការប៉ះទង្គិចគ្នាមួយចំនួន ក្នុងនោះរួមទាំងការវាយលុកចូលមកក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យពីសំណាក់កងកម្លាំង ស.ស.វ។ យោងតាមរបាយការណ៍នេះ ក្នុងការប៉ះ

ទន្ទិចគ្នាទាំងនេះ ខាងភាគីវៀតណាមក៏មានទាហានស្លាប់ និងរបួស និងមានការខូចខាតទ្រព្យសម្បត្តិអស់ជាច្រើនផងដែរ។

៦០- បន្ទាប់ពីព្រឹត្តិការណ៍ខាងលើ ការប្រឈមមុខដាក់គ្នាប្រកបដោយភាពតឹងតែង បានកើតឡើងជាបន្តបន្ទាប់នៅតំបន់"ចំពុះទា" នៃភូមិភាគបូព៌ា នៅអំឡុងពេលពីខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ការប្រឈមមុខដាក់គ្នាជាបន្តបន្ទាប់ទាំងនេះ ដែលក្រោយមកធ្វើឲ្យកងទ័ពវៀតណាមបានវាយលុកទ្រង់ទ្រាយធំចូលក្នុងទឹកដីកម្ពុជា ត្រូវបានសរសេរនៅក្នុងរបាយការណ៍ដែលផ្ញើមកពីភូមិភាគបូព៌ា (ដែលជាថ្មីម្តងទៀត របាយការណ៍ទាំងនេះត្រូវបានសរសេរដោយ សោ ភឹម ហៅ ឝុន)៖

(១) នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៧ សោ ភឹម បានរាយការណ៍ថា កងទ័ពបដិវត្តន៍កម្ពុជានៅមូលដ្ឋានមិនអាចវាយរុញច្រានការវាយលុករបស់កងទ័ព ស.ស.វ ទៅក្នុងទឹកដីមួយភាគរបស់ស្រុកចន្ទ្រា(តំបន់២៣)បានទេ ដោយសារកងកម្លាំងមួយចំនួនធំត្រូវបានបញ្ជូនដើម្បីរំដោះនៅភូមិបារិតលើ និងបារិតកណ្តាល ឃុំបារិត ស្រុកចន្ទ្រា។

(២) មុននោះនៅថ្ងៃដដែល កងកម្លាំងមូលដ្ឋាន បានវាយជោគជ័យទៅលើទីតាំងឈរជើងនានារបស់កងទ័ព ស.ស.វ ដោយកម្ពុជាប្រជាធិបតេយ្យដណ្តើមបានបារិតលើ និងបារិតកណ្តាលមកវិញ។ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៧ មានការប្រយុទ្ធគ្នាបន្ថែមទៀតនៅក្នុងតំបន់នោះ ដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានបំបែកទីតាំងឈរជើងរបស់កងទ័ព ស.ស.វ។ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧ មានរបាយការណ៍ថាកងទ័ព ស.ស.វ បានដកចេញពីឃុំបារិត(តំបន់២៣) ទោះបីតំបន់នេះនៅតែទទួលរង

ការបាញ់ផ្លោង និងបាញ់ប្រហារពីលើយន្តហោះពីទីតាំងឈរជើងរបស់កងទ័ព ស.ស.វ ហើយថា "មានការប៉ះទង្គិចបន្តិចបន្តួច" នៅតំបន់២៥។

(៣) នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៧ សោ ភឹម បានផ្តល់ព័ត៌មានទៅមជ្ឈិមបក្សអំពីការវាយប្រហាររបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលជា"កងទ័ពតំបន់ និងស្រុករួមគ្នា" មកលើទីតាំងឈរជើងមួយចំនួនរបស់កងទ័ព ស.ស.វ ។ គាត់បានរាយការណ៍បន្ថែមទៀតថា កងទ័ពបដិវត្តន៍កម្ពុជាបានរុញច្រានការវាយចូលរបស់កងទ័ព ស.ស.វ នៅព្រមតំបន់សថ្កូកទាំងសម្លាប់ ឬចាប់បុគ្គលិកយោធា ស.ស.វ បានមួយចំនួនទៀតផង។

(៤) នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៧ សោ ភឹម បានរាយការណ៍ថា កងទ័ពកម្ពុជាប្រជាធិបតេយ្យបានរុញច្រានយ៉ាងជោគជ័យចំពោះការវាយចូលធំៗមកលើគោលដៅមួយចំនួនក្នុងឃុំសំរោង(ស្រុកចន្ទ្រា តំបន់២៣) និងឃុំបន្ទាយក្រាំង(ស្រុកកំពង់រោទិ៍ តំបន់២៣)។

(៥) នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ មានទូរលេខមួយបានបង្ហាញថា កងទ័ពបដិវត្តន៍កម្ពុជា បានបោសសម្អាតកងទ័ព ស.ស.វ ពីទីតាំងមួយចំនួន ក្នុងតំបន់២៣ ហើយបានរាយការណ៍ផងដែរថា "ផ្ទះ និងជំរំរបស់ខ្មាំងចំនួន៩៤កន្លែង ត្រូវបានដុតបំផ្លាញ"។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៧៧ លទ្ធផលនៃប្រតិបត្តិការណ៍ដែលបានធ្វើនៅថ្ងៃទី១៦ និងថ្ងៃទី១៧ ខែវិច្ឆិកា បានរាយការណ៍ថា មូលដ្ឋានទ័ព ស.ស.វ មួយចំនួនត្រូវបានបំផ្លាញ។

៦១- ដោយពឹងផ្អែកទៅលើប្រភពពីភ្នាក់ងារសម្ងាត់ ប្រព័ន្ធសារព័ត៌មានអន្តរជាតិ បានរាយការណ៍ថា មានពេលខ្លះនៅខែវិច្ឆិកា ឆ្នាំ១៩៧៧ កងទ័ពកម្ពុជាប្រជាធិបតេយ្យបាន "ធ្វើការវាយប្រហារជាទ្រង់ទ្រាយធំ" មួយទៀត ទៅក្នុងខេត្តតៃនិញរបស់ប្រទេសវៀតណាម ដោយបានបណ្តាលឲ្យជនស៊ីវិល និងទាហានប្រមាណ២០០០នាក់ ស្លាប់បាត់បង់ជីវិត ឬរងរបួស។ នៅដើមខែធ្នូ ឆ្នាំ១៩៧៧ ប្រទេសវៀតណាមបានធ្វើការវាយប្រហារបកវិញទៅក្នុងខេត្តស្វាយរៀង នៅចំណុចចំពុះទា ដោយប្រើរថពាសដែកធុនធ្ងន់ និងដណ្តើមបួនកងពលពីកងទ័ពកម្ពុជា។ សោ ភឹម និងមេបញ្ជាការកងទ័ពបដិវត្តន៍កម្ពុជា បានរាយការណ៍ជាទៀងទាត់ទៅមជ្ឈិមបក្ស អំពីការវាយលុកចូលជាទ្រង់ទ្រាយធំដោយកងទ័ព ស.ស.វ និងការប៉ុនប៉ងរបស់កងទ័ពបដិវត្តន៍កម្ពុជាក្នុងការដណ្តើមយកវិញនូវទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ៖

(១) នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ មានទូរលេខមួយបានផ្តល់ព័ត៌មានដល់មជ្ឈិមបក្សថា កងទ័ព ស.ស.វ បានវាយចូលចម្ងាយ២០គីឡូម៉ែត្រ ទៅក្នុងទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ តាមបណ្តោយផ្លូវជាតិលេខ១។ ពួកគេក៏បានវាយប្រហារទៅលើទីតាំងនានាឆ្ពោះទៅភាគខាងជើង និងខាងត្បូងផ្លូវជាតិលេខ១ ដោយអង្គភាពរបស់កងទ័ពបដិវត្តន៍កម្ពុជាត្រូវបង្ខំចិត្តដកថយ។

(២) នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៧ មានទូរលេខមួយផ្ញើទៅមជ្ឈិមបក្ស ដោយចង្អុលបង្ហាញបន្ថែមទៀតអំពីកម្រិតនៃការវាយចូលមក ដោយកងពលនានានៃកងទ័ពបដិវត្តន៍កម្ពុជាដែលប្រចាំការនៅភូមិភាគបូព៌ាកំពុងលំបាកក្នុងការរក្សាទីតាំង ហើយ សោ ភឹម ត្រូវបង្ខំចិត្តអំពាវនាវសុំកងទ័ពបន្ថែម។

(៣) នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ សោ ភឹម រាយការណ៍ថា នៅពេលដែលកងទ័ពបដិវត្តន៍កម្ពុជាបាត់បង់ទីតាំងមួយចំនួន កងទ័ពបានវាយទៅខ្សែត្រៀមខាងក្រោយនៃទីតាំងរបស់កងទ័ព ស.ស.វ ដែលជាលទ្ធផល មួយកងវរសេនាតូច "ត្រូវបានកំទេចទាំងស្រុង"។

(៤) នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៧ មជ្ឈិមបក្សបានទទួលព័ត៌មានពីការបាត់បង់ទីរួមខេត្តស្វាយរៀង និងទឹកដីបន្ថែមទៀតនៅតំបន់ចំពុះទាទាំងមូល ដែលស្ថិតក្នុងកណ្តាប់ដៃរបស់កងទ័ព ស.ស.វ។ កងទ័ពបដិវត្តន៍កម្ពុជាបានរាយការណ៍ពីជ័យជំនះមួយចំនួននៅក្នុងការវាយបក និងការត្រៀមកងទ័ព "នៅថ្នាក់ភូមិភាគ តំបន់ និង ស្រុក"។ ត្រឹមពាក់កណ្តាលខែធ្នូ សារព័ត៌មានអន្តរជាតិបានរាយការណ៍ថា កងទ័ពវៀតណាមបានគ្រប់គ្រងទាំងស្រុងទៅលើតំបន់នោះ ដែលជាចំណុចមួយក្បែរនឹងទីរួមខេត្តព្រៃវែង។

(៥) លទ្ធផលនៃសកម្មភាពនានានៅក្នុងតំបន់២៤ ក៏ត្រូវបានរាយការណ៍ផងដែរនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៧ ដោយបង្ហាញថា កងទ័ពកម្ពុជាប្រជាធិបតេយ្យបានឆ្លងពីរគីឡូម៉ែត្រទៅក្នុងទឹកដីវៀតណាម ដើម្បីដេញតាមកងទ័ព ស.ស.វ ដែលបានដកថយ។

(៦) នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៧ កងទ័ពបដិវត្តន៍កម្ពុជាបានរាយការណ៍ថា ខ្លួនបានទទួលជ័យជំនះទៅលើកងទ័ព ស.ស.វ នៅក្នុងតំបន់នានាភាគខាងជើងទីរួមខេត្តស្វាយរៀង និងទៅភាគខាងត្បូងផ្លូវជាតិលេខ១។

៦២- ស្របពេលដែលមានការប្រឈមមុខដាក់គ្នាធំៗនៅតំបន់ចំពុះទា ក៏មានការប្រយុទ្ធគ្នាយ៉ាងតឹងតែងនៅក្នុងតំបន់ទៅភាគខាងត្បូងតំបន់ "ថ្គាសទ្ធច" (និងទៅភាគខាងជើងជំពុះទា) នៅក្នុងតំបន់២០ នៃភូមិភាគបូព៌ា៖

(១) មានការរាយការណ៍ថា នៅថ្ងៃទី២៦ និងទី២៧ ខែតុលា ឆ្នាំ១៩៧៧ មានការប្រយុទ្ធគ្នានៅច្រករបៀងតាមបណ្តោយផ្លូវលេខ២២ និងតាមបណ្តោយផ្លូវជាតិលេខ៧ ក្នុងខេត្តកំពង់ចាម ភាគអាគ្នេយ៍នៃក្រែក។

(២) នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៧ មានការរាយការណ៍បន្ថែមទៀតស្តីពីការប្រយុទ្ធគ្នាដោយបានពណ៌នាពីជ័យជំនះទៅលើទីតាំងឈរជើងរបស់កងទ័ព ស.ស.វ នៅតាមបណ្តោយផ្លូវលេខ២២។ ដោយអនុវត្តតាមសេចក្តីណែនាំរបស់មជ្ឈិមបក្ស កងទ័ពបដិវត្តន៍កម្ពុជាបានប្រយុទ្ធបន្ថែមទៀតនៅតាមបណ្តោយផ្លូវលេខ២២ នៅបរិវេណត្រពាំងផ្លុង រហូតដល់ដើមខែវិច្ឆិកា ឆ្នាំ១៩៧៧។

(៣) នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ការប៉ះទង្គិចគ្នាមួយចំនួនបានកើតឡើងនៅតាមច្រករបៀងបណ្តោយផ្លូវលេខ២២ ដោយកងទ័ព ស.ស.វ ទទួលរងនូវការស្លាប់ និងរបួសជាច្រើន យានជំនិះសម្រាប់ចម្បាំងត្រូវបានខូចខាតជាដំណំ ហើយអាវុធ និងគ្រាប់រំសេវរបស់ខ្លួនមួយចំនួន ក៏ត្រូវបានរឹបអូស។

(៤) នៅត្រឹមដើមខែធ្នូ ឆ្នាំ១៩៧៧ មជ្ឈិមបក្សបានទទួលសេចក្តីរាយការណ៍អំពីបញ្ហានៅសមរភូមិនេះដោយមានការបាត់បង់ទឹកដីនៅតំបន់ចំពុះទា។ នៅថ្ងៃទី៧ ខែធ្នូ មានទូរ

លេខមួយ បានបង្ហាញថាការវាយប្រហាររបស់កងទ័ព ស.ស.វ បានកំទេចខ្សែការពាររបស់កម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃទី៩ ខែធ្នូ កម្ពុជាប្រជាធិបតេយ្យក៏ បានរត់ ចោលសមរភូមិមួយចំនួននៅតាមបណ្តោយផ្លូវលេខ២២។

(៥) នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៧៧ មានរបាយការណ៍មួយផ្ញើមកមជ្ឈិមបក្សដោយបញ្ជាក់ពីការខូចខាតនៅក្នុងសមរភូមិតាមបណ្តោយផ្លូវលេខ២២។ ការបាត់បង់ទឹកដីបន្ថែមទៀតត្រូវបានរាយការណ៍នៅថ្ងៃទី១២ ខែធ្នូ ខណៈដែលមានទូរលេខមួយចុះថ្ងៃទី១៣ ខែធ្នូ បានផ្តល់យោបល់ថា ការប្រយុទ្ធគ្នាបាននៅស្ងៀមទៅវិញ ដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅគ្រប់គ្រងខ្សែត្រៀមរបស់ខ្លួនបាន។

(៦) នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧ កងទ័ព ស.ស.វ បានជ្រៀតចូលផ្ទល់បំបែកខាងជើងផ្លូវជាតិលេខ៧ និងផ្លូវលេខ២២។ នៅក្នុងដំណាក់កាលនេះ កងទ័ព ស.ស.វ បានកំទេចទីតាំងការពារជាច្រើនរបស់កម្ពុជាប្រជាធិបតេយ្យនៅម្តុំផ្លូវជាតិលេខ៧ និងផ្លូវលេខ២២។ ខណៈដែលកងទ័ពបដិវត្តន៍កម្ពុជា រៀបចំផែនការវាយបកវិញ គេក៏ត្រូវការសេចក្តីណែនាំពីមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាដែរ។

(៧) ពេលនោះមជ្ឈិមបក្សបានទទួលព័ត៌មានពីការបាត់បង់ចំការកៅស៊ូក្រេក និង មេមត់នៅថ្ងៃទី២៣ ខែធ្នូ ដែលបណ្តាលឲ្យមានការច្របូកច្របល់ក្នុងជួរកងទ័ពកម្ពុជា។ ចំពោះចំណុចលម្អិតបន្ថែមទៀត រួមមានការពណ៌នាពីការខូចខាតតាមភូមិរបស់កម្ពុជា

ប្រជាធិបតេយ្យ មានសរសេរនៅក្នុងទូរលេខមួយដែលបង្ហាញថា អ្នកសរសេរត្រូវបានកាត់ផ្ដាច់ចេញពី សោ ភឹម។

(៨) នៅក្នុងដំណាក់កាលនេះ កងទ័ពកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្ខំឱ្យដកថយចេញពីទីតាំងការពាររបស់ខ្លួន និងបន្តទទួលបរាជ័យនៅក្នុងការវាយបកទៅកងទ័ព ស.ស.វ ពួកគេក៏បានរាយការណ៍ថា កងទ័ព និងកងឈ្លបនៅតាមមូលដ្ឋាន ត្រូវបានកំទេចខ្ចាត់ខ្ចាយអស់។

(៩) នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៧ មានការផ្ដល់ព័ត៌មានថ្មីៗទាក់ទងនឹងទីតាំងរបស់កងទ័ព ស.ស.វ នៅជុំវិញចំការកៅស៊ូ។ នៅថ្ងៃទី៣១ ខែធ្នូ មានសំណើមួយផ្ញើមកមជ្ឈិមបក្សសុំការធ្វើអន្តរាគមន៍ផ្នែកយោធានៅតាមតំបន់ពិសេសៗមួយចំនួន។

៦៣- នៅចុងឆ្នាំ១៩៧៧ កងកម្លាំងប្រដាប់អាវុធពីរក្រុម បានប្រយុទ្ធនៅតាមបណ្ដោយព្រំដែនក្នុងតំបន់ស្វយ័ត៥០៥ ក្នុងខេត្តក្រចេះ៖

(១) របាយការណ៍ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៧ បានបង្ហាញថា មានការបង្កើនកម្លាំងកងទ័ព ស.ស.វ នៅខែតុលា ដែលនាំឱ្យមានការវាយចូលរបស់កងទ័ពវៀតណាមនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧។

(២) នៅក្នុងទូរលេខចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៧ បានរាយការណ៍ថា មានការប្រយុទ្ធតិចតួចរវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ ។

(៣) នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧ កងទ័ពបដិវត្តន៍កម្ពុជា បានជូនដំណឹងទៅមជ្ឈិមបក្សអំពីសកម្មភាពនៅតាមបណ្តោយផ្លូវលេខ១៤ ដែលជាកន្លែងដែលមានការអះអាងថា ស.ស.វ បានប្រើរថពាសដែក និងបានស្នើឲ្យបញ្ជូនបន្ថែមនូវកាំភ្លើងត្បាល់ និងគ្រាប់រ៉ុកកែត។ នៅថ្ងៃដដែល មានរបាយការណ៍មួយទៀត បង្ហាញពីតួលេខនៃការស្លាប់ និងរបួស និងតម្រូវការគ្រាប់រំសេវមួយចំនួនបន្ថែមទៀត។

៦៤- គិតមកត្រឹមខែធ្នូ ឆ្នាំ១៩៧៧ សារព័ត៌មានអន្តរជាតិបានរាយការណ៍អំពី "ការប្រយុទ្ធគ្នាជាទ្រង់ទ្រាយធំ"រវាងកម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ ដោយមានការលើកឡើងពីការប្រើយន្តហោះចម្បាំង និងកាំភ្លើងធំ ហើយភាគីទាំងពីរមានការស្លាប់ និងរបួសជាច្រើន។ បើទោះជាក្នុងអំឡុងពេលនោះ កងទ័ពកម្ពុជាបន្តការតស៊ូ ការវាយចូលជាទ្រង់ទ្រាយធំរបស់ ស.ស.វ នៅខែធ្នូ ឆ្នាំ១៩៧៧ បណ្តាលឲ្យមានការច្របូកច្របល់នៅក្នុងកងពលនានានៃកងទ័ពបដិវត្តន៍កម្ពុជា ដោយ អង្គភាពរបស់ពួកគេបានរត់ចោលទីតាំង។

៦៥- នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យបានប្រកាសជាសាធារណៈនូវការផ្តាច់ចំណងទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម ដោយសារតែអ្វីដែល កម្ពុជាហៅថា សកម្មភាពឈ្លានពាន និងការចូលលុកលុយរបស់ប្រទេសវៀតណាម។ នៅថ្ងៃដដែលនោះ ស.ស.វ បានចេញសេចក្តីឆ្លើយតបវិញ តាមរយៈតំណាងអចិន្ត្រៃយ៍របស់ខ្លួននៅអង្គការសហប្រជាជាតិ ដោយបានចោទប្រកាន់កម្ពុជាប្រជាធិបតេយ្យ ថាជាអ្នកឈ្លានពាន។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានចេញសេចក្តីថ្លែងការណ៍មួយបន្ថែមទៀត នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨។ បើទោះជាមិនមានការប្រកាសសង្គ្រាមជាផ្លូវការរវាងភាគីទាំងពីរក្តី

ក៏មានការអះអាងថា មានការប្រកាសសង្គ្រាមមួយដែលបានធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលទំនាក់ទំនងការទូតត្រូវបានកាត់ផ្ដាច់។

៦៦- ក្រៅពីរបាយការណ៍យោធា និងទូរលេខរបស់បក្សកុម្មុយនីស្តកម្ពុជា កម្រិតនៃភ័ស្តុតាង និងទំហំនៃការប្រយុទ្ធគ្នារវាងប្រទេសទាំងពីរនៅតាមតំបន់ខាងលើក្នុងឆ្នាំ១៩៧៧ ក៏មាននៅក្នុងការផ្តល់សក្ខីកម្មរបស់ ណាយ៉ាន់ ចាន់ដា (Nayan Chanda) ក្នុងសវនាការក្នុងសំណុំរឿង០០១ និងនៅក្នុងចម្លើយសាក្សីនានាដែលបានផ្តល់ក្នុងពេលស៊ើបអង្កេតផងដែរ។

## ឆ្នាំ១៩៧៨-១៩៧៩

### ទិដ្ឋភាពទូទៅ

៦៧- របាយការណ៍សារព័ត៌មានចំនួន២៧៤ (ដែលបានបោះពុម្ពផ្សាយនៅចន្លោះខែមករា ឆ្នាំ១៩៧៨ និង ខែមករា ឆ្នាំ១៩៧៩) និងរបាយការណ៍ និងទូរលេខជាច្រើនរបស់រដ្ឋាភិបាល និងយោធាកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលនោះ បានបញ្ជាក់ពីការបន្តជម្លោះក្នុងអំឡុងឆ្នាំ១៩៧៨។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានចេញសេចក្តីថ្លែងការណ៍មួយតាមរយៈតំណាងអចិន្ត្រៃយ៍របស់ខ្លួនប្រចាំអង្គការសហប្រជាជាតិ ដោយអំពាវនាវសុំការគាំទ្រពីបណ្តាប្រទេសជាមិត្ត និងបានលើកឡើងថាមានការប្រឈមមុខដាក់គ្នាមួយចំនួនបានកើតឡើងរវាងកងទ័ពវៀតណាម និងកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៧៧ នៅស្ទើរតែគ្រប់កន្លែង តាមបណ្តោយព្រំដែនរួមរវាងប្រទេសទាំងពីរ។ នៅថ្ងៃដដែលនោះ ក្រសួងឃោសនាការ និងព័ត៌មានរបស់កម្ពុជាប្រជាធិបតេយ្យ បានចេញសេចក្តីប្រកាសព័ត៌មានមួយដែលបានគូសបញ្ជាក់ពីការចោទប្រកាន់របស់កម្ពុជាប្រជាធិបតេយ្យ ក្នុងការជ្រៀតចូលជា

ច្រើនអន្លើរបស់កងទ័ព ស.ស.វ ទៅក្នុងទឹកដីប្រទេសកម្ពុជាពីខែកញ្ញា ឆ្នាំ១៩៧៧។ តាមសេចក្ដីប្រកាសព័ត៌មាននោះ វៀតណាមបានលុកលុយចូលមកជ្រៅទៅក្នុងទឹកដីប្រទេសកម្ពុជា នៅតាមតំបន់នានា រួមមាន៖

(១) រហូតដល់៣០គីឡូម៉ែត្រ តាមបណ្ដោយផ្លូវជាតិលេខ៧ ដោយកាន់កាប់តំបន់ដែលមានប្រវែង២០គីឡូម៉ែត្រនៅក្នុងភូមិភាគបូព៌ា។

(២) ចម្ងាយប្រមាណ៣០គីឡូម៉ែត្រតាមបណ្ដោយផ្លូវជាតិលេខ១ មកដល់ចម្ងាយ១០គីឡូម៉ែត្រខាងកើតទីរួមខេត្តស្វាយរៀង រួមទាំងតាមបណ្ដោយផ្លូវជាតិលេខ១៣ មកដល់ចម្ងាយ១០ គីឡូម៉ែត្រខាងជើងទីរួមខេត្តស្វាយរៀង (ដូចបានកត់សម្គាល់មកខាងលើរួចហើយ គឺថា សោ ភឹម ជាអ្នករាយការណ៍ក្នុងខែធ្នូ ដែលថាទីរួមខេត្តនេះ ត្រូវបានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់វៀតណាម)។

(៣) ចម្ងាយប្រមាណ១០ ១៥ និង៣០គីឡូម៉ែត្រ នៅតាមតំបន់ផ្សេងៗនៃខេត្តតាកែវ។

(៤) ប្រហែល១៣គីឡូម៉ែត្រ ក្នុងខេត្តកំពត។

៦៨- នៅចុងខែធ្នូ ឆ្នាំ១៩៧៧ និងដើមខែមករា ឆ្នាំ១៩៧៨ មានទីភ្នាក់ងារសារព័ត៌មានអន្តរជាតិ និងកាសែតមួយចំនួន បានផ្ដោតទៅលើព្រឹត្តិការណ៍នៃការចូលលុកលុយ នៅតំបន់ខ្លះនៃប្រទេសកម្ពុជាដោយកងទ័ពវៀតណាម និងបានផ្ដល់ព័ត៌មានលម្អិតពីទំហំ និងវិសាលភាពនៃជម្លោះនេះ។ នៅពាក់កណ្ដាលដំបូងក្នុងខែមករា ឆ្នាំ១៩៧៨ សារព័ត៌មានអន្តរជាតិ ក៏បានរាយការណ៍ពីលទ្ធភាពនៃការចរចារវាងភាគីទាំងពីរ ដោយប្រទេសវៀតណាម បង្ហាញពីចេតនាខ្លះចង់ចរចា

ខណៈដែលកម្ពុជាប្រជាធិបតេយ្យដំបូង បដិសេធមិនចូលរួមក្នុងការចរចាតាមរូបភាពណាក៏ដោយ ទើបតែពេលក្រោយមកទៀតប៉ុណ្ណោះ ដែលកម្ពុជាបានបន្ទន់គោលជំហរមកវិញ។

៦៩- នៅទីបញ្ចប់ មិនមានដំណោះស្រាយសន្តិភាពចំពោះជម្លោះនេះទេ ហើយឆ្នាំ១៩៧៨ ត្រូវបានបញ្ចប់ទៅដោយការលុកលុយជាទ្រង់ទ្រាយធំរបស់កងទ័ព ស.ស.វ មកលើកម្ពុជាប្រជាធិបតេយ្យ។ តាមពិតទៅ នៅត្រឹមខែកុម្ភៈ ឆ្នាំ១៩៧៨ វៀតណាមបានរៀបផែនការផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ហើយការប្រយុទ្ធគ្នាបន្ថែមទៀតរវាងប្រទេសទាំងពីរ នៅតែបន្ត។

៧០- សន្ទរកថានៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ ដែលបានថ្លែងដោយ ប៉ុល ពត (ដែលត្រូវបានបោះពុម្ពផ្សាយនៅខែកុម្ភៈ ឆ្នាំ១៩៧៨ ក្នុង"ទស្សនាវដ្តីទង់បដិវត្ត" ដោយបានអះអាងថា ជម្លោះជាមួយ ស.ស.វ បានកើតមានតាំងពីខែឧសភា ឆ្នាំ១៩៧៥មកម្ល៉េះ ដោយចាប់ផ្តើមពីការប៉ះទង្គិចគ្នា មួយចំនួនក្នុងខេត្តស្វាយរៀង មកដល់ការប្រយុទ្ធជាទ្រង់ទ្រាយធំ ពីខេត្តកំពតនៅភាគខាងត្បូង រហូតដល់ខេត្តរតនគិរីនៅភាគឦសាន ពោលគឺនៅតាមបណ្តោយព្រំដែនរួម របស់កម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ តែម្តង។ គាត់បានអះអាងថា "កងសន្តិសុខការពារព្រំដែន កងតំបន់ និងកងយុទ្ធភូមិភាគឃ្លួនទាំង៣ប្រភេទនេះ បានចូលមកវ៉ៃយើងច្រើនដង ច្រើនគ្រាណាស់ តាំងពីខែឧសភា ឆ្នាំ១៩៧៥មក ពិសេសក្នុងឆ្នាំ១៩៧៧" ជាចុងក្រោយបាន "ចូលឈ្លានពានធំមកលើទឹកដីកម្ពុជានៅអំឡុងខែវិច្ឆិកា និងខែធ្នូ១៩៧៧ ហើយនិងនៅអំឡុងខែមករា ១៩៧៨"។ ស្របទៅនឹងភ័ស្តុតាងដែលបានពិនិត្យខាងលើ ប៉ុល ពត ក៏បានទទួលស្គាល់ថា វៀតណាមបានវាយលុកចូលជ្រៅ "រាប់គីឡូម៉ែត្រ ហើយនៅកន្លែងខ្លះរាប់សិបគីឡូម៉ែត្រក្នុងដីរបស់[កម្ពុជា]"។

៧១- នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) បានបញ្ជូនសារទំនាក់ទំនងដូចគ្នាទៅរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ ដោយបានសំដែងក្ដីសង្ឃឹមថា ភាគីទាំងពីរនឹងគោរពវិធាននានានៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ។ ICRC បានបញ្ជូនសារទំនាក់ទំនងបន្ថែមទៀតទៅឲ្យ ស.ស.វ និងកម្ពុជាប្រជាធិបតេយ្យនៅចុងខែមករា ដោយស្នើសុំព័ត៌មានស្ដីពីឈ្លើយសឹក និងសុំការអនុញ្ញាតមកពិនិត្យមើលឈ្លើយសឹកទាំងនោះដែលភាគីទាំងពីរបានចាប់ខ្លួន។ មកត្រឹមពាក់កណ្ដាលខែឧសភា ឆ្នាំ១៩៧៨ ICRC អាចចូលមកពិនិត្យមើល ឈ្លើយសឹកកម្ពុជាចំនួន២០៥ នាក់ដែលត្រូវបានឃុំឃាំងនៅក្នុងជំរំ Yuan Loc ក្នុងប្រទេសវៀតណាម។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មិនបានឆ្លើយតបនឹងសំណើរបស់ ICRC ទេ។

## ការប្រឈមមុខដាក់គ្នាបន្ថែមទៀត និងការវាយលុកចុងក្រោយរបស់ប្រទេសវៀតណាម

៧២- នៅពាក់កណ្ដាលដំបូងនៃខែមករា ឆ្នាំ១៩៧៨ ទោះបីប្រភពព័ត៌មានអន្តរជាតិមួយចំនួនបានរាយការណ៍ថា កងទ័ព ស.ស.វ បានដកខ្លួនពីការប្រឈមមុខ ជាមួយកងទ័ពបដិវត្តន៍កម្ពុជា និងបានដកចេញពីទឹកដីកម្ពុជាប្រជាធិបតេយ្យ ក៏ដោយ តែការប្រយុទ្ធគ្នានៅតែបន្តទៀតពេញមួយឆ្នាំនោះ។ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ មន្ទីរ៨៧០ បានចេញសេចក្ដីណែនាំរបស់មជ្ឈិមបក្សទាក់ទងនឹងបទបញ្ជាចំពោះជម្លោះ រួមទាំងការប្រើប្រាស់យុទ្ធនាការជាទ្រង់ទ្រាយធំ និងការវាយប្រយុទ្ធតូចៗជាលក្ខណៈទ័ពព្រៃផង។ នៅដើមឆ្នាំ១៩៧៨ កងពលមួយចំនួនត្រូវបានផ្លាស់ប្ដូរទីតាំងពីភូមិភាគនិរតីទៅភូមិភាគបូព៌ា ដើម្បីធ្វើការប្រយុទ្ធប្រឆាំងជាមួយពួកវៀតណាម។

៧៣- នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ មជ្ឈិមបក្សបានទទួលព័ត៌មានពីការប៉ះទង្គិចនានាជាច្រើន ដែលបានកើតឡើងក្នុងភូមិភាគភ្លៀសាន តាំងពីពាក់កណ្ដាលរហូតដល់ចុងខែធ្នូ ឆ្នាំ១៩៧៧ (ក្នុងនោះទាហានវៀតណាមមួយចំនួនត្រូវបានសម្លាប់ នៅពេលនោះមានទាហានម្នាក់យ៉ាងតិច ត្រូវបានចាប់ខ្លួន និងសួរចម្លើយ) រួមទាំងការរៀបចំប្រយុទ្ធបន្ថែមទៀតនៅខែមករា។ នៅថ្ងៃដដែលនោះកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅខេត្តមណ្ឌលគិរី តំបន់ស្វយ័ត១០៥ បានរាយការណ៍អំពីការចាប់ខ្លួន និងការសម្លាប់មនុស្ស៩នាក់ ដែលត្រូវសង្ស័យថាជាគិញវៀតណាម រួមទាំងការបន្តការវាយប្រយុទ្ធទៅលើកងទ័ព ស.ស.វ ដែលឈរជើងនៅ ដាក់ដាំ។

៧៤- នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ ដដែល កងទ័ពបដិវត្តន៍កម្ពុជាក៏បានរាយការណ៍ពីការវាយបកវិញដែលមិនបានទទួលជោគជ័យទៅលើកងទ័ព ស.ស.វ នៅតាមបណ្ដោយផ្លូវជាតិលេខ៧។ របាយការណ៍ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨ មួយ ដែលពិពណ៌នាពីការប្រឈមមុខបន្ថែមទៀត និងបានបញ្ជាក់ពីតំបន់ និងទ្រព្យសម្បត្តិនៅភូមិភាគបូព៌ាដែល ស.ស.វ បានកាន់កាប់ និងបានបំផ្លាញ។ របាយការណ៍មួយទៀតនៅថ្ងៃដដែលនោះ ក៏បានពិពណ៌នាពីលទ្ធផលនៃសកម្មភាពវាយប្រហារមួយចំនួនដែលបានកើតឡើងនៅពេលប៉ុន្មានថ្ងៃកន្លងទៅ និងផែនការវាយប្រហារនាពេលខាងមុខ។

៧៥- នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៨ សោ ភឹម បានរាយការណ៍ពីជោគជ័យមួយចំនួននៅភូមិភាគបូព៌ា ដោយបង្ហាញថា កងទ័ពកម្ពុជាប្រជាធិបតេយ្យ បានវាយចូលចម្ងាយពីរគីឡូម៉ែត្រទៅក្នុង ស.ស.វ ដោយក្នុងចំណោមសកម្មភាពផ្សេងៗបានបំផ្លាញបន្ទាយយោធា និងសម្លាប់ជនស៊ីវិលផងដែរ។ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៧៨ សោ ភឹម បានរាយការណ៍ទៅមជ្ឈិមបក្សថា

កងទ័ព ស.ស.វ បានដកថយចេញពីទីតាំងឈរជើងរបស់ខ្លួន តែត្រូវបានកងទ័ពកម្ពុជាប្រជាធិបតេយ្យដេញតាមវាយប្រហារ។ កងទ័ពកម្ពុជាប្រជាធិបតេយ្យបានរាយការណ៍ពីការវាយចូលចម្ងាយ៥គីឡូម៉ែត្រទៅក្នុងប្រទេសវៀតណាមនៅមុខព្រួញព្រៃចំការ និងចូលចម្ងាយ៤ទៅ៥គីឡូម៉ែត្រនៅមុខព្រួញកំពង់រោទិ៍។

៧៦- នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៨ ភីម បានរាយការណ៍បន្ថែមពីការដណ្ដើមបានទឹកដីក្នុងភូមិភាគបូព៌ា។ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៨ គាត់បានជូនដំណឹងទៅមជ្ឈិមបក្សពីការវាយតបដ៏ខ្លាំងរបស់កងកម្លាំង ស.ស.វ ដែលត្រូវគេចោទថាបានប្រើប្រាស់ "គ្រាប់បែកដៃផ្សែងពុល" ក្នុងការប្រឈមមុខគ្នានៅភាគខាងត្បូងនៃ កំ ភរ(Kam Phor)។

៧៧- នៅក្នុងព័ត៌មានស្ដីពីសភាពការណ៍សមរភូមិក្នុងខែមករា ឆ្នាំ១៩៧៨ សារព័ត៌មានអន្តរជាតិបានរាយការណ៍ថា ក្នុងចន្លោះពីថ្ងៃទី៤ ដល់ថ្ងៃទី១១ ខែមករា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានធ្វើការវាយប្រហារតបតទៅលើកងកម្លាំង ស.ស.វ ក្នុងតំបន់ដែលស្ថិតនៅចន្លោះពីខេត្ត Kontum នៅភាគខាងជើង ទៅខេត្ត An Giang នៅភាគខាងត្បូង ដោយមានកងពលធំចំនួនពីរ កំពុងជាប់ដៃប្រយុទ្ធនៅក្នុងការវាយប្រហារទៅលើខេត្ត An Giang តែមួយ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ សារព័ត៌មាន Hanoi Home Service បានរាយការណ៍ពីការវាយប្រហាររបស់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យទៅលើតំបន់ Ha Tien និងភូមិមួយចំនួននៅជិតនោះ ស្ថិតក្នុងខេត្ត Kien Giang។

៧៨- ក្រោយពីមានការដកថយរបស់កងកម្លាំងវៀតណាម ចេញពីខេត្តស្វាយរៀង ក្នុងខែមករា ឆ្នាំ១៩៧៨ ប៉ុល ពត បានចុះទៅត្រួតពិនិត្យទីបញ្ជាការរបស់ សោ ភីម នៅ ស្ទួង ហើយគាត់បាន

ឡើងថ្លែងសន្ទរកថា ដែលក្នុងនោះគាត់បានអំពាវនាវឲ្យប្រើគ្រប់លទ្ធភាពទាំងអស់ ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងវៀតណាម។

៧៩- នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ សុន សេន (សរសេរក្នុងនាមជាបង៤៧) បានផ្ញើទូរលេខមួយច្បាប់ទៅមជ្ឈិមបក្ស ដើម្បីរាយការណ៍ពីការបង្កើនកម្លាំងរបស់ ស.ស.វ នៅតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងភូមិភាគបូព៌ា ក៏ដូចជាការហោះហើរយន្តហោះរបស់ ស.ស.វ លើផ្លូវជាតិលេខ១៣ ស្ថិតក្នុងខេត្តស្វាយរៀង។ គាត់ក៏បានរាយការណ៍ផងដែរ ពីការចាប់ខ្លួន "ពួកយួនចំនួនពីរក្បាល អាយុ១៧ម្នាក់ និងអាយុ២៧ឆ្នាំម្នាក់" ដែលត្រូវគេបញ្ជូនទៅមន្ទីរស-២១។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ គាត់បានរាយការណ៍ពីការវាយប្រយុទ្ធរបស់កងទ័ពថ្មើរជើង និងរថក្រោះរបស់ ស.ស.វ ទៅលើកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការបាញ់ផ្លោងដោយកាំភ្លើងធំទៅលើតំបន់នានាជុំវិញ Tay Ninh ក្នុងប្រទេសវៀតណាម។

៨០- នៅមានការប្រយុទ្ធគ្នាជាច្រើនទៀត បានកើតមានរវាងកងកម្លាំងប្រដាប់អាវុធទាំងពីរ ដែលស្ថិតក្នុងទីតាំងជាច្រើនក្នុងអំឡុងខែមីនា ឆ្នាំ១៩៧៨៖

(១) នៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨ ផ្នែកនយោបាយនៃកងពលធំ១១៧ របស់កងទ័ពបដិវត្តន៍កម្ពុជាក្នុងតំបន់ស្វយ័ត៥០៥ នៅខេត្តក្រចេះ បានបញ្ជូនព័ត៌មានមកមជ្ឈិមបក្សពីលទ្ធផលនៃការវាយប្រហារចូលចម្ងាយ១គីឡូម៉ែតទៅក្នុង ស.ស.វ។ កម្លាំង ស.ស.វ ត្រូវបានគេរាយការណ៍ថា មានរបួស និងស្លាប់ចំនួន៩៨នាក់ ចាប់បានម្នាក់ ហើយកងពលធំ១១៧ ស្លាប់ចំនួនប្រាំពីរនាក់ និងមានរបួស២៩នាក់។

(២) នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ភូមិភាគពាយ័ព្យ បានរាយការណ៍ពីការប្រឈមមុខគ្នាជាមួយនឹងកងកម្លាំង ស.ស.វ ដោយបានសម្លាប់ពួកវៀតណាមចំនួន២៤នាក់។

(៣) នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ [redacted] បានរាយការណ៍ថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានពន្លិចទូករបស់ពួកវៀតណាមដែលស្ថិតក្នុងបរិវេណកោះខ្យង និងបានវាយប្រហារទៅលើទូកពួកវៀតណាមចំនួនពីរគ្រឿង ចាប់បានមនុស្សចំនួន៧៤នាក់ និងដឹកជញ្ជូនពួកទាំងនោះមកដីគោក។

៨១- កងទ័ពកម្ពុជាប្រជាធិបតេយ្យ បានរាយការណ៍សម្រាប់ខែមេសា និងខែឧសភា ឆ្នាំ១៩៧៨ ដោយមានរៀបរាប់ពីការប្រឈមមុខរវាងកងទ័ពទាំងពីរជាច្រើនលើក៖

(១) នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៨ កងពលធំ៨០១ បានរាយការណ៍ទៅ សុន សេន និងមជ្ឈិមបក្ស អំពីការបាញ់តបតជាមួយកងទ័ព ស.ស.វ ដោយប្រើកាំភ្លើងធំ ក្នុងតំបន់ផ្លូវលេខ១៩។ របាយការណ៍ដែលបានដាក់ជូននៅថ្ងៃទី២៥ ខែមេសា ឆ្នាំ ១៩៧៨ បានបង្ហាញថា "សកម្មភាពប៉ះទង្គិចគ្នាកំពុងបន្ត" នៅក្នុងតំបន់។

(២) នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៨ តា ម៉ុក ជាលេខាភូមិភាគនិរតី បានផ្ដល់ដំណឹងដល់មជ្ឈិមបក្ស អំពីការព្យាយាមប៉ុនប៉ងវាយលុកលុយរបស់កងកម្លាំង ស.ស.វ ទៅក្នុងភូមិភាគនិរតី ត្រូវវាយច្រានចេញទៅវិញ ដោយបានសម្លាប់កងកម្លាំង ស.ស.វ ចំនួន១០០នាក់។ គាត់បានផ្ដល់ព័ត៌មានបន្ថែមទៀតថា តំបន់ដែលស្ថិតនៅចន្លោះទន្លេមេគង្គ និងទន្លេបាសាក់ ដែលលាតសន្ធឹងប្រវែងប្រាំមួយ ទៅប្រាំពីរគីឡូម៉ែតនោះ ត្រូវបានរំដោះ ហើយតំបន់ស្ថិតនៅភាគខាងត្បូងនៃភ្នំដារប្តី ក៏ត្រូវបានវាយសម្អាតផងដែរ។

(៣) នៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៨ សុន សេន បានរាយការណ៍ថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានវាយលុកចូលក្នុងខេត្ត Dong Thap ប្រទេសវៀតណាម ដែលនៅទីនោះ ពួកគេបានឆក់ប្លន់ និងដុតបំផ្លាញនៅក្នុងភូមិមួយចំនួន ស្ថិតក្នុងត្រពាំងព្រាម (Trapeang Peam) និងតឹង ចូវ(Than Chau)។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨ សុន សេន បានរាយការណ៍ពីការវាយលុករបស់កងកម្លាំង ស.ស.វ នៅភាគខាងជើងផ្លូវជាតិលេខ១ ខាងកើតទីរួមខេត្តស្វាយរៀង ដែលនៅទីនោះ មានការចូលរួមប្រយុទ្ធពីកងទ័ពថ្មើរជើង និងរថពាសដែកផងដែរ។

(៤) នៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៨ កែ ពក បានរាយកាណ៍ទៅមជ្ឈិមបក្សពីការវាយលុកដោយកងទ័ពថ្មើរជើងរបស់ ស.ស.វ មួយចំនួនតាមដងផ្លូវជាតិលេខ៧ ដែលត្រូវវាយរុញច្រានទៅវិញ ដោយមានការត្រៀមផែនការវាយបកវិញផង។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ គាត់បានរៀបរាប់លម្អិតពីសកម្មភាពវាយប្រហារនៅតាមច្រករបៀង ផ្លូវលេខ២២ របស់កងម្លាំងថ្មើរជើង និងកងកាំភ្លើងធំរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជា ការប្រយុទ្ធនៅភាគខាងកើតនៃតំបន់មេមត់ តាមបណ្តោយផ្លូវជាតិលេខ៧។ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨ កែ ពក បានរាយការណ៍ពី លទ្ធផលនៃការប្រយុទ្ធគ្នានៅច្រករបៀងផ្លូវលេខ២២ និងជិតស្រុកមេមត់ ដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យជាអ្នកដណ្តើមបានជ័យជម្នះ ព្រមទាំងបានរៀបចំការវាយតបតបន្ថែមទៀតផង។

(៥) នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៨ កែ ពក បានរាយការណ៍ទៅមជ្ឈិមបក្សពីការបន្តប្រយុទ្ធគ្នានៅតាមផ្លូវលេខ២២ នៅមុខព្រួញលេខ៧ ដោយមានការវាយលុក ដោយ

កងកម្លាំង ស.ស.វ នៅស្អំ(Sa-am)។ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៨ គាត់បានផ្តល់ព័ត៌មានលម្អិតបន្ថែមពាក់ព័ន្ធនឹងផ្លូវលេខ២២ សមរភូមិលេខ៧ ដោយមានការវាយប្រហាររបស់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យនៅតំបន់មេមត់។ ការវាយប្រហាររបស់កងទ័ពបដិវត្តន៍កម្ពុជាពីភូមិភាគកណ្តាល និងបូព៌ា ឆ្ពោះទៅស្អំ(Sa-am) ត្រូវបានរៀបផែនការទុកសម្រាប់អនុវត្តន៍នៅថ្ងៃបន្ទាប់។ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៧៨ កែ ពក បានផ្តល់ព័ត៌មានបន្ថែមដល់មជ្ឈិមបក្សអំពីស្ថានភាពនៃការតស៊ូប្រយុទ្ធនៅកំពង់រការ និងនៅឯតំបន់ស្ពានដែក។

៨២- ក្នុងការផ្សព្វផ្សាយមួយរបស់ Phnom Penh Home Service កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ បានបង្ហាញថា ការការពារព្រំដែនខាងកើតរបស់កម្ពុជាប្រជាធិបតេយ្យនាឆ្នាំកន្លងមកគឺជា “ការតស៊ូដ៏ស្វិតស្វាញខ្លាំងក្លា” ហើយនៅក្នុងអំឡុងរយៈពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ដល់ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ “ការប្រយុទ្ធគ្នាកើតមានជាបន្តបន្ទាប់ក្នុងសមរភូមិទ្រង់ទ្រាយតូច មធ្យម និងធំ”។

៨៣- នៅពាក់កណ្តាលឆ្នាំ១៩៧៨ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានវាយប្រយុទ្ធឆ្លងចូលទៅក្នុងព្រំដែន ស.ស.វ ពីស្រុករំដួល និងស្រុករមាសហែក ក្នុងតំបន់២៣។ របាយការណ៍ អំពីការវាយឆ្មក់ទាំងនេះ បានលើកឡើងពីអំពើសាហាវយង់ឃ្នងដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តឡើង។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ កងយោធាភូមិភាគនិរតីបានចូលរួមសហការជាមួយកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងភូមិភាគបូព៌ា ដើម្បីគាំទ្រការប្រយុទ្ធបន្តទៀត។

៨៤- នៅខែកញ្ញា ឆ្នាំ១៩៧៨ ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ បានបោះពុម្ពផ្សាយ "សៀវភៅខ្មៅៈ ការពិត និងភស្តុតាងនៃអំពើឈ្លានពាន និងភ្ជាប់យកទឹកដីកម្ពុជា ពីសំណាក់វៀតណាម"។ **អៀង សារី** បានចែកចាយសៀវភៅដែលបោះពុម្ពផ្សាយនោះ ក្នុងសន្និសីទសារព័ត៌មាននៅទីក្រុងម៉ានីល នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៨ ។

៨៥- នៅដើមខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំង ស.ស.វ បានបើកការវាយប្រហារ ដោយកម្លាំងយ៉ាងខ្លាំងមួយ ដើម្បីកាត់ផ្តាច់កម្ពុជាប្រជាធិបតេយ្យប៉ែកឦសាន និងដើម្បីបង្កើតតំបន់រំដោះ សម្រាប់កងកម្លាំងកម្ពុជាដែលប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខណៈដែលវៀតណាមកំពុងរៀបចំផែនការវាយលុកមកលើកម្ពុជាប្រជាធិបតេយ្យ ជាលើកចុងក្រោយរបស់ខ្លួននៅខែមករា ឆ្នាំ១៩៧៩។ បន្ទាប់មករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានវាយប្រហារជាច្រើនទៅលើវៀតណាមនៅថ្ងៃទី២០ និងថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៨ ដែលបណ្តាលឲ្យអាជ្ញាធរវៀតណាម ប្តូរមកអនុវត្តផែនការ វាយលុកមកលើកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ វិញ។

៨៦- នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ មន្ទីរ៨៧០ បានដាក់ចេញបទបញ្ជាទៅ "បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជាទាំងមូល កងទ័ពបដិវត្តន៍កម្ពុជាទាំងអស់ ព្រមទាំងយុទ្ធជន និងយុទ្ធនារី កម្មាភិបាលនៅគ្រប់មន្ទីរ និងក្រសួង" ដោយបញ្ជាឲ្យពួកគេទាំងអស់គ្នាត្រូវ "ពង្រីក និងពង្រឹងគោលជំហរឲ្យបានរឹងមាំ និងដាច់ខាត ដើម្បីប្រយុទ្ធប្រឆាំងនឹងខ្មាំងយួនឈ្លានពាន និងវាតទីនិយមលេបទឹកដី" និងបានលើកឡើងថា "រាល់អំពើ និងគ្រប់សកម្មភាពទាំងអស់ ត្រូវតែធ្វើឡើងដោយផ្អែកលើជំហររួមតែមួយគឺដាច់ខាតវាយប្រហារខ្មាំងយួន"។ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ប៉ុល

ពត បានដាក់ចេញអ្វីដែលគេហៅថា សេចក្តីថ្លែងការណ៍ចុងក្រោយរបស់មជ្ឈិមបក្ស ទៅកាន់ប្រជាជនទាំងមូល មុនពេលដែលបែកភ្នំពេញ ដោយអំពាវនាវឲ្យប្រជាជន រួបរួម ដោយអង់អាចប្រយុទ្ធប្រឆាំងនឹងពួកឈ្លានពានវៀណាម ដែល"ស្ថិតនៅក្នុងអណ្តាតភ្លើងសន្ធោសន្ធៅនៃកំហឹងរបស់ជាតិ និងប្រជាជនកម្ពុជាទាំងមូល"។

៨៧- ទោះបីជាការវាយប្រហារទ្រង់ទ្រាយធំជាចុងក្រោយរបស់កងកម្លាំងវៀតណាម បានជួបប្រទះនឹង ការតស៊ូដ៏ស្រួចស្រាវ និងតម្រូវឲ្យមានការប្រើកាំភ្លើងធំ រថក្រោះ និងទ័ពអាកាសក៏ដោយ ក៏ចុងក្រោយទីក្រុងភ្នំពេញត្រូវបានដណ្តើមបាន និងមានការដួលរំលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

## ខ- រចនាសម្ព័ន្ធគ្រប់គ្រង

## បក្សកុម្មុយនីស្តកម្ពុជា

៨៨- [redacted]។

### ប្រវត្តិសាស្ត្រមុនខែមេសា ឆ្នាំ១៩៧៥

៨៩- ឫសគល់នៃ ប.ក.ក អាចនឹងមានប្រភពចេញមកពីបក្សកុម្មុយនីស្តឥណ្ឌូចិន (ICP) ដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៣០។ នៅក្នុងឆ្នាំ១៩៥១ បក្សកុម្មុយនីស្តឥណ្ឌូចិនត្រូវបានរំលាយចោល ហើយបន្ទាប់មក អង្គការបដិវត្តន៍ដាច់ដោយឡែកពីគ្នា ត្រូវបានបង្កើតឡើងសម្រាប់

ប្រទេសវៀតណាម ឡាវ និងកម្ពុជា ដោយបក្សថ្មីនៅកម្ពុជាមានឈ្មោះថាបក្សប្រជាជនបដិវត្តខ្មែរន៍(KPRP)។ នៅថ្ងៃ ទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ KPRP ត្រូវបានប្តូរឈ្មោះទៅជាបក្សពលករកម្ពុជា (WPK) ហើយសមាជបក្សលើកដំបូងត្រូវបានធ្វើឡើងនៅភ្នំពេញ ដើម្បីសម្រេចអំពី"មាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្ស"។ មាគ៌ាមួយក្នុងចំណោមមាគ៌ាសំខាន់ៗដែលបានទទួលការឯកភាពនៅក្នុង សមាជនោះគឺការសម្រេចប្រើប្រាស់ "អំពើហិង្សាប្រដាប់អាវុធ"បន្ថែមពីលើសកម្មភាពនយោបាយ "ដើម្បីវាយរំលំពួកសក្តិភូមិ ពួកនាយទុន និងពួកប្រតិកិរិយានៅកម្ពុជា"។ បក្សក៏បានសម្រេច នៅដើមដំបូងនេះថាតំបន់ជនបទគឺជា "មូលដ្ឋានយ៉ាងសំខាន់សម្រាប់បដិវត្តន៍" ហើយទីក្រុងគឺជា "ប្រភពនៃវណ្ណៈជិះជាន់ និងពួកចក្រពត្តិ ជាទីកន្លែងដែលខ្មាំងបដិវត្តអាចប្រមូលអំណាចដើម្បីកៀបសង្កត់យើង"។ មានមនុស្សចំនួនប្រហែល២០នាក់បានចូលរួមក្នុងសមាជនេះ ដែលក្នុងនោះមាន **នួន ជា** (អនុលេខាបក្សដែលបានទទួលការបោះឆ្នោតតែងតាំង) សាឡុត ស ហៅ ប៉ុល ពត (សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍) **អៀង សារី** និង សោ ភឹម (សមាជិកបម្រុងនៃគណៈកម្មាធិការអចិន្ត្រៃយ៍) និង វន វេត។ បន្ទាប់ពីពេលអនុម័តមាគ៌ាបក្សថ្មីនេះ សមាជិកបក្សទាំងអស់ត្រូវ "ដាក់ពាក្យសុំចូលបក្សម្តងទៀត"។

៩០- បន្ទាប់ពីពេលចាប់ខ្លួន និងប្រហារជីវិតលេខាបក្សពលករកម្ពុជាឈ្មោះ ទូ សាមុត នៅឆ្នាំ១៩៦២ សមាជលើកទី២របស់បក្សត្រូវបានធ្វើឡើងនៅចុងខែកុម្ភៈ ឆ្នាំ១៩៦៣ ដែលកាលណោះ សាឡុត ស បានក្លាយខ្លួនជាលេខាបក្សថ្មី ចំណែក **នួន ជា** នៅបន្តធ្វើជាអនុលេខាបក្សដដែល។ សមាជនេះ ត្រូវបានធ្វើឡើងនៅផ្ទះបញ្ឈលដីហ្គោលទីក្រុងភ្នំពេញ ហើយអ្នកចូលរួមគឺជាមនុស្សមួយក្រុមតូច ដែលក្នុងនោះមាន **អៀង សារី** និង សោ ភឹម (អ្នកទាំងពីរ ត្រូវបានបោះឆ្នោត

ជ្រើសតាំងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍) តា ម៉ុក វន វ៉េត សុន សេន វស់ ញឹម និង គង់ សុផល។ បន្ទាប់មកក្នុងឆ្នាំ១៩៦៣ បន្ទាប់ពីរបបសម្តេចសីហនុ បានចេញផ្សាយនូវបញ្ជី ឈ្មោះមនុស្សដែលគេស្គាល់ថាជា "អ្នកឆ្វេងនិយម" ចំនួន៣៤រូប ប៉ុល ពត និងមេដឹកនាំបក្ស ពលករកម្ពុជាមួយចំនួន ដែលមានឈ្មោះក្នុងបញ្ជីនោះ រួមទាំង **អៀង សារី** និង សុន សេន ក៏បានភៀសខ្លួនពីទីក្រុងទៅជ្រកកោននៅឯបន្ទាយយោធាវៀតណាមមួយ នៅតាមបណ្តោយ ព្រំដែន ហើយក្រោយមកបានបង្កើតមន្ទីរមួយនៅទីនោះឈ្មោះថា មន្ទីរ១០០។ មកដល់ឆ្នាំ១៩៦៥ ប្រពន្ធរបស់ពួកគេដូចជា ខៀវ ប៉ុណ្ណារី **អៀង ធីរិទ្ធ** និង **យុន យ៉ាត** បានចូលរួមជាមួយពួកគេ នៅមន្ទីរ១០០នោះ។ ដោយសារអត្តសញ្ញាណរបស់ **នួន ជា** បន្តស្ថិតនៅជាការសម្ងាត់ ទើបឈ្មោះរបស់គាត់ពុំស្ថិតនៅក្នុងបញ្ជីឈ្មោះមនុស្សទាំង៣៤នាក់នោះ ហើយគាត់បានស្នាក់នៅ ភ្នំពេញ និងទទួលបន្ទុកប្រតិបត្តិការរបស់បក្សពលករកម្ពុជា ក្នុងទីក្រុង និងតំបន់ជាច្រើន។

៩១- នៅសរទរដូវឆ្នាំ១៩៦៤ បក្សពលករកម្ពុជាបានចាប់ផ្តើមប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់ នៅ មន្ទីរ១០០ ហើយនៅខែមករា ឆ្នាំ១៩៦៥ ពួកគេបានឯកភាពលើសេចក្តីសម្រេចមួយ ដែល បានបដិសេធការផ្តល់លទ្ធភាពដល់"ការផ្លាស់ប្តូរដោយសន្តិវិធី"ទៅកាន់លទ្ធិសង្គមនិយម ហើយ បានបញ្ជាក់ អះអាងថា "ជាការចាំបាច់ដែលត្រូវប្រើប្រាស់ហិង្សាបដិវត្តន៍" ក្នុងការតស៊ូ ប្រឆាំងនឹងពួកចក្រពត្តិ។ ក្នុងអង្គប្រជុំគណៈមជ្ឈិម កាលពីខែកញ្ញា ឬខែតុលា ឆ្នាំ១៩៦៦ មេដឹកនាំបក្ស ពលករកម្ពុជាបានសម្រេចប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា (ទោះជា គេរក្សាការ សម្រេចនោះទុកជាសម្ងាត់រហូតដល់សមាជបក្សលើកក្រោយក្តី) ប្តូរទីតាំង មន្ទីរ១០០ ទៅខេត្តរ តនគិរី ហើយភូមិភាគនីមួយៗត្រូវចាប់ផ្តើមរៀបចំការតស៊ូប្រដាប់អាវុធ។ នៅពាក់កណ្តាល ឆ្នាំ១៩៦៧ សមាជិកគណៈអចិន្ត្រៃយ៍ (ប៉ុល ពត **នួន ជា អៀង សារី** និង សោ

ភឹម) បានជួបប្រជុំគ្នានៅមន្ទីរ ១០០ និងបានឯកភាពធ្វើការបះបោរជាទូទៅមួយនៅដើមឆ្នាំ១៩៦៨ មិនយូរប៉ុន្មានបន្ទាប់ពីពេលបះបោរ ទីស្នាក់ការគណៈមជ្ឈិមថ្មីមួយ (ឈ្មោះមន្ទីរ១០០ដែរ) ត្រូវបានបង្កើតឡើងក្នុងខេត្តរតនគិរី ចម្ងាយប្រមាណពី២ ទៅ៣ គីឡូម៉ែត្រពីមន្ទីរ១០២ មន្ទីរភូមិភាគឦសានដែលត្រូវបានប្រើប្រាស់ដោយ **អៀង សារី** (គាត់ត្រូវបានតែងតាំងជាលេខាតំបន់)។

៩២- នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ អនុលោមតាមបញ្ជារបស់ **នួន ជា** កាលពីខែមុន កងកម្លាំងរបស់ ប.ក.ក បានវាយប្រហារបន្ទាយកងទ័ពរបស់រដ្ឋាភិបាលនៅភូមិ បាយដំរ៉ាម ភាគខាងត្បូងក្រុងបាត់ដំបង ដោយរឹបអូសបានអាវុធមួយចំនួន។ ក្នុងគ្រាបន្ទាប់មកទៀត កាលបរិច្ឆេទខាងលើនេះ ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជា ថ្ងៃកំណើតកងទ័ពបដិវត្តកម្ពុជា។ នៅខែបន្តបន្ទាប់ កងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា នៅបានបន្តការវាយប្រហារតាមលក្ខណៈទ័ពព្រៃនៅទូទាំងប្រទេស។

៩៣- នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សម្តេចនរោត្តមសីហនុត្រូវបានឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់សិរីមតៈទម្លាក់ពីតំណែង ហើយពួកគេបានបង្កើតរបបមួយឈ្មោះថា របបសាធារណរដ្ឋខ្មែរ។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចសីហនុ បានប្រកាសអំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងបានអំពាវនាវឲ្យកូនចៅរបស់ទ្រង់បើកយុទ្ធនាការវាយប្រហារតាមក្បួនទ័ពព្រៃ និងឲ្យប្រជាជនស៊ីវិលធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ សម្ពន្ធភាពមួយត្រូវបានបង្កើតឡើង រវាងសម្តេចសីហនុ និងបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងរដ្ឋាភិបាលនិរទេសដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំង ដែលមានឈ្មោះថារាជរដ្ឋា

ភិបាលរួបរួមជាតិកម្ពុជា ដែលក្នុងនោះមាន **ខៀវ សំផន** ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងត្រូវបានប្រកាសជាផ្លូវការ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០។ នៅខែសីហា ឆ្នាំ១៩៧០ **អៀង ធីរិទ្ធ** ត្រូវបានតែងតាំងជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំយុវជន នៅក្នុងជួររាជរដ្ឋាភិបាលរួបរួមជាតិ។

៩៤- ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានចាកចេញពីខេត្តរតនគិរី និងបានចាប់ផ្តើមធ្វើដំណើរអស់រយៈពេលប៉ុន្មានខែ ទៅភាគខាងត្បូងស្ទឹងជីនិតតាមបណ្តោយព្រំដែនខេត្តកំពង់ចាម និងកំពង់ធំ ដែលជាទីតាំងទីស្នាក់ការលេខាភូមិភាគឧត្តរ ឈ្មោះកុយ ធួន។ ដំបូង ប៉ុល ពត និង **នួន ជា** បានស្នាក់នៅឯបន្ទាយមួយឈ្មោះ ក-១ ស្ថិតនៅភូមិដងក្តារ ប៉ែកព្លៃសាន នៃឃុំស្ដី ដែលមានផ្ទះក្បឿង៣ខ្នង។ នៅចុងឆ្នាំ១៩៧០ ពួកគេបានប្តូរទៅកាន់ទីតាំងធំមួយនៅទិសខាងជើងស្ទឹងជីនិតចម្ងាយ៥ម៉ាយ ពីទីតាំងចាស់ឈ្មោះថា មន្ទីរស-៧១ ដែលមានផ្ទះចំនួន២០ ទៅ៣០ និងត្រូវបានប្រើប្រាស់ធ្វើជាទីបញ្ជាការ និងកន្លែងរៀនសូត្រ។ មេដឹកនាំបក្សដែល បោះមូលដ្ឋាននៅទីកន្លែងនេះមានដូចជា ប៉ុល ពត **នួន ជា ខៀវ សំផន** ហ៊ូ នឹម ហ៊ូ យន់ និង ឈិម សំអោក ហៅ ប៉ង់ ដែលធ្លាប់ធ្វើជាប្រធានមន្ទីរ១០០។ **អៀង សារី** បានធ្វើដំណើរទៅហាណូយនៅខែធ្នូ ឆ្នាំ១៩៧០ ដើម្បីរៀបចំឡើងវិញនូវ “វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមសិទ្ធិអំណាចគ្រប់គ្រងរបស់ **អៀង ធីរិទ្ធ** រហូតដល់ខែឧសភា ឆ្នាំ១៩៧៥ ហើយក្នុងខែមេសា ឆ្នាំ១៩៧១ គាត់បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ដើម្បីស្នាក់នៅជាមួយសម្តេចសីហនុ និងធ្វើជា“បេសកជនពិសេសនៃចលនាតស៊ូ”។ នៅឯភូមិគ្រឹះរបស់គាត់នៅទីក្រុងប៉េកាំង **អៀង សារី** មានទំនាក់ទំនងតាមរយៈទូរលេខផ្ទាល់ជាមួយមន្ទីរ ស-៧១។

៩៥- នៅពាក់កណ្ដាលខែមករា ឆ្នាំ១៩៧១ គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នា ជាលើកដំបូងចាប់តាំងពីខែតុលា ឆ្នាំ១៩៦៦ ចំនួនរយៈពេល៣ថ្ងៃ នៅមន្ទីរស-៧១ ដោយមានសមាជិកចូលរួមចំនួន២៧រូប ក្នុងនោះមាន ប៉ុល ពត នួន ជា សោ ភឹម វន វ៉េត តា ម៉ុក រស់ ញឹម គង់ សុផល ជូ ជេត កង ចា កុយ ធួន កែ ពក សឿ វ៉ាស៊ី ហៅ ឌឿន និង ប៉ង់។ អង្គប្រជុំបានពិភាក្សាអំពីយុទ្ធសាស្ត្រសម្រាប់សង្គ្រាមទ័ពព្រៃ ការរៀបចំកម្លាំងយោធា និងព្រំដែនថ្មី និងលេខកូដរបស់តំបន់។ នៅខែកក្កដា និងខែសីហា ឆ្នាំ១៩៧១ ប៉ុល ពត បានបើកវគ្គបណ្ដុះបណ្ដាលរយៈពេល១ខែដើម្បីបំពាក់បំប៉នកម្មាភិបាលស្រុក តំបន់ និង ភូមិភាគចំនួន២០០នាក់ នៅឯទីស្នាក់ការភូមិភាគឧត្តរ បន្ទាប់ពីការប្រជុំអ្នកចូលរួមដែលត្រូវបានគេជ្រើសរើស ត្រូវបានគេនាំចេញពីទីនោះចម្ងាយ១៥ម៉ាយ ឆ្ពោះទៅកាន់ជំរំមួយនៅក្នុងព្រៃ ដែលជាកន្លែងប្រារព្ធសន្និបាតបក្សលើកទី៣។ សន្និបាតបក្សលើកនេះមានប្រតិភូចូលរួមប្រហែល ៦០នាក់ ក្នុងនោះមាន **ខៀវ សំផន** លេខាភូមិភាគ និងតំបន់ទាំងអស់ និងមេបញ្ជាការយោធាដូចជា កែ ពក ជាដើម។ ក្នុងសន្និបាតលើកនេះ គេបានឯកភាពអំពីលក្ខន្តិកៈបក្សថ្មី អនុម័តជាផ្លូវការនូវឈ្មោះបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានប្រើប្រាស់អស់រយៈពេល៥ឆ្នាំរួចមកហើយ និងបានបោះឆ្នោតតែងតាំងគណៈមជ្ឈិមថ្មី ដែលបានដាក់បញ្ចូល ខៀវ សំផន ជាសមាជិក "បម្រុង" ឬសមាជិក "ត្រៀម" ។

៩៦- នៅខែឧសភា ឆ្នាំ១៩៧២ គណៈមជ្ឈិមថ្មី បានជួបប្រជុំគ្នា និងបានចេញសេចក្ដីណែនាំទៅកាន់សមាជិកបក្ស ឲ្យខំពង្រឹងការតស៊ូប្រឆាំងនឹង"វណ្ណៈជិះជាន់ផ្សេងៗ" និងបានឯកភាពលើផែនការសមូហភាវូនីយកម្មកសិកម្ម។ មួយឆ្នាំក្រោយមក ពោលគឺនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ

១៩៧៣ សហករណ៍ត្រូវបានបក្សកុម្មុយនីស្តកម្ពុជា បង្កើតឡើងជាផ្លូវការ នៅតាមបណ្តាតំបន់នានាដែលពួកគេបានចូលកាន់កាប់។

៩៧- បន្ទាប់មកទៀតនៅឆ្នាំ១៩៧៣ បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតមូលដ្ឋានជួរមុខថ្មីមួយ នៅក្បែរភូមិច្រកស្តេច ខាងលិចឧត្តុង្គក្នុងស្រុកកំពង់ត្រឡាចលើ ជិតនឹងទីតាំងទីស្នាក់ការភូមិភាគពិសេសរបស់ វន វ៉េត និងបន្ទាយបញ្ជាការរបស់ សុន សេន។ កងទ័ពចំនួន២៥វរសេនាតូចរបស់បក្សកុម្មុយនីស្តកម្ពុជា បានកាន់កាប់ទីតាំងនានាជុំវិញតំបន់ឧត្តុង្គ និងបានបើកការវាយប្រហារទៅលើទីតាំងអតីតរាជធានីមួយនេះនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៤។

៩៨- នៅខែមិថុនា ឆ្នាំ១៩៧៤ គណៈមជ្ឈិមបានជួបប្រជុំគ្នានៅឃុំព្រែកគោក ស្ថិតនៅចម្ងាយប្រាំបីម៉ាយ ភាគខាងត្បូងអតីតទីតាំងមន្ទីរ ក-១ នៅភូមិដងក្តា និង"បានសម្រេចបើកការវាយលុកផ្តាច់ព្រ័ត្រ ដើម្បីរំដោះភ្នំពេញ និងប្រទេសទាំងមូល"។ នៅក្នុងអង្គប្រជុំ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានសម្រេចថា ភ្នំពេញ និងទីក្រុងផ្សេងៗទាំងអស់នៅកម្ពុជា ត្រូវជម្លៀសទៅកាន់តំបន់ទីជនបទនៅពេលពួកគេរំដោះបាន ដូចពួកគេធ្លាប់បានធ្វើទៅលើខេត្តក្រចេះ និង កំពង់ចាមនៅឆ្នាំ១៩៧៣ និងឧត្តុង្គក្នុងខែមីនា ឆ្នាំ១៩៧៤ ដើម្បីធ្វើឱ្យកម្លាំងខ្មាំងជ្រួលច្របល់នៅក្នុងចំណោមប្រជាជនទីក្រុង។ គណៈមជ្ឈិមក៏បានពិភាក្សា និងឯកភាពទៅលើការប្រហារជីវិតសមាជិករបស់ខ្លួនឈ្មោះ ប្រាសិទ្ធ ហៅ ចុង ជាប្រធានតំបន់កោះកុង ដែល តា ម៉ុក បានចោទថាបានប្រឆាំងនឹងសមូហភាវូបនីយកម្ម និងបានធ្វើការឱ្យសេអ៊ីអា និងរដ្ឋាភិបាលថៃ។

៩៩- ការវាយប្រហារផ្តាច់ព្រ័ត្រយកទីក្រុងភ្នំពេញ ត្រូវបានគ្រោងធ្វើនៅខែធ្នូ ឆ្នាំ១៩៧៤ នៅឯមន្ទីរ ប-៥ ដែលជាមូលដ្ឋានមួយនៅក្បែរភូមិទាំងពាន់(Taing Poun) ស្រុកកំពង់ត្រឡាចលើ

និងបានចាប់ផ្ដើមអនុវត្តនៅខែមករា ឆ្នាំ១៩៧៥។ នៅដើមខែមីនា ឆ្នាំ១៩៧៥ ប៉ុល ពត បានបង្កើតមូលដ្ឋានបញ្ជាការមួយនៅភូមិស្ដុកទាល់ ស្រុកឧត្ដុង្គ ឬពញាឮ ចម្ងាយតែ២០ម៉ាយប៉ុណ្ណោះពីភ្នំពេញ។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងកម្លាំងបក្សកុម្មុយនីស្ដកម្ពុជា "បានរំដោះយកបានអ្នកលឿង" លន់ នល់ បានចុះពីតំណែង និងនិរទេសខ្លួនទៅហាវៃ។ បុគ្គលិកស្ថានទូត សហរដ្ឋអាមេរិកបានចាកចេញពីភ្នំពេញនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៥ ហើយនៅពេល២ថ្ងៃ បន្ទាប់មក អគ្គរដ្ឋទូតរបស់អាមេរិក ក៏បានចាកចេញពីភ្នំពេញដែរ។ នៅព្រឹកថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ កងកម្លាំងបក្សកុម្មុយនីស្ដកម្ពុជា បានចូលមកដល់ទីក្រុងភ្នំពេញ។

### មហាសន្និបាតបក្ស

១០០- លក្ខន្តិកៈបក្សកុម្មុយនីស្ដកម្ពុជាបានប្រគល់ "សិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ទូទាំងប្រទេស" ទៅឲ្យ "មហាសន្និបាតតំណាងទូទាំងប្រទេស" (ពោលគឺ មហាសន្និបាតបក្ស) ដែលត្រូវបានធ្វើឡើង "រៀងរាល់៤ឆ្នាំម្ដង" ដើម្បី (i)"ពិនិត្យ តាមដាន វិនិច្ឆ័យសកម្មភាពរបស់គណៈកម្មាធិការ មជ្ឈិមចាស់" (ii)"កំណត់មាគ៌ានយោបាយ និងលក្ខន្តិកៈ" និង(iii)"ជ្រើសតាំងគណៈកម្មាធិការ មជ្ឈិមថ្មី"។ ដូចដែលបានរៀបរាប់ខាងលើ នៅរយៈកាលមុនសម័យកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតបក្សត្រូវបានប្រារព្ធធ្វើនៅឆ្នាំ១៩៦០ ១៩៦៣ និងឆ្នាំ១៩៧១ ដែលមហាសន្និបាតឆ្នាំ ១៩៦០ និង១៩៦៣ មានអ្នកចូលរួមចំនួន២០នាក់ ហើយមហាសន្និបាតឆ្នាំ១៩៧១ មានអ្នកចូល រួមប្រមាណ៦០នាក់។ ក្នុងអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ មហាសន្និបាតបក្ស លើកទី៤ ត្រូវបានប្រារព្ធ

ធ្វើនៅខែមករា ឆ្នាំ១៩៧៦ នៅបុរីកីឡាភ្នំពេញ ហើយគេបានបើកមហាសន្និបាតបក្សលើកទី៥ នៅសរទរដូវឆ្នាំ១៩៧៨ ដោយមានការចូលរួមពីមនុស្សចំនួនប្រមាណ៦០នាក់។

## គណៈកម្មាធិការមជ្ឈិម

១០១- នៅក្នុងរយៈពេលពីមហាសន្និបាតមួយទៅមួយទៀត លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា បានចាត់ទុកគណៈកម្មាធិការមជ្ឈិមថាជា "អង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសម្រាប់ទូទាំងប្រទេស"។ គណៈកម្មាធិការមជ្ឈិម មានសមាជិកសរុបទាំងអស់ចំនួន យ៉ាងហោចណាស់ ៣០រូប។ បន្ថែមពីលើសមាជិកនៃគណៈអចិន្ត្រៃយ៍ (ដែលយើងនឹងរៀបរាប់ខាងក្រោម) សមាជិកគណៈមជ្ឈិម រួមមានលេខាតំបន់ និងភូមិភាគ ដូចជា កែ ពក ម៉ែន សាន ហៅ យ៉ា សំ ប៊ិត និង [redacted] លេខាក្រសួង ដូចជា កុយ ធួន មេបញ្ជាការកងពល ដូចជា [redacted] និង **ខៀវ សំផន** ដែលបានចាប់ផ្តើមធ្វើជាសមាជិក"ត្រៀម" នៅឆ្នាំ១៩៧១ និងបានក្លាយខ្លួនជាសមាជិកពេញសិទ្ធិ ក្នុងមហាសន្និបាតលើកទី៤ នៅខែមករា ឆ្នាំ១៩៧៦។ គណៈមជ្ឈិម បានជួបប្រជុំគ្នារៀងរាល់៦ខែម្តង។ ភារកិច្ចចាត់តាំងរបស់ខ្លួនតាមលក្ខន្តិកៈរបស់បក្ស គឺជាការ"អនុវត្តន៍មាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្សនៅក្នុងជួរបក្ស" ណែនាំដល់អង្គការចាត់តាំងរបស់បក្សតំបន់ និងភូមិភាគ ឱ្យ"អនុវត្តសកម្មភាពស្របតាមមាគ៌ានយោបាយ" និង "គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឱ្យច្បាស់ និងឱ្យជាប់ជានិច្ច" ។

## គណៈកម្មាធិការអចិន្ត្រៃយ៍

១០២- ក្នុងការអនុវត្តន៍ជាក់ស្តែង វាគឺជាអនុគណៈកម្មាធិការនៃគណៈមជ្ឈិមដែលត្រូវគេស្គាល់ថាជាគណៈអចិន្ត្រៃយ៍ដែលដើរតួនាទីជាអង្គការ ដែលមានសិទ្ធិអំណាចខ្ពស់ និងផ្តាច់ការជាងគេបំផុតក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ។ [redacted]

១០៣- នៅដើមរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ គណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាគឺស្ថិតក្រោមការដឹកនាំរបស់ ប៉ុល ពត ជាលេខា និង **នួន ជា** ជាអនុលេខា។ ប៉ុល ពត ធ្លាប់ជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា (ឬបក្សមុនរបស់ខ្លួន) ចាប់តាំងពីឆ្នាំ១៩៦០ ហើយ **នួន ជា** ជាសមាជិកចាប់តាំងពីឆ្នាំ១៩៥៨។ ក្នុងអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា មានសមាជិកសរុបចំនួន៧រូប ក្នុងនោះ៥រូបជាសមាជិក"ពេញសិទ្ធិ" និង២រូបទៀតជាសមាជិក"ត្រៀម" ឬ"ជំនួស"។ មកទល់ខែមេសា ឆ្នាំ១៩៧៥ ក្រៅពី ប៉ុល ពត និង **នួន ជា** សមាជិក"ពេញសិទ្ធិ" នៃគណៈអចិន្ត្រៃយ៍មាន សោ ភឹម លេខាភូមិភាគបូព៌ា តា ម៉ុក លេខាភូមិភាគនិរតី និង **អៀង សារី**។ ទាំង សោ ភឹម និង **អៀង សារី** គឺជាសមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍ ចាប់តាំងពីមហាសន្និបាតបក្សលើកដំបូងនៅឆ្នាំ១៩៦០ និងបានក្លាយខ្លួនជាសមាជិកពេញសិទ្ធិ ចាប់តាំងពីពេលមហាសន្និបាតបក្សលើកទី២នៅឆ្នាំ១៩៦៣។ សមាជិកត្រៀមនៃគណៈអចិន្ត្រៃយ៍មាន វន វេត និង សុន សេន

ដែលបានទទួលការតែងតាំងនៅចុងឆ្នាំ១៩៧៥។ លេខាភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម និងអនុលេខាឈ្មោះ គង់ សុផល ហៅ កឺ ដែលអ្នកទាំង២ ត្រូវបានបោសសម្អាតនៅឆ្នាំ១៩៧៨ ក៏អាចជាសមាជិកត្រៀមក្នុងពេលណាមួយផងដែរ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ សោ ភឹម បានស្លាប់ ក្នុងអំឡុងនៃការបោសសម្អាតភូមិភាគបូព៌ានៅពាក់កណ្តាលឆ្នាំ១៩៧៨ ហើយ វន វ៉េត បានត្រូវចាប់ខ្លួន បញ្ជូនទៅកាន់មន្ទីរ ស-២១ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨។

១០៤- គណៈអចិន្ត្រៃយ៍ [redacted]។ មានពេលខ្លះ ក្នុង១ថ្ងៃ គណៈអចិន្ត្រៃយ៍បានជួបប្រជុំគ្នាជាច្រើនលើកដើម្បីពិភាក្សាអំពីបញ្ហាផ្សេងៗ ហើយមានពេលខ្លះទៀត គណៈ អចិន្ត្រៃយ៍បានជួបប្រជុំគ្នាជាបន្តបន្ទាប់អស់ជាច្រើនថ្ងៃក្នុងមួយលើក ដើម្បីពិចារណាអំពីរបៀបវារៈធំៗនៃបញ្ហា។ ជាធម្មតា ការជួបប្រជុំគ្នារបស់គណៈអចិន្ត្រៃយ៍ ត្រូវបានធ្វើឡើងនៅមន្ទីរ ក-១ និងជួនកាលនៅមន្ទីរ ក-៣ (ដែលយើងនឹងយកមន្ទីរទាំងនោះមកពិភាក្សាបន្ថែមទៀតខាងក្រោម)។ ការជួបប្រជុំគ្នាពុំចាំបាច់តម្រូវឱ្យមានវត្តមានចូលរួមពីសំណាក់រាល់គ្រប់សមាជិកទាំងអស់ឡើយ ហើយជាទៀងទាត់ ការជួបប្រជុំគ្នាត្រូវបានធ្វើដោយគ្មានវត្តមាន របស់ សោ ភឹម និង តា ម៉ុក ដែលមនុស្សទាំង២នាក់នេះ ស្ថិតនៅតាមខេត្ត។ សមាជិកមួយចំនួនរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេហៅឱ្យចូលរួមជាទៀងទាត់ ក្នុងអង្គប្រជុំ និងបានក្លាយខ្លួនជាសមាជិក*តាមព្រឹត្តិន័យ* នៃគណៈអចិន្ត្រៃយ៍ ពិសេសគឺ **ខៀវ សំផន** (ដែលមានវត្តមានចូលរួមចំនួន១៤លើក ក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ទាំង១៧លើក ដែលគេនៅមានបញ្ជីវត្តមានសមាជិកចូលរួមប្រជុំមកទល់សព្វថ្ងៃ) និង សឿ វ៉ាស៊ី ហៅ ឌឿន (ដែលមានវត្តមានក្នុងកិច្ចប្រជុំចំនួន១២លើក ក្នុងចំណោមការប្រជុំទាំង១៧លើក)។ ក្រុមមេដឹកនាំ

ជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដែលតែងបានជួបប្រជុំគ្នា និងធ្វើការងាររួមគ្នាជាទៀងទាត់នៅមន្ទីរក-១ និងក-៣ នៅភ្នំពេញ បង្កើតបានជាអ្វីដែលគេស្គាល់ឈ្មោះថា "មជ្ឈិមបក្ស"។

១០៥- គណៈអចិន្ត្រៃយ៍បានបង្កើត ដឹកនាំ និងតាមដានការអនុវត្តន៍រាល់គ្រប់គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ពិសេស គណៈអចិន្ត្រៃយ៍ជាអ្នកក្តោបក្តាប់គោលនយោបាយទាក់ទិននឹងសន្តិសុខផ្ទៃក្នុង និងខាងក្រៅ ការបរទេស កិច្ចការក្នុងស្រុក ដូចជាការងារហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខាភិបាល និងសង្គមកិច្ច ឃោសនាការ និងការលត់ដំកែប្រែ បក្សកុម្មុយនីស្តកម្ពុជា និងបុគ្គលិករដ្ឋ និងបញ្ហារដ្ឋបាល ។ គណៈអចិន្ត្រៃយ៍បានពិភាក្សា និងបានបញ្ជាឲ្យមានការជម្លៀសប្រជាជនដោយបង្ខំក្នុងទ្រង់ទ្រាយធំ ការប្រើប្រាស់ការធ្វើការងារពលកម្មដោយបង្ខំ និងការចាប់ខ្លួន និងការសួរចម្លើយ"ខ្លាំង" បានតាមដានស្ថានភាពរស់នៅរបស់ប្រជាជននៅទូទាំងប្រទេស និងជាអ្នកមានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យមានការហារជីវិតមនុស្សភ្លាមៗ តាមទំនើងចិត្ត។

១០៦- សេចក្តីណែនាំនានារបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានបញ្ជូនទៅមន្ទីរភូមិភាគ កងពលយោធា និងតាមក្រសួងនានា បន្ទាប់មកស្ថាប័នទាំងនោះនឹងធ្វើការផ្សព្វផ្សាយបែងចែកបន្តទៅឲ្យតំបន់ ស្រុក និងថ្នាក់ទាបផ្សេងៗទៀត។ កម្មាភិបាល ប.ក.ក មួយរូប បានបញ្ជាក់នៅក្នុងសម្តីរបស់ខ្លួនថា៖ "គ្រប់យ៉ាង" គឺបានមកពីមជ្ឈិមបក្សទាំងអស់។ មជ្ឈិមបក្សបានផ្តល់នូវការណែនាំយ៉ាងច្បាស់លាស់ នៅក្នុងសេចក្តីណែនាំរបស់ខ្លួន ស្តីពីរបៀបដែលពួកគេត្រូវធ្វើការប្រាស្រ័យទាក់ទង និងប្រតិបត្តិការ។ ឧទាហរណ៍ នៅក្នុងសេចក្តីថ្លែងការណ៍របស់គណៈមជ្ឈិមដែលបានធ្វើនៅខែមិថុនា ឆ្នាំ១៩៧៨ ក្នុងគោលបំណងពិនិត្យ

គោលនយោបាយរបស់បក្ស ចំពោះសេអ៊ីអា កាហ្សេបេ និងខ្មាំងឃ្មួនឡើងវិញ នៅក្នុងសេចក្តីថ្លែងការណ៍នោះ មានផ្តល់នូវការណែនាំដូចតទៅនេះ៖ "ស្នើឲ្យគ្រប់ភូមិភាគ តំបន់ និងកងយោធាទាំងអស់ ឲ្យយកការណែនាំខាងលើនេះ ទៅរៀនសូត្រ និងដើម្បីចាត់ឲ្យមានអង្គប្រជុំនៅតាមបក្ស រចនាសម្ព័ន្ធសំខាន់ៗនៅតាមក្រសួង និងមន្ទីរក្នុងកងយោធា សហករណ៍ រោងចក្រ និងការដ្ឋានរៀងៗខ្លួន ដើម្បីផ្សព្វផ្សាយឲ្យប្រជាជនទាំងអស់ បានដឹងពីគោលនយោបាយរបស់បក្ស ...ចាប់ពីពេលនេះរហូតដល់ដំណាច់ឆ្នាំ១៩៧៨ សូមស្នើឲ្យសហករណ៍ រោងចក្រ ការដ្ឋាន កងនៅតាមកន្លែងនីមួយៗ ឲ្យរៀនសូត្រ និងរៀបចំអង្គប្រជុំឲ្យបានពី៥ ទៅ៦ដង"។ សមាជិកគណៈអចិន្ត្រៃយ៍ ក៏បានធ្វើការត្រួតពិនិត្យនៅ តាមភូមិភាគនានា ដោយមានពេលខ្លះ សមាជិកគណៈអចិន្ត្រៃយ៍ទាំងនោះ បានធ្វើដំណើរជាក្រុមទៀតផង។

១០៧- គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ បានត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួនទៅលើសិទ្ធិរបស់ពួកគេ ក្នុងការកំណត់ និងជម្រុញគោលនយោបាយ ប.ក.ក ដែលគេស្គាល់ជាទូទៅ ថាជា "មាគ៌ា"បក្ស។ ការព្យាយាមប៉ុនប៉ងរិះគន់ ឬផ្លាស់ប្តូរមាគ៌ាបក្សនោះ ត្រូវបានគេចាត់ទុកថាជាសកម្មភាពក្បត់មួយរបស់ "លទ្ធិសេរីនិយម"។ លក្ខន្តិកៈ ប.ក.ក បានហាមប្រាមរាល់ "ឯករាជ្យនិយម សេរីនិយម [និង] បក្ខពួកនិយម" និងត្រូវដាក់វិន័យ ចំពោះសមាជិកបក្សរូបណា "ដែលប្រឆាំងនឹងមាគ៌ានយោបាយបក្ស" និង"ជំហរសតិអារម្មណ៍បក្ស"។ [redacted]

## មន្ទីរ ៨៧០

១០៨- គណៈមជ្ឈិមរបស់ ប.ក.ក ត្រូវបានគេហៅផងថា "គណៈ៨៧០" និងជាទីបញ្ជាការរបស់គណៈអចិន្ត្រៃយ៍ និងមជ្ឈិមនៅភ្នំពេញ ដែលគេឲ្យឈ្មោះថា "មន្ទីរ៨៧០"។ សមាជិកគណៈអចិន្ត្រៃយ៍ ដែលនៅទីក្រុងភ្នំពេញ ប៉ុល ពត **នួន ជា** **អៀង សារី** វន វ៉េត សុន សេន និង **ខៀវ សំផន** ជាសមាជិកតាមព្រឹត្តិន័យ បានរស់នៅ និងធ្វើការនៅក្នុង ក-១ និង ក-៣។ មន្ទីរ ក-១ ដែលជាមន្ទីរដំបូង និងជាកន្លែងស្នាក់អាស្រ័យរបស់ ប៉ុល ពត នោះ មានទីតាំងស្ថិតនៅមាត់ទន្លេបាសាក់ខាងត្បូងទីតាំងរបស់រដ្ឋសភានាពេលបច្ចុប្បន្ន។ វាជាអគារធំមួយដែលមានកំពស់ពីរជាន់ ដែលព័ទ្ធជុំវិញទៅដោយ"ជញ្ជាំងធ្វើអំពីក្ដារ និងលួស" អមទៅដោយប៉ម ចំនួន បួនព័ទ្ធជុំវិញបរិវេណនោះ ដោយនៅតាមជ្រុងនីមួយៗ មានមនុស្សល្បាតមួយក្រុមចំនួនពី៥០ទៅ៦០នាក់។ មន្ទីរក-៣ រួមមាន ផ្ទះនៅក្នុងប្លុកខាងលិចព្រះបរមរាជវាំងទាំងអស់ ដែលស្ថិតនៅលើវិថីប៉ាស្ទ័រ និងផ្លូវវេជ្ជបណ្ឌិត ហាន ដោយមាន "របាំងជាបន្ទះដែកស័ង្កសី និងលួសបន្លា" ព្រមទាំងយាមកាមដោយអ្នកយាមទៀតផង។ ជាទូទៅ ដោយថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់រស់នៅក្នុងក-១ ឬក-៣នោះថ្នាក់ដឹកនាំមួយចំនួនបានរក្សាទុកមន្ទីរធ្វើជាទីកន្លែងសម្រាប់ស្នាក់នៅ។ **អៀង ធីរិទ្ធ** ធ្វើការនៅក-២ ដែលទីនោះ គឺជាមន្ទីររបស់ក្រសួងសង្គមកិច្ច។ គាត់ត្រូវបានគេជឿជាក់ថា បានរស់នៅ ក-៣ ជាមួយស្វាមីរបស់គាត់ គឺ **អៀង សារី** ប៉ុន្តែគាត់នៅមានផ្ទះវីឡាមួយស្ថិតនៅក្នុងតំបន់ចំការមន ដែលម្ដាយរបស់គាត់ រស់នៅទីនោះ។

១០៩- នៅពីក្រោមគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម មានមន្ទីរសំខាន់ៗចំនួនពីរ ដែលមានសារៈសំខាន់ចំពោះប្រតិបត្តិការនានារបស់បក្ស។ មន្ទីរទីមួយគឺ "មន្ទីរនយោបាយ៨៧០" ដែលគេហៅផង

ដែរថា "គណៈមន្ទីរ៨៧០" មានសមាជិកតែពីររូបប៉ុណ្ណោះ គឺ - សឿ វ៉ាស៊ី ហៅ ឌឿន និង **ខៀវ សំផន**។ ទាំង ឌឿន និង **ខៀវ សំផន** គឺជាសមាជិកគណៈមជ្ឈិម និងជាអ្នកដែលបាន ចូលរួមជាទៀងទាត់ នៅក្នុងអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍។ ការទទួលខុសត្រូវផ្សេងៗ មន្ទីររបស់ពួកគេរួមមាន ការត្រួតពិនិត្យមើលការអនុវត្តន៍គោលនយោបាយ ប.ក.ក និងការ ចែកចាយ និងផ្គត់ផ្គង់សម្ភារៈដល់អង្គការចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យទាំងអស់ ទូទាំង ប្រទេស។ បន្ថែមលើ នេះទៀត សេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម ធ្វើនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បានប្រគល់សមត្ថកិច្ចដល់ "គណៈមន្ទីរមជ្ឈិម" ដើម្បី "កម្ទេច" ប្រជាជន "ជុំវិញមន្ទីរមជ្ឈិម"។ ឌឿន ត្រូវបានតែងតាំងជាប្រធានមន្ទីរនេះ ក្នុងខែតុលា ឆ្នាំ១៩៧៥ ប៉ុន្តែគាត់ត្រូវបានគេផ្លាស់ទៅក្រសួងពាណិជ្ជកម្ម ក្នុងខែមេសា ឬខែឧសភា ឆ្នាំ១៩៧៦ និងត្រូវ គេចាប់ខ្លួន រួចបញ្ជូនទៅមន្ទីរ ស-២១ ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ ដោយទុកឱ្យ **ខៀវ សំផន** នៅ គ្រប់គ្រងតែម្នាក់ឯង។

១១០- មន្ទីរ៨៧០ សំខាន់ទីពីរ ដែលស្ថិតក្រោមមជ្ឈិមបក្សនោះ គឺស-៧១ ដែលគេហៅផងដែរថា "គណៈកម្មាធិការនៃក្រុមការងារជុំវិញមន្ទីរ៨៧០" ដែលប្រធានមន្ទីរនោះមានឈ្មោះថា ឈឹម សំអោក ហៅ ប៉ង់ និងអនុប្រធាន ឈ្មោះ ខាន់ លីន ហៅ កែន (ជាអ្នកជំនួសកន្លែង ប៉ង់ បន្ទាប់ ពី ប៉ង់ ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៨)។ ប៉ង់ និង កែន ត្រូវទទួលខុសត្រូវចំពោះ ប្រតិបត្តិការ ប្រចាំថ្ងៃរបស់មន្ទីរក-ផ្សេងៗ ដែលស្ថិតនៅទីក្រុងភ្នំពេញ រួមមាន មន្ទីរនិរសារ (ក-៧) និងកងបើកបរ(ក-១២)ជាដើម។ សំខាន់ជាងនេះទៅទៀត ស-៧១ គឺជាកងសន្តិសុខ របស់ មជ្ឈិមបក្សទទួលបន្ទុកការពារថ្នាក់ដឹកនាំជាន់ខ្ពស់នៅមន្ទីរក-១ និងមន្ទីរក-៣ តាមដាន ត្រួត ពិនិត្យ "សមាជិកដែលជាជនសង្ស័យរបស់បក្ស ឱ្យគណៈអចិន្ត្រៃយ៍" និងចាប់ខ្លួនព្រម

ទាំងដឹកជញ្ជូនអ្នកទោសទៅមន្ទីរស-២១។ ប៉ង់ គឺជាសមាជិករបស់គណៈមជ្ឈិម ប.ក.ក បានធ្វើដំណើរទៅមន្ទីរក-១ និង ក-៣ ជារៀងរាល់ថ្ងៃ ដើម្បីជួបជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក។

១១១- មន្ទីរនិរសារ ក-៧ មានទីតាំងស្ថិតនៅតាមបណ្ដោយមាត់ទន្លេខាងជើងព្រះបរមរាជវាំង មានមុខងារសំខាន់ដែលពាក់ព័ន្ធ ទាំងក្នុងការប្រាស្រ័យទាក់ទង និងសន្តិសុខ។ ជនណាក៏ដោយដែលមានបំណងចង់ជួប ឬទំនាក់ទំនងជាមួយមជ្ឈិមបក្ស ត្រូវធ្វើតាមរយៈមន្ទីរក-៧។ រាល់លិខិត ឬឯកសារនានា ដែលទទួលបាន ឬបញ្ជូនទៅតាមខេត្ត ត្រូវផ្ញើទៅកាន់មន្ទីរក-៧ ជាមុនសិន បន្ទាប់មកទើបផ្ញើចេញពីមន្ទីរនោះ ទៅឱ្យអ្នកដែលត្រូវទទួលលិខិត ឬឯកសារនោះជាក្រោយ។ កម្មាភិបាលដែលធ្វើដំណើរទៅទីក្រុងភ្នំពេញ ដើម្បីចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំបក្ស ត្រូវគេណែនាំឱ្យទៅមន្ទីរក-៧ជាមុនសិន បន្ទាប់មកត្រូវគេអមដំណើរពីទីនោះទៅកាន់មន្ទីរក-១ ឬ មន្ទីរក-៣។ មន្ទីរក-៧ ក៏មានតួនាទីជា "មន្ទីរឃុំឃាំងបណ្ដោះអាសន្ន" ផងដែរ សម្រាប់អ្នកទោសដែលត្រូវបញ្ជូនទៅមន្ទីរស-២១ ឬទៅកាន់ទីកន្លែងរៀនសូត្រ ឬកន្លែងលត់ដំផ្សេងៗទៀត ទាំងសម្រាប់កម្មាភិបាលដែលត្រូវគេចាប់ខ្លួននៅភ្នំពេញ និងទាំងសម្រាប់ជនទាំងឡាយដែលត្រូវគេចាប់ខ្លួននៅតាមភូមិភាគផ្សេងៗទៀត រួចត្រូវគេបញ្ជូនមកភ្នំពេញ។ ប្រធានមន្ទីរក-៧ ពីមុនដំបូងនោះ គឺ មិន មីន ហៅ ព្រុំ ដែលក្រោយមកត្រូវគេបោសសម្អាត និងជំនួសដោយ តាគូ ហៅ គី។ ប្រធានមន្ទីរស-៧១ ប៉ង់ និងអនុប្រធាន កែន អាចរស់នៅក្នុងមន្ទីរក-៧ ឬក-៨ ដែលជាទីតាំងសម្រាប់ដាំបន្លែ។

១១២- កងបើកបរមន្ទីរក-១២ មានទីតាំងស្ថិតនៅលើមហាវិថីព្រះមុនីវង្ស ជិតផ្សារថ្មី មានបុគ្គលិកសរុបចំនួន៣០នាក់ និងជាទីតាំងសម្រាប់ស្តុកប្រេងសាំង និងដាក់រថយន្ត ដែលត្រូវប្រើសម្រាប់ដឹកជញ្ជូន "សម្ភារៈ ដូចជា ចាន កាំបិត កំសៀវ ខោអាវ អង្ករ ទៅឱ្យប្រជាជននៅតាមភូមិភាគ"។ មន្ទីរ ក-៤ គឺជាកងកាត់ដេរខោអាវ មន្ទីរ ក-៥ គឺជាសាលានយោបាយ និងមន្ទីរក-១១ គឺជាមន្ទីរពេទ្យ។

## រដ្ឋកម្ពុជាប្រជាធិបតេយ្យ

១១៣- បន្ទាប់ពីចូលកាន់អំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ប.ក.ក បានប្រសិទ្ធនាមសម្តេចនរោត្តម សីហនុ ជាប្រមុខរដ្ឋ។ ប៉ុន្តែ សម្តេចសីហនុ មិនធ្លាប់បានចូលជាសមាជិករបស់ ប.ក.ក ទេ និងជាអ្នកដឹកនាំបដិទាននាមដែលគ្មានអំណាច ឬសមត្ថកិច្ចជាក់ស្តែង ត្រូវគណៈអចិន្ត្រៃយ៍បកស្រាយថាជា "ខ្លាស្គម នៅតែស្បែក និងឆ្អឹង អត់ក្រចក អត់ចង្កូម"។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦ សម្តេចសីហនុ បានដាក់លិខិតសុំលាលែងរបស់គាត់ ដែលលិខិតនេះត្រូវបានគណៈអចិន្ត្រៃយ៍ទទួលយក ក្រោយពីមានការជជែកពិភាក្សាពីស្ថានភាពរបស់សម្តេចសីហនុប្រើពេលយ៉ាងយូររួចមក ដោយត្រូវសម្រេចថាតើគួរសម្លាប់គាត់ចោល ឬយ៉ាងណា។ ចំពោះបញ្ហាទាំងអស់នេះ គណៈអចិន្ត្រៃយ៍ បានសម្រេចថា ពួកគេ"ត្រូវតែបញ្ចប់សក្តិភូមិ" និងរជ្ជកាលគ្រប់គ្រងរបស់ស្តេចដែលមានរយៈពេល២០០០ឆ្នាំមកនេះ ហើយពួកគេនឹងមិនសម្លាប់សម្តេចសីហនុទេ ដោយលើកហេតុផលថាគាត់មិនបានតស៊ូ និងមិនបង្កបញ្ហា ហើយជាមួយគ្នានេះ គាត់នឹងមិនត្រូវគេអនុញ្ញាតឱ្យចាកចេញពីប្រទេស ព្រមទាំងត្រូវគេរក្សាទុកជា"ឥស្សរជន"មួយរូបជំនួសវិញ។ **ខៀវ សំផន** ត្រូវបានតែងតាំងជំនួសសម្តេចសីហនុ ជាប្រមុខរដ្ឋកម្ពុជា

ប្រជាធិបតេយ្យ ដោយគាត់មានឋានៈជាប្រធានគណៈប្រធានរដ្ឋ។ ប៉ុន្តែពាក់ព័ន្ធនឹងកូនរបស់សម្តេចសីហនុ គណៈអចិន្ត្រៃយ៍បានកំណត់ថាត្រូវ“ដោះស្រាយបញ្ហានេះ ឲ្យស្អាត” តាមរយៈការបញ្ជូនទូរលេខ ហៅកូនគាត់ត្រឡប់មកប្រទេសកម្ពុជា“ភ្លាម” ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំ និងបុណ្យឯករាជ្យ។

១១៤- ស្រដៀងគ្នានេះដែរ ចាប់តាំងពីពេល “តែងតាំង” របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៥ រហូតដល់ពេល “លាលែងពីអំណាច”របស់ខ្លួនវិញ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៦ ប.ក.ក ត្រូវបានគេរក្សាការបោកប្រាស់ ដែលរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានដើរតួជារដ្ឋាភិបាលបណ្តោះអាសន្ន និងបង្កើតរដ្ឋាភិបាលថ្មីមួយរបស់ប្រជាជន។ រដ្ឋធម្មនុញ្ញបង្កើតឲ្យមានរចនាសម្ព័ន្ធរដ្ឋកម្ពុជាប្រជាធិបតេយ្យថ្មីមួយ ដែលត្រូវបានអនុម័តនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានគាំទ្រការប្រព្រឹត្តិទៅ“ការបោះឆ្នោតជ្រើសរើស និងតែងតាំងតំណាងសភាប្រជាជនរបស់កម្ពុជា”ដែលស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ជាស្ថាប័ននីតិបញ្ញត្តិដែលមានសមាជិកចំនួន២៥០នាក់។ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ សភាថ្មីបានជួបជុំ និងគាំទ្រឲ្យជ្រើសរើសស្ថាប័ននីតិប្រតិបត្តិ របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយតែងតាំង ប៉ុល ពត ជានាយករដ្ឋមន្ត្រី **អៀង សារី** ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ វន វ៉េត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច និង **អៀង ធីរិទ្ធ** ជារដ្ឋមន្ត្រីសង្គមកិច្ច។ **ខៀវ សំផន** ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ដែលស្ថិតក្រោមធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ

ដោយ“ទទួលបន្ទុកតំណាងរដ្ឋកម្ពុជាប្រជាធិបតេយ្យទាំងក្នុង និងនៅក្រៅប្រទេស”។ **នួន ជា** ត្រូវបានគេជ្រើសតាំងជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន។

១១៥- តាមការពិត ទោះបីជាគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក បាន សម្រេចចិត្តរួចហើយ អំពីរចនាសម្ពន្ធជាមូលដ្ឋានរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងតួនាទីផ្សេងៗមុនពេលនោះ ដែលធានាថាអង្គការរដ្ឋ គឺជា“អង្គការរដ្ឋបដិវត្តរបស់យើង សុទ្ធសាធ”។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍ ប.ក.ក បានបែងចែកនូវមុខងាររដ្ឋាភិបាលសំខាន់ៗក្នុងចំណោមថ្នាក់ដឹកនាំជាន់ខ្ពស់ចំនួន១៣នាក់ របស់ ប.ក.ក ឧទាហរណ៍ ដូចជាការចាត់តាំង **អៀង សារី** ឱ្យទទួលខុសត្រូវកិច្ចការបរទេស **ខៀវ សំផន** ឱ្យទទួលខាងរណសិរ្ស[រួបរួមជាតិកម្ពុជា] រាជរដ្ឋាភិបាល[រួបរួមជាតិកម្ពុជា] ព្រមទាំងទទួលបន្ទុកពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ សុន សេន ទទួលខាងសេនាធិការ និងសន្តិសុខ វន វ៉េត ទទួលខាងឧស្សាហកម្ម រទេះភ្លើង និងនេសាទ និង **អៀង ធីរិទ្ធ** ទទួលខាង “វប្បធម៌ សង្គមកិច្ច និងការងារបរទេស”។ គណៈអចិន្ត្រៃយ៍បានបង្ហាញពីគោលបំណងច្បាស់លាស់របស់ខ្លួននៅពេលបើកកិច្ចប្រជុំនោះក្នុងការគ្រប់គ្រងលើមុខងាររបស់រដ្ឋាភិបាល និងនយោបាយ ដោយសង្កត់ធ្ងន់អំពីសារៈសំខាន់នៃ“ការអនុវត្តន៍មាគ៌ាបក្ស” និងបានបញ្ជាក់ថាវាជា “ការខុសឆ្គង” បើចាត់វិធានការថ្មី “ដោយពុំបានសួរនាំគណៈអចិន្ត្រៃយ៍”។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ប្រហែលពីរសប្តាហ៍មុនថ្ងៃបើកប្រជុំសភាតំណាងប្រជាជន គណៈអចិន្ត្រៃយ៍ ប.ក.ក បាន តែងតាំង **នួន ជា** ជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន **ខៀវ សំផន** ជាប្រធានគណៈប្រធានរដ្ឋ ហើយ ប៉ុល ពត ជានាយករដ្ឋមន្ត្រី។

១១៦- ជាងនេះទៅទៀត នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ការបោះឆ្នោតជ្រើសរើសសភាតំណាងប្រជាជន គឺជាដំណាក់កាលបញ្ឆោតមួយដែលថ្នាក់ដឹកនាំ ប.ក.ក បានធ្វើឡើងដើម្បីជ្រើសរើសសមាជិកសភាតំណាងដោយខ្លួនឯង។ ទស្សនៈពិតប្រាកដរបស់គណៈអចិន្ត្រៃយ៍ ក្នុងការជ្រើសរើសសភាតំណាងប្រជាជន ត្រូវបាន ប៉ុល ពត លើកឡើងនៅក្នុងកិច្ចប្រជុំនៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលមានខ្លឹមសារថា "បើមានគេសួរ យើងត្រូវពន្យល់កុំច្រងេងច្រងាង កុំឱ្យឃើញថាយើងចង់បង្ក្រាប។ ទន្ទឹមនេះក៏កុំនិយាយលេងពីសភានៅមុខប្រជាជន ឱ្យគេឃើញថាយើងបន្តឹមបន្ថុំ ហើយសភាយើងក៏គ្មានតម្លៃអី"។ មិនមានភស្តុតាងណាបន្សល់ទុកទេ អំពីកិច្ចប្រជុំរបស់តំណាងសភាប្រជាជនដែលធ្វើឡើងម្តងទៀត ឬក៏ការអនុម័តច្បាប់ផ្សេងៗឡើយ បន្ទាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦។

១១៧- អង្គការរដ្ឋមួយចំនួនដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បន្ថែមលើតំណាងសភាប្រជាជន គឺជាស្ថាប័នបោកបញ្ឆោតដែលគ្មានអំណាច ឬមុខងារអ្វីឡើយ ហើយវាគ្រាន់តែមានតួនាទីជារណសិរ្សរបស់ ប.ក.ក តែប៉ុណ្ណោះ។ ឧទាហរណ៍ មាត្រា៩ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានចែងថា តុលាការ"គឺជាតុលាការរបស់ប្រជាជន" ហើយតុលាការគ្រប់ជាន់ថ្នាក់ ត្រូវសភាតំណាងប្រជាជនជ្រើសរើស និងតែងតាំង។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជន បានអះអាងពីការតែងតាំង កង ចាប ជាប្រធានគណៈកម្មាធិការតុលាការ។ ប៉ុន្តែ តាមការពិត មិនមានការបង្កើតឱ្យមានស្ថាប័នតុលាការទេ ហើយតួនាទីពិតប្រាកដរបស់ កង ចាប គឺជាអនុលេខាភូមិភាគនិរតី (ក្រោយមកគាត់ត្រូវតម្លើងទៅជាលេខាភូមិភាគឧត្តរថ្មី)។ ស្រដៀងគ្នានេះដែរ ថ្វីត្បិតតែ សភាតំណាងប្រជាជន បានតែងតាំង

ជួន ជឿន ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏មិនមានការបង្កើតឱ្យមានក្រសួងសុខាភិបាលទេ ហើយ ជួន ជឿន ផ្ទាល់ ធ្វើជាប្រធានផ្នែករះកាត់ នៅមន្ទីរពេទ្យ ព-១៧ (ហៅពេទ្យកម្ពុជា-សូវៀត ឬមន្ទីរពេទ្យ១៧មេសា) ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ចទៅវិញ។ [redacted]។

១១៨- ម្យ៉ាងវិញទៀត ក្រសួងខ្លះទៀតរបស់កម្ពុជាប្រជាធិបតេយ្យ មានមនុស្សកាន់ការងារ ហើយបំពេញតួនាទីសំខាន់ៗឱ្យរបបនោះ។ រចនាសម្ព័ន្ធ និងមុខងារនៃក្រសួងចំនួនពីរ គឺក្រសួងការបរទេស និងក្រសួងសង្គមកិច្ច ត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងផ្នែកភស្តុតាងអង្គហេតុទាក់ទងនឹង **អៀង សារី** និង **អៀង ធីរិទ្ធ**។ ក្រសួងឃោសនាការ រួមមាន មន្ទីរក-២៥ មន្ទីរក-២៦ និងមន្ទីរក-២៧ ដែលទទួលបន្ទុកក្នុងការបោះពុម្ព*ទស្សនាវដ្តីទង់បដិវត្ត ទស្សនាវដ្តីយុវជនបដិវត្ត* ព្រមទាំងឯកសាររបស់កម្ពុជាប្រជាធិបតេយ្យផ្សេងៗទៀត និងកាន់កាប់ស្ថានីយ៍វិទ្យុរបស់រដ្ឋាភិបាលមួយដែលផ្សព្វផ្សាយសេវាក្នុងទីក្រុងភ្នំពេញ។ ក្រសួងឧស្សាហកម្មមានមុខងារផ្សេងៗខុសៗគ្នា ដូចជា ការផលិតសម្ភារៈកសិកម្ម ការផលិតក្រណាត់ និងការងារសាធារណៈ ដែលទទួលខុសត្រូវក្នុងការសាងសង់ផ្លូវថ្នល់ ព្រមទាំងអគារផ្សេងៗ ព្រមទាំងវារីអគ្គីសនី និងការផ្គត់ផ្គង់ទឹក។

១១៩- ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវ ទាំងការនាំចេញទំនិញដែលអាចធ្វើពាណិជ្ជកម្មបានផង និងការនាំចូលនូវវត្ថុធាតុដើម និងសម្ភារៈសម្រាប់បែងចែកឱ្យស្ថាប័នរដ្ឋរបស់កម្ពុជា

ប្រជាធិបតេយ្យទូទាំងប្រទេស។ ទំនិញទាំងឡាយត្រូវបានដឹកមកតាមរយៈកំពង់ផែកំពង់សោម ហើយពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ជាភារកិច្ចរបស់ស្ថាប័នដែលបង្កើតដោយក្រសួងពាណិជ្ជកម្ម ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មក្រៅប្រទេស ដូចជាក្រុមហ៊ុនខ្មែរកម្ពុជាប្រជាធិបតេយ្យសម្រាប់ពាណិជ្ជកម្មក្រៅប្រទេស ("ហ្សិត្រា") និងធនាគារពាណិជ្ជកម្មអន្តរជាតិនៅភ្នំពេញ និងក្រុមហ៊ុនរិនហ្វ៊ុង នៅទីក្រុងហុងកុង។ ទំនិញទាំងនោះគេស្តុកនៅក្នុងឃ្លាំងរដ្ឋ ហើយតំណាងខាងពាណិជ្ជកម្ម មកពីភូមិភាគផ្សេងៗ បានមកភ្នំពេញដើម្បីដោះដូរទំនិញជាមួយមជ្ឈិម។

១២០- ក្រសួងផ្សេងៗរាយការណ៍ឲ្យថ្នាក់ដឹកនាំរបស់ ប.ក.ក និងផ្ញើរបាយការណ៍ដោយចម្លងជូនមន្ទីរ៨៧០ ហើយជួបប្រជុំជាប្រចាំជាមួយគណៈអចិន្ត្រៃយ៍ អំពីបញ្ហាដែលពាក់ព័ន្ធនឹងក្រសួងនីមួយៗរបស់ខ្លួន។ ឧទាហរណ៍ **អៀង ធីរិទ្ធ** ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ដែលនិយាយអំពីបញ្ហាផ្សេងៗ ពាក់ព័ន្ធនឹងក្រសួងសង្គមកិច្ច។ សមាជិកគណៈអចិន្ត្រៃយ៍ពីររូប គឺ**អៀង សារី** និង វន វ៉េត ដែលជាលេខាក្រសួង ក្នុងខណៈដែល **នួន ជា** ត្រូវបានតែងតាំងឲ្យទទួលខុសត្រូវពីលើក្រសួងសង្គមកិច្ច ក្រសួងឃោសនាការ និងក្រសួងសិក្សាធិការ ចំណែកឯ **ខៀវ សំផន** វិញ ទទួលបន្ទុកខាងពាណិជ្ជកម្ម។ ថ្នាក់ដឹកនាំក្រសួងក៏ចូលរួមផងដែរ នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់គណៈរដ្ឋមន្ត្រី ជាមួយ ប៉ុល ពត ជាលេខា ប.ក.ក ដែលនៅក្នុងអង្គប្រជុំនោះ ប៉ុល ពត បានពិភាក្សាពីស្ថានភាពទូទៅ នៅក្នុងប្រទេសដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងក្រៅប្រទេស ការការពារជាតិ សន្តិសុខក្នុងប្រទេស ការកសាងប្រព័ន្ធធារាសាស្ត្រ ការបង្កបង្កើនផលស្រូវ និងរបបហូបចុក ដែលការណែនាំត្រូវបាន

ផ្សព្វផ្សាយឲ្យដឹង ហើយកម្មាភិបាលក្រសួងបានរាយការណ៍អំពីផ្នែក ដែលពួកខ្លួនទទួលខុសត្រូវ។

## ការបែងចែកភូមិសាស្ត្ររដ្ឋបាលរបស់ ប.ក.ក

១២១- មុនសម័យរំដោះ ប.ក.ក បានបែងចែកប្រទេសកម្ពុជា ជាតំបន់សំខាន់ៗចំនួន៥ ដែលតំបន់នីមួយៗមានលេខកូដសម្គាល់ ភូមិភាគឦសាន្ត(១០៨) ភូមិភាគឧត្តរ(៣០៤) ភូមិភាគពាយ័ព្យ(៥៦០) ភូមិភាគនិរតី(៤០៥) និងភូមិភាគបូព៌ា(២០៣) ព្រមទាំង"ភូមិភាគពិសេស" ដែលរួមបញ្ចូលតំបន់ជុំវិញទីក្រុងភ្នំពេញ។ ភូមិភាគទាំងនេះត្រូវបានរៀបចំឡើងវិញ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ភូមិភាគនិរតីត្រូវបានបែងចែកភ្លាមៗ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ ដែលផ្នែកខ្លះនៃភូមិភាគនេះ បង្កើតជាភូមិភាគបស្ចិម(៤០១) ដែលជាភូមិភាគទី៦របស់កម្ពុជាប្រជាធិបតេយ្យ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ភូមិភាគទី៧ បានបង្កើតឡើងបន្ទាប់ពីតំបន់ស្វយ័តលេខ១០៣ និង១០៦ បានប្រែក្លាយទៅជាភូមិភាគឧត្តរថ្មី(៨០១) ហើយភូមិភាគឧត្តរចាស់ បានដូរឈ្មោះមកជាភូមិភាគកណ្ដាល។

១២២- ភូមិភាគត្រូវបែងចែកជាតំបន់ដែលតំបន់បានបែងចែកទៅជាស្រុកទៀត។ ស្រុកមួយ រួមមានឃុំមួយចំនួនដែលក្នុងមួយឃុំៗ មានភូមិជាច្រើន។ រចនាសម្ពន្ធភូមិជាប្រពៃណីរបស់កម្ពុជា ត្រូវបានលុបបំបាត់បន្តិចម្តងៗ ហើយត្រូវបានបង្កើតទៅជា"សហករណ៍"។ សាខា គឺជារចនាសម្ពន្ធថ្នាក់ទាបបំផុតនៅក្នុងឋានានុក្រម របស់ ប.ក.ក ហើយត្រូវបានបង្កើតឡើងនៅតាមសហករណ៍នីមួយៗ តាមរោងចក្រ តាមកម្រិតកងអនុសេនាធំ តាមការដ្ឋានផ្សេងៗ និងទៅតាមមន្ទីរក្រសួងនានា។

១២៣- ភូមិភាគ តំបន់ ស្រុក និងសាខា គឺជាឧបករណ៍ សម្រាប់ការអនុវត្តន៍នូវមាគ៌ាណែនាំរបស់មជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ ប.ក.ក នៅទូទាំងប្រទេស។ គណៈកម្មាធិការមួយ រួមមានសមាជិក៣រូប គឺលេខា អនុលេខា និងសមាជិក ដែលគ្រប់គ្រងនូវថ្នាក់នីមួយៗ នៅក្នុងឋានានុក្រមរចនាសម្ពន្ធរបស់ ប.ក.ក។ ឧទាហរណ៍ គណៈកម្មាធិការភូមិភាគ ទទួលខុសត្រូវត្រួតពិនិត្យការអនុវត្តន៍ ផែនការ ភារកិច្ច និងមាគ៌ាបក្សនៅតាមតំបន់ ស្រុក និងសាខា ដែលស្ថិតនៅក្នុងភូមិភាគនោះ ហើយ"រាយការណ៍ឲ្យគណៈមជ្ឈិមអំពីស្ថានការណ៍ និងការងារនៅក្នុងភូមិភាគ"។ គណៈកម្មាធិការនៅកម្រិតតំបន់ ស្រុក និងសាខា បំពេញមុខនាទីស្រដៀងគ្នាដែរ ក្នុងការអនុវត្តន៍នូវភារកិច្ចដែលថ្នាក់លើរបស់ ប.ក.ក ប្រគល់ឲ្យ ហើយត្រូវរាយការណ៍ឲ្យថ្នាក់លើអំពីស្ថានភាព និងការងាររៀងៗខ្លួន។ គណៈកម្មាធិការភូមិភាគ តម្រូវឲ្យ "មានការប្រជុំជាប្រចាំក្នុង៣ខែម្តង ដើម្បីពិនិត្យតាមដាន និងពិភាក្សាអំពីការងារកន្លងមក និងដាក់ការងារថ្មី"។ គណៈកម្មាធិការតំបន់ និងស្រុក តម្រូវឲ្យបើកការប្រជុំជារៀងរាល់ខែ។

១២៤- ភូមិភាគបើកសន្និបាតបក្សប្រចាំឆ្នាំ។ លក្ខន្តិកៈប.ក.ក ចែងថាគណៈកម្មាធិការភូមិភាគ ត្រូវទទួលការជ្រើសរើស និងតែងតាំងនៅក្នុង"សន្និបាតតំណាងភូមិភាគ"ប្រចាំឆ្នាំ ដោយមាន "ការត្រួតពិនិត្យជាមុន ពិគ្រោះពិភាក្សា និងឯកភាពពីគណៈមជ្ឈិម"។ នៅក្នុងការអនុវត្ត ជាក់ស្តែងមជ្ឈិមបក្សអាចតែងតាំងលេខាថ្មី អនុលេខា ឬសមាជិករបស់គណៈកម្មាធិការ ភូមិភាគបានទៅតាមតម្រូវការ(មានន័យថា នៅពេលដែលតំណែងមួយនៅទំនេរ ដោយសារតែមានការផ្លាស់ប្តូរ បោសសម្អាត ឬស្លាប់)។ គណៈកម្មាធិការភូមិភាគ ត្រូវបានមជ្ឈិមបក្សផ្តល់អំណាច ក្នុងការបោសសម្អាតសត្រូវនៅក្នុងមូលដ្ឋានរៀងៗខ្លួន ហើយសមាជិករបស់

គណៈកម្មាធិការភូមិភាគ ជាទូទៅ មានតំណែងនៅក្នុងគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមរបស់ ប.ក.ក។ ឧទាហរណ៍លេខាភូមិភាគ២រូប (ភូមិភាគនិរតី តា ម៉ុក និងលេខាភូមិភាគបូព៌ា សោ ភឹម) គឺជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍ ហើយម្នាក់ទៀតដែលជាលេខាភូមិភាគពាយ័ព្យ រស់ ញឹម គឺជាសមាជិកបម្រុង លេខាភូមិភាគកណ្តាល កែ ពក លេខាភូមិភាគឦសាន ម៉ែន សាន ហៅ យ៉ា លេខាភូមិភាគបស្ចិម ជូ ជេត ហៅ ស៊ី និងលេខាភូមិភាគឧត្តរ កង ចាប ហៅ សែ ទាំងអស់គ្នាគឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស។ នៅតាមភូមិភាគជាច្រើន លេខាតំបន់នីមួយៗចូលរួមប្រជុំជាមួយគណៈកម្មាធិការភូមិភាគ ហើយអ្នកចូលរួមមានតួនាទីជាអនុលេខាភូមិភាគ ឬជាសមាជិក ឬសមាជិកបម្រុងនៃគណៈកម្មាធិការភូមិភាគ។

## កងទ័ពបដិវត្តកម្ពុជា

១២៥- រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ប្រគល់ឲ្យកងទ័ពបដិវត្តកម្ពុជានូវតួនាទី "ការពាររដ្ឋអំណាច" និង"រួមចំណែកកសាងប្រទេស"។ កងទ័ពបដិវត្តកម្ពុជាទាំងបីប្រភេទ៖ កងស្រួច កងតំបន់ និងកងឈ្លប ផ្តល់នូវសន្តិសុខខាងក្នុង និងខាងក្រៅ ក្រោមការដឹកនាំផ្តាច់មុខដាច់ខាតរបស់ ប.ក.ក។ កងទ័ពបដិវត្តកម្ពុជាស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីគណៈអចិន្ត្រៃយ៍ របស់ ប.ក.ក ជាពិសេស សមាជិកគណៈកម្មាធិការយោធា ដែលរួមមាន ប៉ុល ពត នួន ជា និង សុន សេន។ សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ផ្តល់អំណាចឲ្យ ប៉ុល ពត នូវការទទួលខុសត្រូវរួមលើយោធា ហើយ សុន សេន ទទួលបន្ទុកសេនាធិការ និងសន្តិសុខ។ សេនាធិការរបស់កងទ័ពបដិវត្តកម្ពុជាដើរតួនាទី ដូចជា បញ្ជា ដាក់ផែនការ

ចុះប្រតិបត្តិការស៊ើបការណ៍ និងភស្តុភារសម្រាប់យោធា រួមមាន ការផ្គត់ផ្គង់អាវុធ និងគ្រាប់រំសេវ។ សុន សេន ក្នុងឋានៈជាអគ្គសេនាធិការ ទទួលបន្ទុកបើកកិច្ចប្រជុំជាទៀងទាត់ ជាមួយមេបញ្ជាការកងពល និងកងវរសេនាធំឯករាជ្យទាំងអស់។ [redacted]។

១២៦- បើតាមបក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តកម្ពុជាត្រូវបានបង្កើតឡើងនៅថ្ងៃទី១៨ ខែមករា ឆ្នាំ ១៩៦៨ ទោះបីមុនឆ្នាំ១៩៧៥ កងទ័ពនេះត្រូវបានគេឲ្យឈ្មោះថា កងទ័ពជាតិរំដោះប្រជាជនកម្ពុជា (PNLAFK) ក៏ដោយ។ នៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ មជ្ឈិមបក្សមិនមានអង្គភាពយោធាខ្លួនឯងទេ ដោយពឹងផ្អែកទៅលើកងទ័ពរបស់ភូមិភាគ ដែលខ្លួនជាអ្នកចេញបទបញ្ជា និងយុទ្ធសាស្ត្រ។ **ខៀវ សំផន** បានកាន់តួនាទីពីរ ជាអនុប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាអគ្គបញ្ជាការ PNLAFK ប៉ុល ពត មានតួនាទីជាប្រមុខថ្នាក់ដឹកនាំយោធានៅក្នុងជួរកងទ័ព **នួន ជា** ជាប្រមុខមេដឹកនាំនយោបាយនៅក្នុងជួរកងទ័ព ហើយ សុន សេន ជាអគ្គសេនាធិការ។

១២៧- ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឋានានុក្រមយោធាត្រូវបានរៀបចំជាថ្មី ដោយមជ្ឈិមបក្ស រចនាសម្ពន្ធថ្មីនៃកងទ័ពបដិវត្តកម្ពុជា ត្រូវបានប្រកាសដោយ ប៉ុល ពត នៅក្នុងសុន្ទរកថាមួយដែលបានធ្វើឡើង នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ទៅកាន់ទាហានចំនួន៣០០០នាក់។ សុន

សេន ក្លាយជាអគ្គសេនាធិការ និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ។ អតីតកងពលយោធានៅតាមភូមិភាគ ត្រូវបានរៀបចំជាកងពលថ្មី ដែលត្រូវរាយការណ៍ផ្ទាល់ទៅសេនាធិការ។ កងពលធំៗដែលបង្កើតនៅក្រោមមជ្ឈិមបក្ស រួមមានៈ

(ក) *កងពល១៦៤* ត្រូវបានបង្កើតចេញពីកងពលទី៣ មកពីភូមិភាគនិរតី ហើយក្លាយជាកងពលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ដែលមានមូលដ្ឋាននៅកំពង់សោម។ [redacted]។

(ខ) *កងពល១៧០* ឈរជើងនៅភូមិភាគបូព៌ាទល់មុខនឹងក្រុងភ្នំពេញ ដែលមានភារកិច្ចការពារមជ្ឈិមបក្ស។ មុនដំបូង ប្រធានកងពលនេះគឺឈ្មោះ ចាន់ ចក្រី ហៅ នៅ មាន ដែលកាន់តំណែងនេះរហូតដល់ពេលចាប់ខ្លួននៅខែឧសភា ឆ្នាំ១៩៧៦។

(គ) *កងពល២៩០* មានមូលដ្ឋាននៅភូមិភាគបូព៌ា និងទទួលខុសត្រូវតំបន់២៤ ហើយមិត្ត តាល់ ជាប្រធានកងពល។

(ឃ) *កងពល៣១០* មានមូលដ្ឋាននៅម្តុំក្រុងភ្នំពេញ (ជ្រោយចង្វារ) និងមានភារកិច្ចការពារមជ្ឈិមបក្ស។ មុនដំបូង ប្រធានកងពលនេះគឺឈ្មោះ ស្បូវ ហ៊ឹម ហៅ អឿន ដែលកាន់តំណែងរហូតដល់ពេលចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៧។

(ង) *កងពល៤៥០* មានមូលដ្ឋាននៅភូមិភាគឧត្តរ។ មុនដំបូង លេខាកងពលនេះគឺឈ្មោះ ជា ណុន ហៅ សួង ដែលកាន់តំណែងរហូតដល់ពេលចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៧។

(ច) *កងពល៥០២* មានមូលដ្ឋាននៅព្រលានយន្តហោះពោធិ៍ចិនតុង និងបញ្ចូលទាំងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យផងដែរ ហើយត្រូវបានបង្កើតឡើងពីសមាសភាពនានាពី

ភូមិភាគផ្សេងគ្នា រួមមាន កងពល១១ របស់ភូមិភាគពិសេស។ [redacted]។ (ដូចបានពិភាក្សាពិស្តាររួចមកហើយនៅផ្នែក *ការងារពលកម្មដោយបង្ខំ* នៅក្នុងដីកានេះ ដែលថាកងពល៥០២ ប្រតិបត្តិការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង)។

(ឆ) *កងពល៧០៣* ត្រូវបានបង្កើតឡើងពីកងពល១២ របស់ភូមិភាគបូព៌ា និងក៏មានមូលដ្ឋាននៅក្រុងភ្នំពេញ (ខាងត្បូងចំការមន) និងមានភារកិច្ចការពារមជ្ឈិមបក្ស។ មិត្ត ពីន ជាប្រធានកងពលនេះ។

(ជ) *កងពល៨០១* មានមូលដ្ឋាននៅខេត្តរតនៈគិរី (ភូមិភាគឦសាន) និងបង្កើតឡើងដោយការបញ្ចូលគ្នារវាងកងពលតូចលេខ១១ និង ១៤។ សូរ សារឿន ហៅ តា០៥ ជាប្រធានកងពលនេះ។ (ដូចបានពិភាក្សាពិស្តាររួចមកហើយនៅផ្នែក *មន្ទីរសន្តិសុខ* នៅក្នុងដីកានេះដែលថា មន្ទីរសន្តិសុខ អូរកន្សែង (ភូមិ៣) ស្ថិតក្រោមការគ្រប់គ្រងរបស់កងពល ៨០១)។

(ឈ) *កងពល៩២០* ឈរជើងនៅខេត្តមណ្ឌលគិរី (តំបន់១០៥)។ ម៉ែន ម៉េង ហៅ ឈិន ដែលជាប្រធានកងពលចាស់ ត្រូវបានចាប់ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយ ញ៉ែម សាន ឡើងជំនួសវិញ។ (ភ័ស្តុតាងពាក់ព័ន្ធនឹងការសម្រិតសម្រាំងកម្មាភិបាលនៅកងពល៩២០ ត្រូវបានពិភាក្សានៅផ្នែក *មន្ទីរសន្តិសុខភ្នំក្រោល* នៅក្នុងដីកានេះ)។

១២៨- បន្ថែមទៅលើកងពលធំទាំងប្រាំបួននេះ មានកងវរសេនាធំឯករាជ្យ និងមន្ទីរមួយចំនួនស្ថិតក្រោមការគ្រប់គ្រងរបស់សេនាធិការ រួមទាំង កងវរសេនាធំ១៥២ ៣៧៧ និង៤៨៨ និងមន្ទីរ ម-៦៣ និង ម-៦២។ ស-២១ ក៏ស្ថិតក្រោមការគ្រប់គ្រងផ្នែករដ្ឋបាលរបស់សេនាធិការដែរ ទោះ

បីមន្ទីរនេះត្រូវរាយការណ៍ដំណើរការសន្តិសុខទៅគណៈអចិន្ត្រៃយ៍ តាមរយៈ សុន សេន រហូតដល់ខែសីហា ឆ្នាំ១៩៧៧ និងបន្ទាប់មកទៅ **នួន ជា** ក៏ដោយ។ នៅខែមីនា ឆ្នាំ១៩៧៧ កងទ័ពបដិវត្តកម្ពុជាមានទាហានចំនួនប្រហែល៦១០០០នាក់។

១២៩- នៅថ្នាក់ភូមិភាគវិញ មានកងពលប្រចាំការត្រូវស្ថិតនៅក្នុងទីតាំងរបស់ខ្លួន មានភារកិច្ចទៅលើបញ្ហាសន្តិសុខប្រចាំថ្ងៃរបស់ភូមិភាគនោះ។ ជារឿយៗ កងពលនៅតាមភូមិភាគប្រើលេខដដែលៗ ឧទាហរណ៍ កងពលលេខ១ មាននៅភូមិភាគបូព៌ា និរតី បស្ចិម និងពាយ័ព្យ។ នៅតាមភូមិភាគ ស្រុកក៏មានកងវរសេនាតូចសម្រាប់ការពារមូលដ្ឋានរបស់ខ្លួនដែរ។ នៅថ្នាក់ក្រោមនេះ មានកងឈ្លបមូលដ្ឋាន ដែលស្ថិតក្រោមការគ្រប់គ្រងថ្នាក់ឃុំ និងមានភារកិច្ចបឋម គឺផ្នែកសន្តិសុខមូលដ្ឋាន និងឈ្លបយកការណ៍ពីប្រជាជនស៊ីវិល។ ដូចបានពិភាក្សារួចមកហើយ នៅផ្នែកជម្លោះប្រដាប់អាវុធដែលថា ការងារសន្តិសុខនៅតាមព្រំដែន ត្រូវធ្លាក់ទៅលើកងពលតាមមូលដ្ឋានរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ នៅពេលដែលមជ្ឈិមបក្សផ្ទេរកងពលសំខាន់ ទៅឈរជើងតាមព្រំដែនកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅភូមិភាគបូព៌ា។

១៣០- កងពលធំរបស់មជ្ឈិមបក្ស និងកងពលនៃកងទ័ពមូលដ្ឋានរបស់ភូមិភាគ ត្រូវបានបង្កើតដោយយកគំរូតាមសូវៀត ឬចិន ដែលមានចំនួន៣កងពលតូច ក្នុងមួយកងពលធំ ៣កងវរសេនាតូចក្នុងមួយកងវរសេនាធំ ៣កងអនុសេនាធំ ក្នុងមួយអនុសេនាធំ ៣កងអនុសេនាតូច ក្នុងមួយកងអនុសេនាធំ និង៣កងក្នុងមួយកងអនុសេនាតូច។ នៅជាប់នឹងថ្នាក់នីមួយៗមានអង្គភាពពិសេស ដូចជា អង្គភាពអាវុធធុនធ្ងន់ អង្គភាពកាំភ្លើងធំ អង្គភាពរថពាសដែក អង្គភាពដឹកជញ្ជូន

និងអង្គភាពភ័ស្តុភារ និងផ្គត់ផ្គង់។ ក្នុងមួយកងពលមានទាហានប្រមាណ៤០០០នាក់ ទោះបីចំនួននេះមានការប្រែប្រួលទៅតាមពេលវេលាក៏ដោយ។

១៣១- កងពលធំរាយការណ៍ដោយផ្ទាល់ទៅសេនាធិការ។ ការប្រជុំរវាងមេបញ្ជាការកងពល និង សុន សេន ត្រូវបានធ្វើឡើងនៅមន្ទីរសេនាធិការ មួយសប្ដាហ៍ម្ដង ឬមួយខែម្ដង ទៅតាមការចាំបាច់។ បន្ទាប់ពីការប្រជុំទាំងនេះ មេបញ្ជាការកងពលនឹងធ្វើការប្រជុំជាមួយអង្គភាពនៅថ្នាក់ក្រោមទៀត។ ក្នុងអំឡុងពេលមានការសម្រិតសម្រាំងនៅភូមិភាគបូព៌ា និងជម្លោះជាមួយវៀតណាម សុន សេន ក៏មានសមត្ថភាពទាក់ទងជាមួយកងពលនៃកងទ័ពមូលដ្ឋានដោយផ្ទាល់ និងចេញបទបញ្ជាតែម្ដង។ មេបញ្ជាការនៅតាមមូលដ្ឋានដូចជា លេខាភូមិភាគ ឬមេបញ្ជាការកងពលប្រចាំភូមិភាគ មិនមានអំណាចបញ្ជូនទ័ពបន្ថែម ទៅកាន់ទីតាំងពិសេសណាមួយ ក្នុងពេលមានប្រតិបត្តិការសឹកនោះទេ។ ផ្ទុយទៅវិញ មានតែគណៈអចិន្ត្រៃយ៍ទេជាអ្នកមានអំណាច អនុញ្ញាតឱ្យមានការបញ្ជូនទ័ពហើយរាល់សំណើទាំងអស់ត្រូវធ្វើឡើងតាមរយៈគណៈ៨៧០។

១៣២- កម្មាភិបាលដែលត្រូវបានគេសង្ស័យថាជាខ្សែរយៈខ្មាំង ឬមិនស្មោះត្រង់នឹងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវគេបញ្ជូនទៅមន្ទីរស-២១ ឬមន្ទីរសន្តិសុខនៅថ្នាក់កងពលណាមួយ ដូចជា អូរកន្សែង(កងពល៨០១)ជាដើម។ ក្នុងករណីដែលកម្មាភិបាលត្រូវបញ្ជូនទៅស-២១ កងពលនោះត្រូវទទួលខុសត្រូវក្នុងការធានាការបញ្ជូនមនុស្សនោះឱ្យដល់ទីកន្លែង ហើយជួនកាលគេធ្វើការសួរចម្លើយបឋមនៅមន្ទីរសន្តិសុខថ្នាក់កងពលនោះ។

១៣៣- ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានការបណ្ដុះបណ្ដាលជំនាញដែលធ្វើឡើង ដោយគ្រូជនជាតិចិនដែលមកដល់ប្រទេសកម្ពុជារយៈពេលខ្លី បន្ទាប់ពីការដួលរលំរបបសាធារណ

រដ្ឋខ្មែរ។ កម្មាភិបាលមួយចំនួនត្រូវបានបញ្ជូនទៅបណ្តុះបណ្តាលនៅប្រទេសចិន រួមមាន អាកាសយានិក វិទ្យុទាក់ទង រ៉ាដា ការលោតឆ័ត្រយោង និងប្រព័ន្ធការពារផ្លូវអាកាស សម្រាប់កងពល៥០២។ អ្នកបច្ចេកទេសជនជាតិចិនក៏បានជួយសាងសង់ព្រលានយន្តហោះយោធានៅកំពង់ឆ្នាំង និងផ្តល់យោបល់ចំពោះទីតាំង និងការសាងសង់អាគារកំពង់ផែនៅស្ទឹងហាវ សម្រាប់កងពល១៦៤។ ប្រទេសចិនក៏បានផ្តល់នូវអាវុធយុទ្ធភ័ណ្ឌ គ្រាប់រំសេវ និងបរិក្ខារយោធាផ្សេងទៀតដល់កងទ័ពបដិវត្តកម្ពុជា ដែលដឹកតាមកប៉ាល់នៅកំពង់ផែកំពង់សោម។ ក្រៅពីនេះ ក៏នៅមានវគ្គរៀនសូត្រម្តងម្កាលនៅសេនាធិការដែរ។

## បណ្តាញទំនាក់ទំនង

### ទិដ្ឋភាពទូទៅ

១៣៤- មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតនូវ"របបរាយការណ៍ប្រចាំសប្តាហ៍ទៅមន្ទីរ ៨៧០"ជាផ្នែកមួយដែលថ្នាក់ក្រោម នៅក្នុងអង្គការទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវរាយការណ៍ជាទៀងទាត់ទៅថ្នាក់លើស្តីពី "សភាពការណ៍" និង"ការងារ" របស់ខ្លួន។ មានការប្រើនូវបណ្តាញទំនាក់ទំនងមួយដ៏ស្មុគ្រស្មាញ ដើម្បីអនុញ្ញាតឲ្យអង្គភាពផ្សេងទៀតនៃក្បាលម៉ាស៊ីនដឹកនាំរបស់បក្ស រដ្ឋ និងយោធា អាចរាយការណ៍ទៅគណៈអចិន្ត្រៃយ៍បាន។ ដោយមានការសម្របសម្រួលពីមន្ទីរ ក-៧ ក-១៨ និងអង្គភាពផ្សេងទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ បណ្តាញនេះបានប្រើមធ្យោបាយផ្សេងៗយ៉ាងទូលំទូលាយ ដើម្បីរក្សាទំនាក់ទំនងបិតថេរជាមួយអង្គភាពចាត់តាំងផ្សេងទៀត។ មធ្យោបាយទាំងនេះរួមមាន ប្រព័ន្ធវិទ្យុទាក់ទងនៅទូទាំងប្រទេស(បង្កើតនៅខែតុលាឆ្នាំ១៩៧៥) ទូរស័ព្ទ(ទៀងទាត់ និងចល័តតាមមូល

ដ្ឋាន) ទូរលេខ និងលិខិតឆ្លើយឆ្លង។ ដើម្បីរក្សាសន្តិសុខនៅក្នុងរបបនេះបាន កម្មាភិបាលជាន់ខ្ពស់ និងមន្ទីរទាំងអស់ ប្រើលេខកូដផ្ទាល់ខ្លួន។

១៣៥- បណ្ដាញទំនាក់ទំនងនេះ ជួយសម្រួលប្រព័ន្ធរាយការណ៍ទៀងទាត់ដោយគណៈកម្មាធិការនានារបស់បក្សនៃបក្សកុម្មុយនីស្ដកម្ពុជា ក្រសួងនានានៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងអង្គភាពចាត់តាំងទាំងអស់ ដែលផ្ដល់ព័ត៌មានប្រចាំថ្ងៃទៅឱ្យគណៈអចិន្ត្រៃយ៍ ស្ដីពីសភាពការណ៍នៅក្នុងប្រទេស។ បណ្ដាញទំនាក់ទំនងនេះ ក៏ដើរតួនាទីជាយន្តការសម្រាប់ឱ្យគណៈអចិន្ត្រៃយ៍ ចេញសេចក្ដីណែនាំដល់អង្គភាពចាត់តាំងផ្សេងទៀត។ វាអាចឱ្យអង្គភាពចាត់តាំងសំខាន់ៗទាំងអស់ធ្វើការទាក់ទងបានភ្លាមៗជាមួយមន្ទីរស-២១ ដោយធ្វើការផ្លាស់ប្ដូរព័ត៌មានស្ដីពី"ខ្មាំង" ដែលជាប់សង្ស័យ និងរៀបចំបញ្ជូន "ខ្មាំង" ទាំងនោះទៅមន្ទីរស-២១។ បណ្ដាញនេះអាចជួយឱ្យគណៈអចិន្ត្រៃយ៍ រក្សាបាននូវការគ្រប់គ្រងទៅលើការអនុវត្តន៍គោលនយោបាយទាំងអស់របស់បក្សកុម្មុយនីស្ដកម្ពុជា។

## បណ្ដាញវិទ្យុទាក់ទង [ក-១៨ និង ក-១]

១៣៦- ក-១៨ ជាមន្ទីរទូរលេខសំខាន់របស់បក្សកុម្មុយនីស្ដកម្ពុជា ដែលមានទីតាំងនៅមុំអតីតស្ថានទូតសហរដ្ឋអាមេរិក នៅកែងមហាវិថីនរោត្ដម និងមហាវិថីសុទ្ធារស។ ក-១៨ ទទួលខុសត្រូវផ្នែកវិទ្យុទាក់ទងរវាងមជ្ឈិមបក្ស និងភូមិភាគ រួមទាំងទីតាំងនានាដែលនៅក្រៅប្រទេសកម្ពុជាផងដែរ។ ក្រុមកម្មាភិបាលដែលទទួលខុសត្រូវក្នុងការបញ្ជូន និងពាក់ព័ន្ធវិទ្យុទាក់ទងត្រូវប្រើលេខសម្ងាត់ម៉កតាមរលកវិទ្យុ។

១៣៧- នៅ ក-១ មានក្រុមកម្មាភិបាលទទួលខុសត្រូវសរសេរលេខកូដនិងផ្ញើចេញ និងទទួលនិងបកប្រែលេខកូដ ទៅលើសារទាក់ទង។ មានការបែងចែកជាពីរក្រុមដែលទទួលខុសត្រូវក្នុងការសរសេរលេខកូដ និង បកប្រែលេខកូដចំពោះសារទាក់ទងនេះ។ "ក្រុមក្នុង" ទទួលខុសត្រូវសារទាក់ទងសំខាន់ៗ រីឯ "ក្រុមក្រៅ" ទទួលខុសត្រូវសារទាក់ទងជាប្រចាំធម្មតា។ រាល់សារទាំងអស់ត្រូវសរសេរជាលេខកូដដោយម៉ាទ្រីក ១០ លើ ១០ ចំណែកឯសំឡេងទូរស័ព្ទ និងភាសាទូទៅរួមមានអង្គភាពដែលទទួលការចាត់តាំងនឹងបានទទួលជាតួលេខវិញ។ ចំពោះផ្នែកទំនាក់ទំនងជាសម្ងាត់ឬមានចំណុចរសើបខ្លាំង គេប្រើការសរសេរលេខកូដបន្ថែមទៀត។ នៅដើមទំព័រនៃទូរលេខមានសរសេរជាលេខរៀងឯកសារ ជាមួយលេខខ្ទង់ ដែលផ្តល់ឲ្យភ្នាក់ងារចាំទទួលជាចំនួនតួអក្សរសម្រាប់ផ្សាយចេញ។

១៣៨- នៅមន្ទីរក-១ នៅពេលបានទទួលសញ្ញា និងបកប្រែលេខកូដរួចហើយ កម្មាភិបាលដែលទទួលបន្ទុកផ្នែកទូរលេខ (ប៊ុន និង ចេរ) នឹងពិនិត្យមើលលើការបញ្ជូនសារ និងចារលើឯកសារនោះនូវឈ្មោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវចម្លងជូន។ ទូរលេខត្រូវគេចម្លងដោយប្រើក្រដាសកាបូន ហើយឯកសារដែលចម្លងរួចហើយនៅមន្ទីរទូរលេខ ត្រូវផ្ញើទៅមន្ទីរក-១ ផង និងមន្ទីររបស់ **ខៀវ សំផន** នៅក-៣ ផងដែរ។ ចំពោះទូរលេខដែលចារថា "ឯកសារ" ឬ"មន្ទីរឯកសារ" មានន័យថាឯកសារចម្លងមួយច្បាប់ត្រូវបញ្ជូនទៅមន្ទីរក-១ នៅក្នុងផ្នែកបកប្រែលេខកូដ។ ស្រដៀងគ្នានេះដែរ ឯកសារចម្លងនៃអត្ថបទ និងទូរលេខដែលសរសេរជាលេខកូដត្រូវរក្សាទុកនៅមន្ទីរទទួលនៅថ្នាក់ភូមិភាគ ឬថ្នាក់តំបន់ រហូតទាល់តែមានការអនុញ្ញាតឲ្យកម្ទេចចោល។

## ទូរស័ព្ទ

១៣៩- ប្រព័ន្ធទូរស័ព្ទដំបូងមាននៅក្រុងភ្នំពេញ ដើម្បីបម្រើដល់កម្មាភិបាលជាន់ខ្ពស់ពីរបីនាក់ប៉ុណ្ណោះ។ មានខ្សែទូរស័ព្ទសុវត្ថិភាពមួយរវាង សុន សេន និង ឌុច សម្រាប់ទាក់ទងគ្នាលើបញ្ហានានានៅមន្ទីរស-២១។ **ខៀវ សំផន** នឹងប្រើទូរស័ព្ទមួយនៅគេហដ្ឋានរបស់គាត់ ដើម្បីទាក់ទងជាមួយមនុស្សផ្សេងទៀត។ ប្រព័ន្ធទំនាក់ទំនងទូរស័ព្ទមួយ មានទីតាំងនៅក្នុងក្រសួងសង្គមកិច្ច ដែលអនុញ្ញាតឲ្យ **អៀង ធីរិទ្ធ** អាចធ្វើការទាក់ទងជាមួយអង្គភាពនានា ដែលចំណុះក្រសួងនេះបាន។

## ការទាក់ទងរវាងថ្នាក់លើ និងថ្នាក់ក្រោម

១៤០- សេនាធិការរក្សាក្រុមសរសេរលេខកូដ ជាអ្នកមានតួនាទីផ្ញើទូរលេខជាលេខកូដទៅមន្ទីរ ក-១៨ ដើម្បីបញ្ជូនបន្ត។ សេនាធិការក៏មានសមត្ថភាពទាក់ទងជាមួយកងពលនានារបស់មជ្ឈិម ដោយផ្ទាល់ប្រើវិទ្យុទាក់ទងដែលប្រើលេខកូដ។ ដោយសារមិនមានទំនាក់ទំនងរវាងភូមិភាគ និងអង្គភាពយោធា រាល់ទំនាក់ទំនងទាំងអស់ត្រូវបានធ្វើឡើង តាមរយៈមន្ទីរទំនាក់ទំនងដើម្បីផ្ញើសារជាលេខកូដទៅអង្គភាពដែលពាក់ព័ន្ធ។ ទំនាក់ទំនងរវាងកងពលយោធា និងអង្គភាពក្រោមការគ្រប់គ្រងក៏ប្រើលេខកូដដែរ ដោយផ្តល់ជាព័ត៌មានទាក់ទងទៅនឹងចំនួនមនុស្សស្លាប់ ការបែងចែកសម្ភារៈ និងសំណើសុំទ័ពបន្ថែម។ ការទាក់ទងដែលធ្វើឡើងរវាងសេនាធិការ និងផ្នែកកងពលយ៉ាងហោចណាស់ពីរទៅបីដងក្នុងមួយថ្ងៃ ទៅតាមកម្មវិធីដែលមានការរៀបចំជាមុន ដោយមានការទាក់ទងបន្ថែមទៀតក្នុងករណីពិសេស។ សារទាក់ទងដែលសេនាធិការទទួលបាន ត្រូវបញ្ជូនបន្តទៅមជ្ឈិមបក្ស។

១៤១- កងអនុសេនាធំចល័តដែលមកពីកងពលសំខាន់ៗ ដែលឈរជើងនៅជុំវិញក្រុងភ្នំពេញ តម្រូវឱ្យបោះទីតាំងជាយុទ្ធសាស្ត្រនៅក្នុងក្រុងភ្នំពេញតែម្តង និងត្រូវរក្សាការទាក់ទងតាមវិទ្យុទាក់ទងជាអចិន្ត្រៃយ៍ជាមួយសេនាធិការ។ ក្នុងអំឡុងពេលមានជម្លោះជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមនៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ មជ្ឈិមបក្សជាអ្នកពិនិត្យតាមដានពីការចរាចរវិទ្យុទាក់ទងរវាងអង្គភាពយោធាជួរមុខ។ នៅថ្នាក់ភូមិភាគ កងពលមូលដ្ឋានត្រូវទាក់ទងដោយប្រើសារជាលេខកូដ ដែលបញ្ជូនសារតាមវិទ្យុទាក់ទង។ នៅក្នុងសភាពការណ៍មានការប្រយុទ្ធគ្នា មានវិទ្យុទាក់ទងចំនួនពីរត្រូវបានប្រើ ដើម្បីសម្របសម្រួលដល់អង្គភាពដែលចូលរួមក្នុងប្រតិបត្តិការណ៍យោធាទាំងនោះ។

១៤២- ការបញ្ជូនសារពីភូមិភាគទៅមជ្ឈិមបក្ស និងពីមជ្ឈិមបក្សទៅភូមិភាគវិញត្រូវបានធ្វើឡើងទៅតាមពេលវេលាដែលមានកំណត់ជាទៀងទាត់។ ទំនាក់ទំនងទៅលើបញ្ហានានាដែលចាំបាច់និងបន្ទាន់ ត្រូវបានអនុញ្ញាតឱ្យធ្វើតាមតម្រូវការចាំបាច់។ តំបន់ស្វយ័តដែលមានឋានៈស្មើនឹងភូមិភាគ ត្រូវទាក់ទងដោយផ្ទាល់ជាមួយមជ្ឈិមបក្ស។ មន្ទីររបស់ភូមិភាគនឹងទទួលការបញ្ជូនសារជាលេខកូដរហូតដល់បួន ឬប្រាំដងក្នុងមួយថ្ងៃពីមន្ទីរ៨៧០។

១៤៣- មជ្ឈិមបក្សទាក់ទងទៅស្រុកតាមរយៈភូមិភាគនិងតំបន់។ ការប្រជុំត្រូវបានរៀបចំឡើងនៅថ្នាក់តំបន់ និងស្រុក នៅពេលមានសេចក្តីណែនាំពីមជ្ឈិមបក្ស ដែលត្រូវផ្សព្វផ្សាយដោយផ្ទាល់មាត់ទៅប្រធានអង្គភាព នៅឯកិច្ចប្រជុំថ្នាក់ឃុំនិងសហករណ៍។ នៅថ្នាក់ស្រុក និងតំបន់ លិខិតទាក់ទង ត្រូវបានបញ្ជូនជារៀងរាល់ថ្ងៃទៅមន្ទីរទំនាក់ទំនងកណ្តាលមួយរបស់ភូមិភាគ ហើយនឹងត្រូវ

បញ្ជូនបន្តពីមន្ទីរនោះ។ កម្មាភិបាលដែលធ្វើការនៅផ្នែកបញ្ជូន និងទទួលសារទាក់ទង ដាច់ពីអ្នកដែលទទួលខុសត្រូវក្នុងការសរសេរ និងបកប្រែលេខកូដទូរលេខ។

១៤៤- នៅថ្នាក់ឃុំ និងភូមិ លិខិតទាក់ទង ត្រូវបានបញ្ជូនដោយនិរសារដែលមានភារកិច្ចនាំសំបុត្រពីកន្លែងមួយទៅកន្លែងមួយទៀត។ សារខ្លះដែលត្រូវបញ្ជូនទៅឱ្យអ្នកក្រោមបង្គាប់ គឺធ្វើឡើងដោយផ្ទាល់មាត់។ ស្រដៀងគ្នានេះដែរ អង្គភាពយោធាថ្នាក់ក្រោមត្រូវសរសេរសារផ្ញើទៅថ្នាក់លើតាមរយៈនិរសារ។

១៤៥- នៅក្រុងភ្នំពេញ សារត្រូវបានបញ្ជូនទៅមន្ទីរទំនាក់ទំនងដោយនិរសារ ពីតាមក្រសួងនានា និងមន្ទីរនានារបស់បក្ស ដូចជាក-១ តែតាមរយៈក-៧ ដែលជាអង្គភាពនិរសារក្រុង។ ចំពោះសារវែងៗ ឬសារដែលទាក់ទិននឹងការចាប់ខ្លួនមិនត្រូវយកទៅផ្សព្វផ្សាយទេ តែត្រូវបញ្ជូនតាមរយៈនិរសារទៅឱ្យមជ្ឈិមបក្សតែម្តង។ មន្ទីរក-១ និង ក-៧ នៅក្បែរគ្នា។ មេដឹកនាំជាន់ខ្ពស់បក្សកម្មុយនីស្តកម្ពុជា មាននិរសាផ្ទាល់ខ្លួនដែលត្រូវបញ្ជូនសារនៅជុំវិញក្រុងភ្នំពេញ។ ឧទាហរណ៍ **នួន ជា** បានប្រើនិរសារឱ្យទៅទទួល និងបញ្ជូនសំបុត្រទៅឱ្យ **ឌុច** នៅស-២១។

១៤៦- រាល់លិខិតទាក់ទងរវាងរដ្ឋាភិបាល និងរដ្ឋាភិបាលត្រូវឆ្លងកាត់មជ្ឈិមបក្ស។ លិខិតទាក់ទងពីស្រុកមួយទៅស្រុកមួយ ពីតំបន់មួយទៅតំបន់មួយ ឬពីភូមិភាគមួយទៅភូមិភាគមួយទៀតត្រូវហាមឃាត់ ហើយការទាក់ទងបែបនេះត្រូវតែឆ្លងកាត់មជ្ឈិមបក្សជាមុនសិន។ ភូមិភាគមិនអាចទាក់ទងដោយផ្ទាល់ជាមួយកងពលនានានៃកងទ័ពបដិវត្តកម្ពុជាបានទេ តែអាចទាក់ទងគ្នាបានដោយឆ្លងកាត់មជ្ឈិមបក្សជាមុនសិន។ ជាងនេះទៅទៀត ភូមិភាគមិនត្រូវបានអនុញ្ញាតឱ្យទាក់

ទងដោយផ្ទាល់ជាមួយសេនាធិការទាក់ទិននឹងបញ្ហាយោធាទេ ហើយការទាក់ទងអាចធ្វើបាន ដោយឆ្លងកាត់មន្ទីរ៨៧០ ជាមុនសិន។

**រវាងស្ថានទូត និងស្ថានទូត**

១៤៧- ទំនាក់ទំនងរវាងក្រសួងការបរទេស (MFA) និងបេសកកម្មការទូតកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឡើងតាមរយៈស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅក្រុងប៉េកាំង។ ទូរលេខដែលសរ សេរជាលេខកូដ ត្រូវបានបញ្ជូនដោយផ្ទាល់ជាទម្រង់លេខកូដម៉កពីក្រសួងការបរទេស ទៅឲ្យស្មៀនកាន់លេខកូដ និងអ្នកទទួលបន្ទុកបញ្ជូនទូរលេខ ដែលមានមូលដ្ឋាននៅស្ថានទូតក្នុងក្រុងប៉េងកាំង។ ស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅក្រុងព្យុងយ៉ាងប្រទេសកូរ៉េខាងជើង ទាក់ទងជាមួយមជ្ឈិមបក្សតាមរយៈទូរលេខ ហើយស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវក៏ប្រើមធ្យោបាយទំនាក់ទំនងដូចគ្នានេះដែរ។ កងពល៥០២ រក្សាអង្គភាពទំនាក់ទំនងឯករាជ្យតាមរយៈការទាក់ទងតាមរលកធាតុអាកាសពីក្រុងវៀងច័ន្ទ ហាណូយ និង ប៉េកាំង។

**ឯកសារបោះពុម្ពផ្សាយ និងទំនាក់ទំនងផ្ទៃក្នុង**

១៤៨- មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ទំនាក់ទំនងជាទៀងទាត់រួមមាន សំបុត្រ អនុស្សរណៈ របាយការណ៍ ការណែនាំពីគោលនយោបាយ និងការបោះពុម្ពផ្សាយជាផ្លូវការដូចជាទស្សនាវដ្តី *ទង់បដិវត្ត* និង*យុវជនបដិវត្ត*។ ទស្សនាវដ្តី *ទង់បដិវត្ត* និង*យុវជនបដិវត្ត* គឺជាប្រភពផ្លូវការសម្រាប់ផ្សព្វផ្សាយគោលនយោបាយផ្ទៃក្នុងរបស់របបនេះ។ ទស្សនាវដ្តី *ទង់បដិវត្ត* និង *យុវជនបដិវត្ត* ត្រូវបានចែកចាយទៅដល់ថ្នាក់ភូមិភាគ តំបន់ ស្រុក និង ឃុំ និងកំហិតត្រឹមតែបក្សជនប៉ុណ្ណោះ។ ដោយវាជាឯកសារដែលមានកំហិត ទស្សនាវដ្តីទាំងនេះត្រូវបានបោះពុម្ពនៅមន្ទីរក-

២៥។ ខ្លឹមសាររបស់ទស្សនាវដ្ដី *ទង់បដិវត្ត* និង*យុវជនបដិវត្ត* ត្រូវបានគេយកទៅអានក្នុងពេលប្រជុំ និងវគ្គរៀនសូត្រនានា។ ទស្សនាវដ្ដីទាំងនេះ ក៏ត្រូវបានផ្ញើទៅស្ថានកុងស៊ុល និងស្ថានទូតនានារបស់កម្ពុជាប្រជាធិបតេយ្យដែរ។

១៤៩- ទំនាក់ទំនងភាគច្រើនរវាងមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្ដកម្ពុជាធ្វើឡើងដោយផ្ទាល់មាត់ ដោយសារមេដឹកនាំទាំងនោះរស់នៅ និងធ្វើការជាមួយគ្នារៀងរាល់ថ្ងៃនៅ ក-១ និង ក-៣ ក្នុងក្រុងភ្នំពេញ។ សមាជិកគណៈអចិន្ត្រៃយ៍ក៏មានធ្វើដំណើរជាទៀងទាត់ ទៅតាមអង្គភាពចាត់តាំងថ្នាក់ក្រោមដែរ ដើម្បីប្រមូលព័ត៌មាន និងចេញសេចក្ដីណែនាំដោយខ្លួនឯង។

១៥០- ការផ្សាយវិទ្យុស្ដីពីសេវាកម្មតាមផ្ទះនៅក្រុងភ្នំពេញ ក៏ត្រូវបានគេប្រើផងដែរសម្រាប់ផ្សព្វផ្សាយព័ត៌មាន។ សុន្ទរកថារបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្ដកម្ពុជា ត្រូវគេធ្វើការកែសម្រួលយ៉ាងប្រុងប្រយ័ត្នមុននឹងយកទៅអានតាមវិទ្យុ ហើយ “ចម្លើយសារភាព” របស់ឈ្លើយសឹកវៀតណាម ក៏ត្រូវបានយកទៅផ្សាយផងដែរ។

## ការតាមដានរបាយការណ៍អន្តរជាតិ

១៥១- គណៈអចិន្ត្រៃយ៍បានតាមដានយ៉ាងយកចិត្តទុកដាក់ទៅលើព័ត៌មានអន្តរជាតិ ដោយមានរបាយការណ៍ប្រចាំថ្ងៃ ត្រូវបានចែកជូនដោយផ្ទាល់ដល់មេដឹកនាំកំពូល ពីក្រសួងឃោសនាការដែលទទួលខុសត្រូវតាមដានរាល់ព័ត៌មាន និងរបាយការណ៍ទាក់ទិននឹងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសនានាដែលនៅជុំវិញ។ នេះជាភារកិច្ចរបស់មន្ទីរក-៣៣ ដែលត្រូវទទួលខុសត្រូវក្នុងការចាប់យកទិន្នន័យពីប្រទេសនានាជាភាសាបរទេស បន្ទាប់មកយកមកបកប្រែ និងបញ្ជូនបន្តទៅមជ្ឈិមបក្ស។

# គ- ផែនការឧក្រិដ្ឋកម្មរួម

១៥២- ជនត្រូវចោទទាំងនេះ គឺជាអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មនានាដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះតាមរយៈសហកម្មឧក្រិដ្ឋកម្មរួមមួយ។ សហកម្មឧក្រិដ្ឋកម្មរួមនេះ បានចាប់ផ្ដើមមានអត្ថិភាពយ៉ាងហោចណាស់ក៏ចាប់តាំងពីត្រឹមខែមិថុនា ឆ្នាំ១៩៧៥មក ហើយបានបន្តនៅក្នុងទូទាំងអម្ពុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រហូតមកទល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលនៅក្នុងអម្ពុងពេលនោះឧក្រិដ្ឋកម្មទាំងឡាយដូចដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះត្រូវបានប្រព្រឹត្ត។

## គោលដៅ

១៥៣- គោលដៅជាចំបងនៃសហកម្មឧក្រិដ្ឋកម្មរួមនេះទាក់ទងទៅនឹងចេតនារបស់ជនត្រូវចោទក្នុងការចង់ពង្រឹងការអនុវត្តនូវបដិវត្តន៍នយោបាយមួយ និងបំផ្លាញចោលនូវអ្នកនយោបាយប្រឆាំងណាមួយនឹងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្ត (បកក)។ មានគោលដៅសំខាន់ៗចំនួន៣នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម៖ (១)គឺដើម្បីចង់ដាក់ប្រជាជនស៊ីវិលចំនួនភាគច្រើនបំផុតឲ្យទៅជាទាសករនៅតាមបណ្ដាសហករណ៍កសិកម្ម និងការដ្ឋានពលកម្មនានា។ (២)ដើម្បីធ្វើការលុបបំបាត់ចោលឲ្យអស់នូវរាល់សិទ្ធិមនុស្ស និងសេរីភាពរបស់ប្រជាជនដែលរួមមាន សិទ្ធិក្នុងការរស់រានមានជីវិត មានសេរីភាព និងសន្តិសុខ សិទ្ធិក្នុងការនិយាយស្ដីដោយសេរី សិទ្ធិមានគ្រួសារ និងសិទ្ធិខាងសាសនា។ និង (៣)ដើម្បីស្រាវជ្រាវរកកលក្ខណៈជាប្រព័ន្ធ និងដើម្បីសម្លាប់ជនទាំងឡាយណាដែលត្រូវបានស្គាល់អត្តសញ្ញាណថាជាសត្រូវឬ អ្នកប្រឆាំងពិតប្រាកដ

និងដ៏មានសក្តានុពលរបស់ បកក ។ គោលដៅទាំងនេះដែលមានលក្ខណៈឧក្រិដ្ឋ ត្រូវបានគេព្រមព្រៀងគ្នាថាត្រូវសំរេចឲ្យបានតាំងតែពីដំបូងមក ដោយមធ្យោបាយនានា ដែលរួមមានការប្រព្រឹត្តិនូវបទឧក្រិដ្ឋកម្មផ្សេងៗដូចជា ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការជម្លៀសចេញដោយការប្រើកម្លាំង ការធ្វើឲ្យទៅជាទាសករ ការធ្វើពលកម្មដោយបង្ខំ ការឲ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការចាប់រំលោភសេពសន្ថវៈ ការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ អំពើអមនុស្សធម៌និងឧក្រិដ្ឋកម្មដទៃទៀតដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះស្រាប់។ ឧក្រិដ្ឋកម្មទាំងនេះត្រូវផ្តន្ទាទោសផ្អែកតាមមាត្រា ៣(ថ្មី) មាត្រា៤ ៥ និងមាត្រា៦ នៃច្បាប់ អវតក។

១៥៤- នៅក្នុងឆ្នាំ១៩៧៧ ជនត្រូវចោទទាំងនេះព្រមទាំងសមាជិកដទៃៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួមបានពង្រីកមធ្យោបាយនៃឧក្រិដ្ឋកម្មរបស់ខ្លួន ដោយរួមបញ្ចូលនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើក្រុមជនជាតិចាម និងវៀតណាមដែលនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ ទោះបីជាគោលដៅឧក្រិដ្ឋក្នុងការសម្លាប់ពួកអ្នកដែលគេយល់ឃើញថាជាសត្រូវឬអ្នកប្រឆាំងពិតប្រាកដឬដ៏មានសក្តានុពល គឺស្ថិតនៅដដែល មិនមានការប្រែប្រួលទេនៅក្នុងអំឡុងពេលទាំងមូលនៃសហកម្មឧក្រិដ្ឋកម្មរួមនោះក៏ដោយ ក៏ការផ្តោតរបស់មជ្ឈិមបក្សបានប្តូរទិសសំដៅឆ្ពោះទៅរកពួកក្បត់ផ្ទៃក្នុងកាន់តែខ្លាំងឡើង។ ក្នុងការចាប់ផ្តើមដំបូងផ្នែកនេះនៃសហកម្មឧក្រិដ្ឋកម្មរួម បានផ្តោតជាសំខាន់ទៅលើពួកអ្នកដែលសមាជិកនៃរបបសាធារណៈរដ្ឋខ្មែរ និងជនដទៃៗទៀតដែលត្រូវបានគេយល់ឃើញថា មានការជាប់ទាក់ទងទៅនឹងវណ្ណៈមូលធន សក្តិភូមិ ចក្រពត្តិ និងអភិជន។ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មជ្ឈិមបក្សបានខំប្រឹងផ្តោតការប្រមូលផ្តុំរបស់ខ្លួនលើការសម្លាប់ពួកអ្នកដែលត្រូវបានគេចោទថាជាភ្នាក់ងារ និងអ្នកចូល

ដៃជាមួយ សេអ៊ីអា កាហ្សេបេ និងវៀតណាម ដែលត្រូវបានគេគិតស្មានថា បានជ្រៀតចូលនៅតាមតំបន់មូលដ្ឋាននានា និងក្នុងជួរបក្សនៅគ្រប់លំដាប់ថ្នាក់ក៏ដូចជាជនដទៃទៀតណាក៏ដោយ ដែលត្រូវបានយល់ឃើញថាប្រឆាំងចំពោះបក្ស។

## សមាជិកភាព

១៥៥- សមាជិកនានានៃសហឧក្រិដ្ឋកម្មរួម រួមមាន៖ សមាជិកទាំងឡាយនៃ គណៈអចិន្ត្រៃយ៍នៃ បកក ដែលជាក់ស្តែង និង*កំពុងកាន់តំណែងក្នុងពេលនោះ(តាមព្រឹត្តន័យ)* ពោលគឺ៖ ប៉ុល ពត **នួន ជា អៀង សារី ខៀវ សំផន** សុន សេន តា ម៉ុក សោ ភឹម វន វ៉េត និងសៀ វ៉ាស៊ី។ សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សនៃ បកក ប្រធាន និងសមាជិកគណៈកម្មការនានានៃ បណ្តាក្រសួងនានានៃ បកក ដែលក្នុងនោះរួមមាន **អៀង ធីរិទ្ធ** និងលេខាភូមិភាគ តំបន់នានានៃ បកក និងកងពលធំរបស់មជ្ឈិមបក្ស។ ជនម្នាក់ៗក្នុងចំណោមជនទាំងនេះ ដោយសារតែអំពើ ឬការខាតខានរបស់ខ្លួន បានរួមចំណែកនៅក្នុងការធ្វើឲ្យបានសម្រេចនូវការចែករំលែកនូវគោលដៅនៃសហឧក្រិដ្ឋកម្មរួម។ ផ្ទុយទៅវិញ ជនមួយចំនួននៅក្នុងចំណោមជនទាំងនេះ គឺមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនោះទេ តែពួកគេត្រូវបានសមាជិកនៅក្នុងសហកម្មនេះប្រើប្រាស់ ដើម្បីឲ្យអនុវត្តនូវឧក្រិដ្ឋកម្មផ្សេងៗដែលត្រូវបានប្រព្រឹត្ត ដើម្បីជួយជំរុញគោលដៅរបស់ខ្លួនឲ្យបានស្ថិតនៅជាបន្តទៅទៀត។

# ការអនុវត្ត

១៥៦- គោលដៅនានានៃសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានអនុវត្តដោយជនត្រូវចោទទាំងនេះនិងសមាជិកដទៃទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម ក្នុងចំណោមគោលដៅដទៃៗទៀតជាច្រើនតាមរយៈៈ (១) ដោយការត្រួតមើលពីលើ និង/ឬការចូលរួមដោយផ្ទាល់ នៅក្នុងស្ថាប័នសំខាន់ជាគន្លឹះនានាដែលចូលរួមនៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗដែលរួមមាន កងទ័ពបដិវត្តន៍កម្ពុជា បណ្តាក្រសួងនានានៃកម្ពុជាប្រជាធិបតេយ្យ គណៈកម្មាធិការស្រុកនិងឃុំ និងមន្ទីរសន្តិសុខនានាដូចជាមន្ទីរស-២១ផង ព្រមទាំងគណៈកម្មាធិការនានារបស់ បកក ដែលស្ថិតនៅក្នុងបណ្តាការដ្ឋានពលកម្មដោយបង្ខំ និងសហករណ៍នានា។ (២)ដោយកិច្ចប្រជុំនានា ដែលរួមមាន ការប្រជុំជាមួយកម្មាភិបាលជាន់ខ្ពស់ដែលស្ថិតនៅក្រោមការត្រួតពិនិត្យពីសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួម (ឧទាហរណ៍ដូចជា មេដឹកនាំតំបន់នានា និងមន្ត្រីផ្លូវការណ៍នៃបណ្តាក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យ)។ (៣)ដោយសារាចរណែនាំ សេចក្តីណែនាំ និងសេចក្តីសម្រេចផ្សេងៗដែលដាក់ចេញដោយស្ថាប័នកំពូលនានានៃ បកក (ដែលរួមមាន គណៈកម្មាធិការមជ្ឈិមបក្ស គណៈកម្មាធិការអចិន្ត្រៃយ៍ និងមន្ទីរនយោបាយ-៨៧០) រួមទាំងសារាចរនានាពីមន្ទីរ៨៧០និងការបោះផ្សាយទស្សនាវដ្តីទង់បដិវត្តន៍និងយុវជនបដិវត្តន៍។ (៤)ដោយការប្រើប្រាស់នូវប្រព័ន្ធខ្សែរយៈរាយការណ៍តាមខ្សែបណ្តាយដ៏តឹងរឹងមួយ ដើម្បីត្រួតមើលលើការអនុវត្តផែនកាឧក្រិដ្ឋ និងដោយការដាក់ចេញជាសេចក្តីណែនាំជាបន្ថែមទៀត ហើយបន្ទាប់មកទទួលរបាយការណ៍។ និង(៥)ដោយការបំពាក់បំប៉ននូវទ្រឹស្តីនយោបាយ ដល់បណ្តាកម្មាភិបាលនានានៃ

បកក តាមរយៈការឃោសនាផ្ទៃក្នុង ការណែនាំ និងរៀនសូត្រអំពីមនោគមន៍វិជ្ជា ហើយនិង ការថ្លែងសន្ទរកថា និងការប្រកាសផ្សេងៗ។

## ទិដ្ឋភាពជាទូទៅដោយសង្ខេបអំពីសហកម្មឧក្រិដ្ឋកម្មរួម

### គោលដៅទី១៖ ការធ្វើឱ្យទៅជាទាសករ

១៥៧- ការធ្វើឱ្យទៅជាទាសករនូវប្រជាជនស៊ីវិលភាគច្រើនយ៉ាងទូលំទូលាយ នៅតាមបណ្តាសហករណ៍កសិកម្មនិងការដ្ឋានពលកម្មដោយបង្ខំនានា គឺជាគោលដៅចំបងជាងគេមួយក្នុងចំណោមគោលដៅចំបងៗចំនួនបីនៃសហកម្មឧក្រិដ្ឋកម្មរួម។ តាមរយៈគោលដៅនេះ សមាជិកទាំងឡាយនៃសហកម្មឧក្រិដ្ឋកម្មរួម ខំប្រឹងស្វែងរកដើម្បីធ្វើការកែប្រែសង្គមកម្ពុជាឱ្យទៅជាគំរូនៃប្រទេសកសិកម្មមួយដែលគ្មានវណ្ណៈហើយដាក់ប្រទេសកម្ពុជា ឱ្យស្ថិតនៅក្រោមការត្រួតត្រាតាមរបបផ្តាច់ការរបស់ពួកខ្លួន។ គោលដៅនេះត្រូវបានធ្វើឱ្យសំរេចតាមរយៈការបង្កើតឡើងនូវគោលនយោបាយដ៏ឧក្រិដ្ឋជាគន្លឹះចំនួនពីរគឺ៖ (១)ការជម្លៀសដោយបង្ខំ។ និង(២)ការធ្វើពលកម្មដោយបង្ខំ។ គោលនយោបាយដ៏ឧក្រិដ្ឋទាំងនេះ មិនគ្រាន់តែមានដើមកំណើតចេញមកពីគោលមាគ៌ានយោបាយ នៅពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ-បកក ប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវបានយកមកអនុវត្តយ៉ាងល្អិតល្អន់ក្រោយពី បកក បានឡើងកាន់កាប់អំណាចទៀតផង។

### ការជម្លៀសដោយបង្ខំ

១៥៨- ក្នុងការជួយជំរុញធ្វើឱ្យគោលដៅចំបងរបស់ បកក ក្នុងការធ្វើប្រជាជនឱ្យក្លាយទៅជាទាសករបាន បន្តទៅមុខទៀត បកក បានអនុវត្តនូវគោលនយោបាយឧក្រិដ្ឋរបស់ខ្លួនក្នុងការជម្លៀសជនស៊ីវិលរាប់លាននាក់ដោយបង្ខំ។ ដូចបានរៀបរាប់យ៉ាងពិស្តារនៅក្នុងផ្នែកស្តីពីការជម្លៀសចេញដោយបង្ខំ រួចហើយគោលនយោបាយស្តីពីការធ្វើឱ្យទៅជាទាសករនេះត្រូវបានអនុវត្តជាផ្នែកៗតាមរយៈ ការជម្លៀសចេញដោយបង្ខំក្នុងទ្រង់ទ្រាយធំដែលជាគន្លឹះចំនួនបីគឺ៖

(១) ***ការជម្លៀសឱ្យចេញពីទីប្រជុំជននៃទីក្រុងនានា:*** ការជម្លៀសចេញដោយបង្ខំរួមមានការបណ្តេញប្រជាជនឱ្យចេញពីបណ្តាទីប្រជុំជននៃទីក្រុងសំខាន់ៗនានាដែលរួមមាន ទីក្រុងភ្នំពេញ បាត់ដំបង កំពង់សោម ព្រៃវែង ពោធិសាត់ និងសៀមរាប និងការបង្ខំប្រជាជនឱ្យនៅតាមសហករណ៍ជនបទនានាក្នុងពេលភ្លាមៗបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ការជម្លៀសចេញទាំងនេះ គឺជាការខំប្រឹងស្វែងរកដើម្បីបន្សាបកម្លាំងនៃតំបន់ទាំងឡាយណាដែលគេយល់ឃើញថាមានការតស៊ូខាងយោធា និងនយោបាយដ៏ខ្លាំងក្លាជាងគេបង្អស់ប្រឆាំងនឹង បកក ដើម្បីជួយជំរុញធ្វើឱ្យការវាយកំទេច ពួកមូលធននិយមបានដំណើរការតទៅមុខទៀត និងបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តនូវគោលនយោបាយពលកម្មដោយបង្ខំ។

(២) *ជំហានលើកទី២នៃការជម្លៀសដោយបង្ខំ៖* ជំហានទី២ នៃការបំលាស់ទីប្រជាជនក្នុងទ្រង់ទ្រាយធំដោយបង្ខំឱ្យទៅតាំងទីលំនៅថ្មីបានចាប់ផ្តើមនៅនាចុងខែកញ្ញា និងដើមខែតុលា ឆ្នាំ១៩៧៥ ហើយបានតម្រូវឱ្យការបំលាស់ទីជនស៊ីវិលយ៉ាងហោចណាស់ក៏ចំនួន៥០០០០០នាក់ ដែលភាគច្រើនជាប្រជាជនថ្មី ឱ្យទៅកាន់ភូមិភាគពាយ័ព្យ ក៏ដូចជារាប់សែននាក់ទៀត ឱ្យទៅកាន់ភូមិភាគឧត្តរចាស់ និងតំបន់ព្រះវិហារ។ ការជម្លៀសចេញដោយបង្ខំលើក

នេះដោយសេចក្តីសម្រេចរបស់មជ្ឈិមបក្សនៃ បកក ដើម្បីចង់បង្កើនផលិតផលកសិកម្មនៅក្នុង តំបន់ទាំងនេះតាមមធ្យោបាយការធ្វើពលកម្មដោយបង្ខំ។

(៣)*ដំណាក់កាលទី៣ នៃការជម្លៀសចេញដោយបង្ខំ៖* ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពីការបោសសំអាតនៅភូមិភាគបូព៌ាស្រាប់ហើយ ការបោសសំអាតរួមមានការជម្លៀសឲ្យចេញដោយបង្ខំប្រជាជនភូមិភាគបូព៌ាស្ទើរតែទាំងអស់ឲ្យទៅកាន់ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី ភូមិភាគពាយ័ព្យ ភូមិភាគឥសាន្ត ភូមិភាគបស្ចិម និងនិរតីនៅក្នុងត្រីមាសទី២និងទី៣ នៃឆ្នាំ១៩៧៨។ ការជម្លៀសនេះជាចំបងគឺដោយសារមូលហេតុដែលគេមានការយល់ឃើញថាមានការជ្រៀតចូលនៃភ្នាក់ងារគិញរបស់វៀតណាមនៅក្នុងភូមិភាគ និងនៅក្នុងអ្នកគាំទ្រនានានៅក្នុងភូមិភាគនោះ។

១៥៩- នៅក្នុងពេលនៃការជម្លៀសចេញមួយលើកៗមានជនស៊ីវិលក្នុងចំនួនយ៉ាងច្រើន បានស្លាប់ដោយសារការបាក់កម្លាំង ការអត់អាហារ ការស្ថិតនៅហាលថ្ងៃហាលខ្យល់ ជម្ងឺឈឺថ្កាត់ និង/ឬ ការសម្លាប់ដោយកម្មាភិបាលរបស់ បកក។ ការជម្លៀសប្រជាជនឲ្យចេញដោយបង្ខំលើកទី១ គឺជាកម្មវត្ថុនៃការធ្វើផែនការ និងការត្រៀមរៀបចំមួយដែលធ្វើឡើងដោយសមាជិកនានានៃសហកម្មឧក្រិដ្ឋកម្មរួមជាយូរមកហើយ តាំងពីមុនពេលឡើងកាន់អំណាចមកទៅទៀត។ ផលប្រយោជន៍របស់បដិវត្តន៍ពឹងផ្អែកទៅលើជនបទជាជាងទីក្រុង ត្រូវបានគូសបញ្ជាក់ដោយមេដឹកនាំជាន់ខ្ពស់នានាតាំងពីដំបូងទីមកគឺតាំងពីពេលធ្វើសន្និបាតបក្សលើកទី១ ដែលធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០ មកម្ល៉េះ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ គណៈមជ្ឈិមបក្សនៃ បកក បានសម្រេចថាត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងពីគ្រប់ទីប្រជុំជនដទៃទៀតទាំងអស់។ ផែនការស្ថាពរនៃការជម្លៀសដោយបង្ខំនេះ បន្ទាប់មកត្រូវបានដឹកនាំឲ្យធ្វើនៅ

ក្នុងអង្គប្រជុំមួយនៃគណៈកម្មាធិការសមរភូមិចម្រុះ នាដើមខែមេសា ឆ្នាំ១៩៧៥ ដែលនៅក្នុងអង្គប្រជុំនោះ **នួន ជា** និង **ខៀវ សំផន** ទាំងពីរនាក់ បានអនុម័តយល់ព្រមនៅលើផែនការសកម្មភាពនេះ។

១៦០- ការអនុវត្តការជម្លៀសដោយបង្ខំ ក្នុងលក្ខណៈនេះបានក្លាយទៅជាគោលនយោបាយបមាណើយរបស់ បកក នៅដើមឆ្នាំ១៩៧១ ហើយត្រូវបានគេអនុវត្តនៅពេលណាដែល បកក បានកាន់កាប់ភូមិ ឬសហគមន៍តូចណាមួយ។ បកក បានជម្លៀសប្រជាជនចេញពីទីរួមខេត្តក្រចេះ និងខេត្តកំពង់ចាម នៅក្នុងឆ្នាំ១៩៧៣ និងចេញពីឧដុង្គ នៅខែមីនា ឆ្នាំ១៩៧៤ ព្រមទាំងជម្លៀសជនជាតិចាមចេញពីភូមិភាគនិរតីក្នុងឆ្នាំ១៩៧៣ ទៅដល់ឆ្នាំ១៩៧៤ ក្នុងគោលបំណងដើម្បីធ្វើឱ្យកម្លាំងខ្មាំងនៅជាមួយនឹងប្រជាជនទីក្រុងមានអស្ថេរភាព។

## ពលកម្មដោយបង្ខំ

១៦១- គោលនយោបាយឧក្រិដ្ឋរបស់ បកក ស្តីពីពលកម្មដោយបង្ខំនេះ គឺជាមធ្យោបាយទីពីរ ដែលពួកសមាជិកនានានៃសហកម្មឧក្រិដ្ឋកម្មរួម បានអនុវត្តនូវគោលដៅរបស់ពួកគេក្នុងការធ្វើឱ្យទៅជាទាសករ។ ការបង្កើតឡើងក្នុងលក្ខណៈដ៏ទូលំទូលាយនៃគោលនយោបាយនេះ គឺត្រូវបានតភ្ជាប់ទៅនឹងគោលដៅរបស់មជ្ឈិមបក្សនៃ បកក ស្តីពីការបង្កើនផលិតផលកសិកម្ម និងការដាក់ឱ្យទៅជាសហភាវូបនីយកម្មដោយបង្ខំ។ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពីពលកម្មដោយបង្ខំ បន្ទាប់ពីការជម្លៀសពួកគេដោយបង្ខំឱ្យចេញពីទីក្រុង(និងទីរួមខេត្ត)នានាមក អ្នកត្រូវគេជម្លៀស ត្រូវបានគេដាក់បង្ខាំងឱ្យនៅតាមសហករណ៍ និងការដ្ឋាននានានៅទូទាំងកម្ពុជាប្រជាធិបតេយ្យ រួមជាមួយនឹងជនស៊ីវិលដទៃទៀត។ នៅតាមសហករណ៍ និងការដ្ឋាននានា

ដែលមាននៅតាមភូមិភាគនីមួយៗ ហើយដែលជាទូទៅតម្រូវឱ្យធ្វើស្រែចម្ការ និងហេដ្ឋារចនាសម្ព័ន្ធនោះ មានពលករារាប់ពាន់នាក់ត្រូវបានគេបង្ខំធ្វើការដោយដៃ ឬដោយប្រើប្រាស់នូវគ្រឿងឧបករណ៍តាមបែបចាស់បុរាណ ដែលជាលក្ខណៈអមនុស្សធម៌មែនទែន ហើយដែលស្ថិតនៅក្រោមការត្រួតពិនិត្យមើលដ៏តឹងរ៉ឹងពីសំណាក់ពួកកម្មាភិបាល បកក។ ពួកអ្នកដែលបានតវ៉ា ឬមិនបានធ្វើការឱ្យបានមុតមាំ ត្រូវបានគេគិតទុកជាមុនថាត្រូវបង្អត់អាហារ វាយធ្វើបាប បង្ខំឱ្យទទួលធ្វើកិច្ចការបន្ថែម ត្រូវបានគេយកទៅឱ្យធ្វើការលត់ដំ ឬ ត្រូវបានគេចាប់ខ្លួន និង/ឬ សម្លាប់ចោល។ នៅក្នុងចំណោមសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំជាច្រើន កិច្ចស៊ើបសួរបានផ្ដោតទៅលើទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំកន្លែង ដែលគេបានអនុវត្តនូវពលកម្មដោយបង្ខំ៖ **សហករណ៍ត្រាំកក់ ស្រែអំបិល ទំនប់១មករា ទំនប់ត្រពាំងថ្ម** និង **អាកាសយានដ្ឋានកំពង់ឆ្នាំង**។

១៦២- ដូចជាគោលនយោបាយរបស់ បកក ស្ដីពីការជម្លៀសដោយបង្ខំនេះដែរ ពួកសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួម បានចាត់ទុកការបង្កើតនូវពលកម្មដោយបង្ខំនេះ ថាមានសារៈសំខាន់យ៉ាងខ្លាំងណាស់សម្រាប់ជោគជ័យនៃរដ្ឋាភិបាលរបស់ពួកគេ។ តាមពិត នៅខែឧសភា ឆ្នាំ ១៩៧២ គណៈមជ្ឈិម បកក ដែលរួមមាន ប៉ុល ពត **នួន ជា អៀង សារី** និងបន្ទាប់មកទៀតបេក្ខជនសមាជិក **ខៀវ សំផន** បានកំណត់ថា សហភាវូបនីយកម្មដោយបង្ខំ ត្រូវតែបានដាក់តម្រូវឱ្យធ្វើជាផ្នែកមួយនៃការរៀបចំកសាងសង្គមកម្ពុជាឡើងវិញរបស់បក្ស។ បកកថែមទាំងធ្លាប់បានអនុវត្តនូវផែនការនេះ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣នៅក្នុងតំបន់នានានៅក្នុងប្រទេសដែលបន្ទាប់មកត្រូវបានត្រួតត្រាដោយ បកក ថែមទៀតផង។

## គោលដៅទី២៖ ការលប់បំបាត់សិទ្ធិមនុស្ស

១៦៣- គោលបំណងសំខាន់ទីពីរនៃសហកម្មឧក្រិដ្ឋកម្មរួម គឺការលប់បំបាត់ចោលនូវសិទ្ធិមនុស្ស និង សេរីភាពទាំងអស់នៅក្នុងទូទាំងកម្ពុជាប្រជាធិបតេយ្យដែលជាការប្រមូលផ្តុំទាំងអស់សម្រាប់ឲ្យ បកក រក្សាបាននូវការត្រួតត្រាមកលើប្រជាជនកម្ពុជា និងការដាក់បង្ខំឲ្យអនុវត្តនូវកម្មវិធីនយោបាយរបស់ខ្លួន។ ជាផលវិបាក សិទ្ធិ និងសេរីភាពរបស់បុគ្គល ត្រូវបានគេលុបបំបាត់ចោល ឬមួយក៏ត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរដោយ បកក នៅក្នុងទូទាំងរយៈកាលដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។ ក្នុងចំណោមសិទ្ធិដែលត្រូវគេលុបបំបាត់ ឬរំលោភ មានសិទ្ធិក្នុងការមានសេរីភាព និងសន្តិសុខ សិទ្ធិក្នុងការគោរពសាសនា សិទ្ធិក្នុងការនិយាយស្តី និងសិទ្ធិក្នុងការមានគ្រួសារ ដូចបានរៀបរាប់លម្អិតដូចខាងក្រោម៖

(១) ***សិទ្ធិក្នុងការរស់រានមានជីវិត មានសេរីភាព និងសន្តិសុខរបស់បុគ្គល៖*** នៅពេល បកក ឡើងកាន់កាប់អំណាចភ្លាមសិទ្ធិជាមូលដ្ឋានបំផុតក្នុងការមានសេរីភាព និងសន្តិសុខរបស់ ជនស៊ីវិលត្រូវបានគេរំលោភបំពាន។ ដូចដែលបានរៀបរាប់យ៉ាងពិស្តារនៅក្នុងផ្នែកការជម្លៀសដោយបង្ខំ រួចមកហើយការជម្លៀសដែលមានលក្ខណៈបង្ខំ និងការជម្លៀសដោយបង្ខំ នៅពេលក្រោយៗមកទៀត គឺមិនត្រឹមតែដកហូតនូវសិទ្ធិរបស់ពួកជនស៊ីវិលនៅក្នុងការមានសេរីភាពធ្វើដំណើរប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានដាក់ពួកទាំងនោះឲ្យឋិតនៅក្នុងលក្ខខណ្ឌ នានាដ៏លំបាកបំផុតថែមទៀតផង។ ផលប៉ះពាល់នៃលក្ខខណ្ឌទាំងនេះទៅលើជនរងគ្រោះ ជាលទ្ធផលគឺមានការស្លាប់ជីវិតមនុស្សអស់រាប់ពាន់ ដែលបណ្តាលមកពីការអត់អាហារ ការហួសកម្លាំង ការរងផលប៉ះពាល់ផ្សេងៗ និងជម្ងឺ។ នៅក្នុងអំឡុងពេលនៃការជម្លៀសម្តងៗ ជនស៊ីវិលក្នុងចំនួនយ៉ាងច្រើនត្រូវបានសម្លាប់

ចោលដោយសារមិនគោរពតាមបញ្ជា ឬដោយ សារពួកគេត្រូវបានកំណត់អត្តសញ្ញាណថា ជាសមាជិកនៃក្រុមដែលជាចំណុចដៅរបស់បក្ស កុម្មុយនីស្តកម្ពុជា។ រដ្ឋអំណាចនានា ដែលជាអ្នកអនុវត្តនូវសារាចរណែនាំផ្សេងៗរបស់មជ្ឈិម បក្សនៃ បកក បានបន្តដាក់បង្ខំ ឲ្យពួកជនរងគ្រោះស្ថិតរស់ក្នុងស្ថានភាពអមនុស្សធម៌យ៉ាង ធ្ងន់ធ្ងរ នៅពេលពួកគេបាន ទៅដល់ឃុំ និងសហករណ៍នានាដែលគ្រប់គ្រងដោយ បកក ព្រោះមិនមានការផ្តល់ឲ្យ បានគ្រប់គ្រាន់នូវអាហារ ជំរក អនាម័យ ឬជាជំនួយផ្នែកពេទ្យអ្វី នោះទេ។ នៅក្នុង ករណីភាគច្រើនគ្រួសារត្រូវបានបែកគ្នាហើយសមាជិកគ្រួសារត្រូវហាមឃាត់ មិនឲ្យធ្វើការទាក់ទងគ្នាទៅមក ក្រៅតែពីរដ្ឋអំណាចរបស់ បកកដែលធ្វើការ ត្រួតពិនិត្យយ៉ាងដឹតដល់បំផុត។ ជនស៊ីវិលទាំងអស់ដែលត្រូវបានគេជម្លៀសឲ្យទៅតាម ការដ្ឋានពលកម្មដោយបង្ខំទាំងនោះ ត្រូវបានគេបង្ខំឲ្យប្រឈមទៅនឹងលក្ខខណ្ឌដ៏រន្ធត់នានា នៃការងារ ដូចបាន រៀបរាប់យ៉ាងលំអិតនៅក្នុងផ្នែកស្តីពីពលកម្មដោយបង្ខំ។ មានការ ស្លាប់ជីវិតមនុស្សរាប់ពាន់ នាក់ដែលបណ្តាលមកពីការអត់អាហារ ការបាក់កម្លាំង និង ជម្ងឺឈឺថ្កាត់ ការរំលោភបំពានលើរាងកាយ និងការសម្លាប់នៅតាមបណ្តាការដ្ឋាន ទាំងនោះ។ ជាការបន្ថែម ដូចដែលបាន រៀបរាប់លំអិតនៅក្នុងផ្នែកស្តីពីមន្ទីរសន្តិសុខនានា ជនណាដែលត្រូវបានគេចាត់ទុកថាជាខ្មាំងនយោបាយ ឬជាអ្នកប្រឆាំងនឹង បកក ត្រូវបាន គេដកហូតនូវសេរីភាព និងសន្តិសុខរបស់ខ្លួន តាមរយៈការចាប់ខ្លួន ការឃុំឃាំង ការធ្វើ បាបដោយអមនុស្សធម៌ ការធ្វើទារុណកម្ម និងការ សម្លាប់ចោល។

(២)***សិទ្ធិសេរីភាពខាងសាសនា*** ផ្នែកដ៏សំខាន់ជាស្នូលមួយនៃ លុបបំបាត់ចោលនូវសិទ្ធិ មនុស្សគ្រប់បែបយ៉ាងហើយ និងការត្រួតត្រាលើប្រជាជន គឺការលុបបំបាត់សាសនា។ រដ្ឋ

ធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦ បានហាមឃាត់មិនឱ្យមានគ្រប់សាសនា "ប្រតិកិរិយា"ទាំងអស់ ដែលការណ៍នេះត្រូវបានគេបកស្រាយ ថារាប់បញ្ចូលទាំងសាសនាអ៊ីស្លាម និងពុទ្ធសាសនាផងដែរ។ គោលនយោបាយរបស់ បកក បានស្តែងឡើងដោយខ្លួនឯងផ្ទាល់ នៅក្នុងការធ្វើទុក្ខបុកម្នេញ ដែលបានទទួលរងដោយពួកអ្នកដែលបានប្រតិបត្តិសាសនា ដែលគេបានហាមឃាត់ទាំងនេះ។ ដូចដែលបានពន្យល់នៅ ក្នុងផ្នែកឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនា ការប្រតិបត្តិសាសនាព្រះពុទ្ធត្រូវបានហាមឃាត់ ទីកន្លែងសម្រាប់គោរពបូជាព្រះពុទ្ធ និងព្រះបដិមាករត្រូវបានបំផ្លាញចោល ហើយព្រះសង្ឃ ត្រូវបានផ្សឹក និងបង្ខំឱ្យធ្វើការងារណាដែលសាសនាបានហាមឃាត់ ព្រមទាំងត្រូវបានសម្លាប់ ចោលទៀតផងនៅក្នុងករណីជាច្រើន។ ជនជាតិចាមក៏ត្រូវបានគេធ្វើទុក្ខបុកម្នេញមាន លក្ខណៈជាប្រព័ន្ធផងដែរ ដូចដែលបានពិពណ៌នានៅក្នុងផ្នែកឧក្រិដ្ឋកម្មប្រឆាំងនឹង ជនជាតិចាម។ បកក មិនត្រឹមតែបានហាមឃាត់ពួកទាំងនោះមិនឱ្យប្រតិបត្តិសាសនាអ៊ីស្លាម និងថែរក្សាវិធីរស់នៅជាប្រពៃណីរបស់ពួកខ្លួនប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៧ បកក ថែមទាំងបានស្វែងរកយ៉ាងសកម្ម ធ្វើការបំផ្លិចបំផ្លាញជារូបវន្តនូវសាសនា និងក្រុមជាតិពន្ធុរបស់ពួកគេថែមទៀតផង ។

(៣) ***សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងគំនិតៈ*** គំនាបនយោបាយ គឺជាទិដ្ឋភាពគន្លឹះមួយរបស់របបបក្សកុម្មុយនីស្តកម្ពុជា និងជារបៀបបន្ថែមមួយដែលសិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាជនត្រូវបានរំលោភ។ ដូចបានរៀបរាប់នៅក្នុងផ្នែកស្តីពីតួនាទីរបស់ជនត្រូវចោទ ជនត្រូវចោទម្នាក់ៗ សុទ្ធតែបានជាប់ពាក់ព័ន្ធក្នុងការបំពាក់បំប៉នគោលនយោបាយទៅលើក

ម្នាភិបាលបក្សកុម្មុយនីស្តកម្ពុជាបញ្ជាវន្តដែលបានធ្វើមាតុភូមិនិវត្ត និងជនស៊ីវិលតាមរយៈការបំពាក់បំប៉នគោលនយោបាយ និងវគ្គអប់រំរៀនសូត្រ ដែលអ្នកចូលរួមនានាត្រូវបានគេអប់រំអំពីមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងបានទទួចឲ្យធ្វើការប្តេជ្ញាចិត្តចំពោះមាគ៌ាបក្ស។ ជនស៊ីវិលក៏ដូចកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែរត្រូវបានគេបង្ខំឲ្យចំណុះទៅនឹងកម្មវិធីស្វ័យទិទានជាបន្តបន្ទាប់ និងបើចាំបាច់ ការលុតដំអប់រំឡើងវិញ និងនៅទីតាំងការដ្ឋានពលកម្មការងារដោយបង្ខំ។ នៅទីតាំងទាំងនោះ ដូចគ្នានឹងនៅមន្ទីរសន្តិសុខនានាដែរពលករ និងអ្នកទោសមិនអាចធ្វើចលនាឬប្រាស្រ័យទាក់ទងដោយសេរីជាមួយគ្នាបានទេ ហើយពួកគេត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការឃ្លាំមើលរបស់ឆ្មាំប្រដាប់អាវុធ ដូចបានរៀបរាប់នៅក្នុងផ្នែកពលកម្មដោយបង្ខំ និងមន្ទីរសន្តិសុខ។ ជនស៊ីវិលទាំងឡាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចបញ្ចេញមតិជំទាស់ផ្នែកនយោបាយចំពោះបក្សកុម្មុយនីស្តកម្ពុជា ទោះក្នុងទម្រង់ណាក៏ដោយ ដោយសារការភ័យខ្លាចចំពោះអាយុជីវិតរបស់ខ្លួន និងជីវិតរបស់គ្រួសាររបស់ពួកគេ ។

(៤) ***សិទ្ធិមានគ្រួសារៈ*** គ្រួសារស្ថិតក្រោមការវាយប្រហាររបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ តាមរយៈការខ្នះខ្នែងក្នុងការត្រួតត្រាប្រជាជន។ មេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាយកការប្តេជ្ញាចិត្តចំពោះបក្ស និងការអនុវត្តតាមសារាចរណែនាំរបស់បក្សខ្ពស់ជាងចំណងសម្ព័ន្ធភាពគ្រួសារ។ នេះត្រូវបានគេអនុវត្តជាក់ស្តែងតាមមធ្យោបាយមួយចំនួន។ អាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគេចាប់បង្ខំឲ្យអនុវត្តយ៉ាងទូលំទូលាយចាប់តាំងដើមឆ្នាំ១៩៧៥ នៅក្នុងគ្រប់ភូមិភាគទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងពាសពេញជួរ

បក្សកុម្មុយនីស្តកម្ពុជា។ ដូចបានរៀបរាប់នៅក្នុងផ្នែកអាពាហ៍ពិពាហ៍ដោយបង្ខំតាមរយៈគោលនយោបាយនេះបក្សកុម្មុយនីស្តកម្ពុជា មិនត្រឹមតែបានដាក់ការបង្ខំទៅលើបុគ្គលជាដៃគូអាពាហ៍ពិពាហ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុញ្ញាតឲ្យមានការរំលោភសេពសន្ថវៈយ៉ាងរីករាលដាល និងការមានផ្ទៃពោះដោយបង្ខំ។ បន្ថែមលើនេះ គ្រួសារទាំងឡាយត្រូវបានគេបំបែកនៅតាមសហករណ៍និងការដ្ឋានពលកម្មដោយបង្ខំ និងនៅតាមមន្ទីរសន្តិសុខនានា ដូចបានរៀបរាប់យ៉ាងលម្អិតក្នុងផ្នែកពលកម្មដោយបង្ខំ ការជម្លៀសដោយបង្ខំ និងមន្ទីរសន្តិសុខ។ ការបែកបាក់គ្រួសារនេះ ក៏មានគ្រួសារចាម និងវៀតណាមផងដែរដែលសមាជិករបស់ពួកគេត្រូវបានដកចេញទាំងបង្ខំក្នុងកិច្ចប្រឹងប្រែង ដើម្បីបំផ្លាញពួកគេ ដូចបានលើកយកមកពិភាក្សានៅក្នុងផ្នែកស្តីពីឧក្រិដ្ឋកម្មប្រឆាំងចាម និងវៀតណាម

## គោលដៅទី៣៖ ការបោសសម្អាតខ្មាំង

១៦៤- គោលដៅទី៣ ជាចំបងនៃសហកម្មឧក្រិដ្ឋកម្មរួមនេះ គឺជាការធ្វើអត្តសញ្ញាណកម្ម និងការបំផ្លិចបំផ្លាញជាប្រព័ន្ធនៃជនទាំងឡាយដែលគេមើលឃើញថាជាខ្មាំង ឬអ្នកប្រឆាំងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ចេតនារបស់ជនត្រូវចោទ គឺដើម្បីពង្រឹងការថ្ពាមអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា និងការគាបសង្កត់ទៅលើការជំទាស់ជាក់ស្តែង ឬជាសក្តានុពលណាមួយចំពោះសិទ្ធិអំណាចដាច់ខាតរបស់បក្ស។ នៅពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាចអាជ្ញាធរបានដាក់ជនស៊ីវិលទាំងអស់នៅក្រោមការឃ្លាំមើលដ៏តឹងរ៉ឹង ដើម្បីតាមដានចាប់ខ្លួនដាក់គុក និងសម្លាប់ជាក់ស្តែង និងខ្មាំងដែលគេសង្ស័យ។ យ៉ាងហោចណាស់ក៏ចាប់តាំងពីឆ្នាំ១៩៧៦ដែរ ដែលកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានធ្លាក់ទៅក្នុងការសម្រិតសម្រាំងរបស់

បក្សកុម្មុយនីស្តកម្ពុជា។ ជនណាដែលគេមើលឃើញថា មានគោលជំហរប្រឆាំងនឹងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ឬអាណិតអាសូរជនដែលគេបានចាត់ទុកថាជាខ្មាំង ត្រូវជាកម្មវត្ថុនៃការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់ចោលនៅ ទីតាំងការដ្ឋាន ឬទីតាំងអប់រំកែប្រែឡើងវិញ។ មានមន្ទីរសន្តិសុខប្រមាណ២៦០កន្លែង និងទីតាំងសម្លាប់រង្គាលរាប់រយ ត្រូវបានបង្កើតឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ សម្រាប់ដាក់គុក ធ្វើទារុណកម្ម និងសម្លាប់ខ្មាំង។ ទាំងនេះរួមមាន មណ្ឌលសន្តិសុខចំនួន១១ ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ (**ស-២១ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច ភ្នំក្រោល វត្តធ្លក អូរកន្សែង**(ភូមិ៣) **វត្តគីរីរម្យ** និង **សៀម រាប**)។ ខណៈដែលក្រុមដែលត្រូវបានគេចាត់ថ្នាក់ថាជា “ខ្មាំង” ត្រូវបានគេពង្រីកបន្ថែមក្នុងអំឡុងពេលនៃសម័យកាលបក្សកុម្មុយនីស្តកម្ពុជា មានខ្មាំង៥ជំពូកសំខាន់ៗ ដែលបក្សកុម្មុយនីស្តកម្ពុជាបានស្វែងរក ដើម្បីកំទេច ៖

(១) ***មន្ត្រីរបបសាធារណរដ្ឋខ្មែរ*** ដូចបានរៀបរាប់នៅក្នុងផ្នែក ការជម្លៀសដោយបង្ខំនៅក្នុងពេល និងភ្លាមៗបន្ទាប់ពីការជម្លៀសដោយបង្ខំនៃមជ្ឈមណ្ឌលទីប្រជុំជន បក្សកុម្មុយនីស្តកម្ពុជា បានស្វែងរក ឡោមព័ទ្ធ និងសម្លាប់ មន្ត្រី ទាហាននៃអតីតរបបសាធារណរដ្ឋខ្មែរ និងអ្នកពាក់ព័ន្ធផ្សេងទៀតជាមួយនឹងរបបនេះ។ សមាជិកជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ (រួមទាំង២នាក់ក្នុងចំណោម “ជនក្បត់ទាំងប្រាំពីរ” ដែលត្រូវបានគេកាត់ទោសប្រហារជីវិតតាមដំណោះស្រាយមួយដែលបានចូលរួមជាអធិបតីដោយ **ខៀវ សំផន**) ត្រូវបានគេសម្លាប់ចោល។ ដូចបានរៀបរាប់យ៉ាងលម្អិតនៅក្នុងផ្នែកមន្ទីរសន្តិសុខ និង

ពលកម្មដោយបង្ខំនៅទូទាំងថិរវេលាដែលនៅសល់នៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ មានមនុស្សបន្ថែមជាច្រើនទៀត ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលផ្អែកលើការពាក់ព័ន្ធជាក់ស្តែង ឬតាមការយល់ឃើញជាមួយអតីតរបបសាធារណរដ្ឋខ្មែរ។

(២) ***ខ្មាំងវណ្ណៈ និង "ប្រជាជនថ្មី"៖*** នៅពេលបានឡើងកាន់អំណាច បក្សកុម្មុយនីស្តកម្ពុជា ក៏បានស្វែងរកដើម្បីលុបបំបាត់ចោលសមាជិករបស់អ្នកដែលគេហៅថា វណ្ណៈនាយទុន ឬគហបតី ឬសក្តិភូមិ រួមទាំងម្ចាស់ពាណិជ្ជកម្ម បញ្ញវន្ត និងអ្នកអាជីពនៅក្នុងចំណោមប្រជាជនផ្សេងៗទៀត។ ជាការបន្ថែម ប្រជាជនអ្នកក្រុង ដែលត្រូវបានគេជម្លៀសចេញទាំងបង្ខំទៅកាន់ជនបទ និងជាអ្នកដែលត្រូវបានគេចាត់ថា "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី"នោះ ត្រូវជាកម្មវត្ថុនៃទម្រង់នៃការរំលោភបំពាន និងការព្រឹត្តិមកលើដោយអមនុស្សធម៌ខុសៗគ្នា អាស្រ័យទៅលើគំនិតយល់ឃើញរបស់បក្សកុម្មុយនីស្តកម្ពុជាដែលថាពួកគេ បានជាប់ពាក់ព័ន្ធ ឬត្រូវបានគេធ្វើឱ្យជាប់ពាក់ព័ន្ធជាមួយនឹងតម្លៃ ឬនិន្នាការ វណ្ណៈនាយទុន ឬគហបតី ឬសក្តិភូមិ។ ក្រុមទាំងនេះជាទូទៅត្រូវបានគេប្រព្រឹត្តមកលើក្នុងនាមជាប់ការសង្ស័យ និងទទួលរងការរើសអើងថាជាអ្នក ដែលបានបង្កើតមូលដ្ឋានប្រឆាំងផ្នែកនយោបាយដ៏មានសក្តានុពល ចំពោះការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដូចបានរៀបរាប់នៅក្នុងផ្នែកមន្ទីរសន្តិសុខ និងពលកម្មដោយបង្ខំនៅតាមសហករណ៍ និងការដ្ឋាន ប្រជាជនថ្មី ត្រូវជាកម្មវត្ថុនៃការប្រព្រឹត្តិឃោរឃៅ និងត្រូវបានគេចាប់ខ្លួន និងសម្លាប់ចោលញឹកញាប់ជាងគេ ។

(៣) ***កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតនៅក្រោមការសង្ស័យ៖***

ចាប់ពីឆ្នាំ១៩៧៦ ដោយសារ ការកើនឡើងនៃការសង្ស័យរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទៅលើអ្វីដែលថាមានការជ្រៀតចូលនៃគិញសេអ៊ីអា កាហ្សេបេ និងវៀតណាមក្នុងជួររបស់ខ្លួននោះ ក៏បានញុះញង់ឲ្យមានការបោសសម្អាតផ្ទៃក្នុងទ្រង់ទ្រាយធំ នៅពាសពេញក្នុងមុខនាទីនៃជួរយោធា និងស៊ីវិលរបស់ខ្លួន។ ការណ៍នេះបាននាំឲ្យមានការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជារាប់ពាន់នាក់នៅតាមបណ្តាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់នានា។ ភូមិភាគក្នុងកងពលធំយោធា និងក្រសួងនីមួយៗ ត្រូវបិតនៅក្រោមការបោសសម្អាតក្នុងទ្រង់ទ្រាយធំ ដែលគណៈមជ្ឈិមបក្សបានដាក់ទិសឲ្យ។ ពួកខ្មាំងផ្ទៃក្នុងជាសក្តានុពល ត្រូវបានគេធ្វើការកំណត់រកចេញពីក្នុងចម្លើយសារភាពនានារបស់អ្នកផ្សេងដែលត្រូវគេចាប់ដាក់គុករួចហើយ។ បន្ទាប់មកពួកគេត្រូវបានចាប់ខ្លួន សួរចម្លើយ ក្រោមការធ្វើទារុណកម្ម និងបង្ខំឲ្យឆ្លើយសារភាពចំពោះបទឧក្រិដ្ឋនានា និងបានភ្ជាប់ទៅកម្មាភិបាលផ្សេងទៀត មុនពេលពួកគេត្រូវបានសម្លាប់ចោល។ តាមរបៀបនេះបានធ្វើឲ្យរលកនៃការចាប់ខ្លួនបង្កើតបាននូវខ្មាំងតាមការសន្មតបន្ថែមទៀត និងជាហេតុនាំឲ្យមានការបោសសម្អាតបន្ថែមទៀត។ ការបោសសម្អាតធំៗចំនួនពីរ ក្នុងចំណោមការបោសសម្អាតធំៗនានា ត្រូវបានលើកយកមកពិភាក្សានៅក្នុងផ្នែកការបោសសម្អាតភូមិភាគឧត្តរ និងភូមិភាគបូព៌ា។ ការចាប់ខ្លួន និងការសម្លាប់ពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវបានពិភាក្សាផងដែរ នៅក្នុងផ្នែកមន្ទីរសន្តិសុខ។

(៤) ***ជនជាតិវៀតណាម៖*** ដោយបានបញ្ជា និងអនុវត្តការនិរទេសជាតិពន្ធុវៀតណាមរស់នៅប្រទេសកម្ពុជា ប្រមាណ១៥០០០០ ទៅ២០០០០០នាក់ ចេញពីប្រទេសកម្ពុជាភ្លាមៗបន្ទាប់ពីការឡើងកាន់អំណាចរបស់ខ្លួន ចាប់ផ្តើមពីឆ្នាំ១៩៧៧ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក៏បានបើកធ្វើយុទ្ធនាការនៅទូទាំងប្រទេស ដើម្បីលុបបំបាត់ជាតិពន្ធុវៀតណាមដែលនៅសល់ក្នុងប្រទេសនេះ។ កម្មវិធីប្រល័យពូជសាសន៍នេះ ត្រូវបានជំរុញទឹកចិត្តតាមការបន្សំនៃការប្រកាន់ពូជសាសន៍ និងការសន្មតគោលបំណងពង្រីកទឹកដីរបស់វៀតណាម។ ដូចបានបំភ្លឺបន្ថែមនៅក្នុងផ្នែកឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម ជនជាតិវៀតណាមត្រូវបានគេតាមរក និងសម្លាប់ទូទាំងប្រទេស ដោយរួមទាំង នៅខេត្តព្រៃវែង និងស្វាយរៀង និងនៅតាមបណ្តាមន្ទីរសន្តិសុខមួយចំនួនផ្សេងទៀតដែរ ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។ ស្របនឹងគោលនយោបាយនេះដែរ មេដឹកនាំ បកក បានបញ្ជាឱ្យមានការលុកលុយទៅក្នុងទឹកដីវៀតណាម និងការនិរទេស និងការសម្លាប់កាន់តែខ្លាំងក្លាឡើងទៅលើជនស៊ីវិលវៀតណាម ដែលកំពុងរស់នៅក្នុងតំបន់ដែល បានទទួលរងការវាយប្រហារដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យ។

(៥) ***ចាម៖*** ចាប់ពីឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការសម្លាប់យ៉ាងរីករាលដាលទៅលើចាមនៅកម្ពុជា ក្នុងបំណងបំផ្លាញក្រុមជាតិពន្ធុ និងសាសនានេះ។ ជាផ្នែកនៃយុទ្ធនាការណ៍ ប្រល័យពូជសាសន៍នេះ ចាមត្រូវបានគេតាមស្វែងរកជាពិសេស និងសម្លាប់ចោល*ជាក្រុម*។ ដូចជាតិពន្ធុវៀតណាមរស់នៅកម្ពុជាដែរ ការដាក់ចំណុចដៅលើចាមត្រូវបានគេធ្វើឡើង ដោយសារតែជាតិពន្ធុរបស់ពួកគេតែប៉ុណ្ណោះ (និងសាសនា

ក្នុងករណីរបស់ចាម)។ សំណុំរឿងមានផ្ទុកភស្តុតាងអំពីការសម្លាប់រង្គាលនេះ នៅតាមបណ្តាទីតាំងមួយចំនួនក្នុងស្រុកកងមាស ក្រូចឆ្មារ និងស្ទឹងត្រង់។

១៦៥- គោលនយោបាយបំបាត់ចោលនូវរាល់ខ្មាំងទាំងអស់របស់ បកក ទោះជាខ្មាំងពិតប្រាកដ ឬតាមការយល់ឃើញក្តី គឺជាគោលមាគ៌ានយោបាយស្នូលរបស់ បកក។ ចាប់តាំងពីដំបូងទីមក គឺនៅពេលធ្វើសន្និបាតបក្សលើកទី១ ក្នុងឆ្នាំ១៩៦០ ដែលអ្នកចូលរួមនៅពេលនោះរួមមាន ប៉ុល ពត **នួន ជា** និង **អៀង សារី** និងមេដឹកនាំបក្សដទៃៗទៀត បានសម្រេចថា “ហឹង្សាដោយអាវុធ” ត្រូវតែប្រើប្រាស់ “ដើម្បីធ្វើការវាយប្រហារនិងផ្តួលរំលំពួកសក្តិភូមិ មូលធន និងប្រតិកិរិយានៅក្នុងប្រទេសកម្ពុជា”។ គោលនយោបាយនេះ ត្រូវបានបញ្ជាក់អះអាងជាថ្មីឡើងវិញស្របគ្នានៅក្នុងពេលសន្និបាតបក្ស និងក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិមបក្ស ជាបន្តបន្ទាប់មកទៀត (ដែលចាប់ពីខែមករា ឆ្នាំ១៩៧១ បានបញ្ចូល **ខៀវ សំផន** ពីដំបូងគ្រាន់តែជាសមាជិកត្រៀម) រួមទាំងនៅក្នុងសេចក្តីសម្រេចចិត្តមួយរបស់គណៈកម្មាធិការមជ្ឈិមបក្សនៅខែមករា ឆ្នាំ១៩៦៥ ដែលបញ្ជាក់ច្បាស់ថាគឺ “ចាំបាច់ដាច់ខាតត្រូវប្រើហឹង្សាបដិវត្តន៍”។ ស្រដៀងគ្នានេះ មន្ទីរសន្តិសុខនានា គឺជាមធ្យោបាយដែលគេបានប្រើប្រាស់សម្រាប់លុបបំបាត់ខ្មាំង នៅក្នុងអំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោមការត្រួតត្រារបស់ **អៀង សារី** មានមន្ទីរសន្តិសុខមួយនៅភូមិភាគឥសាន បានចាប់ផ្តើមដំណើរការ ក្នុងឆ្នាំ១៩៦៦។ មន្ទីរសន្តិសុខត្រាំងតាចាន់ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧២ ហើយ ឌុច បានចាប់ផ្តើមដំណើរការ និងគ្រប់គ្រងមន្ទីរសន្តិសុខម-១៣ នៅក្នុង ឆ្នាំ១៩៧១ ក្រោមការត្រួតមើលពីលើនៃមេដឹកនាំរបស់ បកក។ ក្នុងមន្ទីរ

សន្តិសុខនិមួយៗនៃមន្ទីរសន្តិសុខទាំងនេះ អ្នកដែលគេយល់ថាជាខ្មាំងរបស់ បកក ត្រូវបានគេចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងប្រហារជីវិតដោយខុសច្បាប់ ។

## ផលប៉ះពាល់

១៦៦- ស្ទើរតែគ្រប់ប្រជាជនកម្ពុជាទាំងអស់ គឺសុទ្ធតែជាជនរងគ្រោះពីគោលនយោបាយឧក្រិដ្ឋនានានៃ បកក ដែលនាំមកនូវការរំលោភបំពានយ៉ាងរីករាលដលទៅលើប្រជាជនស៊ីវិល និងការបំផ្លាញចោលនូវអ្នកប្រឆាំងពិតប្រាកដ និងតាមការយល់ឃើញ ទៅនឹងការគ្រប់គ្រងរបស់ខ្លួន។ សហកម្មឧក្រិដ្ឋកម្មរួម បានផ្តោតគោលដៅទៅលើប្រជាជនស៊ីវិលភាគច្រើនបំផុតនៅក្នុងប្រទេសដែល មកទល់ត្រឹមខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនចន្លោះពី ៧,៨ លាន ទៅ ៨,១ លាននាក់។ សហកម្មឧក្រិដ្ឋកម្មរួម បានបណ្តាលឱ្យមានការស្លាប់ជីវិតប្រជាជនកម្ពុជាចំនួនចន្លោះពី១,៧៥ លាន ទៅ ២,២ លាននាក់ នៅក្នុងរយៈពេលជាង៣ឆ្នាំ ៨ខែ។ ក្នុងចំណោមការស្លាប់ជីវិត ទាំងនេះ មានជាង ៥០% ឬ មានចន្លោះពី ៨០០០០០ ទៅ ១,៣ លាននាក់ ជាការស្លាប់ដែល បណ្តាលមកពីអំពើហិង្សា។ លើសពីនេះ មានជនជាតិវៀតណាម ១០០% និងជនជាតិចាម ៣៦% ដែលបានរស់នៅក្នុងប្រទេសកម្ពុជា នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានឡើង កាន់អំណាច បានស្លាប់ ឬមួយត្រូវបានគេបង្ខំឱ្យចាកចេញពីប្រទេសកម្ពុជា នៅពេលចុងបញ្ចប់នៃរបបនេះ។

# ឃ- បទឧក្រិដ្ឋនានា

# ការជម្លៀសដោយបង្ខំ

## ដំណាក់កាលទី១៖ ពីភ្នំពេញ

### ការជម្លៀស

១៦៧- ចាប់ផ្តើមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា បាន ជម្លៀសដោយបង្ខំនូវប្រជាជនទីក្រុងភ្នំពេញទាំងអស់សរុបប្រមាណ២លាននាក់ ទៅកាន់ ទីជនបទ។ ការជម្លៀសប្រជាជនបានកើតមានដំណាលគ្នានៅតាមបណ្តាទីក្រុង ទីរួមខេត្ត និងភូមិនានា នៅកម្ពុជាផងដែរ ក្នុងនោះមាន កំពង់សោម កំពត តាកែវ ស្ទោង ប៉ៃលិន បាត់ដំបង សេរីសោភ័ណ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង ព្រៃវែង និងតំបន់ផ្សេង ៗទៀត។ គោលនយោបាយនេះត្រូវបានបង្កើត ឡើងដោយមជ្ឈិមបក្ស និងត្រូវបានអនុវត្តនៅ ទូទាំងប្រទេស។

១៦៨- នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងការពាររបបសាធារណរដ្ឋខ្មែរនៅតាមតំបន់ខ្សែ ក្រវាត់ក្រុងភ្នំពេញបានដួលរលំ ហើយកងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជាបានសម្រុកចូល កាន់កាប់ទីក្រុងភ្នំពេញយ៉ាងលឿនពីរគ្រប់មុខព្រួញ។ ទ័ពមកពីភូមិភាគឧត្តររបស់ **កុយ ធួន** បាន ធ្វើដំណើរតាមផ្លូវជាតិលេខ៥ និងក្តោបក្តាប់តំបន់ទួលគោក និងតំបន់ជុំវិញវត្តភ្នំ រហូត ដល់តំបន់ផ្សារធំថ្មី។ កងពលធំរបស់ភូមិភាគបូព៌ារបស់ **សោ ភឹម** បានលើកទ័ពចូលទីក្រុង ភ្នំពេញដោយឆ្លងតាមទន្លេមេគង្គ និងជាអ្នកត្រួតត្រាខណ្ឌដូនពេញ ដែលស្ថិតនៅចន្លោះទន្លេ មេគង្គ និងមហាវិថីព្រះនរោត្តម និងបានជួបប្រទះជាមួយកងកម្លាំងភូមិភាគឧត្តរនៅក្បែរ

តំបន់នោះ។ នៅប៉ែកខាងត្បូង និងខាងលិចទីក្រុង កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាមកពីភូមិភាគពិសេស(ក្រោមបញ្ជាការរបស់ **វន វ៉េត** និង **សុន សេន**) និងភូមិភាគនិរតី (ក្រោមបញ្ជាការរបស់ **តា ម៉ុក**) បានធ្វើដំណើរចូលទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ**២** លេខ**៣** និងលេខ**៤** ដោយបានចូលកាន់កាប់ព្រលានយន្តហោះពោធិចិនតុង និងតំបន់ក្រុងដែលនៅសល់។

១៦៩- នៅពេលមុនថ្ងៃត្រង់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមប្រកាសថា ប្រជាជនទាំងអស់ ត្រូវចាកចេញពីទីក្រុង"ជាបណ្តោះអាសន្ន"សិន។ កម្មាភិបាលខ្លះបានអះអាងថាប្រជាជនត្រូវចាកចេញពីទីក្រុង ដោយសារសហរដ្ឋអាមេរិកបម្រុងនឹងទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ បើទោះបីជាមនុស្សខ្លះទៀតនិយាយថា កងកម្លាំងបដិវត្តន៍ត្រូវបោសសម្អាតខ្មាំងចេញពីភ្នំពេញក្តី។ ដូចដែល **ខៀវ សំផន** បានបញ្ជាក់គឺថា គ្មានជម្រើសអ្វីផ្សេងពីនេះឡើយពោលគឺគេត្រូវតែជម្លៀសប្រជាជន និងដាក់ឱ្យនៅតាមសហករណ៍ជនបទ។ អ្នកណាប្រឆាំងនឹងបទបញ្ជាក្នុងការជម្លៀស ត្រូវគេបាញ់សម្លាប់នៅនឹងកន្លែង។ បទបញ្ជាគឺត្រូវបង្ខំឱ្យប្រជាជនទាំងអស់ចាកចេញពីទីក្រុង និងទីរួមខេត្ត។

១៧០- ផ្លូវសំខាន់ៗនៅក្រៅក្រុងភ្នំពេញ ត្រូវបានប្រើប្រាស់សម្រាប់ប្រជាជនជម្លៀសធ្វើដំណើរទៅកាន់តំបន់ជនបទនានា។ មនុស្សដែលត្រូវគេជម្លៀសតាមទិសខាងជើងបណ្តោយផ្លូវជាតិលេខ**៥** ត្រូវបានបំបែកគ្នានៅព្រែកក្តាម ដោយខ្លះត្រូវឆ្លងសាឡាងតាមទន្លេសាប និងបន្តដំណើរតាមផ្លូវជាតិលេខ**៦** រួចប្រជាជនត្រូវបានខ្មែរក្រហមបំបែកជាក្រុមផ្សេងៗ ឱ្យធ្វើដំណើរទៅកាន់គ្រប់ទិសតំបន់នៃភូមិភាគឧត្តរ ដូចជា ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តព្រះវិហារ និងខេត្តសៀមរាប។ ហ្វូងមនុស្សដែលនៅសល់ ត្រូវគេជម្លៀសទៅភាគខាងលិចតាមបណ្តោយ

ផ្លូវជាតិលេខ៥ ចូលទៅខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ ហ្វូងមនុស្សដែលត្រូវបានជម្លៀសទៅកាន់ទិសខាងលិចក្រៅក្រុងភ្នំពេញ បានបែកខ្ញែកគ្នានៅ ចោមចៅ ដោយមួយផ្នែកត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៣ ទៅកាន់ភូមិភាគនិរតី ពិសេស ខេត្តតាកែវ និងខេត្តកំពត ចំណែកមួយក្រុមទៀតត្រូវបានជម្លៀសតាមបណ្ដោយផ្លូវជាតិលេខ៤ ចូលទៅតំបន់មួយ ដែលក្រោយមកជាតំបន់ភូមិភាគបស្ចិម គឺពីខេត្តកំពង់ស្ពឺ រហូតដល់ ខេត្តកោះកុង។ ហ្វូងប្រជាជនជម្លៀសដែលត្រូវបានបង្ខំឲ្យធ្វើដំណើរចេញពីក្រុងភ្នំពេញតាមទិសខាងត្បូងត្រូវបានខ្មែរក្រហមបំបែកត្រង់ស្ពានព្រះមុន្នីវង្ស រីឯខ្លះទៀតធ្វើដំណើរតាមទិសខាងត្បូងបណ្ដោយផ្លូវជាតិលេខ២ ចូលទៅខេត្តកណ្ដាល ខេត្តតាកែវ និងខេត្តកំពត។ ខ្លះត្រូវបត់តាមទិសខាងកើតឆ្លងស្ពានព្រះមុន្នីវង្ស រួចបន្តដំណើរតាមផ្លូវជាតិលេខ១ ចូលទៅខេត្តកណ្ដាល ហើយមានមនុស្សយ៉ាងច្រើនបានឆ្លងសាឡាងអ្នកលឿងពីខេត្តកណ្ដាល រួចខ្មែរក្រហមបានបំបែកពួកគេនៅភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ចូលទៅខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។ ការធ្វើដំណើរដោយថ្មើរជើងខ្លះត្រូវចំណាយពេលយូររហូតទៅដល់មួយខែ ឬលើសពីនេះ។

១៧១- ខ្មែរក្រហមមានផែនការជាលក្ខណៈប្រព័ន្ធ ក្នុងការសម្លាប់ជាបន្ទាន់នូវមន្ត្រីរដ្ឋការ និងទាហាននៃរបបមុនដែលពួកគេភាគច្រើន ត្រូវបានសម្លាប់នៅភ្នំពេញ។ មេបញ្ជាការយោធាត្រូវបានបញ្ជាឲ្យ"ជម្លៀសប្រជាជនស៊ីវិលចេញពីទីក្រុង ដើម្បីដឹងថាអ្នកណាជាទាហាន លន់ នល់"។ នៅតាមចំណុចត្រួតពិនិត្យតាមផ្លូវ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានត្រួតពិនិត្យរកទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់ នៅក្នុងហ្វូងប្រជាជនជម្លៀស។ នៅពេលរកឃើញ គេយកមនុស្សទាំងនោះ ចេញពីគេឯង ហើយដឹកយកទៅបាត់។ ជាក់ស្ដែង

តាមផ្លូវជាតិលេខ៥ ខាងជើងក្រុងភ្នំពេញ មានចំណុចត្រួតពិនិត្យមួយនៅព្រែកក្តៅ សម្រាប់ប្រមូលយកទាហានរបបសាធារណរដ្ឋខ្មែរទៅប្រហារជីវិត។ នៅរង្វង់មូលចោមចៅត្រង់ផ្លូវបំបែកផ្លូវជាតិលេខ៣ និងលេខ៤ គេប្រទះឃើញសាកសពមនុស្សស្លាប់គរលើគ្នា។

១៧២- នៅខេត្តសៀមរាប ទាហានរបបសាធារណរដ្ឋខ្មែររាប់រយនាក់ដែលបានចុះចាញ់ ត្រូវបានខ្មែរក្រហមបណ្តើរទៅសម្លាប់នៅក្រៅទីរួមខេត្ត។ ក្នុងអំឡុងការជម្លៀសប្រជាជននៅទីរួមខេត្តពោធិ៍សាត់ ស្ទឹងពោធិ៍សាត់ពោរពេញទៅដោយសាកសពមនុស្សចាស់ ក្មេង ស៊ីវិល និងយោធា។ ប្រជាជនដែលត្រូវបានជម្លៀសចេញក្រៅតំបន់ទីរួមខេត្តកំពង់ឆ្នាំង ត្រូវបានខ្មែរ ក្រហមសម្លាប់ភ្លាមៗទាំងហ្វូង។ នៅខេត្តបាត់ដំបង បក្សកុម្មុយនីស្តកម្ពុជាបានចាក់ផ្សាយសេចក្តីអំពាវនាវឲ្យនាយទាហាន និងកងទ័ពរបបសាធារណរដ្ឋខ្មែរ ជួបជុំគ្នានៅទីស្នាក់ការយោធភូមិភាគទី៣ ដែលនៅទីនោះ ពួកគេត្រូវបានបំបែកជាក្រុមតាមឋានានុក្រម និងដឹកតាមរថយន្តកាមីញ៉ុងនៅថ្ងៃទី២០ ទី២១ និងទី២៣ ខែមេសា ឆ្នាំ១៩៧៥ ទៅកាន់តំបន់ក្រៅក្រុង និងត្រូវបានប្រហារជីវិត*ទាំងហ្វូង*។ ហេតុការណ៍នេះបានកើតមានដូចគ្នានៅខេត្តប៉ៃលិន និងពោធិ៍សាត់។

១៧៣- កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានចេញបញ្ជាឲ្យជនបរទេសទាំងអស់ប្រមូលផ្តុំគ្នា នៅស្ថានទូតបារាំង។ ប្រជាជនកម្ពុជាជាច្រើននាក់រួមទាំងឥស្សរជននយោបាយជាន់ខ្ពស់មួយ ចំនួននៃរបបសាធារណរដ្ឋខ្មែរផង ក៏បានស្វែងរកការជ្រកកោននៅទីនោះដែរ។ កងទ័ពប្រដាប់អាវុធរបស់បក្សកុម្មុយនីស្តកម្ពុជា បានទាមទារឲ្យស្ថានទូតបារាំងប្រគល់ខ្លួនមន្ត្រីរបបសាធារណរដ្ឋខ្មែរដែលបានពួនសម្ងំនៅក្នុងស្ថានទូត។ នៅថ្ងៃទី២០ ខែមេសា ជនជាតិខ្មែរ ចិន

និងវៀតណាមចំនួនជាង៦០០នាក់ ត្រូវបានស្ថានទូតបារាំងប្រគល់ខ្លួន ទៅឱ្យបក្សកុម្មុយនីស្តកម្ពុជា ហើយពួកគេទាំងនេះបានចាកចេញពីទីក្រុងតាមផ្លូវទិសខាងជើង។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ **ចៅ សេង** ក្នុងនាមសមាជិកការិយាល័យនយោបាយគណៈមជ្ឈិមនៃរណសិរ្សរួបរួមជាតិកម្ពុជាបានប្រកាសថារបបថ្មីនេះ ពុំទទួលស្គាល់អភ័យឯកសិទ្ធិការទូតរបស់មន្ត្រីបរទេសដែលរបបមុនធ្លាប់បានទទួលស្គាល់ឡើយ ហើយដែលពេលនេះ ពួកគេកំពុងស្ថិតក្រោមការឡោមព័ទ្ធស្ថានទូតបារាំង។

១៧៤- បក្សកុម្មុយនីស្តកម្ពុជាមានបញ្ជីឈ្មោះមន្ត្រីជាន់ខ្ពស់៧រូប នៃរបបសាធារណរដ្ឋខ្មែរ ដែលខ្លួនបានដាក់ឈ្មោះថាជា "**ពួកមហាក្បត់**" ដែលត្រូវប្រហារជីវិត។ ក្នុងចំណោមបុគ្គលទាំង៧រូប នោះមានតែលោក **ឡុង បូរ៉េត** និងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិសិរីមតៈ** តែប៉ុណ្ណោះ ដែលស្ថិតនៅក្នុងកម្ពុជា ខណៈពេលដែលកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា បានចូលកាន់កាប់ទីក្រុងភ្នំពេញ។ អ្នកទាំងពីរត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួន និងប្រហារជីវិតនៅភ្នំពេញ។ លោកនាយករដ្ឋមន្ត្រី **ឡុង បូរ៉េត** បានប្រគល់ខ្លួនឱ្យបក្សកុម្មុយនីស្តកម្ពុជា នៅក្រសួងព័ត៌មាននាវេលាម៉ោង៤ និង៥០នាទី រសៀលថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពីមានការអំពាវនាវពីសំណាក់ថ្នាក់ចាត់តាំងបក្សកុម្មុយនីស្តកម្ពុជា ថាឱ្យមន្ត្រីនៃរបបចាស់ប្រមូលផ្តុំគ្នានៅ ទីនោះ។ ស្ថានទូតបារាំងបានបដិសេធមិនឱ្យព្រះអង្គម្ចាស់សិរីមតៈ និងមនុស្សផ្សេងៗ ទៀតធ្វើការជ្រកកោននៅទីនោះ និងបានប្រគល់ពួកគេឱ្យបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។ ក្នុងអំឡុងទស្សនកិច្ចផ្លូវការមួយទៅកាន់ទីក្រុងបាងកក នាខែវិច្ឆិកា ឆ្នាំ១៩៧៥ អៀង សារី បានបញ្ជាក់អះអាងជាសាធារណៈអំពីការប្រហារជីវិតពួកគេ។

១៧៥- នៅព្រឹកថ្ងៃទី១៩ ខែមេសា ប៉ែកខាងជើងទីក្រុងភ្នំពេញ ស្ទើរតែគ្មានមនុស្សសោះ មានតែកងល្បាតរបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ស្ថានទូតបារាំងនៅភ្នំពេញ បានរាយការណ៍ប្រាប់ទីក្រុងប៉ារីសថា "រដ្ឋធានីនេះឥឡូវនេះគ្មានប្រជាជនរស់នៅហើយមានសភាពដូចជាទីក្រុងខ្មោច"។

## ស្ថានភាពអមនុស្សធម៌

១៧៦- មនុស្សយ៉ាងច្រើនត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើដំណើរផ្លូវឆ្ងាយដោយថ្មើរជើង មុនពេលត្រូវបានបង្ខាំងដោយខុសច្បាប់នៅតាមសហករណ៍ជនបទ។ កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានទទួលការណែនាំឱ្យប្រាប់ អតីតប្រជាជនទីក្រុងភ្នំពេញ និងតំបន់ទីប្រជុំជនថា ការជម្លៀសប្រជាជនគឺជាការបណ្តោះអាសន្ន។ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាបានដឹងថា ការជម្លៀសដោយបង្ខំតាមផ្លូវវែងឆ្ងាយ ដោយថ្មើរជើងក្រោមកំដៅហួតហែងនៃរដូវប្រាំង ដោយគ្មានអាហារបរិភោគ ទីជម្រក ឬការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់ នឹងបណ្តាលឱ្យជនរងគ្រោះរងទុក្ខវេទនាពីស្ថានភាពអមនុស្សធម៌ និងអាចបណ្តាលឱ្យស្លាប់ទៀតផង។ សូម្បីតែស្ត្រីជាម្តាយដែលទើបសម្រាលកូនរួច ក៏ពុំរួចខ្លួនពីការធ្វើដំណើរវែងឆ្ងាយនេះដែរ។ អ្នកជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត្រ និងមន្ទីរពេទ្យផ្សេងៗ ត្រូវបានបណ្តេញចេញទាំង "នៅលើគ្រែ"។ [redacted]។

១៧៧- ក្រៅពីប្រជាជនជម្លៀសដែលត្រូវបានប្រហារជីវិតដោយចេតនា ដោយសារហេតុផលនយោបាយ ការជម្លៀសប្រជាជនទីក្រុងភ្នំពេញដោយបង្ខំ បានបណ្តាលឱ្យមានការស្លាប់បាត់បង់ជីវិតមនុស្សយ៉ាងច្រើន។ ប្រជាជនត្រូវបានប្រហារជីវិត ដោយសារខ្លួនបដិសេធពុំ

ព្រមចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ឬយឺតយ៉ាវក្នុងការគោរពតាមបទបញ្ជា ក្នុងការជម្លៀសប្រជាជន។ មនុស្សរាប់ពាន់នាក់បានស្លាប់ ដោយសារការខ្វះស្បៀងអាហារ ទឹក ទីជម្រក និងជំនួយវេជ្ជសាស្ត្រ ក្នុងអំឡុងពេលនៃការជម្លៀស។ មន្ទីរពេទ្យ និងស្ថាប័នផ្សេងៗសម្រាប់ប្រជាជនងាយរងគ្រោះ ក៏ត្រូវស្ថិតក្រោមបទបញ្ជាជម្លៀសដែរ ដែលបានបណ្ដាលឱ្យមនុស្សជាច្រើនត្រូវស្លាប់បាត់បង់ជីវិត។

១៧៨- បក្សកុម្មុយនីស្តកម្ពុជា បានដកហូតជាមូលដ្ឋាន នូវរាល់ទ្រព្យសម្បត្តិឯកជនទាំងអស់នៅទូទាំងប្រទេស។ នៅពេលបញ្ជាឱ្យប្រជាជនជម្លៀសពីទីក្រុង កងទ័ពបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់ពួកគេកុំឱ្យយករបស់របរច្រើនទៅជាមួយ។ ភាគច្រើននៃទ្រព្យសម្បត្តិដែលប្រជាជនបានយកជាប់ខ្លួន ត្រូវបានទ័ពបក្សកុម្មុយនីស្តកម្ពុជារឹបអូស អំឡុងពេលនៃការជម្លៀសដោយបង្ខំចេញពីទីក្រុង។ ទាំងទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន ដែលបានបន្សល់ទុកនៅទីក្រុង ត្រូវបានប្រកាសថាជា "ជ័យភណ្ឌ" និងត្រូវបានបក្សកុម្មុយនីស្តកម្ពុជារឹបអូសយក។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ សម្ភារៈជាច្រើន ដែលបានមកដោយខុសច្បាប់នេះ ត្រូវបានដុតកម្ទេច ឬបំផ្លាញចោល នៅក្នុងយុទ្ធនាការនៃ"ការបំផ្លិចបំផ្លាញជាលក្ខណៈប្រព័ន្ធ"។

## សេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការជម្លៀសដោយបង្ខំ

១៧៩- ជនត្រូវចោទបានទទួលស្គាល់ថា ពួកគេពិតជាបានបញ្ជាឱ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងមែន ហើយគោលនយោបាយនេះ គឺចេញមកពីសេចក្តីសម្រេចរបស់ថ្នាក់ចាត់តាំងជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា។ **នួន ជា** បានគូសបញ្ជាក់ថា ការសម្រេចជម្លៀសប្រជាជន

ចេញពីទីក្រុង គឺ "មជ្ឈិមបក្ស" ជាអ្នកធ្វើ។ **ខៀវ សំផន** បានគូសបញ្ជាក់ថា ការជម្លៀសប្រជាជន គឺជាការសម្រេចរបស់គណៈអចិន្ត្រៃយ៍ ពិសេស គឺវាជាគោលនយោបាយរបស់ ប៉ុល ពត **នួន** ជា និង **អៀង សារី**។ **អៀង សារី** បានចាត់ទុកគោលនយោបាយនៃការជម្លៀសប្រជាជនចេញពីទីក្រុង ថាជា"ការសម្រេចរួម" ពិសេសគាត់បានឆ្លើយដាក់ ប៉ុល ពត **នួន** ជា សុន សេន និង យុន យ៉ាត។ **អៀង ធីរិទ្ធ** បានបញ្ជាក់ថាការជម្លៀសប្រជាជនគឺជាការសម្រេចរបស់ "មេដឹកនាំ" បក្ស។

១៨០- មានឧទាហរណ៍ជាច្រើន ចំពោះការសម្រេចជម្លៀសប្រជាជនចេញពីភ្នំពេញ និងទីក្រុងផ្សេងៗ នៅពេលខ្មែរក្រហមបានទទួលជ័យជម្នះនោះ ការជម្លៀសប្រជាជន គឺជានីតិវិធីបទដ្ឋាន នៅពេញមួយរយៈកាលសម័យសង្គ្រាម។ ជាក់ស្តែង នៅឆមាសទី២ នៃឆ្នាំ១៩៧៣ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា បានចូលកាន់កាប់ទីរួមខេត្តក្រចេះ និងបានជម្លៀសប្រជាជនទាំងអស់ចូលទៅក្នុងតំបន់រំដោះរបស់ខ្លួន។ នៅឆ្នាំនោះ ហេតុការណ៍នេះបានកើតមានដូចគ្នា នៅ បាណាម។ នៅឆ្នាំ១៩៧៣ដដែល បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាបានកាន់កាប់ទីរួមខេត្ត កំពង់ចាមមួយរយៈនៅពេលដកថយ ពួកគេបានជម្លៀសប្រជាជនចំនួន១៥០០០ទៅជាមួយ។ នៅខែមីនា ឆ្នាំ១៩៧៤ បក្សកុម្មុយនីស្តកម្ពុជា បានរំដោះឧត្តុង្គ និងបានជម្លៀស ប្រជាជនទៅកាន់ជនបទយ៉ាងបន្ទាន់។

១៨១- ដូចបានរៀបរាប់នៅក្នុងផ្នែករចនាសម្ពន្ធសិទ្ធិអំណាចខាងលើ គោលនយោបាយជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងនៅពេលរំដោះ ត្រូវបានសម្រេចក្នុងពេលនៃកិច្ចប្រជុំគណៈមជ្ឈិមក្នុងខែមិថុនា ឆ្នាំ១៩៧៤ និងដែលបានលើយកមកពិភាក្សាបន្តទៀត នៅក្នុងអង្គប្រជុំមួយ បកក នៅខែកុម្ភៈ ឆ្នាំ១៩៧៥។ ក្នុងអង្គប្រជុំមួយនៅមន្ទីរ **ប៥** នៅភូមិតាំងពោន

ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា បានចេញបទបញ្ជាចុងក្រោយ ឱ្យមេបញ្ជាការយោធាភូមិភាគជម្លៀសប្រជាជន នៅដើមខែមេសា ឆ្នាំ១៩៧៥។ **នួន ជា** និង **ខៀវ សំផន** មានវត្តមានក្នុងអង្គប្រជុំនោះ ថែមទាំងបានឯកភាពយ៉ាងច្បាស់លាស់ ទៅនឹងគោលនយោបាយនោះទៀតផង។ បន្ទាប់មក បទបញ្ជាទាំងនេះ ត្រូវបានបញ្ជូនពីមេបញ្ជាការយោធាភូមិភាគទៅកាន់មេបញ្ជាការកងពលធំ និងមេបញ្ជាការកងវរសេនាធំ រួចបន្តផ្សព្វផ្សាយទៅបញ្ជាការថ្នាក់ក្រោមរបស់ខ្លួន។ ជាក់ស្តែងនៅតំបន់៣៥ **តា ម៉ុក** លេខាភូមិភាគនិរតី បានធ្វើប្រធានអង្គប្រជុំមួយ ជាមួយមេបញ្ជាការយោធានៅមុនពេលនៃការដួលរលំរបបសាធារណរដ្ឋខ្មែរ ដើម្បីគូសបញ្ជាក់អំពីគោលនយោបាយនៃការជម្លៀសប្រជាជនចេញពីទីក្រុង។ សមាជិកកងទ័ពរបស់បក្ស កុម្មុយនីស្តកម្ពុជាភាគច្រើនដែលបានធ្វើដំណើរចូលទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗ ត្រូវបានគេ ប្រាប់ឱ្យដឹងអំពីការជម្លៀសប្រជាជននៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

១៨២- យោងតាម ប៉ុល ពត គោលបំណងនៃគោលនយោបាយជម្លៀសប្រជាជន គឺដើម្បី“កម្ទេចរាល់គ្រប់អង្គការចាត់តាំងរបស់គិញខ្មាំង”។ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាមានជំនឿថា បដិវត្តន៍សង្គមនិយមនៅសូវៀត ចិន និងប្រទេសឯទៀត ទទួលបរាជ័យដោយសារពួកគេពុំបានកម្ចាត់ “**វណ្ណៈជិះជាន់**” ដែលបណ្តាលនាំឱ្យមាន “**ទំនាស់បដិបក្ខ**” ដែលបានបន្តប៉ះពាល់ដល់ការបោះជំហានរបស់បដិវត្តន៍ទាំងនោះ ឆ្ពោះទៅកាន់លទ្ធិសង្គមនិយមឆ្អិនឆ្អៅ។ បក្សកុម្មុយនីស្តកម្ពុជា មានបំណងដោះស្រាយបញ្ហានេះ តាមរយៈការកម្ចាត់មូលដ្ឋានសេដ្ឋកិច្ច និងសង្គមនៃវណ្ណៈសក្តិភូមិ និងវណ្ណៈនាយទុន ដោយការវាយរំលំតែមួយលើក។ អ្វីៗទាំងអស់គឺជាការតស៊ូវណ្ណៈ៖ នៅជនបទ យើងមានអានុភាពលើឯកជនមែន តែដល់យើងចូលមកភ្នំពេញ

យើងរណបវា។ តែយើងមិនទុកវានៅភ្នំពេញ។ ដល់អីចឹងទៅ កម្មសិទ្ធិឯកជនវាគ្មានអានុភាព ទេ។...វណ្ណៈសក្តិភូមិត្រូវវាយរលំហើយ ក្នុងឋានៈជាមូលដ្ឋានសេដ្ឋកិច្ច និងជារបបនយោបាយ។ វណ្ណៈនាយទុនក៏ត្រូវវាយរលំដែរ ទាំងមូលដ្ឋានសេដ្ឋកិច្ច និងរបបនយោបាយ។

១៨៣- **អៀង សារី** បានការពារគោលនយោបាយនេះ“រហូតដល់ទីបញ្ចប់”។ **ខៀវ សំផន** បានការពារ គោលការណ៍នៃការជម្លៀសប្រជាជនហួសទីបញ្ចប់ទៅទៀត ក្នុងអំឡុងនៃការស្តាប់យកចម្លើយ ជាមួយសហចៅក្រមស៊ើបអង្កេត នាពេលថ្មីៗនេះ។

**ការប្រហារជីវិតជាទ្រង់ទ្រាយធំទៅលើទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ**

**ទីកន្លែងប្រហារជីវិត “ទួលពោធិ៍ជ្រៃ”**

**ទីតាំង**

១៨៤- ទីកន្លែងប្រហារជីវិតទួលពោធិ៍ជ្រៃ (“ទួលពោធិ៍ជ្រៃ”) មានទីតាំងស្ថិតនៅភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ចម្ងាយប្រមាណ១៨គីឡូម៉ែត្រ នៅប៉ែកពាយ័ព្យនៃទីរួមខេត្ត ពោធិសាត់ ក្នុងតំបន់៧ នៃភូមិភាគពាយ័ព្យ។ ទួលពោធិ៍ជ្រៃគឺជាកន្លែងប្រហារជីវិតជា ទ្រង់ទ្រាយធំ នៅខែមេសា ឆ្នាំ១៩៧៥ ដែលនៅទីនោះទាហាន និងអ្នករដ្ឋការនៃរបបសាធារណ រដ្ឋខ្មែរមួយចំនួនធំ ត្រូវបានប្រហារជីវិត បន្ទាប់ពីកងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានចូលកាន់ កាប់ខេត្តពោធិ៍សាត់។

១៨៥- មានទីកន្លែងពាក់ព័ន្ធចំនួន៣ ក្នុងការស្វែងយល់អំពីលំដាប់លំដោយនៃហេតុការណ៍ ដែលបាន កើតឡើងនៅទួលពោធិ៍ជ្រៃនៅចុងខែមេសា ឆ្នាំ១៩៧៥។ **កន្លែងទី១** ស្ថិតនៅកណ្តាលទីរួមខេត្ត

ពោធិ៍សាត់ និងជាអតីតទីស្នាក់ការខេត្តពោធិ៍សាត់កាលជំនាន់របបសាធារណរដ្ឋខ្មែរ។ បក្សកុម្មុយនីស្តកម្ពុជាបានកាន់កាប់ និងយកកន្លែងនេះធ្វើជាទីស្នាក់ការមូលដ្ឋានរបស់ខ្លួនភ្លាមៗក្រោយពីថ្ងៃរំដោះ នៅខែមេសា ឆ្នាំ១៩៧៥។ **កន្លែងទី២** មានចម្ងាយប្រមាណ១១គីឡូម៉ែត្រពីប៉ែកខាងជើងទីស្នាក់ការខេត្ត និងជាទីតាំងបន្ទាយយោធាក្នុងរបបសាធារណរដ្ឋខ្មែរ ក្បែរអតីតវត្តមួយ។ **កន្លែងទី៣** គឺទីកន្លែងប្រហារជីវិតទួលពោធិ៍ជ្រៃ ដែលស្ថិតនៅចម្ងាយប្រមាណ៣គីឡូម៉ែត្រ ទៅប៉ែកខាងជើងបន្ទាយយោធា។ ទីកន្លែងប្រហារជីវិត គឺជាអតីតបន្ទាយយោធាកងវរសេនាតូច។ បន្ទាយនេះព័ទ្ធជុំវិញទៅដោយរបង៤ជួរ ដែលមានចំណុចកណ្តាលរួមគ្នា ធ្វើពីលួសបន្លា និងបន្លាឫស្សី។ នៅទីកន្លែងនេះ គ្មានមន្ទីរឃុំឃាំងទេ ដោយសារគេយកទីកន្លែងនេះ ធ្វើជាកន្លែងប្រហារជីវិតតែមួយមុខប៉ុណ្ណោះ។ ក្រៅពីទីកន្លែងទាំងនេះ មានទីកន្លែងមួយទៀតដែលគេសង្ស័យថា ជាកន្លែងប្រហារជីវិតធំនៅចម្ងាយ២ ឬ៣គីឡូម៉ែត្រ ពីទួលពោធិ៍ជ្រៃ។

## ការសម្លាប់ដោយខុសច្បាប់

១៨៦- បន្ទាប់ពីពេលបែកភ្នំពេញ និងទីរួមខេត្តនានា បានចំនួន២ ឬ៣ថ្ងៃ មេបញ្ជាការយោធាបក្សកុម្មុយនីស្តកម្ពុជានៅតំបន់៧ បានទទួលបញ្ជាឱ្យប្រមូលនាយទាហាន និងអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរនៅខេត្តពោធិ៍សាត់ យកទៅប្រហារជីវិតនៅទួលពោធិ៍ជ្រៃ។ លេខាតំបន់៧ ឈ្មោះ **សុត** បានអញ្ជើញអភិបាលខេត្តពោធិ៍សាត់នៃរបបសាធារណរដ្ឋខ្មែរ ឧត្តមសេនីយ៍ **ព្រុំ លីហួន** ឱ្យហៅអតីតនាយទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទៅប្រជុំនៅឯទីស្នាក់ការខេត្ត នៅទីរួមខេត្តពោធិ៍សាត់។

១៨៧- នៅថ្ងៃដែលត្រូវបានចាត់តាំង គឺថ្ងៃទី២៤ ឬ២៥ ខែមេសា ឆ្នាំ១៩៧៥ មន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរ បានមកដល់ទីស្នាក់ការខ្មែរក្រហមនៅខេត្តពោធិ៍សាត់។ នៅទីនោះពួកគេស្ថិតក្រោមការឃាមកាមរបស់កម្មាភិបាលខ្មែរក្រហម ដែលបានឈរជើងនៅឯទីស្នាក់ការនោះ។ [redacted] បានដឹកនាំកិច្ចចរចាខាងភាគីបក្សកុម្មុយនីស្តកម្ពុជា។ អតីតមេបញ្ជាការកងវរសេនាតូចនៃរបបសាធារណរដ្ឋខ្មែរ ឈ្មោះ តា ប៉ាល់ ជាអ្នកចូលរួមក្នុងកិច្ចចរចា តំណាងឱ្យទាហានដែលបានប្រគល់ខ្លួនចុះចាញ់។ ក្នុងអង្គប្រជុំនោះខ្មែរក្រហមបានប្រាប់អ្នកតំណាងរបបសាធារណរដ្ឋខ្មែរថា ខ្លួននឹងបញ្ជូនពួកគេទៅទទួលអង្គការនៅទួលពោធិជ្រៃ និងជួបសម្តេចសីហនុ។ ខ្មែរក្រហមក៏បានប្រាប់ឱ្យ ពួកគេដឹងថាពួកគេនឹងត្រូវរៀនសូត្រ និងតម្លើងសក្តិ រួចត្រឡប់មកអតីតទីតាំងរបស់ពួក គេវិញ។

១៨៨- នៅថ្ងៃបន្ទាប់ ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរចំនួនរាប់ពាន់នាក់ ត្រូវបានខ្មែរក្រហមប្រមូលផ្តុំ និងដឹកតាមរថយន្តយោធាចំនួនយ៉ាងហោចណាស់ពី៣០ ទៅ៤០ រថយន្ត។ យានជំនិះរបស់កងទ័ពបដិវត្តកម្ពុជាចំនួន២ បានធ្វើដំណើរអមក្បួនរថយន្តរបស់ពួកគេ ដោយយានជំនិះមួយដែលមានទាហានចំនួនប្រហែល១០នាក់ នៅខាងមុខក្បួនរថយន្ត និងរថយន្តហ្ស៊ីបមួយទៀតដែលមានទាហាន៥នាក់ នៅខាងក្រោយក្បួនរថយន្ត។ គោលដៅនៃការធ្វើដំណើរគឺសំដៅទៅកាន់បន្ទាយយោធាក្បៀរវត្ត (ទីកន្លែងទី២ ដែលបានពិពណ៌នាពីខាងលើ)។

១៨៩- នៅព្រឹកថ្ងៃបន្ទាប់ ទាហាននៃរបបសាធារណរដ្ឋខ្មែរត្រូវបានខ្មែរក្រហមប្រមូលផ្តុំ នៅខាងក្រៅបន្ទាយ ក្រោមការឃាមកាមពីសំណាក់កងទ័ពបដិវត្តកម្ពុជា។ ក្រុមអ្នកទោសត្រូវបានដឹកពី

ទីនោះ ទៅកាន់កន្លែងប្រហារជីវិតទួលពោធិ៍ជ្រៃ ហើយក្នុងចន្លោះពេល២០នាទីម្តង មានរថយន្តមួយបានដឹកអ្នកទោសចេញទៅ ដែលនៅទីកន្លែងនោះអ្នកទោសត្រូវបានគេចង និងបាញ់សម្លាប់។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ពុំអនុញ្ញាតឱ្យរថយន្តបន្ទាប់ចាកចេញពីទីកន្លែងនោះឡើយ ទាល់តែរថយន្តមុននោះបានត្រឡប់មកពីទីកន្លែងប្រហារជីវិតសិន។ ទាហានបក្សកុម្មុយនីស្តកម្ពុជា បានចំណាយពេលពេញមួយថ្ងៃ ដើម្បីបាញ់សម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែរ ចាប់តាំងពីព្រឹកដល់ល្ងាច។ ជាសរុប ខ្មែរក្រហមបានចំណាយរយៈពេលមួយសប្តាហ៍ក្នុងការសម្លាប់ពួកគេ។

១៩០- [redacted] គឺជាមេដឹកនាំតំបន់ និងស្រុក ដែលបានដឹកនាំការប្រហារជីវិត។ កងទ័ពបដិវត្តកម្ពុជាដែលបានអនុវត្តប្រតិបត្តិការប្រហារជីវិតនេះ គឺជាសមាជិកកងវរសេនាតូច២០១ ពីតំបន់៧ និងកងទ័ពកងវរសេនាតូចលេខ២៤ របស់ភូមិភាគ។

១៩១- នៅឯទួលពោធិ៍ជ្រៃ សាកសពមនុស្សស្លាប់ ត្រូវបានត្រាក់ទ័រកាយដី កាយដាក់ជាមួយគ្នា ហើយកាយកប់នៅ១ថ្ងៃ ឬ២ថ្ងៃបន្ទាប់ ដោយបន្សល់ទុកនូវទីកន្លែងជាច្រើន ដែលគេសង្ស័យថាជារណ្តៅសាកសព។ សាកសពខ្លះត្រូវបានបោះចូលទៅក្នុងស្រះជម្រៅ៣ម៉ែត្រ នៅក្បែរទីកន្លែងនោះ។ គេបានប៉ាន់ប្រមាណថា មានអ្នកទោសចន្លោះពី២០០០ ទៅដល់៣០០០នាក់ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃនៅខែមេសា ឆ្នាំ១៩៧៥។ បន្ថែមពីលើនេះ មានបឹងមួយក្បែរទួលពោធិ៍ជ្រៃដែលគេជឿថា ក្នុងបឹងនោះមានសាកសពចំនួនច្រើន រហូតទៅដល់៥០០០ នាក់។

១៩២- សាក្សី២នាក់ដែលបានឃើញទីកន្លែងប្រហារជីវិតភ្លាមៗ បន្ទាប់ពីការសម្លាប់ នៅខែមេសា ឆ្នាំ១៩៧៥ រៀបរាប់អំពីការបានឃើញសាកសពត្រូវគ្រាប់ត្រង់ក្បាល និងខ្លួន។ ជនរងគ្រោះត្រូវ

បានគេចងខ្សែពួរភ្ជាប់គ្នា ជាក្រុម ក្នុងមួយក្រុម១៥នាក់ ទៅ២០នាក់ ដែលជាប់ចំណងស្លាបសេក។ សាកសពខ្លះមានស្លៀកពាក់ឯកសណ្ឋានយោធា ហើយខ្លះទៀតស៊ីវិល។ សាក្សីម្នាក់ទៀតដែលបានទៅដល់ទីកន្លែងនោះ ក្រោយខែមករា ឆ្នាំ១៩៧៩ បានឃើញឯកសណ្ឋានយោធានៃរបបសាធារណរដ្ឋខ្មែរ នៅក្បែរគំនរអដ្ឋិធាតុ ដែលគេបានគាស់ចេញពីរណ្តៅសាកសពចំនួន៤ ទៅ៥ ។ អ្នកស៊ើបអង្កេត ក.ស.ច.ស ដែលបានត្រួតពិនិត្យទីកន្លែងនេះ បានប្រទះឃើញអដ្ឋិធាតុ កេសគ្រាប់ ក្បាលគ្រាប់ ឧបករណ៍ធ្វើពីលោហៈ ដូចជាក្បាលខ្សែក្រវាត់ ខ្សែរូត និងសម្លៀកបំពាក់មានកប់នៅក្នុងដី។ កេសគ្រាប់ទទេរ ត្រូវបានគេប្រទះឃើញនៅក្នុង និងជុំវិញរណ្តៅកប់សាកសព។

**របចនាសម្ពន្ធគ្រប់គ្រង**

១៩៣- [redacted] លេខាភូមិភាគពាយ័ព្យឈ្មោះ **មូល សម្បត្តិ** ហៅ **រស់ ញឹម**។ អនុប្រធានរបស់ **ញឹម** ឈ្មោះ **គង់ សុផល** ហៅ **កឹ**។ ទាំងឈ្មោះ **ញឹម** និងឈ្មោះ **កឹ** អាចជាសមាជិកនៃគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។

**ស្រុកកំពង់ត្រឡាចលើ**

**សេចក្តីផ្តើម**

១៩៤- ដូចដែលបានពិភាក្សាខាងលើ បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ការជម្លៀសប្រជាជនទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗ ដើម្បីវែកមុខ និងកម្ចាត់មន្ត្រីរដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ។ នៅក្នុងរយៈកាលមុនរំដោះ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសន្និដ្ឋានថាមាន "ខ្មាំងតិច" នៅតាមតំបន់ជនបទ ប៉ុន្តែនៅទីក្រុង "មានខ្មាំងច្រើន"។ ដូចដែលបានគូសបញ្ជាក់ខាងក្រោម នៅពេលប្រជាជនជម្លៀសពីភ្នំពេញ និងតំបន់ប្រជុំជនផ្សេងៗ បានទៅដល់ទីតាំង នានាដូចជា ស្រុកកំពង់ត្រឡាចលើ (ស្រុក១២) នៃតំបន់៣១ (ខេត្តកំពង់ឆ្នាំង) នៃភូមិភាគបស្ចិម កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានកំណត់អត្តសញ្ញាណមន្ត្រីរដ្ឋការ និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ព្រមទាំងមនុស្សផ្សេងៗដែលគេបានចាត់ទុកថាជាខ្មាំង និងបានអនុវត្តការប្រហារជីវិតជាទ្រង់ទ្រាយធំនៅតាមទីកន្លែងផ្សេងៗនៅក្នុងស្រុកនោះ។ ហេតុការណ៍ស្រដៀងគ្នានេះ ក៏បានកើតមាននៅតាមតំបន់ផ្សេងៗនៅទូទាំងប្រទេសផងដែរ។

## ការសម្លាប់ដោយខុសច្បាប់

១៩៥- អនុលោមតាមបទបញ្ជារបស់គណៈស្រុក និងគណៈឃុំ ប្រជាជនជម្លៀសដែលបានមកដល់ស្រុក១២ ត្រូវបានខ្មែរក្រហមសួរប្រវត្តិរូប និងបែងចែកជា២ក្រុម **ក្រុមទី១** គឺ"ប្រជាជនសាមញ្ញដូចជា កសិករ" **ក្រុមទី២** គឺ "ប្រជាជនពិសេសដូចជា ទាហាន អ្នករដ្ឋការនៃរបបលន់ នល់ និងពួកនាយទុន"។ ប្រជាជនក្នុងក្រុមទី១ ត្រូវបានគេទុកជីវិត "សម្រាប់ធ្វើការ" ចំណែកក្រុមទី២ ត្រូវយកទៅប្រហារជីវិត។ [redacted]

[redacted] ការប្រហារជីវិតទាំងនេះបានកើតមាននៅតាមទីតាំងមួយចំនួនផ្សេងៗគ្នា ក្នុងស្រុកកំពង់ត្រឡាចលើ។

១៩៦- ក្នុងឱកាសពាខុសគ្នា អំឡុងរយៈពេល១ ទៅ ២ខែ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនជម្លៀសជាច្រើនក្រុមប្រមាណ៥០០នាក់ រួមទឹងទាហានសាធារណរដ្ឋខ្មែរ ត្រូវបានល្អួបដឹកទៅកាន់វត្តត្បែងខ្ពស់ នៅឃុំត្បែងខ្ពស់ ដែលនៅទីនោះ ពួកគេត្រូវបានឃុំឃាំងរយៈពេលមិនលើសពី២ថ្ងៃ ហើយបន្ទាប់មក"ត្រូវបានបញ្ជូន"ទៅប្រហារជីវិត។ បន្ទាប់ពីទៅដល់វត្ត "ទាហាន គ្រូបង្រៀន គ្រូពេទ្យ បញ្ញវន្ត ឬនិស្សិត" ត្រូវបានបំបែកពីប្រជាជនផ្សេងទៀត និងត្រូវបាននាំយកទៅសម្លាប់ជាក្រុម ក្នុងមួយក្រុមមានគ្នា១០នាក់ ក្នុងមួយលើក។ ប្រពន្ធ និងកូនរបស់ពួកគេត្រូវបានសម្លាប់នៅពេលបន្ទាប់។ ទីកន្លែងប្រហារជីវិតដែលត្រូវបានប្រើប្រាស់សម្រាប់សម្លាប់មនុស្សគឺ គោករនាមដែលស្ថិតនៅចម្ងាយប្រមាណ២ គីឡូម៉ែត្រ ពីភូមិត្បែងខ្ពស់ត្រពាំងអណ្ដូង និងត្រពាំងខ្លុង។ មនុស្សចំនួនប្រមាណ១២០០ ទៅ១៣០០នាក់ ត្រូវបាន សម្លាប់នៅទីកន្លែងទាំងនោះ ដែលភាគច្រើននៃពួកគេគឺជា"មន្ត្រី ទាហាន ពលករ ដែលត្រូវបានខ្មែរក្រហមជម្លៀសពីភ្នំពេញ"។ [redacted] បានអះអាងបញ្ជាក់ថា"ប្រជាជនជម្លៀសជាច្រើនពីភ្នំពេញ" ត្រូវបានឃុំឃាំង នៅក្នុងវត្តត្បែងខ្ពស់ និងនាំយកទៅប្រហារជីវិត តាមបញ្ជារបស់មេបញ្ជាការយោធាស្រុក ហើយខ្លួនគាត់ផ្ទាល់បានឃើញសាកសពជាច្រើននៅទីតាំងគោករនាម។ [redacted] ក៏បានបញ្ជាក់អះអាងអំពីការប្រហារជីវិតទាំងនេះដែរ។ នៅឆ្នាំ១៩៨២ មានលលាដ៍ក្បាលចំនួនជាង៥០០ ព្រមទាំងឆ្អឹងជើង និងដៃ ត្រូវបានប្រមែប្រមូល និងយកទៅដាក់នៅវត្តត្បែងខ្ពស់ ប៉ុន្តែ សព្វថ្ងៃពុំមានអត្ថិភាពទៀតឡើយ។

១៩៧- នៅក្នុងឃុំដដែលនេះ នៅចុងខែមេសា ឬដើមខែឧសភា ឆ្នាំ១៩៧៥ ក្រុមប្រជាជនភៀសខ្លួនដែលមានគ្នាពី៣០ ទៅ៥០នាក់ ក្នុងនោះ រួមមាន ស្ត្រី កុមារ និងមនុស្សចាស់ ត្រូវបានឃុំខ្លួននៅភូមិថ្មីខ្មែរ និងបន្ទាប់មកត្រូវបានលួបដែលប្រដាប់ដោយអាវុធ នាំយកទៅប្រហារជីវិត ចម្ងាយ ១គីឡូម៉ែត្រ ពីព្រៃស្រែវាល។ បទបញ្ជាប្រហារជីវិតប្រជាជនជម្លៀសទាំងនេះ ចេញមកពី "ថ្នាក់លើ" និងត្រូវបានផ្សព្វផ្សាយបន្ត ដោយប្រធានឃុំស្វាយជុក និងអនុប្រធានរបស់គាត់។ សាកសពត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួមចំនួន១៥ដែលក្នុងរណ្តៅសាកសពនីមួយៗ អាចដាក់សាកសពបានចំនួនជាង២០។ ក្នុងរយៈពេល៣ថ្ងៃ យ៉ាងហោចណាស់ មានមនុស្សចំនួន ១២០០នាក់ ត្រូវបានសម្លាប់។ កម្មាភិបាល២រូបដែលត្រូវបានចាត់តាំង ឲ្យនាំយកអ្នកជម្លៀសពីភូមិថ្មីខ្មែរ ទៅព្រៃស្រែវាល បានបញ្ជាក់អះអាងអំពីហេតុការណ៍ទាំងនេះ។ លលាដ៍ក្បាល និងឆ្អឹង ក៏ត្រូវបានប្រទះឃើញនៅតំបន់នេះ និងបាននាំយកទៅដាក់នៅវត្តត្បែងខ្ពស់។

១៩៨- ការប្រហារជីវិតទ្រង់ទ្រាយធំ ទៅលើទាហាននៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនជម្លៀសឯទៀតក៏បានកើតមាននៅតាមទីតាំងផ្សេងៗក្នុងស្រុកកំពង់ត្រឡាចលើផងដែរ។ នៅភូមិត្រពាំងម្ទេស ក្នុងឃុំស្វាយជុក ប្រជាជនជម្លៀសមកពីកំពង់ឆ្នាំង ត្រូវបានឃុំឃាំងនៅក្នុងវិហារក្នុងមូលដ្ឋាននោះរយៈពេល២ថ្ងៃ ហើយបន្ទាប់មកត្រូវបាននាំទៅកាន់ព្រៃតាគុជ និងប្រហារជីវិត *ទាំងហ្វូង*។ នៅភ្នំគ្រេច ក្នុងឃុំក្រាំងល្វា ប្រជាជន១៧ មេសា និងទាហានសាធារណរដ្ឋខ្មែររាប់រយនាក់ ត្រូវបានសម្លាប់ដោយអង្គភាពយោធាស្រុក១២ ដែលមានគ្នាចំនួន៣០នាក់។ [redacted] បានបញ្ជាក់អះអាងថា រៀងរាល់ពេលដែលប្រជាជនជម្លៀសថ្មីពីភ្នំ ពេញចូលមកដល់ គេបានកំណត់អត្តសញ្ញាណជាទាហានរបបសាធារណរដ្ឋខ្មែរ និងយក

ពួកគេទៅប្រហារជីវិត ជាទូទៅនៅឯត្រពាំងអម្ពិល និងត្រពាំងក្រែង។ យ៉ាងហោចណាស់ ប្រជាជនជម្លៀសចំនួន៧០០នាក់ ត្រូវបានសម្លាប់ និងកប់នៅទីកន្លែងមួយដែលស្ថិតនៅចម្ងាយកន្លះគីឡូម៉ែត្រភាគខាងលិចនៃដំរីស្រុត តាមបញ្ជារបស់គណៈស្រុក។ នៅវត្តច្រកស្តេច ឃុំ ពាម ខ្មែរក្រហមបានបំបែកអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសារពីប្រជាជនឯទៀត និងនាំយកទៅសម្លាប់ក្នុងព្រៃ រួចកប់សាកសពពួកគេក្នុងរណ្តៅសាកសព រួម។

## របនាសម្ពន្ធគ្រប់គ្រង

១៩៩- កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់មូលដ្ឋានដែលទទួលបន្ទុកការប្រហារជីវិត ជាទ្រង់ទ្រាយធំ នៅស្រុកកំពង់ត្រឡាចលើ មានដូចជា [redacted]

## ដំណាក់កាលទី២៖ ទៅកាន់ភូមិភាគឧត្តរ និងពាយ័ព្យ

## ការជម្លៀស

២០០- ការជម្លៀសប្រជាជនដោយបង្ខំទ្រង់ទ្រាយធំលើកទី២ បានចាប់ផ្តើមនៅចុងខែកញ្ញា ឆ្នាំ១៩៧៥ ឬនៅដើមខែតុលា ឆ្នាំ១៩៧៥។ នៅក្នុងការជម្លៀសដោយបង្ខំទ្រង់ទ្រាយធំនេះ យ៉ាងហោចណាស់ មនុស្ស៥០០០០០នាក់ ដែលភាគច្រើនជាប្រជាជនថ្មី ត្រូវបានបញ្ជូនពីភូមិភាគបូព៌ា និរតី និង បស្ចិម ទៅកាន់ភូមិភាគពាយ័ព្យ ខណៈមនុស្សរាប់ម៉ឺននាក់ ត្រូវបានបញ្ជូនទៅភូមិភាគ

ឧត្តរចាស់ និងតំបន់ព្រះវិហារ។ គោលបំណងចម្បងនៃការជម្លៀសទាំងបង្ខំដោយខុសច្បាប់នេះ គឺដើម្បីដាក់ប្រជាជនឱ្យស្ថិតនៅក្រោមការធ្វើពលកម្មដោយបង្ខំ ដោយខុសច្បាប់។

## ស្ថានភាពអមនុស្សធម៌ និងពលកម្មដោយបង្ខំ

២០១- ស្ថានភាពអមនុស្សធម៌ និងការធ្វើពលកម្មដោយបង្ខំ មនុស្សរាប់ម៉ឺននាក់បានស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺដង្កាត់ គ្រោះថ្នាក់ ការបាក់កម្លាំង ការធ្វើទារុណកម្ម និងការប្រហារជីវិត នៅក្នុងដំណើរការនៃការជម្លៀសជាទ្រង់ទ្រាយធំនេះ។ មនុស្សជាច្រើនបានស្លាប់ក្នុងអំឡុង ពេលនៃការជម្លៀសនេះផ្ទាល់តែម្តង ហើយមនុស្សជាច្រើនទៀត បានស្លាប់នៅប៉ុន្មានខែ ក្រោយ ពីបានមកដល់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ។ សមាជិកគ្រួសារទាំងអស់របស់ប្រជាជនថ្មីត្រូវបានបញ្ជាឱ្យចាកចេញពីសហករណ៍ដែលពួកគាត់ត្រូវបានដាក់ឱ្យស្នាក់នៅទីនោះ អស់រយៈពេលប៉ុន្មានខែ មុននឹងមានការជម្លៀសដោយបង្ខំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មនុស្សជាច្រើនត្រូវបានខ្មែរក្រហមបណ្តើរទៅកាន់ទន្លេ ឆ្លងទូកទៅភ្នំពេញ ហើយបញ្ជូន ពីភ្នំពេញតាមរថភ្លើងទៅកាន់ភូមិភាគពាយ័ព្យ ក្រោមការឃាមកាមរបស់ឆ្មាំប្រដាប់ដោយអាវុធ ក្នុងករណីផ្សេងទៀត ប្រជាជនត្រូវបានដឹកតាមរថយន្តទៅកាន់ភូមិភាគពាយ័ព្យ ឬពួកគេត្រូវបានបង្ខំឱ្យធ្វើដំណើរដោយថ្មើរជើងក្នុងចម្ងាយដ៏វែងឆ្ងាយ។

២០២- នៅក្នុងករណីជាច្រើន ក្នុងអំឡុងពេលធ្វើដំណើរ ពួកគេពុំបានទទួលអាហារ ឬទឹកបរិភោគឡើយ។ នៅលើរថភ្លើង មនុស្សត្រូវបានដាក់ផ្តុំគ្នា ឱ្យជិះក្នុងទូរដឹកទំនិញដែលបានបណ្តាលឱ្យមានការស្លាប់បាត់បង់ជីវិតដោយពុំចាំបាច់សម្លាប់។ ជនរងគ្រោះម្នាក់ បានរៀបរាប់អំពីអ្វីដែលហាក់ដូចជាការធ្វើដំណើរធម្មតា [redacted]

[redacted]

២០៣- ការជម្លៀសមនុស្សជាទ្រង់ទ្រាយធំដោយបង្ខំ បានបន្តអស់រយៈពេលចំនួន៦ខែ។ ពលកររថភ្លើងបានសង្កេតឃើញរថភ្លើងដឹកមនុស្សណែនតាន់តាប់ ពីទិសខាងត្បូង ទៅកាន់ទិសខាងជើង កាត់តាមបាត់ដំបង ពីក្នុងខែតុលា ឬវិច្ឆិកា ឆ្នាំ១៩៧៥ ដល់ខែកុម្ភៈ ឬមីនា ឆ្នាំ១៩៧៦ រថភ្លើងចំនួន១ ឬ២ ក្នុងមួយសប្តាហ៍ មានទូចំនួន២០ ទៅ២៥ ក្នុងរថភ្លើងមួយ និងមានមនុស្ស៥០នាក់ ក្នុងមួយទូ។ ខ្មែរក្រហមក៏បានដឹកមនុស្សពីទិសខាងត្បូង ទៅកាន់ទិសខាងជើង តាមរថយន្ត ស៊ីវិល និងយោធាដែរ ក្នុងពេលតែមួយជាមួយនឹងពេលជម្លៀសមនុស្សដោយបង្ខំតាមរថភ្លើង។ នៅពេលទៅដល់ ជនរងគ្រោះត្រូវបានទម្លាក់ចុះនៅតំបន់វាលរហោឋាន ឬភូមិដែលរងការបំផ្លិចបំផ្លាញ ដែលនៅទីនោះ ខ្មែរក្រហមបានបញ្ជាឱ្យពួកគេសង់ទីជម្រក ឬដាំស្រូវ ជាទូទៅគ្មានអ្វីជួយទំនុកបម្រុង ដូចជា អណ្តូង សម្ភារៈ ឬគ្រាប់ពូជទេ។ [redacted]

[redacted]

២០៤- នៅស្រុកសិរីសោភ័ណ ក្នុងតំបន់៥ ភូមិភាគពាយ័ព្យ ចំនួនប្រជាជនមាន៥០០០០នាក់ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ដែលស្ទើរតែទាំងអស់នៃពួកគេ គឺជាប្រជាជនថ្មី។ នៅស្រុកភ្នំស្រុក នៃតំបន់៥ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនតែចំនួន៣០០គ្រួសារប៉ុណ្ណោះ ប៉ុន្តែក្រោយ មកមានមនុស្សមកពីភ្នំពេញចំនួន៥០០០០នាក់ បានទៅដល់ទីនោះ រួមជាមួយនឹង "ប្រជាជនថ្មី" នៅមូលដ្ឋានចំនួន២០០០០នាក់ទៀត ដែលត្រូវបានជម្លៀសចេញពីទីក្រុងក្បែរៗនោះ ក្រោយថ្ងៃរំដោះ។ ស្រុកព្រះនេត្រព្រះ មានប្រជាជនចំនួនត្រឹមតែ១៥០គ្រួសារ ប៉ុណ្ណោះ នៅមុនថ្ងៃទី១៧ ខែមេសា ហើយបន្ទាប់មកជនរងគ្រោះចំនួន៧០០០០នាក់ ត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់ទីនោះ នៅក្នុងជុំទី២ នៃការជម្លៀសដោយបង្ខំ។ ដូច្នេះ គ្រាន់តែនៅក្នុងស្រុកចំនួន៣នៃស្រុកទាំង៤ របស់តំបន់៥នេះ ក្នុងតំបន់មួយនៃតំបន់ទាំង៧របស់ភូមិភាគពាយ័ព្យ "ប្រជាជនថ្មី" ចំនួនជិត២០០០០០នាក់ ត្រូវបានគេយកមកដាក់នៅទីនេះ។

២០៥- នៅក្នុងស្រុកមួយនៃតំបន់៥ ក្នុងភូមិភាគពាយ័ព្យ ពោល គឺស្រុកព្រះនេត្រព្រះ តំបន់បានរាយការណ៍ ថាមានប្រជាជនជាង២០០០០នាក់ ស្លាប់ដោយភាពអត់ឃ្លាននៅឆ្នាំ១៩៧៦។ បើទោះបីជាយ៉ាងដូច្នេះក្តី របាយការណ៍មួយកាលពីប៉ុន្មានសប្តាហ៍មុន បានរាយការណ៍ថា "សមាសភាព១៧ មេសា មានចំនួនច្រើនលើសលប់នៅតំបន់៥" ហើយបានគូសបញ្ជាក់អំពីកិច្ចខិតខំក្នុងការកម្ចាត់ពួកគេ។ ឯកសារនេះកត់សម្គាល់ថា វិធានការទាំងនេះ កំពុងត្រូវបាន អនុវត្តមកលើ"ជនក្បត់ដែលជាសមាសភាព១៧ មេសា មកពីភ្នំពេញ" ផ្អែកតាមការណែនាំពី

"សេចក្តីថ្លែងការណ៍របស់បក្ស" ដែលត្រូវបានផ្សព្វផ្សាយ នៅក្នុងសន្និបាតថ្នាក់ភូមិភាគកាលពី ១សប្តាហ៍មុន។

២០៦- **អៀង ធីរិទ្ធ** បានធ្វើទស្សនកិច្ចចុះត្រួតពិនិត្យភូមិភាគពាយ័ព្យនៅត្រីមាសទី២ ឆ្នាំ១៩៧៦ ដោយបានឃើញដោយផ្ទាល់នូវស្ថានភាពដែលអាចបណ្តាលឱ្យមានការបាត់បង់ជីវិត ដែលត្រូវបានបង្កើតឡើងតាមការបញ្ជារបស់គណៈអចិន្ត្រៃយ៍ ឱ្យជម្លៀសមនុស្សរាប់សែននាក់។ "នៅខេត្តបាត់ដំបង ខ្ញុំបានឃើញច្បាស់ថា ពួកគេបានឱ្យប្រជាជនទាំងអស់ ចុះទៅវាលស្រែឆ្ងាយសន្ធឹមពីភូមិ ហើយប្រជាជនគ្មានផ្ទះសម្បែង ហើយខ្ញុំបានឃើញថាពួកគេគ្មានផ្ទះ ហើយសុទ្ធតែមានជំងឺ។ ...ខ្ញុំបានឃើញ មនុស្សគ្រប់គ្នានៅតាមវាលស្រែល្ហល្ហេវ គ្មានអ្វីទាំងអស់ ក្រោមកម្តៅព្រះអាទិត្យក្តៅហែង។ ខ្ញុំបានឃើញមនុស្សជាច្រើនកើតជំងឺរាគរូស និងគ្រុនចាញ់"។ ទោះបីជាយ៉ាងដូច្នេះក្តី ជំនួសឱ្យការទទួលស្គាល់ថា គោលនយោបាយរវើរវាយរបស់ខ្លួន ជាអ្នកបានបង្កឱ្យមានមហន្តរាយនេះ ថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាបានសន្និដ្ឋានថា បញ្ហានេះមកពីមានជនក្បត់ក្នុងជួរ ហើយដំណោះស្រាយ គឺត្រូវសម្លាប់ និងបោសសម្អាតថែមទៀត។

## ការសម្លាប់ក្នុងទ្រង់ទ្រាយធំនៅភូមិភាគពាយ័ព្យ

២០៧- មនុស្សជាច្រើនដែលស្ថិតនៅក្រោមការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ បានស្លាប់ ឬត្រូវបានសម្លាប់ នៅតាមឃុំ និងសហករណ៍ និងនៅតាមការដ្ឋាន។ ប្រសិនបើគ្មានកិច្ចខិតខំទាល់តែសោះ ក្នុងការស្តុកស្បៀងអាហារទុកសម្រាប់ហូបចុកឱ្យបានមុនពេលនៃការជម្លៀសប្រជាជនដោយបង្ខំនោះទេ ម្ល៉េះនឹងពុំមានអាហារហូបគ្រប់គ្រាន់ឡើយ ហើយភាពអត់ឃ្លានក្នុងទ្រង់ទ្រាយធំ និងការស្លាប់នៅគ្រប់ទីកន្លែង នឹងរង់ចាំជនរងគ្រោះ។ មានជំងឺរាតត្បាត

គ្រប់ទីកន្លែងនៅក្នុងស្ថានភាពអមនុស្សធម៌ ដែលខ្មែរក្រហមបានបង្កមកលើជនរងគ្រោះនៃការជម្លៀសដោយបង្ខំ ទៅកាន់ភូមិភាគពាយ័ព្យ ហើយបូកផ្សំជាមួយនឹងការខ្វះសេវាថែទាំវេជ្ជសាស្ត្រទាំងស្រុងផងនោះ។ ស្ថានភាពនេះ បានបណ្តាលឱ្យមានការស្លាប់ក្នុងចំនួនច្រើនសន្ធឹកសន្ធាប់។ លើសពីនេះទៀត មនុស្សមួយចំនួនធំ ត្រូវបានបង្ខំឱ្យធ្វើការរហូតដល់ស្លាប់ដោយដួលស្លាប់ ដោយសារការបាក់កម្លាំងនៅតាមវាលស្រែ។

### សេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការជម្លៀសដោយបង្ខំ

២០៨- នៅចន្លោះពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានធ្វើទស្សនកិច្ចចុះត្រួតពិនិត្យភូមិភាគពាយ័ព្យ។ នៅក្នុងដំណើរចុះត្រួតពិនិត្យនេះ គណៈអចិន្ត្រៃយ៍បានសន្និដ្ឋានថា សក្តានុពលកសិកម្មនៃភូមិភាគពាយ័ព្យ ពុំត្រូវបានប្រើប្រាស់ឱ្យបានត្រឹមត្រូវឡើយ ដោយសារតែខ្វះកម្លាំងពលកម្ម។ មួយខែបន្ទាប់មក នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាបានសម្រេចថា ពួកគេនឹងជម្លៀសប្រជាជនថ្មី យ៉ាងហោចណាស់ក្នុងចំនួនកន្លះលាននាក់ ពីភូមិភាគផ្សេងៗ ទៅកាន់ភូមិភាគពាយ័ព្យ ដើម្បីកែតម្រូវអតុល្យភាពក្នុងផ្នែកបង្កបង្កើនផល។

## ការធ្វើពលកម្មដោយបង្ខំ

### សហករណ៍ត្រាំកក់

### ទីតាំង និងប្រតិបត្តិការ

២០៩- ស្រុកត្រាំកក់ ឬស្រុក១០៥ ស្ថិតនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី។ មេដឹកនាំឃុំថ្មី និង ការចាត់តាំងការងារសមូហភាព ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាបង្កើតឡើងក្នុងឆ្នាំ១៩៧០ ពេល ដែលពួកគេបានចូលគ្រប់គ្រងតំបន់នេះ។ សហករណ៍កម្រិតតូចនៅថ្នាក់ភូមិ ត្រូវបានចាប់ បង្កើតឡើងនៅអំឡុងឆ្នាំ១៩៧៣។ ទ្រព្យសម្បត្តិឯកជនត្រូវបានលុបបំបាត់ក្នុងឆ្នាំ១៩៧៥ ហើយសហករណ៍កម្រិតធំនៅថ្នាក់ឃុំ ត្រូវបានចាប់បង្កើតឡើងនៅអំឡុងឆ្នាំ១៩៧៦។ ការ រៀបចំការរស់នៅតាមសហករណ៍ ដូចជា ការបរិភោគរួម ត្រូវបានបង្កើតឡើងជាទូទៅ នៅ ឆ្នាំ១៩៧៦។ ចំនួនប្រជាជនដើមនៃស្រុកនេះ បានកើនឡើងនៅពេលដែលប្រជាជនឯទៀត ត្រូវបានជម្លៀសទៅកាន់ទីនោះ ពីភូមិនៅក្នុងស្រុកក្បែរៗ និងកាន់តែមានចំនួនច្រើនឡើង នៅ ពេលដែលប្រជាជនជម្លៀសពីភ្នំពេញ ឬទីក្រុងផ្សេងៗ ដែលជា “**ប្រជាជនថ្មី**” ឬ “**ប្រជាជន ១៧ មេសា**” បានមកដល់ទីនោះ ក្នុងឆ្នាំ១៩៧៥។

២១០- ក្នុងស្រុកត្រាំកក់ មានភូមិ និងសហករណ៍ដែលបង្កើតបានជាឃុំគុស **សំរោង ត្រពាំងធំត្បូង ត្រពាំងធំជើង ត្រាំកក់ ញ៉ែងញ៉ង ស្រែរនោង** និង **តា ភេន**។ ចាប់ពីឆ្នាំ១៩៧៣ ភូមិនីមួយៗ ត្រូវ បានបែងចែកជាសហករណ៍ និងក្នុងមួយឃុំមានសហករណ៍ច្រើន។ ចាប់ពីឆ្នាំ១៩៧៦ សហ ករណ៍ខ្នាតភូមិ ត្រូវបានបញ្ចូលទៅក្នុងសហករណ៍ខ្នាតឃុំជាបណ្តើរៗ។ នៅតាមសហករណ៍ ប្រជាជនត្រូវបានបែងចែកទៅក្នុងកងផ្សេងៗ ដូចជា កងកុមារ កងយុវជន កង ប្រមូលផ្តុំ កង មនុស្សចាស់ កងនារី និងកងដាំបន្លែ។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើការដ្ឋាន

២១១- តា ម៉ុក ជាលេខាភូមិភាគនិរតី និងជាសមាជិកគណៈឃោសាមជ្ឈិមបក្សជាមួយ នួន ជា និងក្រោយមក គាត់បានក្លាយខ្លួនជាសមាជិកគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា។ ឈ្មោះ ចាន់ សំ *ហៅ* កង ចាប *ហៅ* សែ បានធ្វើជាអនុលេខាតំបន់រហូតមកខែកុម្ភៈ ឆ្នាំ១៩៧៧ និងបានចុះត្រួតពិនិត្យសហករណ៍យ៉ាងហោចណាស់ចំនួន១ នៅស្រុកត្រាំកក់។ បន្ទាប់ពី កង ចាប ត្រូវបានផ្ទេរទៅកាន់ភូមិភាគឧត្តរថ្មី សំ ប៊ិត ត្រូវបានដំឡើងតួនាទីជាអនុលេខាភូមិភាគ។ [redacted]។

**រចនាសម្ព័ន្ធក្នុងការដ្ឋាន**

២១២- គ្រប់ឃុំក្នុងស្រុកត្រាំកក់ មានគណៈឃុំមួយ។ ឃុំនីមួយៗ ក៏មានឈ្លបចំនួនប្រហែល១២នាក់ដែរ ។ លើសពីនេះទៀត នៅតាមភូមិ ឬសហករណ៍ មានប្រធាន និងកម្មាភិបាលទទួលបន្ទុក

កងការងារ។ ប្រធានឃុំ ប្រធានសហករណ៍ និងប្រធានភូមិ ឬសមាជិកគណៈកម្មាធិការ កាល ក្នុងអំឡុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ដែលគេស្គាល់ឈ្មោះមានដូចតទៅ៖

[redacted]

## ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស

## ពីបញ្ហាការជាន់ខ្ពស់ ប.ក.ក ទៅការដ្ឋាន

២១៣- មជ្ឈិមបក្សបង្គាប់បញ្ហាអំពីបរិមាណនៃការដាំស្រូវ រួមទាំងការបែងចែកស្រូវអង្ករឡើងវិញ និងការនាំចេញផង ប្រាប់ទៅកម្មាភិបាលថ្នាក់ទាប។ ស្រូវមួយភាគដែលផលិតបាននៅតាមសហករណ៍នីមួយៗ ត្រូវបានដឹកជញ្ជូនតាមរថយន្តទៅឱ្យមជ្ឈិមបក្ស។ ឃ្លាំងរដ្ឋភ្នំពេញជាអ្នកបញ្ជូនទំនិញផ្សេងៗ រួមទាំងស្រូវអង្ករ ដោយសម្រួលទៅដល់ការដោះដូរទំនិញ រវាងទីក្រុងនិងជនបទ។ **ខៀវ សំផន** គឺជាអ្នកទទួលបន្ទុកបែងចែកស្បៀងអាហារ និងការផ្គត់ផ្គង់ រួមទាំងស្រូវអង្ករ នៅក្នុងអង្គភាពផ្សេងៗគ្នានៃរបបកម្ពុជាប្រជាធិបតេយ្យ ចំណែកឯឈ្មោះ វ៉ាន់ រិត ទទួលបន្ទុកទំនិញ នាំចេញ រួមទាំងគ្រឿងឧបភោគបរិភោគផងដែរ។

២១៤- នៅរវាងថ្នាក់ផ្សេងៗគ្នានៃឋានានុក្រមភូមិភាគនិរតី ដូចជា រវាងថ្នាក់ដឹកនាំភូមិភាគ និងតំបន់ ឬថ្នាក់ដឹកនាំតំបន់ និងស្រុក ការដោះដូរព័ត៌មាន និងការចេញបញ្ជា ត្រូវបានធ្វើឡើងតាមរយៈការប្រជុំតាមកាលកំណត់។ តែងមានការប្រជុំជាទៀងទាត់រវាងគណៈភូមិភាគ និងគណៈតំបន់ បន្ទាប់មកមានការប្រជុំប្រចាំខែរវាងគណៈតំបន់១៣ និងគណៈស្រុក១០៥ តាមរយៈប្រធានតំបន់១០៩ និងប្រធានឃុំ។ ក្នុងអង្គប្រជុំ សេចក្តីណែនាំនានាពីមន្ទីរ៨៧០ ទាក់ទិននឹងការ វាយ និងការវែកមុខខ្មាំងត្រូវបានគេអានឱ្យកម្មាភិបាលឃុំ និងស្រុក ស្តាប់។ បន្ថែមពីលើនេះ របាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែ អំពីការអនុវត្តន៍"ផែនការការងារ" ត្រូវបានរៀបចំឡើងដោយមន្ត្រីស្រុក១០៥ និងផ្ញើទៅឱ្យតំបន់១៣។ ថ្នាក់ដឹកនាំស្រុកក៏បានជួបប្រជុំជាមួយថ្នាក់ដឹកនាំឃុំ ដើម្បីផ្សព្វផ្សាយអំពីផែនការការងារ។ បន្ទាប់មកទៀត ថ្នាក់ដឹកនាំឃុំជាអ្នករាយការណ៍អំពីផែនការនេះដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឱ្យសហករណ៍ បានដឹង។

## ពីការដ្ឋានទៅបញ្ជាការជាន់ខ្ពស់ ប.ក.ក

២១៥- រាល់សេចក្តីសម្រេចណាមួយរបស់គណៈឃុំ ត្រូវទទួលបានការឯកភាពពីថ្នាក់លើជាមុនសិន មុននឹងយកមកអនុវត្តនៅតាមសហករណ៍។ គណៈឃុំបើកអង្គប្រជុំជារៀងរាល់ខែ និងបាន រាយការណ៍ជូនគណៈស្រុក១០៥ តាមរយៈរបាយការណ៍ជាលាយលក្ខណ៍អក្សរ និងការ រាយការណ៍ផ្ទាល់មាត់។ ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការបោសសម្អាត ឃុំជាអ្នករាយការណ៍ ជូនថ្នាក់ស្រុកអំពីសកម្មភាពគួរឱ្យសង្ស័យរបស់ប្រជាជន (ដូចជា ការលួចអាហារ ការពុំប្រឹង ប្រែងធ្វើការ ការធ្វើពុតឈឺ ការរៀបចំផែនការប្រឆាំង "អង្គការ" ឬការរៀបចំគម្រោងរត់ គេចខ្លួន) ហើយបន្ទាប់មកគណៈស្រុកជាអ្នកធ្វើសេចក្តីសម្រេចក្នុងការចាប់ខ្លួន "ជនក្បត់" ហើយបញ្ជូនពួកគេទៅកាន់មន្ទីរសន្តិសុខស្រុកនៅមូលដ្ឋាន ឈ្មោះ មន្ទីរសន្តិសុខក្រាំងតាចាន់ (ក.ត.ច)។ ឃុំក៏ជាអ្នកធ្វើរបាយការណ៍ជូនមន្ទីរក្រាំងតាចាន់ផ្ទាល់ ដោយជម្រាបកម្មាភិបាល មន្ទីរ ក.ត.ច អំពីសេចក្តីសម្រេចរបស់ "បក្សថ្នាក់លើ" ឬ"ស្រុក" ក្នុងការបញ្ជូន "ជនក្បត់" ទៅកាន់ ក.ត.ច។

២១៦- ឯកសាររបស់ស្រុកត្រាំកក់កាលពីពេលនោះ បង្ហាញថាឃុំក៏ជាអ្នកធ្វើរបាយការណ៍ជូនបណ្តាញ បញ្ជាការ អំពីការប្រើប្រាស់ស្រូវអង្ករ និងប្រេងឥន្ធនៈ ការចោទសួរអំពីមាគ៌ានយោបាយរបស់ អង្គការ និងបញ្ជីប្រជាជនក្នុងឃុំ ដោយបានកំណត់អត្តសញ្ញាណជាប្រជាជនកម្ពុជាក្រោម ជនក្បត់ដែលត្រូវបានចោទប្រកាន់ និងប្រភេទពលករផ្សេងៗ (កម្លាំងទី១ ទី២ និងទី៣)។ ខ្មែរក្រហមប្រើប្រាស់និរសាសម្រាប់បញ្ជូនទៅមករវាងថ្នាក់ផ្សេងៗនូវរបាយការណ៍ និងបទ បញ្ជាដែលត្រូវបានសរសេរដោយដៃ ឬវាយដោយម៉ាស៊ីនអង្គុលីលេខ។ គណៈស្រុកមាន និរសា

យ៉ាងតិចណាស់ចំនួន១២នាក់ពិសេសគឺទទួលបន្ទុកធ្វើលិខិតអញ្ជើញប្រជុំ។ ជា ធម្មតា ក្នុង មួយឃុំ មាននិរសាចំនួន២នាក់។

## ការធ្វើពលកម្មដោយបង្ខំ

២១៧- នៅសហករណ៍ត្រាំកក់ ពលករត្រូវបានបែងចែកជាប្រភេទផ្សេងៗដូចជា **កម្លាំងទី១** មានប្រុស ស្រី ក្មេងៗ គឺត្រូវរែកដី **កម្លាំងទី២** មានអ្នកជំងឺប្រុសស្រី ឬអាយុពី៣០ឆ្នាំឡើង និង**កម្លាំងទី៣** គឺ មនុស្សចាស់។ អ្នកជំងឺ កុមារ និងស្ត្រីមានផ្ទៃពោះ ត្រូវខ្មែរក្រហមបង្ខំឱ្យធ្វើការ ទាំងអស់ និង គ្មាននរណាម្នាក់ហ៊ានប្រកែកតវ៉ាឡើយ ដោយសារពួកគេខ្លាចខ្មែរក្រហម សម្លាប់។ ជាពិសេស កម្មករនៅតាមសហករណ៍នានា ក្នុងស្រុកត្រាំកក់ ត្រូវបានខ្មែរក្រហម បង្ខំឱ្យធ្វើការនៅ តាមវាលស្រែ ដូចជា ធ្វើស្រែ ជីកប្រឡាយ រើសអាចម៍គោ រែកដីដំបូក លើកទំនប់ និង សង់ស្ពាន។ ម៉ោងធ្វើការជាធម្មតាគឺចាប់ពីខ្ទង់ម៉ោង៦ព្រឹក រហូតដល់ថ្ងៃត្រង់ និងពី ម៉ោង១រសៀល ដល់ម៉ោង៥ល្ងាច ប៉ុន្តែជួនកាលបន្តរហូតជិតដល់ម៉ោង១០យប់។

២១៨- ការងារនៅសហករណ៍ត្រាំកក់ត្រូវបានកំណត់ដោយបរិមាណទិន្នផលស្រូវ តាមការកំណត់ របស់មជ្ឈិមបក្ស និងតាមការប្រកាសរបស់គណៈស្រុក១០៥។ បរិមាណទិន្នផលស្រូវ ខុសៗគ្នាពី៣តោន ទៅ៤តោន ក្នុងមួយហិកតា។ ដើម្បីបំពេញតាមបរិមាណកំណត់ ពលករ ត្រូវចូលរួមក្នុងអង្គប្រជុំថ្នាក់ឃុំ និងស្រុក ដែលនៅទីនោះកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកទិតៀនថាពួកគេខ្ជិលច្រអូស ណែនាំឱ្យពួកគេខិតខំប្រឹងប្រែងធ្វើការងារ និងអនុវត្ត តាមផែនការការងារ និងប្រាប់ពួកគេឱ្យប្រើប្រាស់សម្ភារៈផ្សេងៗ ដូចជា លាមកមនុស្ស

អាចម៍សត្វ និងជីដំបូក ដើម្បីបង្កើនទិន្នផល។ ពលករក៏ត្រូវបានខ្មែរក្រហមបង្ខំឲ្យទិតៀនគ្នាទៅវិញទៅមក និងទទួលស្គាល់ចំណុចខ្វះខាតរបស់ខ្លួនឯងក្នុងអង្គប្រជុំ។

## ស្ថានភាពអមនុស្សធម៌

២១៩- នៅពេលមកដល់សហករណ៍ ខ្មែរក្រហមបានបែងចែកប្រជាជនជា ១)ប្រជាជន"ពេញសិទ្ធិ" (អ្នកក្រខ្សត់ក្រោមការគាបសង្កត់របស់របបសាធារណរដ្ឋខ្មែរ ឬមនុស្សដែលមានសមាជិកគ្រួសារច្បាំងវាយរបបសាធារណរដ្ឋខ្មែរ) ២)ប្រជាជន"បម្រុង" ឬ"បេក្ខជន" (មនុស្សដែលខ្មែរក្រហមយល់ថាមានសាច់ញាតិគាំទ្ររបបសម្ដេចសីហនុ ឬរបបសាធារណរដ្ឋខ្មែរ) ឬ៣) មនុស្ស"បរាសិត" ឬប្រជាជន"បញ្ញើក្អែក" (ប្រជាជន ដែលត្រូវបានខ្មែរក្រហមជម្លៀសចេញពីភ្នំពេញ)។ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ប្រជាជននៅតាមសហករណ៍នានាក្នុងស្រុកត្រាំកក់បានរស់នៅជាមួយមនុស្សដែលស្ថិតនៅក្នុងប្រភេទក្រុមរបស់ខ្លួនតែប៉ុណ្ណោះ ដែលមនុស្សជាច្រើនត្រូវបានបង្ខំឲ្យរស់នៅក្នុងបន្ទប់តូចៗតាមផ្ទះ។ បើទោះបីជាមនុស្សមួយចំនួនតូចបានរស់នៅជុំគ្នាជាមួយបងប្អូន ឪពុកម្ដាយ និងកូនក្មេងតូចៗក្ដី ក៏ជាធម្មតា សមាជិកក្រុមគ្រួសារភាគច្រើនត្រូវបានបង្ខំឲ្យរស់នៅបែកពីគ្នា។ ស្ថានភាពនេះ បានបង្កើតឲ្យគ្មានភាពឯកជន ដោយសារអ្នកស្រុកត្រូវបានបង្ខំឲ្យរស់នៅ និងបរិភោគរួម។ ស្ថិតក្នុងចំណោមមនុស្សចម្លែកពុំស្គាល់គ្នា អ្នកស្រុកពុំអាចនិយាយស្ដីដោយសេរីឡើយ ហើយពួកគេត្រូវបានបង្ខំឲ្យរស់នៅជាមួយគ្នាជាសម្ងហភាព។

២២០- បក្សកុម្មុយនីស្តកម្ពុជា ក៏បានដាក់ប្រព័ន្ធនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅត្រាំកក់ ដែលបានបង្ខំឲ្យមនុស្សប្រុស ស្រី សម្រេចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាក្រុមដែលមានពី១០ ទៅ

២០គូ។ ឪពុកម្ដាយខាងប្រុស និងខាងស្រី មិនត្រូវបានគេជូនដំណឹង ឬហៅទៅចូលរួមពិធីនោះទេ។ ប្ដីប្រពន្ធត្រូវបានមេដឹកនាំឃុំជ្រើសរើស ដោយពុំពិចារណាអំពីការយល់ឃើញ ឬការពេញចិត្តរបស់មនុស្សដែលគេចាប់គូជាប្ដី និងប្រពន្ធឡើយ។ អ្នកណាជំទាស់ទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ បើប្រុសត្រូវគេបញ្ជូនទៅធ្វើកងទ័ព បើស្រីត្រូវគេបញ្ជូនទៅលត់ដំ។ ប្ដីប្រពន្ធខ្លះព្រមរៀបការដោយបង្ខំដោយសារខ្លាចការដាក់ទណ្ឌកម្ម។

២២១- នៅពេលរៀបអាពាហ៍ពិពាហ៍ ប្ដីប្រពន្ធបានរស់នៅបែកគ្នា ប៉ុន្តែពេលខ្លះថ្នាក់ដឹកនាំឃុំបានបញ្ជាឲ្យពួកគេនៅជាមួយគ្នាមួយយប់។ ក្រៅពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលមាននៅត្រាំកក់ មាននារីចំនួន៣ ទៅ៥នាក់ មកពីឃុំញ៉ែងញ៉ង និងនារីមួយចំនួនទៀត មកពីតាមបណ្ដាឃុំផ្សេងៗ ត្រូវបានខ្មែរក្រហមបញ្ជូនទៅកំពង់សោម ដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយទាហានពិកាតាមសំណើរបស់កងទ័ព។

២២២- អ្នករស់នៅតាមសហករណ៍នានាក្នុងស្រុកត្រាំកក់ ត្រូវបានបង្ខំឲ្យបោះបង់ការគោរពសាសនារបស់ពួកគេ។ ក្នុងគោលបំណងសម្រួលដល់ការសង្កត់សង្កិនក្នុងការប្រតិបត្តិសាសនា កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានបោះរូបព្រះពុទ្ធបដិមាចោល ទម្លាក់ចូលទៅក្នុងទឹករិះគន់ប្រជាជនថាគោរពបូជាស៊ីម៉ងត៍ បានយកវត្តធ្វើជាមន្ទីរសន្តិសុខ មន្ទីរពេទ្យ និងរោងជាង ហើយបានដៀលត្មេះ និងផ្សឹកព្រះសង្ឃ។ មនុស្សខ្លាចមិនហ៊ានអុជធូប។ នៅពេលមនុស្សបានស្លាប់ដោយសារជំងឺ ការបាក់កម្លាំង និងការខ្វះជីវជាតិ សមាជិកក្រុមគ្រួសារពុំត្រូវបានអនុញ្ញាតឲ្យយកសាកសពទៅបូជា ឬធ្វើបុណ្យឡើយ។

២២៣- ពលករបានទទួលអាហារពុំគ្រប់គ្រាន់។ របបអាហារមានបបរ បាយ និងសម្លត្រកួន បន្លិច បន្លួចស្លួចស្ដើង។ ឃុំបានទទួលស្បៀងអាហារពីស្រុក និងជាអ្នកទទួលបន្ទុកកំណត់របបអាហារ និងបែងចែកអាហារទៅតាមចំនួនមនុស្ស នៅតាមសហករណ៍នីមួយៗ។ ឧទាហរណ៍ របបអង្ករពី២ ទៅ៤កំប៉ុង ក្នុងមួយថ្ងៃត្រូវបានផ្ដល់ឲ្យសម្រាប់មនុស្សចំនួន១០នាក់។ អាហារត្រូវបានគេ ចែកឲ្យមួយថ្ងៃ២ពេល ថ្ងៃត្រង់ និងម៉ោងប្រហែល៦ល្ងាច។ ដោយសារតែស្រុកផ្គត់ផ្គង់ស្បៀងអាហារពុំគ្រប់គ្រាន់ទៅឲ្យឃុំតាមសហករណ៍ខ្លះ កម្មាភិបាលមូលដ្ឋានបានក្លែងបន្លំរបាយការណ៍ផលិតស្រូវសម្រាប់មជ្ឈិមបក្ស ដើម្បីទុកស្បៀងមួយចំនួនសម្រាប់អ្នកស្រុក។ ភាពអត់ឃ្លានក៏បានបណ្ដាលឲ្យមនុស្សខ្លះលួចហូប ឬដើររកអាហារ ដោយ ប្រថុយប្រថាននឹងការចាប់ខ្លួន។ បើទោះបីមានកិច្ចខិតខំប្រឹងប្រែងតែម្នាក់ឯង ក្នុងការ ប្រឆាំងនឹងគោលនយោបាយស្បៀងរបស់បក្សកុម្មុយនីស្តកម្ពុជាក្តី ក៏ពលករជាច្រើនបានឃ្លានដាច់ពោះស្លាប់ ហើយថ្នាក់ស្រុកបានដឹងអំពីស្ថានភាពទាំងនេះ។

២២៤- ពលករ និងអ្នកស្រុកឃុំត្រាំកក់ធ្លាក់ខ្លួនស្គមស្គាំង ហើយមនុស្សជាច្រើន កើតជំងឺគ្រុនក្ដៅ រាគរូស និងហើម។ ឱសថដែលមាន គឺពុំមែនជាឱសថវិទ្យាសាស្ត្រ ហើយជាឱសថផលិតក្នុងស្រុក ហើយពេទ្យដែលមកពីពេទ្យឃុំ គឺជាពេទ្យក្មេងៗ និងគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ មានតែអ្នកជំងឺធ្ងន់ប៉ុណ្ណោះដែលត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ដែលគេបានរាយការណ៍ថាទីនោះអ្នកជំងឺជាច្រើនបានស្លាប់។ មនុស្សជាច្រើនទៀតក៏បានស្លាប់ដោយសារជំងឺនៅតាមឃុំផងដែរ។ ពិសេសមនុស្សដែលងាយរងគ្រោះនៅត្រាំកក់ គឺប្រជាជន១៧មេសា ដែលភាគច្រើនបានស្លាប់ដោយសារជំងឺ និងភាពអត់ឃ្លាននៅតាមសហករណ៍។

២២៥- នរណាម្នាក់ដែលប្រឆាំង ឬពុំឯកភាពជាមួយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបញ្ជូនទៅ "លត់ដំ" និងបាត់ខ្លួន ដែលទង្វើនេះបានធ្វើឲ្យប្រជាជនភ័យខ្លាចជាប់ជាប្រចាំមិនប៉ានតវ៉ា។ សូម្បីអ្នកស្រុកដែលត្រូវបានបង្ខំឲ្យធ្វើការងារក្រោមស្ថានភាពយ៉ាប់យ៉ឺនបំផុត ក៏ពុំប៉ានត្អូញត្អែរឡើយ ដោយហេតុថាពួកគេខ្លាចខ្មែរក្រហមចាប់ខ្លួន ឬសម្លាប់។ ជាការពិត នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មនុស្សជាច្រើនត្រូវបានគេបញ្ជូនទៅឆ្ងាយ ហើយពលករ បានរស់នៅ និងធ្វើការក្រោមការភ័យខ្លាចការសម្លាប់ជាប់ជាប្រចាំ។

## ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់

២២៦- ពលករ និងកម្មាភិបាលតាមសហករណ៍នៅបណ្តាឃុំនានា នៅស្រុកត្រាំកក់ ត្រូវស្ថិតនៅក្រោមការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់។ ខ្មែរក្រហមមានគោលនយោបាយជាលក្ខណៈប្រព័ន្ធ ក្នុងការចាប់ខ្លួនខ្មាំងបដិវត្តដែលត្រូវបានចោទប្រកាន់ ដែលគេបានរកឃើញនៅតាមឃុំ។ មនុស្សដែលត្រូវបានចាប់ខ្លួននៅតាមសហករណ៍ដូចជា អតីតគ្រូបង្រៀន ទាហានរបបសាធារណរដ្ឋខ្មែរ នគរបាល និងសិស្ស និស្សិត ពលករដែលបានត្អូញត្អែរអំពីស្ថានភាពរស់នៅ ឬស្ថានភាពការងារ និងពលករដែលពុំចុះសម្រុងជាមួយរបបនេះ រួមទាំង"ប្រជាជនថ្មី"ជាច្រើនផងដែរ។ ការចាប់ខ្លួនបានកើតមាននៅពេលយប់ និងត្រូវបានធ្វើឡើង ដោយឈ្លបឃុំតាមបញ្ជារបស់ប្រធានឃុំ។ ជាធម្មតា ពលករត្រូវបានចាប់ខ្លួនជាក្រុម ដោយភ្ជង់នឹងកាំភ្លើងត្រូវបានគេចង និងបណ្តើរជាជួរចេញទៅ។ ក្នុងចំណោមមនុស្សដែលត្រូវបានចាប់ខ្លួន មានមនុស្សជាច្រើនបានបាត់ខ្លួន ឬត្រូវបានបញ្ជូនទៅ "រៀនសូត្រ" ហើយមិនដែលបានឃើញត្រឡប់មកវិញ។ មនុស្សជាច្រើនមកពីស្រុកត្រាំកក់ ត្រូវបានបញ្ជូន

ទៅកាន់មន្ទីរសន្តិសុខក្រាំងតាចាន់ ដើម្បីឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងប្រហារជីវិតជាលក្ខណៈប្រព័ន្ធ។

២២៧- ពលករទាំងឡាយណាដែលពុំត្រូវបានចាប់ខ្លួន ហើយបន្តស្ថិតនៅក្នុងស្រុកត្រាំកក់ ត្រូវបានចាប់ខ្លួន *តាមព្រឹត្តិន័យ* នៅតាមសហករណ៍របស់ពួកគេ ដោយហេតុថាពួកគេត្រូវបានដកហូតសិទ្ធិ និងសេរីភាព ក្នុងការចាកចេញពីសហករណ៍ និងដោយសារពួកគេត្រូវទទួលការអនុញ្ញាតឲ្យធ្វើដំណើរ។

## ស្រែអំបិល

### ទីតាំង និងប្រតិបត្តិការ

២២៨- ការដ្ឋានរបស់រដ្ឋឈ្មោះស្រែអំបិល ឬហៅថាស្រែអំបិលរដ្ឋ មានទីតាំងស្ថិតនៅក្បែរភូមិជុំក្រៀល ឃុំស្រែអំបិល ស្រុកកំពត តំបន់៣៥ ភូមិភាគនិរតី ក្នុងទីតាំងសំខាន់ទាំង៣គឺ កំពង់កណ្តាល ត្រើយកោះ និងសេះស។ ស្រែអំបិលនេះបានធ្វើប្រតិបត្តិការ ក្រោមការត្រួតពិនិត្យរបស់បក្សកុម្មុយនីស្តកម្ពុជាយ៉ាងហោចណាស់ពីឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

២២៩- នៅស្រែអំបិលកំពង់កណ្តាល មានឃ្លាំងផ្ទុកអំបិលមួយចំនួន ដែលទីនោះមានកន្លែងសម្រាប់ពលករស្នាក់នៅ ផ្ទះបាយនៅអគារមួយដាច់ដោយឡែក និងកន្លែងហូបដាច់ដោយឡែកមួយ។ ស្រែអំបិលកំពង់កណ្តាលមានផ្ទៃដីចំនួន១៥០០ហិកតា។ ទីតាំងស្រែអំបិលមួយទៀតឈ្មោះត្រើយកោះ មានអគារមួយចំនួនដែលគេបានយកធ្វើជាកន្លែងរស់នៅ និងឃ្លាំង។ ទីតាំងនេះស្ថិតនៅលើកោះមួយនៃដែនដីសណ្តរទន្លេកំពង់បាយ និងលាតសន្ធឹងលើផ្ទៃដីសរុប

ប្រមាណ៧៩៧ហិកតា។ នៅឯទីតាំងសេះស ការដ្ឋានស្រែអំបិលមានផ្ទៃដីប្រមាណ៣១៤ ហិកតា។ ជាសរុប ស្រែអំបិលគ្របដណ្តប់លើផ្ទៃដីជាង២៥០០ហិកតា។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើការដ្ឋាន

២៣០- ការប្រមូលអំបិលស្ថិតក្រោមការចាត់តាំងផ្ទាល់របស់មជ្ឈិមបក្ស ហើយពិសេស គឺក្រសួងឧស្សាហកម្ម(ឬគណៈកម្មាធិការឧស្សាហកម្ម) ដែលមានឈ្មោះ ចេង អន *ហៅ* អន ជាប្រធានរហូតដល់ថ្ងៃចាប់ខ្លួន នៅដើមខែវិច្ឆិកា ឆ្នាំ១៩៧៨។ ក្រសួងឧស្សាហកម្មស្ថិតក្រោមការគ្រប់គ្រង និងការចាត់តាំងរបស់ វន វ៉េត *ហៅ* វ៉ន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច។ មជ្ឈិមបក្សជាអ្នកទទួលបន្ទុកជ្រើសរើសកម្លាំង សម្រាប់ស្រែអំបិល និងដឹកជញ្ជូន និងចែកចាយអំបិលទៅតាមភូមិភាគ។ **ខៀវ សំផន** ទទួលបន្ទុកចែកចាយរបស់របរផ្សេងៗដែលផលិតបាន រួមទាំងអំបិល ទៅឱ្យអង្គភាពផ្សេងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបី ក្រសួងពាណិជ្ជកម្ម ពិសេសផ្នែកពាណិជ្ជកម្មក្រៅប្រទេស ជាអ្នកទទួលបន្ទុកនាំចេញអំបិល និងគ្រឿងឧបភោគបរិភោគផ្សេងៗក្តី។

២៣១- នៅថ្នាក់តំបន់ ឈ្មោះ កង ចាប *ហៅ* ចាន់ សំ *ហៅ* សែ គឺជាលេខាតំបន់៣៥ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពេលដែលគាត់បានទទួលតំណែងជាលេខាភូមិភាគឧត្តរថ្មី ហើយបន្ទាប់មក សំ ប៊ិត បានធ្វើជាលេខាតំបន់នោះ។ កង ចាប បានចុះត្រួតពិនិត្យស្រែអំបិល យ៉ាងហោចណាស់ម្តង។ តា ម៉ុក គឺជាលេខាភូមិភាគនិរតី ហើយបានចុះត្រួតពិនិត្យស្រែអំបិល យ៉ាង

ហោចណាស់ម្តង ហើយអាចច្រើនដង។ តួនាទីរបស់ភូមិភាគ គឺកំណត់ត្រឹមតែការប្រមូលអំបិលតែប៉ុណ្ណោះ។

## នៅក្នុងការដ្ឋាន

២៣២- ការដ្ឋានវាលស្រែអំបិលត្រូវបានបង្កើតឡើងតាមគោលការណ៍យោធា។ ពលករត្រូវបានបែងចែក ជាកងវរសេនាធំ កងវរសេនាតូច(៣០០នាក់) កងអនុសេនាធំ(១០០នាក់) កង ឬកងអនុសេនាតូច(៥០នាក់) និងក្រុម(១២-១៥នាក់)។ កម្មាភិបាលទាំងអស់សុទ្ធសឹងជាទាហាននារី។ [redacted] យាយ រេត និងយាយ សន គឺជាកម្មាភិបាលនៅកំពង់កណ្តាល ហើយបន្ទាប់ពីអ្នកទាំងពីរ ត្រូវបានចាប់ខ្លួន នៅឆ្នាំ១៩៧៧ [redacted] នៅត្រើយកោះ ឈ្មោះ វ៉េង គឺជាប្រធាន [redacted] ក្រោយមកឈ្មោះ វ៉េង បានជាប់ចោទពីបទក្បត់ និងត្រូវបានប្រហារជីវិត ហើយ[redacted] បានចូលកាន់តំណែងជំនួស។

## ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស

២៣៣- វាលស្រែអំបិល ស្ថិតក្រោមការត្រួតពិនិត្យតាមដានជាទៀងទាត់ ពីសំណាក់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា។ នួន ជា បានចុះមកត្រួតពិនិត្យវាលស្រែអំបិលកំពង់កណ្តាល ជាមួយប្រធានភូមិភាគបស្ចិមឈ្មោះ ជូ ជេត នៅឆ្នាំ១៩៧៧ និងបានកោះប្រជុំ ដើម្បីណែនាំ

ពលករឲ្យខិតខំធ្វើការដើម្បីអនាគតប្រទេសជាតិ។ វន វ៉េត ក្នុងតួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកឧស្សាហកម្ម ហ៊ូ នឹម និងហ៊ូ យន់ ក៏បានចុះត្រួតពិនិត្យការដ្ឋានស្រែអំបិលនៅត្រើយកោះដែរ។ ដួច **នួន ជា** ដែរ ប៉ុល ពត បានចូលរួមអង្គប្រជុំនៅស្រែអំបិល ក្នុងនោះគាត់បានណែនាំឲ្យពលករប្រឹងផលិតអំបិលឲ្យបានច្រើន និងបោះជំហានទៅមុខ។ បើទោះបី **អៀង ធីរិទ្ធ** ពុំត្រូវបានគេប្រទះឃើញថាបានចុះត្រួតពិនិត្យស្រែអំបិលនេះក្តី ក៏នៅឆ្នាំ១៩៧៨ ប្រជាជនភូមិភាគបូព៌ា ត្រូវបានបោសសម្អាតក្នុងទ្រង់ទ្រាយធំ ពីមន្ទីរពេទ្យនៅភ្នំពេញ និងរោងចក្រផលិតឱសថក្រោមការគ្រប់គ្រងរបស់គាត់ ហើយត្រូវបានបញ្ជូនទៅវាលស្រែអំបិល ដើម្បីលត់ដំ ចំណែកឯពលករនារីស្រែអំបិលដែលមិនចេះអក្សរជាច្រើន បានចូលមកជំនួសពួកគេនៅតាមអង្គភាពនានានៃក្រសួងសង្គមកិច្ចនៅភ្នំពេញ។

២៣៤- បរិមាណកំណត់ប្រចាំឆ្នាំសម្រាប់ការផលិតអំបិល គឺជាការសម្រេចរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។ បន្ថែមពីលើនេះ ព័ត៌មាននានាស្តីពីមាគ៌ាបក្ស ត្រូវបានណែនាំប្រាប់ពលករស្រែអំបិលទាំងអស់ ក្នុងអង្គប្រជុំរៀងរាល់១០ថ្ងៃម្តង នៅវត្តជុំក្រៀល។

## ការធ្វើពលកម្មដោយបង្ខំ

២៣៥- នៅស្រែអំបិល ពលករស្ទើរតែទាំងអស់ គឺជានារី។ ជាសរុប មានពលករចំនួនចន្លោះពី៥០០០នាក់ ដល់៨០០០នាក់។ គ្រាន់តែនៅទីតាំងកំពង់កណ្តាលតែមួយកន្លែង មានពលករចំនួនពី៣០០០នាក់ ដល់៥០០០នាក់ ហើយនៅស្រែអំបិលត្រើយកោះមានពលកររាប់ពាន់នាក់។ បើគិតអំពីទំហំដែលតូចជាងស្រែអំបិលផ្សេងៗ ស្រែអំបិលសេះស ទំនងជាមានពលករចំនួនតិចជាងនេះ។ ពីដើមដំបូង ពលករភាគច្រើនដែលត្រូវបានបញ្ជូន *ទាំងហ្វូង* ទៅកាន់ស្រែអំបិល

គឺជាប្រជាជនដែលខ្មែរក្រហមបានជម្លៀសចេញពីតំបន់នានាដូចជា កណ្តាល តាកែវ កំពង់ចាម និងកំពង់ស្ពឺ ដោយសារហេតុផលតែមួយគត់គឺថា ស្រែអំបិលត្រូវការកម្លាំងការងារ។ បើទោះបីជាយ៉ាងដូច្នេះក្តី ក្នុងអំឡុងពេលនៃការបោសសម្អាតនៅឆ្នាំ១៩៧៨ បុគ្គលិកភូមិភាគបូព៌ាចំនួនរាប់រយនាក់ដែលកំពុងធ្វើការនៅភ្នំពេញក្រោមឱវាទក្រសួងសង្គមកិច្ច ត្រូវបានបញ្ជូនទៅលត់ដំនៅស្រែអំបិល។

២៣៦- ខ្មែរក្រហមបានដាក់បញ្ចូលពលករទៅតាមអង្គភាពនារី ដែលមានគ្នាប្រមាណ៥០នាក់។ ពលករនារីនៅស្រែអំបិល ត្រូវបានខ្មែរក្រហមបង្ខំឱ្យជីកប្រឡាយ លើកទំនប់ កើបដី និងអាចម៍ដីតាមវាលស្រែ បង្ហាប់ផ្នែកដែលបានជីកហើយជាមួយនឹងប្រដាប់បង្ហាប់ដី ដែលគេហៅថាជើងដំរី អូសឧបករណ៍ម្យ៉ាងដូចរនាស់កាត់ស្រែអំបិល ឬកើប ឬរែកអំបិលចូល និងចេញពីឃ្លាំង ទៅដាក់រថយន្តដែលក្នុងអំបិលមួយបាវមានទម្ងន់៤០ទៅ៧០ គីឡូក្រាម។ ពលករបុរសមួយចំនួនតូចដែលបានធ្វើការងារនៅស្រែអំបិល(មានចំនួនប្រមាណ១០០នាក់ នៅកំពង់កណ្តាល) ភាគច្រើនគឺជាអ្នកបច្ចេកទេសបញ្ហាម៉ាស៊ីនទឹក និងគ្រប់គ្រងពលករនារីដែលជាអ្នកបាចទឹកបញ្ចូលស្រែអំបិល។ នៅរដូវវស្សា ពលករខ្លះក៏ត្រូវបានគេបញ្ជូនទៅកាន់ភ្នំកង្កែបនៅកំពតដើម្បីដាំបន្លែ ជីកប្រឡាយ កើបស្រូវ លើកភ្លឺ ឬរែកថ្ម លើកទំនប់ទប់ទឹកសមុទ្រ។

២៣៧- ជាធម្មតា ម៉ោងធ្វើការ គឺចាប់ពីម៉ោង៦ ឬ៧ព្រឹក រហូតដល់ពេលអាហារថ្ងៃត្រង់ម៉ោង១១ថ្ងៃ ឬថ្ងៃត្រង់ និងបន្តក្រោយពេលអាហារថ្ងៃត្រង់ រហូតដល់ម៉ោង៥ ឬ៦ល្ងាច ដែលជាពេលពលករបានទទួលរបបអាហារលើកទី២។ នៅពេលគេត្រូវផលិតអំបិលឱ្យគ្រប់តាមបរិមាណកំណត់ ក្នុងអំឡុងរដូវការងារមមាញឹក និងមុនពេលភ្លៀងខ្លាំង គេបន្តការងារម្តងទៀតក្រោយ

ពេលអាហារពេលល្ងាច ដែលជាពេលពលករត្រូវកើបដី និងច្រកអំបិល រហូតដល់កណ្តាលអធាត្រ ឬព្រឹកព្រលឹម។ ជាទូទៅ ការផលិតអំបិលមានរយៈពេលពីខែវិច្ឆិកា ដល់ខែមេសា ហើយពេលមមាញឹកបំផុត គឺពីខែមករា ដល់ខែមីនា។ បរិមាណកំណត់នៃការផលិតអំបិលបានកើនឡើងជារៀងរាល់ឆ្នាំ។ ពលករណាដែលពុំអាចបំពេញការងារតាមការចាត់តាំង ត្រូវទទួលរងការដាក់ពិន័យ។

## ស្ថានភាពអមនុស្សធម៌

២៣៨- ពលករគ្មានភាពឯកជនឡើយ ដោយហេតុថាពួកគេត្រូវដេក និងបរិភោគ ក្នុងចំណោមក្រុមមនុស្សធំៗ ហើយមានមនុស្សច្រើនកកកុញស្នាក់នៅក្នុងអគារ។ សេរីភាពនៃការធ្វើដំណើររបស់កម្មករពីកន្លែងរស់នៅត្រូវបានដាក់កំហិត ដោយសារមានការចាត់តាំងប្តូរវេនយាមនៅពេលយប់ ដើម្បីឱ្យឆ្មាំអាចឃ្លាំមើលពលករនៅពេលពួកគេដេក។ ឆ្មាំប្រដាប់ដោយអាវុធ ក៏បានត្រួតពិនិត្យការដ្ឋាននៅពេលថ្ងៃផងដែរ។

២៣៩- ពលករត្រូវបានឃុំឃាំង *តាមព្រឹត្តិន័យ* នៅស្រែអំបិល នៅពេលដែលពួកគេស្ថិតក្រោមការឃាមកាមទាំងយប់ទាំងថ្ងៃ និងត្រូវបានហាមមិនឱ្យចាកចេញទៅណាពីស្រែអំបិល ដោយគ្មានការអនុញ្ញាត។ គេកម្រអនុញ្ញាតឱ្យនរណាម្នាក់ចាកចេញពីស្រែអំបិលណាស់ ហើយពលករមួយចំនួន ភ័យខ្លាចក្នុងការស្នើសុំការអនុញ្ញាត នៅពេលកម្មាភិបាលសង្ស័យថាពួកគេនឹកផ្ទះ ហើយពេលនោះពួកគេនឹងរងការដាក់ពិន័យ។ ពួកគេត្រូវបានព្រមានអំពីការប៉ុនប៉ងលួចរត់ ហើយមនុស្សលួចរត់ដែលគេចាប់ខ្លួនបាន នឹងត្រូវទទួលពិន័យ។ ការរត់គេចខ្លួនពីវាលស្រែអំបិលមានការលំបាក ដោយសារស្រែអំបិលត្រើយកោះស្ថិតនៅលើកោះ ហើយមានឆ្មាំយាមនៅផ្លូវដីនៅ

កំពង់កណ្តាល ដោយសល់តែផ្លូវទឹកមួយប៉ុណ្ណោះ សម្រាប់រត់គេចខ្លួន។ ដូច្នេះទើបបណ្តាលឱ្យពលករធ្វើការងារក្រោមការបង្ខិតបង្ខំមួយចំនួន បានលង់ទឹកស្លាប់ក្នុងអំឡុងពេលប៉ុនប៉ងលួចរត់។

២៤០- អាហារដែលគេបានផ្តល់ទៅឱ្យពលករពុំគ្រប់គ្រាន់ឡើយ ទាំងបរិមាណ និងគុណភាព។ ពលករបានទទួលអាហារចំនួន២ពេលក្នុងមួយថ្ងៃ ជាទូទៅ គឺនៅពេលថ្ងៃត្រង់ និងពេលល្ងាច ឬយប់អាស្រ័យទៅតាមពេលចប់ការងារ។ អាហារមួយលើកៗ មានបបររាវបន្តិចបន្តួច ហូបពុំឆ្អែត បបរខ្លះ ឬបាយលាយបន្លែ ឬទឹកសម្លផ្សំឡើងពីទឹកត្រកួន និងព្រលឹត។ គេយកអង្ករចំនួនតែ៨កំប៉ុងប៉ុណ្ណោះ ទៅដាំបបរសម្រាប់មនុស្សមួយកងគ្នា៥០នាក់ ហើយពលករពុំត្រូវបានគេឱ្យបបរបន្ថែមឡើយ ក្រៅពីរបបដែលគេចែកឱ្យមួយមុខ។ មួយសប្តាហ៍ម្តង គេចែកបង្អែមឱ្យពលករ ហើយមួយខែម្តងគេឱ្យក្តាម ឬត្រី។ ដើម្បីគេចផុតពីស្លាប់ ពលករខ្លះត្រូវដើរស្វែងរកអាហារ ឬលួចត្រីអាំងពីរោងបាយ ប៉ុន្តែប្រសិនបើគេចាប់បាន ពួកគេនឹងត្រូវរងការបង្អត់អាហារជាច្រើនថ្ងៃ។ របបអាហារត្រូវបានកាត់បន្ថយច្រើន ឬទាំងស្រុង នៅពេលពលករធ្លាក់ខ្លួនឈឺ ដោយហេតុថាពួកគេគ្មានលទ្ធភាពធ្វើការងារ។ អាហារភាគច្រើនត្រូវបានប្រើប្រាស់ ជាយន្តការសម្រាប់អនុវត្តស្ថានភាពការងារនៅស្រែអំបិល ដោយហេតុថា មានតែមនុស្សដែលធ្វើការប៉ុណ្ណោះ ដែលទទួលបានរបបអាហារ។

២៤១- ពលករត្រូវបានបង្ខំឱ្យរស់នៅក្នុងស្ថានភាពខ្វះអនាម័យគ្រប់គ្រាន់។ ពលករត្រូវបានខ្មែរក្រហមផ្តល់ឱ្យសម្លៀកបំពាក់ម្នាក់២កំប្លេ ក្នុងមួយឆ្នាំ ដែលជារឿយៗ សម្លៀកបំពាក់ទាំងនោះក៏បានដាច់រហែករយ៉េ។ ពលករត្រូវដេរ ឬបោកសម្លៀកបំពាក់ដោយខ្លួនឯងក្នុងមួយសប្តាហ៍ម្តង។

ពលករខ្លះអាចងូតទឹកស្អាតរៀងរាល់៣ថ្ងៃ ទៅ៧ថ្ងៃម្តង ចំណែកខ្លះទៀតបានត្រឹមតែងូតទឹកអំបិលប៉ុណ្ណោះ។

២៤២- ដោយសារ ការផ្គត់ផ្គង់អាហារពុំបានគ្រប់គ្រាន់ ការងារហួសកម្រិត អនាម័យ និងបទដ្ឋានអនាម័យយ៉ាប់យ៉ឺន និងការថែទាំវេជ្ជសាស្ត្រពុំបានដិតដល់ ពលករភាគច្រើនមានសុខភាពទ្រុឌទ្រោម។ ជំងឺបានរាតត្បាតនៅគ្រប់ទីកន្លែង ហើយពលករបានកើតជំងឺគ្រុនចាញ់ គ្រុនក្តៅ និងរាគមួល។ ដោយសារ ការធ្វើការហួសកម្រិត និងការងារយ៉ាប់យ៉ឺន ដូចជា ការសែងបាវអំបិលធ្ងន់ៗជាច្រើនម៉ោង និងការចំណាយពេលយូរត្រាំក្នុងទឹកអំបិល ពលករជាច្រើនបានកើតជំងឺឈឺសន្លាក់ និងហើមក្បាលជង្គង់និងឈឺជើង។ បន្ថែមពីលើជំងឺដង្កាត់ទាំងអស់នេះនៅមានពលករជាច្រើននាក់ទៀត ធ្លាក់ខ្លួនស្គមស្គាំងស្បែកដណ្តប់ឆ្អឹង និងស្លេកស្លាំង ហើយខ្លះទៀតបាក់កម្លាំង និងខ្វះជីវជាតិដួលសន្លប់ពេលកំពុងធ្វើការ។ អ្នកណាដែលរបួសមិនអាចធ្វើការបានពុំត្រូវបានគេផ្តល់អាហារឲ្យឡើយ។ ពលករដែលបានធ្លាក់ខ្លួនឈឺ ត្រូវបានកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ជៀលត្មេះថាខ្ជិល និងចោទថាធ្វើពុតឈឺ។

២៤៣- សាលារៀនបឋមសិក្សាមួយដែលមានចំនួន១០បន្ទប់ ស្ថិតនៅវត្តជុំក្រៀល សព្វថ្ងៃក្បែរការដ្ឋានត្រូវបានខ្មែរក្រហមយកធ្វើជាមន្ទីរពេទ្យ។ បើទោះបីជាមន្ទីរពេទ្យជុំក្រៀលស្ថិតនៅក្បែរការដ្ឋានក្តី ក៏មានតែអ្នកជំងឺធ្ងន់ប៉ុណ្ណោះដែលគេបញ្ជូនមក ហើយពលករណាដែលគេបានចាត់ទុកថា "ឈឺមួយផ្នែក" ត្រូវបានបង្ខំឲ្យនៅបន្តធ្វើការ។ អ្នកជំងឺពុំត្រូវបានគេនាំយកទៅមន្ទីរពេទ្យឡើយទាល់តែរហូតដល់ពួកគេដើរលែងរួច ទើបត្រូវសែងអ្នកជំងឺទៅមន្ទីរពេទ្យ។ ដូច្នេះទើបបានជាពលករជាច្រើនបានស្លាប់នៅការដ្ឋាន មុនពេលទទួលបានការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រ

ណាមួយ។ នៅឯមន្ទីរពេទ្យស្រែអំបិល និងជុំក្រៀល ថ្នាំសង្កូវមានការខ្វះខាត ឬគ្មានតែម្តង ឬជាថ្នាំក្លែងក្លាយ ក្នុងនោះមានថ្នាំមួយប្រភេទឈ្មោះ ថ្នាំ"អាចម៍ទន្សាយ"។ បុគ្គលិកវេជ្ជសាស្ត្រពុំបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ហើយមានចំនួនពុំគ្រប់គ្រាន់សម្រាប់ព្យាបាល អ្នកជំងឺនៅមន្ទីរពេទ្យ និងនៅទីតាំងវាលស្រែអំបិលឡើយ។ ដូច្នេះទើបបានជាមានមនុស្សជាច្រើនបានស្លាប់នៅមន្ទីរពេទ្យជុំក្រៀល ឬនៅស្រែអំបិល បន្ទាប់ពីពួកគេបានចាកចេញពីមន្ទីរពេទ្យ។

២៨៤- ពលករត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការរស់នៅ និងទណ្ឌកម្មបែបអមនុស្សធម៌។ ពួកគេត្រូវបានបង្ខំឱ្យសរសេរប្រវត្តិរូប ហើយក្នុងអំឡុងពេលនៃអង្គប្រជុំជាក្រុម ត្រូវបានទិតៀនថាជាមនុស្សខ្ជិល និងបានណែនាំឱ្យពួកគេខំប្រឹងធ្វើការ និងបានប្រាប់ពួកគេកុំឱ្យនឹកសមាជិកគ្រួសាររបស់ពួកគេ។ នៅក្នុងករណីមានកំហុសធ្ងន់ ពលករត្រូវបានរងការវាយដំ បង្អត់អាហារ និងត្រូវបានបង្ខំជាការព្រមានដល់ពលករឯទៀតកុំឱ្យធ្វើតាមគំរូអាក្រក់របស់ពួកគេ។ ពលករពុំហ៊ានត្អូញត្អែរ និងខ្លាចក្រែងគេចាប់ខ្លួន។

២៨៥- ដោយសារមកពីស្ថានភាពអមនុស្សធម៌ដែលបានដាក់មកលើស្រែអំបិល ទើបបណ្តាលឱ្យកម្មករយ៉ាងហោចណាស់ចំនួន២០នាក់ បានរត់គេចខ្លួន ឬព្យាយាមរត់គេចខ្លួន ហើយពលករ៧នាក់បានលង់ទឹកសមុទ្រស្លាប់។ បន្ថែមពីលើនេះ ស្ថានភាពមានលក្ខណៈពិបាកទ្រាំលែងបាន រហូតដល់ពួកគេមួយចំនួនបានចងក ឬផឹកថ្នាំពុល ដើម្បីធ្វើអត្តឃាត។

## ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់

២៨៦- ពលករ និងកម្មាភិបាលនៅស្រែអំបិលបានស្ថិតនៅក្រោមការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់។ មនុស្សដែលត្រូវបានចាប់ខ្លួន មានដូច ជាពលករដែលមានសមាជិកគ្រួសារពាក់ព័ន្ធនឹង

របបសាធារណរដ្ឋខ្មែរ ពលករដែលសម្តែងការជំទាស់នឹងគោលនយោបាយបក្សកុម្មុយនីស្ត កម្ពុជា ពលករដែលជាប់ចោទពីបទខុសសីលធម៌ ឬជាខ្មាំង និងពលករដែលគ្រាន់តែបានឈរ នៅខាងក្រៅនៅពេលយប់។ ជាធម្មតា ការចាប់ខ្លួនពលករ បានកើតមាននៅពេលយប់។ កម្មករ ត្រូវបានពួកវាឲ្យឈរតម្រង់ជួរ ដាក់ខ្នោះដៃជើង និងនាំយកទៅ។ ពលករក៏ត្រូវបានបញ្ជូនទៅ កាន់វាលស្រែអំបិលត្រើយកោះផងដែរ ដែលជាការពិន័យសម្រាប់ទង្វើដែលគេបានចាត់ទុកថា ជាការខ្ជិលច្រអូស ឬការប៉ុនប៉ងលួចរត់។

## ការសម្លាប់ដោយខុសច្បាប់

២៤៧- បើទោះបីជានៅស្រែអំបិល ហាក់ដូចជាគ្មានការប្រហារជីវិតពលករជាក់ស្តែងក្តី ក៏បុគ្គលិកខ្លះ បានបាត់ខ្លួនពីការដ្ឋាន និងត្រូវបានគេជឿថាត្រូវបានគេប្រហារជីវិត។ ពិសេស ពលករ២នាក់ ដែលគេបានជឿថាត្រូវបានគេបញ្ជូនទៅសម្លាប់នៅឯព្រៃកោងកាង។ អ្នកលួចរត់ម្នាក់ដែលខ្មែរ ក្រហមចាប់ខ្លួនបាន ត្រូវបានបញ្ជូនទៅកន្លែងដាក់អ្នកទោសមួយនៅឯភ្នំសន្លុង។ កម្មាភិបាលបក្ស កុម្មុយនីស្តកម្ពុជា និងពលករមកពីស្រែអំបិលរដ្ឋ យ៉ាងហោចណាស់ចំនួន២៤នាក់ ត្រូវបានឃុំ ឃាំង និងប្រហារជីវិតនៅឯមន្ទីរស-២១។ ក្នុងចំណោមមនុស្សដែលត្រូវបានចាប់ខ្លួន និង ពលករដែលជាប់ចោទពីបទប៉ុនប៉ងលួចរត់ត្រូវគេយកទៅប្រហារជិវិត ដោយកំហុសឆ្គងការងារ តូចតាច មនុស្សដែលគេចាត់ទុកថាជាជនក្បត់ និងអំពើដែលបានចាត់ទុកថាជាអំពើខុសសីល ធម៌។

## ទំនប់១ មករា

## ទីតាំង និងប្រតិបត្តិការ

២៤៨- ទំនប់១ មករា ស្ថិតនៅក្នុងស្រុក២ នៃខេត្តកំពង់ធំ គឺស្រុកសន្ទុក (ឃុំបឹងល្វា និងឃុំកំពង់ថ្ម) ដែលជាផ្នែកមួយនៃតំបន់៤៣ ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) និងស្រុកបារាយណ៍ (ឃុំបល្ល័ង្ក) ដែលជាផ្នែកមួយនៃតំបន់៤២ ភូមិភាគកណ្តាល។ ការដ្ឋាននេះបានប្រតិបត្តិការក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់តាំងពីពេលនៃការសាងសង់នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ រហូតដល់ពេលបញ្ចប់នៃការសាងសង់ នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ នៅក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ ទំនប់១មករាត្រូវបានស្តារ និងកែលម្អឡើងវិញ និងមានអត្ថិភាពមកទល់សព្វថ្ងៃ ហើយមានឈ្មោះថាគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ និងធារាសាស្ត្រស្ទឹងជីនិត។

២៤៩- ទំនប់នេះបង្កើតឡើងដោយដីច្រាំងទន្លេ ដែលមានចម្ងាយប្រមាណ៦៦គីឡូម៉ែត្រ ខ្នងមានទទឹង៧ម៉ែត្រ បាតមានទទឹង២០ម៉ែត្រ និងមានកំពស់មធ្យមប្រវែងពី២ម៉ែត្រ ទៅ៣ម៉ែត្រ ដែលត្រូវបានសង់ឡើង ដើម្បីទប់ទឹកស្ទឹងជីនិត។ ជញ្ជាំងធំនៃទំនប់ ១ មករា នេះ មានប្រវែង២គីឡូម៉ែត្រ។ ប្រឡាយមួយដែលមានទទឹងប្រវែង២០ម៉ែត្រ មានបណ្តោយចម្ងាយ៣៣គីឡូម៉ែត្រ នៅស្រុកសន្ទុក។ គម្រោងពាក់ព័ន្ធមួយ (ដែលជាផ្នែកមួយនៃប្រព័ន្ធធារាសាស្ត្រនេះ) គឺទំនប់៦ មករា និងស្ពាន៦ មករា។

២៥០- មន្ទីរសន្តិសុខស្រុកបារាយស្ថិតនៅក្បែរទំនប់ ១ មករា នៅឯបារាយណ៍ជាន់ដែក ភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ បន្ទាប់ពីពេលចាប់ផ្តើមការសាងសង់ទំនប់ ១ មករា នេះ

ចំនួនប្រជាជនជាប់គុកនៅវត្តបារាយណ៍ជាន់ដែកនេះ មានការកើនឡើង។ ក្នុងមន្ទីរសន្តិសុខនេះ មានសាលាឆាន់ធំមួយ និងអគារដាច់ដោយឡែកមួយនៅក្នុងវត្ត ដែលកន្លែងទាំង២នេះ ត្រូវបានខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំងអ្នកទោស ហើយអគារកំពស់២ជាន់មួយទៀត ត្រូវបានខ្មែរក្រហមយកធ្វើជាកន្លែងសួរចម្លើយ។

## របនាសម្ពន្ធគ្រប់គ្រង

## ការគ្រប់គ្រងលើការដ្ឋាន

២៥១- លេខាភូមិភាគកណ្តាលឈ្មោះ កែ ពក ជាអ្នកទទួលខុសត្រូវរួមនៅទំនប់ ១ មករា នេះ។ គាត់បានធ្វើការនៅមន្ទីរមួយស្ថិតនៅចម្ងាយប្រមាណ៦ ទៅ៧គីឡូម៉ែត្រប៉ុណ្ណោះពីទំនប់នេះ ហើយតែងបានចុះពិនិត្យទីកន្លែងនេះជាញឹកញយ។ ប្រធានតំបន់ទាំង៣ នៅភូមិភាគកណ្តាល (តំបន់៤១ ៤២ និង៤៣) ក៏ជាអ្នកដែលបានមានតួនាទីជាសមាជិកគណៈភូមិភាគផង ហើយក៏ជាអ្នកបានផ្តល់ពលករពីតំបន់របស់ខ្លួន ហើយប្រសិនបើពុំបានបញ្ជូនពលករទៅទីនោះ ក៏ពួកគេបានចូលរួមក្នុងគម្រោងនេះទៅតាមកម្រិតខុសៗគ្នា។ ឈ្មោះ អឿន ដែលត្រូវជាបង ឬប្អូនថ្លៃរបស់ កែ ពក គឺជាលេខាតំបន់៤២ និងជាមនុស្សទី២ ដែលទទួលបន្ទុកការងារនៅទំនប់នេះបន្ទាប់ពីឈ្មោះ ពក។ [redacted] បានក្លាយខ្លួនជាលេខាតំបន់៤២ បន្ទាប់ពីការបោសសម្អាតទ្រង់ទ្រាយធំមួយ នៅភូមិភាគកណ្តាលក្រោមស្នាដៃរបស់កម្មាភិបាលភូមិភាគនិរតី ដែលបានផ្តើមឡើងនៅខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយដែលក្នុងនោះអតីតលេខាតំបន់ឈ្មោះ ចាន់ ម៉ុន *ហៅ* តុល ត្រូវបានចាប់ខ្លួន បញ្ជូនទៅមន្ទីរស-២១។ ស្របពេលជាមួយគ្នានោះ [redacted] បានចូលជំនួសតំណែងរបស់មនុស្ស២នាក់ ទី១៖ជំនួសកន្លែងរបស់ឈ្មោះ ជុន ឈុំ *ហៅ* តាំង

ក្នុងឋានៈជាលេខាតំបន់៤១ និងទី២ៈជំនួសកន្លែងរបស់ ជ ឆាន *ហៅ* ស្រេង ក្នុងឋានៈជាអនុលេខាភូមិភាគ។ គាំ ចាន់ បានបន្តធ្វើជាលេខាតំបន់៤៣ រហូតដល់ពេលចាប់ខ្លួន នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយតួនាទីជាលេខាតំបន់៤៣ ត្រូវបាន [redacted] ចូលជំនួស។

២៥២- ឈ្មោះ ចាន់ ស៊ន បានធ្វើជាលេខាស្រុកសន្ទុករហូតដល់ថ្ងៃចាប់ខ្លួននៅថ្ងៃទី១៦ ខែសីហា ឆ្នាំ ១៩៧៧។ លេខាស្រុកបារាយណ៍ដែលគេស្គាល់កាលអំឡុងពេលនៃការសាងសង់ទំនប់ ១ មករា មានឈ្មោះ [redacted] និងឈ្មោះ [redacted] វត្តបារាយណ៍ជាន់ដែក គឺជាមន្ទីរសន្តិសុខស្រុកមួយក្រោមការត្រួតត្រារបស់លេខាស្រុកបារាយណ៍ ដែលបានចុះពិនិត្យគុកនេះ យ៉ាងហោចណាស់ម្តងក្នុងមួយខែ។ ប្រធានគុកវត្តបារាយណ៍ជាន់ដែក តាមលំដាប់លំដោយមានដូចជា [redacted] បន្ទាប់ពីមានការបោសសម្អាតនៅភូមិភាគកណ្តាល កម្មាភិបាលភូមិភាគនិរតី ក្រោមការដឹកនាំរបស់ឈ្មោះ [redacted] បានកាន់កាប់មន្ទីរសន្តិសុខនេះ។

## រចនាសម្ព័ន្ធនៅក្នុងការដ្ឋាន

២៥៣- ប្រធានការដ្ឋានទំនប់១មករា ដំបូង ឈ្មោះ សោ កម្មាភិបាលមកពីក្រសួងសាធារណការ។ [redacted] ថ្នាក់ដឹកនាំការដ្ឋាននេះមួយចំនួន ត្រូវបានបញ្ជូនទៅកាន់សាលាបច្ចេកទេសឬស្សីកែវភ្នំពេញក្នុងឆ្នាំ១៩៧៦ ដើម្បីសិក្សាអំពីធារាសាស្ត្រ និងវារីអគ្គិសនី មុនពេលនៃការចាប់ផ្តើមសាងសង់ទំនប់។ [redacted]

[redacted]។

## ការប្រាស្រ័យទាក់ទងជាមួយនឹងមជ្ឈិមបក្ស

២៥៤- ផែនការសម្រាប់ទំនប់១មករា គឺមជ្ឈិមបក្សជាអ្នកដាក់ចេញ។ ផែនការទាំងនោះ មានបញ្ជាក់ពី "ប្រវែង បណ្ដោយ ជម្រៅ និងកំពស់របស់ទំនប់" និងកំណត់ការសាងសង់ទំនប់ដែលមានប្រវែង៦០គីឡូម៉ែត្រនោះឱ្យហើយ ក្នុងរយៈពេលមួយឆ្នាំ។ ការសាងសង់ទំនប់១មករា គឺជាផ្នែកមួយនៃផែនការសេដ្ឋកិច្ចរបស់ ប.ក.ក ដើម្បីបង្កើនទិន្នផលកសិកម្មទូទាំងប្រទេស។ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក ភាគច្រើន បានចុះទៅត្រួតពិនិត្យការដ្ឋានទំនប់១មករា រួមមាន ប៉ុល ពត **នួន ជា អៀង សារី អៀង ធីរិទ្ធ ខៀវ សំផន** សុន សេន និង តា ម៉ុក។ លេខាភូមិភាគ កែ ពក បានប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស តាមរយៈទូរលេខជាទៀងទាត់ ទៅតាមពេលវេលាដែលបានកំណត់ទុក។

២៥៥- នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ ឧបនាយករដ្ឋមន្ត្រីប្រទេសចិនឈ្មោះ ចិន យុងគើយ (Chen Yung-Kuei) បានចុះមកត្រួតពិនិត្យទំនប់១មករា ដោយរួមដំណើរជាមួយ ប៉ុល ពត វន វ៉េត កែ ពក ជាលេខាភូមិភាគកណ្ដាល និង [redacted]។ នាឱកាសនោះ កែ ពក បានធ្វើការកត់សម្គាល់ថា "លោកសង្ឃធ្លាប់តែមានសង្ឃដីកាថាមានតែព្រះទេដែលអាចធ្វើទំនប់កាត់ស្ទឹងជីនិតបាន" ដោយ ប៉ុល ពត បានបន្ថែមថា "ប្រជាជនខ្លួនឯង" គឺជា"ព្រះជាម្ចាស់"។

## ការធ្វើពលកម្មដោយបង្ខំ

២៥៦- ការសាងសង់ទំនប់១មករាត្រូវបានបញ្ចប់ ដោយពឹងផ្អែកលើកម្លាំងពលកម្មមនុស្សសុទ្ធសាធ។ គេបានប៉ាន់ស្មានថា មានប្រជាជនក្នុងចំនួនលើសពី២០០០០នាក់ ដែលត្រូវ ប.ក.ក ប្រើឱ្យសាងសង់ទំនប់។ គណៈកម្មការនៃតំបន់៤១ តំបន់៤២ និងតំបន់៤៣ ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់នូវកម្លាំងពលកម្ម និងប្រភពពលករដែលមកពីបណ្តាស្រុកស្ថិតនៅក្នុងតំបន់នីមួយៗ។ សម្រាប់តំបន់៤២ និងតំបន់៤៣ ត្រូវទទួលខុសត្រូវក្នុងការផ្តល់ពលករចំនួន១០០០០នាក់រៀងៗខ្លួន រីឯតំបន់៤១ ត្រូវផ្តល់កម្លាំងពលករបន្ថែមដែលមានចំនួន១០០០នាក់។ ពលករត្រូវបានគេបែងចែករៀបចំជាកងចល័ត ដែលមានសមាជិករហូតដល់៥០០នាក់។ នៅក្នុងកងចល័តទាំងនោះ មានក្រុមតូចៗជាច្រើនទៀត ដែលមានមនុស្សចំនួនពី៣០ ទៅ៥០នាក់ ហើយនៅក្នុងក្រុមតូចៗទាំងនោះ ពលករត្រូវធ្វើការជាក្រុមដែលមាន សមាជិកចំនួន៣នាក់ ដោយម្នាក់ជាអ្នកកាប់ដី និងពីរនាក់ផ្សេងទៀត ជាអ្នកសែងដី។ ភាគច្រើនពលករ ត្រូវគេបង្ខំឱ្យជីកប្រឡាយ និងអាងស្តុកទឹក។

២៥៧- ជាធម្មតា ម៉ោងពេលធ្វើការ គឺចាប់ផ្តើមពីម៉ោង៣ភ្លឺ បន្តរហូតដល់ម៉ោង៥ ឬ៦ល្ងាច ដោយពលករមានពេលសម្រាកក្នុងរយៈពេលមួយខ្លីប៉ុណ្ណោះ សម្រាប់អាហារថ្ងៃត្រង់។ ប្រជាជនជាច្រើន ត្រូវបន្តធ្វើការនៅពេលយប់ ពេលខ្លះរហូតដល់ម៉ោង១០យប់ ឬពាក់កណ្តាលអធ្រាត្រក៏មាន។ ពលករបានទទួលបរិមាណការងារចាត់តាំងក្នុងកម្រិតខ្ពស់ ដោយតម្រូវឱ្យជីក និងសែងដីដែលមានចំនួនពី១ទៅ៣ម៉ែត្រគូបជារៀងរាល់ថ្ងៃ។ សាក្សីមួយរូបបានរំឮកពីបរិមាណ

ចាត់តាំងក្នុងចំនួន៧ម៉ែត្រគូបក្នុងមួយថ្ងៃ។ មានប្រជាជនតិចណាស់ដែលអាចសម្រេចបានតាមគោលការណ៍កៀបសង្កត់បែបនេះ។

## ស្ថានភាពអមនុស្សធម៌

២៥៨- ពលករដែលធ្វើការនៅការដ្ឋាន ត្រូវគេឱ្យស្នាក់នៅក្នុងអគារឈើវែងមួយ ដោយគ្មានមុង ភួយ ឬកន្ទេល។ កន្លែងស្នាក់នៅសម្រាប់បុរស និងនារី ត្រូវគេដាក់ដោយឡែក (រួមទាំងប្ដីប្រពន្ធរៀបការរួចផងដែរ) ហើយពលករត្រូវបានគេអនុញ្ញាតឱ្យប្រាស្រ័យទាក់ទង និងសន្ទនាគ្នាក្នុងកម្រិតតិចតួចប៉ុណ្ណោះ។ ពលករនៅទំនប់១មករាជាច្រើននាក់ ត្រូវគេបង្ខំឱ្យរៀបការក្នុងពិធីរៀបការរួម។ ម្ហូបអាហារដែលផ្ដល់ឱ្យពលករ មិនគ្រប់គ្រាន់ទេ។ ជាទូទៅ របបអាហាររួមមាន បបររាវៗ ឬសម្លមានតែទឹក ដែលត្រូវគេផ្ដល់ឱ្យពីរដងក្នុងមួយថ្ងៃ។ [redacted]។

មនុស្សជាច្រើនបានធ្លាក់ខ្លួនឈឺ ហើយស្លាប់ដោយសារការអត់ឃ្លាន ជំងឺ ឬបាក់កម្លាំង។

២៥៩- ពលករត្រូវបានគេបង្ខំឱ្យរស់នៅជាមួយនឹងស្ថានភាពគួរឱ្យខ្ពើមរអើម ដែលគ្មានបទដ្ឋានអនាម័យគ្រប់គ្រាន់។ ការដ្ឋានទំនប់១មករា ពោរពេញទៅដោយសត្វល្អិត គ្មានបង្គន់អនាម័យប្រើប្រាស់ឱ្យបានត្រឹមត្រូវ ព្រមទាំងស្ថិតក្នុងស្ថានភាពគ្មានអនាម័យទាល់តែសោះ ជាពិសេសសម្រាប់ស្ត្រី។ សាក្សីម្នាក់បានរៀបរាប់តំបន់នោះជាតំបន់ដែល "មានសត្វរុយរោមខ្មៅងងឹត"។ មនុស្សភាគច្រើនត្រូវធ្វើការនៅក្នុង"សម្លៀកបំពាក់រហែករយ៉េ" ហើយសម្លៀកបំពាក់ថ្មីមួយឈុត ត្រូវគេផ្ដល់ឱ្យតែម្ដងប៉ុណ្ណោះ ក្នុងមួយឆ្នាំ។ ដោយសារគ្មានការផ្គត់ផ្គង់អាហារគ្រប់គ្រាន់ ធ្វើការហួសកម្លាំង និងគ្មានអនាម័យគ្រប់គ្រាន់ ពលករជាច្រើនត្រូវស្ថិតក្នុងស្ថានភាព

សុខភាពទន់ខ្សោយ និងធ្លាក់ខ្លួនឈឺ ដោយសារក្តៅខ្លួន អាសន្នរោគ ឬរោគរាគមូលជាដើម។ ពលករដែលឈឺមិនបានទទួលការព្យាបាល ឬថែទាំតាមបែបវេជ្ជសាស្ត្រគ្រប់គ្រាន់ទេ រួមទាំងការខ្វះខាតថ្នាំសង្កូវ ហើយអ្នកជំងឺទាំងនោះត្រូវគ្រប់គ្រងដោយយុវជន ដែលគ្មានការបណ្តុះបណ្តាលវេជ្ជសាស្ត្រត្រឹមត្រូវឡើយ។

២៦០- បរិយាកាសភ័យខ្លាច បានកើតមាននៅការដ្ឋាន ព្រោះពលករអាចនឹងត្រូវគេដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិបទល្មើសផ្សេងៗជាច្រើន។ នៅពេលដែលត្រូវគេបញ្ជូនទៅដល់ការដ្ឋាន គេមិនអនុញ្ញាតឲ្យពលករចាកចេញទេ ហើយពលករត្រូវគេដាក់ទណ្ឌកម្ម ចំពោះការផ្លាស់ទីដែលមិនបានទទួលការអនុញ្ញាត។ ពលករក៏ត្រូវគេដាក់ទណ្ឌកម្មផងដែរ ប្រសិនបើគេមិនអាចបំពេញតាមបរិមាណការងារបាននោះ។ ការដាក់ទណ្ឌកម្មដែលអាចកើតឡើង រួមមានការចាត់តាំងឲ្យធ្វើការច្រើន(ភាគច្រើនត្រូវធ្វើនៅពេលយប់) ការឃុំឃាំងនៅក្នុងទ្រុងអស់រយៈពេលជាច្រើនថ្ងៃ និងការវាយនឹងរំពាត់។

## ការឃុំឃាំង និងការចាប់ខ្លួនដោយខុសច្បាប់

២៦១- ពលករជាច្រើននៅការដ្ឋានទំនប់១មករា ត្រូវគេចាប់ខ្លួន និងឃុំឃាំង។ ពលករទាំងឡាយដែលត្រូវគេចាប់ខ្លួន រួមទាំងពលករដែលត្រូវគេដាក់ទណ្ឌកម្មនៅការដ្ឋាន ហើយមិនបានបង្ហាញពីការ"កែប្រែខ្លួន"ឲ្យបានគ្រប់គ្រាន់ ពលករដែលត្រូវគេចោទប្រកាន់ថាជាខ្សែបណ្តាញរបស់សេអ៊ីអា ប្រជាជនថ្មី និងជាជនជាតិចាម។ នៅក្នុងអង្គប្រជុំមួយ ដែលមានការចូលរួមពីប្រធានកងចល័ត មេដឹកនាំថ្នាក់ស្រុកជាច្រើនបានពិភាក្សាពីផែនការសាងសង់របស់អង្គការ [redacted]

[redacted] ប្រសិនបើពលករណាម្នាក់ ខកខានមិនបានធ្វើតាមបញ្ជា និងមិនប្រតិបត្តិទៅតាមផែនការការងារទេនោះ នឹងត្រូវចាប់ខ្លួន ហើយសម្លាប់ចោល។ អ្នកយាមដើរល្បាតការដ្ឋានទំនប់ទឹក រីឯពលករត្រូវរស់នៅជាមួយនឹងការគម្រាមកំហែងជាប្រចាំពីការចាប់ខ្លួន និងការសម្លាប់។ ប្រជាជនត្រូវគេបញ្ជាឱ្យស៊ើបការណ៍ពីអ្នកដែលរួមការងារជាមួយគ្នា។ ជនទាំងឡាយដែលត្រូវគេចាប់ខ្លួន ត្រូវគេនាំយកទៅ"អប់រំកែប្រែ"នៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ហើយមិនដែលបានឃើញពួកគេម្តងទៀតឡើយ។

២៦២- អ្នកដែលជាប់ឃុំឃាំងនៅវត្តបារាយណ៍ជាន់ដែក ត្រូវគេដាក់ខ្នោះជើង២៤ម៉ោង ក្នុងមួយថ្ងៃ។ អ្នកទោស មានទាំងស្ត្រី និងកុមារ។ គេកម្រនឹងឱ្យអ្នកទោសទៅមុជទឹកណាស់ មានពេលខ្លះអ្នកទោសបានមុជទឹករៀងរាល់ប្រាំមួយថ្ងៃម្តង ឬមួយខែម្តង ហើយគេតម្រូវឱ្យអ្នកទោសទាំងនោះ បត់ជើងតូច ឬធំ នៅក្នុងធុងដែលដាក់នៅតាមជួរ។ របបអាហារដែលផ្តល់ឱ្យអ្នកទោស គឺមានតិចតួចស្តួចស្តើងណាស់ គឺមានតែអង្ករមួយកំប៉ុងសម្រាប់មនុស្សប្រាំនាក់ ឬបបររាវតែពីរវែកប៉ុណ្ណោះ។ មនុស្សជាច្រើនបានស្លាប់ដោយសារការអត់ឃ្លាន គ្មានថ្នាំសង្កូវសម្រាប់ព្យាបាល និងអ្នកទោសដែលធ្លាក់ខ្លួនឈឺ។ អ្នកទោសត្រូវគេសួរចម្លើយនៅក្នុងអគារកំពស់ពីរជាន់ដែលស្ថិតនៅក្នុងបរិវេណការដ្ឋាននោះ អ្នកទោសត្រូវគេធ្វើទារុណកម្ម និងវាយដំក្នុងពេលសួរចម្លើយ។

# ការសម្លាប់ដោយខុសច្បាប់

២៦៣- ភ័ស្តុតាងបង្ហាញថា មានពលករក្នុងចំនួនដ៏ច្រើន មកពីការដ្ឋានទំនប់១មករា ត្រូវគេសម្លាប់។ ពលករតែងតែបាត់ខ្លួនពីការដ្ឋាន ជាពិសេសគឺនៅពេលយប់ ដែលភាគច្រើនគេជឿថា ត្រូវបានគេសម្លាប់ចោលនៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក។ អ្នកទោសត្រូវគេនាំទៅមន្ទីរសន្តិសុខនេះ ទាំងយប់ និងទាំងថ្ងៃ។ ភាគច្រើន ប្រជាជនទាំងនោះ គ្មានជីវិតរស់រានទេ។ ចម្លើយសារភាពរបស់អ្នកទោសទាំងនោះ ត្រូវគេបញ្ជូនទៅគណៈស្រុកបារាយណ៍ដែលជាអ្នកត្រូវធ្វើការសម្រេច ថាតើអ្នកទោសណាខ្លះដែលត្រូវ "កម្ទេច"។ ការសម្លាប់មនុស្សនៅវត្តបារាយណ៍ជាន់ដែក កើតឡើងច្រើនបំផុតក្នុងឆ្នាំ១៩៧៨។ ដោយផ្អែកលើបរិមាណអដ្ឋិធាតុដែលបានគាស់ចេញពីរណ្តៅសាកសពរួមទាំងនោះ ជនរងគ្រោះជាច្រើនពាន់នាក់ប្រាកដជាត្រូវគេសម្លាប់នៅទីតាំងនេះ។ អ្នកស៊ើបអង្កេតមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការប៉ាន់ស្មានថា តួលេខសរុបអាចមានច្រើនពី១៥០០០នាក់ រហូតដល់ ២០០០០នាក់។ អ្នកទោសដែលនៅរស់រានមានជីវិតម្នាក់ពីមន្ទីរសន្តិសុខនោះ បានធ្វើការប៉ាន់ស្មានពីតួលេខសរុបដែលមានចំនួន២៥០០០នាក់។ អដ្ឋិធាតុរាប់សិបពាន់នាក់ទៀតរបស់ជនរងគ្រោះ ត្រូវគេរក្សាទុកនៅក្នុងចេតិយក្នុងវត្ត។

២៦៤- ការសម្លាប់មនុស្សធ្វើឡើងនៅពេលយប់ នៅភាគខាងត្បូងនៃមន្ទីរសន្តិសុខ ឬនៅចំពីមុខវត្ត។ អ្នកទោសត្រូវគេចងមុខ សម្លាប់ដោយសំពងនឹងដំបងឬស្សីពីក្រោយកញ្ចឹងក ឬនឹងចបកាប់ រួចហើយកប់នៅក្នុងរណ្តៅ។ ជនរងគ្រោះមួយចំនួន ត្រូវគេទម្លាក់យ៉ាងជាក់ស្តែងចូលទៅក្នុងអណ្តូងទឹក។ មាន"ក្លិនអសោចភាយចេញពី"វត្ត និងមានស្នាមឈាមនៅលើជញ្ជាំងអគារ។

ប្រជាជនត្រូវគេសម្លាប់ដោយសារត្រូវគេចោទថាបានប្រព្រឹត្តអំពើបំពាន ដូចជាការព្យាយាមប្រមូល ម្ហូបអាហារបន្ថែម ជាអ្នកមូលធននិយម ឬសក្តិភូមិនិយម មានទិន្នាការ "យួន" ជាអ្នក "១៧មេសា" ឬជាជនជាតិចាម និងជាមនុស្សខ្ជិល ឬរអ៊ូរទាំជាដើម។

## ទំនប់ទឹកត្រពាំងថ្ម

### ទីតាំង និងប្រតិបត្តិការ

២៦៥- ទំនប់ទឹកត្រពាំងថ្ម មានទីតាំងស្ថិតនៅភូមិត្រពាំងថ្ម ភាគពាយ័ព្យ និងនៅជិតភូមិប៉ោយចារ ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ (អតីតខេត្តបាត់ដំបង មុនពេលព្រំដែនមានការផ្លាស់ប្តូរ) គឺស្ថិតនៅក្នុងកន្លែងដែលគេហៅថា តំបន់៥ នៃភូមិភាគពាយ័ព្យ។ កន្លែងនោះត្រូវបានសាងសង់ឡើង ដោយប្រើពលករជាច្រើនពាន់នាក់ ដែលត្រូវគេបង្ខំឱ្យប្រើកម្លាំងដៃសុទ្ធសាធ ក្រោមការត្រួតត្រារបស់ ប.ក.ក ពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៧។ ទំនប់នោះនៅមានប្រតិបត្តិការនៅឡើយ ទោះបីជាក្រោយពេលមានការជួសជុលខ្លះក្នុងឆ្នាំ២០០៤ក៏ដោយ ទំនប់នោះស្ថិតក្នុងសភាពខុសគ្នាបន្តិចបន្តួច ពីទិដ្ឋភាពក្នុងឆ្នាំ១៩៧០។

២៦៦- ទំនប់នោះ មានចំនួនពីរខ្សែ ដែលមួយខ្សែមានប្រវែងប្រមាណ៩គីឡូម៉ែត្រ លាតសន្ធឹងពីទិសខាងកើតរហូតដល់ទិសខាងលិច តាមបណ្តោយផ្នែកខាងត្បូងនៃអាងស្តុកទឹក និងមួយខ្សែទៀតមានប្រវែង១៣គីឡូម៉ែត្រ លាតសន្ធឹងពីភាគខាងជើងទៅខាងត្បូង តាមបណ្តោយផ្នែកខាងកើតនៃអាងស្តុកទឹក។ ស្របពេលដែលមានរបាយការណ៍ថា ផែនការដើមបានបង្ហាញថា ទំនប់ទឹកនេះមានមុខលើប្រវែងប្រមាណ៥០ម៉ែត្រ និងមុខកាត់ផ្ទៃបាតប្រវែងប្រមាណ១០០ម៉ែត្រនោះ មានការប៉ាន់ស្មានខុសៗគ្នាពីទំហំ និងខ្នាតនៃទំនប់ទឹក ដែលសាងសង់រួច៖ មានកំពស់ពី៥ម៉ែត្រ

ទៅ៨ម៉ែត្រ និងមានទទឹងមុខលើចន្លោះពី១០ម៉ែត្រ ទៅ២៥ម៉ែត្រ និងមានបាតក្រោមប្រវែង ប្រមាណពី៣០ម៉ែត្រ ទៅ៥០ម៉ែត្រ។ ទំនប់ទាំងពីរខ្សែរនោះ ត្រូវបាន សាងសង់ឡើងពីដីបុកបង្ហាប់ ដោយមានមុខបង្ហូរទឹកធ្វើពីបេតុង និងស្ពានមួយចំនួនទៀតផង។

២៦៧- នៅតាមបណ្តោយទំនប់ខ្សែទីមួយ មានស្ពានចំនួនបី ស្ពានទីមួយ ស្ថិតនៅជាប់នឹងផ្នែកខាង លិចនៃចំណុចប្រសព្វរបស់ទំនប់ទាំងពីរខ្សែតែម្តង ស្ពានទី២ ស្ថិតនៅចម្ងាយ៣,២គីឡូ ម៉ែត្រខាងលិចពីស្ពានទី១ និងស្ពានទី៣ ស្ថិតនៅចម្ងាយប្រមាណជា៣,៥គីឡូម៉ែត្រខាងលិចពី ស្ពានទី២។ ពាក់កណ្តាលផ្នែកខាងក្រោយនៃស្ពានទី១ ត្រូវបានបញ្ចប់ក្នុងពេលដំណាលគ្នាជា មួយនឹងការសាងសង់ទំនប់ដែរ រីឯស្ពានទី២ និងទី៣ នៅមិនទាន់បានសាងសង់នៅឡើយទេ ពេលនោះ។ ទំនប់ទឹកនោះមានច្រកទ្វារបង្ហូរទឹក។ ណាតសន្ទឹងនៅតាមបណ្តោយដៃទំនប់ទាំង ពីរខ្សែនោះ គឺផ្លូវតូចចង្អៀត។ មានប្រឡាយធារាសាស្ត្រជាច្រើន ត្រូវបានសាងសង់ឡើង ក្នុង ពេលដែលទំនប់កំពុងត្រូវបានគេសាងសង់។ ជម្រកត្រូវបានគេផ្តល់ឱ្យដល់ពលករដែលស្ថិតនៅ ជាប់នឹងការដ្ឋាន។ មានទីតាំងសម្លាប់មនុស្សជាច្រើនកន្លែង ដែលស្ថិតនៅជិតនឹងទីជម្រកទាំង នោះ។

## រចនាសម្ព័ន្ធគ្រប់គ្រង

## ការគ្រប់គ្រងពីលើការដ្ឋាន

២៦៨- ម៉ែន ជុន *ហៅ* ហ៊ុង្ស ជាលេខាតំបន់៥ រហូតដល់ពេលដែលគាត់ត្រូវគេចាប់ខ្លួន ក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ជាចំណែកមួយនៃការបោសសម្អាតក្នុងតំបន់ ដែលចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ។ ហ៊ុង្ស ត្រូវជំនួសដោយ ហេង រិន *ហៅ* ម៉ី ដែលគាត់ផ្ទាល់ត្រូវគេចាប់ខ្លួន ក្នុងខែវិច្ឆិកា ឆ្នាំ

១៩៧៨។ សមាជិកដទៃទៀតនៃគណៈតំបន់៥ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហ៊ុយ្ស [redacted] និង តា ជាល ជាកូនប្រុសរបស់លេខាភូមិភាគពាយ័ព្យឈ្មោះ មូល សម្បត្តិ *ហៅ* រស់ ញឹម។ តា ជាល ជាប់ពាក់ព័ន្ធក្នុងការចុះពិនិត្យមើលការសាងសង់ទំនប់ទឹក និងត្រួតពិនិត្យការដ្ឋានការងារ ជាច្រើនលើកច្រើនសា។ រស់ ញឹម បានចុះត្រួតពិនិត្យការដ្ឋានដោយផ្ទាល់យ៉ាងហោចណាស់ម្តង ក្នុងឆ្នាំ១៩៧៧។ គាត់ និងកូនប្រុសរបស់គាត់ តា ជាល ត្រូវគេចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៨។

២៦៩- ង៉ាន ម៉ែម *ហៅ* ហាត គឺជាលេខាស្រុកភ្នំស្រុក ពីឆ្នាំ១៩៧៥ រហូតដល់ពេលដែលគាត់ត្រូវចាប់ខ្លួន ក្នុងឆ្នាំ១៩៧៧។ [redacted] គឺជាអនុលេខាស្រុក ហើយ ប៉ែន យ៉ុយ *ហៅ* យុយ គឺជាសមាជិកគណៈស្រុក រហូតដល់ពេលដែលគាត់ត្រូវគេចាប់ខ្លួន នៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៧៧។ [redacted] ជាសមាជិកគណៈឃុំប៉ោយចារ បានចុះត្រួតពិនិត្យការដ្ឋាន។ [redacted] លេខាស្រុកភ្នំស្រុក ឈ្មោះ ហាត ក៏បានបញ្ជូនប្រជាជនទៅធ្វើការនៅទំនប់ទឹកដែរ ដោយធ្វើតាមបញ្ជារបស់តំបន់។

## ការគ្រប់គ្រងនៅក្នុងការដ្ឋាន

២៧០- តា វ៉ាល់ គឺជាប្រធានកងចល័តតំបន់ និងជាអ្នកទទួលខុសត្រូវយ៉ាងមានប្រសិទ្ធភាពនៅការដ្ឋានការងារ។ [redacted]

២៧១- តា វ៉ាល់ និង [redacted] បានចូលរួមជាគណៈអធិបតី នៅក្នុងអង្គប្រជុំស្ដីពីការសាងសង់ជាប្រចាំ តា វ៉ាល់ [redacted] ជាអ្នកធ្វើផែនការការងារ ហើយ តា វ៉ាល់ បានចេញបញ្ជាឱ្យអ្នកដឹកនាំថ្នាក់ក្រោមនៃកងបំពេញការងារ ដោយរួមបញ្ចូលទាំង ប្រធានកងវរសេនាតូចផង ដែរ។ តា វ៉ាល់ បានតែងតាំងអ្នកដឹកនាំក្រោមបង្គាប់ជាច្រើន នៅក្នុងក្រុមពលករ។ ពលករទាំងនោះត្រូវគេដឹកនាំឱ្យធ្វើការដោយក្នុងមួយកងមានគ្នា១០នាក់។ នៅក្នុងកងអនុសេនាតូចនីមួយៗ មានកងចំនួន៣ មានកងអនុសេនាតូចពី៣ទៅ៦ក្នុងកងអនុសេនាធំនីមួយៗ និងមានកងអនុសេនាធំចំនួន៣ ក្នុងកងវរសេនាតូចមួយ។ ប្រធានកងអនុសេនាតូចត្រូវរាយការណ៍ទៅប្រធានកងអនុសេនាធំ ហើយប្រធានកងអនុសេនាធំ ត្រូវរាយការណ៍ជូនទៅប្រធានកងវរសេនាតូច។ យ៉ាងហោចណាស់ មានកងវរសេនាតូចចំនួន៧ បានចូលរួមក្នុងការសាងសង់នោះ។ នៅមានកងពិសេសមួយចំនួនទៀត ដែលមានចំនួនពលករខុសៗគ្នា។ មានកងដោយឡែកមួយ ដែលមានពលករសុទ្ធតែជាជនដែលត្រូវគេដាក់ទណ្ឌកម្ម ដោយសារតែមិនខិតខំប្រឹងប្រែងធ្វើការងារ ក្រុមនេះត្រូវគេចាត់តាំងឱ្យធ្វើការងារពិបាកៗជាពិសេស។

២៧២- តា វ៉ាល់ ត្រូវគេបោសសម្អាតនៅពាក់កណ្ដាលឆ្នាំ១៩៧៧ ដោយកម្លាំងភូមិភាគនិរតី។ បន្ទាប់ពីនេះ កងចល័តតំបន់ដែល តា វ៉ាល់ ជាអ្នកទទួលបន្ទុក ត្រូវគេបំបែកទៅជាកងចល័តស្រុកសម្រាប់មនុស្សពេញវ័យ និងកងចល័តតំបន់សម្រាប់យុវជន។ [redacted] មកពីភូមិភាគនិរតីជាអ្នកទទួលបន្ទុកលើការសាងសង់ទំនប់ទឹកនោះ បានចាប់ខ្លួន និងសម្លាប់មនុស្សអស់ច្រើននាក់។

## ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស

## បញ្ហាជាន់ខ្ពស់របស់ ប.ក.ក មកលើការដ្ឋាន

២៧៣- នៅពេលដែលមេដឹកនាំភូមិភាគពាយ័ព្យ ជាអ្នករៀបចំផែនការសាងសង់ មជ្ឈិមបក្សបានទទួលច្បាប់ចម្លងនៃផែនការជាច្រើន និងតាមដានការអនុវត្តផ្សេងៗផងដែរ។ មេដឹកនាំជាន់ខ្ពស់ ប.ក.ក បានចុះត្រួតពិនិត្យការដ្ឋានទំនប់ទឹក ដូចជា៖ ប៉ុល ពត ដែលបានចុះមកម្តងម្កាល **ខៀវ សំផន** បានចុះមកត្រួតពិនិត្យការដ្ឋាននេះជាញឹកញាប់ ហើយមានពេលមួយនោះ គាត់បានចុះមកត្រួតពិនិត្យ និងបានជម្រុញឲ្យពលករបន្តខិតខំប្រឹងប្រែងធ្វើការងារ។ ក្រោយមកគាត់បានសម្តែងនូវការដឹងគុណរបស់គាត់ផ្ទាល់ ចំពោះការបញ្ចប់ការសាងសង់ទំនប់ទឹកនេះ ដែលនៅក្នុងនោះគាត់បាននិយាយថា ដោយសារទំនប់ទឹកនេះ បង្កើតឲ្យមានវាលស្រែ ដែលគាត់អាច មើលឃើញដាច់កន្ទុយភ្នែក។ លេខាតំបន់ និងលេខាភូមិភាគ ក៏បានចុះទៅត្រួតពិនិត្យការដ្ឋាន ដូចជាលេខាស្រុក តា ហាត ។ តា ហាត តែងបានប្រាស្រ័យទាក់ទងជាប្រចាំជាមួយនឹង តា វ៉ាល់ ដែលជាអ្នកដឹកនាំការសាងសង់នៅទំនប់ទឹកនោះ។ តា យ៉ុយ តែងតែរៀបចំការប្រជុំនានា ពាក់ព័ន្ធនឹងការសាងសង់នេះ។

២៧៤- ទំនប់ទឹកត្រពាំងថ្ម ត្រូវបានប្រើជាការបង្ហាញពីសមិទ្ធិផលរបស់របបកម្ពុជាប្រជាធិបតេយ្យ។ តា ជាល ជាកូនប្រុសរបស់លេខាភូមិភាគ បានចូលរួមជាអធិបតីក្នុងពិធីសម្ពោធបើកការសាងសង់ស្ពានទី១។ កម្មាភិបាលជាន់ខ្ពស់ជាច្រើន ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ បានចូលរួម នៅក្នុងព្រឹត្តិការណ៍នោះ។ ក្នុងចំណោមអ្នកចូលរួមទាំងនោះ នៅមានគណៈប្រតិភូចិន មួយក្រុមដែលអមដំណើរដោយ រស់ ញឹម ផងដែរ។ ប៉ុល ពត ក៏បានចូលរួមដែរ ហើយបាននិយាយថា

ចិនបានផ្តល់នូវបរិក្ខារសម្រាប់ការសាងសង់។ គណៈប្រតិភូចិន តែងចុះមកត្រួតពិនិត្យការដ្ឋាននេះជាទៀងទាត់។ ចិនបានផ្តល់សម្លៀកបំពាក់ ព្រមទាំង ចបកាប់ សម្រាប់ការសាងសង់ផងដែរ។ ប៉ុល ពត វន វ៉េត និង ជួន ជឿន បានរួមដំណើរជាមួយគណៈប្រតិភូចិនមួយក្រុម ក្នុងពេលចុះត្រួតពិនិត្យការដ្ឋាន នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៧។

## ការគ្រប់គ្រងពីការដ្ឋានទៅកាន់បញ្ហាការជាន់ខ្ពស់ ប.ក.ក

២៧៥- តា ជាល បានរាយការណ៍ទៅមជ្ឈិមបក្ស ពីកម្លាំងដែលត្រូវប្រើក្នុងអំឡុងពេលសាងសង់។ របាយការណ៍ស្តីពីការវិវឌ្ឍន៍នៃការសាងសង់ ត្រូវបានបញ្ជូនទៅគណៈកម្មាធិការមជ្ឈិមថ្នាក់ខ្ពស់បំផុត។ តំបន់៥ បានដាក់របាយការណ៍ប្រចាំសប្តាហ៍ ទៅមន្ទីរភូមិភាគពាយ័ព្យ(ម-៥៦០) អំពីការវិវឌ្ឍន៍នៃការសាងសង់។ មន្ទីរភូមិភាគ បានផ្ញើរបាយការណ៍ជាទៀងទាត់ទៅមន្ទីរ៨៧០ រួមទាំងរបាយការណ៍ផ្សេងៗទៀត ដែលរាយការណ៍ពីស្ថានភាពទំនប់ទឹកត្រពាំងថ្ម។ មានពេលមួយនោះ [redacted] បានស្នើសុំដោយផ្ទាល់ខ្លួននូវសម្លៀកបំពាក់ សម្រាប់ពលករ មកពីភ្នំពេញដែលត្រូវបានសម្រេចផ្តល់ឲ្យដោយ តា ម៉ុក។

## ការធ្វើពលកម្មដោយបង្ខំ

២៧៦- ពលករជាច្រើនពាន់នាក់ ត្រូវគេបង្ខំឲ្យធ្វើការសាងសង់ទំនប់ទឹកត្រពាំងថ្ម។ ពលករ រួមមានទាំងស្ត្រី និងបុរស យុវជន និងកុមារផងដែរ។ ពួកគេទាំងនោះភាគច្រើន គឺត្រូវ គេយកមកពីបណ្តាស្រុកក្នុងតំបន់៥ ហើយត្រូវដាក់បញ្ចូលជាមួយប្រជាជនថ្មីដ៏ច្រើនលើសលប់ដែលត្រូវគេជម្លៀសមកពីភ្នំពេញ។ ដោយសារគោលបំណងនៃការធ្វើការនេះ គឺសាងសង់ទំនប់ទឹកសម្រាប់ធារាសាស្ត្រ ពលករត្រូវគេបង្ខំឲ្យសែងដី ឬជីក និងបិទទំនប់។ រាល់កិច្ចការ

ទាំងអស់ត្រូវធ្វើដោយដៃ ទោះបីជាមាន បង្គី ចបកាប់ ដងរែក ផ្តល់ឲ្យក៏ដោយ។ ជាទូទៅ ម៉ោងធ្វើការគឺមាន៣វគ្គ ព្រឹក រសៀល និងល្ងាច។ ការប៉ាន់ស្មានពីបរិមាណការងារកំណត់ប្រចាំថ្ងៃ គឺត្រូវសែងដីចន្លោះពី១ ២ ឬ៣ម៉ែត្រគូប សម្រាប់ពលករម្នាក់ៗក្នុងមួយថ្ងៃ។ ដល់ពេលស្ទូង ពលករក៏ត្រូវស្ទូងស្រូវផងដែរ។

២៧៧- ពលករត្រូវគេតម្រូវឲ្យស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ហើយប្រសិនបើគេបើកអាវពណ៌សឲ្យនោះ ត្រូវយកអាវសទាំងនោះទៅជ្រលក់ឲ្យខ្មៅ ដោយប្រើភក់ ឬសម្បកឈើ។ គ្មានស្បែកជើង និងមួកផ្តល់ឲ្យនោះទេ។ ជាធម្មតា គេផ្តល់ភ្លើងបំភ្លឺសម្រាប់ធ្វើការនៅពេលយប់។ ក្នុងពេលកំពុងបំពេញការងារ ការផ្លាស់ទី និងការប្រាស្រ័យទាក់ទងដោយសេរី ត្រូវបានហាមឃាត់ ស្ត្រី និងបុរស ត្រូវបំបែកដោយតឹងរ៉ឹងបំផុត។ ការសម្រាកមិនត្រូវបានអនុញ្ញាតឡើយរហូតដល់ពេលដែលការងារចប់ ទើបអាចសម្រាកបាន។

២៧៨- ប្រធានកងជាអ្នកត្រួតពិនិត្យការងារ ហើយឈ្លបយកការណ៍ត្រូវបានគេដាក់ឲ្យឈ្លបយកការណ៍នៅតាមកងនីមួយៗ។ ពលករត្រូវទទួលទណ្ឌកម្ម ចំពោះការមិនបានខិតខំប្រឹងប្រែងធ្វើការងារ ហើយទម្រង់នៃការដាក់ទណ្ឌកម្មសាមញ្ញបំផុតនោះ គឺបន្ថែមបរិមាណការងារ ឬមិនផ្តល់របបអាហារជាដើម។ ពលករក៏ត្រូវគេបញ្ជូនទៅ កងករណី(Case Unit)ផងដែរ ដែលនៅទីនោះ ពលករត្រូវគេតម្រូវឲ្យសែងដីបន្ថែមទៀត ព្រមទាំងត្រូវគេចាត់តាំងឲ្យធ្វើការងារកាន់តែលំបាកឡើងៗ។ ប្រជាជនថ្មីជាច្រើន ត្រូវគេបង្ខំឲ្យធ្វើការនៅក្នុង កងនេះ។ ការវាយដំត្រូវបានចាត់ទុកជារឿងធម្មតាដែរ។ ពេលខ្លះពលករត្រូវអ្នកយាមរំលោភបំពានលើរាងកាយ

ដោយចងជើងព្យួរឡើងលើ រួចទាញចុះ ទាញឡើងជាច្រើនសា។ ការបាត់ខ្លួនក៏មានកើតឡើងដែរ។ មានមនុស្សជាច្រើនដែលបានស្លាប់ដោយសារបាក់កម្លាំង។

## ស្ថានភាពអមនុស្សធម៌

២៧៩- ពលករ សង់ទីជម្រកដែលស្ថិតនៅជិតការដ្ឋានសាងសង់នោះដោយខ្លួនឯង រួមមាន រោងជំរំវែងមួយធ្វើពីឫស្សី ឬមែកឈើ ដោយមានដំបូលប្រក់ស្បូវ។ ទីជម្រកខ្លះគ្មានជញ្ជាំងទេ។ រោងសម្រាប់ដេកមានទំហំខុសៗគ្នា ប៉ុន្តែជាទូទៅវាមានទទឹងប្រវែងប្រាំមួយម៉ែត្រ។ បុរស និងស្ត្រីត្រូវគេបំបែកចេញពីគ្នា។ ស្ថានភាពនៃការរស់នៅស្ថិតនៅក្នុងការលំបាក ដោយពលករត្រូវដេកជាពីរជួរទល់ជើងគ្នា។ ជាទូទៅ មុង និងសម្ភារៈសម្រាប់ដេកផ្សេងៗ មិនត្រូវបានគេផ្តល់ឱ្យទេ។ ពលករបានច្នៃបាវអង្ករធ្វើជាអង្រឹង។ កុមារក៏ជួបប្រទះស្ថានភាពរស់នៅដូចគ្នានេះដែរ ប៉ុន្តែគេមិនបានបែងចែងភេទចំពោះកុមារទេ។ ជនចាស់ជរាមួយចំនួន ស្នាក់នៅក្នុងផ្ទះដែលស្ថិតនៅក្នុងភូមិស្រុករបស់ពួកគាត់។

២៨០- ម្ហូបអាហារដែលគេផ្តល់ឱ្យពលករ គឺមានចំនួនមិនគ្រប់គ្រាន់ទេ ទាំងគុណភាព និងបរិមាណ ដែលជាហេតុ ធ្វើឱ្យពលករទទួលរងភាពអត់ឃ្លាន និងខ្វះជីវជាតិ។ របបអាហារសម្រាប់ពេលអាហារមួយពេលៗ គឺមិនគ្រប់គ្រាន់សម្រាប់ហូបទេ ដូចជា បបររាវៗ បាយ ត្រីងៀត ឬត្រីប្រហុក។ របបអាហារ គឺមានសណ្ឋានដូចគ្នា សម្រាប់ពលករទាំងអស់។ អាហារត្រូវគេផ្តល់ឱ្យចំនួនពី ២ ទៅ៣ ដងក្នុងមួយថ្ងៃ។ ពលករដែលអត់ឃ្លាន និងស្គមស្គាំងបានស៊ីសត្វជីងចក់ ឬស៊ីស្លឹកឈើពុល ដើម្បីដោះទាល់ និងផឹកទឹកមិនស្អាត។ ពលករធ្លាក់ខ្លួនឈឺ ហើយស្លាប់ដោយសារ តែការអត់ឃ្លាន។

២៨១- ពលករត្រូវគេបង្ខំឱ្យរស់នៅក្នុងស្ថានភាពដែលគ្មានអនាម័យគ្រប់គ្រាន់។ បង្គន់អនាម័យ គឺគ្មានជារូបរាងទេ ហើយរុយគឺនៅពាសពេញ។ ពលករ មិនអាចនិយាយទៅកាន់គ្នាបានទេ សូម្បីតែទំពារអាហារក៏មានរុយហោះចូលមាត់ខ្លួនដែរ។ ដោយសារតែខ្វះជីវជាតិ ធ្វើការលើសកម្លាំង និងការខ្វះអនាម័យ ព្រមទាំងថែរក្សាសុខភាពមិនបានដិតដល់ បណ្ដាលឱ្យកើតមានជំងឺផ្សេងៗ ដូចជា អាសន្នរោគ និងគ្រុនចាញ់ កើតឡើងពាសពេញ។ ពលករដែលធ្លាក់ខ្លួនឈឺជាច្រើនត្រូវបានបាត់ខ្លួន។ បុគ្គលិកពេទ្យដែលមិនបានទទួលការបណ្ដុះបណ្ដាល ព្យាបាលពលករដែលធ្លាក់ខ្លួនឈឺ ដោយបានផ្ដល់ថ្នាំដែលគេស្គាល់ជាទូទៅថាជា ថ្នាំគ្រាប់ "អាចម៍ទន្សាយ"។ ពលករដែលធ្លាក់ខ្លួនឈឺជាទម្ងន់ ត្រូវគេបញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតនោះ ដែលគ្មានថ្នាំព្យាបាលគ្រប់គ្រាន់។ ជាទូទៅ ស្ថានភាពរស់នៅកាន់តែយ៉ាប់យ៉ឺនទៅៗ បន្ទាប់ពីកងកម្លាំងភូមិភាគនិរតី បានចូលមកគ្រប់គ្រងនៅភូមិភាគពាយ័ព្យ ក្រោយពីមានការបោសសម្អាត នៅឆ្នាំ១៩៧៧។

## ការចាប់ខ្លួន និងការឃុំឃាំងដោយខុសច្បាប់

២៨២- គេមិនបានដឹងពីចំនួនពលករនៅត្រពាំងថ្ម ដែលត្រូវគេចាប់ខ្លួន និងឃុំឃាំង នៅក្នុងបណ្ដាមន្ទីរសន្ដិសុខទេ ប៉ុន្ដែការចាប់ខ្លួនបានកើតឡើងរាល់ថ្ងៃជាប្រចាំ។ ពលករដែលត្រូវគេចាប់ខ្លួនទាំងនោះ រួមមាន ពលករដែលមិនអាចគោរពតាមបរិមាណការងារ ខុសសីលធម៌ ឬមានខ្សែរយៈ"យួន"។ ជាទូទៅ "ប្រជាជនថ្មី" គឺជាគោលដៅសំខាន់ និងមានគោលដៅផ្សេងៗជាច្រើនទៀត ដូចជា ពលករដែលធ្លាប់បានបួសរៀនជាសង្ឃ និងបុគ្គលដែលធ្លាប់បានរៀនសូត្រ ដូចជា អ្នកកាន់ស្ថិតិ និងគ្រូបង្រៀនជាដើម។

២៨៣- ជាធម្មតា ការចាប់ខ្លួនធ្វើឡើងនៅពេលយប់ ប៉ុន្តែមានការចាប់ខ្លួនមួយចំនួន បានធ្វើឡើងនៅពេលកំពុងធ្វើការ។ នៅពេលដែលឃោធារបស់ តា វ៉ាល់ ធ្វើការចាប់ខ្លួន និងសម្លាប់មនុស្សមួយចំនួននៅទំនប់ទឹកនោះ យ៉ាងហោចណាស់មានការចាប់ខ្លួន និងសម្លាប់មួយចំនួន ត្រូវបានធ្វើឡើងតាមបញ្ជាផ្ទាល់ពីមជ្ឈិមបក្សតែម្តង។ នៅពេលធ្វើដំណើរមកដល់ការដ្ឋានដំបូង កងកម្លាំងបានធ្វើប្រវត្តិរូបរបស់ពលករម្នាក់ៗ ហើយប្រវត្តិរូបទាំងនោះ នឹងត្រូវគេយកទៅសម្រិតសម្រាំង ដើម្បីរក"ខ្មាំង"។ ជនដែលត្រូវគេចាប់ខ្លួន ត្រូវគេចងស្លាបសេក រួចត្រូវគេបណ្តើរយកទៅឆ្ងាយ។ អ្នកយាមពេលយប់ម្នាក់ បានឃើញគេបណ្តើមនុស្សជាខ្សែដែលមានចំនួនពី១៥ ទៅ២០នាក់ របៀបនេះចំនួនបីលើកផ្សេងៗគ្នា។ ជនដែលត្រូវគេចាប់ខ្លួន ត្រូវគេយកទៅកសាង ឬត្រូវបាត់ខ្លួនទៅជាមួយគ្នាទាំងអស់។ [redacted]។ [redacted]បានផ្តល់សក្ខីកម្មថា អ្នកដែលត្រូវគេចាប់ខ្លួន ត្រូវទាហានដែលប្រដាប់ដោយអាវុធបណ្តើរយកទៅ រួចសម្លាប់ចោលទាំងខ្សែៗ។

## ការសម្លាប់ដោយខុសច្បាប់

២៨៤- ការសម្លាប់ដោយខុសច្បាប់ គឺកើតមានជាធម្មតា នៅទំនប់ទឹកត្រពាំងថ្ម។ ជនដែលត្រូវគេជ្រើសយកទៅសម្លាប់ចោលនោះ ត្រូវគេយកទៅកសាង ឬត្រូវគេចោទថាមិនបានខិតខំប្រឹងប្រែង

ធ្វើការជាច្រើនដង។ ជនទាំងឡាយដែលត្រូវគេចោទប្រកាន់ថាជាភ្នាក់ងារសេអ៊ីអា ក៏ត្រូវគេយកទៅសម្លាប់ដែរ។ ជាពិសេស ប្រជាជនថ្មីត្រូវគេចាត់ទុកជាគោលដៅ។

២៨៥- ក្នុងពេលដែលចំនួនសរុបជនរងគ្រោះដែលត្រូវគេសម្លាប់នៅទំនប់ទឹកត្រពាំងថ្ម មិនបានដឹងក្នុងចំនួនមួយពិតប្រាកដទេ។ មានជនរងគ្រោះចំនួន២០០០នាក់ ត្រូវគេកប់នៅក្នុងអាងត្រពាំងថ្ម ស្ថិតនៅជិតនឹងអាងស្តុកទឹកដែលជាទីតាំងសម្លាប់មនុស្សមួយធំជាងគេបំផុត នៅស្រុកភ្នំស្រុក។ ដោយសារតែប្រជាជននៅស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ ភាគច្រើនបំផុតជាប្រជាជនថ្មី ជនរងគ្រោះភាគច្រើន គឺជាប្រជាជនថ្មី។ រណ្តៅសាកសពរួម ក៏មាននៅទាំងក្នុងទំនប់ និងទាំងនៅក្រោមអាងស្តុកទឹក។ ការសម្លាប់មនុស្ស ច្រើនធ្វើឡើងនៅពេលយប់ ហើយដំណើរការនៃការសម្លាប់មនុស្ស គឺប្រព្រឹត្តទៅខុសៗគ្នា។ នាល្ងាចមួយនោះ អ្នកទោសម្នាក់ដែលដើមឡើយត្រូវគេជម្លៀសមកពីភ្នំពេញ ត្រូវគេបញ្ជាឱ្យជីករណ្តៅខ្លួនឯង បន្ទាប់មកគាត់ត្រូវគេសំពងនឹងចបកាប់ឱ្យស្លាប់ រួចហើយត្រូវគេបោះចូលទៅក្នុងរណ្តៅ។ សាក្សីមួយរូបបានរំឮកថា មានពេលមួយនោះ នៅពេលដែលពលករស្ត្រីមានផ្ទៃពោះ ដែលមានគក៏អាយុចន្លោះពី៥ខែទៅគ្រប់ខែនោះ ត្រូវគេយកទៅសម្លាប់ និងកប់ចោល នៅក្នុងគ្រឹះស្ពានទី១ ដែលគេចាត់ទុកថា ជាការធ្វើឱ្យគ្រឹះទំនប់ទឹកមានសភាពរឹងមាំ។ ស្ត្រីមានផ្ទៃពោះម្នាក់ ត្រូវគេវាយ និងទម្លាក់ចូលទៅក្នុងរណ្តៅនៅគែមនៃស្ពានទី១ រួចហើយកប់ជាមួយថ្មទាំងនៅរស់។ ជនរងគ្រោះដទៃទៀត ក៏មានជោគវាសនាដូចគ្នានេះដែរ ដោយត្រូវគេកប់នៅក្នុងរណ្តៅមួយនៅជិតស្ពានទី១។ ទីពិឃាតមនុស្សផ្សេងៗទៀត មានទីតាំងនៅជិតទីជម្រក របស់ពលករ។ សាក្សីមួយរូបបានបង្ហាញថា ពលករត្រូវ*ល្បួប* ក្មេងៗ សម្លាប់ជាច្រើន រយនាក់ រួចកប់នៅបាតទំនប់ទឹក។

# អាកាសយានដ្ឋានកំពង់ឆ្នាំង

## ទីតាំង និងប្រតិបត្តិការ

២៨៦- ទីតាំងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ("ទ.ក.ព.ក") មានទីតាំងស្ថិតនៅភូមិប៉ាតឡាង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដែលស្ថិតក្នុងតំបន់៣១ នៃភូមិភាគបស្ចិម។ ទីតាំងការដ្ឋាននេះ បានចាប់ដំណើរការក្រោមការត្រួតពិនិត្យរបស់ ប.ក.ក ពីខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៩។ ការសម្រេចបង្កើតឱ្យមាន ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ដោយគណៈអចិន្ត្រៃយ៍ ប.ក.ក។ ទ.ក.ព.ក ទំនងជាជំរំប្រមូលផ្តុំការងារ ដ៏ធំបំផុតដែលដាក់ឱ្យដំណើរការដោយកងទ័ពបដិវត្តកម្ពុជា។ ព្រលានយន្តហោះកំពង់ឆ្នាំង ធ្វើឡើងក្នុងគោលបំណងប្រើប្រាស់សម្រាប់តែផ្នែកយោធាតែប៉ុណ្ណោះ គឺដើម្បីទុកឱ្យយន្តហោះដឹកជញ្ជូនធំៗ របស់ចិនចុះចត ដូច្នេះហើយការងារនេះត្រូវរក្សាទុក ជារឿងសម្ងាត់។ ហេតុផលនេះពន្យល់ពីមូលហេតុដែលគណៈអចិន្ត្រៃយ៍បានយល់ព្រមឱ្យសាងសង់ព្រលានយន្តនេះ នៅក្នុងទីតាំងមួយដាច់ស្រយាល។ ការសាងសង់ព្រលានយន្តហោះនេះ គ្រោងនឹងបញ្ចប់នៅក្នុងចុងឆ្នាំ១៩៧៨ ប៉ុន្តែវាមិនទាន់បានបញ្ចប់ទេ ហើយព្រលានយន្តហោះនោះ ក៏មិនដែលបានប្រើប្រាស់ដែរ។

២៨៧- ទ.ក.ព.ក មានផ្លូវសម្រាប់យន្តហោះរត់ចំនួនមួយខ្សែប្រវែង២៤០០ម៉ែត្រ ដែលធ្វើឡើងសម្រាប់ឱ្យយន្តហោះធំៗចុះចត ដោយមានផ្លូវសម្រាប់យន្តហោះរត់ និងសំចតសម្រាប់យន្តហោះ ប៉មមួយសម្រាប់ត្រួតពិនិត្យការហោះហើរកំពស់ប្រាំជាន់ អគាររដ្ឋបាល និងទីបញ្ជាការយោធា ផ្ទះតូចៗធ្វើអំពីឈើ ឬកន្លែងស្នាក់នៅសម្រាប់ពលករ ផ្ទះបាយសម្រាប់ការដ្ឋានមួយ

ស្ថានីយ៍ចាក់ប្រេងមួយ រោងម៉ាស៊ីនអារឈើមួយ និងការដ្ឋានរូងយកថ្មមួយ។ បន្ថែមលើនេះទៀត នៅចម្ងាយប្រហែលជា៣គីឡូម៉ែត្រ ខាងត្បូងឈៀងខាងកើត ព្រលានយន្តហោះនេះ នៅម្ខាងផ្លូវលេខ១៤៥ ដែលមានបណ្តុំកូនភ្នំតូចៗជាច្រើននោះ មានរូងដែលគេជីកមួយប្រើសម្រាប់ជាកន្លែងស្តុកប្រេង ជាទីបញ្ជាការឃោធាក្រោមដី និងជារោងសម្រាប់ទុកយន្តហោះ ឬជួសជុលយន្តហោះ។ បរិក្ខារ និងម៉ាស៊ីនប្រើនៅ ទ.ក.ព.ក នោះ ត្រូវបានដឹកជញ្ជូនមកផ្ទាល់ពីប្រទេសចិនតាមរយៈកបាល់។ ទ.ក.ព.ក ត្រូវបានបង្កើតឡើងនៅលើទីតាំងដ៏ធំទូលាយមួយ (បណ្តោយប្រវែង៧គីឡូម៉ែត្រ) គ្របដណ្តប់លើទីតាំងមួយស្ថិតនៅចន្លោះវត្តក្រាំងលាវ និងស្ពានសាបអង្គាម ដែលស្ថិតនៅលើផ្លូវជាតិលេខ៥។ គ្រាន់តែព្រលានយន្តហោះតែមួយប៉ុណ្ណោះ គ្របដណ្តប់លើផ្ទៃដីចំនួនប្រមាណ៣០០ហិតតា ទៅហើយ។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងពីលើការដ្ឋាន

២៨៨- ទ.ក.ព.ក គឺជាការដ្ឋានពិសេសមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្ស និងខ្សែសង្វាក់បញ្ជានៃកងពល៥០២។ [redacted] ជាអ្នកគ្រប់គ្រង ទ.ក.ព.ក គាត់គឺជាបុគ្គលក្រោមបង្គាប់ [redacted]។ [redacted] ត្រូវគណៈអចិន្ត្រៃយ៍ចាត់តាំងនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ ឲ្យទទួលបន្ទុកគ្រប់គ្រងសេវាផ្នែកទ័ពអាកាស ហើយក្រោយមកត្រូវបានគេផ្លាស់គាត់ទៅសេនាធិការ និងក្រោយមកទៀត គាត់ត្រូវបានជំនួសដោយឈ្មោះ [redacted]។

២៨៩- កងពល៥០២ ដើរតួជាកងទ័ពអាកាសរបស់របបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលកងកម្លាំងកងពលសំខាន់ៗទាំង១០ ត្រូវរាយការណ៍ឱ្យសេនាធិការ ហើយដែលកងពលទាំងនោះត្រូវបែងចែកជាកងវរសេនាធំចំនួន៣ ដែលមាន៩កងវរសេនាតូច រួមមានទាហានចំនួន៤០០០នាក់ ទៅ៦០០០នាក់ កងពល៥០២ មានកងវរសេនាធំយ៉ាងតិចពីរ ឬច្រើនជាងនេះ ដែលរួមមាន១៨កងវរសេនាតូច។ កងពលនេះរួមជាមួយ កងពល១៦៤ មានមុខងារជាកងទ័ពជើងទឹករបស់របបកម្ពុជាប្រជាធិបតេយ្យ ជាអ្នកឯកទេសទទួលខុសត្រូវលើសពីកងពលផ្សេងៗទៀត ដែលត្រូវចាត់តាំងជាកងពលមជ្ឈិមធម្មតា។

២៩០- សុន សេន អគ្គសេនាធិការ គឺជាអ្នកទទួលខុសត្រូវពីលើ [redacted]។ សុន សេន ទទួលខុសត្រូវដោយផ្ទាល់ចំពោះ ទ.ក.ព.ក ដូចជា ត្រូវរាយការណ៍ទៅឱ្យគណៈអចិន្ត្រៃយ៍ និងជាអ្នកអនុវត្តសេចក្តីសម្រេចនានារបស់គណៈអចិន្ត្រៃយ៍ជាដើម។

## ការគ្រប់គ្រងក្នុងការដ្ឋាន

២៩១- ទ.ក.ព.ក ត្រូវដាក់ឱ្យស្ថិតក្រោមអំណាចគ្រប់គ្រងផ្ទាល់របស់ [redacted]។ កម្មាភិបាលកងពល៥០២ផ្សេងៗទៀត ដែលគ្រប់គ្រងការដ្ឋានសាងសង់ភាគច្រើនមកពីភូមិភាគនិរតី [redacted]

[redacted]។

២៩២- មានជំនាញការ និងកម្មាភិបាលជនជាតិចិនចំនួនប្រមាណពី១០០ ទៅ៣០០នាក់ ដោយមានជំនួយពីអ្នកបកប្រែ ជាអ្នកទទួលបន្ទុកផ្នែកបច្ចេកទេសការដ្ឋានសាងសង់ព្រលានយន្តហោះ។ អ្នកជំនាញការជនជាតិចិនទាំងនោះមិនមានការពាក់ព័ន្ធជាមួយនឹងការរៀននយោបាយទេ ប៉ុន្តែពួកគេជាអ្នកបញ្ជាផ្នែកការងារសំណង់ និងដំណើរការផ្នែកម៉ាស៊ីន។ ពេលខ្លះពួកជំនាញការចិនទាំងនោះស្លៀកពាក់ឯកសណ្ឋានជាកងទ័ព។ ពួកជំនាញចិនទាំងនោះ មិនទទួលលក្ខខណ្ឌការងារ ដូចពលករដែលគេបង្ខំឱ្យធ្វើការទាំងនោះទេ ពីព្រោះពួកគេស្នាក់នៅក្នុងទីរួមខេត្តកំពង់ឆ្នាំង និងត្រូវគេដឹកជញ្ជូនមកធ្វើការនៅ ទ.ក.ព.ក ជារៀងរាល់ថ្ងៃតាមរថយន្តក្រុង។

## ការប្រាស្រ័យទាក់ទងជាមួយមជ្ឈិមបក្ស

២៩៣- ការសាងសង់ និងការបញ្ចប់កិច្ចការសាងសង់ព្រលានយន្តហោះ បានក្លាយជាការព្រួយបារម្ភយ៉ាងខ្លាំង និងដោយផ្ទាល់ របស់សមាជិកគណៈអចិន្ត្រៃយ៍ ប.ក.ក ចាប់តាំងពីពេលដែលពួកគេសម្រេចចិត្តធ្វើការសាងសង់ព្រលានយន្តហោះនោះមក។ សមាជិកថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក ជាច្រើន បានចុះទៅត្រួតពិនិត្យការដ្ឋាន ដើម្បីចង់ដឹងអំពីដំណើរការទៅមុខក្នុងការសាងសង់ ដូចជា សុន សេន **នួន ជា** **អៀង សារី** **ខៀវ សំផន** និង តា ម៉ុក ជាដើម។ នៅពេលដែលគណៈអចិន្ត្រៃយ៍ សម្រេចចិត្តធ្វើការបោសសម្អាតកងកម្លាំងយោធារបស់ភូមិភាគបូព៌ា នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ គណៈអចិន្ត្រៃយ៍បានបញ្ជូនកូនទាហាន

របស់ភូមិភាគបូព៌ាដែលគេបានដកអាវុធ ឱ្យទៅកាន់ ទ.ក.ព.ក ដើម្បីបង្ខំឱ្យ ការសាងសង់ឆាប់ហើយ។

២៩៤- នៅក្នុងពេលនោះដែរ មជ្ឈិមបក្សបានជូនដំណឹងជាប្រចាំអំពីស្ថានភាពសន្តិសុខក្នុងតំបន់ (និងប្រការគួរឱ្យកត់សម្គាល់ គឺការចាប់ខ្លួនអ្នកដែលរត់គេចខ្លួនពី ទ.ក.ព.ក) តាមរយៈរបាយការណ៍ប្រចាំខែ ដែលផ្ញើចេញដោយការិយាល័យភូមិភាគបស្ចិម។ ថ្វីត្បិត ទ.ក.ព.ក មានទីតាំងស្ថិតនៅតំបន់៣១ [redacted] ភូមិភាគបស្ចិមក៏ដោយ ថ្នាក់ដឹកនាំរបស់ ទ.ក.ព.ក មិនបានបង្កើតឱ្យមានទំនាក់ទំនងជិតស្និទ្ធ ឬធ្វើការទាក់ទងជាមួយនឹងថ្នាក់ដឹកនាំតំបន់ ឬភូមិភាគឡើយ។ [redacted] ដែលជាមេផ្ទាល់របស់ [redacted] តែងតែទៅពិនិត្យមើល ទ.ក.ព.ក ជាញឹកញាប់ ដើម្បីតាមដាននូវដំណើរការសាងសង់ ហើយគាត់បានរាយការណ៍ទៅឱ្យ សុន សេន។ កែ ពក ក៏បានចុះមកត្រួតពិនិត្យ ទ.ក.ព.ក ដែរ។

## ពលកម្មដោយបង្ខំ

២៩៥- កម្មាភិបាលដែលជាកងទ័ពរាប់សិបម៉ឺននាក់ ត្រូវបានបញ្ជូនទៅ ទ.ក.ព.ក ដើម្បីលត់ដំ ដែលនៅទីនោះ ពួកគេត្រូវបានគេឃុំឃាំងដោយខុសច្បាប់ ក្រោមការគម្រាមកំហែងយកទៅសម្លាប់ចោល។ ចំនួននៃអ្នកជាប់ឃុំមានតែប៉ុន្មានរយនាក់ប៉ុណ្ណោះ នៅពេលចាប់ផ្តើមដំណើរការសាងសង់ដំបូងនាដើមឆ្នាំ១៩៧៦ ហើយបានកើនដល់រាប់សិបម៉ឺននាក់ ក្នុងចន្លោះពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ (ការប៉ាន់ស្មានក្នុងចន្លោះពី២០០០០នាក់ ទៅ៣៥០០០នាក់) ចាប់ពីពេលមានការបោសសម្អាតនៅភូមិភាគពាយ័ព្យ និងបូព៌ា។ មានអ្នកជាប់ឃុំឃាំងជាច្រើនដែលមកពីកងពលធំ១៧០ កងពលធំ៣១០ កងពលធំ៤៥០ (ឬហៅថាកងពលធំ ៦០៣)

និងកងពលធំ ៧០៣ជាដើម។ ចំនួនពលករដ៏ច្រើនសម្បើមនេះ គឺជាពួកបុរសដែលស្ថិតក្រោមបញ្ជារបស់កម្មាភិបាលជាថ្នាក់ដឹកនាំ ដែលត្រូវគេចាប់ខ្លួនដោយសារតែការក្បត់របស់ខ្លួន ក្នុងនោះដែរក៏មានកង ទាហាននារីមួយចំនួនដែរ។ អ្នកជាប់ឃុំភាគច្រើនត្រូវបានយកមកកាន់ទីតាំងនេះ ពីភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៧ និងពីភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨ ហើយអ្នកជាប់ឃុំខ្លះទៀតបញ្ជូនមកពីភូមិភាគកណ្តាល ភូមិភាគបស្ចិម និងភូមិភាគនិរតី ។ យោធាដែលពិការ ឬអសមត្ថភាព (ជាឧទាហរណ៍ មកពីកង ក៤ នៃកងពលធំ៣១០) ក៏ត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅ ទ.ក.ព.ក ផងដែរ ។

២៩៦- ពួកពលករត្រូវបានបែងចែកជាផ្នែកផ្សេងៗ និងត្រូវបានបង្ខំឲ្យទទួលរ៉ាប់រងការងារធ្វើដោយដៃដ៏ខ្លាំងក្លា ដូចជារុះរើផ្ទះទាំងឡាយនៅក្នុងភូមិប៉ាតឡាង សម្អាតព្រៃ និងគាស់គល់ឈើ ដកស្មៅចុចបំផ្ទុះថ្មនៅកន្លែងខ្លួងយកថ្ម បំបែកដី និងរៀបថ្ម បុកបង្ហាប់ដី ពង្រាបដី ដឹកស៊ីម៉ង់ត៍ និងលាយខ្សាច់ ចាក់បេតុង ជីកប្រឡាយ សាងសង់លូបង្ហូរទឹក និងជីករន្ធសម្រាប់ធ្វើលេណដ្ឋានក្រោមដី និងរោងទុកយន្តហោះ ។ ពលករជាស្ត្រីភេទខ្លះទៀត ស្ទូងស្រូវ ។ ពលករ ទ.ក.ព.ក ត្រូវបានគេប្រគល់ឧបករណ៍ធ្វើដោយដៃ ដូចជា បង្គី ចបកាប់ ចបជីក ប៉ែល និងជើងដំរីសម្រាប់បុកបង្ហាប់ដី ហើយការងារនោះត្រូវធ្វើដោយគ្មានគោ ឬក្របីជួយអូសទាញឡើយ។

២៩៧- ការងារដែលធ្ងន់ធ្ងរបំផុតត្រូវបម្រុងទុកឲ្យអ្នកជាប់ឃុំក្នុងប្រភេទខ្លះ ដូចជាអ្នកដែលគេបញ្ជូនមកពីភូមិភាគពាយ័ព្យ និងបូព៌ា ព្រមទាំង"អ្នកសមាភាពមិនល្អ" ឬ"យោធាដែលជាប់និន្នាការ" ទាំងឡាយដែលត្រូវបានចោទប្រកាន់ ពីការមាននិន្នាការជាមួយអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ

ឬជាមួយអ្នកដែលគេចោទថាបានក្បត់ ។ ចំណែកពលករដែលមានឯកសិទ្ធិមានឱកាសបានបើកគ្រឿងចក្រយកមកពីប្រទេសចិន ដូចជាត្រាក់ទ័រ ឡានបែនដឹកដី រ៉ូឡូកិន ប៊ុលឌូហ្ស៊ែរ ម៉ាស៊ីនលាយស៊ីម៉ង់ត៍ ឡានដឹកទឹក ឬក៏បើកបញ្ជាអេស្កាវ៉ាទ័រ ។ គ្រឿងម៉ាស៊ីនទាំងនោះ ជួយពួកគេក្នុងការកៀរបង្ហាប់ដី ដឹកជញ្ជូនថ្ម ពង្រាបផ្ទៃដី បង្ហាប់ដី សាងសង់ផ្លូវយន្តហោះរត់ ដោយចាក់កៅស៊ូលាយជាមួយថ្ម និងស៊ីម៉ង់ត៍ កសាងស្ពាន និងផ្លូវ ព្រមទាំងជីកអាងស្តុកទឹកផង។ ចំណែកអ្នកជាប់ឃុំមួយប្រភេទទៀត ត្រូវបានចាត់តាំងឲ្យសំលៀងផ្លែរណាអារឈើនៅពេលទំនេរ។

២៩៨- ដោយសារតែថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក និងថ្នាក់ដឹកនាំ ទ.ក.ព.ក ត្រូវការឲ្យព្រលានយន្តហោះ អាចដំណើរការបានឆាប់រហ័សនោះ ស្ថានភាពធ្វើការកាន់តែសាហាវខ្លាំងឡើង ។ ម៉ោងធ្វើការធម្មតា ចាប់ផ្តើមនៅម៉ោង៤ព្រឹក គឺបន្ទាប់ពីពួកពលករបានចូលរួមប្រជុំស្វ័យទិតៀនរួចហើយ ឬបន្ទាប់ពីបានស្ងួតស្រូវរួចហើយ ។ ជួនកាលពលករត្រូវដើរក្នុងចម្ងាយរាប់គីឡូម៉ែត្រ ដើម្បីឲ្យទៅដល់កន្លែងធ្វើការនៅម៉ោង៦ព្រឹក ហើយត្រូវធ្វើការពីម៉ោង៦ព្រឹក រហូតដល់ម៉ោង៦ល្ងាច ដោយគ្រាន់តែឈប់សម្រាកមួយម៉ោងប៉ុណ្ណោះ ដើម្បីហូបបាយថ្ងៃត្រង់។ ក្រៅពីពេលបាយថ្ងៃត្រង់នេះ មិនមានការអនុញ្ញាតឲ្យឈប់សម្រាកទេ។ នៅពេលយប់មានការបើកភ្លើងបំភ្លឺ ហើយផ្នែកខ្លះត្រូវបន្តធ្វើការជាប្រចាំ ពីម៉ោង៧ល្ងាច ដល់ម៉ោង១១យប់ ឬជួនកាល ក្រោយម៉ោង១១យប់ក៏មានដែរ។ ក្រុមយោធាដែលមានឯកសិទ្ធិ ធ្វើការត្រឹមតែម៉ោង៥ល្ងាចប៉ុណ្ណោះ។ មានក្រុមអ្នកជាប់ឃុំមួយចំនួន ធ្វើការតែពេលយប់ប៉ុណ្ណោះ។

២៩៩- ពលករត្រូវស្ថិតក្រោមការគាបសង្កត់ជាប្រចាំឱ្យធ្វើការជាទម្ងន់ និងត្រូវស្ថិតក្នុងការ តាមដានជាប្រចាំ។ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យដើរដោយសេរីទេ ហើយក៏មិនឱ្យជជែក គ្នាទៅវិញទៅមកដែរ ហើយមានការបំបែកគ្នាជាក្រុម និងមិនអនុញ្ញាតឱ្យមាន ការជំនុំគ្នាទេ។

## ស្ថានភាពអមនុស្សធម៌

៣០០- អាហារសម្រាប់ផ្គត់ផ្គង់ឱ្យពលករមិនបានគ្រប់គ្រាន់ទេ។ ពលករខ្លះបានហូបតែបបរាវ។ ទាហានរបស់កងពលធំ៥០២ ជាអ្នកគ្រប់គ្រងអ្នកជាប់ឃុំទាំងនោះ បានបាយហូប ឬក៏មានសម្លរបន្លែ ដោយមានលាយជាមួយត្រីមួយចំនួន ។ មានពេលខ្លះ របបអាហារមិនគ្រប់គ្រាន់ទេ ហើយវាកាន់តែតិចទៅៗនៅក្រោយឆ្នាំ១៩៧៧។ របបអាហារត្រូវបានផ្គត់ផ្គង់ពីរដងក្នុងមួយថ្ងៃ ។ មនុស្សភាគច្រើនស្គម ដូចការរៀបរាប់របស់ពលករម្នាក់ដែលនៅរស់ថា“ពលករទាំងនោះអត់អាហារជាខ្លាំង ដូច្នេះហើយ ក្បាលជង្គង់គេធំជាងក្បាលខ្លួនឯងទៅទៀត” ។ ពលករនឹងត្រូវគេសម្លាប់ភ្លាម បើសិនជាគេចាប់បានពេលកំពុងលួចអាហារ។ ផ្ទុយទៅវិញ ពួកអ្នកជំនាញ និងបច្ចេកទេសចិន ព្រមទាំងពួកទាហាន ដែលមានឯកសិទ្ធិ និងធ្វើការផ្ទាល់ជាមួយពួកចិនទាំងនោះ ទទួលបានម្ហូបអាហារគ្រប់គ្រាន់ ព្រមទាំងមានស្រាបៀរផឹកក្នុងពិធីជប់លៀងមួយសប្តាហ៍ម្តងនៅទីរួមខេត្តកំពង់ឆ្នាំង។

៣០១- អ្នកជាប់ឃុំទទួលបានការព្យាបាលពីពេទ្យដែលគ្មានសមត្ថភាព ជាមួយនឹងថ្នាំពេទ្យដែលធ្វើនៅក្នុងស្រុក ។ អ្នកដែលឈឺធ្ងន់ត្រូវគេដឹកទៅមន្ទីរពេទ្យវត្តព្រះទ្វារ ឬក៏ដឹកយកទៅក្រុងកំពង់ឆ្នាំង ប៉ុន្តែអ្នកដែលត្រឡប់មកវិញមានចំនួនតិចតួច។ ពលករដែលគេបង្ខំឱ្យធ្វើការនេះមួយចំនួនធំបានរងរបួសធ្ងន់ ឬក៏ស្លាប់ដោយសារតែថ្មខ្ទាតត្រូវពេលគេបំផ្ទុះភ្នំដើម្បីយកថ្ម។ ផ្ទុយពីវិស្វករ

ពួកពលករគ្មានការការពារពីគ្រាប់បែកទាំងនោះទេ។ អ្នកជាប់ឃុំខ្លះទៀតធ្លាក់ពីលើផ្ទាំងថ្ម ក្នុងពេលកំពុងធ្វើជីករូងភ្នំ ដើម្បីធ្វើរោងយន្តហោះ ។ គ្រោះថ្នាក់បែបនេះកើតមាន ជារៀងរាល់ថ្ងៃ។ ពលករជាច្រើនរាប់រយរាប់ពាន់នាក់បានស្លាប់ ដោយធ្វើការហួសកម្លាំង ខ្វះជីវជាតិ នឿយហត់ខ្លាំង និងកើតជំងឺផ្សេងៗពេលធ្វើការនៅ ទ.ក.ព.ក។ ដោយសារតែចំនួនពលករបានកើនឡើង ស្ថានភាពការងារ និងស្ថានភាពសុខភាពកាន់តែយ៉ាប់យ៉ឺនឡើង ចំនួនមនុស្សស្លាប់ក៏កាន់តែកើនឡើងដែរ។ សាកសពត្រូវបានដឹកចេញ និងកប់ក្នុងរណ្តៅក្បែរព្រៃនៅជិតវត្តស្ទឹង។ ដោយសារស្ថានភាពការងារមិនអាចទ្រាំទ្របាន មានការសម្លាប់ខ្លួនកើតឡើងជារៀងរាល់សប្តាហ៍ ដោយអ្នកធ្វើអត្តឃាតរត់ចូលកង់ឡាន ឬកង់រ៉ូឡូ។

## ការចាប់ខ្លួន និងឃុំឃាំងដោយខុសច្បាប់

៣០២- ពលករ ទ.ក.ព.ក ជាច្រើននាក់ ត្រូវបានចាប់ខ្លួននៅឯជំរុំការងារ ហើយដឹកយកចេញក្រៅ ជួនកាលគេយកទៅឃុំឃាំងក្នុងមន្ទីរសន្តិសុខ។ ការចាប់ខ្លួនត្រូវបានធ្វើឡើងចំពោះការប្រព្រឹត្តិបទល្មើសផ្សេងៗដូចជា មានទំនាក់ទំនងជាមួយវៀតណាម ការធ្វើឲ្យខូចខាតឧបករណ៍ ការមិនបានអនុវត្តតាមផែនការដែលដាក់ឲ្យធ្វើ និយាយស្តីមិនគោរពវិន័យ ខ្ជិលច្រអូស ឬឈឺសតិអារម្មណ៍ លួចអាហារ ឬលួចថ្នាំជក់ លួចរត់ ឬឈឺច្រើន។ ការចាប់ខ្លួនកើតមានជារៀងរាល់ថ្ងៃ ហើយការចាប់ខ្លួនធ្វើឡើងនៅពេលយប់។ អ្នកដែលត្រូវគេចាប់ខ្លួន ត្រូវបានគេប្រាប់ថា ខ្លួនត្រូវទៅចូលរួមប្រជុំរៀនសូត្រ ឬទៅច្រូតស្រូវ ។ នៅពេលទៅដល់ការិយាល័យ [redacted]ភ្លាម ពួកគេត្រូវភ្ជង់ដោយកាំភ្លើង ហើយចាប់ចង មុនពេលចាប់ចងដាក់ក្នុងឡានបើកចេញទៅ។

៣០៣- នៅត្រឹមចុងឆ្នាំ១៩៧៨ ពេលដែលមានការវាយប្រហារធ្ងន់ធ្ងរពីសំណាក់កងទ័ពវៀតណាម ពួកអ្នកជាប់ឃុំនៅ ទ.ក.ព.ក រាប់ពាន់នាក់ ត្រូវគេបង្ខំឱ្យចូលធ្វើទាហានឡើងវិញ ហើយបញ្ជូនទៅសមរភូមិវាយប្រយុទ្ធជាមួយវៀតណាម។

## ការសម្លាប់ដោយខុសច្បាប់

៣០៤- ពួកអ្នកជាប់ឃុំនៅ ទ.ក.ព.ក ជាទូទៅត្រូវបានគេយកទៅផ្លូវជាតិលេខ៥ ហើយតម្រង់ឆ្ពោះទៅភ្នំពេញ ដើម្បីសម្លាប់នៅកន្លែងមួយដែលមិនស្គាល់ ឬក៏នៅទិសអមលាំង ត្រង់ម្តុំភ្នំពាមលោក ដែលមានចម្ងាយប្រហែល៥គីឡូម៉ែត្រ ពី ទ.ក.ព.ក ក្បែរស្ថានីយ៍រថភ្លើងរមាស ឬជួនកាលគេដឹកយកទៅស-២១។ ពួកពលករដែលរបួស និងពិកា ត្រូវបានគយកទៅ សម្លាប់នៅអមលាំង ដោយមេបញ្ជាការកងអនុសេនាធំ[redacted] បន្ទាប់ពីត្រូវបានគេ ប្រាប់ថា គេយកទៅច្បាំងគ្នា។ ការសម្លាប់ចេះតែកើនឡើងជាលំដាប់។

៣០៥- បន្ថែមនៅលើការចាប់ខ្លួន និងសម្លាប់ដែលកើតឡើងនៅឯ ទ.ក.ព.ក ក្នុងរយៈពេលកំពុងដំណើរការសាងសង់នេះ ពួកអ្នកជាប់ឃុំឃាំងខុសច្បាប់ជាច្រើននាក់ ត្រូវបានគេសម្លាប់ជាលើកចុងក្រោយទៀតបន្ទាប់ពីថ្ងៃ០៦ ខែមករា ឆ្នាំ១៩៧៩ នៅឯស្រុកទឹកផុស ស្រុក១៣ នៃតំបន់៣១ ។ ពួកអ្នកជាប់ឃុំដែលគេសម្លាប់នៅពេលនោះ គឺជាអ្នកដែលគេរកឃើញថា មាននិន្នាការជាមួយពួកភូមិភាគបូព៌ា។ បន្ទាប់ពីការជម្លៀសពួកអ្នកទាំងនោះចេញពី ទ.ក.ព.ក និងបន្ទាប់ពីបានដុតគ្រឿងម៉ាស៊ីន និងឧបករណ៍រួចហើយ អតីតយោធារបស់ភូមិភាគបូព៌ាជាច្រើននាក់ត្រូវបានសម្លាប់នៅម្តុំវត្តមង្គលខណ្ឌ ស្ថិតនៅឯភូមិវត្ត ដោយពួកទាហានប្រហែល១០០នាក់មកពីស្រុក១៤ នៃស្រុកទឹកផុស។ យោធាបូព៌ាផ្សេងទៀតរាប់ពាន់នាក់ត្រូវបានចាប់ចង និងដឹក

តាមឡានទៅស្ថានីយ៍រថភ្លើងរមាស និងសម្លាប់នៅអតីតបន្ទាយបារាំង (ស្ថិតនៅចម្ងាយប្រហែល២០ម៉ែត្រ ពីផ្លូវលេខ៥៣) ដោយអ្នកទាំងនោះត្រូវគេអារក ។ អ្នកឯទៀតត្រូវគេសម្លាប់នៅវត្តទួលខ្ពស់។

## អាពាហ៍ពិពាហ៍ដោយបង្ខំ

### សេចក្តីផ្តើម

៣០៦- ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាពាហ៍ពិពាហ៍ដោយបង្ខំ បានចាប់ផ្តើមមានឡើងតាំងពីដើមឆ្នាំ ១៩៧៥ និងបានបន្តរហូតដល់ក្នុងអំឡុងឆ្នាំ១៩៧៩។ អាពាហ៍ពិពាហ៍ដោយបង្ខំ បានចាប់ផ្តើមកើតមាននៅតាមភូមិភាគរបស់កម្ពុជាប្រជាធិបតេយ្យទាំងអស់ និងគ្រប់កំរិតទាំងអស់នៃឋានានុក្រមរបស់បក្សកុម្មុនីស្តកម្ពុជា។ អាពាហ៍ពិពាហ៍ដោយបង្ខំនេះ ត្រូវបានគេដាក់ឲ្យអនុវត្តនៅថ្នាក់ក្រោមដូចជា ភូមិ ឃុំ និងនៅក្នុងអង្គភាពយោធា ព្រមទាំងនៅថ្នាក់ខ្ពស់ក្នុងបណ្តាក្រសួងផ្សេងៗ។

### ការបង្កើតគោលនយោបាយ

៣០៧- គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ បានហ៊ុំព័ទ្ធក្នុងរង្វង់នៃមនោគមវិជ្ជា ដែលថាការរំដោះបំផ្លូលផ្លូវចិត្ត និងសេចក្តីស្នេហាបុគ្គល លែងជាផ្នែកនៃដំណើរការនៃការជ្រើសរើសគូស្រករសម្រាប់ជីវិតទៀតហើយ។ ការគាបសង្កត់ខាងផ្លូវភេទ បានក្លាយទៅជាគោលនយោបាយគំរូ ហើយនរណាម្នាក់ដែលជាប់សង្ស័យក្នុងសកម្មភាពខាងផ្លូវភេទក្រៅពីរង្វង់សកម្មភាពដែលបានរៀបចំឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេចាត់ទុកថា

ជាអ្នកទោសខុសសីលធម៌ ដែលអាចឱ្យគេផ្តន្ទាទោសបាន ដែលផលវិបាកមានចាប់ពី ការបញ្ជូនទៅអប់រំឡើងវិញ ទៅមន្ទីរពន្ធនាគារ ឬសម្លាប់តែម្តងដើម្បីទុកជាឧទាហរណ៍។

៣០៨- គោលនយោបាយបានផ្តល់អាណត្តិឱ្យបក្ស ក្នុងនាមជាអង្គការ ដើម្បីដាក់បង្ខំឱ្យជនណាម្នាក់ចាប់គូជាមួយនឹងអ្នកណាម្នាក់ ហើយបង្ខំឱ្យរៀបការតែម្តង ដើម្បីកសាង"គ្រួសារបដិវត្ត"។ សេចក្តីសម្រេចទាំងនេះ តម្រូវឱ្យ"គោរពតាមដាច់ខាត" ហើយការជំទាស់ជាទូទៅ មិនអនុញ្ញាតឡើយ។ នៅពេលព្រឹត្តិការណ៍នៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានបញ្ចប់ បក្សនៅតែបន្តបង្គាប់បញ្ជាទៅលើការធ្វើអន្តរកម្ម ដូចជាសម្ពន្ធភាពខាងផ្លូវភេទដោយបង្ខំ រវាង គូស្រករថ្មីថ្មោងក្មេងក្លាយទាំងនេះ។ អាពាហ៍ពិពាហ៍ដោយបង្ខំ និងលទ្ធផលនៃការមានគភ៌ ដោយបង្ខំជាផ្នែកនៃផែនការប្រជាសាស្ត្រមួយរបស់បក្សកុម្មុយនីស្តកម្ពុជាធ្វើឡើងដំបូង ដើម្បី បង្កើន និងធ្វើឱ្យចំនួនប្រជាជនកើនទ្វេដង និងបន្ទាប់មក ហើយជាចុងក្រោយ គឺដើម្បីឱ្យ កម្លាំងពលកម្មកើនទ្វេដង ដើម្បីបង្កើនផលិតកម្មដ៏គំហុក។

៣០៩- ការអនុញ្ញាតឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគេយល់ជាទូទៅថា បានបញ្ជាឡើងដោយ"អង្គការ"។ អាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគេអនុញ្ញាត និងរៀបចំឡើងដោយប្រធានភូមិ ប្រធានគណៈឃុំ និងដោយប្រធានអង្គភាពជាក់លាក់ណាមួយ។ នៅក្នុងអង្គភាពទ័ពជួនកាល យោធានៃបក្សកុម្មុយនីស្តកម្ពុជា ជ្រើសយកស្ត្រីជាជនស៊ីវិលពីតាមភូមិ ឃុំ ដើម្បីរៀបការ។ ចំពោះយោធាបក្សកុម្មុយនីស្តកម្ពុជាផងដែរ ក្រោយមានការយល់ព្រមពីអង្គការ ជាញឹកញាប់ តែងតែទទួលបានរង្វាន់ចំពោះការរួមចំណែករបស់ពួកគេចំពោះបដិវត្តន៍ តាមរយៈការជ្រើសរើសគូស្រករនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ មានអង្គភាព និងឃុំមួយ ចំនួន

ដែលបុរសអាចដាក់សំណើសុំរៀបការជាមួយដៃគូណាមួយ។ សំណើនេះ បន្ទាប់មក ត្រូវ បាន គេបញ្ជូនទៅឱ្យប្រធានអង្គភាពនារី ឬមជ្ឈិមបក្ស ដើម្បីសម្រេច។ ទោះបី នារីម្នាក់ នោះ ចង់ជំទាស់នឹងសំណើនេះក៏ដោយ តែផលវិបាកជារឿយៗតែងតែត្រូវបានគេចាត់ទុកថា មានការពិបាកខ្លាំងណាស់ក្នុងការជំទាស់នេះណាស់ ។

៣១០- ការចាត់ចែងរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានគេអនុញ្ញាត និងបញ្ជាធ្វើឡើង ដោយប្រធានគណៈស្រុក និងដោយអាជ្ញាធរថ្នាក់តំបន់។ អាពាហ៍ពិពាហ៍ដោយបង្ខំ ក៏កើត មានឡើងផងដែរ នៅថ្នាក់ភូមិភាគ ពេលមានការអនុញ្ញាតដោយប្រធានភូមិភាគ។ ក្រសួង នានា ដូចជា ក្រសួងពាណិជ្ជកម្ម (ទាំងផ្នែកពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស) និងក្រសួងសង្គមកិច្ច បានបញ្ជា និងអនុម័តលើអាពាហ៍ពិពាហ៍ដោយបង្ខំ។ **អៀង ធីរិទ្ធ** បានរៀបចំ និងអនុម័តឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំនៃបុគ្គលមួយចំនួន ដែលបំរើការងារនៅក្នុងក្រសួងសង្គមកិច្ចដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ អាពាហ៍ពិពាហ៍ដោយ បង្ខំ ត្រូវបានអនុញ្ញាតនៅក្នុងក្រសួងពាណិជ្ជកម្មដែលស្ថិតនៅក្រោម វ៉ាន់ រិត ដែលជាញឹកញាប់ ត្រូវបានធ្វើឡើងបន្ទាប់ពីបុរសបានលើកឈ្មោះនារីជាដៃគូរបស់ខ្លួនជាមួយថ្នាក់លើរបស់គេ និង បន្ទាប់មក ត្រូវមានការអនុម័តយល់ព្រមពីប្រធានអង្គភាពនារី។

៣១១- បុគ្គលដែលបំរើការជិតស្និតនឹងគណៈកម្មាធិការមជ្ឈិម ដូចជានិរសារ និងកងការពារ បានរៀបការដោយផ្ទាល់ តាមរយៈការស្នើរបស់ [redacted] ឬ ប៉ុល ពត។ បន្ទាប់ពីមានសំណើជាក់លាក់ ពីអាពាហ៍ពិពាហ៍ដោយបង្ខំ ក្រោយមកត្រូវមានការឯកភាពពី ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ។ [redacted] អតីតលេខាតំបន់១០៥ បានរ៉ាយរ៉ាប់ថា

នៅពេលប្រជុំមួយជាមួយ ប៉ុល ពត គាត់ត្រូវបាន ប៉ុល ពត បង្គាប់ឲ្យរៀបការ២ ឬ៣គូម្ដង និងជាពិសេស ធានាឲ្យប្រាកដថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា អំពីអាពាហ៍ពិពាហ៍ដោយបង្ខំជាក្រុម ត្រូវបានគេដាក់ឲ្យអនុវត្ត។

## ការប្រាស្រ័យទាក់ទងនៃគោលនយោបាយ

៣១២- គោលនយោបាយបដិវត្តន៍នៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងគំនិតនៃ"ការកសាងគ្រួសារ" ត្រូវបានគេធ្វើការប្រាស្រ័យទាក់ទងគ្នា តាមរយៈការបោះពុម្ពផ្សាយទស្សនាវដ្ដី *យុវជន និងយុវនារីបដិវត្ត* របស់បក្សកុម្មុនីស្តកម្ពុជា ជាពិសេសនៅក្នុងអត្ថបទដែលមានចំណងជើងថា "លោកទស្សនៈបដិវត្តន៍ និងមិនមែនបដិវត្តន៍ ចំពោះបញ្ហាកសាងគ្រួសារ"។ នៅក្នុងការជ្រើសរើសគូស្រករ ការបោះពុម្ពផ្សាយនេះ បានគូសបញ្ជាក់ពីរបៀបដែលសំណើនានា ត្រូវបានស្នើឡើងទៅ"អង្គការ" និងការវាយតម្លៃ និងការសម្រេចរបស់"អង្គការ" ត្រូវតែ"គោរពតាមដាច់ខាត"។ ការបោះពុម្ពផ្សាយនេះ បានធ្វើការប្រាស្រ័យទាក់ទងបន្តទៀតថា ការកសាងគ្រួសារមួយមិនមែនតាម"អ្វីដែលបេះដូងរបស់យើងមើលឃើញ" ឬ"ជាប្រយោជន៍បុគ្គល"ទេ ប៉ុន្តែវាជាការកសាង"គ្រួសារបដិវត្ត"។ ជាការបន្ថែម វាត្រូវបានគេដាក់បញ្ហាថា បក្សនឹងចំរុងចំរើន ទៅបាន លើកលែងតែ"បានប្រគល់គ្រួសារឲ្យបក្ស" និងឲ្យ"សម្ហូហភាព" កសាង។

៣១៣- ការបោះពុម្ពផ្សាយដដែលនេះបានបញ្ជាក់ថា សហព័ន្ធទាំងឡាយមិនត្រូវបានគេទុក "គ្រាន់តែដើម្បីឲ្យដាំស្ល មើលថែទាំកូន និងមើលថែរក្សាផ្ទះសំបែងដូចជាគ្រួសារនានា នៅក្នុងសង្គមចាស់" តទៅទៀតឡើយ។ ទាក់ទងនឹងទិដ្ឋភាពនៃភារកិច្ចគ្រួសារ ប៉ុល ពត បានថ្លែងនៅចំពោះមុខមជ្ឈិមបក្ស នូវសេចក្ដីពន្យល់មួយអំពីផែនការរបស់បក្ស សម្រាប់ឆ្នាំ១៩៧៧-១៩៨០។ គាត់

បានថ្លែងថា ដើម្បីឲ្យសម្រេចតាមគោលដៅនានាស្ដីពីការផលិត ចាំបាច់ត្រូវតែដោះស្រាយបញ្ហាគ្រួសារ ហើយថា"ម្ដាយមិនត្រូវឲ្យជាប់ជំពាក់ជាមួយកូនៗខ្លាំង ពេកនោះទេ" ដោយសារគោលដៅរបស់បក្សតម្រូវឲ្យម្ដាយត្រូវទៅធ្វើការវិញ ដើម្បីសម្រេចឲ្យ បានទៅតាមតម្រូវការនៃការផលិត"។ ផែនការរបស់បក្សបានគូសបញ្ជាក់ អំពីគោល នយោបាយមួយក្នុងការផ្ដល់នូវការត្រួតមើលទៅលើកូនៗដែលទើបនឹងកើតហើយ និងកុមារ តូចៗ នៅក្នុងពេលដែលម្ដាយត្រូវបានបំបែកចេញ នៅក្នុងអំឡុងពេលទៅបំពេញការងារ នៃពលកម្មដោយបង្ខំ។

៣១៤- ការទំនាក់ទំនងស្ដីពីការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងពេលនោះ គឺមានការផ្ញើមកនូវលិខិតនានា ពីខាងឃោឆាមកជូនតាមឃុំនានាដែលស្នើសុំឲ្យផ្ដល់ស្រីៗ។ ព័ត៌មានទាក់ទងអំពីការអនុវត្តន៍នូវគោលនយោបាយស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ក៏ត្រូវបានគេផ្ញើជូនតាមរបាយការណ៍នានាផងដែរ ជាក់ស្ដែង ការខុសសីលធម៌ផ្សេងៗ មានដូចជា ការមិនអនុញ្ញាតឲ្យមានការប្រព្រឹត្តិការរួមភេទក្រៅអាពាហ៍ពិពាហ៍។ ឧទាហរណ៍ដូចជា ការប៉ុនប៉ងក្នុងការរួមភេទជាមួយស្ត្រី គឺត្រូវបានចោទប្រកាន់បន្ទាប់ពីគេសង្កេតឃើញនៅក្រោយពេលមានទំនាក់ទំនងជាមួយគ្នា ហើយក៏ត្រូវបានគេរាយការណ៍ទៅមជ្ឈិមបក្ស។ មានសេចក្ដីរាយការណ៍បន្ថែមនានាលើសពីនេះទៀតជូនមជ្ឈិមបក្ស ដែលរៀបរាប់យ៉ាងលំអិត អំពីការជំទាស់ចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ទោះបីជាគូស្រករដែលត្រូវគេបង្ខំនោះ បាន រួមដំណេកជាមួយគ្នាហើយក៏ដោយ។

៣១៥- ការប្រជុំត្រូវបានគេធ្វើឡើង ដើម្បីផ្សព្វផ្សាយដល់ប្រជាជនទូទៅ ឲ្យបានយល់ដឹងអំពីអត្ថន័យនៃពាក្យខុសសីលធម៌ ហើយក្នុងករណីខ្លះបានលើកយកករណីអ្នកដែលបានប្រព្រឹត្តនូវកំហុសនេះ

ហើយបានធ្វើការប្រមាថមើលងាយដល់អ្នកទាំងនេះជាសាធារណៈ។ សូម្បីតែកុមារៗ នៅ ក្នុង អំឡុងពេលទទួលនូវការអប់រំដែលមានកំរិតក៏ដោយ ក៏ពួកគេត្រូវបានគេបង្រៀនឱ្យយល់ ដឹងអំពីគោលនយោបាយ "ប្ដីមួយ-ប្រពន្ធមួយដែរ" និងអំពីថាតើពួកអ្នកខុសសីលធម៌ នឹងត្រូវ គេ"កំទេចចោល"យ៉ាងដូចម្ដេចខ្លះ?។ នៅក្នុងអង្គប្រជុំប្រចាំឆ្នាំថ្នាក់តំបន់ពិសេសដោយឡែក មួយក្រោមអធិបតីភាពរបស់ [redacted] នៃតំបន់១៣ គោលនយោបាយស្ដីពីការរៀបអាពាហ៍ ពិពាហ៍ដោយបង្ខំ ត្រូវបានគេលើកយកមកពិភាក្សានៅក្នុងអង្គប្រជុំ ដែលធ្វើឡើងនៅឯភ្នំ ខ្ពង។ គោលនយោបាយ "ប្ដីមួយ-ប្រពន្ធមួយ" ត្រូវបានលើកយកមកពិភាក្សា ហើយ [redacted] បានបញ្ជាថា អ្នកណាដែលបានប្រព្រឹត្តខុសសីលធម៌ គឺត្រូវតែ"កំទេចចោល"។

## អំពីការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំ

៣១៦- មុនពេល ប.ក.ក បានឡើងកាន់អំណាច ជាទូទៅ ការរៀបអាពាហ៍ពិពាហ៍ គឺធ្វើឡើងដោយ ឪពុកម្ដាយនៃអ្នកទាំងឡាយ ដែលត្រូវចូលរួមក្នុងនោះ។ តាមប្រពៃណី គ្រួសារខាងកូនស្រីគឺ ជាអ្នកផ្ដល់ការយល់ព្រមនៅក្នុងការរៀបអាពាហ៍ពិពាហ៍ សម្រាប់គូភាគីដែលមានបំណងចង់រៀប ការ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ឪពុកម្ដាយលែងត្រូវបានគេឱ្យចូលរួមនៅក្នុងពិធី អាពាហ៍ពិពាហ៍តទៅទៀតហើយ ដោយសារតែបក្សបានដណ្ដើមយកតួនាទី នៅក្នុងការជ្រើស រើសគូស្រករនេះ។ ជាទូទៅ ឪពុកម្ដាយមិនដែលត្រូវបានគេអនុញ្ញាតឱ្យចូលរួម ឬ ដឹងឮ អំពីព្រឹត្តិការណ៍នៃការរៀបអាពាហ៍ពិអាហ៍ដោយបង្ខំទេ ដោយសារ អង្គការបានរៀបចំអ្វីៗ សព្វគ្រប់អស់ហើយ។ ព្រឹត្តិការណ៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាញឹកញាប់

គេតែងតែហៅថា ការធ្វើ"ការប្ដេជ្ញាចិត្ត" នៅក្នុងអង្គប្រជុំមួយ ដែលប្រៀប បានទៅនឹងការរៀបអាពាហ៍ពិពាហ៍មួយតាមបែបប្រពៃណី នៅក្នុងប្រពៃណីតាមវប្បធម៌របស់កម្ពុជា។

៣១៧- អ្នកដែលត្រូវមានសិទ្ធិនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាតួយ៉ាង គឺសំដៅចំពោះស្ត្រីដែលមានអាយុពី២០ឆ្នាំឡើងទៅ និងបុរសដែលមានអាយុពី២៥ឡើងទៅ។ ក្នុងការជ្រើសរើសដៃគូដែលត្រូវរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាញឹកញាប់ អាជ្ញាធរនានាតែងតែប្រើប្រាស់នូវធាតុផ្សំនយោបាយមួយដែលមានការរើសអើង។ តាមការអនុវត្តន៍ជាក់ស្ដែង ជនទាំង ឡាយដែលត្រូវបានគេចាត់ទុកថាជា"ប្រជាជនមូលដ្ឋាន" អាចនឹងរៀបអាពាហ៍ពិពាហ៍ដោយការបង្ខំបានតែជាមួយអ្នកដែលត្រូវបានចាត់ទុកថាជា"ប្រជាជនមូលដ្ឋាន"ដែរតែប៉ុណ្ណោះ។ ជនទាំងឡាយដែលត្រូវបានគេចាត់ទុកថាជា"ប្រជាជនថ្មី" ក៏ដូចគ្នាដែរ អាចរៀបការបានតែជាមួយ"ប្រជាជនថ្មី"តែប៉ុណ្ណោះ ហើយប្រជាជនដែលត្រូវបានចាត់ទុកថាជា ប្រជាជន ត្រៀម គឺមានការកំរិត ឲ្យរៀបអាពាហ៍ពិពាហ៍បានត្រឹមតែជាមួយនឹងប្រជាជនត្រៀមផ្សេង ទៀតតែប៉ុណ្ណោះ។ ជនស៊ីវិលជនជាតិចាម ត្រូវបានគេប្រាប់ឲ្យដឹងថាត្រូវតែរៀបអាពាហ៍ ពិពាហ៍ជាមួយនឹងជនដែលមិនមែនជាជនជាតិចាម។

៣១៨- ការប្រជុំរៀបគូស្រករជាក្រុមដែលមានលក្ខខណ្ឌតម្រូវ ដោយរើសអើង តែងតែត្រូវបានគេបង្កើតឡើងជាញឹកញាប់តាមទំនើងចិត្ត។ នៅពេលខ្លះពួកគេ ត្រូវបានគេផ្ដល់ជាចំនួនមក ដោយស្នានៗ ដើម្បីឲ្យចាប់គូជាមួយអ្នកដែលមានភេទផ្ទុយដែលមានចំនួនស្មើគ្នា នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ជាក្រុម។ មានពេលខ្លះទៀត អ្នកដែលមានភេទផ្ទុយ ត្រូវគេឲ្យឈរទន្ទឹមគ្នាជាជួរៗ តាមបណ្ដោយជញ្ជាំង ហើយឲ្យដើរតម្រង់មករកគ្នាទៅវិញទៅមក ដើម្បីចាប់ គូគ្នា។

ក្រុមដែលត្រូវបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានចំនួនចាប់ពី៣គូរ ដល់ រាប់១០០គូ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំទាំងនេះ។ នៅក្នុងពិធីរៀប អាពាហ៍ពិពាហ៍ដោយបង្ខំនានាដែលមានខ្នាតធំជាងនេះ គឺមានចំនួនមនុស្សយ៉ាងច្រើនចាប់គូគ្នា ដែលបន្ទាប់មក ធ្វើឱ្យពួកគេមិនអាចចំណាំគ្នាទៅវិញទៅមកបាន។ មានគម្លាតគ្នានៅក្នុង ប្រព្រឹត្តិកម្មបែបនេះ ដោយសារតែមានករណីខ្លះ មានកម្មាភិបាលខ្មែរក្រហមដែលមានថ្នាក់ ខ្ពស់ជាង បានរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្ត ដោយមានវត្តមានសមាជិកគ្រួសារចូលរួម ផង ដូចជាករណី កាំង ហ្កេកអ៊ាវ *ហៅ* ឌុច ជាដើម។ល។ ចំនួនសរុបនៃអ្នកដែលត្រូវ បានគេឱ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺ មិនមានច្បាស់លាស់ទេ ក៏ប៉ុន្តែតាមការប៉ាន់ស្មាន ថាមានចំនួនជនរងគ្រោះជាច្រើនរយពាន់នាក់។ ឧទាហរណ៍ ដូចជា តាមការសិក្សាស្រាវជ្រាវដែលបានធ្វើឡើង បានរកឃើញថា ក្នុងចំណោមលោកសង្ឃទាំង៦៨អង្គដែលគង់នៅក្នុងវត្តជំនីកកាលពីមុនរបបនេះ គឺមានលោកសង្ឃសរុបចំនួន៤០អង្គ ដែលត្រូវបានគេឱ្យចូលរួមនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយ បង្ខំ។

៣១៩- នៅក្នុងអំឡុងពេលនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទីមួយ៖ គូស្រករទាំងនោះត្រូវបានគេតម្រូវឱ្យធ្វើការប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់ និងធ្វើសេចក្ដីសម្រេចចិត្តបំរើអង្គការ ហើយទីពីរ៖ ត្រូវទទួលយកគូស្រកររបស់ខ្លួនជារៀងរហូត។ ការបំរើអង្គការ រួមមាន ការប្ដេជ្ញាចិត្តក្នុងការ បង្កបង្កើនផល ការគោរពអង្គការ ការធ្វើពលកម្មឱ្យខ្លាំង ការផលិតស្រូវឱ្យបានមួយ ចំនួន និងត្រូវមានភាពស្មោះត្រង់ជាមួយអង្គការ។ ដៃគូខ្លះត្រូវបានគេសួរថា តើពួកគេ ស្រឡាញ់គ្នា និងព្រមទទួលយកគ្នាទៅវិញទៅមកដែរ ឬទេ។ ទោះបីជាភាគីអាចឆ្លើយថា យល់ព្រមទទួល

យកអាពាហ៍ពិពាហ៍នោះក៏ដោយ ក៏ជាញឹកញាប់ ការយល់ព្រមនោះត្រូវបាន សម្តែងចេញមក ដោយផ្ទុយពីឆន្ទៈរបស់គូភាគី យ៉ាងហោចណាស់ ក៏ផ្ទុយពីឆន្ទៈរបស់ភាគីម្ខាង ដែរ។

៣២០- ពួកកម្មាភិបាល ប.ក.ក បានប្រើប្រាស់វិធីសាស្ត្រប្លែកៗពីគ្នា ដើម្បីបង្ខំដៃគូឱ្យសុខចិត្តយល់ព្រម ទទួលយកអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយវត្តមានរបស់ពួកគេ នៅពេលអាពាហ៍ពិពាហ៍ ដោយបង្ខំមួយចំនួន បានរារាំងកុំឱ្យមានការរត់គេច។ ពួកអ្នកជំទាស់ត្រូវបានគេយកទៅកាន់មណ្ឌលធ្វើការអប់រំកែប្រែជាការដាក់ទណ្ឌកម្ម ដូច្នេះនៅពេលត្រឡប់មកវិញពួកគេក៏ស្រុះស្រួលសុខចិត្តរៀបអាពាហ៍ពិពាហ៍ ដោយខ្លាចគេបញ្ជូនត្រឡប់ទៅវិញ។ បុគ្គលដែលប៉ុនប៉ង បដិសេធក៏ត្រូវបានគេបង្ខំផងដែរ ដោយមានការគំរាមកំហែង ឬក៏ជាក់ស្តែងត្រូវបានគេបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងយោធាពិការណាម្នាក់ បញ្ជូនត្រឡប់ទៅធ្វើការអប់រំកែប្រែវិញ ដាក់គុក ឬបញ្ជូនទៅកាន់ការដ្ឋានពលកម្មដោយបង្ខំណាមួយ។ ទីបញ្ចប់ ពួកអ្នកជំទាស់ត្រូវបានគេគំរាមកំហែង ឬជាក់ស្តែងត្រូវបានគេវាយ ឬធ្វើទារុណកម្ម រំលោភសេពសន្ថវៈ និងក្នុងករណីខ្លះផ្សេងទៀត ត្រូវបានគេសម្លាប់ចោល។

៣២១- នៅក្នុងករណីជាច្រើន ភ្លាមៗបន្ទាប់ពីការប្តេជ្ញាចិត្ត ត្រូវបានធ្វើឡើង គូស្រករត្រូវបានគេបញ្ជាឱ្យនៅជាមួយគ្នា២ ទៅ៣ថ្ងៃ ដើម្បីរួមដំណេកជាប្តី-ប្រពន្ធ ក្នុងគោលបំណងដើម្បីបង្កើត កូន។ ការដែលត្រូវបានគេរៀបអាពាហ៍ពិពាហ៍ឱ្យដោយបង្ខំទាំងនេះ ជាទូទៅ គឺស្ថិតនៅ ក្រោមជំនឿមួយដែលថាបើការរួមភេទជាមួយគ្នាពុំបានកើតឡើងទេនោះ ជាផលវិបាកពួកគេ នឹងត្រូវបានគេ “កំទេច” វាយធ្វើបាប ឬត្រូវបានគេបញ្ជូនទៅធ្វើការអប់រំកែប្រែ។ នៅក្នុងអំឡុងពេលការរួមដំណេកដោយបង្ខំលើកទីមួយនេះ ជួនកាលមានពួកឈ្លប ប.ក.ក តាមឃ្លាំ

មើលនូវសកម្មភាពតាមផ្លូវភេទនានា ដោយការលួចស្តាប់ការណ៍សម្ងាត់ នៅតាមផ្ទះដែលគេបានចាត់តាំងឱ្យ។ បន្ទាប់ពីបានតាមឃ្លាំមើលរួចមក ជាទូទៅ ពួកគូស្រករដែលត្រូវបានគេបង្ខំទាំងនោះ ត្រូវបានបំបែកចេញ ហើយបញ្ជូនត្រឡប់ទៅកាន់ការដ្ឋានរៀងៗខ្លួនវិញ។ ដោយស្ថិតនៅលើមូលដ្ឋានជាប់ជានិច្ចមួយ បន្ទាប់ពីមានការជួបគ្នាជាលើកទីមួយរួចហើយ គូស្រករដែលត្រូវបានគេបង្ខំទាំងនោះ ត្រូវបានគេណែនាំ ជាពិសេស ពីពេលដែលត្រូវជួបគ្នាជាថ្មី ដូចជា ចំនួន២ ទៅ៣ដងក្នុងមួយខែ នៅពេលដែលខាងស្ត្រីអាចបន្តពូជបាន។

៣២២- ជនរងគ្រោះត្រូវបានគេប្រាប់ឱ្យដឹងថា គោលបំណងរបស់ពួកគេពីការឱ្យមានដៃគូអាពាហ៍ពិពាហ៍ដោយបង្ខំនេះ គឺដើម្បីបង្កើតជាគ្រួសារមួយ មិនមែនសម្រាប់ពួកគេទាំងនោះទេ គឺដើម្បី "អង្គការ"។ មានពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនានា ដែលដៃគូបានសន្យាថានឹងបង្កើតកូនបានមួយ ក្នុងរយៈពេលមួយឆ្នាំ។ ការរួមដំណេកដោយបង្ខំ ពិតជាបានលេចចេញលទ្ធផលនាំមកនូវការមានផ្ទៃពោះដោយបង្ខំ។ ជាញឹកញាប់ ការណ៍ទាំងនេះបានតម្រូវឱ្យ ជនរងគ្រោះជាស្ត្រី បំពេញករណីយកិច្ចនានា អំពីការបន្តថែរក្សាកូន ក្នុងអំឡុងពេលទារកភាព មុននឹងត្រូវបានបំបែកចេញដោយកម្មាភិបាល ប.ក.ក។ ជាញឹកញាប់ពួកក្មេងៗ ត្រូវបានគេ បំបែកចេញពីឪពុក-ម្តាយ ហើយបញ្ជូនទៅធ្វើការ កាលណាដល់អាយុជាក់លាក់ ណាមួយ ដូចជាយ៉ាងឆាប់ ចាប់ពីអាយុ៣ឆ្នាំ រហូតដល់៥ឆ្នាំ។ គោលនយោបាយបក្សបាន ប៉ុនប៉ងធ្វើការកាត់បន្ថយការថែរក្សាកូនក្មេងឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យ ម្តាយអាចនឹងត្រូវបានគេប្រើ ឱ្យធ្វើពលកម្មដោយបង្ខំ ជាជាងទុកឱ្យចិញ្ចឹមអប់រំគ្រួសារ។ ជាងនេះទៀត បក្សបានបញ្ជាថាសហព័ន្ធណាម្នាក់ក៏ដោយ គឺលែងឱ្យធ្វើការដាំស្ល និងការបោសសម្អាតទៀតហើយ គឺថាកិច្ចការទាំងនេះត្រូវប្រគល់ឱ្យទៅសហករណ៍ជាអ្នកធ្វើ ជំនួសវិញ។

៣២៣- ជនរងគ្រោះ ទាំងបុរស ទាំងស្ត្រី ត្រូវបានគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងអ្នកចម្លែក ដែលគេមិនបានស្រឡាញ់ ហើយជាលទ្ធផល គឺបានទទួលរងនូវទុក្ខវេទនាតាមផ្លូវចិត្ត។ បន្ថែមលើនេះ មានជនរងគ្រោះខ្លះ ត្រូវបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ទោះបីជាគេកំពុងចាប់ចិត្តស្រឡាញ់ជាមួយនឹងអ្នកផ្សេងទៀតក៏ដោយ ឬកំពុងឋិតនៅជាមេម៉ាយដែលកំពុង កើតទុក្ខ ឬ(អតីត)ព្រះសង្ឃដែលបានស្បថថានឹងនៅលីវ។ របួសតាមផ្លូវចិត្តដែលកើត ចេញពីអាពាហ៍ពិពាហ៍ដោយបង្ខំ គឺមានលក្ខណៈធ្ងន់ធ្ងរណាស់ ដែលថាជនរងគ្រោះមួយចំនួនបានធ្វើអត្តឃាត ដោយការលោតទឹក ឬការបំពុលដោយខ្លួនឯង។

៣២៤- នៅពេលមានអាពាហ៍ពិពាហ៍ដោយបង្ខំកើតមាន សេចក្តីស្រឡាញ់បែបស្នេហា ឬគ្រួសារត្រូវបានហាមឃាត់។ គោលនយោបាយនៃការទាក់ទងគ្នាតាមផ្លូវភេទដោយបង្ខំនេះ បានបណ្តាលឲ្យជនរងគ្រោះមានការក្រៀមក្រំក្នុងចិត្ត មានជម្ងឺ និងមានភាពមិននឹងនរក្នុង ចិត្ត។ ជាប្រតិកម្មទៅនឹងគោលនយោបាយនៃភាពដាច់មុខរវាងដៃគូអាពាហ៍ពិពាហ៍ដោយ បង្ខំនេះ មានជនរងគ្រោះខ្លះបានក្លាយទៅជាមានសកម្មភាពខាងផ្លូវភេទ ដែលស្ថិតនៅខាងក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយបើសិនជាត្រូវចាប់បាននោះ ពួកគេនឹងត្រូវទទួលរងនូវការវាយឲ្យមានរបួសស្នាមខាងរាងកាយដែលបង្កឡើងដោយពួកកម្មាភិបាល ប.ក.ក។ បន្ថែមលើ នេះ តួយ៉ាង កាលណាជន រងគ្រោះដែលបានបដិសេធមិនយកអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានសម្លាប់ចោល។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ទៅ មានស្ត្រីជាច្រើននាក់បានទទួលរងនូវការឈឺចាប់ក្នុងភាពស្ងប់ស្ងាត់អំពីអំពើហិង្សាខាងផ្លូវភេទដែល ពួកគេបានទទួលរង ដោយសារតែមានការភ័យខ្លាចថា អាចនឹងមានភាពអាម៉ាស់។

# មន្ទីរសន្តិសុខ

## មន្ទីរសន្តិសុខស-២១

### ទីតាំង និងប្រតិបត្តិការ

៣២៥- មន្ទីរសន្តិសុខស-២១ ត្រូវបានបង្កើតឡើងក្រោយពេលមានការប្រជុំមួយនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ដែលពេលនោះ សុន សេន បានណែនាំ អ៊ិន លន ហៅ ណាត ជា លេខាកងពល ៧០៣ នៃកងទ័ពបដិវត្តន៍កម្ពុជា និង ឌុច ឲ្យបង្កើតពន្ធនាគារ។ ពន្ធនាគារនេះចាប់ផ្ដើម ប្រតិបត្តិការនៅខែតុលា ឆ្នាំ១៩៧៥ និងដំណើរការរហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមលុកលុយចូលដល់ក្រុងភ្នំពេញ។

៣២៦- ដោយពន្ធនាគារនេះមានការរៀបចំប្រព័ន្ធសន្តិសុខតឹងតែង ពន្ធនាគារនេះដំណើរការទៅតាម សេចក្ដីណែនាំ និងក្រោមការគ្រប់គ្រងផ្ទាល់របស់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។ មុខងារចម្បងរបស់មន្ទីរសន្តិសុខនេះ គឺឃុំឃាំងជនដែលជាប់សង្ស័យថា ជាខ្មាំងរបស់បក្ស កុម្មុយនីស្តកម្ពុជា សួរចម្លើយ និងធ្វើទារុណ្ណកម្មអ្នកទាំងនោះ ដើម្បីទាញយកចម្លើយសារភាព ពាក់ព័ន្ធនឹងសកម្មភាពក្បត់របស់ពួកគេប្រឆាំងនឹងរបបនោះ (ដើម្បីកំណត់អត្តសញ្ញាណខ្មាំង សត្រូវបន្ថែមទៀតដែលស្រង់ចេញពីចម្លើយសារភាពទាំងនោះ និងសម្លាប់អ្នកទោសនោះបន្ទាប់ ពីសួរចម្លើយរួច)។ ជាសំខាន់ គោលបំណងនៃការបង្កើត ស-២១ គឺដើម្បីអនុវត្តផែនការឧក្រិដ្ឋ

របស់បក្សកុម្មុយនីស្តកម្ពុជា នៅថ្នាក់ខ្ពស់បំផុត ក្នុងការលុបបំបាត់ជាប្រព័ន្ធនូវខ្មាំង និង អ្នកប្រឆាំងតាមការស្រមើលស្រមៃ និងជាក់ស្តែង។

៣២៧- ក្នុងនាមជាមន្ទីរសន្តិសុខមួយដែលផ្តោតទៅលើ "ខ្មាំង" ដែលគេចាត់ទុកថាជាការគំរាមកំហែងដល់របបនោះ ស-២១ គឺជាពន្ធនាគារសំខាន់បំផុតនៅក្នុងក្បាលម៉ាស៊ីនដឹកនាំផ្នែកសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាឧបករណ៍សំខាន់ក្នុងការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួម។ ពន្ធនាគារនេះមានលក្ខណៈពិសេស នៅក្នុងទិដ្ឋភាពនានាជាច្រើនដូចជា៖

(១) ពន្ធនាគារនេះធ្វើការដោយផ្ទាល់ក្រោមការគ្រប់គ្រងរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា និងត្រូវរាយការណ៍ដោយផ្ទាល់ដល់មេដឹកនាំជាន់ខ្ពស់ទាំងនោះដែរ។

(២) ពន្ធនាគារនេះជួយសម្រួល និងចូលរួមក្នុងការសម្រិតសម្រាំងកម្មាភិបាល នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា កម្ពុជាប្រជាធិបតេយ្យ និងកងទ័ពបដិវត្តន៍កម្ពុជា នៅក្នុងប្រទេសទាំងមូល ដោយសម្របសម្រួលសកម្មភាពរបស់ពន្ធនាគារជាមួយអាជ្ញាធរយោធា និងរដ្ឋបាលនានាជាច្រើនទៀត។ ឧទាហរណ៍ ពន្ធនាគារនេះបានទទួលអ្នកទោសមកពីគ្រប់អង្គភាពយោធាទាំងអស់ ដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្រប់ក្រសួងនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រួមទាំង មកពីមន្ទីរសន្តិសុខជាច្រើនទៀត។

(៣) ពន្ធនាគារនេះគឺជាពន្ធនាគារដែលធំជាងគេ របស់កម្ពុជាប្រជាធិបតេយ្យ បើគិតពីចំនួនបុគ្គលិក និងមានភាពស្មុគ្រស្មាញជាងគេ ចំពោះដំណើរការក្នុងការឃុំឃាំង ការសួរចម្លើយ និងការសម្លាប់អ្នកទោស។

៣២៨- ស-២១ ដើរតួនាទីយ៉ាងសំខាន់ក្នុងការដំណើរការ របស់ក្បាលម៉ាស៊ីនផ្នែកសន្តិសុខនៃបក្សកុម្មុយនីស្តកម្ពុជា ដោយកំណត់អត្តសញ្ញាណជនក្បត់និងខ្មាំងសត្រូវថ្មីៗ និងការបញ្ជាក់ពីការសង្ស័យរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដែលថា ពួកគេកំពុងស្ថិតក្រោមការគំរាមកំហែង៖ ពន្ធនាគារជាអ្នកស្រង់ចម្លើយសារភាព និងអំណះអំណាងភ័ស្តុតាងនៃសកម្មភាពក្បត់ប្រឆាំងនឹងរបបនោះក៏ត្រូវបានផ្សព្វផ្សាយក្នុងចំណោមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទាំងនោះដែរ។ ការបញ្ជាក់ពីការសង្ស័យរបស់មេដឹកនាំបានជួយជំរុញបន្ថែមទៀត ដែលធ្វើឲ្យស-២១ ចូលរួមជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួច ក្នុងការពង្រីកចរន្តនៃការសម្រិតសម្រាំងនៅទូទាំងប្រទេស។ ក៏ប៉ុន្តែ ប្រការគួរឲ្យចាប់អារម្មណ៍នោះគឺថា ក្នុងការសង្កត់ធ្ងន់ពីសារៈសំខាន់នៃក្បាលម៉ាស៊ីនដឹកនាំផ្នែកសន្តិសុខចំពោះរបបនោះ **ខៀវ សំផន** បានអះអាងថា ស-២១ បានជួយរកមុខខ្មាំងថ្មីៗ និងថែមទាំងដើរតួនាទីជាអ្នកបញ្ជាក់ពីការសង្ស័យផងដែរ។ គាត់ថ្លែងថា៖

'ភ័ស្តុតាង...បានបញ្ជាក់ថា ការតាមដានទាំងប៉ុន្មានរបស់លោកប៉ុលពត ចំពោះចក្រី ឈូក យ៉ា និង អតីតកម្មាភិបាល ដែលបានរួមជាមួយពួកវៀតមិញ តាមគោលការណ៍ ៣-៧-៨ របស់ប៉ុលពតគឺត្រូវ។ ដូច្នេះមិនមែនដូចលោក ហ្វីលិព ហ្សូត សរសេរមិនត្រឹមត្រូវថា "តួនាទីរបស់ពន្ធនាគារ ស-២១ និងសេចក្ដីសារភាពមិនមែនសម្រាប់ផ្ដល់ព័ត៌មានជាសំខាន់នោះទេ គឺ

សម្រាប់តែផ្តល់"ភស្តុតាង" នៃអំពើក្បត់ដែលគេត្រូវការ ដើម្បីចាប់អ្នកណាដែលគេសម្រេចចាប់ខ្លួនរួចទៅហើយ""។

៣២៩- ទោះបីពន្ធនាគារនេះត្រូវបានផ្លាស់ប្តូរទៅទីតាំងមួយចំនួនប៉ុន្មានលើក នៅក្នុងដំណាក់កាលដំបូងៗនៅចុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ក៏ដោយ តែនៅពេលពន្ធនាគារនេះ ត្រូវបានបង្កើតឡើងពេញលេញនោះ វារួមបញ្ចូលទាំងបរិវេណកណ្តាលមួយដែលមានអគារមួយចំនួននៅជុំវិញ មានមន្ទីរនិងអគារឃុំឃាំងនៅក្នុងក្រុងភ្នំពេញ មន្ទីរអប់រំនិងពន្ធនាគារនៅព្រៃស (ស-២៤) និងជើងឯក ដែលជាវាលពិឃាត និងកន្លែងកប់សាកសពធំរបស់ ស-២១។

៣៣០- ស-២១ មានរៀបចំជាប្រព័ន្ធកត់ត្រាកំណត់ហេតុផ្ទៃក្នុង ដើម្បីគ្រប់គ្រងការកត់ត្រា និង"ដំណើរការ" អ្នកទោស ដំណើរការសួរចម្លើយ និងការសម្លាប់អ្នកទោស រួមទាំងទិដ្ឋភាពផ្សេងទៀតនៃប្រតិបត្តិការនៃពន្ធនាគារនេះ។ កំណត់ហេតុរួមមាន ប្រវត្តិរូបអ្នកទោសម្នាក់ៗរូបថត ឯកសារជំរឿនស្ថិតិរបស់អ្នកទោស (រួមទាំងស្ថិតិសម្លាប់ផង) ចម្លើយសារភាពរបស់អ្នកទោស កំណត់ហេតុស្តីពីការហ្វឹកហ្វឺនផ្ទៃក្នុង និងការប្រើទារុណ្ណកម្ម និងឯកសារផ្សេងៗទៀតដែលទាក់ទងនឹងការងាររបស់ពន្ធនាគារនោះ។

## បរិវេណកណ្តាលនៅស-២១

៣៣១- ដូចបានកត់សម្គាល់មកខាងលើរួចមកហើយគឺថា ដំណាក់កាលដំបូងនៃការកកើតពន្ធនាគារនេះពីខែតុលា ឆ្នាំ១៩៧៥ រហូតមក ស-២១ ប្រើអគារបណ្តោះអាសន្នរួមមាន៖ ជាដំបូង ការសួរចម្លើយត្រូវបានធ្វើឡើងនៅក្នុងផ្ទះមួយនៅកែងផ្លូវលេខ១៦៣ និងលេខ៣៦០ រីឯផ្ទះនៅជុំវិញ

នោះត្រូវបានប្រើសម្រាប់ឃុំឃាំងអ្នកទោស។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ស-២១ ត្រូវបានផ្លាស់ទៅបរិវេណ *នគរបាលយុត្តិធម៌* នៅផ្លូវលេខ៥១។ ក៏ប៉ុន្តែ នៅខែមករា ឆ្នាំ១៩៧៦ ដោយមានកង្វល់ថា ភ្ញៀវចិនអាចនឹងឃើញប្រតិបត្តិការទៅលើអ្នកទោសនៅទីតាំងនោះ ស-២១ ត្រូវបានត្រឡប់មកអគារដើមវិញនៅផ្លូវលេខ១៦៣ និងលេខ៣៦០។ នៅខែមេសា ឆ្នាំ១៩៧៦ នៅពេលឌុច ត្រូវបានតែងតាំងជាប្រធានស-២១ មន្ទីរសន្តិសុខនេះត្រូវបានផ្លាស់ជាអចិន្ត្រៃយ៍ទៅ *វិទ្យាល័យពញាយ៉ាត* ដែលបច្ចុប្បន្នត្រូវបានគេស្គាល់ថាជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ជាប់ផ្លូវលេខ១១៣ ១៣១ ៣២០ និង៣៥០។ បរិវេណនេះអាចដាក់អ្នកទោសបានប្រហែល១៥០០នាក់ ក្នុងពេលតែមួយបាន។

៣៣២- ដោយមានការរៀបចំជាទីតាំងដែលមានសន្តិសុខខ្ពស់ បរិវេណកណ្តាលត្រូវបានហ៊ុំព័ទ្ធដោយរបងពីខាងក្រៅ ដែលមានស័ង្កសីបិទជិតកម្ពស់ពីរម៉ែត្រ ដែលខាងលើមានរាយបន្លាលួស ហើយរបងខាងក្នុងធ្វើពីឥដ្ឋកម្ពស់ពីរម៉ែត្រ និងមានចំរឹងដែក។ មានការរាយបន្លាលួសពីរជាន់ទៀតនៅចន្លោះរបងទាំងពីរ៖ បន្លាលួសមួយជាន់រាយចន្លោះរបងខាងក្រៅ និងចំរឹងដែកនៅផ្ទៃខាងក្នុង និងបន្លាលួសមួយជាន់ទៀតគឺរាយនៅរបងខាងក្នុង។ របងទាំងពីរមានរាយខ្សែភ្លើងផងដែរ។

៣៣៣- សន្តិសុខនៅក្នុងបរិវេណនេះត្រូវបានរឹតបន្តឹង ដោយមានអ្នកយាមដែលមានបំពាក់អាវុធ មានច្រើនដំណាក់។ មានកងកម្លាំងអ្នកយាមខាងក្នុង អ្នកយាមចល័តនៅខាងក្រៅរបងនៃបរិវេណកណ្តាល និងអ្នកយាមបន្ថែមដែលចល័តនៅតាមទីតាំងជុំវិញនោះ។

៣៣៤- បរិវេណកណ្តាលស-២១ មានអគារធំៗចំនួនប្រាំ មានអគារ **ក ខ គ ឃ** និង**ង**។ អគារ **ក ខ គ** និង**ឃ** ត្រូវបានប្រើជាអគារឃុំឃាំង។ ដោយរួមជាមួយផ្ទះដែលនៅប៉ែកខាងត្បូងផង អគារ **ក** មានតួនាទីជា "គុកពិសេស" សម្រាប់ដាក់អ្នកទោសសំខាន់ៗ។ ខុសប្លែកពីអ្នកទោសដទៃទៀត ជួនកាលអ្នកទោសប្រភេទនេះ ត្រូវគេធ្វើទារុណ្ណកម្ម និងសួរចម្លើយនៅក្នុងបន្ទប់ឃុំឃាំងផ្ទាល់តែម្តង។ អគារ **ខ គ** និង **ឃ** មានបន្ទប់ឃុំធំៗផង បន្ទប់ឃុំសម្រាប់ម្នាក់ៗផងដែលធ្វើពីឥដ្ឋ មានទំហំបណ្តោយប្រមាណពីរម៉ែត្រ និងទទឹងមួយម៉ែត្រ។ អគារ **ង** ដែលមានកម្ពស់តែមួយជាន់ ស្ថិតនៅចំកណ្តាលបរិវេណត្រូវបានប្រើជារោងជាង និងការិយាល័យរដ្ឋបាល។ ក្រៅពីនេះ អគារនេះក៏ត្រូវបានយកទៅប្រើសម្រាប់ទទួលចុះឈ្មោះ និង ថតរូបអ្នកទោសផងដែរ នៅពេលអ្នកទោសត្រូវបានបញ្ជូនមកដល់ស-២១។

៣៣៥- អគារ និងផ្ទះជាច្រើនដែលមានទីតាំងនៅក្នុងតំបន់គេហដ្ឋានដែលនៅជុំវិញបរិវេណកណ្តាលក៏ត្រូវបានពន្ធនាគារនេះយកទៅប្រើប្រាស់ដែរ។ ទីតាំងដ៏ធំនេះមានប្លុកគេហដ្ឋានប្រមាណ៩៤ ប្លុក ដែលស្ថិតក្រោមការគ្រប់គ្រងផ្តាច់មុខដោយស-២១ គឺចាប់ពីមហាវិថីម៉ៅសេទុង មហាវិថីមុនីវង្ស មហាវិថីសីហនុ និងផ្លូវលេខ១៦៣។ អគារនិងទីតាំងផ្ទាល់នៅក្នុងតំបន់នោះត្រូវបានប្រើសម្រាប់៖ ការងាររដ្ឋបាល រៀនសូត្រនយោបាយ ទទួលអ្នកទោស ផ្ទះបាយរួម ការងារសួរចម្លើយ ការសម្លាប់និងកប់អ្នកទោស អគារមន្ទីរពេទ្យ កន្លែងសម្រាប់បុគ្គលិក ស-២១ ស្នាក់នៅ (រួមទាំងផ្ទះនិងការិយាល័យរបស់ **ឌុច** ផងដែរ) កន្លែងផ្តិតរូបថត និងជាឃ្លាំងផង។

៣៣៦- អ្នកទោសដំបូងគេដែលមកដល់ទីតាំងបណ្តោះអាសន្នស-២១ នៅភ្នំពេញនៅខែតុលា ឆ្នាំ១៩៧៥ ត្រូវបានឃុំឃាំងនៅមន្ទីរពេទ្យឆ្លូតតាខ្មៅ ដែលត្រូវបានកងពល ៧០៣ របស់ ណាត យកមក

ប្រើជាអគារគុក ហើយក៏ត្រូវបានប្រើសម្រាប់បណ្តុះបណ្តាលបុគ្គលិក ធ្វើស្រែ និង ឃុំឃាំងអ្នកទោស នៅពេលដែលស-២១ មិនអាចផ្ទុកអ្នកទោសបាន។ ជនរងគ្រោះដំបូងទាំងនោះទំនងជាត្រូវបានគេបញ្ជូនទៅតាខ្មៅដើម្បីសម្លាប់ និងកប់។ ឃឹម វ៉ាត ហៅ ហ៊ៃ ដែលក្លាយជាអនុប្រធានរបស់ **ឌុច** មានតួនាទីគ្រប់គ្រងតាខ្មៅមុនគេ។ ទីតាំងនេះត្រូវបានប្រើប្រាស់រហូតដល់ពាក់កណ្តាល ឬចុងឆ្នាំ១៩៧៦។ នៅឆ្នាំ១៩៧៧ **ឌុច** បញ្ជាឲ្យកប់ និងដុតសាកសពដែលបានកប់នៅតាខ្មៅ ដោយហេតុថាទីតាំងនេះត្រូវបានប្រគល់ទៅឲ្យក្រសួងសង្គមកិច្ចជាអ្នកគ្រប់គ្រងវិញ។

**ជើងឯក**

៣៣៧- បន្ថែមទៅលើការប្រើប្រាស់ទីតាំងតាខ្មៅ មុនពេលបង្កើតវាលពិឃាតអចិន្ត្រៃយ៍មួយ ការសម្លាប់ និងកប់សាកសពត្រូវបានធ្វើឡើងនៅវាលមួយ ដែលនៅជាប់នឹងបរិវេណកណ្តាលនៃស-២១ និងនៅបរិវេណជុំវិញនោះ។ នៅដើមឆ្នាំ១៩៧៦ ដោយសារមានសាកសពជាច្រើននៅក្នុងតំបន់នេះ និងដោយសារមានលេចឡើងនូវជម្ងឺឆ្លងផងនោះ **ឌុច** បានសម្រេចបង្កើតទីតាំងថ្មីមួយដើម្បីសម្លាប់និងកប់អ្នកទោស។ ចំពោះការងារនេះ **ឌុច** បានជ្រើសរើសវាលបញ្ចុះសពជនជាតិចិនដែលគេហៅថា **ជើងឯក** ដែលមានទីតាំងក្នុងខេត្តកណ្តាល មានចម្ងាយប្រហែល ១៥ គ.ម. ប៉ែកនិរតីនៃក្រុងភ្នំពេញ។

៣៣៨- ទីតាំងជើងឯករួមមាន ផ្ទះឈើមួយខ្នងដែលអ្នកទោសត្រូវបានគេយកទៅទុកមុននឹងយកទៅសម្លាប់ និងជាទីវាលមួយសម្រាប់ជីករណ្តៅធំៗជាច្រើន ដែលប្រើសម្រាប់កប់អ្នកទោសក្រោយពេលសម្លាប់រួច។ ទោះបីជើងឯកក្លាយជាទីតាំងពិឃាតនិងកប់សាកសពរបស់ស-២១ ពីឆ្នាំ

១៩៧៦ ក៏ដោយ តែសូម្បីតែក្រោយពេលបង្កើតទីតាំងនោះហើយក្ដី ក៏នៅមានអ្នកទោសជាច្រើន ត្រូវបានសម្លាប់ និងកប់នៅក្នុងបរិវេណស-២១ ដដែល។

### ស-២៤ (ព្រៃស)

៣៣៩- មន្ទីរឃុំឃាំងដែលគេស្គាល់ថាជា ព្រៃស/ស-២៤ ត្រូវបានបង្កើតឡើងក្នុងរយៈពេលខ្លី ក្រោយព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មុនពេលបង្កើតស-២១ក៏ដោយ តែវាក្លាយជាផ្នែកមួយរបស់ស-២១ នៅពេល ឌុច ធ្វើជាប្រធាន។ មន្ទីរឃុំឃាំងនេះមានទីតាំងនៅទិសទក្សិណ និង និរតីនៃក្រុងភ្នំពេញ និងជាប់ផ្លូវជាតិលេខ២នៅភាគបូព៌ា ជាប់ស្ទឹងព្រែកត្នោតនៅភាគទក្សិណ ជាប់ផ្លូវជាតិលេខ៣ នៅភាគបច្ចិម និងជាប់ជាយក្រុងភ្នំពេញនៅភាគឧត្តរ។

៣៤០- ស-២៤ ត្រូវបានប្រើសម្រាប់ "អប់រំកែប្រែ" អ្នកទោសដែលត្រូវបានជាប់ចោទពីបទថាបានប្រព្រឹត្តបទល្មើសស្រាលៗ។ មន្ទីរឃុំឃាំងនោះគ្រប់គ្រងដោយ នុន ហ៊ុយ ហៅ ហ៊ុយស្រែ ដែលជាអ្នកត្រូវរាយការណ៍ទៅប្រធាន ស-២១ (ដំបូងគឺ ណាត និងក្រោយមកគឺ ឌុច)។ ណាត និង ឌុច បានបង្កើតជំរុំធ្វើការដោយបង្ខំ ឬ"អប់រំកែប្រែ" នៅស-២៤ នោះ។ ការអប់រំកែប្រែដែលអះអាងមកនោះធ្វើឡើងតាមរយៈ ការបង្ខំឱ្យធ្វើការជាទម្ងន់ជាការផ្ដន្ទាទោស រួមទាំងការធ្វើស្រែផងដែរ។ ផលិតផលដែលផលិតបាននៅស-២៤ ត្រូវយកមកប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចដល់ ស-២១។

### រចនាសម្ពន្ធគ្រប់គ្រង

### ការគ្រប់គ្រងពីលើមន្ទីរសន្តិសុខនេះ

៣៨១- ដូចបានកត់សម្គាល់ខាងលើរួចមកហើយគឺថា ស-២១ ប្រតិបត្តិការក្រោមបញ្ជាផ្ទាល់របស់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។ ចាប់ពីពេលបង្កើតមន្ទីរសន្តិសុខនេះមក លេខារបស់គណៈ ស-២១ (ដំបូងគឺ ណាត និងក្រោយមក គឺ ឌុច) ជាអ្នករាយការណ៍ទៅ សុន សេន ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ ជាមួយ នួន ជា ដែលមានការទទួលខុសត្រូវផ្តាច់មុខចំពោះស-២១ ក្នុងនាមគណៈកម្មាធិការនេះ។

៣៨២- នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ នៅពេល សុន សេន ចាកចេញពីភ្នំពេញ ដើម្បីទៅបញ្ជាកងទ័ពបដិវត្តន៍កម្ពុជាដោយផ្ទាល់ នៅក្នុងជម្លោះប្រដាប់អាវុធជាមួយវៀតណាម នួន ជា ទទួលបន្ទុកជាអ្នកគ្រប់គ្រងស-២១ ដោយផ្ទាល់។ ស្ថានភាពបែបនេះបានបន្តរហូតពេលរបបនេះត្រូវបានផ្តួលរំលំនៅខែមករា ឆ្នាំ១៩៧៩ ហើយនឹងមានការពណ៌នាលំអិតនៅក្នុងផ្នែកអង្គហេតុជាក់ស្តែងរបស់ នួន ជា។

## នៅក្នុងមន្ទីរសន្តិសុខ

៣៨៣- បើយើងឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធនៃអង្គភាពគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជាវិញយើងឃើញថា ស-២១ ត្រូវបានចាត់ចែងដោយគណៈកម្មាធិការមួយដែលគ្រប់គ្រងនិងផ្តល់បញ្ជាទៅអង្គភាពក្រោមឱវាទជាច្រើនទៀត។ ក្នុងពេលដែល ណាត នៅជាលេខាស-២១ ឌុច មានតួនាទីជាអនុលេខា ត្រួតពិនិត្យការសួរចម្លើយ។ ពេលនោះ ហ៊ី ជាសមាជិកទីបីនៃគណៈកម្មាធិការនេះ។ នៅខែមីនា ឆ្នាំ១៩៧៦ នៅពេល ណាត ត្រូវបានផ្ទេរទៅផ្នែកសេនាធិការកងទ័ព ឌុច ត្រូវបានតែងតាំងជាលេខាស-២១ ជាតួនាទីមួយដែលគាត់កាន់រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ហ៊ី ក្លាយជាអនុលេខា ដែលទទួលខុសត្រូវអង្គភាព

ការពារ។ នៅពេលនោះ ហ៊ុយស្រែ ត្រូវបានតែងតាំងជាសមាជិកទីបីនៃគណៈស-២១។ នៅចុងឆ្នាំ១៩៧៨ គាត់ត្រូវបានគេចាប់ខ្លួន និង សម្លាប់នៅស-២១។ ប្រធានស-២៤ ថ្មីដែលចូលមកជំនួសគាត់មានឈ្មោះ ផល ដែលជាកម្មាភិបាលជាន់ខ្ពស់នៅក្នុងអង្គភាពការពារនៅស-២១។

៣៨៤- អង្គភាពនានាដែលនៅក្រោមការគ្រប់គ្រងរបស់គណៈ ស-២១ រួមមាន៖

(១) (**អង្គភាពការពារ** ដឹកនាំដោយ ហ៊ឺ ដែលមាន ផល ជាជំនួយការ។ នៅចុងឆ្នាំ១៩៧៨ ប៉េង ឡើងមកជំនួស ផល។ អង្គភាពនេះត្រូវបានបែងចែកជាកងរងនានាដូចខាងក្រោម)៖

(ក) អ្នកយាមខាងក្នុងបរិវេណកណ្តាល (ប៉េង ជាអ្នកដឹកនាំមុនគេ) ត្រូវបានចាត់តាំងឱ្យយាមអ្នកទោស និងទប់ស្កាត់ពួកនោះកុំឱ្យរួចចេញពីគុក ឬធ្វើអត្តឃាត។

(ខ) អ្នកយាមខាងក្រៅបរិវេណ (ហ៊ឹម ហ៊ុយ ជាអ្នកដឹកនាំមុនគេ) ជាអ្នករក្សាសន្តិសុខក្នុងការចេញចូលស-២១ និងមិនឱ្យមនុស្សដែលគ្មានការអនុញ្ញាតចេញចូលពន្ធនាគារបាន។

(គ) "កងពិសេស" (ប៉េង ជាអ្នកដឹកនាំមុនគេ បន្ទាប់មកដឹកនាំដោយ ប៉ូច និង ចុងក្រោយគេដឹកនាំដោយ ហ៊ឹម ហ៊ុយ) ទទួលខុសត្រូវនានារួមមាន ការចេញក្រៅ ស-២១ ដើម្បីចាប់អ្នកទោស ដឹកអ្នកទោសចេញពី ស-២១ ទៅជើងឯក ដើម្បីយកទៅសម្លាប់ និងយាមគុកពិសេសដែលដាក់កម្មាភិបាលជាន់ខ្ពស់។

អង្គភាពនេះត្រូវរាយការណ៍ផ្ទាល់ទៅ ហ៊ាំ ទោះបី ឌុច គ្រប់គ្រងជាមួយក៏ដោយ ហើយយូរៗម្តង ឌុច ក៏ជាអ្នកចេញបញ្ជាទៅអង្គភាពនេះដែរ។

(ឃ) អង្គភាពការពារស-២១ ក៏រួមទាំងអ្នកយាមនៅជើងឯក និងស-២៤ ដែរ។ ប្រធានអង្គភាពអ្នកយាមនៅជើងឯកគឺ តយ តេង ដែលត្រូវរាយការណ៍ទៅ ហ៊ឹម ហ៊ុយ ដែលត្រូវរាយការណ៍បន្តទៅ ហ៊ាំ។ អង្គភាពរងនេះមានតួនាទីដឹករណ្តៅសាកសពរួម យាមអ្នកទោសពេលយកមកដល់កន្លែងពិឃាត និង សម្លាប់អ្នកទោស។

(២) **អង្គភាពសួរចម្លើយ** (គ្រប់គ្រងដោយ ឌុច តែជាទូទៅចាត់ចែងការងារដោយ ម៉ម ណៃ ហៅ ចាន់ និង ប៊ុន) ដែលទទួលខុសត្រូវក្នុងការសួរចម្លើយអ្នកទោស ដើម្បីទាញយកចម្លើយសារភាព នឹងត្រូវប្រមូលចងក្រង និងផ្ញើទៅ ឌុច។ អង្គភាពនេះបែងចែកជា៖

(ក) អង្គភាពរងពិសេស ដែលសួរចម្លើយអ្នកទោសសំខាន់ៗ និងអនុវត្តវិធីសាស្ត្របញ្ចូលគ្នាក្នុងការទាញយកចម្លើយ។

(ខ) អង្គភាពរងទូទៅ ដែលសួរចម្លើយអ្នកទោសធម្មតា ហើយបែងចែកជាបីក្រុមទៀត ដែលអនុវត្តវិធីសាស្ត្រខុសៗគ្នាក្នុងការសួរចម្លើយ

(i) ក្រុមត្រជាក់ដែល “ប្រើនយោបាយ” ដោយប្រើពាក្យពេចន៍លួងលោម និងជេរប្រទេច តែមិនប្រើទារុណ្ណកម្មផ្លូវកាយទេ

(ii) ក្រុមក្ដៅ ដែលវាយនិងធ្វើទារុណ្ណកម្មលើអ្នកទោស ដើម្បីទទួលបានចម្លើយ និង

(iii) ក្រុមអង្គាម ដែលដឹកនាំការសួរចម្លើយយូរអង្វែង ដោយសួរសំនួរដដែលៗទៅអ្នកទោស និងធ្វើទារុណ្ណកម្មដែរដើម្បីទទួលបានចម្លើយដែលខ្លួនពេញចិត្ត។

(គ) ជាងនេះទៅទៀត ក្នុងករណីមួយចំនួន ការសួរចម្លើយអ្នកទោសស្ត្រីក៏ត្រូវបានធ្វើឡើងដោយក្រុមតូចៗ ដែលអ្នកសួរចម្លើយជាស្ត្រីដែរ។

(ឃ) ឌុច ចាន់ ប៉ុន និង ម៉េង ដឹកនាំការសួរចម្លើយអ្នកទោសដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា និងជនបរទេស។ ចាន់ ក៏ធ្លាប់បានសួរចម្លើយអ្នកទោសជាជនជាតិវៀតណាមដែរ។

(៣) **អង្គភាពឯកសារ** (ដឹកនាំដោយ សួស ធី ដែលជាអ្នកត្រូវរាយការណ៍ទៅ ហ៊ី) មានតួនាទីសំខាន់គឺរក្សាបញ្ជីឈ្មោះអ្នកទោសនៅស-២១ រួមមានបញ្ជីអ្នកទោសដែលទើបមកដល់ជារៀងរាល់ថ្ងៃ និងអ្នកទោសត្រូវបញ្ជូនយកទៅសម្លាប់។ អង្គភាពនេះមានភារៈរក្សាបណ្ដុំឯកសាររបស់អ្នកទោសដែលមានរូបថតនិងជីវប្រវត្តិផង រក្សាកំណត់ហេតុនៃទីតាំងអ្នកទោសម្នាក់ៗនៅក្នុងបរិវេណផង និងសរសេរនិងធ្វើសង្ខេបចម្លើយសារភាពផងដែរ។

(៤) **អង្គភាពថតរូប** ដឹកនាំដោយ នឹម គឹមស្រ៊ាង ដែលត្រូវរាយការណ៍ទៅ ចាន់ និង ឌុច។ អង្គភាពនេះមានតួនាទីថតរូបអ្នកទោសដែលទើបមកដល់ និងផ្ដិតរូបថតភ្ជាប់នឹងជីវប្រវត្តិ

របស់អ្នកទោស។ តែអង្គភាពនេះមិនបានថតរូបកម្មាភិបាលជាន់ខ្ពស់ទេ ដោយការងារនេះ អង្គភាពពិសេសជាអ្នកធ្វើ។ ក៏ប៉ុន្តែ អង្គភាពនេះជាអ្នកផ្តិតរូបថតសាកសពដែលបានថត ដោយអង្គភាពពិសេសដែរ ដើម្បីបញ្ជាក់ពីការសម្លាប់អ្នកទោសមួយចំនួន។

(៥) **អង្គភាពពេទ្យ** ដឹកនាំដោយ ទ្រី (ឬ ដឹកនាំផ្លាស់ប្តូរគ្នាដោយ ហ៊ី ឬ ប៉ោ) ដែលត្រូវរាយការណ៍ទៅ ឌុច។ តួនាទីដំបូងរបស់អង្គភាពនេះគឺត្រូវផ្តល់ការព្យាបាលដល់កម្មាភិបាលនៅស-២១។ អង្គភាពនេះក៏មានភារកិច្ចពិនិត្យ និងផ្តល់ការព្យាបាលជាមូលដ្ឋានដល់អ្នកទោស ដែលទទួលរងការធ្វើទារុណ្ណកម្ម ដើម្បីកុំឱ្យស្លាប់សម្រាប់បញ្ចប់ការសួរចម្លើយ។ អង្គភាពនេះក៏មានភារកិច្ចបូមឈាមអ្នកទោសផ្ទុយពីឆន្ទៈរបស់គេ ដឹកនាំការសិក្សាក្នុងការវះកាត់ និងការធ្វើពិសោធន៍ទៅលើអ្នកទោស និងកប់អ្នកទោសដែលស្លាប់ក្នុងបន្ទប់ឃុំឃាំងនៅស-២១។

(៦) **អង្គភាពនីរសារ** ដែលត្រូវរាយការណ៍ទៅ ផល និងរួមទាំងនិរសារផ្ទាល់របស់ ឌុច ឈ្មោះ ឆេន ដែលរត់សំបុត្រឱ្យឌុចទៅមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។

(៧) **អង្គភាពកុមារ** ស្ថិតក្រោមការគ្រប់គ្រងរបស់ ចាន់ មានភារកិច្ចចិញ្ចឹមទន្សាយ និង មាន់។

(៨) **អង្គភាពខាងដាំស្ល** ឬ **អង្គភាពសេដ្ឋកិច្ច** ត្រូវរាយការណ៍ទៅ ហ៊ី និងមានតួនាទីដាំស្លសម្រាប់បុគ្គលិកនៅស-២១។

(៩) **អង្គភាពខាងភ័ស្តុភារ** ត្រូវរាយការណ៍ទៅ ហ៊ី មានភារកិច្ចខាងផ្នែកទំនាក់ទំនង ទូរស័ព្ទ ទូរលេខ អាវុធ យានជំនិះ ទឹក និងអគ្គិសនី។

៣៤៥- មានតារាងបុគ្គលិកទូទៅមួយពីខែមេសា ឆ្នាំ១៩៧៧ បង្ហាញថា មានបុគ្គលិកជាង២.៣០០ នាក់ធ្វើការនៅស-២១។ បុគ្គលិកមុនគេ គឺមកពីកងពល៧០៣។ បុគ្គលិកនៅអង្គភាពសួរចម្លើយមួយចំនួនគឺមកពីមន្ទីរសន្តិសុខម-១៣ ដែល ឌុច ធ្លាប់ធ្វើជាប្រធាននៅទីនោះ។ ឌុច ក៏បានជ្រើសរើសកុមារ និងយុវជនមួយចំនួនដែលមកពីជនបទឲ្យធ្វើជាបុគ្គលិកបន្ថែម។ ចុងក្រោយបុគ្គលិកជាច្រើនត្រូវបានជ្រើសរើសចេញពីអង្គភាពកុមារ។

## ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៣៤៦- ស-២១ គឺជាបណ្តុំកណ្តាលនៃរចនាសម្ព័ន្ធនយោបាយ និងយោធារបស់បក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពី "ការកំទេច" រាល់ខ្មាំងសត្រូវទាំងអស់ គឺត្រូវបានអប់រំណែនាំម្តងហើយម្តងទៀតដល់បុគ្គលិករបស់ខ្លួន និងជាពិសេសគឺអ្នកសួរចម្លើយថា៖ ពួកគេបំពេញភារកិច្ចរបស់ខ្លួន ដើម្បីអនុវត្ត"នូវអ្វីដែលបក្សតម្រូវ" ដើម្បី "ការពារក្បាលម៉ាស៊ីនដឹកនាំរបស់ បក្សកុម្មុយនីស្តកម្ពុជា"។

៣៤៧- កម្មាភិបាលនៅ ស-២១ ត្រូវបានគេចាត់ទុកថាជា "ឧបករណ៍របស់មេដឹកនាំផ្តាច់ការវណ្ណៈអធនរបស់បក្ស"។ (អ្នកជំនាញខាងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា គឺលោក Chandler និងEtcheson បានផ្តល់ភ័ស្តុតាងយ៉ាងច្រើននៅក្នុងសវនាការលើរឿងក្តី០០១ ចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្រិតសម្រាំងខ្មាំង និងការផ្សព្វផ្សាយនៅស-២១)។

៣៤៨- (ឌុច និងបុគ្គលិករបស់ខ្លួន "មានមោទនភាពចំពោះភាពល្អិតល្អន់ ភាពទំនើប និងភាពស្មុគស្មាញ" និង"ចាត់ទុកខ្លួនឯងមានវិជ្ជាជីវៈជាអ្នកជំនាញខាងសន្តិសុខ")។ នៅពេលជាមួយគ្នានោះ

ស-២១ បានដើរតួនាទីស្របតាមគោលនយោបាយ ដែលបានដាក់ចេញដោយថ្នាក់ដឹកនាំបក្ស កុម្មុយនីស្តកម្ពុជា រួមទាំងគោលនយោបាយអនុវត្តដាច់ខាតតាមមាគ៌ាបដិវត្តន៍ផង។ ទោស កំហុសរបស់អ្នកដែលត្រូវបាននាំខ្លួនមកស-២១ ត្រូវបានបង្កើតឡើងរួចមកហើយ តាមរយៈការ សម្រេចចិត្តឲ្យចាប់ខ្លួនអ្នកទាំងនោះ ហើយមិនមានយន្តការណាមួយដែលអ្នកទាំងនោះអាច ជំទាស់ពីភ័ស្តុតាងដែលនាំឲ្យពួកគេត្រូវជាប់សង្ស័យនោះទេ។ នៅពេលទទួលការចាប់ខ្លួនហើយ អ្នកទោសម្នាក់ៗទទួលវាសនាថាសេចក្តីស្លាប់របស់ខ្លួន គឺស្ថិតក្នុងកណ្តាប់ដៃរបស់បុគ្គលិកស-២១ រួចជាស្រេច)។

៣៤៩- ឌុច បានជ្រើសរើសកុមារ និងក្មេងប្រុសៗធ្វើជាបុគ្គលិករបស់ខ្លួន ពីព្រោះពួកគេ "ដូចជាក្រដាស សមួយសន្លឹកដែលពួកគេអាចសរសេរនូវអ្វីដែលគេចង់បាន"។ ការអប់រំពួកគេឲ្យមាន "ជំហរ ប្រឆាំងខ្មាំងសត្រូវ" ធ្វើឲ្យគាត់ធានាថា ពួកគេនឹងក្លាយជាអ្នកធ្វើទារុណកម្ម និងអ្នកសួរចម្លើយ ដែលមានប្រសិទ្ធិភាព។ ការបញ្ចូលមនោគមវិជ្ជានយោបាយជួយឲ្យអ្នកសួរចម្លើយមានអាវុធ ផ្នែកចិត្តសាស្ត្រដែលគេអាចប្រើក្នុងពេលធ្វើទារុណកម្ម និងសួរចម្លើយអ្នកទោសនៅស-២១។ ដំណើរការនេះសម្រេចបានតាមរយៈការបណ្តុះបណ្តាលជាទៀងទាត់ដែលធ្វើដោយ ឌុច ខ្លួនឯង ផ្ទាល់ នៅក្នុងទម្រង់ជាការរៀនសូត្រនយោបាយរយៈពេលជាច្រើនថ្ងៃ និងជារៀងរាល់សប្តាហ៍ ឬរវាងពីរសប្តាហ៍ម្តង ស្តីពីបច្ចេកទេសក្នុងការសួរចម្លើយ និងធ្វើទារុណកម្ម។ កម្មាភិបាលរូបនេះក៏ធ្លាប់បានចូលរួមកិច្ចប្រជុំ ដែលរៀបចំដោយថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្ស កុម្មុយនីស្តកម្ពុជាផងដែរ ដើម្បីពិភាក្សាពីតម្រូវការចាំបាច់ក្នុងការ "កំទេច" ខ្មាំង និងកិច្ចប្រជុំ ស្តីពីផែនការផលិតកម្មផ្នែកនយោបាយនិងកសិកម្មដែលរៀបចំដោយមជ្ឈិមបក្ស។ គោល នយោបាយដែលពាក់ព័ន្ធនឹងការសម្លាប់មនុស្សក្រៅច្បាប់ត្រូវបានពិភាក្សានៅក្នុងការប្រជុំ

ប្រចាំឆ្នាំ និងការប្រជុំតូចៗរបស់អង្គភាពរងក្នុងស-២១។ ការបណ្តុះបណ្តាលកម្មាភិបាលគឺជាទិដ្ឋភាពមួយដែលសំខាន់ក្នុងប្រតិបត្តិការរបស់ ស-២១ ដែលធ្វើឡើងនៅក្នុងអគារដាច់ពីគេមួយដែលត្រូវបានចាត់តាំងសំរាប់គោលបំណងនេះ។

៣៥០- ការបណ្តុះបណ្តាលមានគោលបំណងធានាថា បុគ្គលិកពិតជាប្រកាន់យកនូវគោលជំហរវណ្ណៈដាច់ខាត និងដាច់ខាតក្នុងការទាញយកចម្លើយសារភាពពីខ្មាំងសត្រូវឱ្យបាន។ មានភស្តុតាងបង្ហាញពីការបណ្តុះមនោគមវិជ្ជានៅសេសសល់ ដែលក្នុងនោះរួមមានសៀវភៅកំណត់ហេតុដែលកត់ត្រាពីការណែនាំដល់អ្នកសួរចម្លើយជាន់ខ្ពស់ពីដើមឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨។ ឧទាហរណ៍ សៀវភៅកំណត់ដែរបស់ ចាន់ និង“បញ្ជីស្ថិតិរបស់សាខាពិសេស” អះអាងថា អ្នកសួរចម្លើយគួរតែផ្តោតទៅលើការសួរចម្លើយខ្មាំងសត្រូវសម្រាប់ជាប្រយោជន៍ល្អដល់បក្ស។ បញ្ជីស្ថិតិបញ្ជាក់ថាការសួរចម្លើយបែបនេះគឺជា“កាតព្វកិច្ចក្នុងការតស៊ូប្រយុទ្ធស្វិតស្វាញ” រវាងខ្មាំងសត្រូវ និងរបបកម្ពុជាប្រជាធិបតេយ្យ និង“កាតព្វកិច្ចរួមមានការតស៊ូវណ្ណៈយ៉ាងស្វិតស្វាញក្តៅគគុក”។ កំណត់ហេតុរបស់ ប៉ុន និង ទុយ កត់ត្រានូវសេចក្តីណែនាំថា៖ “ការសម្រិតសម្រាំងពួកក្បត់ផ្ទៃក្នុងជាការចាំបាច់។ យើងត្រូវតែធ្វើដោយខានមិនបាន”។

៣៥១- នៅពេលមាគ៌ារបស់បក្សត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់កម្មាភិបាល នេះក៏មានន័យថាកម្មាភិបាលទាំងនោះក៏ត្រូវតែយកវាជាមធ្យោបាយក្នុងការអនុវត្តន៍ដែរ។ ឧទាហរណ៍ កំណត់ហេតុរបស់ ប៉ុន និងទុយ កត់ត្រាពីគោលបំណងពីរយ៉ាងរបស់បក្សដែលអ្នកសួរចម្លើយរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវអនុវត្តតាម៖ គឺការរកឃើញពួកឃ្មួន (“ឈ្នះធំ”) និងរកមិនឃើញឃ្មួនតែចាប់ខ្លួនពួកក្បត់ថែមទៀត(“ឈ្នះតូច”)។ ដើម្បីសម្រេចបានតាមគោលដៅនេះ កម្មាភិបាល

ត្រូវបានបណ្តុះបណ្តាលពីវិធីសាស្ត្រក្នុងការសួរចម្លើយដើម្បី "សួរតែចំណុចណាដែលបក្សឲ្យ [អ្នកឯង]សួរ ពីព្រោះបក្សក្តាប់សភាពការណ៍បានអស់ហើយ" និងក្នុងចំណោមបញ្ហាផ្សេងទៀត ដើម្បី"ស្វែងរកសាច់រឿងឲ្យល្អិត" "ស្វែងរកទំនាក់ទំនង ... តើគេបាននិយាយពីការធ្វើដំណើរ និងផ្លូវថ្នល់ឬទេ ... ការលាក់អាវុធ និងត្រង់សេ" "សួរចម្លើយដើម្បីទទួលបានជាអតិបរមានូវអត្ថបទច្បាស់ៗ" និងដើម្បី "វិភាគខ្សែបណ្តាញខ្មាំង និងចាត់វិធានម៉ឹងម៉ាត់"។

៣៥២- នៅក្នុងវគ្គបណ្តុះបណ្តាល អ្នកសួរចម្លើយត្រូវបានណែនាំអំពីការសម្ងាត់នៃមូលហេតុក្នុងការសួរចម្លើយ និងដើម្បី"សួរចម្លើយរហូតទាល់តែរកឃើញថាវាមានសារៈសំខាន់"។ មានការផ្តល់ការណែនាំជាក់លាក់ផងដែរ ដែលទាក់ទងទៅនឹងការប្រើទារុណ្ណកម្ម។ ឧទាហរណ៍ ដូចបានកត់ត្រាក្នុងបញ្ជីស្ថិតិដែរគឺថា អ្នកសួរចម្លើយត្រូវបានគេប្រាប់ថា៖

"បើអង្គការប្រាប់មិនឲ្យវាយ[អ្នកទោស] មិនត្រូវវាយដាច់ខាត។ បើបក្សបញ្ជាយើងឲ្យវាយ យើងត្រូវវាយដោយម្ចាស់ការ វាយរហូតទាល់តែវាព្រមនិយាយ មិនឲ្យងាប់ មិនឲ្យគេចខ្លួន មិនឲ្យទន់ខ្សោយ និងបាក់កម្លាំង ដែលអាចទៅជាឈឺ ហើយយើងនឹងបាត់បង់វាមិនខាន"។

៣៥៣- ទំនាក់ទំនងដោយផ្ទាល់ និងគ្មានការច្រឡំរវាងការធ្វើទារុណ្ណកម្មដែលអនុវត្តនៅ ស-២១ និងសេចក្តីណែនាំឧក្រិដ្ឋកម្មរបស់មជ្ឈិមបក្ស ដែលបានបញ្ជាក់ដោយ **ឌុច** នៅក្នុងវគ្គបណ្តុះបណ្តាល។ គាត់បានណែនាំដល់អ្នកក្រោមបង្គាប់ថា៖

"អ្នកត្រូវកម្ចាត់នូវទស្សនៈផ្ទាល់ខ្លួនថា វាយអ្នកទោសគឺឃោរឃៅ។ (ករណីនេះ) មិនត្រូវធ្វើចិត្តល្អទេ។ ត្រូវវាយ (វា) ដោយមូលហេតុជាតិ មូលហេតុវណ្ណៈ និងមូលហេតុអន្តរជាតិ"។

៣៥៤- នៅពេលដែលខ្មាំងរបបនេះត្រូវបានកំណត់អត្តសញ្ញាណ ឬបញ្ជាក់ពីបក្សមក ព័ត៌មាននេះនឹងផ្ទេរទៅឱ្យអ្នកសួរចម្លើយនៅស-២១។ ឌុច ណែនាំឱ្យប្រើពាក្យថា "កាហ្សេបេ" "សេអ៊ីអា" និង "បណ្ដាញខ្មាំងឃួន" និងបានណែនាំអ្នកសួរចម្លើយឱ្យស្វែងរកព័ត៌មានទាក់ទងនឹង"ខ្សែបណ្ដាញរបស់អ្នកទោស"។ អ្នកសួរចម្លើយនៅស-២១ ត្រូវបានគេបង្រៀនថា បក្សកុម្មុយនីស្តកម្ពុជា "មិនបែងចែកថាតើខ្មាំងនោះធ្វើសកម្មភាព ឬមិនធ្វើ"ទេ។ ខ្មាំងត្រូវបានកំណត់អត្តសញ្ញាណ "ទៅតាមគោលការណ៍របស់បក្ស"។

៣៥៥- មាគ៌ាបក្សក៏បានពង្រឹកដល់កម្មាភិបាលនៅស-២១ដែរ តាមរយៈទស្សនាវដ្ដី*ទង់បដិវត្ត* និង *យុវជនបដិវត្ត* ដែលធ្វើឱ្យបុគ្គលិកយល់ពីតួនាទីរបស់ខ្លួន ក្នុងការអនុវត្តន៍គោលនយោបាយ។ តាមរយៈសេចក្ដីថ្លែងការណ៍ដែលបានចេញផ្សាយនៅក្នុង*ទង់បដិវត្ត* នៅដើមឆ្នាំ១៩៧៦ ប៉ុល ពត បានព្រមានប្រឆាំងនឹងមនុស្សដែល "មានប្រវត្តិរូបស្មុគ្រស្មាញជាប្រព័ន្ធ" ជាសារមួយដែលមានការយកចិត្តទុកដាក់ជាខ្លាំងនៅស-២១ នៅពេលដែលការបណ្ដុះបណ្ដាលត្រូវបានប្រើជា "ការឆ្លង... ប្រវត្តិរូបបដិវត្តន៍"។ មជ្ឈិមបក្សបានឃោសនាពីសេចក្ដីណែនាំដោយគោរពចំពោះ "បញ្ហា" របស់មនុស្សដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព។ អ្នកសួរចម្លើយត្រូវបានគេប្រាប់ថា៖ "នៅពេលខ្មាំងឆ្លើយ មិនត្រូវឱ្យប្រាប់មិត្តរបស់អ្នកឯងទេ។ [អ្នកឯង]ត្រូវរាយការណ៍ទៅថ្នាក់លើវិញ"។

៣៥៦- មុនថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ឌុច ជាអ្នកផ្ញើចម្លើយសារភាពទៅឱ្យ សុន សេន ដែលជាអ្នកផ្ញើបន្តទៅ នួន ជា និង/ឬ ប្រធានអង្គភាពរបស់អ្នកទោសដែលត្រូវគេសួរចម្លើយនោះ។ ក្រោយខែសីហា ឆ្នាំ១៩៧៧ ឌុច ផ្ញើចម្លើយសារភាពផ្ទាល់ទៅឱ្យ នួន ជា ដែលជាអ្នកផ្ដល់ការណែនាំឱ្យ

ធ្វើសកម្មភាពបន្ថែមទៀត និងផ្ញើឯកសារចម្លើយសារភាពទៅប្រធានអង្គភាពដែលពាក់ព័ន្ធ។ តាមវិធីធ្វើការងារបែបនេះ ស-២១ មានឥទ្ធិពលទៅលើការវិវត្តន៍នៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា៖ ចម្លើយសារភាពដែលធ្វើឲ្យមជ្ឈិមបក្ស និងទ្រឹស្តីនៃការរួមគំនិតដែលបញ្ចោះឡើងដោយចម្លើយសារភាព ការផ្តល់ជាព័ត៌មានទូវសេចក្តីសម្រេចរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាទៅលើលក្ខណៈ និងវិសាលភាពនៃការសម្រិតសម្រាំង (ដូចមានភស្តុតាងជាឧទាហរណ៍ស្រាប់ ដោយការសម្រិតសម្រាំងជាទ្រង់ទ្រាយធំលើកទី២ នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨)។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

## សមាសភាពអ្នកទោស

### *បរិវេណកណ្តាលនៃស-២១*

៣៥៧- ដោយស្របទៅនឹងបេសកកម្មរបស់ស-២១ ក្នុងការស្វែងរកមុខសញ្ញាខ្មាំងដែលអាក្រក់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា អ្នកទោសនៅទីនោះរួមមានសមាជិកជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជា បក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាលតាមភូមិភាគ តំបន់ និងស្រុក រួមទាំងឈ្លើយសឹក និងជនស៊ីវិលវៀតណាម និងជនបរទេសដទៃទៀតផង។ (ទំនាក់ទំនងភ្ជាមៗរវាងស-២១ និងគោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស អាចមើលឃើញបាន នៅពេលដែលសមាសភាពអ្នកទោសនៅស-២១ (និងបទឧក្រិដ្ឋដែលអ្នកនោះត្រូវបានគេបង្ខំឲ្យសារភាព) ត្រូវបានគេភ្ជាប់ទៅនឹងការប្រឆាំងនឹងការប្រកាស និងបទបញ្ជាជាសាធារណៈ ដែលចេញដោយមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្ត

កម្ពុជា៖ សាវតាររបស់អ្នកទោស និង/ឬ តំបន់ដែលអ្នកទោសនោះត្រូវបានគេនាំយកមកស-២១ និងបទឧក្រិដ្ឋដែលអ្នកទោសទាំងនោះសារភាព ត្រូវឆ្លុះបញ្ចាំងជា "ខ្មាំង" ប្រភេទណាក៏ដោយដែលមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាមានកង្វល់)។ ចំណុចនេះនឹងពិភាក្សាពិស្តារបន្ថែមទៀតនៅក្នុងផ្នែក ការចូលរួមក្នុងការសម្រិតសម្រាំងខាងក្រោម។

៣៥៨- បញ្ជីឈ្មោះអ្នកទោសនៅស-២១ ដែលបានពិនិត្យឡើងវិញ (បញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញ) រួមមានឈ្មោះ និងព័ត៌មានស្តីពីអត្តសញ្ញាណរបស់អ្នកទោសចំនួន១២.២៧៣នាក់។ ចំនួនជនរងគ្រោះពិតប្រាកដមានចំនួនច្រើនជាងនេះ ហើយចំនួនភាគច្រើនលើសលុបជាជនជាតិខ្មែរ។ នៅពេលដែលស-២១ ឃុំឃាំង និងសម្លាប់អ្នកទោសដែលមានសាវតារផ្សេងៗ (រួមមាន អតីតទាហាន និងមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ ទាហាន និងជនស៊ីវិលវៀតណាម បញ្ញាវ័ន្ត ជនជាតិខ្មែរដែលត្រឡប់មកពីបរទេស និងជនបរទេស) មានក្រុមជនពីរក្រុមធំៗគឺមន្ត្រីកងទ័ពបដិវត្តន៍កម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងចំណោមនោះ៖ អ្នកទោសចំនួន៥.៦០៩ នាក់ដែលស្ថិតក្នុងបញ្ជីជាសមាជិកកងទ័ពបដិវត្តន៍កម្ពុជា រីឯអ្នកទោសចំនួន៤.៣៧១ នាក់ផ្សេងទៀតត្រូវបានគេពណ៌នាថា ជាអ្នកធ្លាប់ធ្វើការនៅក្នុងមន្ទីរនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

៣៥៩- ពីដំបូងស-២១ កំហិតដាក់តែអ្នកទោស"សំខាន់" ទេ តែក្រោយមកក៏ទទួលអ្នកទោសមកពីទីជនបទដែរ។ ចំនួនអ្នកទោសដែលជាប់នៅក្នុងបរិវេណធំ មានចំនួនប្រែប្រួល តែមន្ទីរសន្តិសុខនេះអាចដាក់អ្នកទោសជាអតិបរមាបានរហូតដល់ទៅប្រហែល១៥០០ នាក់។ បញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញ បានកត់ត្រាថាមានអ្នកទោសចំនួន៥៩៩៤នាក់ ជាបុរស ១៦៩៨នាក់

ជាស្ត្រី និង៨៩នាក់ ជាកុមារ។ ជាថ្មីម្តងទៀត តួលេខនេះមិនបានឆ្លុះបញ្ចាំងពីចំនួនសរុបពិតប្រាកដទេ ដោយមានឧទាហរណ៍មួយចំនួនបញ្ជាក់ថា ជាធម្មតាកុមារមិនត្រូវបានកត់ត្រានៅក្នុងបញ្ជីឈ្មោះអ្នកទោសទេ។ ជារួម អ្នកទោសចំនួនប្រមាណ៧៧ភាគរយនៃអ្នកទោសទាំងអស់ដែលភេទរបស់ពួកគេត្រូវបានកត់ត្រានៅក្នុងបញ្ជីនេះគឺជាបុរស ស្ត្រីចំនួន ២១,៨ភាគរយ និង១,១ភាគរយ ជាកុមារ។

៣៦០- ជាក់ស្តែង គ្រប់មន្ទីរទាំងអស់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សុទ្ធតែមានអ្នកទោសនៅស-២១។ បញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញបង្ហាញថា យ៉ាងហោចណាស់ក៏មានអ្នកធ្លាប់បម្រើការនៅតាមក្រសួង និងមន្ទីររបស់រដ្ឋាភិបាល ដែលត្រូវបានគេឃុំខ្លួន មានដូចខាងក្រោមនេះ៖

(១) ការបរទេស
(២) សង្គមកិច្ច
(៣) អប់រំ
(៤) ឧស្សាហកម្ម
(៥) ឃោសនាការ
(៦) ពាណិជ្ជកម្ម
(៧) ថាមពល
(៨) អយស្ម័យយាន
(៩) កសិកម្ម
(១០) សាធារណការ
(១១) មន្ទីរ ៨៧០
(១២) ស-៧១
(១៣) បឹងត្របែក (ប-៣២)
(១៤) ផលិតសម្លៀកបំពាក់
(១៥) ដឹកជញ្ជូនផ្លូវទឹក
(១៦) ដឹកជញ្ជូនផ្លូវគោក
(១៧) អគ្គិសនី
(១៨) ឃ្លាំងរដ្ឋ

៣៦១- យ៉ាងហោចណាស់ក៏មានកម្មាភិបាលចំនួន៦៩នាក់ដែរ ដែលបញ្ជូនពីមន្ទីរសន្តិសុខនានានៅទូទាំងប្រទេសមកស-២១។

៣៦២- ដោយហេតុថា ឌុច ដំណើរការពន្ធនាគារនេះដោយមានវិន័យតឹងរ៉ឹងនោះ មានបុគ្គលិករបស់គាត់មួយចំនួនធំត្រូវបានគេចាប់ខ្លួន និងសម្លាប់នៅស-២១ដែរ ដោយសារមូលហេតុអ្នកទាំងនោះបានបំពានទៅលើបទបញ្ជានានា៖ មានអ្នកទោសចំនួន១៥៥នាក់ ត្រូវបានពណ៌នាថាធ្លាប់បានបម្រើការងារនៅស-២១ មុនពេលចាប់ខ្លួន តែចំនួនពិតប្រាកដអាចច្រើនជាងនេះ។ យ៉ាងហោចណាស់ក៏មានអ្នកទោសចំនួន៤៧នាក់ដែរ ដែលត្រូវបានផ្ទេរពីស-២៤ មកស-២១ ដែលអ្នកទោសទាំងនោះជាអតីតបុគ្គលិកនៅស-២៤។

៣៦៣- មានអ្នកទោសប្រភេទផ្សេងទៀតក៏បានបញ្ជូនមកស-២១ដែរ។ មានអតីតទាហានរបស់របបសាធារណរដ្ឋខ្មែរចំនួន៣២៨នាក់ ត្រូវបានកត់ត្រានៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញ។ បញ្ជីនេះកត់ត្រាបញ្ញវន្តចំនួន២៧៨នាក់ (គ្រូបង្រៀន សាស្ត្រាចារ្យ សិស្សនិស្សិត វេជ្ជបណ្ឌិត មេធាវី និងវិស្វករ)។ មានអ្នកទោសចំនួន៣៤៥នាក់ ត្រូវបានពណ៌នាថាជាជនជាតិវៀតណាម រួមមានទាហានវៀតណាមចំនួន១២២នាក់ គិញចំនួន១៤៤ នាក់ និងជនស៊ីវិលចំនួន៧៩នាក់។ មានកត់ត្រាជាប្រជាជនថ្មីចំនួន២១៥នាក់។ បញ្ជីនេះរួមមានឈ្មោះសាច់ញាតិអ្នកទោសចំនួន៨៧៦នាក់ រួមមាន ប្រពន្ធចំនួន៥៨៣នាក់ ប្តី ចំនួន៣១នាក់ កូនស្រីចំនួន១១២នាក់ និងកូនប្រុសចំនួន១០៧នាក់។

*ស-២៤ (ព្រៃស)*

៣៦៤- មានពេលខ្លះ មានមនុស្សរាប់រយនាក់ត្រូវបានឃុំឃាំងនៅស-២១។ ជាទូទៅ អ្នកទាំងនោះត្រូវបានបែងចែកជាពីរប្រភេទ៖ ប្រភេទទីមួយជាអតីតកម្មាភិបាល (រួមមានសមាជិកកងពលនានានៃកងទ័ពបដិវត្តន៍កម្ពុជា និងក្រសួង/មន្ទីរនានារបស់រដ្ឋាភិបាល រួមទាំងបុគ្គលិកស-២១ ដែល

ត្រូវគេបញ្ជូនទៅលត់ដំផង)។ ប្រភេទទីពីរ គឺជាសមាជិកគ្រួសាររួមមាន កូនចៅរបស់អ្នកទោស ទាំងនោះ។ អ្នកទោសប្រភេទទីពីរមានចំនួនភាគច្រើន។ មនុស្សធម្មតាដែលត្រូវបានគេចាត់ថាជាពួកក្បត់ (ឧទាហរណ៍ សាច់ញាតិរបស់អតីតទាហានសាធារណរដ្ឋខ្មែរ) ក៏ត្រូវជាប់ឃុំឃាំងនៅស-២៤ ដែរ។

៣៦៥- មានអ្នកទោសនៅស-២៤ ជាច្រើនត្រូវបានបញ្ជូនមកស-២១។ មានអ្នកទោសប្រភេទនេះចំនួន៥៩០នាក់ ត្រូវបានកត់ត្រាទៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញ។ ក្នុងចំណោមអ្នកទោសទាំងនេះ ចំនួន៣៤២នាក់ធ្លាប់ត្រូវបានលត់ដំនៅស-២៤។ ដូចបានកត់សម្គាល់ខាងលើមកហើយថាមាន៤៧នាក់ ជាបុគ្គលិកនៅស-២៤ និងមានចំនួន២០១នាក់ (មិនដឹងជាអ្នកទោស ឬជាបុគ្គលិកនៅស-២៤) មិនមានកំណត់អត្តសញ្ញាណច្បាស់លាស់។ មានមនុស្សរាប់រយនាក់ត្រូវបានបញ្ជូនឲ្យធ្វើការនៅការដ្ឋាន ស-២៤ នៅពេលដែលមានចំនួនរាប់ពាន់នាក់ទៀត រួមមានបុរស និងស្ត្រី ត្រូវគេឃុំឃាំង។

៣៦៦- អ្នកទោសនៅ ស-២៤ ត្រូវបានបែងចែកជាបីប្រភេទ៖ (១)អ្នកដែលជាប់ចោទពី "កំហុស" ស្រាល និងអ្នកដែលធ្វើការសកម្មនៅ ស-២៤ និងមានកិរិយាមាយាទត្រឹមត្រូវ (២)ប្រភេទមធ្យម គឺអ្នកដែលអាចឡើងទៅប្រភេទទី១បាន តាមរយៈការបំពេញការងារបានល្អ ឬត្រូវធ្លាក់ទៅប្រភេទទី៣ តាមរយៈការបំពេញការងារផ្សេងៗមិនបានល្អ និង(៣)អ្នកដែលមិនអាចកែប្រែបាន និងអ្នកដែលស្ទើរតែនឹងត្រូវយកទៅសម្លាប់នៅស-២៤ ឬបញ្ជូនទៅស-២១ ឬដើងឯកដើម្បីសម្លាប់។ ភាគច្រើន អ្នកទោសប្រភេទទី១ អាចនឹងធ្លាក់ទៅប្រភេទទី២ និងទី៣ តែមិនសូវមានអ្នកទោសប្រភេទទី២ និងទី៣ ឡើងមកប្រភេទទី១ទេ។

៣៦៧- អ្នកជាប់ឃុំឃាំងនៅស-២៤ ត្រូវបានចាត់ទុកជា "កងសមាសភាព" ដែលបញ្ជាក់ពីឋានៈមិនច្បាស់លាស់ និងកំពុងទទួលការសម្រេចចិត្តថាតើ ត្រូវ"អប់រំកែប្រែ" ឬត្រូវយកទៅ "កំទេច"។

## ដំណើរការចាប់ខ្លួន

៣៦៨- អ្នកដែលត្រូវគេសង្ស័យថាជាមុខសញ្ញាចាប់ខ្លួន និងឃុំឃាំងនៅស-២១ ភាគច្រើន **ឌុច** ជាអ្នកកំណត់អត្តសញ្ញាណ ដោយផ្អែកលើការវិភាគទៅលើចម្លើយសារភាពរបស់អ្នកទោសដែលមាន។ ការវិភាគ និងការផ្តល់យោបល់ទាំងនេះ បានទទួលការឯកភាពពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលមានភារកិច្ច បញ្ជា អនុម័ត ឬផ្តល់សិទ្ធិអំណាចក្នុងការចាប់ខ្លួនខ្មាំង និង ពួកក្បត់ដែលជាប់សង្ស័យបន្ថែមទៀត។ នៅក្នុងគុកមានតែ **ឌុច** ម្នាក់គត់ដែលមានសិទ្ធិអំណាចរាយការណ៍ និងទាក់ទងជាមួយថ្នាក់លើ។ គាត់រាយការណ៍ផ្ទាល់ទៅសមាជិកគណៈអចិន្ត្រៃយ៍ ដូចបានកត់សម្គាល់ខាងលើមកហើយគឺដំបូងទៅ សុន សេន ដែលជាមនុស្សដែលគាត់បានទាក់ទងគ្នាប្រចាំថ្ងៃ និងបានរាយការណ៍ទៅ **នួន ជា** ចាប់ពីខែសីហា ឆ្នាំ១៩៧៧។

៣៦៩- នៅពេលដែលស-២១ ដំណើរការយ៉ាងតឹងរ៉ឹង ទៅតាមគោលនយោបាយដែលបានកំណត់ដោយមជ្ឈិមបក្ស ជាមនុស្ស ឬអង្គការដែលធ្វើសេចក្តីសម្រេចជាក់ស្តែងទៅលើការចាប់ខ្លួនបុគ្គលណាម្នាក់ អាស្រ័យទៅតាមអតីតភាព និងតួនាទីរបស់អ្នកជាប់សង្ស័យនោះ។ **ឌុច** ក៏អាចស្នើការចាប់ខ្លួនបានដែរ គាត់អះអាងថាមានតែគណៈអចិន្ត្រៃយ៍ទេ ដែលមានសិទ្ធិអំណាចសម្រេចបាន។ [redacted]។ គាត់ក៏បានបំភ្លឺផងដែរថា គណៈអចិន្ត្រៃយ៍ ជា

ពិសេសគឺ នួន ជា ជាអ្នកទាក់ទងជាមួយភូមិភាគ តំបន់ ឬស្រុក ពាក់ព័ន្ធនឹងការចាប់មនុស្សនៅក្នុងតំបន់នោះ។

៣៧០- ដំណើរការពេលអ្នកទោសថ្មីមកដល់ស២១ មាននីតិវិធីមួយចំនួន។ អ្នកទោសដែលត្រូវបានចាប់ និង/ឬ ការផ្ទេរខ្លួនអ្នកទោសមួយចំនួនខាងក្រៅក្រុង ដោយបុគ្គលិកមន្ទីរស២១ ដែលពួកគេទទួលបានលិខិតដើរផ្លូវពិសេសដែលចេញដោយ សុន សេន។ នៅក្នុងករណីបែបនេះ អង្គភាពពិសេសមួយរបស់ស-២១ ត្រូវបានបញ្ជូនទៅតាមភូមិភាគ ដើម្បីចាប់ ឬប្រមូលអ្នកទោស។ នៅពេល ឌុច អះអាងថា អ្នកទោសដែលគេទៅប្រមូលនោះសុទ្ធតែត្រូវបានគេចាប់ខ្លួនជាមុនហើយនោះ គាត់ក៏ទំនងជាបានដឹងយ៉ាងច្បាស់ថា តាមពិតស-២១ ជាអ្នកអនុវត្តការចាប់ខ្លួនមនុស្សតែម្តង៖ ឧទាហរណ៍ គាត់បានអះអាងថា ហ៊ី "មានកងប្រតិបត្តិផ្ទាល់ខ្លួន" ដែល "ជាធម្មតា" ជាអ្នកទៅចាប់ និងនាំអ្នកទោសមកស-២១។ អំណះអំណាងនេះស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងដែលផ្តល់ដោយ ហ៊ឹម ហ៊ុយ ដែលបញ្ជាក់ថាទាំង ឌុច និង ហ៊ី ជាអ្នកដឹកនាំការចាប់ខ្លួនមនុស្សជាច្រើននៅខាងក្រៅស-២១។ ហ៊ឹម ហ៊ុយ ក៏បានរំលឹកឡើងវិញ នៅពេលគាត់ត្រូវបានគេបញ្ជូនចេញក្រៅដោយមានលិខិតប្រគល់សិទ្ធិពី ឌុច ក្នុងការដឹកនាំការចាប់ខ្លួនមនុស្សនៅតាមខេត្តបាត់ដំបង កំពង់សោម កណ្តាល ស្វាយរៀង និងតាកែវ ក្នុងឆ្នាំ១៩៧៧ ដល់១៩៧៨។ នៅក្នុងកាលៈទេសៈបែបនេះ គេចាត់តាំងអង្គរក្សពីរនាក់ជាអ្នកនាំអ្នកទោសម្នាក់។

៣៧១- ជួនកាលអ្នកទោសដែលត្រូវបានគេចាប់ខ្លួនហើយ ក៏បានផ្ទេរមកឱ្យបុគ្គលិកស-២១ ដែលនៅខាងក្រៅបរិវេណ រួមមានក្នុងខេត្តបាត់ដំបង និងក្រុងភ្នំពេញ។ ការចាប់ខ្លួនបែបនេះត្រូវបានធ្វើឡើងដោយអង្គភាពនានារបស់កម្ពុជាប្រជាធិបតេយ្យ រួមមាន មន្ទីរស-៧១ និងក្រសួងការ

បរទេស និងអ្នកទោសដែលត្រូវបានផ្ទេរជាចុងក្រោយមកស-២១។ មានអ្នកទោសជាច្រើន ត្រូវបានបញ្ជូនផ្ទាល់មកស-២១តែម្តង ដោយកងកម្លាំងនៃកងទ័ពបដិវត្តន៍កម្ពុជានៅភូមិភាគឧត្តរ ដោយមានអមជាមួយនូវលិខិតដែលបិទជិត និងមានត្រាផង ក៏មានផ្ញើមក **ឌុច** ដែរ។

៣៧២- ការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានសម្របសម្រួលយ៉ាងជិតស្និទ្ធិ ដោយ **ឌុច** ជាអ្នករៀបចំកលល្បិចផង។ កម្មាភិបាលទាំងនោះរួមមាន កុយ ធួន (អតីតលេខាភូមិភាគឧត្តរ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម) ឈិម សំអោក ហៅ ប៉ង់ (អតីតប្រធានមន្ទីរស-៧១ និងជាកូនចៅរបស់ **ខៀវ សំផន**) និង ណៃ សារ៉ាន *ហៅ* ម៉ែន សាន ហៅយ៉ា (លេខាភូមិភាគឥសាន)។ ឧទាហរណ៍ នៃ សារ៉ាន ត្រូវបានគេប្រាប់ថា គាត់នឹងត្រូវពិនិត្យសុខភាព តែផ្ទុយទៅវិញគាត់ត្រូវគេចាប់ខ្លួន និងបញ្ជូនមកស-២១ ។ **ឌុច** ខ្លួនឯងបានរៀបចំឯកសារមួយ ដែលមានសេចក្តីដកស្រង់នៃចម្លើយសារភាពពាក់ព័ន្ធនឹងលេខាតំបន់ ២៤ ឈ្មោះ សួស នៅ *ហៅ* ឈូក ហើយបានចម្លងឯកសារដើម្បីឱ្យសមាជិកគណៈអចិន្ត្រៃយ៍ធ្វើការពិចារណា ។ បន្ទាប់ពីមានការចាប់ខ្លួន ឈូក នៅ ក-៧ **ឌុច** បានបញ្ជូន ឈូក ទៅមន្ទីរស-២១ ដោយមាន **នួន ជា** នៅតាមឃ្លាំមើលដំណើរការនោះ។

៣៧៣- អ្នកទោសភាគច្រើនដែលចូលមកស-២១ ត្រូវបានគេដាក់ខ្នោះ និងចងមុខ និងផ្ទេរដឹកតាមឡានដែលបិទជិត។ ជួនកាល ពួកគេត្រូវបានដឹកជាក្រុមធំៗ ពេញក្នុងឡានមិនអាចឱ្យអ្នកទោសអង្គុយបានទេ។ អ្នកទោសទាំងនេះមានអមដំណើរដោយកងការពារ ដែលមានបំពាក់អាវុធផងដែរ។

៣៧៤- ដូចបានកត់សម្គាល់ខាងលើរួចមកហើយថា អតីតបុគ្គលិកស-២១ និងស-២៤ មួយភាគធំត្រូវបានគេចាប់ខ្លួន និងសម្លាប់នៅស-២១៖ ឌុច មានអំណាចក្នុងការបញ្ជាឲ្យធ្វើសកម្មភាពខាងវិន័យប្រឆាំងនឹងបុគ្គលិកស-២១ ឧទាហរណ៍ ដោយធ្វើការបញ្ជូនពួកគេទៅលត់ដំនៅស-២៤ ឬផ្ដើមឲ្យមានការចាប់ខ្លួន និងដាក់ឃុំឃាំងនៅស-២១។ ឌុច បានបញ្ជាឲ្យមានការចាប់ខ្លួនបែបនេះ "ប្រសិនបើកម្មាភិបាលមានពាក់ព័ន្ធ និងមាននិន្នាការ" ឬប្រសិនបើពួកគេមិនបានកែប្រែខ្លួនឯង បន្ទាប់ពីមានការចោទប្រកាន់ថាធ្វើការមិនបានល្អ។

៣៧៥- ដោយមិនគិតដល់ពីមូលហេតុដែលអ្នកទោសទាំងនោះត្រូវនៅក្នុងមន្ទីរស-២១ នោះ ជាធម្មតាពួកគេមិនដែលបានទទួលព័ត៌មានពីមូលហេតុដែលត្រូវគេចាប់ខ្លួននោះទេ ពួកគេក៏គ្មានសិទ្ធិជំទាស់ទៅនឹងការចាប់ខ្លួនតាមយន្តការផ្នែកតុលាការណាមួយដែរ។ ឌុច ដឹងពីភាពស្លូតត្រង់របស់អ្នកទោសទាំងនោះ ដោយនិយាយថា អ្នកដែលត្រូវគេចាប់ខ្លួនភាគច្រើនគឺ "ត្រូវគេចាប់ដោយច្រឡំ" និង"វាជាការខុសឆ្គងដែលបានចាប់ពួកគេ"។

៣៧៦- ក្នុងពេលផ្ទេរអ្នកទោសទៅស-២១ ដំបូងគេទទួលអ្នកទោសនៅផ្ទះមួយនៅលើផ្លូវលេខ៣៦០។ បន្ទាប់មក ពួកគេត្រូវបានចងជាប់គ្នា និងដើរជាខ្សែៗទៅបរិវេណធំ ដើម្បីទៅចុះឈ្មោះនៅអគារ ខ។ ជាទូទៅ កុមារមិនចុះឈ្មោះទេ។ ចំពោះអ្នកទោសពិសេសដូចជា ជនបរទេស ឬមន្ត្រីជាន់ខ្ពស់យោធា ឬមន្ត្រីរដ្ឋាភិបាល ត្រូវគេដំណើរការដោយឡែកនៅក្នុងគុកពិសេស។ ជាធម្មតា គេផ្ដល់ព័ត៌មានឲ្យ ឌុច ជាមុនៗនឹងពួកអ្នកទោសសំខាន់មកដល់ ហើយគាត់ជាអ្នកដំណើរការអ្នកទោសនោះដោយខ្លួនឯង។

៣៧៧- អ្នកទោសដែលទើបមកដល់ត្រូវនៅចងមុខ ឬជាប់ខ្នោះដដែល ហើយត្រូវផ្តល់ព័ត៌មានពីប្រវត្តិរូបរបស់ខ្លួនឱ្យ សួស ធី រួមមាន ឈ្មោះ ទីកន្លែងកំណើត និងមុខរបរ។ ហ៊ិ ជាអ្នកនាំអ្នកទោសសំខាន់ទៅឱ្យ ធី ដើម្បីបញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកទោស តែក្រោយមក ធី មិនមែនជាអ្នកធ្វើប្រវត្តិរូបអ្នកទោសប្រភេទនេះទេ។ ចុងក្រោយ បុគ្គលិកនៅអង្គភាពថតរូបជាអ្នកថតរូបអ្នកទោសដែលចូលមកដល់។ បន្ទាប់មក សួស ធី ជាអ្នកកត់ត្រាពីអគារ និងបន្ទប់ឃុំឃាំងដែលត្រូវដាក់អ្នកទោសនោះ។ បន្ទាប់មក អ្នកយាមក៏នាំអ្នកទោសទៅកាន់បន្ទប់ឃុំឃាំងនោះតែម្តង។

## ការចូលរួមក្នុងការសម្រិតសម្រាំង

៣៧៨- ការចាត់ថ្នាក់អ្នកទោសនៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញ បង្ហាញថា ស-២១ បានចូលរួមចំណែកក្នុងការសម្រិតសម្រាំងរបស់បក្សកុម្មុយនីស្តកម្ពុជា នៅទូទាំងប្រទេសកម្ពុជា។ ការចាត់ថ្នាក់អ្នកទោសទាំងនោះរួមមាន៖

(១) ការសម្រិតសម្រាំងនៅថ្នាក់ភូមិភាគ ដែលបញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញឆ្លុះបញ្ចាំងពីចរន្តនៃការសម្រិតសម្រាំង ដែលបានផ្តួចផ្តើមឡើងដោយមជ្ឈិមបក្ស៖

(ក). មានអ្នកទោសចំនួន៣៦០នាក់ ត្រូវបានចាប់ខ្លួនពីភូមិភាគឧត្តរចាស់ ឬមជ្ឈិមដែលការចាប់ខ្លួនបានកើនឡើងនៅត្រីមាសទី២ ក្នុងឆ្នាំ១៩៧៧។

(ខ) មានអ្នកទោសចំនួន១២១១នាក់ មកពីភូមិភាគឥសាន ដែលការចាប់ខ្លួនបានកើនឡើងចន្លោះត្រីមាសទីបី ក្នុងឆ្នាំ១៩៧៧ និងត្រីមាសទីមួយក្នុងឆ្នាំ១៩៧៨។

(គ) មានអ្នកទោសចំនួន១១៦៥នាក់ មកពីភូមិភាគបូព៌ា ដែលការចាប់ខ្លួនបានកើនឡើងនៅត្រីមាសទីពីរ ក្នុងឆ្នាំ១៩៧៨។

(២) ការសម្រិតសម្រាំងនៅក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យគឺ សមាជិកកងទ័ពបដិវត្តន៍កម្ពុជាក្លាយជាអ្នកទោសដែលមានចំនួនច្រើនជាងគេនៅស-២១ ហើយស-២១ បានចូលរួមពាក់ព័ន្ធដោយផ្ទាល់ ទៅនឹងការសម្រិតសម្រាំងនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា។ ឧទាហរណ៍៖

(ក) នៅខែកញ្ញា ឆ្នាំ១៩៧៦ ឌុច ជួបជាមួយ សុន សេន មិត្ត តាល់ និង ស៊ាត ឆែ (អនុប្រធានសេនាធិការ) ដើម្បីពិភាក្សាអំពីការសម្រិតសម្រាំងនៅកងពល២៩០ និង១៧០ និងបានដោះស្រាយរួមគ្នាជាមួយអ្នកទាំងនោះថា បុគ្គលចំនួន២៩នាក់បន្ថែមទៀតគួរតែត្រូវបញ្ជូនមកស-២១។ ឈ្មោះអ្នកទាំងនោះត្រូវបានសម្រេចរួមគ្នារវាងស-២១ និងកងពលទាំងពីរនោះ។ ជាសរុប មានមនុស្សបីនាក់ត្រូវបានចាប់ខ្លួនពីកងពល២៩០ និង៦៧នាក់ពីកងពល១៧០ ដែលត្រូវបានចាប់ខ្លួនដោយ ស-២១ នៅខែកញ្ញា ឆ្នាំ១៩៧៦។

(ខ) នៅខែមីនា ឆ្នាំ១៩៧៧ លេខាកងពលនានានៃកងទ័ពបដិវត្តន៍កម្ពុជា បានរាយការណ៍ថា ពួកគេបានប្រើប្រាស់ស-២១ ក្នុងការអនុវត្តន៍ការសម្រិតសម្រាំងផ្ទៃក្នុង។

(គ) ឧទាហរណ៍សំខាន់មួយស្តីពីការសម្របសម្រួលរបស់ ស-២១ ក្នុងការចាប់ខ្លួន ជាមួយអង្គភាពនានារបស់កម្ពុជាប្រជាធិបតេយ្យ នៅក្នុងភ័ស្តុតាងដែលទាក់ទងទៅ

នឹងការសម្រិតសម្រាំងកងពល៥០២ នៃកងទ័ពបដិវត្តន៍កម្ពុជា។ ស៊ូ ម៉េត ដែលជាមេបញ្ជាការកងពលនេះ បានផ្លាស់ប្តូរយោបល់គ្នាជាមួយ ឌុច តាមរយៈសំបុត្រចំនួនប្រាំបួនយ៉ាងតិច ចន្លោះថ្ងៃទី១ ខែមេសា និងថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧។ សំបុត្រទាំងនេះបង្ហាញថា បុរសទាំងពីរនាក់នេះពឹងផ្អែកលើព័ត៌មាន និងការសហការពីគ្នាទៅវិញទៅមក៖ ឌុច ជាអ្នកគ្រប់គ្រងលើការសួរចម្លើយទាហានដែល ស៊ូ ម៉េត ចាប់ខ្លួនហើយ ដោយផ្អែកលើចម្លើយសារភាពរបស់ទាហានដែលទទួលរងទារុណកម្មនោះ គាត់ជាអ្នកផ្តល់ឈ្មោះបន្ថែមទៀតទៅឲ្យ ស៊ូ ម៉េត ហើយបន្ទាប់ទៀត ពួកគេក៏កំណត់មុខសញ្ញាជនជាប់សង្ស័យដែលត្រូវចាប់ខ្លួនបន្ថែមទៀត។ យ៉ាងហោចណាស់ក៏មានទាហានចំនួន២៧៣នាក់ដែរពីកងពល៥០២ ដែលត្រូវជាប់ឃុំឃាំង និងសម្លាប់ដោយមន្ទីរស-២១។

(ឃ) ស-២១ ជាអ្នកចាប់ខ្លួន និងសម្លាប់កម្មាភិបាលចំនួន៦៥០នាក់យ៉ាងតិច ពីកងពល៣១០ យ៉ាងហោចណាស់ក៏មានកម្មាភិបាលនិងទាហានចំនួន៧៧៥នាក់ ពីកងពល៤៥០ យ៉ាងហោចណាស់កម្មាភិបាល និងទាហានចំនួន២៧១នាក់ ពីកងពល៧០៣ និងយ៉ាងហោចណាស់កម្មាភិបាល និងទាហានចំនួន២៥៦នាក់ពីកងពល៩២០។

(៣) ការសម្រិតសម្រាំងតាមក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យរួមមាន៖ យ៉ាងហោចណាស់ក៏មានបុគ្គលិកចំនួន២៥៥២នាក់ មកពីក្រសួងនានានៅថ្នាក់មជ្ឈិម និងបុគ្គលិកចំនួន១៥៩៥នាក់មកពីក្រសួងនានានៅថ្នាក់ភូមិភាគ ត្រូវបានចាប់ខ្លួន និងបញ្ជូនមកស-

២១។ ក្រសួងនានានៅថ្នាក់មជ្ឈិមដែលក្លាយជាគោលដៅក្នុងការការសម្រិតសម្រាំងធ្ងន់ធ្ងរ រួមមាន ក្រសួងសង្គមកិច្ចរបស់ **អៀង ធីរិទ្ធ** (មានជនរងគ្រោះ១២០នាក់ យ៉ាងតិច) ក្រសួងការបរទេសរបស់ **អៀង សារី** (មានរងគ្រោះ១៩៥នាក់ យ៉ាងតិច) ក្រសួងសាធារណៈការ (មានជនរងគ្រោះ៥៣២នាក់ យ៉ាងតិច) ក្រសួងពាណិជ្ជកម្ម (មានជនរងគ្រោះ៣៨៦នាក់ យ៉ាងតិច) ក្រសួងថាមពល (មានជនរងគ្រោះ២៦៨នាក់ យ៉ាងតិច) និងក្រសួងអយស្ម័យយាន(មានជនរងគ្រោះ២៥១នាក់ យ៉ាងតិច)។

(៥) ការសម្រិតសម្រាំងផ្ទៃក្នុងនៅថ្នាក់លើ៖ ការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ត្រូវបានដំណើរការជាធម្មតា ដោយការចាប់ខ្លួនអ្នកនៅក្រោមបង្គាប់ (ជាពិសេសកម្មាភិបាលផ្នែកសន្តិសុខដែលមានភារកិច្ចការពារកម្មាភិបាលជាន់ខ្ពស់ទាំងនោះ) ដែលនឹងផ្តល់ចម្លើយសារភាពបញ្ជាក់ពីពិរុទ្ធភាពនៃថ្នាក់លើរបស់ខ្លួន តាមរយៈការធ្វើទារុណ្ណកម្ម និងសួរចម្លើយ។ ឌុច បានពិពណ៌នាពីការអនុវត្តបែបនេះថា៖ "មុនកាប់ឫស្សី ត្រូវកាប់បន្លា"។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

*បរិវេណកណ្តាលនៅ ស-២១*

៣៧៩- អ្នកទោសនៅស-២១ ត្រូវទទួលរងក្នុងស្ថានភាពអមនុស្សធម៌ធ្ងន់ធ្ងរ រហូតធ្វើឱ្យពួកគេមានអារម្មណ៍ថាខ្លួនលែងជាមនុស្សទៀតហើយ។ ឌុច បានទទួលស្គាល់ថា "ការឃុំឃាំង និងការរស់នៅមានលក្ខណៈអមនុស្សធម៌" នៅក្នុងចំណោមឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅស-២១។ អ្នក

ទោសភាគច្រើនត្រូវបានឃុំឃាំងនៅក្នុងបន្ទប់ធំ ដែលមានអ្នកទោសប្រមាណពី២០ ទៅ៦០នាក់ ក្នុងមួយបន្ទប់ ដោយតំរៀបជាជួរ។ ជាធម្មតាអ្នកទោសទាំងនោះត្រូវបានចងភ្ជាប់គ្នានឹងរបាដែក ដែលមានបណ្តោយប្រវែងពី៦០ ទៅ៧០ សង់ទីម៉ែត្រ ហើយដាក់ខ្នោះជើងភ្ជាប់គ្នាត្រង់កជើង។ ជួនកាលអ្នកទោសបុរសត្រូវបានគេដាក់ច្រវាក់បន្តគ្នាជាជួរពី១០ ទៅ១៥ នាក់។ ប្រសិនបើគេឃើញថា មានអ្នកទោសណាម្នាក់មានកម្លាំងខ្លាំងជាងគេអ្នកនោះ នឹងត្រូវគេដាក់ខ្នោះជើងទាំងពីរបន្ថែមទៀត។ មានអ្នកទោសជាច្រើនក៏ត្រូវបានគេចងមុខដែរនៅពេលជាប់ឃុំឃាំង។

៣៨០- អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងបន្ទប់តូចៗ មិនត្រូវបានគេផ្តល់មុង ខ្នើយ ឬភួយទេ។ អ្នកទាំងនោះត្រូវដេកលើកន្ទេលរហែករយ៉ែ ឬលើកំរាលឥដ្ឋទទេតែម្តង។ ជាធម្មតា បន្ទប់ឃុំឃាំងតូចៗ គឺប្រើសម្រាប់ដាក់អ្នកដែលទើបមកដល់ថ្មី និងអ្នកទោសសំខាន់ៗដូចជាកម្មាភិបាលជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យជាដើម។

៣៨១- អ្នកទោសប្រុសៗទាំងអស់ត្រូវគេឃុំឃាំង២៤ម៉ោង ក្នុងមួយថ្ងៃ ដោយអ្នកយាមមានអាវុធនៅប្រចាំការ។ អ្នកទោសទាំងនោះត្រូវជាប់ខ្នោះជើងដដែល នៅពេលនាំចេញចូល ទទួលទានអាហារ ដេក និងពេលបាញ់ទឹកលាងបន្ទប់ ថតរូប ឬយកចេញទៅសួរចម្លើយ និងនាំត្រឡប់មកវិញ។ អ្នកទោសទាំងនោះត្រូវប្រាប់អ្នកយាម ប្រសិនបើគេចង់ប្តូរបៀបដេក។ បទបញ្ជាសម្រាប់អ្នកទោសនៅស-២១ ត្រូវបានបង្ខំឱ្យអនុវត្តតាមយ៉ាងតឹងរ៉ឹងគឺ៖ អ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យចេញពីបន្ទប់ឃុំឃាំង ឬហាត់ប្រាណអ្វីទេ ប្រសិនបើគេបញ្ចេញសំឡេងឡូឡានៅពេលដេក នឹងត្រូវគេវាយមិនខាន គេក៏មិនទទួលបានការអនុញ្ញាតឱ្យនិយាយជាមួយអ្នកយាមដែរ។

៣៨២- ជាធម្មតា ស្ត្រី និងកុមារត្រូវគេចាក់សោឃុំនៅក្នុងបន្ទប់ជាមួយគ្នា។ មានស្ត្រីមានផ្ទៃពោះមួយចំនួនក៏ត្រូវបានគេដាក់ឃុំឃាំងដែរ ហើយមានស្ត្រីមួយចំនួនក៏បានឆ្លងទន្លេដោយមានជំនួយពីពេទ្យនៅទីនោះដែរ។ ទារកដែលកើតមកត្រូវបានគេបំបែកចេញពីម្តាយដោយបង្ខំ។ អ្នកទោសស្ត្រីម្នាក់ជាអតីតបុគ្គលិកពេទ្យស២១ ត្រូវបានគេឆក់ខ្សែភ្លើង ត្រូវបានគេ សម្រាតខោអាវអស់ដោយប្រើកម្លាំង ហើយបន្ទាប់មកត្រូវឆ្មាំគុកម្នាក់ចាប់រំលោភសេពសន្ថវៈនៅក្នុងបន្ទប់ឃុំឃាំង របស់គាត់។

៣៨៣- នៅស-២១ អ្នកទោសមិនមានសម្លៀកបំពាក់គ្រប់គ្រាន់ទេ។ អ្នកទោសបុរសត្រូវបានគេបញ្ជាឲ្យស្រាតនៅសល់តែខោទ្រនាប់ ឬខោខ្លីតែប៉ុណ្ណោះ ដែលពួកគេត្រូវស្លៀករហូតពេលចប់ពីការឃុំឃាំងនោះ។ អ្នកទោសបុរសត្រូវបានគេហាមឃាត់មិនឲ្យស្លៀកខោជើងវែង ចៀសវាងយកខោមកធ្វើអត្តឃាត។ ទោះបីនៅក្នុងខែរងាក៏ដោយ ក៏អ្នកទោសបុរសត្រូវបានគេអនុញ្ញាតត្រឹមតែឲ្យស្លៀកខោខ្លី និងពាក់អាវប៉ុណ្ណោះ រីឯអ្នកទោសស្ត្រីអាចស្លៀកពាក់សម្លៀកបំពាក់ធម្មតារបស់ខ្លួនបាន។

៣៨៤- អ្នកទោសនៅស-២១ត្រូវគេបង្អត់អាហារ ទោះបីមានម្ហូបអាហារផលិតនៅស-២៤ ដែលផ្គត់ផ្គង់ដល់គណៈអចិន្ត្រៃយ៍លើសពីសេចក្តីត្រូវការក៏ដោយ។ ឌុច បានបញ្ជាក់ លើចម្លើយសាក្សីនានាដែលអះអាងពីការកង្វះរបបអាហារ។ ក្នុងមួយថ្ងៃមានរបបអាហារតែពីរដងប៉ុណ្ណោះ គឺនៅពេលព្រឹក និងពេលល្ងាច ជាធម្មតាមានបាយ និងសម្ល ឬទឹកបបររាវៗ។ ការទទួលរបបអាហារមិនគ្រប់គ្រាន់ធ្វើឲ្យអ្នកទោសស្គមស្គាំង ទ្រុឌទ្រោមរាងកាយ និងស្លាប់បាត់បង់ជីវិត។

ជួនកាលគេយកការបង្អត់អាហារមកធ្វើជាទណ្ឌកម្មដែរ។ ចំពោះអ្នកទោសសំខាន់ និងអ្នកយាម បានទទួលរបបអាហារប្រសើរជាងនេះ។

៣៨៥- ទឹកផឹកក៏មានការខ្វះខាតដែរនៅស-២១។ អ្នកទោសត្រូវសុំអ្នកយាមផឹកទឹក តែមានអ្នកទោសមួយចំនួនប៉ុណ្ណោះដែលបានទទួលទឹកផឹក។ អ្នកទោសម្នាក់បានបញ្ជាក់ថា ដោយសារគាត់ខ្លាចអ្នកយាមពេក គាត់មិនដែលហ៊ានសុំទឹកផឹកថែមទេ។

៣៨៦- ស្ថានភាពអនាម័យនៅស-២១ គួរឱ្យរន្ធត់ជាពន់ពេក។ គ្មានបង្គន់សម្រាប់បន្ទោរបង់ទេ ផ្ទុយទៅវិញ អ្នកទោសត្រូវបានគេបង្ខំឱ្យបន្ទោរបង់ក្នុងកេសគ្រាប់ ឬប៊ីដុងទឹក នៅក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួន ដែលត្រូវហុចតគ្នាពីម្នាក់ទៅម្នាក់។ ជារៀងរាល់ថ្ងៃ អ្នកទោស "ស្រាល" ជាអ្នកដើរប្រមូលលាមកនិងទឹកនោមនេះចេញ។ បន្ទប់ឃុំឃាំងមិនបានសម្អាតជាទៀងទាត់ទេ តែលើកលែងក្នុងករណីចាំបាច់ប៉ុណ្ណោះ ដូចជាពេលដែលក្លិនស្អុយនោះទ្រាំលែងបាន។ អ្នកទោសត្រូវអ្នកយាមបាញ់ទឹកដាក់ដើម្បីសម្អាតបន្ទប់ឃុំឃាំង ដោយអ្នកយាមឈរពីខាងក្រៅ ហើយបាញ់ទឹកចូលក្នុងបន្ទប់តែម្តង។ អ្នកទោសនៅជាប់ខ្នោះជើងដដែល ហើយមិនត្រូវបានអនុញ្ញាតឱ្យដុសសម្អាតខ្លួនទេ និងមិនឱ្យសាប៊ូដុសខ្លួនអ្វីដែរ។ ការងូតទឹកត្រូវបានធ្វើឡើងផ្សេងៗពីគ្នា មានការរាយការណ៍ថា ជួនកាលពីរដងក្នុងមួយថ្ងៃ ជួនកាលពីរថ្ងៃម្តង ជួនកាលបួនថ្ងៃម្តង ឬ"បួនទៅដប់ថ្ងៃម្តង"។ ដោយសារអ្នកទោសមិនបានងូតទឹកទៀងទាត់ធ្វើឱ្យបន្ទប់ឃុំឃាំងនៅមានក្លិនស្អុយដដែល។

៣៨៧- អ្នកទោសជាច្រើនត្រូវធ្លាក់ខ្លួនឈឺ ដោយសារតែស្ថានភាពបែបនេះ។ ស្បែកពួកគេឡើងរមាស់ និងកើតជាចៃក្នុងស្បែកទៀតផង។ ជម្ងឺទូទៅរួមមាន ជម្ងឺរាគរូស ជម្ងឺគ្រុន និងឈឺក្បាល។ អ្នក

ទោសក៏មានស្លាប់ដោយសារជម្ងឺផ្សេងដែរ (រួមមាន រាគមួល) និងខ្វះអាហារូបត្ថម្ភ បន្ថែមទៅលើការធ្វើទារុណ្ណកម្មហួសប្រមាណ។ សាកសពមួយចំនួនត្រូវគេកប់នៅក្នុងបរិវេណនោះតែម្តង ។ [redacted]។

៣៨៨- ជំងឺទាំងនេះកើតឡើងដោយសារខ្វះការថែរទាំផ្នែកពេទ្យឲ្យបានត្រឹមត្រូវ។ គេថែរទាំផ្នែកពេទ្យដល់អ្នកទោសតែក្នុងគោលបំណងឲ្យនៅរស់ សម្រាប់បន្តការសួរចម្លើយតែប៉ុណ្ណោះ។ នៅពេលជាមួយគ្នានោះ ចំពោះអ្នកទោសដែលកំពុងរងទារុណ្ណកម្មមិនត្រូវបានទទួលការថែរទាំផ្នែកពេទ្យដែលមានកម្រិតនេះទេ ហើយមានអ្នកទោសមួយចំនួនត្រូវបាត់ខ្លួន មុនពេលទទួលបានការព្យាបាលនេះទៅទៀត។ ផ្ទុយទៅវិញ អ្នកយាមទទួលបានការព្យាបាលផ្នែកពេទ្យកម្រិតខ្ពស់ជាងនេះ។

៣៨៩- នៅស-២១ មានគ្រូពេទ្យដែរ ប៉ុន្តែពួកគេមិនបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ មិនមានសម្ភារៈគ្រប់គ្រាន់ ហើយបានត្រឹមតែព្យាបាលជម្ងឺគ្រុនផ្តាសាយធម្មតា និងលាងរបួសដែលបណ្តាលមកពីការធ្វើទារុណ្ណកម្មតែប៉ុណ្ណោះ (រួមមាន ស្នាមជាំ និងរបួសលើខ្នងដៃ ជើង និងត្រចៀកអ្នកទោស រួមទាំងដំបៅលើស្បែក និងរបួសដែលកើតចេញពីការដកក្រចកដៃក្រចកជើង) ដោយប្រើជាតិអ៊ីយ៉ូដប៉ុណ្ណោះ។ មានពេទ្យចាស់ៗជាច្រើនត្រូវបានគេចាប់ខ្លួន និងយកទៅសម្លាប់ ហើយក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ នៅសល់តែពេទ្យក្មេងតែប៉ុណ្ណោះដែលនៅរស់។

៣៩០- ជាធម្មតាអ្នកទោសត្រូវបានគេព្យាបាលនៅក្នុងបន្ទប់ឃុំឃាំងតែម្តង ទោះបីគេមានជំងឺបែបណាក៏ដោយ។ មានការផ្គត់ផ្គង់ថ្នាំពេទ្យតិចតួច ហើយជារឿយៗជាថ្នាំដែលផលិតនៅក្នុងស្រុកគ្មានប្រសិទ្ធទេ ដូចជាថ្នាំអាចម៍ទន្សាយជាដើម។

៣៩១- អ្នកទោសនៅស-២១ជាច្រើន ក៏ក្លាយជាជនរងគ្រោះនៃការធ្វើពិសោធន៍វេជ្ជសាស្ត្រផ្សេងៗដែររួមមាន ការរៀនវះកាត់ ដែល ឌុច ជាអ្នករៀបចំឈ្មោះអ្នកដែលត្រូវយកទៅធ្វើពិសោធ ពីបញ្ជីឈ្មោះអ្នកទោស។ [redacted]។

៣៩២- អ្នកទោសក៏ត្រូវគេបូមឈាមយកដោយបង្ខំដែរ ដើម្បីផ្គត់ផ្គង់ដល់ការព្យាបាលយុទ្ធជនដែលរងរបួស។ ការបូមឈាមនេះ បានបណ្តាលឱ្យមនុស្សមួយចំនួនត្រូវស្លាប់ដែរ ដោយសារអ្នកទោសត្រូវបានគេទុកចោលឱ្យស្លាប់តែម្តង បន្ទាប់ពីត្រូវបានគេបូមឈាមយកក្នុងបរិមាណដ៏ច្រើន។ វាមិនច្បាស់លាស់ទេ អ្វីដែលបានកើតឡើងចំពោះឈាមដែលត្រូវបានបូម ពីអ្នកទោស។ ទំនងជាលេចឡើងនូវករណីដែលថា ឈាមទាំងនោះត្រូវគេយកទៅផ្គត់ផ្គង់នៅតាមមន្ទីរពេទ្យដែលនៅក្រៅស-២១ តែមិនច្បាស់លាស់ថាតើករណីបែបនេះតែងកើតឡើងជាប្រចាំ ឬមួយយ៉ាងណានោះទេ។ ឌុច អះអាងថា គេមិនបានយកឈាមទៅមន្ទីរពេទ្យមុនីវង្ស ឬពេទ្យ ១៧ មេសាទេ ដោយសារថាស-២១ ក៏មានមន្ទីរពេទ្យរបស់ខ្លួនដែរ គឺពេទ្យ៩៨ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ សុន សេន។ គេរក្សាឈាមទុកនៅកន្លែងមួយដែលគេឱ្យឈ្មោះថា ស្រះស្រង់

នៅខាងកើតស-២១។ នៅគ្រាមួយ មានឈោម "ខូច" ឬ"មិនបានប្រើ" ចំនួនពី៣០ ទៅ៤០ប្លោក ត្រូវបានគេបំផ្លាញចោល។

៣៩៣- លក្ខណៈអមនុស្សធម៌ ការវាយបំពារបំពានផ្នែករាងកាយ និងការខ្លាចរអានូវការវាយដំ និងការប្រព្រឹត្តមិនគប្បីផ្សេងៗទៀត បានធ្វើឱ្យអ្នកទោសនៅ ស-២១ បាត់បង់អស់នូវសេចក្តីថ្លៃថ្នូរបស់ខ្លួន។ អ្នកទោសតែងបានឮថាអ្នកទោសផ្សេងទៀតត្រូវគេធ្វើទារុណ្ណកម្ម និងឃើញអ្នកទាំងនោះត្រឡប់មកបន្ទប់ឃុំឃាំងវិញដោយមានស្នាមរបួស។ សភាពអស់សង្ឃឹមរបស់អ្នកទោសបណ្តាលឱ្យមានការប៉ុនប៉ងធ្វើអត្តឃាតជាច្រើនករណី។ ឧទាហរណ៍ ឌុច បានរំលឹកឡើងវិញថា មានអ្នកទោសម្នាក់នៅស-២១ ប៉ុនប៉ងធ្វើអត្តឃាតដោយលេបខ្មៅ ហើយត្រូវបានគេយកធ្វើការវះកាត់យកខ្មៅមកវិញ ដើម្បីបន្តសួរចម្លើយតទៅទៀត។ គេណែនាំអ្នកយាមឱ្យប្រុងប្រយ័ត្នបំផុតចំពោះរឿងនេះ ហើយអ្នកយាមរូបនោះនឹងត្រូវទទួលទណ្ឌកម្មមិនខាន ប្រសិនបើអ្នកទោសអាចធ្វើអត្តឃាតបាន។ ទោះបីមានវិធានការទាំងនេះក៏ដោយ ក៏នៅមានអ្នកទោសមួយចំនួនអាចសម្លាប់ខ្លួនបានដោយជោគជ័យដែរ។ មានអ្នកទោសម្នាក់បានបាញ់សម្លាប់ខ្លួនឯងដោយឆក់បានកាំភ្លើងពីអ្នកយាមម្នាក់ ហើយរឿងនេះ ឌុច បានលើកយកមកធ្វើជាឧទាហរណ៍ប្រាប់ដល់អ្នកយាមឱ្យមានការប្រុងប្រយ័ត្នបំផុត។ មានអ្នកទោសផ្សេងទៀតចងក លេបថ្នាំ ឬប្រើដែកគោលដើម្បីសម្លាប់ខ្លួន។ សូម្បីតែអ្នកយាមក៏មានការភ័យខ្លាចដែរ និងជួនកាលមានអ្នកខ្លះធ្វើអត្តឃាត ដើម្បីចៀសផុតពីការជាប់ឃុំឃាំងនៅ ស-២១។

*ស-២៤ (ព្រៃស)*

៣៩៤- លក្ខណៈអមនុស្សធម៌ក៏មាននៅស-២៤ដែរ។ ជាទូទៅ កម្រិតនៃលក្ខណៈអមនុស្សធម៌គឺអាស្រ័យទៅលើកម្រិតទោសដែលគេបែងចែក ដោយអ្នកទោសប្រភេទទីបី ត្រូវទទួលរងនូវលក្ខណៈអមនុស្សធម៌ធ្ងន់ធ្ងរជាងគេ។ អ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យដើរហើរដោយសេរីនោះទេ ហើយមានការឃាមតឹងរ៉ឹងទៀតផង។ គេប្រើគិញដើម្បីស៊ើបរកពួកក្បត់ដែលគេសង្ស័យ។ អ្នកទោសត្រូវបានគេអនុញ្ញាតត្រឹមតែឱ្យនិយាយជាមួយគ្នា នៅក្នុងកងតែមួយប៉ុណ្ណោះ។ នៅពេលយប់ អ្នកទោសត្រូវបានគេចាក់សោរទុកក្នុងអគាររួម។ អ្នកទោសខ្លះក៏ត្រូវគេឃុំឃាំងក្នុងបន្ទប់បិទជិតដែរ ជាមួយអ្នកទោសផ្សេងទៀតអាចដាក់បានដល់ទៅដប់ពីរនាក់ឯណោះ។ អ្នកទោសខ្លះទៀតត្រូវបានគេដាក់ខ្នោះនៅពេលយប់ និងពេលកំពុងធ្វើការ។

៣៩៥- ដូចបានកត់សម្គាល់ខាងលើរួចមកហើយដែរថា អាហារដែលលើសពីសេចក្តីត្រូវការដែលផលិតបាននៅស-២៤ ត្រូវបានយកទៅផ្គត់ផ្គង់ដល់គណៈអចិន្ត្រៃយ៍ទៀត។ នៅពេលជាមួយគ្នានោះដែរ ក៏កើតមានការអត់ឃ្លានយ៉ាងរាលដាលនៅស-២៤ ទៀតផង។ អ្នកទោសទាំងបីប្រភេទត្រូវរងគ្រោះដោយសាររបបអាហារមិនគ្រប់គ្រាន់ ជាពិសេសដោយសារការងារពលកម្មជាទម្ងន់ដោយបង្ខំដែលធ្វើដោយដៃដែលពួកខ្លួនត្រូវបានគេឱ្យបំពេញ។ របបអាហារដែលផ្តល់ឱ្យគឺមានលក្ខណៈប្រែប្រួលខុសៗពីគ្នាក្នុងចំណោមអ្នកទោស អាស្រ័យទៅតាមកងនីមួយៗ៖ អ្នកទោសដែលឋិតនៅក្នុងប្រភេទទី៣ បានទទួលបបររាវប៉ុណ្ណោះ រីឯអ្នកទោសក្នុងប្រភេទទី១ និងទី២ បានទទួលរបបអាហារគ្រាន់បើជាង។ ដូចនៅស-២១ ដែរគឺថា មានការបង្អត់អាហារជាការដាក់ទណ្ឌកម្មដែរ។ មានកុមារ៣ ឬ៤នាក់បានស្លាប់ដោយសារការអត់អាហារដែរ។

៣៩៦- លក្ខណៈអនាម័យ និងគុណភាពនៃការថែទាំផ្នែកពេទ្យរបស់មន្ទីរស-២៤ មានផ្សេងៗពីគ្នាដែលជារួម មិនគ្រប់គ្រាន់ទេ។ នៅពេលយប់ អ្នកទោសត្រូវបន្ទោរបង់លាមកដាក់កេសគ្រាប់នៅក្នុងបន្ទប់របស់ខ្លួន។ សេវាពេទ្យជារើយៗមិនត្រូវបានផ្ដល់ឱ្យអ្នកទោសដែលរងរបួស ទេ។ អ្នកទោសប្រភេទទី៣ បានទទួលការព្យាបាលសុខភាពអាក្រក់ជាងគេ។ មានបុគ្គលិកពេទ្យម្នាក់ដែលត្រូវបានគេឱ្យទៅធ្វើការលត់ដំកែប្រែខ្លួននៅ ស២៤ បានរំលឹកឡើង វិញថាគេផ្ដល់ថ្នាំឱ្យតែមួយចង់គត់ប៉ុណ្ណោះសម្រាប់អ្នកទោស "គ្រប់គ្នា"។ អ្នកទោសទាំងឡាយណាដែលធ្វើការយឺតមិនទាន់គេ ព្រោះមានជម្ងឺត្រូវបានគេបន្ទោសថាអ្នកនោះ ខ្ជិល។

## ពលកម្មដោយបង្ខំ

៣៩៧- ស-២៤ ត្រូវបានគេយកទៅប្រើសម្រាប់ "លត់ដំ" និង"អប់រំកែប្រែ" ដែលរួមទាំងការងារដោយបង្ខំផងដែរ។ ក៏ប៉ុន្តែ គោលបំណងនៃការងារដោយបង្ខំនៅស-២៤ គឺមិនត្រឹមតែ "លត់ដំ" និង"អប់រំកែប្រែ" ប៉ុណ្ណោះទេ តែថែមទាំងផ្ដល់ការគាំទ្រដល់ស-២១ ផងដែរ។ ការងារដែលគេចាត់ចែងឱ្យអ្នកទោសធ្វើ អាស្រ័យទៅតាមប្រភេទនីមួយៗរបស់អ្នកទោសនេះ។ ឧទាហរណ៍ អ្នកទោសក្នុងប្រភេទទីបី ធ្វើការលំបាកជាងគេរួមមានការសំអាតដីដោយប្រើដៃ។ អ្នកទោសប្រភេទទីពីរផ្សេងទៀត ត្រូវបានបង្ខំឱ្យអូសនង្គ័លរនាស់ដូចជាសត្វ។ ចំណែកអ្នកទោសប្រភេទទី១ ត្រូវបានគេចាត់តាំងឱ្យធ្វើការងារស្រាលៗ។

៣៩៨- ជាទូទៅ លក្ខខណ្ឌធ្វើការងារគួរឱ្យរន្ធត់ណាស់។ ការងារទាំងអស់ត្រូវធ្វើដោយដៃ ហើយជារឿយៗគ្មានសម្ភារៈសមរម្យសម្រាប់ផ្ដល់ឱ្យទេ។ ទម្រង់នៃការងាររួមមាន ធ្វើស្រែ ច្រូតស្រូវ រកត្រី ចិញ្ចឹមសត្វ ត្បាញកន្ទេល សំណង់ និងលើកទំនប់ និងជីកប្រឡាយ។ អ្នកទោសទាំងអស់

នៅស-២៤ សុទ្ធតែត្រូវបានគេបង្ខំឱ្យធ្វើការដោយដៃ រួមទាំងស្ត្រី និងកុមារផងដែរ។ អ្នកទោសទាំងនោះក៏មិនអនុញ្ញាតឱ្យដើរហើរ ឬនិយាយស្តីជាមួយអ្នកដទៃពេលកំពុងធ្វើការឡើយ។

៣៩៩- ជាធម្មតា ការងារចាប់ផ្តើមពីព្រឹកព្រលឹម ជួនកាលពីម៉ោង៣ព្រឹក និងបញ្ចប់នៅពេលព្រលប់ ជួនកាលដល់កណ្តាលអាធ្រាត។ អ្នកទោសអាចសម្រាក និងទទួលទានអាហារបានរយៈពេលពីរម៉ោង។ ឬមួយពួកគេមិនត្រូវបានអនុញ្ញាតឱ្យសម្រាកទេ ទាល់តែធ្វើការចប់។ មនុស្សជាច្រើនស្លាប់ដោយបាក់កម្លាំង និងអត់អាហារ។ ទណ្ឌកម្មចំពោះការធ្វើការមិនបានល្អរួមមាន ការវាយនឹងខ្សែតី និងការវាយនឹងដំបង ការធ្វើទារុណ្ណកម្ម ការកាត់បន្ថយរបបអាហារ និងយកទៅសម្លាប់។ ជាងនេះទៅទៀត គេតម្រូវឱ្យអ្នកទោសចូលរួមរៀនសូត្រនៅពេលល្ងាច ដែលត្រូវគេបង្រៀនអំពីមាគ៌ាបក្ស និងត្រូវគេព្រមានមិនឱ្យលួចអាហារ។ អ្នកទោសទាំងនោះក៏ត្រូវគេបង្ខំឱ្យធ្វើស្វ័យទិតៀនទៀតផង។

## ការសួរចម្លើយ និងទារុណ្ណកម្ម

### គោលបំណង

៤០០- ដូចបានកត់សម្គាល់រួចមកហើយនៅក្នុងផ្នែកទីតាំងនិងប្រតិបត្តិការគឺថាការកំណត់អត្តសញ្ញាណខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺជាគោលបំណងបឋមមួយរបស់ស-២១។ ដើម្បីសម្រេចបានតាមគោលបំណងនេះ អ្នកទោសភាគច្រើននៅស-២១ ត្រូវឆ្លងកាត់ការសួរចម្លើយដែលមានលក្ខណៈជាប្រព័ន្ធ ដែលនាំឱ្យមាន “ចម្លើយសារភាព” យ៉ាងពិស្តារ។ សារៈសំខាន់នៃចម្លើយសារភាព គឺពាក់ព័ន្ធនឹងការពិតដែលថា អ្នកសួរចម្លើយខ្លួនឯងត្រូវគេគំរាមកំហែងថានឹង

ត្រូវទទួលទារុណ្ណកម្ម ប្រសិនបើអ្នកទោសស្លាប់មុនពេលយកចម្លើយសារភាពដែលគេពេញចិត្តបាន។

៤០១- ចម្លើយសារភាពរួមមានបួនផ្នែកសំខាន់ៗគឺៈ ប្រវត្តិរូបលម្អិតរបស់អ្នកទោស ប្រវត្តិ"សកម្មភាពក្បត់" របស់ខ្លួន ផែនការដែលរៀបចំសម្រាប់ដំណើរការការបំផ្លិចបំផ្លាញនាពេលអនាគត និង "ខ្សែក្បត់"របស់អ្នកទោសនោះ។ នៅពេលផ្តល់ចម្លើយសារភាព ជាធម្មតាអ្នកទោសត្រូវឆ្លើយទទួលស្គាល់ថា ខ្លួន និងអ្នកផ្សេងទៀតជាពួកក្បត់ ដែលបម្រើមហាអំណាច ឬទីភ្នាក់ងារបរទេស (ជាធម្មតាគឺ សេអ៊ីអា កាហ្សេបេ និងបក្សកុម្មុយនីស្តវៀតណាម)។

៤០២- ចម្លើយសារភាពមានគោលបំណងពីរយ៉ាងគឺៈ ទី១ តាមរយៈការសារភាពថាមាន"បណ្តាញ" ទៅនឹងសេអ៊ីអា កាហ្សេបេ ឬវៀតណាម អ្នកទោសបានបញ្ជាក់ពីការផ្តល់យុត្តិកម្មក្នុងការដែលខ្លួនត្រូវបានគេចាប់ខ្លួន និងយកទៅសម្លាប់ ទី២ "ខ្សែក្បត់" ដែលមាននៅក្នុងចម្លើយសារភាពនោះ រួមទាំងព័ត៌មានអំពីសកម្មភាពក្បត់របស់អ្នកទោសនោះ ត្រូវបានគេយកទៅប្រើដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យបន្ថែមទៀតដែលនឹងត្រូវគេចាប់ខ្លួន និងនាំមកស-២១ ដែរ។ ចម្លើយសារភាពដែលស-២១ទាញយកមកបាន ក៏ត្រូវបានគេយកទៅប្រើដើម្បីជាមធ្យោបាយឃោសនាដោយបក្សកុម្មុយនីស្តកម្ពុជា។ ចម្លើយសារភាពត្រូវបានគេយកទៅផ្សាយតាមវិទ្យុជាទៀងទាត់ និងត្រូវបានគេយកទៅអានឮៗនៅពេលមានប្រជុំ និងវគ្គរៀនសូត្ររបស់បក្សកុម្មុយនីស្តកម្ពុជាម្តងៗ។

៤០៣- ទារុណ្ណកម្មត្រូវបានគេយកមកប្រើជាបច្ចេកទេសបឋម ដើម្បីទាញយកចម្លើយ។ អ្នកទោសនឹងត្រូវរងរបួស ឬទទួលការគំរាមកំហែង ប្រសិនបើខ្លួនមិនបានសារភាព ឬមិនបានប្រាប់ឈ្មោះ

ពួកក្បត់ផ្សេងទៀត។ តាមការពិត មានសាក្សីជាច្រើនបានអះអាងថា រាល់ការសួរចម្លើយទាំងអស់នៅស-២១ គឺសុទ្ធតែមានទារុណ្ណកម្មធ្ងន់ធ្ងរទាំងអស់។ អ្នកសួរចម្លើយត្រូវផ្ញើទៅឱ្យ ឌុច ដើម្បីវិភាគ និងផ្តល់ការណែនាំបន្ថែមទៀត។ ឌុច បានវិភាគ និងបានចារនៅលើចម្លើយសារភាពនានា បានពិភាក្សាពីចម្លើយសារភាពទាំងនោះជាមួយនឹងថ្នាក់លើផ្ទាល់របស់ គាត់ និងបានផ្តល់យោបល់ជូនទៅគណៈអចិន្ត្រៃយ៍ដើម្បីធ្វើការចាប់ខ្លួនបន្តទៀត។

## វិធីសាស្ត្រ និងទម្រង់

៤០៤- (ជារឿយៗ ការសួរចម្លើយតែងចាប់ផ្តើមក្រោយពេលអ្នកទោសនោះមកដល់ស-២១ ភ្លាម។ អ្នកទោសពិសេសត្រូវបានគេយកទៅសួរចម្លើយនៅអគារ **ក** នៃបរិវេណកណ្តាល អ្នកទោសភាគច្រើនផ្សេងទៀត ត្រូវបានគេយកទៅសួរចម្លើយ និងធ្វើទារុណ្ណកម្មនៅផ្ទះនានាដែលនៅជុំវិញបរិវេណកណ្តាល។ អ្នកទោសដែលត្រូវគេយកទៅសួរចម្លើយ ត្រូវបានកំណត់នៅក្នុងបញ្ជីដែលរួមមានឈ្មោះ និងពេលវេលាដែលត្រូវយកទៅសួរចម្លើយ។ អ្នកយាមជាអ្នកទៅយកអ្នកទោសដល់បន្ទប់ឃុំឃាំងដោយចងមុខ និងដាក់ខ្នោះ រួចបណ្តើរទៅបន្ទប់សួរចម្លើយ ដែលជាធម្មតាត្រូវបានគេដាក់ខ្នោះភ្ជាប់នឹងតុមួយ។ បន្ទាប់មក គេដោះខ្នោះ និងស្រាយមុខចេញដើម្បីសួរចម្លើយ និងធ្វើទារុណ្ណកម្ម។ ជាធម្មតា មានអ្នកសួរចម្លើយម្នាក់ និងអ្នកទោសម្នាក់ក្នុងពេលសួរចម្លើយម្តងៗ។)

៤០៥- ការសួរចម្លើយត្រូវបានធ្វើឡើងម្តងហើយម្តងទៀត និងមានរយៈពេលយូរ ជាធម្មតាគេសួរចម្លើយបីដងក្នុងមួយថ្ងៃគឺៈ ពីម៉ោង៧ ដល់ម៉ោង១១ព្រឹក ពីម៉ោង២ ដល់ម៉ោង៥ល្ងាច និងពី

ម៉ោង៧ ដល់ម៉ោង១១យប់។ ការសួរចម្លើយដល់អ្នកទោសនឹងត្រូវបញ្ចប់ តែក្នុងករណីដែលគេយល់ថា ចម្លើយសារភាពរបស់អ្នកទោសនោះពេញលេញតែប៉ុណ្ណោះ។

៤០៦- ដូចបានកត់សម្គាល់រួចមកហើយ នៅផ្នែកលក្ខណៈអមនុស្សធម៌បានបញ្ជាក់ខាងលើថា ក្នុងករណីអ្នកទោសត្រូវរងគ្រោះថ្នាក់អាចនឹងបាត់បង់ជីវិតដោយសារការធ្វើទារុណ្ណកម្ម បុគ្គលិកស-២១ រៀបចំការព្យាបាលឲ្យអ្នកទោសនោះបាននៅរស់បន្តទៅទៀត ដើម្បីអាចបញ្ចប់ការសួរចម្លើយបាន។ ការឆ្លើយតប និងចម្លើយសារភាពរបស់អ្នកទោសត្រូវបានគេកត់ត្រាយ៉ាងយកចិត្តទុកដាក់បំផុត៖ គេអាចវាយជាអង្គុលីលេខ ឬសរសេរដៃ នៅពេលកំពុងសួរចម្លើយ និងក្រោយមកគេទៅវាយអង្គុលីលេខម្តងទៀត។ នៅចុងឆ្នាំ១៩៧៨ ការសួរចម្លើយអ្នកទោសត្រូវថតសម្លេងជាខ្សែអាត់ដើម្បីជួយសម្រួលដល់អ្នកទោសផង និងអ្នកសួរចម្លើយផង។

៤០៧- ក្រុមអ្នកសួរចម្លើយអនុវត្តវិធីសាស្ត្របីយ៉ាងក្នុងការសួរចម្លើយ ឬធ្វើទារុណ្ណកម្ម ដែលបានពណ៌នាក្នុងផ្នែករចនាសម្ពន្ធគ្រប់គ្រងខាងលើ។ ជារួមវិធីសាស្ត្រនៃការធ្វើទារុណ្ណកម្មដែលអនុវត្តនៅស-២១ មានលក្ខណៈស្រដៀងគ្នានឹងវិធីសាស្ត្រដែលបានអនុវត្តនៅមន្ទីរម-១៣ ដែលជាមន្ទីរមុនមាន ស-២១។ សេចក្តីណែនាំក្នុងការសួរចម្លើយត្រូវបានកត់ត្រានៅក្នុងសៀវភៅកំណត់ ដៃរបស់បុគ្គលិកស-២១ ចំនួនបីក្បាល។ ពាក់ព័ន្ធនឹងទារុណ្ណកម្ម បញ្ជីស្ថិតិបានអះអាងថា៖

៤០៨- "សំណួមពរនៃការធ្វើទារុណកម្ម គឺយកចម្លើយវា ដូចនេះត្រូវធ្វើអោយវាឈឺ ដើម្បីអោយវាឆាប់ឆ្លើយ។ ពេលធ្វើទារុណកម្មត្រូវពិនិត្យសុខភាពវាមុន ត្រូវពិនិត្យមើលរំពាត់។ កុំលោភចង់ឆាប់ នាំអោយស្លាប់បាត់ព័ត៍មាន ខាត។"។

៤០៩- ដូចបានពណ៌នានៅផ្នែក ការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា រួចមកហើយគឺថា ស-២១ តែងតែទទួលការអប់រំជាបន្តបន្ទាប់ស្តីពីវិធីសាស្ត្រក្នុងការធ្វើទារុណ្ណកម្ម នៅតាមវគ្គរៀនសូត្រនានា ដែលរៀបចំដោយ ឌុច និងអ្នកសួរចម្លើយចាស់ៗ។ នៅក្នុងវគ្គនីមួយៗ អ្នកទោសត្រូវបានគេនាំចូលមក ហើយសិក្ខាកាមត្រូវកត់ត្រានៅពេលដែលអ្នកសួរចម្លើយមានបទពិសោធន៍សួរចម្លើយអ្នកទោសនោះ។ ឌុច បានប្រើប្រាស់នូវអ្វីដែលគេហៅថា វិធីសាស្ត្ររៀនសូត្រ "ការវាយប្រហារឆាប់ សម្រេចជោគជ័យឆាប់"ធ្វើជាផ្នែកអ្នកសួរចម្លើយដែលបានចូលរួមនៅវគ្គរៀនសូត្រពេលព្រឹក ត្រូវបានគេបញ្ជូនឱ្យអនុវត្តតាមមេរៀនដែលបានរៀនសូត្រដោយឱ្យអ្នកសួរ ចម្លើយអ្នកទោសនៅពេលក្រោយក្នុងថ្ងៃដដែល។

៤១០- ឌុច ពន្យល់ថា "មានទារុណ្ណកម្មបួនប្រភេទត្រូវបានយកមកប្រើនៅ ស-២១ ដែលទទួលការឯកភាពពី សុន សេន ផងគឺ៖ ១-វាយនឹងរំពាត់ ២-ឆក់ខ្សែភ្លើង ៣-យកថង់ផ្លាស្ទិកមកគ្របក្បាលដើម្បីឱ្យថប់ដង្ហើម និង៤-យកកន្សែងពោះគោគ្របមាត់និងមុខ ហើយចាក់ទឹកត្រជាក់ពីកំសៀវ"។ ក៏ប៉ុន្តែ មានវិធីសាស្ត្រនៃការធ្វើទារុណ្ណកម្មមួយចំនួនបន្ថែមទៀត ក៏ត្រូវបានគេយកមកអនុវត្តដែរ រួមមាន៖ ដុតនឹងបារី និងអំពូលភ្លើង ធ្វើឱ្យរងាដោយប្រើទឹកត្រជាក់ និងកង្ហារចាក់ឬដកក្រចកដៃនិងក្រចកជើង ជ្រមុជទឹក ហែកសាច់នឹងដង្កាប់ បង្ខំអ្នកទោសឱ្យវាយតប់គ្នាចងព្យួរជើងឡើងលើ បង្ខំឱ្យស៊ីលាមក និងផឹកទឹកនោម យកឈើរុកចូលប្រដាប់ភេទស្ត្រី និងបង្ខំឱ្យអ្នកទោសសំពះជញ្ជាំង តុ ឬកៅអី ឬ រូបឆ្កែ។

៤១១- ការវាយនឹងដំបងដែក អារុធ ខ្សែភ្លើង ខ្សែតី មែកត្របែក ឬរំពាត់ផ្តៅ គឺជាវិធីសាស្ត្រនៃការធ្វើទារុណ្ណកម្មដែលនិយមប្រើជាងគេ ព្រោះវាមានប្រសិទ្ធិភាពជាង។ អ្នកសួរចម្លើយក៏ចូលចិត្តប្រើ

ការឆក់ខ្សែភ្លើង និងវិធីសាស្ត្រនៃទារុណ្ណកម្មដោយប្រើទឹកដែរ។ ការឆក់ខ្សែភ្លើងត្រូវបានប្រើដោយយកខ្សែភ្លើងញាត់ចូលត្រចៀក និងប្រដាប់ភេទរបស់អ្នកទោស។ ជួនកាលអ្នកទោសត្រូវឆក់រហូតដល់សន្លប់ ឬស្លាប់ក៏មាន។ ទោះបី ឌុច ហាមប្រាមមិនឱ្យអ្នកសួរចម្លើយបណ្ដោយឱ្យអ្នកទោសស្លាប់ក្នុងពេលកំពុងធ្វើទារុណ្ណកម្មក៏ដោយ តែដោយសារទារុណ្ណកម្ម និងការវាយវាត់មានលក្ខណៈធ្ងន់ធ្ងរពេក ក្នុងករណីជាច្រើនមានអ្នកទោសក៏បាត់បង់ជីវិតដែរ។

៤១២- អតីតអ្នកទោសម្នាក់ឈ្មោះ ប៊ូ ម៉េង បានពណ៌នាថា គាត់ត្រូវបានគេធ្វើទារុណ្ណកម្មម្ដងហើយម្ដងទៀតក្នុងពេលសួរចម្លើយដែលមានរយៈពេលជាច្រើនថ្ងៃ។ គាត់ត្រូវបានគេវាយនឹងដំបង នឹងខ្សែតី និងឆក់ខ្សែភ្លើងដោយប្រើខ្សែភ្លើងភ្ជាប់នឹងឆ្នៅផ្នែកខាងក្នុងក្បែរប្រដាប់ភេទគាត់។ គាត់ក៏ត្រូវបានគេវាយលើផ្ទៃមុខ និងក្បាល ដែលបណ្ដាលឱ្យគាត់ត្រូវខូចដល់ប្រព័ន្ធសោតវិញ្ញាណជាអចិន្ត្រៃយ៍។ អ្នកសួរចម្លើយបានយកឈើរុកក្ដិះទៅក្នុងស្នាមរបួសរបស់គាត់ ដែលនៅលើខ្នងបណ្ដាលឱ្យគាត់មានស្នាមរហូតដល់សព្វថ្ងៃ។ ចំណែក ជុំ ម៉ី វិញត្រូវបានគេសួរចម្លើយ និងធ្វើទារុណ្ណកម្មរយៈពេល១២ថ្ងៃ ១២យប់។ គាត់ក៏ត្រូវបានគេវាយវាត់និងឆក់ខ្សែភ្លើងដែរ។ ក្នុងគ្រាពិសេសមួយ គាត់ត្រូវបានដកក្រចកជើងដោយសេង។ វ៉ាន់ ណាត បានឃើញផ្ទាល់ភ្នែកពេលអ្នកទោសម្នាក់ត្រូវ "ចងព្យួរជើងឡើងលើដោយខ្សែពួរ រួចទម្លាក់ក្បាលជ្រមុជចូលពាងដែលមានទឹកពេញ"។

៤១៣- ពួកបុគ្គលិកដែលមិនបានចូលរួមសួរចម្លើយ និងអ្នកទោសនៅស-២១ សុទ្ធតែបានដឹងពីការអនុវត្តន៍ការធ្វើទារុណ្ណកម្ម។ មានសាក្សីជាច្រើនបានបញ្ជាក់ថា អ្នកទោសមានស្នាមបន្សល់ទុកក្រោយពេលធ្វើទារុណ្ណកម្មរួចរួមមាន៖ ស្នាមរបួស បាត់ក្រចកដៃក្រចកជើង លលាដ៍ក្បាលបែក

ស្នាមជាំ និងដំបៅរលួយពេញខ្លួន។ គេឮស្នូរសម្រែកស្រែក រួមទាំងសំឡេងកុមារផង ពេញទាំងស-២១។

## ការសម្លាប់មនុស្សក្រៅច្បាប់

៤១៤- ឌុច ពន្យល់ថា "មនុស្សទាំងអស់ដែលជាប់នៅស-២១ សន្មត់ថានឹងត្រូវកំទេចទាំងអស់"។ [redacted] សូម្បីតែអ្នកទោសដែលត្រូវបានគេចាប់ច្រឡំ ក៏ត្រូវយកទៅសម្លាប់ដែរ ដើម្បីរក្សាការសម្ងាត់នៅស-២១។ ការសម្លាប់គឺជាលទ្ធផលចុងក្រោយសម្រាប់អ្នកទោសទាំងអស់ លើកលែងតែអ្នកដែលគេចាត់ទុកថាមានសារៈសំខាន់ ដោយសារតែមានជំនាញណាមួយតែប៉ុណ្ណោះ(ដូចជា វ៉ាន់ ណាត និងប៊ូ ម៉េង) ហើយអាចចៀសផុតពីសេចក្ដីស្លាប់នៅពេលវៀតណាមវាយលុកចូលមកដល់។

៤១៥- ស្របទៅនឹងប្រតិបត្តិការសម្ងាត់ខ្ពស់នៅស-២១ ការសម្លាប់ និងអំពើឃោរឃៅបានកើតឡើងជាដំបូងនៅក្នុងបរិវេណកណ្ដាល និងបរិវេណជុំវិញ។ ដូចបានកត់សម្គាល់នៅផ្នែកទីតាំង និងប្រតិបត្តិការរួចមកហើយថានៅឆ្នាំ១៩៧៦ ដើម្បីបង្ការការរាលដាលនៃជំងឺដែលកើតចេញពីការកើនឡើងនៃចំនួនសាកសពនៅខាងក្នុង និងជុំវិញបរិវេណនោះ ឌុច បានប្ដូរទីតាំងសម្រាប់សម្លាប់មនុស្សទៅជើងឯកវិញ។ ការរៀបចំកន្លែងសម្លាប់នៅជើងឯករួចរាល់នៅដើមឆ្នាំ១៩៧៧។ បន្ថែមលើចំនួនជនរងគ្រោះដែលបញ្ជូនពីមន្ទីរឃុំឃាំងពីបរិវេណកណ្ដាលនៅស-២១ ស-២៤ ក៏បញ្ជូនអ្នកទោសទៅជើងឯកដែរ។

៤១៦- ទោះបីបញ្ជីឈ្មោះអ្នកទោសដែលបានពិនិត្យឡើងវិញបង្ហាញថា យ៉ាងហោចណាស់ក៏មានអ្នកទោសចំនួន១២២៧៣នាក់ ត្រូវបានសម្លាប់នៅស-២១ក៏ដោយ ក៏អ្នកស្លាប់ពិតប្រាកដនៅស-២១មានចំនួនច្រើនជាងនេះ ហើយជនរងគ្រោះអាចឡើងរហូតដល់១៤០០០នាក់។ ជនរងគ្រោះចំនួនច្រើនបំផុតដែលត្រូវបានគេយកទៅសម្លាប់នៅជើងឯក ដែលមាននៅក្នុងរណ្តៅកប់សាកសពរួមមានបុរស ស្ត្រី និងកុមារចំនួនជាង៩០០០នាក់។ ឯកសារមួយដែលបានកត់ត្រាពីការជីកកកាយសាកសពនៅជើងឯកមុនឆ្នាំ១៩៨៩បង្ហាញថា មានសាកសពចំនួន៨៩៨៥នាក់ ត្រូវជីកកកាយចេញពីរណ្តៅចំនួន៨៦ ក្នុងចំណោមរណ្តៅសរុបចំនួន ១២៩។ រូបថតនៃរណ្តៅសាកសពដែលបានជីកនៅជើងឯកក៏បញ្ជាក់ពីការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ដែលបានធ្វើឡើងនៅកន្លែងនោះដែរ។ អដ្ឋិធាតុមួយចំនួនក៏នៅមានតំកល់ក្នុងស្តូបមួយនៅជើងឯក។

៤១៧- ដូចការសួរចម្លើយដែរ ការសម្លាប់មនុស្សនៅស-២១ មានការរៀបចំល្អ និងមានលក្ខណៈជាប្រព័ន្ធផង។ ជាធម្មតា ទាល់តែក្រោយពេលគេកត់ត្រាបានចម្លើយសារភាពពេញលេញហើយ ទើបគេយកអ្នកទោសទៅសម្លាប់។ ក៏ប៉ុន្តែ តាមរយៈភ័ស្តុតាងចេញពីបញ្ជាជាលាយលក្ខណ៍អក្សររបស់ ឌុច បញ្ជាក់ថាយ៉ាងហោចណាស់ក៏មានបីដងដែរ ដែលអ្នកត្រូវបានគេបញ្ជូនយកទៅសម្លាប់ផ្ទាល់ ដោយមិនចាំបាច់ឆ្លងកាត់ការសួរចម្លើយ។ មានអ្នកទោសដឹកពេញឡានដែលតម្រង់មកស-២១ ក៏ត្រូវបង្វែរត្រង់យកទៅសម្លាប់នៅជើងឯក ដោយគ្មានសួរចម្លើយអ្វីទាំងអស់នៅពេលស-២១ ពេញប្រៀបដោយមនុស្សមិនអាចផ្ទុកបានបន្ថែមទៀត ឬ ប្រសិនបើអ្នកទោសដែលទើបដឹកមកដល់ថ្មី ត្រូវបានគេយល់ថា"មិនសូវសំខាន់"។

៤១៨- នៅក្នុងមន្ទីរស-២១ ចាប់ពីពេលដែលគាត់ត្រូវបានគេចាត់តាំងជាលេខាមក ឌុច មានអំណាច ត្រឹមតែថា ត្រូវសម្លាប់អ្នកទោសណាមុនតែប៉ុណ្ណោះ។ ដោយឡែក តាមបញ្ជារបស់ ហ៊ី សួស ធី បានរៀបចំបញ្ជីឈ្មោះអ្នកទោសដែលត្រូវយកទៅកំទេច។ បន្ទាប់មក គេយកបញ្ជីនេះទៅឱ្យ ឌុច ដើម្បីឱ្យគាត់មានយោបល់ និងឯកភាព។ បន្ទាប់មក ឌុច ចារពាក្យថា "កំទេច" ក្បែរឈ្មោះអ្នក ដែលត្រូវគេយកទៅសម្លាប់នោះ ហើយក៏ត្រូវបញ្ជាក់ពីឈ្មោះអ្នកទោសដែលត្រូវទុកសិន ដើម្បី បញ្ចប់ការសួរចម្លើយ។ បន្ទាប់មក គេយកបញ្ជីទាំងនេះទៅឱ្យអ្នកយាម ដែលជាអ្នកត្រូវបញ្ចេញ អ្នកទោសពីបន្ទប់ឃុំឃាំង ដោយមានដាក់ខ្នោះដៃ និងចងមុខ រួចបណ្តើរអ្នកទោសទាំងនោះ ចេញទៅឱ្យអ្នកយាមនៅខាងក្រៅ។ ប្រសិនបើគេកំណត់ថា ត្រូវយកទៅសម្លាប់នៅជើងឯក គេ ក៏ដឹកអ្នកទោសតាមឡានចេញទៅតែម្តង។

## បរិវេណកណ្តាលស-២១

៤១៩- ជនរងគ្រោះមួយភាគត្រូវបានគេសម្លាប់ ឬស្លាប់នៅក្នុង ឬជុំវិញបរិវេណកណ្តាល។ អ្នកទោស សំខាន់ ដែលជាធម្មតាត្រូវបានគេថតរូបជាមុនៗនឹងយកទៅកប់ ដូចជា កុយ ធួន វន វ៉េត ឆាយ គឹមហ៊ រ និង ណាត ត្រូវបានគេសម្លាប់នៅស-២១ និងត្រូវបានគេកប់តាមកន្លែងនានានៅក្នុង បរិវេណគុកនេះ។ អ្នកទោសផ្សេងទៀតដូចជាសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ជនបរទេស(ជាសំខាន់គឺជនជាតិវៀតណាម) ជនរងគ្រោះដោយសារការសួរចម្លើយ និងការបួម ឈាមដោយបង្ខំ បុគ្គលិកស-២១ និងកុមារ ក៏ត្រូវបានគេយកទៅសម្លាប់ និងកប់នៅក្នុង ឬជុំវិញ បរិវេណកណ្តាលដែរ។

៤២០- មានការប៉ាន់ស្មានថាមានអ្នកទោសមិនតិចជាងមួយពាន់នាក់ទេ ដែលបានស្លាប់បាត់បង់ជីវិតដោយសារត្រូវគេបូមឈាមច្រើនហួសចំណុះ។ ក្រោយពេលសួរចម្លើយចប់សព្វគ្រប់ហើយ ហ៊ិ និងពេទ្យនៅទីនោះ បានជ្រើសរើសអ្នកទោសដែលមានសុខភាពល្អ រួចនាំយកទៅគិលានដ្ឋានរបស់ ស-២១ ដែលស្ថិតតាមផ្លូវលេខ១១៣។ បន្ទាប់ពីពេទ្យបានបូមឈាមអស់ពីខ្លួនជនរងគ្រោះដាក់ក្នុងប្លោកឈាមរួចហើយ ហ៊ិ ប្រាប់ សួស ធី ឱ្យបញ្ចូលឈ្មោះជនរងគ្រោះទៅក្នុងបញ្ជីឈ្មោះដែលត្រូវបាន "កំទេច" ហើយ។

៤២១- ការសម្លាប់មនុស្សនៅស-២១ ធ្វើឡើងនៅពេលយប់។ ជាទូទៅ អ្នកទោសត្រូវបានគេវាយរហូតដល់ស្លាប់ ដោយប្រើដំបងដែក និងជារឿយៗបំពង់កពួកគេត្រូវបែកធ្លាយ។ អ្នកទោសពីបីនាក់ដែលនៅអគារជុំវិញស-២១ ត្រូវបានគេដុតទាំងរស់។

៤២២- កុមារជាច្រើនក៏ត្រូវបានគេសម្លាប់នៅស-២១ដែរ បន្ទាប់ពីឪពុកម្តាយពួកគេត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ហើយ។ ក្នុងករណីខ្លះ ពួកគេត្រូវបានសម្លាប់ដោយទម្លាក់តាមបង្អួចពីជាន់ទីបីទៅលើកម្រាលបេតុងនៅខាងក្រោម។ កុមារត្រូវបានគេយកទៅកប់ចម្ងាយ១០០ម៉ែត្រ ខាងជើងបរិវេណកណ្តាល។

៤២៣- ជាធម្មតា ជនរងគ្រោះដែលត្រូវបានគេសម្លាប់នៅស-២១ ត្រូវបានគេកប់នៅក្នុង ឬជុំវិញបរិវេណនោះ។ ក្នុងពេលកំពុងជីករណ្តៅសពរួមនៅក្នុងតំបន់នេះ គេបានជីកឃើញសាកសពមានជាប់ជាមួយនូវខ្សែទីឡុង ខ្សែពួរ ច្រវាក់ជើង ក្រណាត់ចងមុខ ស្បង់លោក ខោអាវ និង ឯកសណ្ឋានយោធា។

៤២៤- នៅខែមករា ឆ្នាំ១៩៧៩ នួន ជា បានបញ្ជាឲ្យមានការសម្លាប់អ្នកទោសទាំងអស់ដែលនៅសល់ក្នុងស-២១។ ជាច្រើនថ្ងៃមុនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានអ្នកទោសក្នុងចំនួនដ៏ច្រើន ត្រូវបានគេសម្លាប់នៅស-២១ខ្លះ និងខ្លះទៀតនៅជើងឯក។ អ្នកសួរចម្លើយម្នាក់ឈ្មោះ ណាន បានប្រើចំពុះទង់ចាក់សម្លាប់អ្នកទោសដែលនៅសេសសល់ក្នុងអគារ ក ដោយធ្វើឲ្យដាច់ក្បាលមនុស្សពីរនាក់។

## ជើងឯក

៤២៥- ជាមធ្យម មានអ្នកទោសពី៦០ ទៅ១០០នាក់ត្រូវបានដឹកចេញពី២ទៅ៣ដងក្នុង១ខែ ចេញពីស-២១ ទៅសម្លាប់នៅជើងឯក។ ជាងនេះទៅទៀត ការសម្លាប់ចំនួនច្រើន ត្រូវបានធ្វើនៅជើងឯកក្នុងកាលៈទេសៈជាច្រើន រួមមានថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ និងនៅខែធ្នូ ឆ្នាំ១៩៧៨ នៅពេលមានជនរងគ្រោះចំនួន៣០០នាក់មកពីភូមិភាគបូព៌ា ត្រូវបានសម្រិតសម្រាំងដោយគ្មានការសួរចម្លើយ។ ការសម្លាប់កុមារក្នុងចំនួនដ៏ច្រើនក៏បានកើតឡើងផងដែរនៅជើងឯក រួមមានការសម្លាប់កុមារចំនួន១៦០នាក់ក្នុងពេលតែមួយថ្ងៃនៅខែកក្កដា ឆ្នាំ១៩៧៧។

៤២៦- ជាធម្មតា អ្នកទោសត្រូវបានគេដឹកតាមឡានទៅជើងឯក ដោយមានដាក់ខ្នោះដៃ ច្រវាក់ជើង និងចងមុខ។ ការផ្ទេរអ្នកទោសធ្វើឡើងនៅពេលយប់ ហើយអ្នកទោសទៅដល់ជើងឯកនៅចន្លោះម៉ោង៧ និងម៉ោង៩យប់។ ពេលទៅដល់ អ្នកទោសត្រូវបានគេទុកក្នុងផ្ទះឈើមួយ ហើយគេបណ្តើរយកទៅសម្លាប់នៅមាត់រណ្តៅម្នាក់ម្តងៗ។ នៅពេលគេយកទៅដល់មាត់រណ្តៅ អ្នកទោសម្នាក់ៗត្រូវគេបង្ខំឲ្យលុតជង្គង់នៅពីមុខមាត់រណ្តៅ ហើយបន្ទាប់មកក៏ត្រូវគេសំពងកញ្ចឹងកពីក្រោយដោយដំបងដែកថែប ភ្លៅរទេះ ឬដែកបំពង់ទីប ដោយពេលនោះបំពុងកអ្នកទោស

នោះក៏ត្រូវចាក់ធ្លាយ។ បន្ទាប់មកអ្នកយាមក៏សម្រាតយកសម្លៀកបំពាក់និងខ្នោះដៃចេញ រួចរុញសាកសពទម្លាក់ក្នុងរណ្តៅ។ ក្នុងមួយរណ្តៅមានសាកសពជាងដប់នាក់ ហើយមានរណ្តៅខ្លះមានសាកសពរហូតដល់សែសិបនាក់។

## មន្ទីរសន្តិសុខកោះខ្សឹង

### ទីតាំង និងប្រតិបត្តិការ

៤២៧- មន្ទីរសន្តិសុខកោះខ្សឹង(តទៅនេះហៅថា "កោះខ្សឹង") មានទីតាំងនៅភូមិកោះខ្សឹង ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តកំពង់សោម និងជាផ្នែកមួយនៃតំបន់៣៧ នៃភូមិភាគបស្ចិម។ កោះខ្សឹងប្រតិបត្តិការយ៉ាងហោចណាស់ពីចុងឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ នៅពេលដែលមានអ្នកទោសជាច្រើនដែលជាប់ឃុំឃាំងនៅកោះខ្សឹង ត្រូវបានផ្ទេរមកគុកតានៃ នៅស្រុកព្រៃនប់។

៤២៨- កោះខ្សឹងជាមន្ទីរសន្តិសុខធំមួយដែលបែងចែកជាពីរទីតាំង។ បរិវេណទីមួយជាគុកដែលរួមមានអគារឃុំឃាំងជាច្រើន និងមានផ្ទះសួរចម្លើយមួយ និងត្រូវបានគេប្រើសម្រាប់ឃុំឃាំងអ្នកទោសផង និងសួរចម្លើយអ្នកទោសធ្ងន់ផង។ បរិវេណទីពីរជាជំរំអប់រំកែប្រែ ដែលប្រើសម្រាប់ឲ្យធ្វើការជាទម្ងន់ និងលត់ដំពួកអ្នកទោសស្រាល។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងមន្ទីរសន្តិសុខ

៤២៩- ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ កោះខ្យងគឺជាមន្ទីរសន្តិសុខសម្រាប់តំបន់៣៧ នៃភូមិភាគបស្ចិម។ នៅខែធ្នូ ឆ្នាំ១៩៧៦ កងពលលេខ១ ត្រូវបានផ្ទេរមកពីភូមិភាគនិរតីមកភូមិភាគបស្ចិម និងទទួលខុសត្រូវផ្នែកសន្តិសុខក្នុងតំបន់៣៧ និងភូមិភាគបស្ចិមទាំងមូល។ ពេទ្យ សឿង គឺជាមេបញ្ជាការកងពលលេខ១ ហើយក្រោយមកក៏ក្លាយជាសមាជិកគណៈភូមិភាគ។ សឿង មានទាហានចំនួន៧០០០នាក់ និងឈរជើងនៅស្រុកព្រៃនប់ មកមើលមន្ទីរសន្តិសុខនេះយូរៗម្តង ហើយនៅឆ្នាំ១៩៧៧ ក៏បានចូលរួមក្នុងការប្រជុំធំមួយដែលមានកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាចំនួន១០០នាក់នៅកោះខ្យង។ មេបញ្ជាការរងប្រចាំកងពលលេខ១ [redacted] ឈរជើងនៅខេត្តកោះកុងក្នុងតំបន់៣៧។ [redacted]។

[redacted] នៅខែធ្នូ ឆ្នាំ១៩៧៦ នៅពេលដែលកងពលលេខ១ ទទួលខុសត្រូវផ្នែកសន្តិសុខនៅភូមិភាគបស្ចិម លេខាតំបន់៣៧ ឈ្មោះ សៅ កង ហៅ ញ៉ឹក ត្រូវបានចាប់ខ្លួន និងនាំមកស-២១ ហើយតំបន់១១ ត្រូវបានបញ្ចូលទៅក្នុងតំបន់៣៧។ ដោយមានការដឹកនាំ និងសម្របសម្រួលផ្ទាល់ពីមជ្ឈិមបក្ស នោះ ព្រឹត្តិការណ៍ទាំងនេះក្លាយជាចំណុចចាប់ផ្តើមនៃការសម្រិតសម្រាំងនៅភូមិភាគបស្ចិមជាទ្រង់ទ្រាយធំដែលចំណាយរយៈពេលជាងមួយឆ្នាំ។ [redacted]

៤៣១- ជូ ជេត ហៅ ស៊ី ជាលេខាភូមិភាគបស្ចិម រហូតដល់ពេលត្រូវចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៨។ នៅពេល តា ម៉ុក ចូលមកជំនួសតំណែង ជូ ជេត ជាផ្លូវការក្នុងឋានៈជាលេខាភូមិភាគ ហាក់ដូចជាមានលេចឡើងនូវព្រឹត្តិការណ៍ដែលថា អនុលេខា [redacted] ជាអ្នកទទួលខុសត្រូវការងារប្រចាំថ្ងៃនៅភូមិភាគបស្ចិមនេះ។ មន្ទីរភូមិភាគបស្ចិមដែលគេហៅថាមន្ទីរម-៤០១ មានទីតាំងស្ថិតនៅច្បារមន ខេត្តកំពង់ស្ពឺ។ មន្ទីរភូមិភាគនេះផ្ញើរបាយការណ៍ជាទៀងទាត់ទៅមន្ទីរ៨៧០ អំពីបញ្ហាផ្សេងៗ ដែលបានពណ៌នាពី“សភាពការណ៍ខ្មាំងខាងក្នុង” ក្នុងតំបន់៣៧ និងវិធាននានា “ដើម្បីអនុវត្តមាគ៌ាចាត់តាំងរបស់បក្ស ដើម្បីពិនិត្យ និងបោសសម្អាត” ខ្មាំងទាំងនោះ។

## នៅក្នុងមន្ទីរសន្តិសុខ

៤៣២- កោះខ្យងត្រូវបានគ្រប់គ្រង និងការពារដោយផ្ទាល់របស់ឃោធាកងពលលេខ១ ដែលមកពីកំពង់ឆ្នាំង។ ប្រធានមន្ទីរសន្តិសុខនេះមុនគេឈ្មោះ វឿន។ អនុប្រធានមន្ទីរសន្តិសុខនេះ [redacted] គឺជាប្រធានក្រុមសួរចម្លើយ ហើយក្លាយជាប្រធានក្រោយពេល វឿន ធ្វើអត្តឃាត។

## ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៤៣៣- ទំនាក់ទំនងរវាងកោះខ្យង និងថ្នាក់លើដែលមានឋានានុក្រមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកើតមានតាមរយៈការរាយការណ៍ព័ត៌មានជាទៀងទាត់ ពីលើចុះមកក្រោមតាមឋានានុក្រម។ ព័ត៌មានដែលបានទទួលពីការសួរចម្លើយត្រូវបានចែករំលែករវាងកោះខ្យង មន្ទីរភូមិភាគបស្ចិម

និងមជ្ឈិមបក្ស។ ក្រៅពីនេះ ក៏មានការប្រជុំរវាងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ ហើយព័ត៌មានទាក់ទងនឹងការចាប់ឃុំឃាំងពួកក្បត់ និងខ្មាំងក៏ត្រូវបានពិភាក្សាដែរ។

៤៣៤- កម្មាភិបាលភូមិភាគបានទទួលសេចក្តីណែនាំជាក់លាក់បន្ថែមទៀត ពីតំណាងមជ្ឈិមបក្សនៅពេលមានសន្និបាតប្រចាំឆ្នាំនៅភូមិភាគបស្ចិម។ ក្នុងសន្និបាតដែលរៀបចំពីថ្ងៃទី៣ ដល់ទី៧ ខែមិថុនា ឆ្នាំ១៩៧៦ ផ្តោតជាសំខាន់ទៅលើសុន្ទរកថារបស់ "សមមិត្តតំណាងអង្គការបក្ស" ដែលគេជឿថាអាចជា ប៉ុល ពត ឬ **នួន ជា** ក្នុងការខិតខំបង្កើនផលិតកម្មស្រូវ និងសម្រេចឱ្យបានតាមគោលដៅរបស់បក្សគឺ ៣តោនក្នុងមួយហិកតា។ ក៏ប៉ុន្តែ នៅឆ្នាំបន្ទាប់មកទៀត ក្នុងសុន្ទរកថាដែលថ្លែងដោយ "តំណាងអង្គការបក្ស" ដែលគេជឿថាជា **នួន ជា** ផ្តោតតែទៅលើការបន្តសម្រិតសម្រាំងនៅភូមិភាគបច្ចិមតែប៉ុណ្ណោះ។

៤៣៥- នៅក្នុងសុន្ទរកថាដែលបានថ្លែងនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ និងបានបោះពុម្ពនៅខែសីហា ឆ្នាំ១៩៧៧ ក្នុងទស្សនាវដ្តីទង់បដិវត្តន៍ កម្មាភិបាលភូមិភាគបានទទួលព័ត៌មានថា តំបន់៣៧ "មានលក្ខណៈស្មុគស្មាញជាងតំបន់៣១ និងតំបន់៣២ ពីព្រោះមានសមាសភាពថ្មីៗជាច្រើន ហើយមានប្រវត្តិមិនល្អ"។ វាគ្មិនរូបនោះបានពិភាក្សាជាពិសេសអំពី "ក្រុមអាញ៉ឹក" ដែលសំដៅដល់អតីតលេខាតំបន់៣៧ ឈ្មោះ សៅ កង ហៅ ញ៉ឹក ដែលត្រូវគេសម្រិតសម្រាំង ដែលជាក្រុមមួយត្រូវបាន "បង្កើតឡើងនៅក្នុងបក្សជន នៅក្នុងកម្មាភិបាល នៅក្នុងយោធា"។

៤៣៦- តំណាងមជ្ឈិមបក្សក៏បានត្អូញត្អែរផងដែរថា សហករណ៍ជាច្រើននៅក្នុងភូមិភាគបស្ចិមត្រូវបានគ្រប់គ្រងដោយអតីតទាហានរបបសាធារណរដ្ឋខ្មែរ ហើយបានដឹកនាំឱ្យកម្មាភិបាលភូមិភាគធ្វើ

ការស្រាវជ្រាវរក "ខ្មាំងបង្កប់" ដោយធ្វើការសើរើពីសវតា និងវណ្ណៈសង្គមរបស់គណៈសហករណ៍ ដើម្បី"វាយកំទេចខ្មាំង និង សមាសសភាពមិនល្អដែលបង្កប់នៅខាងក្នុង និង គ្រប់គ្រងសហករណ៍" និងដើម្បីធានាថា យ៉ាងហោចណាស់ក៏មានសហករណ៍៥០% ដែរដែលនឹងត្រូវគ្រប់គ្រងដោយកសិករក្រ ឬកណ្តាលថ្នាក់ក្រោម នៅដំណាច់ឆ្នាំ។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៤៣៧- អនុលោមតាមសេចក្តីណែនាំរបស់មជ្ឈិមបក្ស មនុស្សជាច្រើននៅតំបន់៣៧ ត្រូវបានចាប់ឃុំឃាំងនៅមន្ទីរសន្តិសុខកោះខ្យង ពេលសម្រិតសម្រាំងក្នុងភូមិភាគបស្ចិម ដោយការចាប់ផ្តើមចាប់ខ្លួនលេខាតំបន់៣៧ នៅខែធ្នូ ឆ្នាំ១៩៧៦ ហើយមិនបានបញ្ចប់ការចាប់ខ្លួនទេ រហូតទាល់តែមានការចាប់ខ្លួនលេខាភូមិភាគនៅខែមីនា ឆ្នាំ១៩៧៨។ ក្នុងពេលធ្វើការសម្រិតសម្រាំងនោះ មានការរៀបចំការប្រជុំកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា រួមទាំង [redacted] ដែលជាមេបញ្ជាការកងពលលេខ១ទៀតផង ត្រូវបានរៀបចំធ្វើឡើងនៅកោះខ្យង។ ប្រជាជននៅទីតាំងនោះត្រូវបានគេប្រាប់ថា "កុំមានការព្រួយបារម្ភ ប្រសិនបើមេសហករណ៍ ឬសមាជិកគណៈស្រុកបាត់ខ្លួន" ដោយសារពួកគេជា "ពួកក្បត់" និងជា"ភ្នាក់ងារបង្កប់" ដែលត្រូវរកឲ្យឃើញ និង"កម្ចាត់ចោល"។

៤៣៨- មន្ទីរសន្តិសុខនេះបានដាក់អ្នកទោសម្តងចំនួនចន្លោះពី១០០ ទៅ២០០នាក់។ តាមការប៉ាន់ស្មានជារៀងរាល់ថ្ងៃមានអ្នកទោសចំនួន៥ ទៅ១០នាក់ បានមកដល់មន្ទីរសន្តិសុខនេះ។ ក្នុងអគារឃុំឃាំងធំនីមួយៗ មានអ្នកទោសចំនួនពី២០ ទៅ៣០នាក់។ អ្នកទោសជាច្រើនត្រូវបានឃុំឃាំងនៅក្នុងកន្លែងកសាងខ្លួនដាច់ដោយឡែកពីគ្នា។

៤៣៩- ភាគច្រើននៃអ្នកទោសនៅគុកកោះខ្យងគឺជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលមកពីតាមបណ្តាស្រុក ឃុំ និងសហករណ៍នានានៃតំបន់៣៧ ដែលបានជាប់ចោទពីបទក្បត់។ កម្មាភិបាលមូលដ្ឋានរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរសន្តិសុខនេះ មានឈ្មោះ ប៉ែន ភ្លួង *ហៅ* ប៉ុង ជាលេខាស្រុកព្រៃនប់ តា ព្រឿង ជាប្រធានឃុំស្រែអំបិលរួម និងប្រធានសហករណ៍ជាច្រើននាក់ទៀត។ ២ថ្ងៃបន្ទាប់ពីគណៈឃុំ និងប្រធានសហករណ៍ត្រូវបានគេហៅទៅប្រជុំនៅឯមន្ទីរស្រុកព្រៃនប់ តាម បណ្តោយផ្លូវជាតិលេខ៤ នៅពេលមួយគេបានប្រទះឃើញ"គេដឹកមួយឡានពេញរួមទាំង ប្រធានភូមិ និងប្រធានសហករណ៍ផងដែរ"។

៤៤០- គុកនេះក៏បានដាក់ប្រជាជនថ្មី និងអតីតកងទ័ពនៃរបបសាធារណរដ្ឋខ្មែរផងដែរ។ នៅឆ្នាំ១៩៧៧ ក្រុមជាតិពន្ធុវៀតណាម និងខ្មែរក្រោមមួយក្រុមធំដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីដែលគេបានផ្ញើពីភូមិនានាទៅឲ្យមន្ទីរស្រុក ត្រូវបានចាប់ខ្លួនយកទៅកាន់កោះខ្យង។ មនុស្សជាប់ឃុំឃាំងផ្សេងៗនៅកោះខ្យង ជាមនុស្សដែលបានជាប់ចោទពីបទលួចហូបអាហារ ផ្តល់ស្បៀងឲ្យខ្មែរស ឬអំពើផ្សេងៗដែលបានធ្វើឲ្យពួកគេក្លាយខ្លួនជាសត្រូវរបស់អង្គការ។

៤៤១- មុននឹងបញ្ជូនអ្នកទោសទៅកាន់កោះខ្យង ខ្មែរក្រហមបានឃុំឃាំង និងសួរចម្លើយពួកគេនៅមន្ទីរមូលដ្ឋាន ឬនៅតាមទីកន្លែងផ្សេងៗដូចជាមន្ទីរស្រុកនៅភូមិបត់សេម៉ាន់។ ជាទូទៅ កងទ័ពនៃកងពលធំលេខ១ គឺជាអ្នកចាប់ខ្លួនអ្នកទោស។ អ្នកជាប់ឃុំឃាំងភាគច្រើន ត្រូវបានដឹកតាមរថយន្តទៅកាន់កោះខ្យង។ [redacted]

[redacted] កម្មាភិបាលតំបន់៣៧ មួយចំនួនដែលគេបាន ចាប់ខ្លួន ជាចុងក្រោយ ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរស-២១។

៤៤២- ការចាប់ខ្លួន និងការឃុំខ្លួនអ្នកទោសដែលគេបានកំណត់អត្តសញ្ញាណថាជាខ្មាំងផ្ទៃក្នុង ត្រូវបាន មន្ទីរភូមិភាគបស្ចិម(ម-៤០១) រាយការណ៍ប្រាប់មជ្ឈិមបក្សក្នុងរបាយការណ៍ប្រចាំសប្តាហ៍ និង ប្រចាំខែ។ ជាក់ស្តែង របាយការណ៍ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ បានរៀបរាប់ឈ្មោះ "ជន ក្បត់ក្នុងជួរទូទាំងភូមិភាគទាំងមូល" ដែលត្រូវបានចោទប្រកាន់ និង"បោសសម្អាត" ក្នុងនោះ រួមមាន កម្មាភិបាលមកពីតំបន់៣៧ ចំនួន១៧នាក់ និងមនុស្សមួយក្រុមទៀតដែល "ជាប់ សង្ស័យពីបទស្តីកស្រពន់ ឬក្បត់ជាតិ ក្នុងកម្រិតស្រាល" និងត្រូវឃុំឃាំងនៅកន្លែងមួយដើម្បី "ឃ្លាំមើល និងរៀនសូត្រ"។

៤៤៣- របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ១៩៧៨ បានគូសបញ្ជាក់ថា "សមាសភាពពួក១៧មេសា ក្នុង នោះមានពួករដ្ឋការរបបចាស់ និងចិនយួនខ្លះ" ត្រូវបានយើង "សម្រិតសម្រាំងប្រមែប្រមូលយក មកពីខាងអង្គភាពនានា និងខាងកងទ័ព" និងត្រូវបានចាត់ទុកថាជា "វិធានការ" ចំពោះសកម្ម ភាពខ្មាំងដែលកំពុងបន្តធ្វើដើម្បីបន្ត "ស្រាវជ្រាវរែកមុខបណ្តាញខ្មាំងគ្រប់ប្រភេទដែលលាក់ខ្លួន ស៊ីរូងផ្ទៃក្នុង និងបោសសម្អាតខ្មាំងនៅតាមមូលដ្ឋាន អង្គភាព មន្ទីរ និងស្ថាប័ននានា ជាបន្ត បន្ទាប់ និងឲ្យបានជាដាច់ខាត"។ របាយការណ៍នេះក៏បានបង្ហាញថាការបោសសម្អាតកម្មា ភិបាលមូលដ្ឋាននៅកំពុងបន្តធ្វើតាមរយៈការគូសបញ្ជាក់ថា "កម្មាភិបាលសហករណ៍ចំនួនពីរ នាក់ គឺលេខាម្នាក់ និងសមាជិកសហករណ៍ម្នាក់ ត្រូវយើងដកចេញ និងបញ្ជូនទៅកាន់[មន្ទីរ]

សន្តិសុខ ដោយសារពួកវាជាសមាសភាពមិនល្អ” ដែលយើងបាន“ឃ្លាំមើលជាយូរមកហើយ” និង“ស្ថិតក្នុងបណ្តាញក្បត់”។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៤៤៤- ការឃុំឃាំងនៅកោះខ្យងមានសភាពឃោរឃៅ។ អ្នកទោសត្រូវបានដាក់ខ្នោះជើងគ្រប់ពេល លើកលែងតែពេលធ្វើការ។ កន្លែងឃុំឃាំងធំបំផុតមានខ្នោះជើងចំនួនប្រាំបីជួរ ក្នុងខ្នោះមួយ ដាក់អ្នកដាក់ទោសពី៣ ទៅ១០នាក់។ អ្នកទោសបានរងការបង្អត់អាហារ ឬពុំបានទទួលអាហារ បរិភោគគ្រប់គ្រាន់។ អ្នកទោសធ្ងន់បានទទួលរបបអាហារតិចតួចត្រឹមតែបបរមួយស្លាបព្រា។ ក្នុង កន្លែងឃុំឃាំងអ្នកទោសធ្ងន់ ត្រូវបានដាក់ខ្នោះនៅនឹងដី បង្ខំឲ្យដេកនៅលើលាមករបស់ខ្លួន និងត្រូវសត្វល្អិតខាំដោយសារគ្មានការផ្តល់មុងឲ្យអ្នកទោស។ នៅក្នុងអគារមួយទៀត អ្នកទោស ត្រូវបន្ទោបង់ដាក់បំពង់ទឹកត្នោត កេសគ្រាប់ និងក្រឡ ទាំងខ្លួនជាប់ខ្នោះ។ គុកស្ថិតក្នុងសភាព គ្មានអនាម័យ ហើយចៃបានកើតពេញខ្លួនអ្នកទោស។ ស្ថានភាពបែបនេះតែងបានធ្វើឲ្យអ្នក ទោសបាត់បង់ជីវិតជារឿយៗដោយសារការអត់ឃ្លាន ជំងឺគ្រុនចាញ់ រាគរូស និងជំងឺដង្កាត់ ផ្សេងៗ។

### ពលកម្មដោយបង្ខំ

៤៤៥- អ្នកទោសនៅកន្លែងកសាងខ្លួន ត្រូវបានគេដោះខ្នោះចេញនៅពេលថ្ងៃ និងបង្ខំឲ្យធ្វើពលកម្ម យ៉ាប់យ៉ឺនដូចជា ជីកដំឡូង និងលើកទំនប់នៅក្បែរនោះ។ នៅកន្លែងកសាងខ្លួន អ្នកទោសដែល

គេបង្ខំឲ្យធ្វើការ បានទទួលរបបអាហារពុំគ្រប់គ្រាន់ ជួនកាលបានទទួលរបបបាយមួយកូនចាន។ អ្នកទោសដែលត្រូវគេចាប់បានពេលកំពុងហូបដំឡូង ត្រូវគេវាយដំ។

## ការសួរចម្លើយ និងទារុណកម្ម

៤៤៦- អ្នកទោសកោះខ្យងត្រូវបានសួរចម្លើយ និងធ្វើទារុណកម្មជាលក្ខណៈប្រព័ន្ធ។ ការសួរចម្លើយ និងការធ្វើទារុណកម្មគឺដើម្បីចង់ដឹងថា តើអ្នកទោសគឺជាអតីតទាហានរបបសាធារណរដ្ឋខ្មែរ គិញសេអ៊ីអា អ្នកចូលដៃជាមួយខ្មែរស ឬខ្មាំងផ្សេងៗ និងដើម្បីបង្ខំឲ្យអ្នកទោសប្រាប់អត្តសញ្ញាណមនុស្សផ្សេងៗនៅក្នុងបណ្តាញក្បត់របស់ខ្លួន។ វិធីសាស្ត្រនៃការធ្វើទារុណកម្មមួយចំនួន មានដូចជា ការវាយដំ ការឆក់នឹងខ្សែភ្លើង និងការធ្វើឲ្យថប់ដង្ហើម។ អំឡុងពេលសួរចម្លើយគេបានឮអ្នកទោសស្រែកដោយការឈឺចាប់។ ជាទូទៅ អ្នកទោសត្រូវបានសួរចម្លើយជាច្រើនដង។

៤៤៧- ការសួរចម្លើយអ្នកទោសត្រូវបានធ្វើឡើងដោយក្រុមឆ្មាំ ក្នុងនោះមានម្នាក់ជាអ្នករៀបចំកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយ។ ប្រវត្តិរូបរបស់អ្នកទោស និងរបាយការណ៍នៃការសួរចម្លើយត្រូវបានផ្ញើចេញពីមន្ទីរសន្តិសុខជូនថ្នាក់លើ ហើយប៉ុន្មានថ្ងៃក្រោយ នៅពេលដែលគេបញ្ជូនឯកសារទាំងនោះត្រឡប់មកវិញ ពេលនោះហើយគឺគេត្រូវយកអ្នកទោសទៅសម្លាប់។ របាយការណ៍ដែលមន្ទីរភូមិភាគផ្ញើជូនមជ្ឈិមបក្ស រួមមានទាំងព័ត៌មានដែលទទួលបានពីការសួរចម្លើយអ្នកជាប់ឃុំឃាំង។ ក្នុងករណីខ្លះទៀត ឯកសារចម្លើយសារភាពជាលាយលក្ខណ៍អក្សរទាំងមូលត្រូវបានភូមិភាគផ្ញើជូនអង្គការ។

## ការសម្លាប់មនុស្សក្រៅច្បាប់

៤៤៨- សេចក្តីសម្រេចដោះលែង និងត្រូវប្រហារជីវិតអ្នកទោស ត្រូវបានគណៈតំបន់៣៧ និងមេបញ្ជាការកងពលធំលេខ១ រាយការណ៍ជូនមន្ទីរសន្តិសុខ។ ជារៀងរាល់សប្តាហ៍ ទាហានបានមកដល់កោះខ្សង ដោយជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកទោសចំនួនដប់ ទៅម្ភៃនាក់ ដែលត្រូវប្រហារជីវិត។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបោសសម្អាត និងអ្នកទោសដែលជាអតីតកងទ័ពរបបសាធារណរដ្ឋខ្មែរត្រូវបានចាត់ទុកថាជាអ្នកទោស"ធ្ងន់" ហើយតែងតែត្រូវបានប្រហារជីវិតភ្លាមៗក្រោយពីមកដល់គុកកោះខ្សង។

៤៤៩- ការប្រហារជីវិតអ្នកទោសនៅកោះខ្សង ត្រូវបានធ្វើឡើងជាចំហរនៅចំពោះមុខអ្នកទោសផ្សេងទៀត។ មានពេលមួយ អ្នកទោសម្នាក់ត្រូវបានឆ្មាំបញ្ជាឲ្យសម្លាប់អ្នកទោសគ្នាឯង ហើយអ្នកទោសនោះក៏បានធ្វើតាមបញ្ជារបស់ឆ្មាំ។ ប៉ុន្តែក្នុងករណីជាច្រើន អ្នកទោសត្រូវបានយកទៅប្រហារជីវិតនៅឯទីតាំងរណ្តៅសាកសពរួមក្បែរនោះ។ អំឡុងពេលដឹកអ្នកទោសទៅប្រហារជីវិតអ្នកទោសត្រូវបានគេចងរុំមុខ និងចងដៃ ហើយពេលទៅដល់រណ្តៅ គេបញ្ជាឲ្យអ្នកទោសលុតជង្គង់ និងវាយចំកញ្ចឹងក។ អ្នកទោសតែងត្រូវបានយកទៅប្រហារជីវិតនៅពេលយប់ក្នុងលក្ខណៈជាក្រុមចំនួនពី១០ ទៅ២០នាក់អំឡុងពេលដែលក្រុមអ្នកទោសថ្មីមកដល់។ អ្នកទោសផ្សេងទៀតត្រូវបានចាត់តាំងឲ្យជីករណ្តៅសាកសព និងប្រមូលសម្លៀកបំពាក់អ្នកទោសដែលគេបានប្រហារជីវិតរួច។ ក្នុងការជីកគាស់រណ្តៅសាកសពចំនួនពីរ ទៅបី កាលពីឆ្នាំ១៩៧៩ យើងបានប្រទះឃើញសាកសពមនុស្សចំនួន២៣៣ នាក់។

៤៥០- ការប្រហារជីវិតនៅតំបន់៣៧ ត្រូវបានមន្ទីរភូមិភាគរាយការណ៍ជាទៀងទាត់ឱ្យមជ្ឈិមបក្សបានដឹង។ របាយការណ៍មួយចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ បានបង្ហាញឱ្យអង្គការដឹងអំពីអត្តសញ្ញាណរបស់"ពួកក្បត់មួយចំនួនធំ" ដែលត្រូវបាន"បោសសម្អាត និងកម្ទេច" ក្នុងនោះមានកម្មាភិបាលតំបន់៣៧ ចំនួន១៧នាក់ផង។ របាយការណ៍មួយចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៨ បានបញ្ជាក់ថាតំបន់៣៧ បានកំពុង"ស្វែងរកគិញយួន"។ ក្រោយមកមិនដល់២សប្តាហ៍ផង ភូមិភាគបានរាយការណ៍ប្រាប់មជ្ឈិមបក្សថា មនុស្ស"ដែលត្រូវបានកម្ទេច" នៅតំបន់៣៧ នៅខែកក្កដា ឆ្នាំ១៩៧៨ រួមមាន"ជនជាតិយួនចំនួនមួយរយនាក់ ទាំងតូច ទាំងធំ ទាំងចាស់ ទាំងក្មេង" និងភ្នាក់ងារសេអ៊ីអាចំនួនហុកសិបនាក់ "ដែលកំពុងសម្ងំលាក់ខ្លួនក្នុងអង្គភាព និងសហករណ៍" ហើយសុំ"វិធានការ"សម្រាប់"យុទ្ធជនយួន"ចំនួនបីនាក់។ សាក្សីជាច្រើននាក់បានបញ្ជាក់អះអាងថា ក្រុមគ្រួសារជនជាតិវៀតណាមជាច្រើនក្រុមធំៗ ត្រូវបានចាប់យកទៅសម្លាប់នៅកោះខ្សែង។

## មន្ទីរសន្តិសុខព្រៃដំរីស្រុត

## ទីតាំង និងប្រតិបត្តិការ

៤៥១- មន្ទីរសន្តិសុខព្រៃដំរីស្រុត ("ដំរីស្រុត") មានទីតាំងស្ថិតនៅក្នុងភូមិច្រកសង្កែ ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង និងជាផ្នែកមួយនៃស្រុក១២ តំបន់៣១ ភូមិភាគបស្ចិម នាកាលអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ។ ដំរីស្រុតបានធ្វើប្រតិបត្តិការចាប់ពីចន្លោះឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៩ និងជាមន្ទីរសន្តិសុខមួយ ដែលជំនួសឱ្យ

មន្ទីរសន្តិសុខចំនួនពីរទៀត។ មន្ទីរសន្តិសុខទីមួយ បានចាប់ធ្វើប្រតិបត្តិការនៅចន្លោះឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ និងបានដើរតួនាទីជាមន្ទីរសន្តិសុខថ្នាក់តំបន់ នៅភូមិជំទាវជ្រៃង ឃុំក្រាំងល្វា។ មន្ទីរនេះរាប់បញ្ចូលទាំងកន្លែងប្រហារសម្លាប់មនុស្ស នៅត្រពាំងអម្ពិល និងត្រពាំង ក្រែង ដែលនៅបន្តប្រើប្រាស់ក្រោយឆ្នាំ១៩៧៥។ មន្ទីរសន្តិសុខទីពីរដើរ តួនាទីជាមន្ទីរសន្តិសុខថ្នាក់ស្រុក នៅទំនប់ត្រពាំងព្រីង ហើយត្រូវបានបិទ នៅពេល បុគ្គលិកមន្ទីរនេះ ត្រូវបានបញ្ជូនទៅកាន់ដំរីស្រុត ក្នុងឆ្នាំ១៩៧៦។

៤៥២- ដំរីស្រុតគឺជាគុកធំជាងគេក្នុងស្រុក១២ តំបន់៣១ ភូមិភាគបស្ចិម។ គុកនេះស្ថិតនៅក្នុងព្រៃខាងក្រៅដំរីស្រុត និងមានអគារឃុំឃាំងយ៉ាងហោចណាស់ចំនួនពីរ អគារមួយវែង និងអគារបួនជ្រុងដែលមានទំហំប្រមាណ១០ម៉ែត្រ គុណនឹង១០ម៉ែត្រ។ នៅខាងលិចមានផ្ទះមួយជួរចំនួន៥ សម្រាប់ប្រធានគុករស់នៅ និងធ្វើការ។ ទីកន្លែងរណ្តៅសាកសពដែលជាទីកន្លែងប្រហារជីវិត និងកប់សាកសពអ្នកទោសក្រោមដើមត្នោត ស្ថិតនៅចម្ងាយប្រមាណប្រាំមួយរយម៉ែត្រនៅប៉ែកពាយ័ព្យនៃមន្ទីរសន្តិសុខ។ គុកដំរីស្រុតពុំមានបំណែកអគារសេសសល់ឡើយ ហើយមានព្រៃស៊ុបទ្រុបដុះពីលើ។

## រចនាសម្ព័ន្ធគ្រប់គ្រង

## ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៤៥៣- ដោយហេតុថា អង្គភាពយោធាកម្ពុជាប្រជាធិបតេយ្យជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខដំរីស្រុត ប្រធានអង្គភាពនេះ គឺជាអ្នករាយការណ៍ជូនមេបញ្ជាការកងអនុសេនាធំរបស់ខ្លួន ដែលជាអ្នក

រាយការណ៍បន្តជូនគណៈស្រុក។ មេដឹកនាំយោធាស្រុក១២ រួមមានដូចជា [redacted] មេបញ្ជាការកងទ័ពស្រុក [redacted] មេបញ្ជាការកងអនុសេនាធំលេខ ៣០៨ និង [redacted] មេបញ្ជាការរងកងអនុសេនាធំលេខ៤៨។ លេខាស្រុក១២ [redacted] អ្នកបន្ទាប់មកទៀតឈ្មោះ [redacted]។

៤៥៤- ពួកគេរាយការណ៍ប្រាប់ឈ្មោះ ព្រឹង សារុន លេខាតំបន់៣១។ សារុន ដែលជាសមាជិកនៃគណៈភូមិភាគបស្ចិម និងគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាផងនោះ ត្រូវបានផ្ទេរទៅកាន់ភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ដោយបានក្លាយខ្លួនជាលេខាតំបន់២ និង តំបន់៧ និងជាសមាជិកគណៈភូមិភាគនោះ។ អ្នកចូលមកជំនួសតំណែងរបស់ឈ្មោះ សារុន ជាលេខាតំបន់៣១ គឺឈ្មោះ មាស យឹម ដែលធ្លាប់ធ្វើលេខាស្រុក និងអនុលេខាតំបន់ ក្រោមបញ្ជា របស់ឈ្មោះ សារុន។ ឈ្មោះ មាស យឹម មេបញ្ជាការយោធាស្រុកឈ្មោះ ប៉ាន និងនិតធ្លាប់បានចុះមកពិនិត្យមន្ទីរសន្តិសុខដំរីស្រុត។

៤៥៥- មកដល់ខែមីនា ឆ្នាំ១៩៧៨ លេខាភូមិភាគបស្ចិមឈ្មោះ ជូ ជេត *ហៅ* ស៊ីត្រូវបានចាប់ខ្លួន។ មន្ទីរភូមិភាគ បស្ចិមដែលគេស្គាល់ថាជាមន្ទីរ ម-៤០១ មានទីតាំងស្ថិតនៅច្បាររមន ខេត្តកំពង់ស្ពឺ។

## របនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ

៤៥៦- កងអនុសេនាតូចនៃអង្គភាពយោធាស្រុក១២ ត្រូវបានចាត់តាំងឲ្យបើកប្រតិបត្តិការមន្ទីរសន្តិសុខដំរីស្រុត។ មេបញ្ជាការនៃកងអនុសេនាតូចលេខ៤០៣ [redacted] បានធ្វើជាប្រធានមន្ទីរសន្តិសុខនេះ។ [redacted] បានធ្វើរបាយការណ៍ប្រចាំខែជាលាយលក្ខណ៍

អក្សរទៅកាន់គណៈស្រុក ដោយធ្វើការវាយតម្លៃអំពីអ្នកទោសម្នាក់ៗ។ ឈ្មោះនេះ ជាអ្នកទទួលបញ្ជាពីលេខាស្រុក និងបានចូលប្រជុំនៅទីស្នាក់ការស្រុក។ ឈ្មោះ [redacted] គឺជាអនុប្រធានគុកដំរីស្រុត និងជាកម្មាភិបាលគុកទទួលបន្ទុកសួរចម្លើយ និងបានចូលរួមជាញយដងក្នុងការធ្វើទារុណកម្មអ្នកទោស។ កម្មាភិបាលគុកផ្សេងទៀត ដែលត្រូវបានកំណត់អត្តសញ្ញាណ មាន [redacted] ជាឆ្មាំ និងជាពេជ្ឈឃាដ [redacted] ជានិរសារ [redacted] ជាពេទ្យ និង [redacted] ជាឆ្មាំ។

**ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា**

៤៥៧- មន្ទីរភូមិភាគបស្ចិមបានផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំសប្តាហ៍ និងប្រចាំខែយ៉ាងទៀងទាត់ជូនមន្ទីរ៨៧០ ដែលក្នុងនោះបានរៀបរាប់លម្អិតអំពី"សភាពការណ៍ខ្មាំងផ្ទៃក្នុង" នៅតំបន់៣១ និងវិធានការក្នុងការ"អនុវត្តមាគ៌ាចាត់តាំងរបស់បក្សដើម្បីកម្ចាត់ សម្រិតសម្រាំងនិងបោសសម្អាតឲ្យបានជាប់ជាប្រចាំ"ចំពោះខ្មាំងទាំងនោះ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ស្រុក និងថ្នាក់តំបន់នៃភូមិភាគបស្ចិម បានទទួលឱវាទណែនាំពីមជ្ឈិមបក្សស្តីពី គោលនយោបាយ និងមាគ៌ាដែលត្រូវអនុវត្តចំពោះខ្មាំងក្នុងអង្គសន្និបាតភូមិភាគប្រចាំឆ្នាំ និងនៅ ក្នុងវគ្គរៀនសូត្រនយោបាយ។

៤៥៨- មជ្ឈិមបក្សបានយកចិត្តទុកដាក់ខ្លាំង និងបានគ្រប់គ្រងសកម្មភាពនានានៅស្រុក១២។ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៧ ក្នុងពេលដែលមានការបោសសម្អាតយ៉ាងសស្រាក់សស្រាំទៅលើកម្មាភិបាលភូមិភាគបស្ចិមនៅទីកន្លែងផ្សេងៗ ស្រុកកំពង់ត្រឡាចលើគឺជាស្រុកមួយ ក្នុងចំណោមស្រុកចំនួនបី ដែលត្រូវបានគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ប្រគល់ទង់ក្រហម

ផ្អិនផ្អោជារង្វាន់កិត្តិយសដោយបានចាត់ទុកស្រុកមួយនេះថាជា "ស្រុកគំរូ" របស់ប្រទេសចំពោះស្នាដៃនៃ"ការតស៊ូវណ្ណៈយ៉ាងខ្លាំងក្លា និងពេញទំហឹងក្នុងស្រុកទាំងមូល ពិសេសក្នុងបក្សតែម្តង"។

៤៥៩- មិនដល់មួយខែផង តំបន់៣៧ តំបន់៣២ និងស្រុក១៦ (កំពង់លែង) និងស្រុក១៨ (កំពង់ត្រឡាចក្រោម)នៃតំបន់៣១ ត្រូវបាន **នួន ជា** រិះគន់យ៉ាងចាស់ដៃក្នុងអង្គសន្និបាតកម្មាភិបាលភូមិភាគបស្ចិមនាខែកក្កដា ឆ្នាំ១៩៧៧ ខណៈពេលដែលស្រុក១២ (កំពង់ត្រឡាចលើ) បានទទួលការកោតសរសើរថាជាស្រុកគំរូដែលត្រូវអនុវត្តតាម។ ដោយសារឆ្លងកាត់ការពិនិត្យ និងវាយ តម្លៃរបស់មជ្ឈិមបក្ស ទើបស្ទើរតែគ្មានកម្មាភិបាលណាម្នាក់នៅស្រុក១២ត្រូវបាន បោស សម្អាត បើទោះបីនៅតំបន់៣៧ មានការបោសសម្អាតយ៉ាងខ្លាំងក្លាក្តី (ដូចដែលបានលើក យកមកពិភាក្សាក្នុងផ្នែកស្តីអំពីមន្ទីរសន្តិសុខកោះខ្យង)។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៤៦០- ខ្មាំង និងជនក្បត់បក្សកុម្មុយនីស្តកម្ពុជាជាច្រើនប្រភេទ ត្រូវបានឃុំឃាំងនៅឯមន្ទីរសន្តិសុខដំរីស្រុត ក្រោយពេលត្រូវបានចាប់ខ្លួនយកមកពីតំបន់មូលដ្ឋាន ឬត្រូវបានចាប់ខ្លួនដោយកងពលយោធាកម្ពុជាប្រជាធិបតេយ្យ។ មន្ទីរសន្តិសុខនេះមានគោលបំណងឃុំឃាំងអ្នកទោសធ្ងន់ និងអ្នកទោសស្រាលដែលមកពីទូទាំងស្រុក១២ និងមនុស្សដែលត្រូវបោសសម្អាតដែលគេចាត់ទុក ថាជាសត្រូវនយោបាយ។ មានការព្យាករណ៍ខុសៗគ្នាអំពីចំនួនអ្នកជាប់ឃុំឃាំងនៅគុកដំរីស្រុត ដែលថាមានអ្នកទោសចំនួនពី១០នាក់ ទៅ៣០នាក់ ជាប់ឃុំឃាំងក្នុងមួយលើក

ដល់ ចំនួន៣០០នាក់។ ប៉ុន្តែ គុកនេះតែងតែពោរពេញទៅដោយអ្នកជាប់ ឃុំឃាំងថ្មីៗ ដែលគេបាននាំចូលមកជាទៀងទាត់ នៅពេលគេសម្លាប់អ្នកទោសចាស់រួច។

៤៦១- អ្នកទោសត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅគុកដំរីស្រុតដោយសារហេតុផលផ្សេងៗ។ អ្នកទោស "ស្រាល" ជាមនុស្សដែលត្រូវបានចោទប្រកាន់ចំពោះការដាំស្រូវមិនបានត្រឹមត្រូវ ការបណ្តោយឱ្យគោក្របីស៊ីស្រូវ ការផ្តល់ស្បៀងទៅឱ្យប្រជាជនថ្មី ឬការធ្វើដំណើរដោយគ្មានការអនុញ្ញាត និងការលួចជាដើម។ អ្នកទោស"ធ្ងន់" គឺជាអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ ឬមនុស្សដែលជាប់ចោទពីបទពាក់ព័ន្ធជាមួយរបបសាធារណរដ្ឋខ្មែរ ខ្មែរស និងមនុស្សផ្សេងៗដែលគេចាត់ទុកថាជាខ្មាំង ឬខ្មាំងពិតប្រាកដនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកទោសផ្សេងទៀតដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខដំរីស្រុត ជាមនុស្សដែលត្រូវបានគេចោទប្រកាន់ថាបានប្រព្រឹត្ត"ខុសសីលធម៌" ជាឃ្លូន ឬជាអ្នករៀបចំគម្រោងផែនការវិទ្ធ្វេសកម្ម ដូចជាការធ្វើឱ្យបាក់បែកសម្ភារៈធ្វើស្រែចម្ការ។ សមាជិកគ្រួសារទាំងអស់រួមទាំងកុមារផង ត្រូវបានឃុំឃាំងនៅក្នុងគុកនេះ។

៤៦២- ជាទូទៅ ការសម្រេចចាប់ខ្លួនត្រូវបានធ្វើឡើងនៅថ្នាក់ស្រុក ផ្អែកតាមរបាយការណ៍របស់ឃុំ និងមូលដ្ឋាន។ ពិសេស ប្រធានគុកដំរីស្រុតតែងបានទទួលរបាយការណ៍ពីមន្ទីរស្រុក ដែលជាអ្នកកំណត់អត្តសញ្ញាណអ្នកទោសដែលត្រូវចាប់ខ្លួន និងកំហុសឆ្គងរបស់ពួកគេ។ ការចាប់ខ្លួនបានធ្វើឡើងដោយឈ្លបស្រុក។ ជួនកាល ស្រុកជាអ្នកផ្តល់ឱវាទណែនាំឱ្យឃុំ និងអង្គភាពក្នុងការចាប់ខ្លួន និងបន្ទាប់មកត្រូវរាយការណ៍ឱ្យស្រុកបានដឹងវិញ។ ក្នុងអង្គប្រជុំថ្នាក់ស្រុកមួយ លេខាស្រុក១២ បានណែនាំឱ្យកម្មាភិបាលឃុំបញ្ជូន "ខ្មាំង" ទៅរៀនសូត្រ។

៤៦៣- ការចាប់ខ្លួន និងការឃុំឃាំងខ្មាំងខាងក្នុងត្រូវបានមន្ទីរភូមិភាគរាយការណ៍ឱ្យមជ្ឈិមបក្ស តាមរយៈរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែ។ ជាក់ស្តែង របាយការណ៍មួយរបស់ភូមិភាគ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៧ ផ្ញើជូនអង្គការ ចម្លងជូន **ប៉ុល ពត នួន ជា** និង **អៀង សារី** បានរាយការណ៍អំពីការចាប់ខ្លួនមនុស្សចំនួន២៤នាក់ នៅតំបន់កំពង់ឆ្នាំង ដែលបានរត់គេចខ្លួនពីស្រុកព្រៃឈរ ភូមិភាគកណ្តាល និងបានស្នើសុំវិធានការពីអង្គការដើម្បីអនុវត្ត។ របាយការណ៍មន្ទីរភូមិភាគចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៨ សម្រាប់តំបន់៣១ បានរៀបរាប់ អំពីការចាប់ខ្លួន និងការឃុំឃាំងខ្មាំងមួយចំនួននៅ"កន្លែងកសាងខ្លួន" ក្នុងស្រុក១០ ១៤ ១៦ និង១៨ ក្នុងនោះមាន "ប្រជាជនថ្មី" យួន និងអតីតទាហាន និងសិស្សនិស្សិត។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៤៦៤- ស្ថានភាពនៅក្នុងគុកដំរីស្រុតធ្វើឱ្យអ្នកជាប់ឃុំឃាំងពិបាករស់នៅ។ អ្នកជាប់ឃុំឃាំងត្រូវបានគេនាំទៅកាន់មន្ទីរសន្តិសុខនេះទាំងដៃជាប់ចំណង ហើយពេលពួកគាត់ទៅដល់ ពួកគាត់ត្រូវបានខ្មែរក្រហមដាក់ខ្នោះជើង។ អ្នកជាប់ឃុំឃាំងត្រូវបានបែងចែកជាប្រភេទអ្នកទោស "ស្រាល" និងអ្នកទោស"ធ្ងន់"។ អ្នកទោស"ធ្ងន់" ជាប់ខ្នោះជើងពេញមួយថ្ងៃ។ ចំណែកអ្នកទោស"ស្រាល" ត្រូវបានគេដោះខ្នោះជើងចេញនៅពេលថ្ងៃ ដើម្បីធ្វើការងារ ប៉ុន្តែជាប់ខ្នោះជើងនៅពេលយប់។ អ្នកទោសត្រូវបានគេដាក់ខ្នោះជើងជាជួរយ៉ាងវែងដោយស៊ករនុកដែកចូលក្នុងបន្ទះក្តារ។ សមាជិកគ្រួសារត្រូវគេបំបែកពីគ្នា ដោយស្រី និងប្រុស ត្រូវបានដាក់ខ្នោះដោយឡែកពី គ្នា។

៤៦៥- អ្នកទោសត្រូវបានគេបង្ខំឱ្យធ្វើការងារជាច្រើនម៉ោង ដោយពុំមានអាហារបរិភោគគ្រប់គ្រាន់។ របបអាហារទូទៅគឺបបរចំនួន២ពេលក្នុងមួយថ្ងៃ។ អ្នកទោសជាច្រើននាក់បានធ្លាក់ខ្លួនស្គមស្គាំង។ សត្វសង្អើចកើតមាននៅគ្រប់ទីកន្លែង។ អ្នកទោសត្រូវបានផ្នាំវាយដំដោយគ្មានមូលហេតុ ជួនកាលវាយនឹងខ្សែតី។ មានពេទ្យម្នាក់នៅទីនោះ ប៉ុន្តែពេទ្យមាន សិទ្ធិត្រឹមតែព្យាបាលបុគ្គលិកគុកប៉ុណ្ណោះ និងមិនមានសិទ្ធិព្យាបាលអ្នកទោសទេ។ ជាទៀងទាត់ អ្នកទោសបានស្លាប់ដោយសារការអត់ឃ្លាន និងជំងឺដង្កាត់។ ក្នុងចំណោម អ្នកទោស មានបរិយាកាសភ័យខ្លាចថាប្រសិនបើពួកគាត់ប៉ុនប៉ងលួចរត់ គេនឹងសម្លាប់ពួកគាត់។

## ពលកម្មដោយបង្ខំ

៤៦៦- នៅពេលមិនជាប់ឃុំឃាំង អ្នកទោសត្រូវបានគេបង្ខំឱ្យធ្វើកពលកម្មដោយដៃលំបាកយ៉ាប់យ៉ឺនជាច្រើនម៉ោង។ ស្ត្រីត្រូវបានគេបង្ខំឱ្យរែកទឹក និងត្រូវបានគេទាត់ធាក់ ប្រសិនបើពួកគេធ្វើការយឺតយ៉ាវ។ អ្នកទោស"ស្រាល" ត្រូវបានចាត់តាំងឱ្យធ្វើការងារផ្សេងៗដូចជា ជីកឬសឈើ និងដកសំណាប ខណៈពេលអ្នកទោស"ធ្ងន់" ត្រូវរែកដីឱ្យបានពីបី ទៅប្រាំមួយម៉ែត្រគុបក្នុងមួយថ្ងៃ។ កុមារដែលជាប់ឃុំឃាំងនៅគុកដំរីស្រុត ក៏ត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការងារ និងត្រូវទទួលពិន័យ ប្រសិនបើពួកគេពុំបំពេញតាមភារកិច្ចដែលបានចាត់តាំង។ អ្នកទោស ខ្លះត្រូវបានបង្ខំឱ្យក្រោកធ្វើការពីម៉ោង៣ទៀបភ្លឺ ចំណែកខ្លះទៀតត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការនៅពេលយប់ ជួនកាលរហូតដល់កណ្តាលអាធ្រាត្រ។ អ្នកទោសត្រូវបានបង្ខំឱ្យធ្វើការហួសកម្រិតរហូតដល់បាក់កម្លាំង និងធ្លាក់ខ្លួនឈឺ។

## ការសួរចម្លើយ និងទារុណកម្ម

៤៦៧- អ្នកទោសនៅគុកដំរីស្រុតត្រូវបានសួរចម្លើយ និងធ្វើទារុណកម្មជាទៀងទាត់។ ការសួរចម្លើយ និងការធ្វើទារុណកម្ម គឺដើម្បីស្វែងរកអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ គិញវៀតណាម ឬភ្នាក់ងារសេអ៊ីអា។ ប្រធានគុកដំរីស្រុតឈ្មោះ អុល ជាអ្នកជាប់ពាក់ព័ន្ធខ្លាំងក្នុងការសួរចម្លើយ និងការធ្វើទារុណកម្ម ពិសេសការកត់ត្រាអំឡុងពេលសួរចម្លើយ និងការបញ្ជាកូនចៅរបស់ខ្លួនឲ្យធ្វើទារុណកម្មអ្នកទោស។ វិធីសាស្ត្រក្នុងការធ្វើទារុណកម្មមួយចំនួន មានដូចជាការយកថង់ប្លាស្ទិកគ្របមុខឲ្យថប់ដង្ហើម ការដកក្រចក ការបំបាក់ ម្រាមដៃ ការវាយដំនឹងខ្សែតី និងដំបង និងការឆក់នឹងខ្សែភ្លើងជាដើម។ ការសួរចម្លើយអ្នកទោសមានរយៈពេលចំនួនជាច្រើនថ្ងៃ។ អ្នកទោសដែលពុំព្រមឆ្លើយសារភាព ត្រូវបាន គេវាយដំ និងជួនកាលត្រូវបានគេសម្លាប់។ អ្នកសួរចម្លើយនៅគុកដំរីស្រុត បានប្រើប្រាស់ ទារុណកម្មតាមបញ្ជារបស់ប្រធានគុកនេះ។

៤៦៨- របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសួរចម្លើយ និងចម្លើយសារភាពនានាត្រូវបានរៀបចំឡើង។ របាយការណ៍ត្រូវបានផ្ញើទៅឲ្យមជ្ឈិមបក្ស តាមរយៈមន្ទីរភូមិភាគដែលជាអ្នកបានដាក់បញ្ចូលឈ្មោះរបស់មនុស្សដែលត្រូវបានចោទប្រកាន់ថាជា “ខ្មាំង” ដែលទទួលបានពីអ្នកទោស អំឡុងពេលសួរចម្លើយ។ ករណីខ្លះឯកសារចម្លើយសារភាព ក៏ត្រូវបានផ្ញើជូនអង្គការដែរ។ ជាក់ស្តែង នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ មន្ទីរភូមិភាគបានរាយការណ៍អំពីការសួរចម្លើយដែលកំពុងធ្វើទៅលើអតីតគ្រូបង្រៀន និងជាអនុសេនីយ៍ត្រីនៅស្រុក១៦ តំបន់៣១ ដោយ

បានគូសបញ្ជាក់ថា "ក្រោយពីយើងសួរចម្លើយចប់ យើងនឹងបញ្ជូនវា និងចម្លើយសារភាពជូនអង្គការ"។

## ការសម្លាប់មនុស្សក្រៅច្បាប់

៤៦៩- បន្ទាប់ពីបានទទួលរបាយការណ៍របស់ប្រធានគុកដំរីស្រុតស្តីពីអ្នកទោសម្នាក់ ក្នុងករណីខ្លះគណៈស្រុកជាអ្នកសម្រេចទុកអ្នកទោសដែលជាប់ឃុំឃាំង រហូតដល់ពួកគេស្លាប់ដោយការអត់ឃ្លាន ឬជំងឺគ្រុនចាញ់។ ក្នុងករណីខ្លះទៀត អ្នកទោសត្រូវបានខ្មែរក្រហមប្រហារជីវិតនៅពេលមានបញ្ជាពីថ្នាក់តំបន់។ អ្នកទោសមួយចំនួន ដូចជាអ្នកទោសដែលត្រូវបានចោទប្រកាន់ថាជាខ្មែរស ត្រូវបានសម្លាប់ភ្លាមៗក្រោយពីបានមកដល់គុកនេះ។ [redacted]។ [redacted] និង [redacted] បានចូលរួមក្នុងការប្រហារជីវិតអ្នកទោស។

៤៧០- ជាទូទៅ ការប្រហារជីវិតកើតមាននៅពេលយប់ នៅពេលដែលអ្នកទោសត្រូវបានគេនាំយកទៅហើយបាត់ខ្លួន។ អ្នកទោសត្រូវបានគេចងរុំមុខ ដៃចងស្លាបសេក និងនាំយកទៅកន្លែងប្រហារជីវិតស្ថិតនៅក្បែរគុក និងត្រូវបានសម្លាប់ដោយការវាយត្រង់កញ្ចឹងកនឹងដំបងឬស្សី។ ជួនកាលស្ត្រីត្រូវបានកម្មាភិបាលមន្ទីរសន្តិសុខនេះរំលោភមុននឹងសម្លាប់។ បុគ្គលិកគុកដំរីស្រុតបានចូលរួមក្នុងការប្រហារជីវិត "ជាច្រើន" ជួនកាលបានសម្លាប់អ្នកទោស ចំនួនពី៥ ទៅ១០ នាក់ក្នុងមួយលើកៗ។ មន្ទីរភូមិភាគបានរាយការណ៍ជូនមជ្ឈិមបក្ស ស្តីពីខ្មាំងដែលត្រូវបាន

"កម្មេច" ឬ"បោសសម្អាត" និងបានស្នើសុំការណែនាំពីអង្គការអំពី "វិធានការ" ទៅលើអ្នកទោសមួយចំនួន។

៤៧១- សាកសពអ្នកទោសត្រូវបានកប់នៅក្បែរមន្ទីរសន្តិសុខក្នុងរណ្តៅដែលអ្នកទោស និងឆ្មាំបានជីកទុករួចជាស្រេច ហើយខ្មែរក្រហមបានដាំដើមដូងពីលើរណ្តៅទាំងនោះ។ ជួនកាលសាកសពជនរងគ្រោះត្រូវបានកាត់ជាពីរចំណែកមុនពេលកប់ក្នុងរណ្តៅ។ យ៉ាងហោចណាស់ មានរណ្តៅចំនួនពី៨ ទៅ១០ នៅក្បែរគុកនេះ ដែលគេបានយកធ្វើជារណ្តៅសាកសពរួម ហើយក្នុងមួយរណ្តៅមានសាកសពមនុស្សចំនួនពី១០ ទៅ១៥នាក់។ ការព្យាករណ៍ផ្សេងៗអំពីកន្លែងរណ្តៅសាកសពរួមនៅគុកដំរីស្រុតបញ្ជាក់ថា មានរណ្តៅសាកសពរហូតដល់ចំនួន ១០០រណ្តៅ ក្រោមដើមដូងក្បែរមន្ទីរសន្តិសុខនេះ។

## មន្ទីរសន្តិសុខក្រាំងតាចាន់

### ទីតាំង និងប្រតិបត្តិការ

៤៧២- មន្ទីរសន្តិសុខក្រាំងតាចាន់ ("ក.ត.ច") ឬ"មន្ទីរលត់ដំ១០៥" ស្ថិតនៅភូមិក្រាំងតាចាន់ ឃុំគុស ខេត្តតាកែវ និងជាផ្នែកមួយនៃស្រុក១០៥ តំបន់១៣ ភូមិភាគនិរតី កាលអំឡុងរបបសម័យកម្ពុជាប្រជាធិបតេយ្យ។ ក.ត.ច បានបើកប្រតិបត្តិការនៅចន្លោះឆ្នាំ១៩៧២ ឬ១៩៧៣ ដល់ខែមករា ឆ្នាំ១៩៧៩។

៤៧៣- ក.ត.ច គឺជាមន្ទីរធំមួយដែលមានបរិវេណចំនួនពីរ។ បរិវេណខាងក្រៅនៃ ក.ត.ច មានទំហំប្រមាណ៥០០ម៉ែត្រ គុណនឹង៥០០ ទៅ៨០០ម៉ែត្រ និងមានរបងល្ងសបន្លាព័ទ្ធជុំវិញ។ បរិវេណ

ខាងក្នុងមានទំហំប្រមាណ៥០ ទៅ១០០ម៉ែត្រគុណនឹង៧៥ ទៅ១០០ម៉ែត្រ និងមានរបងលួសបន្លាព័ទ្ធជុំវិញ ហើយនៅចម្ងាយ៥០ម៉ែត្រ ពីច្រកចូលទៅកាន់បរិវេណខាងក្នុង មានរបងមួយទៀត។ បរិវេណខាងក្នុង មានអគារឈើមួយចំនួនព័ទ្ធទៅដោយលួសបន្លា។ ក្នុងនោះអគារចំនួន២ ឬ៤ សម្រាប់ឃុំឃាំងអ្នកទោស ចំណែកអគារផ្សេងទៀតសម្រាប់បុគ្គលិកគុកស្នាក់នៅ ហូបចុក និងសួរចម្លើយអ្នកទោស។ រណ្តៅសាកសពរួមស្ថិតនៅខាងក្នុង និងខាងក្រៅមន្ទីរសន្តិសុខនេះ។ រណ្តៅសាកសពរួមធំមួយនៅខាងក្នុងបរិវេណនេះមានទំហំ៣០ម៉ែត្រគុណនឹង២០ម៉ែត្រ និងជម្រៅ២ម៉ែត្រ។ ឌីយ៉ាក្រាមនៅក្នុងសំណុំរឿងផ្តល់ព័ត៌មានរូបភាពលម្អិតអំពីបរិវេណ ក.ត.ច អំឡុងរយៈពេលប្រតិបត្តិការនៃគុកនេះ។ ក.ត.ច ពុំមានបំណែកសេសសល់ឡើយ។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៤៧៤- ក្រាំងតាចាន់ គឺជាមន្ទីរសន្តិសុខថ្នាក់ស្រុកមួយស្ថិតក្រោមសិទ្ធិអំណាចរបស់គណៈស្រុក១០៥ ដែលត្រូវបានស្គាល់ថាជាស្រុកត្រាំកក់។ តំបន់១៣ ឬត១៣ ជាអ្នកត្រួតពិនិត្យសកម្មភាពរបស់មន្ទីរសន្តិសុខក្រាំងតាចាន់ និងអនុញ្ញាតឲ្យមានការប្រហារជីវិត និងការប្រព្រឹត្តិឧក្រិដ្ឋកម្មផ្សេងៗនៅគុកក្រាំងតាចាន់។ ចាប់ផ្តើមក្នុងឆ្នាំ១៩៧៥ កម្មាភិបាលជាច្រើននាក់ធ្លាប់បានធ្វើជាលេខាស្រុក១០៥ ដូចជា [redacted]

[redacted]។

នៅឆ្នាំ១៩៧៥ លេខាតំបន់១៣ គឺ [redacted] បន្ទាប់មកអ្នកដែលបានចូលមកជំនួសឈ្មោះ [redacted] នៅចុងឆ្នាំ១៩៧៦ គឺឈ្មោះ សេក សាត *ហៅ* ប្រាក់ ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៨។ នៅខាងលើតំបន់១៣ គឺភូមិភាគនិរតីដឹកនាំដោយ តាម៉ុក ដែលជាលេខាភូមិភាគ។ មេដឹកនាំថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា នួន ជា តាម៉ុក [redacted] សុទ្ធតែត្រូវបានគេឃើញនៅមន្ទីរសន្តិសុខក្រាំងតាចាន់។

**រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ**

៨៧៥- [redacted] ពីពាក់កណ្តាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តំណែងជាប្រធានមន្ទីរសន្តិសុខត្រូវបានប្រគល់ទៅឱ្យឈ្មោះ [redacted]។ [redacted] ក៏ជាអ្នកបានសួរចម្លើយអ្នកទោសផងដែរ ហើយ [redacted] បានកាន់កាប់តួនាទីជាអនុប្រធានមន្ទីរសន្តិសុខ។ បុគ្គលិកមន្ទីរសន្តិសុខ ក.ត.ច មានចំនួនសរុបពី ១០ ទៅ ១២នាក់ និងត្រូវបានបែងចែកជាផ្នែកដឹកនាំសម្រាប់សួរចម្លើយអ្នកទោស និងផ្នែកយាមកាម។ ក្នុងផ្នែកបុគ្គលិក [redacted] គឺជាអ្នករក្សាកំណត់ហេតុ និងជាអ្នកសួរចម្លើយជាន់ខ្ពស់ រីឯបុគ្គលិកម្នាក់ទៀតដែលឈ្មោះ [redacted] ដែរបានចូលរួមក្នុង

ការសួរចម្លើយ និងសរសេរចម្លើយសារភាព។ [redacted] គឺជា អ្នកសួរចម្លើយ អ្នកធ្វើទារុណកម្ម និងពេជ្ឈឃាដដ៏សំខាន់។

**ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា**

៤៧៦- ដូចដែលបានបញ្ជាក់ច្បាស់ដោយឯកសារស្រុក១០៥ មួយសំណុំធំដែលត្រូវបានប្រទះឃើញ គោលការណ៍មូលដ្ឋាននៃការប្រាស្រ័យទាក់ទងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាព័ត៌មានដែលភាគច្រើនស្តីពីសកម្មភាពក្បត់របស់មនុស្សដែលត្រូវបានចោទប្រកាន់ គឺជានិច្ចកាលតែងតែត្រូវបានបញ្ជូនទៅតាមរយៈខ្សែបណ្តាញបញ្ជាការ ដើម្បី "ជម្រាប" ឲ្យថ្នាក់លើបន្ទាប់របស់ខ្លួនបានដឹង បើទោះបីជាបញ្ហានោះត្រូវបានដោះស្រាយរួចរាល់ទាំងស្រុង ឬមួយផ្នែកក្តី។ ខាងផ្នែកភ័ស្តុភារ និរសារត្រូវបានប្រើប្រាស់ដើម្បីបញ្ជូនរបាយការណ៍ ចម្លើយសារភាព និងបទបញ្ជាដែលត្រូវបានសរសេរដោយដៃ ឬវាយដោយអង្គុលីលេខ ពីមន្ទីរសន្តិសុខក្រាំងតាចាន់ ទៅកាន់គ្រប់ខ្សែសង្វាក់បញ្ជាការនៃភូមិភាគនិរតី។ ឧទាហរណ៍ របាយការណ៍ និងចម្លើយសារភាពរបស់មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលមានស្លាកបោះត្រាត្រូវបានផ្ញើទៅ កាន់គណៈស្រុក១០៥ ហើយគណៈស្រុក១០៥ផ្ញើបន្តទៅឲ្យតំបន់១៣ ហើយពីរបីថ្ងៃបន្ទាប់មក ឯកសារទាំងនេះនឹងត្រូវបានបញ្ជូនត្រឡប់ទៅគណៈស្រុក១០៥វិញ ដោយលើឯកសារនោះគេបានសរសេរអំពីបទបញ្ជាដែលមន្ទីរសន្តិសុខក្រាំងតាចាន់ត្រូវអនុវត្ត ដូចជាត្រូវប្រហារជីវិត ឬដោះលែងអ្នកទោសជាដើម។ របាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែអំពីការអនុវត្តន៍"ផែនការការងារ" ត្រូវបានសរសេរឡើងដោយ កម្មាភិបាលស្រុក១០៥ និងផ្ញើទៅឲ្យតំបន់១៣។ ស្រដៀងគ្នា

នេះ តំបន់១៣ នឹងពន្យល់តាម៉ុក លេខាភូមិភាគនិរតីអំពីសកម្មភាពនៅមន្ទីរសន្តិសុខក្រាំងតាចាន់។

៤៧៧- មានការផ្លាស់ប្តូរព័ត៌មាន និងការចេញបទបញ្ជាក្នុងអង្គប្រជុំដែលត្រូវបានរៀបចំឡើងតាមកាលកំណត់រវាងថ្នាក់ផ្សេងៗនៃថ្នាក់ដឹកនាំភូមិភាគនិរតី ដូចជារវាងថ្នាក់ដឹកនាំស្រុក និងតំបន់ ឬថ្នាក់តំបន់ និងភូមិភាគ។ កិច្ចប្រជុំរវាងគណៈតំបន់ និងគណៈភូមិភាគត្រូវបានកំណត់ធ្វើឡើងរាល់៣ខែ ទៅ៦ខែម្តង ហើយបន្ទាប់មកទើបមានកិច្ចប្រជុំរវាងគណៈតំបន់ និងគណៈស្រុកផ្សេងៗជាហូរហែរ។ ក្នុងអង្គប្រជុំជាមួយលេខាតំបន់ គេបានអានឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់ស្រុក និងថ្នាក់ឃុំ ស្តាប់នូវ "សេចក្តីដកស្រង់ស្តីពីឱវាទណែនាំរបស់មន្ទីរ ៨៧០" ក្នុងនោះរួមមានទាំងការណែនាំឲ្យ "វែកមុខខ្មាំង"ផងដែរ។ ការឃោសនារបស់កម្ពុជាប្រជាធិបតេយ្យក៏ត្រូវបានធ្វើ និងលើកយកមកពិភាក្សានៅក្នុងអង្គប្រជុំកម្មាភិបាលថ្នាក់ស្រុកស្រដៀងគ្នានេះផងដែរ។

៤៧៨- ឯកសារមួយចំនួនធំរបស់ស្រុក១០៥ ដែលត្រូវបានរកឃើញ គឺជាឯកសាររបស់មូលដ្ឋានឃុំដែលបានរាយការណ៍ប្រាប់កម្មាភិបាលថ្នាក់ស្រុក១០៥ ឬកម្មាភិបាលថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីសកម្មភាពគួរឲ្យសង្ស័យមួយចំនួន ដូចជាការលួចអាហារ ការពុំប្រឹងប្រែងធ្វើការងារ ការធ្វើពុតឈឺ ការរៀបចំផែនការប្រឆាំង"អង្គការ" ឬការរៀបចំគម្រោងការលួចរត់ និងការស្នើសុំបញ្ជាពី"បក្ស" ជាដើម។ ដូចគ្នានេះ មន្ទីរសន្តិសុខក្រាំងតាចាន់ផ្ទាល់ជាអ្នកស្នើសុំឱវាទណែនាំ ឬជំនួយពីកម្មាភិបាលថ្នាក់លើចំពោះបញ្ហាមួយចំនួន។ របាយការណ៍របស់ឃុំក៏មានភ្ជាប់មកជាមួយនូវមនុស្សដែលត្រូវបានបញ្ជូនទៅថ្នាក់ស្រុកដើម្បីវាយតម្លៃហើយបន្ទាប់មក

គណៈស្រុក១០៥ នឹងសម្រេចថាតើគួរបញ្ជូនមនុស្សនោះទៅមន្ទីរសន្តិសុខក្រាំងតាចាន់ដែរ ឬយ៉ាងណា ទោះបីក្នុងពេលតែមួយខ្លួនបានរាយការណ៍អំពីសភាពការណ៍ប្រាប់ មន្ទីរតំបន់។

៤៧៩- របាយការណ៍ និងចម្លើយសារភាពរបស់មន្ទីរសន្តិសុខក្រាំងតាចាន់ ឬឃុំ ត្រូវបានបញ្ជូនទៅថ្នាក់ស្រុកដើម្បី"ពិភាក្សា"។ ថ្នាក់តំបន់ជាអ្នកពិគ្រោះបញ្ហាទាំងនោះ ហើយថ្នាក់ស្រុកជាអ្នកទទួលបញ្ហាឲ្យមន្ទីរក្រាំងតាចាន់យកទៅអនុវត្ត។ របាយការណ៍ពីថ្នាក់ឃុំត្រូវបានថ្នាក់ស្រុក ឬថ្នាក់តំបន់ធ្វើការឆ្លើយតបតាមរយៈការចេញបញ្ជាឲ្យចាប់ខ្លួន សួរចម្លើយ និង/ឬ"កម្ទេច" មនុស្សដែលគេបានលើកឡើងនៅក្នុងរបាយការណ៍ ការណែនាំឲ្យមន្ទីរសន្តិសុខក្រាំងតាចាន់អនុវត្តសេចក្ដីសម្រេចរបស់ខ្លួន ឬការជូនដំណឹងប្រាប់មន្ទីរក្រាំងតាចាន់ អំពីការបម្រុងចាប់ខ្លួននរណាម្នាក់ និងការបញ្ជូនមនុស្សទៅកាន់មន្ទីរសន្តិសុខនេះ។ ថ្នាក់ឃុំជាអ្នក ផ្ញើរ បាយការណ៍ទៅឲ្យគុកក្រាំងតាចាន់ ដោយរាយការណ៍ឲ្យពួកគេបានដឹងអំពីសេចក្ដីសម្រេច របស់ "ថ្នាក់លើរបស់បក្ស" ឬ "ស្រុក"ក្នុងការបញ្ជូន"ជនក្បត់"ទៅកាន់គុកក្រាំងតាចាន់ ដោយមានរបាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីសកម្មភាពវិទ្ធង្សនារបស់ពួកជនក្បត់ទាំង នោះ អមមកជាមួយ ឬមកតាមក្រោយ។ ឧទាហរណ៍នៃដំណើរការនេះត្រូវបានប្រទះឃើញនៅក្នុងរបាយការណ៍មួយចំនួនរបស់ឃុំគុស ដែលបានរាយការណ៍អំពីសកម្មភាពរបស់ខ្មាំងនៅតំបន់នោះ និងបានស្នើសុំការណែនាំពីថ្នាក់លើ។ ដំណើរការនេះតែងតែនាំឲ្យមានការសួរចម្លើយ ការធ្វើទារុណកម្ម និងការប្រហារជីវិតមនុស្សដែលគេបានចាប់យកមក។

៤៨០- របាយការណ៍មួយរបស់មន្ទីរភូមិភាគនិរតី ក៏បានចង្អុលបង្ហាញអំពីការរាយការណ៍ប្រាប់ថ្នាក់លើ អំពីព័ត៌មានស្ដីពីបញ្ហាសន្តិសុខ ការងារពលកម្ម សុខាភិបាល និងស្បៀងអាហារ ដែលប្រមូល បានពីថ្នាក់ឃុំ និងស្រុក ក្នុងនោះរួមមានព័ត៌មានស្ដីពីឧទាហរណ៍មួយចំនួននៃសកម្មភាពខ្មាំង ផែនការ និងបណ្ដាញក្បត់ ខ្លឹមសារនៃចម្លើយសារភាព ការវិវត្តន៍នៃផែនពលកម្មដោយបង្ខំ ការខ្វះខាតស្បៀង និងការស្លាប់ដោយសារជំងឺ។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៤៨១- មន្ទីរសន្តិសុខក្រាំងតាចាន់ត្រូវបានបង្កើតឡើងដើម្បីឃុំឃាំងខ្មាំង និងជនក្បត់ដែលត្រូវបានចាប់ ខ្លួន។ ចាប់តាំងពីពេលចាប់ផ្ដើម មន្ទីរសន្តិសុខក្រាំងតាចាន់ត្រូវបានបង្កើតឡើងដើម្បី "លត់ដំ" អ្នកទោសនយោបាយដែលមកពីស្រុក១០៥ និងមនុស្សដែលប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ឬ រំលោភវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាការប្រព្រឹត្តិខុសសីលធម៌។ នៅក្នុងមួយលើកៗ មន្ទីរសន្តិសុខក្រាំងតាចាន់បានឃុំខ្លួនអ្នកទោសចំនួនពី២០ ទៅ៤០នាក់នៅក្នុងអគារឃុំឃាំង នីមួយៗ ឬចំនួនសរុបពី៤០នាក់ ដល់១៦០នាក់។ ចំនួនអ្នកទោសថ្មីដែលត្រូវបាននាំមកឃុំខ្លួននៅ មន្ទីរក្រាំងតាចាន់ ស្ទើរតែជារៀងរាល់ថ្ងៃមានចំនួនចាប់ពីមួយចំនួនតូច ដល់៣០នាក់។

៤៨២- ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខក្រាំងតាចាន់បានបន្តឃុំឃាំងមនុស្សដែល ត្រូវបានចាប់ខ្លួនក្នុងនាមជាគិញខ្មាំង ប្រជាជនថ្មី ដែលពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ ជន ជាតិចិន ជនជាតិចាម ជនជាតិវៀតណាម ឬមនុស្សដែលមានទំនាក់ទំនងជាមួយវៀតណាម ឬមនុស្សដែលបានលួចអាហារ ឬត្អូញត្អែរអំពីការខ្វះស្បៀងអាហារ មនុស្សដែលបានប្រព្រឹត្ត ខុសសីលធម៌ ឬអ្នករត់ចោលជួរកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ បន្ថែមពីលើនេះ មន្ទីរសន្តិសុខ

ក្រាំងតាចាន់ក៏បានឃុំខ្លួនកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនឹងត្រូវបោសសម្អាត និង មនុស្សប្រុសស្រី និងកុមារ។

៤៨៣- នៅទូទាំងស្រុក១០៥ មនុស្សតែងតែត្រូវបានចាប់ខ្លួនដោយសមាជិកនៃក្រុមសេនាជន ភូមិ ឃុំ ឬស្រុក ប៉ុន្តែជួនកាល ឆ្មាំមន្ទីរសន្តិសុខក្រាំងតាចាន់ជាអ្នកចាប់ខ្លួន។ ស្ទើរតែរាល់ថ្ងៃ អ្នកជាប់ឃុំឃាំងថ្មីៗត្រូវបាននាំមកកាន់ ក.ត.ច នៅពេលថ្ងៃ និងនៅពេលយប់ ដោយត្រូវបានគេចងជាក្រុម ឬម្នាក់ៗ និងត្រូវបានគេបណ្តើរ។ នៅពេលអ្នកទោសទៅដល់ ឈ្លបចុច កណ្តឹងនៅក្លោងទ្វារចូលជាសញ្ញាប្រាប់ឆ្មាំ ក.ត.ច អំពីការមកដល់របស់អ្នកទោសថ្មី ហើយ បន្ទាប់មក ការទុកដាក់អ្នកទោសត្រូវបានធ្វើនៅក្លោងទ្វារចូល។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៤៨៤- សម្រាប់អ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ក.ត.ច ពួកគេត្រូវប្រឈមមុខនឹងស្ថានភាពគួរឲ្យខ្ពើមរអើម។ អ្នកទោសដែលជាមនុស្សពេញវ័យទាំងអស់នៅមន្ទីរសន្តិសុខនេះ ត្រូវបានគេដាក់ខ្នោះជើង និង/ឬ ដៃ ដោយភ្ជាប់ទៅនឹងរបារដែកវែងមួយនៅនឹងជញ្ជាំង ដែលក្នុងអគារឃុំឃាំងនីមួយៗ មានរបារចំនួនពីរ ហើយរបារនីមួយៗដាក់អ្នកទោសបានចំនួនប្រមាណពី២០ ទៅ២៥ នាក់។ អ្នកទោសប្រុសស្រីត្រូវបានគេដាក់ខ្នោះរួមគ្នានៅពេលថ្ងៃ និងពេលយប់ លើកលែងតែពេលត្រូវបានបង្ខំឲ្យធ្វើការ។ របបអាហារអ្នកទោសមិនគ្រប់គ្រាន់ ពោលគឺបាយ និង/ឬ បបរលាយបន្លែ ពីរពេលក្នុងមួយថ្ងៃ។ អ្នកទោសប្រុស និងស្រីត្រូវបានបង្ខំឲ្យបន្ទោរបង់ដាក់ត្រឡោក

ឬបឺដុងទាំងខ្លួនជាប់ខ្នោះ ហើយពេលបន្ទោរបង់រួច គេទុកកាកសំណល់នៅក្នុងបន្ទប់ឃុំឃាំងអ្នកទោស។ មន្ទីរឃុំឃាំងពុំមានកន្លែងសម្រាប់បោកគក់ ឬងូតទឹកឡើយ ហើយគេពុំអនុញ្ញាតឱ្យអ្នកទោសងូតទឹកខាងក្រៅមន្ទីរឃុំឃាំងឡើយ។

៤៨៥- អ្នកទោសបានរស់នៅក្រោមវិន័យដ៏តឹងតែងរបស់មន្ទីរឃុំឃាំង ដូចជាការហាមមិនឱ្យមានសំឡេងរំខាន ឬសកម្មភាពនៅពេលដេក ហើយប្រសិនបើអ្នកទោសរំលោភវិន័យទាំងនេះ ពួកគេនឹងត្រូវឆ្មាំវាយដំ។ ឆ្មាំត្រូវគេបញ្ជាឱ្យសម្លាប់អ្នកទោសណាដែលចង់លួចរត់ ហើយឆ្មាំបានធ្វើតាមបញ្ជាទាំងនេះ។ ការរំលោភ និងការបៀតបៀនផ្លូវភេទទៅលើអ្នកទោសស្ត្រី ពីសំណាក់ឆ្មាំ ក.ត.ច បានកើតមានជារឿយៗផងដែរ។ លើសពីនេះ គ្មានគ្រូពេទ្យ ឬគ្មានថ្នាំសង្កូវសម្រាប់អ្នកទោសឡើយ។ សម្រាប់អ្នកទោសដែលបានគេចផុតពីស្លាប់ ដោយសារស្ថានភាពទាំងនេះក្នុងរយៈពេលនៃការឃុំខ្លួនរបស់ពួកគេ គឺចាប់ពី៣ខែដល់ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារស្ថានភាពដ៏ហួសហេតុនៃការឃុំឃាំងនេះ អ្នកទោសបានស្លាប់ជាទៀងទាត់ដោយសារការវាយដំ ការលួចរត់ ជំងឺដង្កាត់ និងការអត់ឃ្លាន។

## ពលកម្មដោយបង្ខំ

៤៨៦- អ្នកទោសគុក ក.ត.ច ត្រូវបានបង្ខំឱ្យធ្វើពលកម្មយ៉ាប់យ៉ឺនដូចជា កាប់គាស់ភ្លឺរាស់ស្រែ រែកទឹក កាប់ឆ្ការព្រៃ ហាន់ថ្ម ជីកដី និងយកដីពីដំបូក និងស្រះដើម្បីធ្វើស្រែចម្ការ ដាំដំណាំ ធ្វើកន្ទេលស្លឹកត្នោត និងដាំស្លឱ្យអ្នកទោស។ អ្នកទោសត្រូវបានបង្ខំឱ្យធ្វើការចាប់ពីម៉ោង០៧ ឬម៉ោង៨ព្រឹក រហូតដល់ម៉ោង១០កន្លះ ឬដល់ម៉ោង១១ព្រឹក និងបន្តពីម៉ោង០១ ឬម៉ោង០២ ដល់ម៉ោង០៣ ឬដល់ម៉ោង០៤រសៀល។

## ការសួរចម្លើយ និងការធ្វើទារុណកម្ម

៤៨៧- អ្នកទោសគុក ក.ត.ច បានឆ្លងកាត់ការសួរចម្លើយ និងការធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ។ គោលបំណងនៃការសួរចម្លើយ គឺដើម្បីស្វែងរកមនុស្សដែលជាអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងភ្នាក់ងារមកពីវៀតណាម សេអ៊ីអា ឬកាហ្សេបេ និងសកម្មភាពក្បត់បណ្តាលមកពីការលួចអាហារ ការពុំខំប្រឹងធ្វើការ ការប្រព្រឹត្តិខុសសីលធម៌ ការធ្វើពុតឈឺ ការត្អូញត្អែរអំពីរបបកម្ពុជាប្រជាធិបតេយ្យ ការបំផុសការបះបោរ ឬការរៀបចំផែនការរត់គេចពីរបបកម្ពុជាប្រជាធិបតេយ្យ។ វិធីសាស្ត្រក្នុងការធ្វើទារុណកម្មមួយចំនួនមានដូចជា "វិធីត្រជាក់" ដូចជា"ការសន្យា ការលួងលោម ការបោកបញ្ឆោត ឬការប្រើឧបាយកល"ព្រមទាំង "វិធីក្តៅ" ដូចជាការវាយដំធ្ងន់ធ្ងរនឹងខ្សែតី ឬរំពាត់ផ្តៅ ការយកខ្សែព្យួរចងដៃ ជើង និង/ឬ របស់អ្នកទោសអស់រយៈពេលជាយូរ ការប្រើប្រាស់ដង្កាប់ដកច្រមុះ និងក្រចក និងការធ្វើឲ្យថប់ដង្ហើមដោយយកថង់ប្លាស្ទិកគ្របមុខ។ អ្នកទោសស្ត្រីបីនាក់ត្រូវបានគេយកដង្កាប់ដកក្រចកយ៉ាងសាហាវព្រៃផ្សៃ រងការជះទឹកអាស៊ីដ ត្រូវបានគេសម្រាតសម្លៀកបំពាក់ និងវះយកថ្លើមអាំងស៊ី។ ជាទៀងទាត់ អ្នកទោសបានស្លាប់ដោយសារការរងទារុណកម្ម។

៤៨៨- ការសួរចម្លើយ និងការធ្វើទារុណកម្ម តែងតែកើតមានជាទៀងទាត់ ដោយត្រូវបានធ្វើឡើងផ្អែកតាមរបាយការណ៍របស់ឃុំដែលអ្នកទោសរស់នៅ។ អ្នកសួរចម្លើយនៅគុក ក.ត.ច បានទទួលការបណ្តុះបណ្តាលពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ថ្នាក់ស្រុក និងថ្នាក់តំបន់ ឲ្យប្រើប្រាស់"វិធីត្រជាក់"មុន "វិធីក្តៅ" ប្រសិនបើពុំបានសម្រេចក្នុងការយកចម្លើយ ដែលខ្លួនចង់

បាន។ ការធ្វើទារុណកម្មប្រព្រឹត្តទៅក្នុងអគារដោយឡែកមួយក្នុងបរិវេណគុក ក.ត.ច នៅចម្ងាយពី២០ ទៅ៣០ម៉ែត្រពីអគារឃុំឃាំង។ បុគ្គលិកចំនួន២ទៅ៣នាក់របស់មន្ទីរសន្តិសុខនេះ មានវត្តមានអំឡុងពេលសួរចម្លើយដោយម្នាក់ ឬ២នាក់ជាអ្នកសួរចម្លើយ និង/ឬ ធ្វើទារុណកម្ម រីឯម្នាក់ទៀតកត់ត្រាចម្លើយសារភាពជាលាយលក្ខណ៍អក្សរ និងវាយអង្គលីលេខនៅពេលក្រោយ។ អំឡុងពេលសួរចម្លើយ កម្មាភិបាលមន្ទីរសន្តិសុខម្នាក់ជាអ្នកឈរយាមនៅខាងក្រៅ។ ជារឿយៗ ប្រធានគុក ក.ត.ច ត្រូវបានគេប្រទះឃើញដើរជុំវិញកន្លែងសួរចម្លើយ ដៃកាន់ដំបង ក្បាលរុំក្រមារ និងដើរចូលមកកន្លែងសួរចម្លើយ។ [redacted] សមាជិកគណៈស្រុក១០៥ ត្រូវបានគេឃើញពេលគាត់កំពុងសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោសនៅ ក.ត.ច។

## ការសម្លាប់មនុស្សក្រៅច្បាប់

៤៨៩- ការប្រហារជីវិត គឺជាលទ្ធផលចុងក្រោយរបស់អ្នកទោសចំនួនរាប់ពាន់នាក់ នៅគុកក្រាំងតាចាន់ ហើយមានការលើកទឹកចិត្ត និងការណែនាំឱ្យមានការសម្លាប់ខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យនៅគ្រប់ជាន់ថ្នាក់ក្នុងស្រុក១០៥ និងគ្រប់ឋានានុក្រមនៅគុកក្រាំងតាចាន់។ នៅក្នុងអង្គប្រជុំថ្នាក់មូលដ្ឋាន តា ម៉ុក បានណែនាំឱ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា នៅស្រុក១០៥ ធ្វើការវែកមុខ និងសម្លាប់ខ្មាំង។ ឯកសាររបស់ស្រុក១០៥ បង្ហាញអំពីផ្នត់គំនិតរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថ្នាក់មូលដ្ឋានក្នុងការស្រាវជ្រាវ និង"កម្ទេច" ខ្មាំងបដិវត្តន៍។ ក្នុងឯកសាររបស់កម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងពេលនោះ មានបទបញ្ជាមួយចំនួនរបស់លេខាតំបន់១៣ ដែលបញ្ជាទៅកាន់ប្រធានគុក ក.ត.ច ឱ្យ"កម្ទេច" អ្នកទោស។

៤៩០- ដំណើរការនៃការប្រហារជីវិតបានចាប់ផ្តើមកើតមាននៅពេលនិរសារស្រុក១០៥ បាននាំយកបញ្ហាប្រហារជីវិតពីកម្មាភិបាលថ្នាក់ស្រុក ឬថ្នាក់តំបន់របស់កម្ពុជាប្រជាធិបតេយ្យមកឱ្យប្រធានគុក ក.ត.ច ក្នុងទម្រង់ជាចំណារទឹកប៊ិចពណ៌ក្រហមនៅលើចម្លើយសារភាពរបស់អ្នកទោស ឬស្នាមគូសក្រហមនៅលើឈ្មោះអ្នកទោសដែលត្រូវកម្ទេចនៅលើបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានគេបញ្ជូនត្រឡប់មកវិញ។ ក្នុងអង្គប្រជុំ បុគ្គលិកត្រូវបានគេប្រាប់ឱ្យដឹងអំពីពេលវេលានៃការសម្លាប់ នៅពេលដែលប្រធានគុកបានចាត់តាំងបុគ្គលិកឱ្យប្រមូល និងប្រហារជីវិតអ្នកទោសដែលគេបានជ្រើសរើស។ គេអានឈ្មោះរបស់អ្នកទោស បន្ទាប់មកគេដោះខ្នោះអ្នកទោសចេញ និងនាំទៅកាន់កន្លែងសួរចម្លើយ រួចគេចងរុំមុខអ្នកទោស ហើយនាំទៅកាន់កន្លែងប្រហារជីវិត។ បុគ្គលិកខ្លះឈរយាមនៅខាងក្រៅបរិវេណគុកក្រាំងតាចាន់ បុគ្គលិកខ្លះបណ្តើរអ្នកទោស ហើយបុគ្គលិកគុកម្នាក់ត្រូវបណ្តើរអ្នកទោសម្នាក់ទៅកាន់រណ្តៅឱ្យអ្នកទោសអង្គុយ ហើយប្រាប់អ្នកទោសថា "កុំចងគំនុំនឹងអង្គការ" ហើយក៏ប្រហារជីវិតអ្នកទោសតែម្តង។

៤៩១- អ្នកទោសស្រី ប្រុស ត្រូវបានប្រហារជីវិតដោយការវាយត្រង់កញ្ចឹងកនឹងដំបងឫស្សី ឬដែកគោលរទេះ ហើយបន្ទាប់មកគេអារកអ្នកទោសនឹងដាវ ឬកាំបិត។ អ្នកទោសកុមារបានទទួលរងការវាយដំរហូតដល់ស្លាប់ដោយសារការបោកផ្ទប់នឹងដើមឈើ។ អំឡុងពេលប្រហារជីវិតអ្នកទោស គេបានកាប់ឈើ និង/ឬចាក់មីក្រូដើម្បីបន្លប់សំឡេងនៃការប្រហារជីវិត និងសម្រែកអ្នកទោស។ ការប្រហារជីវិតបានកើតមានជារៀងរាល់ថ្ងៃ ឬចំនួនពី ២ទៅ ៣ដងក្នុងមួយខែខុសៗគ្នា នៅពេលទៀបភ្លឺរហូតដល់ពេលយប់ ហើយអ្នកទោសដែលត្រូវបានសម្លាប់

ក្នុងមួយលើកមានចំនួនតិចតួច រហូតដល់រាប់រយនាក់អាស្រ័យទៅតាមភាពចាំបាច់។ បន្ទាប់ពីការប្រហារជីវិត បញ្ជីអ្នកទោសគុកក្រាំងតាចាន់ត្រូវបានប្រធានគុកក្រាំងតាចាន់សរសេរចំណារថា "សម្រេចកម្ទេច" និងហត្ថលេខា រួចសរសេររបាយការណ៍នោះ ជាអក្សរវាយដោយម៉ាស៊ីនអង្គុលីលេខ។

៨៩២- ការប្រហារជីវិតអ្នកទោសបានកើតមាននៅឯរណ្តៅសាកសពរួម ក្នុងបរិវេណធំនៃគុក ក.ត.ច និងនៅខាងក្រៅបរិវេណ។ រណ្តៅសាកសពរួមធំដែលស្ថិតនៅបរិវេណខាងក្នុង ត្រូវបានគេបោះបង់ចោលនៅពេលអស់បន្ទប់ទំនេរសម្រាប់ដាក់អ្នកទោសនៅចន្លោះឆ្នាំ១៩៧៧-១៩៧៨ ហើយ រណ្តៅសាកសពរួមនានាត្រូវបានគេជីកនៅខាងក្រៅបរិវេណ។ អ្នកទោសត្រូវបានបង្ខំឱ្យជីករណ្តៅសាកសពរួម ជារៀងរាល់ថ្ងៃ ឬបីដងក្នុងមួយខែ។ រណ្តៅទាំងនេះមានទទឹង០២ម៉ែត្រ បណ្តោយ០៣ម៉ែត្រ និងជម្រៅ០១ម៉ែត្រ ទៅ០១ម៉ែត្រកន្លះ ដាក់សាកសពអ្នកទោសបានពី៣០ ទៅ៦០នាក់។ ប្រធានគុក ក.ត.ច ក៏បានចាត់តាំង ឱ្យបុគ្គលិកជីករណ្តៅផងដែរ។

៨៩៣- បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម អ្នកភូមិបានប្រទះឃើញរណ្តៅសាកសពរួមដែលគេបានលុបដីកប់ និងពុំបានលុបដីកប់។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ មន្ត្រីមូលដ្ឋាន អ្នកសារព័ត៌មាន និងអង្គការOxfam International បានជីកគាស់រណ្តៅសាកសពរួមទាំងនេះ ហើយការរាប់ចំនួនសាកសពមិនផ្លូវការដែលត្រូវបានប្រទះឃើញក្នុងរណ្តៅទាំងនោះ មានចំនួនខុសៗគ្នា ពីចន្លោះ១០០៤៥ ទៅ១៧០០០នាក់។ របាយការណ៍នាពេលដំណាលគ្នា នោះដែលមានហត្ថលេខារបស់ប្រធានគុក ក.ត.ច [redacted] [redacted]

[redacted] មានសេចក្តីដូចតទៅ"មន្ទីរអប់រំ១០៥ បច្ចុប្បន្ន យើងបានកម្ទេចខ្មាំងបានចំនួន១៥០០០នាក់។ សូមបក្សជ្រាបជាព័ត៌មាន។ [redacted]។ នៅចន្លោះឆ្នាំ២០០២ ទៅ២០០៣ គេបានសង់ចេតិយមួយ ដើម្បីដាក់ឆ្អឹងជនរងគ្រោះនៅគុកក្រាំងតាចាន់ ហើយកាលនោះ សាកសពអ្នកទោសត្រូវបានគេរាប់ឃើញចំនួន១០០១១នាក់។ មកទល់សព្វថ្ងៃ រណ្តៅសាកសពជាច្រើនទៀត នៅពុំទាន់ត្រូវបានគេប៉ះពាល់នៅឡើយទេ។

## មន្ទីរសន្តិសុខសង់

## ទីតាំង និងប្រតិបត្តិការ

៤៩៤- មន្ទីរសន្តិសុខសង់ ("សង់") ឬគុកសង់ ស្ថិតនៅចម្ងាយប្រាំរយម៉ែត្រពីទិសខាងកើតភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងជាផ្នែកមួយនៃស្រុក១៥៤ តំបន់២៥ ភូមិភាគនិរតី កាលអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ គុកសង់បានចាប់បើកប្រតិបត្តិការនៅចន្លោះចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៩។

៤៩៥- មន្ទីរសន្តិសុខសង់ ត្រូវបានសាងសង់នៅលើបរិវេណនៃសាលាបណ្តុះបណ្តាលគរុកោសល្យ គុកសង់ គឺជាមន្ទីរសន្តិសុខដ៏ធំដែលមានអគារចំនួនពីរនៅលើផ្ទៃដីចំនួន០២ហិកតា។ អគារទីមួយ គឺជាគុកដែលមានបរិវេណទំហំប្រមាណ២០០ម៉ែត្រ ទៅ៣០០ម៉ែត្រ គុណនឹង១០០ ទៅ៣០០ម៉ែត្រ និងមានអគារឃុំឃាំងធ្វើពីបេតុងចំនួន០២ ទៅ០៤អគារ កន្លែងសួរចម្លើយមួយ ចង្ក្រានបាយមួយ និងខ្ទមមួយសម្រាប់បុគ្គលិកគុកស្នាក់នៅ និងផ្ទះមួយសម្រាប់ប្រធាន

គុកសង់។ កន្លែងឃុំឃាំងទីមួយមានទំហំ០៨ គុណនឹង២០ម៉ែត្រ សម្រាប់ដាក់អ្នកទោសស្រី។ កន្លែងឃុំឃាំងទីពីរ ឬ"គុកងងឹត" មានទំហំ០១ម៉ែត្រ គុណនឹង០៧ម៉ែត្រ ចែកចេញជាបន្ទប់មួយចំនួន សម្រាប់ដាក់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចោទប្រកាន់អំពីបទល្មើសធ្ងន់ធ្ងរ។ គុកសង់ គ្មានបំណែកសេសសល់ឡើយ។ ទីតាំងនៃកន្លែងប្រហារជីវិតទ្រង់ទ្រាយធំស្ថិតនៅចម្ងាយ២០០ម៉ែត្រ ទៅ៥០០ម៉ែត្រ ត្រង់ភាគខាងកើតនៃបរិវេណគុក។

## រចនាសម្ព័ន្ធគ្រប់គ្រង

## ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៤៩៦- សង់ គឺជាមន្ទីរសន្តិសុខថ្នាក់ស្រុកមួយ ក្រោមសិទ្ធិអំណាចរបស់ស្រុក១៥៤ នៅពេលដែលតំបន់២៥ មានមន្ទីរសន្តិសុខផ្ទាល់ខ្លួនឈ្មោះ កោះគ ដែលមានឈ្មោះតាមលេខកូដថាមន្ទីរ ១៥។ ប្រធានគុកសង់ជាអ្នករាយការណ៍ជូន [redacted] និងបានចូលរួមជាទៀងទាត់ក្នុងអង្គប្រជុំនៅមន្ទីរស្រុកកន្ទួត។ [redacted] បានចុះពិនិត្យមន្ទីរសន្តិសុខនេះរៀងរាល់ពីរបីខែម្តង ហើយ តា ម៉ុក លេខាភូមិភាគនិរតី ជួនកាលបានចុះមកពិនិត្យមន្ទីរនេះដែរ។ លេខាតំបន់២៥ កាលអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យមានឈ្មោះ [redacted]។

## រចនសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ

៤៩៧- ឈ្មោះ ម៉ុង គឺជាប្រធានគុកសង់ដំបូង។ ក្រោមការគ្រប់គ្រងរបស់ខ្លួន ឈ្មោះ ម៉ុង ទទួលបន្ទុកដោះស្រាយបញ្ហាសន្តិសុខ ដូចជាការសួរចម្លើយអ្នកទោស ការអានចម្លើយសារភាព និងការ

កំណត់មុខសញ្ញាខ្មាំង។ អនុប្រធានឈ្មោះ [redacted] (គាត់ក៏ជាអ្នកសួរចម្លើយអ្នកទោសផងដែរ) ហើយឈ្មោះ [redacted] ជាសមាជិកគណៈគុកសង់។ ក្នុងចុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ ឈ្មោះ ម៉ុង ត្រូវបានចាប់ខ្លួន ហើយកម្មាភិបាលឈ្មោះ [redacted] បានចូលជំនួស។ គុកនេះមានបុគ្គលិកចំនួនប្រមាណ២០នាក់។ បុគ្គលិកត្រូវបានបែងចែកចេញជាផ្នែកឃាមកាមសម្រាប់ស្ត្រី និងសម្រាប់បុរស និងអង្គភាពសួរចម្លើយ។ ឈ្មោះ [redacted] ជាអ្នកទទួលខុសត្រូវទុកដាក់កំណត់ហេតុអ្នកទោស រួមទាំងរបាយការណ៍នៃការសួរចម្លើយ និងការសួរចម្លើយអ្នកទោស។ [redacted] គឺជាពេជ្ឈឃាដដ៏សំខាន់។

## ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៤៩៨- ក្នុងពេលធ្វើជាប្រធានគុកសង់ ឈ្មោះ ម៉ុង បានចូលរួមក្នុងអង្គប្រជុំនៅមន្ទីរស្រុក១៥៤ នៅកន្ទួតនៅចន្លោះពីពីរដងក្នុងមួយសប្តាហ៍ ទៅពីរដងក្នុងមួយខែ។ ឈ្មោះ ម៉ុង ជាអ្នកប្រាស្រ័យទាក់ទងជាមួយមន្ទីរសន្តិសុខផ្សេងៗ ជារឿយៗតាមរយៈការបញ្ជូននិរសាររបស់គាត់ឱ្យយកសំបុត្រប្រគល់ឱ្យមន្ទីរសន្តិសុខ កោះគ ដែលជាមន្ទីរសន្តិសុខតំបន់ ២៥។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៤៩៩- អ្នកទោសត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅគុកសង់ ដោយសារពួកគាត់ជាខ្មាំងនយោបាយរំលោភបំពានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬអំពើល្មើសដែលត្រូវបានចាត់ទុកថាជាអំពើក្បត់ខាងនយោបាយ។ ភាគច្រើននៃអ្នកជាប់ឃុំឃាំង គឺជាទាហាននៃអតីតរបបសាធារណរដ្ឋខ្មែរ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចោទថាជាជនក្បត់ និង

ប្រពន្ធកូនរបស់ពួកគេ ឬ"ប្រជាជនថ្មី"មកពីភ្នំពេញ។ ក្នុងមួយលើក យ៉ាងហោចណាស់មានអ្នកទោសចំនួនមួយរយនាក់ត្រូវបានឃុំឃាំងនៅគុកសង់។ អ្នកទោសថ្មីបានចូលមកដល់ជាក្រុមក្នុងចំនួនខុសគ្នា ដែលក្រុមអ្នកទោសខ្លះមានចំនួនរហូតដល់ចិតសិបនាក់។ មានអ្នកទោសចំនួនប្រហែលប៉ែតសិបនាក់ត្រូវបានឃុំឃាំង នៅពេលវៀតណាមបានចូលកាន់កាប់មន្ទីរសន្តិសុខនេះ។

៥០០- អ្នកទោសថ្មីបានមកដល់គុកសង់ជាទៀងទាត់ ពិសេសមកពីស្រុក១៥៤ ហើយជាទូទៅពួកគាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរសន្តិសុខនេះតាមរយៈប្រធាន និង/ឬ ឈ្លបនៃអង្គភាព ភូមិ ឬឃុំរបស់ពួកគាត់ដោយថ្មើរជើង តាមកង់ ឬរទេះគោ។ នៅពេលមកដល់ អ្នកទោសថ្មីត្រូវចុះឈ្មោះ។ គេស្វែងរកចាប់ខ្លួន និងឃុំឃាំងមនុស្សបន្ថែមទៀត ផ្អែកតាមចម្លើយសារភាពរបស់អ្នកជាប់ឃុំឃាំងនៅគុកសង់។

៥០១- ឯកសារអ្នកទោសដែលបានជាប់ឃុំឃាំងនៅគុកសង់ ត្រូវបានរៀបចំដោយប្រធានគុកឈ្មោះ ម៉ុង ហើយនិរសារឈ្មោះ [redacted] ជាអ្នកប្រគល់ឯកសារនោះ ទៅឱ្យប្រធានសហករណ៍ ឃុំ កងចល័ត និងអង្គភាពមួយចំនួនទៀតនៅខាងក្រៅមន្ទីរឃុំឃាំង។ គោលបំណងទូទៅនៃការប្រាស្រ័យទាក់ទងគ្នានេះ គឺដើម្បីជម្រាបអ្នកទទួលសំបុត្រ ឱ្យបានដឹងអំពីខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកទោស ពិសេសអំពីឈ្មោះមនុស្សដែលអ្នកទោសបានឆ្លើយដាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ ដើម្បីងាយស្រួលដល់ការសម្គាល់អត្តសញ្ញាណ និងការចាប់ខ្លួនបណ្តាញសង្ស័យរបស់ខ្មាំងបន្ថែមទៀត។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

## លក្ខណៈអមនុស្សធម៌

៥០២- អ្នកទោសនៅគុកសង់បានទទួលរងគ្រោះពីស្ថានភាពដ៏ឃោរឃៅ។ អ្នកទោសប្រុសស្រីត្រូវបានឃុំឃាំងដោយឡែកពីគ្នា។ អ្នកទោសប្រុសជាប់ខ្នោះជើងដែលត្រូវបានគេភ្ជាប់ទៅនឹងរបារវែងមួយដាក់អ្នកទោស២០នាក់។ អ្នកទោសប្រុសត្រូវដាក់ខ្នោះនៅពេលយប់ ប៉ុន្តែអ្នកទោសស្រីពុំជាប់ខ្នោះនៅពេលយប់ទេ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបោសសម្អាតត្រូវបានគេដាក់ក្នុង"គុកងងឹត"ដែលមានចំនួន០៥បន្ទប់ បន្ទប់នីមួយៗមានទំហំ០១ម៉ែត្រការ៉េ។ អ្នកទោសក្នុងគុកដ៏តូចនេះ ត្រូវអង្គុយចោងហោង អាក្រាតកាយគ្មានសម្លៀកបំពាក់។ អ្នកទោសទាំងអស់ត្រូវបានបង្ខំឱ្យបន្ទោរបង់ដាក់ធុងសាំង ដែលគេបានទុកសម្រាប់បន្ទោបង់ទាំងដៃជើងជាប់ខ្នោះ។

៥០៣- អាហារមិនគ្រប់គ្រាន់។ សម្រាប់អ្នកទោសម្នាក់ គេផ្តល់បបរមួយវែកទៅបីវែក ម្តងឬពីរដងក្នុងមួយថ្ងៃ។ អ្នកទោសតែងតែស្លាប់ដោយភាពអត់ឃ្លានជាទៀងទាត់ ពោលគឺជាមធ្យមក្នុងមួយថ្ងៃមានអ្នកទោសស្លាប់ប្រហែល៣នាក់។ មានតែអ្នកជាប់ឃុំឃាំងដែលអាចធ្វើការបានតែប៉ុណ្ណោះ ដែលត្រូវគេផ្តល់ឱ្យនូវថ្នាំសង្កូវ ផ្ទុយទៅវិញអ្នកទោសផ្សេងដែលគ្មានកម្លាំងធ្វើការមិនត្រូវបានគេផ្តល់ការថែទាំវេជ្ជសាស្ត្រទេ។ ការស្លាប់ដោយសារជំងឺដង្កាត់ និងការខ្វះ ការថែទាំព្យាបាលកើតមានជាប្រចាំ។ ស្ថានភាពទាំងនេះធ្ងន់ធ្ងររហូតដល់ប្រធានគុកសង់ ទទួលស្គាល់ថា របស់របរ ដូចជាសម្លៀកបំពាក់គួរត្រូវបានទុកឱ្យឆ្ងាយពីខ្លួនអ្នកជាប់ឃុំឃាំងដើម្បីកុំឱ្យពួកគេចងកសម្លាប់ខ្លួន។

## ពលកម្មដោយបង្ខំ

៥០៤- ការធ្វើពលកម្មដោយបង្ខំនៅគុកសង់មានលក្ខណៈយ៉ាប់យ៉ឺន។ អាស្រ័យទៅតាមភាពធ្ងន់ធ្ងរនៃទោសកំហុសរបស់ពួកគេ អ្នកទោសខ្លះត្រូវបានបង្ខំឱ្យធ្វើការទាំងដៃជើងជាប់ខ្នោះ ដូចជា ជីកដីធ្វើស្រែ លើកថ្នាលដំឡូង និងឆ្ការព្រៃ និងគាស់ឫសឈើ។ អ្នកទោសដែលជាស្ត្រីមានផ្ទៃពោះត្រូវបានបង្ខំឱ្យរែកទឹកបឹងពី៥០ ទៅ៧០ប៉ោតក្នុងមួយថ្ងៃ ដើម្បីស្រោចដើមខ្ទុរ។ ស្ថិតក្រោមការឃោមកាម អ្នកទោសត្រូវបានបង្ខំឱ្យធ្វើការពីម៉ោង០៥ ទៅ០៦ព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់ និងចាប់ពីម៉ោង០១ ឬម៉ោង០២រសៀល រហូតដល់ម៉ោង០៥ ឬម៉ោង០៦ល្ងាច។ ឆ្មាំជាអ្នកនាំអ្នកទោសទៅកាន់ការដ្ឋាន និងនាំត្រឡប់មកគុកវិញ ហើយឆ្មាំតែងតែឃ្លាំមើលអ្នកទោសជាប់ជាប្រចាំខ្លាចក្រែងពួកគេលួចរត់។ ដោយសារស្ថានភាពការងារទាំងនេះ ការស្លាប់របស់អ្នកទោសដោយការបាក់កម្លាំង គឺជារឿងធម្មតា។

៥០៥- ការរំលោភបំពានធ្ងន់ធ្ងរលើរូបរាងកាយ គឺជាផ្នែកទូទៅមួយនៃការធ្វើពលកម្មដោយបង្ខំនៅគុកសង់។ នៅពេលដើរទៅធ្វើការ អ្នកជាប់ឃុំតែងតែត្រូវបានរងការវាយដំនឹងដំបង និងរំពាត់ខ្សែតី។ អ្នកទោសម្នាក់ត្រូវបានគេវាយដំដោយសារការធ្វើកំពប់ស្រូវនៅពេលធ្វើការ និងត្រូវបានចោទថាព្យាយាមធ្វើវិទ្ធ្វេទកម្មសេដ្ឋកិច្ច។ អ្នកទោសម្នាក់ទៀតបានរងការវាយដំនឹងធាងត្នោតរហូតដល់ស្លាប់ដោយសារបានតមាត់នឹងឆ្មាំ ហើយអ្នកទោសម្នាក់ទៀតត្រូវបានឆ្មាំវាយនឹងដំបងឫស្សីដោយសារអ្នកទោសនោះបានរើសកន្ទុយបារីជក់។

## ការសួរចម្លើយ និងការធ្វើទារុណកម្ម

៥០៦- អ្នកសួរចម្លើយនៅគុកសង់ បានប្រើប្រាស់ទារុណកម្មដ៏សាហាវព្រៃផ្សៃ ក្នុងអំឡុងពេលសួរចម្លើយ ការសួរចម្លើយ និងការធ្វើទារុណកម្ម គឺដើម្បីរកមុខខ្មាំងរបស់បក្សកុម្មុយនីស្ត កម្ពុជា

ពិសេសមនុស្សដែលជាប់ពាក់ព័ន្ធនឹងអតីតរបបសាធារណរដ្ឋខ្មែរ ពួកនាយទុន ពួកសក្តិភូមិ និង មនុស្សដែលជាប់សង្ស័យអំពីអំពើខុសសីលធម៌ និងភ្នាក់ងាររបស់សេអ៊ីអា និងកាហ្សេបេ។ គេបានប្រើប្រាស់វិធីសាស្ត្រមួយចំនួនក្នុងការធ្វើទារុណកម្មមានដូចជា ការ វាយដំនឹងរំពាត់ផ្តៅ ឬការគ្របក្បាលអ្នកទោសនឹងថង់ប្លាស្ទិករហូតដល់ថប់ដង្ហើមសន្លប់។ នៅពេលអ្នកទោស“ឆ្លើយខុស” ពួកគេបានរងការវាយដំ និងត្រូវបានបញ្ជូនឲ្យទៅដេក ជាមួយ សាកសព ឬមនុស្ស ជិតស្លាប់។ អ្នកជាប់ឃុំឃាំងជានារីបានត្អូញត្អែរថា ខ្លួនបានទទួល រងការរំលោភផ្លូវភេទក្នុង អំឡុងពេលសួរចម្លើយ។ ដូច្នេះ ការស្លាប់របស់អ្នកទោស ដោយសារទារុណកម្មបានកើតមាន នៅគុកសង់។

៥០៧- ការសួរចម្លើយមួយចំនួនមានរយៈពេលពេញមួយល្ងាច និងបន្តរហូតដល់យប់ជ្រៅ។ លេខាម្នាក់ ជាអ្នកកត់ត្រាចម្លើយសារភាព រួចទើបយកកំណត់ត្រានោះទៅវាយអង្គុលីលេខ ហើយ ប្រធានគុកសង់ជាអ្នកពិនិត្យមើល និងចុះហត្ថលេខា។ បញ្ជីឈ្មោះមនុស្សដែលត្រូវបាន អ្នកទោសឆ្លើយដាក់នៅក្នុងចម្លើយសារភាព ត្រូវបាននិរសាររបស់ប្រធានគុកប្រគល់ទៅឲ្យ ប្រធានកងចល័ត និងសហករណ៍ទូទាំងស្រុក“ដើម្បីស្រាវជ្រាវរកបណ្តាញ”។ ប៉ុន្មានថ្ងៃក្រោយ មកមនុស្សដែលត្រូវបានអ្នកទោសឆ្លើយដាក់ក្នុងចម្លើយសារភាព នឹងត្រូវបានចាប់ខ្លួន និង បញ្ជូនទៅកាន់គុកសង់ដើម្បីសួរចម្លើយ។

## ការសម្លាប់មនុស្សក្រៅច្បាប់

៥០៨- មនុស្សដែលត្រូវបានចាត់ទុកថាជាខ្មាំងរបស់បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា នៅស្រុក១៥៤ និង តាមបណ្តាឃុំនានាជុំវិញស្រុកនេះ ត្រូវបានប្រហារជីវិតជាលក្ខណៈប្រព័ន្ធនៅគុកសង់ ដោយ

ហេតុថាគុកនេះមានគោលដៅ "ចាប់ខ្មាំងដាក់គុក...រួចសម្លាប់ចោល"។ រដ្ឋអំណាចនៅគុកសង់បានទទួលបញ្ជីឈ្មោះអ្នកទោសដែលត្រូវប្រហារជីវិត និងអ្នកទោសដែលត្រូវនាំទៅកាន់ទីតាំងផ្សេងៗ។ គុកសង់រក្សាទុកនូវ"បញ្ជីអ្នកទោសចូល" និង"បញ្ជីអ្នកទោសចេញ" ហើយបញ្ជីប្រហារជីវិត គឺជាឯកសារ"សម្ងាត់បំផុត"។ ពាក្យ"កម្ទេច" ត្រូវបានគេប្រទះឃើញនៅលើបញ្ជីអ្នកទោសទាំងនេះ។

៥០៩- ជាធម្មតា ការប្រហារជីវិតបានកើតមាននៅពេលយប់ដែលជាពេលអ្នកទោសមួយចំនួនធំ ត្រូវបាននាំយកទៅសម្លាប់នៅឯព្រៃឫស្សីក្បែរនោះ។ ក្នុងមួយលើក យ៉ាងហោចណាស់មានអ្នកទោសចំនួនសាមសិបនាក់ត្រូវបាននាំយកទៅសម្លាប់។ នៅពេលខ្លះ អ្នកទោសដែលត្រូវប្រហារជីវិតមានចំនួនលើសពី៨០នាក់។ ជួនកាល អ្នកជាប់ឃុំឃាំងត្រូវបានគេបណ្តើរទៅកាន់កន្លែងប្រហារជីវិត ប៉ុន្តែភាគច្រើនអ្នកទោសត្រូវបានគេដឹកតាមរថយន្ត។ រថយន្តទាំងនេះ"ចេញចូលទៅមក"។

៥១០- អ្នកជាប់ឃុំឃាំងដែលត្រូវបានជ្រើសរើសយកទៅសម្លាប់ត្រូវបានគេដោះខ្នោះ ចងស្លាបសេកបណ្តើរទៅមុខអគារឃុំឃាំង រាប់ចំនួន និងបណ្តើរ ឬដឹកតាមរថយន្តទៅកាន់ទីតាំងប្រហារជីវិត។ ឆ្មាំបានកុហកប្រាប់អ្នកជាប់ឃុំឃាំងថាខ្លួនកំពុងនាំពួកគេទៅកាន់សហករណ៍។ នៅពេលអ្នកទោសទៅដល់កន្លែងប្រហារជីវិត អ្នកជាប់ឃុំឃាំងត្រូវបានគេសម្រាតសម្លៀកបំពាក់ បញ្ជាឱ្យអង្គុយលុតជង្គង់នៅមាត់រណ្តៅ និងត្រូវបានសម្លាប់ដោយការវាយត្រង់កញ្ចឹងក អារក វះពោះ និងគ្រវែងសាកសពអ្នកទោសទៅក្នុងរណ្តៅ។ គេបានប្រទះឃើញដំបងដែកនៅមាត់រណ្តៅ។ ប្រមាត់អ្នកទោសត្រូវបានគេវះយកចេញ និងហាលថ្ងៃឱ្យស្ងួត ហើយជួនកាលកម្មាភិបាល

បក្សកុម្មុយនីស្តកម្ពុជាថ្នាក់មូលដ្ឋាន បានយកប្រមាត់ទាំងនោះទៅបរិភោគទៀតផង។ មនុស្សពេញវ័យ និងកុមារត្រូវបានគេប្រហារជីវិតនៅទីតាំងទាំងនោះ ហើយកុមារត្រូវបានគេបោកផ្ទប់នឹងដើមឈើរហូតដល់ស្លាប់។ សាកសពអ្នកទោសទាំងអស់ត្រូវបានដាក់ចូលក្នុងរណ្តៅសាកសពរួមធំៗ ដែលមានទំហំខុសៗគ្នា ប៉ុន្តែមានទំហំប្រមាណ០២ ទៅ០៣ម៉ែត្រ គុណនឹង០៣ ទៅ០៥ម៉ែត្រ និងជម្រៅពី០១ម៉ែត្រ ទៅ០២ម៉ែត្រ។

៥១១- មានអ្នកទោសចំនួនប្រមាណ៥០០០នាក់ ត្រូវបានសម្លាប់ ដែលចំនួននេះត្រូវនឹងចំនួនដែលត្រូវបានកត់ត្រាទុកក្នុងស្ថិតិជាតិនៃស្រុកកណ្តាលស្ទឹង ដែលគេបានចងក្រងនៅចុងឆ្នាំ១៩៧៩។ ការជីកគាស់រណ្តៅ ដែលស្ថិតនៅចម្ងាយប្រមាណកន្លះគីឡូម៉ែត្រ ពីគុកសង់ បានរកឃើញបំណែកសាកសពមនុស្សចំនួន២០០០ ទៅ២៧៨០នាក់ ពីរណ្តៅសាកសពរួមចំនួន១១២ ហើយឆ្អឹងត្រូវបានយកទៅដាក់នៅក្នុងបូជនីយស្ថានមួយ។ រណ្តៅខ្លះតូចមានសាកសពអ្នកទោសតិច ប៉ុន្តែភាគច្រើននៃរណ្តៅដែលគេបានជីកគាស់ គឺជារណ្តៅធំៗដែលក្នុងរណ្តៅនីមួយៗ មានសាកសពអ្នកទោសចន្លោះ ពី២០នាក់ ទៅ ១០០នាក់។ នៅពេលដែលបូជនីយដ្ឋាននោះ ត្រូវការជួសជុលកែលម្អរ អដ្ឋិធាតុរបស់ អ្នកទោសត្រូវបានរើយកទៅដាក់នៅចេតិយថ្មី។ រណ្តៅសាកសពរួមដែលពុំទាន់ត្រូវ បានប៉ះពាល់ផ្សេងៗ នៅមិនទាន់ត្រូវបានជីកគាស់នៅឡើយទេ។

## មន្ទីរសន្តិសុខគោកក្តួច

## ទីតាំង និងប្រតិបត្តិការ

៥១២- មន្ទីរសន្តិសុខគោកក្ដួច ("គោកក្ដួច") ស្ថិតនៅភូមិកែងប្រាសាទ ឃុំសម្បូរ ស្រុកសម្បូរ ខេត្តក្រចេះ និងជាផ្នែកមួយនៃតំបន់៥០៥ កាលអំឡុងរយៈកាលសម័យខ្មែរក្រហម។ មន្ទីរនេះបានបើកប្រតិបត្តិការឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងបានចាប់បើកប្រតិបត្តិការតាំងពីដើមឆ្នាំ១៩៧០មកម្ល៉េះ។

៥១៣- គោកក្ដួច គឺជាមន្ទីរសន្តិសុខធំមួយដែលក្នុងនោះមានមន្ទីរជាច្រើន ដូចជាទីតាំងធំនៅគុកក្ដួច គុកនារីស្រែត្នោត ទីស្នាក់ការអាហារនៃមន្ទីរសន្តិសុខស្រុកកោះសំតួច និងជំរំការងារ ប្រាស្រាល និងត្រាច។ គោកក្ដួចស្ថិតនៅលើផ្ទៃដី៥០ម៉ែត្រការ៉េនៅលើទួលមួយចម្ងាយមួយគីឡូម៉ែត្រកន្លះ ពីទន្លេមេគង្គចន្លោះតំបន់សម្បូរ និងក្រចេះ។ ទីតាំងធំមានអគារធំចំនួនពី០១ ទៅ០៣អគារសម្រាប់ដាក់អ្នកទោស និងអគារតូចៗមួយចំនួន មានដូចជាផ្ទះឆ្មាំ រោងជាង ឃ្លាំង និងផ្ទះបាយ។ ទីតាំងនេះជាគុក មន្ទីរសួរចម្លើយ និងកន្លែងប្រហារជីវិត និងជាទីស្នាក់ការរបស់មន្ទីរចំណុះ។ អ្នកទោសត្រូវបានសួរចម្លើយនៅគោកក្ដួច និងត្រូវបានផ្ទេររវាងមន្ទីរចំណុះទាំងអស់នេះ។ ការផ្ទេរអ្នកទោសបានកើតមានរវាងមន្ទីរចំណុះទាំងអស់នេះ អាស្រ័យទៅតាមភាពធ្ងន់ធ្ងរនៃទោសរបស់អ្នកទោសដែលត្រូវបានចោទប្រកាន់ ហើយការផ្ទេរអ្នកទោស គឺដើម្បីទុកកន្លែងដាក់អ្នកទោសសម្រាប់កន្លែងនីមួយៗ ដើម្បីយកអ្នកទោសទៅធ្វើការងារ សួរចម្លើយ ឬយកទៅប្រហារជីវិតនៅគោកក្ដួច។

៥១៤- ប្រាស្រាល មានអគារពីមួយ ទៅបីអគារសម្រាប់ដាក់អ្នកទោស និងមានខ្ទមតូចៗជាច្រើនសម្រាប់ក្រុមគ្រួសារអ្នកទោស។ កោះសំតួចស្ថិតនៅកោះមួយដែលមានទំហំ៨០០ម៉ែត្រ គុណ

នឹង៥០០ម៉ែត្រ តាមបណ្តោយទន្លេមេគង្គ និងមានអគារតូចចំនួន០២ សម្រាប់ឆ្មាំស្នាក់នៅ និងដាក់អ្នកទោស។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើមន្ទីរសន្តិសុខនេះ

៥១៥- គោកក្តួច ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ [redacted] និងជាផ្នែកមួយ នៃកងសន្តិសុខ ៣២។ ឈ្មោះ ឈឹម យូង *ហៅ* ចែត ជាលេខាស្រុកសម្បូរពីឆ្នាំ១៩៧១ មកទល់ឆ្នាំ១៩៧៦ ដែលជាពេលគាត់ត្រូវគេចាប់ខ្លួន ឬបាត់ខ្លួន។ ឈ្មោះ នី ជាប្រធាន សន្តិសុខស្រុក ហើយឈ្មោះ អ៊ុំង សាម៉ុន ជាអនុប្រធានរបស់គាត់។ ពីឆ្នាំ១៩៧៦ ដល់ដើមឆ្នាំ១៩៧៨ ឈ្មោះ នី ជាលេខាស្រុក ឈ្មោះ អឿន ជាប្រធានសន្តិសុខស្រុក ហើយមនុស្សទាំងពីរនាក់នេះ ត្រូវបានចាប់ខ្លួននៅដើមឆ្នាំ១៩៧៨ ដែលជាផ្នែកមួយនៃ ការបោសសម្អាតទ្រង់ទ្រាយធំនៅតំបន់ ៥០៥។ [redacted]

[redacted]

៥១៦- ស្រុកសម្បូរ គឺជាផ្នែកមួយនៃតំបន់៥០៥ ដែលជាតំបន់ស្វយ័ត និងដែលជាអ្នករាយការណ៍ផ្ទាល់ជូន មជ្ឈិមបក្ស។ មុនឆ្នាំ១៩៧៦ លេខាតំបន់៥០៥ ឈ្មោះ [redacted] ហើយចាប់ពីឆ្នាំ ១៩៧៦ ដល់ខែមីនា ឆ្នាំ១៩៧៨ លេខាតំបន់នេះឈ្មោះ ប៊ិន ណាន *ហៅ* យី។ នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ឈ្មោះ យី និងកម្មាភិបាលស្រុក និងតំបន់ផ្សេងៗ ដូចជា អនុលេខាតំបន់ ឈ្មោះ សាន់ ប៊ុនហ៊ី *ហៅ* គួន និងប្រធាន សន្តិសុខតំបន់ឈ្មោះ បាន សារឿន *ហៅ* កង ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ ដែលនេះជាផ្នែកមួយនៃការបោសសម្អាតតំបន់៥០៥។ (កម្មាភិបាលមូលដ្ឋានផ្សេងៗដែល ត្រូវបានបោសសម្អាត ត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខតំបន់ នៅទីរួមខេត្តក្រចេះ ឬប-៣ ដែលជាមន្ទីរសន្តិសុខមួយសម្រាប់ឃុំឃាំងអ្នកទោសកម្មាភិបាលពីពាក់កណ្តាលឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨)។ កម្មាភិបាលមកពីភូមិភាគនិរតីឈ្មោះ [redacted] បានចូលមកជំនួសឈ្មោះ យី ក្នុងតួនាទីជាលេខាតំបន់។ [redacted]

**របទនាសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ**

៥១៧- ថ្នាក់ដឹកនាំគុកគោកក្ដួច និងមន្ទីរក្រោមចំណុះរបស់ខ្លួនតែងតែផ្លាស់វេនគ្នាជាញឹកញាប់។ មនុស្សសំខាន់ៗដែលធ្លាប់ជាប្រធានមន្ទីរសន្តិសុខគោកក្ដួចដែលគេបានស្គាល់ នាអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យមានដូចជាឈ្មោះ [redacted]។

៥១៨- [redacted] កម្មាភិបាលឈានមុខនៅគោកក្ដួចជាអ្នកត្រួតត្រាមើលមន្ទីរចំណុះទាំងនេះ តាមរយៈការចុះពិនិត្យមើល និងទទួលរបាយការណ៍ដែលត្រូវបានរក្សាទុកនៅឯមន្ទីរធំ។

៥១៩- នៅគុកគោកក្ដួចមានឆ្មាំចំនួនពី១០ ទៅ១២នាក់ នៅប្រាស្រោល មានឆ្មាំចំនួន១៥នាក់ នៅកោះសំតួច មានឆ្មាំចំនួនពី៣ ទៅ៦នាក់។

**ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា**

៥២០- ជាញឹកញាប់ [redacted] តែងតែចុះមកពិនិត្យគុកគោកក្ដួច និងមន្ទីរក្រោមចំណុះដើម្បីពិនិត្យមើលបុគ្គលិក និងព្រមានអំពីការលួចរត់របស់អ្នកទោស និងខ្មាំងខាងក្នុង និងដើម្បីចូលរួមក្នុងការសួរចម្លើយ។

[redacted]

[redacted]

[redacted] មន្ទីរសន្តិសុខនេះជាអ្នកបញ្ជូនរបាយការណ៍ប្រចាំខែជូន[redacted] ក្នុងនោះមាន បច្ចុប្បន្នភាពស្តីពីឆ្មាំ និងអ្នកទោស ការខ្វះការផ្គត់ផ្គង់ និងការរាយការណ៍អំពី "សកម្មភាពតាមដានខ្មាំង" និងរាយការណ៍"ជាបន្ទាន់" អំពីបញ្ហាដែលមានសារសំខាន់ចាំបាច់។ សំណៅដើមនៃចម្លើយសារភាពត្រូវបានផ្ញើទៅកាន់មន្ទីរស្រុក។

៥២១- ទស្សនាវដ្តី *ទង់បដិវត្ត* ត្រូវបាន[redacted]ចែកចាយទៅឱ្យឃុំយកទៅរៀនសូត្រ និងអនុវត្តតាម។ ដូចការពន្យល់របស់[redacted] ប្រសិនបើគេអនុវត្តតាមខ្លឹមសារនៃឯកសារបោះពុម្ពផ្សាយទាំងនោះ "មនុស្សជាច្រើននឹងត្រូវសម្លាប់ ពីព្រោះគោលការណ៍ណែនាំ នៅក្នុងទស្សនាវដ្តីនោះត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់មុតមាំ ហើយប្រសិនបើបុគ្គលណាពុំសម្របខ្លួនទៅតាមគោលការណ៍ទាំងនោះទេ ពេលនោះបុគ្គលនោះ នឹងត្រូវបានចាត់ទុកថាជាខ្មាំងជាស្វ័យប្រវត្តិ"។

៥២២- [redacted]បានចូលរួមប្រជុំនៅ[redacted]ចំនួន០២លើកក្នុងមួយខែ ដើម្បីរាយការណ៍អំពីបញ្ហាស្បៀង សុខភាព និងសន្តិសុខ។ ក្នុងអង្គប្រជុំ គេសម្រេចអំពី "មនុស្សណាដែលត្រូវសម្លាប់ និងអ្នកដែលមិនត្រូវសម្លាប់"។

៥២៣- [redacted]។ នួន ជា គឺជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

របស់មជ្ឈិមបក្សទទួលបន្ទុកតំបន់៥០៥ និងតែងតែបានចុះមកពិនិត្យតំបន់នេះ។ [redacted] ជាអ្នកទទួលសំបុត្រដែល ប៉ុល ពត ឬ នួន ជា ផ្ញើមកពីមន្ទីរ៨៧០។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៥២៤- ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាជនជាតិវៀតណាម ជនក្បត់ក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងមនុស្ស“ខុសសីលធម៌” ត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅឯគុកគោកក្ដួច និងមន្ទីរឃុំឃាំងពាក់ព័ន្ធ។ នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ចំនួនអ្នកទោសនៅក្នុងគុកនេះប្រែប្រួលទៅតាមពេលវេលា។ នៅឆ្នាំ១៩៧៦ មានអ្នកទោសចំនួន១០០នាក់។ នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មានអ្នកទោសចំនួនចន្លោះពី១០០ ដល់៣០០នាក់ ក្នុងនោះអ្នកទោសធ្ងន់មានចំនួន៥០នាក់។ នៅចុងឆ្នាំ១៩៧៨ អ្នកទោសមានចំនួន២៥០នាក់ ហើយនៅក្នុងរយៈកាលមុនពេលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដួលរលំមានទាហានភូមិភាគបូព៌ាចំនួន៥០នាក់។

គុកប្រាស្រាល បានដាក់អ្នកទោសចំនួនចន្លោះពី៥០ ទៅ២០០នាក់។ កោះសំតួចបានដាក់អ្នកទោសស្រាលចំនួនពី១២ ទៅ៣០នាក់ ឬអ្នកទោសធ្ងន់ចំនួនពី៥០ ទៅ៦០នាក់។ អ្នកទោសថ្មីត្រូវបាននាំមកដល់គុកគោកក្ដួចមួយក្រុម ឬពីរក្រុម ជារៀងរាល់២ ទៅ៣ថ្ងៃម្ដង។ ក្រោយឆ្នាំ១៩៧៧ ជារៀងរាល់ថ្ងៃ គេបាននាំអ្នកទោសដែលត្រូវបានចោទប្រកាន់ពីបទឃុបឃិតជាមួយវៀតណាម មកកាន់គុកគោកក្ដួច។ ជួនកាល ជនជាតិភាគតិចត្រូវបានចាប់ខ្លួនជាទ្រង់ទ្រាយធំ ពីបទប្រឆាំងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

៥២៥- នៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មនុស្សជាប់ឃុំឃាំងនៅគុកគោកក្ដួចរួមមាន កម្មាភិបាលដែលត្រូវបោសសម្អាតមកពីស្រុកសម្បូរ ទាហានភូមិភាគបូព៌ា និងទាហានតំបន់៥០៥ ដែលត្រូវបានចាប់

ខ្លួននៅចុងឆ្នាំ១៩៧៨ មនុស្សដែលជាប់ចោទពីបទធ្វើសកម្មភាពប្រឆាំងនឹងបក្ស អ្នកភូមិដែលបានរត់គេចខ្លួនពីការសម្រុកចូលរបស់ទ័ពវៀតណាម ជនជាតិភាគតិចមានដូចជា ភ្នង គ្រោល និងខ្លួណ ជាតិពន្ធុវៀតណាមរស់នៅកម្ពុជា មនុស្សទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងបណ្ដាញក្បត់ដូចជា អ្នកភូមិសម្បូរភាគច្រើន មនុស្សទាំងឡាយណា ដែលមានចំណងគ្រួសារជាមួយវៀតណាម មនុស្សដែលជាប់ចោទពីបទខុសសីលធម៌ មនុស្សដែលគេបានចោទថាបានហូបអាហារ ឬលួចហូបអាហារដែលគេហាមឃាត់ មនុស្សដែលជាប់ចោទពីបទបំផ្លាញទ្រព្យសម្បត្តិរបស់សហករណ៍ មនុស្សដែលជាប់ចោទពីបទខ្ជិលច្រអូស សមាជិកក្រុមគ្រួសាររបស់អ្នកទោសនៅគុកគោកក្ដួច ប្រជាជនថ្មីមកពីភ្នំពេញ និងក្រចេះ និងខ្មែរស។

៥២៦- អ្នកទោសត្រូវបានចាប់ខ្លួនដោយប្រធានសហករណ៍ កងសន្តិសុខគោកក្ដួច ឬត្រូវបានប្រាប់ឲ្យរាយការណ៍ជូនគោកក្ដួច។ ការចាប់ខ្លួនដោយប្រធានសហករណ៍ និងបុគ្គលិកគុកគោកក្ដួចត្រូវបានធ្វើឡើងតាមបញ្ជារបស់ថ្នាក់ស្រុក ឬតំបន់។ ប្រធានសហករណ៍បានជួបប្រជុំជាមួយកម្មាភិបាលស្រុកជាមុន ដើម្បីទទួលការណែនាំមុនពេលមានការចាប់ខ្លួន។ អ្នកទោសត្រូវគេនាំខ្លួនយកមកបង្ហាញកម្មាភិបាលគុកគោកក្ដួច ជាមួយនឹងលិខិតចោទប្រកាន់របស់ប្រធានសហករណ៍ដែលមានបញ្ជាក់ថាឲ្យសួរចម្លើយ និងលត់ដំអ្នកទោសរូបនោះ។ សំបុត្រដើមត្រូវបានផ្ញើទៅឲ្យមន្ទីរស្រុក ហើយមួយច្បាប់ទៀតត្រូវបានទុកនៅគោកក្ដួច។

៥២៧- ឃុំបានផ្ញើរបាយការណ៍ជូនស្រុក ហើយស្រុកជាអ្នករាយការណ៍ជូនថ្នាក់តំបន់។ មន្ទីរស្រុកបើកអង្គប្រជុំជាទៀងរាល់សប្ដាហ៍ជាមួយប្រធានឃុំដើម្បីពិភាក្សាអំពីសភាពការណ៍ខ្មាំង ការ

បង្កបង្កើនផល និងសុខភាពរបស់ប្រជាជន ហើយក្នុងអង្គប្រជុំ ប្រធានឃុំជាអ្នករាយការណ៍អំពីមនុស្សណា "ដែលធ្វើសកម្មភាពប្រឆាំងបដិវត្តន៍" និងមានការឯកភាពលើ "លិខិតចោទប្រកាន់" ដែលតម្រូវឱ្យមានការស្តួរចម្លើយ និងការលត់ដំមនុស្សនោះ។ មនុស្សដែលត្រូវបានឃុំកំណត់អត្តសញ្ញាណត្រូវបានសេនាជនឃុំ ឬស្រុក ចាប់ខ្លួនជាបន្តបន្ទាប់។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៥២៨- លើអ្នកទោសនៅគោកក្តួច អាស្រ័យទៅតាមប្រភេទទោសធ្ងន់ ឬស្រាល ប៉ុន្តែអ្នកទោសទាំងអស់សុទ្ធតែបានទទួលរងស្ថានភាពអមនុស្សធម៌ដូចគ្នា។ នៅពេលអ្នកទោសមកដល់ អ្នកទោសទាំងអស់ត្រូវបានគេដាក់ខ្នោះដៃ និងខ្នោះជើងភ្ជាប់គ្នាទៅវិញទៅមក។ ទោះបីជាអ្នកទោសស្រាលត្រូវបានគេដោះខ្នោះចេញខ្លះៗក្តី ក៏អ្នកទោសធ្ងន់ត្រូវបានគេដាក់ខ្នោះដៃខ្នោះជើងជាប់ជាប្រចាំ ទាំងពេលហូបអាហារ និងត្រូវបានដោះលែងដើម្បីប្រើប្រាស់ បង្គន់រណ្តៅតែប៉ុណ្ណោះ។ អ្នកទោសធ្ងន់ត្រូវបានដាក់ខ្នោះជើងជាពីរជួរ ដោយជើងឱ្យ ប៉ះគ្នា។ អ្នកទោសស្រាលខ្លះត្រូវបានគេបញ្ជាឱ្យសង់កន្លែងជ្រកផ្ទាល់ខ្លួន ឬដេកក្នុងជង្រុកស្រូវរបស់មន្ទីរគោកក្តួច។

៥២៩- អ្នកទោសត្រូវបានគេផ្តល់បបរ ឬជួនកាលផ្តល់បាយ។ អ្នកទោសពុំត្រូវបានអនុញ្ញាតឱ្យដើររកចំណីអាហារឡើយ ហើយមនុស្សដែលបានលបលួចអាហារ ត្រូវបានដាក់ខ្នោះជើងរហូតដល់ ០៣ថ្ងៃ។ អ្នកទោសពុំអាចងូតទឹកបានឡើយ។ គ្មានវិធីត្រឹមត្រូវសម្រាប់ការប្រព្រឹត្ត

មកលើអ្នកទោសនៅគុកគោកក្ដួចឡើយ។ នៅពេលអ្នកទោសឈឺធ្ងន់ គេផ្ដល់ថ្នាំបុរាណឱ្យអ្នកទោស។ អ្នកទោសដែលធ្វើការត្រូវបានគេផ្ដល់ថ្នាំសង្កូវ និងស្វែងរកថ្នាំបុរាណនៅពេលកំពុងធ្វើការងារ។ ជំងឺគ្រុនចាញ់ និងរាគរូសកើតមានជាទូទៅ និងបានធ្វើឱ្យអ្នកទោសស្លាប់ ដូចជាការខ្វះជីវជាតិដែរ។

៥៣០- នៅការដ្ឋានប្រាស្រាល អ្នកទោសប្រុសត្រូវបានគេដាក់ខ្នោះជើង និងដៃ ជាពីរជួរនៅពេលយប់។ ក្រុមគ្រួសារអ្នកទោសត្រូវបានអនុញ្ញាតឱ្យរស់នៅជុំគ្នា ប៉ុន្តែត្រូវសាងសង់កន្លែងស្នាក់នៅដោយខ្លួនឯង។ អាហារមូលដ្ឋាននៅប្រាស្រាល គឺបបរ។ អ្នកទោសគ្មានអាហារបរិភោគគ្រប់គ្រាន់ហើយបានអត់ឃ្លានរហូតដល់ស្លាប់។ អ្នកទោសដែលបានដើរស្វែងរកអាហារ ឬយកអាហារបរិភោគបន្ថែមត្រូវបានគេវាយដំ ឬដាក់ខ្នោះចំនួន០៣ថ្ងៃ។ ជាមួយគ្នានេះផងដែរ អ្នកទោសបានទទួលរងទណ្ឌកម្មចំពោះការពុំបានគោរពបុគ្គលិកគុកឱ្យបានត្រឹមត្រូវ។ អ្នកទោសពុំបានទទួលការព្យាបាលវេជ្ជសាស្ត្រ ឬថ្នាំសង្កូវឡើយ។ ការស្លាប់ដោយសារជំងឺផ្សេងៗ ដូចជាជំងឺគ្រុនចាញ់កើតមានជាទូទៅ។

៥៣១- នៅកោះសំតូច អ្នកទោសធ្ងន់ត្រូវបានដាក់ខ្នោះជើងរួមគ្នានៅពេលយប់ និងអាចនៅពេលថ្ងៃផងដែរ។ អ្នកទោសស្រាលពុំជាប់ខ្នោះជើងទេ។ អ្នកទោសទទួលបបរពីរពេលក្នុងមួយថ្ងៃ។ ពេលបន្ទោរបង់ អ្នកទោសធ្ងន់ត្រូវគេដោះខ្នោះចេញ។ គ្មានពេទ្យទេ ហើយគេបានផ្ដល់ថ្នាំឫសឈើដល់អ្នកទោសឈឺ។ ដូច្នេះ អ្នកទោសនៅគុកកោះសំតូចតែងតែបានស្លាប់ជាទៀងទាត់ដោយសារស្ថានភាពអស់ទាំងនេះ។

## ពលកម្មដោយបង្ខំ

៥៣២- អ្នកទោសទាំងអស់នៅគោកក្តួច និងការដ្ឋានពាក់ព័ន្ធ និងមន្ទីរឃុំឃាំង ត្រូវធ្វើការងារដោយដៃដ៏សែនយ៉ាប់យ៉ឺន។ នៅគោកក្តួច អ្នកទោសត្រូវធ្វើស្រែចម្ការ កាប់គាស់ដី និងជាន់រហាត់ទឹកស្រោចទឹកដាក់ស្រែ។ វេនធ្វើការចាប់ផ្តើមពីពេលម៉ោង០៤ទៀបភ្លឺ រហូតដល់យ៉ាងហោចណាស់ដល់ពេលថ្ងៃត្រង់ ហើយចាប់បន្តពីម៉ោង០១រសៀល ដល់ពេលព្រលប់ ឬយប់ក៏មាន។ គ្មានការសម្រាកក្នុងម៉ោងការងារទេ ហើយអ្នកទោសបានស្លាប់ដោយសារការធ្វើការងារច្រើន និងបាក់កម្លាំង។

៥៣៣- នៅ ប្រាស្រាល អ្នកទោសត្រូវធ្វើស្រែចម្ការ កាប់គាស់ដី លើកទំនប់ និងជីកប្រឡាយ។ វេនធ្វើការចាប់ផ្តើមពីម៉ោង៣ទៀបភ្លឺ រហូតដល់យ៉ាងហោចណាស់ពេលថ្ងៃត្រង់ និងចាប់បន្តពីម៉ោង០១រសៀល ដល់ព្រលប់ ឬយប់ក៏មាន។ អ្នកដែលពុំបានមកធ្វើការត្រូវបានកាត់បន្ថយរបបអាហារចំនួន២៥ និង៥០ភាគរយ ចំពោះការខកខានពុំបានមកធ្វើការចំនួន០២ថ្ងៃ។ អ្នកទោសបានស្លាប់ដោយសារការធ្វើការងារច្រើន និងការបាក់កម្លាំង។ បន្ទាប់ពីមានហេតុការណ៍មួយ អ្នកទោសត្រូវបានប្រមូលផ្តុំ និងគំរាមសម្លាប់ចំពោះការប្រឆាំងរដ្ឋអំណាច ឬការបែកបាក់សាមគ្គី។

៥៣៤- នៅកោះសំតួច អ្នកទោសត្រូវធ្វើស្រែចម្ការ កិនស្រូវ បោកស្រូវ កាប់គាស់ដី ធ្វើអង្រុតត្រី និងលើកទំនប់។ វេនធ្វើការចាប់ផ្តើមពីម៉ោង៣ទៀបភ្លឺរហូតដល់យ៉ាងហោចណាស់ថ្ងៃត្រង់ និងចាប់បន្តពីម៉ោងមួយរសៀល រហូតដល់ព្រលប់ ឬជួនកាលដល់យប់។

## ការសួរចម្លើយ និងការធ្វើទារុណកម្ម

៥៣៥- អ្នកទោសត្រូវបានសួរចម្លើយអស់ពេលយ៉ាងយូរ និងទទួលរងទារុណកម្មដ៏ព្រៃផ្សៃនៅគោកក្តួច នៅប្រាស្រាល នៅកោះសំត្ងច និងនៅអាហារ។ គោលបំណងនៃការសួរចម្លើយ និងការធ្វើទារុណកម្មគឺដើម្បីយកប្រវត្តិរូបអ្នកទោស និងចំណងពាក់ព័ន្ធរបស់ពួកគេជាមួយបណ្តាញវៀតណាម និងបទឧក្រិដ្ឋមួយចំនួនដូចជា ការជួយទំនុកបម្រុងវៀតណាម អំពើខុសសីលធម៌ ការបំផ្លិចបំផ្លាញ ទ្រព្យសម្បត្តិសហករណ៍ និងការវាយប្រហារ មកលើកម្មាភិបាល មូលដ្ឋាន។ វិធីសាស្ត្រមួយចំនួនក្នុងការធ្វើទារុណកម្មមានដូចជា ការវាយនឹងរំពាត់ផ្តៅ ការឆក់នឹងខ្សែភ្លើង ការវាយដៃ និងជើង និង/ឬការទាត់ធាក់។ អ្នកទោសខ្លះត្រូវគេវាយដំ នឹងកាំភ្លើង។ អ្នកទោសខ្លះបានរងការធ្វើទារុណកម្មរហូតដល់សន្លប់បាត់ស្មារតី ឬលេចអាចម៍លេចនោមដាក់ខោ។ អ្នកទោសស្រាលដែលព្រមឆ្លើយសារភាពពុំជាប់ ខ្នោះជើងទេ។ អ្នកទោសដែលពុំព្រមឆ្លើយសារភាពត្រូវបានគេគំរាមសម្លាប់។

៥៣៦- បន្ទាប់ពីមកដល់គុកគោកក្តួចបានរយៈពេល០៤ថ្ងៃ គេចាប់ផ្តើមសួរចម្លើយអ្នកទោស។ អ្នកទោសស្រាល ត្រូវបានសួរចម្លើយចំនួន១០ដងក្នុងមួយខែ ដោយមានអ្នកសួរចម្លើយផ្លាស់គ្នា។ ការសួរចម្លើយមានរយៈពេលមួយម៉ោងកន្លះ។ ជារឿយៗ ការសួរចម្លើយ និងការធ្វើទារុណកម្មតែងតែត្រូវបានធ្វើឡើងដោយកម្មាភិបាលគុកគោកក្តួច រួមទាំងប្រធានគុក។ អ្នកសួរចម្លើយតែងតែស្ពាយកាំភ្លើងជាប់ខ្លួន។ អ្នកទោសនៅគោកក្តួចត្រូវបានសួរចម្លើយនៅក្នុងការិយាល័យរបស់ឆ្មាំ ឬក្នុងបរិវេណគុកផ្ទាល់។ ជួនកាល អ្នកទោសត្រូវបានគេនាំទៅកាន់គុកអាហារនៅពេលយប់ ហើយពេលត្រឡប់មកវិញអ្នកទោសមានប្រឡាក់ឈាម និងស្នាមវាយដំជាប់ខ្លួន។

នៅ ប្រាស្រាល ឈ្មោះ ម៉េង អាន ជាអ្នកសួរចម្លើយ និងកត់ត្រាចម្លើយអ្នកទោស។ អ្នកទោសនៅគុកកោះសំតួចក៏ត្រូវបានគេសួរចម្លើយដែរ។

៥៣៧- ការសួរចម្លើយត្រូវបានថត និងកត់ត្រាទុកជាឯកសារ។ កំណត់ត្រាទាំងអស់ដែលអ្នកសួរចម្លើយបានកត់ទុកត្រូវបានផ្ញើទៅ [redacted] ដូចចម្លើយសារភាពជាលាយលក្ខណ៍អក្សររបស់អ្នកទោសដែរ។ ក្នុងករណីខ្លះ ចម្លើយសារភាពត្រូវបានផ្ញើទៅកាន់ [redacted]។ ចម្លើយសារភាពមួយច្បាប់ទៀតត្រូវបានរក្សាទុកនៅគោកក្ដួច។ ការសួរចម្លើយនៅគោកក្ដួចត្រូវបានធ្វើឡើងដោយបុគ្គលិក និងអ្នកត្រួតពិនិត្យមានដូចជា [redacted] ក៏ជាអ្នកធ្វើទារុណកម្មអ្នកទោសផងដែរ។

## ការសម្លាប់មនុស្សក្រៅច្បាប់

៥៣៨- [redacted] មានវត្តមាននៅពេលមានការនាំខ្លួន ឬការប្រហារជីវិតអ្នកទោសធ្ងន់នៅគុកគោកក្ដួច។ [redacted]។ ក្នុងមួយខែ អ្នកទោសជាក្រុមតូចៗ ដែលមានគ្នាចំនួនពី២ ទៅ៥នាក់ ត្រូវបានគេយកចេញចំនួន៤លើក ចំណែកអ្នកទោសជាក្រុមធំៗដែលមានគ្នាពី១០ ទៅ១៥នាក់ ពុំសូវត្រូវបានគេយកចេញញឹកញាប់ទេ។ មានរណ្ដៅកប់សាកសពចំនួន៣នៅក្នុងបរិវេណគុកគោកក្ដួច ដែលរណ្ដៅនីមួយៗមានទំហំប្រមាណ២ម៉ែត្រគុណនឹង៥ម៉ែត្រ។ នៅពេលយប់អ្នកទោសមួយចំនួនត្រូវបានឡានដឹកយកទៅប្រហារជីវិត និងកប់នៅទីតាំងផ្សេងទៀត។

៥៣៩- អ្នកទោសនៅប្រាស្រោលត្រូវស្ថិតនៅក្រោមការសម្លាប់ដោយខុសច្បាប់។ ក្នុងរយៈពេលមួយឆ្នាំនៅប្រាស្រោលមានអ្នកទោសចំនួន៨៩នាក់បានស្លាប់ និងនៅឆ្នាំបន្តបន្ទាប់ចំនួននៃការស្លាប់បានកើនឡើង។ អ្នកទោសបានស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺ ការបាក់កម្លាំង ការធ្វើទារុណកម្ម និងការប្រហារជីវិត និងត្រូវបានកប់នៅក្នុងគុក ជុំវិញដើមអំពិល។ អ្នកទោសក៏ត្រូវបានគេយកចេញពីគុកកោះសំតួច និងសន្មតបានថាត្រូវបានគេសម្លាប់។

៥៤០- ចម្លើយសារភាពរបស់អ្នកទោសណាដែល"ពិបាកដោះស្រាយនៅថ្នាក់ស្រុក" ដូចជា ចម្លើយសារភាពរបស់"អ្នកទោសធ្ងន់" ដែល"ជាប់ចោទពីបទធ្វើសកម្មភាពប្រឆាំងបក្ស" ត្រូវបានបញ្ជូនទៅឲ្យតំបន់។ ជារឿយៗ អ្នកទោសទាំងនោះត្រូវបានកម្មាភិបាលស្រុក ឬតំបន់ នាំយកទៅប្រហារជីវិត ហើយកម្មាភិបាលខ្លះបានមកដល់គុកគោកក្ដួចដោយមានបញ្ជីប្រហារជីវិតមកជាមួយផង។

## មន្ទីរសន្តិសុខភ្នំក្រោល

## ទីតាំង និងប្រតិបត្តិការ

៥៤១- មន្ទីរសន្តិសុខភ្នំក្រោល ("ភ្នំក្រោល") ស្ថិតក្នុងឃុំ ស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី និងជាផ្នែកមួយនៃតំបន់១០៥ភូមិភាគឦសានកាលអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ។ ភ្នំក្រោលបានចាប់បើកប្រតិបត្តិការនៅចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

៥៤២- មន្ទីរសន្តិសុខភ្នំក្រោលអាចដាក់អ្នកទោសបានចំនួនរាប់រយនាក់ក្នុងមួយលើក។ មន្ទីរនេះស្ថិតនៅក្នុងបន្ទាយកងវរៈសេនាតូចលេខ ២ ក្បែរទំនប់ភ្នំក្រោល និងមានអគារឃុំឃាំងមួយដែលមាន

វនាបឫស្សី គ្មានជញ្ជាំង សសរឈើ និងដំបូលប្រក់ស្បូវ។ មន្ទីរសន្តិសុខទីពីរឈ្មោះមន្ទីរក-១១ ស្ថិតនៅចម្ងាយមិនដល់មួយគីឡូម៉ែត្រពីភ្នំក្រោល ក្នុងមន្ទីរយោធាតំបន់ ១០៥។ ជាសំខាន់ មន្ទីរក-១១ ត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរឃុំឃាំងបណ្ដោះអាសន្ន សម្រាប់បញ្ជូនអ្នកទោសបន្ត ទៅភ្នំក្រោល ការដ្ឋានលត់ដំ ឬជូនកាលទៅមន្ទីរ ស-២១។

## វចនាសម្ពន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៥៤៣- មន្ទីរក-១១ និងភ្នំក្រោល គឺជាមន្ទីរសន្តិសុខថ្នាក់តំបន់ដែលជាអ្នករាយការណ៍ជូនលេខាតំបន់ ១០៥។ តា ហម *ហៅ* ឡាំង បានធ្វើជាលេខាតំបន់នេះរហូតដល់ខែតុលា ឆ្នាំ១៩៧៧ នៅពេលដែលគាត់ត្រូវបានសម្លាប់នៅភ្នំពេញបន្ទាប់ពី នួន ជា បានហៅគាត់ឱ្យទៅប្រជុំបន្ទាន់។ អ្នកដែលបានចូលមកជំនួសតំណែងរបស់ឈ្មោះ ឡាំង គឺ [redacted]។

## វចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ

៥៤៤- ប្រធានយោធាតំបន់១០៥ ឈ្មោះ ហួត កែ *ហៅ* សុភា ជាមេបញ្ជាការកងវរៈសេនាតូចចំនួន២ ទទួលបន្ទុកកិច្ចការសន្តិសុខតំបន់ និងជាប្រធានមន្ទីរក-១១។ [redacted] គឺជាអ្នកត្រួតពិនិត្យមន្ទីរសន្តិសុខក-១១ តាមរយៈការចូលរួមក្នុងការសួរចម្លើយ និងការចាប់ខ្លួន។ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ តា សុភា ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរស-២១

បន្ទាប់ពីគាត់បានចូលប្រជុំជាមួយ ប៉ុល ពត **នួន ជា** និងសុន សេន ដែលក្នុងអង្គប្រជុំ គាត់ត្រូវបានគេស្នើឱ្យស្នាក់នៅភ្នំពេញ ដើម្បី“ធ្វើកិច្ចការឃោធា”។

៥៤៥- មេបញ្ជាការកងវរៈសេនាតូចលេខ២ ឈ្មោះ ខ្វេន ង៉ុក *ហៅ* ឡេង ជាអ្នកត្រួតពិនិត្យមើលទំនប់ភ្នំក្រោល និងធ្វើរបាយការណ៍ជូន តា សុភា។ មេបញ្ជាការកងវរៈសេនាតូចលេខ១ [redacted]។ អនុប្រធានរបស់ តា ឡេង ឈ្មោះ [redacted] ហើយសមាជិកឈ្មោះ [redacted]។ នៅពេល តា ឡេង ត្រូវគេចាប់ខ្លួន និងបាត់ខ្លួន នៅដើមឆ្នាំ១៩៧៨ [redacted] បានក្លាយខ្លួនជាមេបញ្ជាការកងវរៈសេនាតូចលេខ២ និងជាប្រធានមន្ទីរសន្តិសុខភ្នំក្រោល។ [redacted] គឺជាប្រធានកងអនុសេនាធំនៃកងវរៈសេនាតូចលេខ២ ក្រោមបញ្ជារបស់ តា ឡេង និង ម៉ាំង ដែលឈរជើងនៅមន្ទីរសន្តិសុខភ្នំក្រោល។

**ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា**

៥៤៦- ចំពោះបញ្ហាសន្តិសុខ មន្ទីរតំបន់១០៥ ជាអ្នករាយការណ៍ផ្ទាល់ឱ្យ **នួន ជា** និងមជ្ឈិមបក្ស និងបានទទួលឱវាទណែនាំពី **នួន ជា** និងប៉ុល ពត។ ការណែនាំរបស់មជ្ឈិមបក្សបានប្រាប់កម្មាភិបាលតំបន់១០៥ អំពី“ខ្មាំងបង្កប់” និង“ជនក្បត់” ដែលត្រូវតាមដាន និងចាប់ខ្លួន។ មេដឹកនាំតំបន់ ជាអ្នកធ្វើដំណើរទៅប្រជុំជាមួយមជ្ឈិមបក្សនៅភ្នំពេញ និងបើកអង្គប្រជុំប្រចាំខែជាមួយគណៈស្រុក និងគណៈឃោធាតំបន់ ដើម្បីផ្សព្វផ្សាយការណែនាំពីមជ្ឈិមបក្សដូចជា [redacted]។

៥៤៧- [redacted] ជាអ្នកធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ និងសារទូរលេខ ជាទៀងទាត់ជូនមន្ទីរ៨៧០ ពាក់ព័ន្ធនឹងបញ្ហាទូទៅ និងបញ្ហាសន្តិសុខមួយចំនួន

ពាក់ព័ន្ធនឹងខ្មាំងខាងក្នុង។ [redacted] គឺជាអ្នកទទួលរបាយការណ៍ពីមន្ទីរស្រុកស្ដីពីបញ្ហាការលើកទំនប់ ការបង្កបង្កើនផល សុខាភិបាល "សមាសភាពល្អ ឬមិនល្អ" និងសមាសភាព"ក្បត់"។ [redacted] ជាអ្នកផ្ដល់ឱវាទណែនាំទៅឱ្យស្រុក និងយកព័ត៌មានទាំងនេះដាក់បញ្ចូលក្នុង"របាយការណ៍ការងារស្រុក" រួចផ្ញើជូនមជ្ឈិមបក្សជាប្រចាំថ្ងៃ។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៥៤៨- មន្ទីរសន្ដិសុខភ្នំក្រោលបានចាប់ខ្លួន និងឃុំឃាំងខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ ពិសេសកម្មាភិបាលដែលត្រូវបោសសម្អាត។ ចំនួនអ្នកទោសដែលជាប់នៅគុកភ្នំក្រោលមានចំនួនចាប់ពី ៨០នាក់ ដល់៣៨៥នាក់ ទៅតាមពេលវេលា។ ជាពិសេសក្នុងអំឡុងពេលបោសសម្អាតកម្មាភិបាលកងពលធំលេខ៩២០ ចំនួនអ្នកជាប់ឃុំនៅគុកភ្នំក្រោលមានការកើនឡើង។ ជាក់ស្ដែង ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៧ ដល់ខែមេសា ឆ្នាំ១៩៧៨ "អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងគុកនោះមានចំនួន៣៨៥នាក់ ភាគច្រើនជាទាហានមកពីកងពលធំលេខ៩២០"។ "ជាច្រើនលើក អ្នកទោសមកពីកងពលធំលេខ៩២០ "ត្រូវបានដឹកចូលគុកនេះនៅពេលព្រឹក" និង"ត្រូវគេនាំចេញទៅ"នៅពេលយប់។ ការចាប់ខ្លួនកម្មាភិបាលកងពលធំលេខ៩២០ ត្រូវបានលើកឡើងនៅក្នុងសារទូរលេខមួយចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ ពីលេខាតំបន់១០៥ [redacted] ទៅកាន់មន្ទីរ៨៧០ ដែលក្នុងសារទូរលេខនោះ គេបានរាយការណ៍ថា បើទោះបីតំបន់បានកំពុង"ចាប់ខ្លួនហើយ ចាប់ទៀត"នូវមនុស្សរបស់ "អង្គភាព៩២០"ក្ដី ក៏ខ្មាំង"នៅបន្តសកម្មភាពឥតឈប់ឈរ"។ ចំពោះសកម្មភាពខ្មាំងទាំង

អស់នេះ [redacted] បានទម្លាក់កំហុសទៅលើ"បក្សពួក" របស់"អា ឈិន" ដែលចង់សំដៅទៅដល់អតីតលេខាកងពលធំលេខ៩២០ ឈ្មោះ ម៉ែន ម៉េង *ហៅ* ឈិន ហើយឈ្មោះនេះត្រូវបានចាប់ខ្លួននៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៧។

៥៤៩- ការបោសសម្អាតកងទ័ពនៃកងពលធំលេខ៩២០ បានបន្តធ្វើរហូតដល់ខែមីនា ឆ្នាំ១៩៧៨ ហើយពេលនោះកងទ័ពនៃកងពលធំលេខ៩២០ចំនួនជាង៤០០នាក់ ត្រូវបានចាប់ខ្លួន ឃុំឃាំងនៅភ្នំក្រោលមួយរយៈពេលខ្លី និងបញ្ជូនទៅកាន់មន្ទីរស-២១។ អំឡុងពេលនោះ ប្រធានឃោឃាតំបន់១០៥ ឈ្មោះ តា សុភា បានទទួលចម្លើយសារភាពរបស់កងទ័ពនៃកងពលធំលេខ៩២០ពីមន្ទីរស-២១ [redacted]។

៥៥០- មន្ទីរក-១១ គឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន ដោយបានដាក់អ្នកទោសចំនួនពីម្ភៃ ទៅសាមសិបនាក់ប៉ុណ្ណោះ ហើយអ្នកទោសត្រូវបានដឹកចេញចូលទីនោះជារៀងរាល់ពី ២ ឬ៣ថ្ងៃម្តង។ ជាទូទៅ អ្នកជាប់ឃុំឃាំងនៅមន្ទីរក-១១ ណាដែលគេបានចាត់ទុកថាជាមនុស្សដែល "អាចកែប្រែបាន" ត្រូវបានគេបញ្ជូនទៅកាន់ការដ្ឋានលត់ដំមួយឈ្មោះ ណាង ឃីលឹក នៅពេលដែលមនុស្សណាដែលគេចាត់ទុកថាជា"អ្នកទោសធ្ងន់" ត្រូវគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខភ្នំក្រោល។ នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពីការស្លាប់របស់ឈ្មោះ ឡាំង អ្នកទោសខ្លះត្រូវបានឃុំឃាំងនៅមន្ទីរក-១៧ ដែលជាមន្ទីររបស់លេខាតំបន់ ហើយមន្ទីរនេះត្រូវបានគេពិពណ៌នាថាជាអគារ២ជាន់ ក្នុងនោះជាន់ទី២ សម្រាប់ដាក់អ្នកទោសដែលជាមនុស្សមានតួនាទីធំ។

៥៥១- អ្នកទោសដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរក-១១ និងនៅមន្ទីរសន្តិសុខភ្នំក្រោល មានដូចជា អតីតកងទ័ព ប៉ូលីស និងក្រុមគ្រួសាររបស់ពួកគេ ជនជាតិវៀតណាម និងមនុស្ស ដែលមានទំនាក់ទំនងជាមួយវៀតណាម និងមនុស្សដែលគេបានចោទថាជាភ្នាក់ងារសេអ៊ីអា ឬ ជាជនក្បត់។ ជាមួយគ្នានេះដែរ គេបានចាប់ខ្លួនមនុស្សពីបទប្រព្រឹត្ត"ខុសសីលធម៌" ការលួច ការគេចវេសពីការងារ ការវាយគោក្របី ការនិយាយខុស និងការប្រើមន្តអាគម។ [redacted] បានផ្តល់ឱវាទណែនាំប្រាប់ស្រុកថាមនុស្សដែលជាប់ចោទពីបទល្មើសទីមួយ និងទីពីរត្រូវអប់រំ នៅមូលដ្ឋាន ចំណែកមនុស្សដែលជាប់ចោទពីបទល្មើសទីបី ត្រូវបញ្ជូនទៅកាន់គុកភ្នំក្រោល។

៥៥២- ការចាប់ខ្លួនត្រូវបានធ្វើឡើងដោយទាហានកងវរសេនាតូចលេខ២ ដោយគោរពទៅតាមបទ បញ្ជារបស់គណៈយោធាតំបន់ឈ្មោះ សុភា ផ្អែកតាម"របាយការណ៍ពីមូលដ្ឋាន"។ ជារឿយៗ ការចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន គឺធ្វើឡើងដោយកងពលធំ៩២០ ជាកងពលធំមួយ ក្នុងចំណោមកងពលធំយោធាជាច្រើនរបស់មជ្ឈិមបក្ស [redacted] នៅក្នុងករណីផ្សេងៗទៀត ការចាប់ខ្លួនត្រូវបានធ្វើឡើង ដោយកម្មាភិបាលសន្តិសុខមកពីមន្ទីរក-១១។ ជារឿយៗ ប្រជាជនត្រូវគេចាប់ខ្លួនជាក្រុមៗ ហើយបញ្ជូនទៅមន្ទីរសន្តិសុខ តាមរថយន្ត ដោយប្រជាជនទាំងនោះត្រូវគេចងស្លាបសេក។

៥៥៣- [redacted] បានទទួលបញ្ជាពីមជ្ឈិមបក្ស ឱ្យចាប់ខ្លួន "ខ្មាំងបង្កប់" និង"ជនក្បត់" ដែលជាប់ទាក់ទិននឹងចម្លើយសារភាព កម្មាភិបាលតំបន់១០៥ នៅស-២១ ឬមានទំនាក់ទំនងនឹង កម្មាភិបាលដែលត្រូវគេបោសសម្អាត។ ឧទាហរណ៍ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ មានប្រជាជន លើសពី៨០នាក់ដែលមានជាប់ពាក់ព័ន្ធជាមួយអនុលេខាតំបន់ ខាំ ភួន ត្រូវបានគេប្រមូលផ្តុំ ចាប់

និងឃុំខ្លួននៅភ្នំក្រោល ក-១១ និងក-១៧។ ខាំ ភួន ត្រូវបាន“ថ្នាក់លើ”ប្រកាសជាជនក្បត់ក្រោយពីការស្លាប់របស់គាត់នៅចុងខែតុលា ឆ្នាំ១៩៧៧ ដែលបណ្តាលឲ្យមានការបោសសម្អាត “ខ្សែ”បណ្តាញរបស់គាត់ភ្លាម។

៥៥៤- នៅពេលនោះ កម្មាភិបាលមូលដ្ឋានមួយរូបដែលមានជាប់ទាក់ទងនឹង ខាំ ភួន ត្រូវបានចាប់ខ្លួន គឺ ផាន ឃន *ហៅ* ជួន ជាសមាជិកពាណិជ្ជកម្មតំបន់១០៥។ ពីដំបូងឈ្មោះ ជួន ត្រូវបានឃុំខ្លួននៅជាន់ទី២នៃមន្ទីរក-១៧ ហើយបន្ទាប់មកទៀត ក៏ត្រូវគេបញ្ជូនទៅភ្នំពេញ ដែល នៅទីនោះ គាត់បានចូលទៅមន្ទីរស-២១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ និងបានចុះហត្ថលេខាលើចម្លើយសារភាពចំនួន២ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ក្រោយមក។ នៅមានកម្មាភិបាលកងពលធំ៩២០ និងកម្មាភិបាលតំបន់១០៥ផ្សេងទៀត ដែលមានចំនួនលើសពី១៣០ នាក់ ក៏ត្រូវបានគេយកទៅមន្ទីរស-២១ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ដូចជាឈ្មោះ ជួន ដែរ។ ចំពោះការអនុវត្តន៍ជាបទដ្ឋានជាមួយនឹងកម្មាភិបាលថ្នាក់តំបន់ ដែលត្រូវសួរចម្លើយនៅស-២១ [redacted] ត្រូវបានគេផ្តល់ដំណឹងពីបុគ្គលដែលមានជាប់ពាក់ព័ន្ធនឹងចម្លើយសារភាពរបស់ ជួន តាមរយៈការទទួលនូវចម្លើយសារភាពជាច្បាប់ចម្លងមួយច្បាប់ ឬបញ្ជីរាយនាមដែលមានបញ្ជាក់ឈ្មោះនៅក្នុងនោះ។

៥៥៥- [redacted]

[redacted]។

៥៥៦- [redacted]

[redacted]។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

## លក្ខណៈអមនុស្សធម៌

៥៥៧- អ្នកទោសភ្នំក្រោលរស់នៅក្នុងស្ថានភាពរន្ធត់ញាប់ញ័រ។ អ្នកជាប់ឃុំឃាំងនៅភ្នំក្រោលទាំងនោះ ត្រូវគេដាក់ខ្នោះជើងធ្វើពីឈើរួមគ្នា ដោយក្នុងជួរនីមួយៗមានមនុស្សចំនួនប្រមាណពី៤ ទៅ២០ នាក់។ នៅមន្ទីរសន្តិសុខក-១១ អ្នកទោសត្រូវគេដាក់ខ្នោះរបាជាប់នឹងជើងធ្វើពីដែក និងឈើ ដោយក្នុងរបាមួយមានអ្នកទោសចំនួន០៥នាក់។ អ្នកទោសទាំងអស់ត្រូវគេដាក់ខ្នោះជើងនៅ ពេលដេក ហើយអ្នកទោសកម្រិតធ្ងន់ ត្រូវគេដាក់ខ្នោះជើងជាអចិន្ត្រៃយ៍។ អ្នកទោសមួយ ចំនួនបានរៀបរាប់ថា ត្រូវគេចងព្យួរជើងចុះក្រោមទាំងជើងជាប់ខ្នោះ ក្នុងរយៈពេលយ៉ាង យូរ។ អ្នកទោសត្រូវគេហាមឃាត់មិនឲ្យនិយាយ ឬប្រើភាសាជនជាតិភាគតិច ដើម្បី និយាយគ្នាឡើយ។

៥៥៨- អ្នកជាប់ឃុំឃាំងគ្មានអាហារគ្រប់គ្រាន់ទេ ដោយទទួលបានតែត្រឹមបបររាវៗមួយ ឬពីរពេល ប៉ុណ្ណោះក្នុងមួយថ្ងៃ។ អ្នកទោសមានសភាពទន់ខ្សោយ និងស្គមស្គាំងដោយសារតែខ្វះចំណី អាហារ ហើយនៅពេលដែលពួកគេធ្លាក់ខ្លួនឈឺនោះ គ្មានថ្នាំពេទ្យព្យាបាលផ្តល់ឲ្យនោះទេ។ ហេតុដូច្នេះហើយ អ្នកទោសមួយចំនួនបានស្លាប់ដោយសារខ្វះជីវជាតិ។ អ្នកជាប់ឃុំឃាំង

ត្រូវគេតម្រូវឱ្យបន្ទោរបង់ទឹកនោម និងលាមកនៅក្នុងកេសគ្រាប់។ ការខ្វះអនាម័យបានបណ្តាលឱ្យបន្ទប់ឃុំខ្លួនអ្នកទោសមានក្លិនអាសោច។ វនាបឫស្សីនៅកន្លែងឃុំឃាំង ភ្នំក្រោលគឺពោរពេញទៅដោយសង្កើច។ អ្នកទោសទាំងឡាយដែលធ្លាក់ខ្លួនឈឺ ដោយសារ តែស្ថានភាពទាំងនេះ ត្រូវគេចោទថាធ្វើពុតជាឈឺ និងក៏ត្រូវបាត់ខ្លួនជាបន្តបន្ទាប់។

## ពលកម្មដោយបង្ខំ

៥៥៩- ចំពោះជនទាំងឡាយដែលត្រូវបង្ខំឱ្យធ្វើការ ការងារមានការលំបាកខ្លាំងណាស់។ អ្នកទោសធ្ងន់ត្រូវគេដាក់ខ្នោះជើងពេញ២៤ម៉ោងក្នុងមួយថ្ងៃ រីឯអ្នកទោសបទល្មើសស្រាល ត្រូវគេដោះខ្នោះជើងនៅពេលថ្ងៃ ហើយបង្ខំឱ្យធ្វើការ។ អ្នកទោសស្រាលត្រូវធ្វើការក្រោមការឃាម កាមទាំងក្នុង និងក្រៅបរិវេណមន្ទីរឃុំឃាំងដូចជា អាររណ្ដើដើម្បីធ្វើគ្រឿងសង្ហារឹម វាយគ្រាប់ ក្រចៅ ស្ទូងស្រូវ និងលើកទំនប់ជាដើម។ អ្នកទោសត្រូវធ្វើការពីម៉ោង៦កន្លះព្រឹក រហូតដល់ម៉ោង៤កន្លះល្ងាច ដោយបានសម្រាកតែរយៈពេលខ្លីប៉ុណ្ណោះ សម្រាប់អាហារថ្ងៃត្រង់។

## ការសួរចម្លើយ និងការទារុណកម្ម

៥៦០- អ្នកជាប់ឃុំឃាំងត្រូវគេសួរចម្លើយ និងធ្វើទារុណកម្មនៅភ្នំក្រោល និងមន្ទីរក-១១ ជាប្រចាំ។ គោលបំណងនៃការសួរចម្លើយ និងធ្វើទារុណកម្ម គឺដើម្បីឱ្យដឹង ថាតើអ្នកទោស មានទំនាក់ទំនងជាមួយវៀតណាម មានផែនការរត់ចោលស្រុក និង/ឬធ្វើការឱ្យសេអ៊ីអាឬយ៉ាងណា។ អ្នកទោសដែលត្រូវគេចាប់ខ្លួន ដោយសារតែខ្លួនមានទំនាក់ទំនងជាមួយជនក្បត់នោះ ត្រូវបានគេសួរ ពីការក្បត់របស់បុគ្គលនោះចំពោះបក្ស។ ជនគ្រប់ៗរូបដែល

ត្រូវគេនាំទៅភ្នំក្រោល ត្រូវគេតម្រូវឱ្យរៀបចំប្រវត្តិរូប។ អ្នកទោសម្នាក់ ត្រូវបានគេសួរ នាំទាំងជើងជាប់ខ្នោះ និងត្រូវគេវាយជាច្រើនដង ជាមួយនឹងព្រនង់ឈើវែងមានប្រវែង កន្លះម៉ែត្រ រហូតដល់គាត់សន្លប់បាត់ស្មារតី។

៥៦១- តា សុភា និងតា ឡេង គឺជាអ្នកសួរចម្លើយដោយផ្ទាល់។ [redacted]។

## ការសម្លាប់មនុស្សខុសច្បាប់

៥៦២- អ្នកទោសដែលត្រូវសម្លាប់ ត្រូវបានគេយកទៅត្រពាំងព្រីង ជាទីតាំងសម្លាប់ដំបូងនៅក្នុងតំបន់នោះ ដែលគេហៅថា ទួលខ្មោច ឬត្រពាំងព្រីង ឬអូរគ្រៀង ដែលស្ថិតនៅប្រមាណ០៤គីឡូម៉ែត្រ ពីភ្នំក្រោល។ អ្នកទោសដែលត្រូវសម្លាប់រួមមាន ទាហានមកពីកងពលធំ៩២០ កម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបោសសម្អាត និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងអ្នកដែល ជាទាហាន ប៉ូលីស មន្ត្រីរាជការ ឬគណៈឃុំនៅក្នុងរបបមុនៗ។ ក្រុមគ្រួសារទាំងមូលត្រូវបាន សម្លាប់ចោល ឧទាហរណ៍ ក្ដួយប្រុស និងកូនប្រុសរបស់ ខាំ ភួន ចំនួន០៨នាក់ត្រូវគេយក ទៅសម្លាប់។ ផ្ដើមនៅក្នុងឆ្នាំ១៩៧៧ ជនរងគ្រោះជាច្រើនដែលត្រូវគេសម្លាប់ គឺជាជនដែល

ត្រូវគេចោទប្រកាន់ជាអ្នកស៊ើបការណ៍ ឬអ្នកគាំទ្រពួកវៀតណាម ខ្មែរស និងកា ហ្សេបេ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេប្រាប់ថា ប្រជាជនទាំងអស់ដែលស្ថិតនៅក្នុងស្រុកមួយ (កែវសីម៉ា) ត្រូវគេចាត់ទុកថា "ក្បាលយួន ខ្លួនខ្មែរ" ជាអ្នកដែល "បានក្បត់អង្គការ"ហើយប្រជាជនមកពីស្រុកនោះជាច្រើន ត្រូវគេសម្លាប់ក្នុងខែកក្កដា ឆ្នាំ ១៩៧៧។

៥៦៣- អ្នកទោសភ្នំក្រោលជាច្រើននាក់ ត្រូវបានគេយកទៅសម្លាប់នៅពេលយប់តាមរថយន្ត។ ប្រសិនជាប្រជាជនក្នុងចំនួនតិចតួចត្រូវយកទៅសម្លាប់នោះ ពួកគេនឹងមិនយកទៅត្រពាំងព្រីងទេ ប្រជាជន ទាំងនោះ នឹងត្រូវគេសម្លាប់នៅក្បែរបរិវេណគុកវិញ។ អ្នកទោសត្រូវគេវាយ សម្លាប់ នឹងព្រនង់ ហើយសាកសពរបស់ពួកគេត្រូវគេបោះចូលទៅក្នុងរណ្តៅ និងត្រូវគ្រាក់ទ័រកាយដីកប់។ ការជីកគាស់កាយសាកសព បានរកឃើញសាកសពចំនួន២០០ នៅក្នុងរណ្តៅ ដីដ៏ធំមួយ។ ដីទួលមួយដែលមានទំហំ២ម៉ែត្រគុណ៦ម៉ែត្រ ក៏ត្រូវបានគេរកឃើញផងដែរ នៅក្នុងនោះមានទាំងចប និងកាំបិត។ នៅមានរណ្តៅកប់សាកសពចំនួន០៤ផ្សេងទៀត ដែលត្រូវបានគេរកឃើញនៅក្នុងបរិវេណនោះ។

៥៦៤- របាយការណ៍ផ្ញើមកពីតំបន់១០៥ ទៅមជ្ឈិមបក្សបានបញ្ជាក់អំពី "ការកម្ទេច" ខ្លាំង។ ឧទាហរណ៍ ទូរលេខមួយច្បាប់របស់លេខាតំបន់ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ ផ្ញើទៅមន្ទីរ៨៧០ បាននិយាយអំពីការកម្ទេចពួកវៀតណាម និងបានធ្វើការកត់សម្គាល់ថា "អំពីបញ្ហាយួននេះបានសម្រេចហើយ"។ [redacted]

[redacted]។

៥៦៥- បន្ថែមលើការសម្លាប់ដែលកើតមាននៅភ្នំក្រោល នៅមានកម្មាភិបាលមូលដ្ឋានជាច្រើនទៀត ដែលបានបាត់ខ្លួនបន្ទាប់ពីត្រូវបាន នួន ជា និងប៉ុល ពត ហៅទៅភ្នំពេញ ឬត្រូវបាន កងពលធំ៩២០ចាប់ខ្លួន រួមមានគណៈឃោធាតំបន់ ហួត កែ *ហៅ* សុភា មេបញ្ជាការ កងវរសេនាតូចលេខ២ បាន បួយ *ហៅ* តា ឡេង អនុលេខាតំបន់ទទួលបន្ទុកការងារនយោបាយ សូ គិមអាន *ហៅ* ម៉ី មេបញ្ជាការកងពលធំ៩២០ ម៉ែន ម៉េង *ហៅ* ឈិន និងបញ្ជាការ រងរបស់គាត់ អ៊ា ជី *ហៅ* តា សយ និងសួន អុល *ហៅ* តាគីម។

## មន្ទីរសន្តិសុខវត្តធ្លក

## ទីតាំង និងប្រតិបត្តិការ

៥៦៦- មន្ទីរសន្តិសុខវត្តធ្លក (“វត្តធ្លក”) មានទីតាំងស្ថិតនៅក្នុងនិង បរិវេណវត្តធ្លក ក្នុងភូមិធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ស្ថិតនៅទិសពាយ័ព្យមានចម្ងាយប្រមាណ២៨គីឡូម៉ែត្រ ពីខេត្ត ស្វាយរៀង និងជាផ្នែកមួយនៃភូមិភាគបូព៌ាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វត្តធ្លកបាន ចាប់ផ្តើមដំណើរការ ចន្លោះពីខែឧសភា ឆ្នាំ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ និងជំនួសមន្ទីរសន្តិសុខ ម៉ឺនសាយ ដែលកំពុងដំណើរការ។ នៅចន្លោះខែឧសភា ឆ្នាំ១៩៧៥

និងពាក់កណ្តាលឆ្នាំ១៩៧៨ បក្សកុម្មុយនីស្តកម្ពុជាបានផ្តល់ទីកន្លែងស្នាក់នៅសម្រាប់កម្មាភិបាលសន្តិសុខនៅ វត្តធ្លក។

៥៦៧- វត្តធ្លកត្រូវបានបង្កើតឡើង បន្ទាប់ពីមានការរៀបចំចាត់ចែងផ្នែករដ្ឋបាលឡើងវិញដែលបានបែងចែងស្រុកស្វាយរៀងចេញពីស្រុកមានជ័យថ្មី។ វត្តធ្លកមានមន្ទីរឃុំឃាំងចំនួន០២ និងទីពិឃាត០១កន្លែងនៅក្បែរនោះ។ ទីតាំងពីដំបូងស្ថិតនៅក្នុងបរិវេណវត្តធ្លក។ទីតាំងបន្ទាប់មកគឺនៅបញ្ជាការដ្ឋានសន្តិសុខស្រុក ដែលមានទំហំប្រមាណ២ហិកតាស្ថិតនៅចម្ងាយ៥០០ម៉ែត្រ។ បញ្ជាការដ្ឋានសន្តិសុខស្រុកមានអគារប្រក់ក្បឿងទំហំ៧ម៉ែត្រ និង៨ម៉ែត្រ ចំនួន០៣ ដែលគេប្រើប្រាស់ជាកន្លែងសម្រាប់សួរចម្លើយអ្នកទោស។ ទីពិឃាតគឺ ស្ថិតនៅខាងកើតជាប់បរិវេណវត្តដែលមានរណ្តៅសាកសពរួមជាច្រើន។ នាពេលបច្ចុប្បន្ននេះ អគារទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ និងទីបញ្ជាការសន្តិសុខស្រុកបានបាត់អស់ហើយ។ ថ្មីៗនេះទីកន្លែងនេះ គឺជាទីតាំងការិយាល័យគណបក្សប្រជាជនកម្ពុជា ដែលស្ថិតនៅទល់មុខនឹងសាលាបឋមសិក្សាធ្លក។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៥៦៨- វត្តធ្លកមានទីតាំងស្ថិតនៅស្រុកមានជ័យថ្មី តំបន់២៣នៃភូមិភាគបូព៌ា។ លេខាស្រុកមានជ័យថ្មីដែលគេស្គាល់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺ ផឹង សុន *ហៅ* សយ ដែលត្រូវគេចាប់ខ្លួនយកទៅមន្ទីរស-២១ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ ជាផ្នែកមួយនៃការបោសសម្អាតនៃ

ភូមិភាគបូព៌ា និង [redacted]។ អនុលេខាស្រុក រហូតមកទល់ពេលដែលគាត់ត្រូវចាប់ខ្លួននៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៨ គឺ សួស ធុន *ហៅ* ឈាង ស៊ី។ អ្នកបន្តវេនពីគាត់ គឺគណៈសន្តិសុខស្រុក វង់ អោ *ហៅ* តា អោ ដែលត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៨។

៩៦៩- លេខាតំបន់២៣ រហូតដល់ពេលដែលគាត់ត្រូវគេដកចេញក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ និងចាប់ខ្លួននៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨ គឺ អ៊ុក សាវ៉ាន់ *ហៅ* សូ។ គាត់ត្រូវបានជំនួសជាលេខាតំបន់២៣ ដោយអនុលេខាភូមិភាគបូព៌ា មាស សេងហុង *ហៅ* ចាន់។ សមាជិកផ្សេងៗទៀតនៃគណៈតំបន់២៣ ដែលត្រូវបានបោសសម្អាតនៅពេលនោះដែរមាន៖ អនុលេខា ម៉ែន ឡៀក *ហៅ* នួន ដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ សមាជិកឈ្មោះ នៅ សាលី *ហៅ* សាលើវ ត្រូវចាប់ខ្លួន និងបញ្ជូន ទៅកាន់មន្ទីរស-២១នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨ និងគណៈសន្តិសុខតំបន់ ណាម សុត *ហៅ* សាម ត្រូវចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨។

៩៧០- មកទល់ពេលដែលគាត់ធ្វើអត្តឃាតខ្លួន ប្រហែលជានៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨ លេខាភូមិភាគបូព៌ា សោ ភឹម ដែលជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែរនោះ ជាអ្នកទទួលបន្ទុករាល់កិច្ចការនៅភូមិភាគបូព៌ា។ បន្ទាប់ពី ភឹម ស្លាប់ទៅ មានសេចក្តីប្រកាសសរសេរដោយដៃចុះហត្ថលេខាដោយ កែ ពក ត្រូវបានផ្សព្វផ្សាយដោយមានខ្លឹមសារថា សោ ភឹម គឺជាជនក្បត់ ហើយ វន វេត បានក្លាយទៅជាលេខាភូមិភាគជំនួស ហើយ មាស សេងហុង

*ហៅ* ចាន់ នៅរក្សាតួនាទីជាអនុលេខាតំបន់ដដែល។ រយៈពេលប៉ុន្មានខែក្រោយមក ចាន់ ត្រូវ "គេហៅទៅភ្នំពេញ" ហើយក៏បាត់ខ្លួន និងជំនួសដោយមេបញ្ជាការយោធាពាយ័ព្យ ឈ្មោះ រ៉ែន។

**រចនាសម្ព័ន្ធនៅក្នុងមន្ទីរសន្តិសុខ**

៥៧១- វត្តធ្លក គឺជាមន្ទីរឃុំឃាំងថ្នាក់ស្រុក ក្រោមការគ្រប់គ្រងដោយផ្ទាល់ពីទីបញ្ជាការសន្តិសុខ ស្រុក។ សួស ផុន *ហៅ* ឈាង ស៊ី ជាអនុលេខាថ្មីស្រុកមានជ័យថ្មី បានទទួលតួនាទីជា ប្រធានវត្តធ្លក ហើយ វង់ អោ *ហៅ* តា អោ គឺជាសមាជិកគណៈគ្រប់គ្រងគុក។ អនុប្រធានមន្ទីរសន្តិសុខ គឺ [redacted]។ នៅពេលឈ្មោះ ឈាង ត្រូវចាប់ខ្លួននៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៨ គណៈសន្តិសុខស្រុក តា អោ នៅទទួលបន្ទុកគ្រប់គ្រងនៅឡើយ ហើយគាត់ត្រូវគេចាប់ខ្លួន ២ខែក្រោយមក។

៥៧២- មានបុគ្គលិកសន្តិសុខប្រមាណពី២០ ទៅ៣០នាក់ ដែលធ្វើការនៅទីបញ្ជាការសន្តិសុខស្រុក និង មន្ទីរសន្តិសុខវត្តធ្លក។ បុគ្គលិកសន្តិសុខទាំងនេះ រួមមាន [redacted]។ [redacted] ត្រូវបានចាត់តាំងឲ្យចាប់ និងសម្លាប់អ្នកទោសនៅតាមបណ្តា ឃុំ។ មកទល់ពាក់កណ្តាលឆ្នាំ១៩៧៨ ខ្សែរយៈចាត់តាំងបញ្ជានៃភូមិភាគបូព៌ាទាំងអស់ សម្រាប់ វត្តធ្លកត្រូវបានគេសម្លាប់ ឬជាប់គុកនៅមន្ទីរស២១ ហើយមន្ទីរសន្តិសុខវត្តធ្លកបាន បញ្ឈប់ប្រតិបត្តិការ។

**ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា**

៥៧៣- ក្នុងអំឡុងពេលដែលវត្តធ្លកនៅមានប្រតិបត្តិការ មន្ទីរសន្តិសុខភូមិភាគបូព៌ា បានបញ្ជូនរបាយការណ៍ មកមន្ទីរសន្តិសុខ៨៧០ជាប្រចាំ ស្តីពីជម្លោះយោធាជាមួយវៀតណាម ការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់ខ្មាំង ព្រមទាំងបញ្ហាផ្គត់ផ្គង់ស្បៀង ហើយបានទទួលការណែនាំ និងបញ្ជាពីអ្នកដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៥៧៤- ប្រជាជនរាប់រយ ឬអាចមានចំនួនរាប់ពាន់នាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន នៅវត្តធ្លក ដែលស្របគ្នានឹងគោលបំណងសំខាន់របស់វា គឺការឃុំខ្លួនខ្មាំងដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅទីនោះពីទីបញ្ជាការសន្តិសុខស្រុក។ នៅខែឧសភា ឆ្នាំ១៩៧៥ អ្នកទោសដែលធ្លាប់តែឃុំឃាំងនៅមន្ទីរសន្តិសុខ ម៉ឺន សាយ ត្រូវបានផ្លាស់មកវត្តធ្លក។ ក្នុងមួយលើកៗ មានអ្នកទោសមានចំនួនពី២០០ ទៅ៣០០នាក់ ស្ថិតនៅក្នុងមន្ទីរសន្តិសុខ។ បន្ទាប់ពីការបញ្ជូននេះ អ្នកទោសនៅវត្តធ្លក គឺមកពីបណ្តាភូមិ និងឃុំនៅជុំវិញបរិវេណនោះ។ អ្នកទោសគឺជាប្រជាជនសាមញ្ញ មិនមានគ្រូបង្រៀន និងកូនសិស្សទេ។ អ្នកទោសមានទាំងស្រី និងប្រុស។ អ្នកទោសខ្លះត្រូវបានដោះលែងឲ្យទៅបររទេះគោ ប៉ុន្តែពួកគេត្រូវបានអ្នកយាមគុកឃ្លាំមើល និងយាមគ្រប់ពេលវេលា។ ពួកគេភាគច្រើនត្រូវបានចាប់ខ្លួន ដោយសារពួកគេបានលួចម្ហូបអាហារ លួចមាន់ ឬ“ខុសសីលធម៌”។ ក្នុងអំឡុងពេលប្រតិបត្តិការរបស់វត្តធ្លក ក្នុងមួយថ្ងៃមានអ្នកទោសថ្មីជាមធ្យមប្រមាណពី៥ ទៅ៦នាក់ ត្រូវបានបណ្តើរចូលក្នុងគុក។ អ្នកទោសដែលមកដល់ ត្រូវបណ្តើរចូលមន្ទីរសន្តិសុខ ដោយដៃត្រូវគេចងព័ន្ធទៅក្រោយ ហើយអាចត្រូវកម្មាភិបាលសន្តិសុខប្រើរំពាត់វាយ។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៥៧៥- អ្នកទោសកម្រិតធ្ងន់ ត្រូវដាក់ខ្នោះជើងធ្វើពីឈើទាំងសងខាង។ អ្នកទោសមានសភាពទ្រុឌទ្រោម និងស្លេកស្លាំង។ គេអាចឮសម្រែកអ្នកទោសពីខាងក្រោមមន្ទីរសន្តិសុខ។ អ្នកទោសត្រូវគេវាយបណ្តើរពីកន្លែងឃុំខ្លួនទៅកាន់កន្លែងសួរចម្លើយ។

### ពលកម្មដោយបង្ខំ

៥៧៦- អ្នកទោសវគ្គធូកមួយចំនួន ត្រូវធ្វើការដោយប្រើកម្លាំងដោយដៃក្នុងរយៈពេលជាច្រើនម៉ោង។ ការងាររួមមានលើកភ្លឺស្រែ ជួសជុលរទេះអូស អូសសំណាញ់បង់ត្រី ឬប្រមូលអាចម៍គោ។ អ្នកទោសដែលត្រូវឃុំខ្លួនដោយសារបានប្រព្រឹត្តបទល្មើសស្រាលៗ ត្រូវបង្ខំឱ្យធ្វើការ រីឯអ្នកទោសកម្រិតធ្ងន់ ត្រូវឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងជាអចិន្ត្រៃយ៍។ ការដ្ឋានស្ថិតនៅទីតាំងចំនួន៣គឺ៖ ទី១ ស្ថិតនៅខាងត្បូងមន្ទីរសន្តិសុខ ទីតាំងទី២ នៅខាងជើង និងទីតាំងទី៣ គឺជាទីកន្លែងដែលកម្មាភិបាលយកអ្នកទោសទៅសម្លាប់។ អ្នកទោសធ្វើការពីម៉ោង៦ ឬម៉ោង៧ព្រឹក រហូតដល់ម៉ោង១១ថ្ងៃ ហើយឈប់សម្រាកដើម្បីទទួលទានបបរាវៗ និងបង្ខំឱ្យត្រឡប់ទៅធ្វើការវិញពីម៉ោង១រសៀល រហូតដល់ម៉ោង៦ល្ងាច។ អ្នកទោសមួយចំនួន លើចបនៅលើស្មារបស់ខ្លួន ដោយមានកម្មាភិបាលប្រដាប់ដោយអាវុធដើរតាមពីក្រោយ។ ប្រសិនបើអ្នក ទោសធ្វើការងារមិនបានល្អទេ នឹងទទួលរងនូវការវាយដំ។

### ការសួរចម្លើយ និងការធ្វើទារុណកម្ម

៥៧៧- អ្នកទោសនៅវត្តធ្លក ត្រូវគេសួរចម្លើយ និងធ្វើទារុណកម្ម។ វិធីសាស្ត្រក្នុងការធ្វើទារុណកម្មជាក់លាក់ រួមបញ្ចូលទាំងការវាយដំផងដែរ។ គេបានឮសម្រែកក្នុងពេលកំពុងសួរចម្លើយ។ បន្ទាប់ពី ត្រូវគេធ្វើទារុណកម្ម អ្នកទោសត្រូវគេយកទៅកប់ចោល ទោះបីជាពួកគេនៅមានជីវិតក៏ដោយ។ ការសួរចម្លើយត្រូវបានធ្វើឡើងនៅក្នុងវិហារ។

## ការសម្លាប់មនុស្សក្រៅច្បាប់

៥៧៨- មុនពេលអ្នកទោសត្រូវគេចង និងបិទមុខ ត្រូវគេបណ្ដើរទៅកន្លែងពិឃាត កម្មាភិបាលសន្តិសុខបានបញ្ជាឲ្យអ្នកទោសផ្សេងទៀតជីករណ្ដៅ។ ប៉ុន្តែ មានពេលខ្លះ អ្នកទោសត្រូវគេតម្រូវឲ្យជីករណ្ដៅខ្លួនឯង ដោយគេប្រាប់ថារណ្ដៅទាំងនោះត្រូវប្រើសម្រាប់ធ្វើជី។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាប្រមាណ៥នាក់ ក្នុងសម្លៀកបំពាក់ខ្មៅដោយដៃមានកាន់កាំភ្លើងអាកា បានបណ្ដើរអ្នកទោសទៅកន្លែងពិឃាត។ នៅពេលកំពុងរង់ចាំឲ្យគេសម្លាប់ គេឲ្យអ្នកទោសលុតជង្គង់នៅក្បែររណ្ដៅ ដោយជាប់ចំណង និងបិទមុខជិត។

៥៧៩- អ្នកទោសត្រូវគេសម្លាប់ម្ដងម្នាក់ៗ។ កម្មាភិបាលសន្តិសុខ២នាក់ផ្លាស់វេនគ្នា សម្លាប់អ្នកទោស ហើយមានកម្មាភិបាល៥នាក់ផ្សេងទៀត ឈរ និងយាមអ្នកទោស ដែលនៅរង់ចាំស្ថិតនៅប្រមាណ៣ ឬ៤ម៉ែត្រពីមាត់រណ្ដៅ។ កម្មាភិបាលសន្តិសុខ បានប្រើចបកាប់ និងដែកគាស់វែង វាយទៅលើអ្នកទោស២ ឬ៣ដង ពេលខ្លះវាយត្រូវកញ្ចឹងក ឬត្រូវក្បាលផ្នែកខាងក្រោយ មុនពេលធាក់អ្នកទោសចូលទៅក្នុងរណ្ដៅ។ គេអាចឮសម្រែកមនុស្សស្រែក នៅពេលកម្មាភិបាលសន្តិសុខវាយ និងសម្លាប់អ្នកទោស។ អ្នកទោសត្រូវបានគេគ្រវែង ចូលទៅក្នុងរណ្ដៅសាកសពរួម ទោះបីជាពួកគេមិនទាន់ស្លាប់ក៏ដោយ។ អ្នកទោសផ្សេងទៀត បានព្យាយាម

វត់គេច ប៉ុន្តែត្រូវកម្មាភិបាលសន្តិសុខចាប់បាន ហើយបាញ់ចោល។ បន្ទាប់ពីការសម្លាប់បានបញ្ចប់ កម្មាភិបាលសន្តិសុខបានបង្ខំឱ្យអ្នកទោសលុបរណ្តៅ។ ក្នុងព្រឹត្តិការណ៍ចំនួន៣ មានអ្នកទោសចំនួនពី៣០ ទៅ៤០នាក់ត្រូវគេសម្លាប់ជារួមនៅទិសខាងកើត នៃមន្ទីរសន្តិសុខ។ ការសម្លាប់ទាំងនេះត្រូវបានប្រព្រឹត្តទៅអស់ជាច្រើនថ្ងៃជាបន្តបន្ទាប់ នាចុងឆ្នាំ១៩៧៥។ អ្នកដែលត្រូវគេសម្លាប់ភាគច្រើន គឺជាបុរសដែលមានអាយុចាប់ពី២០ឆ្នាំឡើងទៅ។

៥៨០- បន្ថែមលើការសម្លាប់អ្នកទោសដោយមានផែនការ នៅមានទម្រង់នៃការសម្លាប់ផ្សេងៗទៀតដែលកើតមាននៅក្នុង និងជុំវិញវត្តធ្លក។ នារីជំទង់ចម្រុះពូជសាសន៍ មានចិន វៀតណាម និងខ្មែរត្រូវកម្មាភិបាលសន្តិសុខបក្សកុម្មុយនីស្តកម្ពុជា កែនទៅធ្វើការនៅទីកន្លែងដែលកម្មាភិបាលរស់នៅ។ ក្រោយមកកម្មាភិបាលបានរំលោភស្ត្រីទាំងនោះរួច កាត់ប្រដាប់បន្តពូជរបស់ពួកគេចោល ហើយចងព្យួរឱ្យស្លូតក្រោមដើមក្រសាំង ហើយបន្ទាប់មកគេសម្លាប់ស្ត្រីទាំងនោះចោល។ នៅមានការត្រួតពិនិត្យដោយជិះសេះនៅពេលយប់ ដើម្បីពិនិត្យមើលប្រជាជននៅក្នុងឃុំមូលដ្ឋាន ហើយប្រសិនបើមានការប្រាប់ពីអ្វីមិនត្រឹមត្រូវ គេនឹងយកជនរងគ្រោះចេញទៅហើយសម្លាប់ពួកគេចោល។

៥៨១- ការជីកគាស់កាយសពបានធ្វើឡើងនៅឆ្នាំ១៩៨០ ដល់៨២ ទៅលើរណ្តៅសាកសពរួមធំៗដែលមានចន្លោះពី៤១ ទៅ៤៥ ស្ថិតនៅខាងកើតវត្ត។ គេបានរកឃើញអដ្ឋិធាតុមនុស្សចន្លោះពី៥០៦ ទៅ៩៣២ នាក់។ នាពេលថ្មីៗនេះ អដ្ឋិធាតុទាំងនេះ ត្រូវបានបញ្ចុះក្នុងចេតិយមួយស្ថិតនៅច្រកចូលភូមិធ្លក។ មានការប៉ាន់ស្មានថា អាចមានរណ្តៅសាកសពតូចៗប្រមាណ២០០ ឬលើសពីនេះនៅព័ទ្ធជុំវិញបរិវេណនោះ ដែលគេជឿជាក់ថា អាចមានអដ្ឋិធាតុប្រមាណ២

ឬ៣នាក់ ក្នុងមួយរណ្តៅ។ បន្ទាប់ពីមានការជីកគាស់កាយសាកសពនៅក្នុងទីតាំងនេះមានការប៉ាន់ស្មានថា

ជនរងគ្រោះទាំងអស់ដែលត្រូវកប់នៅក្នុងបរិវេណវត្តធ្លកមានប្រមាណ១៥០០នាក់។

## មន្ទីរសន្តិសុខអូរកន្សែង(ភូមិ៣)

### ទីតាំង និងប្រតិបត្តិការ

៥៨២- មន្ទីរសន្តិសុខអូរកន្សែង("អូរកន្សែង") មានទីតាំងស្ថិតនៅឃុំឡាបាសៀក ស្រុកបានលុង ខេត្តរតនៈគិរី និងស្ថិតក្នុងផ្នែកនៃភូមិភាគឦសានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អូរកន្សែង បានចាប់ផ្តើមដំណើរការចន្លោះពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ និងខែមករា ឆ្នាំ១៩៧៩។

៥៨៣- អូរកន្សែង ត្រូវបានគេហៅតាមឈ្មោះជាច្រើន រួមមាន មន្ទីរសន្តិសុខបឹងកន្សែង មន្ទីរសន្តិសុខអូរកន្សែង គុកអូរកន្សែង សាលាអប់រំ និងជាមន្ទីរអប់រំកែប្រែរបស់ កងពលធំ៨០១ ឬ ៨១០ មន្ទីរសន្តិសុខភូមិ៣ និងមន្ទីរសន្តិសុខភូមិ៦។ មន្ទីរសន្តិសុខ នេះ ស្ថិតនៅដីដែលមានទំហំ៣ហិកតា ជាមន្ទីរដែលទីតាំងមានទំហំធំជាងគេ និងមាន អគារឃុំឃាំងចំនួន៤ សម្រាប់អ្នកទោសប្រុស និងអ្នកទោសស្រី អគារឃុំឃាំងពីរសម្រាប់ អ្នកទោសកម្រិតធ្ងន់ ផ្ទះសម្រាប់បុគ្គលិកសន្តិសុខ និងមានទីកន្លែងសម្រាប់ សួរចម្លើយមួយទៀតដែល ស្ថិតនៅក្នុងព្រៃក្បែរនោះ។ នៅពេលដែលចំនួនអ្នកទោស កើនឡើង អគារឃុំឃាំងចំនួន៣បន្ថែមទៀតត្រូវបានសាងសង់។ មន្ទីរឃុំឃាំងត្រូវបាន សាងសង់ ពីឫស្សី និងដំបូលប្រក់ស្បូវ មានទំហំ

ប្រមាណ៤ម៉ែត្រគុណ៦ម៉ែត្រ។ គុកត្រូវហ៊ុំព័ទ្ធដោយចម្រូងបូស្សី។ កន្លែងពិឃាតស្ថិតនៅប្រមាណជា៥០ម៉ែត្រពី អូរកន្សែង។

## រចនាសម្ព័ន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៥៨៤- អូរកន្សែងមានតួនាទីជាគុកកងពលធំ និងស្ថិតក្រោមបង្គាប់កងពលធំ៨០១។ ប្រធានមន្ទីរសន្តិសុខត្រូវរាយការណ៍ទៅមេបញ្ជាការកងពលធំ៨០១ សូ សារឿន *ហៅ* តា០៥ ដែលពីមុន មន្ទីររបស់គាត់ស្ថិតនៅបានលុង និងក្រោយមកនៅវ៉ឺនសៃ។ ប្រធានគុក ឆោម សែ បានចូលរួម ប្រជុំជាមួយ សារឿន ជារៀងរាល់៣ ទៅ៤ខែម្តង បន្ថែមលើតម្រូវការឲ្យមានការប្រជុំបន្ទាន់ផ្សេងទៀតនោះ។ សារឿន ជាមេបញ្ជាការកងពលធំ៨០១ ទទួលបន្ទុកមើលខុសត្រូវសកម្មភាពនៅអូរកន្សែង ចេញបញ្ជាឲ្យសម្លាប់អ្នកទោស និងពិនិត្យមើលមន្ទីរសន្តិសុខ តាមពេលវេលាខុសៗគ្នា។

៥៨៥- អូរកន្សែង ក៏ស្ថិតនៅក្រោមអំណាចរបស់គណៈភូមិភាគឦសានផងដែរ គឺ ម៉ែន សាន *ហៅ* យ៉ា រហូតដល់ពេលដែលមានការចាប់ខ្លួនរបស់គាត់ក្នុងខែកញ្ញា ឆ្នាំ១៩៧៦ រឺ រហូតដល់ឆ្នាំ១៩៧៨ និង សូ សារឿន សម្រាប់រយៈពេលនៅសល់ចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងអំឡុងពេលអន្តរកាលខ្លីមួយ បន្ទាប់ពីគណៈភូមិភាគ ឈ្មោះ យ៉ា ត្រូវបានចាប់ខ្លួន នួន ជា មានតួនាទីជាគណៈភូមិភាគឦសានស្តីទី។ មានឱកាសជាច្រើន ដែលអនុលេខា

ភូមិភាគតាឡាវ និង/ឬគណៈភូមិភាគឦសាន សារឿន បានបញ្ជូនបញ្ជាឲ្យសម្លាប់អ្នកទោសនៅអូរកន្សែង។

## របចនាសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ

៥៨៦- ក្នុងអំឡុងពេលដែលអូរកន្សែងមានប្រតិបត្តិការ [redacted] ជាអ្នកទទួលខុសត្រូវលើការដឹកនាំសរុប និងជាទូទៅលើកិច្ចការនយោបាយនៅក្នុងមន្ទីរសន្តិសុខ។ [redacted] បានចូលរួមក្នុងពេលសួរចម្លើយអ្នកទោស និងរៀបចំឯកសារអ្នកទោស។ [redacted] សមាជិកគណៈកម្មការទទួលខុសត្រូវសន្តិសុខ និងមើលខុសត្រូវអ្នកយាម។ នៅមានបុគ្គលិកផ្សេងទៀត ដែលមានបុគ្គលិកសន្តិសុខ០៩រូប។

## ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៥៨៧- របាយការណ៍លម្អិតស្តីពីសកម្មភាពអ្នកទោស ត្រូវបានបញ្ជូនជាប្រចាំថ្ងៃពីអូរកន្សែងទៅកងពលធំ។ របាយការណ៍សង្ខេបពីការសួរចម្លើយ ត្រូវបានផ្ញើទៅ[redacted] ហើយបន្ទាប់មកបញ្ជូនទៅមេបញ្ជាការកងពលធំ សារឿន។ សារទូរលេខត្រូវបានបកប្រែនៅអង្គភាពទូរលេខនៃកងពល៨០១។ ក្រោយមក មេបញ្ជាការកងពលធំ សារឿន បានបញ្ជូនត្រឡប់មកវិញនូវបញ្ជាពាក់ព័ន្ធទៅអូរកន្សែងតាមរយៈនិរសារមួយរូប។ ទំនាក់ទំនងផ្ទាល់ក៏កើតមានដែររវាងអូរកន្សែង និងមន្ទីរអប់រំកែប្រែមន្ទីរ៨០៩ ដែលជាមន្ទីរសន្តិសុខកងពលមួយផ្សេងទៀតដែលស្ថិតក្រោមកងពលធំ៨០១ ទទួលឃុំឃាំងជនដែលត្រូវគេសង្ស័យថាបាន ប្រព្រឹត្តបទល្មើសតូចតាចនៅពេលដែលជនណាប្រព្រឹត្តបទល្មើសស្រាលៗ ត្រូវគេបញ្ជូនពីអូរកន្សែងទៅទីនោះ។

៥៨៨- ដោយផ្អែកលើព័ត៌មានបានទទួលពីអ្នកន្សែង និងប្រភពផ្សេងទៀត កងពលធំ៨០១ បានរៀបចំរបាយការណ៍នានា ផ្ញើទៅ សុន សេន។ របាយការណ៍ទាំងនេះ បាននិយាយពីការកើតមាននូវបណ្ដាញខ្មាំងនៅក្នុងកងវរសេនាធំផ្សេង ហើយក៏បានសរសេរពីការតាំងចិត្តរបស់ពួកគេចំពោះ គោលនយោបាយក្នុងការចាប់ខ្លួន "ជនណាក៏ដោយដែលត្រូវគេសង្ស័យថាជាខ្មាំង"។ ការឆ្លងឆ្លើយបែបនេះ ក៏មានបង្ហាញពីរបៀបនៃការចាត់ចែងជនទាំងឡាយដែលអប់រំហើយ មិនស្ដាប់ត្រូវមានវិធានការ"ដកទុកមួយដុំតាមដាន"។ ការឆ្លងឆ្លើយបន្ថែមទៀត ពីគណៈកងពលធំ៨០១ដែលបានស្នើសុំសេចក្ដីសម្រេចស្ដីអំពី ថាតើត្រូវដកកម្មាភិបាលមួយចំនួន ឬយ៉ាងណា ដែលមិនគោរពទៅតាមមាគ៌ាបក្សឲ្យបានខ្ជាប់ខ្ជួន។ ការិយាល័យសេនាធិការធំត្រូវបានតម្រូវបញ្ជូនទៅអង្គការនូវរបាយការណ៍ទាំងអស់ដែល សុន សេន បានទទួលពីកងពល៨០១។

៥៨៩- សកម្មភាពទូទៅដែលកើតមាននៅក្នុងភូមិភាគឦសាន ត្រូវបានរាយការណ៍ទៅមជ្ឈិមបក្សក្នុងទូរលេខដែលផ្ញើទៅជូនអង្គការ។ សន្ដិសុខតំបន់នៃភូមិភាគឦសានដែលមានជាប់ពាក់ព័ន្ធជាក់ស្ដែងនឹងតំបន់១០១នោះ គឺជាប្រធានបទនៃការឆ្លងឆ្លើយរវាងកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្ដកម្ពុជា។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៥៩០- អ្នកន្សែងមានការចាប់ខ្លួនខ្មាំងរបស់បក្សកុម្មុយនីស្ដកម្ពុជាជាច្រើនប្រភេទ ប៉ុន្តែពីដំបូងឡើយ "មន្ទីរនេះត្រូវបានបង្កើតក្នុងពេលមានសភាពការច្របូកច្របល់របស់ចលនាខ្មាំងផ្ទៃក្នុង" "ដាក់អ្នកទោសដែលជាទាហាននៃកងពលធំ៨០១"។ នៅក្នុងពេលមានប្រតិបត្តិការរបស់ខ្លួន ចំនួន

ជនជាប់ឃុំឃាំងដែលនៅ អូរកន្សែងមានកម្រិតខុសៗគ្នាទៅតាមពេលវេលា ប៉ុន្តែបរិវេណគុកផ្ទាល់អាចផ្ទុកអ្នកទោសរហូត ដល់ជាង២០០នាក់។ ក្នុងអំឡុងឆ្នាំ១៩៧៦ មានអ្នកទោសប្រមាណជា៤០នាក់ នៅក្នុង ឆ្នាំ១៩៧៧ មានអ្នកទោសចន្លោះពី៧០ ទៅ២០០នាក់ និងគិតត្រឹមឆ្នាំ១៩៧៨ មានអ្នកទោសយ៉ាងហោចណាស់ចំនួន១០០នាក់។ ប៉ុន្តែ អូរកន្សែង ក៏អាចទទួលយកអ្នកទោសក្នុងចំនួន ច្រើនបានដែរ ដូចដែលធ្លាប់មានរួចមកហើយចំពោះជនជាតិចារ៉ាយ ដែលមានចំនួនពី១០០ ទៅ២០០នាក់ ដែលត្រូវឃុំខ្លួនរយៈពេលខ្លីនៅក្នុង មន្ទីរសន្តិសុខ មុនពេលត្រូវគេសម្លាប់។

៥៩១- ទាហានដែលត្រូវចាប់ខ្លួន ត្រូវបានគេហៅថា"សមាសភាពសេរី" និងត្រូវគេសង្ស័យថាបានរិះគន់ ដែលត្រូវគេចោទថាបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបក្ស។ អ្នកទោសគុកអូរកន្សែងបានកើនឡើងទៅតាមពេល ដោយរួមបញ្ចូលទាំងពលករមកពីសហករណ៍ និងចំការកៅស៊ូមកពីតំបន់១០១ ដែលត្រូវចាប់ខ្លួនពីដំបូងដោយសហករណ៍របស់ពួកគេ ឬប្រធានសហជីព។ ប៉ុន្តែ អូរកន្សែងបានបន្តប្រើប្រាស់ជាកន្លែងសម្រាប់បោសសម្អាតកម្មាភិបាលយោធាកងពលធំ៨០១។ អ្នកជាប់ឃុំដទៃទៀត រួមមានជនជាតិភាគតិចចារ៉ាយ និងជនបរទេសដូចជាទាហានវៀតណាមជាដើម។

៥៩២- ការសម្រេចថាតើ នរណាត្រូវចាប់ខ្លួននោះ គឺតាមរយៈការពាក់ព័ន្ធដែលមាននៅក្នុងចម្លើយសារភាព ជាពិសេសចម្លើយសារភាពដែលមកពីភ្នំពេញ។ អ្នកទោសថ្មីមានមកជារៀងរាល់ថ្ងៃ ហើយ ការចាប់ខ្លួនទាហានកងពលធំ៨០១ ត្រូវបានធ្វើឡើងដោយទាហានដែលស្ថិតនៅក្នុងអង្គភាព នីមួយៗ។ អ្នកទោសដែលមិនមែនជាយោធា ត្រូវបានចាប់ខ្លួនដំបូងដោយ

ប្រធានសហករណ៍ ឬប្រធានសហជីព។ មានពេលមួយនោះ ជនជាតិចាវ៉ាយមួយក្រុមធំដែលត្រូវទាហានកងពលធំ៨០១ចាប់ខ្លួនជារួម និងឃុំខ្លួននៅអូរកន្សែង។ អ្នកទោសក៏ត្រូវបានគេចាប់ខ្លួន និងឃុំតាមអំពើចិត្តទៅតាមកំហុសផ្សេងៗ ដូចជាត្រូវគេសង្ស័យថាជាខ្មាំងនយោបាយ ជាប់ខ្សែរយៈ សេអ៊ីអា ឬលួចផ្លែឈើពីកន្លែងខ្លួនស្នាក់នៅជាដើម។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៥៩៣- អ្នកទោសអូរកន្សែងត្រូវគេឃុំខ្លួនក្នុងស្ថានភាពរស់នៅគួរឱ្យភ័យខ្លាច។ បន្ទប់ឃុំឃាំងមានទំហំ៤ម៉ែត្រគុណ៦ម៉ែត្រ និងមានមនុស្សជាប់ឃុំយ៉ាងច្រើន។ អ្នកជាប់ឃុំឃាំងដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ត្រូវគេដាក់ខ្នោះជើងនៅនឹងដែករនុកជាប់នឹងកជើង ដោយក្នុងមួយជួរមានអ្នកទោសចំនួនរហូតដល់១០នាក់។ អ្នកទោសមួយចំនួន ត្រូវគេដាក់ច្រវ៉ាក់ក្នុងរយៈ ពេល៣ខែ ហើយត្រូវគេហាមមិនឱ្យឈរ ដើរ ឬធ្វើចលនាឡើយ។ ប៉ុន្តែ គេអនុញ្ញាតឱ្យអ្នកទោសស្រាលងូតទឹកនៅក្នុងអូរក្បែរនោះក្រោមការត្រួតពិនិត្យរបស់អ្នកយាម។ អ្នកជាប់ឃុំឃាំងដេកផ្ទាល់នៅលើកម្រាលឫស្សី ហើយការដាក់ខ្នោះជើងធ្វើឱ្យស្ថានភាព ដេកពួនរបស់ពួកគេកាន់តែពិបាកថែមទៀត។

៥៩៤- របបអាហារមិនគ្រប់គ្រាន់។ មានករណីស៊ីសាច់មនុស្សបានកើតមាននៅអូរកន្សែង ដោយអ្នកទោសបានយករំពាត់ឫស្សី អាររសាច់សពអ្នកទោសដើម្បីធ្វើជាអាហារ។ មានអ្នកទោសជាច្រើនធ្លាក់ខ្លួនចុះស្គមកំព្រឹង ហើយស្លាប់ដោយអត់ឃ្លាន ដែលជាហេតុបង្កឱ្យមានជម្ងឺ

ផ្សេងៗ។ អ្នកជាប់ឃុំឃាំងផ្សេងទៀត ដែលស្លាប់ដោយសារការថែទាំជំងឺមិនបានជិតដល់ ដូចជា ការខ្វះជាតិស្ករដែលអាចការពារយ៉ាងស្រួលបើមានការផ្គត់ផ្គង់អាហារត្រឹមត្រូវ។ អ្នកទោសត្រូវគេបង្ខំ ឱ្យបន្ទោរបង់នៅក្នុងបំពង់ឫស្សី និងបន្ទោរបង់លាមកនៅក្នុងឆ្នាំងមានដាក់ផេះដែលគេរក្សានៅក្នុងបន្ទប់ឃុំឃាំងគ្រប់ពេលវេលា។ ជំងឺរាកមូល គឺបានកើតឡើងជាទូទៅក្នុងចំណោមអ្នកទោសទាំងអស់ ប៉ុន្តែអ្នកទោសមិនបានទទួលថ្នាំសង្កូវ ឬការព្យាបាលសម្រាប់ជំងឺនេះ ឬជំងឺផ្សេងៗទៀតឡើយ។ ការដាក់ខ្នោះជើងជាប់គ្រប់ពេលវេលាបានបណ្តាលឱ្យអ្នកទោសមានជំងឺផ្សេងៗដូចជា ស្លឹកស្រពន់ និងហើមជើងទាំងសងខាងជាដើម។ ដូច្នេះកង្វះខាតការថែទាំបែបវេជ្ជសាស្ត្រនៅអូរកន្សែងបណ្តាលឱ្យអ្នកទោសស្លាប់ដោយសារតែជំងឺដែលអាចព្យាបាលបាន និងការពារបាន។ លក្ខខណ្ឌលំបាកអស់ទាំងនេះ បណ្តាលឱ្យអ្នកទោសជាច្រើនធ្វើអត្តឃាតដោយចងក។

## ពលកម្មដោយបង្ខំ

៩៩៥- ការធ្វើពលកម្មដែលលំបាកក្រៃលែង ត្រូវបានដាក់បង្ខំទៅលើអ្នកទោសអូរកន្សែង។ អ្នកជាប់ឃុំឃាំងត្រូវបង្ខំឱ្យលីឈើធ្ងន់ៗ ធ្វើស្រែ លើកទំនប់ទឹក និងភ្ជួរស្រែ ដាំដំឡូង និងដាំបន្លែបង្ការផ្សេងៗទៀត។ អ្នកទោសត្រូវធ្វើការ០៧ថ្ងៃក្នុងមួយសប្តាហ៍ ពីម៉ោង៧ព្រឹក ដល់ម៉ោង៥ល្ងាច ដោយមានពេលសម្រាកសម្រាប់អាហារថ្ងៃត្រង់តែមួយម៉ោងប៉ុណ្ណោះ។ នៅពេលកំពុងធ្វើការ អ្នកជាប់ឃុំឃាំងមានអ្នកយាមដែលប្រដាប់ដោយអាវុធ នៅឃ្លាំមើលរហូត។ ក្រៅពីការខ្វះខាតឧបករណ៍ប្រើប្រាស់សម្រាប់ឱ្យអ្នកទោសការពារខ្លួនមិនឱ្យមុតបន្លា និងហើមដៃ ដោយសារតែធ្វើការឬសកំណាត់នោះ អ្នកជាប់ឃុំឃាំងខ្លាចរអារមិនហ៊ានត្អូញ

ក្នែរពីស្ថានភាពការងារឡើយ។ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវបានហាមឃាត់យ៉ាងមានប្រសិទ្ធិភាព។

## ការសួរចម្លើយ និងការធ្វើទារុណកម្ម

៥៩៦- អ្នកទោសនៅអូរកន្សែងត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្មក្នុងលក្ខណៈជាប្រព័ន្ធ។ គោលបំណងនៃការសួរចម្លើយ និងការធ្វើទារុណកម្ម គឺដើម្បីស្វែងរកខ្មាំងខាងក្រៅ និងខាងក្នុង។ ក្នុងពេលកំពុងសួរចម្លើយ អ្នកទោសត្រូវគេសួរពីជីវប្រវត្តិ និងពីស្ថានការណ៍នៃការចាប់ខ្លួនរបស់ពួកគេ។ ទារុណកម្មត្រូវបានប្រើ ប្រសិនបើអ្នកសួរចម្លើយសង្ស័យថាអ្នកទោសមិនបានឆ្លើយដោយស្មោះត្រង់ ឬលាក់លៀមព័ត៌មានពាក់ព័ន្ធ។ វិធីសាស្ត្រធ្វើទារុណកម្មជាក់លាក់មួយចំនួន រួមមានវាយនឹងព្រនង់ ឬរំពាត់ និងឆក់ខ្សែភ្លើង។ អ្នកទោសត្រូវបញ្ជូនត្រឡប់ទៅវិញដោយមានស្លាកស្នាម និងឈាម។ អ្នកទោសមួយចំនួន បានឃើញផ្ទាល់ភ្នែកនូវការសួរចម្លើយ និងអ្នកទោសផ្សេងៗទៀត បានឮសម្រែកអ្នកទោសស្រែកដែលគេវាយសួរចម្លើយ។

៥៩៧- ក្រោយពីមកដល់អូរកន្សែងបន្តិចមក អ្នកទោសត្រូវគេយកទៅសួរចម្លើយ ការសួរចម្លើយ និងទារុណកម្មត្រូវបានប្រព្រឹត្តឡើងដោយអ្នកសួរចម្លើយ និងមានអ្នកយាមជាអ្នកជួយសួរផងដែរ នៅក្នុងអគារស្ថិតនៅក្នុងព្រៃមួយដែលមានទីតាំងនៅក្នុងបរិវេណគុក។ របាយការណ៍ត្រូវបានព្រាងដោយប្រធានអ្នកសួរចម្លើយ រួចហើយបញ្ជូនទៅឲ្យប្រធានមន្ទីរសន្តិសុខដែលនឹងបញ្ជូនរបាយការណ៍ទាំងនោះបន្តទៅមេបញ្ជាការកងពលធំ នៅពេលដែលរកឃើញខ្មាំងផ្ទៃក្នុង។

៥៩៨- [redacted] បាន កាន់ចម្លើយសារភាពដែលដកស្រង់ពីភ្នំពេញដោយផ្ទាល់ទៅអូរកន្សែង។ [redacted] គឺជាអ្នកសួរចម្លើយមកពី [redacted] ដែលបានទទួលការចាត់តាំងឱ្យចូលរួមនៅក្នុងការសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោសនៅអូរកន្សែង។ បន្ថែមលើនេះទៀតចម្លើយសារភាពមកពីភ្នំពេញ ត្រូវបញ្ជូនទៅមេបញ្ជាការកងពលធំឈ្មោះសារឿន រួមបន្ទាប់មក សារឿន នឹងបញ្ជូនចម្លើយសារភាពទាំងនោះទៅតាមកងអង្គភាពដែលមានបុគ្គលពាក់ព័ន្ធទាំងអស់។ ចម្លើយសារភាពទាំងនោះមានការណែនាំដែលសរសេរជាទឹកប៊ិចពណ៌ក្រហម បញ្ជាក់ពីកម្មាភិបាលដែលជាប់ពាក់ព័ន្ធនឹងត្រូវចាប់ខ្លួន ព្រមទាំង"ត្រួតពិនិត្យដោយសារតែពួកគេគឺជាភ្នាក់ងារ នៅក្នុងបណ្ដាញ"។ នៅពេលចាប់ខ្លួនរួចហើយបុគ្គលទាំងនោះ នឹងត្រូវយោធាកងពលតូចដែលជាអ្នកចាប់ខ្លួនយកទៅអូរកន្សែងជាមួយនឹងចម្លើយសារភាព។

៥៩៩- ការចូលរួមចំណែករបស់មជ្ឈិមបក្សនៅក្នុងការចាប់ខ្លួន និងការត្រួតពិនិត្យការចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន គឺត្រូវបានបញ្ជាក់ដោយឯកសារសហកាលផ្សេងៗជាច្រើន។ ប៊ូ ខាវ ជាលេខាស្រុក កុកឡាក់ នៅតំបន់១០១ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៧។ ឯកសារបង្ហាញថា សុន សេន បានទំនាក់ទំនងជាមួយប្រធានមន្ទីរស-២១ ឌុច ពាក់ព័ន្ធនឹង ប៊ូ ខាវ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៧ ពីរសប្ដាហ៍មុនពេលគាត់ត្រូវចាប់ខ្លួន។ បន្ទាប់ពីការចាប់ខ្លួនរបស់គាត់ [redacted] បានកោះប្រជុំមួយជាមួយកម្មាភិបាលមូលដ្ឋាន ដោយបានប្រាប់ពួកគេថា ប៊ូ ខាវ មានទំនាក់ទំនងជាមួយពួកវៀតណាម ហើយប្រសិនបើពួកគេធ្វើខ្លួនដូចជា ប៊ូ ខាវ ពួកគេនឹងត្រូវគេសម្លាប់ចោល។ ប៉ុន្មានសប្ដាហ៍

ក្រោយមក មនុស្សដែលជា"ខ្សែរយៈ"របស់ ប៊ូ ខាវ ក៏ត្រូវចាប់ខ្លួន និងសួរចម្លើយនៅតំបន់១០១ (ត្រូវគេសន្មតថានៅអូរកន្សែង) និងលទ្ធផលត្រូវគេរាយការណ៍ទៅមជ្ឈិមបក្ស។ លេខាកងពលធំ៨០១បានរាយការណ៍ថា ពួកគេបាន"តាមដាន"ពួក"ខ្មាំងឆ្អើយដាក់" និងអ្នក"ទំនាស់នឹងមាគ៌ាបក្ស"។

## ការសម្លាប់មនុស្សក្រៅច្បាប់

៦០០- បន្ទាប់ពីបញ្ជូនសំណើសុំការសម្រេចចំពោះបុគ្គលមួយចំនួនមក ប្រធាននឹងទទួលបានការផ្ដល់សិទ្ធពីមេបញ្ជាការកងពលធំ ឬអនុលេខាភូមិភាគដើម្បីសម្លាប់អ្នកទោស។ បន្ទាប់មកអ្នកយាមត្រូវគេបញ្ជាឲ្យ"កម្ទេច"អ្នកទោសដែលត្រូវបានគេចាត់ទុកថាជាខ្មាំង។ អ្នកទោសដែលត្រូវបានគេជ្រើសរើសយកទៅសម្លាប់ ត្រូវគេយកចេញទៅទាំងដៃជាប់ចំណង និង/ឬចងមុខបិទជិត។ ការសម្លាប់ត្រូវបានប្រព្រឹត្តទៅនៅទីពិឃាត និងរណ្ដៅសាកសព ដែលស្ថិតនៅក្បែរនោះដែលមានរណ្ដៅបេ-៥២ និងអតីតលេណដ្ឋានយោធាដែលសល់ពីមុនចំនួន១០។ ទីតាំងទាំងនេះស្ថិតនៅប្រមាណ១៥០ម៉ែត្រពីការដ្ឋានអ្នកទោសធ្វើការ និងមានរណ្ដៅបន្ថែមមួយទៀតស្ថិតនៅក្នុងបរិវេណមន្ទីរសន្តិសុខជិតច្រកចេញទិសអាគ្នេយ៍។

៦០១- នៅពេលទៅដល់ទីកន្លែងពិឃាត អ្នកជាប់ឃុំឃាំងត្រូវគេសម្លាប់ ដោយត្រូវគេសំពងនឹងចបកាប់ ឬបាញ់ចំពីក្រោយក្បាល។ មានពេលខ្លះ អ្នកទោសដែលនៅសល់ ត្រូវគេបញ្ជាឲ្យកប់សាកសពអ្នកដែលគេសម្លាប់រួចហើយ។ ការសម្លាប់អ្នកទោសបានប្រព្រឹត្តទៅជាហូរហែរ ដោយអ្នកទោសចាស់ៗត្រូវបាត់ខ្លួន ស្របពេលដែលអ្នកទោសថ្មីមកដល់ជារៀងរាល់ថ្ងៃ។ ការ

សម្លាប់ក៏មានពាក់ព័ន្ធនឹងអ្នកទោសក្នុងចំនួននឹងសមាសភាពដ៏ច្រើនផងដែរ ដូចជា មានអ្នកជាប់ឃុំឃាំងជាជនជាតិចាវ៉ាយលើសពី១០០នាក់ជាដើម។

៦០២- ការសម្លាប់អ្នកទោសបានកើតមានតាមមធ្យោបាយផ្សេងៗទៀតនៅអូរកន្សែង។ អ្នកយាមអាចសម្លាប់អ្នកទោសមួយណាក៏បានដែលធ្វើខុសវិន័យ ដូចជាព្យាយាមរត់គេច ឬលួចម្ហូបអាហារជាដើម។ អ្នកទោសស្ត្រីម្នាក់ត្រូវគេកាប់ចិញ្ច្រាំរះពីខ្នង ហើយគេយកថង់ប្រមាត់ ទៅព្យួរនៅចង្ក្រានបាយដើម្បីព្រមានដល់អ្នកទោសឯទៀត។ អ្នកខ្លះបានធ្វើការប៉ាន់ស្មានថា ចំនួនមនុស្សដែលត្រូវគេសម្លាប់នៅអូរកន្សែងមានចំនួនរាប់រយនាក់ ក្នុងពេលដែលមានការសម្លាប់រួមយ៉ាងហោចណាស់ក៏មានជនជាតិចាវ៉ាយ១០០នាក់ដែរសម្រាប់មួយដង ដែលនេះបញ្ជាក់ថាមានចំនួនមនុស្សស្លាប់ច្រើនជាងនេះ។ យ៉ាងហោចណាស់មានទីតាំងរណ្តៅសាកសពដែលគេសង្ស័យចំនួនពីរកន្លែងត្រូវបានគេកំណត់អត្តសញ្ញាណ និងនៅមានទីតាំងរណ្តៅសាកសពដែលគេសង្ស័យផ្សេងៗទៀត ដែលមានសំណល់ឆ្អឹងមនុស្សជាភស្តុតាង ត្រូវបានគេរកឃើញនៅជិតអូរកន្សែង។

៦០៣- ហេតុការណ៍ដែលមានទាហានចាវ៉ាយរាប់រយនាក់មកពីវៀតណាមត្រូវគេចាប់ខ្លួន ត្រូវបានរាយការណ៍ ទៅមជ្ឈិមបក្សដែលជាអ្នកចេញបញ្ជាឱ្យគេសម្លាប់ពួកគេអស់ទាំងនោះនាពេលក្រោយមក។ ទូរលេខចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ផ្ញើទៅឱ្យ ប៉ុល ពត **នួន ជា** និង **អៀង សារី** ពី [redacted] បានផ្តល់សេចក្តីលំអិតពីការចាប់ខ្លួន និងឃុំខ្លួនទាហានយួនចំនួន២០៩នាក់របស់កងពលធំ៨០១ ដែលអ្នកទាំងអស់សុទ្ធតែជាជនជាតិចាវ៉ាយ ក្នុងនោះមានស្ត្រីចំនួន៩នាក់ ព្រមទាំងមានការសម្រេចដែលបានស្នើសុំពីសកម្មភាពដែលត្រូវដាក់ចេញ បន្ទាប់ពី

អ្នកទោសត្រូវបានគេសួរចម្លើយរួច។ ដោយផ្អែកលើ[redacted] វាបង្ហាញឱ្យឃើញថាអ្នកទោសជនជាតិចាវ៉ាយមួយចំនួនធំដែលនេះត្រូវគេយកទៅអូរកន្សែង បន្ទាប់ពីពួកគេត្រូវបានសួរចម្លើយរួចហើយសម្លាប់ចោល។ ការបញ្ជាឱ្យសម្លាប់គឺចេញមកពីមន្ទីរភូមិភាគ ដែលជាការពិភាក្សារវាងអនុលេខាភូមិភាគ តា ឡាវ និងមេបញ្ជាការកងពលធំ សារឿន រួចបន្ទាប់មកក៏ផ្ញើបញ្ជានោះទៅ[redacted]។ ការសម្លាប់រង្គាលទៅលើអ្នកទោសជនជាតិចាវ៉ាយទាំងនេះ ធ្វើឡើងនៅពេលយប់ ដែលមានរណ្តៅបេ-៥២ប្រហែល៣ ដោយមានទាំង បុរស ស្ត្រី និងកុមារ ដែលត្រូវគេយកទៅទាំងបិទមុខ និងដៃជាប់ចំណង។

**មន្ទីរសន្តិសុខវត្តគីរីវង្ស**

៦០៤- ក្នុងផ្នែកនេះផ្តល់នូវការវិភាគពីភស្តុតាងពាក់ព័ន្ធនឹងវត្តគីរីវង្ស ជាមន្ទីរសន្តិសុខ និងទីពិឃាត ព្រមទាំងការចោទប្រកាន់ដែលពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនដូចតទៅនេះ៖

(១). ការប្រើប្រាស់ទីតាំងចន្លោះក្តោងដែលជាកន្លែងមួយនៅជិតវត្តគីរីវង្ស ជាទីពិឃាត និងកន្លែងកប់សាកសព និងជាមន្ទីរឃុំឃាំង។

(២).សកម្មភាព តា ឆាំ ជាអនុលេខាស្រុកដែលទទួលខុសត្រូវក្នុងតំបន់នោះ ដោយគាត់ត្រូវគេចោទប្រកាន់ថាបានទាក់ទងប្រតិបត្តិ និងអនុវត្តនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរួមទាំងគោលនយោបាយកម្ទេចជនដែលត្រូវគេសង្ស័យថាជាខ្មាំងផងដែរ។

**ទីតាំង និងប្រតិបត្តិការ**

## មន្ទីរសន្តិសុខ និងទីពិឃាតវត្តគីរីរម្យ

៦០៥- មន្ទីរសន្តិសុខនេះមានទីតាំងស្ថិតនៅក្នុងវត្តគីរីរម្យ ភូមិភ្នំសំពៅ ស្រុកភ្នំសំពៅ (សព្វថ្ងៃគឺស្រុកបាណន់ ខេត្តបាត់ដំបង) តំបន់៣ ភូមិភាគពាយ័ព្យ។ ក្នុងពេលដែលមន្ទីរនេះ បានដំណើរការរហូតដល់ប៉ុន្មានថ្ងៃចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីបានបញ្ជាក់ពីភាពខុសគ្នាថាតើមន្ទីរនេះបានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ១៩៧៥ ឬឆ្នាំ១៩៧៦។

៦០៦- មន្ទីរមានទីតាំងស្ថិតនៅលើកំពូលភ្នំគីរីរម្យ ដែលមានទីតាំងស្ថិតនៅក្នុងវត្ត ជាទីជម្រកសម្រាប់ព្រះសង្ឃចំនួន៥០អង្គ និងដូនជីចំនួន៧០នាក់។ គេអាចចូលទៅដល់ទីតាំងនោះ ដោយប្រើ"ជណ្តើរស"។ នៅក្បែរផ្នែកខាងលើបំផុតនៃជណ្តើរ មានល្អាងបីខុសៗគ្នា (ល្អាងតែងខ្លួន ល្អាងល្ខោន និងល្អាងកង្កែប)។

## មន្ទីរសន្តិសុខចន្លោះក្តោង

៦០៧- មន្ទីរសន្តិសុខនេះត្រូវបានសាងសង់ឡើងក្នុងចន្លោះឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ នៅជ្រលងភ្នំចន្លោះភ្នំសំពៅ និងភ្នំក្តោង ប្រមាណជា៣០០ម៉ែត្រ ពីជើងភ្នំវត្តគីរីរម្យ។ តាមរយៈសាក្សីមួយចំនួនដែលបានសង្កេតទីតាំងពីខាងក្រៅ មន្ទីរនេះមានអ្នកយាមប្រមាណ១០នាក់ ហើយផ្ទៃដីមន្ទីរត្រូវបានហ៊ុំព័ទ្ធទៅដោយរបងលួសបន្លា។ នៅលើផ្ទៃនោះ អ្នកទោសត្រូវគេដាក់នៅក្នុងបន្ទប់ធំមួយដែលមានលក្ខណៈស្រដៀងនឹងរោងជាង ដោយមានប្រក់ដំបូលស័ង្កសី។

## រចនាសម្ព័ន្ធគ្រប់គ្រង

## ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៦០៨- នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ វត្តគីរីរម្យត្រូវ តា ឆាំ ជាអ្នកគ្រប់គ្រង ដែលមនុស្សនៅក្នុងតំបន់ជាច្រើនជឿជាក់ថាគាត់គឺជាលេខាស្រុកភ្នំសំពៅនាពេលនោះ តាមពិតគាត់ជាអនុលេខាស្រុកភ្នំសំពៅក្នុងទៅវិញទេ។ ហឿន គឺជាលេខាស្រុកភ្នំសំពៅក្នុង ដែលជាស្រុកពិសេសមួយស្ថិតក្នុងស្រុកភ្នំសំពៅក្រៅ។ ដោយសារមានការបោសសម្អាតនៅភូមិភាគពាយ័ព្យដែលធ្វើឡើងដោយកម្មាភិបាលនិរតីក្នុងឆ្នាំ១៩៧៧-១៩៧៨ ហឿន និង ឆាំ ក៏ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ [redacted]។ នៅក្នុងអំឡុងពេលនោះ លេខាស្រុកភ្នំសំពៅក្រៅ កើត ព្រំ *ហៅ* ប៊ា ត្រូវគេចាប់ខ្លួន និងជំនួសដោយអនុរបស់គាត់ឈ្មោះ ហែម មិ ដែលគាត់ត្រូវបានគេបោសសម្អាតដែរ ក្នុងខែមិថុនា ឆ្នាំ១៩៧៨។

៦០៩- គណៈឃុំភ្នំសំពៅមាន [redacted] គឺជាអនុម្នាក់របស់ តា ឆាំ។ តា ភ្លី ត្រូវគេស្គាល់ថាជា តា ឌុច ភ្លី ជាអ្នកទទួលបន្ទុកមើលខុសត្រូវយុវជននៅក្នុងស្រុក។ [redacted]បានចូលរួមពាក់ព័ន្ធយ៉ាងហោចណាស់ក៏ក្នុងការសម្លាប់ជាចំហរមួយលើកដែលធ្វើឡើងដោយ តា ឆាំ។

៦១០- គណៈស្រុកភ្នំសំពៅបានរាយការណ៍ទៅតំបន់៣។ គោគ សារី *ហៅ* តុំ គឺជាលេខាតំបន់៣ រហូតដល់ពេលដែលគាត់ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៧៨ នាដំណាក់កាលចុងក្រោយនៃការបោសសម្អាតភូមិភាគពាយ័ព្យ។

## រចនាសម្ពន្ធក្នុងមន្ទីរសន្តិសុខ

៦១១- ដោយកិច្ចស៊ើបអង្កេតតុលាការមិនបញ្ជាក់ពីអត្តសញ្ញាណអ្នកទោស ទាហាន ឬកម្មាភិបាលដែលនៅរស់រានជីវិតនៅក្នុងវត្តគីរីរម្យ ឬចន្លោះក្តោង គេមិនបានស្គាល់ពីរចនាសម្ព័ន្ធគ្រប់គ្រងស្ថិតនៅក្នុងទីតាំងនោះទេ។

## ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៦១២- នៅក្នុងអំឡុងពេលកាន់តំណែងរបស់គាត់ ឆាំ តែងតែទៅត្រួតពិនិត្យមើលការដ្ឋាន និងរោងជាងនៅក្នុងស្រុក និងបានចាត់អង្គប្រជុំរួមជាច្រើនដង ដែលមានការចូលរួមពីអ្នកក្រោមបង្គាប់របស់គាត់ [redacted] ដើម្បីធ្វើការបែងចែកទិសដៅ ដែលបក្សកុម្មុយនីស្តកម្ពុជាបានដាក់ចេញ ដូចជា ត្រូវ"ដាច់ខាតជាមួយអង្គការ" និងកម្ទេចខ្មាំង និងខ្មាំងស៊ីរូងផ្ទៃក្នុង។ មានអង្គប្រជុំមួយចំនួនត្រូវបានធ្វើឡើង បន្ទាប់ពីបាន"រកឃើញ"ខ្មាំង។ [redacted] ក៏បានដឹកនាំអង្គប្រជុំដែរ ដោយគាត់បានបញ្ជាក់ថា នរណាក៏ដោយដែលមិនស្តាប់បង្គាប់អង្គការនឹងត្រូវកម្ទេចចោល។

៦១៣- ទិសដៅរបស់អង្គការ ក៏ត្រូវបានគេផ្សព្វផ្សាយទៅថ្នាក់ក្រោមនៃឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជាផងដែរ។ នៅ ថ្នាក់ស្រុក [redacted] ទទួលបន្ទុកមេភូមិ និងអ្នកមើលខុសត្រូវការដ្ឋាន

ឧទាហរណ៍ ចេញបញ្ជាឲ្យសាក្សីមួយរូបឲ្យតាមដានប្រជាជននៅក្នុងក្រុមការដ្ឋានការងាររបស់ខ្លួន និងរាយការណ៍ខ្លាំងបង្កប់ទៅឲ្យគាត់។ មេកង និងមេក្រុម ត្រូវគេតម្រូវឲ្យទៅរៀនសូត្រទស្សនាវដ្ដីទង់បដិវត្តន៍ និងផ្សព្វផ្សាយគោលនយោបាយទៅឲ្យកម្មាភិបាលទូទៅ ដូចជា សូមឲ្យលះបង់ដាច់ខាតចំពោះបដិវត្តន៍។ ការប្រជុំស្វ័យទិតៀនត្រូវបានប្រព្រឹត្តទៅសម្រាប់ពលករដែលនៅក្នុងអង្គប្រជុំនេះ គឺពង្រឹងខ្លឹមសារដែលថាប្រជាជនដែល“ខ្ជិល” និង“ខុសសីលធម៌” និងអ្នកដែល“ឈឺច្រើន” នឹងត្រូវកម្ទេចចោល។

៦១៤- នៅថ្នាក់ខ្ពស់ៗនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យបានទទួលរបាយការណ៍ជាច្រើនពីតំបន់៣ និងបានជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅឲ្យមជ្ឈិមបក្ស ដោយរៀបរាប់ក្នុងចំណោមនោះ នូវអត្តសញ្ញាណដើម្បីការស្វែងរកខ្មាំងផ្ទៃក្នុងរបស់កម្មាភិបាលមូលដ្ឋាន។ រស់ ញឹម លេខាភូមិភាគពាយ័ព្យបានចុះទៅត្រួតពិនិត្យភូមិ និងស្រុក ដើម្បីនិយាយទៅកាន់កម្មាភិបាលនាឱកាសជាច្រើន និងបានដឹកនាំអង្គប្រជុំរួមដើម្បីផ្សព្វផ្សាយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងខែមេសា ឆ្នាំ១៩៧៧ នៅក្នុងអង្គប្រជុំរួមមួយ ដែលមានវត្តមានចូលរួមពីសំណាក់កម្មាភិបាលជាន់ខ្ពស់ដូចជា [redacted] តា ឆាំ និង [redacted] គាត់បានលើកសរសើរអង្គការថ្នាក់លើ និងអំពាវនាវសុំឲ្យកម្ទេចខ្មាំង។ ក្នុងខែឧសភា ឆ្នាំ១៩៧៨ ក្រោយពី“ជួបប្រជុំជាមួយអង្គការ”រួចមក រស់ ញឹម បានរាយការណ៍ថាគាត់បានព្យាយាមប្រតិបត្តិតាម“ការណែនាំរបស់មន្ទីរ៨៧០”តាមរយៈ“ការប្រុងប្រយ័ត្នខ្ពស់” ក្នុងការខិតខំប្រឹងប្រែង“កម្ទេចខ្មាំងល្អានពាន” និង“បោសសម្អាតសមាសភាពបំផ្លិចបំផ្លាញទាំងអស់ ឲ្យបានជោគជ័យ”។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

### វត្តគីរីរម្យ

៦១៥- នៅទីតាំងវត្តគីរីរម្យត្រូវបានគេបម្រុងទុកសម្រាប់អ្នកទោស ដែលត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្ត“បទល្មើស”ធ្ងន់ធ្ងរ។ សាក្សីមួយរូបបានបង្ហាញថា សមាជិកប្រជាជនមូលដ្ឋាន ដែលត្រូវគេចោទថាបានប្រព្រឹត្តបទល្មើសដូចជា មិនគោរពអង្គការ ត្រូវគេចាប់ខ្លួន និងយកទៅមន្ទីរសន្តិសុខ ហើយគេមិនដែលឃើញពួកគេទាំងនោះត្រឡប់មកវិញទេ។ បុគ្គលរូបនេះ បានឃើញផ្ទាល់ភ្នែកការចាប់ខ្លួនដោយសារបទល្មើសបែបនេះចំនួន២លើក និងបានបង្ហាញទៀតថាជនភៀសខ្លួនដែលស្ថិតនៅទីតាំងបង្ខំឲ្យធ្វើពលកម្មមូលដ្ឋាន ត្រូវគេគម្រាមកំហែង ដោយចាប់ខ្លួន និងយកទៅឡើង“ជណ្ដើរស”។

៦១៦- មានសាក្សីជាច្រើនបានឃើញអ្នកទោសជាក្រុម ត្រូវអ្នកយាមប្រដាប់ដោយអាវុធនាំយកទៅឡើងជណ្ដើរសនោះ។ សាក្សីម្នាក់ផ្សេងទៀត បានឃើញអ្នកទោសមកពីគុកចន្លោះក្ដោង (មានទាំងមនុស្សពេញវ័យ និងក្មេង) ត្រូវគេនាំឡើងទៅវត្តគីរីរម្យ ចំនួនប្រាំមួយលើក ផ្សេងៗគ្នា។ សាក្សីក៏បានឃើញ អ្នកទោសត្រូវគេនាំចុះពីភ្នំទៅមុជទឹកនៅក្នុងព្រែកជីក ជិតគុកចន្លោះក្ដោងផងដែរ។

### ចន្លោះក្ដោង

៦១៧- ចន្លោះក្ដោង គឺជាទីតាំងគុកមួយដែលបម្រុងទុកសម្រាប់តែបុគ្គលដែលត្រូវគេចោទប្រកាន់ពីកំហុសស្រាលៗ។ អ្នកដែលត្រូវគេតាមដានរកឃើញថាជា “អ្នកប្រព្រឹត្តកំហុសធ្ងន់ធ្ងរ” នឹងត្រូវ

បញ្ជូនទៅមន្ទីរសន្តិសុខវត្តគីរីរម្យ។ អ្នកទោសនៅចន្លោះក្តោង រួមមានទាំង បុរស ស្ត្រី និង កុមារ។ សាក្សីមួយចំនួនបានឃើញ អ្នកទោសមកដល់តាមរថយន្តដែលមានផ្ទុកមនុស្សពី៣ ទៅ៤នាក់ ឬយ៉ាងច្រើន១៤នាក់។ សាក្សីបានផ្តល់ការប៉ាន់ស្មានខុសៗគ្នា ពីចំនួនមនុស្ស ដែលត្រូវឃុំឃាំងតាមពេលវេលាខុសៗគ្នាពី១០ ទៅ២០នាក់ ចន្លោះពី៥០ ទៅ៦០នាក់ និង២០០នាក់។

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌-វត្តគីរីរម្យ

៦១៨- គ្មានភស្តុតាងផ្ទាល់អំពីស្ថានភាពដែលអ្នកទោសត្រូវគេឃុំខ្លួន នៅមន្ទីរសន្តិសុខវត្តគីរីរម្យនោះទេ។ ប៉ុន្តែភស្តុតាងរូបវ័ន្ត ត្រូវបានគេរកឃើញនៅទីតាំងនោះ ដូចមានរៀបរាប់នៅក្នុង ផ្នែក *សួរចម្លើយ និងទារុណកម្ម*ខាងក្រោមបានបង្ហាញថា អ្នកទោសត្រូវបានគេឃុំខ្លួនក្នុងស្ថានភាព អមនុស្សធម៌ ហើយត្រូវគេធ្វើទារុណកម្ម និងធ្វើបាបយ៉ាងព្រៃផ្សៃមុនពេលត្រូវគេសម្លាប់។

### លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ - ចន្លោះក្តោង

៦១៩- តាមរយៈការរៀបរាប់របស់សាក្សីមួយរូបដែលបានឃើញផ្ទាល់ គាត់បានឃើញអ្នកទោស ចន្លោះក្តោងស្ថិតក្នុងស្ថានភាពស្គមស្គាំង និងមើលទៅដូចជាទទួលរងការឈឺចាប់ ប៉ុន្តែដូចជាមិន បានឃើញគេដាក់ខ្នោះជើងនៅក្នុងបន្ទប់ធំ ដែលពួកគេត្រូវឃុំខ្លួននោះទេ។ សាក្សីបានរំឭក ឡើងវិញថា គាត់បានឃើញអ្នកទោសធ្វើការងារសាងសង់ ជីកប្រឡាយ សង់របង ចិញ្ចឹមជ្រូក និងគោ។

៦២០- ពីមួយពេលទៅមួយពេល អ្នកទោសត្រូវល្បួបនាំយកទៅមុជទឹកនៅក្នុងប្រឡាយនៅក្បែរនោះ។ សាក្សីបានរំឭកថាបានឃើញអ្នកយាម និងកូនរបស់ពួកគេ វាយ និងទាត់អ្នកទោស។ សាក្សីម្នាក់ទៀត បានឮអ្នកទោសនិយាយគ្នាពីការអស់សង្ឃឹមរបស់ពួកគេ។ អ្នកទោសមួយចំនួនធ្លាក់ខ្លួនឈឺ។ សាក្សីមួយរូបបានឃើញហេតុការណ៍ នៅពេលដែលអ្នកទោសបានព្យាយាមរត់គេចពីចន្លោះក្តោង ត្រូវអ្នកយាមដេញតាមទាន់ ហើយសម្លាប់ចោល។

## ការសួរចម្លើយ និងទារុណកម្ម

៦២១- លទ្ធផលនៃការស៊ើបអង្កេតមិនបានផ្តល់ភស្តុតាងផ្ទាល់ពាក់ព័ន្ធជាក់លាក់ ចំពោះការសួរចម្លើយ និងទារុណកម្មនៅទីតាំងទាំងពីរនោះទេ។ ប៉ុន្តែ សាក្សីមួយរូបបាននិយាយថា បានឮសម្រែករបស់ជនរងគ្រោះចេញពីវត្តគីរីរម្យ ក្នុងអំឡុងពេលមន្ទីរសន្តិសុខកំពុងមានប្រតិបត្តិការ។ បន្ទាប់ពីខែមករា ឆ្នាំ១៩៧៩ គេបានរកឃើញឧបករណ៍សម្លាប់ និង/ឬធ្វើទារុណកម្មជាច្រើននៅទីតាំងនោះដូចជា ដែកវែងៗស្រួចៗ របារដែកថែប ចបកាប់ កាំបិត ពូថៅដៃ ល្បួសបន្លា និងខ្នោះជើងជាច្រើន។ មានឧបករណ៍មួយចំនួននៅមានជាប់ប្រឡាក់ស្នាមឈាមនៅឡើយ។

## ការសម្លាប់មនុស្សក្រៅច្បាប់

### វត្តគីរីរម្យ

៦២២- វាហាក់បីដូចជាត្រូវគេបានដឹងយ៉ាងទូលំទូលាយ នៅក្នុងរយៈពេលដែលពាក់ព័ន្ធនេះថា វត្តគីរីរម្យ គឺជាទីតាំងគុក និងទីកន្លែងដែលអ្នកទោសត្រូវគេសម្លាប់ដោយមិនបានជំនុំជម្រះក្តី។

៦២៣- បន្ថែមលើភស្តុតាងដែលមានរៀបរាប់នៅក្នុង *ផ្នែកសួរចម្លើយ និងទារុណកម្ម* ភស្តុតាងរូបវ័ត្ថុដែល សាក្សីបានរកឃើញនៅលើទីតាំងនេះ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរំលំនោះ រួមមាន ស្នាមខ្នងនៅលើជញ្ជាំងព្រះវិហារ ដែលជាក់ស្តែងត្រូវបានគេប្រើសម្រាប់បង្ហូរទឹក និងមានស្នាមបង្ហូរឈាម សាកសពមនុស្សជាច្រើនដែលស្ថិតក្នុងសភាពរលួយជាច្រើនដំណាក់កាលនៅក្នុងរូងភ្នំ និងនៅក្នុងបរិវេណជាប់គ្នានោះ និងសាកសពផ្សេងៗទៀត នៅក្នុងអាងស្តុកទឹក ឬព្យួរលើល្ហសបន្លា។ ក្នុងករណីដែលយ៉ាងហោចណាស់ មានជនរងគ្រោះម្នាក់ត្រូវគេចងដៃទៅក្រោយ។

៦២៤- សាកសពមានទាំងបុរស ស្ត្រី និងកុមារ។ មានសាក្សីមួយចំនួន បានឃើញសាកសពកុមារត្រូវគេដោតជាប់នឹងមែកឈើនៅតាមផ្លូវចុះទៅល្អាងល្ខោន។ គេមិនបានដឹងពីតួលេខពិតប្រាកដនៃចំនួនសាកសពដែលត្រូវទុកចោលនៅក្នុងទីតាំងនោះទាំងអស់ទេ ប៉ុន្តែតាមរយៈការរៀបរាប់របស់សាក្សី អាចត្រូវគេប៉ាន់ស្មានបានយ៉ាងងាយរហូតដល់រាប់រយនាក់។ សូម្បីតែក្រុមអ្នកទោសចុងក្រោយក៏អាចនឹងត្រូវគេសម្លាប់ក្នុងដើមឆ្នាំ១៩៧៩ដែរ មុនពេលដែលទាហានខ្មែរក្រហមចេញដំណើរពីវត្តគីរីរម្យ។

### ចន្លោះក្តាង

៦២៥- ចន្លោះក្តាងគឺជាទីកន្លែងសម្លាប់មនុស្ស និងកប់សាកសពរួមមួយនៅក្នុងស្រុក មុនពេលបង្កើតមន្ទីរសន្តិសុខវត្តគីរីរម្យ និងមន្ទីរសន្តិសុខចន្លោះក្តាង។ ដូច្នេះ នៅពេលប្រើឃ្លាថា “ចន្លោះក្តាង” នៅពេលប្រជុំក្នុងស្រុក គឺមានន័យស្មើនឹងពាក្យសម្លាប់។

៦២៦- នៅក្នុងអំឡុងពេលប្រតិបត្តិការរបស់មន្ទីរសន្តិសុខចន្លោះក្តោង អ្នកទោសរបស់មន្ទីរសន្តិសុខនេះ ត្រូវគេយកទៅវត្តគីរីរម្យដើម្បីសម្លាប់៖ សាក្សីម្នាក់បានរៀបរាប់ថា បានឃើញក្រុមអ្នកទោស ត្រូវ ទាហានយកទៅវត្តគីរីរម្យ ចំនួនប្រាំមួយលើក ដោយគ្មានអ្នកទោសណាម្នាក់ត្រឡប់មក វិញឡើយ។ ព្រឹត្តការណ៍បែបនេះ ស៊ីសង្វាក់គ្នានឹងចម្លើយរបស់សាក្សីម្នាក់ផ្សេងទៀតដែល បាន ឃើញហេតុការណ៍ដោយផ្ទាល់ភ្នែកដែរនោះ។

## តា ផាំ - ការសម្លាប់នៅក្នុងស្រុក

៦២៧- ក្នុង ឬរវាងខែមេសា ឆ្នាំ១៩៧៥ តា ផាំ បានរកឃើញ និងសម្លាប់អតីតទាហាន និងមន្ត្រីក្នុង របប លន់ នល់ អស់រាប់រយនាក់។ ក្នុងអំឡុងពេលដែលគាត់នៅកាន់តួនាទី គាត់បានបង្ខំយ៉ាង សាហាវយង់ឃ្នង ឲ្យអនុវត្តគោលនយោបាយ "កម្ទេច" ជនដែលចាត់ទុកថាជាខ្មាំងសត្រូវ អនុវត្តនូវការចាប់ខ្លួនជាច្រើន សួរចម្លើយ និងសម្លាប់កម្មាភិបាលដែលត្រូវគេសង្ស័យ និង រៀបចំចាត់ចែងសាកសពជនរងគ្រោះដែលនៅចន្លោះក្តោង។

៦២៨- ផាំ ខ្លួនឯងផ្ទាល់បានចូលរួមក្នុងការសម្លាប់មនុស្សជាចំហរ ក្នុងចំនួន"ច្រើនរាប់មិនអស់" រួមមាន៖ ឪពុក និងកូនប្រុស ដែលត្រូវគេកំណត់អត្តសញ្ញាណថាជាខ្មាំងរបស់អង្គការ ហើយត្រូវ គេសម្លាប់ចោលក្នុងអំឡុងពេលមានកិច្ចប្រជុំធំមួយនៅសាលាភ្នំសំពៅ (ទីតាំងមន្ទីរស្រុក) មនុស្សស្រីបួននាក់ និងមនុស្សប្រុស៤នាក់ ដែលត្រូវគេចោទថាជាជនក្បត់នៅក្នុងអង្គប្រជុំជា សាធារណៈក្នុងឆ្នាំ១៩៧៦ មនុស្សចំនួន១០នាក់ ដែលត្រូវគេចោទប្រកាន់ថា "ខុសសីលធម៌" នៅក្នុងអង្គប្រជុំ ពលករស្រី៤នាក់នៅការដ្ឋានកំពីងពួយ ដែលត្រូវគេចោទប្រកាន់ថាជា "ខ្មាំងរបស់បដិវត្តន៍" និងស្ត្រីម្នាក់ដែលមានអាយុប្រមាណ២០ឆ្នាំ មកពីការដ្ឋានកំពីងពួយ

(ត្រូវគេចោទថាជាទាហាន លន់ នល់) សុទ្ធតែត្រូវបាន ឆាំ វាយលោភដោយផ្ទាល់ រួចសម្លាប់ចោល។ សាក្សីមួយរូបបានផ្ដល់សក្ខីកម្មថា បានឃើញ តា ឆាំ សម្លាប់មនុស្សពី៥០ ទៅ ៦០នាក់ ក្នុងពេលខុសៗគ្នា។

៦២៩- អតីតទាហាន លន់ នល់ បីរូបត្រូវគេសម្លាប់នៅវាលស្រែបឹងរលួស តាមបញ្ជារបស់[redacted]។ បន្ថែមលើនេះទៀត យ៉ាងហោចមានចំនួន២លើកដែរ ដែល[redacted]ប្រជុំរួម ដែលនៅក្នុងអង្គប្រជុំនោះ គាត់បានប្រកាសបុគ្គលជាខ្មាំងដែលត្រូវគេចាប់ខ្លួនបាន និងស្នើឲ្យសមាជិកដោះស្រាយ "កម្ទេច" ពួកនោះ បន្ទាប់មកពួកគេត្រូវគេសម្លាប់ នៅចំពោះមុខសមាជិកទាំងអស់។

៦៣០- វាហាក់ដូចជា ក្នុងចំណោមកំហុសដទៃទៀត ការសម្លាប់ចំពោះកំហុស"ខុសសីលធម៌" នៅតែបន្តទោះបីជា ឆាំ ត្រូវបានដកចេញ ឬក្រោយពីមានការបោសសម្អាតភូមិភាគពាយ័ព្យ ហើយក៏ដោយ ដោយមាន[redacted]ជាអ្នកកោះប្រជុំរួម ដើម្បីថ្កោលទោសបុរស និងស្ត្រីរូបណាដែលត្រូវចាប់ខ្លួនដោយសារ ពួកគេបានប្រព្រឹត្តអំពើផិតក្បត់។

**មន្ទីរសន្តិសុខ សៀមរាប**

**ទីតាំង និងប្រតិបត្តិការ**

៦៣១- មន្ទីរសន្តិសុខ សៀមរាប មានទីតាំងស្ថិតនៅសៀមរាប និងជាផ្នែកមួយនៃភូមិភាពឧត្តរថ្មី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មន្ទីរនេះបានចាប់ផ្ដើមដំណើរការយ៉ាងហោចណាស់ ពីចុងខែមករា ឆ្នាំ១៩៧៧ រហូតដល់ខែមករា ឆ្នាំ១៩៧៩។

៦៣២- មន្ទីរសន្តិសុខមានទីតាំងស្ថិតនៅក្នុងអតីតមន្ទីរឃុំឃាំងក្នុងសម័យអាណានិគមបារាំង ត្រង់ទីប្រសព្វផ្លូវជាតិ និងមហាវិថីស៊ីវុត្ថា ហើយមន្ទីរនេះត្រូវបានប្រើជាមន្ទីរឃុំឃាំងរណប ដែលនឹងមានរៀបរាប់ដូចខាងក្រោមនេះ។ មន្ទីរសន្តិសុខផ្ទាល់មានអគារចំនួន៨ ហ៊ុំព័ទ្ធទៅដោយជញ្ជាំងបេតុងខ្ពស់ និងមានលួសបន្លាពីលើ។ អគារទី I ស្ថិតនៅចំកណ្តាលបរិវេណ ទុកសម្រាប់ដាក់អ្នកទោសមកថ្មី ទម្រាំដល់ពេលដែលពួកគេត្រូវបញ្ជូនទៅផ្នែកផ្សេងៗទៀត នៃមន្ទីរឃុំឃាំង។ អគារនេះទុកសម្រាប់ដាក់អ្នកទោសស្រាលនៅពេលយប់ផងដែរ។ អគារ II និងIII ស្ថិតនៅអែបនឹងជញ្ជាំងខាងកើត និងខាងលិចរៀងគ្នា អាចដាក់អ្នកទោសធ្ងន់បានរហូតដល់៣០០នាក់ក្នុងមួយអគារ។ មន្ទីរឃុំឃាំងទាំងនេះ ត្រូវគេ“បិទយ៉ាងតឹងរ៉ឹង” ដោយទ្វារត្រូវចាក់សោរពីរជាន់។ អគារទី IV គឺជាទីកន្លែងសម្រាប់អ្នកទោសស្រាល មុន និង ក្រោយពេលដែលពួកគេត្រូវគេបញ្ជូនទៅធ្វើការខាងក្រៅគុក។ ពីដើមឡើយអគារទីV ត្រូវគេប្រើសម្រាប់ធ្វើជាផ្ទះបាយ ប៉ុន្តែក្រោយមកក៏បានប្តូរទៅជារោងជាងសម្រាប់ជួសជុលទៅវិញ។ អគារ VI និងVII ទុកសម្រាប់ដាក់អ្នកទោសស្រាល និងអ្នកទោសនារី។ អគារ VIII ត្រូវគេប្រើជាផ្ទះបាយ។

៦៣៣- វត្តធម្មយុត្តិ គេអាចហៅថា វត្តកេសារ៉ាម មានទីតាំងស្ថិតនៅមន្ទីរសន្តិសុខខាងលិច និងត្រូវបានគេប្រើប្រាស់ជាកន្លែងសម្រាប់សួរចម្លើយ និងធ្វើទារុណកម្ម។ នៅជាប់នឹងខាងលិចនៃវត្តធម្មយុត្តិ គឺសាលាបឋមសិក្សាកេសារ៉ាម ជាកន្លែងសម្រាប់កប់សាកសពអ្នកទោសដែលស្លាប់នៅក្នុងមន្ទីរសន្តិសុខ។ អគារស្នាក់នៅរបស់មន្ទីរសន្តិសុខ លែងមានទៀតហើយដែលបច្ចុប្បន្ននេះ គឺជាទីតាំងរបស់សណ្ឋាគារសុខាអង្គរ។

## វចនាសម្ពន្ធគ្រប់គ្រង

### ការគ្រប់គ្រងលើមន្ទីរសន្តិសុខ

៦៣៤- មន្ទីរសន្តិសុខសៀមរាប គឺជាគុកថ្នាក់ភូមិភាគ។ ភូមិភាគឧត្តរថ្មី ត្រូវបានបង្កើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៧ និងត្រូវបាន នួន ជា ប្រកាសជាផ្លូវការនៅចុងឆ្នាំ១៩៧៧ នៅមន្ទីរតំបន់១០៣ ក្នុងខេត្តព្រះវិហារ។ ភូមិភាគឧត្តរថ្មីរួមមាន ខេត្តព្រះវិហារ(តំបន់១០៣) ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ(តំបន់១០៦)។

៦៣៥- ចាន់ សំ *ហៅ* កង ចាប *ហៅ* សែ គឺជាលេខាទីមួយនៃភូមិភាគឧត្តរថ្មី។ ពីមុនមកគាត់មានតួនាទីជាអនុលេខានៃភូមិភាគនិរតី និងលេខា នៃតំបន់៣៥ ហើយគាត់ក៏បានចេញពីតួនាទីនោះក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ ដើម្បីរៀបចំភូមិភាគឧត្តរថ្មី។ កង ចាប ត្រូវបានមជ្ឈិមបក្សបញ្ជូនទៅសៀមរាប បន្ទាប់ពីអតីតប្រធានតំបន់សៀមរាប ប៉ា ផល *ហៅ* សុត ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១។ សារឿន មកពីភូមិភាគនិរតី គឺជាអនុលេខាភូមិភាគ ពីចុងឆ្នាំ១៩៧៧ រហូតដល់ពេលដែលគាត់ត្រូវគេចាប់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៨។ [redacted] គឺជាសមាជិក នៃគណៈភូមិភាគដោយទទួលបន្ទុកផ្នែកឃោសនា។ តាមរយៈសាក្សីពីររូប បានឲ្យដឹងថាកូនប្រុសរបស់ កង ចាប ឈ្មោះ ណាន និង ភាព បានចុះមកត្រួតពិនិត្យមន្ទីរភូមិភាគឧត្តរ ហើយបានប្រើប្រាស់អំណាចរបស់ខ្លួនទៅលើតំបន់នោះ។

៦៣៦- នៅក្នុងខែសីហា ឆ្នាំ១៩៧៨ កង ចាប ត្រូវគេចាប់ខ្លួន និងជំនួសដោយ ពេទ្យសឿង ដែលនៅមុនពេលនោះ គាត់គឺជាមេបញ្ជាការកងពលធំលេខ១ នៃភូមិភាគបស្ចិម និងជាសមាជិកនៃគណៈភូមិភាគបស្ចិម។ សឿង ត្រូវបានគេ“តែងតាំង” ជាប្រធានភូមិភាគថ្មីនៅក្នុងអង្គប្រជុំមួយ

នៅសៀមរាបដែលចូលរួមដោយ ប៉ុល ពត និង តា ម៉ុក។ កង ចាប ត្រូវគេសម្លាប់នៅមន្ទីរស-២១ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៨។

## រចនាសម្ព័ន្ធក្នុងមន្ទីរសន្តិសុខ

៦៣៧- មន្ទីរសន្តិសុខសៀមរាបដឹកនាំដោយប្រធាន ឈ្មោះ វុន និងអនុរបស់គាត់ម្នាក់ ម៉ៅ។ វុន ត្រូវជំនួសដោយ តា សុង ក្នុងឆ្នាំ១៩៧៨ និង ម៉ៅ ត្រូវជំនួសដោយ អ៊ឹម។ ក្រោយមក អ៊ឹម ត្រូវជាប់ឃុំឃាំង ហើយបាត់ខ្លួន។ [redacted] ជាអ្នកសួរចម្លើយជាន់ខ្ពស់មួយរូប ដែលទទួលបន្ទុកចុះបញ្ជីអ្នកទោសផងដែរ។ [redacted] ត្រូវបានអនុរបស់គាត់ឈ្មោះ [redacted] ជួយមើលការខុសត្រូវ និងមានអ្នកសួរចម្លើយមួយក្រុមទៀត ដែលមាន [redacted]។ អ្នកសួរចម្លើយត្រូវបាន [redacted] បណ្តុះបណ្តាលពីរបៀបនៃការសួរចម្លើយ។ អ្នកយាមគុករួមមាន [redacted]។ [redacted] គឺជាអ្នកបើករថយន្តដឹកជញ្ជូនជនរងគ្រោះទៅសម្លាប់។ ទោះបីជាគ្មានអ្នកយាមស្រីនៅមន្ទីរឃុំឃាំងក៏ដោយ តែប្រពន្ធរបស់អ្នកយាមគុកទាំងនោះ ក៏បានធ្វើការងារដាំស្លដែរ។ សរុបមក មន្ទីរមានបុគ្គលិកប្រមាណ៦០នាក់។

## ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា

៦៣៨- មន្ទីរភូមិភាគឧត្តរ ឬហៅថា ម-៨០១ បានផ្ញើរបាយការណ៍ជាប្រចាំទៅមជ្ឈិមបក្ស រាយការណ៍ពីស្ថានភាពនៅក្នុងភូមិភាគ រួមមាន ការចាប់ខ្លួន ការសួរចម្លើយ និងកម្មេចខ្មាំងជាដើម។

ការចាប់ខ្លួន និងបញ្ជូនអ្នកទោសមកពីតំបន់ផ្សេងៗ ទៅកាន់មន្ទីរសន្តិសុខសៀមរាប ត្រូវរាយការណ៍ទៅជូន"ថ្នាក់លើ"។

៦៣៩- ទាំង **នួន ជា** និង **ខៀវ សំផន** បានចុះទៅត្រួតពិនិត្យ និងមើលខុសត្រូវនៅភូមិភាគឧត្តរ។ នៅចុងឆ្នាំ១៩៧៧ **នួន ជា** បានកោះប្រជុំសម្ងាត់មួយជាមួយលេខាភូមិភាគ សែ និងអនុលេខា សារឿន ក្រោយពីមានការចាប់ខ្លួនជាបន្តបន្ទាប់នៅក្នុងតំបន់ រួមមានតំបន់១០៣ លេខា ហង់ និង"បុគ្គលផ្សេងៗទៀតនៅតំបន់១០៣"។

៦៤០- លេខាភូមិភាគ កង ចាប ក៏បានអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងមាគ៌ាបក្សពេញក្នុងតំបន់។ ឧទាហរណ៍ នៅក្នុងខែសីហា ឆ្នាំ១៩៧៧ គាត់បានទទួលទិសដៅពីបក្សឱ្យធ្វើការនៅតំបន់១០៣ ដើម្បីផ្សព្វផ្សាយ"មាគ៌ានយោបាយរបស់បក្ស"។ អស់រយៈពេល១០ថ្ងៃ គាត់បានធ្វើសន្និបាតនៅក្នុងស្រុកចំនួន៥ ដែលមានការចូលរួមដោយគណៈឃុំ និងស្រុក ព្រមទាំងបណ្តាមន្ទីរផ្សេងៗ ដែលនៅក្នុងសន្និបាតនោះ គាត់បានណែនាំកម្មាភិបាលមូលដ្ឋានស្តីពី"មាគ៌ាបក្សក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម" និង"មាគ៌ាក្នុងការបង្កើនទិន្នផល"។ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧ លេខាភូមិភាគបានរាយការណ៍ជាលាយលក្ខណ៍អក្សរ ទៅកាន់មន្ទីរ៨៧០ ពីលទ្ធផលនៃសន្និបាតទាំងនោះ ដោយបានលើកឡើងថា "ចាំបាច់ត្រូវតែសម្រិតសម្រាំងកម្មាភិបាលតាំងពីថ្នាក់ស្រុកជាបណ្តើរៗ" ព្រមទាំងបន្ត"វាយសម្រុកបោសសម្អាតខ្មាំង"។

## ការចាប់ខ្លួន និងការឃុំឃាំងខុសច្បាប់

៦៤១- គេមិនបានដឹងច្បាស់ទេ អំពីតួលេខសរុបនៃចំនួនមនុស្សដែលត្រូវជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខសៀមរាបក្នុងរយៈពេលដូចបានរៀបរាប់នោះទេ តែមន្ទីរនេះមានផ្ទុកអ្នកទោសលើសពី៥០០

នាក់។ មន្ទីរសន្តិសុខបានទទួលជនទាំងឡាយដែលត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសធ្ងន់ពីបណ្តាមន្ទីរសន្តិសុខតូចៗជាច្រើននៅតាមភូមិភាគឧត្តរ រួមមាន ពង្រ មន្ទីរសន្តិសុខភ្នំទ្រង់បាតក្នុងស្រុកក្រឡាញ់ ផ្ទះសន្តិសុខភូមិសង្វើយ មន្ទីរសន្តិសុខស្រុកសំរោង និងមន្ទីរសន្តិសុខស្រុកផ្សាររដំដែក។ អ្នកទោសត្រូវគេបញ្ជូនជាទៀងទាត់ ចេញពីមន្ទីរសន្តិសុខហើយត្រូវគេចាត់តាំងទៅតាមការដ្ឋានផ្សេងៗ ដូចជាទំនប់ស្ពានមេម៉ាយ ជាដើម។

៦៤២- មូលហេតុនៃការចាប់ខ្លួន និងឃុំឃាំងរួមមានការចោទប្រកាន់ថាក្បត់ អំពើខុស សីលធម៌ ឬមានខ្សែរយៈជាមួយសេអ៊ីអា។ អ្នកទោសទាំងអស់នោះមាន ប្រជាជន មូលដ្ឋាន "ប្រជាជនថ្មី" កម្មាភិបាល និងទាហានបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាអតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងគ្រួសាររបស់ពួកគេ។ អ្នកទោស រួមមានទាំងបុរស ស្ត្រី និងកុមារ បានមកដល់ជាញឹកញាប់ពីបណ្តាខេត្ត ស្រុក និងសហករណ៍ផ្សេងៗ រួមមានមកពីតំបន់ព្រះវិហារ ឧត្តរមានជ័យ និងស្វាយលើ។

៦៤៣- ក្នុងចំណោមអ្នកទោសនៃមន្ទីរសន្តិសុខ មានកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួន រួមមាន៖ [redacted] សុទ្ធ និង [redacted] តំបន់១០៦។ ចុងក្រោយ [redacted] ក៏ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខដែរ។

៦៤៤- អ្នកទោសត្រូវគេដឹកទៅមន្ទីរសន្តិសុខតាមរថយន្ត ការបញ្ជូនក្នុងមួយលើកៗ មានអ្នកទោសចំនួនប្រមាណជា១០នាក់ត្រូវគេដាក់ខ្នោះដៃ ហើយត្រូវគេចងដៃទាំងសងខាងព័ទ្ធទៅក្រោយ។ ក្នុងមួយយប់ មានឡានចំនួន២ ឬ៣ចូលមក។ អ្នកទោសតែងតែត្រូវអមដំណើរដោយទាហានដែលជាអ្នកចាប់ពួកគេមក។

៦៤៥- ការបោសសម្អាតក្នុងទ្រង់ទ្រាយធំនៅតំបន់១០៣ ដែលកើតមានពីចុងឆ្នាំ១៩៧៧ ដល់ពាក់កណ្តាល ឆ្នាំ១៩៧៨ ត្រូវបានលេខាភូមិភាគឧត្តរ សែ រាយការណ៍ជាទៀងទាត់ទៅឲ្យមជ្ឈិមបក្ស។ ជាញឹកញាប់ កម្មាភិបាលដែលត្រូវគេបោសសម្អាត ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខសៀមរាប ឬស-២១។

៦៤៦- [redacted]។

៦៤៧- [redacted]

[redacted]

## លក្ខណៈអមនុស្សធម៌ និងពលកម្មដោយបង្ខំ

### លក្ខណៈអមនុស្សធម៌

៦៤៨- អ្នកទោសត្រូវគេឃុំក្នុងមន្ទីរសន្តិសុខសៀមរាបក្នុងស្ថានភាពគួរឱ្យខ្លាច។ អ្នកទោសបុរស និងស្ត្រី ត្រូវគេបំបែកចេញពីគ្នា អ្នកទោសបុរសទាំងអស់ត្រូវគេដាក់ខ្នោះជើងនៅពេលយប់ និងដេកតំរៀបគ្នាក្នុងមួយជួរ៣០នាក់ ជើងទល់គ្នា។ អ្នកដែលត្រូវគេចោទប្រកាន់ពី "បទល្មើស" ស្រាលៗ ត្រូវបានគេអនុញ្ញាតឱ្យធ្វើការនៅពេលថ្ងៃដោយមិនមានដាក់ខ្នោះជើង។ អ្នកទោសនារីមិនត្រូវគេដាក់ខ្នោះជើងទេ ហើយគេអនុញ្ញាតឱ្យកុមារនៅជាមួយម្តាយ។ គេផ្តល់ឱ្យអ្នកទោសនូវបបររាវៗ ពីរពេលក្នុងមួយថ្ងៃ និងកម្រឱ្យទឹកហូបណាស់។ មនុស្សជាច្រើនបានស្លាប់ ដោយសារអត់ឃ្លាន ដែលមានជាមធ្យម១០នាក់ ឬច្រើនជាងនេះ ក្នុងមួយថ្ងៃៗ។

៦៤៩- បន្ទប់ឃុំឃាំង ដែលផ្ទុកអ្នកទោសរហូតដល់រាប់រយនាក់នាពេលមួយនោះ ស្ថិតក្នុងស្ថានភាពដែលគ្មានអនាម័យទាល់តែសោះ និងមានក្លិនយ៉ាងអសោច។ អ្នកទោសមានចៃ និងសត្វល្អិតដោយសារគេមិនឱ្យមុជទឹក ឬផ្លាស់សម្លៀកបំពាក់។ ពួកគេបន្ទោរបង់ និងបន្ទោរបង់លាមកក្នុងម្ជូកដែក ដែលនឹងត្រូវគេចាក់ចូលទៅក្នុងឡាំងមួយទុកនៅខាងចុងជួរនីមួយៗ។ អ្នកទោសមួយចំនួនត្រូវ គេបង្ខំឱ្យប្រើម្ជូកដដែលនោះសម្រាប់ការហូបចុក និងបន្ទោរបង់របស់ខ្លួន។

៦៥០- អ្នកទោសជាច្រើនបានស្លាប់ដោយសារជម្ងឺ។ សាកសពរបស់ពួកអ្នកដែលស្លាប់នៅពេលយប់ត្រូវគេទុកចាំរហូតដល់ពេលថ្ងៃត្រង់នៃថ្ងៃបន្ទាប់ ទើបបានគេយកចេញ ដែលបណ្តាលឱ្យសាកសពត្រូវហើម និងមានក្លិនស្អុយយ៉ាងអសោច។

៦៥១- អ្នកទោសទាំងអស់ ត្រូវគេធ្វើបាប និងវាយដំតាមអំពើចិត្ត។ ជាឧទាហរណ៍ កូនស្រីរបស់អ្នកទោសម្នាក់ ដែលមានអាយុបីឆ្នាំ ត្រូវគេវាយនឹងចង្កោមសោរ ដោយសារយំស្រែករកម្តាយ។ បន្ទាប់មក ក្មេងនោះក៏ត្រូវស្លាប់។ ការដាក់ទណ្ឌកម្មសម្រាប់ការលាក់ដំឡូងនៅក្នុងដៃ អ្នកទោសនារីម្នាក់ត្រូវគេវាយចំដើមកយ៉ាងដំណំ ធ្វើឱ្យគាត់សន្លប់បាត់ស្មារតី។ អ្នកទោសប្រុសម្នាក់ត្រូវគេប្រើពូថៅវាយជើង ដោយសារត្បាត្រចៀកខ្លួនឯង។ អ្នកទោសបុរសម្នាក់ទៀតត្រូវគេវាយនឹងព្រនង់ជ្រុង ដោយសារយកគ្រាប់ខ្នុរចំនួនដប់គ្រាប់ ដែលអ្នកយាមគុកម្នាក់បោះចោល។ ការថែទាំ ឬព្យាបាល តាមបែបវេជ្ជសាស្ត្រ គឺសម្រាប់តែអ្នកយាម និងបុគ្គលិកតែប៉ុណ្ណោះ។

## ពលកម្មដោយបង្ខំ

៦៥២- អ្នកទោសត្រូវគេបង្ខំឱ្យធ្វើពលកម្ម។ ជនដែលត្រូវគេចោទពី "កំហុសតូចតាច" ត្រូវគេបង្ខំឱ្យធ្វើការពីម៉ោង៧ព្រឹក រហូតដល់ម៉ោង៥ល្ងាច ក្រោមការតាមដានរបស់អ្នកយាម៤ ទៅ៥នាក់។ ពួកគេធ្វើការនៅក្រៅបរិវេណមន្ទីរឃុំឃាំងរួមមាន ច្រូតស្រូវ ដាំបន្លែ និងជីកស្រះជាដើម។ អ្នកទោសបុរសក៏ត្រូវគេបង្ខំឱ្យជីករណ្តៅសម្រាប់កប់អ្នកទោសផ្សេងទៀតដែលបានស្លាប់នៅក្នុងគុក។ អ្នកទោសបុរសដែលមានជំនាញត្រូវគេចាត់ឱ្យទៅរោងជាង ដើម្បីជួសជុលឡានគ្រឿងម៉ាស៊ីន និងបរិក្ខារផ្សេងៗទៀត។ អ្នកទោសនារីត្រូវគេប្រគល់ភារកិច្ចសំខាន់ ឱ្យបេះបន្លែ និងដាំស្ល ម្ហូបអាហារសម្រាប់អ្នកទោសទាំងអស់។

## ការសួរចម្លើយ និងទារុណកម្ម

៦៥៣- អ្នកទោសមន្ទីរសន្តិសុខសៀមរាប បានឆ្លងកាត់បទពិសោធន៍ការធ្វើទារុណកម្មដ៏គួរតក់ស្លុត ក្នុងពេលសួរចម្លើយ។ គោលបំណងនៃការសួរចម្លើយ និងធ្វើទារុណកម្ម គឺដើម្បីពិនិត្យមើលមូលហេតុនៃការចាប់ខ្លួនរបស់អ្នកទោសម្នាក់ៗ បង្ខំឱ្យអ្នកទោសសារភាព ដាក់ទណ្ឌកម្មពួកគេ ឬដើម្បីរកការទំនាក់ទំនងជាមួយនឹងសេអ៊ីអា។ វិធីសាស្ត្រក្នុងការធ្វើទារុណកម្មរួមមាន ធ្វើឱ្យថប់ខ្យល់ ឆក់ខ្សែភ្លើង ដកក្រចកជើង ព្រមទាំងគម្រាមកំហែង និងការវាយដំជាដើម។ មានករណីមួយ អ្នកទោសបានសន្លប់បាត់ស្មារតី ដោយសារការធ្វើទារុណកម្មក្នុងអំឡុងពេលសួរចម្លើយយ៉ាងតិច២វគ្គផ្សេងគ្នា។ មានករណីមួយទៀត នៅពេលដែលអ្នកទោសម្នាក់បដិសេធមិនព្រមឆ្លើយ អ្នកយាមបានចងដៃ និងជើងរបស់គាត់ ហើយបោះគាត់ចូលទៅក្នុងភ្នក់ភ្លើង។ ដើម្បីកុំឱ្យគាត់រត់ចេញ អ្នកយាមបានដាក់ក្តារប្រវែងពីរម៉ែត្រនៅពីលើគាត់។ ត្រចៀកអ្នកទោសម្ខាង ត្រូវកាត់ និងដុតចោល។ អ្នកទោសដែលគេចាប់បានវិញ

ត្រូវធ្វើទារុណកម្ម និងវាយនៅចំពោះមុខអ្នកទោសឯទៀតដើម្បីកុំឲ្យគេយកតម្រាប់តាម។ ជើងរបស់គាត់ត្រូវគេដំដែកគោលជាប់ទៅនឹងក្ដារ ដោយប្រើដែកគោលវែងដែលមានប្រវែងដប់សង់ទីម៉ែត្រ ហើយបន្ទាប់មកគេបញ្ជាឲ្យគាត់លើកដៃត្រដាង ហើយច្រៀង។ មានសាក្សីជាច្រើនបាននឹកឃើញ ដល់ការយំស្រែករបស់អ្នកទោស នៅពេលដែលត្រូវគេធ្វើទារុណកម្ម។

៦៥៤- អ្នកទោសត្រូវគេសួរចម្លើយ២ដងក្នុងមួយថ្ងៃ ម្ដងនៅម៉ោងប្រាំពីរ ឬប្រាំបីព្រឹក និងម្ដងទៀតម៉ោង០១ ឬ២រសៀល។ វគ្គសួរចម្លើយ មានរយៈពេលប្រហែលជា៣ម៉ោង ហើយជាធម្មតាអ្នកទោសម្នាក់ត្រូវគេសួរចម្លើយសរុប ពី៣ ទៅ៤ដង។ អ្នកទោសពី៨ ទៅ១០នាក់ត្រូវគេនាំទៅសម្រាប់វគ្គសួរចម្លើយនីមួយៗ។ មានអ្នកសួរចម្លើយពី៤ ទៅ៥នាក់ ក្នុងមួយវគ្គ ហើយកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរចម្លើយទាំងនោះ ត្រូវគេរក្សាទុក។

## ការសម្លាប់មនុស្សក្រៅច្បាប់

៦៥៥- អ្នកទោសដែលត្រូវគេយកទៅសម្លាប់ ត្រូវគេដឹកតាមឡានរៀងរាល់ពេលថ្ងៃត្រង់ ទៅកាន់ចំការទ្រិញវ៉ាញ ដើម្បីសម្លាប់ចោល។ ក្នុងពេលកំពុងធ្វើដំណើរ ដៃរបស់អ្នកទោសត្រូវគេចង។ វិធីសាស្ត្រក្នុងការសម្លាប់មនុស្ស គឺស្រដៀងគ្នាទៅនឹងវិធីសាស្ត្រដែលប្រើនៅក្នុងមន្ទីរសន្តិសុខ និងទីពិឃាតឯទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ "អ្នកទោសត្រូវគេសម្លាប់ដោយកាប់នឹងពូថៅ ឬកាំបិត ហើយសាកសពរបស់ពួកគេត្រូវគេទម្លាក់ចូលទៅក្នុងលេណដ្ឋានចាស់ៗ"។ ក្នុងមួយពេល មានអ្នកទោសចំនួន៦០នាក់ ត្រូវគេសម្លាប់របៀបនេះ។ ចំការទ្រិញវ៉ាញនៅមានបណ្ដាញលេណដ្ឋានជាច្រើន ដែលជនរងគ្រោះត្រូវគេសម្លាប់។

៦៥៦- អ្នកទោសក៏ត្រូវគេសម្លាប់ដោយសារការប្រព្រឹត្តបទល្មើសតូចតាច នៅមន្ទីរសន្តិសុខផ្ទាល់ដែរ។ អ្នកទោសម្នាក់ត្រូវគេសម្លាប់ ដោយសារគាត់បានរើសកាកអំពៅហូប។ ក្មេងស្រីជាចុងភៅមួយរូប ត្រូវអ្នកយាមជាច្រើននាក់រំលោភ៖ [redacted] សាកសពជនរងគ្រោះដែលត្រូវគេសម្លាប់នៅក្នុងបរិវេណ និងនៅក្នុងវត្តធម្មយុត្តិ ត្រូវគេកប់នៅក្នុងវត្ត និងនៅសាលាបឋមសិក្សាកេសារ៉ារ៉ាម។

៦៥៧- ក្នុងពេលកំពុងសាងសង់បន្ទប់ថ្មី ក្នុងឆ្នាំ១៩៨០-១៩៨១ នៅវត្តធម្មយុត្តិ គេឃើញមានអដ្ឋិធាតុជាច្រើន ដាក់ជាមួយគ្នាដោយជាប់ខ្នោះដៃ ជាប់ច្រវ៉ាក់ និងខ្សែនីឡុង។ អដ្ឋិធាតុផ្សេងៗទៀតរបស់ជនរងគ្រោះចំនួន៥០នាក់ ត្រូវគេរក្សាទុកនៅក្នុងបរិវេណនោះ។

៦៥៨- ក្នុងពេលជីកកាស់កាយរណ្តៅសាកសពនៅសៀមរាប ពីឆ្នាំ១៩៨០-១៩៨៨ គេបានប្រមូលសាកសពចំនួន ពី៥០០០-៦០០០ នៅក្នុងបរិវេណនោះ ហើយត្រូវគេរក្សាទុកនៅវត្តថ្មី។ សាកសពដែលជីកកាស់ឡើងមកស្ថិតក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ សាកសពខ្លះមានចងស្លាបព្រានៅជាប់នឹងចង្កេះ ឬត្រូវគេចងដៃទៅក្រោយជាមួយនឹងខ្សែនីឡុង និងខ្សែអង្រឹង។ លលាដ៏ក្បាលមួយចំនួនមានស្នាមប្រេះ និងអដ្ឋិធាតុទាំងនោះក៏មានអដ្ឋិធាតុរបស់កុមារផងដែរ។ ទោះបីជាអដ្ឋិធាតុសាកសពមួយចំនួនធំដែលយកមកពីចំការទ្រិញវ៉ាញ ត្រូវគេរក្សាទុកនៅវត្តថ្មី និងមួយចំនួនទុកនៅវត្តធម្មយុត្តិក៏ដោយ ក៏ការស៊ើបអង្កេតមិនទាន់បង្ហាញទេ ថាតើអដ្ឋិធាតុសាកសពទាំងអស់នោះ ជារបស់ជនរងគ្រោះនៅមន្ទីរសន្តិសុខ ឬយ៉ាងណានោះទេ។

*សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អវតក/កសចស*

# ការសម្រិតសម្រាំងនៅភូមិភាគឧត្តរ

## សេចក្តីផ្តើម

៦៥៩- សមាជិកគណៈមជ្ឈិមឈ្មោះ កុយ ធួន ហៅ ឃួន ហៅ ធុច គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់របស់បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា និង បានចំណាយពេលរបស់ខ្លួនជាច្រើនឆ្នាំធ្វើការជាមួយមេដឹកនាំ បក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតនៅទូទាំងប្រទេស ដំបូងគាត់ជាលេខាភូមិភាគឧត្តរ និងក្រោយមកក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។ ក៏ប៉ុន្តែនៅដើមខែមេសា ឆ្នាំ១៩៧៦ គាត់ត្រូវបានគេចាប់ខ្លួនឃុំឃាំងនៅផ្ទះដោយគណៈអចិន្ត្រៃយ៍ ហើយនៅខែមករា ឆ្នាំ១៩៧៧ គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ ដែល **ឌុច** ជាអ្នកសួរចម្លើយគាត់ដោយផ្ទាល់ ហើយ ប៉ុន ដែលជាអ្នកក្រោមបង្គាប់ជាអ្នកធ្វើទារុណ្ណកម្ម។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន កុយ ធួន បានឆ្លើយដាក់កម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាជាច្រើននាក់។ ផ្អែកតាមព័ត៌មាននេះ គណៈអចិន្ត្រៃយ៍បានធ្វើការសម្រិតសម្រាំងជាទ្រង់ទ្រាយធំជាច្រើន។ នៅពេលការសម្រិតសម្រាំងឈានមកដល់ទីបញ្ចប់នៅឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំភូមិភាគនានា កងពលនានានៃកងទ័ពបដិវត្តកម្ពុជា និងក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានដកចេញពីតំណែង និងយកទៅសម្លាប់ចោល។ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជារួមមាន **នួន ជា អៀង សារី** និង **ខៀវ សំផន** សមាជិកតាមព្រឹត្តិន័យ បានបញ្ជាឲ្យចាប់ខ្លួន កុយ ធួន និងបានអនុម័តការសម្រិតសម្រាំងជាទ្រង់ទ្រាយធំនៅភូមិភាគឧត្តរ ក្រសួងពាណិជ្ជកម្ម និងស្ថាប័នកម្ពុជាប្រជាធិបតេយ្យផ្សេងៗទៀតជាបន្តបន្ទាប់។

## ការចាប់ខ្លួន និងចម្លើយសារភាពរបស់ កុយ ធួន

៦៦០- នៅថ្ងៃទី២៤ ឬទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ មានការផ្ទុះជាបន្តបន្ទាប់ក្នុងឃ្លាំងគ្រាប់មួយកន្លែង នៅក្រុងសៀមរាប ដែលមានចំនួនមនុស្សពី១៥ ទៅ១០០នាក់ បានស្លាប់បាត់បង់ជីវិត។ ពីរសប្តាហ៍ក្រោយមក នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ លេខាតំបន់១០៦ ឈ្មោះ ប៉ា ផល ហៅ សុត លេខាតំបន់១០៣ ឈ្មោះ បូ ផាត ហៅ ហង្ស និងអនុលេខាភូមិភាគឧត្តរឈ្មោះ ជ ឆាន ហៅ ស្រេង ត្រូវបានកោះហៅមកភ្នំពេញ ដើម្បីរាយការណ៍ជូនគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា អំពី "សភាពការណ៍" នៅក្នុងតំបន់នោះ។ លេខាតំបន់១០៦ សុត បានរាយការណ៍ទៅ ប៉ុល ពត នួន ជា និង ខៀវ សំផន ថា "មិនទាន់រកឃើញឬសគល់ច្បាស់លាស់ចំពោះព្រឹត្តិការណ៍នៅសៀមរាបកាលពីថ្ងៃទី២៤ ខែកុម្ភៈ ទេ"។ អតីតលេខាភូមិភាគឧត្តរ កុយ ធួន មិនមានវត្តមានក្នុងការប្រជុំដែលមានលក្ខណៈរសើបនេះទេ។

៦៦១- កុយ ធួន បានចូលរួមប្រជុំទៀងទាត់ជាមួយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា រហូតមកដល់ពេលនេះ។ គាត់ចូលរួមប្រជុំចុងក្រោយនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ ជាពេលដែលគាត់បានទទួលការតែងតាំងជាប្រធានគណៈកម្មាធិការមួយ ដើម្បីរៀបចំទិញសម្ភារៈពីប្រទេសចិន។ នៅខែមីនា ឆ្នាំ១៩៧៦ កុយ ធួន ក្លាយជាជនសង្ស័យក្នុងក្រសែភ្នែករបស់គណៈអចិន្ត្រៃយ៍ ដោយសារមានព្រឹត្តិការណ៍ផ្ទុះនៅខេត្តសៀមរាប និងការចោទប្រកាន់ពីអំពើខុសសីលធម៌ផ្លូវភេទផង។ ក្រោយពេលមានការផ្ទុះគ្រាប់បែកមួយគ្រាប់នៅខាងក្រោយវាំង នាថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៦ កុយ ធួន ត្រូវបានគេចាប់ឃុំឃាំងក្នុងផ្ទះនៅមន្ទីរ ក-១ ដើម្បីឲ្យសកម្មភាពរបស់គាត់

ត្រូវស្ថិតក្រោមការតាមដានរបស់មជ្ឈិមបក្ស។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ គាត់ត្រូវបាន គេបញ្ជូនមកសួរចម្លើយនៅមន្ទីរស-២១។

៦៦២- ចម្លើយសារភាពចំនួនពីរដំបូងរបស់ កុយ ធួន ត្រូវបានធ្វើឡើងដោយ កាំង ហ្កេចអ៊ាវ ហៅ ឌុច ក្រោមបញ្ជាពី សុន សេន ដើម្បីប្រើត្រឹមតែវិធីសាស្ត្រ "ត្រជាក់" ដែលជាការសួរចម្លើយដោយមិនធ្វើទារុណ្ណកម្ម។ ឌុច ទទួលចម្លើយសារភាពទីមួយ បាននៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៧។ ក្រៅពីធ្វើចំណារជាធម្មតាទៅលើចម្លើយសារភាព ឌុច បានផ្ញើចម្លើយសារភាពនោះទៅឲ្យ សុន សេន ភ្លាម។ ពីរថ្ងៃក្រោយមក សុន សេន បានផ្ដល់ព័ត៌មានមកឲ្យ ឌុច វិញថា ការចាប់ខ្លួនកម្មាភិបាលភូមិភាគឧត្តរជាទ្រង់ទ្រាយធំត្រូវបានបញ្ជា ដោយផ្អែកតាមចម្លើយសារភាពរបស់ កុយ ធួន។

៦៦៣- សុន សេន បានចាត់តាំង ប៊ុន ឲ្យសួរចម្លើយ កុយ ធួន បន្ថែមទៀត ដោយលើកនេះគេប្រើវិធីសាស្ត្រធ្វើទារុណ្ណកម្មផង។ ប៊ុន បានប្រើទារុណ្ណកម្មធ្ងន់ធ្ងររហូតធ្វើឲ្យ កុយ ធួន សារភាពពីផែនការប្រឆាំងបក្សតាំងពីឆ្នាំ១៩៥៨ មុនពេលបក្សចាប់កំណើតទៅទៀត។ ការសង្ស័យត្រូវធ្លាក់ទៅលើ៖បុគ្គលិកក្រសួងពាណិជ្ជកម្មដែល កុយ ធួន ជាអ្នកជ្រើសរើស ភូមិភាគឧត្តរ ដែល កុយ ធួន ជាលេខាភូមិភាគ និងកងពលចំនួនបី របស់ភូមិភាគឧត្តរគឺ៖ កងពលលេខ១៧៤ ៣១០ និង៤៥០ ដែលបង្កើតឡើងដោយ កុយ ធួន។ ទាក់ទងនឹងការសម្រិតសម្រាំងដែលបន្តមកទៀត មានកម្មាភិបាល និងយុទ្ធជនរាប់ពាន់នាក់ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ហើយរាប់ពាន់នាក់ផ្សេងទៀតដែលត្រូវបានបញ្ជូនទៅជំរំ "អប់រំកែប្រែ" រួមមានមន្ទីរស-២៤ ផងដែរ។

៦៦៤- ក៏ប៉ុន្តែ ការសម្រិតសម្រាំងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាជាទ្រង់ទ្រាយធំលើកទីមួយ បាន រាលដាលឆ្ងាយពីបណ្តាញរបស់ កុយ ធួន ទៅទៀត។ ក្រោមការធ្វើទារុណ្ណកម្ម ធួន បាន សារភាពពីការរួមគំនិតជាទ្រង់ទ្រាយធំ ដោយបានឆ្លើយដាក់មេដឹកនាំនៅតាមភូមិភាគ ក្រសួង និងកងពលជាច្រើនរបស់កម្ពុជាប្រជាធិបតេយ្យ។ ផែនការនោះពាក់ព័ន្ធនឹងការបង្កើតគណបក្ស នយោបាយប្រឆាំងមួយ ដែលដឹកនាំដោយអតីតលេខាភូមិភាគពាយ័ព្យឈ្មោះ ម៉ែន សាន ហៅ នៃ សារ៉ាន់ ហៅ យ៉ា ដែល កុយ ធួន ជាអនុប្រធាន។ វាមានការពាក់ព័ន្ធដល់កម្មាភិបាលជាន់ ខ្ពស់ជាច្រើនរួមមាន៖ សឿ វ៉ាស៊ី ហៅ ឌឿន ជាប្រធានមន្ទីរ៨៧០ អនុប្រធានគណៈកម្មាធិការ ពាណិជ្ជកម្មឈ្មោះ ទិត សុន ហៅ ញ៉ែម អនុលេខាភូមិភាគឧត្តរឈ្មោះ ស្រេង លេខាភូមិភាគ ពាយ័ព្យឈ្មោះ អ៊ុម ណេង ហៅ វី (ជាអ្នកបន្តវេនពី យ៉ា) និងអនុលេខាឈ្មោះ ឡាវ លេខាតំបន់ ១០៥ ឈ្មោះ ហាម ហៅ ឡាំង លេខាតំបន់៥០៥ ឈ្មោះ ប៊ិន ណាន ហៅ យី លេខាតំបន់១០៦ ឈ្មោះ សុត លេខាភូមិភាគបូព៌ាឈ្មោះ សួស នៅ ហៅ ឈូក ហៅ ម៉ែន រដ្ឋមន្ត្រីក្រសួង ឃោសនាការឈ្មោះ ហ៊ូ នឹម ហៅ ភាស់ រដ្ឋមន្ត្រីក្រសួងកសិកម្មឈ្មោះ នន សួន ហៅ ជ័យ សួន ហៅ សែន លេខាកងពល១៧០ ឈ្មោះ ចាន់ ចក្រី ហៅ នៅ មាន លេខាកងពល៣១០ ឈ្មោះ ស្បូវ ហ៊ឹម ហៅ អឿន និងលេខាកងពល៤៥០ឈ្មោះ ជា ណុន ហៅ សួង។

៦៦៥- ទោះបី **ឌុច** មិនជឿលើព័ត៌មានពាក់ព័ន្ធនឹងផែនការបែបសន្មតនោះក៏ដោយ តែវាក្លាយជាព័ត៌មាន គ្រប់គ្រាន់សម្រាប់ឱ្យមជ្ឈិមបក្សបញ្ជាចាប់ខ្លួនមនុស្សបន្ថែមទៀត។ ក្រោយមកមេដឹកនាំជាន់ ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា បានប្រើចម្លើយសារភាពរបស់ កុយ ធួន នៅតាមវគ្គរៀនសូត្រ នយោបាយ និងនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ដើម្បីធ្វើយុត្តិកម្មចំពោះការសម្រិតសម្រាំងដែលចេះ

តែបន្ត ដោយបញ្ចុះបញ្ចូលកម្មាភិបាលថា ខ្មាំងផ្ទៃក្នុងបានជ្រៀតចូលក្នុងបក្ស និងបានជំរុញឲ្យកម្មាភិបាលស្វែងរក និងកម្ទេចខ្មាំងទាំងនោះ។

៦៦៦- កម្មាភិបាលជាច្រើនដែលមានឈ្មោះនៅក្នុងបញ្ជីពួកក្បត់របស់ កុយ ធួន ត្រូវបានសួរចម្លើយ និងសម្លាប់នៅមន្ទីរស-២១ រួមមាន ចក្រី ជាលេខាកងពល១៧០ ឈូក ជាលេខាតំបន់២៤ យ៉ា ជាលេខាភូមិភាគឦសាន និង សែន ជារដ្ឋមន្ត្រីក្រសួងកសិកម្ម។ ភាគច្រើននៃអ្នកដែលនៅសល់ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ ក្រោយពេល កុយ ធួន ឆ្លើយដាក់បានមួយរយៈខ្លី។ ពេលនោះ មជ្ឈិមបក្សបានបង្វែរការចាប់អារម្មណ៍របស់ខ្លួនក្នុងការបោសសម្អាតមកលើអ្នកក្រោមបង្គាប់របស់មេដឹកនាំជាន់ខ្ពស់ទាំងនោះទៀត។

## កងពល៣១០

៦៦៧- កងពល៣១០ គឺជាកងពលមួយ ក្នុងចំណោមកងពលចំនួន៣ ដែលបានបង្កើតឡើងដោយ កុយ ធួន ហើយលេខាកងពលនេះឈ្មោះ ស៊្បួរ ហ៊ឹម ហៅ អឿន មានលេខរៀងទី១៤ នៅក្នុងបញ្ជីពួកក្បត់របស់ ធួន។ អឿន ត្រូវបានឃុំខ្លួនលើកដំបូង នៅមន្ទីរសន្តិសុខក្នុងកងពល៣១០ នៅវត្តភ្នំ ក្នុងក្រុងភ្នំពេញ និងត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ក្នុងរយៈពេលមួយឆ្នាំនេះ មេដឹកនាំដែលនៅសល់ក្នុងកងពល៣១០ ត្រូវបានបញ្ជូនជាប្រព័ន្ធទៅមន្ទីរស-២១ រួមមានបុគ្គលិកនៅទីបញ្ជាការកងពល និងគណៈកម្មាធិការ (ដូចជា លេខា អនុលេខា និងសមាជិក) កងវរសេនាធំ កងវរសេនាតូច និងកងអនុសេនាតូច។ ពលទាហាននៃកងពល៣១០ទាំងមូលត្រូវបានប្រមូលផ្តុំ និងបញ្ជូនទៅធ្វើការងារពលកម្មដោយបង្ខំនៅការដ្ឋាន

"អប់រំកែប្រែ" រួមមាននៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និង ព្រៃស (ស-២៤)។ មន្ទីរពេទ្យក្នុងកងពល៣១០នេះ ក៏ត្រូវបានសម្រិតសម្រាំងដែរ។

**កងពល៤៥០**

៦៦៨- ជា ណុន ហៅ សួង ដែលជាលេខាកងពល៤៥០ (ជាកងពលមួយទៀតដែលបានបង្កើតឡើងដោយ កុយ ធួន) ក៏ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដំណាលគ្នានឹងអឿនដែរ។ គាត់ស្ថិតនៅលេខរៀងទី១៩ ក្នុងបញ្ជីរបស់ ធួន។ អនុលេខារបស់គាត់ឈ្មោះ អៀ ឆយ ហៅ យាន ត្រូវបានចាប់ខ្លួនមុនពីរថ្ងៃ គឺនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧។ សមាជិកគណៈកងពល៤៥០ ឈ្មោះ មាស សុក ហៅ សឹម ត្រូវបានចាប់ខ្លួននៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧៧ និងត្រូវបានគេសម្លាប់ពីរថ្ងៃក្រោយមក។ លេខា អនុលេខា និងសមាជិកគណៈកងវរសេនាធំ និងកងវរសេនាតូចនានាដែលនៅក្នុងកងពល៤៥០ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ជាបន្តបន្ទាប់ គ្រាន់តែនៅថ្ងៃទី៥ និងទី៦ ប៉ុណ្ណោះ មានលេខាមកពីកងវរសេនាតូចចំនួន៩នាក់ បានមកដល់មន្ទីរស-២១។ បន្ទាប់ពីបានកំចាត់កម្មាភិបាលជាន់ខ្ពស់រួច ការសម្រិតសម្រាំងបានបន្តទៅថ្នាក់ក្រោមទៅដល់អនុសេនាធំ អនុសេនាតូច និងកងទៀតផង។

**កងពល១៧៤**

៦៦៩- កងពល១៧៤ នៃភូមិភាគឧត្តរត្រូវបានបង្កើតឡើងដោយ កុយ ធួន ជាអង្គភាពទទួលខុសត្រូវផ្នែកអាវុធ ដែលមានជំនាញខាងផលិតគ្រាប់រំសេវសម្រាប់បដិវត្តន៍។ កងពលនេះជាអង្គភាពយោធាដែលបង្កើតឡើងដោយ កុយ ធួន ត្រូវបានសម្រិតសម្រាំងចុងក្រោយគេ ដោយមានការចាប់ខ្លួនជាចំនួនច្រើនបំផុតនៅខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ១៩៧៧។ កម្មាភិបាលនៅគណៈកម្មាធិការ

កងវរៈសេនាតូចលេខ៧០១ ៧០២ ៧០៤ ៧០៥ និង៧០៦ មកពីកងវរសេនាធំលេខ៦០១ របស់កងពលលេខ១៧៤ ត្រូវបានចាប់ខ្លួនកើនឡើងជាលំដាប់ និងបញ្ជូនមកមន្ទីរស-២១។ អង្គភាពទាំងនេះត្រូវបានធ្វើការសម្រិតសម្រាំងម្តងហើយម្តងទៀត៖ ឧទាហរណ៍ លេខាកងវរៈសេនាតូចលេខ៧០២ ឈ្មោះ សាក់ ម៉ាន ហៅ វឿន ត្រូវបានចាប់ខ្លួននៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយអ្នកបន្តតំណែងពីគាត់ឈ្មោះ អ៊ុន អ៊ឹម ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៧៨។

## ក្រសួងពាណិជ្ជកម្ម

៦៧០- ក្រោយពេល កុយ ធួន ត្រូវចាប់ខ្លួន កម្មាភិបាលជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម ឈ្មោះ វ៉ាន់ រិត ជាអ្នកឡើងកាន់តំណែងបន្ត និងបានដឹកនាំការសម្រិតសម្រាំងក្នុងក្រសួងពាណិជ្ជកម្ម ដោយចាប់ផ្តើមពីបុគ្គលិកជាន់ខ្ពស់ទៅ។ វ៉ាន់ រិត ជាអ្នកកំណត់ និងបរិហារ"ជនក្បត់" "អ្នកបំផ្លិចបំផ្លាញ" និង"ខ្មាំង"ផ្សេងទៀត ឬសមាសភាពសង្ស័យនៅក្នុងក្រសួងពាណិជ្ជកម្ម ដើម្បីចាប់ខ្លួន ធ្វើទារុណ្ណកម្ម និងសម្លាប់។ កម្មាភិបាលទាំងនេះរួមមាន អនុលេខាឈ្មោះ តាន់ ទ្រី ហៅ ឈឿន និងអនុលេខាក្រោយមកទៀតឈ្មោះ ង៉ែត យូ ហៅ ហុង កម្មាភិបាលជាន់ខ្ពស់ដូចជា សូ ជា ហៅ សូ ហៅ សូ ជួន ជាដើម។ ទិត សុន ហៅ ញ៉ែម ដែលមានលេខរៀងទី១៧ នៅក្នុងបញ្ជីរបស់ ធួន ត្រូវបានចាប់ខ្លួន បន្ទាប់ពី ធួន ត្រូវបានឃុំឃាំងនៅក្នុងផ្ទះ។ គាត់ត្រូវបានតែងតាំងជាអនុប្រធានគណៈពាណិជ្ជកម្មរដ្ឋ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ តែនៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៦ ត្រូវបានគេសួរចម្លើយនៅមន្ទីរស-២១។ មុនពេលត្រូវបានគេយកទៅសម្លាប់ គាត់ទ្រាំទ្ររស់បាន១៣ខែ ក្រោមការធ្វើទារុណ្ណកម្មយ៉ាងធ្ងន់ធ្ងរ ពី ប៊ុន និងបានផ្តល់នូវចម្លើយសារភាពចំនួន៤០ ដែលសរុបចំនួនជិត៥០០ទំព័រ។ "ខ្មាំង" ដែលត្រូវធ្វើការសម្រិតសម្រាំងបន្ថែមទៀត រួមមាន

ស្វាយ ឡូញ ហៅឃត ជាអនុប្រធានច្រកប៉ោយប៉ែត ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៧៧ និង អ៊ឹម អុន *ហៅ*ធ ជាប្រធានច្រកបាត់ដំបង ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៧៧។ នៅខែធ្នូ ឆ្នាំ១៩៧៨ វ៉ាន់ រិត បានបញ្ជាឲ្យបញ្ជូន អ៊ឹង សុក និងប្រពន្ធឈ្មោះ ផល វ៉ា *ហៅ*ហ្វូ ណាត ត្រឡប់ពីហុងកុងវិញ ដែលពួកគេជាបុគ្គលិកក្នុងក្រុមហ៊ុន រ៉ឺន ហ្វុង (Ren Fung)។ ពេលពួកគេមកដល់ អ្នកទាំងពីរត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ហើយក្រោយមកក៏ត្រូវគេសម្លាប់។

៦៧១- ក្នុងអំឡុងពេលធ្វើការសម្រិតសម្រាំងក្នុងក្រសួងពាណិជ្ជកម្មពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ វ៉ាន់ រិត បានអះអាងថា "ការបោសសំអាត ត្រូវធ្វើដើម្បីទុកតែអ្នកល្អ ទោះបីជាត្រូវនៅសល់តែអ្នកល្អតែម្នាក់ក៏ដោយ"។ គាត់ដឹកនាំប្រជុំការងារនៅក្នុងក្រសួងពាណិជ្ជកម្ម និងមន្ទីរតូចៗដែលនៅអមក្រសួងនោះដែលក្នុងនោះ គាត់បាននិយាយគាំទ្រគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាចំពោះខ្មាំង និងជនសង្ស័យផ្សេងទៀត និងបានធ្វើយុត្តិកម្មចំពោះការចាប់ខ្លួនមនុស្សផងដែរ។ គាត់បានបរិហារ "អំពើក្បត់ជាតិ" របស់ កុយ ធួន និង អ្នកផ្សេងទៀតដែលបានចាប់ខ្លួននៅឆ្នាំ១៩៧៧ និងបានប្រកាសថា ជនដែលជាប់សង្ស័យថាមានទំនាក់ទំនងទៅនឹងនិន្នាការនយោបាយរបស់ សោ ភឹម ត្រូវបញ្ជូនទៅ "អប់រំកែប្រែ"។ ការចាប់ខ្លួន និងការបាត់ខ្លួនជាបន្តបន្ទាប់នៃកម្មាភិបាលនៅក្នុងក្រសួងពាណិជ្ជកម្ម បានបង្កើតជាបរិយាកាសភ័យខ្លាច និងការបំភិតបំភ័យ។ វ៉ាន់ រិត បានបញ្ជាឲ្យចាប់ប្រពន្ធ កូនកម្មាភិបាលជាប់ចោទទាំងនោះ ត្រូវបញ្ជូនទៅមន្ទីរស-២១ និងសម្លាប់។ និរសាររបស់ កុយ ធួន និង ទិត សុន ហៅ ញ៉ែម ក៏ត្រូវបានចាប់ខ្លួន ចំពោះករណីដូចគ្នានេះផងដែរ។ ក្នុងរយៈពេលដ៏វែងមួយ កម្មាភិបាលដែលទទួលការចោទប្រកាន់ រួមទាំងកម្មាភិបាលជាន់ទាបមកពីអង្គភាពជាច្រើន នៅក្នុងក្រសួងពាណិជ្ជកម្ម ត្រូវបានឃុំឃាំង

និងបញ្ជូនទៅមន្ទីរស-២១ ដោយផ្ទាល់ ឬក្នុងឱកាសផ្សេងទៀត ត្រូវបញ្ជូនតាមរយៈមន្ទីរស-២៤ (ព្រៃស)។

៦៧២- សរុបមក ចាប់ពីថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ ជាពេលវេលាដែល កុយ ធួន ត្រូវបានចាប់ខ្លួន មានមនុស្សចំនួន៦២នាក់ នៅក្រសួងពាណិជ្ជកម្ម និងមន្ទីរជុំវិញក្រសួងនោះ ត្រូវបានបញ្ជូនទៅមន្ទីរស-២១។ ពីថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ រហូតដល់ពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ មានមនុស្សចំនួន៤២៥នាក់បន្ថែមទៀត ត្រូវបានដកចេញពីក្រសួងពាណិជ្ជកម្ម និងជាប់ឃុំឃាំងនៅមន្ទីរស-២១។ យ៉ាងហោចណាស់ អ្នកទោសចំនួន៩៧នាក់ក្នុងចំណោមអ្នកទោសទាំងនេះ ជាទូទៅត្រូវបានគេយកចម្លើយសារភាពតាមរយៈការធ្វើទារុណកម្ម។ ក្នុងចន្លោះពេលដែល កុយ ធួន ត្រូវចាប់ខ្លួននៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៧ មានការចាប់ខ្លួនមនុស្សចំនួន១៦៤នាក់ ត្រូវបានធ្វើឡើងនៅក្នុងក្រសួងពាណិជ្ជកម្ម៦០នាក់ នៅឃ្លាំងរដ្ឋ និង១១៣នាក់ នៅកំពង់ផែកំពង់សោម។ នៅឆ្នាំ១៩៧៨ មានមនុស្សយ៉ាងហោចណាស់ចំនួន២២នាក់ ត្រូវបានចាប់ខ្លួនពីក្រសួងពាណិជ្ជកម្ម១៦នាក់ ចាប់ខ្លួនពីឃ្លាំងរដ្ឋ និង៥០នាក់ពីកំពង់ផែកំពង់សោម។ មានបុគ្គលិកពីក្រសួងពាណិជ្ជកម្មជាច្រើនផ្សេងទៀត ត្រូវបានបញ្ជូនទៅកន្លែងអប់រំកែប្រែ និងការដ្ឋានធ្វើពលកម្មដោយបង្ខំ រួមមាន នៅពេជ្រនិលតាមផ្លូវជាតិលេខ៤ ជំរុំការដ្ឋានផ្លូវអាយស្ម័យយានខាងជើងព្រលានយន្តហោះពោធិ៍ចិនតុង ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងស្រែអំបិលក្នុងតំបន់៣៧ នៃភូមិភាគបស្ចិម ដែលនៅទីនោះ ពួកគេមួយចំនួនត្រូវបានគេសម្លាប់ ហើយអ្នកផ្សេងទៀតត្រូវស្លាប់បាត់បង់ជីវិត។

## ភូមិភាគកណ្ដាល (ឧត្តរចាស់)

៦៧៣- នៅខែមេសា ឆ្នាំ១៩៧៥ កុយ ធួន បានគ្រប់គ្រង"ភូមិភាគឧត្តរ" ដ៏ធំដែលរួមមាន តំបន់៤១ ៤២ ៤៣ ១០៣ និង១០៦។ នៅពេល ធួន ក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងខែឧសភា ឆ្នាំ ១៩៧៥ អនុប្រធានរបស់គាត់ឈ្មោះ កែ ពក ត្រូវបានតម្លើងឋានៈជាលេខាភូមិភាគឧត្តរមួយ ដែលរួមមាន តំបន់៤១ ៤២ និង៤៣ ទន្ទឹមនឹងពេលដែលតំបន់១០៣ និង១០៦ ត្រូវបានបង្កើតជា តំបន់ស្វយ័តដែលត្រូវរាយការណ៍ផ្ទាល់ទៅគណៈអចិន្ត្រៃយ៍។ នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ភូមិ ភាគឧត្តរថ្មីមួយ ត្រូវបានបង្កើតឡើងដោយរួមមាន តំបន់១០៣ និង១០៦ ហើយភូមិភាគឧត្តរ ចាស់ ក្លាយជាភូមិភាគកណ្ដាលវិញ។

៦៧៤- លេខាភូមិភាគកណ្ដាល កែ ពក ត្រូវបានកោះហៅដោយ ប៉ុល ពត និង **នួន ជា** ឱ្យមកភ្នំពេញ នៅដើមឆ្នាំ១៩៧៧ ដើម្បីជួយរៀបចំផែនការសម្រិតសម្រាំងនៅក្នុងភូមិភាគរបស់គាត់។ កែ ពក ខ្លួនឯងបានផ្ដល់នូវការងារពិស្ដារនៃព្រឹត្តិការណ៍នានានៅក្នុងភូមិភាគកណ្ដាលដូចតទៅ៖

"នៅខែកុម្ភៈ ឆ្នាំ១៩៧៧ រថយន្តសន្តិសុខមួយពីភ្នំពេញមកចាប់លេខាក្រសួង រួមមាន ក្រសួង កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សាធារណៈការ។ ... ក្នុងឆ្នាំ១៩៧៧ដែរ រថយន្តសន្តិសុខ មួយពីភ្នំពេញ មកចាប់សមាជិកគណៈតំបន់៤១ ចំនួន៥-៦នាក់ តំបន់៤២ ចំនួន៥-៦នាក់ តំបន់ ៤៣ ចំនួន៥-៦នាក់។ ក្រោយពីចាប់សមាជិកគណៈតំបន់អស់ហើយ ពួកគេក៏ចាប់ថ្នាក់ដឹកនាំ ក្រសួងតាមតំបន់ទៀត ព្រោះតំបន់នីមួយៗនោះសុទ្ធតែមានក្រសួងផ្ទាល់របស់ខ្លួន។ មិនយូរ ប៉ុន្មាន រថយន្តសន្តិសុខមួយពីភ្នំពេញ មកចាប់គណៈបញ្ជាការយោធាភូមិភាគទៀត។ សរុប កម្មាភិបាលក្រសួង និងតំបន់ដែលត្រូវបានចាប់ខ្លួនមានចំនួន៥០ ទៅ៦០នាក់។.. ក្រោយមក គឺ

ក្នុងខែឧសភា ឆ្នាំ១៩៧៧ រថយន្តសន្តិសុខមួយពីភ្នំពេញមកចាប់គណៈស្រុកទៀត ដែលមួយស្រុកៗ មានចំនួនពី២-៣នាក់។ រួចហើយពួកគេចាប់ប្រធានឃុំខ្លះ (មិនគ្រប់ឃុំទាំងអស់ទេ)។ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ ការចាប់ខ្លួនក្នុងវគ្គដំបូងត្រូវបានបញ្ចប់។ នៅពេលនោះនៅសល់តែខ្ញុំ(កែ ពក) ម្នាក់គត់"។

៦៧៥- ដូចបានរំលឹកឡើងវិញដោយ កែ ពក ថា បណ្តាសមាជិកគណៈភូមិភាគ និងមេដឹកនាំតំបន់នានានៃភូមិភាគកណ្តាលភាគច្រើន ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១ ចន្លោះពាក់កណ្តាលខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧។ អ្នកទាំងនោះរួមមាន អនុលេខាភូមិភាគ ឈ្មោះ ជ ឆាន់ ហៅ ស្រេង (ស្ថិតនៅលេខរៀងទី១០ ក្នុងបញ្ជីរបស់ កុយ ធួន) និងលេខាតំបន់៤១ ឈ្មោះ ជុន ឈុំ ហៅ តាំង ដែលអ្នកទាំងពីរ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ រួមទាំងលេខាតំបន់៤២ និងសមាជិកគណៈភូមិភាគ ឈ្មោះ ចាន់ ម៉ុន ហៅ តុល ដែលត្រូវបានបញ្ជូនចូលមន្ទីរស-២១ នៅថ្ងៃបន្ទាប់។ ក្នុងរយៈពេលពីរថ្ងៃដូចគ្នានោះ ពួកប្រធានគណៈពាណិជ្ជកម្ម កសិកម្ម មន្ទីរពេទ្យ សាធារណៈការ និងសមាជិកគណៈឧស្សាហកម្ម របស់ភូមិភាគ ក៏ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ដែរ។ ជាងនេះទៀត ថ្នាក់ដឹកនាំក្រសួង និងយោធាភូមិភាគផ្សេងទៀត ក៏ត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៧ ដោយមានការសម្រិតសម្រាំងបន្ថែមទៀត នៅខែតុលា ឆ្នាំ១៩៧៧ និងឆ្នាំបន្ទាប់។ ថ្នាក់ដឹកនាំ នៅថ្នាក់ស្រុកក្នុងភូមិភាគនេះ ត្រូវចាប់ខ្លួនជាទ្រង់ទ្រាយធំដែរនៅចុងខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧ ដោយការចាប់ខ្លួននៅវគ្គទីពីរធ្វើឡើងចន្លោះខែសីហា និងខែវិច្ឆិកា ឆ្នាំ១៩៧៧។

៦៧៦- ក្នុងអំឡុងពេលនៃការសម្រិតសម្រាំងក្នុងភូមិភាគនេះ មានកម្មាភិបាលរាប់រយនាក់មកពីថ្នាក់ភូមិ សហករណ៍ ស្រុក តំបន់ និងភូមិភាគ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដើម្បីធ្វើទារុណ្ណកម្ម និងសម្លាប់។ គ្រាន់តែបញ្ជីឈ្មោះអ្នកទោសមួយប៉ុណ្ណោះ មានកម្មាភិបាលជាថ្នាក់ដឹកនាំភូមិភាគកណ្ដាលចំនួន៨៤នាក់ ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៧៧។ នៅពេលការសម្រិតសម្រាំងត្រូវបានបញ្ចប់ លេខាភូមិភាគកណ្ដាល កែ ពក បានត្អូញត្អែរថា គាត់ជាកម្មាភិបាលចាស់តែម្នាក់គត់ដែលនៅរស់។ អតីតកម្មាភិបាលភូមិភាគនេះម្នាក់ទៀត បានរំលឹកឡើងវិញថា មានកម្មាភិបាលធំៗតែបួននាក់ប៉ុណ្ណោះ មកពីភូមិភាគកណ្ដាលដែលនៅរស់ពីការសម្រិតសម្រាំងនោះ។ នៅពេល កែ ពក ត្អូញត្អែរប្រាប់ **អៀង សារី** ពីការចាប់ខ្លួនជាទ្រង់ទ្រាយធំទៅលើអ្នកក្រោមបង្គាប់របស់គាត់ **អៀង សារី** បានកត់សម្គាល់ថា បញ្ហាដដែលនេះក៏ធ្លាប់បានកើតឡើងដែរ នៅក្នុងសម័យបដិវត្តន៍ចិន។

៦៧៧- មានកម្មាភិបាលភូមិភាគនិរតីចំនួនជាង២០០នាក់ ត្រូវបានបញ្ជូនទៅជំនួសកម្មាភិបាលនៅភូមិភាគកណ្ដាល ដែលត្រូវបានគេសម្រិតសម្រាំង ក្រោមការដឹកនាំរបស់លេខាតំបន់៣៥ ឈ្មោះ ចាន់ សំ ហៅ កង ចាប ហៅ សែ (ជាអ្នកដែលធ្លាប់ទៅសៀមរាប ដើម្បីដឹកនាំភូមិភាគឧត្តរថ្មី) [redacted]។ កម្មាភិបាលភូមិភាគនិរតីដែលគ្រប់គ្រងភូមិភាគកណ្ដាល បានពង្រីកវិសាលភាពនៃការសម្រិតសម្រាំងទៅដល់ថ្នាក់ភូមិទៀតផង។ ឧទាហរណ៍ ថ្នាក់ដឹកនាំនៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ត្រូវបានសម្រិតសម្រាំងបួនដងបន្តបន្ទាប់គ្នា។ កម្មាភិបាលជាច្រើនក្នុងចំណោមកម្មាភិបាលដែលត្រូវបានសម្រិតសម្រាំង ត្រូវ

បានសម្លាប់នៅតាមមន្ទីរសន្តិសុខភូមិភាគ តំបន់ និងស្រុក នៅក្នុងភូមិភាគកណ្តាលនេះ ដូចជា នៅវត្តបារាយណ៍ជាន់ដែកជាដើម ដោយមិនចាំបាច់យកមកមន្ទីរស-២១ទេ។

## ភូមិភាគឧត្តរថ្មី

៦៧៨- ចម្លើយសារភាពរបស់ កុយ ធួន នៅមន្ទីរស-២១ បានកំណត់ជនក្បត់១៩នាក់ នៅក្នុងមូលដ្ឋានចាស់របស់គាត់គឺតំបន់១០៦ ដែលត្រូវបានគេចាត់ទុកថាជា "គណៈកម្មាធិការប្រឆាំងបដិវត្តន៍"។ កម្មាភិបាលដែលត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១ ទាំងនេះរួមមាន៖ លេខាតំបន់១០៦ និងស្ថិតនៅលេខរៀងទី១១ ក្នុងបញ្ជីរបស់ ធួន ឈ្មោះ ប៉ា ផល ហៅ សុត (ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧) លេខាស្រុកស្វូត្រនិគមឈ្មោះ ញ៉ែម នឿន ហៅ ឃឿន (ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៧) លេខាស្រុកពួកឈ្មោះ ប្រាក់ សំ ហៅ បេង (ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៧) សមាជិកពាណិជ្ជកម្មតំបន់១០៦ ឈ្មោះ តុប សាគុម ហៅ សាន (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧) ប្រធានសន្តិសុខតំបន់១០៦ ឈ្មោះ យ៉ង់ ពៅ (ខែមីនា ឆ្នាំ១៩៧៧) លេខាកងពល៣៣៥ នៃតំបន់១០៦ និងស្ថិតនៅលេខរៀងទី១៨ ក្នុងបញ្ជីរបស់ កុយ ធួន ឈ្មោះ នូ ឆន ហៅ ប៊ាន (ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧) និងអនុលេខាកងពល៣៣៥ ឈ្មោះ ចាន់ ចុល ហៅ ប៉ូល (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧)។ នៅពេលដែលមេដឹកនាំតំបន់១០៦ ទាំងនេះ ត្រូវបានឃុំឃាំងនៅមន្ទីរ ស-២១ ការសម្រិតសម្រាំងបានធ្វើឡើងតាមរយៈថ្នាក់ក្រោម រួមមានមេកង និងប្រធានភូមិផងដែរ។

៦៧៩- កម្មាភិបាលដែលត្រូវគេសម្រិតសម្រាំង ត្រូវបានជំនួសដោយកម្មាភិបាលដែលមកពីភូមិភាគនិរតី។ កង ចាប ហៅ សែ បានចាកចេញពីតំបន់៣៥ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ជាមួយនឹង

កម្មាភិបាលភូមិភាគនិរតីមួយក្រុមធំ មកដល់សៀមរាបនៅចុងខែមីនា ឬដើមខែមេសា ឆ្នាំ ១៩៧៧ ហើយក្រោយមកក៏ត្រូវបានគេតែងតាំងជាលេខាភូមិភាគឧត្តរថ្មី។ គាត់បន្តការសម្រិតសម្រាំងភូមិភាគនេះ ដោយរាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្ស រួមមាន **នួន ជា** និង **អៀង សារី**។ ឧទាហរណ៍ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧ កង ចាប បានរាយការណ៍ទៅមន្ទីរ៨៧០ ស្តីពីលទ្ធផលនៃសន្និបាតដែលគាត់រៀបចំធ្វើនៅស្រុកចំនួន៥ ក្នុងតំបន់១០៣ ដោយបានអះអាងថា "ត្រូវសម្រិតសម្រាំងកម្មាភិបាលតាំងពីថ្នាក់ស្រុក ដល់ថ្នាក់សហគមន៍ជាបណ្តើរៗ ដើម្បីបង្កើនគុណភាពដឹកនាំ" និងដើម្បីបន្ត "វាយសម្រុកបោសសម្អាតខ្មាំង"។ **នួន ជា** និង **ខៀវ សំផន** ធ្លាប់បានធ្វើទស្សនកិច្ច និងបានគ្រប់គ្រងភូមិភាគឧត្តរ។

៦៨០- នៅចុងឆ្នាំ១៩៧៧ **នួន ជា** បានរៀបចំកិច្ចប្រជុំសម្ងាត់មួយជាមួយលេខាភូមិភាគ កង ចាប និងអនុលេខាឈ្មោះ សារឿន បន្ទាប់ពីមានការចាប់ខ្លួនមនុស្សជាបន្តបន្ទាប់នៅក្នុងមូលដ្ឋាននេះ រួមមាន៖ លេខាតំបន់១០៣ ឈ្មោះ ប៊ូ ផាត ហៅ ហង្ស (ដែលចូលមន្ទីរស-២១ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៨) និង"មនុស្សផ្សេងទៀតក្នុងតំបន់១០៣"។ ហង្ស ត្រូវបានជំនួសក្នុងឋានៈជាលេខាតំបន់ដោយ តា ឃឹម ដែលជាកម្មាភិបាលមកពីភូមិភាគនិរតី។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ ១៩៧៨ មួយសប្តាហ៍បន្ទាប់ពីការចាប់ខ្លួន ហង្ស ដែលជាលេខាតំបន់១០៣ កង ចាប បានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍ (រួមមាន **នួន ជា** និង **អៀង សារី**) ថា ខ្មាំងបានជ្រៀត "ពីថ្នាក់តំបន់ ស្រុក ទៅដល់ឃុំ" ហើយថាគាត់នឹងត្រូវបន្តធ្វើការនៅតំបន់១០៣ និង"បញ្ជូនក្រពើជាច្រើនទៀតទៅឱ្យអង្គការ"។ ពីរខែក្រោយមក កង ចាប បានផ្ញើរបាយការណ៍ទៅមជ្ឈិមបក្សដោយអះអាងថា ពួកគេបាន"ធ្វើការសម្រិតសម្រាំងជាប្រព័ន្ធ" នូវខ្មាំងដែលមានទំនាក់ទំនងជាមួយអតីត "ប៉ូលីស ទាហាន និងមន្ត្រីរដ្ឋាភិបាល" និង"ប្រជាជនថ្មី" ហើយថា ពួកគេមាន

ផែនការ "ចាប់ខ្លួនមនុស្សបន្ថែមទៀត"។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ កង ចាប បាន និយាយយោងទៅដល់ការចាប់លេខា "ហង្ស និងកូនចៅរបស់វានៅស្រុកជាំក្សាន្ត និងក្នុងយោធាតំបន់១០៣" ហើយបានរាយការណ៍ថា ពួកគេ "កំពុងបន្តសម្រិតសម្រាំងក្រុមដែលនៅសេសសល់ជាបន្តទៀត រួមទាំងអ្នកប្រឆាំងនឹងបដិវត្តន៍របស់យើងផង"។ កម្មាភិបាលជាច្រើនដែលត្រូវបានគេសម្រិតសម្រាំងពីតំបន់១០៣ និងតំបន់១០៦ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភូមិភាគនៅសៀមរាប ជាជាងបញ្ជូនទៅមន្ទីរស-២១។ [redacted]។ ការចាប់ខ្លួនសាក្សីរូបនេះត្រូវបាន [redacted]។

៦៨១- វលកចុងក្រោយនៃការសម្រិតសម្រាំងនៅភូមិភាគឧត្តរ ធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨។ កង ចាប ខ្លួនឯងជាលេខាភូមិភាគ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៨ និងត្រូវជំនួសដោយ ពៅទ្យ សឿង ដែលពីមុនជាមេបញ្ជាការកងពលលេខ១ នៃភូមិភាគបស្ចិម និង ជាសមាជិកគណៈភូមិភាគបស្ចិម។ សឿង ត្រូវបាន "តែងតាំង" ជាប្រធានភូមិភាគថ្មីនៅឯកិច្ចប្រជុំមួយដែលបានរៀបចំឡើងនៅសៀមរាប ដោយមានការចូលរួមពី ប៉ុល ពត និង តា ម៉ុក។ នៅខែសីហា ឆ្នាំ១៩៧៨ ដដែលនោះដែរ ឃឹម ជាលេខាតំបន់១០៣ ក៏ត្រូវបានចាប់ខ្លួន និងបញ្ជូន

ទៅសៀមរាប [redacted]

[redacted]។ កង ចាប ត្រូវបានគេសម្លាប់នៅមន្ទីរស-២១ ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៨។

## កងពល និងក្រសួងផ្សេងទៀតដែល កុយ ធួន បានឆ្លើយដាក់

៦៨២- ក្រៅពីកងពល៣១០ ៤៥០ និង១៧៤ ក្រសួងពាណិជ្ជកម្ម ភូមិភាគកណ្តាល និងភូមិភាគឧត្តរ ដែលបង្កើតឡើង និង/ឬដឹកនាំដោយ កុយ ធួន មានកងពល ក្រសួង ភូមិភាគ និងតំបន់ស្វយ័ត ជាច្រើនផ្សេងទៀត ត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់គាត់ ហេតុនេះវាក៏ក្លាយជា កម្មវត្ថុនៃការសម្រិតសម្រាំងផ្ទាល់ពីមជ្ឈិមបក្សដែរ។

៦៨៣- ការសម្រិតសម្រាំងកងពលលេខ១៧០ បានចាប់ផ្តើមជាលើកដំបូង ដោយការចាប់ខ្លួន ចាន់ ចក្រី ជាលេខាកងពល នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ ដែលស្ថិតនៅលេខរៀងទី៩ ក្នុងបញ្ជីខ្សែក្បត់ របស់ កុយ ធួន។ អនុលេខាកងពលឈ្មោះ លី វ៉ាយ ហៅ សុផាន បានផ្តល់ចម្លើយ សារភាពលើកទី១ ចំនួន៤១សន្លឹកយ៉ាងតិច នៅមន្ទីរស-២១ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៦។ មានយុទ្ធជន និងកម្មាភិបាលជាន់ខ្ពស់នៅកងពល១៧០ ជាង១០០នាក់ ត្រូវបានបញ្ជូនមកមន្ទីរ ស-២១ ចន្លោះខែកក្កដា និងខែធ្នូ ឆ្នាំ១៩៧៦ និងយ៉ាងហោចមានមនុស្សចំនួន១១០នាក់ ផ្សេង ទៀត ត្រូវបានបញ្ជូនមកមន្ទីរស-២១ នៅឆ្នាំ១៩៧៧។ ការសម្រិតសម្រាំងកងពលលេខ១៧០ បន្តរហូតដល់ឆ្នាំបន្ទាប់ ហើយអ្នកបន្តតំណែងពី ចាន់ ចក្រី ជាលេខាឈ្មោះ កែ សាន ហៅ សុក ក៏ត្រូវបានចាប់ខ្លួននៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៧៨។

៦៨៤- រដ្ឋមន្ត្រីក្រសួងកសិកម្មឈ្មោះ នន សួន ស្ថិតនៅលេខរៀងទី៤ ក្នុងបញ្ជីរបស់ កុយ ធួន ត្រូវបានឆ្លើយដាក់តាមចម្លើយសារភាពរបស់ ចក្រី និង ឈ្យូក ហេតុនេះក៏ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ នៅក្នុងលិខិតមួយផ្ញើទៅឲ្យ នុន សួន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ប៉ុន្តែអ្នកសួរចម្លើយបានពន្យល់ពីស្ថានភាពធ្ងន់ធ្ងររបស់គាត់ថា៖ "ការឃុំឃាំងអ្នកឯងជាការសម្រេចមកពីគណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស មិនមែនធ្វើឡើងដោយថ្នាក់ណា ឬ ផ្នែកណាមួយរបស់បក្សទេ"។ អនុលេខាគណៈកម្មាធិការកសិកម្មឈ្មោះ ដួង ធឿន ហៅ សេង ហៅ ណេង ត្រូវបានសម្លាប់នៅមន្ទីរស-២១ នាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៧៧ និង សមាជិកគណៈកម្មាធិការកសិកម្មឈ្មោះ ប៊ិន ឈាង ហៅ លី ត្រូវបានសម្លាប់នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៧៧។ បន្ទាប់ពីការចាប់ខ្លួនមេដឹកនាំគណៈកម្មាធិការកសិកម្មរួច ការសម្រិតសម្រាំង បានរាលដាលទៅគ្រប់លំដាប់ថ្នាក់នៅក្នុងក្រសួងកសិកម្មទាំងមូល។

៦៨៥- សឿ វ៉ាស៊ី ហៅ ឌឿន គឺជាសមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាមន្ត្រីសំខាន់របស់មជ្ឈិមបក្ស ដែលត្រូវបានតែងតាំងជា "ប្រធានមន្ទីរនយោបាយ៨៧០" នៅខែតុលា ឆ្នាំ១៩៧៥។ គាត់បានបង្កើតគណៈមន្ទីរ៨៧០ រួមគ្នាជាមួយ **ខៀវ សំផន**។ គាត់ស្ថិតនៅលេខរៀងទី៣ ក្នុងបញ្ជីពួកក្បត់របស់ កុយ ធួន ហើយត្រូវបានចាប់ខ្លួននៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៧។ កម្មាភិបាលផ្សេងទៀតដែលនៅមន្ទីរ៨៧០ ដូចជា អោគ ឆាយ ហៅ ទូច ក៏ត្រូវបានបញ្ជូនមកមន្ទីរស-២១ តាមក្រោយ ឌឿន ភ្លាមដែរ។ នៅពេល ឌឿន ចេះតែបន្តបញ្ចេញឈ្មោះ "ខ្សែរយៈ" របស់ខ្លួន ការគម្រាមកំហែងចំពោះចំណុចស្នូលរបស់អង្គការបក្សលាតសន្ធឹងផ្ទាល់ទៅក្នុងទីបញ្ជាការបុគ្គលិករបស់ ប៉ុល ពត តែម្តង។ ប្រធានមន្ទីរក-១ ឈ្មោះ កេត ចៅ ហៅ កេត ធ

ហៅ សែម បានឆ្លើយសារភាពក្រោម "ការធ្វើទារុណ្ណកម្មធ្ងន់ធ្ងរ" ពី ប៉ុន ចំពោះផែនការសម្លាប់ ប៉ុល ពត និង **នួន ជា**។ កម្មាភិបាលកាន់តែច្រើនទៀតនៅ ក-១ និង ក-៣ ត្រូវបានសម្រិតសម្រាំងតាមការចោទប្រកាន់ទាំងនោះ។

៦៨៦- រដ្ឋមន្ត្រីក្រសួងឃោសនាការឈ្មោះ ហ៊ូ នឹម ហៅ ភាស់ ស្ថិតនៅលេខរៀងទី១៣ ក្នុងបញ្ជីរបស់ កុយ ធួន។ បន្ទាប់ពីត្រូវគេតាមដានមួយរយៈមក ភាស់ ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧។ ក្រោយបន្តិចមក អនុរបស់គាត់ឈ្មោះ ទីវ អុល ហៅ ពេញ ត្រូវបានចាប់ខ្លួនដោយមន្ទីរស-២១។ មនុស្សជំនិតពីរនាក់របស់ ហ៊ូ នឹម ឈ្មោះ តូច ភឿន ហៅ ភិន ស្ថិតនៅលេខរៀងទី១២ ក្នុងបញ្ជីរបស់ កុយ ធួន និង កោគ ឆាយ ហៅ ទូច ត្រូវបានចាប់ខ្លួនជាមុនរួចហើយ។ ជាបន្តបន្ទាប់មកទៀត គឺមានការសម្រិតសម្រាំងកម្មាភិបាលនៅក្នុងក្រសួងឃោសនាការតែម្តង។ កម្មាភិបាលមួយចំនួនត្រូវបានគេបញ្ជូនឲ្យធ្វើពលកម្មដោយបង្ខំនៅមន្ទីរស-២៤ ដែលនៅរស់រានមានជីវិត។

## ការសម្រិតសម្រាំងនៅភូមិភាគបូព៌ា

### សេចក្តីផ្តើម

៦៨៧- ការសម្រិតសម្រាំងនៅភូមិភាគបូព៌ាត្រូវបានគេអះអាងថា បានធ្វើឡើងចំពោះជីវិតមនុស្សពីចន្លោះ១០០០០០នាក់ ដល់២៥០០០០នាក់។ វាជាប្រតិបត្តិការសម្លាប់មនុស្សដែលស្មុគស្មាញជាងគេ ដែលបានធ្វើឡើងដោយមជ្ឈិមបក្ស ដោយចំណាយពេលជាងមួយឆ្នាំ គឺពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨។ អ្នកដែលមិនត្រូវបានគេសម្លាប់ ត្រូវគេបញ្ជូនទៅតាម

សហករណ៍នៅក្នុងភូមិភាគផ្សេងទៀត ដូចជានៅខេត្តពោធិ៍សាត់ ក្នុងភូមិភាគពាយ័ព្យ ឬទៅធ្វើការនៅតាមការដ្ឋាននានា ដូចជា ការសាងសង់ព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំង ជាដើម។

៦៨៨- ផ្នែកនេះ យើងនឹងពិភាក្សាអំពីទិដ្ឋភាពនានានៃការសម្រិតសម្រាំងនោះ៖ (១)ការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា ដែលចាប់ផ្តើមដោយការសម្រិតសម្រាំងតំបន់២២ នៅពាក់កណ្តាលឆ្នាំ១៩៧៧ និងឡើងដល់កំពូលនៅចុងខែឧសភា ឆ្នាំ១៩៧៨ ជាពេលដែលការចាប់ខ្លួនបានរីករាលដាលពេញភូមិភាគទាំងមូល (២)ការសម្លាប់រង្គាលទាំងអ្នកភូមិនៃភូមិភាគបូព៌ាមកពីស្រុកពញាក្រែក នៅស្ទឹងតូច នៅដើមខែមិថុនា ឆ្នាំ១៩៧៨ (៣)ការជម្លៀសអ្នកភូមិភាគបូព៌ាដែលនៅសល់ដោយបង្ខំ ទៅកាន់មូលដ្ឋានផ្សេងទៀតនៅទូទាំងប្រទេស និង(៤)ការសម្លាប់រង្គាលអ្នកត្រូវជម្លៀសពីភូមិភាគបូព៌ា នៅខេត្តពោធិ៍សាត់នៃភូមិភាគពាយ័ព្យ នៅចុងឆ្នាំ១៩៧៨។

## ការចាប់ខ្លួន និងការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា

៦៨៩- ទស្សនាវដ្តីទង់បដិវត្តដែលចេញផ្សាយខែមិថុនា ឆ្នាំ១៩៧៧ បានដាស់តឿនក្រើនរំលឹកកម្មាភិបាល ឱ្យ“ដាច់ខាត” ក្នុងការបន្តសម្រិតសម្រាំងរបស់បក្ស៖ “យើងបានសម្រិតសម្រាំងផ្ទៃក្នុងបក្សបានល្អ គ្រប់ថ្នាក់ គ្រប់ផ្នែក តាំងពីលើដល់ក្រោម។ ... ប៉ុន្តែទន្ទឹមនឹងនេះ ខ្មាំងបង្កប់ផ្ទៃក្នុងមិនទាន់អស់នៅឡើយទេ។ កម្លាំងចាស់ ដែលខ្មាំងគ្រប់ប្រភេទបង្កប់ស៊ីរូងមិនទាន់អស់ទាំងស្រុងទេ។ វានៅសល់ច្រើនប៉ុន្មានទេ តែវានៅសល់ខ្លះ នៅរាយរងតាមមូលដ្ឋាន តាមអង្គភាពនានា ក្រសួង និងមន្ទីរ។ ... ត្រូវមានវិធានការកំចាត់វាដាច់ខាត គ្មានសម្រុះសម្រួល គ្មានអធ្យាស្រ័យ គ្មានញញើតញញើមរារែកអ្វីទាំងអស់”។

៦៩០- មជ្ឈិមបក្សកំពុងរៀបចំផែនការមួយដើម្បីបោសសម្អាត "កម្លាំងចាស់" ដែលត្រូវគេកំណត់ថាជាខ្មាំង។ សួស នៅ ហៅ ឈូក ដែលជាលេខាតំបន់២៤ ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ និងជំនួសដោយ សេង ហុង ហៅ ចាន់។ ចាន់ ក៏ត្រូវបានតែងតាំងជាអនុលេខាភូមិភាគបូព៌ា និងជាសមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា កម្មាភិបាលភូមិភាគនិរតីដែលត្រូវបានគេនាំមកជំនួសលេខាស្រុកទាំងអស់ ក្នុងតំបន់២៤ ដែលត្រូវគេសម្រិតសម្រាំង។ ចម្លើយសារភាពរបស់ ឈូក នៅមន្ទីរស-២១ ព្រមទាំងចម្លើយសារភាពរបស់ ចក្រី (ខែសីហា ឆ្នាំ ១៩៧៦) យ៉ា (ខែកញ្ញា ឆ្នាំ១៩៧៦) និង ទុំ (ខែមិថុនា ឆ្នាំ១៩៧៧) បានធ្វើឱ្យមជ្ឈិមបក្សជឿថា ភូមិភាគបូព៌ាពោរពេញដោយពួកក្បត់។ មកដល់ពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៧ បុគ្គលិកនៅមន្ទីរស-២១ បានអនុវត្តការស្រាវជ្រាវយ៉ាងល្អិតល្អន់ក្នុងរចនាសម្ព័ន្ធរបស់ថ្នាក់ដឹកនាំនៅភូមិភាគបូព៌ា។

៦៩១- នៅខែកក្កដា ឆ្នាំ១៩៧៧ មជ្ឈិមបក្សបានចេញសេចក្តីសម្រេចថា ទីបញ្ជាការយោធាពិសេសថ្មីពីរ នឹងត្រូវបង្កើតឡើង ដែលគេឱ្យឈ្មោះថា "ខ្សែត្រៀមផ្លូវជាតិលេខ១" និង"ខ្សែត្រៀមផ្លូវជាតិលេខ៧"។ **ខ្សែត្រៀមផ្លូវជាតិលេខ១** គឺនៅតាមបណ្តោយផ្លូវជាតិលេខ១ កាត់តាមផ្នែកខាងត្បូងនៃភូមិភាគបូព៌ាពីអ្នកលឿង ត្រង់ទន្លេមេគង្គនៅក្នុងតំបន់២៤ ទៅដល់ព្រំដែនវៀតណាម នៅខេត្តស្វាយរៀង ក្នុងតំបន់២៣។ ខ្សែត្រៀមនេះស្ថិតក្រោមបញ្ជាការផ្ទាល់របស់ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកការពារជាតិ និងជាអគ្គសេនាធិការកងទ័ពបដិវត្តកម្ពុជា ឈ្មោះ សុន សេន។ **ទិសផ្លូវជាតិលេខ៧** នៅតាមបណ្តោយផ្លូវជាតិលេខ៧ កាត់តាមផ្នែកខាងជើងភូមិភាគបូព៌ា ពីត្រើយខាងកើតទន្លេមេគង្គក្នុងខេត្តកំពង់ចាម កាត់តាមតំបន់២០ និងតំបន់២១ ឡើងទៅ

ភូមិភាគឦសាន កាត់តាមតំបន់៥០៥។ តាមការប៉ាន់ស្មាន ខ្សែត្រៀមនេះស្ថិតក្រោមបញ្ជាការផ្ទាល់របស់លេខាភូមិភាគបូព៌ា ឈ្មោះ សោ ភឹម ដែលមានលេខាភូមិភាគកណ្តាល ឈ្មោះ កែ ពក ជាអនុលេខា។ ចលនានេះគឺធ្វើឲ្យចុះខ្សោយដល់សិទ្ធិអំណាចរបស់សេនាធិការភូមិភាគបូព៌ាទាំងមូល។

៦៩២- មជ្ឈិមបក្សក៏បានផ្តួចផ្តើមនូវគោលនយោបាយថ្មីៗផ្សេងទៀត ដែលមានឥទ្ធិពលក្នុងការធ្វើឲ្យភូមិភាគបូព៌ានៅឯកោ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ បក្សបានបញ្ជាឲ្យដាក់ពង្រាយកងទ័ពនៅភូមិភាគបូព៌ានៅតាមព្រំដែនវៀតណាម ហើយបន្ទាប់មក ក៏បញ្ជូនកងទ័ពមជ្ឈិមទៅឈរពីក្រោយពួកគេ។ ជាលទ្ធផល មានយុទ្ធជនរបស់ភូមិភាគបូព៌ាម្នាក់ត្រូវបានកងទ័ពមជ្ឈិមបាញ់សម្លាប់ពីក្រោយខ្នង នៅព្រំដែននោះ។ នៅពេលជាមួយគ្នានោះ មានអ្នកភូមិចំនួន៦០០០០នាក់ ដែលរស់នៅកៀកនឹងព្រំដែនវៀតណាម ត្រូវបានជម្លៀសចេញឆ្ងាយពីព្រំដែនមកវិញ ដោយបង្កើតជាកន្លែងខ្សែត្រៀម (*cordon sanitaire*) ដែលមានបង្កប់គ្រាប់មីនយ៉ាងច្រើនក្រាស់ក្រែល។ មជ្ឈិមបក្សក៏បានលុបបំបាត់នូវប្រព័ន្ធ *លិខិតធ្វើដំណើរ* ដែលកន្លងមកអនុញ្ញាតឲ្យកម្មាភិបាលដើរហើរទៅកាន់ភូមិភាគផ្សេងទៀត ដោយមានលិខិតដើរផ្លូវដែលចេញដោយលេខាភូមិភាគរបស់ខ្លួន។ ជាលទ្ធផលបុគ្គលិកនៅភូមិភាគបូព៌ាមិនអាចធ្វើដំណើរទៅភាគខាងជើងក្នុងតំបន់៥០៥ និងទៅភាគខាងលិច ក្នុងភូមិភាគកណ្តាល ឬទៅភាគខាងត្បូងក្នុងភូមិភាគនិរតី ដោយមិនប្រឈមមុខនឹងការចាប់ខ្លួនឡើយ។

៦៩៣- ចម្លើយសារភាពរបស់ សៀត ឆែ ហៅ ទុំ នៅមន្ទីរស-២១ ត្រូវបានធ្វើឡើងក្នុងដំណើរការមួយដែលលេចចេញជាលទ្ធផលឲ្យមានការសម្រិតសម្រាំងនៅភូមិភាគបូព៌ាទាំងមូល។ ទុំ ជាអតីត

លេខាតំបន់២២ ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧។ ការយកចម្លើយសារភាពរបស់ ទុំ នៅមន្ទីរស-២១ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៧៧ ត្រូវបានបណ្តាលឲ្យមានការសម្រិតសម្រាំងសំខាន់មួយភ្លាមៗទៅលើតំបន់២២។ តំបន់នោះជាកង្វល់ជាពិសេសចំពោះមជ្ឈិមបក្ស ព្រោះវានៅកៀកនឹងក្រុងភ្នំពេញកាត់តាមទន្លេមេគង្គ។ ចន្លោះថ្ងៃទី០៨ ខែមិថុនា និងចុងខែកញ្ញា ឆ្នាំ១៩៧៧ លេខាស្រុកទាំងអស់ នៅតំបន់២២ ត្រូវបានបញ្ជូនម្នាក់ម្តងៗជាប្រព័ន្ធទៅកាន់មន្ទីរស-២១។

៦៩៤- ហ៊ឹង អឿន ជាប្រធានសន្តិសុខប្រចាំភូមិភាគបូព៌ា ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧។ កុយ ហ៊្វូត ហៅ ធា ជាលេខាមន្ទីរតំបន់២២ បានចូលមន្ទីរស-២១ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៧៧។ មានលេខាស្រុកជាច្រើនដែលត្រូវបានជ្រើសរើសឲ្យមកជំនួសកម្មាភិបាលតំបន់២២ ដែលត្រូវគេសម្រិតសម្រាំង ក៏ត្រូវបានចាប់ខ្លួនមុនពេលការសម្រិតសម្រាំងនៅភូមិភាគបូព៌ាត្រូវបានបញ្ចប់ រួមមាន លេខាស្រុកល្វាឯម (អ៊ុយ សាត ហៅ គុន ហៅ គឹម ត្រូវបានចាប់ខ្លួននៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៧៨) ស្រុកអូរាំងឪ (កែវ សាន ហៅ សុក ត្រូវបានចាប់ខ្លួននៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៧៨) និងស្រុកមុខកំពូល (ឈឹម ស្រេង ហៅ សឿន ត្រូវបានចាប់ខ្លួននៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៨) ក៏ដូចជាលេខាថ្មីតំបន់២២ ឈ្មោះ មាន ឈួន ហៅ រឹក ហៅ ឈាន (ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨)។

៦៩៥- នៅពាក់កណ្តាលខែសីហា ឆ្នាំ១៩៧៧ សុន សេន បានចាកចេញពីក្រុងភ្នំពេញ ដើម្បីទៅបញ្ជាផ្ទាល់នៅខ្សែត្រៀមផ្លូវជាតិលេខ១។ សុន សេន បានបង្កើតមូលដ្ឋានទ័ពមួយនៅអ្នកលឿង ដែលមានមូលដ្ឋានទ័ពស្រួចមួយនៅក្រុងស្វាយរៀង ស្ថិតក្រោមការគ្រប់គ្រងរបស់ [redacted]

។ សុន សេន ខ្លួនឯងបានបើកប្រតិបត្តិការពីទីបញ្ជាការចល័តចុះឡើងតាមបណ្ដោយផ្លូវជាតិលេខ១។

៦៩៦- នៅចុងឆ្នាំ១៩៧៧ មជ្ឈិមបក្សបានអនុវត្តផែនការសម្រិតសម្រាំងនៅភូមិភាគបូព៌ាយ៉ាងក្ដៅគគុក។ តាម៉ុក បានកោះប្រជុំមេបញ្ជាការកងទ័ពជាន់ខ្ពស់របស់ខ្លួននៅភូមិភាគនិរតី ដោយផ្ដល់ព័ត៌មានអំពីប្រតិបត្តិការនាពេលដ៏ខ្លីខាងមុខប្រឆាំងនឹងពួកភូមិភាគបូព៌ា។ [redacted]។ ការណែនាំទាំងនេះក៏ត្រូវបានប្រកាសជាថ្មីម្ដងដោយ នួន ជា ក្នុងការប្រជុំមេបញ្ជាការកងទ័ពនៅភ្នំពេញថា៖ [redacted] កែ ពក បានរៀបចំកម្លាំងរបស់ខ្លួនជាមុន មុននឹងចូលទៅព័ទ្ធក្រុងកំពង់ចាម។ សុន សេន បានបង្កើនកម្លាំងទ័ពរបស់ខ្លួននៅខេត្តព្រៃវែង និង ស្វាយរៀង។

៦៩៧- នៅខែមីនា ឆ្នាំ១៩៧៨ មជ្ឈិមបក្សបានសម្រិតសម្រាំងតំបន់២៣ ក្នុងភូមិភាគបូព៌ា រៀបស្រដៀងគ្នានឹងការសម្រិតសម្រាំងតំបន់២២ កាលពីឆ្នាំកន្លងទៅដែរ។ លេខាតំបន់២៣ ឈ្មោះ អ៊ុក សុវណ្ណ *ហៅ ស៊ិន សូ* (Sin So) ត្រូវបានដកតំណែងនៅខែកុម្ភៈ ឆ្នាំ១៩៧៨ ដោយអនុលេខាភូមិភាគបូព៌ាឈ្មោះ ចាន់ ឡើងជំនួសគាត់នៅដើមខែមីនា។ ប្រការនេះផ្ដល់ឱកាសឱ្យ ចាន់ គ្រប់គ្រងទៅលើអ្វីដែលគេហៅថា "តំបន់ភ្លោះ" គឺតំបន់២៣ និង២៤។ នៅខែមីនា ឆ្នាំ១៩៧៨

ឈ្មោះ ចាន់ បានជួយ សុន សេន ក្នុងការវាយប្រហារយ៉ាងធំមួយទៅលើមេដឹកនាំនយោបាយ និង យោធានៅតំបន់២៣។

៦៩៨- សុន សេន និង ចាន់ បានសម្រិតសម្រាំងស្រុកនានានៅក្នុងតំបន់២៣ ជាប្រព័ន្ធ ដោយចាប់ផ្តើមពីអនុលេខាស្រុកសំរោង ស្រុកចន្ទ្រា ស្រុកបន្ទាយថ្មី ស្រុកស្វាយរៀង និងស្រុករមាសហែក ដោយអ្នកទាំងអស់នោះត្រូវបានចាប់ខ្លួនចន្លោះថ្ងៃទី០៨ ខែមីនា ដល់ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៨។ បន្ទាប់មកពួកគេក៏បង្វែរការចាប់អារម្មណ៍មកលើលេខាស្រុកនានា ក្នុងតំបន់២៣ ទៀតដូចជា៖ លេខាស្រុកកំពង់រោទិ៍ ឈ្មោះ សួន សាផន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៤ ខែមីនា លេខាស្រុកសំរោងឈ្មោះ សុន យុន ហៅ សៅ សារ៉េត លេខាស្រុកបន្ទាយថ្មីឈ្មោះ ធឹង សុន ហៅ សយ និងលេខាស្រុកចន្ទ្រាឈ្មោះ ប្រែង អោក ហៅ សំអាន ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ និងលេខាស្រុកស្វាយរៀងឈ្មោះ អន យុន ហៅ ឧស្សាហ៍ ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨។

៦៩៩- នៅពេល កងទ័ពមជ្ឈិមបក្សបញ្ជូនលេខាស្រុកនានានៅតំបន់២៣ ទៅមន្ទីរស-២១នោះ កងទ័ពទាំងនោះក៏ចាប់ផ្តើមប្រឆាំងនឹងមេដឹកនាំពីមុនរបស់ឈ្មោះ ចាន់ ដែរ ដោយធ្វើការចាប់ខ្លួនលេខាតំបន់២៣ឈ្មោះ អ៊ុក សុវណ្ណ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨។ គ្រាន់តែនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៨ តែមួយប៉ុណ្ណោះ មានកម្មាភិបាលចំនួនជាង៥០នាក់ត្រូវបានចាប់ខ្លួនពីតំបន់២៣ បញ្ជូនទៅមន្ទីរស-២១ ដែលពួកគេភាគច្រើនត្រូវបានសម្លាប់ក្នុងពេលមួយសប្តាហ៍។ ក្នុងរយៈពេល៧សប្តាហ៍បន្ទាប់មក មានមនុស្សជាង៧០០នាក់ ត្រូវបានចាប់ខ្លួនពីតំបន់២៣ និងបញ្ជូន

ទៅមន្ទីរស-២១ នៅពេលដែលការសម្រិតសម្រាំងក្នុងតំបន់នេះ បានរាលដាលទៅដល់ថ្នាក់ឃុំ និងថ្នាក់ក្រោមៗទៀត។

៧០០- កងពលទី៣ របស់ភូមិភាគបូព៌ាឈរជើងនៅតំបន់២៣ និងមានមូលដ្ឋាននៅក្រុងស្វាយរៀង។ កងពលទី៣នេះ រួមមានបីកងវរសេនាធំគឺ៖ វរសេនាធំលេខទី១១២ ទី១១៦ និងទី១៣០ រួមនឹងកងវរសេនាតូចកាំភ្លើងធំ និងកងវរសេនាតូចទ័ពពិសេសផងដែរ។ ក្នុងមួយសប្តាហ៍ចុងក្រោយនៃខែមីនា ឆ្នាំ១៩៧៨ លេខាកងវរសេនាធំទាំងបីត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១។ ឧទាហរណ៍ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៨ លេខាកងវរសេនាធំ១១៦ ឈ្មោះ វ៉ា មាន ត្រូវបានចាប់ខ្លួន ហើយនៅថ្ងៃបន្ទាប់សមាជិកគណៈកងវរសេនាធំ១១៦ ឈ្មោះ ប៉ុក ឆុន និងក្រោយមកទៀតគឺអនុលេខាឈ្មោះ ជេត ឆឹម ក៏ត្រូវបានចាប់ខ្លួនដែរ។ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៨ លេខាកងពលទី៣ ឈ្មោះ ប៉ែន ជឿន ត្រូវបានបញ្ជូនទៅមន្ទីរស-២១។ ក្នុងរយៈពេលបួនថ្ងៃបន្ទាប់មកទៀត មេដឹកនាំកងពលទាំងអស់ដែលនៅសេសសល់ក៏ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១ ដែររួមមាន៖ មេបញ្ជាការកងវរសេនាតូច៦៨ ៧៣ និង ៧៧ នៃកងវរសេនាធំ១១២ កងវរសេនាតូច២៣ ៧៥ និង៩៣ នៃកងវរសេនាធំ១១៦ និង កងវរសេនាតូច ៣៧ ៤៦ និង៩០ នៃកងវរសេនាធំ១៣០ រួមទាំងអង្គភាពទ័ពពិសេសកងវរសេនាតូច៩ និងកងវរសេនាតូចកាំភ្លើងធំ របស់កងពលទី៣ ផងដែរ។ ការបោសសម្អាតនៅក្នុងកងពលធំលេខ៣ ត្រូវបានធ្វើសេចក្តីសង្ខេបនៅក្នុងឧបសម្ព័ន្ធទី៤។

៧០១- កងពល៧០៣ របស់មជ្ឈិម គឺជាអង្គភាពសំខាន់ដែលអនុវត្តការសម្រិតសម្រាំងនៅតំបន់២៣។ មុនបេសកកម្មនេះ មានការប្រជុំមេបញ្ជាការកងទ័ព ដែលត្រូវបានចាត់តាំងឱ្យអនុវត្តការសម្រិត

សម្រាំងនៅភូមិភាគបូព៌ា នៅភ្នំពេញ នួន ជា បាននិយាយពី "ការបោសសម្អាតក្នុងជួរបក្ស" និង បានផ្ដល់នូវព័ត៌មានពិស្ដារស្ដីពីផែនការចាប់ខ្លួន និង ដកតំណែងកម្មាភិបាលភូមិភាគបូព៌ា។ កងពល៧០៣ បានទទួលបញ្ជាឲ្យដាក់ពង្រាយនៅអ្នកលឿងរយៈពេលពីរសប្ដាហ៍ មុននឹងបង្កើតទ័ពស្រួចនៅខេត្តស្វាយរៀង។ កងវរសេនាធំ៤០២ នៃកងពល៧០៣ [redacted] ត្រូវបានបញ្ជូនទៅឃុំសំរោង ស្រុកចន្ទ្រា ដើម្បីចាប់ខ្លួនកងទ័ពចំនួន ១.០០០នាក់ ពីកងពលទី៣ នៃភូមិភាគបូព៌ា។ [redacted]។ [redacted]ការសម្រិតសម្រាំងកងវរសេនាតូចទាំងប្រាំបួន ក្នុងកងពលទី៣នៃភូមិភាគបូព៌ា ដែលក្នុងពេលប្រតិបត្តិការមានកងទ័ពចំនួន៥០០០នាក់ត្រូវបានចាប់ខ្លួន។ ក្នុងករណីមួយ នៅពេលមេយោធាទាំងនោះជាច្រើនត្រូវបានបញ្ជូនទៅមន្ទីរស-២១ នួន ជា បានបញ្ជា ឌុច ឲ្យសម្លាប់ពួកគេចំនួន៣០០នាក់ ដោយមិនបានសួរចម្លើយទៅតាមនិយាមត្រឹមត្រូវឡើយ។

៧០២- មកដល់ចុងសប្ដាហ៍ទីពីរក្នុងខែមេសា ឆ្នាំ១៩៧៨ មេដឹកនាំយោធានៅតំបន់២៣ នៃភូមិភាគបូព៌ាទាំងអស់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ខណៈដែលកងពល៧០៣ និងអង្គភាពប្រតិបត្តិការផ្សេងទៀតបន្តប្រមូលផ្ដុំពលទាហាន និងដឹកជញ្ជូនពួកគេទៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ មជ្ឈិមបក្សបានអនុវត្តការសម្រិតសម្រាំងជាទ្រង់ទ្រាយបែបនេះទៅលើតំបន់២៣ ដោយសារការរុលចូលរបស់កងទ័ពវៀតណាម ទៅក្នុងតំបន់នោះនៅខែធ្នូ ឆ្នាំ១៩៧៧ ដែលមជ្ឈិមបក្សបានសន្និដ្ឋានថា ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបានជ្រៀតចូលក្នុងបក្សនៅមូលដ្ឋាននោះអស់ហើយ។ ដូចដែល ប៉ុល ពត បាននិយាយប្រាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅពាក់

កណ្ដាលខែមេសា ឆ្នាំ១៩៧៨ ថា៖ "កាលឃ្លួនវាចូលស្វាយរៀងបានដោយមានរនុកក្នុងវា។ វាវាយចូលស្វាយរៀងពីខែ១២។ យើងចាប់អារនុកក្នុងនេះ"។ ដោយមានមូលដ្ឋានឈរជើងនេះ នៅចុងភាគខាងត្បូងនៃភូមិភាគបូព៌ា កងទ័ពភូមិភាគនិរតីរបស់ សុន សេន និង តាម៉ុក បាន បង្កើតជាមូលដ្ឋានប្រតិបត្តិការសឹកដែលអនុញ្ញាតឱ្យកងទ័ពពីភូមិភាគកណ្ដាលរបស់ កែ ពក ធ្វើ ដំណើរចុះពីភាគខាងជើង និងបញ្ចប់ការសម្រិតសម្រាំងនៅភូមិភាគនេះ ក្នុងរយៈពេលពីរខែ បន្ទាប់។

៧០៣- ការសម្រិតសម្រាំងមេដឹកនាំនៅភូមិភាគបូព៌ា បានឡើងដល់កំពូលនៅខែឧសភា ឆ្នាំ១៩៧៨ ដោយចាប់ផ្ដើមចាប់ខ្លួនអនុលេខាកងពលលេខ៣ និងកងពល២៨០ និងលេខាកងពល៤ ៥ និង ២៩០ ជាមួយនឹងលេខាកងវរសេនាធំ១៥៣ ១៥៨ ១៨២ ២៦៩ ៤៨៨ និង៥១២។ ប្រធានទី បញ្ជាការភូមិភាគបូព៌ាឈ្មោះ សុក ខ្នុល ត្រូវបានចាប់ខ្លួននៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៧៨ និង ប្រធានមន្ទីរភូមិភាគបូព៌ាឈ្មោះ មាស ម៉ុន ត្រូវបានបញ្ជូនមកមន្ទីរស-២១ នៅថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ១៩៧៨។ ក្នុងរយៈពេលបីសប្ដាហ៍ ចាប់ពីថ្ងៃទី២៣ ខែឧសភា ដល់ ថ្ងៃទី១២ ខែ មិថុនា ឆ្នាំ១៩៧៨ អនុលេខាតំបន់២០ ត្រូវបានចាប់ខ្លួន ជាមួយនឹងលេខាតំបន់២០ ២១ និង ២២។ តំបន់២៣ និង២៤ ត្រូវស្ថិតក្រោមការត្រួតត្រារបស់អនុលេខាតំបន់ឈ្មោះ ចាន់។ លេខា តំបន់ឈ្មោះ សោ ភឹម បានស្លាប់បាត់បង់ជីវិតនៅពេលដែលកងកម្លាំងរបស់ សុន សេន ប៉ុនប៉ង ព័ទ្ធចាប់ខ្លួនគាត់នៅថ្ងៃទី០៣ ខែមិថុនា។ កម្មាភិបាលជាន់ខ្ពស់នៃភូមិភាគបូព៌ា ចំនួន១២០នាក់ ដែលត្រូវបានគេសម្លាប់នៅមន្ទីរស២១ ក្នុងអំឡុងពេលធ្វើការបោសសម្អាតនេះ គឺមានរាយឈ្មោះនៅក្នុងឧបសម្ព័ន្ធទី៣។

៧០៤- យន្តហោះចម្បាំងរបស់កងពល៥០២ បានគាំទ្រអង្គភាពរបស់កងទ័ពមជ្ឈិម ដោយធ្វើការវាយប្រហារទៅលើកងទ័ពភូមិភាគបូព៌ា។ ទន្ទឹមនឹងនោះដែរ យន្តហោះចម្បាំងផ្សេងទៀតដែលស្ថិតក្រោមបញ្ជារបស់កងពល៥០២ បានបាចខិតប័ណ្ណនៅទូទាំងភូមិភាគបូព៌ា ដោយប្រកាសថា សោ ភឹម ជាជនក្បត់ និង សុំឲ្យកងទ័ពភូមិភាគបូព៌ាចុះចាញ់កងទ័ពមជ្ឈិមបក្ស។ អ្នកដែលប្រកាសចុះចាញ់ទាំងអស់ ត្រូវបានចាប់ខ្លួន ឬសម្លាប់ភ្លាមៗ ឬបញ្ជូនទៅធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងរបស់កងពល៥០២ ដែលនៅទីនោះអ្នកទាំងនោះ ត្រូវធ្វើការរហូតដល់ស្លាប់បាត់បង់ជីវិត ឬត្រូវគេយកទៅសម្លាប់។

៧០៥- កងពលលេខ៤ របស់ភូមិភាគបូព៌ាមានមូលដ្ឋាននៅក្នុងបរិវេណមន្ទីរស្រុកពញាក្រែក នៅបាក់អាយ លើផ្លូវជាតិលេខ៧ ត្រង់ផ្លូវបំបែកផ្លូវលេខ២៤ បច្ចុប្បន្ន។ មន្ទីរពេទ្យភូមិភាគបូព៌ាស្ថិតនៅជិតនោះ ចម្ងាយប្រមាណ២០០ម៉ែត្រ តាមផ្លូវជាតិលេខ៧។ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ ១៩៧៨ លេខាកងពលទី៤ ឈ្មោះ កុយ ឈឿន ត្រូវបានកោះហៅឲ្យមកប្រជុំជាមួយ កែ ពក ហើយត្រូវបានគេចាប់ខ្លួនតែម្តង។ នៅពេលមិនឃើញគាត់ និងកម្មាភិបាលកងពលផ្សេងទៀតមិនបានត្រឡប់ទៅវិញ ក្នុងរយៈពេល៥ ឬ៦ថ្ងៃក្រោយមក កងទ័ពនៅកងពលលេខ៤ ទាំងអស់បានបោះបង់មូលដ្ឋានទ័ព និងមន្ទីរពេទ្យ ហើយគេចខ្លួនតែម្តង។ មានកម្មាភិបាលភូមិភាគបូព៌ាជាច្រើននាក់ផ្សេងទៀតក៏ត្រូវបានគេកោះហៅទៅប្រជុំនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ ហើយត្រូវបានគេចាប់ខ្លួន និងសម្លាប់នៅនឹងកន្លែងតែម្តង។

៧០៦- នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៨ កងទ័ពមជ្ឈិមបានចាប់ផ្តើមដាក់ពង្រាយតាមផ្លូវជាតិលេខ១ និងលេខ៧។ តាមបណ្តោយផ្លូវជាតិលេខ៧ កងពលនានារបស់មជ្ឈិមបានពង្រាយពីមូលដ្ឋាន

របស់ខ្លួន តាមបណ្តោយព្រំដែនវៀតណាម និងពីមូលដ្ឋាននៅវត្តស្រះ ជិត កោងកាង របស់លេខាភូមិភាគកណ្តាលឈ្មោះ កែ ពក។ នៅចុងខែនេះ កងទ័ពរបស់កងពល២៨០ ដែលស្ថិតក្រោមបញ្ជាការរបស់ ពក បានផ្លាស់ទីទៅតំបន់ ម៉ៃសាក ឬប្រាក់អាយ តាមផ្លូវជាតិលេខ៧ ដោយកាន់កាប់បានទីបញ្ជាការដ្ឋានរបស់កងពលទី៤ រួមទាំងមន្ទីរស្រុកពញាក្រែកផងដែរ។ ក្រោយពីការរៀបចំការគ្រប់គ្រងទៅលើទីតាំងជាយុទ្ធសាស្ត្រនេះហើយ កងពល២៨០ បានផ្លាស់ទៅបញ្ចប់ការសម្រិតសម្រាំងកម្មាភិបាល និងកងទ័ពភូមិភាគបូព៌ានៅតំបន់២០ និង២១ទៀត។ ចលនាផ្លាស់ទីរបស់កងពលនានាទៅតាមផ្លូវជាតិលេខ១ និងលេខ៧ ត្រូវបានគូសនៅក្នុងដ្យាក្រាម១ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១។

៧០៧- កែ ពក បានគ្រប់គ្រងប្រតិបត្តិការនៅផ្នែកខាងជើងនៃភូមិភាគបូព៌ា ពីមូលដ្ឋានរបស់ខ្លួន នៅវត្តស្រះ រីឯ សុន សេន វិញគ្រប់គ្រងប្រតិបត្តិការនៅផ្នែកខាងត្បូង ចាប់ពីមូលដ្ឋានចល័តរបស់ខ្លួនតាមបណ្តោយផ្លូវជាតិលេខ១។ ក្នុងរយៈពេលជាងពីរសប្តាហ៍ លេខាតំបន់ទាំងអស់ក្នុងភូមិភាគបូព៌ាត្រូវបានបញ្ជូនទៅមន្ទីរស-២១ លើកលែងតែឈ្មោះ ចាន់ ដែលគ្រប់គ្រងតំបន់ភ្លោះ។

៧០៨- មេដឹកនាំយោធាភូមិភាគបូព៌ាចាប់ពីថ្នាក់កងវរសេនាតូចឡើងទៅ និងមេដឹកនាំនយោបាយចាប់ពីថ្នាក់គណៈស្រុកឡើងទៅ ត្រូវបានគេសម្រិតសម្រាំងជាទ្រង់ទ្រាយធំ នោះកងទ័ពមជ្ឈិមចាប់ផ្តើមផ្តោតទៅលើមេដឹកនាំក្រសួងភូមិភាគ ឃុំ សហករណ៍ និងភូមិទៀតផង។ ឧទាហរណ៍ ភូមិធ្លក ឃុំកក់ ស្រុកពញាក្រែក ដែលមានឈ្មោះ ប៉េង ជាមេភូមិចាស់ត្រូវបានចាប់ខ្លួនជាមួយប្រពន្ធឈ្មោះ មឿន ឡើងជំនួសដោយឈ្មោះ ទិន ដែលក្រោយមកក៏ត្រូវគេចាប់ខ្លួនទៀត ហើយ

ឈ្មោះ ពៅ ជាអ្នកឡើងជំនួស ក៏ត្រូវគេចាប់ខ្លួនបន្តទៀត ក្រោយព្រឹត្តិការណ៍នេះមក អ្នកណាដែលនៅរស់ត្រូវគេជម្លៀសទៅខេត្តកំពង់ធំ។

៧០៩- នៅក្នុងដំណាក់កាលនៃការសម្រិតសម្រាំងនេះ កម្មាភិបាលមូលដ្ឋានមួយចំនួនគឺគ្រាន់តែត្រូវគេយកចេញទៅក្រៅភូមិ រួចសម្លាប់ចោលនៅនឹងកន្លែងតែម្តង។ មានមន្ត្រីឃុំ និង សហករណ៍ជាច្រើនត្រូវបានគេប្រាប់ថានឹងត្រូវបញ្ជូនឱ្យទៅរៀនសូត្រនយោបាយ តែត្រូវគេដឹកតាមឡានទៅសម្លាប់នៅកណ្តាលជ្រុំតែម្តង។ ប្រពន្ធកូនកម្មាភិបាលទាំងនោះមិនត្រូវបានរួចផុតពីការសម្រិតសម្រាំងនោះទេ។ [redacted]។ នៅក្នុងឧទាហរណ៍មួយទៀត កងទ័ពភូមិភាគបូព៌ាចំនួន៣០០នាក់ ត្រូវបានទុកឱ្យនៅរស់ដើម្បីយកទៅឱ្យធ្វើការនៅវត្តកណ្តាលជ្រុំនៅរដូវវស្សា មុនពេលយកទៅសម្លាប់នៅខាងជើងក្រញូង។ ការសម្លាប់មនុស្សស្រដៀងគ្នានេះក៏កើតមាននៅតំបន់ផ្សេងទៀតដែរ។

## កន្លែងប្រហារជីវិតនៅស្ទឹងតូច

### ទីតាំង

៧១០- ភូមិបុស្ស ត្រូវបានគេហៅថា តានប់ ឬទំនប់ មានទីតាំងស្ថិតនៅឃុំដូនតីខាងកើត ស្រុកពញាក្រែក ខេត្តកំពង់ចាម និងជាផ្នែកមួយរបស់តំបន់២០នៃភូមិភាគបូព៌ា។ វាស្ថិតនៅចម្ងាយប្រមាណ៤០គីឡូម៉ែត្រ ភាគខាងកើតក្រុងកំពង់ចាម និងប្រមាណ១០គីឡូម៉ែត្រខាងត្បូងផ្លូវជាតិលេខ៧។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិបុស្សមានប្រជាជនរស់នៅពី១៥០គ្រួសារទៅ

៣០០គ្រួសារ ដែលមានមនុស្សសរុប៥០០នាក់។ វាជាភូមិរបស់ប្រជាជនធម្មតា មិនមានឋានៈតួនាទី ឬមានទីតាំងមូលដ្ឋានយោធាស្ថិតនៅទេ។

៧១១- ភូមិបុស្សជាមូលដ្ឋានបក្សកុម្មុយនីស្តកម្ពុជានៅដើមឆ្នាំ១៩៦១។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ភូមិនេះមានមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាស្នាក់នៅដូចជា ប៉ុល ពត **នួន ជា អៀង ធីរិទ្ធ** និង យុន យ៉ាត។ **នួន ជា** បានមកទស្សនាភូមិនេះក្នុងឆ្នាំ១៩៦២ ១៩៦៣ និង ១៩៦៧។ ភាពសំខាន់របស់ភូមិបុស្សបានបន្តរហូតដល់ក្រោយឆ្នាំ១៩៧៥។ វាជាភូមិគំរូ ដែលមានផ្ទះសក្តិសមសម្រាប់ឥស្សរជនមកទស្សនា។ លេខាភូមិភាគបូព៌ា សោ ភឹម បានបោះទីតាំងមូលដ្ឋានមួយកន្លែងនៅក្បែរនោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានចម្ងាយប្រមាណ១,៥គីឡូម៉ែត្រ ពីភូមិនោះ។ **អៀង សារី** និង លេខាភូមិភាគកណ្តាល កែ ពក ធ្លាប់បានទៅទស្សនា ហើយ **នួន ជា** ធ្លាប់បានបង្ហាញភូមិនោះដល់ភ្ញៀវបរទេសទៀតផង។

## ការសម្លាប់មនុស្សដោយខុសច្បាប់

៧១២- ដោយសារគេចាត់ទុកថាមូលដ្ឋាននោះមានភក្តីភាពជាមួយ សោ ភឹម ជាអ្នកដែលរស់នៅទីនោះក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និងមានរក្សាមន្ទីរមួយនៅក្បែរនោះផងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ភូមិបុស្សបានក្លាយជាគោលដៅរបស់មជ្ឈិមបក្ស ថាជាផ្នែកមួយនៃការសម្រិតសម្រាំងជាទ្រង់ទ្រាយធំចំពោះភូមិភាគបូព៌ាដែលបានអនុវត្តនៅពាក់កណ្តាលឆ្នាំ១៩៧៨។ [redacted] ភូមិបុស្សធ្លាប់ជា "មូលដ្ឋានធំតស៊ូ និងរស់នៅ" របស់ សោ ភឹម ចាប់តាំងពីឆ្នាំ១៩៦១មកម្ល៉េះ ហើយថា "ប្រជាជនភូមិបុស្សជាភ្នែកច្រមុះរបស់គាត់"។

៧១៣- ប្រហែលជានៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧៨ មានកងកម្លាំងមួយកងពីភូមិភាគកណ្ដាលបានមកដល់ភូមិបុស្ស។ កងទ័ពនោះបានប្រមូលផ្ដុំអ្នកភូមិហើយប្រាប់ថា ពួកគេនឹងត្រូវផ្លាស់ឱ្យទៅរស់នៅចំការកៅស៊ូស្នួង ដែលនៅទីនោះគេនឹងមានផ្ទះថ្មី និងមានរបបអាហារគ្រប់គ្រាន់។ អ្នកភូមិទាំងអស់ត្រូវបានគេណែនាំឱ្យចាកចេញភ្លាម ហើយថាមិនចាំបាច់យករបស់របរផ្ទាល់ខ្លួនអ្វីទៅជាមួយទេ។ អ្នកភូមិភាគច្រើនយល់ព្រមឡើងជិះឡាន ដោយមានមនុស្សចំនួន១៦០នាក់ ដឹកចេញលើកទីមួយនៅប្រហែលម៉ោង៤រសៀល។

៧១៤- ពេលទៅដល់ផ្លូវជាតិលេខ៧ ឡានទាំងនោះក៏បើកតម្រង់ទៅទិសខាងកើត ដោយចេញពីផ្លូវជាតិលេខ៧ ហើយបន្តដំណើរតាមផ្លូវជាតិលេខ២៤ ដែលមានចម្ងាយ ២០ គីឡូម៉ែត្រ ពីព្រំដែនវៀតណាម។ ផ្លូវនេះល្មមសម្រាប់តែរទេះគោធ្វើដំណើរតាមព្រៃម៉ៃសាក់ញឹកស្អេក ដែលគេឱ្យឈ្មោះថា ស្ទឹងតូច។ បន្ទាប់ពីធ្វើដំណើរប្រហែល៧,៥គីឡូម៉ែត្រ ឡានទាំងអស់ក៏ឈប់ ពេលនោះប្រហែលម៉ោង ៦ ល្ងាច។ មានយោធាត្រៀមប្រយុទ្ធចំនួនពី៣០ ទៅ ៥០នាក់ពីកងពល២៨០ ចេញពីក្នុងព្រៃមកព័ទ្ធឡាន និងភ្ជង់កាំភ្លើងតម្រង់ទៅប្រជាជនស៊ីវិលទាំងនោះ។ យោធាទាំងនោះបញ្ជាឱ្យប្រុសៗចុះពីឡាន រួចពួកគេក៏ចងអ្នកទាំងនោះតែម្ដង។ ចំពោះស្រីៗក៏ដូចគ្នាដែរ តែពួកគេមិនចងកុមារទេ។ នៅពេលនោះ ពួកយោធាទាំងនោះនាំគ្នាស្រែកថាអ្នកភូមិជាពួកក្បត់ងារសេអ៊ីអា និងជា"កូនចៅអា ភឹម"។

៧១៥- អ្នកភូមិបុស្សប្រុសៗ ត្រូវបានគេចងភ្ជាប់គ្នាមុនគេជាក្រុមពី៥ ទៅ៨នាក់ រួចបណ្ដើរទៅរណ្ដៅដែលគេជីកទុករួចជាស្រេចនៅក្នុងព្រៃ។ បន្ទាប់មកគេស្រាយចំណងជនរងគ្រោះទាំងនោះ រួចបណ្ដើរទៅមាត់រណ្ដៅម្ដងម្នាក់ៗ។ ក្រោយមកគេក៏យកដំបងសំពងក្បាល រួចរុញទម្លាក់រណ្ដៅ

តែម្តង។ អ្នកដែលមិនទាន់ស្លាប់ ត្រូវគេចាក់នឹងចំពុះទុងបន្ថែមទៀត។ ជួនកាលមានឃាតករម្នាក់ជាអ្នកចុះទៅក្នុងរណ្តៅ ដើម្បីរៀបសាកសពឱ្យមានចន្លោះទំនេរ។ ពួកឃោធាស្ថិតនៅមូលដ្ឋាននោះ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៧៨។ ជាចុងក្រោយ ពួកគេបានទុកចោលរបស់របរផ្សេងៗមានដូចជា មុង ភួយ កញ្ច្រែង ល្អី សម្លៀកបំពាក់ ប្រដាប់ប្រដាក្មេងលេង អកកំបោរ ជាដើមនៅរាយប៉ាយពេញផ្លូវចម្ងាយប្រហែល៥០ម៉ែត្រ។ បន្ទាប់ពីសម្លាប់មនុស្សរួច ទីកន្លែងនោះមានក្លិនស្អុយអសោចរយៈពេលជាច្រើនថ្ងៃ។

៧១៦- មានអ្នកនៅរស់រានមានជីវិតជាច្រើននាក់ ពីការសម្លាប់រង្គាលជាទ្រង់ទ្រាយធំនៅស្ទឹងតូចនោះ។ [redacted] មើលឃើញច្បាស់ពេលអ្នកភូមិត្រូវគេសម្លាប់នៅពេលយប់។ [redacted]

សរុបមក មានមនុស្សចំនួន១១នាក់ ប៉ុណ្ណោះដែលនៅរស់ពីការសម្លាប់រង្គាលនោះ។

[redacted]

[redacted]

៧១៨- មានរបាយការណ៍ជាច្រើនស្ដីពីការសម្លាប់មនុស្សផ្សេងទៀតនៅស្រុកពញាក្រែក រួមទាំងការមើលឃើញរណ្ដៅសពរួម និងមានសាកសពចំនួនប្រហែលសាមសិបនៅក្នុងបរិវេណមន្ទីរស្រុកពញាក្រែក។ ការស៊ើបអង្កេតទៅលើរណ្ដៅសពរួមទាំងនោះឃើញមានអដ្ឋិធាតុមនុស្ស។ ការសម្លាប់ ឬការជម្លៀសមនុស្សជាទ្រង់ទ្រាយធំនៅក្នុងមូលដ្ឋាននេះ ក៏កើតមានផងដែរនៅភូមិបុស្សរកា ភូមិពន្លៃ ក្នុងឃុំកក់ និងភូមិសំរោង។

## ការជម្លៀសមនុស្សពីភូមិភាគបូព៌ា

៧១៩- ដំណាក់កាលចុងក្រោយនៃការសម្រិតសម្រាំងនៅភូមិភាគបូព៌ា គឺការផ្លាស់មនុស្សដែលនៅសេសសល់ គឺអ្នកដែលត្រូវបានគេកំណត់ថាមាន "ក្បាលយួនខ្លួនខ្មែរ"។ ជាទូទៅ ប្រជាជនភូមិភាគបូព៌ាទាំងអស់ ក្លាយជាកម្មវត្ថុនៃការជម្លៀសដោយបង្ខំនៅក្នុងសម័យកាលនេះ។ ប្រជាជនទាំងនេះភាគច្រើនត្រូវបានគេសម្លាប់ភ្លាមពេលទៅដល់ភូមិភាគផ្សេងទៀត រីឯអ្នកខ្លះទៀតត្រូវបានគេដាក់គុក ទើបយកទៅសម្លាប់ជាក្រោយ។

៧២០- អ្នកនៅរស់រានមានជីវិតពីការសម្រិតសម្រាំងក្នុងភូមិភាគបូព៌ានៅពាក់កណ្ដាលឆ្នាំ១៩៧៨ ត្រូវបានគេឲ្យក្រម៉ាខៀវមួយ នៅពេលគេដឹកទៅកាន់ភូមិភាគផ្សេងទៀត។ ក្រម៉ាពណ៌នោះជា "សញ្ញាដែលត្រូវសម្លាប់"។ [redacted] ពេលពួកគេទៅដល់អ្នកលឿង ដើម្បីរង់ចាំជិះទូកទៅភូមិភាគពាយ័ព្យនោះ [redacted] បានទទួលក្រម៉ាខៀវមួយគំនរ និងត្រូវបានគេណែនាំឲ្យចែកក្រមានេះទៅអ្នកផ្សេងទៀតនៅក្នុងក្រុមរបស់គាត់ម្នាក់មួយ។ ប្រជាជននៅភូមិភាគពាយ័ព្យដឹងភ្លាមថា ពួកគេមកពីភូមិភាគបូព៌ាដោយសារមានក្រម៉ាពណ៌ខុសគេ។ [redacted] បានពណ៌នាពីសាកសព [redacted]។ ក្រណាត់ពណ៌ខៀវត្រូវបានគេនាំចូលជាពិសេសពីបរទេសសម្រាប់គោលបំណងនៃការកំណត់អំពីជនរងគ្រោះដោយសារការជម្លៀសដោយបង្ខំពីភូមិភាគបូព៌ា ដើម្បីយកទៅសម្លាប់នៅពេលក្រោយ ហើយមនុស្សទាំងអស់ដែលជម្លៀសពីភូមិភាគបូព៌ាតម្រូវឲ្យពាក់ក្រម៉ាទាំងនោះ។

៧២១- ប្រជាជននៅតំបន់២០ ត្រូវបានគេធ្វើឲ្យបែកខ្ញែកគ្នាជាទ្រង់ទ្រាយធំ ក្នុងអំឡុងពេលជម្លៀសដោយបង្ខំចំពោះប្រជាជននៅភូមិភាគបូព៌ាទាំងមូល។ អ្នកដែលប្រកែកនឹងត្រូវគេបាញ់សម្លាប់ភ្លាម។ អ្នកដែលមកពីចុងភាគខាងត្បូងនៃតំបន់២០ ក្បែរផ្លូវជាតិលេខ១ ដូចជាអ្នកស្រុកមេសាង និងព្រៃវែងជាច្រើននាក់ ត្រូវបានគេបង្ខំឲ្យដើរទៅអ្នកលឿង ឡើងជិះទូកនៅទីនោះ បន្ទាប់មកឡើងនៅច្បារអំពៅ ដើម្បីជិះរថភ្លើងចេញទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង នៅភូមិភាគពាយ័ព្យ។ អ្នកដែលមកពីផ្នែកចុងខាងជើងនៃតំបន់២០ ជាប់នឹងផ្លូវជាតិលេខ៧ ដូចជា

អ្នកស្រុកពញាក្រែក និងកំចាយមារ ត្រូវជិះឡានទៅកាន់តំបន់៤១ ៤២ និង៤៣ នៃភូមិភាគកណ្តាល ឬទៅចំណុចខាងជើងឆ្ងាយទៀតនៅក្នុងភូមិភាគឧត្តរថ្មី ឬភូមិភាគពាយ័ព្យ។ មានមនុស្សពីរបីនាក់ ជាពិសេស គឺពួកយោធាភូមិភាគបូព៌ា បានបញ្ចប់ជីវិតនៅភូមិភាគបស្ចិម ឬភូមិភាគនិរតី។ មនុស្សជាច្រើនត្រូវបានបញ្ជូនដោយផ្ទាល់ទៅសម្លាប់ នៅមន្ទីរសន្តិសុខនានា។ ឧទាហរណ៍ នៅមន្ទីរសន្តិសុខវត្តបាធាយក្នុងតំបន់៤១ នៅពាក់កណ្តាលឆ្នាំ១៩៧៨ មានឡានដឹកបុគ្គលិកភូមិភាគបូព៌ាមកដល់ជាទៀងទាត់ ត្រូវបានដឹកដោយផ្ទាល់ទៅមន្ទីរសួរចម្លើយ រួចយកទៅសម្លាប់តែម្តង។

៧២២- ពីតំបន់២១ និង២២ អ្នករស់នៅភូមិភាគបូព៌ាត្រូវបានជម្លៀសដោយបង្ខំទៅភាគខាងជើង។ អ្នកខ្លះត្រូវបានបញ្ជូនទៅតំបន់៤៣ នៃភូមិភាគកណ្តាល។ អ្នកផ្សេងទៀតត្រូវបានដឹកយកទៅខេត្តស្ទឹងត្រែងក្នុងតំបន់១០៣ នៃភូមិភាគឧត្តរថ្មី ឬតំបន់១០៤ នៃភូមិភាគពាយ័ព្យ ... 

៧២៣- មនុស្សភាគច្រើននៅក្នុងតំបន់២៣ និង២៤ ត្រូវបានគេជម្លៀសដោយបង្ខំទៅទិសខាងលិច ដោយបញ្ចប់ជីវិតនៅភូមិភាគនិរតី ភូមិភាគបស្ចិម ឬភូមិភាគពាយ័ព្យ។ នៅក្នុងភូមិមួយ ប្រជាជនថ្មីត្រូវបានគេជម្លៀសលើកទីមួយ និងបញ្ជូនទៅភូមិភាគពាយ័ព្យ មួយខែក្រោយមកមានអ្នកមូលដ្ឋានត្រូវបានបញ្ជូនទៅភូមិភាគនិរតី ដែលនៅទីនោះត្រូវបានគេចោទសួរពីបណ្តាញទាក់ទងនឹងពួកវៀតណាម។ មនុស្សទាំងនេះជាច្រើនដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ត្រូវបានដឹកតាមទូក និងតាមរថភ្លើង តែអ្នកខ្លះទៀតត្រូវបានបញ្ជូនតាមឡាន។ គោលដៅជាចម្បងនៅ

ភូមិភាគពាយ័ព្យគឺតំបន់២ និង៧ ក្នុងខេត្តពោធិ៍សាត់។ សភាពការណ៍នៅក្នុងតំបន់ទាំងនោះគឺថា មនុស្សជាច្រើនដែលទើបទៅដល់ថ្មីៗត្រូវស្លាប់បាត់បង់ជីវិត ដោយសារការអត់ឃ្លាន ឬ ជំងឺ។ អ្នកផ្សេងទៀតជាច្រើនត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ដូចនឹងមានពិភាក្សានៅខាងក្រោម។ ជាគោលការណ៍ អ្នកដែលត្រូវបញ្ជូនទៅភូមិភាគនិរតីត្រូវបញ្ចប់ត្រឹមតំបន់១៣ និង២៥។ ពលទាហានភូមិភាគបូព៌ាពីតំបន់២៣ និង២៤ រួមជាមួយប្រជាជនធម្មតាមួយចំនួនតូចទៀត ត្រូវបញ្ជូនទៅភូមិភាគបស្ចិម។

៧២៤- ការសម្រិតសម្រាំងបានលាតសន្ធឹងទៅដល់អតីតអ្នកស្រុក ដែលលែងរស់នៅភូមិភាគបូព៌ាទៅហើយ។ ពលករសាមញ្ញពីមន្ទីរក្រសួងនានានៅក្រុងភ្នំពេញដែលជាប់ទាក់ទិងនឹងភូមិភាគបូព៌ាក៏ត្រូវក្លាយជាមុខសញ្ញានៃការសម្រិតសម្រាំងដែរ។ នៅក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បានប្រកាសនៅក្នុងកិច្ចប្រជុំរបស់បក្សថា លេខាភូមិភាគបូព៌ា សោ ភឹម ជាជនក្បត់។ នៅក្នុងរោងចក្រផលិតថ្នាំពេទ្យ ធ-២ របស់ក្រសួងនេះ មានមនុស្សចំនួន១២០ នាក់មកពីភូមិភាគបូព៌ាត្រូវបានផ្លាស់ចេញ និងបញ្ជូនទៅជំរុំអប់រំកែប្រែដើម្បីលត់ដំ ដូចជាឲ្យទៅវាយថ្មនៅវាលរេញជាដើម។ នៅក្រសួងពាណិជ្ជកម្ម បន្ទាប់ពី សោ ភឹម ត្រូវបានគេចោទថាក្បត់បានរយៈពេលមួយខែ "បណ្ដាញខ្សែក្បត់ភូមិភាគបូព៌ា" ត្រូវបានសម្រិតសម្រាំង និងបញ្ជូនទៅសម្លាប់រហូតដល់មួយរយនាក់ក្នុងពេលតែមួយក៏មាន។ បន្ទាប់ពីការសម្លាប់ទាំងនោះមក បុគ្គលិកក្រសួងពាណិជ្ជកម្មត្រូវបានបញ្ជូនទៅលុតដំនៅពេជ្រនិល។

៧២៥- មជ្ឈិមបក្សមានមោទនភាពចំពោះការងាររបស់ខ្លួននៅភូមិភាគបូព៌ា។ ទស្សនាវដ្ដីទង់បដិវត្តច្បាប់ចេញផ្សាយខែឧសភា-មិថុនា ឆ្នាំ១៩៧៨ បានបំពងសម្លេងថា៖ "យើងកំទេចបាននូវក្បាល

ម៉ាស៊ីនដឹកនាំក្បត់ទូទាំងប្រទេស ព្រមទាំងបក្សពួកវា ជាក់ស្តែងគឺកំទេចកម្លាំងក្បត់នៅភូមិភាគបូព៌ា ពាយ័ព្យ បស្ចិម ភ្នំពេញ ១០៣ ក្រចេះ និងតំបន់២៥"។ នៅពេលចុងក្រោយនៃការសម្រិតសម្រាំងនេះ នៅភូមិភាគបូព៌ា "គ្មានប្រជាជនស៊ីវិលទេ"។

## ការសម្លាប់រង្គាលជាទ្រង់ទ្រាយធំទៅលើអ្នកដែលត្រូវគេជម្លៀសពីភូមិភាគបូព៌ា

៧២៦- ដូចបានកត់សម្គាល់ខាងលើរួចមកហើយថា មនុស្សជាច្រើនត្រូវបានជម្លៀសចេញពីភូមិភាគបូព៌ានៅឆ្នាំ១៩៧៨ ដោយជម្លៀសដោយបង្ខំទៅតំបន់២ និង៧ នៅខេត្តពោធិ៍សាត់ ក្នុងភូមិភាគពាយ័ព្យ។ មនុស្សដែលគេយកទៅមូលដ្ឋាននោះ គឺមកពីខេត្តកំពង់ចាម ខេត្តស្វាយរៀង និងខេត្តព្រៃវែង និងទៅដល់ទីនោះដោយពាក់ក្រម៉ាពណ៌ខៀវ និងស្បែកជើងកង់ឡានដែលកំណត់ថាពួកគេជាអ្នកដែលត្រូវជម្លៀសពីភូមិភាគបូព៌ា។ ជាដំបូង ពួកគេត្រូវដឹកតាម រថភ្លើង និងអាចយករបស់របរតាមខ្លួនបាន ដូចជា ចាន ឆ្នាំង មាន់ ទា។ អ្នកខ្លះត្រូវស្លាប់នៅតាមផ្លូវដោយសារប្រកែកមិនព្រមទៅ ហើយត្រូវគេបាញ់សម្លាប់ចោលតែម្តង។ ពេលទៅដល់ខេត្តពោធិ៍សាត់ ពួកគេជួបជាមួយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាប្រចាំមូលដ្ឋាន [redacted] ហើយត្រូវដឹកចេញពីស្ថានីយ៍រថភ្លើងបឹងខ្នារ ទៅកាន់សហករណ៍និងការដ្ឋានតាមរទេះគោចំនួនពី២០០ ទៅ៣០០រទេះ។ នៅតាមសហករណ៍ និងការដ្ឋានទាំងនេះ អ្នកដែលត្រូវគេជម្លៀសទាំងនោះត្រូវគេបង្ខំឲ្យជីកប្រឡាយ និងធ្វើស្រែ។

៧២៧- នៅពាក់កណ្តាលឆមាសទី២ ឆ្នាំ១៩៧៨ បន្ទាប់ពី រស់ ញឹម ត្រូវបានសម្រិតសម្រាំង ដោយកងទ័ពនិរតី ក្នុងឋានៈជាលេខាតំបន់ពាយ័ព្យ នៅឯកិច្ចប្រជុំមួយនៅក្នុងអតីតរោងភាពយន្តមួយ តាម៉ុក ដែលជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានប្រាប់កម្មាភិបាលទាំងនោះថា

រស់ ញ៉ឹម និង សោ ភឹម ជាពួកក្បត់ [redacted]។ បន្ទាប់ពីពួកភូមិភាគបូព៌ាដែលជម្លៀសមកនោះត្រូវបានបញ្ជូនទៅសហករណ៍រួចហើយ ពួកគេត្រូវធ្វើប្រវត្តិរូបដើម្បីរកអតីត ប្រធាន និងអនុប្រធានភូមិ ឃុំ គ្រូបង្រៀន ប៉ូលីស និងទាហានដែលអ្នកទាំងនោះក្លាយជាគោលដៅនៃការចាប់ខ្លួន យកទៅសម្លាប់ភ្លាមៗ។ អ្នកដែលត្រូវគេជម្លៀសពីភូមិភាគបូព៌ាជាច្រើននាក់ ត្រូវបានឃុំឃាំង និងយកទៅ សម្លាប់នៅតាមមន្ទីរសន្តិសុខក្នុងមូលដ្ឋាននោះ។

៧២៨- នៅចុងឆ្នាំ១៩៧៨ មួយរយៈខ្លីមុនពេលកងទ័ពវៀតណាមចូលមកដល់ អ្នកដែលត្រូវគេជម្លៀសពីភូមិភាគបូព៌ាហើយនៅរស់ត្រូវបានគេប្រមូលផ្តុំនៅតាមទីតាំងមួយចំនួន ក្នុងខេត្តពោធិ៍សាត់ និងយកសម្លាប់ជាទ្រង់ទ្រាយធំ។ នៅឃុំស្រែស្តុក ស្រុកកណ្តៀង (ផ្នែករបស់តំបន់៧) បន្ទាប់ពីបានចូលរួមក្នុងការប្រជុំជាមួយកម្មាភិបាលសហករណ៍ និងថ្នាក់ស្រុក គណៈសហករណ៍ផ្តាអំពិលបានបញ្ជាឲ្យកងរទេះគោ ដឹកជញ្ជូនអ្នកដែលត្រូវគេជម្លៀសពីភូមិភាគបូព៌ាទាំងនោះទៅ វាលបាក់ជញ្ជីង ដែលមានចម្ងាយដប់គីឡូម៉ែត្រខាងលិចទួលពោធិ៍ជ្រៃ។ មានមនុស្សរាប់ពាន់នាក់ត្រូវបានដឹកទៅទីតាំងនោះរយៈពេល៣-៤ថ្ងៃ ដោយប្រើរទេះគោចំនួន៣០។ ពេលដឹកទៅដល់វាលបាក់ជញ្ជីង កងឈ្លបបក្សកុម្មុយនីស្តកម្ពុជាបានបណ្តើរជនរងគ្រោះទៅកាន់ស្រះទឹកមួយដែលមានចម្ងាយ១០០ម៉ែត្រ រួចបាញ់សម្លាប់ពួកគេតែម្តង។ បន្ទាប់មក គេទម្លាប់សាកសពទៅក្នុងស្រះទឹកនោះ។

៧២៩- នៅចុងឆ្នាំ១៩៧៨ នៅឃុំរំលេច ស្រុកបាកាន (ក៏ជាផ្នែកមួយនៃតំបន់៧ដែរ) ក៏មានអ្នកត្រូវជម្លៀសពីភូមិភាគបូព៌ារាប់រយនាក់ ត្រូវបាននាំយកទៅបាញ់សម្លាប់នៅវត្តចន្ទរង្សី ក្នុងឃុំរលេច ។ នៅពេលព្រឹកស្អែកឡើង គេយករទេះគោមកដឹកសាកសពប្រាំមួយនាក់ក្នុងមួយរទេះ ទៅកប់នៅរណ្ដៅរួម និងក្នុងអណ្ដូងទឹកមួយនៅភូមិកូនត្នោត ឬភូមិចាម ក្នុងឃុំរំលេច។ ក្រម៉ាពណ៌ខៀវ និងគ្រោងឆ្អឹងត្រូវបានរកឃើញ នៅពេលដែលមានការជីករណ្ដៅសាកសពទាំងនោះ ក្នុងឆ្នាំ១៩៧៩។ តាមការប៉ាន់ស្មាន មានជនរងគ្រោះប្រមាណពី៣០០នាក់ ទៅ ៦៤០នាក់ ត្រូវបានសម្លាប់នៅក្នុងការសម្លាប់យ៉ាងរង្គាលនេះ។

៧៣០- [redacted]។

## ឧក្រិដ្ឋកម្មប្រឆាំងពុទ្ធសាសនិក

### សេចក្ដីផ្ដើម

៧៣១- ទាំងព្រះសង្ឃ និងអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវទទួលរងការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ដែលធ្វើឡើងដោយ ប.ក.ក ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះសង្ឃត្រូវបង្ខំឱ្យសឹក ចំណែកអ្នកដែលរឹងទទឹងត្រូវសម្លាប់ចោល ហើយព្រះសង្ឃដែលគេផ្សឹកត្រូវគេបង្ខំឱ្យធ្វើការដែលគេហាមឃាត់ ដូចជាតម្រូវឱ្យចូលធ្វើជាទាហានជាដើម។ ពិធីប្រារព្ធប្រពៃណីតាមបែប

ព្រះពុទ្ធសាសនាទាំងអស់ ជាពិសេសការប្រគេនចង្ហាន់ ឬទេយ្យវត្ថុចំពោះព្រះសង្ឃពីសំណាក់ពុទ្ធសាសនិកជន ដែលជាការអនុវត្តន៍មួយចាំបាច់សម្រាប់ឲ្យព្រះសង្ឃនៅគង់មានជីវិត ត្រូវបាន ប.ក.ក ហាមឃាត់ កន្លែងចូលថ្វាយបង្គំតាមបែបពុទ្ធសាសនា ត្រូវបានបំផ្លាញជាទូទៅ ឬក៏ប្រែក្លាយទៅការប្រើប្រាស់ផ្សេងៗ ដែលមិនមែនក្នុងផ្លូវសាសនា ដូចជាការប្រែក្លាយឲ្យទៅជាទ្រុងចិញ្ចឹមជ្រូក ទីសត្តឃាត និងជាកន្លែងធ្វើទារុណកម្មជាដើម។ បុរាណវត្ថុស័ក្តិសិទ្ធទាំងឡាយដូចជា ឯកសារ គម្ពីរ រូបបដិមា និងទេយ្យវត្ថុសាសនាត្រូវបានដុតបំផ្លាញ កម្ទេច ឬក៏យកទៅបោះចោលក្នុងបឹង ឬទន្លេ។ ជាសរុប ព្រះពុទ្ធសាសនា ដែលជាស្ថាប័ន និងជាការគោរពបូជាត្រូវបានគេធ្វើឲ្យសាបសូន្យដោយរបប ប.ក.ក។ អ្នកណាក៏ដោយដែលតវ៉ានឹងរបបនេះ ពីអ្វីដែលខ្លួនធ្វើនោះ នឹងត្រូវសម្លាប់ចោល។ ការកើតឡើងបែបនេះ ពិតជាបានបង្អាក់យ៉ាងខ្លាំងនូវទំនាក់ទំនងដ៏ជ្រាលជ្រៅចំពោះបុគ្គលសាមញ្ញទាំងឡាយ ដែលខ្លួនមានចំពោះពិភពនៃដួងវិញ្ញាណ ដែលវាបណ្តាលឲ្យមានផលវិបាកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរចំពោះមនុស្សជាច្រើន។

## ប្រភពដើមនៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

៧៣២- ព្រះពុទ្ធសាសនាហិនយាន គឺជាសាសនាដែលទទួលបានការគោរពជាងគេនៅកម្ពុជា ហើយការគោរពខ្ជាប់ខ្ជួននេះ បានបញ្ជាក់សញ្ញាណជាក្រុមសាសនាមួយ។ សាសនានេះមានលក្ខណៈសម្គាល់ដោយសារតែការគោរពពិធីផ្សេងៗផ្ទាល់ខ្លួន ទម្រង់នៃជំនឿ និងនិម្មិតរូបនិយម។ ប្រជាជនកម្ពុជាភាគច្រើន បានប្រែក្លាយជាអ្នកកាន់ព្រះពុទ្ធសាសនាហិនយាននៅក្នុងសតវត្សទី១៣។ ជនជាតិខ្មែរ ដែលជាក្រុមជនជាតិភាគច្រើននៅប្រទេសកម្ពុជា គឺជាអ្នកមានជំនឿស៊ប់ក្នុងសាសនាយ៉ាងខ្លាំង ហើយចំណុចផ្តោតទៅលើជីវិតជនបទស្រែចម្ការ ដែល

សម្គាល់ គឺជានិច្ចជាកាល ជាទីវត្តអារ៉ាមព្រះពុទ្ធសាសនានេះឯង។ ប្រជាជនកម្ពុជាភាគច្រើន ចាត់ទុកខ្លួនឯងជាពុទ្ធសាសនិកជន ទោះបីជាពួកគាត់ថ្វាយបង្គំព្រះនៅឯវត្តអារ៉ាម ឬនៅឯផ្ទះក៏ដោយ។ ព្រះពុទ្ធសាសនា "មានការជ្រួតជ្រាបយ៉ាងខ្លាំងនៅក្នុងវប្បធម៌ខ្មែរ" ហើយដែលវាជះឥទ្ធិពលទៅដល់ "ភាសា ប្រតិទិនប្រចាំឆ្នាំ ម្ហូបអាហារ ការរាំរែក សិល្បៈ ព្រមទាំងអត្តចរិតរបស់ប្រជាជន ចំពោះជីវិតរស់នៅរបស់ពួកគាត់"។ មុនរបបកម្ពុជាប្រជាធិបតេយ្យ ព្រះពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋ ហើយមានការប៉ាន់ស្មានថា យ៉ាងហោច៨៥ភាគរយនៃប្រជាជនកម្ពុជា គឺជាអ្នកកាន់សាសនាព្រះពុទ្ធ។

៧៣៣- ព្រះសង្ឃ គឺជាក្រុមសម្គាល់មួយនៃពុទ្ធសាសនាហិនយាន ដែលគង់នៅក្នុងទីវត្តអារ៉ាម ដែលគេគោរពប្រណិប័តន៍នូវប្រពៃណី និងវិន័យតឹងរ៉ឹងក្នុងជំនឿព្រះពុទ្ធសាសនា ហើយគេអាចសម្គាល់បាន តាមរយៈស្បង់ជីពរពណ៌លឿងទុំ។ ពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៧ ចំនួនព្រះសង្ឃក្នុងប្រទេសកម្ពុជាកើនឡើងដល់៧២ភាគរយ គឺមានព្រះសង្ឃពី៣៧៥៥៣អង្គ ដល់៦១០១៤អង្គ ដែលរួមមាន ព្រះសង្ឃក្មេងៗជាច្រើនផងដែលបានបួសជាសាមណេរ។

## គោលនយោបាយរបស់ ប.ក.ក កំណត់ចំពោះពុទ្ធសាសនិកជន និងព្រះពុទ្ធសាសនា

៧៣៤- គោលនយោបាយជាមូលដ្ឋានរបស់ ប.ក.ក គឺជាការបំបាត់ចោលនូវសាសនាទាំងអស់។ ដោយឡែក ព្រះពុទ្ធសាសនាបានប្រឆាំងទៅនឹងនយោបាយ និងមនោគមវិជ្ជារបស់ ប.ក.ក ពីព្រោះគោលការណ៍នៃការមានកម្មផល បង្ហាញពីនិរន្តភាពនៃភាពមិនស្មើគ្នានៃឋានៈក្នុងសង្គម ហើយផ្អែកតាមវិន័យនៃព្រះពុទ្ធសាសនាហិនយាន ព្រះសង្ឃមិនត្រូវអនុញ្ញាតឲ្យទៅធ្វើស្រែចម្ការទេ ប៉ុន្តែព្រះសង្ឃត្រូវទទួលបាននូវការប្រគេនចង្ហាន់ ឬទេយ្យវត្ថុពីគ្រហស្ថ។ ផ្អែកលើ

ហេតុផលបែបនេះ ទើប ប.ក.ក ដាក់ឈ្មោះឱ្យព្រះសង្ឃថាជា "ឈ្លើង" "ជាពួនជញ្ជក់ឈាម" និងជា"ពួកសក្តិភូមិដែលចាំតែជញ្ជក់ឈាមប្រជាជន"។ នៅក្នុងតំបន់ទាំងឡាយ ដែលគ្រប់គ្រងដោយ ប.ក.ក មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ វត្តអារ៉ាមត្រូវបានបិទ ហើយព្រះសង្ឃ ត្រូវបានផ្សឹក។

៧៣៥- នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ រយៈពេលប្រហែល១ខែ បន្ទាប់ពីខ្លួនដណ្តើមអំណាច មេដឹកនាំ ប.ក.ក បានបើកអង្គសន្និបាតមួយនៅទីក្រុងភ្នំពេញ ដែលចូលរួមដោយលេខាស្រុក លេខាតំបន់ និងលេខាភូមិភាគទាំងអស់នៅក្នុងប្រទេស ក៏ដូចជាអ្នកតំណាងខាងស្ថាប័នយោធា។ កម្មាភិបាលនៅក្នុងអង្គសន្និបាតនោះ ត្រូវបាន **នួន ជា** និង ប៉ុល ពត ណែនាំពីមាគ៌ាបក្ស និងនយោបាយ ថាពួកគេទាំងអស់ត្រូវអនុវត្តនៅតាមតំបន់របស់ខ្លួន ដោយធ្វើការបិទវត្តអារ៉ាម និងផ្សឹកលោកសង្ឃទាំងអស់។ **នួន ជា** និង ប៉ុល ពត បានណែនាំជាពិសេសដល់កម្មាភិបាល ប.ក.ក ដែលបានចូលរួមនោះថា ព្រះសង្ឃ គឺជា"វណ្ណៈពិសេស" ដែលត្រូវ "បោសសម្អាតចោល" ហើយមិនត្រូវឱ្យមានវត្តអារ៉ាមទេ។ បន្ទាប់ពីអង្គសន្និបាតនោះមក លេខាស្រុក និងលេខាតំបន់ទាំងនោះ បានត្រឡប់ទៅកាន់តំបន់រៀងខ្លួនៗ នៅទូទាំងប្រទេស ហើយបានជូនដំណឹងដល់កម្មាភិបាលក្រោមបង្គាប់ និងព្រះសង្ឃអំពីគោលនយោបាយរបស់មជ្ឈិមបក្ស ដែលតម្រូវឱ្យព្រះសង្ឃត្រូវសឹក និងមិនឱ្យគង់នៅក្នុងវត្តអារ៉ាមតទៅទៀត។

៧៣៦- ការអនុវត្តដោយជោគជ័យនូវគោលនយោបាយនេះ ត្រូវបានបោះពុម្ពផ្សាយ ថាជាមាគ៌ាណែនាំ ឬជាសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំ ប.ក.ក។ ជាឧទាហរណ៍ សារាចរមួយចុះនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ របស់បក្សចែងថា ព្រះសង្ឃភាគច្រើនបានលាចាកសិក្ខាបទ "វត្តអារ៉ាម

ដែលជាមូលដ្ឋានគ្រឹះសម្រាប់និរន្តភាពរបស់ព្រះសង្ឃ ត្រូវបានគេបោះបង់ចោល” ដែលប្រជាជនលែងបានទៅវត្ត ឬប្រគេនចង្ហាន់ ឬទេយ្យវត្ថុ ថ្វាយព្រះសង្ឃទៀតហើយ ហើយការគោរពជំនឿសាសនាក៏ “លែងមានតទៅទៀត”ដែរ។ ដោយផ្អែកលើនិទ្ទាការ បក្សបានសន្និដ្ឋានថា “ពី៩០ ទៅ៩៥ភាគរយនៃព្រះសង្ឃ និងពុទ្ធសាសនិក ដែលគោរពប្រណិប័ត៌ព្រះពុទ្ធសាសនានឹងត្រូវបាត់បង់” ហើយ“ស្រទាប់ដ៏សំខាន់ [របស់សង្គមនេះ] នឹងលែងបង្កជាបញ្ហាទៀតហើយ”។ នៅក្នុងទស្សនាវដ្ដី*ទង់បដិវត្ត* ច្បាប់ចេញផ្សាយក្នុងខែមិថុនា ឆ្នាំ១៩៧៧ សរសេរថា អតីតព្រះសង្ឃជាច្រើនត្រូវបានគេចាត់ទុកជាផ្នែកមួយនៃពួក“អនុជន” ដែលភាគច្រើនជាខ្មាំងរបស់ ប.ក.ក។ ក្នុងខែមេសា ឆ្នាំ១៩៧៨ **អៀង ធីរិទ្ធ** បានប្រាប់ទៅប្រតិភូយូហ្គោស្លាវីដែលចុះមកធ្វើទស្សនកិច្ចថា “ព្រះពុទ្ធសាសនា គឺមិនអាចប្រៀបផ្ទឹមជាមួយនឹងបដិវត្តន៍បានទេ” ហើយ“បញ្ហា”នេះលែងកើតមានទៀតហើយ ព្រោះ“ព្រះពុទ្ធសាសនាបានស្លាប់បាត់ទៅហើយ”។

**ការអនុវត្តន៍គោលនយោបាយរបស់ ប.ក.ក ក្នុងការលុបបំបាត់ព្រះពុទ្ធសាសនា**

៧៣៧- គោលនយោបាយរបស់ ប.ក.ក គឺបិទវត្តអារ៉ាម ផ្សឹកព្រះសង្ឃ និងលុបបំបាត់ចោលនូវការប្រណិប័តព្រះពុទ្ធសាសនារបស់ពុទ្ធសាសនិកជន ដែលត្រូវបានអនុវត្តទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោយពី ប.ក.ក បានកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មិនបានយូរប៉ុន្មាន ព្រះសង្ឃជាពុទ្ធសាសនិក “ជាន់ខ្ពស់” ដែលបង្កើតជាថានានុក្រមសាសនានោះ ត្រូវគេសម្លាប់នៅទីក្រុងភ្នំពេញ។ បន្ទាប់ពីកាន់អំណាចបានប៉ុន្មានខែមក ព្រះសង្ឃជាច្រើនទូទាំងប្រទេសត្រូវគេបង្ខំឱ្យសឹក ដោយមិនបានគោរពតាមពិធីប្រពៃណីតាមបែបព្រះពុទ្ធសាសនា

ដែលតម្រូវឱ្យព្រះសង្ឃត្រូវគោរពប្រណិប័ត៌ មុនពេលលាចាកសិក្ខាបទនោះទេ។ បន្ទាប់ពីត្រូវបានគេផ្សឹកហើយ ព្រះសង្ឃជាច្រើនត្រូវគេបញ្ជាឱ្យធ្វើស្រែ ធ្វើទំនប់ទឹក ឬជីកប្រឡាយ ដែលតម្រូវឱ្យព្រះសង្ឃត្រូវអនុវត្តនូវកិច្ចខ្លះ ដែលត្រូវបានហាមឃាត់តាមធម៌វិន័យពុទ្ធសាសនាបែបហិនយានរបស់បុព្វជិត ដូចជា កាប់ដីជាដើម។ ព្រះសង្ឃផ្សេងៗទៀត ត្រូវគេបង្ខំឱ្យចូលបម្រើកងទ័ពបដិវត្តកម្ពុជា ដោយមិនគិតពីទស្សនៈតាមបែបព្រះពុទ្ធសាសនា ដែលប្រកាន់ខ្ជាប់នូវសន្តិភាពនិយម និងអហិង្សានោះទេ។ ព្រះសង្ឃមួយចំនួន ត្រូវគេបង្ខំឱ្យរៀបការ ដែលជាការរំលោភបំពានលើសម្បថនៅលីវរបស់ព្រះសង្ឃទាំងនោះ។ វត្តអារ៉ាមព្រះពុទ្ធសាសនា ត្រូវ ប.ក.ក បិទទ្វារ ឬយកធ្វើជាមន្ទីរសន្តិសុខ កន្លែងហូបបាយ ឃ្លាំងស្តុក ឬជាកន្លែងចិញ្ចឹមជ្រូក។ វត្តអារ៉ាមជាច្រើនត្រូវបាន ប.ក.ក រុះរើ ហើយរូបបដិមាករព្រះពុទ្ធ និងគ្រឿងសក្ការៈរបស់ព្រះពុទ្ធសាសនាផ្សេងៗទៀត ត្រូវបានបំផ្លាញចោល។

៧៣៨- ក្នុងរង្វង់ឆ្នាំ១៩៧៧ ការអនុវត្តគោលនយោបាយរបស់ ប.ក.ក ប្រឆាំងនឹងព្រះពុទ្ធសាសនា បានបណ្តាលឱ្យមានការបិទទ្វារវត្តអារ៉ាមជាប្រព័ន្ធ ព្រមទាំងបំផ្លាញនូវបុរាណវត្ថុទាំងឡាយរបស់អ្នកដែលគោរពបូជាចំពោះព្រះពុទ្ធសាសនា។ ថ្វីត្បិតតែ វត្តអារ៉ាមមួយចំនួនត្រូវបានបំផ្លាញនៅក្នុងសង្គ្រាមចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ក៏ ប.ក.ក ផ្ទាល់បានប្រកាសថា ខ្លួនបានបំផ្លាញវត្តអារ៉ាមព្រះពុទ្ធសាសនាអស់ចំនួន៩០ភាគរយ។

៧៣៩- ឧទាហរណ៍ខាងក្រោមនេះ ដូចមានចែងនៅក្នុងគោលនយោបាយ និងការអនុវត្តន៍ទូទៅរបស់ ប.ក.ក បង្ហាញឱ្យឃើញពីការធ្វើទុក្ខបុកម្នេញចំពោះព្រះពុទ្ធសាសនា និងពុទ្ធសាសនិកជន។

**វត្តសំរោងក្នុង (ខេត្តបាត់ដំបង)**

៧៤០- វត្តសំរោងក្នុង មានទីតាំងនៅក្នុងភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ បន្ទាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ភ្លាម មានព្រះសង្ឃប្រហែល៣០០អង្គ ត្រូវបានជម្លៀសពីវត្តផ្សេងៗនៅក្នុងខេត្តបាត់ដំបង ឲ្យទៅគង់នៅក្នុងវត្តសំរោងក្នុង។ នៅទីនោះ ព្រះសង្ឃទាំងនោះបានទទួលបញ្ជាពី [redacted] ហើយដែលមានខ្សែរយៈជាមួយនឹង ប.ក.ក បានណែនាំឲ្យព្រះសង្ឃទាំងនោះដឹងពីរបៀបនៃការដាំដុះបន្លែ និងធ្វើស្រែ។ ព្រះសង្ឃទាំង៣០០អង្គនោះ ក្រោយមកត្រូវគេបែងចែកចេញជាពីរក្រុម មួយក្រុមត្រូវបានគេចាត់ឲ្យទៅលើកទំនប់ និងប្រឡាយនៅក្នុងស្រុកសង្កែ មួយក្រុមទៀត ត្រូវធ្វើស្រែ និងដាំដំណាំ។ ព្រះសង្ឃទាំងនោះត្រូវបាន ប.ក.ក ទិតៀនថាជា "វណ្ណៈជិះជាន់" ដោយសារតែខ្លួនត្រូវពឹងពាក់លើចង្ហាន់ពីឧបាសក ហើយមិនអនុញ្ញាតឲ្យមានការបិណ្ឌបាត្រ ឬទទួលទេយ្យវត្ថុតទៅទៀតទេ។

៧៤១- ក្នុងខែមេសា ឆ្នាំ១៩៧៦ មានព្រះសង្ឃប្រហែល៤០អង្គ ត្រូវបានកម្មាភិបាល ប.ក.ក កោះហៅឲ្យទៅប្រជុំនៅអណ្តូងត្នោត ស្ថិតនៅភូមិស្វាយធំ ឃុំសំរោងក្នុង។ នៅពេលប្រជុំនេះ [redacted] បានប្រកាសថា មជ្ឈិមបក្សបានលុបបំបាត់មិនឲ្យមានលោកសង្ឃ និងព្រះពុទ្ធសាសនាតទៅទៀតហើយ។ ពេលនោះមានព្រះសង្ឃចំនួន៣០អង្គមិនព្រមដោះស្បង់ជីវរទេ ប៉ុន្តែក្រោយមក ព្រះអង្គទាំងនោះក៏បានយល់ព្រមសឹក បន្ទាប់ពី [redacted] បានប្រាប់ថា បើសិនជាមិនព្រមសឹក លោកនឹងត្រូវគេសម្លាប់ចោល។ នៅអំឡុងចុងខែមេសា ឆ្នាំ១៩៧៦ មិនមានព្រះសង្ឃគង់នៅក្នុងវត្តសំរោងក្នុងតទៅទៀតទេ។

៧៤២- តាមទិសដៅរបស់ ប.ក.ក វត្តអាវ៉ាមត្រូវបានប្រែក្លាយទៅជាមន្ទីរសន្តិសុខ។ អ្នកទោសដែលជាប់ឃុំនៅក្នុងវត្តសំរោងក្នុង ត្រូវបានគេស្ទូចម្ដើយនៅក្នុងកុដិមួយ នៅខាងក្រោយវត្ត ហើយត្រូវបានសម្លាប់ និងកប់នៅក្នុងរណ្ដៅដែលស្ថិតនៅក្បែរនោះ។ ទីធ្លាវត្តទាំងមូលត្រូវបានយកធ្វើជាទីស្នាក់ការឃុំ និងជាឃ្លាំងសម្រាប់ស្ដុកអង្ករ និងម្ហូបអាហារផ្សេងៗ។ មានកុដិចំនួន១៥ ស្ថិតនៅក្នុងវត្តសំរោងក្នុង ដែលត្រូវ ប.ក.ក បំផ្លាញ ហើយកុដិដែលនៅសល់ត្រូវបានគេយកធ្វើជាផ្ទះសម្រាប់ឈ្លបស្នាក់នៅ។ រូបបដិមាករតូចៗ ដែលស្ថិតនៅក្នុងបរិវេណវត្ត ត្រូវបានកម្ទេចចោល។ នៅពេលដែលកម្មាភិបាល ប.ក.ក បានភៀសខ្លួនចេញពីវត្តសំរោងក្នុងនៅ ខែមករា ឆ្នាំ១៩៧៩ ពួកនោះបានទុកអ្នកទោសដែល នៅរស់ ឲ្យជាប់ច្រវ៉ាក់ជើងនៅក្នុងវត្ត។ គេឃើញមានស្នាមឈាម សម្លៀកបំពាក់ និងខ្នោះនៅក្នុងកុដិ ហើយផ្នូរ និងសាកសពមនុស្សគេឃើញនៅក្បែរវត្ត។

### វត្តដំណាក់ត្រយឹង (ខេត្តកំពត)

៧៤៣- វត្តដំណាក់ត្រយឹង ស្ថិតនៅក្នុងភូមិដំណាក់ត្រយឹង ឃុំសំរោងលើ ស្រុកបន្ទាយមាស ខេត្តកំពត។ វត្តនេះគឺជាវត្តមួយក្នុងចំណោមវត្តដែលចំណាស់ៗបំផុត សម្រាប់ឲ្យប្រជាជនគោរពបូជានៅក្នុងតំបន់នោះ។ តំបន់នោះត្រូវបាន ប.ក.ក កាន់កាប់ និងគ្រប់គ្រងតាំងពីមុនឆ្នាំ១៩៧៥។ នៅក្នុងកិច្ចប្រជុំដែលកោះហៅដោយគណៈស្រុក ប.ក.ក ព្រះសង្ឃទាំងអស់ត្រូវបានគេប្រាប់ថា លោកត្រូវតែលាចាកសិក្ខាបទ ដើម្បីធ្វើការ ឬចូលបម្រើទាហាន។ នៅពាក់កណ្ដាលឆ្នាំ១៩៧៥ មានតែចៅអធិការវត្តដំណាក់ត្រយឹងតែមួយអង្គគត់ ដែលមិនព្រមលាចាកសិក្ខាបទ។ ជាយថាហេតុ ព្រះចៅអធិការបានរត់គេចខ្លួន ប៉ុន្តែលោកត្រូវបានកងនារី

ប.ក.ក ចាប់ខ្លួន ហើយក៏បាត់ខ្លួនរហូតមក។ បន្ទាប់ពីព្រះចៅអធិការវត្តបានបាត់ខ្លួន កម្មាភិបាល ប.ក.ក ក្នុងតំបន់បានកោះប្រជុំ ហើយបានផ្តន្ទាទោសព្រះអង្គថាជា "បិសាច"។

៧៤៤- តាមទិសដៅរបស់ ប.ក.ក ទីសំណាក់ធម៌ និងកុដិលោកទាំងឡាយនៅវត្តដំណាក់ត្រយឹង ត្រូវបានរុះរើ ឈើ និងសសររបស់កុដិទាំងនោះ ត្រូវបានគេយកទៅធ្វើជារោងបាយ កម្មាភិបាល ប.ក.ក បានរស់នៅក្នុងកុដិមួយដែលនៅសល់ពីការរុះរើ ហើយទីធ្លាវត្តអារ៉ាម ត្រូវបានប្រើជាទីស្នាក់ការ។ នៅក្នុងបរិវេណវត្ត ព្រះពុទ្ធបដិមាករធំៗទាំងឡាយ ត្រូវបានបំផ្លាញទាំងស្រុង ហើយព្រះពុទ្ធបដិមាតូចៗ ត្រូវបានវាយបំបាក់ ហើយបោះចូលទៅក្នុងត្រពាំងនៅខាងមុខវិហារធំ។ កម្មាភិបាល ប.ក.ក បានសម្លាប់សត្វក្របី និងគោ នៅក្នុងទីធ្លាវត្តនេះ។

## វត្តអន្លង់វៀន (ខេត្តក្រចេះ)

៧៤៥- វត្តអន្លង់វៀន ដែលគេស្គាល់ថាជាវត្តមុនីវណ្ណារ៉ាម ស្ថិតនៅក្នុងភូមិអន្លង់វៀន ឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ។ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ មានព្រះសង្ឃប្រាំមួយអង្គ ក្នុងចំណោមព្រះសង្ឃ៧អង្គដែលគង់នៅវត្តអន្លង់វៀន ត្រូវលាចាកសិក្ខាបទ ដោយសារតែមានការកៀបសង្កត់ពី ប.ក.ក។ [redacted] ជាលោកសង្ឃអង្គចុងក្រោយ ដែលត្រូវ [redacted] បង្ខំឱ្យសឹកនៅក្នុងឆ្នាំ១៩៧៦ ហើយបង្ខំលោកឱ្យធ្វើការនៅក្នុងសហករណ៍។ ព្រះសង្ឃផ្សេងៗទៀតនៅក្នុងតំបន់នោះ ត្រូវបានសម្លាប់ ដោយសារលោកមិនព្រមលាចាកសិក្ខាបទ។ នៅដើមឆ្នាំ១៩៧៦ មានលោកសង្ឃ៤អង្គ ត្រូវបានឈ្លបឃុំកន្ទួតយកមកឱ្យគង់ចំនួន៣ថ្ងៃនៅក្នុងវត្តអន្លង់វៀននេះ ហើយក្រោយមកក៏បានធ្វើគតលោកទាំង៣អង្គនោះទៅ។

៧៤៦- តាមទិសដៅរបស់ ប.ក.ក វត្តអន្ទង់វៀន ត្រូវបានយកទៅធ្វើជារោងបាយរួម។ ក្នុងរយៈពេល១០ ថ្ងៃ នៅដើមឆ្នាំ ១៩៧៧ សមាជិកកងចល័តឃុំដែល [redacted] បានបំផ្លាញព្រះវិហារធំ ហើយបានយកដែកសសៃពីកំទេចកំទីវិហារទៅសាងសង់ទំនប់ឃុំ។ ព្រះពុទ្ធរូបទាំង១៤អង្គ នៅក្នុងវត្តត្រូវបានវាយកំទេច និងយកទៅបោះចោលក្នុងស្ទឹងខាងត្បូងវត្ត។ ទីបញ្ចប់មិនមានអ្វីនៅសល់នៅក្នុងវត្តតទៅទៀតទេ។

## វត្តជ័យមង្គល (ខេត្តស្ទឹងត្រែង)

៧៤៧- វត្តជ័យមង្គល ស្ថិតនៅក្នុងភូមិកំភុន ឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ព្រះសង្ឃនៅក្នុងតំបន់នេះ ត្រូវបានបង្ខំឱ្យលាចាកសិក្ខាបទ ក្រោមការគៀបសង្កត់យកទៅសម្លាប់ចោល។ មេគុណខេត្តស្ទឹងត្រែង ព្រះតេជគុណ ស៊ិន ត្រូវបានយោធាខ្មែរក្រហមយកទៅសម្លាប់ បន្ទាប់ពីព្រះអង្គមិនព្រមលាចាកសិក្ខាបទ។ បន្ទាប់ពីផ្សឹកហើយ ព្រះសង្ឃត្រូវបានគេបញ្ជូនទៅលើកទំនប់ និងជីកប្រឡាយ។

៧៤៨- តាមទិសដៅរបស់ ប.ក.ក ព្រះវិហារធំរបស់វត្តជ័យមង្គល ត្រូវបានបំផ្លាញចោល ចំណែកឯព្រះពុទ្ធរូប ត្រូវបានគេយកទៅទម្លាក់ចោលនៅក្នុងទន្លេសេសាន ដែលស្ថិតនៅខាងមុខវត្ត។ កុដិលោកនៅក្នុងទីបរិវេណវត្ត ត្រូវបានរុះរើ ដោយគេយកឈើទៅធ្វើជាជង្រុកស្រូវ ជារោងបាយរួម និងធ្វើជាទ្រុងចិញ្ចឹមជ្រូក។

## វត្តចំបក់ធំ (ខេត្តស្វាយរៀង)

៧៤៩- វត្តចំបក់ធំស្ថិតនៅក្នុងភូមិដីក្រហម ឃុំមេសថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ចម្ងាយប្រមាណជាង៥គីឡូម៉ែត្រ ពីព្រំប្រទល់វៀតណាម។ គិតត្រឹមឆ្នាំ១៩៦៥ មានព្រះសង្ឃចំនួន

៨០អង្គគង់នៅក្នុងវត្តនោះ។ នៅក្នុងឆ្នាំ១៩៧០ តំបន់នោះត្រូវបាន ប.ក.ក ចូលកាន់កាប់ ហើយ វត្តចំបក់ធំ ត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ប្រជុំបំពាក់បំប៉នគោលនយោបាយបក្សកុម្មុយនីស្តបដិវត្តដល់ព្រះសង្ឃ និងប្រជាជនមូលដ្ឋាន។ នៅដើមឆ្នាំ១៩៧៣ ប.ក.ក បានចាប់ផ្តើមផ្សឹកព្រះសង្ឃនៅក្នុងវត្ត ដោយលើកឡើងថា ព្រះសង្ឃពឹងផ្អែកលើពួកគេក្នុងការហូបចុក និងចិញ្ចឹមជីវិត ដូច្នេះត្រូវតែផ្សឹកដើម្បីចូលរួមជាមួយចលនាតស៊ូ។ ជាការឆ្លើយតប ព្រះសង្ឃជាច្រើនអង្គបានរត់ទៅវៀតណាម។ ប៉ុន្តែដោយសារតែភ័យខ្លាចនឹង ប.ក.ក ព្រះសង្ឃដែលនៅសល់ប្រមាណជា៣០អង្គ បានស្ម័គ្រចិត្តលាចាកសិក្ខាបទ ដោយរួមទាំង ព្រះចៅអធិការ សោម សែម ព្រះសង្ឃដែលបដិសេធមិនព្រមសឹកដោយស្ម័គ្រចិត្ត ត្រូវ ប.ក.ក បង្ខំឲ្យសឹកក្នុងឆ្នាំ១៩៧៣។

៧៥០- តាមទិសដៅរបស់ ប.ក.ក វត្តចំបក់ធំ ត្រូវបានប្រែក្លាយទៅជារោងសិប្បកម្ម។ នៅទីបំផុត ប.ក.ក បានបំផ្លាញវត្តនោះ ដែលរួមមាន ព្រះវិហារ សាលាឆាន់ កុដិ និងរូបបដិមាព្រះពុទ្ធជាដើម។ បំណែកកម្ទេចកម្ទីរស្ថិតនៅពាសពេញក្នុងវត្ត លោណដ្ឋានត្រូវបាន ប.ក.ក ជីកនៅក្នុងបរិវេណវត្តនោះ។

## វត្តតាគត់មង្គល (ខេត្តកណ្តាល)

៧៥១- វត្តតាគត់មង្គលស្ថិតក្នុងភូមិព្រែកថ្មី ឃុំជ័យធំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ក្នុងឆ្នាំ១៩៦៤ មានព្រះសង្ឃចំនួន១០០អង្គនៅក្នុងវត្តនោះ។ តំបន់នោះបានស្ថិតក្នុងការកាន់កាប់ របស់ ប.ក.ក មុនពេលបែកភ្នំពេញ ហើយព្រះសង្ឃគ្រប់អង្គត្រូវបានបង្ខំឲ្យសឹក មុនថ្ងៃ១៧ ខែ មេសា ឆ្នាំ១៩៧៥។ ប.ក.ក បានហាមឃាត់ការប្រគេនទេយ្យវត្ថុ និងហាមឃាត់ការ

ប្រារព្ធពិធីបែបពុទ្ធសាសនាផ្សេងៗ។ ប្រធានកង ប្រធានភូមិ និងប្រធានឃុំ ប.ក.ក បាន ប្រកាសថា មិនអនុញ្ញាតឲ្យមានជំនឿសាសនាទេ ហើយបានប្រកាសថា ព្រះសង្ឃគឺ "អនុធន" "សក្តិភូមិនិយមដែលជញ្ជក់ឈាមប្រជាជន" និងជា"ខ្មាំង" របស់ ប.ក.ក។ ព្រះសង្ឃទាំងឡាយដែលប្រណិប័តតាមសាសនាព្រះពុទ្ធ ត្រូវគេកៀបសង្កត់ គម្រាមកំហែង និងពេលខ្លះត្រូវគេសម្លាប់។

៧៥២- តាមទិសដៅរបស់ ប.ក.ក សមាជិកគណៈស្រុករស់នៅក្នុងវត្ត។ កុដិមួយនៅក្នុងវត្តនោះ ត្រូវបានប្រើជាឃ្លាំងសម្រាប់ស្តុកស្រូវ ហើយកុដិមួយផ្សេងទៀត ត្រូវប្រើជាមន្ទីរឃុំឃាំង។ អតីតកន្លែងសម្រាប់ជាទីសក្ការៈមួយ ត្រូវបានប្រើជាកន្លែងចិញ្ចឹមជ្រូក។ ព្រះពុទ្ធបដិមា ត្រូវបានយកចេញពីព្រះវិហារ ហើយទម្លាក់ចោលនៅក្នុងត្រពាំងដែលនៅក្បែរនោះ។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម

### សេចក្តីផ្តើម

៧៥៣- ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប.ក.ក បានកំណត់ឲ្យកម្ទេចក្រុមជាតិពន្ធុ និងក្រុមសាសនាចាម នៅខេត្តកំពង់ចាម ដែលជាមូលដ្ឋានប្រវត្តិសាស្ត្ររបស់ប្រជាជនចាមនៅប្រទេសកម្ពុជា។ ផែនការរបស់ ប.ក.ក បានទទួលជោគជ័យ ដោយបានបំផ្លាញមួយផ្នែកដ៏សំខាន់នៃប្រជាជនចាម ដោយសារតែប្រវត្តិសាសនា និងជាតិពន្ធុរបស់ពួកគេតែម្យ៉ាងប៉ុណ្ណោះ។ ការកម្ទេចនេះ រួមមាន ការយកស្ត្រី និងកុមារចាម ចេញពីក្នុងក្រុម ហើយដាក់ពួកគេនៅក្នុងសហគមន៍ខ្មែរ បង្ខំឲ្យជនជាតិចាមរៀបការជាមួយនឹងជាតិពន្ធុក្នុងក្រុមដទៃទៀត និងហាមឃាត់គ្រប់ផ្នែកពាក់ព័ន្ធនឹងវប្បធម៌ ដែលជាប្រពៃណីបញ្ជាក់ពីអត្តសញ្ញាណរបស់ក្រុមនោះ

ដូចជា ប្រពៃណី សាសនា ការតមអាហារ និងការប្រើប្រាស់សម្លៀកបំពាក់ ព្រមទាំងការប្រើប្រាស់ភាសារបស់ពួកគេជាដើម។ ប.ក.ក បានបន្តការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម តាមរយៈការបំបែកភូមិនានារបស់ជនជាតិចាម និងការពង្រាយសហគមន៍របស់ជនជាតិចាមទាំងនោះ ទៅក្នុងចំណោមក្រុមជាតិពន្ធុឯទៀត ព្រមទាំងតាមរយៈការកំណត់យកមេដឹកនាំរបស់ក្រុមជនជាតិចាមទៅសម្លាប់ចោលជាប្រព័ន្ធ។ យុទ្ធនាការនេះ បានឈានដល់កម្រិតកំពូលក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ១៩៧៨ ដោយកម្មាភិបាល ប.ក.ក នៅតាមបណ្តាភូមិភាគនានា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានកាប់សម្លាប់ទៅលើសហគមន៍ជនជាតិចាមទាំងមូលតាមការព្រាងទុក។

## ប្រភពដើមរបស់ជនជាតិចាមនៅកម្ពុជា

៧៥៤- ប្រជាជនចាម គឺជាក្រុមជាតិពន្ធុ និងក្រុមសាសនាផ្សេងដោយឡែក ដែលរស់នៅក្នុងប្រទេសកម្ពុជា។ ពួកគេគឺជាអ្នកកាន់សាសនាអ៊ីស្លាម និងជាកូនចៅជំនាន់ក្រោយរបស់អាណាចក្រចម្ប៉ា ដែលក្រោយមកបានតាំងទីលំនៅ ពីដំបូងនៅតាមបណ្តោយដងទន្លេមេគង្គ ក្នុងប្រទេសកម្ពុជា ជាអន្តោប្រវេសន៍ធំជាងគេបំផុត ដែលកើតមាននៅក្នុងចុងទសវត្ស១៧៩០។ មុនពេល ប.ក.ក ដណ្តើមបានអំណាច ប្រជាជនចាមប្រើភាសារបស់ខ្លួន ដើម្បីទំនាក់ទំនងគ្នារស់នៅក្នុងភូមិរបស់ខ្លួន គោរពប្រពៃណីសាសនា និងស្លៀកសម្លៀកបំពាក់ប្រពៃណីរបស់ខ្លួន។ ទោះបីជា សហគមន៍របស់ជនជាតិចាមស្ថិតនៅរាយប៉ាយតាមកន្លែងផ្សេងៗ ប៉ុន្តែកន្លែងប្រមូលផ្តុំសំខាន់មួយ ក្នុងចំណោមកន្លែងប្រមូលផ្តុំទាំងឡាយរបស់ប្រជាជនចាម ក្នុងប្រទេសកម្ពុជា នោះគឺស្ថិតនៅក្នុងខេត្តកំពង់ចាម ហើយភូមិរបស់ជនជាតិចាមភាគច្រើនស្ថិតនៅតាមបណ្តោយទន្លេមេគង្គ ក្នុងភូមិភាគកណ្តាល(ឧត្តរចាស់) និងភូមិភាគបូព៌ា។

## គោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់គោលដៅលើប្រជាជនចាម

៧៥៥- សហគមន៍ចាមនៅក្នុងប្រទេសកម្ពុជា ត្រូវទទួលរងការធ្វើទុក្ខបុកម្នេញ និងត្រូវកំណត់ជាគោលដៅ ចាប់ពីពេលដែល ប.ក.ក ចូលកាន់កាប់តំបន់របស់ពួកគេ ដែលមានទីតាំងមួយចំនួន ត្រូវគេចូលកាន់កាប់មុនខែមេសា ឆ្នាំ១៩៧៥។ ប.ក.ក បានចាត់ទុកពួកជនជាតិចាម ជាប្រជាជន "ដែលអន់ជាងប្រជាជន១៧មេសា"ទៅទៀត ហើយ ប៉ុល ពត ជាលេខា ប.ក.ក បានធ្វើសេចក្តីថ្លែងការណ៍ ដោយអំពាវនាវឲ្យធ្វើទុក្ខបុកម្នេញ និងបំផ្លិចបំផ្លាញទៅលើជនជាតិចាម។

៧៥៦- ដំបូងនៅចុងឆ្នាំ១៩៧៥ ប.ក.ក បានបង្ខំឲ្យជនជាតិចាមជាច្រើន រើចេញពីភូមិរបស់ពួកគេ និងពង្រាយពួកគេពាសពេញភូមិប្រជាជនខ្មែរ។ ប្រជាជនចាមចំនួនរាប់ម៉ឺននាក់ ត្រូវគេបង្ខំឲ្យផ្លាស់ទី ទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ ជាផ្នែកមួយនៃគោលនយោបាយរបស់ ប.ក.ក ដែលបានរៀបចំឡើងសម្រាប់ "បំបែក" ជនជាតិចាមលើសពី១០០០០០នាក់ ដែលរស់នៅភូមិភាគបូព៌ា។ ជាញឹកញាប់ បុរសជាជនជាតិចាម ត្រូវគេបំបែកចេញពីស្ត្រី និងកុមារជនជាតិចាម ហើយត្រូវគេផ្លាស់ទៅតំបន់ផ្សេងៗទៀតជាផ្នែកមួយនៃកងចល័ត។ ហេតុការណ៍នេះ បានកើតមាននៅទីកន្លែងមួយចំនួន រួមមាន ស្រុកកងមាស ស្រុកក្រូចឆ្មារ និងស្រុកកោះសូទិន ក្នុងខេត្តកំពង់ចាម។

៧៥៧- នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ប្រហែលជាមួយខែ បន្ទាប់ពីពេលកាន់កាប់អំណាចរបស់ខ្លួន មេដឹកនាំ ប.ក.ក បានធ្វើសន្និសីទនៅទីក្រុងភ្នំពេញ ដែលមានការចូលរួមពីសំណាក់លេខាស្រុក លេខាតំបន់ និងលេខាភូមិភាគទាំងអស់នៅក្នុងប្រទេស ព្រមទាំងតំណាងរាល់អង្គភាពយោធាទាំងអស់ផងដែរ។ កម្មាភិបាល ប.ក.ក ដែលចូលរួមក្នុងអង្គសន្និសីទ ត្រូវបាន **នួន ជា** និង ប៉ុល

ពត ធ្វើការណែនាំពីមាគ៌ា និងគោលនយោបាយបក្ស ដែលពួកគេត្រូវអនុវត្តនៅក្នុងតំបន់របស់ខ្លួន។ នៅក្នុងចំណោមការណែនាំនេះ មានផែនការប្រាំបីចំណុច ដែលចំណុចទីប្រាំនៅក្នុងសេចក្តីណែនាំនោះ គឺ"ត្រូវលុបបំបាត់វាល់សាសនា ដោយសារតែ វាសុទ្ធតែប្រតិកិរិយា"។ ជាពិសេស ប៉ុល ពត បានណែនាំឲ្យកម្មាភិបាល ប.ក.ក ត្រូវបង្ខំជនជាតិចាមឲ្យចិញ្ចឹមជ្រូក និងទទួលទាន សាច់ជ្រូក ហើយប្រសិនបើជនណាមួយជំទាស់នឹងត្រូវគេសម្លាប់។ "សារាចរ" ពាក់ព័ន្ធនឹងសកម្មភាពធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម ក៏ត្រូវបានគេចែកជូនផងដែរ។ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តជាផ្លូវការ នៅក្នុងឆ្នាំ១៩៧៦ ដោយហាមប្រាមសាសនា "ប្រតិកិរិយា" ដែល ប.ក.ក អនុម័ត ដោយរួមទាំងសាសនាអ៊ីស្លាមផងដែរ។

៧៥៨- ជនជាតិចាមត្រូវគេហាមឃាត់មិនឲ្យចូលរួមក្នុងគ្រប់កាតព្វកិច្ចរបស់សាសនាអ៊ីស្លាម(*vachip*) ដូចជា ការសូត្រធម៌(*sambahyang*) ការតមអាហារ ការចូលរួមក្នុងការផ្តល់ទយ្យទាន ឬការធ្វើពិធីបុណ្យសព ឬបុណ្យសាសនាផ្សេងៗ។ ពួកគេត្រូវហាមឃាត់មិនឲ្យរក្សាទុកគម្ពីរអ៊ីស្លាមដែលត្រូវបានប្រមូល និងដុតកម្ទេចចោល ដោយពួកល្បាបប្រដាប់អាវុធខ្មែរក្រហមក្រោមការត្រួតពិនិត្យរបស់ប្រធានឃុំ ឬកម្មាភិបាលថ្នាក់ខ្ពស់ផ្សេងទៀត។ សាក្សីមួយរូបដែលផ្ទះរបស់គាត់ត្រូវគេចូលឆែក បានប្រាប់ថា គាត់នឹងត្រូវគេសម្លាប់ចោល ប្រសិនបើពួកគេរកឃើញគម្ពីរកូរ៉ាននោះ។ វិហារអ៊ីស្លាមជាច្រើនត្រូវរងការខូចខាត ឬកម្ទេចចោល ឬប្រែក្លាយទៅជាមន្ទីរ ប.ក.ក កន្លែងហូបបាយរួម ជាឃ្លាំង ឬកន្លែងចិញ្ចឹមជ្រូកជាដើម រីឯសម្បត្តិរបស់ជនជាតិចាមដទៃទៀត ក៏មានសភាពដូចគ្នានេះដែរ។ ប.ក.ក មានគោលដៅសម្លាប់អ្នកដឹកនាំនយោបាយ និងសាសនារបស់ជនជាតិចាម ក៏ដូចជាសម្លាប់ជនជាតិចាមទាំង

ឡាយណា ដែលបដិសេធមិនព្រមបោះបង់ចោលសាសនារបស់ពួកខ្លួន។ ជនជាតិចាមដែលបានបន្តប្រតិបត្តិសាសនាអ៊ីស្លាម ត្រូវបានគេគម្រាមកំហែងថានឹង "យកទៅធ្វើជី"។

៧៥៩- គោលនយោបាយរបស់ ប.ក.ក បានហាមមិនឱ្យប្រើភាសាចាម មិនឱ្យស្លៀកសម្លៀកបំពាក់ប្រពៃណីរបស់ជនជាតិចាម(សារ៉ុង*fez* និងរ៉ូបវែងសម្រាប់ស្ត្រីពាក់នៅពេលស្លូត្រធម៌*makhna*) និងមិនឱ្យប្រើប្រាស់ឈ្មោះរបស់ជនជាតិចាមទេ។ ប្រជាជនចាមគ្រប់ៗរូប ត្រូវគេគម្រាមកំហែងយកទៅសម្លាប់ ប្រសិនបើពួកគេនិយាយភាសាចាម។ ជាលទ្ធផលនៅឆ្នាំ១៩៧៩ កុមារជនជាតិចាម លែងចេះនិយាយភាសាកំណើតរបស់ជនជាតិខ្លួនទៀតហើយ។ ជនជាតិចាមត្រូវគេបង្ខំឱ្យប្រព្រឹត្តអំពើ ដែលត្រូវបានហាមប្រាមដាច់ខាតក្នុងជំនឿរបស់ខ្លួន ដូចជា ការទទួលទានសាច់ជ្រូក និងចិញ្ចឹមជ្រូកជាដើម។ ស្ត្រីជនជាតិចាម ត្រូវគេបង្ខំឱ្យកាត់សក់ឱ្យខ្លី ហើយមិនអនុញ្ញាតឱ្យប្រើរបាំងគ្របក្បាលជាប្រពៃណីនោះឡើយ។ ជនជាតិចាមត្រូវបានគេប្រាប់ឱ្យរៀបការជាមួយ អ្នកដែលមិនមែនជាជនជាតិចាម។ ពាក់ព័ន្ធជាមួយនឹងការកប់សាកសពរបស់ជនជាតិចាម ប៉ុល ពត បានប្រាប់ទៅកម្មាភិបាល ប.ក.ក ថា"សាកសពត្រូវកប់ដោយបែបណានោះ គឺអាស្រ័យលើបដិវត្តន៍"។ ការមិនគោរពទៅតាមវិន័យរបស់ ប.ក.ក អាចនឹងត្រូវគេយកទៅសម្លាប់ចោល ហើយការបន្តភ័យខ្លាចចំពោះការគម្រាមកំហែងនេះ បានកើតមានឡើង។

## ការអនុវត្តន៍គោលនយោបាយរបស់ ប.ក.ក ក្នុងការកម្ទេចជនជាតិចាម

៧៦០- ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ សហគមន៍ជនជាតិចាមទាំងមូល ត្រូវបានគេប្រមូលផ្តុំ និងយកទៅកាន់មន្ទីរសន្តិសុខ និងទីពិឃាតផ្សេងៗដើម្បីសម្លាប់ចោល ជាកិច្ចគាំទ្រដល់ការលុបបំបាត់

ទាំងស្រុងជនជាតិចាមដែលនៅសេសសល់ក្នុងតំបន់ទាំងនោះ។ អំពើប្រល័យពូជសាសន៍ គឺជាផ្នែកមួយនៃការប្រព្រឹត្តិជាសណ្ឋានដែលបានកើតមាននៅតាមបណ្តាភូមិចាម ដែលស្ថិតនៅទាំងភូមិភាគកណ្តាល និងភូមិភាគបូព៌ា។ ការកើតមាននូវសកម្មភាពអស់ទាំងនេះនៅក្នុងភូមិភាគទាំងនោះ រួមជាមួយការប្រាស្រ័យទាក់ទងរបស់មជ្ឈិមបក្ស ចំពោះការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម ព្រមទាំងបញ្ជាទាំងឡាយដែលដាក់ចេញតាមរយៈខ្សែសង្វាក់ បញ្ជាឱ្យប្រមូលជនជាតិចាម ដើម្បីសម្លាប់រង្គាល ជាភស្តុតាងបង្ហាញថាឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានព្រាងទុកដោយមានការសម្របសម្រួល ហើយជាពិសេស ត្រូវបានប៉ុនប៉ងដោយមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក នៅទីក្រុងភ្នំពេញ។

## នៅក្នុងស្រុកកងមាស (ភូមិភាគកណ្តាល)

[redacted] នៅថ្ងៃមួយ កងកម្លាំងសន្តិសុខនៅឃុំពាមជីកង ក្នុងស្រុកកងមាស ខេត្តកំពង់ចាម បានប្រមូលផ្តុំជនជាតិចាមទាំងអស់នៅក្នុងឃុំ ហើយនាំយកពួកគេទៅដាក់នៅគុកស្រុក ស្ថិតនៅវត្តអូរត្រកួន។ ជនជាតិចាមប្រហែល៣០០នាក់ដែលត្រូវគេចាប់ខ្លួននៅថ្ងៃនោះ មកពីភូមិ សំបួរមាស ក ភូមិសំបួរមាស ខ និងភូមិសាច់ស្ង។ ពួកគេត្រូវចាប់ខ្លួន ដោយកងមួយដែលមានឈ្មោះថា ឈ្លបដាវវែង ដែលកងនេះត្រូវបានបង្កើតឡើង ដោយកម្មាភិបាលភូមិភាគនិរតី បន្ទាប់ពីមានការបោសសម្អាតនៅភូមិភាគកណ្តាល នាដើមឆ្នាំ១៩៧៧។ ពេជ្ឈឃាតគុកទាំងនោះត្រូវគេឃើញ និងបានឮការសម្លាប់អ្នកទោសជនជាតិចាមទាំងនោះ រហូតដល់ពេលទៀបភ្លឺ នៅក្នុងចំការមួយជាប់នឹងគុកនោះ។ កុមារៗត្រូវគេសម្លាប់ ដោយបោកនឹងដើមឈើ។ [redacted]

[redacted]

៧៦២- ក្នុងអំឡុងរយៈពេលដូចគ្នានោះ ជនជាតិចាមដែលនៅសល់ទាំងអស់ពីឃុំមួយទៀត នៅស្រុកកងមាស គឺឃុំអង្គរបាន ក៏ត្រូវគេប្រមូលផ្តុំ រួចបញ្ជូនទៅគុកវត្តអូរត្រកួន ស្រដៀងគ្នានេះដែរ។ ជនជាតិចាម ដែលយកមកពីភូមិមួយក្នុងចំណោមភូមិក្នុងឃុំអង្គរបាន សុទ្ធតែជាស្ត្រី និងកុមារ ដោយសារតែបុរសត្រូវបានគេបំបែកចេញពីក្រុមគ្រួសាររបស់ពួកគេ ហើយបញ្ជូនទៅកងចល័តវិញ។ ជនជាតិចាមមកពីភូមិទាំងនេះ ត្រូវគេរាយការណ៍ថា ខិតខំប្រឹងប្រែងធ្វើការងារណាស់ ហើយមិនបានប្រព្រឹត្តរំលោភបំពានទៅលើគោលនយោបាយរបស់ ប.ក.ក ទេ ហើយ "ពួកគេត្រូវចាប់ខ្លួន ដោយសារតែពួកគេជាជនជាតិចាម តែម្យ៉ាងប៉ុណ្ណោះ"។

៧៦៣- នៅក្នុងឃុំរកាគយ ស្រុកកងមាស នៅពេលបុរសជាជនជាតិចាម ត្រូវគេបញ្ជូនទៅកាប់ឫស្សីនៅខេត្តកំពង់ធំ ស្ត្រី និងកុមារជនជាតិចាម ត្រូវបានគេប្រមូលផ្តុំ រួចសម្លាប់ចោល។

៧៦៤- ការសម្លាប់រង្គាលទៅលើសហគមន៍ជនជាតិចាមនៅក្នុងស្រុកកងមាស នាវត្តអូរត្រកួន បានកើតឡើង ក្រោយពី [redacted] កោះប្រជុំនៅក្នុងតំបន់នោះ។ នៅក្នុងអង្គប្រជុំមួយក្នុងចំណោមអង្គប្រជុំទាំងនោះ ដែលធ្វើឡើងប្រមាណជាដប់ថ្ងៃមុនពេលដែលការចាប់ខ្លួន និងការសម្លាប់រួមកើតមាន [redacted] បានបញ្ជាឲ្យប្រធានកងនៅតាមការដ្ឋាន ធ្វើការប្រមូលផ្តុំជនជាតិចាមដែលនៅសេសសល់ "ដើម្បីយកពួកគេទៅកាន់មូលដ្ឋានរបស់ពួកគេវិញ" ដែលគេអាចយល់បានថា ពួកគេនឹងត្រូវយកទៅមន្ទីរសន្តិសុខក្នុងស្រុក

របស់ពួកគេ។ មេកងបានចងក្រងបញ្ជីឈ្មោះជនជាតិចាមពីមុនមក ដែលមាន នៅក្នុងកងរបស់ខ្លួន ដោយគោរពតាមការណែនាំជាលាយលក្ខណ៍អក្សរមក ពីអនុលេខា ស្រុក។ បទបញ្ជាឱ្យចាប់ខ្លួនប្រជាជនចាម ត្រូវបានបញ្ជូនទៅឱ្យឈ្លប តាមរយៈ [redacted] ដែលជាអ្នករាយការណ៍ទៅឱ្យ [redacted]។

៧៦៥- ក្នុងអំឡុងពេលដែលការកាប់សម្លាប់រង្គាល បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៧ ជនជាតិចាមមិនត្រូវបានគេសួរចម្លើយមុនពេលត្រូវគេសម្លាប់ ដូចការអនុវត្តន៍គំរូចំពោះជាតិពន្ធុខ្មែរដែលត្រូវគេចាប់យកទៅមន្ទីរសន្តិសុខ។ វាមិនសំខាន់ទេ ថាតើជនជាតិចាមនោះ បានប្រព្រឹត្តកំហុស ឬអត់ ពួកគេត្រូវតែចាប់ខ្លួន និងសម្លាប់ចោល ដោយគ្មានការពាក់ព័ន្ធអ្វីទាំងអស់។ ប្រជាជនចាមដែលត្រូវគេចាប់ខ្លួន និងយកទៅវត្តអូរត្រកួន "មិនត្រូវគេឃុំឃាំងខ្លួនយូរនោះទេ" ប៉ុន្តែភាគច្រើនពួកគេ"ត្រូវគេយកទៅ រួចបញ្ជូនទៅរណ្តៅ ដើម្បីសម្លាប់តែម្តង"។

៧៦៦- អដ្ឋិធាតុ ត្រូវគេរកឃើញនៅវត្តអូរត្រកួន ក្នុងឆ្នាំ១៩៧៩ ក្នុងរណ្តៅសាកសពជាច្រើន ពាសពេញតំបន់មួយដែលមានផ្ទៃក្រឡាជិតមួយហិកតា និងមានរណ្តៅសាកសពធំៗ យ៉ាងតិចណាស់ចំនួន២០០(រណ្តៅនីមួយៗមានទំហំបណ្តោយ៥ម៉ែត្រ និងទទឹង៤ម៉ែត្រ ជម្រៅ២ម៉ែត្រ) និងនៅមានរណ្តៅតូចៗប្រមាណជា១០០០រណ្តៅទៀត។ មុនពេលដែល ប.ក.ក ប្រែក្លាយវត្តនេះទៅជាមន្ទីរសន្តិសុខ តំបន់នេះមិនធ្លាប់មានរណ្តៅអស់ទាំងនេះទេពីមុនមក។ លលាដ៏ក្បាលរាប់ពាន់ត្រូវគេរកឃើញ ហើយជញ្ជាំងរបស់វត្តមានប្រឡាក់សុទ្ធតែស្នាមឈាម។ អដ្ឋិធាតុក្នុងរណ្តៅកប់សាកសពទាំងនោះ ត្រូវបានអ្នកស្វែងរក (scavengers) ធ្វើការជីកកកាយ

ឡើង ហើយត្រូវគេរក្សាទុកនៅក្នុងចេតិយមួយនៅវត្តនោះ ជាចំណែកតូចមួយនៃតំណាងសាកសពទាំងអស់ ដែលត្រូវគេកប់នៅក្នុងតំបន់នេះ។

## នៅស្រុកក្រូចឆ្មារ (ភូមិភាគបូព៌ា)

៧៦៧- ការសម្លាប់សហគមន៍ចាមទាំងមូល ក៏បានកើតមាននៅផ្នែកម្ខាងទៀតនៃទន្លេមេគង្គដែរ គឺនៅក្នុងស្រុកក្រូចឆ្មារដែលជាផ្នែកមួយនៃតំបន់២១ ក្នុងភូមិភាគបូព៌ា ដែលត្រូវបានគេពិពណ៌នាប្រៀបដូចជា "ទឹកដីបេះដូង របស់ប្រជាជនចាមនៅកម្ពុជា"។

៧៦៨- នៅក្នុងឃុំក្រូចឆ្មារ មានប្រជាជនចាមជាច្រើនរយនាក់ ដែលត្រូវគេប្រមូលផ្តុំនៅវត្តខ្សាច់ប្រឆេះ។ ប្រជាជនទាំងក្មេង និងមនុស្សចាស់ មកពី៨០គ្រួសារ ត្រូវបានគេដឹកតាមទូកយកទៅ ហើយគេមិនដែលឃើញពួកគេទាំងនោះត្រឡប់មកវិញទេ។ ស្ត្រីវ័យក្មេងដែលមិនទាន់រៀបការ ដែលមានចំនួនពី៤០នាក់ ទៅ២០០នាក់ ត្រូវគេយកទៅទីបញ្ជាការស្រុកក្រូចឆ្មារ ស្ថិតនៅក្នុងភូមិទ្រា២ ជាកន្លែងដែលពួកគេត្រូវគេចង្អួចសួរ ថាតើពួកគេជា"ខ្មែរ ឬចាម" ហើយបែងចែកទៅតាមចម្លើយដែលឆ្លើយប្រាប់នោះ។ អ្នកដែលឆ្លើយថា ពួកគេជាជនជាតិចាមត្រូវគេយកទៅហើយសម្លាប់ចោល។ អ្នកខ្លះត្រូវគេរំលោភមុននឹងត្រូវគេសម្លាប់។ ស្ត្រីដែលបញ្ជាក់ថាខ្លួនជាជនជាតិខ្មែរ ត្រូវគេឃុំឃាំងជាច្រើនថ្ងៃ ដោយក្នុងអំឡុងពេលឃុំឃាំងនោះ ពួកគេត្រូវគេសាកល្បង ដោយឲ្យទទួលទានសម្លសាច់ជ្រូក។ អ្នកដែលអនុវត្តការសម្លាប់នេះ ជាកម្មាភិបាល ប.ក.ក មកពីភូមិភាគកណ្តាល ឬភូមិភាគនិរតី រួមមាន [redacted]។

៧៦៩- ជនជាតិចាម មកពីតំបន់ផ្នែកផ្សេងៗទៀតក្នុងស្រុកក្រូចឆ្មារ ក៏ត្រូវគេនាំយកទៅភូមិទ្រា ដើម្បីសម្លាប់រង្គាលដែរ។ នៅឆ្នាំ១៩៧៨ កម្មាភិបាល ប.ក.ក មកពីភូមិភាគនិរតី បានបញ្ជាឱ្យប្រជាជនចាមត្រឡប់ទៅកាន់ភូមិកំណើតរបស់ពួកគេវិញ។ ប៉ុន្មានថ្ងៃក្រោយមក គ្រួសារជនជាតិចាមនៅភូមិអំពិលដែលនៅសល់ ត្រូវមេឃុំរបស់ខ្លួនចេញបញ្ជាឱ្យទៅភូមិទ្រា។ នៅតាមផ្លូវ ពួកគេបានជួបជនជាតិចាមដែលមកពីភូមិផ្សេងៗទៀត ដែលបានទទួលបញ្ជាឱ្យទៅភូមិទ្រាដែរ។ នៅពេលដែលពួកគេទៅដល់ បុរសត្រូវគេបំបែកចេញ ហើយឃុំឃាំងនៅក្នុងផ្ទះជាមួយនឹងបុរសជនជាតិចាមឯទៀត ហើយនៅថ្ងៃបន្ទាប់ ពួកគេត្រូវគេអូសយកទៅឡើងទូកតាមដងទន្លេមេគង្គ រួចទម្លាក់ចូលទឹក។

៧៧០- នៅចុងឆ្នាំ១៩៧៨ លេខាភូមិភាគកណ្តាល កែ ពក បានថ្លែងនៅក្នុងសន្និសីទមួយ នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ ដោយមានការចូលរួមពីលេខាស្រុកដែលមកពីភូមិភាគកណ្តាល និងភូមិភាគបូព៌ា។ នៅក្នុងអង្គប្រជុំនេះ កែ ពក បានសួរទៅកាន់[redacted]ថា "ផែនការដាក់ចេញរបស់បក្ស" បានសម្រេច"បានប៉ុន្មានភាគរយ"ហើយ ដោយបន្ថែមទៀតថា"មិត្តឯងត្រូវតែកម្ទេចពួកចាម[នៅក្នុង]កងចល័តជាមុនសិន ពួកវាសុទ្ធតែជាពួកក្បត់"។

៧៧១- ពីរថ្ងៃបន្ទាប់ពីការប្រជុំនេះ ប្រជាជនចាមនៅក្នុងឃុំជំនិក ស្រុកក្រូចឆ្មារ ត្រូវបានគេបញ្ជូនទៅវត្តស្វាយដំណាក់ រួចបន្ទាប់មក បញ្ជូនតាមទូកឆ្លងទន្លេទៅស្រុកស្ទឹងត្រង់ស្ថិតក្នុងភូមិភាគកណ្តាល។ នៅពេលទៅដល់ស្រុកស្ទឹងត្រង់ ពួកគេបានជួបកម្មាភិបាលយោធា ដែលបានចាប់ពួកគេចង ហើយប្រកាសថា ពួកគេកំពុងស្វែងរកជនក្បត់។ អ្នកដែលបានព្យាយាមលួចរត់ត្រូវគេបាញ់ចោល។ ទូកជាច្រើនបានដឹកពួកជនជាតិចាមទៅភូមិបឹងប្រចូត (ឬហៅ

ថាភូមិបឹងដែង) ក្នុងស្រុកស្ទឹងត្រង់ជារៀងរាល់ថ្ងៃ មានរយៈពេលមួយសប្ដាហ៍។ ប្រជាជនដែលបានទៅដល់ បានទុករបស់របរផ្ទាល់ខ្លួននៅក្នុងទូក ត្រូវគេបណ្ដើរកាត់តាមភូមិ ហើយគេមិនបានឃើញពួកគាត់ម្ដងទៀតទេ។ សាកសពជនជាតិចាមដែលមានទាំងសាកសពកុមារ ដែលក្បាលរបស់កុមារទាំងនោះ មានសភាពធ្ងន់ធ្ងរ ត្រូវបានគេទម្លាក់ចូលទៅក្នុងទន្លេមេគង្គ។ យ៉ាងហោចណាស់មានរណ្ដៅកប់សាកសពរួមចំនួន៥ ដែលមានទីតាំងស្ថិតនៅក្បែរទន្លេ ក្នុងភូមិទ្រា២ ដោយមានរណ្ដៅសាកសពធំមួយ មានសុទ្ធតែសាកសពស្ត្រីជនជាតិចាម។ មានរណ្ដៅសាកសពរួមជាច្រើន ត្រូវបានគេរកឃើញ នៅក្រោយភូមិបឹងប្រចូត ក្នុងស្រុកស្ទឹងត្រង់។

៧៧២- មជ្ឈិមបក្ស បានណែនាំ និងបានដឹងឮពីការសម្លាប់រង្គាលទៅលើជនជាតិចាម ក្នុងស្រុកក្រូចឆ្មារ។ ការសម្លាប់ទាំងនោះ ត្រូវបានប្រព្រឹត្តដោយកងអន្តរាគមន៍ពិសេសមួយរបស់មជ្ឈិមបក្ស ដែលត្រូវរាយការណ៍ដោយផ្ទាល់ទៅ សុន សេន។ របាយការណ៍មួយ បានបញ្ជាក់ថាជនជាតិចាមមកពីស្រុកនេះ ត្រូវបានចាប់ខ្លួនដោយកងអន្តរាគមន៍ពិសេស ដាក់តាមទូក ត្រូវកាត់ក្បាលចោល និងទម្លាក់ចូលទៅក្នុងទន្លេមេគង្គ ឬត្រូវបានបញ្ជូនដោយលេខាភូមិភាគកណ្ដាល កែ ពក ទៅកាន់មន្ទីរ៨៧០។ [redacted]។

## ក្នុងតំបន់៥ (ភូមិភាគពាយ័ព្យ)

៧៧៣- ក្នុងខែឧសភា ឆ្នាំ១៩៧៧ ជនជាតិចាមមកពីភ្នំពេញ បានតវ៉ាប្រឆាំងនឹងការផ្តល់អាហារ នៅក្នុងរោងហូបបាយរួម ដោយបានលើកឡើងថា នេះជាការរំលោភបំពានលើលក្ខខណ្ឌសាសនារបស់ពួកគេ ហើយការការពារសាសនានានា ត្រូវបានគាំទ្រដោយរដ្ឋធម្មនុញ្ញរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ជាការឆ្លើយតប គណៈតំបន់៥បានដាក់ចេញនូវ "វិធានការពិសេស" ដើម្បីកំណត់ពីខ្សែរយៈ និងអ្នកដឹកនាំរបស់ជនជាតិចាម "ដើម្បីបោសសម្អាតពួកគេឱ្យអស់"។ គណៈតំបន់៥បានរាយការណ៍សកម្មភាពរបស់ខ្លួនជូនទៅមជ្ឈិមបក្ស។

## គោលបំណងកម្ទេចជនជាតិចាម

៧៧៤- ដូចបានពិភាក្សាខាងលើរួចមកហើយគឺថា តាមរយៈភស្តុតាងខាងក្រោមបានបង្កើតជាករណីដែលថា ផែនការសម្លាប់រង្គាលជាទ្រង់ទ្រាយធំដល់សហគមចាម នៅស្រុកកងមាស និងស្រុកក្រូចឆ្មារ ត្រូវបានរៀបចំឡើងដោយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា និងមានចេតនាកំទេចទាំងស្រុងក្តី ឬមួយផ្នែកក្តី នូវជាតិពន្ធុចាម និងក្រុមសាសនានៅក្នុងតំបន់ទាំងនោះ៖

ក. ប៉ុល ពត បានប្រាប់កម្មាភិបាលបក្សថា ជនជាតិចាម និងក្រុមអំបូរជនជាតិភាគតិចផ្សេងទៀត នឹងត្រូវ"សម្លាប់ចោលទាំងអស់"។ ការសម្លាប់រង្គាលទាំងនោះ ចាប់ផ្តើមយ៉ាងយឺតៗ ប៉ុន្តែនៅឆ្នាំ១៩៧៨ ការសម្លាប់នេះ ក្លាយជា "ការសម្រុក" "យ៉ាងខ្លាំងក្លា" ទៅវិញ។

ខ. សមាជិកគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជារួមមាន កែ ពក ដែលជាលេខាភូមិភាគកណ្តាល បានដឹកនាំកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា នៅភូមិភាគកណ្តាល និងភូមិភាគបូព៌ា អនុវត្ត"ផែនការដែលដាក់ចេញដោយបក្ស" និង"កំទេចពួកចាម"។ មានអតីត

កម្មាភិបាលជាច្រើនបានផ្តល់សក្ខីកម្មថា ពួកគេបានដឹងពីគោលនយោបាយប្រឆាំងពួកចាម ឬអ្នកខ្លះទៀតបានឃើញផ្ទាល់នឹងភ្នែក នូវសកម្មភាពទាំងនេះផងដែរ។ [redacted]។

គ. មានសាក្សីនានាក៏បានបំភ្លឺទាក់ទងនឹងឯកសារបក្សកុម្មុយនីស្តកម្ពុជា ដែលយោងទៅដល់សេចក្តីសម្រេចក្នុងការកំទេចប្រជាជនចាម រួមទាំងលិខិតមួយច្បាប់ដែលមេដឹកនាំតំបន់២១ ផ្ញើមកមេបញ្ជាការអនុសេនាធំ និងប្រធានឃុំ ដោយបញ្ជាក់ថាត្រូវប្រមូលផ្តុំជនជាតិចាមទាំងអស់ ហើយមានឯកសារមួយទៀតដែលអះអាងថា "ជនជាតិចាមជាសត្រូវធំបំផុតដែលត្រូវតែកំទេចឲ្យអស់មុនឆ្នាំ១៩៨០"។

ឃ. ការសម្លាប់រង្គាលជនជាតិចាមជាទ្រង់ទ្រាយធំនៅស្រុកក្រូចឆ្មារ ត្រូវបានប្រព្រឹត្តឡើងដោយអង្គភាពអន្តរាគមន៍ពិសេសរបស់មជ្ឈិមបក្ស ក្រោមការបញ្ជារបស់ សុន សេន។ សុន សេន ដែលជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងជាអគ្គនសេនាធិការ ជាអ្នករាយការណ៍ទៅឲ្យ នួន ជា និងទៅសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងៗទៀត។ មានរបាយការណ៍មួយបានបញ្ជាក់ថា ជនជាតិចាមដែលមកពីស្រុកនោះ ត្រូវបានចាប់ខ្លួនដាក់លើទូក កាត់ក្បាល និងទម្លាក់ទៅក្នុងទន្លេមេគង្គ នៅចន្លោះស្រុកក្រូចឆ្មារ

និងស្រុកស្ទឹងត្រង់ ត្រូវបានផ្ញើមកមន្ទីរ៨៧០ ដោយ កែ ពក ដែលជាលេខាភូមិភាគកណ្តាល។

ង. ដូចបានកំណត់ខាងលើរួចមកហើយ ថាការសម្លាប់រង្គាលជាទ្រង់ទ្រាយធំដែលមានការរៀបចំត្រឹមត្រូវទៅលើសហគមន៍ជនជាតិចាមទាំងមូលកើតឡើងទាំង នៅភូមិភាគកណ្តាល និងភូមិភាគបូព៌ា ដោយបង្ហាញជាភ័ស្តុតាងថា ការសម្លាប់ទាំងនេះមិនមែនកើតឡើងដោយមិនមានការអនុញ្ញាត ឬដោយរើសមុខ ដែលប្រព្រឹត្តដោយកម្មាភិបាលមូលដ្ឋានដែលកាចសាហាវតែប៉ុណ្ណោះទេ។ ប៉ុន្តែ ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានរៀបចំ ក្រោមកិច្ចខិតខំដោយចេតនារបស់មជ្ឈិមបក្ស។

ច. តំបន់ដែលជ្រើសរើសដោយបក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើការសម្លាប់រង្គាល ជាទីតាំងសំខាន់របស់ប្រជាជនចាម នៅក្នុងប្រទេសកម្ពុជា គឺបណ្តាភូមិចាមដែលស្ថិតនៅតាមដងទន្លេមេគង្គ ក្នុងស្រុកក្រូចឆ្មារ និងស្រុកកងមាស ខេត្តកំពង់ចាម ដែលវាបានបង្ហាញពីចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបំផ្លាញក្រុមជនជាតិចាម។

ឆ. អំពើប្រល័យពូជសាសន៍ដែលបានពណ៌នាខាងលើ មិនមែនគ្រាន់តែជាការសម្លាប់តែមួយមុខនោះទេ តែជាការសម្លាប់រង្គាលទៅលើសហគមន៍ជនជាតិចាមទាំងមូល ដែលរៀបចំដោយលេខាស្រុកនៃបក្សកុម្មុយនីស្តកម្ពុជា ដែលទទួលខុសត្រូវក្នុងតំបន់ទាំងនោះ។ នៅស្រុកកងមាស រាល់ជនជាតិចាមគ្រប់រូបដែលមកពីភូមិចាមទាំងអស់ ត្រូវបាត់ខ្លួន ហើយត្រូវបានគេនាំយកទៅសម្លាប់ នៅមន្ទីរសន្តិសុខវត្តអូរត្រកួន។ ការចាប់ខ្លួនត្រូវបានបញ្ជាដោយ [redacted] និងបានកើតឡើង ក្រោយពេលមានការប្រជុំដែលបានរៀបចំដោយ

អនុលេខាភូមិភាគកណ្តាល ដែលនៅពេលនោះ ប្រធានកងនីមួយៗត្រូវបានគេបញ្ជាឲ្យប្រមូលផ្តុំប្រជាជនចាម ដើម្បីបញ្ជូនពួកគេទៅកាន់មូលដ្ឋានរបស់ខ្លួនវិញ។

ជ. នៅស្រុកក្រូចឆ្មារ សហគមន៍ចាមទាំងមូល ត្រូវបានបញ្ជូនតាមផ្លូវគោកទៅភូមិទ្រា ឬបញ្ជូនតាមទូកទៅស្ទឹងត្រង់ និងសម្លាប់រង្គាលជាទ្រង់ទ្រាយធំតែម្តង។ ពួកគេបានសួរ ថាតើជាជនជាតិខ្មែរ ឬចាម? ហើយចំពោះអ្នកដែលប្រាប់គេថា ខ្លួនជាជនជាតិចាមនោះ ត្រូវបានគេសម្លាប់ចោល ដោយគ្មានការវិនិច្ឆ័យអ្វីទាំងអស់។ អំពើប្រល័យពូជសាសន៍នេះត្រូវបានធ្វើឡើង ដោយកម្មាភិបាលទទួលបន្ទុកផ្នែកសន្តិសុខនៅថ្នាក់ស្រុកតែម្តង ដែលទទួលការបញ្ជាពី [redacted] និងអង្គភាពអន្តរាគមន៍ពិសេសមួយដែលបញ្ជាផ្ទាល់ពី សុន សេន។

ឈ. ជនជាតិចាមត្រូវបានចាប់ខ្លួនក្នុងអំឡុងឆ្នាំ១៩៧៧-៧៨ ដោយមិនខ្វល់ថា ពួកគេបានប្រព្រឹត្ត"កំហុស" ឬត្រូវបានឆ្លើយដាក់ដោយអ្នកផ្សេងណាម្នាក់ឡើយ ហើយពួកចាមត្រូវបានគេយកទៅសម្លាប់ភ្លាមៗ ឬបន្ទាប់ពីចាប់ខ្លួនបានមួយរយៈខ្លី ដោយគ្មានការឃុំឃាំង និងសួរចម្លើយអ្វីទាំងអស់។ ហេតុផលតែមួយគត់ ដែលកើតចេញពីហេតុការណ៍ទាំងនោះ គឺថាបក្សកុម្មុយនីស្តកម្ពុជាមិនត្រឹមតែស្វែងរកកម្ទេចជនជាតិចាមដែលជាប់សង្ស័យថាមានទំនាក់ទំនងទៅនឹងរបបសាធារណរដ្ឋខ្មែរ ឬអ្នកដែលស្ថិតក្នុងវណ្ណៈសក្តិភូមិ ឬមូលធន ឬអ្នកដែលជាភ្នាក់ងារសេអ៊ីអា កាហ្សេបេ ឬគិញយួន ប៉ុណ្ណោះទេ ថែមទាំងសម្លាប់ជនជាតិចាម<u>ទាំងអស់តែម្តង</u>។ ផ្ទុយទៅវិញ ជនជាតិចាមដែលត្រូវគេចាប់ខ្លួននៅឆ្នាំ១៩៧៥ បន្ទាប់ពីមានការបះបោរ នៅកោះផល ត្រូវបានគេសួរចម្លើយ ដើម្បីស្វែងរកបណ្តាញរបស់ពួកគេ។ សេចក្តីសម្រេចរបស់ ប.ក.ក ថាជនជាតិចាមទាំងអស់ជា "ខ្មាំង"ដែលត្រូវតែ

កំទេច គឺជាគោលនយោបាយមួយដែលមានការវិវត្តន៍តាមពេលវេលា ឆ្លើយតបទៅនឹងព្រឹត្តិការណ៍ នៅកោះផុលផង និងព្រឹត្តិការណ៍ផ្សេងៗទៀតផង។

ញ. បន្ថែមទៅលើការសម្លាប់នៅក្នុងភូមិចាមទាំងមូល បក្សកុម្មុយនីស្តកម្ពុជាបានលុបបំបាត់វប្បធម៌ និង របៀបរស់នៅរបស់ជនជាតិចាមទៀតផង ដោយហាមឃាត់មិនឲ្យពួកគេប្រើភាសា និងឈ្មោះជាប្រពៃណីរបស់ខ្លួន និងបានបំផ្លាញចោលនូវគម្ពីរកូរ៉ាន និងវិហារអ៊ីស្លាមថែមទៀត។

ដ. គោលនយោបាយផ្សេងទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបង្កើតឡើងដោយមជ្ឈិមបក្ស មានគោលដៅជាសំខាន់ទៅលើប្រជាជនចាមតែម្តង រួមមាន ការហាមឃាត់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលមិនឲ្យមានសាសនាបែប "ប្រតិកិរិយា" ហើយនៅខែវិច្ឆិកា ឆ្នាំ១៩៧៥ មានការរៀបចំផែនការ "បំបែក" ជនជាតិចាម ដោយជម្លៀសដោយបង្ខំនូវ"ប្រជាជនអ៊ីស្លាម"ចំនួន៥០០០០នាក់យ៉ាងតិច ពីភូមិភាគបូព៌ា។ ផែនការនោះត្រូវបានបញ្ជាក់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ តាមរយៈទូរលេខដែលផ្ញើមកពីលេខាភូមិភាគបូព៌ា ទៅ ប៉ុល ពត ដោយចម្លងជូន នួន ជា ដែលយោងទៅដល់ "ការពិភាក្សា"ជាមុនជាមួយអង្គការ ដែលក្នុងនោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានផ្តល់ "ការណែនាំ" ថាជនជាតិចាមត្រូវតែដកចេញទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ "ដើម្បីបំបែកប្រជាជនអ៊ីស្លាម និងផ្តាច់ពួកគេ" ចេញពីផ្ទះសម្បែងរបស់ពួកគេ ដែលមានមូលដ្ឋាននៅតាមដងទន្លេមេគង្គ។ ទូរលេខនោះដែលយោងទៅដល់តម្រូវការចាំបាច់ ដើម្បី"ធ្វើឲ្យបរិយាកាសធូរស្រាល"នៅក្នុងភូមិចាម ដោយបង្ហាញថាការជម្លៀសដោយបង្ខំ ជាការ

ឆ្លើយតបដោយផ្ទាល់ទៅនឹងការបះបោរ នៅកោះផល ក្នុងស្រុកក្រូចឆ្មារ ដែលបានកើតឡើង កាលពីដើមខែនោះ។

## ការបំផ្លិចបំផ្លាញជនជាតិចាម

៧៧៥- លទ្ធផលចុងក្រោយ ការសម្លាប់រង្គាលទាំងនេះ គឺជាការលុបបំបាត់ចោលមួយផ្នែកធំនៃប្រជាជនចាមនៅខេត្តកំពង់ចាម។ ក្នុងចំណោមប្រជាជនចាមដែលរស់នៅភូមិទាំង៤ដែលគេស្គាល់ នៅក្នុងស្រុកកងមាស ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មានតែប្រជាជននៅក្នុងភូមិ២ប៉ុណ្ណោះដែលនៅរស់រានមានជីវិត។ ជនជាតិចាមដែលត្រូវបានជម្លៀសចេញពីភូមិទាំងនោះ ទៅតំបន់ផ្សេងទៀត តាំងពីដើមសម័យកម្ពុជាប្រជាធិបតេយ្យនោះ ក៏ត្រូវបានគេសម្លាប់ចោលផងដែរ។ នៅក្នុងភូមិមួយក្នុងចំណោមភូមិទាំង៤ គឺភូមិអន្ទង់សាលដែលគេស្គាល់ថាជាភូមិអង្គរបាន១ ដែលមានប្រជាជនចាមចំនួនជាង៦០០គ្រួសាររស់ នៅក្នុងឆ្នាំ១៩៧៥ មិនមានជនជាតិចាមណាម្នាក់នៅសល់ទេនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយមានតែចំនួន៣០គ្រួសារប៉ុណ្ណោះ ដែលវិលត្រឡប់មកវិញបន្ទាប់ពីរបបនោះដួលរលំទៅ។ នៅភូមិសាច់ស្រូ ក្នុងចំណោមគ្រួសារចាមចំនួន៤០០គ្រួសារ ដែលត្រូវបានឲ្យទៅរស់នៅទីនោះ មុនរបបខ្មែរក្រហម មានត្រឹមតែ៥០គ្រួសារប៉ុណ្ណោះដែលនៅរស់រួចជីវិត និងបានវិលត្រឡប់មកវិញ។ មានតែ២០គ្រួសារប៉ុណ្ណោះ ក្នុងចំណោមជនជាតិចំនួន២០០គ្រួសារនៅភូមិពង្រ ឃុំរកាគយ ដែលបានរស់រានមានជីវិត។ មានជនជាតិចាមរហូតដល់ចំនួន១០០០០នាក់ ត្រូវបានសម្លាប់នៅក្នុងមន្ទីរសន្តិសុខ វត្តអូរត្រកួនតែមួយ។

៧៧៦- នៅស្រុកក្រូចឆ្មារ មានជនជាតិចាមត្រឹមតែ១៨០នាក់ប៉ុណ្ណោះ ក្នុងចំណោមចំនួន១៨៦៤នាក់ ដែលរស់នៅភូមិកោះផល ក្នុងឆ្នាំ១៩៧៥ នៅរស់រានមានជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យ។ មានជនជាតិចាមត្រឹមតែ១២០គ្រួសារប៉ុណ្ណោះ ក្នុងចំណោមចំនួន១២៤០គ្រួសារនៅស្វាយឃ្លាំង នៅរស់រានមានជីវិត និងមានជនជាតិចាមត្រឹមតែ៥០០គ្រួសារប៉ុណ្ណោះ ក្នុងចំណោម១០០០ គ្រួសារនៅរស់ក្នុងភូមិទ្រា។

៧៧៧- ក្នុងចំណោមប្រជាជនចំនួនជាង១៥៨០០០នាក់ ដែលគេជឿថា ត្រូវបានសម្លាប់ នៅខេត្តកំពង់ចាម ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មានចំនួនប្រមាណ៧៤០០០នាក់(ជិត៥០%នៃអ្នកស្លាប់សរុប) ត្រូវបានរកឃើញអត្តសញ្ញាណថាជា "អំបូរជនជាតិភាគតិច"។

## ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម

### សេចក្តីផ្តើម

៧៧៨- ផ្នែកខាងក្រោមនេះ ពិនិត្យលើភស្តុតាងទាំងឡាយទាក់ទងនឹងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងក្រុមនៃជនជាតិវៀតណាមនៅកម្ពុជា (និងជាពិសេសនៅក្នុងខេត្តព្រៃវែងនិងស្វាយរៀង) រួមទាំងឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល និងឈ្លើយសឹកវៀតណាម ក្នុងបរិបទនៃការលុកលុយរបស់កងទ័ពបដិវត្តន៍កម្ពុជា ឬកងកម្លាំងកម្ពុជាប្រជាធិបតេយ្យទៅក្នុងវៀតណាម។

៧៧៩- សំណុំរឿង មានផ្ទុកនូវភស្តុតាងយ៉ាងច្រើនអំពីការបង្កើត និងការអនុវត្តន៍ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៧តមក ដើម្បីធ្វើឱ្យសាបសូន្យនៃអ្នកតាំងទីលំនៅជនជាតិវៀតណាមទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា។ គោលនយោបាយនេះ បានធ្វើឡើងបន្ទាប់ពីមានការនិរទេសដោយបង្ខំដ៏ធំមួយនៃជនជាតិវៀតណាមពីកម្ពុជា ដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជា និងអនុវត្តបន្ទាប់ពីពួកគេបានឡើងកាន់អំណាចភ្លាម។ ការនិរទេសដោយបង្ខំនេះ បង្កឱ្យមានការកាត់បន្ថយយ៉ាងគំហុកនៃប្រជាជនវៀតណាមក្នុងប្រទេសកម្ពុជា ពីចំនួនប្រមាណ២០០០០០នាក់ មកនៅត្រឹមប្រហែល២០០០០នាក់។ គោលនយោបាយលប់បំបាត់អ្នកតាំងទីនៅវៀតណាមនៅកម្ពុជាដែលនៅសេសសល់ បាននាំឱ្យមានការសម្លាប់រង្គាលនៃក្រុមជនជាតិនេះ នៅក្នុងប្រទេសកម្ពុជាក្នុងពេលដែលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានដកចេញពីអំណាច។ ឧក្រិដ្ឋកម្មនានាដែលបានកើតឡើងនៅខេត្តព្រៃវែង និងស្វាយរៀង ដែលធ្វើឡើងតាមគោលនយោបាយនេះ អនុវត្តតាមទ្រង់ទ្រាយដែលបានកើតឡើងនៅក្នុងផ្នែកផ្សេងទៀតនៃប្រទេស និងមានការពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាលលើជនស៊ីវិលវៀតណាម ដែលពួកគេត្រូវបានគេតាមដានរែកមុខដោយសារតែជាតិពន្ធុរបស់ពួកគេតែប៉ុណ្ណោះ។

៧៨០- ឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជា/កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអម្លុងពេលនៃការលុកលុយរបស់ពួកគេទៅក្នុងវៀតណាម ចាប់ពីឆ្នាំ១៩៧៥ តមកមានជាប់ពាក់ព័ន្ធនឹងការសម្លាប់ជនស៊ីវិល រួមមានទាំងស្ត្រី និងកុមារ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនជាច្រើន។ បន្ថែមលើនេះ ជនជាតិវៀតណាមរាប់រយនាក់

ដែលគេបានជួបប្រទះក្នុងពេលនៃការលុកលុយនេះ រួមទាំងឈ្លើយសឹក និងជនស៊ីវិល ត្រូវបាន គេផ្ទេរមកកាន់មន្ទីរស-២១ ជាទីដែលពួកគេត្រូវបានគេដាក់ឱ្យជាប់ក្នុងមន្ទីរឃុំឃាំង ធ្វើទារុណកម្មដើម្បីទាញយកចម្លើយសារភាពចំពោះអំពើឧក្រិដ្ឋប្រឆាំងនឹងរបបនៃបក្សកុម្មុយនីស្តកម្ពុជា និងសម្លាប់ចោល ។

## ឧប្បត្តិដ្ឋាននៃក្រុមជនជាតិវៀតណាមនៅកម្ពុជា

៧៨១- ជនជាតិវៀតណាម បានបង្ហាញខ្លួនលើកដំបូងជាក្រុមជាតិពន្ធុមួយនៅក្នុងខេត្តខាងទុង និងដែនដីសណ្តរទន្លេក្រហម (Red River Delta) នៃប្រទេសចិនភាគខាងត្បូង រាប់ពាន់ឆ្នាំមក ហើយ។ បន្ទាប់ពីទទួលបានស្វ័យភាពមួយសតវត្សរ៍ នៅក្រោមរាជាណាចក្រវៀតណាម ដំបូង (ណាមវៀត ដែលបានលេចមុខប្រហែលក្នុងឆ្នាំ២០៨ មុន គ.ស) ជនជាតិវៀតណាម ត្រូវបានត្រួតត្រាដោយរាជវង្សហាននៃប្រទេសចិន អស់រយៈពេលមួយពាន់ឆ្នាំ។ ក្នុងឆ្នាំ៩៣៩ ក្រោយ គ.ស ទើបពួកគេរកបានសន្តតិវង្សឯករាជ្យមួយដោយទទួលបាន ឯករាជ្យពេញបរិបូរណ៍ពីចិន ក្នុងឆ្នាំ១៤២៧ និងបន្ទាប់មកក៏រក្សាបានអធិបតេយ្យភាពរបស់ខ្លួន រហូតដល់បារាំងច្បាំងដណ្តើមយកនៅពាក់កណ្តាលឆ្នាំ១៨០០។

៧៨២- ជនជាតិវៀតណាម បានបន្តពង្រីកអាណាចក្ររបស់ពួកគេជារហូតរៀងមក មកកាន់ភាគខាងត្បូងនៃទឹកដីដែលគេឱ្យឈ្មោះថា ជ្រោយឥណ្ឌូចិន ដោយការចាប់យកត្រួតត្រាតំបន់ថ្មីៗ ដោយចាប់ផ្តើមក្នុងសតវត្សរ៍ទី១៥។ តំបន់ទាំងនេះហ៊ុំព័ទ្ធតំបន់ភាគកណ្តាលវៀតណាមបច្ចុប្បន្ន (ពីមុនជាផ្នែកនៃរាជាណាចក្រចំប៉ា) និងចម្រៀកទឹកដីដ៏ធំដែលបានបង្កើតជាផ្នែកនៃអាណាចក្រខ្មែរចាប់ពីសតវត្សរ៍ទី១៧មក។ អាណាចក្រខ្មែរ រួមមាន តំបន់ដែនដីសណ្តរទន្លេមេគង្គនៅ

វៀតណាមខាងត្បូងសព្វថ្ងៃ (ជាស្រុកកំណើតនៃជនជាតិដើមខ្មែរកំពុងរស់នៅដែលគេស្គាល់ថា ខ្មែរក្រោម) រួមទាំងព្រៃនគរ (ទីក្រុងហូជីមិញ/សៃហ្គន)។ ការពង្រីកទឹកដីនេះ បានកើតឡើងព្រមគ្នាជាមួយនឹងចលនាមួយនៃអាណានិគមជនវៀតណាមទៅក្នុងតំបន់នេះ។

៧៨៣- ការមកដល់កម្ពុជានៃជនជាតិវៀតណាម គឺវាប្រទាក់ក្រឡាគ្នាជាមួយនឹងពេលវេលានៃការគ្រប់គ្រងប្រទេសទាំងដោយវៀតណាម និងបារាំងក្នុងសតវត្សរ៍ទី១៩។ នៅពាក់កណ្ដាលសតវត្សរ៍ទី១៩ដំបូង ជនជាតិវៀតណាមនៅតែបន្តមានវត្តមាននៅក្នុងប្រទេសកម្ពុជា ក្នុងពេលដែលមានការអនុវត្តអនុក្រិត្យសំខាន់មួយក្នុងការត្រួតត្រាមកលើព្រះមហាក្សត្រខ្មែរ។ កម្មវិធីប៉ុនប៉ងធ្វើវៀតណាមូបនីយកម្មមកលើកម្ពុជា ដែលបានបង្កើតឡើងដោយអធិរាជមីងម៉ាំង (Minh Mang) នៅក្នុងសម័យកាលនាឆ្នាំ១៨៣៤ ទៅ១៨៤០ បានបង្កឲ្យមានការធ្វើអាណានិគម មកក្នុងប្រទេសបន្តទៀត តាមរយៈជនអន្តោប្រវេសន៍វៀតណាម។

៧៨៤- បារាំង បានបង្កើតនូវអាណាព្យាបាលមួយ នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ១៨៦៣។ រដ្ឋបាលតាមបែបអាណានិគមថ្មីនេះ រើសអើងប្រឆាំងនឹងប្រជាជនខ្មែរដើម តាមរយៈការផ្ដល់រង្វាន់លើកទឹកចិត្តផ្នែកសេដ្ឋកិច្ច និងការងារ រួមទាំងការការពារតាមផ្លូវច្បាប់ផង ទៅឲ្យជនជាតិវៀតណាម ដោយជឿថាជនជាតិវៀតណាមមានជំនាញបច្ចេកទេសជាង។ ការណ៍នេះបានបង្កើនដល់កំពូលនៃការហូរចូលនៃជនជាតិវៀតណាមបន្ថែមទៀតកាន់កម្ពុជា ដើម្បីបំពេញមុខនាទីក្នុងរដ្ឋបាលអាណានិគម និងផ្ដល់កម្លាំងពលកម្ម។

ជនជាតិវៀតណាម ជាក្រុមជាតិ/ជាតិពន្ធុដាច់ដោយឡែកមួយនៅកម្ពុជា

៧៨៥- ជនជាតិវៀតណាម ជាក្រុមជាតិពន្ធុដាច់ដោយឡែកមួយនៅកម្ពុជា ខុសគ្នាពីក្រុមដទៃទៀត តាមលក្ខណការ ដូចជា ភិនភាគនៃរូបរាងកាយ ភាសា និងទំនៀមទម្លាប់ ។ ជនជាតិនេះ មានពណ៌សម្បុរសជាង និងមានភិនភាគ និងទ្រង់ទ្រាយនៃផ្ទៃមុខ និងដងខ្លួនខុសគ្នាពីជនជាតិខ្មែរ។ ទម្រង់វប្បធម៌ខុសៗគ្នារបស់ពួកគេ រួមមានភាសាវៀតណាម មរតកប្រវត្តិសាស្ត្រនិងជំនឿ (ពុទ្ធសាសនាមហាយាន្ត) ខុសគ្នាពីជនជាតិខ្មែរ ព្រមទាំងសម្លៀកបំពាក់ប្រពៃណី និងម្ហូបអាហារខុសគ្នា។ ក្រុមជនជាតិវៀតណាមភាគច្រើននៅកម្ពុជា ប្រមូលផ្តុំតាមភូមិសាស្ត្រ ជាពិសេសតាមបណ្តាភូមិអណ្តែតទឹកនៅជុំវិញបឹងទន្លេសាប និងនៅតាមតំបន់ជាប់ព្រំដែនវៀតណាម ដូចជា ព្រៃវែង និងស្វាយរៀង។ នៅតាមបណ្តាភូមិនានាភាគច្រើនដែលមានប្រជាជនវៀតណាមច្រើនគួរសម នៅតែមានសាលារៀនវៀតណាមដាច់ដោយឡែកដោយមានបុគ្គលិកជាគ្រូបង្រៀននិយាយភាសាវៀតណាម។ ជាចុងក្រោយ ចាប់ពីការ មកដល់ពីដើមដំបូងរបស់ពួកគេមកកាន់ប្រទេសនេះ និងរហូតមកដល់បច្ចុប្បន្ននេះ សហគមន៍វៀតណាម បានកំណត់អត្តសញ្ញាណខ្លួនឯងថាជាតិពន្ធុខុសពីគេនៅក្នុងប្រទេសកម្ពុជា និងបានទទួលស្គាល់យ៉ាងដូច្នេះដោយសង្គមខ្មែរដ៏លើសលុប។

៧៨៦- ខណៈគេគ្មានតួរលេខពិតប្រាកដអំពីទំហំនៃជនជាតិភាគតិចនៅក្នុងប្រទេសនេះ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ក៏ដោយ ក៏ប្រជាជនវៀតណាមឆ្នាំ១៩៧០ ត្រូវបានគេប៉ាន់ប្រមាណថា មានប្រហែល៤០០០០០ ទៅ៤៥០០០០នាក់។ រដ្ឋាភិបាលសាធារណៈរដ្ឋខ្មែរដែលមើល ឃើញជនជាតិវៀតណាម របស់កម្ពុជា ថាជាការគំរាមកំហែងខាងផ្នែកសន្តិសុខនោះ បាន សម្លាប់រង្គាល

"ជាច្រើនពាន់នាក់" និងនិរទេសប្រហែល២០០០០០នាក់។ ជនជាតិ វៀតណាមចំនួន ៣៤០០០នាក់បន្ថែមទៀត បានទៅបោះទីលំនៅថ្មីក្នុងប្រទេសថៃឡង់ដ៏ក្នុង អម្លុងពេលនេះ។ នៅក្នុងខែឧសភា ឆ្នាំ១៩៧៥ គឺនៅក្នុងអម្លុងពេលមួយខែនៃកា រកាន់អំណាច មេដឹកនាំបក្ស កុម្មុនីស្តកម្ពុជាបានបង្កើតគោលនយោបាយស្រដៀងគ្នាមួយ ដោយបញ្ជាឲ្យនិរទេសអ្នកស្រុក វៀតណាម ដែលជាលទ្ធផលជនជាតិវៀតណាមប្រហែល ១៥០០០០នាក់ ត្រូវបាននិរទេស ទៅវៀតណាមត្រឹមខែកញ្ញា ឆ្នាំ១៩៧៥។

៧៨៧- នៅក្នុងខេត្តកំពង់ឆ្នាំង នៅក្នុងពេលប្រហែលជានៅខែមេសា ឆ្នាំ១៩៧៥ អាជ្ញាធរយោធា បានធ្វើបំលាស់ទីជាតិពន្ធុវៀតណាមដែលរស់នៅក្នុងទីក្រុង និងនៅតាមភូមិនានានៅជុំវិញ ដងទន្លេសាបឲ្យទៅតាំងទីលំនៅថ្មីនៅតាមឃុំនានា នៅក្នុងស្រុកកំពង់លែងដែលរួមមាន៖ ឃុំព្រៃគ្រី ពាមឆ្កក(Pean Chhkauk) កំពង់ហាវ(Kompong Haov) ប្រឡាយមាស(Brolay Meas) ផ្លូវទូក(Phlov Tuouk) ត្រងិល(Tro Ngel)ស្វាយរំពារ(Svay Rompear) ដុះដាល(Dos Darl) ដារ(Dar) ច្រនុក(Chranouk) សំរោងសែន(Sam Rong Sen) និងឃុំពូ(Pou)។

៧៨៨- បន្ទាប់មក ចាប់តាំងពីខែមិថុនា ដល់ខែកញ្ញា ឆ្នាំ១៩៧៥ មានក្រុមជាតិពន្ធុវៀតណាមជាច្រើន ពាន់នាក់ ដែលពីដំបូងត្រូវបានជម្លៀសឲ្យទៅកាន់ឃុំនានាក្នុងស្រុកកំពង់លែង ត្រូវបានបញ្ជូន ទៅកាន់ប្រទេសវៀតណាម។ ការជម្លៀសដំបូងដែលមានជនជាតិវៀតណាមចំនួន៤០០គ្រួសារ បានកើតឡើងនៅម្តុំពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៧៥។ ការបញ្ជូនទៅស្រុក កំណើតវិញជា បន្តបន្ទាប់មកទៀត បានកើតឡើងបន្ទាប់ពីការចរចាររវាង បកក និងអាជ្ញាធរ សាធារណរដ្ឋ

សង្គមនិយមវៀតណាម ដែលមានការប្តូរក្រុមជាតិពន្ធុវៀតណាម ជាមួយនឹង អំបិល និងអង្ករ។ នៅក្នុងកាលៈទេសៈមួយចំនួន មន្ត្រីផ្លូវការវៀតណាមបាន ផ្តល់អង្ករចំនួន២០គីឡូក្រាម និងអំបិលចំនួន២០គីឡូក្រាមជូនទៅ បកក សម្រាប់ជន ជាតិពន្ធុវៀតណាមម្នាក់ៗ ដែលបានចេញពីប្រទេសកម្ពុជា។ នៅភូមិជ្រលង ឃុំដារ មាន ការតស៊ូរបស់ជនជាតិវៀតណាមមួយចំនួន មិនចង់ឱ្យគេបញ្ជូនវិលត្រឡប់ទៅកាន់ ប្រទេស វៀតណាមវិញ បានចេញលទ្ធផលជាការសម្លាប់ក្នុងចំនួនជាច្រើននៃក្រុមជាតិពន្ធុវៀតណាម ពី២០០-៣០០គ្រួសារ។

៧៨៩- មានជនជាតិវៀតណាមតិចបំផុតនៅសល់ក្នុងខេត្តកំពង់ឆ្នាំង ដែលភាគច្រើនគឺជាប្រជាជនដែល បានរៀបការចម្រុះគ្នារវាងខ្មែរ និងវៀតណាម។ អ្នកដែលនៅសល់ក្នុងខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំ១៩៧៦ ត្រូវបានដាក់ឱ្យស្ថិតក្រោមគោលនយោបាយអាពាហ៍ពិពាហ៍ចម្រុះ ដែលជាគំរោង ធ្វើឡើងដើម្បី "លប់បំបាត់ឬសគុលវៀតណាម ចេញពីប្រជាជនកម្ពុជា"។ នៅក្រោម គោលនយោបាយនេះសហព័ទ្ធខ្មែរ នៅក្នុងអាពាហ៍ពិពាហ៍ចម្រុះនេះ ត្រូវបានគេបញ្ជាឱ្យសម្លាប់ ប្តី ឬប្រពន្ធរបស់ខ្លួនដែលជាជនជាតិវៀតណាម និងកូនដែលបានចាប់ កំណើតពីអាពាហ៍ពិពាហ៍ នេះ ឬប្រឈមមុខនឹងការស្លាប់នៃសមាជិកគ្រួសារទាំងមូល របស់ខ្លួន។

៧៩០- ចំនួនជនជាតិវៀតណាមសរុប ដែលបាននិរទេសក្នុងសម័យកាលនៃការកាន់អំណាចរបស់បក្ស កុម្មុយនីស្តកម្ពុជា ត្រូវបានគេប៉ាន់ប្រមាណថា ប្រហែល១៥០០០០ ទៅ២០០០០០នាក់។ ខណៈដែលទិន្នន័យប្រជាសាស្ត្រច្បាស់លាស់អំពីចំនួនប្រជាជនវៀតណាមនៅសល់នៅកម្ពុជា មិនអាចឱ្យគេរកបានក៏ដោយការប៉ាន់ស្មានដ៏ល្អបំផុត អំពីទំហំនៃក្រុមនេះនៅត្រីមាសចុងក្រោយ

នៃឆ្នាំ១៩៧៥ គឺមានចំនួន២០០០០នាក់ ដែលភាគច្រើនបំផុតនៃពួកគេត្រូវបានបក្សកុម្មុយនីស្តកម្ពុជាសម្លាប់ចោលត្រឹមឆ្នាំ១៩៧៩ ។

## គោលនយោបាយសម្លាប់រង្គាលលើជនជាតិវៀតណាមរបស់បក្សកុម្មុយនីស្តកម្ពុជា

៧៩១- គោលនយោបាយសម្លាប់រង្គាលលើជនជាតិវៀតណាមនៅកម្ពុជា បានវិវត្តពីការភ័យខ្លាចដ៏តឹងតែងអំពីការត្រួតត្រារបស់វៀតណាមមកលើកម្ពុជារបស់របបនេះ និងទស្សនៈនៃជាតិពន្ធុនិយមរបស់ខ្លួនចំពោះប្រជាជនវៀតណាមជារួម ដូចរៀបរាប់ខាងក្រោមនេះ។

៧៩២- មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានផ្តល់អំណះអំណាងថា ការពង្រីកអតីតអាណាចក្រវៀតណាម ការត្រួតត្រារបស់វៀតណាមមកលើកម្ពុជាក្នុងសតវត្សរ៍ទី១៩ និងគោលនយោបាយនានារបស់បក្សកុម្មុយនីស្តវៀតណាមនៅក្នុងសតវត្សរ៍ទី២០ ទាំងអស់នេះសុទ្ធតែបានបង្ហាញទ្រង់ទ្រាយស៊ីសង្វាក់គ្នាមួយរបស់ពួកពង្រីកទឹកដី ដែលធ្វើឡើងនៅខាងផ្នែកវៀតណាម ផ្តោះតម្រង់មករកកម្ពុជា។ បក្សកុម្មុយនីស្តកម្ពុជាបានមើលឃើញថា ការបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន ដោយមានគោលនយោបាយមួយដើម្បីបង្កើតសហព័ន្ធឥណ្ឌូចិន ដើម្បីធ្វើជាយន្តការក្នុងការអនុវត្តន៍គោលដៅដែលមានអាយុរាប់សតវត្សរ៍របស់វៀតណាម ស្តីពីការត្រួតត្រាទាំងស្រុងមកលើតំបន់ និងការដាក់ប្រជាជននៃតំបន់នេះឲ្យនៅក្រោមអំណាចរបស់ខ្លួន (រួមទាំងពូជសាសន៍ខ្មែរ)។ ទស្សនៈដ៏សំខាន់មួយនៃផែនការដែលគេបានសន្មតឡើងនេះ ដោយសារវាទាក់ទងនឹងកម្ពុជា ធ្វើឲ្យមានកំណើនយ៉ាងគំហុកនៃអ្នកបោះទីលំនៅវៀតណាមនៅក្នុងប្រទេសនេះ។ យោងតាមបក្សកុម្មុយនីស្តកម្ពុជា ការណ៍នេះនាំឲ្យមានក្រុមជនជាតិ វៀតណាមឡើងដល់៩០ភាគរយ នៃប្រជាជនសរុបនៅក្នុងស្រុកពាមជ័រ ខេត្តព្រៃវែង។ ដោយបានលើក

យោងពីការប៉ុនប៉ងរបស់វៀតណាមក្នុងការដាក់ព្រងាយប្រជាជនតាមតំបន់ទន្លេមេគង្គ និង ទន្លេបាសាក់ ការបោះពុម្ពផ្សាយផ្លូវការនៃ *សៀវភៅខ្មៅ* របស់បក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ អះអាងថា "បើគ្មានវិធានការទប់ស្កាត់ទេ ម៉្លេះពួកវាបានបញ្ចូលស្រុងស្អាង និងកោះធំទាំងស្រុងទៅហើយ"។ ដូចកត់សំគាល់ពីខាងលើ បក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្ដើម ចាប់ខ្លួន និងនិរទេសវៀតណាមដែលរស់នៅក្នុងកម្ពុជាបន្ទាប់ពីពីបានកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥។ ត្រឹមឆ្នាំ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជាបានប្រកាសថា "មហាព្យុះសង្ឃរានៃបដិវត្តរបស់យើងបានបោសសម្អាតជនបរទេស រាប់រយពាន់នាក់... ឲ្យស្អាត និងបណ្ដេញចេញពីប្រទេសរបស់យើង ឲ្យអស់ពីប្រទេសជា អចិន្ត្រៃយ៍ជារៀងរហូត"។

៧៩៣- បក្សកុម្មុយនីស្តកម្ពុជាបានផ្ដល់អំណះអំណាងថា អត្ថិភាពតែមួយគត់នៃក្រុមជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា គឺជាការគំរាមកំហែងទៅលើការរស់រានមានជីវិតរបស់ប្រទេស និងពូជសាសន៍ខ្មែរ ដែលបក្សបានកំណត់ត្រូវឆ្លើយតបតាមរបៀបធ្ងន់ធ្ងរបំផុត។ ដោយមិនប្រើយុទ្ធវិធីនៃការធ្វើនិរទេសប្រជាជនវៀតណាម ដូចដែលពួកគេបានធ្វើតាំងពីដើមដំបូងនោះ ចាប់ពីឆ្នាំ១៩៧៧ តមក បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតគោលនយោបាយមួយធ្វើឡើងដើម្បីលុបបំបាត់ក្រុមនេះ នៅក្នុងប្រទេស។ ភស្តុតាងនៃដំណើរការតាមរុករក និងសម្លាប់ជនជាតិវៀតណាមនៅទូទាំងប្រទេសចាប់តាំងពីពេលនេះតមក បញ្ជាក់អះអាងអំពីការណាត់ខាងផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីកំទេចចោលទាំងស្រុងនៃជនជាតិនេះ ។

៧៩៤- ដើម្បីជាយុត្តិកម្មចំពោះគោលនយោបាយនានារបស់ខ្លួននិងធ្វើឲ្យពួកកម្មាភិបាលដាច់ខាត ដើម្បីប្រើប្រាស់ពួកគេក្នុងការអនុវត្តឧក្រិដ្ឋកម្មទាំងនេះ បក្សកុម្មុយនីស្តកម្ពុជាបានប្រឌិត និងធ្វើ

អាជីវកម្មនូវទេវកថាផ្សេងៗទាក់ទងនឹងវប្បធម៌ មនោទស្សន៍ពូជសាសន៍ និងការបង្ខូចកេរ្តិ៍មាន លក្ខណៈមើលងាយដែលជាប់ទាក់ទងទៅនឹងប្រជាជនវៀតណាម ដែលវាជាដំណើរការមួយ ដែលគេពិពណ៌នាថាជា"ការផលិតនូវភាពខុសគ្នា"។ ទេវកថា និងមនោទស្សន៍ខ្លះ បានចាក់ឫស នៅក្នុងភាពអយុត្តិធម៌ជាប្រវត្តិសាស្ត្រជាក់ស្តែង ឬដែលអាចឲ្យគេដឹងបានដូចជាការធ្វើបាបមក លើប្រជាជនខ្មែរ និងការដាក់អ្នកកាន់អំណាចខ្មែរឲ្យនៅក្រោមអំណាចរបស់វៀតណាម ឧទ្ទាមកម្មខ្មែរប្រឆាំងនឹងប្រជាជនវៀតណាម ការប៉ុនប៉ងដោយជោគជ័យរបស់អធិរាជមីងម៉ាំង ដើម្បីធ្វើវៀតណាមូបនីយកម្មមកលើកម្ពុជាជាដើម (ដែលក្រៅអំពីការធ្វើ អាណានិគមមកលើកម្ពុជាជាមួយនឹងប្រជាជនវៀតណាម ក៏ខំស្វែងរកធ្វើយ៉ាងណាឲ្យ ពូជសាសន៍ខ្មែរ "មានភាពស៊ីវីល័យ" និងតម្រូវឲ្យពលរដ្ឋកម្ពុជាសម្របខ្លួនទៅតាមបែប ផែនសង្គម នយោបាយ និងវប្បធម៌របស់វៀតណាម)។

៧៩៥- បក្សកុម្មុយនីស្តកម្ពុជា បានដាក់ឲ្យទទួលយកនូវទស្សនៈយល់ឃើញអំពីពូជសាសន៍ខ្មែរថាជា បញ្ហាដ៏ខ្ពង់ខ្ពស់ឧត្តុងឧត្តមទៅលើជនជាតិវៀតណាម និងការមើលខុសត្រូវលើការសម្លាប់រង្គាល ជនជាតិវៀតណាមនៅកម្ពុជាថាជា ទម្រង់មួយនៃការធ្វើបន្សុទ្ធកម្មពូជសាសន៍។ ដូចបាន លើកយកមកពិភាក្សានៅខាងក្រោម *នៅក្នុងចំណោមសកម្មភាពផ្សេងៗទៀត* ការណ៍នេះតម្រូវ ឲ្យមានការសម្លាប់សមាជិកនៃក្រុមគ្រួសារចម្រុះនៃជនជាតិវៀតណាម។ ដោយសារបំណង ហួសហេតុក្នុងការកំទេចស្លាកស្នាមនៃដានជាតិពន្ធុវៀតណាមនៅកម្ពុជា របបនេះក៏ដាក់ចំណុច ដៅសូម្បីតែសមាជិកនៃក្រុមខ្មែរកម្ពុជាក្រោមក៏ដោយ ដោយសារតែការជាប់ពាក់ព័ន្ធរបស់ពួក គេជាមួយនឹងវៀតណាម ។

៧៩៦- មេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា ក៏ស្វែងរកផងដែរដើម្បីធ្វើឲ្យប្រជាជនវៀតណាម បាត់បង់ភាពជាមនុស្សដោយលាបពណ៌ពួកគេថាជា "អ្នកផ្សេង"ដ៏អាក្រក់កំណាចឃោរឃៅ និងលើកទឹកចិត្តឲ្យមានការស្អប់ខ្ពើមខ្លាំងចំពោះពួកគេ។ ដោយការប្រើពាក្យបង្ខូចកេរ្តិ៍ស្រដៀង គ្នានឹងពួកណាស៊ីអាល្លឺម៉ង់ ដែលបានប្រើជាយុត្តិកម្មសំដៅទៅលើជនជាតិជ្វីព បក្សកុម្មុយនីស្តកម្ពុជាបានធ្វើផ្ទុយពីបដិវត្តន៍ខ្មែរបរិសុទ្ធ ដោយពាក្យថាវៀតណាមវៀចវេរ ធ្វើឲ្យខកចិត្ត និងទុយ៌ស។ គេបានចោទក្រុមជាតិពន្ធុវៀតណាមថាបានចូលរួមក្នុងប្រភេទ នៃអំពើ ហិង្សាផ្សេងៗ អំពើបោកបញ្ឆោត និងគ្មានសីលធម៌ផ្សេងៗទៀតប្រឆាំងនឹងប្រជាជនកម្ពុជា រួមមាន៖

ក. រំលោភសេពសន្ថវៈលើក្មេងស្រីកម្ពុជា ចាប់ខ្លួន និងសម្លាប់កម្មាភិបាលកុម្មុយនីស្តកម្ពុជានិងការប្រព្រឹត្តអំពើឃោរឃៅយ៉ុងឃ្នងធំៗជាច្រើនទៀតដូចជាដុតសម្លាប់ប្រជាជនកម្ពុជាទាំងរស់ជាដើម ។

ខ. លក់ក្មេងស្រីវៀតណាម ដើម្បីធ្វើឲ្យសម្រេចបានមហិច្ឆិតាទេសានុពន្ធរបស់ខ្លួន និងការបញ្ជូនមនុស្សរបស់ខ្លួនដើម្បីបានដីកម្ពុជា តាមរយៈអំពើពុករលួយ។

គ. អំពើឆក់ប្លន់ទំនិញ និងម្ហូបអាហារដែលជាកម្មសិទ្ធិរបស់ប្រជាជនកម្ពុជា។

ឃ. ការកសាងទ្រព្យសម្បត្តិរបស់ពួកគេលើដីកម្ពុជា និងចូលកាន់កាប់ដីកម្ពុជាបន្តិចម្តងៗ។

ង. ធ្វើខ្លួនជាចៅហ្វាយនាយ "ទោះបីជាអន់ជាងពួកអាណានិគមនិយមបារាំងក៏ដោយ" និង

ច. រៀបចំផែនការធ្វើឃាត និងប៉ុនប៉ងធ្វើរដ្ឋប្រហារប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។

៧៩៧- នៅក្នុងសេចក្ដីឆ្លើយឆ្លងផ្លូវការរបស់បក្សកុម្មុយនីស្ដកម្ពុជា ការអប់រំគោលនយោបាយចំពោះកម្មាភិបាលរបស់ខ្លួន និងនៅក្នុងសេចក្ដីថ្លែងការណ៍ផ្លូវការនៃរបបនេះចាប់ពីឆ្នាំ១៩៧៧មក ប្រជាជនវៀតណាមត្រូវបានគេនិយាយសំដៅថា "យួន" ដែលជាពាក្យប្រមាថដែលរបប នេះ អះអាងថា "គឺជាឈ្មោះដែលប្រជាជនកម្ពុជាផ្ដល់ឲ្យដល់ប្រជាជនវៀតណាម តាំងពី សម័យអង្គរ និងដែលមានន័យថា "សាហាវឃោរឃៅបំផុត""។ បក្សកុម្មុយនីស្ដកម្ពុជា បានពិពណ៌នាស្របគ្នានេះដែរចំពោះប្រជាជនវៀតណាមថា"អួតអាង ជាអ្នកឈ្លានពាន អ្នកទេសានុពន្ធនិយម អ្នកពង្រីកទឹកដី អ្នកស្រក់ទឹកមាត់ ចង់លេបទឹកដី ជាមនុស្ស "អកតញ្ញូអន់ជាងសត្វក្រពើទៅទៀត" និងជាជាតិមួយប្រឆាំងនឹងកម្ពុជា ដែល ប្រជាជនកម្ពុជាស្អប់ខ្ពើមយ៉ាងខ្លាំង ។

## ការអនុវត្តគោលនយោបាយចំពោះជនជាតិវៀតណាម

៧៩៨- នៅក្នុងការទាក់ទងគ្នាទៅមកផ្ទៃក្នុងរបស់ ប.ក.ក កំណត់ហេតុអង្គប្រជុំនានា ការឃោសនា និងឯកសារនានាជាផ្លូវការណ៍មានភស្តុតាងដែលស៊ីសង្វាក់គ្នាអំពីការបង្កើត និងការវិវឌ្ឍន៍នៃគោលនយោបាយដ៏ឧក្រិដ្ឋរបស់របបនេះ ដូចបានលើកឡើងខាងលើស្រាប់។ ដូចបានធ្វើការកត់សំគាល់រួចមកហើយនៅក្នុងសេចក្ដីផ្ដើម គឺគោលនយោបាយនេះត្រូវបានវិវឌ្ឍន៍ចាប់តាំងពីមានការបណ្ដេញជនជាតិវៀតណាមចេញម្ដងនៅក្នុងឆ្នាំ១៩៧៥ ដល់១៩៧៧ក្លាយទៅជាការសម្លាប់យ៉ាងរង្គាលក្នុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩។ លេខចេញផ្សាយខែមេសាឆ្នាំ១៩៧៧ *នៃទស្សនាវដ្ដីទង់បដិវត្ត* បានរំលេចឲ្យឃើញយ៉ាងច្បាស់អំពីការផ្លាស់ប្ដូរនេះ៖ដោយយោងទៅលើ "យួនលេបទឹកដី" មេដឹកនាំរបស់ ប.ក.ក បានប្រកាសជូនដំណឹងថា "ដាច់ខាតគឺ ត្រូវតែធ្វើឲ្យប្រជាជនភ្ញាក់រឭក (whip up) ធ្វើការការបោសសំអាតពួកវាឲ្យបាន

ស្អាតថែមទៀត និងធ្វើឲ្យអ្វីៗទាំងអស់បានស្អាតជាអចិន្ត្រៃយ៍”។ មកទល់ត្រឹមខែមេសា ឆ្នាំ១៩៧៨ ពួកមេដឹកនាំនានាកំពុងតែអួតអាងពីជោគជ័យជាច្រើននៃយុទ្ធនាការ៖ “ហើយឥឡូវនេះ តើយួនវាយ៉ាងម៉េចទៅហើយ? គ្មានយួននៅក្នុងទឹកដីកម្ពុជាទេ។ កាលពីមុនមានយួនជិត១០០០០០០នាក់។ បច្ចុប្បន្ននេះពួកវាគ្មានមួយគ្រាប់ទេ”។ ក៏ប៉ុន្តែ ការចាប់ខ្លួន និងសម្លាប់ជាទ្រង់ទ្រាយធំបានបន្ត ហើយពួកមេដឹកនាំនានាបានតាមដានពួកគេយ៉ាងដិតដល់: ឧទាហរណ៍ដូចជា មានរបាយការណ៍ប្រចាំខែមួយក្នុងខែសីហា ឆ្នាំ១៩៧៨ មកពីភូមិភាគបស្ចិម បានរាយការណ៍ថា៖ “បានកំទេចចោលជាតិពន្ធុយួនចំនួន១០០នាក់ ក្នុងនោះមានទាំងតូចទាំងធំ មនុស្សពេញវ័យ និងកុមារផង”។

៧៩៩- មានភស្តុតាងនៅក្នុងសំណុំរឿងអំពីស្ថិតិនៃជនជាតិវៀតណាមដែលមានទីលំនៅទាំងឡាយដែលត្រូវបានរៀបចំចងក្រងនៅថ្នាក់ភូមិនិងស្រុក និងអំពីរបាយការណ៍នានាស្តីពីការចាប់ខ្លួនជនជាតិវៀតណាមដែលកំពុងត្រូវបានរៀបចំធ្វើសម្រាប់ជូនទៅថ្នាក់លើ។ ឧទាហរណ៍ដូចជា អនុប្រធានភូមិម្នាក់នៅភូមិព្រៃនប់នៅក្នុងខេត្តព្រះសីហនុ (កំពង់សោម) ដែលជាអ្នកទទួលបន្ទុកចងធ្វើស្ថិតិ បានបញ្ជាក់ថា មានជនជាតិវៀតណាមប្រមាណជា ៣០គ្រួសារដែលរស់នៅក្នុងភូមិនេះ។ ស្ថិតិទាំងនេះត្រូវបានគេបញ្ជូនទៅឲ្យថ្នាក់ស្រុក ហើយនៅក្នុងឆ្នាំ១៩៧៧ ជនជាតិវៀតណាមដែលចុះនៅក្នុងស្ថិតិទាំងនេះត្រូវបានគេចាប់ខ្លួន និងសម្លាប់ចោលនៅឯមន្ទីរសន្តិសុខកោះខ្យង។ មានសាក្សីទីពីរម្នាក់មកពីកំពង់សោមបានបញ្ជាក់ថា ស្ថិតិនៃជនជាតិវៀតណាមដែលមានលំនៅដ្ឋានរស់នៅក្នុងតំបន់នេះត្រូវបាន ប.ក.ក រក្សាទុក និងប្រើប្រាស់សម្រាប់សំគាល់អត្តសញ្ញាណនិងដើម្បីចាប់ខ្លួនពួកគេ។

៨០០- ក្រៅពីបណ្ដាខេត្តដែលកំពុងស្ថិតក្រោមការស៊ើបសួរ (ព្រៃវែង និងស្វាយរៀង) នៅក្នុងសំណុំរឿងក៏មានផងដែរនូវភស្តុតាងផ្សេងៗ អំពីការចាប់ខ្លួននិងសម្លាប់ជនជាតិវៀតណាមនៅក្នុងខេត្តក្រចេះ បាត់ដំបង កំពង់ឆ្នាំង កំពត កំពង់ចាម កំពង់ធំ កណ្ដាល ពោធិសាត់ និង សៀមរាប។

៨០១- ការសម្លាប់ជាតិពន្ធុវៀតណាម នៅក្នុងខេត្តសៀមរាប មានលក្ខណៈទូលំទូលាយជាពិសេស។ ទីតាំងសម្រាប់ប្រហារជិវិតសំខាន់មួយនៅក្នុងឆ្នាំ១៩៧៨ គឺវត្តខ្សាច់ ក្នុងភូមិខ្សាច់ ឃុំសង្វើយ ស្រុកជីក្រែង។ ជនរងគ្រោះជនជាតិវៀតណាមទាំងឡាយត្រូវបានគេដឹកជញ្ជូនតាមរទេះគោពីភូមិដទៃទៀតទៅកាន់ទីតាំងនេះ ហើយត្រូវបានគេដាក់គុកនៅក្នុងសាលាឆាន់នៃវត្តនេះ ។ មុននឹងសម្លាប់ ពួកគេត្រូវបានពួកយោធាសួរថា តើពួកគេជា "យួន" ឬជា "ចិន?"។ [redacted] មានជាតិពន្ធុវៀតណាមចំនួនរវាងពី៦០០ ទៅ៧០០នាក់ ត្រូវបានគេសម្លាប់នៅវត្តខ្សាច់ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨។ មានពេលមួយនោះ មានជនជាតិវៀតណាមរវាងពី៧០ ទៅ៨០នាក់ ត្រូវបានគេសម្លាប់ក្នុងរយៈពេលមួយម៉ោងនៅទីតាំងនេះដោយយោធាដែលមានគ្នាពី ១០ ទៅ១២នាក់។ មានសាក្សីម្នាក់ទៀតបានឃើញគេសម្លាប់ជនជាតិវៀតណាមចំនួន១០០នាក់ នៅក្នុងពេល៣ ឬ៤លើកផ្សេងពីគ្នាដែលក្នុងនោះមានបុរស ស្ត្រី និងកុមារចំនួន២៥នាក់ ត្រូវបានគេសម្លាប់នៅពេលល្ងាចក្នុងអម្លុងពេល មួយម៉ោង។ មនុស្សពេញវ័យត្រូវបានគេវាយនឹងគល់ឬស្សីប្រវែងមួយម៉ែត្ររហូតដល់ស្លាប់ ចំណែកឯកុមារត្រូវបានគេគ្រវីហើយបោកផ្ទប់ទៅនឹងដើមដូងមួយដើម។ នៅក្នុងពេល សម្លាប់នោះ ជនរងគ្រោះត្រូវបានគេកាត់យកប្រម៉ាត់ចេញ ហើយព្យួរទុកឱ្យស្ងួត។ បន្ទាប់មក ជនរងគ្រោះ

ត្រូវគេបោះចូលទៅក្នុងរណ្តៅមួយដែលនៅជាប់នឹងវត្តខ្សាច់។ ទីតាំងប្រហារជីវិតជិតខាងមួយទៀត ស្ថិតនៅឯតំបន់អណ្តូងនួន (Tamban Andaung Nuon) ក្នុងភូមិចាក (Chak)។ ជាតិពន្ធុវៀតណាមក៏ត្រូវបានគេចាប់ខ្លួន និងសម្លាប់ផងដែរនៅការដ្ឋានទំនប់ព្រៃប្រស់។

៨០២- ភស្តុតាងអំពីការសម្លាប់នៅក្នុងខេត្តផ្សេងៗទៀត រួមមានដូចខាងក្រោមនេះ៖

១. ការសម្លាប់សមាជិកជនជាតិវៀតណាមប្រមាណជា២០នាក់ដែលជាសមាជិកនៃកងវរៈសម្រាប់ធ្វើការងារមួយនៅក្នុងខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៦។

២. ការសម្លាប់គ្រួសារជនជាតិវៀតណាមចំនួន ៣០គ្រួសារដែលរស់នៅក្នុងភូមិក្រពើខាងត្បូង ក្នុងខេត្តបាត់ដំបង។

៣. ការសម្លាប់ជនជាតិវៀតណាមចំនួន២៤នាក់នៅឯវត្តកណ្តាលក្នុងខេត្តបាត់ដំបង។

៤. ការសម្លាប់ជាតិពន្ធុវៀតណាមយ៉ាងច្រើននៅក្នុងខេត្តក្រចេះ ដែលក្នុងនោះមានគ្រួសារមួយដែលមានសមាជិក៣៧នាក់នៅឯមន្ទីរសន្តិសុខកោះស្រការ(Koh Srakar)។ និង

៥. ការប្រើអណ្តូងច្រោះនៅក្នុងខេត្តពោធិ៍សាត់ ធ្វើជាមណ្ឌលសម្រាប់ប្រហារជីវិតជនជាតិវៀតណាម។

៨០៣- ការវិវឌ្ឍន៍នៃគោលនយោបាយរបស់របបនេះ ចំពោះជនជាតិវៀតណាមក៏ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញផងដែរអំពីការបោសសំអាតផ្ទៃក្នុងនានារបស់កម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍ដូចជា ចាប់តាំងពីឆ្នាំ១៩៧៧មក មន្ទីរស-២១បានផ្លាស់ប្តូរចំណុចគោលដៅរបស់ខ្លួនបន្តិចម្តងៗចំពោះអ្នកដែលគេសន្មត់ថាជាគេញប្អូជាអ្នកចូលដៃជាមួយវៀតណាមដើម្បីឲ្យកម្មាភិបាលភាគ

ច្រើនដែលត្រូវបានគេធ្វើទារុណកម្ម ឬសួរចម្លើយនៅក្នុងមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៨ត្រូវបានចោទប្រកាន់ពីបទឃុបឃិតជាមួយវៀតណាម។

៨០៤- ជនជាតិវៀតណាម ក៏ជាក្រុមជាតិពន្ធុមិនមែនខ្មែរដ៏ធំជាងគេបង្អស់ក្នុងចំណោមជនរងគ្រោះនានានៃមន្ទីរស-២១ដែរ ដែលមានអ្នកទោសប្រមាណជា៣៤៥នាក់ត្រូវបានស្គាល់អត្តសញ្ញាណថាជាជនជាតិវៀតណាម។ សៀវភៅកត់ត្រារបស់ ម៉ម ណៃ អ្នកសួរចម្លើយរបស់មន្ទីរ ស-២១ ដែលមានជំនាញខាងធ្វើទារុណកម្ម និងសួរចម្លើយអ្នកទោសជនជាតិវៀតណាមបានរំលឹកឡើងវិញពីការចាំបាច់ត្រូវធ្វើការសួរចម្លើយ"ខ្លាំង"ជាលក្ខណៈប្រព័ន្ធ ដើម្បីរកឲ្យឃើញបុគ្គល ឬខ្សែបណ្ដាញរបស់វៀតណាមនៅក្នុងប្រទេស។

៨០៥- ដូចដែលបានរៀបរាប់មកហើយនៅក្នុងផ្នែកស្ដីពីការបោសសំអាតនៅក្នុងភូមិភាគបូព៌ា ដែលជាការបោសសំអាតមួយដ៏ធំសម្បើមនៃភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ ដែលនាំឲ្យមានការធ្វើឡើងនៅក្នុងកម្រិតដ៏ធំធេងដោយសារមានការសង្ស័យថា មេដឹកនាំ និងកម្មាភិបាលជាន់ខ្ពស់នានានៃភូមិភាគនេះបានចូលដៃ និងឃុបឃិតគ្នាជាមួយវៀតណាម។ កម្មាភិបាល និងប្រជាជននៃភូមិភាគបូព៌ាត្រូវបានគេពិពណ៌នាថាជាពួក "ក្បាលយួនខ្លួនខ្មែរ" ដែលនៅតាមការយល់ឃើញរបស់របបនេះ គឺពួកនេះត្រូវបានធ្វើយុត្តិកម្មដោយការសម្លាប់រង្គាល។

៨០៦- គោលនយោបាយរបស់ ប.ក.ក ក៏ត្រូវបានបញ្ជាក់ជាភស្តុតាងដោយសារការធ្វើបាបសហគមន៍ខ្មែរក្រោមនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលជាផ្នែកនៃតំបន់៧ នៃភូមភាគពាយ័ព្យ។ ភូមិមួយចំនួននៅក្នុងស្រុកបាកានមានខ្មែរក្រោមរស់នៅភាគច្រើន ដូចជាភូមិរំលេច (ដែលបន្ទាប់មកហៅថា ព្រៃឈើទាល) ដែលស្ថិតនៅក្នុងឃុំរំលេច និងភូមិបាក់មែក (Bak Mek Village)

(ដែលបន្ទាប់មកទៀតហៅថា សេះញ៉ូវ) នៅក្នុងឃុំខ្នារទទឹង។ ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ មានខ្មែរក្រោមជាច្រើនត្រូវបានគេចាប់ខ្លួននិងឃុំខ្លួននៅក្នុងមណ្ឌលសន្តិសុខនានាក្នុងតំបន់នេះ ដែលនៅទីនោះពួកគេត្រូវបានគេធ្វើទារុណកម្ម និងសួរចម្លើយថាតើពួកគេមានធ្លាប់ធ្វើជាគេញរបស់វៀតណាមដែរឬទេ? ហើយត្រូវគេសម្លាប់ចោល។ នៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ការសម្លាប់ខ្មែរក្រោម ជាទ្រង់ទ្រាយធំបានកើតឡើងនៅតាមទីតាំងនានាក្នុងឃុំរំលេចនិងខ្នារទទឹ ដែលរួមមានរណ្តៅនានានៅទួលសេះញ៉ូវ និងវាលពិឃាតព្រៃក្របៅ។ ការសម្លាប់ទាំងនេះត្រូវបានធ្វើឡើងក្រោមការត្រួតពិនិត្យ និងបញ្ជារបស់[redacted] បន្ទាប់ពី[redacted] និង[redacted] បាន "ធ្វើការណែនាំទៅប្រធានៗគ្រប់សហករណ៍ទាំងអស់នៅក្នុងស្រុកបាកានឱ្យស្រង់ឈ្មោះប្រជាជនខ្មែរកម្ពុជាក្រោម និង[ឱ្យយកពួកគេ] ទៅកាន់សហករណ៍ខ្នារទទឹង"។ ខ្មែរក្រោមនៅស្រុកបាកានត្រូវបាន ប.ក.ក ចោទថា ជាពួក "ក្បាលយួនខ្លួនខ្មែរ" ហើយត្រូវគេសម្លាប់ចោលពីព្រោះពួកគេមានជាប់ពាក់ព័ន្ធនិង "យួន"។

## ការសម្លាប់នៅព្រៃវែង និងស្វាយរៀង

៨០៧- ទោះបីជាមានភស្តុតាងប្រយោលសំខាន់ៗ អំពីការសម្លាប់ជនជាតិវៀតណាមជាប្រព័ន្ធនៅក្នុងខេត្តទាំងពីរនេះក៏ដូចជាផលប៉ះពាល់ដ៏ខ្មៅខ្មាំនៃគោលនយោបាយនោះចំពោះប្រជាជនក្តី ក៏នៅក្នុងកំរិតនៃមូលដ្ឋានឧក្រិដ្ឋកម្មក្នុងកិច្ចស៊ើបសួរ បានប្រមូលភស្តុតាងអំពីគ្រួសារចំនួន២០ ដែលបានទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីការការចាប់ខ្លួន ការបាត់ខ្លួន និងការ

សម្លាប់នៅក្នុងខេត្តព្រៃវែង។ ចំណែកឯនៅស្វាយរៀងវិញ មានភស្តុតាងដែលត្រូវគេប្រមូលបាន ស្តីពីគ្រួសារចម្រុះពូជសាសន៍ចំនួន៥គ្រួសារ ដែលមានឪពុកជាខ្មែរ និងម្តាយជាវៀតណាម (ឬក៏បញ្ច្រាស់មកវិញ) ដែលត្រូវបានគេចាប់ខ្លួន និងត្រូវបានគេនាំយកទៅ។

## ព្រៃវែង

៨០៨- នៅក្នុងឆ្នាំ១៩៧៥ និង១៩៧៦ ប្រជាជនដែលមានជីដូនជីតាជាវៀតណាមដែលរស់នៅក្នុងខេត្តព្រៃវែងត្រូវបានគេបង្ខំឲ្យជម្លៀសទៅប្រទេសវៀតណាម។ មកទល់ត្រឹមចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ ពួកអ្នកភូមិជនជាតិវៀតណាមដែលរួមមានស្ត្រី និងកុមារដែលមានខ្សែស្រឡាយជាវៀតណាមត្រូវបានគេចាប់ខ្លួន ប្រមូល ហើយនាំយកទៅសម្លាប់។

៨០៩- ការចាប់ខ្លួន និងសម្លាប់គ្រួសារជនជាតិវៀតណាមនៅព្រៃវែង ដែលបណ្តាលមកពីមូលហេតុជនរងគ្រោះត្រូវបានគេយល់ថាជាជនអន្តោប្រវេសន៍ ដូចគ្នានឹងករណីដែលនៅតាមបណ្តាខេត្តផ្សេងៗទៀត ដែលបានពិភាក្សាខាងលើដែរ។ ការអនុវត្តទាក់ទងនឹងការសម្លាប់គ្រួសារដែលចម្រុះសាសន៍នៅព្រៃវែង គឺរំលេចឲ្យឃើញពីរឿងនេះ៖ “[]បើសិនជាម្តាយជាវៀតណាម និងឪពុកជាខ្មែរនោះ គឺទាំងម្តាយទាំងកូនត្រូវគេយកទៅសម្លាប់ចោល។ ការលើកលែងគឺមានតែចំពោះឪពុកប៉ុណ្ណោះ។ បើសិនជាម្តាយជាខ្មែរ ហើយឪពុកជាវៀតណាមនោះ គឺគេយកតែឪពុកប៉ុណ្ណោះទៅសម្លាប់។ ការលើកលែងត្រូវបានធ្វើឡើងចំពោះម្តាយនិងកូន”។ ដូចដែលបានរៀបរាប់ខាងក្រោមគោលនយោបាយដូចគ្នានេះត្រូវបានគេអនុវត្តនៅស្វាយរៀង។ ជាថ្មីម្តងទៀត ការផ្តោតទៅលើគ្រួសារចម្រុះសាសន៍បានកើតមាននៅផ្នែកដទៃៗទៀតនៃប្រទេស៖ លេខាភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម បានសរសេរលិខិតផ្ញើជូនទៅមន្ទីរ៨៧០ ក្នុងខែឧសភា

ឆ្នាំ១៩៧៨ ស្វែងរកសុំការណែនាំរបស់អង្គការស្ដីពី "សមាសភាពយួនដែលមានប្ដីខ្មែរ សមាសភាពខ្មែរដែលមានប្រពន្ធយួន និងកូនដែលចម្រុះសាសន៍យួន"។

៨១០- ក្នុងករណីមួយនៅព្រៃវែងមានស្ដ្រីជាតិពន្ធុវៀតណាមម្នាក់មានផ្ទៃពោះ និងកូនៗរបស់គាត់ចំនួន ៦នាក់ ត្រូវបានគេយកចេញទៅតាមទូកមួយហើយត្រូវបានគេសម្លាប់ ចំណែកឯប្ដីជនជាតិខ្មែរត្រូវបានគេទុកជីវិតឲ្យ។ នេះគឺជាការស៊ីសង្វាក់គ្នាទៅនឹងការរៀបរាប់ផ្សេងៗទៀត អំពីរឿងការចាប់ខ្លួននិងសម្លាប់ស្ដ្រីនិងកុមារជនជាតិវៀតណាម ដែលរួមទាំងករណីនានាដែលក្នុងនោះរាល់សមាជិកភេទស្រីទាំងអស់នៃគ្រួសារដែលចម្រុះសាសន៍ និងកូនៗរបស់ពួកគេត្រូវបានចាប់ខ្លួន និងដឹកជញ្ជូនទៅកាន់វាលតូច (ស្រុកព្រៃវែង) ដែលនៅទីនោះគេជឿថា ពួកគេទាំងនោះត្រូវបានគេសម្លាប់ចោលអស់ហើយ។ មានករណីមួយចំនួន ក៏មានបុរសជាតិខ្មែរដែលបានរៀបការជាមួយស្ដ្រីវៀតណាមខ្លួនគេផ្ទាល់នោះ ក៏ត្រូវបានគេចាប់ខ្លួន និងឃុំខ្លួនផងដែរ។ ក្នុងសំណុំរឿងនេះ ក៏មានភស្តុតាងអំពីករណីរឿងជាច្រើនស្ដីពីការចាប់ខ្លួន និងបាត់ខ្លួនប្ដីៗ និងឪពុកដែលជាជាតិពន្ធុវៀតណាមដែរ។

៨១១- ឥទ្ធិពលនៃការចាប់ខ្លួន និងបាត់ខ្លួនទាំងនេះទៅលើបងប្អូនសាច់ញាតិជាខ្មែរនានា គឺបានឆ្លុះបញ្ចាំងឲ្យឃើញថានៅក្នុងចម្លើយនានាជាច្រើនដែលក្នុងនោះសាក្សីទាំងឡាយ បានរៀបរាប់អំពីការភ័យខ្លាចមិនហ៊ានសំដែងចេញឲ្យដឹងពីអារម្មណ៍ណាមួយ នៅពេលដែលសមាជិកគ្រួសាររបស់ពួកគេដែលមានដើមកំណើតជាជនជាតិវៀតណាមកំពុងត្រូវគេចាប់ខ្លួន និងត្រូវគេនាំយកទៅ។ មានករណីមួយ បុរសម្នាក់ដែលបានសំដែងការអាណិតអាសូរចំពោះក្មួយៗរបស់គាត់ ដែលត្រូវគេយកទៅព្រោះតែជីដូនជីតារបស់ពួកគេមានជាប់ខ្សែស្រឡាយជា

វៀតណាមខ្លះៗនោះ ក៏ត្រូវបានគេយកទៅឱ្យធ្វើការលត់ដំកែប្រែខ្លួន ហើយត្រូវបានគេណែនាំកុំឱ្យសំដែងការអាណិតអាសូរ។

៨១២- ការចាប់ខ្លួនទាំងនេះត្រូវបានធ្វើឡើងទៅតាមបញ្ជារបស់ថ្នាក់លើ និង"ត្រូវបានរាយការណ៍ពីថ្នាក់ក្រោមឡើងទៅលើ"។ កិច្ចការណ៍ទាំងនេះត្រូវបានអនុវត្តដោយពួកឈ្លបភូមិ ឬដោយ "មនុស្សដែលមកពីថ្នាក់លើ" ដែលធ្វើសហប្រតិបត្តិការជាមួយប្រធានភូមិនិងជាមួយគណៈកម្មាធិការស្រុកព្រៃវែង។ ដើម្បីធានាកុំឱ្យមានអ្នកភូមិណាម្នាក់ដែលត្រូវគេចោទថាជាជនជាតិវៀតណាមអាចលាក់ខ្លួនបាននោះ កម្មាភិបាលជាន់ខ្ពស់ត្រូវស្ថិតនៅ ក្នុងភូមិនានាក្នុងរយៈពេលដ៏យូរ។ សាក្សីមួយចំនួនក៏បាននិយាយផងដែរថា ការចាប់ខ្លួន ទាំងនោះត្រូវបានធ្វើឡើង បន្ទាប់ពីប្រជុំភូមិជាច្រើនលើក និងការចុះឈ្មោះនៅក្នុងបញ្ជី អនុប្រជាជនជនជាតិវៀតណាម។

៨១៣- ពួកអ្នកភូមិបានជឿថាអ្នកដែលជាជនជាតិវៀតណាមក៏ត្រូវបានគេយកចេញទៅដែរ ដោយសំអាងលេសថាកំពុងកាត់"វល្លិ៍ផ្តៅ" ឬ "ស្ទូងស្រូវ"។ ជាធម្មតាពួកគេត្រូវបានដឹកជញ្ជូនតាមទូកឬតាមរទេះសេះ ទៅកាន់វាលតូច ដែលជាវាលពិឃាតមួយស្ថិតនៅ ខាងត្បូងមន្ទីរសន្តិសុខនៅវត្ត អូរកណ្តាល (Wat Au Kandaol)។ វត្តអូរកណ្តាល ស្ថិតនៅចន្លោះភូមិអូរកណ្តាល និងភូមិ ត្រពាំងព្រីងក្នុងស្រុកព្រៃវែង។ វាលតូចស្ថិតនៅ ខាងត្បូងវត្តអូរកណ្តាលត្រូវបានគេប្រើធ្វើជា វាលពិឃាត។ សាក្សីមួយរូបបានបញ្ជាក់ថា មានសាកសពមនុស្សចំនួនជាង៩០០នាក់ ត្រូវបានគេគាស់ចេញពីរណ្តៅសពរួមនានានៅវាលតូចក្រោយឆ្នាំ១៩៧៩ ហើយត្រូវបានគេដាក់នៅខាងក្នុង "វត្តវាលតូច"។ ប៉ុន្តែនៅមិនទាន់ច្បាស់ថាតើជនរងគ្រោះទាំងអស់នោះជាជនជាតិវៀតណាមឬយ៉ាងណាទេ ដោយសាក្សី

នានា បានបញ្ជាក់ថា ជនរងគ្រោះទាំងនោះ ត្រូវបានគេយកចេញ ទៅដើម្បីសម្លាប់ចោល នៅវាលតូច "ដោយត្រូវបានគេចោទថាក្បត់ ថាជាទាហាននៃសាធារណរដ្ឋខ្មែរ ឬជាជនជាតិវៀតណាម"។

## ស្វាយរៀង

៨១៤- ប្រហែលជានៅក្នុងពេលជាមួយគ្នានឹងព្រឹត្តការណ៍នានា បានកើតឡើងនៅក្នុងខេត្តព្រៃវែង ជាតិពន្ធុវៀតណាមក៏កំពុងត្រូវបានគេចាប់ខ្លួន និងសម្លាប់នៅស្វាយរៀងដែរ។ [redacted] "ជាតិពន្ធុវៀតណាមណាដែលបានបដិសេធមិនព្រមទៅ ឬដែលបានបន្លំខ្លួនធ្វើជាជាតិពន្ធុខ្មែរត្រូវបានគេចាប់ខ្លួន យកចេញទៅ ហើយសម្លាប់ចោល"។ ដូចគ្នានឹងនៅព្រៃវែងដែរ គឺមានការប្រកាសជូនដំណឹងជាសាធារណៈមួយអំពីសារាចរណែនាំស្តីពីការសម្លាប់ប្តីៗជនជាតិវៀតណាម ឬប្រពន្ធៗជនជាតិវៀតណាម និងកូនដែលនៅក្នុងគ្រួសារចម្រុះសាសន៍។

## អំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងជម្លោះប្រដាប់អាវុធជាមួយវៀតណាម

## ការពិពណ៌នាជាទូទៅត្រួសៗអំពីឧក្រិដ្ឋកម្មនានា

៨១៥- ផ្នែកដែលស្តីពីជម្លោះប្រដាប់អាវុធនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ គឺពិនិត្យមើលទៅលើភស្តុតាង ដែលទាក់ទងទៅនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិមួយរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។ ផ្នែកដែលរៀបរាប់ដូចខាងក្រោមនេះ គឺទាក់ទងទៅនឹងភស្តុតាងដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្សេងៗ ដែលប្រឆាំងនឹង

ជនស៊ីវិល និងអ្នកទោសណ្ដើយសឹក ក៏ដូចជា ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដែលបានប្រព្រឹត្ត ដោយកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងអម្លុងពេលនៃការចូលលុកលុយរបស់ពួកគេ ទៅក្នុងទឹកដីវៀតណាម។

៨១៦- កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយប្រហារទៅលើកោះភូកុក (កោះត្រល់) ហើយតែក្នុងប៉ុន្មានថ្ងៃប៉ុណ្ណោះ ទៅលើកោះថ-ជូ (កោះ Poulou Panjang ឬកោះក្រចកសេះ) នៅក្នុងប្រទេសវៀតណាម។ នៅក្នុងពេលវាយប្រហារទៅលើកោះថ-ជូនោះ ពួកខ្មែរក្រហមបាន ជម្លៀសអ្នកស្រុកជនជាតិវៀតណាមចំនួនប្រាំរយនាក់ចេញដោយការប្រើចុងកាណុង។ ជនស៊ីវិលទាំងនេះមិនដែលឃើញត្រឡប់មកវិញទាល់តែសោះ។ ពួកទាហានខ្មែរក្រហម ក៏បានបំផ្លិចបំផ្លាញផ្ទះសំបែងផងដែរ ហើយបានសម្លាប់អ្នកស្រុកមួយចំនួននៅក្នុងអម្លុងពេលនៃការវាយប្រហារនេះ។

៨១៧- ចាប់ផ្ដើមពីខែមករា ឆ្នាំ១៩៧៧ និងពេញទាំងឆ្នាំ១៩៧៧ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានធ្វើការលុកលុយជាច្រើនលើកច្រើនសារចូលទៅក្នុងប្រទេសវៀតណាម ដែលនៅក្នុងអំឡុងពេលនោះ ពួកគេបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មជាច្រើនទៅលើពួកប្រជាជនស៊ីវិលវៀតណាម។ នៅក្នុងខែមេសា ឆ្នាំ១៩៧៧ កងកម្លាំងដែលមានចំនួនជាលំដាប់កងពលធំនៃកងទ័ពបដិវត្តកម្ពុជា ត្រូវបានបញ្ជូនទៅកាន់ទីក្រុងហាទៀង នៃខេត្តគៀងយ៉ាង និងទៅកាន់ទីក្រុងចូវដុក នៃខេត្តអានយ៉ាង ដែលនៅទីនោះពួកគេបានដុតផ្ទះសម្បែង និងបានសម្លាប់ប្រជាជនស៊ីវិល មួយចំនួនធំ។ នៅក្នុងខែ ឧសភា ឆ្នាំ១៩៧៧ ប្រជាជននៃទីក្រុងទាំងពីរនេះត្រូវបានជម្លៀស ចេញមួយរយៈពេលដែលជាវិធានការប្រុងប្រយ័ត្នមួយដើម្បីការពារសុវត្ថិភាព។ នៅក្នុង

សៀវភៅរបស់ខ្លួនដែលចេញផ្សាយ នៅឆ្នាំ២០០៧ ឈ្មោះ **ខៀវ សំផន** បានបញ្ជាក់អំពីភស្តុតាងពាក់ព័ន្ធទៅនឹងការវាយប្រហារទាំងនេះ ដោយបានថ្លែងថា "នៅថ្ងៃទី៣០ ខែមេសា កងកម្លាំងរបស់ខ្មែរក្រហមដែលត្រូវបានបានអមគាំទ្រដោយកងកាំភ្លើងធំ បានចូលទៅក្នុងទឹកដីវៀតណាម បានសម្លាប់ប្រជាជន និងបានកំទេចភូមិនានា យ៉ាងចាស់ដៃ"។ នៅក្នុង រយៈកាលនេះ កងទ័ពបដិវត្តកម្ពុជាបានធ្វើការវាយប្រហារទៅលើភូមិជាច្រើនផងដែរ នៅតាម បណ្តោយព្រំដែននៅចន្លោះពីទីក្រុងហាទៀង ទៅទីក្រុងចូវដុក ដោយ រួមទាំង ទិនបៀន (ខេត្តអានយ៉ាង) (Tinh Bien - An Giang province) ដែលមានប្រជាជនស៊ីវិល ចំនួនមួយរយនាក់ត្រូវបានសម្លាប់។

៨១៨- នៅមុនពាក់កណ្តាលឆ្នាំ១៩៧៧បន្តិច កងទ័ពកម្ពុជាប្រជាធិបតេយ្យបានសម្លាប់យ៉ាងរង្គាលទៅលើពួកប្រជាជនស៊ីវិលចំនួន២០០នាក់ ទាំងពួកវៀតណាមនិងទាំងពួកជាតិពន្ធុខ្មែរ ដែលនៅក្នុងភូមិព្រៃតាមាំង (Prey Tameang village)។ បន្ទាប់មក ពួកនោះបានវាយប្រហារទៅលើភូមិអាប់សាសេ (Ap Sase village) (ខេត្តគៀងយ៉ាង) ដែលនៅទីនោះពួកគេបានដុតផ្ទះ និងបានសម្លាប់មនុស្សដែលពុំអាចរត់គេចរួចប្រមាណជាម្ភៃនាក់។ កងទ័ពបដិវត្តកម្ពុជាបានធ្វើការវាយប្រហារជាបន្តទៀតនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ដោយបានសម្លាប់ប្រជាជនស៊ីវិលរាប់រយនាក់ នៅក្នុងខេត្តតាយនិញ។ កងកម្លាំងកម្ពុជាបានចល័តចេញពីកន្លែងនានា ដូចជាចេញពីទីតាំងការដ្ឋានអាកាសយានដ្ឋានខេត្តកំពង់ឆ្នាំង សំដៅចូលទៅក្នុងខេត្តតាយនិញ ដោយមានបញ្ជាឲ្យសម្លាប់ពួក វៀតណាមគ្រប់ៗរូបដែលពួកគេបានជួបទាំងទាហាន និងទាំងស៊ីវិល ។

៨១៩- ចាប់ពីខែមករា រហូតដល់ខែមីនា ឆ្នាំ១៩៧៨ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានបន្តធ្វើការជ្រៀតចូលទៅក្នុងប្រទេសវៀតណាម ដោយមានរបាយការណ៍ស្តីពីការវាយប្រហារទៅលើ ហាទៀង ណាស៊ីយ៉ា និង គីឡូ នៅក្នុងខេត្តកៀងយ៉ាង (Ha Tien Naxia and Kylo in Kien Giang province)។ នៅក្នុងខែមីនា ឆ្នាំ១៩៧៨ ភូមិព្រៃស្វាយដែលស្ថិតនៅតាមតំបន់ភ្នំបៃនើយ ក្នុងខេត្តអានយ៉ាង (Prey Svay village in the Bay Nui mountain region in An Giang province) ត្រូវបានដុតឆេះខ្ទេចខ្ទីដល់ដី ហើយមានតែប្រជាជនចំនួន៣០ភាគរយប៉ុណ្ណោះដែល បានរត់គេចចេញពីការជន្លៀសដោយបង្ខំឱ្យទៅកាន់កម្ពុជាប្រជាធិបតេយ្យ។ ព្រះសង្ឃព្រះពុទ្ធ សាសនាមកពីវត្តនានាចំនួនម្ភៃវត្តត្រូវបានចាប់ពង្រត់ និងត្រូវបានបង្ខំឱ្យសឹក។ មួយខែក្រោយមក កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានកាន់កាប់ភូមិស្វាយចេក ខេត្តអានយ៉ាង (Svay Chek village An Giang province) ហើយបានបង្ខំគ្រួសារខ្មែរចំនួន៣០០គ្រួសារដែលកំពុងរស់នៅក្នុងភូមិនោះឱ្យវិលត្រឡប់មកកម្ពុជាវិញ។ ការវាយប្រហារទៅលើតំបន់នានានៃប្រទេសវៀតណាម ដោយរួមទាំង ហាទៀង ក្នុងខេត្តកៀងយ៉ាង (Ha Tien in Kien Giang province) ហុងងូ ក្នុងខេត្តដុងថាប់ (Hong Ngu in Dong Thap province) ព្រមទាំងតំបន់ភ្នំចំនួនប្រាំពីរ កន្លែងទៀតនៅក្នុងខេត្តអានយ៉ាង ត្រូវបានប្រព្រឹត្តជាបន្តទៀត រហូតដល់ចុងឆ្នាំ១៩៧៨។

៨២០- ប្រជាជនស៊ីវិល និងទាហានវៀតណាមចំនួនរាប់រយនាក់ ត្រូវបានកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ចាប់បាននៅក្នុងអំឡុងពេលនៃការជ្រៀតចូលទាំងនេះ។ ពួកទាំងនោះត្រូវបានបញ្ជូនខ្លួនទៅកាន់មន្ទីរស-២១ ដើម្បីធ្វើការសួរចម្លើយ និងសម្លាប់ចោលដោយថាហេតុ

ដូចដែលបានពិភាក្សា រួចហើយនៅក្នុងផ្នែក មន្ទីរសន្តិសុខស-២១។ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដែលបានពិនិត្យឡើងវិញ បានបង្ហាញថា ស្របពេលនឹងការរីកកាន់តែខ្លាំងឡើងនៃជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ពួកឈ្លើយសឹកវៀតណាមមួយចំនួនធំត្រូវបាននាំយកទៅកាន់មន្ទីរស-២១។ ពួកជនរងគ្រោះវៀតណាមចំនួន៣៤៥នាក់ ដែលត្រូវបានកត់ត្រាទុកនៅមន្ទីរស-២១ រួមទាំងចំនួន១២២នាក់ ដែលត្រូវបានកត់ត្រាថាជាពួក ឈ្លើយសឹក និងពួកជនស៊ីវិលចំនួន៧០នាក់ផង។ ពួកអ្នកទោសវៀតណាមនៅមន្ទីរស-២១ ត្រូវបានគេធ្វើទារុណកម្ម និងបង្ខំឱ្យឆ្លើយសារភាពថាមានផែនការវាតទីនិយមរបស់ប្រទេសវៀតណាម។ បន្ទាប់មក ចម្លើយសារភាពរបស់ពួកគេត្រូវបានធ្វើការផ្សព្វផ្សាយដោយក្បាលម៉ាស៊ីនឃោសនារបស់កម្ពុជាប្រជាធិបតេយ្យ និងត្រូវបានប្រើប្រាស់ជា "ភស្តុតាង" សម្រាប់ ធ្វើការបញ្ជាក់ពីការឈ្លានពានរបស់វៀតណាម ប្រឆាំងនឹងកម្ពុជា ។

៨២១- នៅពេលដែលថាមិនមានផ្នែកណាមួយនៃយុទ្ធនាការសម្លាប់រង្គាលនៅក្នុងប្រទេសកម្ពុជា ក៏នៅមានអំពើឃោរឃៅយ៉ាងធ្ងន់ធ្ងរទៅលើពួកជនស៊ីវិលវៀតណាម ដែលពិតជាបានជួយពង្រឹងដល់ភស្តុតាងស្តីពីការប្តេជ្ញារបស់ បកក ក្នុងការសម្លាប់រង្គាលលើជនជាតិវៀតណាម ឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ នៅក្នុងការពិភាក្សាអំពីជម្លោះប្រដាប់អាវុធ មេដឹកនាំ បកក បានគាំទ្រដល់គោលនយោបាយមួយស្តីពីការបំផ្លាញប្រជាជាតិវៀតណាមទាំងស្រុង តាមរយៈការអនុវត្តនូវគោលការណ៍ "មួយ ទល់នឹង៣០ - one against 30" របស់ខ្លួន៖ "ពាក់ព័ន្ធនឹងចំនួន ក្នុងយើងម្នាក់ត្រូវសម្លាប់យួន៣០នាក់...យើងត្រូវការតែកម្លាំង២០០០០០០នាក់

ប៉ុណ្ណោះ ដើម្បីកំទេចយួនចំនួន៥០០០០០០០នាក់...។ យើងដាច់ខាតត្រូវតែអនុវត្តពាក្យស្លោក មួយទល់នឹង៣០ ...បញ្ហានេះ មិនពាក់ព័ន្ធតែកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះទេ។

៨២២- ភស្តុតាងស្តីពីអំពើឃោរឃៅទាំងនេះក៏មាននៅក្នុងរបាយការណ៍ជាផ្លូវការមួយ ដែលបានចេញផ្សាយដោយកងទ័ពវៀតណាម ផងដែរ។ យោងទៅតាមរបាយការណ៍នោះ "នៅក្នុងអំឡុងពេលដែលមានរយៈកាលជិតពីរឆ្នាំ ១៩៧៧-១៩៧៨ [កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ] បានប្រព្រឹត្តនូវអំពើសម្លាប់រង្គាលទៅលើភូមិនានា ដែលស្ថិតនៅតាមបណ្តោយព្រំដែនទាំងអស់ ដោយបន្សល់ទុកនូវមនុស្សស្លាប់ ឬបាត់ខ្លួនចំនួនច្រើនជាង៣០០០០នាក់ និងមនុស្សចំនួន៤០០០០០នាក់ផ្សេងទៀតគ្មានទីជម្រក [...]" ។ របាយការណ៍ បានពិពណ៌នាអំពីចំនួននៃការវាយប្រហារដោយរួមទាំងការវាយប្រហារមួយ ដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានស្លាប់ជនស៊ីវិលចំនួន១០០០នាក់ "វះយកពោះវៀនរបស់ពួកនោះចេញ ហើយកាត់យកថ្លើម- disemboweling them and cutting out their livers" ហើយការវាយប្រហារមួយទៀតដែលមានពួកជនស៊ីវិលចំនួន ៩,០០០ នាក់ត្រូវបានសម្លាប់នៅស្រុកតាន់បៀន (ខេត្តតាយនិញ) (Tan Bien district - Tay Ninh province)។ សម្រាប់រយៈកាលពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ របាយការណ៍បានចោទប្រកាន់ថាមានការវាយប្រហារ ពីសំណាក់កងទ័ពបដិវត្តកម្ពុជាចំនួនច្រើនជាង២០០០លើក ដែលត្រូវបានធ្វើឡើងទៅលើទីក្រុង និងទៅលើភូមិនានារបស់វៀតណាម។

## ភស្តុតាងជាសាក្សីផ្ទាល់ភ្នែក

៨២៣- អ្នកសារព័ត៌មានដែលបានទៅទស្សនានៅប្រទេសវៀតណាម តាមកន្លែងនានា ដែលជាគោលដៅនៃការវាយប្រហារខាងលើនេះ អាចមានលទ្ធភាពមើលឃើញនូវភស្តុតាងស្តីពីអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យដោយផ្ទាល់ភ្នែក។ នៅដើមឆ្នាំ១៩៧៨ ណាយ៉ាន់ ចាន់ដា ដែលបានផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីជំនាញមួយរូប នៅក្នុងសំណុំរឿងលេខ០០១ ធ្លាប់បានទៅទស្សនាតាមទីក្រុង និងតាមភូមិនានាមួយចំនួន ដែលត្រូវបានរងនូវការប៉ះពាល់ដោយការវាយប្រហារទាំងនេះ។ នៅក្រុងទិនបៀន ខេត្តអានយ៉ាង (Tinh Bien - An Giang province) ដែលមានការសម្លាប់ជនស៊ីវិលយ៉ាងហោចណាស់១០០នាក់ដែរ ដែលធ្វើឡើងដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចងក្រងជាឯកសារ។ ចាន់ដា អាចមានលទ្ធភាពមើលឃើញច្បាស់នឹងភ្នែកក្រឡែតនូវ "សាកសពដែលបានស្លាប់បាត់បង់ជីវិតចំនួនរាប់ឡូ"។ គាត់ក៏បានទៅទស្សនាភូមិអានភូ នៅខេត្តអានយ៉ាង (An Phu village, An Giang province) ផងដែរ ជាកន្លែងដែលគាត់បានឃើញ ផ្ទះដែលត្រូវបានបំផ្លាញខ្ទេចខ្ទី និងសាកសពមនុស្សដែលនៅមិនទាន់កប់ មានទាំងបុរស ស្ត្រី និង កុមារ ដែលត្រូវបានសម្លាប់ "យ៉ាងសាហាវបំផុត" ។

៨២៤- នៅភូមិតាន់ឡាប់ ខេត្តតាយនិញ (Tan Lap village, Tay Ninh province) ចាន់ដា បានសង្កេតឃើញមានខ្ទមធ្វើពីដីភក់ដែលត្រូវបានឆេះរោលខ្មៅ និងបានសម្ភាសស្ត្រីម្នាក់ដែលធ្លាប់បានឃើញ ពួកខ្មែរក្រហមកំពុងសម្លាប់ពួកជនស៊ីវិលដែលមានចំនួនជាច្រើនសន្ធឹក។ សមាជិកគ្រួសារ របស់ស្ត្រីម្នាក់នេះ ចំនួនប្រាំពីរនាក់ ក្នុងចំណោមប្រាំបីនាក់ ត្រូវបានសម្លាប់។ គាត់ និងបងប្រុស របស់គាត់នៅរស់ដោយការធ្វើពុតជាស្លាប់នៅក្រោមគំនរសាកសព។

នៅពេលដែលគាត់បាន ទៅទស្សនាឃុំមីឌុក ក្នុងខេត្តគៀងយ៉ាង (My Duc commune, Kien Giang province) ចាន់ដាបានឃើញសាកសពបុរស ស្ត្រី និង កុមារ ចំនួន១៥នាក់ ព្រមទាំងបាច់ឈើ (staves) ដែលគេប្រើសម្រាប់វាយសម្លាប់ពួកទាំងនោះ។ គាត់បានសរសេររៀបរាប់នៅក្នុងសៀវភៅរបស់គាត់ ពីអ្វីដែលគាត់បានឃើញថា៖ "ឈើមួយ[កំណាត់] បុកជាប់នៅនឹងចន្លោះជើងរបស់ស្ត្រីម្នាក់ ដែលស្រាតសន្ធឹងដៃ-ជើង(a spread-eagled naked woman)។ កូនៗរបស់គាត់ត្រូវបាន កាត់ជាកំណាត់ៗ ។ មានសាកសពកំបុតក្បាលមួយចំនួន។ សាកសពខ្លះ ត្រូវបានគេបារពោះវៀនចេញក្រៅ"។

៨២៥- អ្នកសារព័ត៌មានម្នាក់ផ្សេងទៀតដែលបានទៅទស្សនាតំបន់ ហាទៀង (Ha Tien) នៅខែមីនា ឆ្នាំ១៩៧៨ បានពិពណ៌នាអំពីការជ្រៀតចូលឆ្លងកាត់ព្រំដែន ពីសំណាក់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និងបានរាយការណ៍ថាបានឃើញសាកសពពួកជនស៊ីវិលចំនួន៣៥នាក់ ដោយបានធ្វើការកត់សម្គាល់ថា "ពួកស្ត្រី និង ពួកកុមារ ដោយរាប់ទាំងទារកតូចៗផង ត្រូវបានគេកាត់ក្បាល ហើយភាគច្រើនត្រូវបានគេធ្វើទារុណកម្ម។ ពួកបុរសៗត្រូវបានគេកាត់ពងស្វាសចេញ ហើយមាន ឈើវែងៗលៀនចេញពីរាងកាយសាកសពស្ត្រី"។

៨២៦- [redacted] ពួកយុទ្ធជនកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ជាឲ្យដុតផ្ទះចោល។ [redacted] ដោយធ្វើតាមបញ្ជារបស់មេបញ្ជាការកងពលតូចឲ្យ "បំផ្លាញចោល និងដុត

កំទេចអ្វីៗគ្រប់យ៉ាង" កងទ័ពកម្ពុជាប្រជាធិបតេយ្យបានដុតផ្ទះសម្បែង និងមន្ទីរពេទ្យយោធានានា នៅចម្ងាយប្រមាណពី១៥ ទៅ២០គីឡូម៉ែត្រខាងក្នុងទឹកដីវៀតណាម។ ពួកគេក៏បានចាប់ពួកបុរស និងស្ត្រី វៀតណាមផងដែរ (ភាគច្រើនគឺខាងក្រោយ) ដែលត្រូវបានបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ។ [redacted] ពួកទ័ពកម្ពុជាប្រជាធិបតេយ្យបានចាប់ក្មេងៗបោះទៅលើ ហើយចាក់សម្លាប់ពួកគេនឹងចំពុះទុង។

## របាយការណ៍ស្តីពីឧក្រិដ្ឋកម្ម ដាក់ជូនទៅគណៈមជ្ឈិមបកក និងសេចក្តីរាយការណ៍អន្តរជាតិ

៨២៧- ដូចដែលបានរៀបរាប់នៅក្នុងផ្នែកជម្លោះប្រដាប់អាវុធ គណៈមជ្ឈិមបកកបានអនុវត្តនូវបញ្ជារបស់ខ្លួនទៅលើពួកកងទ័ពកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអំឡុងពេលនៃជម្លោះជាមួយនឹងវៀតណាម និងបានទទួលនូវរបាយការណ៍នានាជាទៀងទាត់ពីពួកគេវិញ។ ការប្រាស្រ័យទាក់ទងគ្នាជាច្រើនរបស់កងទ័ពបដិវត្តកម្ពុជា ដែលបានដាក់ជូនទៅពួកមេដឹកនាំជាន់ខ្ពស់នៅភ្នំពេញ គឺជាការបញ្ជាក់ច្បាស់អំពីការទទួលរបស់កងទ័ពនូវសេចក្តីណែនាំផ្សេងៗ ពីមជ្ឈិមបក្សឱ្យធ្វើការកម្ទេចវៀតណាម និង/ឬ រាយការណ៍ពីការចាប់ខ្លួន ការសម្លាប់ និងការកាប់សម្លាប់ពួកជនជាតិវៀតណាម ក៏ដូចជា ការដុតលំនៅដ្ឋាន របស់ពួកវៀតណាម។ ឧទាហរណ៍៖

១) នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៨ សោ ភឹម បានរាយការណ៍ថាកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានចូលទៅចម្ងាយពីរគីឡូម៉ែត្រ ខាងក្នុងទឹកដីនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមដែល *លើសពីអង្គហេតុអ្វីៗទាំងអស់(inter alia)* ពួកគេបានបំផ្លាញនូវបន្ទាយទាហាន និងផ្ទះរបស់ជនស៊ីវិល ហើយបានសម្លាប់ជនស៊ីវិល និង "ខ្មាំង" ។

២) នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ សុន សេន បានផ្ញើទូរលេខមួយច្បាប់ជូនទៅគណៈមជ្ឈិម ដោយបានរាយការណ៍អំពីការចាប់ខ្លួន "យួន២ក្បាល អាយុ១៧ និង២៧" ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១ ។

៣) នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៨ សុន សេន បានរាយការណ៍ថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានធ្វើការជ្រៀតចូលទៅក្នុងខេត្តដុងថាប់ (Dong Thap province) នៃប្រទេសវៀតណាម ដែលនៅទីនោះពួកគេបានពាក់ព័ន្ធនឹងការសម្លាប់ ការលួចប្លន់ និងការដុតភូមិត្រពាំងព្រាហ្មណ៍ និងភូមិថាន់ចៅ (Villages of Trapeang Pream and Than Chau)។

៨២៨- គណៈមជ្ឈិមបកក ក៏បានទទួលផងដែរនូវរបាយការណ៍ស្ដីពីឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តដោយកងកម្លាំងរបស់ខ្លួន ពីស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅទីក្រុងហាណូយ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ រដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម បានដាក់ពាក្យតវ៉ាមួយ ជូនទៅឈ្មោះ ហេង សុខខេង ហៅ ឈាន (Heng Sokh-Kheng alias Chhean) ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំទីក្រុងហាណូយ ទាក់ទងទៅនឹងការវាយប្រហារនានារបស់កម្ពុជាប្រជាធិបតេយ្យ ដែលបានកើតឡើងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៧។ យោងតាមវៀតណាម កងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ "បានធ្វើការវាយប្រហារសម្រុកទៅលើប៉ុស្តិ៍សន្តិសុខរបស់[វៀតណាម] ការកាប់សម្លាប់ និងការដុតផ្ទះសម្បែង ដែលបណ្ដាលឱ្យមានការ ខូចខាតស្លាប់ និងរបួសយ៉ាងច្រើន។ ក្រោយមក ឈាន បានរាយការណ៍ថា៖"ការពិតដែលបណ្ដាលឱ្យកងទ័ពកម្ពុជាប្រព្រឹត្តនូវអំពើដោយបំពាន ការសម្លាប់ ការដុតបំផ្លាញ និងកម្ទេចនោះ គឺមិនមែនជាអ្វីៗដែលពួកគេបានលើកតាមរបាយការណ៍នោះទេ

ក៏ប៉ុន្តែអ្វីៗដែលអាចមានភ័ស្តុតាងយ៉ាងច្បាស់ និងដែលមិនអាចប្រកែកបាន។ ប្រសិនបើខ្ញុំចង់មើលរូបថតនោះ គាត់អាចមានសម្រាប់ឲ្យខ្ញុំមើលបាន"។

៨២៩- នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៧ ឈាន បានរាយការណ៍ពីការចោទប្រកាន់ស្តីពីការបាញ់វាំងដោយកាំភ្លើងធំ ពីសំណាក់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ចូលទៅក្នុងខេត្តអានយ៉ាង (An Giang province) របស់ប្រទេសវៀតណាម នៅក្នុងចន្លោះថ្ងៃទី១៦-១៨ ខែកក្កដា ឆ្នាំ១៩៧៧ ដែលមានមនុស្សចំនួន៣០នាក់ត្រូវបានសម្លាប់ និង៥០នាក់ ត្រូវបានរងរបួស ព្រមទាំងអាគារមួយចំនួនធំត្រូវបានបំផ្លាញ"។ នៅថ្ងៃទី០៤ ខែសីហា ឈាន បានរាយការណ៍ថាមានរឿងមួយដែលត្រូវបានគេបញ្ជូនតៗគ្នានៅក្នុងចំណោមសហគមន៍អ្នកការទូតនៅទីក្រុងហាណូយថា កងទ័ពបដិវត្តកម្ពុជាត្រូវទទួលខុសត្រូវចំពោះការសម្លាប់ពួកជនស៊ីវិល ចំនួន១០០០នាក់នៅហាទៀង ក្នុងខេត្តគៀងយ៉ាង (Ha Tien, Kien Giang province)។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៧ ឈាន បានរាយការណ៍ពីការចោទប្រកាន់ស្តីពីការជ្រៀតចូលទៅក្នុងខេត្តអានយ៉ាង គៀងយ៉ាង ឡុងអាន និង តាយនិញ (An Giang, Kien Giang, Long An and Tay Ninh provinces)នៅក្នុងប្រទេសវៀតណាម ដែលពួកកងទ័ពកម្ពុជាប្រជាធិបតេយ្យបានសម្លាប់ពួកជនស៊ីវិល និងបានដុតទ្រព្យសម្បត្តិផ្សេងៗ ដោយរាប់ទាំងលំនៅដ្ឋាន និងស្តុកម្ហូបអាហារទៀតផង។

៨៣០- នៅក្នុងទូរលេខមួយច្បាប់ដែលទំនងជាត្រូវបានបញ្ជូននៅខែធ្នូ ឆ្នាំ១៩៧៧ ស្ថានទូតនៅទីក្រុងហាណូយ បានរាយការណ៍ពីការចោទប្រកាន់ជាបន្តទៀត ស្តីពីការជ្រៀតចូលរបស់កម្ពុជាប្រជាធិបតេយ្យចូលទៅក្នុងទឹកដីនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ដែលបានកើតឡើងនៅក្នុង

ខែកញ្ញា ឆ្នាំ១៩៧៧។ ការជ្រៀតចូលទាំងនេះ មានពាក់ព័ន្ធនឹងការវាយប្រហារនៅក្នុងខេត្តតាយនិញផង ដែលមានមនុស្សច្រើនជាង ១០០០នាក់ ត្រូវបានសម្លាប់ ។ ទូរលេខនេះក៏បានយោងផងដែរទៅដល់ការចោទប្រកាន់នានាដែលថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យឋិតនៅក្នុងចម្ងាយប្រាំមួយគីឡូម៉ែត្រនៅខាងក្នុងទឹកដីនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម នៅក្នុងខេត្តប៊ិនហួ (Ben Hoa province) ហើយថាបានធ្វើការជ្រៀតចូលទៅក្នុងខេត្ត គៀងយ៉ាង យ៉ាឡៃ និង កុងទុម (Kien Giang, Gia Lai, and Kon Tum provinces) ថែមទៀតផង។

៨៣១- នៅចន្លោះថ្ងៃទី០៤ និង១១ ខែមករា ឆ្នាំ១៩៧៨ សារព័ត៌មានអន្តរជាតិបានរាយការណ៍ថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានបង្កើនការវាយប្រហារចូលទៅក្នុងតំបន់ផ្សេងៗនៃសាធារណរដ្ឋសង្គមនិយមវៀតណាម គឺចាប់ពីខេត្តកុងទុម នៅភាគខាងជើង រហូតដល់ខេត្តអានយ៉ាង នៅភាគខាងត្បូង ដោយមានចំនួនពីរកងពលធំតែឯង ដែលមានការពាក់ព័ន្ធទៅនឹងការវាយប្រហារ ទៅលើខេត្តអានយ៉ាង។ សេវាផ្សព្វផ្សាយព័ត៌មានក្នុងប្រទេសប្រចាំទីក្រុងហាណូយ (Hanoi Home Service) បានរាយការណ៍ថា នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានធ្វើការបាញ់រះទៅលើហាទៀង និងទៅលើភូមិនានាដែលស្ថិតនៅជិតៗនោះ។

៨៣២- នៅខែមករា ឆ្នាំ១៩៧៨ បណ្ដាញសារព័ត៌មានអន្តរជាតិក៏បានរាយការណ៍ផងដែរ អំពីការលើកឡើងរបស់ទីក្រុងហាណូយដែលថា មានជនជាតិវៀតណាមជាច្រើនពាន់នាក់ ត្រូវបានសម្លាប់ និងរងរបួសនៅក្រោមការវាយប្រហាររបស់កងទ័ពបដិវត្តកម្ពុជា និងមានមនុស្សរាប់ពាន់នាក់ផ្សេងទៀត ត្រូវបានគេបង្ខំឱ្យចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ដែលត្រូវបានបំផ្លាញ។

នៅខែមេសា ឆ្នាំ១៩៧៨ បណ្តាញសារព័ត៌មានអន្តរជាតិបានរាយការណ៍អំពីសេចក្តីថ្លែងការណ៍មួយ ដែលធ្វើឡើងដោយឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅប្រទេសសេរីលង្កាថា ជាលទ្ធផលនៃការវាយប្រហាររបស់កងទ័ពបដិវត្តកម្ពុជា "ពួកស្ត្រីត្រូវបានគេរំលោភសេពសន្ថវៈ រីឯពួកបុរសចាស់ៗ និងពួកកូនក្មេង ត្រូវបានគេកាត់ក្បាល ហើយអំពើដ៏ឃោរឃៅព្រៃផ្សៃទាំងនេះត្រូវបានពួកកងទ័ពកម្ពុជាប្រព្រឹត្ត ឡើងសំដៅទៅលើជនស៊ីវិលស្លូតត្រង់វៀតណាម"។

៨៣៣- ការប៉ុនប៉ងរបស់ប្រទេសវៀតណាមដើម្បីការពារកុំឲ្យជម្លោះនេះរីករាលដាល និងដើម្បីរកដំណោះស្រាយនយោបាយមួយទៅនឹងជម្លោះនោះ គឺចុងក្រោយមកត្រូវបានបរាជ័យបណ្តាលមកពីទំហំនៃអំពើឃោរឃៅ ដែលត្រូវបានប្រព្រឹត្តឡើងដោយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសវៀតណាម និងការទាមទាររបស់មហាជនមូលដ្ឋានដែលសុំឲ្យមានការការពារ។

## ង- ការដឹងឮអំពីឧក្រិដ្ឋកម្ម

### ទិដ្ឋភាពទូទៅ

៨៣៤- ការដឹងឮរបស់ជនត្រូវចោទចំពោះអំពើឧក្រិដ្ឋកម្ម ដែលកើតចេញពីព្រឹត្តិការណ៍ឧក្រិដ្ឋនានាដែលបានអះអាងនៅក្នុងសារណានេះ គឺត្រូវបានបង្ហាញតាមរយៈការចូលរួមរបស់ជនត្រូវចោទទាំងនោះ ក្នុងការប្រព្រឹត្តិសហកម្មឧក្រិដ្ឋកម្មរួមដែលមានរៀបចំផែនការល្អ និងមានការចាត់ចែងកម្រិតខ្ពស់។ ក៏ប៉ុន្តែមានភស្តុតាងបន្ថែមទៀតថា ជនត្រូវចោទទាំងនោះបានដឹងពីអំពើឧក្រិដ្ឋកម្មទាំងនេះនៅមុនពេល អំឡុងពេល និងបន្ទាប់ពីពេលបានប្រព្រឹត្ត តាមរយៈការរាយការណ៍ដំណាលគ្នា និងជាបន្តបន្ទាប់ អំពីឧក្រិដ្ឋកម្មទាំងនេះ នៅក្នុងឯកសារកម្ពុជាប្រជាធិបតេយ្យ និងឯកសារអន្តរជាតិ។ ***ឯកសារកម្ពុជាប្រជាធិបតេយ្យ*** ដែលបានផ្តល់ជាព័ត៌មានទាក់ទងនឹងអំពី

ឧក្រិដ្ឋកម្មទាំងនេះរួមមាន សេចក្តីថ្លែងការណ៍ជាសាធារណៈដែលបានធ្វើដោយជនត្រូវចោទ ឬអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជាក្នុងនាមពួកគេ ការរាយការណ៍ជាទៀងទាត់ដែលតាមរយៈនេះ មេដឹកនាំជាន់ខ្ពស់បានដឹងព័ត៌មាន អំពីបទឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទូទាំងប្រទេស និងសេចក្តីរាយការណ៍អំពីដំណើរទស្សនកិច្ចរបស់ជនត្រូវចោទទៅទីកន្លែងផ្សេងៗនៃផ្ទៃប្រទេស និងការជួបប្រជុំជាមួយមេដឹកនាំផ្សេងទៀត ***ឯកសារអន្តរជាតិ*** ដែលផ្តល់ព័ត៌មានអំពីអំពើឧក្រិដ្ឋកម្មទាំងនេះរួមមាន របាយការណ៍របស់រដ្ឋាភិបាល អន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងរបាយការណ៍របស់បណ្តាញសារព័ត៌មានអន្តរជាតិ។ របាយការណ៍របស់អង្គការទាំងនេះរួមមាន របាយការណ៍របស់បណ្តាញសារព័ត៌មានដែលត្រូវបានតាមដានជាទៀងទាត់ ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងករណីជាច្រើន របបនេះបានឆ្លើយតបទៅនឹងរបាយការណ៍ទាំងនោះ ដោយបានបញ្ជាក់បន្ថែមពីការយល់ដឹងរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះអំពើឧក្រិដ្ឋកម្មទាំងនេះ។

៨៣៥- ដូចដែលនឹងពិភាក្សាបន្ថែមទៀត នៅក្នុងផ្នែកស្តីពីលក្ខណៈច្បាប់នៅក្នុងដីកាសន្និដ្ឋាននេះថា ការទទួលបានព័ត៌មានជាបន្តបន្ទាប់ដែលស៊ីសង្វាក់គួរឲ្យជឿជាក់បាន អំពីព្រឹត្តិការណ៍ឧក្រិដ្ឋកម្មនានាដែលបានកើតឡើងដំណាលៗគ្នានៅទូទាំងប្រទេស បានធ្វើឲ្យជនត្រូវចោទដឹងពីអំពើឧក្រិដ្ឋកម្មទាំងនោះ ហើយបានធ្វើឲ្យពួកគេត្រូវស្ថិតក្រោមកាតព្វកិច្ចមួយដែលត្រូវបោះជំហានទៅរកការស៊ើបអង្កេតទៀត។ ឧទាហរណ៍នានាស្តីពីប្រភេទឯកសារផ្សេងៗ ដែលបានផ្តល់ឲ្យជនត្រូវចោទដឹងពីអំពើឧក្រិដ្ឋកម្មទាំងនោះនឹងមានពណ៌នានៅខាងក្រោម។

# ឯកសារកម្ពុជាប្រជាធិបតេយ្យ

## ទំនាក់ទំនងនៅក្នុងរដ្ឋាភិបាល

### របាយការណ៍ពីភូមិភាគ កងពលយោធា និងក្រសួងនានា

៨៣៦- ផ្ទុយពីអ្វីដែលបានអះអាងនៅក្នុងសាលាដម្រះក្តីនេះ និងសេចក្តីថ្លែងការណ៍ជាសាធារណៈនានា មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាបានទទួលរបាយការណ៍ពិស្តារជាទៀងទាត់ ពីរដ្ឋាភិបាល និងអង្គភាពយោធានៅទូទាំងប្រទេសស្តីពីបញ្ហាសន្តិសុខ សេដ្ឋកិច្ច និងសុខាភិបាល រួមទាំងការចាប់ខ្លួន ការឃុំឃាំង ការសួរចម្លើយ និងការកម្ទេច ទាំងខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ ការបង្កបង្កើនផលស្រូវ ការខ្វះខាតស្បៀងអាហារ និងថ្នាំសង្កូវ និងការសង់ទំនប់ ប្រឡាយ និងអាងស្តុកទឹកជាដើម។ មានវិធីបីយ៉ាងជាមូលដ្ឋានសម្រាប់ឲ្យមជ្ឈិមបក្សបានទទួលព័ត៌មានពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យទាំងមូល រួមទាំងព្រឹត្តិការណ៍នានា ដែលជាកម្មវត្ថុនៅក្នុងសំណុំរឿង០០២ផងដែរគឺ៖ (១)ការប្រជុំដែលជាបឋមគឺរៀបចំធ្វើឡើងនៅតាមមន្ទីរនានារបស់មេដឹកនាំជាន់ខ្ពស់នៅភ្នំពេញ (២)របាយការណ៍សរសេរប្រចាំសប្តាហ៍ និងប្រចាំខែ និង(៣)ទូរលេខដែលផ្ញើជារៀងរាល់ថ្ងៃ។

### ការប្រជុំ

៨៣៧- មជ្ឈិមបក្សបានរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយមេដឹកនាំភូមិភាគ និងតំបន់ ដើម្បីពិភាក្សាអំពីសភាពការណ៍នៅតាមមូលដ្ឋានរបស់ខ្លួន។ ការប្រជុំទាំងនេះត្រូវបានធ្វើឡើងជាធម្មតានៅមន្ទីរក-១ ឬក-៣ ដែលមានវត្តមានរបស់ ប៉ុល ពត **នួន ជា អៀង សារី** និង **ខៀវ សំផន**។ ជាង

នេះទៅទៀត លេខាភូមិភាគក៏ត្រូវបានគេកោះហៅឱ្យចូលរួមប្រជុំទៀងទាត់របស់គណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយ ប៉ុល ពត ដើម្បីធ្វើយុត្តិកម្មចំពោះសកម្មភាពរបស់ខ្លួន និងដើម្បីទទួលយក "ការណែនាំ"ផងដែរ។ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតនៅភ្នំពេញក៏ ខ ស្សាហ៍ធ្វើដំណើរទៅតាមខេត្តនានា ដើម្បីជួបជាមួយមេដឹកនាំភូមិភាគ និងតំបន់ និងពិនិត្យសភាពការណ៍នៅក្នុងមូលដ្ឋានរបស់ពួកគេ។

៨៣៨- នៅក្នុងអង្គប្រជុំមួយដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅតាមមូលដ្ឋាន បានរាយការណ៍ទៅមជ្ឈិមបក្សគឺការប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ស្តីពី"ការងារមូលដ្ឋាន" ដែលមានវត្តមាន ប៉ុល ពត **នួន ជា** និង **ខៀវ សំផន**។ អង្គប្រជុំនេះនិយាយអំពីរបាយការណ៍មួយពីតំបន់១០៣ និង១០៦ និងភូមិភាគឧត្តរ ដែលតំណាងដោយមិត្ត ស្រេង (អនុលេខាភូមិភាគឧត្តរ) មិត្ត សុត (លេខាតំបន់១០៦) និង មិត្ត ហង់ (លេខាតំបន់១០៣) ស្តីពី "សភាពការណ៍ខ្លាំង" និងការចាប់ខ្លួនមនុស្សជាច្រើននាក់នៅក្នុងមូលដ្ឋាន (រួមទាំងមនុស្សមួយក្រុមដែលមានគ្នា៣៤នាក់ ដែលត្រូវបានចាប់ខ្លួនដោយយោធាភូមិភាគ) ការប្រមូលផលស្រូវ និងស្ថានភាពនៅក្នុង"ការដ្ឋានធំៗ"។ គណៈអចិន្ត្រៃយ៍បានទទួលព័ត៌មានថា នៅតំបន់១០៦ ប្រជាជនជាច្រើនមានជំងឺ និងមានការរាលដាលជំងឺអាសន្នរោគ និងអុតស្វាយ ដែលកើតឡើងដោយសារ "បាត់កម្លាំង៤០ភាគរយ"។ តំបន់១០៣ ក៏បានរាយការណ៍ថា ប្រជាជននៅការដ្ឋានឈឺគ្រុន ហើយថាមានមនុស្សលើស១០០ នាក់ត្រូវបានចាប់ខ្លួននៅក្នុងតំបន់នេះចាប់ពីខែមករាមក។ មានការស្នើមតិយោបល់ពីអង្គការចំពោះមនុស្សមួយក្រុមដែលមានចំនួន៥-៦ នាក់ ដែលប៉ុនប៉ងរត់ទៅវៀតណាម។ ក្នុងការឆ្លើយតបវិញ គណៈអចិន្ត្រៃយ៍បានផ្តល់ យោបល់

ថាត្រូវយកមនុស្សទាំងនោះ មកសួរ ហើយទុកមួយកន្លែង ហើយចំពោះលទ្ធផល“ត្រូវរាយការណ៍មកខាងលើដោយមានសំណុំរឿងផង”។

## របាយការណ៍ប្រចាំសប្ដាហ៍ និងប្រចាំខែ

៨៣៩- នៅឯអង្គប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដូចដែលបានពិភាក្សាខាងលើ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា បានស្នើ“រាយការណ៍ជូនអចិន្ត្រៃយ៍រាល់សប្ដាហ៍” អំពីសភាពការណ៍ភ្លឺស្រែ រួមទាំង“រាយការណ៍ជាទិដ្ឋភាពរួម” “រាយការណ៍តាមមុខព្រួញមួយៗ” និង “រាយការណ៍ខ្លីៗតាមទូរលេខ” ដើម្បីឱ្យ“អចិន្ត្រៃយ៍ដឹងសភាពការណ៍ ដើម្បីណែនាំបានទាន់ពេលវេលា”។ នៅចុងខែនោះ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតនូវ “របបរាយការណ៍ប្រចាំសប្ដាហ៍ទៅមន្ទីរ៨៧០”ដែលមានគោលបំណងដើម្បី“តាមដានផែនការឱ្យជាប់ និងដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលាក្នុងទិសដៅសម្រេចពាតោន ១ហិកតា”។

៨៤០- អនុលោមតាមសេចក្ដីសម្រេចនេះ មន្ទីរនានានៅតាមភូមិភាគបានធ្វើរបាយការណ៍ប្រចាំសប្ដាហ៍ និងប្រចាំខែទៅមន្ទីរ៨៧០ ស្ដីពីសភាពការណ៍នៅតាមមូលដ្ឋានរបស់ខ្លួន។ របាយការណ៍ទាំងនេះរួមទាំង ព័ត៌មានលម្អិតទៅដល់ថ្នាក់ស្រុក ដោយសារថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់ឃុំជាអ្នករាយការណ៍ជាលាយល័ក្ខអក្សរទៅលេខាស្រុក ដែលជាអ្នកមានតួនាទីប្រមូលព័ត៌មាន និងរបាយការណ៍ទៅលេខាតំបន់ ហើយលេខាតំបន់នឹងរាយការណ៍បន្តទៅលេខាភូមិភាគ។ ឧទាហរណ៍មួយអំពីមន្ទីរភូមិភាគបានប្រើព័ត៌មានទទួលពីរបាយការណ៍របស់តំបន់ អាចរកឃើញនៅក្នុងរបាយការណ៍ប្រចាំខែរបស់ភូមិភាគពាយ័ព្យសម្រាប់ខែឧសភា ឆ្នាំ១៩៧៧ ដែលបញ្ចូលព័ត៌មាន ដែលមន្ទីរភូមិភាគបានទទួលពីតំបន់៥ នូវរបាយការណ៍ជាលាយលក្ខណ៍

អក្សរចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧។ បញ្ហានានាដែលទាក់ទងនឹងមន្ទីរសន្តិសុខក៏មាន បញ្ចូលនៅក្នុងរបាយការណ៍បែបនោះដែរ រួមទាំងចម្លើយសារភាពផង។ មានលក្ខណៈជាស្តង់ដាមួយនៅក្នុងរបាយការណ៍ភាគច្រើនដែលពណ៌នាពី"សភាពការណ៍ខ្មាំង" ទាំងខ្មាំងពីក្រៅ និងខ្មាំងខាងក្នុង (ជួនកាលគេនិយាយដល់ "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង") ដោយមានរាយការណ៍ពីសកម្មភាពខ្មាំង និងការចាប់ខ្លួន ការឃុំឃាំង ការសួរចម្លើយ និងការកម្ទេចខ្មាំងទាំងនោះ។ របាយការណ៍ជាលាយលក្ខណ៍អក្សរត្រូវបានផ្ញើទៅមន្ទីរក-៧ ដែលជាមន្ទីរនិរសារសម្រាប់មជ្ឈិមបក្ស ហើយបន្ទាប់មកចែកចាយទៅឲ្យ ប៉ុល ពត **នួន ជា ខៀវ សំផន** និង **អៀង សារី**។

៨៤១- ថ្វីបើមានការបំផ្លាញចោលនូវឯកសារភស្តុតាងជាទ្រង់ទ្រាយធំ ដោយបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ តែក្នុងសំណុំរឿងមានឧទាហរណ៍នានាស្តីពីរបាយការណ៍បែបនោះ ដែលបានផ្ញើពីភូមិភាគបស្ចិម(ម-៤០១) ភូមិភាគនិរតី ភូមិភាគកណ្តាល(ឧត្តរចាស់) ភូមិភាគឧត្តរថ្មី (ម-៨០១) ភូមិភាគឦសាន ភូមិភាគពាយ័ព្យ(ម-៥៦០) ភូមិភាគបូព៌ា និង តំបន់១០៥ និង៥០៥(ជាតំបន់ស្វយ័តដែលត្រូវរាយការណ៍ផ្ទាល់ទៅគណៈចិន្ត្រៃយ៍) ទៅឲ្យមជ្ឈិមបក្ស។

៨៤២- កងពលយោធានៃកងទ័ពបដិវត្តន៍កម្ពុជា ក៏បានផ្ញើរបាយការណ៍ជាទៀងទាត់ទៅឲ្យ សុន សេន ហៅ ខៀវ ហៅ បង៨៩ ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ មានតួនាទីជាប្រធានសេនាធិការដែរ។ ក្នុងសំណុំរឿងនេះមានឧទាហរណ៍ទាក់ទងនឹងរបាយការណ៍បែបនេះ ដែលផ្ញើមកពីកងពល១៦៤ ១៧០ ៣១០ ៤៥០ ៥០២ ៧០៣ ៨០១ និង៩២០ និង កងវរៈសេនាធំ១៥២ និង៤៨៨។ សុន សេន បានផ្ញើឯកសារ និង ទូរលេខជាទៀងទាត់ទៅឲ្យ ប៉ុល ពត និង **នួន ជា** រួមនឹងរបាយការណ៍ដែល សុន សេន បានទទួលពីអង្គភាពយោធាដែលរាយការណ៍មកគាត់

ផ្ទាល់ផងដែរ។ សុន សេន ក៏បានរាយការណ៍ពីបញ្ហាទាំងនេះ នៅឯកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ កម្មាភិបាលនៅសេនាធិការដែលទទួលបន្ទុកទទួលនិងផ្ញើលិខិតទាក់ទងជាមួយអង្គភាពទាំងនោះបានបំភ្លឺថា សុន សេន បានទៅធ្វើការនៅក-១ ជារៀងរាល់ថ្ងៃជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ហើយថា"រាល់បញ្ហាទាំងអស់" ត្រូវតែរាយការណ៍ឱ្យ សុន សេន ហើយសេនាធិការត្រូវរាយការណ៍ឱ្យអង្គការ។

៨៤៣- មន្ទីរ៨៧០ បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរស្រដៀងគ្នានេះដែរ ដែលផ្ញើមកពីក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ និងអង្គភាពនានារបស់រដ្ឋាភិបាល ហើយកម្មាភិបាលជាន់ខ្ពស់នៅតាមក្រសួងទាំងនោះ ក៏នឹងជួបប្រជុំជាមួយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដើម្បីរាយការណ៍ពីសភាពការណ៍នៅតាមក្រសួងរបស់ខ្លួន។ ក្នុងសំណុំរឿងនេះ មានឧទាហរណ៍ពីរបាយការណ៍បែបនេះ ដែលផ្ញើទៅឱ្យអង្គការពីក្រសួងពាណិជ្ជកម្ម និងផ្នែកនេសាទសមុទ្រ។

**ទូរលេខ**

៨៤៤- ទូរលេខត្រូវបានប្រើដើម្បីបញ្ជូនរបាយការណ៍ខ្លីៗ និងផ្តល់ព័ត៌មានដល់មជ្ឈិមបក្សអំពីបញ្ហានានាដែលសំខាន់និងបន្ទាន់។ កម្មវត្ថុនៅក្នុងទូរលេខរួមមាន ការរាយការណ៍ពីការវាយប្រយុទ្ធរបស់កងទ័ពប្រឆាំងនឹងកងទ័ពវៀតណាម ការស្នើសុំការឧបត្ថម្ភ ឬ"បញ្ហាផ្ទៃក្នុង" ដូចជា "បញ្ហាជាមួយប្រជាជន ឬជាមួយខ្មាំង" ដែលសុំ"ការសម្រេច"ពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និង"វិធានការ" ដើម្បីដោះស្រាយសភាពការណ៍ខ្មាំង។ ទូរលេខដែលបានផ្ញើពីមន្ទីរភូមិភាគនានា

ទៅឱ្យមន្ទីរ៨៧០ គឺត្រូវបានផ្ញើជារៀងរាល់ថ្ងៃ ទៅតាមពេលវេលាកំណត់ជាទៀងទាត់ ដោយប្រើទម្រង់ស្តង់ដាដែលបង្កើតឡើងដោយមជ្ឈិមបក្ស។

៨៤៥- ទូរលេខដែលសរសេរអក្សរសម្ងាត់ផ្ញើពីភូមិភាគដំបូង ត្រូវបញ្ជូនទៅឱ្យផ្នែកបកប្រែនៅ ក-១ ដើម្បីសម្រាយជាអក្សរធម្មតា ហើយបន្ទាប់មកត្រូវវាយអង្គុលីលេខ និងបញ្ជូនទៅឱ្យមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា។ ប៉ុន និង ចេរ ជាអ្នកទទួលបន្ទុកផ្នែកទូរលេខ ដែលត្រូវសរសេរចំណារ ឬវាយអង្គុលីលេខទៅលើឯកសារដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាត្រូវទទួល ដែលចម្លងចេញពីទូរលេខ។ ជាទូទៅ "ទូរលេខត្រូវតែចម្លងជូនមេដឹកនាំគ្រប់គ្នាទាំងអស់" ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ ទោះបីក្នុងករណីខ្លះទូរលេខនោះ ត្រូវបញ្ជូនត្រឹមតែទៅឱ្យ"អ្នកដែលពាក់ព័ន្ធដែលមានភារកិច្ចទទួលខុសត្រូវឆ្លើយឆ្លង"។ ក្រដាសកាបោនត្រូវបានយកមកប្រើដើម្បីវាយ៤ ទៅ៥សន្លឹក សម្រាប់ទូរលេខមួយ។ មន្ទីរទូរលេខបានផ្ញើទូរ លេខទៅឱ្យ ប៉ុល ពត នៅ ក-១ ២ ឬ៣ដងក្នុងមួយថ្ងៃ។ បន្ទាប់ពី ប៉ុល ពត បានអានទូរលេខទាំងនោះហើយ គេត្រូវផ្ញើទៅឱ្យ **នួន ជា**។ ទូរលេខនោះក៏ត្រូវចម្លងជូន និងផ្ញើតាមរយៈនិរសារទៅឱ្យមន្ទីររបស់ **អៀង សារី** និង **ខៀវ សំផន** ដែរ។ ឯកសារចម្លងដែល "ទុកជាឯកសារ" ត្រូវតម្កល់នៅមន្ទីរទូរលេខរបស់ ប៉ុន នៅ ក-១ និងរក្សាទុកនៅក្នុងកេះថតៗរៀបចំតាមតំបន់ និងភូមិភាគ ដែលចម្លងជូនទៅ "មន្ទីរ" ត្រូវបានរក្សាទុកដោយមន្ទីរ៨៧០ នៅមន្ទីររបស់ **ខៀវ សំផន**។

៨៤៦- ទូរលេខក៏ត្រូវបានប្រើដោយមជ្ឈិមបក្ស ដើម្បីជាវិធីសាស្ត្រមួយ ក្នុងការបញ្ជូនសេចក្តីសម្រេច ឬការណែនាំទៅឱ្យភូមិភាគ និងតំបន់ដែរ។

## បញ្ហានានាដែលរាយការណ៍ទៅមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា

៨៤៧- តាមរយៈរបាយការណ៍និងទូរលេខដែលផ្ញើទៅមន្ទីរ៨៧០ ឬ សមាជិកគណៈអចិន្ត្រៃយ៍ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាបានទទួលព័ត៌មានជាទៀងទាត់ ពីបញ្ហានានាដែលបានកើតឡើងនៅទូទាំងប្រទេស ដូចខាងក្រោម៖

៨៤៨- <u>ការចាប់ខ្លួន និងការឃុំឃាំង"ខ្មាំង"ដែលត្រូវគេចោទប្រកាន់ដោយភូមិភាគ តំបន់ ស្រុក និងកងពលយោធា</u>។ របាយការណ៍ដែលបានផ្ញើឱ្យមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានពិភាក្សាជាពិសេសអំពី"សកម្មភាពខ្មាំង"នៅក្នុងមូលដ្ឋាន(ឬអង្គភាព)នោះ និង"វិធានការ"ដែលយកមកប្រើដើម្បីដោះស្រាយបញ្ហាទាំងនោះ រួមទាំងការចាប់ខ្លួន និងការឃុំឃាំងមនុស្សទាំងនោះ នៅក្នុងមន្ទីរសន្តិសុខ ឬមន្ទីរអប់រំកែប្រែ។ ឧទាហរណ៍ នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ មានរបាយការណ៍មួយពីលេខាភូមិភាគកណ្ដាលទៅឱ្យ ប៉ុល ពត ចម្លងជូន នួន ជា បានពិភាក្សាអំពីសកម្មភាពរបស់"ទាហានចាស់រួមផ្សំជាមួយពួកចាម និងពួកអតីតប្រធានក្រុមសហករណ៍" និងបានរាយការណ៍ថា ភូមិភាគបានចាត់វិធានការ និង"ណែនាំទៅខាងតំបន់ឱ្យយកចិត្តទុកដាក់តាមដានសកម្មភាពនេះ"ដែល"សមាសភាព" មួយចំនួនត្រូវបានចាប់ខ្លួន ហើយថាវិធានការបន្ថែមទៀតនឹងត្រូវយកមកប្រើ ដើម្បីកំណត់ពី"ខ្សែបង្កប់នៅខាងក្នុង"។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ មានរបាយការណ៍មួយផ្ញើពីកងពល៨០១ ទៅឱ្យ សុន សេន ដោយរាយការណ៍អំពីខ្សែបង្កប់របស់ខ្មាំងនៅកងវរសេនាធំ៨៣ ដែលមានសកម្មភាពចម្បងគឺរិះគន់បដិវត្តន៍បក្សកុម្មុយនីស្តកម្ពុជា និងស្នើ"វិធានការខាងចាត់តាំង"ថា "អ្នកសង្ស័យថាខ្មាំង ត្រូវចាប់ដាច់ខាត" ហើយថាអ្នកដែលមាន"និន្នាការពាក់ព័ន្ធផ្នែកនយោបាយ" គឺអ្នកដែល"ប្រឆាំង" ចំពោះបដិវត្តន៍ ឬ

“មិនសកម្ម” នឹងត្រូវ“ដកដាក់មួយដុំ”។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ ភូមិភាគបស្ចិមបាន រាយការណ៍អំពី“សកម្មភាពបោសសម្អាតពួកអាក្បត់នៅក្នុងជួរ” ដែលបានបង្ហាញឈ្មោះ កម្មាភិបាលតំបន់ជាក់លាក់ ដែលត្រូវបញ្ជូនទៅមន្ទីរស-២១ និង“សមាសភាពផ្សេងទៀត ដែលសង្ស័យស្ពឹកស្រពន់ ឬក្បត់ដែរ តែស្រាល” ត្រូវយកមកទុក“មួយកន្លែងដើម្បីតាមដាន អប់រំ”។ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ មានរបាយការណ៍មួយពីភូមិភាគពាយ័ព្យ ដែលចម្លង ជូន **នួន ជា** និង **អៀង សារី** ពណ៌នាអំពីសភាពការណ៍ខ្មាំងមួយចំនួន និងបានអះអាងថា តំបន់ កំពុង“ខិតខំរកក្បាលម៉ាស៊ីនខ្មាំងតទៅទៀត”។

៨៤៩- នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ គឺមួយសប្តាហ៍បន្ទាប់ពីការចាប់ខ្លួនលេខាតំបន់១០៣ ឈ្មោះ ហង់ លេខាភូមិភាគឧត្តរបានរាយការណ៍ជូនគណៈ៨៧០ (រួមទាំង **នួន ជា** និង **អៀង សារី**) ថាខ្មាំងបានជ្រៀតខ្លួនចូល“ពីតំបន់ ស្រុក ដល់ឃុំ” ហើយគាត់នឹងទៅធ្វើការនៅតំបន់១០៣ និង “បញ្ជូនក្រពើជូនអង្គការចាត់តាំង”។ លុះរំលងបាន២ខែ មានរបាយការណ៍មួយរបស់លេខា ភូមិភាគឧត្តរគូសបញ្ជាក់ថាពួកគេបាន“បោសសម្អាតជាខ្សែសង្វាក់”នូវខ្មាំង ដែលទាក់ទងជា មួយអតីត“ប៉ូលិស ទាហាន និងរដ្ឋការ” និង“ប្រជាជនថ្មី” ហើយពួកគេបានរៀបចំផែនការបន្ត “ចាប់ពួកនេះតទៅទៀត” ។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ លេខាភូមិភាគឧត្តរបានលើក ឡើងអំពីការចាប់ខ្លួនលេខាតំបន់១០៣នាពេលកន្លងមក “ឈ្មោះ ហង់ និងបរិវាររបស់វានៅ ស្រុកជាំក្សាន្ត និងនៅយោធាតំបន់១០៣” និងបានរាយការណ៍ថាពួកគេ“កំពុងបោសសម្អាត ក្រុមដែលនៅសេសសល់ជាបន្តបន្ទាប់ រួមទាំងមនុស្សប្រឆាំងនឹងបដិវត្តន៍របស់យើង” ។

៨៥០- <u>ការសួរចម្លើយអ្នកជាប់ឃុំឃាំង</u>៖ ការប្រាស្រ័យទាក់ទងទៅកាន់មជ្ឈិមបក្ស តែងតែបានលើកឡើងអំពីការសួរចម្លើយអ្នកជាប់ឃុំឃាំង និងព័ត៌មានដែលទទួលបានពីចម្លើយសារភាព ឬ "ចម្លើយ" រួមទាំងអត្តសញ្ញាណរបស់មនុស្សផ្សេងៗដែលអ្នកជាប់ឃុំឃាំងបានឆ្លើយដាក់។ របាយការណ៍មួយចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ របស់លេខាកងពល ៩២០ ផ្ញើជូន សុន សេន និងចម្លងជូន **អៀង សារី** បានគូសបញ្ជាក់ថា "សមាសភាពមិនល្អចំនួន៥នាក់" ត្រូវបានចាប់ខ្លួន និងកំពុងត្រូវបានសួរចម្លើយ ហើយ"សំណុំឯកសារ" ស្តីពីករណីនេះនឹងត្រូវបញ្ជូន ទៅនៅពេលក្រោយ។ ទូរលេខ មួយចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦ របស់ភូមិភាគបូព៌ាផ្ញើជូន ប៉ុល ពត និងចម្លងជូន **នួន ជា** និង **អៀង សារី** បានរៀបរាប់អំពីការចាប់ខ្លួន និងការសួរចម្លើយ "ភ្នាក់ងារ"ម្នាក់ដែលបានបោកគ្រាប់បែកនៅប្រព័ន្ធភ្លើងស្រែ "យើងបានរឺសួរចម្លើយខ្សែចាត់តាំងរបស់វាបានចំនួនជាង២០នាក់ទៀត នៅតាមមូលដ្ឋានក្នុងស្រុកព្រះស្តេច។ របាយការណ៍មួយចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ ស្តីពីភូមិភាគព្រៃសាន បានរៀបរាប់លម្អិតអំពីលទ្ធផលនៃការសួរចម្លើយកម្មាភិបាលមូលដ្ឋានម្នាក់ ដែលមានជាប់ពាក់ព័ន្ធនឹងលេខាស្រុកម្នាក់ដែលកំពុងជាប់ឃុំឃាំងនៅឯមន្ទីរស-២១។ ក្នុងករណី ដែលមនុស្សដែលគេសួរចម្លើយរួច ត្រូវបានកំពុងបញ្ជូនទៅមជ្ឈិមបក្ស ឬមន្ទីរ ស-២១ ចម្លើយសារភាពរបស់ពួកគេនឹងត្រូវបញ្ជូនទៅ ក-៧ ជាមួយនឹងអ្នកជាប់ឃុំឃាំង។

៨៥១- <u>ការប្រហារជីវិត ពោលគឺ"ការកម្ទេច" ឬ"ការបោសសម្អាត"ខ្មាំង និងជនក្បត់</u>៖ ទូរលេខមួយចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៦ របស់ ហង់ លេខាតំបន់១០៣ ជូន ប៉ុល ពត ចម្លងជូន **នួន ជា** និង **អៀង សារី** បានពិភាក្សាអំពីក្រុមមួយដែល"បានវាយប្រហារមកលើរបបកុម្មុយនីស្ត

ចំពោះការលុបបំបាត់ប្រពៃណី ការធ្វើការងារគ្មានឈប់ និងការកំណត់របបស្រូវអង្ករ" និងបានរាយការណ៍ថាមនុស្សទាំងនេះ"ជាប់ពាក់ព័ន្ធ" នឹងជនក្បត់ចំនួន២នាក់ "ដែលត្រូវបានកម្ទេចរួចហើយ ដូចដែលបានរាយការណ៍ពីពេលមុន" ។ របាយការណ៍មួយចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៧ស្ដីពីភូមិភាគឦសានរបស់លេខាកងពលធំលេខ៨០១ បានគូសបញ្ជាក់ថាខ្មាំងដែលអង្គភាពយោធាបានចាប់ខ្លួនបញ្ជូនទៅតំបន់១០១ កំពុងត្រូវបានសម្លាប់ "ភ្លាមៗដោយពុំចាំបាច់សួរចម្លើយត្រឹមត្រូវឡើយ ដើម្បីស្រាវជ្រាវបណ្ដាញខ្មាំង"។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ តំបន់២២ បានរាយការណ៍ជូនមន្ទីរ៨៧០ ទាក់ទិននឹងក្រុមមួយដែលមានគ្នា៣០នាក់ ដែលមានអាវុធ នៅស្រុកមុខកំពូលដែលបានលួចអាហារ។ មន្ទីរ៨៧០ ក៏បានធ្វើការឆ្លើយតបនៅថ្ងៃបន្ទាប់ដោយអនុញ្ញាតឲ្យកម្មាភិបាលតំបន់"ចាត់វិធានការ"លើខ្មាំងទាំងនោះ។ នៅក្នុងរបាយការណ៍ប្រចាំខែ កក្កដា ឆ្នាំ១៩៧៨របស់ខ្លួន កម្មាភិបាលភូមិភាគបស្ចិមបានរាយការណ៍ថានៅតំបន់៣៧ ខ្លួនបាន"កម្ទេចយួនចំនួន១០០នាក់ ទាំងតូចទាំងធំ ទាំងក្មេងទាំងចាស់" និងសេអ៊ីអាចំនួន៦០នាក់"ដែលកំពុងលាក់ខ្លួននៅតាមអង្គភាព និងសហករណ៍"។ សកម្មភាពទាំងអស់នេះ ត្រូវបានអនុវត្តដើម្បីជម្រុញ"មាគ៌ាចាត់តាំងរបស់បក្សក្នុងការលុបបំបាត់ ការសម្រិតសម្រាំង និងការបោសសម្អាត"ខ្មាំងរបស់អង្គការ។

៨៥២- <u>ការបង្កបង្កើនផលស្រូវ និងការខ្វះស្បៀង</u>៖ របាយការណ៍ចុះខែឧសភា ឆ្នាំ១៩៧៧ របស់ភូមិភាគពាយ័ព្យបានជម្រាបប្រាប់អង្គការថា"ភាគច្រើន" នៃប្រជាជនមូលដ្ឋានបានទទួលត្រឹមតែ "បបររាវ" ហើយប្រជាជននៅតំបន់១ ២ ៤ ៦ និង៧ កំពុង"ជួបការខ្វះខាតច្រើនជាងគេ" ។ មួយឆ្នាំក្រោយមក ស្ថានភាពនៃការផ្គត់ផ្គង់ស្បៀងនៅភូមិភាគពាយ័ព្យ ពុំបានប្រសើរឡើងឡើយ ដូចដែលមន្ទីរភូមិភាគនេះបានរាយការណ៍នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ ថាស្រូវអង្ករដែល

បានផ្គត់ផ្គង់ទៅឱ្យតំបន់៥ បានអស់ហើយ ហើយតំបន់១ និងតំបន់៤ នឹងអស់ស្រូវនៅខែបន្ទាប់។ ទូរលេខមួយចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៧ របស់លេខាភូមិភាគបូព៌ា ផ្ញើជូន ប៉ុល ពត ចម្លងជូន **នួន ជា** និង **អៀង សារី** បានស្នើសុំឱ្យអង្គការផ្តល់អង្ករ "ជាបន្ទាន់" ដោយហេតុថា "របបអាហារប្រចាំថ្ងៃរបស់ពួកគេត្រូវបានបរិភោគអស់ហើយ"។ ទូរលេខស្រដៀងគ្នាមួយចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ បានរាយការណ៍ថា"ប្រជាជននៅតាមសហករណ៍និងពលករយ៉ាងច្រើន"នៅឆ្លូង និងក្រូចឆ្មារ កំពុងជួបការខ្វះខាតស្បៀង ដោយសារសភាពការណ៍យោធានៅតំបន់នោះ។

៨៥៣- <u>ស្ថានភាពសុខាភិបាលយ៉ាប់យ៉ឺន និងការខ្វះថ្នាំសង្កូវ</u>៖នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៧ ភូមិភាគនិរតីបានរាយការណ៍ថា "នៅខេត្តកំពត កំពង់ស្ពឺ និងតាកែវ ប្រជាជនបានកើតជំងឺអាសន្នរោគ ហើយខ្លះទៀតបានស្លាប់"។ របាយការណ៍មួយចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ របស់លេខាភូមិភាគពាយ័ព្យបានគូសបញ្ជាក់ថាគាត់ពុំអាចទទួលការព្យាបាលបានឡើយ ពីព្រោះ "ពេទ្យមានវ័យក្មេងដែលបានរៀនសូត្រត្រឹមតែអំពីវិធីពិនិត្យសម្ពាធឈាម និងចាក់ថ្នាំប៉ុណ្ណោះ"។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ ភូមិភាគបស្ចិមបានរាយការណ៍ថាប្រជាជននៅតាមមូលដ្ឋានខ្លះបានកើត"ជំងឺគ្រុនក្តៅ រាករូស និងហើម" ហើយនៅតំបន់៣៧ ប្រជាជនឈឺច្រើនជាងខែមុន ពីព្រោះពួកគេត្រូវបានទាមទារឱ្យ"ខំប្រឹងធ្វើការរាល់ថ្ងៃ" ដោយស្ទូងស្រូវក្រោមភ្លៀង។

៨៥៤- <u>ការសាងសង់ទំនប់ ប្រឡាយ និងអាងស្តុកទឹក</u>៖ ជាទៀងទាត់ ភូមិភាគតែងបានរាយការណ៍ស្តីពីស្ថានភាព ទំនប់ ភ្លឺ និងផែនការការងារដោយបង្ខំទ្រង់ទ្រាយធំផ្សេងៗ ក្រោមការចង្អុល

ណែនាំរបស់មជ្ឈិមបក្ស។ ជាក់ស្តែង របាយការណ៍មួយចុះថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ របស់ភូមិភាគកណ្តាលបានគូសបញ្ជាក់ថា"បងប្អូននៅទូទាំងភូមិភាគ ទាំងចាស់ ទាំងក្មេងកំពុងស្វាហាប់សម្រុកកសាងប្រព័ន្ធភ្លឺស្រែថ្មី តាមគោលដៅរបស់អង្គការ"។ បើទោះបីជាយ៉ាងដូច្នេះក្តី របាយការណ៍នេះក៏បានគូសបញ្ជាក់ថា"ជំងឺគ្រុនក្តៅ និងរាគរូស" បានកើតរាតត្បាត ដោយសារប្រជាជន"ធ្វើការ និងកម្តៅក្តៅខ្លាំង" ដូច្នេះលេខាភូមិភាគបានលើកឡើងអំពី លទ្ធភាពនៃ"ការកាត់បន្ថយម៉ោងធ្វើការ"។ របាយការណ៍មួយចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ របស់ភូមិភាគឧត្តរ ចម្លងជូន **នួន** ជា និង **អៀង សារី** បានបញ្ជាក់ថានៅការដ្ឋានទំនប់ "ផលិតភាពមានល្បឿនលឿនជាងកាលឆ្នាំ១៩៧៧ ចំនួនពី២ ទៅ៣ដង" បើទោះបីជាមាន "មនុស្សជាច្រើន" បាន "ធ្លាក់ខ្លួនឈឺដោយសាររដូវនេះក្តៅខ្លាំងពេក"ក្តី ។

៨៥៥- <u>ការខិតខំបង្កើនចំនួនប្រជាជនតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ</u>៖ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ មន្ទីរភូមិភាគបស្ចិមបានរាយការណ៍ប្រាប់អង្គការថា"គ្រួសារថ្មីចំនួន១០ ត្រូវបានបង្កើតឡើងនៅស្រុក២៦ តំបន់៣២"។ បន្ទាប់មក ពុំមានព័ត៌មានណាមួយស្តីពីតំបន់ ៣១ និង៣៧ ឡើយ។ ក្នុងរបាយការណ៍ប្រចាំខែកក្កដា ឆ្នាំ១៩៧៨ របស់ខ្លួន ភូមិភាគបស្ចិមបានរាយការណ៍ថានៅតំបន់៣២ កាលពីខែនោះ មានទារកទើបកើតចំនួន១៨៥នាក់ មានមនុស្សចំនួន១២១ បានស្លាប់ និងមានប្តីប្រពន្ធរៀបការចំនួន៤២គូ។

៨៥៦- <u>ជម្លោះប្រដាប់អាវុធជាមួយវៀតណាម</u>៖ របាយការណ៍មួយចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ របស់ភូមិភាគបូព៌ា បានបញ្ជាក់ថាការជួបប្រជុំ"កម្មាភិបាលយោធាទាំងអស់មកពីគ្រប់ភូមិភាគ តំបន់ និងស្រុក" ត្រូវបានធ្វើឡើងមួយថ្ងៃមុនដើម្បីផ្សព្វផ្សាយការណែនាំរបស់អង្គការ "ស្តីពីការ

វាយប្រហារប្រឆាំងនឹងការឈ្លានពានរបស់ខ្មាំងចូលក្នុងទឹកដីរបស់យើង" ហើយបានរាយរណ៍ថា ប្រតិបត្តិការយោធាជាបន្តបន្ទាប់ក្បែរត្រពាំងផ្លុងបានទទួលជោគជ័យ។

## ឯកសារបោះពុម្ពផ្សាយ និងការផ្សាយតាមវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជា

៨៥៧- ក្នុងឯកសារបោះពុម្ពផ្សាយប្រចាំខែរបស់បក្សកុម្មុយនីស្តកម្ពុជា *ទង់បដិវត្ត* និង*យុវជនបដិវត្ត* ក៏មានកំណត់ហេតុបញ្ជាក់អំពីការដឹងឮរបស់មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា អំពីឧក្រិដ្ឋកម្មដែរ។ ឧទាហរណ៍ ទស្សនាវដ្តី *យុវជនបដិវត្តន៍* លេខចេញផ្សាយខែកក្កដា ឆ្នាំ១៩៧៥ បានចាត់ទុកការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថាជាវិធានការចាំបាច់ ដើម្បី"ទប់ស្កាត់ការបំពុលមនោគមក្នុងជួរបដិវត្តន៍ដែលគេមិនអាចគ្រប់គ្រងបាន"។ ជាទៀងទាត់ ឯកសារបោះពុម្ពផ្សាយទាំងនេះ តែងបានលើកយកមកពិភាក្សាអំពីការប្រើប្រាស់កម្លាំងមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ដើម្បីផលិតស្រូវឱ្យបានពី៣ ទៅ៦តោនក្នុង១ហិកតា និងដើម្បីសាងសង់អាងស្តុកទឹក ប្រឡាយ និងប្រព័ន្ធភ្លឺស្រែជាដើម។ ពួកគេបានលើកឡើងអំពីការប្រើប្រាស់ កម្លាំងកុមារ និងមនុស្សចាស់ ការពឹងផ្អែកទៅលើកម្លាំងពលកម្មដែលខុសពីយន្តកម្ម និងការធ្វើការនៅពេលថ្ងៃ និងពេលយប់។ បញ្ហាជាច្រើនបានទទួលស្គាល់អំពីអត្ថិភាពនៃការខ្វះស្បៀង និងទឹក។ ឯកសារបោះពុម្ពផ្សាយទាំងនេះ បានលើកឡើងផ្ទាល់អំពីការបោសសម្អាត និងបន្សុទ្ធកម្មក្នុងរចនាសម្ព័ន្ធបក្ស និងបានណែនាំឱ្យកម្មាភិបាលកម្ទេច និងបោសសម្អាតខ្មាំងយួន។

៨៥៨- ការផ្សាយសំឡេងតាមវិទ្យុរបស់របបកម្ពុជាប្រជាធិបតេយ្យ តាមរយៈស្ថានីយវិទ្យុរបស់ខ្លួន Phnom Penh Domestic Service (ឬហៅថា Phnom Penh Home Service) ក៏បញ្ជាក់ផងដែរ អំពីការដឹងឮរបស់មេដឹកនាំជាន់ខ្ពស់អំពីឧក្រិដ្ឋកម្មផ្សេងៗ។ ជាក់ស្តែង"ចម្លើយ

សារភាព"ជាច្រើនរបស់ឈ្លើយសឹកវៀតណាម ដែលបានរងទារុណកម្ម និងការប្រហារជីវិតនៅ ឯមន្ទីរស-២១ ត្រូវបានចាក់ផ្សាយតាម Phnom Penh Domestic Service។

## សន្ទរកថា និងការសម្ភាសន៍

៨៥៩- សន្ទរកថា និងការសម្ភាសន៍ជាច្រើនជាមួយមេដឹកនាំជាន់ខ្ពស់នៃរបបនេះ បញ្ជាក់អំពីការដឹងឮផ្ទាល់របស់ពួកគេអំពីឧក្រិដ្ឋកម្ម រួមទាំងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង និងការបង្ខាំងប្រជាជនស៊ីវិលទុកក្នុងសហករណ៍ និងការដ្ឋាន ការប្រើប្រាស់ការងារពលកម្មដោយបង្ខំ និងគោលនយោបាយនៃការបោសសម្អាតខ្មាំង ដែលកំពុងត្រូវបានបោសសម្អាតយ៉ាងសកម្មនៅគ្រប់ជាន់ថ្នាក់ និងគ្រប់ផ្នែកនៃប្រទេសតាមការណែនាំរបស់មជ្ឈិមបក្ស។

៨៦០- ឧទាហរណ៍ នៅក្នុងកិច្ចសម្ភាសន៍មួយនៅឆ្នាំ១៩៧៧ **អៀង សារី** បានបញ្ជាក់អះអាងថារាល់គ្រប់ទីប្រជុំជនសំខាន់ៗទាំងអស់នៅកម្ពុជា ត្រូវបានជម្លៀសនៅឆ្នាំ១៩៧៥ និងបានទទួលស្គាល់ថាមនុស្សយ៉ាងហោចណាស់ចំនួនពី២០០០ ទៅ៣០០០នាក់ បានស្លាប់នៅក្នុងការជម្លៀសទីក្រុងភ្នំពេញ។ នៅឆ្នាំ១៩៧៧ **ខៀវ សំផន** បានទទួលស្គាល់ថានៅឆ្នាំ១៩៧៥ មានបញ្ហាខ្វះ ស្បៀង ហើយប្រជាជនស៊ីវិលបានទទួលរងទុក្ខវេទនាជាច្រើន។ គាត់ក៏បានទទួលស្គាល់ថា ជាផ្នែកមួយនៃគម្រោងកសាងដ៏មហិមារបស់របបនោះ គេពុំបានប្រើប្រាស់ម៉ាស៊ីនឡើយ ហើយពឹងផ្អែកតែកម្លាំងមនុស្សមួយមុខប៉ុណ្ណោះ។ គាត់បានបញ្ជាក់ថា "ពលករក្នុងចំនួនរហូតដល់១០០០០ ២០០០០ ឬ៣០០០០នាក់" ត្រូវបានគេប្រើឱ្យសាងសង់អាងស្តុកទឹកទំនប់ និងប្រឡាយ។

៨៦១- **អៀង ធីរិទ្ធ** បានថ្លែងសន្ទរកថានៅឆ្នាំ១៩៧៥ ទៅកាន់កម្មាភិបាលបក្សក្នុងអំឡុងវគ្គរៀនសូត្រនយោបាយ ដែលក្នុងនោះគាត់បានគាំទ្រពេញទំហឹង និងចាត់ទុកការជម្លៀសប្រជាជនចេញពីទី

ក្រុង ការបង្កើតសហករណ៍នៅតាមជនបទ ដើម្បីទទួលប្រជាជនជម្លៀស និងការពុំចាយលុយ ថាជាមធ្យោបាយមួយប្រឆាំងនឹងពួកនាយទុន ពួកចក្រពត្តិ ពួកស្នូនតួ និងភ្នាក់ងារដែល ប៉ុនប៉ងចង់ធ្វើវិទ្ធង្សនាបង្កគ្រោះថ្នាក់ដល់របបថ្មី។ នៅឆ្នាំ១៩៧៧ **អៀង ធីរិទ្ធ** ក៏បានថ្លែង សន្ទរកថាទៅកាន់ប្រតិភូបរទេសដែលក្នុងពេលនោះ គាត់បានចាត់ទុកជាពិសេសអំពីនារីខ្មែរថា ជាពលករសម្បូហភាពដែលបានចូលរួមកសាងបណ្តាញភ្លឺស្រែ ទំនប់ ប្រឡាយធារាសាស្ត្រព្រែក និងអាងស្តុកទឹក និងបានកោតសរសើរដល់ប្រជាជនកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា ចំពោះ "ការវាយតបតវាល់ខបាយកលជាច្រើនរបស់ខ្មាំង [ហើយ] និងបានបំផ្លាញបណ្តាញចារកម្ម របស់ខ្មាំង" ។

៨៦២- សន្ទរកថារបស់មេដឹកនាំក៏បានបញ្ជាក់អះអាងផងដែរ អំពីការដឹងឮរបស់ពួកគេអំពីការខិតខំរួម គ្នាដើម្បីបោសសម្អាត និងកម្ចាត់វាល់ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ជាក់ស្តែង សន្ទរកថា ទាំងអស់នោះ បានសង្កត់ធ្ងន់អំពីសារសំខាន់នៃការពង្រឹងការការពារផ្ទៃក្នុង តាមរយៈការលើក កម្ពស់ការប្រុងប្រយ័ត្នបដិវត្តន៍ និងការកម្ទេចខ្មាំងគ្រប់ប្រភេទ និងតម្រូវការឲ្យមានការលត់ដំ និងតម្រង់ទិសក្នុងជួរបក្ស។ នៅក្នុងសន្ទរកថាមួយនៅឆ្នាំ១៩៧៧ ដូចដែលបានលើកឡើងពីខាង លើ **ខៀវ សំផន** បានគូសបញ្ជាក់ថា "យើងត្រូវបោសសម្អាតខ្មាំង ក្នុងឋានៈជាម្ចាស់ សភាពការណ៍ ស្របតាមមាគ៌ាគោលនយោបាយជាតិ គោលនយោបាយការបរទេស និងគោល នយោបាយយោធារបស់អង្គការចាត់តាំងបដិវត្តន៍របស់យើង" ហើយភារកិច្ចនេះ"ត្រូវអនុវត្តឲ្យ បានខ្ជាប់ខ្ជួន និងដោយការផ្ចិតផ្ចង់"។ ក្នុងកិច្ចសម្ភាសន៍មួយជាមួយសមាគមន៍កម្ពុជា បែលហ្ស៊ិកចេញផ្សាយដោយ Phnom Penh Domestic Service (ឬហៅថា Phnom

Penh Home Service) ប៉ុល ពត បានទទួលស្គាល់ថាអង្គការចាត់តាំង និងទីភ្នាក់ងារសន្តិសុខពិតជាបានមានអត្ថិភាព ហើយបានការជួយជ្រោមជ្រែងពីសំណាក់កងទ័ព។

៨៦៣- ទាំងនេះគឺជាឧទាហរណ៍នៃកំណត់ហេតុជាន់ខ្ពស់ ស្តីពីគោលនយោបាយរបស់មជ្ឈិមបក្សដែលកំពុងត្រូវបានអនុវត្តនាពេលនោះ នៅតាមមន្ទីរសន្តិសុខ ការដ្ឋាន និងអង្គភាពយោធា និងរដ្ឋបាលនៅទូទាំងប្រទេស។ ជាឧទាហរណ៍ គោលនយោបាយនេះ កំពុងត្រូវបានអនុវត្ត នៅឯមន្ទីរស-២១ដែលជាទីកន្លែងត្រូវបានយកមកប្រើប្រាស់ ធ្វើជាផ្នែកមួយនៃការហ្វឹកហ្វឺននយោបាយដល់កម្មាភិបាលដែលជាអ្នកអនុវត្តការធ្វើទារុណកម្ម និងការប្រហារជីវិត ទៅលើ "ខ្មាំង"នៃរបបនោះ។

## ឯកសារអន្តរជាតិ

### រដ្ឋាភិបាលនានា អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល

៨៦៤- រដ្ឋាភិបាលបរទេស អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានចេញនូវការផ្តន្ទាទោស ជាសាធារណៈជាច្រើន ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលស្ថិតក្រោមការស៊ើបអង្កេត។ នៅដើមខែឧសភា ឆ្នាំ១៩៧៥ ប្រធានាធិបតីសហរដ្ឋអាមេរិក Gerald Ford មានការ "ការខ្វាយខ្វល់ជាខ្លាំង" ចំពោះភស្តុតាងស្តីពីការសម្លាប់មនុស្សពីសំណាក់ របបកម្ពុជាប្រជាធិបតេយ្យដ៏ច្រើនសម្បើម ជាពិសេសគឺការសម្លាប់ អតីតមន្ត្រីរដ្ឋាភិបាល រួមទាំងភរិយារបស់មន្ត្រីទាំងនោះ។ រដ្ឋមន្ត្រី Henry Kissinger បានថ្លែងនៅក្នុងខែឧសភា ឆ្នាំ១៩៧៥ថា សហរដ្ឋអាមេរិកនឹងមិនទាន់ទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យភ្លាមៗទេ ដោយសារតែ "យើងដឹងថា នៅក្នុងប្រទេសកម្ពុជា សោកនាដកម្ម

និងអមនុស្សធម៌ ព្រមទាំងភាពក្រខ្សត់កំពុងតែកើតមានឡើង”។ គាត់ក៏បានលើកឡើងពីការព្រួយបារម្ភនានារបស់គាត់ ចំពោះការជម្លៀសចេញពីទីក្រុងភ្នំពេញ និងពីបណ្តាក្រុងផ្សេងៗទៀត ភាពអត់ឃ្លានដែលមាននៅក្នុងប្រទេស និងការកាប់សម្លាប់ដែលរបបកម្ពុជាប្រជាធិបតេយ្យជាអ្នកបង្ក។ ប្រធានាធិបតីសហរដ្ឋអាមេរិក Jimmy Carter បានប្រសិទ្ធិនាមឲ្យរបបកម្ពុជាប្រជាធិបតេយ្យថា “អ្នកដែលរំលោភសិទ្ធមនុស្សខ្លាំងជាងគេបំផុត” ដោយជំទាស់នឹង“ការគ្រប់គ្រងអំណាចគួរឲ្យភ័យខ្លាច”របស់របបនោះ ដែលបានសម្លាប់ប្រជាជនកម្ពុជាប្រមាណជាងមួយលាននាក់។ នាដើមឆ្នាំ១៩៧៨ អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក Warren Christopher បានចោទប្រកាន់ទៅលើរដ្ឋាភិបាលកម្ពុជាចំពោះការប្រព្រឹត្តមួយក្នុងចំណោម “ការរំលោភបំពានដ៏ខ្លាំងក្លាបំផុតទៅលើសិទ្ធមនុស្ស ដែលកើតមានលើពិភពលោកនាពេលបច្ចុប្បន្ននេះ”។ សូម្បីតែការប្រឆាំងតបតរបស់ លន់ នល់ចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមានការសម្លាប់ក្នុងទ្រង់ទ្រាយធំ និងការសម្លាប់ប្អូនប្រុសរបស់គាត់បង្កើត ព្រមទាំងការស្នើសុំឲ្យមានអន្តរាគមន៍ពីកម្លាំងយោធាក៏ត្រូវសារព័ត៌មានចុះផ្សាយផងដែរ។

៨៦៥- ក្នុងរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ មានវិធានការការទូតជាច្រើនត្រូវបានដាក់ចេញ ដើម្បីប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ធនាគារពិភពលោកបានកម្រិតកម្ចី ចំពោះកម្ពុជាប្រជាធិបតេយ្យ ដោយសារការរំលោភសិទ្ធិមនុស្សជាក់ស្តែងរបស់របបនេះ។ ប្រទេសភូមា និងសហរដ្ឋអាមេរិកបានដាក់កម្រិតជំនួយសម្រាប់ការអភិវឌ្ឍន៍នៅកម្ពុជា ដោយសារហេតុផលដូចគ្នានេះដែរ សហរដ្ឋអាមេរិកបានចាត់ទុក ប៉ុល ពត ជា “អ្នកកាន់អំណាចផ្តាច់ការដែលបណ្តាលឲ្យមានការស្លាប់ និងការលំបាកវេទនា ព្រមទាំង... អ្នកកាន់អំណាច

ព្រៃផ្សៃ"។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៧ ចក្រភពអង់គ្លេសបានជូនដំណឹងទៅរដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យ ចំពោះការបដិសេធក្នុងការតែងតាំងឯកអគ្គរាជទូតរបស់ខ្លួនទៅកាន់ប្រទេសកម្ពុជា ដោយសារតែការកើតមាននូវព្រឹត្តិការណ៍ដែល"ធ្ងន់ធ្ងរ ប្រៀបដូចជាការជិះជាន់កៀបសង្កត់របស់ Stalin ទៅលើ kulaks និងការកំចាត់របស់ Hitler ទៅលើពួកJews អញ្ចឹង" ដោយបានបញ្ជាក់បន្ថែមទៀតថា នឹងលើកយកការរំលោភបំពានទាំងនេះទៅជូនគណៈកម្មការសិទ្ធមនុស្សអង្គការសហប្រជាជាតិនាពេលឆាប់ៗនេះ។ ក្នុងឆ្នាំ១៩៧៨ សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកចំនួន៨០រូប បានគាំទ្រឲ្យមានការសហការពួតដៃគ្នារវាងយោធាអន្តរជាតិដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏បានអំពាវនាវដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ អំពីបញ្ហាផ្លូវច្បាប់ស្តីពីរបបប្រល័យពូជសាសន៍ និងការអន្តរាគមន៍យោធាផងដែរ។ ក្នុងឆ្នាំ១៩៧៧ សភាប្រទេសកាណាដា បានអនុម័តនូវសេចក្តីសម្រេចមួយ ដោយថ្កោលទោសចំពោះការស្លាប់របស់ប្រជាជនកម្ពុជាចំនួន២លាននាក់។

៨៦៦- ស្ថានភាពនៅប្រទេសកម្ពុជា ត្រូវបានគេលើកយកមកពិភាក្សាយ៉ាងទូលំទូលាយ នៅអង្គការសហប្រជាជាតិ ជាពិសេសនៅក្នុងសម័យប្រជុំលើកទី៣១ ស្តីពីអនុគណៈកម្មការរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអំពីការទប់ស្កាត់ចំពោះការរើសអើង និងការការពារជនជាតិភាគតិច ដែលនៅក្នុងសម័យប្រជុំនោះ មានប្រទេសជាច្រើនបានដាក់នូវរបាយការណ៍ស្តីពីព្រឹត្តិការណ៍ដែលកើតមាននៅក្នុងប្រទេសកម្ពុជា។ សំណើរបស់សហរដ្ឋអាមេរិក មានបង្ហាញនូវបទសម្ភាសន៍ជាមួយនឹងជនភៀសខ្លួនកម្ពុជាជាច្រើនអ្នកដែលស្ថិតនៅក្នុងប្រទេសថៃ ដោយពួកគេទាំងនោះ បានរៀបរាប់ពីជីវិតរបស់ខ្លួនក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដោយរួមមាន ការចោទប្រកាន់ពីការជម្លៀសដោយបង្ខំ និងប្រើពលកម្មដោយបង្ខំ ការសម្លាប់ទាំងគ្រួសារ និងការ

បោសសម្អាតអតីតសមាជិកនៃរបបសាធារណរដ្ឋខ្មែរជាដើម។ សំណើរបស់ប្រទេសកាណាដា ក៏បានបង្ហាញនូវរឿងរ៉ាវមួយចំនួនរបស់ជនភៀសខ្លួនផងដែរ ដោយបានរាយការណ៍ពី ការរំលោភបំពានសេចក្តីប្រកាសសិទ្ធិមនុស្សជាសាកលរបស់របបកម្ពុជាប្រជាធិបតេយ្យ តាម រយៈការអនុវត្តន៍នូវការរំលោភបំពានដែលក្នុងចំណោមនោះមាន ការចាប់ខ្លួន ធ្វើទារុណកម្ម ការ សម្លាប់ ការបោសសម្អាតអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងការធ្វើទុក្ខបុកម្នេញលើ សាសនា។ សំណើរបស់ចក្រភពអង់គ្លេស បានរៀបរាប់លម្អិតពីការជម្លៀសដោយបង្ខំពីទីក្រុង ភ្នំពេញ ការសម្លាប់ និងការបោសសម្អាតអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងបានផ្តល់ ព័ត៌មានលម្អិតពីរឿងរ៉ាវរបស់ជនភៀសខ្លួនស្តីពី ការប្រើពលកម្មដោយបង្ខំ ការចាប់ខ្លួន និង ស្ថានភាពរស់នៅបែបអមនុស្សធម៌នៅក្នុងប្រទេសនោះ។ សំណើរបស់រដ្ឋាភិបាលប្រទេសនរវ៉េ ក៏បានបង្ហាញផងដែរពីការរៀបរាប់របស់ជនភៀសខ្លួន និងអ្នកជំនាញមួយចំនួន *ដែល ក្នុងចំណោមនោះ* បានចោទប្រកាន់ពីការចាប់ខ្លួន ការកើតមាននូវមន្ទីរសន្តិសុខ ការសម្លាប់ ការជម្លៀសដោយបង្ខំ ការប្រើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅបែបអមនុស្សធម៌ រួមមាន ភាពអត់ឃ្លាន និងជំងឺ ការបោសសម្អាត និងការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ ជាដើម។

៨៦៧- **អៀង សារី** តំណាងឲ្យរបបកម្ពុជាប្រជាធិបតេយ្យ បានឆ្លើយតបទៅនឹងការចោទប្រកាន់ទាំង នេះ តាមរយៈលិខិតមួយផ្ញើទៅជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលលិខិតនោះត្រូវ បានគេចែកចាយទៅអង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកទាំងអស់ ដោយបានលើកឡើង ពីការរិះគន់ទៅលើរបបកម្ពុជាប្រជាធិបតេយ្យនេះ ជា“ពាក្យបង្កាច់បង្ខូច និងបន្ទុះបង្អាប់កម្ពុជា ប្រជាធិបតេយ្យ” តាមរយៈ“ក្បាលម៉ាស៊ីនឃោសនារបស់ពួកចក្រពត្តិនិយម ពួកឈ្លានពាននិយម និង ពួកវាតទីនិយម”។

៨៦៨- អង្គការលើកលែងទោសអន្តរជាតិ បានរាយការណ៍ពីការសម្លាប់យ៉ាងទូលំទូលាយ នៅក្នុងប្រទេសកម្ពុជា រួមទាំងការសម្លាប់ "មហាជនក្បត់" ០៧រូប របស់អតីតរបបសាធារណរដ្ឋខ្មែរ នៅដើមឆ្នាំ១៩៧៦ផងដែរ។ ដូចមានបញ្ជាក់នៅក្នុងលិខិតចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ អង្គការលើកលែងទោសអន្តរជាតិ បានផ្ញើលិខិតមួយច្បាប់លើកដំបូង ទៅឱ្យរបបកម្ពុជាប្រជាធិបតេយ្យ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៦ ដោយបានបង្ហាញពីការព្រួយបារម្ភចំពោះការចោទប្រកាន់ពីឧក្រិដ្ឋកម្មនានា ដែលបានកើតមាននៅក្នុងប្រទេស។ រដ្ឋាភិបាលនៃរបបនោះមិនបានឆ្លើយតបចំពោះលិខិតផ្ញើទៅលើកដំបូងនោះទេ។ នៅក្នុងលិខិតមួយច្បាប់ផ្ញើជូន លោក **ខៀវ សំផន** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ អង្គការនោះបានអំពាវនាវឱ្យរបបនេះបកស្រាយចំពោះស្ថានភាពសិទ្ធមនុស្សនៅប្រទេសកម្ពុជា ហើយជាពិសេស ចំពោះករណីដែលមានពាក់ព័ន្ធនឹងការបញ្ជូនខ្លួនជនភៀសខ្លួនចំនួន២៦នាក់ ពីប្រទេសថៃមកប្រទេសកម្ពុជាវិញ។ លិខិតនេះ បានស្នើរដ្ឋាភិបាលនៃរបបនោះ ផ្តោតការយកចិត្តទុកដាក់ ចំពោះរបាយការណ៍ដែលកើតមានជាបន្តបន្ទាប់ ស្តីពីការការគំរាម កំហែងប្រព្រឹត្តិអំពើឃោរឃៅ ពីសំណាក់អ្នកកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ និងការគំរាមកំហែងដល់អ្នកដែលគេសង្ស័យថាជា "ខ្មាំង" ដោយត្រូវគេបញ្ជូនទៅកន្លែងដែលគ្មាននរណាដឹង ក៏ដូចជាភស្តុតាងសង្ខេបពីការសម្លាប់ និងស្ថានភាពអមនុស្សធម៌នានា រួមមាន ការអត់ ឃ្លាន និងខ្វះថ្នាំសង្កូវព្យាបាលជំងឺជាដើម។ ដូចនៅក្នុងលិខិតដំបូងដែរ លិខិតច្បាប់នេះក៏មិនបានទទួលការឆ្លើយតបពីរដ្ឋាភិបាលនៃរបបនោះដែរ។

៨៦៩- ក្នុងឆ្នាំ១៩៧៨ អង្គការលើកលែងទោសអន្តរជាតិ បានអំពាវនាវឱ្យរបបកម្ពុជាប្រជាធិបតេយ្យឆ្លើយតបចំពោះការចោទប្រកាន់ពីការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ដែលមានប្រជាជនកម្ពុជាចំនួនលើសពី១០០.០០០នាក់ ការសម្លាប់អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងការជម្លៀសដោយបង្ខំជាដើម។ នៅក្នុងខែសីហា ឆ្នាំ១៩៧៨ អង្គការលើកលែងទោសអន្តរជាតិ ក៏បានផ្ញើលិខិតទៅកាន់គណៈកម្មការសិទ្ធមនុស្សអង្គការសហប្រជាជាតិផងដែរ ដោយបានបង្ហាញពីភស្តុតាងពីការប្រព្រឹត្តិបែបអមនុស្សធម៌ ការធ្វើទុក្ខបុកម្នេញលើសាសនា ការចាប់ខ្លួន និងការបាត់ខ្លួន ការសម្លាប់ និងការបោសសម្អាតទៅលើកម្មាភិបាល ប.ក.ក ដោយរបបកម្ពុជាប្រជាធិបតេយ្យបានស្វាគមន៍នូវគ្រប់ដំណាក់កាលទាំងអស់ ក្នុងការអនុញ្ញាតឱ្យអ្នកសង្កេតការឯករាជ្យចូលមកស៊ើបអង្កេតពីការរំលោភសិទ្ធមនុស្ស និងដើម្បីបង្កើតនូវយន្តការនានា ក្នុងគោលបំណងការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ ក៏បានដកស្រង់សេចក្តីថ្លែងការណ៍ផ្សេងៗ ជាច្រើនរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមមាន សេចក្តីថ្លែងការណ៍របស់ ប៉ុល ពត ធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ដែលបានលើកឡើងថា សមាសភាពប្រតិកិរិយាដែលមានប្រមាណពីមួយ ទៅពីរភាគរយនៃប្រជាជនទាំងមូល ត្រូវយកទៅលត់ដំ ឬកំចាត់ចោល។

## សារព័ត៌មានអន្តរជាតិ

៨៧០- សំណុំរឿងក្តីនេះ មានបញ្ចូលនូវភស្តុតាងស្តីពីព្រឹត្តិការណ៍នានា ដែលគ្រប់ដណ្តប់លើប្រទេសកម្ពុជាក្នុងរវាងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជាបន្តបន្ទាប់ តាមរយៈការផ្សព្វផ្សាយរបស់ស្ថាប័នសារព័ត៌មានផ្សេងៗជាច្រើន ជាពិសេស ស្ថាប័នសារព័ត៌មានមកពីសហរដ្ឋអាមេរិក ដូចជា

New York Times Los Angeles Times Washingtong Post Chicago Tribune និង Newsweek។ នៅមានប្រភពព័ត៌មានអន្តរជាតិ និងបរទេសផ្សេងៗទៀត ដែលបានផ្សព្វផ្សាយពីព្រឹត្តិការណ៍ដែលកើតមាននៅក្នុងប្រទេសកម្ពុជា រួមមាន British Broadcasting Corporation, Le Monde Reuters Far Eastern Economic Review Bangkok Post Straits Times និង Hong Kong Standard។

៨៧១- ការបោះពុម្ពផ្សាយព័ត៌មានទាំងនេះ បានរាយការណ៍ពីភស្តុតាងឧក្រិដ្ឋកម្មផ្សេងៗ ដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តឡើង រួមមានការការកាប់សម្លាប់ជនស៊ីវិល និងអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ការបោសសម្អាតកម្មាភិបាលរបស់ ប.ក.ក ការចាប់ខ្លួន ធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការប្រើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅបែបអមនុស្សធម៌ និងការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ដូចជាព្រះវិហារពុទ្ធសាសនាជាដើម។ ឧទាហរណ៍ The Wall Street Journal បានរាយការណ៍នៅក្នុងខែមេសា ឆ្នាំ១៩៧៦ ពីការធ្វើបាបទៅលើប្រជាជន តាមរយៈការជម្លៀស ការប្រើពលកម្មដោយបង្ខំ និងការសម្លាប់ក្នុងទ្រង់ទ្រាយធំ បណ្តាលឱ្យមានមនុស្សស្លាប់ចំនួន៨០០០០០នាក់។ The Washington Post បានធ្វើការ បរិយាយនៅក្នុងខែមេសា ឆ្នាំ១៩៧៥ បានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទាំងបង្ខំ ដែលគេហៅថា "ដំណើរឆ្ពោះទៅកាន់មរណៈ"។ A Los Angeles Times បានរាយការណ៍នៅ ឆ្នាំ១៩៧៨បង្ហាញពីការកាប់សម្លាប់ដែលបានកើតជាទម្រង់ធម្មតានៃការធ្វើទណ្ឌកម្មសម្រាប់ការប្រព្រឹត្តបទល្មើសតូចតាចបំផុតនានា ដូចជាការតវ៉ា ឬការមកធ្វើការយឺត។ អត្ថបទនៃសារព័ត៌មាន Washington Post មួយ ដែលចុះផ្សាយក្នុងឆ្នាំ១៩៧៨ បានហៅបដិវត្តន៍កម្ពុជាថាជាបដិវត្តន៍"បង្ហូរឈាមច្រើនជាងគេបំផុតប្រចាំ

សតវត្សរ៍"។ របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេស្គាល់ ជាទូទៅថាជាអ្នកដែលរំលោភសិទ្ធិមនុស្សខ្លាំងជាងគេបំផុតនៅលើពិភពលោក និងជាពួកព្រៃផ្សៃនៅពេលដែលស្ថានភាពនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេហៅជាញឹកញាប់ថាជា"ផ្នូកឈាម"មួយ ព្រមទាំងត្រូវគេប្រៀបធៀបទៅនឹងការប្រល័យជីវិតជនជាតិ Jewish នៅ Nazi ប្រទេសអាល្លឺម៉ង់។ ប្រទេសកម្ពុជាត្រូវបានគេប្រសិទ្ធិនាមថា "ទឹកដីនៃជំរុំប្រមូលផ្តុំ"។ សាព័ត៌មាន ក៏បានរាយការណ៍យ៉ាងទូលំទូលាយ ពីជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ផងដែរ។

៨៧២- សេចក្តីរាយការណ៍របស់សារព័ត៌មានទាំងនេះ មានភាពស៊ីសង្វាក់ទៅនឹងការបោះពុម្ពផ្សាយសាព័ត៌មាន មុនខែមេសា ឆ្នាំ១៩៧៥ ដែលជាភស្តុតាងបង្ហាញពីដំណើរប្រព្រឹត្តទៅរបស់ ប.ក.ក ដែលមានលក្ខណៈស៊ីសង្វាក់ជាមួយនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្ទាប់ពីពេលនោះ។ ឧទាហរណ៍ អត្ថបទរបស់សារព័ត៌មានឡាវមួយ ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៤ បានបង្ហាញថា ខ្មែរក្រហម បានហាមប្រាមយុវជនជនបទមិនឱ្យគោរពចាស់ព្រឹទ្ធាចារ្យ និងបានរាយការណ៍ផងដែរ ពីការសម្លាប់បុគ្គលទាំងឡាយណាដែលនៅបន្តគោរពចំពោះស្តេចសីហនុ។ នៅខែធ្នូ ឆ្នាំ១៩៧៤ សារព័ត៌មាន New York Times បានចុះផ្សាយពីការបដិសេធដ៏ម៉ឺងម៉ាត់របស់ខ្មែរក្រហម ក្នុងការចរចាជាមួយរបបសាធារណរដ្ឋខ្មែរក្នុងអំឡុងពេលមានសង្គ្រាមស៊ីវិល ដែលបានធ្វើឱ្យជីវិត ឬអវៈយវៈរបស់ប្រជាជនរាប់រយរាប់ពាន់នាក់ត្រូវបានបាត់បង់នោះ បានប្រែក្លាយប្រជាជនដែលមានចំនួនពាក់កណ្តាលប្រទេសឱ្យទៅជាជនភៀសខ្លួន។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៥ មានសេចក្តីរាយការណ៍ពីការបន្តបាញ់ផ្លោង និងការប្រយុទ្ធបាញ់រះ របស់ខ្មែរក្រហមមកលើទីក្រុងភ្នំពេញ។

ជាចុងក្រោយសារព័ត៌មានមួយបានធ្វើការសង្ខេប នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៥ ដោយបានបញ្ជាក់ថា ប្រសិនបើស្ថានភាពនៅតែបន្តដូច្នេះ នោះខ្មែរក្រហមនឹងធ្វើឱ្យទីក្រុងភ្នំពេញក្លាយទៅជាផ្នូកឈាម។

## ការត្រួតពិនិត្យការចេញផ្សាយសារព័ត៌មាន និងការឆ្លើយតបរបស់ ប.ក.ក

៨៧៣- ភស្តុតាងដែលមាននៅក្នុងសំណុំរឿងក្តីនេះ បង្ហាញថា ភាពជាអ្នកដឹកនាំរបស់ ប.ក.ក រួមទាំងរបស់ជនត្រូវចោទ ក៏បានដឹងពីសេចក្តីរាយការណ៍អន្តរជាតិ ស្តីពីឧក្រិដ្ឋកម្មនានា ដែលកើតមាននៅប្រទេសកម្ពុជា។ ចំណុចនេះមានភាពប្រាកដប្រជាតាមរយៈប្រព័ន្ធតាមដាន ដែលមាននៅក្នុងរបបនោះ និងតាមរយៈការឆ្លើយតបទាំងឡាយរបស់ខ្លួន។

៨៧៤- នៅក្នុងរបបនោះ ក្រសួងឃោសនាការ ត្រូវបានគេប្រគល់សិទ្ធឱ្យត្រួតពិនិត្យព័ត៌មានពីខាងក្រៅទាំងអស់ដែលមានពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យនៅគ្រប់ពេលទាំងអស់។ ការត្រួតពិនិត្យនេះ គឺមានគោលបំណងជួយដល់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងការអនុវត្តវិធានការឆ្លើយតបឱ្យទាន់សភាពការណ៍។ កំណត់ហេតុនៃការប្រជុំរបស់គណៈអចិន្ត្រៃយ៍ ក៏មានបង្ហាញពីសេចក្តីរាយការណ៍ទាំងនេះដែរ រួមមាន ការវិភាគ និងការស្នើយោបល់សម្រាប់ការឆ្លើយតបនានារបស់ក្រសួងឃោសនាការ ត្រូវបានដាក់ជូនគណៈអចិន្ត្រៃយ៍ នៅម៉ោង៥ និង ១៥នាទីជារៀងរាល់ថ្ងៃ តាមរយៈនិរសារផ្ទាល់ខ្លួនរបស់អង្គការ។ កំណត់ហេតុអង្គប្រជុំ បង្ហាញថាដំណឹងសំខាន់ៗជាក់លាក់មួយចំនួន ត្រូវតែរាយការណ៍ជាបន្ទាន់តាមរយៈទូរស័ព្ទជូនទៅគណៈអចិន្ត្រៃយ៍។

៨៧៥- ថ្នាក់ដឹកនាំរបស់ ប.ក.ក បានឆ្លើយតបនៅនឹងការថ្កោលទោសរបស់អន្តរជាតិចំពោះសកម្មភាពរបស់ខ្លួន ដោយចាត់ទុកប្រភពព័ត៌មានទាំងនោះ ជាមធ្យោបាយរបស់ពួកចក្រពត្តិនិយម និងដោយអះអាងថា ប្រទេសឯទៀត គ្មានសិទ្ធិក្នុងការវិនិច្ឆ័យចំពោះកម្ពុជាប្រជាធិបតេយ្យនោះទេ។ នៅក្នុងសន្ទរកថាមួយ នៅចំពោះអង្គមហាសន្និបាតអង្គការសហប្រជាជាតិ **អៀង សារី** បានថ្កោលទោស "ការបង្កាច់បង្ខូច" ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ពីសំណាក់ "ពួកចក្រពត្តិនិយម"។ ស្រដៀងគ្នានេះដែរ នៅក្នុងបទសម្ភាសន៍មួយនៅឆ្នាំ១៩៧៧ គាត់បានបដិសេធនូវការសម្លាប់ក្នុងទ្រង់ទ្រាយធំទៅលើសមាជិកនៃអតីតរបបសាធារណរដ្ឋខ្មែរ ប៉ុន្តែគាត់បានបញ្ជាក់ពីការលុបបំបាត់ លុយ ទ្រព្យសម្បត្តិឯកជន និងសារព័ត៌មាន ហើយគាត់បានបន្ថែមទៀតថា"ទោះបីជានៅបរទេសគេនិយាយពីយើងយ៉ាងដូចម្ដេចក៏ដោយ ... "វាមិនសំខាន់នោះទេ""។ ប៉ុល ពត បានបដិសេធចំពោះការកើតមាននូវការប្រើពលកម្មដោយបង្ខំនៅក្នុងបទសម្ភាសន៍មួយដែលផ្សាយដោយ Phnom Penh Home Service។ នៅក្នុងការផ្សាយមួយនាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៥ វិទ្យុផ្សាយសំឡេងក្នុងស្រុក បានឆ្លើយបដិសេធនឹងការចោទប្រកាន់នានាពាក់ព័ន្ធនឹងការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលសារព័ត៌មានអន្តរជាតិបានរាយការណ៍។

៨៧៦- ការតបតរបស់ថ្នាក់ដឹកនាំ ប.ក.ក ចំពោះការរិះគន់ពីខាងក្រៅ ត្រូវបានសារព័ត៌មានអន្តរជាតិរាយកាណ៍។ ឧទាហរណ៍ សារព័ត៌មាន Los Angeles Times បានរាយការណ៍ថា តាមរយៈរបបកម្ពុជាប្រជាធិបតេយ្យ ការជម្លៀសប្រជាជនទាំងអស់ចេញទីប្រជុំជន ត្រូវបានរៀបចំផែនការជាមុន។ ស្រដៀងគ្នានេះដែរ សារព័ត៌មានផ្សេងៗទៀត ដូចជា Reuters Le Monde

និង Los Angeles Times ក៏បានរាយការណ៍នៅពាក់កណ្តាលឆ្នាំ១៩៧៨ ថាតាមរយៈលោក **អៀង សារី** សេចក្តីសម្រេចរបស់ ប.ក.ក ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់នោះ គ្រាន់តែធ្វើឡើងបណ្តោះអាសន្នប៉ុណ្ណោះទេ។ សារព័ត៌មាននៅក្រៅប្រទេសផ្សេងៗទៀត បានរាយការណ៍ពីការបដិសេធរបស់រដ្ឋាភិបាលរបបនោះ ចំពោះការកើតមាននូវការរំលោភបំពានសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំ ដោយបានអះអាងថា របាយការណ៍ទាំងនេះ គឺជាការបោកប្រាស់ និងត្រូវបានបង្កើតឡើង ដើម្បីបំបាក់មុខកម្ពុជាប្រជាធិបតេយ្យ។ សារព័ត៌មាន Washington Post និង Bangkok Post បានរាយការណ៍អំពីការបញ្ជាក់របស់លោក **អៀង សារី** អំពីការសម្លាប់អតីតមន្ត្រីរបស់សាធារណរដ្ឋខ្មែរចំនួនពីររូប។

៨៧៧- យ៉ាងហោចណាស់ មានអត្ថបទចំនួនមួយដែលលោក **អៀង សារី** បានទទួលស្គាល់ ថារបបកម្ពុជាប្រជាធិបតេយ្យបានបញ្ជាឲ្យមានការជម្លៀសដោយបង្ខំចេញពីទីក្រុងនានា បានទទួលស្គាល់ពីការខ្វះខាតម្ហូបអាហារ និងទទួលស្គាល់ផងដែរពីការបិទច្រកព្រំដែន។ សេចក្តីរាយការណ៍មួយរបស់សារព័ត៌មាននៅទីក្រុងឡុងដ៍ The Daily Telegraph ចុះផ្សាយក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ បានបង្ហាញថារបបកម្ពុជាប្រជាធិបតេយ្យ បានព្រមទទួលខុសត្រូវចំពោះការសម្លាប់រង្គាលទៅលើជនស៊ីវិលដែលគ្មានប្រដាប់អាវុធចំនួន២៩នាក់ ដោយបានរាយការណ៍បន្ថែមទៀតថា“ការធ្វើឃាតមនុស្សក្នុងទ្រង់ទ្រាយធំ ដែលមិនអាចប្រកែកបាននេះ ត្រូវបានប្រជាជនកម្ពុជាជ្រើសយកធ្វើជាមធ្យោបាយសំខាន់របស់ខ្លួន ក្នុងការ“រៀបចំកិច្ចការផ្ទៃក្នុង” នៅក្នុងប្រទេស”។ សារព័ត៌មាន The Hong Kong Standard បានចុះផ្សាយថាលោក **អៀង សារី** បានបដិសេធការតវ៉ាសិទ្ធិមនុស្ស របស់ចក្រភពអង់គ្លេស ដែលធ្វើឡើងនៅក្នុងឆ្នាំ១៩៧៧ ចំពោះគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ សារព័ត៌មាន The Wall Street

Journal បានចុះផ្សាយពីការថ្កោលទោសរបស់ ខៀវ សំផន និង អៀង សារី ចំពោះការល្មើសពានរបស់វៀតណាម។

## ច- តួនាទីរបស់ជនជាប់ចោទ

### នួន ជា

#### ទិដ្ឋភាពទូទៅ

៨៧៨- ផ្នែកខាងក្រោមនេះ រៀបរាប់ដោយសង្ខេបអំពីការចូលរួមប្រព្រឹត្ត និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ ។

៨៧៩- នួន ជា បានដើរតួនាទីស្នូលទាំងស្រុង ក្នុងការអភិវឌ្ឍន៍ ការដឹកនាំ និងការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ដែលជាផ្នែកមួយនៃរបបខ្មែរក្រហមតាំងពីរបបនេះចាប់បដិសន្ធិមក។ ដោយសកម្មក្នុងចលនាកុម្មុយនីស្ត តាំងពីឆ្នាំ១៩៤៦ នួន ជា គឺជាឧបករណ៍នៃការពន្លឿនគណៈបក្សប្រជាជនបដិវត្តន៍កម្ពុជានិងដែលក្រោយមកត្រូវបានគេស្គាល់ ថា បក្សពលករកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់បានបង្កើតមាគ៌ា យុត្តិសាស្ត្ររបស់បក្សនេះ រួមជាមួយនឹង សា ឡុតស ក្នុងនាមគាត់ជាអនុលេខាបក្ស។ ចាប់តាំងពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៧០ គាត់មានការទទួលខុសត្រូវ លើប្រតិបត្តិការរបស់បក្សនៅភាគជាច្រើនទូទាំងប្រទេសកម្ពុជា។ គាត់ក៏បានចូលកាន់កាប់នៅលើបញ្ជាការទីស្នាក់ការកណ្ដាលរបស់បក្សផងដែរ នៅខេត្តរតនៈគីរី នៅចន្លោះឆ្នាំ១៩៦៩ និង១៩៧០ ពេល សា ឡុតស អវត្តមាន។ ភាពលេចធ្លោរបស់ នួន ជា នៅក្នុងភាពជាមេដឹកនាំរបស់ បក្សកុម្មុយនីស្តកម្ពុជា នៅមុនសម័យកាលកម្ពុជាប្រជាធិបតេយ្យ

ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈ ការតែងតាំងក្នុងសមាជបក្សលើកទី៣ ក្នុងឆ្នាំ១៩៧១ ជាអនុលេខា និងជាសមាជិកគណៈកម្មាធិការ អចិន្ត្រៃយ៍ បក្សមួយរូប ក្នុងចំណោមសមាជិកដែលមានតែ៤រូប។

៨៨០- **នួន ជា** ក្នុងនាមជាកម្មាភិបាលថ្នាក់ខ្ពស់លំដាប់ទី២ក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺនៅ ក្រោមតែ ប៉ុល ពត ម្នាក់គត់។ គាត់នៅរក្សាកាន់មុខតំណែង ជាអនុលេខានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ដែលបណ្តាលឲ្យមានការ ចូលរួមដោយផ្ទាល់របស់គាត់នៅទូទាំង និងពាសពេញនៅក្នុងសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងនាមជាបុគ្គលចំបងដែលទទួលបន្ទុកលើ "កិច្ចការបក្ស" **នួន ជា** បានដឹកនាំ និងចូលរួមប្រព្រឹត្តនៅក្នុងការប៉ាពក់បំប៉នមនោគមវិជ្ជា ការផ្តន្ទាទោស និងការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ គាត់កាន់ការទទួលខុសត្រូវចំពោះបញ្ហាសន្តិសុខនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ដែលមានពួកមេដឹកនាំតាមភូមិភាគនានា និងស-២១ រាយការណ៍ជូនគាត់ដោយផ្ទាល់។ **នួន ជា** គឺជាបុគ្គលនៃសិទ្ធិអំណាចចុងក្រោយក្នុងការត្រួតត្រា និងប្រតិបត្តិការរបស់ ស-២១។ គាត់ក៏ជាសមាជិកនៃគណៈកម្មាធិការ កងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍របស់អង្គការនីតិបញ្ញត្តិរបស់ បក្សកុម្មុយនីស្តកម្ពុជាតាមដែលគេបានអះអាងផងដែរ គឺសភាតំណាងប្រជាជន និងបានចូលរួមយ៉ាងសកម្ម ក្នុងអង្គប្រជុំជាគន្លឹះនានា ក្នុងការចងក្រងបង្កើតគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

៨៨១- អំពើទាំងឡាយដែលជាមូលដ្ឋាននៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌរបស់ នួន ជា ចំពោះ ឧក្រិដ្ឋកម្ម នានាដែលឋិតនៅក្រោមការស៊ើបសួរ រួមមាន(ប៉ុន្តែមិនកម្រិតត្រឹមតែ)៖ ការចូលរួម ប្រជុំ និងការផ្តល់មតិ នានានៅក្នុងកិច្ចប្រជុំផ្សេងៗរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមនៃ បកក ដែលនៅក្នុងកិច្ចប្រជុំទាំងនោះ JCE ត្រូវបានពិភាក្សា របាយការណ៍នានាស្តីពី ការរីកចម្រើនដែលបានទទួល និងបានពិភាក្សា និងសារាចរណែនាំក្រោយៗមកទៀត ដែលត្រូវបានចេញផ្សាយ។ ការចេញបញ្ជា និងការញុះញង់ឲ្យមាន ឧក្រិដ្ឋកម្មផ្សេងៗ *ដែលលើសពីអ្វីៗ ទាំងអស់នោះគឺ (inter alia)* បទឧទ្ទេសនាម នានា ជាសាធារណៈរបស់គាត់ ការបំពាក់បំប៉ន ទស្សនៈនយោបាយ និងការលត់ដំពួកកម្មាភិបាល និងបញ្ញវន្ត។ ការធ្វើផែនការ និងការចូលរួមប្រព្រឹត្តនៅក្នុងអំពីឧក្រិដ្ឋជាក់លាក់ផ្សេងៗ ដូចជា ការជម្លៀសប្រជាជន ចេញពីទីក្រុង ភ្នំពេញដោយបង្ខំ និងការបញ្ជូនប្រជាជនឲ្យទៅភូមិភាគពាយ័ព្យដោយបង្ខំ។ ការអនុម័ត យល់ព្រម និងការត្រួតពិនិត្យមើលការអនុវត្តគោលនយោបាយនានា ស្តីពីពលកម្ម ដោយបង្ខំ និងអាពាហ៍ពិពាហ៍ដោយបង្ខំ តាមតួនាទីរបស់គាត់ក្នុងឋានៈជាសមាជិកមួយរូប នៃគណៈអចិន្ត្រៃយ៍នៃ បកក ។ ការផ្តល់កិច្ចប្រឹក្សា និងការចេញបញ្ជាលើបញ្ហាចាប់ខ្លួន និងការសម្លាប់ ចោលនៅមន្ទីរស-២១ និងការត្រួតពិនិត្យមើលមន្ទីរស-២១ និងមន្ទីរសន្តិសុខ តំបន់ផ្សេងៗ។ ការញុះញង់ ការធ្វើផែនការ និងការដាក់ទិស ក្នុងការបោសសម្អាតភូមិភាគនានា និងការចូលរួមចំណែកនៅក្នុងការធ្វើផែនការ និងការចេញបញ្ជាឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្ម ផ្សេងៗ ប្រឆាំងនឹងពួកអ្នកកាន់ព្រះពុទ្ធសាសនា ពួកវៀតណាម និងពួកចាម។

៨៨២- នៅពេញមួយរយៈកាលនៃកិច្ចស៊ើបសួរនេះ **នួន ជា** ត្រូវបានឱ្យដំណឹងពីឧក្រិដ្ឋកម្មនានា ដែលបានកើតឡើងនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ។ គាត់ត្រូវបានផ្តល់នូវព័ត៌មានពិស្តារស្តីពីវិសាល ភាពនៃឧក្រិដ្ឋកម្មនានា តាមរយៈតំណែងរបស់គាត់នៅក្នុងគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម និងគណៈយោធា នៃបកក ការប្រជុំផ្សេងៗជាប់ជាប្រចាំជាមួយនឹងពួកមេដឹកនាំតាមភូមិភាគ តំបន់ និងស្រុក ហើយនិងរបាយការណ៍នានាពីពួកគេ ហើយនិងដំណើរទស្សនកិច្ចជា ញឹកញាប់របស់គាត់ទៅកាន់ការដ្ឋាននានា នៅអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណាក៏ដោយ **នួន ជា** បានប្រើប្រាស់ នូវមុខតំណែងដ៏មានឥទ្ធិពលយ៉ាងសំខាន់របស់គាត់នៅក្នុងជួរមេដឹកនាំនៃ បកក ដើម្បីជម្រុញ និងសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ដែលផ្ទុយពីធ្វើការស៊ើបអង្កេត និងដាក់ទណ្ឌកម្ម ដល់ពួកចារីទាំងនោះ។ ស្ថិតនៅក្រោមការញុះញង់និងការដឹកនាំរបស់គាត់ គោលនយោបាយ ឧក្រិដ្ឋរបស់ បកក ត្រូវបានអនុវត្តទាំងស្រុងហើយការចាប់ខ្លួន និងការបោសសម្អាតត្រូវបាន សម្របសម្រួលនៅទូទាំងប្រទេស ។

៨៨៣- **នួន ជា** បានរក្សានូវជំនឿស៊ប់ក្នុងការប្តេជ្ញាចិត្តរបស់គាត់ ចំពោះគោលបំណង និងគោលនយោបាយនានារបស់ បកក បន្ទាប់ពីមានការការដកហូតចេញពីអំណាច។ ដោយការរក្សាបាននូវមុខ តំណែងរបស់គាត់ជាអនុលេខានៃ បកក និងជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន **នួន ជា** បានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការតស៊ូយោធា(អាវុធ) ដោយបានធ្វើការដឹកនាំចលនានេះរហូតដល់ឆ្នាំ១៩៩៤។ គាត់បានបន្តគាំទ្រ និងធ្វើការជាមួយនឹង ប៉ុល ពតជាបន្តទៀតរហូតដល់គាត់ស្លាប់ ដោយបានប្រកែកមិនព្រមប្រគល់ ប៉ុល ពត ឱ្យទៅពួកអាជ្ញាធរទេ។ ចាប់តាំងពីមានការចុះចូលរបស់គាត់នៅឆ្នាំ១៩៩៨ **នួន ជា** នៅមានមានះនៅ

ក្នុងការធ្វើយុត្តិកម្មលើគោលនយោបាយរបស់ បកក ស្តីពីការបោសសម្អាតពួកកម្មាភិបាលបកក និង "ពួកខ្មាំង" ដទៃទៀត ហើយការចូលរួមចំណែករបស់គាត់ នៅក្នុងការអនុវត្តនូវគោលនយោបាយទាំងនេះ។ ដោយពុំបានសម្តែងចេញនូវវិប្បដិសារីចំពោះការដែលគាត់បានចូលរួមប្រព្រឹត្តយ៉ាងច្រើននៅក្នុងឧក្រិដ្ឋកម្មនានានៃ បកក នោះ តែ នួន ជា បែរជាបានថ្លែងដោយគ្មានមន្ទិលទេថាគាត់នឹងធ្វើបដិវត្តន៍ម្តងទៀត បើមានឱកាសជាលើកទីពីរ។

**តួនាទីនៅមុនឆ្នាំ១៩៧៥**

៨៨៤- **នួន ជា** មានឈ្មោះពីកំណើតថា ឡៅ គីមលន កើតថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅឆ្នាំ១៩៤១ គាត់បានផ្លាស់ទៅរស់នៅទីក្រុងបាងកកដើម្បីបំពេញការសិក្សាថ្នាក់មធ្យមសិក្សា ហើយនៅឆ្នាំ១៩៤៨ គាត់គឺជានិស្សិតផ្នែកច្បាប់នៅសាកលវិទ្យាល័យ ធម្មសាត្រ(Thammasat)។ ក្នុងពេលកំពុងសិក្សា **នួន ជា** បានបម្រើការងារនៅក្រសួងហិរញ្ញវត្ថុថៃរយៈពេល៣ឆ្នាំ និងបន្ទាប់មកបានផ្លាស់ទៅក្រសួងការបរទេសថៃផ្នែកកិច្ចការឥណ្ឌូចិន។ ក្នុងអំឡុងរយៈកាលនោះ **នួន ជា** បានចូលរួមជាមួយបក្សកុម្មុយនីស្តថៃជាលើកដំបូងនៅឆ្នាំ១៩៤៦ ដែលជាផ្នែកមួយនៃសម្ព័ន្ធយុវជន និងបានក្លាយខ្លួនជាសមាជិកពេញសិទ្ធិនៅឆ្នាំ១៩៥០។

៨៨៥- នៅឆ្នាំ១៩៥០ **នួន ជា** បានផ្លាស់ទៅរស់នៅប៉ៃលិន និងបានប្តូរពីបក្សកុម្មុយនីស្តថៃ ទៅបក្សកុម្មុយនីស្តឥណ្ឌូចិន("ICP") និងបានក្លាយខ្លួនជាអ្នកទទួលបន្ទុកខាងឃោសនាការរបស់ពួកកុម្មុយនីស្ត នៅប៉ែកពាយ័ព្យប្រទេស។ ក្នុងនាមជាសមាជិកមួយរូបរបស់បក្សកុម្មុយនីស្តឥណ្ឌូចិន **នួន ជា** គឺជាផ្នែកមួយនៃចលនាតស៊ូគាំទ្រដោយវៀតណាមនៅខេត្តបាត់ដំបង ហើយ

នៅឆ្នាំ១៩៥២ គាត់បានធ្វើដំណើរទៅកាន់ប្រទេសវៀតណាម ដើម្បីទទួលការបណ្តុះបណ្តាលនយោបាយ។ គាត់បានបន្តស្ថិតនៅក្នុងចលនាតស៊ូនេះរហូតដល់មានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៥៤។

៨៨៦- នៅឆ្នាំ១៩៥៥ **នួន ជា** បានផ្លាស់មកភ្នំពេញ និងបានធ្វើការងាររៀបចំបក្សកុម្មុយនីស្តនៅកម្ពុជាជាសម្ងាត់ ដែលចាប់តាំងពីឆ្នាំ១៩៥១មក បក្សនេះត្រូវបានគេស្គាល់ថាជាបក្សប្រជាជនបដិវត្តខ្មែរ(KPRP)។ គាត់បានទទួលការតែងតាំងជាលេខាគណៈកម្មាធិការបក្សនៅភ្នំពេញ ដោយមាន សាឡុត ស ជាសមាជិកមួយរូបនៃគណៈកម្មាធិការនេះ។ លេខាបក្សទាំងមូលនៅកម្ពុជាកាលពីគ្រានោះឈ្មោះ ស៊ីវ ហេង ក្មួយប្រុសរបស់ នួន ជា ហើយ ទូ សាមុត ជាអនុលេខា។ នៅឆ្នាំ១៩៥៨ នៅពេល ស៊ីវ ហេង បានផ្តាច់ខ្លួនចូលទៅរួបរួមជាមួយរដ្ឋាភិបាលសម្តេច សីហនុ **នួន ជា** បានក្លាយខ្លួនជាអនុលេខាបក្សនៅកម្ពុជា។ ក្នុងគ្រាបន្ទាប់មក គាត់ និង សាឡុត ស មាន"តួនាទីដឹកនាំ"ក្នុងបក្សនេះដោយ សាឡុត ស ទទួលបន្ទុកទីក្រុង រីឯ **នួន ជា** ទទួលបន្ទុកជនបទ។

៨៨៧- ក្នុងតួនាទីថ្មីរបស់ពួកគេ សាឡុត ស និង **នួន ជា** បានធ្វើការជាមួយគ្នាដើម្បីបង្កើតមាគ៌ាយុទ្ធសាស្ត្ររបស់បក្សដែលក្នុងនោះ **នួន** ជា បានបង្ហាញមាគ៌ានេះឲ្យជនជាតិវៀតណាមបានដឹង ហើយមាគ៌ានេះត្រូវបានអនុម័តជាផ្លូវការដោយបក្សពលករកម្ពុជា (ឈ្មោះបក្សថ្មី)នៅឯសមាជលើកទី១ របស់បក្សនៅថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៦០។ ក្នុងសមាជដែលត្រូវបានប្រារព្ធធ្វើនៅក្នុងបរិវេណស្ថានីយអយស្ម័យយាននៅភ្នំពេញ មានអ្នកតំណាងចូលរួមចំនួន ២០រូបតែប៉ុណ្ណោះ ក្នុងនោះ **នួន ជា** ត្រូវបានបោះឆ្នោតជ្រើសតាំងជាអនុលេខាបក្ស ទូ សាមុត

ជាលេខាបក្ស សាឡុត ស ជាសមាជិកទី៣នៃគណៈអចិន្ត្រៃយ៍បក្ស ចំណែក **អៀង សារី** និង សោ ភឹម ជាសមាជិកបម្រុង។ មាគ៌ាយុទ្ធសាស្ត្រសំខាន់មួយក្នុងចំណោមមាគ៌ាយុទ្ធសាស្ត្រសំខាន់ៗ ដែលបក្សបានអនុម័តឯកភាព គឺការសម្រេចប្រើប្រាស់អំពើហឹង្សាប្រដាប់អាវុធដើម្បីវាយរំលំសត្រូវរបស់បក្ស។ ក្រោយសមាជ **នួន ជា** និងមេដឹកនាំបក្សផ្សេងៗ បានចាប់ផ្តើមចែកចាយទស្សនាវដ្តីសម្ងាត់មួយឈ្មោះថា"ទង់បដិវត្ត"ដែលពិភាក្សាអំពីមាគ៌ា និងទ្រឹស្តីបដិវត្តន៍ទាំងឡាយរបស់បក្ស។

៨៨៨- នៅឆ្នាំ១៩៦២ លេខាបក្សឈ្មោះ ទូ សាមុត ត្រូវបានចាប់ខ្លួន។ នៅខែកុម្ភៈ ឆ្នាំ១៩៦៣ ក្នុងឱកាសសមាជបក្សលើកទី២ សាឡុត ស បានក្លាយខ្លួនជាលេខាថ្មី ចំណែក **នួន ជា** បានបន្តស្ថិតនៅជាអនុលេខាបក្ស។ ក្នុងពិធីសមាជនោះ **អៀង សារី** និង សោ ភឹម ត្រូវបានបោះឆ្នោតជ្រើសតាំងជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍។ នៅខែមីនាឆ្នាំ១៩៦៣ បន្ទាប់ពីឈ្មោះ របស់ពួកគេត្រូវបានចុះផ្សាយនៅលើបញ្ជីឈ្មោះមនុស្សដែលគេហៅថា "ជនឆ្វេងនិយម" ពេល នោះ ប៉ុល ពត, **អៀង សារី**, និង សុន សេន បានបង្ខំចិត្តចាកចេញពីទីក្រុងភ្នំពេញ និងបានធ្វើការនៅខាងក្រៅបន្ទាយយោធាវៀតណាមមួយតាមបណ្តោយព្រំដែនរហូតដល់ឆ្នាំ១៩៦៦ និងនៅខេត្តរតនគិរីពីឆ្នាំ១៩៦៦ ដល់ឆ្នាំ១៩៧០។ ក្នុងអំឡុងពេល៧ឆ្នាំនេះ **នួន ជា** បានរក្សានូវអត្តសញ្ញាណសម្ងាត់ ជាអ្នកទទួលបន្ទុកប្រតិបត្តិការរបស់បក្ស តាមបែបផ្សេងៗក្នុងប្រទេស។

៨៨៩- នៅពាក់កណ្តាលឆ្នាំ១៩៦៧ **នួន ជា** និងសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងៗទៀត បានសម្រេចធ្វើការបះបោរជាទូទៅមួយនៅដើមឆ្នាំ១៩៦៨។ ការវាយប្រហារនានាពីសំណាក់កងកម្លាំងទ័ពព្រៃរបស់បក្សកុម្មុយនីស្តកម្ពុជា បានចាប់ផ្តើមនៅបាត់ដំបងនាថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨

អនុលោមតាមបទបញ្ជារបស់ **នួន ជា** និងបានរីករាលដាលពេញផ្ទៃប្រទេស។ នៅពេល សាឡុត ស កំពុងធ្វើដំណើរទស្សនកិច្ចទៅប្រទេសវៀតណាម និងចិន ពីចុងឆ្នាំ១៩៦៩ ដល់ពាក់កណ្ដាលឆ្នាំ១៩៧០ **នួន ជា** បានគ្រប់គ្រងទីស្នាក់ការបក្សនៅរតនគិរី។

៨៩០- ក្នុងឱកាសសមាជលើកទី៣នៅឆ្នាំ១៩៧១ បក្សបានទទួលស្គាល់ជាផ្លូវការនូវឈ្មោះរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានអនុម័តកាលពី៥ឆ្នាំមុន និងបានទទួលស្គាល់សមាជិក៤រូបដដែលនៃគណៈអចិន្ត្រៃយ៍ គឺ សាឡុត ស ជាលេខាបក្ស **នួន ជា** ជាអនុលេខាបក្ស សោ ភឹម និង **អៀង សារី**។

## តួនាទី និងសិទ្ធិអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ

៨៩១- នៅពេញមួយរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ **នួន ជា** បានបន្តស្ថិតក្នុងតួនាទីជាអនុលេខានៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាគឺជាស្ថាប័នសំខាន់ និងមានអំណាចបំផុតក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលជាអ្នកបង្កើតមាគ៌ានយោបាយ និងមានអំណាចក្នុងការសម្រេចប្រកបដោយប្រសិទ្ធភាពទៅលើរាល់គ្រប់បញ្ហាសំខាន់ៗ។ ក្នុងនាមជាកម្មាភិបាលជាន់ខ្ពស់លំដាប់ទី២នៅក្នុងបក្សបន្ទាប់ពី ប៉ុល ពត **នួន ជា** ត្រូវបានគេស្គាល់ឈ្មោះថាជាបងធំទី២។ យោងតាម **អៀង សារី** "អ្វីៗត្រូវឆ្លងកាត់ ប៉ុល ពត និង **នួន ជា**"។ រាល់ការសម្រេចទាំងអស់គឺពួកគេជាអ្នកធ្វើ ហើយ "ប្រសិនបើពួកគេទាំង២នាក់ពុំឯកភាព គឺមិនអាចសម្រេចទៅរួចឡើយ"។ នៅពេល ប៉ុល ពត បានចុះពីតំណែងនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យមួយរយៈនៅចន្លោះខែកញ្ញា និងតុលា ឆ្នាំ១៩៧៦

នួន ជា ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីស្ដីទី។ នួន ជា ក៏បានកាន់កាប់តួនាទីជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា។

៨៩២- ក្នុងអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដែលបានបែងចែកមុខនាទីមួយចំនួន ក្នុងចំណោមកម្មាភិបាលបក្សកុម្មុយនីស្តជាន់ខ្ពស់ នួន ជា បានទទួលចាត់តាំងឱ្យទទួលខុសត្រូវ "កិច្ចការបក្ស សកម្មភាពសង្គម វប្បធម៌ ឃោសនាការ និងអប់រំ"។ ក្នុងតួនាទីនោះ គាត់ជាអ្នក"ទទួលបន្ទុកអប់រំកម្មាភិបាល និងសមាជិកបក្ស" អំពីមាគ៌ា និងគោលនយោបាយបក្ស។ ការទទួលខុសត្រូវរបស់គាត់ចំពោះ"កិច្ចការបក្ស" ក៏បានធ្វើឱ្យគាត់ក្លាយខ្លួនជាមនុស្សសំខាន់ក្នុង ការទទួលបន្ទុកការចាត់តាំង ការតែងតាំង វិន័យ ការលត់ដំទណ្ឌកម្ម និងការដកកម្មាភិបាលបក្ស រួមទាំងការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្នុងទ្រង់ទ្រាយធំកាលពីឆ្នាំ១៩៧៦ ដល់ថ្ងៃបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅចុងឆ្នាំ១៩៧៨ នួន ជា ក៏បានកាន់កាប់តួនាទីជារដ្ឋមន្ត្រីក្រសួងឃោសនាការមួយរយៈពេលខ្លីជំនួសឈ្មោះ យុន យ៉ាត (ប្រពន្ធ សុន សេន) ។

៨៩៣- នួន ជា ទទួលបន្ទុកជាសំខាន់ទៅលើបញ្ហាសន្តិសុខនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់គឺជាសមាជិកមួយរូបនៃគណៈយោធាបក្ស រួមជាមួយ ប៉ុល ពត និង សុន សេន ដែលក្រុមនេះជាអ្នកទទួលបន្ទុកសន្តិសុខផ្ទៃក្នុង និងខាងក្រៅ "ពឹងផ្អែកលើការរាយការណ៍របស់មនុស្សតាមតំបន់ស្តីពីបញ្ហាសន្តិសុខ" ជាអ្នកសម្រេចលើការចាប់ខ្លួន និងបញ្ហាសន្តិសុខផ្សេងៗ និងរាយការណ៍ជូនគណៈអចិន្ត្រៃយ៍។ [redacted]

[redacted]។

៨៩៤- **នួន ជា** បានជួបប្រជុំជាទៀងទាត់ជាមួយមេដឹកនាំថ្នាក់ស្រុក តំបន់ និងភូមិភាគ និងបានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំថ្ងៃពីតំបន់នានា។ ការទទួលខុសត្រូវទូទៅរបស់គាត់ទៅលើបញ្ហាសន្តិសុខក្នុងប្រទេស ត្រូវបានបញ្ជាក់អះអាងដោយមានសង្គតិភាពពីសំណាក់មេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា។ **អៀង សារី** សមាជិកគណៈអចិន្ត្រៃយ៍ បានគូសបញ្ជាក់ថា **នួន ជា** "ជាអ្នកទទួលបន្ទុកផ្នែកសន្តិសុខ"។ [redacted]។ **អៀងធីរិទ្ធ** បានគូសបញ្ជាក់ថា **នួន ជា** ជាអ្នកទទួលខុសត្រូវការចាប់ខ្លួន និងការប្រហារជីវិតនិស្សិតពេទ្យដែលបម្រើការងារឲ្យគាត់។ តា ម៉ុក លេខាភូមិភាគនិរតី និងជាសមាជិកគណៈអចិន្ត្រៃយ៍ បានប្រាប់កម្មាភិបាលរបស់គាត់ថា **នួន ជា** "ទទួលបន្ទុកលើរាល់គ្រប់ផ្នែកសន្តិសុខទាំងអស់នៅក្នុងប្រទេស"។ [redacted]។

៨៩៥- **នួន ជា** បានស្នាក់នៅ និងធ្វើការនៅមន្ទីរក-១ និងក-៣ ជាមួយ ប៉ុល ពត **អៀង សារី ខៀវ សំផន** និងមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា និងបានធ្វើការនៅមន្ទីរនៅសាលា

ពុទ្ធិកព្រះសុរាម្រិត និងបុរីកីឡា។ មន្ទីរ ក-១ ស្ថិតនៅមាត់ទន្លេបាសាក់ខាងត្បូងទីតាំងសភាជាតិបច្ចុប្បន្ន ហើយមន្ទីរក-៣ ស្ថិតនៅខាងលិចព្រះបុរមរាជវាំង។

## ការចូលរួម និងការរួមចំណែក

៨៩៦- **នួន ជា** បានទទួលស្គាល់ថាក្នុងនាមជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់ជាអ្នក "ទទួលបន្ទុកផ្នែកស្មារតី" សម្រាប់ការស្លាប់របស់មនុស្សរាប់លាននាក់។ ប៉ុន្តែ ដូចដែលយើងនឹងបង្ហាញខាងក្រោម ការទទួលខុសត្រូវ ការចូលរួម និងការរួមចំណែករបស់គាត់ក្នុងអំពើឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃសំណុំរឿង០០២ គឺរិតតែមានភាពជាក់ស្តែង និងច្បាស់លាស់ទៅទៀត។

## ការចូលរួមជាទូទៅក្នុងផែនការឧក្រិដ្ឋកម្ម

### ការជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា

៨៩៧- ក្នុងនាមជាអនុលេខាបក្ស និងជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ចាប់តាំងពីឆ្នាំ១៩៥៨ **នួន ជា** តែងតែបានជួបប្រជុំ និងធ្វើការងារជាទៀងទាត់ជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា ដើម្បីបង្កើត និងអនុវត្តមាគ៌ា និងគោលនយោបាយបក្ស ដែលបានបង្កើតបានជាផែនការឧក្រិដ្ឋកម្មរួមរបស់បក្សកុម្មុយនីស្តកម្ពុជា។ "មាគ៌ានយោបាយ"ជាគោលនយោបាយ វិធាន និងមនោគមវិជ្ជាយូរអង្វែងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមហាសន្និបាតតំណាងទូទាំងប្រទេសបានបង្កើតឡើង និងត្រូវបានគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមយកមកអនុវត្ត ហើយដែលសមាជិកបក្សគ្រប់រូបត្រូវអនុវត្តតាម។ ក្នុងនាមជា

អនុលេខា នួន ជា មានវត្តមានក្នុងរាល់គ្រប់អង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលគេបានដឹង និងមានកត់ត្រាទុកជាឯកសារ។

៨៩៨- ជាការពិត មាគ៌ានយោបាយដ៏សំខាន់មួយរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេញមួយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺជាការប្រើប្រាស់អំពើហិង្សាដើម្បីកម្ចាត់មនុស្ស និងក្រុមទាំងអស់ដែលជាសត្រូវពិតប្រាកដ ឬមនុស្សដែលគេបានចាត់ទុកថាជាសត្រូវ របស់បក្សកុម្មុយនីស្តកម្ពុជា។ មាគ៌ាបក្សនេះត្រូវបានបង្កើតឡើងដំបូងបង្អស់ដោយ នួន ជា និង ប៉ុល ពត និងបានទទួលការអនុម័តពីសំណាក់បក្សពលករកម្ពុជានៅឱកាសសមាជបក្សលើកទី១ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៦០ និងតែងបានលើកឡើងជាថ្មីក្នុងឱកាសសមាជបក្សជាបន្តបន្ទាប់ និងក្នុងអង្គប្រជុំគណៈមជ្ឈិម ក្នុងនោះរួមទាំងសេចក្តីសម្រេចមួយដែលបានទទួលការឯកភាពពីសំណាក់គណៈមជ្ឈិមនៅខែមករា ឆ្នាំ១៩៦៥ សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈិមដែលបានប្រគល់សិទ្ធិអំណាច "កម្ទេច" ខ្មាំង និងសារាចររបស់គណៈមជ្ឈិមក្នុងខែមិថុនា ឆ្នាំ១៩៧៨ កែសម្រួលគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាទៅលើគិញយួន សេអ៊ីអា និងកាហ្សេបេ។ ក្នុងពេលទាំងនោះ នួន ជា គឺជាអនុលេខានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម។

៨៩៩- ប្រហាក់ប្រហែលគ្នានេះ នួន ជា គឺជាអ្នកចូលរួមក្នុងអង្គប្រជុំសំខាន់ៗដែលក្នុងនោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតផែនការរបស់ខ្លួនក្នុងការជម្លៀសប្រជាជនទីក្រុង រួមទាំងមហាសន្និបាតបក្ស លើកទី១នៅឆ្នាំ១៩៦០ ការប្រជុំគណៈមជ្ឈិមខែមិថុនា ឆ្នាំ១៩៧៤ និងការប្រជុំគណៈសមរភូមិដើមខែមេសា ឆ្នាំ១៩៧៥ និងការសម្រេចជាបន្តបន្ទាប់របស់

គណៈអចិន្ត្រៃយ៍ក្នុងសរទរដូវឆ្នាំ១៩៧៥ ដើម្បីជម្លៀសដោយបង្ខំនូវប្រជាជនចំនួន ៥០០០០០បន្ថែម ទៀតទៅកាន់ភូមិភាគពាយ័ព្យ និងដើម្បីបំបែកប្រជាជនចាមពីភូមិភាគបូព៌ា។ គាត់ គឺជាផ្នែកមួយនៃថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ ដែលបានរៀបចំផែនការ និងបានដាក់សមូហភាវូបនីយកម្មកសិកម្ម កំណត់បរិមាណផលិតស្រូវប្រចាំឆ្នាំ បំបាត់ការប្រតិបត្តិសាសនាព្រះពុទ្ធ បង្កើតការដ្ឋានធ្វើការងារពលកម្មដោយបង្ខំដូចជាការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង និងបានចេញសេចក្តីសម្រេចរួមស្តីពីការចាប់ខ្លួនកម្មាភិបាលថ្នាក់លើ។

## វគ្គបំពាក់បំប៉ន និងវគ្គរៀនសូត្រនយោបាយ

៩០០- [redacted]។ សាក្សីជាច្រើនបានបញ្ជាក់អះអាងថា **នួន ជា** តែងបានដឹកនាំវគ្គរៀនសូត្រ ឬអប់រំនយោបាយនៅឯបុរីកីឡា និងនៅតាមទីកន្លែងផ្សេងៗដែលមានរយៈពេលជាច្រើនថ្ងៃ និងច្រើនសប្តាហ៍។ មួយឆ្នាំម្តង លេខាស្រុករបស់បក្សកុម្មុយនីស្ត កម្ពុជាត្រូវធ្វើដំណើរទៅភ្នំពេញ ដើម្បីទទួលការអប់រំនយោបាយពីសំណាក់ **នួន ជា** និង ប៉ុល ពត។ នៅឆ្នាំ១៩៧៨ វគ្គរៀនសូត្រនយោបាយប្រចាំឆ្នាំសម្រាប់មេដឹកនាំមន្ទីរស-២១ ក្រសួងសង្គមកិច្ច និងអង្គភាពរដ្ឋាភិបាលផ្សេងៗនៅភ្នំពេញ ត្រូវបានធ្វើឡើងនៅឯមន្ទីររបស់ **នួន ជា** នៅឯសាលាពុទ្ធិកព្រះសុរាម្រិត ដែលមានអ្នកចូលរួមចំនួនជាង១០០នាក់ ក្រោមការណែនាំរបស់ ប៉ុល ពត និង **នួន ជា**។

៩០១- កម្មវិធីនៃការពិភាក្សាក្នុងវគ្គរៀនសូត្រនយោបាយទាំងនោះរួមមាន ការកំណត់អត្តសញ្ញាណ និងការ"កម្ទេច" ខ្មាំងផ្ទៃក្នុង ការបោសសម្អាតមនុស្សដែលជាប់ចោទពីបទក្បត់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះសហករណ៍ និងផលិតផលកសិកម្ម សារសំខាន់នៃការខំប្រឹងធ្វើការដើម្បីបំពេញតាមផែនការបក្ស និងការការពារខ្លួនប្រឆាំងនឹងយួន។ [redacted]។ កិច្ចខិតខំរបស់ នួន ជា នៅពេញមួយរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីធានាបាននូវការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាបញ្ជាក់ថាគាត់ពិតជាបានប្តេជ្ញាចិត្តពេញទំហឹង បានឯកភាព និងបានចូលរួមចេតនា និងគោលដៅនៃគោលនយោបាយទាំងនោះ និងបានរួមចំណែកដោយស្ម័គ្រចិត្តក្នុងការអនុវត្តគោលនយោបាយទាំងនោះ។

### សុន្ទរកថា

៩០២- ចេតនារបស់ នួន ជា ភាវចិត្ត និងការរួមចំណែកក្នុងផែនការឧក្រិដ្ឋកម្មរួមរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ត្រូវបានបញ្ជាក់ឲ្យឃើញតាមរយៈសុន្ទរកថារបស់គាត់ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ពិសេសគឺការអះអាងជាច្រើនដងរបស់គាត់ថាប្រទេសជាតិត្រូវបានញាំញីទៅដោយ "ខ្មាំង" ផ្ទៃក្នុងលាក់មុខ ដែលត្រូវចាប់ខ្លួន និងប្រហារជីវិតពួកគេជាចាំបាច់ ជាក់ស្តែង ក្នុងសុន្ទរកថាមួយក្នុងខែមករា ឆ្នាំ១៩៧៨ នៅឯពិធីទទួលគណៈប្រតិភូចុះធ្វើទស្សនកិច្ចនៃសាធារណរដ្ឋប្រជាមានិតចិន នួន ជា បានលើកឡើងអំពី "អំពើវិទ្ធង្សនាពីខាងក្នុង

សំដៅធ្វើរដ្ឋប្រហារផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ"។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៨ ក្នុងសន្និសីទកថាមួយថ្លែងទៅកាន់គណៈប្រតិភូចុះធ្វើទស្សនកិច្ចនៃបក្សកុម្មុយនីស្តដាណឺម៉ាក នួន ជា បានលាតត្រដាងអំពីភាវចិត្តនៃមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា និងកិច្ចខិតខំរបស់ពួកគេក្នុងការដោះស្រាយបញ្ហាខ្មាំងផ្ទៃក្នុងដែលគេបានចោទប្រកាន់ថាមាន៖

"ចាប់តាំងពីការរំដោះមក ពិសោធន៍របស់យើងគឺពាក់ព័ន្ធនឹងសកម្មភាពប្រឆាំងបក្សដែលបានរៀបចំឡើងនៅក្នុងជួរបក្សយើងតែម្តង។ ពួកគេតែងតែពាក់ព័ន្ធនឹង ពួកសេអ៊ីអា ភ្នាក់ងារកាហ្សេបេ និងភ្នាក់ងារវៀតណាម។ ពិសោធន៍របស់យើង ក្នុងផ្នែកនេះគឺនៅថ្មីថ្មោងខ្លាំងណាស់ ប៉ុន្តែវាបានបង្ហាញឲ្យយើងដឹងថាពួកសេអ៊ីអា ភ្នាក់ងារកាហ្សេបេ និងភ្នាក់ងារវៀតណាម បានធ្វើការងារនៅក្នុងបក្សអស់រយៈពេលជាយូរមកហើយ... ចំពោះការងាកទៅខាងឆ្វេងនិយម ឬខាងស្តាំនិយម យើងបានពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ ទៅលើជីវប្រវត្តិរបស់កម្មាភិបាលទាំងនោះ...ដូច្នេះយើងក៏អាចរកឃើញភ្នាក់ងារសត្រូវជាបណ្តើរៗ។ ...

"ទោះបីជាយើងនិយាយថា យើងបានកម្ទេចផែនការនានាហើយក៏ដោយ ក៏យើងមិនមានន័យថាសត្រូវបានចុះចាញ់ដែរ។ យើងត្រូវតែបន្តកសាង និងការពារបក្សយើង និងអ្នកដឹកនាំយើង និងត្រូវចាប់ពួកអ្នកដែលបានជ្រៀតចូលក្នុងជួរបក្សយើង។ យើងដឹងថាផែនការបច្ចុប្បន្នមិនពាក់ព័ន្ធត្រឹមតែភ្នាក់ងារវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែក្នុងនោះមានពួកចក្រពត្តិនិយមអាមេរិក និងកាហ្សេបេផងដែរ គឺពួកទាំងអស់ហ្នឹង!"

៩០៣- អ្វីដែលបានបង្ហាញឲ្យដឹងដូចគ្នានេះដែរ គឺសេចក្តីថ្លែងការណ៍របស់គាត់ក្នុងសុន្ទរកថា នៅខែកក្កដា ឆ្នាំ១៩៧៨ ដដែលនេះដែលថា"ទោះមានអ្វីកើតឡើងក៏ដោយ" យើងត្រូវតែការពារ "អ្នកដឹកនាំយើង"៖

> "ការបាត់បង់សមាជិក២០០ ទៅ៣០០នាក់ មិនអាចប្រៀបធៀបនឹងការបាត់បង់កម្មាភិបាលដឹកនាំ២ ទៅ៣នាក់បានឡើយ។ ការបាត់បង់សមាជិក២០០ ទៅ៣០០នាក់ ប្រសើរជាងការបាត់បង់សមាជិក២ ទៅ៣នាក់។ បើពុំដូច្នោះទេ បក្សនឹងគ្មានក្បាលម៉ាស៊ីន ហើយមិនអាចដឹកនាំការតស៊ូបានទេ"។

## ការចូលរួមក្នុងហេតុការណ៍ឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន

## ការជម្លៀសដោយបង្ខំ

*ដំណាក់កាលទី១*

៩០៤- ប្រភពនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា បានចាប់ផ្តើមមានតាំងពីខែកញ្ញា ឆ្នាំ១៩៦០ មកម្ល៉េះ ដែលទីបំផុតបាននាំទៅដល់ការជម្លៀសប្រជាជនពីទីក្រុងដោយបង្ខំ នៅខែមេសា ឆ្នាំ១៩៧៥ ក្នុងមាគ៌ានយោបាយដែល នួន ជា និង ប៉ុល ពត បានបង្កើតឡើង និងបានដាក់ជូនមហាសន្និបាតបក្សលើកទី១ ដែលក្នុងនោះមានទាំងការកំណត់ថាទីក្រុងគឺជា "បណ្តុំ" នៃខ្មាំងរបស់បក្ស។ នៅខែ មិថុនា ឆ្នាំ១៩៧៤ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នាដើម្បីរៀបចំផែនការវាយលុកដើម្បី "រំដោះ" ភ្នំពេញ ដែលក្នុងពេលនោះហើយដែលគេបានសម្រេចថាត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងពីទីរួមខេត្តនានាទៅកាន់តំបន់ជនបទ

នៅពេលគេរំដោះបានតំបន់ទាំងនោះ ដូចដែលពួកគេធ្លាប់បានធ្វើនៅទីរួមខេត្តក្រចេះ និងកំពង់ចាមនៅឆ្នាំ១៩៧៣ និងនៅឧត្តុង្គក្នុងខែមីនា ឆ្នាំ១៩៧៤ ដើម្បីបំបែកកម្លាំងខ្មាំងដែលស្ថិតក្នុងចំណោមប្រជាជនទីក្រុង។

៩០៥- ក្នុងអំឡុងរយៈកាលមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប៉ុល ពត **នួន ជា** និង **ខៀវ សំផន** បានស្ថិតនៅឯទីស្នាក់ការរបស់ ប៉ុល ពត នៅភូមិតាំងពន ខាងលិចឧត្តុង្គ ដែលគេស្គាល់ថាជាមន្ទីរប-៥ ផែនការចុងក្រោយនានាសម្រាប់ការជម្លៀសប្រជាជនភ្នំពេញ ត្រូវបានធ្វើឡើងនៅឯក្នុងអង្គប្រជុំគណៈសមរភូមិមួយនៅឯមន្ទីរប-៥ នៅដើមខែមេសា ឆ្នាំ១៩៧៥។ **នួន ជា** មានវត្តមានក្នុងអង្គប្រជុំនោះ និងបានគូសបញ្ជាក់អំពីគំនិតរបស់គាត់ និងបានឯកភាពយ៉ាងច្បាស់លាស់ទៅនឹងផែនការជម្លៀសប្រជាជន។ បទបញ្ជាជម្លៀសប្រជាជន ត្រូវបានផ្សព្វផ្សាយតាមខ្សែបណ្តាញបញ្ជា ពីមេបញ្ជាការយោធាភូមិភាគដែលមានវត្តមានក្នុងអង្គប្រជុំទៅកាន់បណ្តាមេបញ្ជាការកងពលធំ និងកងវរសេនាធំ។

៩០៦- នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ **នួន ជា** បានធ្វើដំណើរចូលភ្នំពេញជាមួយ ប៉ុល ពត **ខៀវ សំផន** សុន សេន តា ម៉ុក វន វេត កែ ពក និងមេបញ្ជាការយោធា និងតំបន់ផ្សេងៗ។ ក្រោយថ្ងៃជម្លៀសបានប្រមាណ១ខែ ក្នុងឱកាសសន្និបាតធំមួយដែលបានការចូលរួមពីមេដឹកនាំយោធាភូមិភាគ តំបន់ និងស្រុកពីថ្ងៃទី២០ ដល់២៥ ខែឧសភា ឆ្នាំ១៩៧៥ **នួន ជា** និង ប៉ុល ពត បានណែនាំប្រាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាថា ការជម្លៀសប្រជាជនចេញពីទីក្រុងដែលកន្លងមកបានប្រកាសថាជាការបណ្តោះអាសន្ននោះ ឥឡូវត្រូវបន្ត។

៩០៧- នួន ជា បានទទួលស្គាល់ថាការជម្លៀសប្រជាជនចេញពីទីក្រុងគឺ "មជ្ឈិមបក្ស" ជាអ្នកសម្រេច។ នៅដើមឆ្នាំ១៩៧៦ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានរាយការណ៍ ក្នុងទស្សនាវដ្ដី "ទង់បដិវត្ត" ថា"ក្រោយថ្ងៃរំដោះប្រទេសទាំងមូល ប្រជាជនជិត៣លាននាក់ត្រូវចាកចេញពីទីក្រុងផ្សេងៗទាំងដៃទទេរ គ្មានអាហារ និងគ្មានមធ្យោបាយ និងសម្ភារៈដើម្បីបង្កើនផលិតកម្ម" ដែលប្រជាជនទាំងនេះបានក្លាយជា"បន្ទុកយ៉ាងធ្ងន់"មួយសម្រាប់បក្ស និងមូលដ្ឋានដែលត្រូវចិញ្ចឹមពួកគេ។

៩០៨- ហេតុផលពិតប្រាកដរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការជម្លៀសប្រជាជនពីទីក្រុងជាអចិន្ត្រៃយ៍ គឺស្ដែងចេញតាមរយៈមតិយោបល់របស់ នួន ជា ក្នុងសន្ទរកថាមួយនៅខែកក្កដា ឆ្នាំ១៩៧៦ ដែលពេលនោះគាត់បានកត់សម្គាល់ឃើញថា នៅសម័យមុនរំដោះមាន"ខ្មាំងតិចតួច"នៅតាមតំបន់ជនបទ ប៉ុន្តែ"មានខ្មាំងច្រើន"នៅតាមទីក្រុង។ បន្ថែមពីលើការបញ្ជាឲ្យមានការ ប្រហារជីវិតថ្នាក់ដឹកនាំកំពូលនៃរបបសាធារណរដ្ឋខ្មែរនូវ"ពួកមហាក្បត់"ទាំង៧រូប មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗ ដើម្បីកំណត់អត្តសញ្ញាណ បំបែក និងប្រហារជីវិតបន្ថែមលើមន្ត្រីរដ្ឋការ និងទាហាននៃ របបសាធារណរដ្ឋខ្មែរបន្ថែមទៀត។ បណ្ដាមេបញ្ជាការយោធាត្រូវបានបញ្ជាឲ្យ "ជម្លៀសប្រជាជនស៊ីវិលចេញពីទីក្រុងដើម្បីវាយតម្លៃដឹងថាអ្នកណាជាទាហាន លន់ នល់"។ គណៈស្រុកនៃបក្សកុម្មុយនីស្តកម្ពុជា បានបែងចែកប្រជាជនជម្លៀស ដែលទើបមកដល់ជា ២ប្រភេទគឺៈ "ប្រជាជន ធម្មតាដូចជាកសិករ"ដែលត្រូវ"បានទុកជីវិតឲ្យធ្វើការងារ" និង "មនុស្សពិសេសដូចជា ទាហាន អ្នករដ្ឋការនៃរបប លន់ នល់ និងពួកនាយទុន"

ដែលត្រូវប្រហារជីវិត។ ក្នុងឱកាសសន្និបាតពីថ្ងៃទី២០ ដល់ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ១៩៧៥ នួន ជា បានបញ្ជាក់អះអាងអំពីសេចក្ដីណែនាំពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ឲ្យកម្ចាត់ថ្នាក់ដឹកនាំនៃអតីតរបបសាធារណរដ្ឋខ្មែរ។

*ទៅកាន់ភូមិភាគពាយ័ព្យ*

៩០៩- ពីថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៥ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានចុះពិនិត្យភូមិភាគពាយ័ព្យ និងបានកំណត់ថាដោយសារស្ថានភាពដីនៅតំបន់នេះអំណោយផលដល់ការផលិតស្រូវ ទើបនៅតំបន់នោះគេត្រូវការកម្លាំងមនុស្សបន្ថែមចំនួន៥០០០០០នាក់ទៀត។ នួន ជា និងគណៈអចិន្ត្រៃយ៍បានសម្រេចដូច្នេះទាំងដឹងថាប្រជាជនតំបន់នេះ កំពុងជួបការខ្វះខាតស្បៀង ហើយប្រជាជន១៧ មេសា ដែលធ្លាប់ត្រូវបានជម្លៀសទៅកាន់តំបន់នេះ "បានខ្វះខាតទាំងអាហារ និងថ្នាំសង្កូវ"។

៩១០- ការជម្លៀសប្រជាជនដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យបានកើតឡើងពីខែតុលា ឆ្នាំ១៩៧៥ ដល់ខែ កុម្ភៈ ឬមីនា ឆ្នាំ១៩៧៦។ ដោយសារការជម្លៀសនោះ តំបន់ជាច្រើននៅភូមិភាគពាយ័ព្យមានប្រជាជនច្រើនហួសកំណត់ និងពុំមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ចិញ្ចឹមប្រជាជនថ្មីដែលត្រូវបានខ្មែរក្រហមជម្លៀសមកកាន់តំបន់នេះឡើយ។ ជាក់ស្តែង នៅតំបន់៥ ស្រុកភ្នំស្រុកមានប្រជាជនមូលដ្ឋានចំនួន២០០០០នាក់ និងប្រជាជនថ្មីចំនួន៥០០០០ នាក់ដែលត្រូវបានជម្លៀសមកពីភ្នំពេញ ចំណែកស្រុកព្រះនេត្រព្រះ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនតែ១៥០គ្រួសារប៉ុណ្ណោះ ប៉ុន្តែចាប់តាំងពីក្រោយថ្ងៃទី១៧ ខែមេសា មក មានប្រជាជនថ្មីមករស់នៅចំនួន៧០០០០នាក់។ នួន ជា និងសមាជិកផ្សេងៗនៃគណៈអចិន្ត្រៃយ៍ បានទទួលរបាយការណ៍ពី

ភូមិភាគពាយ័ព្យ ស្តីពីបញ្ហាខ្វះខាតស្បៀង និងភាពអត់ឃ្លានគ្រប់ទីកន្លែងនៅតំបន់នេះ ពិសេសក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ របាយការណ៍មួយ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧ បានបញ្ជាក់ថា ប្រជាជនចំនួន២០០០០ បានស្លាប់ដោយភាពអត់ឃ្លាននៅស្រុកព្រះនេត្រព្រះ កាលឆ្នាំកន្លងទៅ។ បន្ទាប់ពីនោះមិនដល់មួយឆ្នាំផង ពោលគឺនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ លេខាភូមិភាគពាយ័ព្យ បានរាយការណ៍ជូនមន្ទីរ៨៧០ ថាតំបន់១ ៤ និង ៥ នៅកំពុងជួបការ ខ្វះខាតស្បៀង និងអស់ស្បៀងត្រឹមខែមិថុនា ឆ្នាំ១៩៧៨។

## ការធ្វើពលកម្មដោយបង្ខំ

៩១១- ក្នុងនាមជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍ **នួន ជា** បានចូលរួមក្នុងការរៀបចំផែនការ សេដ្ឋកិច្ច ប្រចាំឆ្នាំរបស់បក្ស ដោយបានបង្កើតឡើងនូវគោលដៅផលិតស្រូវ និងអំបិលប្រចាំឆ្នាំ និងការលើកទំនប់ប្រឡាយថ្មីៗ និងការប្រាស្រ័យទាក់ទងអំពីផែនការទាំងនេះ ទៅកាន់តាម បណ្តាភូមិភាគ។ គាត់បានចូលរួមក្នុងការសម្រេចកសាងព្រលានយន្តហោះយោធាថ្មីមួយនៅ កំពង់ឆ្នាំង។ **នួន ជា** បានជម្រាបមេដឹកនាំថ្នាក់តំបន់នៃបក្សកុម្មុយនីស្តកម្ពុជានៅឯសន្និបាត មួយពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥ អំពីសេចក្តីសម្រេចសាងសង់ទំនប់ ប្រឡាយ ធារាសាស្ត្រនៅទូទាំងប្រទេស ដោយចាប់ផ្តើមពីឆ្នាំ១៩៧៦ និងបានធ្វើជាប្រធានអង្គប្រជុំ នៅភ្នំពេញក្រោមការចូលរួមរបស់កម្មាភិបាលថ្នាក់តំបន់ និងភូមិភាគចំនួនរាប់រយនាក់ ដែល បានពិភាក្សាជាក់លាក់អំពីយុទ្ធសាស្ត្របង្កើនផលិតផលកសិកម្ម។

គាត់តែងបានធ្វើដំណើរជាទៀងទាត់ទៅតាមបណ្តាខេត្តនានា ដើម្បីប្រាប់កម្មាភិបាលតំបន់អំពី ការបង្កើនផលិតផលស្រូវ និងការសាងសង់ទំនប់។ គាត់បានចុះត្រួតពិនិត្យការដ្ឋានទំនប់

"ញឹកញាប់ ណាស់"(ជាច្រើនលើកក្នុងមួយខែ) ហើយក្នុងអំឡុងពេលធ្វើដំណើរនោះ គាត់បានឃើញ "ទុក្ខវេទនា"របស់ប្រជាជន និងស្ថានភាព"ទុរគត"។

៩១២- ការដ្ឋានមួយចំនួនដែល នួន ជា បានចុះទៅពិនិត្យរួមមាន៖ ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ដែលនៅទីនោះគាត់បានសង្កេតមើលប្រជាជនធ្វើការ និងបានណែនាំឱ្យពួកគេខំប្រឹងធ្វើការឱ្យ "ហ្មត់ចត់" និងបានជួបជាមួយអ្នកត្រួតពិនិត្យការដ្ឋាន ការដ្ឋានទំនប់ ១មករា ដែលនៅទីនោះគាត់បានសង្កេតមើលពលករ និងជម្រុញឱ្យពួកគេថែរក្សាទឹកទុកធ្វើស្រែ និងការដ្ឋានស្រែអំបិល ដែលនៅទីនោះគាត់បានប្រជុំជាមួយពលករនៅកណ្ដាលស្រែអំបិលនៅចុងឆ្នាំ១៩៧៧ ហើយក្នុងអង្គប្រជុំនោះគាត់បានណែនាំឱ្យពួកគេខំប្រឹងធ្វើការ ដើម្បីមហាលោតផ្លោះមហាអស្ចារ្យ។ នួន ជា និងគណៈអចិន្ត្រៃយ៍ ក៏បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរស្ដីពីការសាងសង់ទំនប់ និងអាងស្តុកទឹក រួមទាំងទំនប់ត្រពាំងថ្មផង។

៩១៣- ដូចដែល នួន ជា បានទទួលស្គាល់ហើយថា "គោលដៅឯករាជ្យម្ចាស់ការ" ខាងសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាផ្នែកយ៉ាងសំខាន់មួយនៃផែនការ និងយុទ្ធសាស្ត្រ"វាយខ្លាំង"។ ដូច្នេះក្នុងអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ មេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្ត កម្ពុជាបានណែនាំកម្មាភិបាលបក្សថាលក្ខខណ្ឌការងារដ៏មុឺងម៉ាត់ ដែលបានបង្កើតឡើងទាក់ទិន នឹងការសាងសង់ទំនប់នេះ និងការផលិតស្រូវមានភាពចាំបាច់ក្នុងការផ្ដល់រំលំខ្លាំងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

៩១៤- តាមរយៈការចុះពិនិត្យតាមបណ្ដាខេត្ត និងរបាយការណ៍ដែលគាត់បានទទួលជាទៀងទាត់ពីមន្ទីរភូមិភាគ នួន ជា បានដឹងថាមនុស្សជាច្រើននៅតាមការដ្ឋាន និងសហករណ៍ក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យបានជួបការខ្វះខាតស្បៀងអាហារ និងរងទុក្ខវេទនាដោយសារភាពអត់ឃ្លាន។ បើទោះបីជាគាត់បានដឹងអំពីបញ្ហាទាំងអស់នេះក្តី ក៏នួន ជា និងមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជានៅតែបានបន្តនាំចេញស្រូវ និងគ្រឿងឧបភោគបរិភោគនៅពេញមួយរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ។ ផែនការ៤ឆ្នាំរបស់បក្ស បានគូសបញ្ជាក់ថាគោលបំណងនៃការនាំចេញទាំងនេះ គឺ"ដើម្បីទទួលបានទុនសំរាប់ នាំចូលទំនិញដែលយើងត្រូវការ" ដែលទុនទាំងនោះបានមកតែពីការ "ការនាំចេញផលិតផលកសិកម្មផ្សេងៗ ពិសេសគឺស្រូវអង្ករ"។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានគណនាថា ខ្លួនអាចទទួលបានប្រាក់២០លានដុល្លាសហរដ្ឋអាមេរិកសម្រាប់ការនាំស្រូវចេញចំនួន១០០០០០តោន ហើយបានរៀបចំផែនការបង្កើនការនាំស្រូវអង្ករចេញក្នុងចំនួនពី១៣០៤៨០០តោន ក្នុងឆ្នាំ១៩៧៧ (២៧៧,៦លានដុល្លាសហរដ្ឋអាមេរិក) ទៅ១៦២៨៩០០តោនក្នុងឆ្នាំ១៩៧៨ (៣២៥,១ លានដុល្លាសហរដ្ឋអាមេរិក)។ ជាការគួរឱ្យកត់សម្គាល់ ពួកគេបានរៀបចំផែនការរក្សាយ៉ាងហោចណាស់១ភាគ៣ នៃស្រូវអង្ករសម្រាប់នាំចេញពីភូមិភាគពាយ័ព្យ ដែលមានប្រជាជនរាប់ម៉ឺននាក់បានស្លាប់ដោយភាពអត់ឃ្លានក្នុងឆ្នាំនោះ។

## អាពាហ៍ពិពាហ៍ដោយបង្ខំ

៩១៥- នួន ជា បានទទួលស្គាល់ថា បក្សកុម្មុយនីស្តកម្ពុជាមានផែនការប្រាំឆ្នាំ ដើម្បីបង្កើនចំនួនប្រជាជនកម្ពុជាឱ្យដល់១៥លាននាក់ ដែលគាត់គិតថាជាការចាំបាច់ ដើម្បីការពារប្រទេសពីខ្មាំងសត្រូវ។ ផែនការរបស់បក្សដើម្បីបង្កើនចំនួនប្រជាជន ត្រូវបានអនុវត្តដោយកម្មាភិបាលនៅទូទាំងប្រទេស។ ឧទាហរណ៍ ទស្សនាវដ្តី*ទង់បដិវត្ត* ដែលចេញផ្សាយនៅខែកញ្ញា ឆ្នាំ១៩៧៨

បានពិភាក្សាអំពីលទ្ធផលបឋមនៃ“គោលនយោបាយបង្កើនចំនួនប្រជាជន”របស់បក្សកុម្មុយនីស្ត កម្ពុជា ដោយបានកត់សម្គាល់ថា អត្រាកំណើន“នៅមិនទាន់គ្រប់គ្រាន់ទេ បើប្រៀបធៀបនឹង គោលបំណងរបស់បក្ស” ដែលត្រូវ“បង្កើនចំនួនប្រជាជនពី១៥ ទៅ២០លាននាក់ក្នុងរយៈពេល ពី១០ ទៅ១៥ឆ្នាំ”។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានណែនាំជាសំខាន់ដោយលេខាបក្ស ប៉ុល ពត ថាការរៀបការត្រូវតែរៀបចំ ដើម្បីបង្កើនចំនួនប្រជាជន។

៩១៦- កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅមូលដ្ឋានបានរាយការណ៍ត្រឡប់មកមជ្ឈិមបក្សវិញ ស្តីពី ការខិតខំប្រឹងប្រែងរបស់បក្សក្នុងការបង្កើនចំនួនប្រជាជន តាមរយៈការរៀបការដោយបង្ខំ។ ឧទាហរណ៍ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ មានរបាយការណ៍មួយផ្ញើពីមន្ទីរភូមិភាគបស្ចិម (ម-៤០១) មកឱ្យអង្គការដោយផ្តល់ព័ត៌មានថា “មានគ្រួសារថ្មីចំនួន១០គ្រួសារត្រូវបានបង្កើត ឡើងនៅស្រុក២៦ ក្នុងតំបន់៣២” និងមានរបាយការណ៍ប្រចាំខែបានបញ្ចូលនូវតារាងមួយដែល បង្ហាញពីអត្រាកំណើត មរណៈ និងរៀបការក្នុងខែនោះផងដែរ។

## មន្ទីរសន្តិសុខ

### *មន្ទីរសន្តិសុខ ស២១*

៩១៧- មន្ទីរសន្តិសុខស២១ បានរាយការណ៍ទៅគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ទាក់ទិននឹង បញ្ហាសន្តិសុខ។ [redacted]។ ការចូលរួម និងការ

ទទួលខុសត្រូវរបស់ នួន ជា ចំពោះស-២១ ត្រូវបានបង្កើតឡើងតាមរយៈអង្គហេតុ និងភ័ស្តុតាងនានាដូចខាងក្រោម។

៩១៨- មុនថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ស២១ ត្រូវបានគ្រប់គ្រងដោយផ្ទាល់ដោយ សុន សេន ដែលត្រូវរាយការណ៍ទៅឱ្យ នួន ជា និងសមាជិកគណៈអចិន្ត្រៃយ៍ដទៃទៀត។ ក្នុងអឡុងពេលនោះ នួន ជា បានទទួលចម្លើយសារភាពពីស២១ តាមរយៈ សុន សេន បន្ទាប់មកគាត់ធ្វើការពិនិត្យនិងចារលើចម្លើយសារភាពទាំងនោះ ធ្វើការសម្រេច និងចេញបញ្ជាត្រឡប់ទៅប្រធានស២១ គឺ ឌុច វិញតាមរយៈ សុន សេន។ ឧទាហរណ៍ ឌុច ត្រូវបាន នួន ជា បញ្ជា(តាមរយៈ សុន សេន) ឱ្យប្រាប់អ្នកទោសម្នាក់ឈ្មោះ មិល ការិន ហៅ ក្លាត ថា ហ៊ូ នឹម បានឆ្លើយសារភាពទាំងអស់ ហើយបានត្រឡប់ទៅផ្ទះវិញហើយ និងថាគាត់នឹងបានទៅផ្ទះវិញដែរប្រសិនបើគាត់ព្រមធ្វើបែបនេះ។ នៅពេលប្រើយុទ្ធសាស្ត្រនេះមិនបានផល នួន ជា បញ្ជាឱ្យ ឌុច ប្រើទារុណកម្ម។ នៅចុងខែសីហា ឆ្នាំ១៩៧៦ នួន ជា បានទៅក៧(មន្ទីរនិរសារបស់មជ្ឈិមបក្ស) ដើម្បីពិនិត្យដោយខ្លួនឯងនូវការចាប់ខ្លួនលេខាតំបន់២៤ ឈ្មោះ សួស នៅ ហៅ ឈូក ដែលត្រូវបានបញ្ជូនពីភូមិភាគបូព៌ាទៅស២១។ ការសម្រេចចាប់ខ្លួន ឈូក ត្រូវបានធ្វើឡើងរួមគ្នាដោយគណៈអចិន្ត្រៃយ៍ទាំងមូល ដោយពេលនោះ ឌុច បានផ្ញើសម្រង់ចម្លើយសារភាពចំនួនប្រាំពីរច្បាប់ដែលបានឆ្លើយដាក់ ឈូក ដែលមួយច្បាប់ៗគឺសម្រាប់សមាជិកគណៈអចិន្ត្រៃយ៍ម្នាក់។

៩១៩- នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ឌុច ត្រូវបានកោះហៅឱ្យចូលរួមការប្រជុំមួយជាមួយ នួន ជា ហើយបានទទួលព័ត៌មានថា សុន សេន ត្រូវបានចាត់តាំងឱ្យទៅសមរភូមិ ដើម្បីដឹកនាំរណសិរ្សជួរមុខក្នុងពេលមានជម្លោះកាន់តែតានតឹងជាមួយវៀតណាម។ ចាប់ពីថ្ងៃនោះរហូតដល់ពេល

រលំរលាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានរាយការណ៍ផ្ទាល់ទៅឱ្យ នួន ជា។ ឌុច បានជួបជាមួយ នួន ជា រវាងពីបីទៅ៥ថ្ងៃម្តង ដើម្បីរាយការណ៍ពីសកម្មភាពរបស់ស២១ និងទទួលបញ្ជា ជាធម្មតាគឺទៅជួបគាត់នៅមន្ទីររបស់គាត់ដែលស្ថិតនៅសាលាពុទ្ធកសិក្សាព្រះសុរាម្រិតត្រង់ផ្លូវលេខ២៤០ និង យូរៗម្តងទៅបូរីកីឡា។ នៅពេល នួន ជា ចង់ជួប គាត់ប្រាប់និរសាឱ្យទៅហៅ ឌុច និងប្រាប់ឱ្យជួបនៅ“មាត់ទឹក”(ដែលមានន័យថានៅ ព្រះសុរាម្រិត) ឬនៅ“លើទួល”(បូរីកីឡា)។ រៀងរាល់ថ្ងៃ នួន ជា ផ្ញើសំបុត្រទៅឱ្យ ឌុច តាមរយៈនិរសារ ដែលជាសំបុត្រខ្លីៗជា“បញ្ជាសង្ខេបបន្ទាន់”។

៩២០- ក្នុងករណីខ្លះទៀត នួន ជា បានផ្ញើបញ្ជា ឬទាក់ទងតាមវិធីផ្សេងទៀតជាមួយ ឌុច តាមរយៈ ឈឹម សំអោក ហៅ ប៉ង់ ដែលជាលេខាស៧១ ឬអនុលេខារបស់គាត់ឈ្មោះ ខាន់ លីន ហៅ កែន (ដែលឡើងជំនួស ប៉ង់ ក្រោយពេលត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៨)។ ក្នុងចំណោមមុខងារផ្សេងទៀត ស-៧១“ធ្វើការស៊ើបអង្កេតកម្មាភិបាលដែលគេសង្ស័យ សម្រាប់គណៈអចិន្ត្រៃយ៍” និងទទួលខុសត្រូវចាប់ខ្លួន និងបញ្ជូនអ្នកទោសទៅស២១។ ប៉ង់ និង លីន ត្រូវបាន នួន ជា ចាត់តាំងឱ្យជួយការងារនៅស២១។ អ្នកទាំងពីរក៏មានតួនាទីគ្រប់គ្រងមន្ទីរ ក៧ ចាំទទួលអ្នកទោសដែលបញ្ជូនពីភូមិភាគមកស២១ និងទៅ កន្លែងអប់រំកែប្រែ ឬលត់ដំ។

៩២១- [redacted]

[redacted]។ មានចម្លើយសារភាពជាច្រើនដែលបញ្ជាក់ពីសំណោរដៃរបស់ នួន ជា ឬមានចំណារដោយ ឌុច សុន សេន ឬអ្នកផ្សេងទៀត ដែលបង្ហាញថាចម្លើយសារភាពទាំងនោះត្រូវបានបញ្ជូនទៅឱ្យ នួន ជា។ ឌុច ត្រូវទទួលការឯកភាពពី នួន ជា ចំពោះចម្លើយសារភាពណាដែលឆ្លើយដាក់កម្មាភិបាលសំខាន់ៗ។ [redacted]។

ចម្លើយសារភាពដែលបញ្ជូនឱ្យ នួន ជា បានអះអាងជាពិសេសថា ត្រូវប្រើទារុណកម្មទៅលើអ្នកទោស ដើម្បីទាញយកចម្លើយសារភាព អំពីសកម្មភាពក្បត់របស់ពួកគេ។

៩២២- នួន ជា បានចូលរួមនៅក្នុងការសម្រេចចិត្តទៅលើមនុស្សដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅស២១។ ក្នុងនាមជាសមាជិកគណៈអចិន្ត្រៃយ៍ គាត់ជាមេដឹកនាំជាន់ខ្ពស់ម្នាក់ ដែលសម្រេចចាប់ខ្លួនកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដូចជាសមាជិកមជ្ឈិមបក្ស ភូមិភាគ ក្រសួង និងថ្នាក់ដឹកនាំកងពល និងកម្មាភិបាលដទៃទៀតដែលរាយការណ៍ទៅមជ្ឈិមបក្ស។ ដោយសារគាត់មានការទទួលខុសត្រូវមួយផ្នែកនៅស២១ នួន ជា ជាអ្នកពិនិត្យទៅលើចម្លើយសារភាពដែលបញ្ជូនដោយ ឌុច ចំពោះឈ្មោះមនុស្សដែលគេឆ្លើយដាក់ និងបញ្ជូនចម្លើយសារភាពទាំងនោះបន្តទៅប្រធានអង្គភាពដែលពាក់ព័ន្ធ ដើម្បីផ្តល់ព័ត៌មានដល់អ្នកទាំងនោះអំពី "សកម្មភាពខ្មាំងនៅក្នុងអង្គភាពនោះ" និងដើម្បីអនុញ្ញាតឱ្យពួកគេ "រៀបចំការចាប់ខ្លួនមនុស្សដែលត្រូវគេឆ្លើយដាក់ទាំងនោះ"។ ហេតុនេះ ដើម្បីពិគ្រោះជាមួយប្រធានអង្គភាពនោះ គេត្រូវធ្វើសេចក្តីសម្រេចថាតើមនុស្សដែលត្រូវគេឆ្លើយដាក់នោះនឹងត្រូវគេតាមដាន ចាប់ខ្លួន ឬមិនមែនជាកម្មវត្ថុនៃការចាត់

វិធានការណាមួយ។ ឧទាហរណ៍ នួន ជា ជាអ្នកសម្រេចចិត្តក្នុងការចាប់ខ្លួន រី ដែលជាកម្មាភិបាលពីក្រសួងឧស្សាហកម្ម បន្ទាប់ពីបានពិភាក្សា និងរាយការណ៍ដោយ វន វ៉េត។ ក្នុងករណីខ្លះ ចម្លើយសារភាពត្រូវបានគេផ្ញើទៅឱ្យប្រធានអង្គភាពនោះ ដោយឈ្មោះកម្មាភិបាលដែលត្រូវគេឆ្លើយដាក់ដើម្បីចាប់ខ្លួន មានធ្វើសញ្ញាក្រហម។ សាក្សីនានាបានបញ្ជាក់ថា មានការផ្ញើឯកសារចុះឡើងរវាង **នួន ជា** និង **អៀង ធីរិទ្ធ ខៀវ សំផន អៀង សារី** និងថ្នាក់ដឹកនាំភូមិភាគ។

៩២៣- ជាងនេះទៅទៀត មានចម្លើយសារភាពជាច្រើនពីស-២១ មានចំណាររបស់ សុន សេន នួន ជា ឬ ឌុច ដោយបង្ហាញថាឯកសារចម្លងត្រូវបានបញ្ជូនបន្តទៅថ្នាក់ដឹកនាំស្ថាប័ន ដែលកម្មាភិបាលនៅក្នុងស្ថាប័ននោះត្រូវបានគេឆ្លើយដាក់។ ឧទាហរណ៍ ចម្លើយសារភាពរបស់ប្រធានមន្ទីរពេទ្យកម្ចាត់ជម្ងឺគ្រុនចាញ់ផ-៥ ឈ្មោះ ម៉ុក សំអុល ហៅ ហុង បានឆ្លើយដាក់កម្មាភិបាលពីក្រសួងសង្គមកិច្ច និងភូមិភាគបូព៌ា ហើយឯកសារចម្លងក៏ត្រូវបានបញ្ជូនដោយ នួន ជា ទៅឱ្យក្រសួងសង្គមកិច្ច និងអនុលេខាភូមិភាគបូព៌ាឈ្មោះ សេង ហុង ហៅ ចាន់។ ចំណាររបស់ នួន ជា ទៅលើចម្លើយសារភាពនោះបានយោងជាពិសេសទៅដល់កម្មាភិបាលម្នាក់ពីតំបន់២៤ នៃភូមិភាគបូព៌ាដែលត្រូវបានគេឆ្លើយដាក់គឺឈ្មោះ អ៊ុយ សាធ ហៅ កឹម ដែលត្រូវបានគេចាប់ខ្លួន៤ថ្ងៃបន្ទាប់ពីចម្លើយសារភាពនោះ។ ជាងនេះទៅទៀត មានមនុស្សចំនួន៦នាក់ក្នុងចំណោម២០នាក់ពីក្រសួងសង្គមកិច្ចដែលត្រូវបានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់ ម៉ុក សំអុល ត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១។

៩២៤- នៅពេលដែលការចាប់ខ្លួនកម្មាភិបាលនៅថ្នាក់មូលដ្ឋាន អាចសម្រេចដោយគណៈភូមិភាគ សេចក្តីសម្រេចទៅលើអ្នកទោសដែលត្រូវបញ្ជូនទៅស២១ ត្រូវបានធ្វើឡើងដោយ នួន ជា និង

គណៈអចិន្ត្រៃយ៍។ កម្មាភិបាលនៅថ្នាក់មូលដ្ឋានមួយចំនួនត្រូវបានចាប់ខ្លួន **នួន ជា** នឹងផ្ញើទូរលេខមួយ ឬសំបុត្រមួយច្បាប់ទៅមន្ទីរកម្មាភិបាលនោះ ដោយសំណូមពរឲ្យពួកគេមកក្រុងភ្នំពេញ ដើម្បីចូលរួមវគ្គរៀនសូត្រនយោបាយ ឬការប្រជុំនានា។ ក្នុងករណីផ្សេងទៀត កម្មាភិបាលថ្នាក់មូលដ្ឋានត្រូវគេចាប់ខ្លួននៅមូលដ្ឋាននោះតែម្តង រួចបញ្ជូនពីភូមិភាគរបស់គេទៅ ស២១ ដោយ **នួន ជា** ជាអ្នកតាមដានដំណើរការនេះ និងឯកភាពទៅលើការបញ្ជូនទៅ ស២១។ ឧទាហរណ៍ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៨ អ៊ឹម ណែន ហៅ លី ដែលជាលេខាស្រុកឧដុង្គ និងជាភរិយារបស់លេខាភូមិភាគបស្ចិម ជូ ជេត ហៅ ស៊ី ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរនិរសារ ក៧ នៅក្រុងភ្នំពេញ។ មានសំបុត្រខ្លីមួយផ្ញើទៅជូនអង្គការ ដោយបញ្ជូនពី ប៉ាល់ ដែលជាអនុលេខាភូមិភាគបស្ចិម ដោយអះអាងថា លី នឹងត្រូវបានបញ្ជូនទៅឲ្យអង្គការតាមរយៈ ក៧។ **នួន ជា** ជាអ្នកបញ្ជាឲ្យបញ្ជូន លី ទៅស២១ ដោយសារមានចំណាររបស់គាត់នៅលើសំបុត្ររបស់ ប៉ាល់ សរសេរថា “ស២១”។

៩២៥- កម្មាភិបាលខ្លះដែលស្ថិតនៅក្រុងភ្នំពេញស្រាប់ ត្រូវបាន **នួន ជា** កោះហៅទៅជួបនៅមន្ទីររបស់គាត់នៅព្រះសុរាម្រិត ហើយជាអ្នកមើលការចាប់ខ្លួន និងបញ្ជូនទៅស២១។ មនុស្សដែលត្រូវបានគេចាប់ខ្លួនតាមលក្ខណៈបែបនេះរួមមាន វិន ប្រធានមន្ទីរពេទ្យឧស្សាហកម្ម និង ជាភរិយារបស់ វន វ៉េត និង ភាស់ ជាភរិយារបស់ ឈ្មោះ ចេង អន ដែលជាអនុ វន វ៉េត។ ក្នុងករណីខ្លះទៀត **នួន ជា** បានការសម្រេចចិត្តភ្លាមៗ ទៅលើការចាប់ខ្លួនមនុស្សនៅចំពោះមុខ ឌុច តែម្តង ដោយមិនបានពិគ្រោះយោបល់ជាមុនជាមួយ ប៉ុល ពត និងគណៈអចិន្ត្រៃយ៍ទេ ដូចជាការចាប់ខ្លួនកម្មាភិបាលនៅស២១ ជាដើម។ **នួន ជា** មានអំណាចដាក់ទណ្ឌកម្ម ឬវិន័យទៅលើកម្មាភិបាលស២១ ដូចជា ដកពួកគេចេញពីការងារ ឬបញ្ជាឲ្យចាប់ខ្លួន ជាដើម។ ហេតុនេះ សុន

សេន និងបន្ទាប់មកគឺ នួន ជា ដែលជាអ្នកសម្រេច និងចេញបញ្ជាឲ្យចាប់ខ្លួន សួរចម្លើយ និងសម្លាប់បុគ្គលិកស២១ និងព្រៃស ដូចជា នន់ ហ៊ុយ ហៅ ហ៊ុយ ស្រែ ក្នុងករណីខ្លះ គឺផ្អែកទៅលើរបាយការណ៍ដែល ឌុច ផ្ញើទៅគណៈអចិន្ត្រៃយ៍។

៩២៦- នួន ជា បានចេញបញ្ជាទូទៅប្រាប់ ឌុច ថា មនុស្សទាំងអស់ដែលបញ្ជូនទៅស២១ ត្រូវសម្លាប់ចោល។ នួន ជា ក៏បានចេញបញ្ជាពិសេសទៅឲ្យ ឌុច ពាក់ព័ន្ធនឹងការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬការប្រព្រឹត្តិចំពោះអ្នកទោសមួយចំនួន។ ឧទាហរណ៍ នួន ជា បានបញ្ជាថា ជនបរទេសមួយក្រុមដែលត្រូវបានឃុំឃាំងនៅស២១ ត្រូវយកទៅដុតទាំងរស់ ដោយប្រើសំបកកង់ឡាន។ គាត់បានបញ្ជាឲ្យសម្លាប់ វន វ៉េត ដែលជាសមាជិកគណៈអចិន្ត្រៃយ៍ដូចគាត់ដែរ បន្ទាប់ពីបានទទួលចម្លើយសារភាពពី ឌុច។ នៅខែធ្នូ ឆ្នាំ១៩៧៨ គាត់បានបញ្ជាថា អ្នកទោសចំនួន៣០០នាក់មកពីភូមិភាគបូព៌ាមិនគួរយកទៅសួរចម្លើយ តាមដំណើរការធម្មតានោះទេ តែត្រូវយកទៅសម្លាប់ភ្លាម ពេលបញ្ជូនមកដល់ស២១។ នៅថ្ងៃទី២ ឬទី៣ ខែមករា ឆ្នាំ១៩៧៩ គាត់បានចេញ"បញ្ជាដាច់ខាត" ទៅឲ្យ ឌុច សម្លាប់អ្នកទោសដែលនៅសល់ក្នុងស២១ ដែលសរុបចំនួនប្រហែល២០០នាក់។ មនុស្សចុងក្រោយដែលគេសម្លាប់តាមបញ្ជានេះគឺអ្នកទោសដែលមកពី យ៨ ដែលកំពុងសួរចម្លើយទាក់ទិននឹងការស្លាប់របស់ Malcolm Caldwell ដែលអ្នកទាំងនោះត្រូវបានសម្លាប់នៅលើគ្រែ និងទុកចោលក្នុងស២១ នៅពេលមានការជម្លៀសខ្លួន។ នួន ជា ប្រើពាក្យដូចជា "កំទេច" និង "សម្រិតសម្រាំង" ក្នុងការបញ្ជាឲ្យ ឌុច សម្លាប់មនុស្ស។

៩២៧- នួន ជា បានស្នើ និងទទួលរូបថតមួយចំនួនពី ឌុច ដោយបញ្ជាក់ពីការសម្លាប់អ្នកទោសសំខាន់ៗ ដូចជា វន វ៉េត និងអ្នកទោសដែលពាក់ព័ន្ធនឹងបុគ្គលិកស២១ ដែល នួន ជា យល់ថា អាចនឹង

មានការពាក់ព័ន្ធ ដូចជា លី ផែល ហៅ ផែន (មិត្តភក្តិរបស់ ម៉ម ណៃ)។ នៅចុងឆ្នាំ១៩៧៨ នួន ជា បានណែនាំឱ្យ ឌុច បន្តការសួរចម្លើយជាធម្មតានៅស២១ ទោះបីបក្សបានកែប្រែគោលនយោបាយទៅលើភ្នាក់ងារ សេអ៊ីអា កាហ្សេបេ និងយួន តាមរយៈការប្រកាស និងសេចក្តីថ្លែងការណ៍ជាសាធារណៈដែលធ្វើឡើងដោយ ប៉ុល ពត ពីរបីថ្ងៃមុនក៏ដោយ ដែលថាបក្សលែងអនុញ្ញាតឱ្យបុគ្គលិកមន្ទីរសន្តិសុខធ្វើការសួរចម្លើយទៀតហើយ។

៩២៨- នួន ជា ក៏បានបញ្ជាឱ្យយកចម្លើយសារភាពពីអ្នកទោសវៀតណាម ដែលទទួលបានពីស-២១ ទៅផ្សព្វផ្សាយតាមវិទ្យុដែរ។ ឌុច បានទទួលពិសេសពីការមកដល់នៃអ្នកទោសវៀតណាម តាមរយៈ នួន ជា ឬពី លឹម ហៅ កែន ដែលជាអនុលេខាស-៧១។ ការសួរចម្លើយឈ្លើយសឹកវៀតណាម ត្រូវបានធ្វើឡើងក្នុងគោលបំណងទទួលបាន“ចម្លើយសារភាពដែលបង្ហាញថា វៀតណាមបានឈ្លានពានកម្ពុជា ក្នុងគោលបំណងបញ្ចូលប្រទេសនេះ ទៅក្នុងសហព័ន្ធឥណ្ឌូ ចិន”។ ក្នុងពេលមួយនោះ មានអ្នកទោសវៀតណាមមួយចំនួនដែលត្រូវបានឃុំឃាំង និងសួរចម្លើយនៅស២១ មានច្រើនដែលអាចអនុញ្ញាតឱ្យមានការផ្សព្វផ្សាយជាទៀងទាត់តាមវិទ្យុបានម្តងឬ២ដងក្នុងមួយសប្តាហ៍។

៩២៩- មុនពេលភៀសខ្លួនចេញពីក្រុងភ្នំពេញ នួន ជា បានបំផ្លាញចោលនូវឯកសាររបស់គាត់ទាំងអស់ដែលពាក់ព័ន្ធដល់ស-២១។ ជាច្រើនឆ្នាំក្រោយមក គាត់បានបន្ទោស ឌុច ថាមិនបានធ្វើដូចគាត់។

## *មន្ទីរសន្តិសុខនៅតាមតំបន់*

៩៣០- ក្នុងឋានៈជាអនុលេខាគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា នួន ជា គឺជាមេដឹកនាំជាន់ខ្ពស់មួយរូបដែល (ក)បានបង្កើតនូវគោលមាគ៌ារបស់បក្សដែលថា ខ្មាំងសត្រូវទាំង

អស់ត្រូវតែកម្ទេច (ខ)បានអនុញ្ញាតឲ្យថ្នាក់ដឹកនាំនៅតាមភូមិភាគអាចកម្ទេចខ្មាំងដែលមាននៅក្នុងមូលដ្ឋានរបស់ខ្លួន និង(គ)បានណែនាំដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការចេញផ្សាយទស្សនាវដ្តីទង់បដិវត្ត សារាចរពីមន្ទីរ៨៧០ វគ្គរៀនសូត្រនយោបាយ និងលិខិតទំនាក់ទំនងដោយផ្ទាល់ផ្សេងៗទៀត ដែលកំណត់មុខសញ្ញាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល មន្ទីរសន្តិសុខត្រូវបានបង្កើតឡើងនៅតាមថ្នាក់ស្រុក តំបន់ និងភូមិភាគ ដែលត្រូវរាយការណ៍ផ្ទាល់ទៅលេខាគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់នោះ។ ជាទូទៅ លេខាស្រុកត្រូវរាយការណ៍ទៅលេខាតំបន់ លេខាតំបន់ត្រូវរាយការណ៍ទៅលេខាភូមិភាគ លេខាភូមិភាគត្រូវរាយការណ៍ទៅគណៈអចិន្ត្រៃយ៍។ សមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែលទទួលខុសត្រូវច្រើនជាងគេ ចំពោះបញ្ហាសន្តិសុខនៅថ្នាក់មូលដ្ឋាន គឺ នួន ជា។

៩៣១- [redacted] បានបញ្ជាក់ថា នួន ជា ជាអ្នកតំណាងមជ្ឈិមបក្ស ដែលពួកគេត្រូវរាយការណ៍អំពីបញ្ហាសន្តិសុខ។ នួន ជា ជាប្រធានអង្គប្រជុំធំៗដែលរៀបចំនៅស្តាតអូឡាំពិក និងបូរីកីឡា ដែលមានប្រធានភូមិភាគ និង តំបន់ចូលរួម ដើម្បីបង្ហាញពីបញ្ហាសន្តិសុខ និងបានចូលរួមក្នុងការប្រជុំតូចៗជាមួយថ្នាក់ដឹកនាំភូមិភាគ និងតំបន់ ដែលរៀបចំនៅក១ និងក៣។ នៅដើមខែឧសភា ឆ្នាំ១៩៧៥ គាត់បានរៀបចំការពិភាក្សាជាមួយថ្នាក់ដឹកនាំភូមិភាគ ទាក់ទិននឹងផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្រោយពេលរំដោះ ហើយគាត់បានសង្កត់ធ្ងន់ម្តងហើយម្តងទៀត ពីសារៈសំខាន់នៃ"ការពិនិត្យតាមដានភ្នាក់ងារបង្កប់"នៅឯសន្និបាតពី

ថ្ងៃទី២០ ដល់ទី២៥ ខែឧសភា ឆ្នាំ១៩៧៥ ដែលមានលេខាមកពីគ្រប់ស្រុក តំបន់ និងភូមិភាគនៅទូទាំងប្រទេសមកចូលរួម។ **នួន ជា** បានធ្វើដំណើរជាទៀងទាត់ទៅតាមខេត្តនានា "ដើម្បីជួបជាមួយកម្មាភិបាល" ដើម្បី"ផ្សព្វផ្សាយ និងអប់រំពួកគេ [ពី] គោលនយោបាយ [បក្ស]" ស្តីពីខ្មាំងនិងផ្នែកកសិកម្ម។ នៅរាល់ការធ្វើទស្សនកិច្ចទាំងនេះ គាត់បានជួបជាមួយ សោ ភឹម នៅភូមិភាគបូព៌ា ញឹម ជាលេខាភូមិភាគពាយ័ព្យ នៅខេត្តបាត់ដំបង តាម៉ុក ជាលេខាភូមិភាគនិរតី នៅខេត្តតាកែវ និង កែ ពក ជាលេខាភូមិភាគកណ្តាល នៅខេត្តកំពង់ចាម។

៩៣២- ដូចបានពន្យល់យ៉ាងពិស្តារមកហើយ នៅក្នុងផ្នែកនៃដីកានេះពាក់ព័ន្ធនឹងរបាយការណ៍ទៅមន្ទីរ ៨៧០ ថា **នួន ជា** បានទទួលរបាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ ដែលផ្ញើមកពីភូមិភាគទាក់ទិននឹងខ្មាំងផ្ទៃក្នុង និងបញ្ហាសន្តិសុខដទៃៗទៀត។ របាយការណ៍នេះរួមមានព័ត៌មានពិស្តារស្តីពីសកម្មភាពដែលគេចោទថាជាខ្មាំងផ្ទៃក្នុង និងបានស្នើសុំវិធានការនានាដើម្បីឆ្លើយតបទៅនឹងសកម្មភាពទាំងនោះ។ បញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹង "សភាពការណ៍ផ្ទៃក្នុង និងការប្រព្រឹត្តខុសសីលធម៌" ត្រូវតែរាយការណ៍ផ្ទាល់ទៅឲ្យ **នួន ជា** ពីព្រោះគាត់ "ទទួលបន្ទុកខាងប្រជាជន" និង"ការងារផ្ទៃក្នុងរបស់បក្ស"។ ក្នុងការឆ្លើយតបទៅនឹងរបាយការណ៍ទាំងនេះ ប៉ុល ពត និង **នួន ជា** បានផ្ញើទូរសារ និងសំបុត្រនានាទៅកម្មាភិបាលនៅតាមមូលដ្ឋានដោយផ្តល់នូវការណែនាំ ឬសារាចរណែនាំ។

៩៣៣- [redacted]ដែលមាននៅតាមមន្ទីរសន្តិសុខ និងកន្លែងពិឃាត នៅក្នុងរឿងក្តី០០២ [redacted]៖

(១) [redacted] រាយការណ៍ឲ្យ នួន ជា ទៅលើបញ្ហានានាដែលពាក់ព័ន្ធនឹងសន្តិសុខ។ [redacted] ទូរសារដែលគាត់បានផ្ញើទៅមន្ទីរ៨៧០ ដែលរាយការណ៍ពីការចាប់ខ្លួន ការឃុំឃាំង និងការសួរចម្លើយខ្មាំង និងស្នើសុំយោបល់ពីអង្គការ ដោយឆ្លើយតបវិញពី ប៉ុល ពត ឬ នួន ជា។ [redacted] ត្រូវទទួលការអនុញ្ញាតពីមជ្ឈិមបក្សដើម្បីដោះលែងអ្នកទោស [redacted] ចម្លើយសារភាព [redacted] ពីស២១ ឬបញ្ជីឈ្មោះកម្មាភិបាលមូលដ្ឋានដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពទាំងនោះ ត្រូវបានផ្ញើទៅមន្ទីរតំបន់ ដែលត្រូវ"ពិនិត្យតាមដាន" សកម្មភាពរបស់មនុស្សនោះ និងធ្វើការចាប់ខ្លួនបន្ថែមទៀត។

(២) ស្រដៀងគ្នានេះដែរ [redacted] បានអះអាងថា នួន ជា [redacted] និងទទួលខុសត្រូវខេត្តនេះតែម្តង។ [redacted]។

(៣) នៅចុងឆ្នាំ១៩៧៧ នួន ជា បានរៀបចំការប្រជុំនៅ [redacted] ដោយធ្វើការប្រកាសជាផ្លូវការពីការបង្កើតភូមិភាគឧត្តរថ្មី និងការតែងតាំង កង ចាប ហៅ សែ ជាលេខាតំបន់ ដែលក្នុងការប្រជុំនោះគាត់បានពិភាក្សាពីការជ្រៀតចូលក្នុងប្រទេស

ដោយពួក សេអ៊ីអា និងកាហ្វេបេ និងបានជំរុញឱ្យកម្មាភិបាលមូលដ្ឋាន "ខិតខំប្រឹងប្រែងធ្វើការ" ដើម្បីបង្កើនទិន្នផលស្រូវពី៣តោន ទៅ៧តោនក្នុងមួយហិកតា។ បន្ទាប់ពីការប្រជុំនោះមក មាន"ការចាប់ខ្លួនមនុស្សជាច្រើន" រួមមាន លេខាតំបន់១០៣ ឈ្មោះ ហង់ និង "មនុស្សដទៃទៀតក្នុងតំបន់១០៣"។ ការសម្រិតសម្រាំងជាទ្រង់ទ្រាយធំក្នុងតំបន់១០៣ ដែលបានកើតឡើងពីចុងឆ្នាំ១៩៧៧ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ដែលត្រូវបានរាយ ការណ៍ជាទៀងទាត់ដោយលេខាភូមិភាគឧត្តរឈ្មោះ សែ ទៅឱ្យ នួន ជា និងមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្ដកម្ពុជាដទៃទៀត។ កម្មាភិបាលដែលត្រូវបានគេសម្រិតសម្រាំង ជាធម្មតាត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខភូមិភាគឧត្តរនៅខេត្តសៀមរាប ឬទៅស២១។ [redacted]។

ចម្លើយសារភាពរបស់កម្មាភិបាលតំបន់១០៣ ដែលទទួលបាននៅមន្ទីរសន្តិសុខភូមិភាគឧត្តរ ដែលបានផ្ញើដោយលេខាតំបន់ឈ្មោះ សែ ទៅឱ្យមន្ទីរ៨៧០ ដើម្បី "ពិនិត្យ និងទុកជាឯកសារសម្រាប់ធ្វើការស្រាវជ្រាវរកខ្សែក្បត់ដែលបង្កប់ស៊ីរូងផ្ទៃក្នុង" មានអមដោយចំណាររបស់ នួន ជា ដែលណែនាំឱ្យ "តាមដានបន្ត"។

(៤) នៅឆ្នាំ១៩៧៦ នួន ជា បានរៀបចំការប្រជុំជាមួយគណៈភូមិភាគ តំបន់ និងស្រុក នៅភូមិភាគពាយ័ព្យ ដើម្បីរៀបចំផែនការសម្រិតសម្រាំង"ខ្មាំងផ្ទៃក្នុង" ដូចជាពួកទាហានដែលជាក់ពាក់ព័ន្ធនឹងរបបសង្គមរាស្ត្រនិយម និងសាធារណរដ្ឋខ្មែរ។ នៅខែឧសភា ឆ្នាំ១៩៧៨ បន្ទាប់ពី"ការប្រជុំមួយជាមួយអង្គការ" លេខាភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម បានរាយ

ការណ៍ថា គាត់កំពុងព្យាយាមអនុវត្តតាម "សេចក្តីណែនាំរបស់មន្ទីរ៨៧០" អោយមាន "ការប្រុងប្រយ័ត្នឱ្យខ្ពស់ថែមទៀត" ដោយខិតខំ "វាយកំទេចខ្មាំងល្បានពាន" និង"បោសសម្អាតសមាសភាពបង្កអន្តរាយ"។

(៥) នៅភូមិភាគបស្ចិម ទាំង នួន ជា និង ប៉ុល ពត សុទ្ធតែបានចូលរួម និងមានមតិក្នុងសន្និបាតប្រចាំឆ្នាំរបស់ភូមិភាគ។ នៅសន្និបាតកម្មាភិបាលភូមិភាគបស្ចិមដែលបានរៀបចំនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ នួន ជា បានពិភាក្សាយ៉ាងលម្អិតពីការបន្តការសម្រិតសម្រាំងក្នុងភូមិភាគនោះ ដែលសុន្ទរកថារបស់គាត់ត្រូវបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ក្នុងខែសីហា ឆ្នាំ១៩៧៧។ នៅក្នុងសុន្ទរកថានោះ នួន ជា បានបង្ហាញពីការយល់ដឹង ការឯកភាព និងការចូលរួមនៅក្នុងការចាប់ខ្លួន និងការកម្ទេចកម្មាភិបាលភូមិភាគបស្ចិម ដែលបានកើតឡើងរហូតដល់ពេលនោះ។ ឧទាហរណ៍ គាត់បានពិភាក្សាពី"ប្រវត្តិសាស្រ្តមិនល្អ" របស់តំបន់៣៧ និងចាត់ទុកពួកកម្មាភិបាលដែលត្រូវគេសម្រិតសម្រាំងនោះថាជា "សាច់ដំបៅរលួយ" ដែលត្រូវបានកាត់ចោល ដោយធ្វើការដកស្រង់ឧទាហរណ៍ "ក្រុមអាញ៉ឹក"។ ការនិយាយនេះសំដៅទៅអតីតលេខាតំបន់៣៧ ឈ្មោះ សៅ កង ហៅ ញ៉ឹក ដែលត្រូវបានគេចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅពេលចាប់ផ្តើមការសម្រិតសម្រាំងក្នុងខែធ្នូ ឆ្នាំ១៩៧៦ ជាពេលដែលមានការបញ្ជូនកងទ័ពមួយកងពលចំនួន៧០០០នាក់ ពីភូមិភាគនិរតីទៅភូមិភាគបស្ចិម ដើម្បីធ្វើការគ្រប់គ្រងផ្នែកសន្តិសុខ និងអនុវត្តការសម្រិតសម្រាំង។ នួន ជា ក៏បានពិភាក្សាជាមួយកម្មាភិបាលម្នាក់ឈ្មោះ ហម ជាអ្នកដែលបានរិះគន់អំពី "កម្មសិទ្ធិសមូហភាព" នៅចំពោះមុខគាត់នៅមុនពេលមាន សន្និបាតប្រចាំភូមិភាគនេះ នៅខែឧសភា ឆ្នាំ១៩៧៦ និងជាអ្នកដែលបន្ទាប់មកត្រូវបានគេរកឃើញថា ជា"ខ្មាំងបង្កប់នៅក្នុងបក្សរបស់យើង"។ នៅក្នុងករណីនោះ កម្មាភិបាលដែល

គេយោងទៅដល់នោះឈ្មោះ អ៊ូ ពិន ហៅ ទេព ហៃ ហៅ ហំ ដែលជាអតីតអនុលេខាតំបន់៣២ នៃភូមិភាគបស្ចិមដែលពីដំបូងត្រូវបានបញ្ជូនមកក្រសួងការបរទេស និងត្រូវបានគេចាប់ខ្លួន ឃុំឃាំង និងសម្លាប់នៅស-២១។ ការចាប់ខ្លួនកម្មាភិបាលទាំងនោះត្រូវបានរាយការណ៍ផ្ទាល់ទៅ នួន ជា និងមជ្ឈិមបក្ស។

(៦) នៅសុន្ទរកថាដដែល ដែលបានថ្លែងនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ នួន ជា បានញុះញង់ និងណែនាំឱ្យមានការសម្រិតសម្រាំងបន្ថែមទៀត ចំពោះកម្មាភិបាលភូមិភាគបស្ចិម។ គាត់បានអះអាងថា៥០ភាគរយនៃភូមិភាគជា "សមាសភាពមិនល្អ" និងពី១៥ ទៅ២០ ភាគរយ [ជា] ពួកក្បត់។ ជាពិសេស គាត់បានត្អូញត្អែរថា សហករណ៍ជាច្រើននៅក្នុងភូមិភាគនោះនៅតែស្ថិតក្រោមការគ្រប់គ្រងដោយពួកទាហានពីរបបចាស់ និង"អ្នកជំនួញនៅកំពង់សោម" និងបានណែនាំឱ្យកម្មាភិបាលភូមិភាគនោះស្វែងរក "ខ្មាំងបង្កប់" ដោយពិនិត្យទៅមើលប្រវត្តិរូប និងវណ្ណៈភាពរបស់គណៈសហករណ៍ទាំងនោះ ដើម្បី"វាយកម្ទេចខ្មាំង និងសមាសភាពមិនល្អដែលបង្កប់នៅខាងក្នុង និងគ្រប់គ្រងសហករណ៍" និងដើម្បីធានាថា យ៉ាងហោចណាស់ក៏៥០ភាគរយនៃសហករណ៍នៅក្នុងតំបន់នោះ គ្រប់គ្រងដោយកសិករក្រ ឬកសិករកណ្តាលថ្នាក់ក្រោមនៅបំណាច់ឆ្នាំនោះ។ បន្ទាប់ពីការណែនាំនេះដែរ មានប្រធានសហករណ៍និងឃុំជាច្រើនត្រូវបានចាប់ខ្លួន ឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខកោះខ្យង ក្នុងតំបន់៣៧ នៃភូមិភាគបស្ចិម។ នៅគ្រាមួយ ប្រធានសហករណ៍ និងគណៈឃុំត្រូវបានគេកោះហៅឱ្យទៅចូលរួមប្រជុំនៅមន្ទីរស្រុកព្រៃនប់ ហើយពីរថ្ងៃក្រោយមក "ប្រធានភូមិ និងប្រធានសហករណ៍" "ពេញមួយឡាន" ត្រូវបានចាប់ខ្លួន និងដឹកទៅដាក់គុក។ កម្មាភិបាលស្រុក តំបន់ និងភូមិភាគបន្ថែមទៀតត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស-២១ ក្រោយពេល នួន ជា បានថ្លែងសុន្ទរកថាកាលពីថ្ងៃទី២៥

ខែកក្កដា ឆ្នាំ១៩៧៧រួច ក្នុងនោះរួមមានប្រធានសន្តិសុខតំបន់៣២ឈ្មោះ ចាប ណាម (ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៧) លេខាស្រុកព្រៃនប់ឈ្មោះ ប៉ែន ភ្លូង (ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៧) ប្រធានពាណិជ្ជកម្មរបស់ភូមិភាគឈ្មោះ ស៊ិន គឹមអេង ហៅ សួន (ថ្ងៃទី២៨ ខែសីហា ឆ្នាំ ១៩៧៧) លេខាស្រុកកំពង់សែងឈ្មោះ ថៅ វ៉ាន ហៅ ខឹម (ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៧) លេខាស្រុកអង្គស្នួលឈ្មោះ ហង់ នៅ (ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៧) និងជាចុងក្រោយគឺលេខាភូមិភាគឈ្មោះ ជូ ជេត ហៅ ស៊ី និងភរិយាឈ្មោះ អ៊ឹម ណែន ហៅ លី ដែលជាលេខាស្រុកឧដុង្គ (ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៨)។ ការចូលរួមដោយផ្ទាល់របស់ **នួន ជា** នៅក្នុងការចាប់ខ្លួនទាំងនេះ ត្រូវបានបញ្ជាក់ដោយសំបុត្រមួយច្បាប់ដែលផ្ញើទៅអង្គការពីអនុលេខាភូមិភាគបស្ចិមឈ្មោះ ប៉ាល់ ដែលអមដំណើរ អ៊ឹម ណែន និងអនុលេខារបស់គាត់ នៅពេលដែលពួកគេត្រូវបានដឹកទៅ ក-៧ ដែលលិខិតនោះ មានកំណត់ដៃរបស់ **នួន ជា** ដែលបញ្ជាក់ពីការបញ្ជូនអ្នកទាំងនោះទៅកាន់មន្ទីរស-២១។

(៧) **នួន ជា** និងគណៈអចិន្ត្រៃយ៍បានទទួលព័ត៌មានពីការខិតខំប្រឹងប្រែងរបស់ភូមិភាគបស្ចិម ដោយអនុវត្ត"ទៅតាមមាគ៌ាចាត់តាំងរបស់បក្ស មានវិធានការដកហូត សម្រិតសម្រាំង និងបោសសម្អាត"ខ្មាំងរបស់អង្គការ។ ឧទាហរណ៍ របាយការណ៍ប្រចាំខែរបស់ភូមិភាគនេះសម្រាប់ខែកក្កដា ឆ្នាំ១៩៧៨ បានអះអាងថា "សមាសភាព១៧មេសា ជារដ្ឋការចាស់ និងអណិកជនចិន និងយួនមួយចំនួន"ត្រូវបាន"សម្រិតសម្រាំងចេញពីអង្គភាព និងចេញពីកងទ័ពជាដើម" ដែលតំបន់៣៧ បានកំទេចមនុស្សចំនួន៦០នាក់ ដែលគេស្គាល់ថាជាពួក សេអ៊ីអា ដែល"នៅបង្កប់ក្នុងអង្គភាព និងសហករណ៍" និងថា"ដកកម្មាភិបាលសហករណ៍២រូបចេញ ជា

លេខាសហករណ៍ម្នាក់ និងសមាជិកម្នាក់ បានបញ្ជូនទៅសន្តិសុខ ដោយសារពួកគេត្រូវចាត់ទុកថាជាសមាសភាពមិនល្អ” ដែលត្រូវបាន“តាមដានយូរមកហើយ” និង“ជាដៃជើង ខ្មាំង”។

(៨) នៅភូមិភាគនិរតី លេខាតំបន់ទទួលបញ្ជាផ្នែកសន្តិសុខពីលេខាភូមិភាគ តា ម៉ុក សុន សេន និង នួន ជា ជាអ្នក“ទទួលបន្ទុកឃោធា និងកិច្ចការសន្តិសុខ”។

(៩) នៅភូមិភាគពិ្ញសាន នួន ជា បានក្លាយទៅជាប្រធានភូមិភាគស្តីទី អស់រយៈពេលបីឬបួនខែ ក្រោយពីមានការចាប់ខ្លួនលេខាភូមិភាគមុនរួចមក។ ក្រោយៗមកទៀត បញ្ជាសន្តិសុខនានាពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែង(ភូមិ៣) និងភូមិភាគពិ្ញសានត្រូវបានរាយការណ៍ទៅ នួន ជា និងគណៈអចិន្ត្រៃយ៍ដោយលេខាភូមិភាគ និងប្រធានកងពល៨០១ (រាយការណ៍ តាមរយៈ សុន សេន)។ នៅពេលដែលរបាយការណ៍ទាំងនោះ ត្រូវបានលេខាភូមិភាគ វី ផ្ញើទៅឲ្យ ប៉ុល ពត នួន ជា និង **អៀង សារី** ដោយរាយការណ៍លម្អិតពីរបៀបនៃការចាប់ខ្លួន និងឃុំ ខ្លួនពួកទាហានយួនចំនួន២០៩នាក់របស់កងពលធំ៨០១ ដែលពួកទាំងនោះសុទ្ធតែជាជនជាតិ ចារ៉ាយ និង៩នាក់ ក្នុងចំណោមនោះជាស្ត្រី ព្រមទាំងស្នើសុំការណែនាំពីសំណាក់មនុស្ស“ថ្នាក់ខ្ពស់បំផុត”ថាតើត្រូវអនុវត្តសកម្មភាពបែបណា បន្ទាប់ពីអ្នកទោសទាំងនោះត្រូវគេសួរចម្លើយ ព្រមទាំង“អាត់យកសំឡេង”រួចហើយនោះ។ ដោយផ្អែកលើសក្ខីកម្មរបស់ប្រធាន អនុប្រធាន ព្រមទាំងអ្នកជាប់ឃុំឃាំងជាច្រើន នៅមន្ទីរសន្តិសុខអូរកន្សែង បានឲ្យដឹងថាពួកក្រុមអ្នកទោសចារ៉ាយដែលមានចំនួនច្រើននេះ ត្រូវគេយកទៅអូរកន្សែង បន្ទាប់ពីសួរចម្លើយរួច ហើយត្រូវគេសម្លាប់នៅទីនោះ ដោយអនុវត្តតាមបញ្ជាតាមរយៈមន្ទីរភូមិភាគ។

(១០) ការពាក់ព័ន្ធរបស់ **នួន ជា** និងមជ្ឈិមបក្សក្នុងការចាប់ខ្លួន ព្រមទាំងការបោសសម្អាតកម្មាភិបាលនៅភូមិភាគនិរតី ក៏មានបង្ហាញនៅក្នុងឯកសារសហកាលជាច្រើន។ ប៊ូ ខាវ ជាលេខាស្រុកកុកឡាក់ ស្ថិតក្នុងតំបន់១០១ ត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស២១ នៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៧។ ឯកសារបង្ហាញថា សុន សេន បានប្រាស្រ័យទាក់ទងជាមួយនឹង ឌុច ជាប្រធានមន្ទីរស២១ ពាក់ព័ន្ធនឹង ប៊ូ ខាវកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៧ គឺ២សប្តាហ៍មុនពេលដែលមានការចាប់ខ្លួន ប៊ូ ខាវ។ បន្ទាប់ពីការចាប់ខ្លួនគាត់ [redacted] បានចាត់ឱ្យមានអង្គប្រជុំរវាងកម្មាភិបាលមូលដ្ឋាន ដោយបានប្រាប់ពួកគេថា ប៊ូ ខាវ បានធ្វើការប្រាស្រ័យទាក់ទងជាមួយវៀតណាម ហើយប្រសិនបើពួកគេទាំងនោះប្រព្រឹត្តខ្លួនដូចជា ប៊ូ ខាវ ពួកគេនឹងត្រូវគេសម្លាប់។ ប៉ុន្មានសប្តាហ៍បន្ទាប់មកទៀត មនុស្ស “ជាប់ខ្សែរយៈ” របស់ ប៊ូ ខាវ ត្រូវបានចាប់ខ្លួន និងសួរចម្លើយនៅតំបន់១០១ (ត្រូវសន្និដ្ឋានថានៅអូរកន្សែង) ហើយលទ្ធផលដែលទទួលបាន ត្រូវរាយការណ៍ជូនទៅមជ្ឈិមបក្ស។ លេខាកងពលធំ៨០១ បានរាយការណ៍ថា ពួកគេ“កំពុងតាមដាន”បុគ្គលមួយចំនួនដែល“ខ្មាំងឆ្លើយដាក់” និងបុគ្គលមួយចំនួនទៀត ដែល“ប្រឆាំងនឹងមាគ៌ារបស់បក្ស”។ [redacted]កម្មាភិបាលបានដឹងថាបុគ្គលនោះ“ត្រូវបានសង្ស័យ” ឬ“ជាប់ខ្សែរយៈ” នឹងអ្នកជាប់ឃុំឃាំងនៅមន្ទីរស២១បានដោយរបៀបណា [redacted] ចម្លើយសារភាពនានារបស់ទាហាននៃកងពលធំ៨០១ ដែលត្រូវបានសួរចម្លើយនៅភ្នំពេញ ត្រូវបានបញ្ជូនទៅឱ្យលេខាកងពលធំ៨០១ [redacted] ដោយនៅក្នុងចម្លើយសារភាពទាំងនោះមានចំណារណែនាំ ដោយប៊ិចព

ណ៍ក្របាម បញ្ជាក់ពីកម្មាភិបាលដែលជាប់ពាក់ព័ន្ធនឹងអ្នកដែលនឹងត្រូវចាប់ខ្លួន [redacted]។

(១១) នៅភូមិភាគបូព៌ា នួន ជា ជាអ្នកសម្រេចក្នុងការបញ្ជូនអ្នកទោសពីស-៧៩ មន្ទីរសន្តិសុខភូមិភាគបូព៌ាទៅស-២១។ បន្ថែមលើនេះទៀត ការសម្លាប់ទ្រង់ទ្រាយធំក្នុង ឆ្នាំ១៩៧៨ នៅភូមិបុស ស្រុកពញាក្រែកនោះ គឺទទួលការបញ្ជាដោយផ្ទាល់ពី ប៉ុល ពត និងមជ្ឈិមបក្ស ហើយកងទ័ពរបស់ភូមិភាគកណ្ដាលជាអ្នកអនុវត្តតាមបញ្ជានោះ។

## ការបោសសម្អាតកម្មាភិបាលភូមិភាគ

៩៣៤- ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍ និងយោធា និងក្នុងនាមជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក មួយរូបទទួលបន្ទុកទាំង "កិច្ចការបក្ស" និងត្រួតពិនិត្យមើលស-២១ផងនោះ នួន ជា បានចូលរួម ដោយផ្ទាល់នៅក្នុងការសម្រេចបោសសម្អាតកម្មាភិបាលប.ក.ក នៅក្នុងភូមិភាគនានា នៅតាមក្រសួង និងតាមកងពលធំយោធានានាផងដែរ។ [redacted]។ មានម្ដងនោះ ប៉ុល ពត ផ្ទាល់បាន បញ្ជាក់អត្តសញ្ញាណ នួន ជា សុន សេន និង តា ម៉ុក ជា "អ្នកទទួលខុសត្រូវចំពោះការសម្លាប់" ដែលត្រូវរាយការណ៍ឲ្យគាត់នូវ"បណ្ដាឈ្មោះរបស់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងទាំងអស់"។ [redacted]

[redacted]

[redacted]។ ការទទួលបន្ទុកមើលការខុសត្រូវរបស់ **នួន ជា** លើមន្ទីរសន្តិសុខស២១ បានសេចក្តី ថាគាត់មានការពាក់ព័ន្ធដោយផ្ទាល់ និងជាអ្នកទទួលខុសត្រូវចំពោះការបោសសម្អាតនានាដែលកើត មានក្នុងប្រទេស។

*ការបោសសម្អាតភូមិភាគកណ្តាល (ឧត្តរចាស់)*

៩៣៥- ការបោសសម្អាតភូមិភាគកណ្តាល(ឧត្តរចាស់) បានចាប់ផ្តើមជាមួយនឹងការសម្រេចរបស់គណៈអចិន្ត្រៃយ៍របស់ ប.ក.ក ដាក់អតីតលេខាភូមិភាគ កុយ ធួន *ហៅ* ធុច ឱ្យស្ថិតក្រោមការឃុំខ្លួនក្នុងផ្ទះនៅក-១ នាដើមខែមេសា ឆ្នាំ១៩៧៦ បន្ទាប់មក គាត់ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខស-២១ សម្រាប់ការសួរចម្លើយនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ **ខៀវ សំផន** បានសារភាពថា ការចាប់ខ្លួន កុយ ធួន និងបញ្ជូនគាត់ទៅស-២១ គឺជាការសម្រេចរបស់គណៈអចិន្ត្រៃយ៍។ ការពាក់ព័ន្ធរបស់គណៈអចិន្ត្រៃយ៍ គឺមានបង្ហាញជាភស្តុតាងបន្ថែមទៀតតាមរយៈអង្គហេតុ ដែល កុយ ធួន គឺជាអ្នកចូលរួមប្រជុំជាទៀងទាត់ ក្នុងអង្គ ប្រជុំគណៈអចិន្ត្រៃយ៍ នានា រហូតដល់ដំណាច់ខែកុម្ភៈ ឆ្នាំ១៩៧៦ ប៉ុន្តែគាត់បានបាត់ខ្លួនពី អង្គប្រជុំនោះ ក្រោយពីគាត់ ទទួលការតែងតាំងនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៦ ក្នុងឋានៈ ជាប្រធានគណៈកម្មាធិការមួយទទួលបន្ទុកក្នុងការទិញទំនិញពីប្រទេសចិន។ នៅពេល ដែល កុយ ធួន ត្រូវបញ្ជូន ទៅស-២១ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ សុន សេន បានស្នើឱ្យ ឌុច ធ្វើការសួរចម្លើយដោយផ្ទាល់ ព្រមទាំងយកចម្លើយសារភាពលើកដំបូង នៅថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៧ ដែលចម្លើយសារភាពនោះ ត្រូវបានប្រគល់ឱ្យ សុន សេន ភ្លាមបន្ទាប់ពីការសាកសួររួច។

ពីរថ្ងៃក្រោយមក ឌុច បានទទួលដំណឹងពី សុន សេន ថាមានការបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលជាច្រើន មកពីភូមិភាគឧត្តរ ដោយផ្អែកលើចម្លើយសារភាពរបស់ កុយ ធួន។

៩៣៦- បន្ថែមលើការចូលរួមរបស់គាត់នៅក្នុងសេចក្ដីសម្រេចនានារបស់គណៈអចិន្ត្រៃយ៍ ចំពោះបញ្ហាអស់ទាំងនេះ **នួន ជា** និង ប៉ុល ពត បានហៅលេខាភូមិភាគឧត្តរ កែ ពក ឲ្យចូលរួមប្រជុំមួយនៅភ្នំពេញ នាដើមឆ្នាំ១៩៧៧ ដើម្បីជួយជ្រោមជ្រែងធ្វើផែនការបោសសម្អាតភូមិភាគរបស់គាត់។ **នួន ជា** និងលេខាភូមិភាគនិរតី តា ម៉ុក ក៏បានធ្វើដំណើរទៅខេត្តកំពង់ចាមផងដែរ នៅពាក់កណ្ដាល ឆ្នាំ១៩៧៧ ដើម្បីជួបជាមួយ កែ ពក។ **នួន ជា** បានពិភាក្សាអំពីអំពើក្បត់ជាតិរបស់ កុយ ធួន និងការបោសសម្អាតជនទាំងឡាយ ដែលជាប់ពាក់ព័ន្ធនឹង កុយ ធួន ក្នុងវគ្គសិក្សានយោបាយនានា ដែលប្រព្រឹត្តទៅនៅបុរីកីឡា។

៩៣៧- ការបោសសម្អាតកម្មាភិបាលភូមិភាគកណ្ដាល(ឧត្តរចាស់) បានចាប់ផ្ដើមជាមួយនឹងការចាប់ខ្លួន របស់អនុលេខាភូមិភាគ លេខាតំបន់៤១ និងលេខាតំបន់៤២ ព្រមទាំងកម្មាភិបាលតំបន់ និងកម្មាភិបាលភូមិភាគជាន់ខ្ពស់ផ្សេងៗទៀត នៅពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ១៩៧៧ និងក្រោយមកក៏រាលដាលដល់កម្មាភិបាលនានាដែលនៅថ្នាក់ស្រុក ថ្នាក់ឃុំ និងថ្នាក់ភូមិ ដោយអ្នកទាំងអស់នោះ ត្រូវបានជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី។ មានករណីមួយចំនួន កម្មាភិបាលភូមិភាគកណ្ដាលដែលនឹងត្រូវគេបោសសម្អាតនោះ "ត្រូវថ្នាក់លើហៅទៅភ្នំពេញ" ឬឈ្មោះរបស់ពួកគេត្រូវគូសសម្គាល់ដោយទឹកប៊ិចពណ៌ក្រហមក្នុងចម្លើយសារភាពស-២១ ដែលផ្ញើទៅមន្ទីរភូមិភាគ បន្ទាប់មកមន្ទីរនឹងបញ្ជាឲ្យបុគ្គលទាំងនោះ ធ្វើដំណើរទៅភ្នំពេញ។ មានករណីខ្លះទៀត កងសន្តិសុខរបស់មជ្ឈិមបក្ស បានមកកាន់ភូមិភាគ

ដើម្បីធ្វើការចាប់ខ្លួន។ ដូចបានពិភាក្សារួចមកហើយនៅក្នុងផ្នែក*ការបោសសម្អាតនៅភូមិភាគឧត្តរ* ការបោសសម្អាតក៏មានការរួមបញ្ចូលកម្មាភិបាលដែលមានការជាប់ពាក់ព័ន្ធ ឬឆ្លើយដាក់ដោយ កុយ ធួន ក្នុងក្រសួងពាណិជ្ជកម្ម កងពលធំយោធា៣១០ និង៤៥០ ព្រមទាំងនៅក្នុងរចនាសម្ព័ន្ធផ្សេងៗទៀតរបស់កម្ពុជាប្រជាធិបតេយ្យផងដែរ។

*ការបោសសម្អាតភូមិភាគបូព៌ា*

៩៣៨- ការបោសសម្អាតភូមិភាគបូព៌ាក៏ត្រូវបានធ្វើផែនការ និងដឹកនាំដោយមជ្ឈិមបក្សដែរ។ នៅចុងឆ្នាំ ១៩៧៧ តា ម៉ុក បានកោះប្រជុំមួយ រវាងមេបញ្ជាការយោធាជាន់ខ្ពស់របស់គាត់នៅភូមិភាគនិរតី ដើម្បីផ្តល់ដំណឹងឱ្យពួកគេបានដឹងពីប្រតិបត្តិការដែលនឹងមកដល់នាពេលខាងមុខនេះ ដោយបេសកកម្មរបស់ពួកគេ គឺត្រូវ"ប្រយុទ្ធជាមួយពួកវៀតណាមនៅកម្ពុជា ព្រមទាំងបោសសម្អាតអ្នករួមសហការជាមួយវៀតណាម" និង"បោសសម្អាត" ភូមិភាគបូព៌ា។ នៅដើមឆ្នាំ១៩៧៨ ប៉ុល ពត **នួន ជា** សុន សេន និង តា ម៉ុក បានចូលរួមអង្គប្រជុំពិសេសមួយរបស់មេបញ្ជាការយោធានៅភ្នំពេញ ដែលនៅក្នុងអង្គប្រជុំនោះពួកគេបានផ្តល់នូវព័ត៌មានលម្អិតស្តីពីផែនការនានា ក្នុងការចាប់ខ្លួន និងកម្ចាត់កម្មាភិបាលនៅភូមិភាគបូព៌ា។ នៅក្នុងអង្គប្រជុំនោះ **នួន ជា** បាននិយាយអំពី "ការបោសសម្អាតក្នុងជួរបក្ស" និងការបោសសម្អាត"ខ្មាំងដែលជាដៃជើងរបស់យួន" ព្រមទាំងបានដឹកនាំមេបញ្ជាការឱ្យ "បោសសម្អាតខ្មាំងផ្ទៃក្នុង ព្រមទាំងវាយពួកឈ្លានពានយួន"។ ក្រោយមក ប៉ុល ពត បានប្រាប់កម្មាភិបាល ប.ក.ក ក្នុងពេលកំពុងថ្លែងសុន្ទរកថាមួយ នាខែមេសា ឆ្នាំ១៩៧៨ ពិភាក្សាពីការលុកលុយរបស់វៀតណាម នាខែធ្នូ ឆ្នាំ១៩៧៧ថា៖ "យួនអាចចូលមកខេត្តស្វាយរៀងបានដោយ

សារតែពួកវាមានរនុកក្នុង។ ពួកវាចូលមកស្វាយរៀងក្នុងខែ១២។ យើងបានចាប់ខ្លួនរនុកក្នុងទាំងនោះអស់ហើយ”។

៩៣៩- នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ កម្មាភិបាលភូមិភាគបូព៌ាជាច្រើន ត្រូវគេកោះហៅឱ្យចូលរួមប្រជុំ និងត្រូវចាប់ខ្លួន រួមមាន កម្មាភិបាលមួយក្រុមដែលមានគ្នាលើសពី៤០នាក់ ដែលត្រូវលេខាភូមិភាគកណ្តាល កែ ពក កោះហៅទៅចូលរួមប្រជុំ និងត្រូវ សុន សេន ព្រមទាំងទាហានចំនួន៦០នាក់ក្រោមបង្គាប់របស់គាត់ ចាប់ខ្លួន រួចសម្លាប់បន្តិចក្រោយមក ក្នុងយប់នោះ។ លេខាតំបន់ភាគច្រើន ត្រូវបញ្ជូនទៅមន្ទីរស២១ នៅចុងខែឧសភា ឬដើមខែមិថុនា ឆ្នាំ១៩៧៨។ មេបញ្ជាការយោធា ត្រូវបាន សុន សេន ណែនាំថា ទាហានភូមិភាគបូព៌ាដែលត្រូវបោសសម្អាតទាំងអស់ ត្រូវ“បញ្ជូនទៅសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង” រីឯមេបញ្ជាការរបស់ពួកគេត្រូវបញ្ជូនទៅមន្ទីរស២១។ មជ្ឈិមបក្សបានបាចខិតប័ណ្ណពាសពេញតំបន់ដោយចោទលេខាភូមិភាគ សោ ភឹម ថាបានចូលដៃជាមួយវៀតណាមក្បត់ជាតិ ហើយជម្រុញឱ្យទាហានភូមិភាគបូព៌ាទាំងអស់ដាក់អាវុធចុះ។

៩៤០- ក្នុងខែធ្នូ ឆ្នាំ១៩៧៨ នួន ជា បានចេញបញ្ជាមិនបាច់សួរចម្លើយអ្នកទោសចំនួន៣០០នាក់មកពីភូមិភាគបូព៌ាដែលនឹងត្រូវគេបញ្ជូនទៅស២១នោះទេ ដែលការសួរចម្លើយគឺជានីតិវិធីត្រូវអនុវត្តធម្មតានៅស២១។ ការសួរចម្លើយបែបនោះត្រូវបានចាត់ទុកថាមិនចាំបាច់ ដោយសារនៅពេលនោះ គេបានសន្មតថា កម្មាភិបាលមកពីភូមិភាគបូព៌ាក្បត់នឹងថ្នាក់ដឹកនាំរបស់ ប.ក.ក។ ដោយគោរពតាមបញ្ជារបស់ **នួន ជា** អ្នកទោសទាំង៣០០នាក់ ត្រូវបានគេយកទៅសម្លាប់នៅពេលដែលទៅដល់មន្ទីរស២១ភ្លាម។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងពុទ្ធសាសនិក

៩៤១- រយៈប៉ុន្មានខែបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ភ្លាមៗនោះ **នួន ជា** នៅជាមួយ ប៉ុល ពត **អៀង សារី** **ខៀវ សំផន** និងថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងៗទៀត និងជាចំណែកមួយនៃមជ្ឈដ្ឋានផ្ទៃក្នុងរបស់មេដឹកនាំ ប.ក.ក ដែលជាអ្នកចូលរួមធ្វើសេចក្ដីសម្រេចចិត្ត និងពិនិត្យមើលការអនុវត្តទៅលើសេចក្ដីសម្រេចចិត្តទាំងនោះ។ បន្ទាប់ពីចូលភ្នំពេញនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ពីដំបូង **នួន ជា** ប៉ុល ពត **អៀង សារី** **ខៀវ សំផន** និងថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងៗទៀត បានស្នាក់នៅស្ថានីយរថភ្លើង និងវត្តព្រះកែវ(ព្រះវិហារព្រះកែវ) ក្នុងខែឧសភា ឆ្នាំ១៩៧៥ បន្ទាប់មកពួកគេក៏រើចេញពីទីនោះ ទៅកាន់ទីបញ្ជាការអចិន្ត្រៃយ៍របស់ខ្លួននៅ ក១ ស្ថិតនៅមាត់ទន្លេបាសាក់។

៩៤២- នៅដើមខែឧសភា ឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក បានជួបប្រជុំគ្នាអស់រយៈពេល ១០ថ្ងៃ នៅព្រះវិហារព្រះកែវមរកតនាទីក្រុងភ្នំពេញ ដើម្បីពិភាក្សាពីស្ថានការណ៍ក្រោយរំដោះ និង"រៀបចំទិសដៅថ្មី"។ អ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់នេះ រួមមាន ឈ្មោះ សោ ភឹម ឈ្មោះ តា ម៉ុក ឈ្មោះ កែ ពក ឈ្មោះ វន វេត ឈ្មោះ រស់ ញឹម ឈ្មោះ យ៉ា ឈ្មោះ ជូ ជេត *ហៅ*ស៊ី ឈ្មោះ ឡាំង ឈ្មោះ យី ឈ្មោះ ខឿន ឈ្មោះ ប៉ង់ ឈ្មោះ កឺ និងឈ្មោះ ហេង ទាវ *ហៅ* កន្ដុល។ នៅក្នុងកិច្ចប្រជុំនោះ ប៉ុល ពត បានបង្ហាញពីឯកសារផ្សេងៗរបស់បក្ស ហើយ **នួន ជា** ជាអ្នកដឹកនាំការពិភាក្សានានា។

៩៤៣- ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំ ប.ក.ក បានធ្វើមហាសន្និបាតដ៏ធំមួយនៅទីក្រុងភ្នំពេញដែលមានការចូលរួមពីសំណាក់ បណ្ដាលេខាមកពីគ្រប់ស្រុក គ្រប់តំបន់ គ្រប់ភូមិភាគទាំងអស់នៅក្នុងប្រទេស ព្រមទាំងតំណាងរបស់កងយោធាទាំងអស់ផង

ដែរ។ កម្មាភិបាល ប.ក.ក ដែលចូលរួមសន្និបាតនោះ បានទទួលការណែនាំពី នួន ជា និង ប៉ុល ពត អំពីមាគ៌ា និងគោលនយោបាយរបស់បក្ស ដែលពួកគេនឹងយកទៅអនុវត្តតាមតំបន់រៀងៗខ្លួន ក្នុងនោះរួមមានការបិទរាល់វត្តអារ៉ាមទាំងអស់ ព្រមទាំងផ្សឹកព្រះសង្ឃផងដែរ។ នួន ជា និង ប៉ុល ពត បានណែនាំយ៉ាងជាក់លាក់ដល់កម្មាភិបាល ប.ក.ក ដែលចូលរួមថាព្រះសង្ឃទាំងនោះ គឺជាពួក"វណ្ណៈពិសេស"ដែលត្រូវតែ"លុបបំបាត់ចោល" ហើយនឹងមិនអនុញ្ញាតឱ្យមានវត្តអារ៉ាមទេ។ នួន ជា គឺជាវាគ្មិនសម្រាប់ថ្ងៃទីមួយ និងជាអ្នកដែលឡើងមានមតិយោបល់ច្រើនជាងគេ នៅក្នុងសន្និបាតសំខាន់នេះ ដោយគាត់បានធ្វើការណែនាំកម្មាភិបាល ប.ក.ក អំពីគោលនយោបាយ និងទិសដៅផ្សេងៗ ដែលត្រូវយកមកអនុវត្តនៅក្នុងប្រទេស។

### ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិចាម និងប្រជាជនវៀតណាម

៩៨៤- នៅកិច្ចប្រជុំមួយដែលមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំស្រុក តំបន់ និងយោធាភូមិភាគ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥នោះ នួន ជា និង ប៉ុល ពត បានបង្ហាញទិសដៅដំបូងនានា ដល់កម្មាភិបាល ប.ក.ក អំពីការប្រព្រឹត្តិចំពោះពួកវៀតណាម និងពួកជនជាតិភាគតិចផ្សេងៗទៀតនៅក្នុងប្រទេស រួមមានទិសដៅក្នុងការជម្លៀសប្រជាជនវៀតណាមទាំងអស់ ចេញពីប្រទេសកម្ពុជាផងដែរ។ ជនជាតិវៀតណាមទាំងអស់នឹងត្រូវនិរទេសរួមទាំងស្ត្រីជនជាតិវៀតណាម ដែលរៀបការជាមួយបុរសខ្មែរផងដែរ។ យោងតាមការណែនាំនេះ ប្រជាជនវៀតណាមដែលត្រូវបានគេប៉ាន់ស្មានថាមានចំនួនពី១៥០០០០នាក់ ដល់២០០០០០នាក់ ត្រូវបាននិរទេសចេញពីប្រទេសកម្ពុជា ត្រឹមខែកញ្ញា ឆ្នាំ១៩៧៥ ដោយទុកតែជនជាតិវៀតណាមក្នុងចំនួនត្រឹមតែ២០០០០នាក់ ប៉ុណ្ណោះនៅក្នុងប្រទេស

ដែលក្នុងចំណោមនោះ ភាគច្រើនត្រូវបានសម្លាប់រង្គាលពេលបន្តបន្ទាប់មក។ ពាក់ព័ន្ធនឹងជនជាតិចាម ប៉ុល ពត បានប្រាប់កម្មាភិបាលទាំងអស់ ថាចាម និងក្រុមជនជាតិភាគតិចឯទៀត នឹងត្រូវ"សម្លាប់ចោលទាំងអស់"។

៩៤៥- ទូរលេខដែលផ្ញើទៅ ប៉ុល ពត នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ត្រូវបានចម្លងជូន នួន ជា ពាក់ព័ន្ធនឹងការកម្ចាត់ពួកចាមចំនួន៥០០០០នាក់មកពីភូមិភាគបូព៌ា ដោយគោរពតាម "ការណែនាំ"របស់អង្គការ។ នៅក្នុងទូរលេខនោះ លេខាភូមិភាគបូព៌ាបានយោង"ការពិភាក្សានានា" កាលពីពេលមុនជាមួយអង្គការ ដែលនៅក្នុងការពិភាក្សាទាំងនោះ ថ្នាក់ដឹកនាំ ប.ក.ក បានសម្រេចថា ចាមត្រូវតែបញ្ជូនទៅភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ "ដើម្បីបំបែកជនជាតិឥស្លាម"ពីដងទន្លេមេគង្គដែលជាមូលដ្ឋានដើមរបស់ពួកគេ។ ច្បាប់ចម្លងទូរលេខនោះត្រូវបានផ្ញើទៅឱ្យនួន ជា ពីព្រោះវាទាក់ទងនឹង"បញ្ហាផ្ទៃក្នុង" ដែល"ពាក់ព័ន្ធនឹងប្រជាជន" [redacted]។ ការសម្លាប់ជនជាតិចាមក្នុងទ្រង់ទ្រាយធំ ដែលកើតមានជាបន្តបន្ទាប់នៅស្រុកក្រូចឆ្មារ ត្រូវបានប្រព្រឹត្តឡើង ហើយមួយផ្នែកត្រូវបានអនុវត្តដោយអង្គភាពអន្តរាគមន៍ពិសេសរបស់មជ្ឈិមបក្ស ដែលត្រូវរាយការណ៍ជូនសុន សេន។

៩៤៦- គោលនយោបាយរបស់មជ្ឈិមបក្សពាក់ព័ន្ធនឹងប្រជាជនវៀតណាម ត្រូវបានប្រាស្រ័យទាក់ទងម្តងហើយម្តងទៀតទៅកម្មាភិបាល ប.ក.ក នៅក្នុងការបោះពុម្ពផ្សាយប្រចាំខែរបស់ទស្សនាវដ្តី *ទង់បដិវត្ត*។ ទស្សនាវដ្តីដែលចេញនៅក្នុងខែមេសា ឆ្នាំ១៩៧៧ ដែលមានដកស្រង់ខ្លឹមសារនៃ

សុន្ទរកថាដែលថ្លែងដោយ"តំណាងបក្ស"មួយរូប នាឱកាសខួបលើកទីពីរនៃជ័យជម្នះ១៧មេសា បានលើកឡើងពី "ពួកយួនលេបទឹកដី និងឆ្កែបម្រើពួកវាដែលលួចបង្កប់នៅក្នុងបក្ស" ហើយធ្វើការណែនាំថា"ត្រូវបំផុសមហាជនឱ្យគេបោសសម្អាតវាថែមទៀត ឱ្យស្អាតជាស្ថាពរ"។ នៅក្នុងខែមិថុនាឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំ ប.ក.ក បានធ្វើការព្រមានថា បក្សកំពុងតែត្រូវ"កម្មាភិបាលបក្សពលករកម្ពុជាដែលជាយួន"ជ្រៀតជ្រែកផ្ទៃក្នុង ហើយបានធ្វើការណែនាំទៀតថា "ក្បាលម៉ាស៊ីនដែលពួកយើងត្រូវកម្ទេចនោះ គឺសេអ៊ីអា យួន និងកាហ្សេបេ" ក្នុងចំណោមនោះ "ពួកយួន គឺជាពួកដែលមានពិសពុលបំផុត មានគ្រោះថ្នាក់បំផុតជាងគេ" និងជា"សត្រូវស្លាប់រស់របស់យើង"។ នៅក្នុងខែ កក្កដា ឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក បានប្រកាសថា វាគឺជា"ករណីកិច្ចរបស់ប្រជាជនទាំងអស់គ្នា" ក្នុងការលុបបំបាត់"ខ្មាំងយួនប្រល័យពូជសាសន៍" ដែល "stink to high heaven and are degradingly despised as nothing" និងបានកោតសរសើរពី"ការដុតភ្លើងកំហឹងជាតិ និងកំហឹងវណ្ណៈយ៉ាងឆាបឆេះ" ដែលបាន"ប្រែក្លាយទៅជាមហាចលនា" ដើម្បីកម្ទេច និងបោសសម្អាតឱ្យអស់ ពួកខ្មាំងយួនបង្កប់ស៊ីរូងផ្ទៃក្នុង។

៩៤៧- ទិសដៅ និងការត្រួតត្រារបស់មជ្ឈិមបក្សស្តីពីប្រល័យពូជសាសន៍របស់ប្រជាជនវៀតណាម ក៏មានបញ្ជាក់ផងដែរនៅក្នុងរបាយការណ៍ពីមន្ទីរ៨៧០ របស់ រស់ ញឹម លេខាភូមិភាគពាយ័ព្យ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ ដែលបានសួរថា"អង្គការ៨៧០"សម្រេចបែបណា ចំពោះ "សមាសភាពយួន ដែលមានប្តីខ្មែរ និងខ្មែរដែលមានប្រពន្ធយួន ព្រមទាំងកូនកាត់យួនជាដើម"។

៩៤៨- **នួន ជា** បានបញ្ជាក់ពីចេតនា និងផ្នត់គំនិតរបស់គាត់ ចំពោះពួកវៀតណាមនៅក្នុងសុន្ទរកថាមួយធ្វើឡើងក្នុងខែកក្កដា ឆ្នាំ១៩៧៨ ដោយគាត់បានលើកឡើងថា "ភ្នាក់ងាររបស់សេអ៊ីអាមួយចំនួន បានចូលដៃជាមួយពួកវៀតណាម ដើម្បីចូលមកប្រទេសកម្ពុជា" ហើយពួកវៀតណាមមិនបាន"រើសអើងក្នុងការជ្រើសរើសភ្នាក់ងារ"នោះទេ ដោយពួកគេ"ព្រមទទួលមនុស្សគ្រប់ៗរូបដែលវាយ ប.ក.ក"។

## ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

៩៤៩- នៅក្នុងកំរិតមួយដែលពួកគាត់បានបង្ហាញពីអាកប្បកិរិយាជាគំរូដ៏ជាប់លាប់មួយ អំពើរបស់ **នួន ជា** បន្ទាប់ពីការដកហូត បកក ចេញពីអំណាច បានពង្រឹងនូវភស្តុតាងពីការចូលរួមប្រព្រឹត្ត និងចេតនាឧក្រិដ្ឋរបស់គាត់ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។ ដូចដែលបានពិភាក្សានៅខាង ក្រោម **នួន ជា** ដោយបានរត់គេចចេញពីទីក្រុងភ្នំពេញ ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ផ្សេងៗ ទៀតនៃ បកក នៅបានធ្វើការដើម្បីបង្កើតឡើងវិញនូវរចនាសម្ពន្ធដឹកនាំរបស់បក្ស (Party's leadership apparatus) ដែលនៅក្នុងនោះ គាត់បានបន្តដើរតួនាទីសំខាន់មួយ។ គាត់បានបន្តមុខតំណែងរបស់គាត់ក្នុងឋានៈជាសមាជិកលំដាប់ខ្ពស់បំផុតទីពីររបស់បក្ស

ហើយបានធ្វើការជាមួយនឹង **ខៀវ សំផន** ដើម្បីប្រមូលការគាំទ្រសម្រាប់ការតស៊ូអាវុធរបស់ បកក ដើម្បីវិលត្រឡប់ទៅរកអំណាចសាជាថ្មីវិញ។ សូម្បីតែនៅក្រោយពេលដែលគាត់បានដកថយចេញពីជីវិតនយោបាយដ៏សកម្មជាមួយនឹង ប៉ុល ពត និង តាម៉ុក នៅឆ្នាំ១៩៨៩ រួចហើយក៏ដោយ ក៏គាត់នៅតែបានបន្តបញ្ជាកងទ័ព ឲ្យធ្វើការប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលទីក្រុងភ្នំពេញទៀតដែរ គាត់ក៏បាននៅបន្តធ្វើឲ្យខ្លួនគាត់មានការពាក់ព័ន្ធ ទៅនឹងសកម្មភាព

ឧក្រិដ្ឋផ្សេងៗផងដែរ ដូចជា បានធ្វើការបោសសម្អាតពួកប្រឆាំងជាដើម។ គាត់នៅតែបានតាំងចិត្តស៊ប់ និងបានធ្វើការចងសម្ពន្ធភាពយ៉ាងជិតស្និទ្ធជាមួយនឹង ប៉ុល ពត ជាដដែលរហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៩០។ ពេលដែលគាត់បានសម្តែងនូវការសោកស្តាយមួយចំនួនចំពោះការស្លាប់នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ នៅត្រង់ចំណុចមួយនៃការចុះចូលរបស់គាត់ជាមួយនឹងអាជ្ញាធរ ក្នុងឆ្នាំ១៩៩៨ គាត់នៅតែបានតាំងចិត្តស៊ប់ជាសារវន្តចំពោះគោលបំណងឧក្រិដ្ឋនានារបស់ បកក រហូតទាល់សព្វថ្ងៃនេះ ។

## សកម្មភាព និងតួនាទី

៩៥០- នៅថ្ងៃទី៦ ឬទី៧ ខែមករា ឆ្នាំ១៩៧៩ **នួន ជា** និង ប៉ុល ពត បានចាកចេញពីទីក្រុងភ្នំពេញដើម្បីជួបជាមួយ **អៀង សារី** និង **ខៀវ សំផន** នៅស្រុកភ្នំក្រវាញ ក្នុងខេត្តពោធិ៍សាត់។ នៅខែកុម្ភៈ ឬមីនា ឆ្នាំ១៩៧៩ **នួន ជា** និងពួកមេដឹកនាំជាន់ខ្ពស់ដទៃទៀត នៃប.ក.ក បានចូលរួមកិច្ចប្រជុំគណៈមជ្ឈិមលើកដំបូង ដែលបានប្រព្រឹត្តទៅបន្ទាប់ពីមានការឈ្លានពានរបស់វៀតណាម ដែលនៅក្នុងកិច្ចប្រជុំនោះ គាត់បានជម្រុញឲ្យ ប៉ុល ពត នៅតែរក្សាតួនាទីជាលេខាបក្ស។ **នួន ជា** បានរក្សាតួនាទីរបស់គាត់ ជាអនុលេខារបស់គណៈអចិន្ត្រៃយ៍ ប.ក.ក ដដែល។

៩៥១- ចាប់តាំងពីថ្ងៃទី១៥ រហូតដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ គណៈអចិន្ត្រៃយ៍របស់សភាតំណាងប្រជាជន បានសម្រេចជាឯកច្ឆន្ទឲ្យ **នួន ជា** រក្សាតួនាទីរបស់គាត់ជាប្រធានដដែល។ ក្នុងនាមជាប្រធាន **នួន ជា** បានធ្វើសន្និបាតមួយ ជាមួយនឹង **ខៀវ សំផន** នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៨១ ដែលមានការចូលរួមពីសំណាក់អតីតសមាជិកនានារបស់រដ្ឋាភិបាល និងកងទ័ព របស់កម្ពុជា

ប្រជាធិបតេយ្យ ដែលនៅក្នុងសន្និបាតនោះ គេបានធ្វើការសម្រេចចិត្តធ្វើការចរចាជាមួយ រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលដឹកនាំដោយលោក ស៊ឺន សាន ហើយ ពួករាជានិយម ដែលដឹកនាំដោយសម្តេចនរោត្តមសីហនុ ពាក់ព័ន្ធនឹងការបង្កើតរណសិរ្សរួម មួយ ដើម្បីតស៊ូប្រយុទ្ធជាមួយពួកវៀតណាម។ ជួសមុខឱ្យតំណាងសភាប្រជាជនកម្ពុជា ប្រជាធិបតេយ្យ **នួន ជា** និង **ខៀវ សំផន** ក៏បានចេញសារាចរណែនាំនានា ជម្រុញឱ្យយោធា ជនស៊ីវិល និងជនរួមជាតិនៅឯបរទេស ឱ្យស្នេហាជាតិមាតុភូមិ ក្នុងការតស៊ូប្រឆាំង នឹងពួកវៀតណាម។

៩៥២- **នួន ជា** បានចូលពាក់ព័ន្ធយ៉ាងសកម្មនៅក្នុងប្រតិបត្តិការយោធា។ គាត់បានចុះទៅគ្រប់ទិសទីក្នុង ប្រទេសកម្ពុជាបានចែកសម្ភារៈផ្គត់ផ្គង់ផ្សេងៗទៅឱ្យកម្មាភិបាល និងអ្នកប្រយុទ្ធ ហើយនៅចុង ខែមេសា ឆ្នាំ១៩៧៩ គាត់បានបង្កើតភូមិភាគតស៊ូរបស់ ប.ក.ក មួយនៅជិតព្រំដែនថៃ។ ក្នុង ឆ្នាំ១៩៨១ **នួន ជា** គឺជាប្រធានគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ទៅចូលរួមក្នុងសន្និបាតសភា អាស៊ីនៅទីក្រុងប៉េកាំង ដែលនៅទីនោះគាត់បានគាំទ្រខាង ប.ក.ក ចំពោះជម្លោះផ្ទៃក្នុង ដែលកំពុងកើតមាននៅក្នុងប្រទេសកម្ពុជា។

៩៥៣- ក្នុងឆ្នាំ១៩៨៣ **នួន ជា** បានបង្ហាញពីការដឹងឮរបស់គាត់ពីអំពើឧក្រិដ្ឋនានា ដែលគាត់បាន ប្រព្រឹត្ត រួមជាមួយចេតនា និងការខិតខំប្រឹងប្រែងរបស់គាត់ ក្នុងការបំផ្លាញភស្តុតាងអំពីអំពើ ឧក្រិដ្ឋអស់ទាំងនោះ ដោយនៅពេលនោះគាត់បានប្រាប់ទៅ **ឌុច** ថា គាត់បាន“កម្ទេច”ឯកសារ ផ្ទាល់ខ្លួនរបស់គាត់អស់ហើយ ហើយបានបន្ទោស **ឌុច** ដែលមិនបានបំផ្លាញឯកសារសំខាន់ៗ នៅមន្ទីរស-២១ មុនពេលដែលពួកវៀតណាមចូលកាន់កាប់ទីក្រុងភ្នំពេញ។ នៅចុងឆ្នាំ១៩៨៣

ឬដើមឆ្នាំ១៩៨៤ បន្ទាប់ពីការរំលាយ ប.ក.ក ជាផ្លូវការ នួន ជា បានបង្កើតវគ្គរៀនសូត្រនយោបាយមួយនៅសំឡូតដែលនៅក្នុងវគ្គរៀនសូត្រនោះ គាត់បានប្រកាសថា "លទ្ធិកុម្មុយនិស្តវាគ្រាន់តែជាមធ្យោបាយសម្រាប់ស្នេហាជាតិតែប៉ុណ្ណោះ"។

៩៥៤- ក្នុងខែកក្កដា ឆ្នាំ១៩៨៩ នួន ជា ប៉ុល ពត និង តា ម៉ុក គឺជាថ្នាក់ដឹកនាំញរូបដែលត្រូវបានគេសុំឲ្យ"ចូលនិវត្តន៍"ពីតួនាទីរបស់ពួកគាត់ ដើម្បីអាចឲ្យការចរចាសន្តិភាពអាចប្រព្រឹត្តទៅបាននៅទីក្រុងប៉ារីសក្នុងខែនោះ ហើយពួកគាត់បានព្រមព្រៀងថានឹងចូលនិវត្តន៍ ប្រសិនបើកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជា។ ទោះបីមានការព្រមព្រៀងរបស់ពួកគេទាំង៣ ព្រមជាមួយនឹងការដកចេញរបស់កងទ័ពវៀតណាមលើកចុងក្រោយក្នុងខែកញ្ញា ឆ្នាំ១៩៨៩ ក៏ដោយក៏ នួន ជា និង ប៉ុល ពត នៅតែបន្តត្រួតត្រាតំបន់យោធាដោយឡែកនៅកម្ពុជា។ នៅចុងខែឧសភា ឆ្នាំ១៩៩២ ប៉ុល ពត នួន ជា និង តា ម៉ុក បានបដិសេធមិនអនុញ្ញាតឲ្យអធិការរបស់អង្គការសហប្រជាជាតិចូលត្រួតពិនិត្យតំបន់នានា ដែលស្ថិតក្រោមការត្រួតត្រារបស់ពួកគេទេ ពួកគេបានសម្តែងនូវឆន្ទៈមិនព្រមបោះបង់អាវុធរបស់កងកម្លាំងខ្លួន ព្រមទាំងបដិសេធមិនព្រមធ្វើការចរចាជាមួយនឹង"អាយ៉ងវៀតណាម" នៅភ្នំពេញទៀត ផង។

៩៥៥- ពេញមួយទសវត្សរ៍ឆ្នាំ១៩៩០ នួន ជា បានធ្វើបាឋកថានៅមន្ទីរ៨៧ ដែលជាទីបញ្ជាការរបស់ប៉ុល ពត ដោយនៅទីនោះ វគ្គរៀនសូត្រផ្សេងៗសំរាប់មេបញ្ជាការកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យ(NADK)។ នួន ជា បានបន្តដឹកនាំការតស៊ូក្នុងខែឧសភា ឆ្នាំ១៩៩៤ ហើយនៅក្នុងខែសីហា ឆ្នាំ១៩៩៦ នួន ជា សុន សេន និង តា ម៉ុក បានដឹកនាំ ការបោសសម្អាតនានាប្រឆាំងនឹងពួកទ័ពព្រៃផ្តាច់ខ្លួននៅខេត្តប៉ៃលិន។

៩៥៦- នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ បន្ទាប់ពី ប៉ុល ពត បានចេញបញ្ជាឲ្យសម្លាប់ សុន សេន និងក្រុមគ្រួសាររបស់គាត់រួចមក តា ម៉ុក បានដាក់ ប៉ុល ពត ឲ្យស្ថិតក្រោមការ"ឃុំខ្លួនក្នុងផ្ទះ" និងបើកសវនាការឲ្យគ្រាន់តែល្អមើលមួយលើរូប ប៉ុល ពត ពីបទមនុស្សឃាតដែលកើតមាននោះ។ នៅចុង ឆ្នាំ១៩៩៧ **នួន ជា** នៅតែបន្តនៅជាមួយ ប៉ុល ពត ហើយបដិសេធមិនព្រមប្រគល់ខ្លួន ប៉ុល ពត ទៅឲ្យតុលាការអន្តរជាតិ ឬតុលាការយោធាឡើយ។ រហូតដល់ខែធ្នូ ឆ្នាំ១៩៩៨ រយៈពេល លើសពី៦ខែ ក្រោយពី ប៉ុល ពត បានស្លាប់ ទើប **នួន ជា** និង **ខៀវ សំផន** បានយល់ព្រមបញ្ចប់ការតស៊ូប្រដាប់អាវុធរបស់ពួកគេ ព្រមទាំងប្រគល់ខ្លួនឲ្យរដ្ឋាភិបាលភ្នំពេញ។ នៅឯសន្និសីទសារព័ត៌មានមួយដែលបានធ្វើឡើងនាឱកាសនោះ នៅពេលដែលត្រូវគេសួរថា តើគាត់មានវិប្បដិសារីចំពោះការសម្លាប់មនុស្សដែលបានកើតមាន ពេលដែលគាត់កាន់អំណាចនោះទេ **នួន ជា** បាននិយាយបែបកំប្លែងយ៉ាងមុតថា "សោកស្ដាយណាស់" "មិនមែនសោកស្ដាយតែជីវិតមនុស្សប៉ុណ្ណោះទេ សូម្បីជីវិតសត្វដែលបានបាត់បង់ជីវិតនៅក្នុងសង្គ្រាម ក៏ស្ដាយដែរ" ហើយ គាត់ និង **ខៀវ សំផន** បានអំពាវនាវទៅកាន់ពិភពលោកថា "ឲ្យបំភ្លេចអ្វីដែលបានកន្លងហួសទៅ"។

## ការដឹងឮ និងការបដិសេធឧក្រិដ្ឋកម្ម

៩៥៧- សេចក្ដីថ្លែងការណ៍នាពេលថ្មីៗនេះរបស់ **នួន ជា** បានបញ្ជាក់ពីចេតនារបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងការបោសសម្អាតរាល់សត្រូវទាំងឡាយរបស់ ប.ក.ក នៅស-២១ និងនៅតាមមន្ទីរសន្តិសុខនានារបស់កម្ពុជាប្រជាធិបតេយ្យផងដែរ។ នៅក្នុងកិច្ចសម្ភាសន៍មួយក្នុងឆ្នាំ២០០៥ **នួន ជា** បានថ្លែងថា"យើងសម្លាប់តែមនុស្សអាក្រក់ប៉ុណ្ណោះ" ហើយ

ហេតុផលដែលធ្វើឱ្យមានការបោសសម្អាតនោះ គឺ“មនុស្សមួយចំនួនដែលទទួលបន្ទុកនៅតាមបណ្តាស្រុក និងខេត្តនានាគឺជាខ្មាំងរបស់យើង... ពួកក្បត់ទាំងនេះមិនគោរពតាមគោលនយោ បាយរបស់យើងទេ”។ ក្នុងខែមិថុនា ឆ្នាំ២០០៦ គាត់បានអះអាងថា ខ្មាំងអាមេរិក និងវៀតណាម បាន“បង្កប់ខ្លួនក្នុងជួរកម្មាភិបាល” ហើយ“បានបំផ្លាញរបបរបស់ខ្ញុំតាមរយៈការមិនគោរពតាមគោលនយោបាយ”។ គាត់បានការពារមន្ទីរស២១ ថាជា ស្ថាប័ន “ដែលត្រូវបានបង្កើតឡើង ដើម្បីស្រាវជ្រាវរកខ្មាំងរបស់ប្រទេស”ដែលប្រើសម្រាប់ តែ“កម្មាភិបាលមិនល្អ”តែប៉ុណ្ណោះ។

៩៥៨- នៅក្នុងខែតុលា ឆ្នាំ២០០៦ **នួន ជា** បានពោលអះអាងការពារថា មានខ្មាំង “បង្កប់” ហើយអះអាងទៀតថា បដិវត្តន៍របស់ ប.ក.ក គឺ“ត្រឹមត្រូវដោយសារបដិវត្តន៍បានកម្ទេច និងកំចាត់ខ្មាំង” និងបន្តអះអាងទៀតថា “សិទ្ធិដែលធំបំផុត” និង“សិទ្ធិមនុស្សដែលមានសារៈសំខាន់បំផុតនោះគឺជាសិទ្ធិក្នុងការចាប់យកអាវុធប្រយុទ្ធជាមួយនឹងខ្មាំង”។ គួរឱ្យហួសចិត្តនោះ នៅក្នុងកិច្ចសម្ភាសន៍ដដែលនេះ **នួន ជា** បានដកស្រង់យកសម្តីរបស់ Albert Einstein ដែលបាននិយាយថា“ប្រសិនបើយើងមិនផ្លាស់ប្តូរគំនិតរបស់យើងទេ យើងមិនអាចសម្រេចការងារបានទេ”។

៩៥៩- [redacted]

[redacted]។

៩៦០- មកទល់ពេលបច្ចុប្បន្ននេះ **នួន ជា** បានធ្វើការសុំទោសតែបន្តិចបន្តួច និងបានបង្ហាញនូវវិប្បដិសារីដែលមិនពិតប្រាកដពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានា ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្ទុយទៅវិញ នៅពេលដែលគាត់ត្រូវបានគេសាកសួរថា តើគាត់នឹងធ្វើបដិវត្តន៍ទៀតទេ ប្រសិនបើគាត់កើតម្តងទៀត គាត់បានឆ្លើយតបដោយគ្មានមន្ទិលថា"ធ្វើទៀត ធ្វើទៀត"។

## អៀង សារី

### ទិដ្ឋភាពទូទៅ

៩៦១- ផ្នែករងខាងក្រោមនេះពណ៌នាអំពីទិដ្ឋភាពទូទៅនៃការជាប់ពាក់ព័ន្ធរបស់ **អៀង សារី** និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនានាដែលស្ថិតក្រោមការស៊ើបអង្កេត។

៩៦២- **អៀង សារី** ជាសមាជិកក្នុងក្រុមតូចមួយនៃពួកមេដឹកនាំដែលបានបង្កើតបក្សកុម្មុយនីស្តកម្ពុជានៅខែកញ្ញា ឆ្នាំ១៩៦០ និងបានបង្កើតមាគ៌ាស្នូលរបស់បក្ស។ នៅពេលនោះ គាត់ត្រូវបានជាប់ឆ្នោតជាសមាជិកគណៈមជ្ឈិម និងជាសមាជិកត្រៀមគណៈអចិន្ត្រៃយ៍មានលំដាប់ទី៤នៅក្នុងឋានានុក្រមរបស់បក្ស ហើយគាត់បានក្លាយជាសមាជិកពេញសិទ្ធិគណៈអចិន្ត្រៃយ៍នៅឆ្នាំ១៩៦៣។ ក្រោយឆ្នាំ១៩៧១ **អៀង សារី** តំណាងបក្សកុម្មុយនីស្តកម្ពុជានៅលើឆាកអន្តរជាតិក្នុងការស្វែងរកការគាំទ្រពីបរទេសចំពោះបក្សកុម្មុយនីស្តកម្ពុជា និងដើម្បីរក្សាការគ្រប់គ្រង

របស់បក្សកុម្មុយនីស្តកម្ពុជាទៅលើរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា។

៩៦៣- ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ **អៀង សារី** បានកាន់តំណែងជាច្រើនដោយស្ម័គ្រចិត្តដែលមានការទទួលខុសត្រូវ និងមានឥទ្ធិពលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមានតំណែងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសជាដើម។ នៅក្នុងមុខនាទីនេះ គាត់បានដឹកនាំក្រសួងការបរទេសដែលមានទំនាក់ទំនងជាមួយបណ្តាស្ថានទូតបរទេស និងគ្រប់គ្រងកន្លែងអប់រំកែប្រែមួយចំនួនទៀត។ នៅលើឆាកអន្តរជាតិវិញ គាត់តំណាងកម្ពុជាប្រជាធិបតេយ្យនៅចំពោះមុខស្ថាប័នអន្តរជាតិនានា រួមមានមហាសន្និបាតរបស់អង្គការសហប្រជាជាតិ បំពេញទស្សនកិច្ចនៅបរទេស ចេញសេចក្តីថ្លែងការណ៍ និងសុន្ទរកថាការពាររបបកម្ពុជាប្រជាធិបតេយ្យ និងច្រានចោលការចោទប្រកាន់នានាស្តីពីការរំលោភសិទ្ធិមនុស្ស។ គាត់បានបន្តមុខងារជាសមាជិកពេញសិទ្ធិគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមដែលជាស្ថាប័នកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការចេញសេចក្តីសម្រេចចិត្ត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានរស់នៅនិងបំពេញការងារយ៉ាងជិតស្និទ្ធជាមួយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ដែលជាផ្នែកមួយនៃមជ្ឈដ្ឋានផ្ទៃក្នុងរបស់ថ្នាក់លើបង្អស់របស់បក្ស។

៩៦៤- អំពើនានាដែលនាំឱ្យ **អៀង សារី** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋនានាដែលស្ថិតក្រោមការស៊ើបអង្កេត រួមមានតែមិនកំណត់ត្រឹម៖ (ក)ការចូលរួមរបស់គាត់នៅក្នុងមហាសន្និបាតបក្ស និងការប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមដែលបង្កើតនូវផែនការ

ឧក្រិដ្ឋកម្មរបស់ បកក ទទួល និងពិភាក្សាទៅលើរបាយការណ៍ស្ដីពីដំណើរការផែនការទាំងនោះ និងចេញសារាចរណែនាំបន្ថែមទៀត ដើម្បីធានាការអនុវត្តនូវផែនការនោះ (ខ)ការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការចេញសេចក្ដីថ្លែងការណ៍ សុន្ទរកថាជាសាធារណៈ និងការអប់រំនយោបាយ និងការលត់ដំដល់កម្មាភិបាល និងបញ្ញវន្ត (គ)ការឯកភាព និងការជួយជាសំខាន់ក្នុងការសម្រិតសម្រាំងកម្មាភិ បាលបក្សកុម្មុយនីស្ដកម្ពុជា ដោយការទទួលនិងពិនិត្យចម្លើយសារភាពរបស់កម្មាភិបាលដែលគេចាប់ខ្លួន ការស៊ើបអង្កេត និងការរាយការណ៍អំពីកម្មាភិបាលដែលគេឆ្លើយដាក់ និងការទទួលព័ត៌មាន និងឯកភាពទៅលើការចាប់ខ្លួននិងការសម្លាប់មនុស្ស (ឃ)តំណាងកម្ពុជាប្រជាធិបតេយ្យទាំងនៅក្នុងប្រទេស និងអន្តរជាតិ និងការចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់មិនឲ្យរកឃើញពីឧក្រិដ្ឋកម្មដែលកំពុងបន្តប្រព្រឹត្តដោយបក្សកុម្មុយនីស្ដកម្ពុជា និង(ង)ការចូលរួមប្រជុំ និងធ្វើការជាទៀងទាត់ផ្សេងទៀតជាមួយសមាជិកជាន់ខ្ពស់នៃសហាកម្មឧក្រិដ្ឋកម្មរួមដទៃទៀត និងការប្រតិបត្តិអំណាចរបស់ខ្លួនក្នុងការរៀបចំផែនការ និងជួយដល់ការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម។

៩៦៥- **អៀង សារី** បានរៀបចំផែនការ ឯកភាព និងចូលរួមក្នុងការសម្រិតសម្រាំងនៅក្នុងក្រសួងការបរទេសដែលបណ្ដាលឲ្យបុគ្គលិកនៅក្នុងក្រសួងនេះចំនួនមួយភាគបួន ត្រូវបានបញ្ជូនទៅមន្ទីរស២១ ដែលនៅពេលជាមួយគ្នានោះ គាត់បានប្រើអំណាចរបស់ខ្លួនការពារកម្មាភិបាលមួយចំនួនតូចដែលជិតស្និទ្ធនឹងគាត់។ **អៀង សារី** ក៏មានការទទួលខុសត្រូវផងដែរ ចំពោះកន្លែង"អប់រំកែប្រែ" និងលត់ដំ ដូចជាច្រាំងចំរេះ និងបឹងត្របែកជាកន្លែងដែលនិស្សិត បញ្ញវន្ត និងអតីតអ្នកការទូត និងមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលវិលត្រឡប់មកប្រទេសកម្ពុជាវិញ ទទួលរងនូវការធ្វើពលកម្មដោយបង្ខំ និងការបញ្ចូលមនោគមន៍វិជ្ជានយោបាយ។ ក្នុងនាមជាសមាជិក

គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ **អៀង សារី** បានអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើស្ថាប័នឃោសា រដ្ឋបាល និងតំបន់ជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យទាក់ទិននឹងការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មនានា និងទោះបីគាត់ទទួលបានរបាយការណ៍ទៀងទាត់ដែលមានព័ត៌មានអំពើឧក្រិដ្ឋកម្មដែលកំពុងប្រព្រឹត្តឡើងដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទាំងនោះនៅទូទាំងប្រទេស ខកខានមិនបានទប់ស្កាត់ការប្រព្រឹត្តិអំពើឧក្រិដ្ឋទាំងនោះ ឬមិនបានចាត់វិធានការណាមួយក្នុងការស៊ើបអង្កេត និងដាក់ទណ្ឌកម្មដល់ចារីដែលប្រព្រឹត្តផ្ទាល់នោះទេ។ ផ្ទុយទៅវិញ ក្នុងសមត្ថភាពរបស់ខ្លួនជារដ្ឋមន្ត្រីការបរទេស គាត់ធ្វើមិនដឹងមិនឮ ឬច្រានចោលចំពោះការអំពាវនាវរបស់អន្តរជាតិឱ្យធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់អំពីឧក្រិដ្ឋកម្មជាទ្រង់ទ្រាយធំនៅប្រទេសកម្ពុជា។

៩៦៦- ចាប់ពីខែមករា ឆ្នាំ១៩៧៩ យ៉ាងហោចណាស់រហូតដល់ឆ្នាំ១៩៩២ **អៀង សារី** បន្តបម្រើក្នុងឋានៈជាថ្នាក់ដឹកនាំម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាដែលនៅក្នុងពេលនោះ គាត់បានប្រយុទ្ធដើម្បីទាមទារឱ្យបក្សកុម្មុយនីស្តកម្ពុជាអាចវិលត្រឡប់មកកាន់អំណាចសាជាថ្មីវិញ និងជាតំណាងបក្សកុម្មុយនីស្តកម្ពុជានៅចំពោះមុខបរទេស ស្ថាប័ន និងបណ្តាញសារព័ត៌មានអន្តរជាតិ។ ទំនាក់ទំនងយ៉ាងជិតស្និទ្ធទាំងលក្ខណៈបុគ្គល វិជ្ជាជីវៈ និងនយោបាយរបស់ **អៀង សារី** ជាមួយសមាជិកសហកម្មឧក្រិដ្ឋកម្មរួមដទៃទៀតមានរយៈពេលជាង៤០ឆ្នាំ ចាប់ពីដើមទសវត្សរ៍ឆ្នាំ១៩៥០ រហូតដល់ឆ្នាំ១៩៩៦ ស្ទើរតែពេញមួយជីវិតនៃការសិក្សា និងវិជ្ជាជីវៈរបស់ខ្លួន។

## តួនាទីមុនឆ្នាំ១៩៧៥

៩៦៧- **អៀង សារី** មានឈ្មោះកំណើតថា គីម ត្រាង កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅខេត្តតាយនិញជាតំបន់មួយដែលនិយាយភាសាខ្មែរនៅវៀតណាមភាគខាងត្បូង។ ឪពុកគាត់ស្លាប់តាំងពីគាត់នៅក្មេង ហើយគាត់ត្រូវបានបញ្ជូនឲ្យទៅរស់នៅជាមួយសាច់ញាតិ នៅខេត្តព្រៃវែង ប្រទេសកម្ពុជា។ គាត់បានប្តូរមកឈ្មោះ **អៀង សារី** នៅអំឡុងពេលនោះ។

៩៦៨- **អៀង សារី** ចាប់ផ្តើមចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិក្នុងក្រុងភ្នំពេញនាឆ្នាំ១៩៤៥។ នៅវិទ្យាល័យស៊ីសុវត្ថិ គាត់បានជួប **អៀង ធីរិទ្ធ** ក្នុងឆ្នាំ១៩៤៦ ដែលជាអ្នកសកម្មខាងនយោបាយក្នុងចលនាបដិវត្តន៍ប្រឆាំងនឹងអាណានិគមនិយមបារាំង។ នៅឆ្នាំបន្ទាប់ គាត់ក៏បានជួបជាមួយសិស្សម្នាក់ទៀតនៅវិទ្យាល័យស៊ីសុវត្ថិ ឈ្មោះ សាឡុត ស ហៅ ប៉ុល ពត។ ក្នុងនាមជាសិស្ស **អៀង សារី** ក្លាយជាសកម្មជននយោបាយ និងបានចូលរួមយុទ្ធនាការយ៉ាងក្តៅគគុកសម្រាប់គណបក្សប្រជាធិបតេយ្យនៅក្នុងការបោះឆ្នោតជាតិលើកដំបូង នៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៤៦។ គាត់ក៏បានជួយរៀបចំការបះបោររបស់សិស្សដែលបណ្តាលឲ្យមានការចាប់ខ្លួនមនុស្សជាច្រើននាក់រួមទាំងរូបគាត់ផងនៅពេលដែលសម្តេចសីហនុបានព្យួរសភាជាតិ នៅឆ្នាំ១៩៤៨។ ក្នុងអំឡុងពេលនេះ **អៀង សារី** បានអាន និងសិក្សាឯកសារ *Communist Manifesto*។

៩៦៩- **អៀង សារី** បានធ្វើដំណើរទៅក្រុងប៉ារីសនៅខែវិច្ឆិកា ឆ្នាំ១៩៥០ ដើម្បីសិក្សានយោបាយនៅសាលា *Ecole Normale Superieure* ជាកន្លែងដែលគាត់បានចូលរួមជាមួយអតីតមិត្តរួមថ្នាក់របស់គាត់ជាច្រើនដែលមកពីវិទ្យាល័យស៊ីសុវត្ថិ។ នៅពេលទៅដល់ទីនោះបានរយៈពេលមួយខែ **អៀង សារី** ចាប់ផ្តើមចូលរួមក្រុមពិភាក្សាជាមួយបណ្តានិស្សិតកម្ពុជាដទៃទៀតនៅក្រុង

ប៉ារីស និងបានចូលរួមបក្សកុម្មុយនីស្តបារាំង។ គាត់ក៏បានចូលរួមជាមួយសមាគមនិស្សិតខ្មែរ(AEK)ដោយបានចូលរួមក្នុងក្រុមពិភាក្សាជាទៀងទាត់ ដែលទាក់ទិននឹងអនាគតនយោបាយរបស់ប្រទេសកម្ពុជា និងបានបំពេញការងារជាប្រធានសមាគមនិស្សិតខ្មែរ(AEK)ពីឆ្នាំ១៩៥៣ដល់ឆ្នាំ១៩៥៦។ បន្ទាប់ពីបានចូលរួមក្នុងសន្និបាតមួយរបស់និស្សិតនៅក្រុងប៉ែរឡាំង **អៀង សារី** និងសមាជិក AEK ដទៃទៀត បានធ្វើសេចក្តីសន្និដ្ឋានថាប្រទេសកម្ពុជាចាំបាច់ត្រូវមានបដិវត្តន៍កុម្មុយនីស្តមួយ ដើម្បីអាចសម្រេចបាននូវឯករាជ្យភាពពិតប្រាកដ។

៩៧០- បន្ទាប់មក **អៀង សារី** ចាប់ផ្តើមធ្វើយុទ្ធនាការដើម្បីស្វែងរកការគាំទ្រពីក្នុងចំណោមក្រុមនយោបាយកម្ពុជាផ្សេងទៀតដែលប្រតិបត្តិការនៅប្រទេសបារាំង និងបានចាប់ផ្តើមរៀបចំបង្កើតអង្គការសម្ងាត់មួយមានឈ្មោះថា ក្រុមម៉ាក្ស-លេនីន ដែលរួមមានផ្នែកឯករាជ្យដែលជ្រើសរើសបុគ្គល និងធ្វើការលើកស្ទួយទ្រឹស្តីកុម្មុយនីស្តជាមធ្យោបាយមួយ ក្នុងការសម្រេចឲ្យបាននូវឯករាជ្យភាពរបស់កម្ពុជា។ ក្រុមនេះរួមមាន ប៉ុល ពត **ខៀវ សំផន អៀង ធីរិទ្ធ** និង ខៀវ ប៉ុណ្ណារី។

៩៧១- នៅពេលកំពុងស្នាក់នៅប្រទេសបារាំង **អៀង សារី** បានរីតចំណងសាមគ្គីភាពទំនាក់ទំនងផ្ទាល់ខ្លួនដែលនាំឲ្យមានការបង្កើតជាថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានបង្កើនទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយ ប៉ុល ពត និងនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៣ បានរៀបការជាមួយ **អៀង ធីរិទ្ធ**។ ក្រោយមក ប៉ុល ពត បានរៀបការជាមួយ ខៀវ ប៉ុណ្ណារី ដែលជាបងស្រីរបស់ **អៀង ធីរិទ្ធ**។

៩៧២- **អៀង សារី** បានវិលត្រឡប់មកក្រុងភ្នំពេញវិញជាមួយ **អៀង ធីរិទ្ធ** នៅខែមករា ឆ្នាំ១៩៥៧ ដោយទុកឱ្យ **ខៀវ សំផន** ជាអ្នកមើលការខុសត្រូវក្នុងក្រុមនោះ។ នៅក្រុងភ្នំពេញ **អៀង សារី** ចាប់ផ្តើមធ្វើការជាគ្រូបង្រៀននៅវិទ្យាល័យស៊ីសុវត្ថិ។ នៅក្នុងអំឡុងពេលនោះ គាត់បន្តស្ថាបនាការគាំទ្រចលនាកុម្មុយនីស្តកម្ពុជា ដោយរៀបចំក្រុមពិភាក្សានិងបានចូលរួមក្នុងបក្សប្រជាជនបដិវត្តន៍កម្ពុជា (KPRP)។

៩៧៣- ពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៦០ **អៀង សារី** ជាផ្នែកមួយនៃក្រុមតូចមួយ ដែលមានសមាជិកប្រហែល២០នាក់ រួមមាន ប៉ុល ពត **នួន ជា** និង សោ ភឹម ដែលបានចូលរួមក្នុងមហាសន្និបាតលើកដំបូងរបស់បក្សពលករកម្ពុជា(WPK) ជាឈ្មោះថ្មីរបស់ KPRP ដែលកើតមុនបក្សកុម្មុយនីស្តកម្ពុជា។ នៅក្នុងមហាសន្និបាតនោះ **អៀង សារី** និងអ្នកចូលរួមផ្សេងទៀត បានអនុម័តនូវមាគ៌ានយោបាយរបស់បក្សជាលើកដំបូង ដែលរួមមានការប្រើអំពើហិង្សាប្រដាប់អាវុធ ដើម្បីលុបបំបាត់ខ្មាំងសត្រូវរបស់បក្ស និងធ្វើសេចក្តីសន្និដ្ឋានថា ទីជនបទនឹងក្លាយជាមូលដ្ឋានរបស់បក្ស ពីព្រោះទីក្រុងគឺជា“ក្បាលម៉ាស៊ីន”របស់ខ្មាំងសត្រូវ។ **អៀង សារី** ត្រូវបានជាប់ឆ្នោតនៅក្នុងគណៈមជ្ឈិម និងជាសមាជិកត្រៀមនៅក្នុងគណៈអចិន្ត្រៃយ៍ ដែលមានលំដាប់ទី៤ នៅក្នុងឋានានុក្រមរបស់បក្ស។

៩៧៤- នៅឆ្នាំ១៩៦០ **អៀង សារី** និងសមាជិកបក្សពលករកម្ពុជាដទៃទៀតចាប់ផ្តើមធ្វើដំណើរទៅតាមបណ្តាខេត្តនានាដោយប្រមូលផ្តុំមនុស្ស និងធ្វើសេចក្តីថ្លែងការណ៍ ដើម្បីស្ថាបនាមូលដ្ឋានបក្សនៅទីជនបទ។ នៅឯមហាសន្និបាតលើកទីពីររបស់បក្សក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ **អៀង សារី** ត្រូវបានជាប់ឆ្នោតជាសមាជិកពេញសិទ្ធិនៅក្នុងគណៈអចិន្ត្រៃយ៍។ នៅខែមេសា ឆ្នាំ១៩៦៣ បន្ទាប់ពី

ឈ្មោះរបស់គាត់ ត្រូវបានផ្សព្វផ្សាយដោយរបបសម្តេចសីហនុ នៅក្នុងបញ្ជីឈ្មោះមនុស្ស ចំនួន៣៤នាក់ ដែលគេស្គាល់ថាជា"ពួកឆ្វេងនិយម" **អៀង សារី** បានចាកចេញពីក្រុងភ្នំពេញ និងបានចូលរួមជាមួយ ប៉ុល ពត និង សុន សេន នៅមូលដ្ឋានយោធាវៀតណាមមួយនៅតាមបណ្តោយព្រំដែនដែលក្រោយមកពួកគេបានបង្កើតជាមូលដ្ឋានថ្មីរបស់បក្ស និងបានឲ្យឈ្មោះថាមន្ទីរ១០០។

៩៧៥- នៅខែតុលា ឆ្នាំ១៩៦៦ គណៈមជ្ឈិមបានសម្រេចចិត្តផ្លាស់ប្តូរស្នាក់ការគណបក្សមកខេត្តរតនគិរី និងបានចាប់ផ្តើមរៀបចំការប្រយុទ្ធតាមផ្លូវយោធា។ **អៀង សារី** រួមទាំងកម្មាភិបាលដទៃទៀត ត្រូវបានបញ្ជូនទៅខេត្តរតនគីរីដើម្បីរៀបចំស្នាក់ការថ្មីរបស់គណៈមជ្ឈិម ហើយ **អៀង សារី** ត្រូវបានស្នើឲ្យកាន់តំណែងជាលេខាភូមិភាគឦសាន។ មានការបះបោរមួយបានធ្វើឡើងនៅខែមករា ឆ្នាំ១៩៦៨ និងនៅសរទរដូវនាឆ្នាំដដែលនោះ បក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងឃុំចំនួន៣១ ក្នុងចំណោម៣៥ឃុំ ក្នុងខេត្តរតនគិរី។

៩៧៦- នៅចុងឆ្នាំ១៩៧០ បន្ទាប់ពីសម្តេចសីហនុ ត្រូវបានទម្លាក់ពីអំណាច កាលពីដើមឆ្នាំនោះ **អៀង សារី** បានធ្វើដំណើរទៅក្រុងហាណូយ ដើម្បីរៀបចំបង្កើតស្ថានីយ៍វិទ្យុ "សម្លេងរណសិរ្សរួបរួមជាតិកម្ពុជា"។ ពីមូលដ្ឋានរបស់គាត់នៅប្រទេសវៀតណាម **អៀង សារី** បានធ្វើដំណើរទៅក្រុងប៉េកាំង ដើម្បីជួបជាមួយតំណាងបក្សកុម្មុយនីស្តចិន ដោយដំបូងបានទៅដល់ក្រុងប៉េកាំងនៅពាក់កណ្តាលឆ្នាំ១៩៧១ ក្នុងឋានៈជា"បេសកជនពិសេសរបស់ចលនាតស៊ូ"។ បន្ទាប់មកនៅឆ្នាំ១៩៧១ គាត់បានទទួលទីស្នាក់អាស្រ័យអចិន្ត្រៃយ៍មួយនៅក្រុងប៉េកាំង ដោយមានខ្សែទូរស័ព្ទទាក់ទងដោយផ្ទាល់ទៅមូលដ្ឋានរបស់ ប៉ុល ពត នៅប្រទេសកម្ពុជា និងបន្តសកម្មភាពជាអ្នក

តំណាងសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជានៅប្រទេសចិន។ ការងាររបស់ **អៀង សារី** នៅក្រុងប៉េកាំង គឺបង្កើនការគាំទ្រពីបរទេសដល់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីរឹតចំណងការគាំទ្ររបស់ចិនចំពោះឯករាជ្យភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ចេញពីចលនាកុម្មុយនីស្តវៀតណាម ដើម្បីតាមដាន និងសម្របសម្រួលសកម្មភាពរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា និងធានាថាពួកគេគាំទ្រដល់គោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបញ្ចូលសមាជិកពួកគេខ្លះទៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងដើម្បីតាមដានសម្តេចសីហនុ។

៩៧៧- **អៀង សារី** បានវិលត្រឡប់មកប្រទេសកម្ពុជាយ៉ាងហោចណាស់ក៏២ដងដែរ ក្នុងអំឡុងពេលដែលគាត់តាំងមូលដ្ឋាននៅក្រុងប៉េកាំង។ នៅឆ្នាំ១៩៧៣ គាត់បានធ្វើដំណើរទៅកាន់តំបន់រំដោះរបស់បក្សកុម្មុយនីស្តកម្ពុជាជាមួយសម្តេចសីហនុ។ នៅឆ្នាំ១៩៧៤ គាត់បានត្រឡប់មកចូលរួមការប្រជុំគណៈមជ្ឈិមដែលនៅពេលនោះ មានការរៀបចំគម្រោងការវាយប្រហារចុងក្រោយដើម្បីរំដោះ និងជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់គាត់ក្នុងឆ្នាំ១៩៧៤នេះ គាត់ក៏បានទៅទស្សនកិច្ចនៅកែបជាមួយប្រតិភូចិនដែរ ដើម្បីផលិតខ្សែភាពយន្ត និងបានថ្លែងការណ៍នៅក្នុងការជួបជុំមួយជាមួយប្រជាជននៅជនបទ ដោយជំរុញពួកគេឲ្យ"បង្ហាញពីសាមគ្គីភាពក្នុងការវាយប្រយុទ្ធប្រឆាំងពួក លន់ នល់ ... [ជាមួយ] ចម្រូង និងស្នា ពីព្រោះ[វាជា]សង្គ្រាមប្រជាជន"។

៩៧៨- **អៀង សារី** ក៏ធ្លាប់បានបន្តដំណើរទស្សនកិច្ចទៅបរទេសក្នុងឋានៈជាប្រេសិតពិសេស។ នៅឆ្នាំ១៩៧១ គាត់បានទៅបំពេញទស្សនកិច្ច និងបានចូលរួមព្រឹត្តិការណ៍ផ្លូវការនានានៅប្រទេសចិន

និងប្រទេសវៀតណាម ឆ្នាំ១៩៧២ នៅប្រទេសចិន ឆ្នាំ១៩៧៣ នៅប្រទេសសេនេហ្គាល និងវៀតណាម ឆ្នាំ១៩៧៤ នៅប្រទេសវៀតណាម ប្រទេសចិន ប្រទេសកូរ៉េខាងជើង ប្រទេសឡាវ ទ្វីបអឺរ៉ុប និងទ្វីបអាហ្វ្រិក និងឆ្នាំ១៩៧៥ នៅប្រទេសវៀតណាម និងប្រទេសចិន។

៩៧៩- **អៀង សារី** បានចូលមកប្រទេសកម្ពុជាពីប្រទេសវៀតណាម នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៥ ប្រហែលមួយសប្តាហ៍បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាទទួលជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ក៏ប៉ុន្តែ មុនពេលមកដល់ **អៀង សារី** បានឈប់សម្រាកនៅក្រុងប៉េកាំង ដើម្បីពិភាក្សាពីការជួយជ្រោមជ្រែងរបស់ចិន ដើម្បីកសាងអំណាចយោធារបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចនោះ គាត់បានចរចាសន្ធិសញ្ញាមួយជាមួយចិន ដែលបក្សកុម្មុយនីស្តកម្ពុជានឹងទទួលបានអាវុធយុទ្ធភ័ណ្ឌចំនួន១៣៣០០តោន រួមជាមួយស្រូវអង្ករ ប្រេងឥន្ធនៈ និងរបស់របរផ្សេងៗទៀត។

## មុខតំណែង និងអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

៩៨០- **អៀង សារី** ស្ថិតនៅជាសមាជិកពេញសិទ្ធិរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ ដោយខ្លួនជាសមាជិកគណៈអចិន្ត្រៃយ៍ដែលជាស្ថាប័នកំពូលក្នុងការចេញសេចក្តីសម្រេចនៅក្នុងប្រទេស **អៀង សារី** គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជាដែលបង្កើតមាគ៌ានយោបាយ និងប្រតិបត្តិអំណាចនៃការសម្រេចចិត្តទៅលើបញ្ហាទាំងអស់ដែលគួរឲ្យកត់សម្គាល់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានតម្រូវឲ្យស្ថាប័នថ្នាក់ដឹកនាំ ដូចជា គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ត្រូវ"អនុវត្តការដឹកនាំសមូហភាព" និងបានចែងថា"គ្រប់ការសម្រេចចិត្តផ្សេង

១របស់បក្ស ត្រូវធ្វើឡើងដោយសមូហភាព"។ មានការរំពឹងទុកថា សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍"ត្រូវបានអនុវត្តដោយផ្ទាល់ និងឲ្យបានល្អ" ដោយថ្នាក់ក្រោមនៃរបបនេះ ហើយគណៈអចិន្ត្រៃយ៍នេះ"ជាអ្នកតាមដាន"ការអនុវត្តន៍គោលនយោបាយរបស់ខ្លួន។

៩៨១- បន្ថែមទៅលើតួនាទីរបស់គាត់នៅក្នុងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** មានមុខតំណែងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៥ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបានចេញសេចក្តីថ្លែងការណ៍ប្រកាសព័ត៌មានស្តីពីការតែងតាំង **អៀង សារី** ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ តាមការពិត គឺគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាដែល **អៀង សារី** ជាសមាជិក ជាអ្នកតែងតាំងឲ្យគាត់ទទួលខុសត្រូវ"កិច្ចការបរទេសទាំងផ្នែកបក្ស និងផ្នែករដ្ឋ"។ ស្រដៀងគ្នានេះដែរ នៅពេលរដ្ឋាភិបាលរដ្ឋកម្ពុជាប្រជាធិបតេយ្យ បានត្រួតត្រាជាផ្លូវការពីរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជានៅឆ្នាំ១៩៧៦ គឺគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាជាអ្នកតែងតាំង **អៀង សារី** ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ ពីរសប្តាហ៍ក្រោយមក សភាតំណាងប្រជាជនកម្ពុជាបានជួបប្រជុំ និងលើកសំណើសុំតែងតាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថ្មីដែលរួមមាន **អៀង សារី** ជា"ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស" ដែលតាមពិតទៅគាត់បានទទួលការជ្រើសរើសដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជារួចជាស្រេចទៅហើយ។

៩៨២- នៅក្នុងមុខតំណែងនេះ **អៀង សារី** ទទួលខុសត្រូវផ្ទាល់ក្នុងក្រសួងការបរទេស(MFA)ដែលមានឈ្មោះជាលេខកូដហៅថាប-១ និងបណ្តាស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅបរទេស។ **អៀង**

**សារី** ទទួលបន្ទុកការងារផ្ទៃក្នុងរបស់ក្រសួងនេះ ការទទួលខុសត្រូវខាងក្រៅ និងការអប់រំបុគ្គលិកក្រសួងការបរទេសស្តីពីមនោគមវិជ្ជា និងមាគ៌ានយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ការងារផ្នែកកិច្ចការបរទេសរបស់គាត់រួមមាន ការជួបប្រជុំជាមួយមន្ត្រីការទូតបរទេស ការអមដំណើរប្រតិភូបរទេសក្នុងដំណើរទស្សនកិច្ចនៅក្នុងប្រទេស ការអប់រំកែប្រែ និងការចាត់តាំងឲ្យប្រជាជនកម្ពុជាវិលត្រឡប់ពីបរទេស និងការចេញសេចក្តីថ្លែងការណ៍ផ្លូវការស្តីពីបញ្ហានានាទាក់ទិននឹងគោលនយោបាយក្នុង និងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ។ **អៀង សារី** បានធ្វើដំណើរទៅបរទេស ដើម្បីចូលរួមសន្និសីទ និងមានវត្តមាននៅឯកិច្ចប្រជុំមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅក្រុងញូវយ៉ក។ គាត់បានធ្វើដំណើរជាទៀងទាត់ទៅប្រទេសចិន។ នៅចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ **អៀង សារី** បានចំណាយពេលជាច្រើនឈរជើងនៅក្នុងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ទោះបីគាត់ស្នាក់នៅបរទេសក៏ដោយ ក៏ **អៀង សារី** បានទាក់ទងតាមរយៈមន្ទីរ៨៧០ ដើម្បីទទួលបានព័ត៌មាន និង បានដោះស្រាយបញ្ហានានានៅក្រសួងការបរទេសដែរ។

៩៨៣- ទាក់ទិននឹងសកម្មភាពផ្ទៃក្នុងនៅក្នុងក្រសួងនេះ **អៀង សារី** បានដឹកនាំវគ្គរៀនសូត្រនយោបាយក្នុងចំណោមបុគ្គលិកក្រសួងការបរទេស និង“ពួកបញ្ញវ័ន្ត” រៀបចំការធ្វើស្វ័យទិទៀន ពិភាក្សាពី“ខ្មាំង” និងអ្នកក្បត់នឹងរបបនេះ និងការផ្សព្វផ្សាយពីសារាចរណែនាំ និងបទបញ្ជាដែលចេញដោយមជ្ឈិមបក្ស។ ជាងនេះទៅទៀត **អៀង សារី** បានដោះស្រាយបញ្ហាសន្តិសុខផ្ទៃក្នុងដែលពាក់ព័ន្ធនឹងបុគ្គលិករបស់ក្រសួងនេះដែរ។

៩៨៤- **អៀង សារី** ក៏បានគ្រប់គ្រង និងត្រួតត្រាយ៉ាងមានប្រសិទ្ធភាពទៅលើមន្ទីរ និងជំរំធ្វើការដោយបង្ខំ និងការអប់រំកែប្រែមួយចំនួនដែរ។ ជំរំទាំងនោះរួមមាននៅតាខ្មៅ ព្រៃកញ្ចៅ និងព្រៃកប្រាម១ នៅច្រាំងចំរេះ និងបរិវេណ បឹ៣០ ប៣១ ប៣២ នៅទីតាំងបឹងត្របែកក្នុងក្រុងភ្នំពេញ។ ច្រាំងចំរេះ (ម-១) គឺជាអតីតមន្ទីររបស់ក្រសួងពាណិជ្ជកម្មដែលត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសនៅឆ្នាំ១៩៧៦។ បឹងត្របែក គឺជាមន្ទីរ ក (ក១៧)ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អៀង សារី** ក្នុងឋានៈគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍រហូតដល់ខែឧសភា ឆ្នាំ១៩៧៨ជាពេលដែលទីតាំងនេះត្រូវបានដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងការបរទេស ហើយក៏ក្លាយជាមន្ទីរប៣០ ប៣១ និង ប៣២។ បឹងត្របែកត្រូវបានបែងចែកជាបីប្លុក៖ អតីតមន្ត្រីការទូតត្រូវបានដាក់នៅប៣២ អ្នកដែលត្រូវគេត្រៀមយកទៅធ្វើការនៅតាមក្រសួង ត្រូវបានដាក់នៅប៣១ ចំណែកឯនិស្សិត និងអ្នកទោសត្រូវបានដាក់នៅប៣០។ ទាំងនៅច្រាំងចំរេះ និងបឹងត្របែក ត្រូវបានគេប្រើសម្រាប់ឃុំឃាំង និងអប់រំកែប្រែអតីតមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា និស្សិត និងបញ្ញវន្តដែលវិលត្រឡប់មកកម្ពុជាប្រជាធិបតេយ្យវិញ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជា "បានរំដោះ"ប្រទេសជាតិរួច។

៩៨៥- ក្រសួងការបរទេសមានបុគ្គលិកចំនួនជាង១០០០នាក់ ដែលក្នុងនោះមួយចំនួនតូចមានតួនាទីនៅតាមមន្ទីរ ហើយភាគច្រើនជាអ្នកធ្វើការដោយកម្លាំងជាទូទៅ។ ក្រសួងនេះមាន"សិទ្ធិជ្រើសរើសមនុស្សរបស់ខ្លួនដោយផ្ទាល់"ពីបុរីកីឡា ហើយ **អៀង សារី** ជាអ្នកសម្រេចចាត់តាំងមនុស្សឱ្យធ្វើការនៅក្រសួងការបរទេស។ [redacted]

[redacted]។

៩៨៦- កម្មាភិបាលដែលមានលំដាប់ទី៣ នៅក្នុងក្រសួងនេះ [redacted]។ អនុលោមតាមមាត្រា៩ និង១០ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា មន្ទីរក្រសួងនីមួយៗតម្រូវឱ្យមានគណៈសាខាបក្សមួយដែលទទួលខុសត្រូវការងារមួយចំនួន រួមមាន"ការសម្រិតសម្រាំង" និងការអប់រំបក្ខជននៅក្នុងស្ថាប័ននោះ។ ក្នុងឋានៈជាលេខាសាខាបក្ស [redacted] អានទស្សនាវដ្តីទង់បដិវត្តឱ្យកម្មាភិបាលបក្សស្តាប់ និងរៀបចំការប្រជុំ "ទិតៀន និងស្វ័យទិតៀន"។ ប៉ុន្តែ **អៀង សារី** ទេដែលជាអ្នកទទួលខុសត្រូវពិតប្រាកដនៅក្នុងសាខាបក្ស និង"សម្រេចរាល់កិច្ចការទាំងអស់" ដែលទាក់ទិននឹងក្រសួងនេះ។

៩៨៧- [redacted]។ ក្រសួងនេះក៏មាន

ផ្នែក"អាកាសចរស៊ីវិល"ដែរ ដែលត្រូវបានប្រើសម្រាប់ "ដាក់ឥវ៉ាន់ និងផ្គត់ផ្គង់អាហារនៅលើយន្តហោះ"។

៩៨៨- ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តាមការរំឭករបស់មន្ត្រីការទូត និងបុគ្គលិករបស់រាជរដ្ឋាភិបាលរួបរួមជាតិដែលរស់នៅក្នុងប្រទេសទាំងនោះ ក្រសួងការបរទេសបានបិទស្ថានទូតរបស់ខ្លួនប្រចាំនៅបរទេសស្ទើរតែទាំងអស់។ ដូចបានលើកយកមកពិភាក្សាលម្អិតខាងក្រោមនេះ នៅពេលដែលមន្ត្រីការទូត និងបុគ្គលិកស្ថានទូតត្រឡប់មកដល់ប្រទេសកម្ពុជា ពួកគេទាំងនោះត្រូវបញ្ជូនទៅមណ្ឌលលត់ដំខ្លួននានា បន្ទាប់មកពួកគេជាច្រើននាក់ត្រូវបញ្ជូនទៅមន្ទីរស២១ រួចត្រូវគេសម្លាប់ចោល។ ក្រសួងបានរក្សាស្ថានទូតរបស់ខ្លួនប្រចាំនៅបរទេស ក្នុងប្រទេសមានតែបួនប៉ុណ្ណោះ គឺ៖ ប្រទេសចិន ប្រទេសវៀតណាម ប្រទេសឡាវ និងប្រទេសកូរ៉េខាង ជើង។ **អៀង សារី** ក៏មានការពាក់ព័ន្ធជាមួយនឹងបញ្ហានានាទាក់ទិននឹង ពាណិជ្ជកម្ម អន្តរជាតិដែរដោយគាត់ត្រូវបានទទួលការចាត់តាំង ឱ្យធ្វើជាសមាជិកនៃគណៈកម្មាធិការ ធនាគារ និងពាណិជ្ជកម្មដែលត្រូវបានបង្កើតឡើងដោយគណៈអចិន្ត្រៃយ៍ ដើម្បីត្រៀម សម្រាប់ពាណិជ្ជកម្មបរទេស។

៩៨៩- **អៀង សារី** ស្នាក់នៅ និងធ្វើការនៅ ក១ និង ក៣ ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងៗទៀត។ គាត់នៅមានការិយាល័យរបស់គាត់មួយទៀតនៅឯក្រសួងការបរទេស ដែលដើម ឡើយមានទីតាំងស្ថិតនៅតាមមាត់ទន្លេ ប៉ុន្តែក្នុងឆ្នាំ១៩៧៦បានផ្លាស់ទីតាំងមកតាំងនៅមហាវិថីសហព័ន្ធរុស្ស៊ីវិញក្បែរស្ថានីយរថភ្លើង ជាទីតាំងទីស្តីការគណៈរដ្ឋមន្ត្រីនាពេលបច្ចុប្បន្ននេះ។

គាត់ និងប្រពន្ធរបស់គាត់ឈ្មោះ **អៀង ធីរិទ្ធ** អាចមានកន្លែងស្នាក់អាស្រ័យបន្ថែមទៀត នៅក២ ដែលជាទីតាំងរបស់ក្រសួងសង្គមកិច្ច។

**ការចូលរួម និងការរួមចំណែក**

**ការចូលរួមជាទូទៅក្នុងផែនការឧក្រិដ្ឋកម្មរួម**

**ការចូលរួមក្នុងអង្គប្រជុំនានា ជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងៗទៀត**

៩៩០- ក្នុងនាមជាសមាជិកស្ថាបនិកម្នាក់ក្នុងចំណោមសមាជិកស្ថាបនិកទាំងម្ភៃរូបនៅឯមហាសន្និបាតបក្សលើកទីមួយ ប្រព្រឹត្តទៅក្នុងខែកញ្ញា ឆ្នាំ១៩៦០នោះ **អៀង សារី** បានរៀបចំ និងអនុម័តយកមាគ៌ាបក្សសំខាន់ៗនានារបស់ ប.ក.ក រួមមាន ការប្រើហិង្សា ដើម្បីកម្ចាត់ខ្មាំងរបស់បក្សជាដើម។ ក្នុងឋានៈជាសមាជិកនៃគណៈមជ្ឈិមមួយរូប និងជាសមាជិកត្រៀមរបស់គណៈអចិន្ត្រៃយ៍ចាប់តាំងពីមហាសន្និបាតបក្សលើកទីមួយក្នុងឆ្នាំ១៩៦០ និងជាសមាជិកពេញសិទ្ធិគណៈកម្មាធិការអចិន្ត្រៃយ៍តាំងពីសន្និបាតបក្សលើកទី២ ក្នុងឆ្នាំ១៩៦៣មកនោះ **អៀង សារី** រួមជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងៗទៀត ជាអ្នកទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តនូវគោលនយោបាយ របស់ ប.ក.ក។

៩៩១- ដោយគិតត្រឹមតែរយៈពេលកំណត់ ដែលកំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍នានា ត្រូវបានរកឃើញនោះ (ពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦) **អៀង សារី** មានវត្តមានចូលរួមក្នុងអង្គប្រជុំយ៉ាងហោចណាស់ចំនួន១០ដង។ នៅក្នុងអង្គប្រជុំទាំងនេះ **អៀង សារី** និងសមាជិកគណៈអចិន្ត្រៃយ៍ឯទៀត បានលើកឡើង និងសម្រេចចិត្តលើបញ្ហា នានា

ដូចជាការចាប់ខ្លួនកម្មាភិបាល ការបញ្ជូនកុមារជំទង់ៗចេញពីមូលដ្ឋាន ទៅធ្វើការ នៅក្រសួងឧស្សាហកម្ម ការបង្កើនទិន្នផលអំបិល ការចែកចាយផ្គត់ផ្គង់ ស្រូវអង្ករនៅក្នុងប្រទេស បញ្ហាការពារជាតិផ្សេងៗ ដូចជាជម្លោះជាមួយនឹងវៀតណាម និងបញ្ហាពាក់ព័ន្ធនឹងបញ្ហាការទូត ព្រមទាំងជំនួយអន្តរជាតិនានា។ **អៀង សារី** បានដឹកនាំកិច្ចពិភាក្សាស្ដីពីបញ្ហានានាពាក់ព័ន្ធនឹងការបរទេស ឧទាហរណ៍ គាត់បានរាយការណ៍នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៦៧ ថា៖ "អតីតឯកអគ្គរដ្ឋទូត ព្រមជាមួយនឹងក្រុមគ្រួសាររបស់ពួកគាត់បានវិលត្រឡប់"មកកម្ពុជាប្រជាធិបតេយ្យវិញហើយ។ គណៈអចិន្ត្រៃយ៍ បានសម្រេចថា"ពួកទូតចាស់"ទាំងនោះ មិនអាចទុកចិត្តបានគ្រប់គ្រាន់ សម្រាប់ឱ្យក្រសួងការបរទេសយកមកបម្រើការងារ ឬចាកចេញពីប្រទេសបានទេ ហើយផ្ទុយទៅវិញពួកគេនឹងត្រូវបញ្ជូនទៅ "អប់រំ"។ [redacted]។

៩៩២- **អៀង សារី** គឺជាសមាជិកមួយរូបរបស់គណៈមជ្ឈិមដែលគណៈកម្មាធិការនេះ បានដាក់ចេញនូវសេចក្ដីសម្រេចកាលពី ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ចេញបញ្ជាឱ្យគណៈអចិន្ត្រៃយ៍ គណៈមន្ទីរមជ្ឈិម សេនាធិការ និងគណៈភូមិភាគនានា ឱ្យ"កម្ទេច"ខ្មាំង"ក្នុងជួរ និងក្រៅជួរ" និងសារាចរដាក់ចេញនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ ឱ្យពិនិត្យគោលនយោបាយ ប.ក.ក ឡើងវិញ ទៅលើពួកភ្នាក់ងារ សេអ៊ីអា កាហ្សេបេ និងយួន។

៩៩៣- **អៀង សារី** ស្នាក់នៅ និងធ្វើការជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ របស់ ប.ក.ក ឯទៀត នៅ ក១ និង ក៣។ **អៀង សារី** បានរួមដំណើរជាមួយ ប៉ុល ពត **នួន ជា** និង **ខៀវ សំផន** ចូលរួម

ក្នុងអង្គប្រជុំប្រចាំខែដែលប្រព្រឹត្តទៅនៅ ក១ ដោយមានការចូលរួមពីសំណាក់គណៈភូមិភាគ និងគណៈតំបន់ផ្សេងៗ។ គាត់បានសារភាពថា គាត់បានទទួលរបាយការណ៍ ពីបណ្តាភូមិភាគ និងតំបន់ផ្សេងៗដែលនៅក្នុងរបាយការណ៍នោះ មាននិយាយពីការសម្លាប់ ព្រមទាំងការធ្វើបាបអ្នកទោស ជាអង្គហេតុមួយដែលត្រូវបានអះអាងបន្ថែមនៅក្នុងប្រភពព័ត៌មានជាច្រើន។ របាយការណ៍ទាំងនេះ ត្រូវបានលើកយកមកពិភាក្សាជាលម្អិតនៅក្នុងផ្នែក *ការដឹងឮពីអំពើឧក្រិដ្ឋផ្សេងៗ៖ ការប្រាស្រ័យទាក់ទងរវាងរដ្ឋាភិបាល* ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ព្រមទាំងបញ្ជាក់ហួសពីការសង្ស័យទៅទៀត ថា **អៀង សារី** និងថ្នាក់ដឹកនាំជាន់ខ្ពស់នានារបស់ ប.ក.ក បានដឹងឮយ៉ាងពេញទំហឹងពីការចាប់ខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម ការសម្លាប់រាលដាល ព្រមទាំងការកើតមាននូវអំពើឧក្រិដ្ឋនានានៅក្នុងប្រទេស ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

៩៩៤- បន្ថែមលើនេះទៀត មានករណីមួយចំនួនដែលចម្លើយសារភាពរបស់អ្នកជាប់ឃុំឃាំង ត្រូវបានភូមិភាគផ្ញើទៅកាន់បណ្តាសមាជិកគណៈអចិន្ត្រៃយ៍នានា ឲ្យជួយក្នុងការ"ស្រាវជ្រាវរកខ្សែក្បត់ដែលកំពុងបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុង"។ ឧទាហរណ៍ របាយការណ៍មួយចុះនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ ផ្ញើពីលេខាកងពល៩២០ ទៅឲ្យ សុន សេន ដោយចម្លងជូន **អៀង សារី** បានសរសេរថា៖ "អ្នកសមាភាពមិនល្អ" ឥឡូវចាប់បាន"៥នាក់" ហើយកំពុងត្រូវគេសួរចម្លើយ ហើយ "សំណុំរឿង" ដែលពាក់ព័ន្ធនឹងករណីនោះ នឹងបញ្ជូនមកនៅពេលក្រោយ។

## ការបំពាក់បំប៉នរនយោបាយ និងវគ្គសិក្សារៀនសូត្រផ្សេងៗ

៩៩៥- ស្របជាមួយនឹងប្រវត្តិរបស់គាត់ជាអ្នកជួយជ្រោមជ្រែងគោលនយោបាយ ប.ក.ក មួយរូប នោះ **អៀង សារី** គឺជាអ្នកប្រកាន់ខ្ជាប់នូវមនោគមវិជ្ជានាំមុខគេម្នាក់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើការបំពាក់បំប៉នគោលនយោបាយយ៉ាងច្រើន ដល់កម្មាភិបាល ប.ក.ក និងបញ្ញវន្តដែលវិលត្រឡប់ពីបរទេស ដើម្បីអនុវត្តគោលនយោបាយ ព្រមទាំងមាគ៌ានយោបាយនានារបស់ ប.ក.ក។

៩៩៦- ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស ហើយដែលសំខាន់ជាងនេះទៅទៀតនោះ ក្នុងឋានៈជាសមាជិកអចិន្ត្រៃយ៍មួយរូបនោះ **អៀង សារី** គឺជាជនដែលមានអំណាចបំផុតទាំងមនោគមវិជ្ជា និងនយោបាយនៅក្រសួងការបរទេស។ គាត់បានដឹកនាំអង្គប្រជុំនយោបាយផ្សេងៗជាមួយបុគ្គលិកក្រសួងដែលនៅក្នុងអង្គប្រជុំនោះ គាត់បង្រៀនពីមាគ៌ាគោលនយោបាយបក្ស ប.ក.ក ព្រមទាំងធ្វើការសម្រេចចំពោះជោគវាសនារបស់ជនទាំងឡាយ ដែលមិនព្រមធ្វើតាមការបំពាក់បំប៉នទាំងនេះ។ ប្រសិនបើគណៈអចិន្ត្រៃយ៍មានបញ្ហាដោយផ្ទាល់ណាមួយ ចំពោះក្រសួង នោះ **អៀង សារី** នឹងកោះហៅឲ្យមានអង្គប្រជុំ ព្រមទាំងបែងចែកការងារទៅតាមបញ្ហាទាំងនោះ។ គាត់ក៏បានដឹកនាំអង្គប្រជុំបុគ្គលិកជាសមាជិកនានា ពាក់ព័ន្ធនឹងសន្តិសុខផ្ទៃក្នុងក្នុងក្រសួងផងដែរ ដោយនៅក្នុងអង្គប្រជុំទាំងនោះ បុគ្គលិកត្រូវបានគេណែនាំពីរបៀបនៃការការពារមិនឲ្យមាន"ខ្មាំងស៊ីរូងផ្ទៃក្នុង"។ វគ្គសិក្សាអប់រំរបស់បុគ្គលិកក្រសួងការបរទេស បានលើកឡើងពីគោលជំហររបស់ ប.ក.ក អំពីបញ្ហានយោបាយបរទេសសំខាន់ៗនានា ដូចជាជម្លោះជាមួយវៀតណាម ក៏ដូចជាការសាងសង់ទំនប់ទឹក និងប្រឡាយផ្សេងៗ ព្រមទាំងបញ្ហា "ការពារ និងកសាងប្រទេស"។ **អៀង សារី** បានដឹកនាំអង្គប្រជុំ "ជីវទស្សន៍" ប្រចាំខែនៅក្រសួង

ការបរទេស ដោយអង្គប្រជុំមានគោលបំណងធានាឲ្យបានថា កម្មាភិបាលបក្ស "មានគំនិតស្នេហាជាតិ" និងដើម្បីប្រឆាំងជាមួយនឹង"ខ្មាំង"។ ជាញឹកញាប់ គាត់បានចូលរួមក្នុងអង្គប្រជុំស្វ័យទិតៀនប្រចាំថ្ងៃរបស់បុគ្គលិកក្រសួងការបរទេស ព្រមទាំង"ផ្តល់នូវដំបូន្មាន"។

៩៩៧- បន្ថែមលើការបំពាក់បំប៉នបុគ្គលិក **អៀង សារី** បានធ្វើការបណ្តុះបណ្តាលនយោបាយផងដែរដល់បញ្ញវន្ត និងអតីតមន្ត្រីការទូត ព្រមទាំងមន្ត្រីរដ្ឋាភិបាលរួបរួមជាតិ ដែលបានវិលត្រឡប់មកពីបរទេសវិញ នៅបឹងត្របែក ដោយនៅក្នុងអង្គប្រជុំនោះ គាត់បាននិយាយដល់ចម្លើយសារភាពនៅមន្ទីរស២១ របស់សហជីវិនទាំងឡាយនៃបញ្ញវន្តកម្ពុជា ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញនោះ។ គាត់នៅបានដឹកនាំវគ្គសិក្សារៀនសូត្រនយោបាយទូទៅផ្សេងៗទៀត ជាច្រើននៅតាមកន្លែងនានា ដូចជាបុរីកីឡា និងស្តាតអូឡាំពិក ដោយបានណែនាំកម្មាភិបាល អំពីបញ្ហាផ្សេងៗ ដូចជាការការពារប្រឆាំងនឹងយួន ការសម្រេចឲ្យបាននូវគោលការណ៍បង្កបង្កើនផលស្រូវរបស់បក្ស សាមគ្គីភាព និង"ការមិនក្បត់គ្នា"ជាដើម។

## សុន្ទរកថា

៩៩៨- **អៀង សារី** បានចូលរួមចំណែកយ៉ាងសំខាន់ ចំពោះការផ្សព្វផ្សាយគោលនយោបាយ ប.ក.ក ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស រួមមាននៅអង្គការសហប្រជាជាតិជាដើម។ តាមរយៈសុន្ទរកថា និងសេចក្តីថ្លែងការសាធារណៈផ្សេងៗរបស់គាត់ គាត់មានចេតនាផ្សាយពីព័ត៌មានមិនពិត ដើម្បីការពារដល់សកម្មភាព ព្រមទាំងគោលនយោបាយនានារបស់ ប.ក.ក។

៩៩៩- នៅក្នុងកិច្ចសម្ភាសន៍ក្នុង Newsweek នាខែកញ្ញា ឆ្នាំ១៩៧៥ **អៀង សារី** បាននិយាយថា មូលហេតុឲ្យមានការជម្លៀសប្រជាជនចេញពីភ្នំពេញ គឺបណ្តាលមកពីការខ្វះខាតស្បៀង

អាហារ ព្រមជាមួយនឹងការដឹងពីផែនការសម្លាប់របស់សេអ៊ីអា និងរបបខ្មែរសាធារណរដ្ឋ ប៉ុន្តែក្នុងការជម្លៀសនោះ ប្រជាជនត្រូវបានផ្តល់សេរីភាពឱ្យវិលមកទីក្រុងភ្នំពេញ ប្រសិនបើពួកគាត់ចង់ ហើយមានប្រជាជនចំនួន១០០០០០នាក់ បានវិលត្រឡប់មកវិញ។ គាត់ក៏បានអះអាងផងដែរថា វត្តអារ៉ាមពុទ្ធសាសនាមួយចំនួននៅក្នុងប្រទេសកម្ពុជា នៅតែបើកទ្វារដំណើរការ ដោយអះអាងថា ប.ក.ក "គោរពជំនឿសាសនារបស់បុគ្គលគ្រប់ៗរូប"។ នៅពេលសួរនាំអំពីជោគវាសនារបស់មន្ត្រីក្នុងរបបសាធារណរដ្ឋខ្មែរ **អៀង សារី** បានឆ្លើយតបថា "បច្ចុប្បន្នពួកគេចូលរួមក្នុងការបង្កបង្កើនផលកសិកម្ម"។

១០០០- ស្រដៀងគ្នានេះដែរ ក្នុងកិច្ចសម្ភាសន៍ជាមួយ Far Eastern Economic Review នៅខែតុលា ឆ្នាំ១៩៧៥ **អៀង សារី** បានការពារការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីក្រុងឯទៀតថា ជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ ប.ក.ក ក្នុងការរារាំងដល់ផែនការពួកអាមេរិកាំង ដើម្បីធ្វើឱ្យមានអស្ថិរភាពនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងដោយសារតែ"បញ្ហាស្បៀងអាហារនៅក្នុងប្រទេសដែលធ្វើឱ្យពួកយើងគ្មានជម្រើស"។

១០០១- នៅក្នុងសុន្ទរកថានាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៦ **អៀង សារី** បានអះអាងថា៖ "ប្រជាជនកម្ពុជាបានប្រើប្រាស់សិទ្ធិរបស់ខ្លួនយ៉ាងពេញលេញ ក្នុងការជ្រើសរើសសភាតំណាងប្រជាជនដែលជាស្ថាប័នកំពូលនៃរដ្ឋបាលបដិវត្តន៍របស់ពួកគេ"។ ទោះបីជាបានដឹងឮអំពីការខ្វះខាតស្បៀងអាហារដ៏លើសលប់ដែលបណ្តាលឱ្យមានការស្លាប់ ដោយសារភាពអត់ឃ្លានពេញប្រទេសកម្ពុជានោះក៏ដោយ ក៏ **អៀង សារី** នៅតែលើកឡើងថា៖ "បញ្ហាស្បៀងអាហារដែលបង្កឡើងដោយសង្គ្រាមវិនាសកម្មនោះ ត្រូវបានដោះស្រាយជាមូលដ្ឋានហើយ"។

១០០២- នៅក្នុងកិច្ចសម្ភាសន៍ជាមួយ Der Spiegel ក្នុងខែឧសភា ឆ្នាំ១៩៧៧ **អៀង សារី** បានអះអាងថា កម្ពុជាប្រជាធិបតេយ្យមានអង្ករនៅសល់សម្រាប់ការនាំចេញ ហើយបានអះអាងទៀតថា "គ្មានការអត់ឃ្លានទៀតទេ"។ គាត់បានហៅការចោទប្រកាន់ថា "ឆ្កួតៗ" ចំពោះការលើកឡើងថាប្រជាជនចំនួន១លាននាក់ បានស្លាប់ចាប់តាំងពី១៩៧៥ ដោយព្រមទទួលថា មានតែចំនួន "២០០០នាក់ ទៅ៣០០០នាក់ប៉ុណ្ណោះ ដែលបានស្លាប់ក្នុងអំឡុងពេលជម្លៀស ហើយមានប្រជាជនរាប់ពាន់នាក់ផ្សេងទៀត បានស្លាប់នៅតាមវាលស្រែ"។ ទោះបីជាគាត់បានបង្កើត និងបានចុះត្រួតពិនិត្យការដ្ឋានក៏ដោយ ក៏ **អៀង សារី** បានបដិសេធការកើតមាននូវការប្រើពលកម្មដោយបង្ខំ ព្រមទាំងកន្លែងលត់ដំផ្សេងៗ ដោយគាត់បានសួរថា៖ "តើប្រជាជនត្រូវធ្វើការងារដោយរបៀបណា នៅពេលដែលពួកគេត្រូវគេបង្ខំនោះ?"។

១០០៣- នៅក្នុងសុន្ទរកថាមួយថ្លែងទៅកាន់អង្គការសហប្រជាជាតិកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ **អៀង សារី** បានប្រកាសថា"ប្រជាជនយើងមានការសប្បាយរីករាយ ព្រមទាំងមោទនភាពចំពោះកិច្ចការរដ្ឋដែលមានភាពល្អប្រសើរនេះ ដែលពួកគេពិតជាម្ចាស់ជោគវាសនាខ្លួន និងម្ចាស់ប្រទេសជាតិយ៉ាងពិតប្រាកដ"។ ព្រមជាមួយនឹងការអះអាងថា"រូបភាពអាក្រក់"របស់ ប.ក.ក គឺបណ្តាលមកពី"ព័ត៌មានអាក្រក់"នោះ **អៀង សារី** បានចំណាយលើសពីពាក់កណ្តាលនៃអត្ថន័យសុន្ទរកថារបស់គាត់ ដើម្បីអួតអាងអំពីសមិទ្ធិផលដូចដែលបានឃើញរបស់រដ្ឋាភិបាលគាត់ ដូចជា៖ ការកសាងមន្ទីរពិនិត្យសុខភាពមួយ សម្រាប់ក្រុមគ្រួសារប្រជាជន១០០គ្រួសារ ការសាងសង់ទំនប់ទឹក និងផ្លូវបង្ហូរទឹក ការលុបបំបាត់ចោលស្ទើរតែទាំងស្រុងនូវជំងឺគ្រុនចាញ់ និងបាន"ដោះស្រាយភាពមិនចេះអក្សរ"ទៀតផង។ គាត់បានអះអាងបន្ថែម

ថានៅឆ្នាំ១៩៧៦ ប្រទេសកម្ពុជា ប្រជាជនម្នាក់អាចបង្កបង្កើនទិន្នផលអង្ករជាមធ្យម៣១២ គីឡូក្រាមក្នុងមួយឆ្នាំ ដូច្នេះ“បំពេញទៅតាមតម្រូវការរបស់ប្រជាជន”។

១០០៤- នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៨ **អៀង សារី** បានថ្លែងទៅកាន់អង្គមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៣៣។ គាត់បានបង្ហាញប្រាប់ពិភពលោកជាថ្មីម្តងទៀតថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានបង្កើត“សង្គមថ្មីមួយដែលមានសមភាពយុត្តិធម៌ និងប្រជាធិបតេយ្យមានប្រសិទ្ធភាពឥតក្លែងបន្លំ”មួយ ហើយ“អំពើពុករលួយ អំពើខិលខូច និងអបាយមុខ ត្រូវបានលុបបំបាត់ទាំងស្រុង”។ គាត់បានអះអាងពីរបបកម្ពុជាប្រជាធិបតេយ្យថា៖ “បានដោះស្រាយដោយជោគជ័យនូវបញ្ហាធ្ងន់ធ្ងរ និងសំខាន់ៗ ដែលកើតមានក្រោយសង្គ្រាម ដូចជា បញ្ហាស្បៀងអាហារជាដើម” ក្នុងន័យនេះ បានសេចក្តីថា “ម្នាក់ៗបរិភោគទាល់តែឆ្អែត ពួកគេមានជម្រក និងសម្លៀកបំពាក់សមរម្យ មានថ្នាំសង្កូវ មានមន្ទីរពេទ្យ និងការថែទាំវេជ្ជសាស្ត្រនៅតាមបណ្តាសហករណ៍ និងសហជីពនីមួយៗ”។ ជាចុងក្រោយ **អៀង សារី** បានប្រកាសប្រាប់ទៅអង្គមហាសន្និបាតអង្គការសហប្រជាជាតិថា “ប្រសិនបើរបបនេះ មិនយុត្តិធម៌ និងមិនល្អគ្រប់គ្រាន់ទេនោះ ប្រជាជនពិតជាមិនពេញចិត្តសោះឡើយចំពោះសុន្ទរកថា និងការឃោសនាដ៏ល្អបែបនេះ”។

## ការចូលរួមចំណែកក្នុងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មជាក់ស្តែងនានា

## ការជម្លៀសដោយបង្ខំ

១០០៥- **អៀង សារី** បានចូលរួមនៅក្នុងមហាសន្និបាតបក្ស និងអង្គប្រជុំនានាទាំងរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ដែលបានបង្កើតគោលនយោបាយ ប.ក.ក ស្តីអំពីប្រជាជននៅទីក្រុងរបស់

ប្រទេសកម្ពុជា និងធ្វើការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងនៅពេលរំដោះ ដោយរួមទាំងមហាសន្និបាតបក្សលើកទីមួយដែលបានប្រព្រឹត្តទៅនាចុងខែកញ្ញា ឆ្នាំ១៩៦០ផងដែរ និងកិច្ចប្រជុំរបស់គណៈមជ្ឈិមនៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ រៀបចំផែនការ សម្រាប់វាយប្រហារលើកចុងក្រោយរំដោះភ្នំពេញ។ វត្តមានរបស់គាត់នៅក្នុងប្រទេសចិន ក្នុងជំនួបចុងក្រោយរបស់គណៈកម្មាការសមរភូមិ នាដើមខែមេសា ឆ្នាំ១៩៧៥ មិនបានលើកលែងឲ្យ **អៀង សារី** មិនទទួលទោសសម្រាប់ការយល់ព្រមរបស់គាត់ពីគ្រាមុន ចំពោះផែនការ ប.ក.ក ក្នុងឋានៈជាថ្នាក់ដឹកនាំជាន់ខ្ពស់ម្នាក់របស់បក្សនោះឡើយ។

១០០៦- បន្ថែមលើនេះទៀត **អៀង សារី** បានគាំទ្រការសម្រេចធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ របស់រណសិរ្សរួបរួមជាតិ ក្នុងការសម្លាប់មន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ហើយគាត់បានសារភាព ចំពោះការសម្លាប់មន្ត្រីរដ្ឋាភិបាលរបស់របបសាធារណរដ្ឋខ្មែរ ដែលនៅសល់នៅកម្ពុជា និងដែលត្រូវបានចាប់ខ្លួនដោយ ប.ក.ក។ នៅក្នុងកិច្ចសម្ភាសន៍មួយជាមួយ Newsweek ក្នុងខែកញ្ញា ឆ្នាំ១៩៧៥ នៅពេលត្រូវគេសួរអំពីអ្វីដែលបានកើតឡើង ចំពោះមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរដែលត្រូវបានផ្តួលរំលំនោះ **អៀង សារី** បានអះអាងថា ពួកគេបានចូលរួមនៅក្នុងការបង្កបង្កើនផលកសិកម្មហើយ ប្រសិនបើពួកគេស្មោះត្រង់ ពួកគេអាចមករួមរស់ក្នុងសង្គមជាតិកម្ពុជាបាន។ ផ្ទុយទៅវិញ នៅពេលដែលត្រូវគេសួរបន្ទាប់មកទៀត ថាតើអតីតនាយករដ្ឋមន្ត្រី ឡុង បូរ៉េត នៅរស់ ឬក៏ស្លាប់នោះ **អៀង សារី** បានឆ្លើយថា៖“ស្លាប់ ឬក៏មិនស្លាប់នោះ គាត់គឺជាជនក្បត់ម្នាក់ដែលត្រូវបានកាត់សេចក្តីដោយប្រជាជន និងមហាសន្និបាត”។ នៅក្នុងសន្និសីទសារព័ត៌មានមួយ ប្រព្រឹត្តទៅនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅពេលបញ្ចប់ការធ្វើដំណើររយៈពេល៥ថ្ងៃក្នុងប្រទេសថៃនោះ **អៀង សារី** បានសារភាពជាសាធារណៈថា ឡុង

បូរ៉េត និង សិរីមត: ត្រូវបានសម្លាប់បន្ទាប់ពី ប.ក.ក បានទទួលជ័យជំនះ នៅខែមេសា ឆ្នាំ ១៩៧៥។

១០០៧- ពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ ដែលបានចាប់ផ្ដើមនៅសរទរដូវនៃឆ្នាំ ១៩៧៥ ទោះបីជា **អៀង សារី** អវត្តមានមិននៅក្នុងប្រទេស ក្នុងអំឡុងពេលដែលគណៈអចិន្ត្រៃយ៍ ទៅទស្សនកិច្ចនៅភូមិភាគពាយ័ព្យ ចន្លោះថ្ងៃទី២០ ទៅ២៤ ខែសីហា ឆ្នាំ១៩៧៥ ក៏ដោយ ក៏គាត់បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយមានវត្តមាននៅក្នុងប្រទេស ក្នុងរយៈពេលស្ទើរតែ១ខែពេញ គិតចាប់ពីចុងខែកញ្ញា ឬដើមខែ តុលា ឆ្នាំ១៩៧៥ ដែលជាអំឡុងពេលកើតមានទូវការជម្លៀសដោយបង្ខំទៅលើប្រជាជនចំនួន ៥០០០០០នាក់។

## ការធ្វើពលកម្មដោយបង្ខំ

១០០៨- ក្នុងឋានៈជាថ្នាក់ដឹកនាំជាន់ខ្ពស់ម្នាក់របស់ ប.ក.ក និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម **អៀង សារី** បានចូលរួមនៅក្នុងការធ្វើផែនការគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក និងជាអ្នកទទួលខុសត្រូវចំពោះការបង្កើតការដ្ឋានធ្វើពលកម្មដោយបង្ខំផ្សេងៗ។ ផែនការដាក់ចេញដោយមជ្ឈិមបក្ស ត្រូវបានហៅថាគម្រោងធារាសាស្ត្រទ្រង់ទ្រាយធំ និងគោលការណ៍បង្កបង្កើនផលស្រូវ និងអំបិលដែលមិនពិតប្រាកដ។ គាត់ក៏បានចូលរួមនៅក្នុងអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ផងដែរ ក្នុងការសម្រេចសាងសង់អាកាសយានដ្ឋានយោធាមួយនៅខេត្តកំពង់ឆ្នាំង។ នៅកិច្ចប្រជុំរបស់ក្រសួងការបរទេស **អៀង សារី** បានធ្វើការពិភាក្សាពីភាពចាំបាច់ដែលត្រូវមានកម្លាំងបំពេញការងារ ដើម្បីសាងសង់ទំនប់ទឹក

និងប្រឡាយទឹក។ គាត់បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈមួយនៅអង្គមហាសន្និបាតអង្គការសហប្រជាជាតិ ដោយទទួលដឹងឮ និងគាំទ្រចំពោះគម្រោងការងារក្នុងទ្រង់ទ្រាយធំនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

១០០៩- **អៀង សារី** បានយល់ព្រមលើដំណើរប្រតិបត្តិការរបស់ទីតាំងធ្វើពលកម្មដោយបង្ខំទាំងនេះ ទាំងបានដឹងឮដោយពេញទំហឹងពីស្ថានភាពអមនុស្សធម៌ ដែលបានកើតមាននៅក្នុងទីតាំងទាំងនោះ។ ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍មួយរូប គាត់បានទទួលរបាយការណ៍ជា ទៀងទាត់ពីបណ្តាមន្ទីរភូមិភាគស្តីពីការសាងសង់ទំនប់ទឹក និងអាងស្តុកទឹកទាំងនោះ រួមមាន ទំនប់ទឹកត្រពាំងថ្មជាដើម។ ឧទាហរណ៍ នៅក្នុងរបាយការណ៍មួយ មកពីភូមិភាគឧត្តរ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨ ដែលត្រូវបានគេចម្លងជូន **អៀង សារី** នោះ បញ្ជាក់ថា នៅការដ្ឋានទំនប់ទឹក "ការផលិតមានសន្ទុះលឿនជាងពី២ ទៅ ៣ដង ជាងការផលិតនៅក្នុងឆ្នាំ១៩៧៧" ទោះបីជា"ប្រជាជនជាច្រើន"បាន"ធ្លាក់ខ្លួនឈឺ ដោយសាររដូវនេះមានអាកាសធាតុក្តៅខ្លាំងពេក"ក៏ដោយ។ គាត់បានទទួលរបាយការណ៍អំពីការខ្វះខាតស្បៀងអាហារ និងគ្មានថ្នាំសង្កូវគ្រប់គ្រាន់នៅតាមបណ្តាខេត្តនានា។ **អៀង សារី** បានទទួលសារភាពថា គាត់ត្រូវបានកូនៗរបស់គាត់ ជូនដំណឹងក្នុងឆ្នាំ១៩៧៦ ថាប្រជាជន"ត្រូវស្លាប់ដោយសារការអត់ឃ្លាន" ដោយសារតែពួកគេទទួលទានតែបបររាវ មិនមែនបាយ ហើយគាត់អះអាងថាគាត់បានប្រឈមមុខជាមួយនឹង ប៉ុល ពត ចំពោះបញ្ហានេះ។

១០១០- **អៀង សារី** ក៏បានចុះទៅពិនិត្យមើលការដ្ឋានទំនប់ទឹកផ្សេងៗផងដែរ ដែលនៅទីនោះគាត់អាចសង្កេតមើលស្ថានភាពអមនុស្សធម៌ ព្រមទាំងការលំបាកផ្សេងៗរបស់ពលករ រួមមានទំនប់

ត្រពាំងថ្ម និងទំនប់១មករា។ គាត់បានទៅត្រួតពិនិត្យការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង យ៉ាងហោចណាស់២ដង រួមទាំងការធ្វើដំណើរនៅដើមឆ្នាំ១៩៧៧ ក្នុងពេលដែលរូបគាត់ និង **ខៀវ សំផន** បានជួបជាមួយនឹងថ្នាក់ដឹកនាំការដ្ឋាន។ គាត់ក៏បានចូលរួមចំណែកនៅក្នុងប្រតិបត្តិការសាងសង់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ តាមរយៈការចាត់តាំងឱ្យបុគ្គលិករបស់ក្រសួងការបរទេសដែលបានប្រព្រឹត្តកំហុសតូចតាច ទៅធ្វើការនៅទីនោះ។

## មន្ទីរសន្តិសុខតាមតំបន់

១០១១- ក្នុងឋានៈជាសមាជិកគណៈអចិន្ត្រៃយ៍ និងជាសមាជិកគណៈមជ្ឈិមរបស់ ប.ក.ក តាំងពីមហាសន្និបាតបក្សដំបូងក្នុងឆ្នាំ១៩៦០មកនោះ **អៀង សារី** គឺជាថ្នាក់ដឹកនាំជាន់ខ្ពស់មួយរូប ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ជាច្រើនរបស់ ប.ក.ក ដែល (ក)បានបង្កើតមាគ៌ាបក្ស ដោយកំណត់ថាខ្មាំងទាំងអស់ត្រូវតែកម្ទេច (ខ)គឺជាអ្នកផ្តល់អំណាចដល់ថ្នាក់ដឹកនាំភូមិភាគដើម្បីកម្ទេចខ្មាំងដែលមាននៅក្នុងតំបន់របស់ពួកគេកាន់កាប់ ហើយគាត់ជាអ្នក (គ)ដែលបានណែនាំកម្មាភិបាល ប.ក.ក តាមរយៈការបោះពុម្ពផ្សាយទស្សនាវដ្តីទង់បដិវត្តន៍ប្រចាំខែ ការចេញសារាចរណែនាំពីមន្ទីរ៨៧០ វគ្គសិក្សារៀនសូត្រនយោបាយ ព្រមទាំងការប្រាស្រ័យទាក់ទងផ្ទាល់ផ្សេងៗ ថាតើនរណាខ្លះដែលត្រូវជាខ្មាំងរបស់ ប.ក.ក។ ទោះបីជា គាត់បានដឹងឮពីការរាលដាលនូវអំពើឧក្រិដ្ឋតាមរយៈរបាយការណ៍ជាទៀងទាត់នានា ដែលភូមិភាគបានបញ្ជូនមកមន្ទីរ៨៧០ក៏ដោយ ក៏ **អៀង សារី** ខកខានមិនបានដាក់ចេញនូវវិធានការណាមួយ ដើម្បីទប់ស្កាត់ រារាំងចំពោះ ការកើតមាននូវអំពើឧក្រិដ្ឋទាំងនោះ ឬចាត់វិធានការដើម្បីស៊ើបអង្កេត ព្រមទាំងដាក់ទណ្ឌកម្មដល់ចារីផ្ទាល់ដែរ។ ផ្ទុយទៅវិញ ក្នុងឋានៈគាត់ជារដ្ឋមន្ត្រីក្រសួង

ការបរទេស គាត់បែរជាបដិសេធជាសាធារណៈពីសេចក្ដីរាយការណ៍ផ្សេងៗ ស្ដីពីអំពើឧក្រិដ្ឋទាំងនោះទៅវិញ ហើយគាត់បានព្រងើយកន្ដើយ ឬបដិសេធរាល់ការអំពាវនាវរបស់អន្ដរជាតិ ដែលសុំឱ្យមានការស៊ើបអង្កេតទៅលើការចោទប្រកាន់ផ្សេងៗ ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ក្នុងទ្រង់ទ្រាយធំ ដែលកើតមានក្នុងប្រទេសកម្ពុជាផងដែរ។

## ការបោសសម្អាតទៅលើក្រសួងការបរទេស មន្ត្រីការទូត និងកម្មាភិបាលផ្សេងៗទៀត (ស២១)

### *កម្មាភិបាលក្រសួងការបរទេស*

១០១២- ក្នុងនាមជាប្រធានស្ថាប័នមួយ **អៀង សារី** មានតួនាទីទទួលខុសត្រូវខ្ពស់បំផុត ចំពោះរាល់បញ្ហាសន្ដិសុខនានានៅក្រសួងការបរទេស។ ដូចមានលើកយកមកពិភាក្សាខាងក្រោមនេះ ការទទួលខុសត្រូវសន្ដិសុខរបស់គាត់ រួមបញ្ចូលទាំង (ក)ការត្រួតពិនិត្យកម្មាភិបាលដើម្បីកំណត់អត្តសញ្ញាណ"ខ្មាំងផ្ទៃក្នុង" និង(ខ)ធ្វើសេចក្ដីសម្រេចចិត្ត ថាតើត្រូវលត់ដំ ឬចាប់ខ្លួនកម្មាភិបាលដែល"មានការឆ្លើយដាក់"ថាជាខ្មាំង។

១០១៣- ការកំណត់អត្តសញ្ញាណ"ខ្មាំង"នៅក្នុងក្រសួង ត្រូវបានចាត់ទុកថា ជា"បញ្ហាបក្ស"។ លក្ខន្តិកៈរបស់ ប.ក.ក ដែល **អៀង សារី** បានជួយជ្រោមជ្រែងក្នុងការបង្កើតឡើងមកនោះ តម្រូវឱ្យរាល់ស្ថាប័នទាំងអស់ ត្រូវរក្សា"ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឱ្យខ្ពស់ដល់កម្រិត ចំពោះគ្រប់សកម្មភាពរបស់ខ្មាំង"។ បក្ខជន តម្រូវឱ្យមាន "វណ្ណៈភាពល្អជាវណ្ណៈភាពដើម" មានន័យថា ជា "ជំហរវណ្ណៈពលករ" "ស្អាតស្អំល្អខាងនយោបាយ" និងមិនមាន "អ្វីជំពាក់ជំពិននឹងខ្មាំង" ហើយត្រូវតែជាកម្មាភិបាលដែល"មានប្រវត្តិច្បាស់លាស់ដោយសួរបញ្ជាក់ពីមូលដ្ឋានកំណើត ឬកន្លែងរស់នៅធ្វើការងាររបស់សាមីខ្លួន" ។ បណ្ដាអង្គភាព សាខា ដូចជាមន្ទីរ ក្រសួង ត្រូវមានភារកិច្ច

ក្នុងការ“សម្រិតសម្រាំងបក្ខជន និងអង្គការស្អាត” ក៏ដូចជាអប់រំកសាងពួកគេផងដែរ។ ដើម្បីបំពេញកាតព្វកិច្ចទាំងនេះ ក្រសួងបានបង្កើតឱ្យមានការប្រជុំ“ស្វ័យទិតៀន” ជារៀងរាល់ថ្ងៃ ការប្រជុំ“ជីវទស្សន៍” ឬប្រជុំ“ជីវភាព”ប្រចាំខែ ព្រមទាំង បង្កើតឱ្យមាននូវ“អង្គប្រជុំប្រវត្តិរូប”រៀងរាល់៣ខែម្តង ដើម្បីប្រមូលយកប្រវត្តិរូបផ្ទាល់ខ្លួនពីកម្មាភិបាលដែលប្រវត្តិរូបផ្ទាល់ខ្លួនទាំងនោះត្រូវបានគេយកទៅប្រើសម្រាប់កំណត់អត្តសញ្ញាណ“ជនក្បត់” នៅក្នុងក្រសួងការបរទេស។

១០១៤- **អៀង សារី** ផ្ទាល់បានចូលរួមនៅក្នុងដំណើរការនេះ។ គាត់បានដឹកនាំអង្គប្រជុំជីវភាពប្រចាំខែ ហើយជាញឹកញាប់ គាត់ក៏បានចូលរួមវគ្គស្វ័យទិតៀនប្រចាំថ្ងៃផងដែរ។ គាត់ [redacted] បានស្នើឱ្យកម្មាភិបាលក្រសួងការបរទេស ដែលមានជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាពមន្ទីរស-២១ ឬមន្ទីរផ្សេងទៀត ត្រូវគេចោទប្រកាន់ថាជាខ្មាំងឱ្យធ្វើប្រវត្តិរូប។ [redacted] ត្រូវបាន **អៀង សារី** ចោទថាបានចូលដៃជាមួយសេអ៊ីអា ហើយបន្ទាប់មកត្រូវគេបញ្ជាឱ្យសរសេរប្រវត្តិរូបផ្ទាល់ខ្លួនដែលគាត់ប្រើរយៈពេលអស់មួយឆ្នាំ ដើម្បីបញ្ចប់ប្រវត្តិរូប ដែលមាន“កម្រាស់ស្មើនឹងសៀវភៅមួយក្បាល”។

១០១៥- បន្ទាប់ពីមានជាប់ពាក់ព័ន្ធជាមួយនឹងភ្នាក់ងារកាហ្សេបេ ឬសេអ៊ីអា នៅក្នុងចម្លើយសារភាពមន្ទីរស២១ចំនួន២រួចមក [redacted] ត្រូវបាន **អៀង សារី** ណែនាំឱ្យធ្វើជីវប្រវត្តិផ្ទាល់ខ្លួន។ [redacted]

[redacted]។ ច្បាប់ចម្លងនៃប្រវត្តិរូបនោះ គឺមាននៅក្នុងសំណុំរឿងក្តី។ ប្រវត្តិរូបនោះបញ្ជាក់បន្ថែមទៅលើសក្ខីកម្មរបស់ [redacted] ពាក់ព័ន្ធនឹងតួនាទីរបស់ **អៀង សារី** ក្នុងដំណើរការធ្វើប្រវត្តិរូប ព្រមទាំងផ្តល់ជាឧទាហរណ៍ជាក់ស្តែងអំពីរបៀបនៃការប្រើប្រវត្តិរូបទាំងនោះរបស់ប.ក.ក ក្នុងការព្យាយាមកំណត់អត្តសញ្ញាណបុគ្គល ដែលមានប្រវត្តិគួរឱ្យសង្ស័យ ឬមានភាពមន្ទិលទៅលើភាពស្មោះត្រង់ចំពោះបក្ស។ ដោយសារទទួលបានការការពារពីសំណាក់ **អៀង សារី** [redacted] មិនត្រូវបានគេបញ្ជូនទៅស២១ទេ [redacted]។ ដូចមានលើកយកមកពិភាក្សាខាងក្រោមនេះ កម្មាភិបាលក្រសួងការបរទេសភាគច្រើន ដែលមានជាប់ពាក់ព័ន្ធក្នុងចម្លើយសារភាពមន្ទីរស២១ មិនមែនមានសំណាងបែបនោះទេ។

១០១៦- **អៀង សារី** បានបើកអង្គប្រជុំជាមួយបុគ្គលិកក្រសួងការបរទេស អំពីបញ្ហាសន្តិសុខផ្ទៃក្នុងផ្សេងៗ ដូចជា“ខ្មាំងស៊ីរូងផ្ទៃក្នុង” ដោយបានប្រាប់កម្មាភិបាលថា “ការបោសសម្អាតផ្ទៃក្នុង” គឺជាការចាំបាច់ “ពីព្រោះមានភ្នាក់ងារសម្ងាត់របស់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង”។ អង្គប្រជុំទាំងនេះត្រូវបានធ្វើឡើងចំនួន២ ឬ៣ដង ក្នុងមួយឆ្នាំ ដើម្បីពន្យល់ប្រាប់កម្មាភិបាលក្រសួងការបរទេស [redacted]

[redacted]។ ក្នុងឱកាសសន្និបាតក្រសួងនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៦ កម្មាភិបាលត្រូវបានគេប្រាប់ថាមនុស្សចំនួន១ ទៅ៥ភាគរយ ក្នុងប្រទេសទាំងមូល គឺជា“ជនក្បត់” ដែលកើតចេញពីខាងក្នុង និងត្រូវបានណែនាំឲ្យស៊ើបអង្កេតប្រវត្តិរូប “ធ្វើស្វ័យទិតៀន” “តាមដានរាល់គ្រប់សកម្មភាព” របស់បុគ្គលិក និង “ចាត់ការខ្មាំងបង្កប់” ដើម្បី“កុំឲ្យគិញជ្រៀតខ្លួនចូលក្រសួងរបស់យើង”។ សន្និបាតក្រសួងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧ បានកត់សម្គាល់ឃើញថាពួកគេ “បានកម្ទេច និងបោសសម្អាតពួកខ្មាំងដែលជាសេអ៊ីអា កាហ្សេបេ និងយួនលេបទឹកដី” និងអំពាវនាវសុំឲ្យបន្តកិច្ចខិតខំក្នុងការ “បោសសម្អាត” ខ្មាំងដែលនៅសល់ក្នុងក្រសួង។

១០១៧- **អៀង សារី** ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះការកំណត់ថា តើកម្មាភិបាលក្រសួងការបរទេសណាមួយដែលនឹងត្រូវ“កម្ទេច និងបោសសម្អាត”។ ក្នុងឋានៈជាលេខាក្រសួងនេះ ចាំបាច់ទាល់តែមានការឯកភាពពីគាត់ នៅមុនពេលចាប់ខ្លួនកម្មាភិបាលក្រសួងការបរទេស។ សិទ្ធិអំណាចរបស់ **អៀង សារី** ពាក់ព័ន្ធនឹងការចាប់ខ្លួនទាំងនេះ ត្រូវបានបញ្ជាក់អះអាងដោយការពិតចំនួន២ករណី ដែលគាត់អាចមានលទ្ធភាពទប់ស្កាត់ក្នុងការចាប់ខ្លួនកម្មាភិបាលមួយចំនួន ដែលខ្លួនពេញចិត្ត ប៉ុន្តែត្រូវបានគេចោទថាជាភ្នាក់ងារសេអ៊ីអា ឬកាហ្សេបេ។ ក្នុងករណីចម្លើយសារភាពរបស់មន្ទីរស២១ បានឆ្លើយដាក់កម្មាភិបាលក្រសួងការបរទេស សុន សេន ឬ **នួន ជា** ជាអ្នកបញ្ជូនចម្លើយសារភាពមួយច្បាប់ជូន **អៀង សារី** ដើម្បីជម្រាបគាត់អំពី“សកម្មភាពខ្មាំងក្នុងអង្គភាពនោះ” និងអនុញ្ញាតឲ្យគាត់“ពិចារណាអំពីការចាប់ខ្លួនមនុស្ស ដែលគេឆ្លើយ ដាក់ ”។ បន្ទាប់មក គេនឹងសម្រេចរួមគ្នា ថាតើនឹងត្រូវតាមដានជនជាប់ចោទ បញ្ជូនទៅកាន់ការដ្ឋានលត់ដំ ចាប់ខ្លួន ឬមិនចាត់វិធានការ។

១០១៨- [redacted]។ ចម្លើយសារភាពរបស់មន្ទីរស២១ ត្រូវបានគេរកឃើញថាមានចំណាររបស់ នួន ជា ឬ សុន សេន ដែលបញ្ជាក់ថាចម្លើយសារភាពទាំងនោះ ត្រូវបានផ្ញើជូន **អៀង សារី**។ ក្នុងឱកាសមួយចំនួន **អៀង សារី** ជាអ្នកអានចម្លើយសារភាពរបស់មន្ទីរស២១ ឱ្យកម្មាភិបាលក្រសួងការបរទេស ឬអ្នកជាប់ឃុំឃាំងនៅបឹងត្របែកស្តាប់ ឬជម្រាបឱ្យកម្មាភិបាលបានដឹងថា ពួកគេត្រូវបានឆ្លើយ ដាក់នៅក្នុងចម្លើយសារភាពទាំងនោះ។

១០១៩- ក្នុងករណីខ្លះ កម្មាភិបាលជាប់សង្ស័យត្រូវបានបញ្ជូនទៅកាន់ក្រសួងការបរទេស ដែលនៅទីនោះពួកគេអាចស្ថិតក្រោមការតាមដានរបស់មជ្ឈិមបក្ស និងអាចត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរ ស២១។ ជាក់ស្តែងឈ្មោះ អ៊ិន ណាត និង ទាញ ត្រូវបានបញ្ជូនពីសេនាធិការទៅកាន់ក្រសួងការបរទេស "ក្រោមលេសថាបញ្ជូនទៅធ្វើទូតនៅបរទេស"។ អ៊ូ ពិន *ហៅ* ទេព ហៃ *ហៅ* ហំ អនុលេខាតំបន់៣២ ដែលត្រូវបានចាត់ទុកថាជាខ្មាំង បន្ទាប់ពីពួកគេបានទិតៀនអំពីទ្រព្យសម្បត្តិសមូហភាពនៅក្នុងសន្និបាតភូមិភាគបស្ចិម ដំបូងត្រូវបានបញ្ជូនទៅកាន់ក្រសួងការបរទេស រួចចាប់ខ្លួនយកទៅឃុំឃាំង និងប្រហារជីវិតនៅមន្ទីរស២១។ កែ គឹមហួត ហៅ សុត គឺជាលេខាតំបន់មួយ ដែលត្រូវបានតែងតាំងធ្វើជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសយូហ្គោស្លាវី ប៉ុន្តែ"បានបាត់ខ្លួននៅមុនពេលចាកចេញ" និងត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១។ **អៀង សារី**

បានទទួលស្គាល់ថា គាត់ពិតជាបានដឹងថា ក្រសួងរបស់គាត់ត្រូវបានគេយកធ្វើជា "មន្ទីរឃុំឃាំងកម្មាភិបាលជាប់សង្ស័យ"។ ការអនុវត្តន៍នេះ ជាការអនុវត្តន៍ទូទៅ ហើយ **នួន** ជា បានប្រើប្រាស់ពាក្យថា"បញ្ជូនទៅធ្វើទូត"សម្រាប់សម្គាល់ការចាប់ខ្លួន និងប្រហារជីវិតមនុស្ស។

១០២០- គ្រប់កម្មាភិបាលក្រសួងការបរទេសទាំងអស់ ដែលត្រូវបានចាប់ខ្លួន សុទ្ធតែត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១។ គេបានរៀបចំឯកសាររាយនាមអ្នកទោសក្រសួងការបរទេស ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១។ ជាធម្មតា កម្មាភិបាលក្រសួងការបរទេស ត្រូវបានចាប់ខ្លួន បញ្ជូនទៅកាន់មន្ទីរស២១ តាមរយៈប្រធានមន្ទីរស៧១ ឈ្មោះ ប៉ង់ ឬអនុប្រធានឈ្មោះ លើន ប៉ុន្តែក្នុងករណីខ្លះ តាមរយៈបុគ្គលិកសន្តិសុខរបស់ក្រសួងការបរទេស។ សម្រាប់ការចាប់ខ្លួនដែលធ្វើឡើងដោយមន្ទីរស៧១ **អៀង សារី** ជាអ្នកសម្របសម្រួលការចាប់ខ្លួន តាមរយៈការជម្រាបឈ្មោះ ប៉ង់ ឬ លើន [redacted]។ ក្នុងឋានៈជាសមាជិកនៃគណៈអចិន្ត្រៃយ៍ **អៀង សារី** បានដឹងអំពីគោលបំណងរបស់មន្ទីរស២១ និងបានដឹងថា មនុស្សដែលគេបានបញ្ជូនទៅទីនោះ នឹងត្រូវ"កម្ទេច"។ គាត់បានទទួលស្គាល់ថា មនុស្សដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១ "ពុំបានត្រឡប់មកវិញឡើយ" ហើយពួកគេត្រូវបានចាប់ខ្លួនឃុំឃាំងនៅទីនោះ "ដោយគ្មានហេតុផលសមស្រប"។ ក្នុងអំឡុងពេលបណ្តុះបណ្តាលបុគ្គលិកអំពីនយោបាយ **អៀង សារី** បានអានចម្លើយសារភាពរបស់មន្ទីរស២១ ជាគំរូនៃមនុស្សដែលបានរំលោភមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងផលវិបាកនៃការរំលោភនោះ។

*អ្នកការទូត បញ្ញវន្ត និងនិស្សិតដែលបានវិលត្រឡប់ចូលមកកម្ពុជា*

១០២១- ក្រៅពីបុគ្គលិកក្រសួងការបរទេស អៀង សារី ជាអ្នកទទួលខុសត្រូវលើបុគ្គលិកការទូត អតីតមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បញ្ញវន្ត និងនិស្សិតដែលបានវិលត្រឡប់ចូលមកកម្ពុជាក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

១០២២- នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ អៀង សារី បានផ្ញើទូរលេខទៅកាន់ស្ថានទូតនានានៅក្រៅប្រទេសដោយបានអំពាវនាវឱ្យឯកអគ្គរដ្ឋទូតនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងមន្ត្រីការទូតផ្សេងៗ ឱ្យត្រឡប់ចូលភ្នំពេញ ដើម្បីចូលរៀនវគ្គសិក្សា និងវគ្គអប់រំនយោបាយចំនួន១០ថ្ងៃ។ អ្នកការទូតដែលបានវិលត្រឡប់ចូលមកភ្នំពេញមួយចំនួន បានជួបប្រជុំជាមួយ អៀង សារី នៅពេលពួកគេមកដល់។ វគ្គរៀនសូត្រនយោបាយរបស់ពួកគេ ត្រូវបានរៀបចំដោយ អៀង សារី [redacted]។ នៅពេលបញ្ចប់វគ្គរៀនសូត្រនេះ សិក្ខាកាមមួយចំនួនតូច ត្រូវបានចាត់តាំងទៅកាន់ក្រសួងការបរទេសភ្លាមៗ ប៉ុន្តែភាគច្រើនត្រូវបានបញ្ជូនទៅធ្វើពលកម្មយ៉ាប់យ៉ឺននៅតាមទីជនបទ អនុលោមតាមសេចក្ដីសម្រេចមួយរបស់ អៀង សារី និងគណៈអចិន្ត្រៃយ៍ដែលថាអតីតអ្នកការទូត នឹងត្រូវស្ថិតក្រោមការលត់ដំ។ [redacted]។

១០២៣- នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៦ អៀង សារី បានរាយការណ៍ជូនសមាជិកគណៈអចិន្ត្រៃយ៍ ថាស្ថានទូតមួយចំនួនដែលនៅសល់ គឺស្ថានទូតនៅប៉េកាំង កូរ៉េខាងជើង វៀតណាម និងឡាវ

ចំណែកឯកអគ្គរដ្ឋទូតផ្សេងៗទៀត និងក្រុមគ្រួសារបានវិលត្រឡប់ចូលមកកម្ពុជាវិញអស់ហើយ។ មកទល់ពេលនោះ គណៈអចិន្ត្រៃយ៍បានសន្និដ្ឋានថាមាន "ភាពចាំបាច់ដែលត្រូវប្រយ័ត្នប្រយែង" ជាមួយ"អ្នកការទូតចាស់ៗ" ហើយពួកគេពុំត្រូវបានប្រើប្រាស់សម្រាប់បម្រើការងារឱ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឡើយ។

១០២៤- ការកោះហៅកម្មាភិបាលការទូតពីសំណាក់ក្រសួងការបរទេសបានបន្តធ្វើជាច្រើនឆ្នាំបន្តបន្ទាប់ដែលមានការសម្របសម្រួលពីស្ថានទូតកម្ពុជាប្រជាធិបតេយ្យនៅប្រទេសចិន។ ឧទាហរណ៍នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសចិនឈ្មោះ ពេជ្រ ឈាង បានហៅឈ្មោះ អ៊ុក កេត (កម្មាភិបាលទូតនៅប្រទេសសេណេហ្គាល់) ឱ្យត្រឡប់ចូលមកកម្ពុជាដើម្បី "អប់រំ និងរៀនសូត្រ"។ [redacted]។

១០២៥- អៀង សារី ក៏ជាអ្នកទទួលខុសត្រូវផងដែរ ចំពោះការអូសទាញមនុស្សនៅក្រៅស្រុកឱ្យត្រឡប់ចូលមកមាតុប្រទេសវិញ។ គាត់ "បានណែនាំ" បញ្ញវន្តនៅប្រទេស ប៊ុលហ្គារី ហុងហ្គារី និងយូហ្គោស្លាវី ឱ្យត្រឡប់មកមាតុប្រទេសវិញ ហើយក្នុងនោះ យ៉ាងហោចណាស់ មានបញ្ញវន្តចំនួន១០០នាក់ បានវិលត្រឡប់មកកម្ពុជា។នៅចុងឆ្នាំ១៩៧៥ ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិប

គេយ្យនៅប្រទេសចិន បានបញ្ជាឲ្យនិស្សិតខ្មែរដែលរស់នៅទីនោះ ឲ្យវិលត្រឡប់ចូលកម្ពុជា ដើម្បីជួយកសាងប្រទេស។ នៅចុងខែសីហា ឆ្នាំ១៩៧៥ នៅពេលស្នាក់អាស្រ័យនៅប៉ារីស ក្នុងពេលធ្វើដំណើរទៅកាន់ប្រទេសប៉េរូ **អៀង សារី** បានអំពាវនាវឲ្យប្រជាជនកម្ពុជានៅបរទេសត្រឡប់ចូលមាតុប្រទេសវិញ។ ក្នុងអំឡុងពេលទស្សនកិច្ចទៅប្រទេសបារាំង និងប្រទេសផ្សេងៗ **អៀង សារី** បានថ្លែងសន្ទរកថា "ដោយបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃគោលនយោបាយរបស់ប្រទេស" តាមរយៈការអះអាងថា"អ្វីៗគ្រប់យ៉ាងសុទ្ធតែល្អទាំងអស់ ហើយការរស់នៅ នៅកម្ពុជាមានលក្ខណៈល្អប្រសើរ" ដែលការអះអាងបែបនេះបាននាំឲ្យមនុស្សជាច្រើនវិលត្រឡប់ចូលមកកម្ពុជា។ [redacted] មានជើងហោះហើរប្រចាំសប្តាហ៍ពីប៉េកាំងប្រទេសចិន ដែលភាគច្រើនមានសិស្ស និស្សិត និងបញ្ញវន្តដែលបានវិលត្រឡប់មកកម្ពុជាវិញ។ អ្នកធ្វើមាតុភូមិនិវត្តន៍ទាំងនេះ បានជួបជាមួយ [redacted] ហើយលិខិតឆ្លងដែនរបស់ពួកគេត្រូវបានរឹបអូសយក ចំណែក វ៉ាលី និងសម្លៀកបំពាក់របស់ពួកគេត្រូវបានយកទៅរក្សាទុកក្នុងឃ្លាំងក្រសួងការបរទេស ហើយពួកគេត្រូវបានដឹកតាមរថយន្តទៅកាន់ជំរំឃុំឃាំង។

១០២៦- **អៀង សារី** បានទទួលស្គាល់នូវតួនាទីសំខាន់របស់គាត់ ក្នុងការវិលត្រឡប់នៃប្រជាជនកម្ពុជារស់នៅក្រៅស្រុក ដោយបានសម្តែងការសោកស្តាយចំពោះ"ការស្លាប់របស់បញ្ញវន្ត" និងដោយបានគូសបញ្ជាក់ថាគាត់ គឺជា"មនុស្សម្នាក់ ដែលបានប្រមែប្រមូលពួកគេ ឲ្យមកជួយកសាងប្រទេស"។

*មន្ទីរលត់ដំបឹងត្រពែក និងច្រាំងចំរេះ*

១០២៧- ដូចដែលបានពិភាក្សាលម្អិតពីខាងដើមក្នុងផ្នែកតួនាទី និងសិទ្ធិអំណាច **អៀង សារី** ជាអ្នកគ្រប់គ្រង និងទទួលខុសត្រូវមន្ទីរលត់ដំ និងការដ្ឋានធ្វើពលកម្មដោយបង្ខំមួយចំនួន រួមទាំងមន្ទីរលត់ដំច្រាំងចំរេះ និងបឹងត្របែកផងដែរ។

១០២៨- មន្ត្រីទូត បញ្ញវន្ត និងនិស្សិតជាច្រើនដែលបានវិលត្រឡប់ចូលមកកម្ពុជាវិញ ត្រូវបានឃុំឃាំងនៅច្រាំងចំរេះនៅឆ្នាំ១៩៧៦ រួចបញ្ជូនទៅកាន់មន្ទីរបឹងត្របែកនៅឆ្នាំ១៩៧៧។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ អតីតមន្ត្រីទូតមួយក្រុម និងមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលបានជាប់ឃុំឃាំងនៅមន្ទីរលត់ដំច្រាំងចំរេះ ត្រូវបាននាំទៅជួបជាមួយ **អៀង សារី** នៅក្រសួងការបរទេស រួចបន្ទាប់មកត្រូវបានបញ្ជូនទៅកាន់មន្ទីរលត់ដំបឹងត្របែក។ [redacted]។ នៅទីនោះ អ្នកជាប់ឃុំឃាំងត្រូវជួបប្រទះនឹងការធ្វើពលកម្មដោយបង្ខំជាច្រើនម៉ោង វិន័យតឹងរ៉ឹងក្នុងការដើរហើរ ការបំពាក់បំប៉ននយោបាយ "ការបាត់ខ្លួន" និងការប្រហារជីវិតជាចំហរ។ អ្នកជាប់ឃុំឃាំងដែលទទួលការ"លត់ដំ"ពុំបានជោគជ័យ ត្រូវបានបញ្ជូនទៅកាន់មន្ទីរស២១ ដើម្បីប្រហារជីវិត។

១០២៩- **អៀង សារី** ជាអ្នកទទួលខុសត្រូវក្នុងការលត់ដំអតីតមន្ត្រីការទូត និងនិស្សិត បញ្ញវន្ត ដែលបានត្រឡប់ចូលស្រុកវិញ និងការសម្រេចជ្រើសរើសយកមនុស្សណាដែលត្រូវទៅបម្រើការនៅក្រសួងការបរទេស ឬត្រូវនៅបន្តស្ថិតនៅតាមទីកន្លែងទាំងនោះ និងមនុស្សណាដែលត្រូវបញ្ជូនទៅកាន់មន្ទីរស២១។ ខ្លួនគាត់ផ្ទាល់ជាអ្នកបណ្តុះបណ្តាលនយោបាយដល់បញ្ញវន្តនៅមន្ទីរបឹងត្រ

បែក ដោយគាត់បានពិភាក្សាអំពីបញ្ហានៃការកម្ចាត់បណ្ដាញខ្មាំង និងបានលើកឡើងនូវចម្លើយសារភាពស-២១ របស់អតីតអ្នកជាប់ឃុំឃាំងនៅកន្លែងលត់ដំទាំងនោះ។

*កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាផ្សេងៗ*

១០៣០- ក្នុងឋានៈជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** បានចូលរួមក្នុងការសម្រេចបោសសម្អាត និងចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់នានារបស់បក្សកុម្មុយនីស្តកម្ពុជា។ ជាក់ស្ដែង ការសម្រេចចាប់ខ្លួនលេខាតំបន់២៤ ឈ្មោះ សួស នៅ ហៅ ឈូក គឺត្រូវបានធ្វើឡើងរួមគ្នាដោយគណៈអចិន្ត្រៃយ៍ទាំងមូល ក្នុងនោះប្រធានមន្ទីរស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានផ្ដល់ឱ្យ សុន សេន នូវចម្លើយសារភាពដកស្រង់ចំនួន៧ច្បាប់ ដែលបានឆ្លើយដាក់ឈ្មោះ ឈូក សម្រាប់ចែកឱ្យសមាជិកម្នាក់ៗនៃគណៈអចិន្ត្រៃយ៍។ **អៀង សារី** បានមានវត្តមាននៅក្នុងអង្គប្រជុំដែលក្នុងនោះពួកគេបានជជែក និងសម្រេចទៅលើការចាប់ខ្លួន វន វ៉េត។

*ចំនួនជនរងគ្រោះតាមការប៉ាន់ស្មាន*

១០៣១- ដោយសារទង្វើនានាដូចដែលបានរៀបរាប់ខាងលើ **អៀង សារី** ទទួលខុសត្រូវជាពិសេសចំពោះការចាប់ខ្លួន ការឃុំឃាំង ការធ្វើទារុណកម្ម និងការប្រហារជីវិតមនុស្សចំនួនប្រមាណ២០០នាក់នៅមន្ទីរស២១ រួមទាំងកម្មាភិបាលក្រសួងការបរទេសចំនួន ៨២នាក់ អតីតមន្ត្រីការទូត និងមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិចំនួន២៦នាក់ បញ្ញវន្ត និងនិស្សិតដែលវិលត្រឡប់មកកម្ពុជាចំនួន៥៧នាក់ និងប្ដីប្រពន្ធ ឬសមាជិកក្រុមគ្រួសាររបស់ពួកគេចំនួន៣០នាក់។

**ការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក**

១០៣២- ការសម្រេចលុបបំបាត់ព្រះពុទ្ធសាសនា បិទទ្វារវត្តអារាម និងផ្សឹកព្រះសង្ឃ គឺជាគោលនយោបាយស្នូលមួយរបស់បក្សកុម្មុយនីស្តកម្ពុជាមានក្នុងមនោគមវិជ្ជាម៉ាក្សលេនីន ដែលត្រូវបានមេដឹកនាំជាន់ខ្ពស់នានារបស់បក្សនេះ បង្កើតឡើង ។ យោងតាមបក្សកុម្មុយនីស្តកម្ពុជា ព្រះសង្ឃ គឺជា"ពស្លឹង" "ជាព្រូនជញ្ជក់ឈាម" និង "ជាពួកសក្តិភូមិដែលបានជញ្ជក់ឈាមប្រជាជន"។ ការសម្រេចរបស់ពួកមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការចាត់ទុកព្រះសង្ឃជា "វណ្ណៈពិសេស" ដែលគួរត្រូវបានផ្សឹក ដែលស្រដៀងគ្នានឹងពួកទាហានសាធារណរដ្ឋខ្មែរ ត្រូវបានផ្សព្វផ្សាយប្រាប់កម្មាភិបាលនៅឆ្នាំ១៩៧៤ និងត្រូវបាន ប៉ុល ពត និង **នួន** ជា បញ្ជាក់អះអាងក្នុងឱកាសមហាសន្និបាតកម្មាភិបាលបក្សទូទាំងប្រទេសដែលបានចាប់ផ្តើមធ្វើកាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម

១០៣៣- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងការបរទេស និងជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍ **អៀង សារី** បានចូលរួមក្នុងការបង្កើត និងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាម និងបានឯកភាព និងដឹកនាំអំពើដែលរាប់ថា ជាការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។

១០៣៤- របាយការណ៍ និងទូរលេខរបស់យោធាដែលត្រូវបានធ្វើក្នុងអំឡុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ បញ្ជាក់ថា **អៀង សារី** បានដឹងច្បាស់លាស់អំពីការសម្លាប់ដោយចេតនាទៅលើជនស៊ីវិល និងការបំផ្លិចបំផ្លាញជនស៊ីវិលពីសំណាក់កងកម្លាំងប្រដាប់អាវុធដែលបានប្រតិបត្តិការនៅតាមបណ្តោយព្រំដែនវៀតណាម និងការធ្វើបាបឈ្លើយសឹកវៀតណាមនៅមន្ទីរស២១

ដោយខុសច្បាប់ ហើយគាត់គឺជាមេដឹកនាំជាន់ខ្ពស់មួយរូប ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់នានានៃបក្ស កុម្មុយនីស្តកម្ពុជាដែលបានបញ្ជា និងត្រួតពិនិត្យឧក្រិដ្ឋកម្មទាំងនោះ។ ជាក់ស្តែងនៅខែមីនា ឆ្នាំ១៩៧៦ **នួន ជា** និង **អៀង សារី** បានទទួលទូរលេខមួយច្បាប់ដែលបានរាយការណ៍លម្អិតអំពីការចាប់ខ្លួន ការឃុំឃាំង ការសួរចម្លើយ និងការសម្លាប់ទាហានវៀតណាម ។ គ្រាន់តែនៅចន្លោះខែសីហា ឆ្នាំ១៩៧៧ ដល់ខែមេសា ឆ្នាំ១៩៧៨ ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាបង្ហាញថា **អៀង** សារី បានដឹងអំពីការសម្លាប់ប្រជាជនស៊ីវិលវៀតណាមចំនួនជាង១០០០នាក់ ក្រោមស្នាដៃកងកម្លាំងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ នៅវៀតណាម។

១០៣៥- សិទ្ធិអំណាចរបស់ **អៀង សារី** ទៅលើចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មអស់ទាំងនោះ និងការចូលរួមរបស់គាត់ក្នុងការសម្រេចបញ្ជាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ត្រូវបានបញ្ជាក់អះអាងដោយទូរលេខមួយចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៧ របស់លេខាភូមិភាគបូព៌ា ចម្លងជូន **នួន ជា** និង **អៀង សារី** ដោយបានសាកសួរថាតើមន្ទីរ៨៧០ ចង់បានជនជាតិវៀតណាម៣នាក់ដែលគេចាប់ខ្លួនបាន និងកំពុងសួរចម្លើយនៅតំបន់២៣ ដើម្បីបញ្ជូនទៅភ្នំពេញដែរ ឬទេ។ ក្រសួងការបរទេសបានយកចម្លើយសារភាពរបស់ជនជាតិវៀតណាម ទៅប្រើប្រាស់ក្នុងឯកសារបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រួមទាំងសេចក្តីថ្លែងការណ៍ស្តីពី "ភ្នាក់ងារវៀតណាម ដែលបានជ្រៀតខ្លួនចូលក្នុងជួរបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ និងដែលត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៦"។ នៅខែធ្នូ ឆ្នាំ១៩៧៨ **អៀង សារី** បានសរសេរសំបុត្រទៅកាន់ សុន សេន ដោយស្នើសុំឲ្យគាត់ទទួលប្រតិភូកម្មាភិបាលចិន ដើម្បី "ឲ្យពួកគេបានឃើញសមិទ្ធផល

ជោគជ័យ ដែលយកបានពីសាកសពជនជាតិវៀតណាម និងឃ្មួន ក្នុងចំណោមសមិទ្ធផល ផ្សេងៗ"។

**រយៈកាលក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ**

១០៣៦- តាមការបង្ហាញពីទ្រង់ទ្រាយនៃអំពើស៊ីសង្វាក់គ្នាមួយសកម្មភាពរបស់ **អៀង សារី** នៅក្រោយការដកអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា ពង្រឹងចំពោះភស្តុតាងនៃការចូលរួមប្រព្រឹត្ត និងចេតនាឧក្រិដ្ឋកម្មរបស់គាត់ ក្នុងសម័យកាលដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ ដូចបានរៀបរាប់ខាងក្រោមនេះ ពេលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានធ្វើការកសាងខ្លួនឯងឡើងវិញ ក្នុងឆ្នាំ ១៩៧៩ **អៀង សារី** នៅតែជាមេដឹកនាំជាន់ខ្ពស់ម្នាក់របស់បក្ស នៅតែថែរក្សាបាននូវ មុខតំណែងរដ្ឋមន្ត្រីក្រសួងការបរទេស និងបានចូលរួមក្នុងកិច្ចប្រជុំ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់ថ្នាក់លើរបស់បក្ស។ គាត់បានបន្តធ្វើតំណាងឲ្យផលប្រយោជន៍របស់បក្សកុម្មុយនីស្តកម្ពុជានៅបរទេស រួមទាំងនៅក្នុងវេទិកាអន្តរជាតិនានាដូចជា អង្គការសហប្រជាជាតិជាដើម សូម្បីតែក្នុងពេលរូបគាត់ត្រូវបានដាក់ឲ្យកាត់ទោស*កំបាំងមុខ* ចំពោះការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មរបស់កម្ពុជាប្រជាធិបតេយ្យរបស់គាត់ក៏ដោយ ក៏គាត់នៅតែខំប្រមែប្រមូលការគាំទ្រពីអន្តរជាតិ ដើម្បីឲ្យបក្សកុម្មុយនីស្តកម្ពុជាបានវិលមកកាន់អំណាចវិញ។ គាត់នៅតែបន្តធ្វើសកម្មភាព ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា យ៉ាងហោចណាស់ក៏១៣ឆ្នាំដែរ បន្ទាប់ពីឆ្នាំ១៩៧៩មក និងបានលេចមុខជាមេដឹកនាំបក្សថ្មីមួយក្នុងឆ្នាំ១៩៩៦។ ដូចមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតដែរ គាត់នៅតែបន្តបដិសេធជាច្រើនឆ្នាំ ចំពោះឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែទើបតែថ្មីៗនេះ គាត់បានទទួលស្គាល់ឧក្រិដ្ឋកម្មទាំង

នោះ ក្នុងខណៈដែលគាត់កំពុងតែស្វែងរកដើម្បីបដិសេធ ឬធ្វើឲ្យកាន់តែតិចបំផុតនូវការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់គាត់ ។

**សកម្មភាព និងតួនាទី**

១០៣៧- នៅពេលភ្លាមៗក្រោយពីបែកភ្នំពេញ **អៀង សារី** បានជួបជាមួយ ប៉ុល ពត និង **នួន ជា** នៅក្បែរបាត់ដំបង ឬពោធិ៍សាត់ដែលនៅទីនោះមានការសម្រេចមួយដែលថា គាត់ត្រូវធ្វើដំណើរទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីតំណាងបក្សកុម្មុយនីស្តកម្ពុជា និងស្វែងរកជំនួយសម្ពន្ធមិត្តដ៏សំខាន់របស់ខ្លួន។ ដោយចាប់ផ្ដើមពីថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ **អៀង សារី** បានជួបប្រជុំជាច្រើនលើក ជាមួយមេដឹកនាំចិន Deng Xiaoping និង Hua Geofen និងបានទទួលទឹកប្រាក់ជំនួយចំនួន៥លានដុល្លាសហរដ្ឋអាមេរិក។ **អៀង សារី** បានបន្តធ្វើជា "ច្រកចេញចូលយ៉ាងសំខាន់" សម្រាប់ជំនួយពីប្រទេសចិនមកឲ្យបក្សកុម្មុយនីស្តកម្ពុជា និងបានផ្គត់ផ្គង់ថវិកាដល់ចលនានេះ តាមរយៈការជីករ៉ែ និងការកាប់ឈើខុសច្បាប់ បន្ទាប់ពីជំនួយរបស់ប្រទេសចិនបានកាត់ផ្ដាច់ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០។

១០៣៨- តួនាទីថ្នាក់ដឹកនាំជាបន្តបន្ទាប់របស់ **អៀង សារី** នៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបញ្ជាក់អះអាងតាមរយៈការចូលរួមជាទៀងទាត់របស់គាត់ក្នុងអង្គប្រជុំផ្ទៃក្នុង និងចម្រុះ។ នៅខែកុម្ភៈ ឬមីនា ឆ្នាំ១៩៧៩ គាត់បានចូលរួមក្នុងអង្គប្រជុំគណៈមជ្ឈិមលើកដំបូង ក្រោយពីថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមាន ប៉ុល ពត **នួន ជា ខៀវ សំផន** និង តាម៉ុក។ ក្នុងឱកាសសន្និបាតកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១៥-១៧ ខែធ្នូ ឆ្នាំ១៩៧៩ **អៀង សារី** ត្រូវបានបញ្ជាក់តួនាទីជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ ក្នុងអំឡុងឆ្នាំ១៩៧៩

រដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសសិង្ហបុរី បានជម្រុញឱ្យ **អៀង សារី ខៀវ សំផន** និង **អៀង ធីរិទ្ធ** បង្កើតសម្ព័ន្ធភាពមួយជាមួយក្រុមជាតិនិយមផ្សេងៗ ប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម។ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៨២ ការពិភាក្សាអំពីសម្ព័ន្ធភាព ត្រូវបានធ្វើឡើងដោយ **អៀង សារី ខៀវ សំផន** និង **អៀង ធីរិទ្ធ** ជាមួយសម្ដេចនរោត្តមសីហនុ ហើយ **អៀង សារី** ត្រូវបានតែងតាំងជាប្រធាននៃគណៈកម្មាធិការសម្របសម្រួលទទួលបន្ទុកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។ គាត់បានចូលរួមក្នុងអង្គប្រជុំសម្ព័ន្ធភាពជាច្រើនពេញមួយឆ្នាំ១៩៨៣ និងឆ្នាំ១៩៨៤។

១០៣៩- នៅខាងក្រៅប្រទេស **អៀង សារី** បានធ្វើជាអ្នកតំណាងឱ្យបក្សកុម្មុយនីស្តកម្ពុជា នៅចំពោះមុខស្ថាប័នមួយចំនួន រួមទាំងនៅក្នុងកិច្ចប្រជុំកំពូលលើកទី៦នៃបណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធនៅ Havana ក្នុងខែកញ្ញា ឆ្នាំ១៩៧៩ និងបានបង្ហាញជាញឹកញាប់នៅឯសន្និសីទដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិ និងសន្និសីទអង្គការសហប្រជាជាតិ។ តាងនាមឱ្យបក្សកុម្មុយនីស្តកម្ពុជា **អៀង សារី** តែងបានទទួលគណៈប្រតិភូបរទេស និងបានជួបប្រជុំជាមួយអ្នកសារព័ត៌មានបរទេសជាទៀងទាត់។ ជាបន្តបន្ទាប់ គាត់បានធ្វើជាអ្នកតំណាងដោយខ្លួនឯង និងត្រូវបានប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិចាត់ទុកថាជាសមាជិកឈានមុខមួយរូប របស់បក្សកុម្មុយនីស្តកម្ពុជា។

១០៤០- នៅខែសីហា ឆ្នាំ១៩៨៦ **អៀង សារី** បានទទួលភក្ដីភាពពីសំណាក់អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាចំនួនចន្លោះពី៤០០០ ដល់៦០០០នាក់ដែលចំនួននេះស្មើនឹងមួយភាគបី ទៅពីរភាគបីនៃកងកម្លាំង ប.ក.ក ដែលនៅសល់។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨៦ **អៀង សារី** បានប្រកាសអំពីការបង្កើតបក្សថ្មីមួយឈ្មោះថា ចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ។

ប៉ុន្មានសប្តាហ៍បន្ទាប់មកគឺនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៩៦ **អៀង សារី** បានប្រកាសអំពីបទឈប់បាញ់ជាផ្លូវការដែលកំពុងដំណើរការ និងយល់ព្រមចូលចរចាជាមួយរដ្ឋាភិបាលកម្ពុជា ប៉ុន្តែបានដាក់លក្ខខណ្ឌមួយទុកសម្រាប់ការជជែកពិភាក្សារបស់គាត់ ជាមួយរដ្ឋាភិបាលកម្ពុជា។ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ សម្តេចនរោត្តមសីហនុ បានចេញព្រះរាជក្រឹត្យលើកលែងទោស **អៀង សារី** ដែលតុលាការបដិវត្តន៍ប្រជាជន បានប្រកាសកាលពីឆ្នាំ១៩៧៩ និងបានលើកលែងទោសតាម "ច្បាប់ [ឆ្នាំ១៩៩៤] ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់"។

## ការដឹងឮ និងការបដិសេធឧក្រិដ្ឋកម្ម

១០៤១- ទាំងក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ **អៀង សារី** មានចេតនារារាំងការស្វែងរកឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយគាត់បានបដិសេធអំពីអត្ថិភាពនៃឧក្រិដ្ឋកម្មទាំងនេះក្នុងឆាកអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយ។ ទោះបីគាត់បានទទួលស្គាល់ថា គាត់បានដឹងឧក្រិដ្ឋកម្មទាំងនោះ តាមរយៈរបាយការណ៍ជាទៀងទាត់ដែលគាត់បានទទួលបានក្នុងនាមជាសមាជិកមួយរូបនៃគណៈអចិន្ត្រៃយ៍ក្តី **អៀង សារី** បានបដិសេធផ្ទួនៗ នូវអំពើយង់ឃ្នងទាំងនេះ និងបានបរិហារព័ត៌មានទាំងនេះថា ជា"ការឃោសនាអកុសល"។ ក្នុងលក្ខណៈនេះ គាត់បានបង្វែរការរិះគន់ទៅលើគោលនយោបាយខុសច្បាប់របស់បក្សកុម្មុយនីស្តកម្ពុជា ដោយទាញការចាប់អារម្មណ៍ចំពោះការជ្រៀតជ្រែករបស់រដ្ឋផ្សេងៗទៅតាមការសន្មត។

១០៤២- ថ្មីៗនេះ **អៀង សារី** បានស្ទាក់ស្ទើរ ក្នុងការទទួលស្គាល់នូវឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែបានខិតខំសម្រាលជាអតិបរមានូវការទទួលខុសត្រូវផ្ទាល់ខ្លួន និងបានទម្លាក់ការ

ទទួលខុសត្រូវ លើកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ពិសេសគឺ ប៉ុល ពត នួន ជា និង សុន សេន។

## ខៀវ សំផន

### ទិដ្ឋភាពទូទៅ

១០៤៣- ផ្នែកខាងក្រោមនេះពណ៌នាអំពីទិដ្ឋភាពទូទៅនៃការជាប់ពាក់ព័ន្ធរបស់ **ខៀវ សំផន** និងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋកម្មនានាដែលស្ថិតក្រោមការស៊ើបអង្កេត។

១០៤៤- **ខៀវ សំផន** ជាសមាជិកក្នុងក្រុមតូចមួយ ដែលកាន់ចង្កូតបក្សកុម្មុយនីស្តកម្ពុជាដែលជាអ្នកផ្តើមឲ្យមានសហកម្មឧក្រិដ្ឋកម្មរួម ហើយបន្ទាប់មកជាអ្នកដែលណែនាំ និងគ្រប់គ្រងការអនុវត្តន៍ឧក្រិដ្ឋកម្មនោះ។ ដោយសារខ្លួនជាសកម្មជនយ៉ាងយូរអង្វែងនៅក្នុងក្រុមចលនាខ្មែរក្រហម គាត់បានកាន់តួនាទីជាន់ខ្ពស់ជាច្រើន ក្នុងខ្មែរក្រហម រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា យ៉ាងហោចណាស់រយៈពេល៥ឆ្នាំ មុនពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាច។ នៅក្នុងអំឡុងពេលនោះ គាត់ធ្វើការងារដើម្បីធានាពីជ័យជំនះរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានចូលរួមចំណែកនៅក្នុងទស្សនទានផែនការឧក្រិដ្ឋកម្មដែលរូបគាត់ និងសមាជិកសហកម្មឧក្រិដ្ឋកម្មរួមផ្សេងទៀត បានបង្កើតឲ្យលេចចេញជារូបរាងនៅពេលពួកខ្លួនឡើងកាន់អំណាចភ្លាម។

១០៤៥- **ខៀវ សំផន** បានទទួលយកមុខតំណែងដោយស្ម័គ្រចិត្ត និងមានតួនាទីជាច្រើនជាអ្នកទទួលខុសត្រូវ និងមានឥទ្ធិពលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យរួមមានតំណែងជាប្រធានគណៈប្រធានរដ្ឋ និងជាប្រធានមន្ទីរនយោបាយ៨៧០ ហើយគាត់ជាសមាជិក

ស្របច្បាប់ និង/ឬជាក់ស្តែងនៅក្នុងស្ថាប័នកំពូលៗរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានអំណាចចេញសេចក្តីសម្រេច រួមមាន គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការពាណិជ្ជកម្ម និងធនាគារ។ ក្នុងអំឡុងពេលនោះ គាត់រស់នៅ និងបំពេញការងារយ៉ាងជិតស្និទ្ធិជាមួយបណ្តាមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជា និងស្ថិតនៅជាសមាជិកថ្នាក់លើរបស់បក្ស។ គាត់បានបង្ហាញខ្លួនទាំងនៅក្នុងប្រទេស និងបរទេស ក្នុងឋានៈជាមេដឹកនាំម្នាក់របស់របបកម្ពុជាប្រជាធិបតេយ្យ និងត្រូវបានការទទួលស្គាល់ពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា/កម្ពុជាប្រជាធិបតេយ្យ ពីប្រជាជនទូទៅ និងពីសហគមន៍អន្តរជាតិផងដែរ។

១០៤៦- សកម្មភាពនានាដែលបង្ហាញថា **ខៀវ សំផន** ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលស្ថិតក្រោមការស៊ើបអង្កេត រួមមាន (តែមិនកំណត់ត្រឹម)៖ ការចូលរួម និងការរួមចំណែកនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ដែលបង្កើតជាសហកម្មឧក្រិដ្ឋកម្មរួម ការរាយការណ៍ពីដំណើរការការងារដែលទទួលបាន និងយកមកពិភាក្សាគ្នា និងការចេញសេចក្តីណែនាំបន្ថែម ការបំពេញការងារ និងការចាត់ចែងនៅក្នុងមន្ទីរនយោបាយ៨៧០ ដូចជាការណែនាំ ការទទួលរបាយការណ៍ និងការពិនិត្យលើការអនុវត្តន៍គោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ការចូលរួមនៅក្នុងអំពើឧក្រិដ្ឋជាក់លាក់នានា ដូចជាការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ការត្រួតពិនិត្យ និងការជួយសម្រួលការអនុវត្តន៍គោលនយោបាយនៅទូទាំងប្រទេស ដូចជា ការធ្វើពលកម្មទាំងបង្ខំ ការប្រព្រឹត្តិបែបអមនុស្សធម៌ និងអំពើទាសភាពជាដើម នៅក្នុងតួនាទីជាសមាជិកគណៈកម្មាធិការមជ្ឈិមដែលទទួលខុសត្រូវពាណិជ្ជកម្ម និងការបង្កបង្កើនផលរដ្ឋ ការបញ្ជា និងការញុះញង់អំពើឧក្រិដ្ឋកម្ម តាមរយៈការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ សុន្ទរកថា និងការលត់ដំកម្មាភិបាល និងបញ្ញវន្ត ការជួយក្នុងការសម្រិត

សម្រាំងនានា តាមរយៈការស៊ើបអង្កេតរកកម្មាភិបាលដែលជាប់សង្ស័យ ការទទួល និងពិនិត្យចម្លើយសារភាពរបស់កម្មាភិបាលដែលត្រូវគេចាប់ខ្លួន និងការផ្តល់យោបល់ និងឯកភាពលើការចាប់ខ្លួន ការធ្វើជាតំណាងរបស់របបកម្ពុជាប្រជាធិបតេយ្យទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ និងការបដិសេធរាល់ភ័ស្តុតាងនៃឧក្រិដ្ឋកម្មរបស់របបនេះ ម្យ៉ាងទៀតមានការជួបប្រជុំជាទៀងទាត់ និងបំពេញការងារជាមួយបណ្តាមេដឹកនាំជាន់ខ្ពស់ផ្សេងទៀត នៃរបបកម្ពុជាប្រជាធិបតេយ្យ និងការអនុវត្តន៍អំណាចរបស់ខ្លួន ក្នុងការរៀបចំផែនការ និងជួយជ្រោមជ្រែងក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនានាផងដែរ។ តាមរយៈតួនាទីជាផ្លូវការរបស់ខ្លួន និងជាអ្នកមានឥទ្ធិពលនៅក្នុងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផងនោះ **ខៀវ សំផន** ក៏បានអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើរចនាសម្ពន្ធនានារបស់បក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ដូចជាផ្នែកយោធា រដ្ឋបាល និងតាមតំបន់ ដោយទាក់ទិននឹងអំពើឧក្រិដ្ឋនានា និងខកខានមិនបានទប់ស្កាត់ការប្រព្រឹត្តិបទឧក្រិដ្ឋកម្ម ឬការស៊ើបអង្កេត និងដាក់ទណ្ឌកម្មដល់ចារីទាំងនោះឡើយ។

១០៤៧- ក្នុងអំឡុងពេលដែលស្ថិតក្រោមការស៊ើបអង្កេត **ខៀវ សំផន** មានអភ័យឯកសិទ្ធិ ក្នុងការទទួលបានព័ត៌មានស្តីពីបទឧក្រិដ្ឋទាំងនោះ។ ក្រៅពីនេះ គាត់បានជំរុញឲ្យបន្តការចាប់ខ្លួន និងសម្លាប់អ្នកដែលចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ការបង្ខំឲ្យធ្វើពលកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងទៀតប្រឆាំងនឹងប្រជាជនស៊ីវិល។ នៅក្នុងការទាក់ទងជាអន្តរជាតិក្នុងឋានៈជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ គាត់ធ្វើមិនដឹង មិនឮ ឬបានបដិសេធការអំពាវនាវឲ្យធ្វើការស៊ើបអង្កេត ចំពោះការចោទប្រកាន់ពីការប្រព្រឹត្តិបទឧក្រិដ្ឋជាទ្រង់ទ្រាយធំ នៅក្នុងប្រទេសកម្ពុជា។

១០៤៨- ទំនាក់ទំនងផ្ទាល់ខ្លួន ផ្នែកវិជ្ជាជីវៈ និងនយោបាយរបស់ **ខៀវ សំផន** ជាមួយសមាជិកសហកម្ម ឧក្រិដ្ឋកម្មរួមផ្សេងទៀតចាប់ផ្ដើមពីដើមទសវត្សរ៍ឆ្នាំ១៩៥០ រហូតដល់ចុងទសវត្សរ៍ឆ្នាំ១៩៩០ ស្ទើរតែមួយជីវិតនៃការសិក្សា និងវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងអំឡុងពេលនោះ គាត់បានបង្ហាញថា ខ្លួនគាត់ជាអ្នកគាំទ្រគោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្ដកម្ពុជាដ៏ខ្លាំងក្លា និងជាសម្ពន្ធភាពដែលស្មោះត្រង់របស់ ប៉ុល ពត។ ទោះបីគាត់បានបដិសេធពីការដឹងឮរបស់ខ្លួន និងការជាប់ពាក់ព័ន្ធនៅក្នុងអំពើឧក្រិដ្ឋណាមួយក្ដី តែមានភស្តុតាងជាច្រើនលើសលប់នៅក្នុងសំណុំរឿងបានបញ្ជាក់ មិនត្រឹមតែថាគាត់បានដឹងពីអំពើឧក្រិដ្ឋប៉ុណ្ណោះទេ តែថែមទាំងបានចូលពាក់ព័ន្ធយ៉ាងសកម្មថែមទៀតផង។

១០៤៩- **ខៀវ សំផន** ក៏បានបំពេញតួនាទីរបស់ខ្លួនយ៉ាងពេញលេញ ក្នុងឋានៈជាមេដឹកនាំម្នាក់របស់បក្សកុម្មុយនីស្ដកម្ពុជារយៈពេលជិត២០ឆ្នាំ បន្ទាប់ពីបក្សនេះត្រូវបានរុញច្រានចេញពីអំណាច ជាពេលវេលាដែលគាត់តស៊ូវាយប្រយុទ្ធដើម្បីនាំពួកខ្មែរក្រហមត្រឡប់មកវិញ។ គាត់ទើបតែទទួលស្គាល់ពីវិសាលភាពនៃអំពើឧក្រិដ្ឋ បន្ទាប់ពីបរាជ័យរបស់គាត់មិនអាចវិញត្រឡប់មកកាន់អំណាចវិញ និងការចុះចាញ់របស់គាត់នៅចុងឆ្នាំ១៩៩៨។ ក៏ប៉ុន្តែ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ នៅពេលដែលការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលចេះតែកើនឡើង គាត់បានរិះរកការធ្វើយុត្តិកម្មចំពោះគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជាផង និងដកខ្លួនចេញពីការទទួលខុសត្រូវរបស់ខ្លួនផង ក្នុងការចូលរួមចំណែកក្នុងអំពើឧក្រិដ្ឋដែលបានកើតឡើងផង។

## មុនឆ្នាំ១៩៧៥

១០៥០- **ខៀវ សំផន** កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅស្រុករំដួល ខេត្តស្វាយរៀង។ សំណុំរឿងមានព័ត៌មានតិចតួចទាក់ទិននឹងការសិក្សាពីបឋមវ័យរបស់គាត់។ មានប្រភពមួយបានបង្ហាញថា នៅខែកក្កដា ឆ្នាំ១៩៥១ គាត់បានទទួលសញ្ញាបត្រផ្នែកគណិតសាស្ត្រពីវិទ្យាល័យស៊ីសុវត្ថិ ហើយនៅខែឧសភា ឆ្នាំ១៩៥៣ គាត់បានបញ្ចប់ការសិក្សា និងបានទទួលសញ្ញាប័ត្រផ្នែកច្បាប់ពីវិទ្យាស្ថានសិក្សាច្បាប់ នយោបាយ និងសេដ្ឋកិច្ចនៅក្រុងភ្នំពេញ។ ភស្តុតាងផ្សេងទៀតបង្ហាញថា គាត់បានចូលរៀននៅវិទ្យាល័យព្រះសីហនុ ក្នុងខេត្តកំពង់ចាមដែលនៅទីនោះ គាត់បានជួបជាមួយ ប៉ុល ពត ដែលរៀនបានមួយឆ្នាំមុនគាត់។

១០៥១- នៅឆ្នាំ១៩៥៣ ឬ១៩៥៤ **ខៀវ សំផន** បានចូលបន្តការសិក្សានៅក្រុងប៉ារីស តាមរយៈអាហារូបករណ៍។ ពីឆ្នាំ១៩៥៤ ដល់១៩៥៦ គាត់បានទទួលសញ្ញាបត្រមួយចំនួនផ្នែកច្បាប់ សេដ្ឋកិច្ចជនបទ និតីកម្មផ្នែកឧស្សាហកម្ម ភូមិសាស្ត្រសេដ្ឋកិច្ច និងរចនាសម្ព័ន្ធ និងប្រព័ន្ធសេដ្ឋកិច្ច។ នៅឆ្នាំ១៩៥៩ គាត់បានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ច ដែលមានចំណងជើងថា "សេដ្ឋកិច្ចរបស់កម្ពុជា និងការអភិវឌ្ឍន៍ឧស្សាហកម្ម" នៅសាកលវិទ្យាល័យ Sorbonne ក្នុងក្រុងប៉ារីស។ ខណៈដែលមិនបានគិតថានិក្ខេបបទនេះនឹងក្លាយជាគំរូសម្រាប់បដិវត្តបក្សកុម្មុយនីស្តកម្ពុជាផងនោះ (រួមទាំងនិក្ខេបបទរបស់ ហ៊ូ យន់ ផងដែរ) បានផ្តល់នូវទស្សនទាននានាដែលក្លាយជាផ្នែកនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ទស្សនទានទាំងនោះរួមមានទស្សនៈបឋមភាពសេដ្ឋកិច្ចជាតិទៅលើទស្សនៈបុគ្គល និងការរៀបចំរចនាសម្ព័ន្ធសង្គមបែបជ្រុលនិយម ដើម្បីបង្កើនផលកសិកម្មជាអតិបរមា។

១០៥២- **ខៀវ សំផន** សកម្មផ្នែកនយោបាយតាំងពីឆ្នាំ១៩៤៦ នៅពេលគាត់ចូលរួមចលនាមួយរបស់និស្សិតកម្ពុជាដែលអំពាវនាវទាមទារឯករាជ្យ និងសេរីភាពពីអាណានិគមនិយមបារាំង។ នៅពេលគាត់កំពុងរៀននៅក្រុងប៉ារីស គាត់ក្លាយជាប្រធានសមាគមនិស្សិតខ្មែរ និងជាសមាជិកក្រុមម៉ាក្ស- លេនីន ដែលបានបង្កើតឡើង និងដឹកនាំដោយ **អៀង សារី** នៅឆ្នាំ១៩៥១ និងរួមមាន **អៀង ធីរិទ្ធ** ប៉ុល ពត និង ខៀវ ប៉ុណ្ណារី ជាសមាជិក។ អៀង សារី បានគូសបញ្ជាក់ថា **ខៀវ សំផន** ធ្លាប់បានចូលរួមក្នុងគណបក្សកុម្មុយនីស្តនៅប្រទេសបារាំងក្នុងឆ្នាំ១៩៥៥ ចំណែកឯ **នួន ជា** បានអះអាងថា **ខៀវ សំផន** គឺជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៦៣ រហូតមក។ គាត់ក្លាយជាប្រធានក្រុមនេះ នៅពេលដែល **អៀង សារី** ត្រឡប់មកប្រទេសកម្ពុជានៅខែមករា ឆ្នាំ១៩៥៧។ គាត់បានអះអាងថា នៅពេលគាត់ស្នាក់នៅប្រទេសបារាំង គាត់ក៏ធ្លាប់បានចូលរួមក្នុងចលនាខ្មែរវៀតមិញ ប្រយុទ្ធដើម្បីឯករាជ្យសម្រាប់កម្ពុជាដែរ។

១០៥៣- នៅពេលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៥៩ **ខៀវ សំផន** បម្រើការងារជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់នៅក្រុងភ្នំពេញ។ នៅខែកញ្ញា ឆ្នាំ១៩៥៩ គាត់បានបង្កើតសារព័ត៌មានមួយជាភាសាបារាំងដែលមានឈ្មោះថា *L'Observateur* ហើយគាត់បំពេញការងារជានិពន្ធនាយក។ សារព័ត៌មាននេះ ជាឧបករណ៍មួយរបស់ពួកកុម្មុយនីស្ត ដែលវិលត្រឡប់ពីប្រទេសបារាំង ដែលក្លាយជាអ្នកប្រឆាំងយ៉ាងខ្លាំងក្លាចំពោះរបបក្រុងភ្នំពេញ។ រាល់ការចំណាយរបស់សារព័ត៌មាននេះ គឺយកប្រាក់ខែរបស់ **អៀង ធីរិទ្ធ** ដែលបានមកពីការបង្រៀន និងប្រាក់ចំណាយផ្សេងទៀតដែល **ខៀវ សំផន** រកបានពីការបង្រៀនពីចុងសប្តាហ៍។ នៅក្នុង

អំឡុងពេលនោះ **ខៀវ សំផន** បានបង្រៀនកូនសិស្សរបស់គាត់ថា "កម្ពុជាត្រូវបោសសម្អាតអំពើពុករលួយ និងឥទ្ធិពលអាក្រក់ចេញ"។

១០៥៤- សារព័ត៌មាន *L'Observateur* បានរិះគន់ទៅលើគោលនយោបាយរបស់សម្ដេចនរោត្តម សីហនុ ហើយជាលទ្ធផល **ខៀវ សំផន** ត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៦០ ពីបទចោទថាបម្រើសកម្មភាពពួកកុម្មុយនីស្ដ។ គាត់ត្រូវបានគេបៀតបៀនដែលមានអាជ្ញាធរជាអ្នកឱ្យដៃ ហើយនៅខែសីហា ឆ្នាំ១៩៦០ គាត់ត្រូវបានគេចាប់ខ្លួនម្ដងទៀត និងត្រូវបានឃុំខ្លួនរយៈពេល២ខែ ដោយគ្មានការចោទប្រកាន់អ្វីទាំងអស់។ នៅអំឡុងពេលនោះ សារព័ត៌មាននោះក៏ត្រូវបិទទ្វារដែរ។

១០៥៥- ដល់ឆ្នាំ១៩៦២ **ខៀវ សំផន** បានចូលរួមជាមួយគណបក្សសង្គមរាស្ត្រនិយមរបស់សម្ដេចនរោត្តម សីហនុ ក្នុងការចូលរួមការបោះឆ្នោតជ្រើសរើសសភាជាតិ ហើយត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រសម្រាប់មណ្ឌលនៅស្រុកស្អាង ក្នុងខេត្តកណ្ដាល។ នៅខែតុលា ឆ្នាំ១៩៦២ គាត់ក្លាយជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម។ ក៏ប៉ុន្តែ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៦៣ គាត់ត្រូវបានសម្ដេចនរោត្តមសីហនុ ហៅថាជាអ្នកឆ្វេងនិយមម្នាក់ ក្នុងចំណោមជនជាប់សង្ស័យថាជាជនឆ្វេងនិយមចំនួន៣៤នាក់ ដែលត្រូវបានគេចាត់ទុកថាជា "ពួកកំសាក ពួកលាក់ពុត ពួកបំផ្លិចបំផ្លាញ ពួកបង្កវិទ្ធង្សនា និងពួកក្បត់"។ ក្នុងបញ្ជីនោះក៏មាន ប៉ុល ពត និង **អៀង សារី** ដែរ។ មកដល់ខែកក្កដា ឆ្នាំ១៩៦៣ **ខៀវ សំផន** ត្រូវបានបង្ខំឱ្យលាលែងតំណែងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ពីសំណាក់សមាជិករដ្ឋាភិបាលដែលប្រកាន់ស្ដាំ។ គាត់ត្រូវបានជាប់ឆ្នោតសាជាថ្មីជាតំណាងរាស្ត្រក្នុងឆ្នាំ១៩៦៦ តែគាត់មិនអាចបំពេញមុខនាទីរបស់ខ្លួននៅក្រុងភ្នំពេញ

ទេ ដោយសាររបបនោះគម្រាមកំហែងចាប់ខ្លួន និងសម្លាប់ចោល។ នៅខែមេសា ឆ្នាំ១៩៦៧ គាត់ត្រូវបានតុលាការឃោធាកោះហៅជាមួយ ហ៊ូ យន់ និង ហ៊ូ នឹម។ មកដល់ចំណុចនេះ **ខៀវ សំផន** និង ហ៊ូ យន់ បានភៀសខ្លួនពីក្រុងភ្នំពេញ ហើយទៅលាក់ខ្លួននៅក្នុងភូមិដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជានៅខេត្តកំពង់ស្ពឺ។ **ខៀវ សំផន** ស្ថិតនៅតំបន់នោះក្រោមការការពាររបស់ តាម៉ុក រហូតដល់ឆ្នាំ១៩៧០។

១០៥៦- ទោះបីគាត់បានសរសេរយ៉ាងទូលំទូលាយ អំពីការវិវត្តន៍នៅក្នុងចលនាកុម្មុយនីស្តក្នុងអំឡុងពេលនេះក៏ដោយ ក៏ **ខៀវ សំផន** បានផ្តល់ជាព័ត៌មានតិចតួចស្តីពីការជាប់ពាក់ព័ន្ធរបស់ខ្លួននៅក្នុងចលនានេះ បន្ទាប់ពីគាត់បានត្រឡប់ចូលមកប្រទេសកម្ពុជាវិញ។ ប្រការនេះបញ្ជាក់ច្បាស់ថាគាត់រក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបណ្តាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ ដោយបានអះអាងថា គាត់ ១)អាចភៀសខ្លួនចេញពីក្រុងភ្នំពេញបានដោយមានការការពារពីអ្នកទាំងនោះ និង ២)ទទួលបានការតែងតាំងតំណែងជាន់ខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាយ៉ាងឆាប់រហ័ស ដូចមានការពន្យល់នៅខាងក្រោម។ ប្រការដែលស៊ីសង្វាក់គ្នាផងដែរនោះគឺថា គាត់ទំនងជាបានទទួលកិច្ចការពីចលនាកុម្មុយនីស្តដែលបង្កប់នៅខាងក្នុងនៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ដើម្បីធ្វើការប្រមូលផ្តុំអ្នកគាំទ្រមានសក្តានុពល នៅក្នុងក្រុងភ្នំពេញ។

១០៥៧- **ខៀវ សំផន** បានអះអាងថា នៅខែមីនា ឬខែកញ្ញា ឆ្នាំ១៩៧០ គាត់បានជួប **នួន ជា** និង ប៉ុល ពត ជាមួយ ហ៊ូ យន់ ហ៊ូ នឹម និង តាម៉ុក នៅតំបន់ស្ទឹងជីនិតចន្លោះខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ ចាប់ពីពេលនោះមក **ខៀវ សំផន** ធ្វើការជាមួយ ប៉ុល ពត និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

ដទៃទៀត ហើយបានទទួលការតែងតាំងតំណែងជាន់ខ្ពស់ផ្សេងៗទៀត នៅក្នុង ឬក្នុងនាមចលនាខ្មែរក្រហមផងដែរ រួមមាន៖

១. ឧបនាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

២. រដ្ឋមន្ត្រីក្រសួងការពារជាតិរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

៣. អគ្គមេបញ្ជាការកងទ័ពរំដោះជាតិ

៤. សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមរណសិរ្សរួបរួមជាតិកម្ពុជា

៥. ប្រធានសមាគមមិត្តភាពកម្ពុជា វៀតណាម

៦. ស្ថិតក្នុងលេខរៀងទីមួយ ក្នុងចំណោមសមាជិកចំនួន៩១នាក់ នៅក្នុងបញ្ជី "បញ្ញវន្តដែលតំណាងក្រុមបញ្ញវន្តនៅតំបន់រំដោះ" និង

៧. សមាជិកត្រៀមគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពីខែមករាឆ្នាំ១៩៧១ (គាត់ក្លាយជាសមាជិកពេញសិទ្ធិ របស់គណៈកម្មាធិការមជ្ឈិម នៅខែឧសភា ឆ្នាំ១៩៧៦)។

១០៥៨- **ខៀវ សំផន** ក៏បានដើរតួនាទីជាអ្នកភ្ជាប់ទំនាក់ទំនងជាមួយសម្តេចនរោត្តមសីហនុ ដែលបានទទួលការតែងតាំងជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តែមានមូលដ្ឋាននៅក្រៅប្រទេស។ ចំពោះសាធារណជនវិញ **ខៀវ សំផន** ត្រូវបានគេចាត់ទុកជាមេដឹកនាំចលនាតស៊ូកុម្មុយនីស្ត ដែលបញ្ជាទៅលើទ័ពព្រៃកម្ពុជាក្នុងការប្រយុទ្ធតស៊ូផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ។

១០៥៩- រូបភាពរបស់ **ខៀវ សំផន** ចំពោះសាធារណជន នៅក្នុងអំឡុងពេលនោះលើសពីអំណាចដែលគាត់មានពិតប្រាកដ ដោយសារគាត់មិនមែនជាសមាជិកជាន់ខ្ពស់បំផុតនៅក្នុងបក្សកុម្មុយនីស្ដកម្ពុជាទេ។ ក៏ប៉ុន្តែ គាត់ជាសមាជិកក្រុមផ្ទៃក្នុងតូចមួយដែលដឹកនាំបក្ស។ ក្នុងនាមបក្សកុម្មុយនីស្ដកម្ពុជា គាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការភ្ជាប់សម្ព័ន្ធភាពក្នុងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាយ៉ាងជោគជ័យ ដោយសារគាត់ជាសមាជិកខ្មែរក្រហមដែលអាចបង្កើត និងរក្សាបានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយសម្ដេចនរោត្ដមសីហនុ។ គាត់បានធ្វើសកម្មភាពជាច្រើនដែលជួយរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាដែលជារដ្ឋាភិបាលបណ្ដោះអាសន្នមួយ និងប្រមូលផ្ដុំកងទ័ព និងកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា នៅក្នុងសង្គ្រាមប្រឆាំងនឹងកងទ័ពសាធារណរដ្ឋខ្មែរ។ សកម្មភាពរបស់គាត់ទាំងនោះរួមមានៈ ការកោះប្រជុំផ្លូវការជាមួយកម្មាភិបាល និងប្រតិភូអន្តរជាតិ ការចេញសារលិខិតផ្លូវការ និងអំពាវនាវដល់ប្រជាជន រួមទាំងព្រះសង្ឃ និងកសិករផងដែរ ឲ្យចូលរួម និងគាំទ្រដល់កងទ័ពបក្សកុម្មុយនីស្ដកម្ពុជា រៀបចំដំណើរទស្សនកិច្ចផ្លូវការនៅក្នុងប្រទេស និងក្រៅប្រទេស ប្រមូលផ្ដុំ និងរៀបចំការអប់រំនយោបាយ គ្រប់គ្រង និងផ្ដល់ការណែនាំដល់សមាជិកបក្ស លើកសរសើរដល់ជ័យជំនះក្នុងសង្គ្រាមប្រឆាំងកងទ័ពសាធារណរដ្ឋខ្មែរ និងបដិសេធមិនព្រមចូលរួមចរចាជាមួយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥ **ខៀវ សំផន** ក៏បានរស់នៅ និងធ្វើការជាមួយមេដឹកនាំបក្សកុម្មុយនីស្ដកម្ពុជាផ្សេងទៀត (ដូចជា ប៉ុល ពត **អៀង សារី នួន ជា** ហ៊ូ នឹម និង ហ៊ូ យន់) នៅទីស្នាក់ការគណបក្សក្នុងទីតាំងជាច្រើន មុនពេលពួកគេចូលក្រុងភ្នំពេញ។

១០៦០- **នៅអម្លុងខែមេសា** ឆ្នាំ១៩៧៥ មានការរាយការណ៍ថា **ខៀវ សំផន** បានទទួលការសុំចុះចាញ់ជាផ្លូវការពីកងទ័ពសាធារណរដ្ឋខ្មែរ។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងការប្រកាសតាមវិទ្យុនូវសារមួយដែលចេញក្នុងនាមរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា គាត់បានថ្លែងថា នៅពេលដែល លន់ នល់ និង "ជនក្បត់" មួយចំនួនទៀត បានគេចខ្លួន ជនក្បត់ខ្លះទៀតស្ថិតនៅក្នុងប្រទេស ហើយសម្រេចចិត្តបន្ត "សកម្មភាពក្បត់" តទៅទៀត។ គាត់បានជំរុញឲ្យប្រជាជនចុះចូលជាមួយពួកខ្មែរក្រហម ប្រាប់ឲ្យនាយទាហាន "ខាងកងទ័ពក្បត់" ទម្លាក់អាវុធ និងចូលសារភាព ដោយអះអាងថារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា "ប្រាកដជានឹងកាប់កាន់ក្រុងភ្នំពេញមិនខាន"។

## តំណែង និងអំណាចក្នុងកម្ពុជាប្រជាធិបតេយ្យ

## រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងតំណែងជាគណៈប្រធានរដ្ឋ

១០៦១- នៅពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ **ខៀវ សំផន** រក្សាតំណែងរបស់ខ្លួននៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជាដដែល។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គាត់ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវ "រណសិរ្ស និងរាជរដ្ឋាភិបាល" ហើយបន្ទាប់មកគាត់ដើរតួនាទីយ៉ាងសំខាន់ក្នុងការរុះរើរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ធ្វើជាសហប្រធានដឹកនាំសមាជជាតិលើកទីបីជាមួយ ប៉ែន នុត ដើម្បីធ្វើការអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥។ របាយការណ៍របស់គាត់ស្តីពីរដ្ឋធម្មនុញ្ញថ្មីនេះ ត្រូវបានប្រកាសផ្សាយនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។ រដ្ឋធម្មនុញ្ញបានបង្កើតឲ្យមានគណៈប្រធានរដ្ឋ ជាប្រមុខរដ្ឋ

ជំនួសព្រះមហាក្សត្រដែលផ្តល់ការទទួលខុសត្រូវដល់ស្ថាប័នថ្មីនេះ ក្នុងការតំណាងកម្ពុជាប្រជាធិបតេយ្យ "ទាំងក្នុង និងក្រៅប្រទេស"។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបានសម្រេចថា បន្ទាប់ពីការបោះឆ្នោតជាតិរួចហើយ នឹងបង្កើតជាសភាតំណាងប្រជាជន គណៈប្រធានរដ្ឋ និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែល **ខៀវ សំផន** ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ។

១០៦២- នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦ **ខៀវ សំផន** បានទទួលការលាលែងពីតំណែងរបស់ព្រះមហាក្សត្រសម្តេចនរោត្តមសីហនុក្នុងឋានៈជាប្រមុខរដ្ឋនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ នៅពេលនោះ គាត់អះអាងថាព្រះមហាក្សត្រលាលែងពីតំណែងដោយស្ម័គ្រចិត្តនៅក្នុងកំណត់ប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ដែល **ខៀវ សំផន** បានចូលរួមដែរនោះបង្ហាញថា បក្សកុម្មុយ នីស្តកម្ពុជាបានបង្ខំព្រះមហាក្សត្រឲ្យលាលែងពីតំណែង (និងថែមទាំងរៀបចំគំរោងធ្វើគតព្រះអង្គផងដែរ)ដែលជាផ្នែកមួយនៃការឈានទៅរកការក្តោបអំណាចទាំងមូលផង។ ដូចដែរបានកត់សម្គាល់នៅខាងក្រោម នៅក្នុងអំឡុងពេលនេះ **ខៀវ សំផន** ក៏មានការទទួលខុសត្រូវក្នុងការរៀបចំទំនាក់ទំនងរវាង ប.ក.ក និងគ្រួសារស្តេចផងដែរ។

១០៦៣- នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បានតែងតាំង **ខៀវ សំផន** ឲ្យទទួលខុសត្រូវរៀបចំការបោះឆ្នោតទូទាំងប្រទេសមួយតាមរបៀបបញ្ឆោត សម្រាប់ជ្រើសរើសសភាតំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសម័យប្រជុំលើកដំបូងរបស់សភានេះពីថ្ងៃទី១១ ដល់ទី១៣ ខែមេសា ឆ្នាំ១៩៧៦ **ខៀវ សំផន** ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ដោយធ្វើឲ្យ

ខ្លួនគាត់ក្លាយជាប្រមុខរដ្ឋយ៉ាងមានប្រសិទ្ធភាព។ ប្រាំខែក្រោយមក នៅពេល ប៉ុល ពត អវត្តមាន **ខៀវ សំផន** ជាអ្នកពិនិត្យលើការតែងតាំង **នួន** ជា ជានាយករដ្ឋមន្ត្រីស្តីទី។

១០៦៤- ក្នុងឋានៈជាប្រមុខរដ្ឋ កម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានទទួលខុសត្រូវផ្នែកការទូតជាច្រើនរួមមានការចូលរួមជាគណៈប្រតិភូផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់បរទេស ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិក្នុងនាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួល និងរៀបចំការពិភាក្សាជាមួយគណៈប្រតិភូបរទេស រៀបចំទទួលដំណើរទស្សនកិច្ចរបស់មេដឹកនាំបរទេស និងតំណាងជាន់ខ្ពស់បរទេសដទៃទៀត ចូលរួមលាងសាយភោជន៍ និងកិច្ចប្រជុំដែលរៀបចំដោយស្ថានទូតបរទេស ឬរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងអមដំណើរមន្ត្រីជាតិ និងអន្តរជាតិក្នុងដំណើរទស្សនកិច្ចនៅទូទាំងប្រទេស។ គាត់ក៏បានទទួលសារតាំងរបស់ឯកអគ្គរដ្ឋទូតនានាប្រចាំកម្ពុជាផងដែរនៅក្នុងពិធីដែលរៀបចំនៅវិមានរដ្ឋ (ជាធម្មតា **អៀង សារី** ក៏បានចូលរួមដែរ) ឆ្លើយតបជាមួយមេដឹកនាំបរទេសក្នុងនាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងផ្ញើសារលិខិតទៅបណ្តាមេដឹកនាំជាតិក្នុងឱកាសនានា ដូចជាទិវាអបអរបុណ្យជាតិ និងការបោះឆ្នោតជ្រើសរើសរដ្ឋាភិបាលថ្មីជាដើម។ នៅខែសីហា ឆ្នាំ១៩៧៦ គាត់តំណាងកម្ពុជាប្រជាធិបតេយ្យនៅឯសន្និសីទលើកទីបួន របស់បណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅក្រុងកូឡុំបូប្រទេសស្រីលង្កា។

## ជាសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា

១០៦៥- បន្ថែមលើមុខងារជាសមាជិកត្រៀម(ពីឆ្នាំ១៩៧១) និងជាសមាជិកពេញសិទ្ធិរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា(ពីខែមករា ឆ្នាំ១៩៧៦) ចំពោះអំឡុងពេលដែលស្ថិតក្រោម

កិច្ចស៊ើបអង្កេត **ខៀវ សំផន** ក៏ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍តាមព្រឹត្តិន័យដែរ។ ដូចដែលនឹងពិភាក្សានៅក្នុងផ្នែក **ការចូលរួមជាទូទៅនៅក្នុងផែនការឧក្រិដ្ឋកម្ម** ខាងក្រោម គាត់បានរស់នៅ និងធ្វើការប្រចាំថ្ងៃជាមួយសមាជិកថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត ដែលបង្កើតជាផ្នែកមួយនៃ"មជ្ឈិមបក្ស"បក្សកុម្មុយនីស្តកម្ពុជា។ [redacted] បានពណ៌នាថាគាត់ជាសមាជិកម្នាក់នៃគណៈអចិន្ត្រៃយ៍បក្ស "គណៈគ្រប់គ្រងរួម" គណៈមជ្ឈិមថ្នាក់លើ ឬជាមេដឹកនាំម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា "ពួកអ៊ំៗ" ដែលទាំងអស់នេះនិយាយសំដៅដល់មនុស្សមួយក្រុមតូច(ដែលរួមមាន ប៉ុល ពត **នួន ជា អៀង** សារី **ខៀវ សំផន** តាម៉ុក សោ ភឹម (រហូតដល់ថ្ងៃគាត់ស្លាប់) វន វ៉េត (រហូតដល់ថ្ងៃចាប់ខ្លួន) និង សុន សេន) ដែលតំណាងឲ្យអំណាចកំពូលដោះស្រាយរាល់បញ្ហាទាំងអស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកដែលស្ថាប័នទាំងអស់របស់បក្ស យោធា និងរដ្ឋាភិបាលត្រូវរាយការណ៍ជូន។

១០៦៦- សមាជិកភាពរបស់ **ខៀវ សំផន** នៅក្នុងគណៈអចិន្ត្រៃយ៍ ឬមជ្ឈិមបក្ស ត្រូវបានបញ្ជាក់ដោយឯកសារនានាដែលនៅសេសសល់ ស្តីពីការចូលរួមរបស់គាត់ នៅក្នុងកិច្ចប្រជុំនានារបស់គណៈអចិន្ត្រៃយ៍ នៅក្នុងចំណោមកំណត់ហេតុចំនួន១៧របស់គណៈអចិន្ត្រៃយ៍ ដែលបានកត់ត្រាពេញលេញនូវសំដីរបស់អ្នកចូលរួមទាំងអស់ បានបញ្ជាក់ថាគាត់មានវត្តមាន (ហើយជាពិសេសទៅទៀត គឺបានបញ្ជាក់ពីការចូលរួមរបស់គាត់ផង) យ៉ាងហោចណាស់ក៏ចំនួន១៤លើក រវាងខែវិច្ឆិកា ឆ្នាំ១៩៧៥ ដល់ខែមិថុនា ឆ្នាំ១៩៧៦ គិតជាភាគរយដល់ទៅ៨២**ភាគរយ**។ គាត់ជាអ្នកដែលបានចូលរួមប្រជុំទាំងនោះបានច្រើនជាងគេ បន្ទាប់ពី ប៉ុល ពត និង **នួន ជា**។

១០៦៧- កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែល **ខៀវ សំផន** បានចូលរួមពាក់ព័ន្ធនឹងប្រធានបទធំៗដូចជា៖ ការចាប់ខ្លួននៅតាមភូមិភាគ សភាពការណ៍ខ្មាំង ឬពួកក្បត់ប្រជាជនមួយចំនួនធំដែលបានទទួលរងនូវជម្ងឺទាំងនេះនៅក្នុងការដ្ឋានការងារនានា សុខាភិបាល រួមទាំងការបង្កើតនិងការរៀបចំមន្ទីរពេទ្យ និងការផលិតថ្នាំសង្កូវ ការចែកចាយស្បៀងអាហារនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ការបញ្ជូនយុវជន និងឬកុមារឲ្យទៅធ្វើការ ការពារជាតិ រួមទាំងការដឹកជញ្ជូនគ្រាប់រំសេវ និងការសាងសង់រោងចក្រផលិតអាវុធ ជម្លោះជាមួយប្រទេសវៀតណាម និងរបាយការណ៍ស្តីពីអំពើសាហាវព្រៃផ្សៃដែលប្រព្រឹត្តឡើងដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលលុកលុយចូលក្នុងប្រទេសវៀតណាម ការបោះឆ្នោត ការឃោសនា ការបង្កើតក្បាលម៉ាស៊ីនដឹកនាំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងការប្រើសភាតំណាងប្រជាជនជាការបិទបាំងពីខាងក្រៅ សេដ្ឋកិច្ច និងផលិតកម្មក្នុងស្រុកកម្ពុជាប្រជាធិបតេយ្យ រួមមាន វិស័យកសិកម្មជាដើម ការបង្កើតគណៈកម្មាធិការ ឬក្រសួងនានានៅក្រោមអំណាចរបស់មជ្ឈិមបក្ស ដំណើរទស្សនកិច្ចទៅបរទេស ដោយរដ្ឋមន្ត្រីនានារបស់កម្ពុជាប្រជាធិបតេយ្យ ពាណិជ្ជកម្មជាអន្តរជាតិ ជនភៀសខ្លួន និងជំនួយអន្តរជាតិ។

១០៦៨- **ខៀវ សំផន** បានពណ៌នាអំពីការចូលរួមជាញឹកញាប់របស់ខ្លួននៅក្នុងការងាររបស់គណៈអចិន្ត្រៃយ៍នៅក្នុងអត្ថបទសំណេររបស់ខ្លួន ឧទាហរណ៍ គាត់បានបង្ហាញថាជម្លោះជាមួយប្រទេសវៀតណាមត្រូវបានពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងគណៈអចិន្ត្រៃយ៍ អំឡុងឆ្នាំ១៩៧៦។ គាត់អះអាងថា គាត់អាចតាមដានដឹងពីការវិវត្តន៍នៃជម្លោះនេះ និងដឹងពីការលុកលុយរបស់កងទ័ពបដិវត្តកម្ពុជាទៅក្នុងប្រទេសវៀតណាម តាមរយៈរបាយការណ៍នានាដែលបានចែកចាយនៅ

ឯកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងតាមរយៈការពិភាក្សាជាមួយបណ្ដាមេបញ្ជាការកងទ័ពបដិវត្ត កម្ពុជា និងលេខាភូមិភាគ។ ចំពោះកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ ដែលពិភាក្សាអំពីការចរចាជាមួយប្រទេសវៀតណាម **ខៀវ សំផន** បានពន្យល់ពីការខកខាន របស់ខ្លួន ដោយមិនបានបញ្ចេញយោបល់ដូចជាថា៖ "ខ្ញុំដែលចូលរួមស្ដាប់នឹងគេដែរ ខ្ញុំក៏មាន ការព្រួយបារម្ភដូចគេដែរ" ... "ខ្ញុំដឹងថា ទោះបីជាខ្ញុំនិយាយ ក៏ខ្ញុំគ្មានអីបន្ថែមលើសពីនេះទៀត ទេ"។

១០៦៩- [redacted]។ ទោះបីកំណត់ប្រជុំទាំងនោះមិនបានបញ្ជាក់ពីឈ្មោះអ្នកមានមតិ ក៏ដោយ តែវាច្បាស់លាស់ណាស់ដែលថា **ខៀវ សំផន** បានមានមតិជាច្រើនលើក៖ ឧទាហរណ៍ នៅឯកិច្ចប្រជុំមួយនៅខែមីនា ឆ្នាំ១៩៧៦ គាត់បានចូលរួមពិភាក្សាទាក់ទិននឹងការលាលែង តំណែងរបស់សម្ដេចនរោត្តមសីហនុ និងរាយការណ៍ពីទិសដៅ របៀបបោះឆ្នោត និងលក្ខខណ្ឌ ជាបេក្ខជនសម្រាប់ការបោះឆ្នោតនៅឆ្នាំ១៩៧៦ (ការប្រជុំបន្ទាប់ក៏ទាក់ទិននឹងការសម្រិត សម្រាំងដែរ)។ គាត់ក៏ជាសមាជិកម្នាក់ក្នុងចំណោមសមាជិកទាំងបីរូបរបស់មជ្ឈិមបក្ស (រួម មាន ប៉ុល ពត និង **នួន ជា**) ជាអ្នកដែល **អៀង ធីរិទ្ធ** និងបុគ្គលិកជាន់ខ្ពស់របស់គាត់ បានរាយ ការណ៍អំពីបញ្ហាសុខាភិបាល និងសង្គមកិច្ច នៅឯកិច្ចប្រជុំមួយដែលរៀបចំធ្វើឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦។

១០៧០- ក្នុងឋានៈជាសមាជិកមជ្ឈិមបក្សបក្ស កុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានជួយវិស័យនានានៅក្រៅវង្វង់នៃការទទួលខុសត្រូវរបស់ខ្លួន។ ឧទាហរណ៍ យ៉ាងហោចណាស់ក៏នៅក្នុងឱកាសចំនួនពីរដងដែរ ដែលគាត់បំពេញតួនាទីគ្រប់គ្រងក្រសួងការបរទេស នៅពេល **អៀង សារី** មិននៅ។ អតីតភាពរបស់គាត់នៅក្នុងជួរមជ្ឈិមបក្ស ក៏បានឆ្លុះបញ្ចាំងបន្ថែមទៀតនៅតាមឯកសារមួយចំនួន។ បញ្ជីផ្លូវការមួយរបស់បុគ្គលិកមន្ទីរ "ក" បានចាត់តាំងអង្គរក្សការពារថ្នាក់ដឹកនាំជាន់ខ្ពស់ដែលមានលំដាប់ថ្នាក់ដូចគ្នា នឹងលំដាប់ថ្នាក់ដែលបានប្រើនៅក្នុងសេចក្តីសម្រេចចិត្តរបស់គណៈអចិន្ត្រៃយ៍ដែលបានចាត់តាំងការទទួលខុសត្រូវនានា ក្នុងចំណោមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា (ប៉ុល ពត **នួន ជា អៀង សារី** និង **ខៀវ សំផន**) ដែរ។

១០៧១- មានភស្តុតាងតិចតួចដែលប្រមូលបានក្នុងពេលស៊ើបអង្កេតរបស់តុលាការ ដែលបង្ហាញថា **ខៀវ សំផន** មិនមែនជាសមាជិកថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ ច្បាស់ណាស់ភស្តុតាងដែលបានពិភាក្សានៅផ្នែកនេះ មានទម្ងន់ជាង។

## ក្នុងឋានៈជាប្រធានមន្ទីរនយោបាយ៨៧០

១០៧២- សមាជិកភាពរបស់ **ខៀវ សំផន** និងក្នុងឋានៈខ្លួន ជាប្រធានមន្ទីរនយោបាយ៨៧០ ជាមុខងារបន្ថែម ដែលឆ្លុះបញ្ចាំងពីតួនាទីរបស់គាត់ជាមេដឹកនាំម្នាក់របស់បក្សដែលទទួលខុសត្រូវក្នុងការតាក់តែង និងអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ មន្ទីរនយោបាយ៨៧០ គឺជាផ្នែកមួយនៃទីបញ្ជាការ និងជាលេខាធិការដ្ឋានមួយរបស់គណៈអចិន្ត្រៃយ៍នៃរបបនោះ ហេតុនេះ វាជាស្ថាប័នក្នុងចំណោមស្ថាប័នសំខាន់ៗបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងប្រព័ន្ធរាយការណ៍បែបខ្សែបណ្តោយយ៉ាងតឹងរ៉ឹងរបស់បក្សកុម្មុយនីស្តកម្ពុជា មន្ទីរនយោបាយ៨៧០

ទទួលបន្ទុកតាមដានការអនុវត្តន៍សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍។ ក្នុងនាមគណៈអចិន្ត្រៃយ៍ ឬមជ្ឈិមបក្ស មន្ទីរនេះចេញសេចក្តីណែនាំ និងទទួលរបាយការណ៍ពីអង្គភាពយោធា រដ្ឋាភិបាល និងតាមតំបន់នៅទូទាំងប្រទេស។ ដូចបានពន្យល់នៅក្នុង ផែនការឧក្រិដ្ឋកម្មរួម និងការវាយប្រហារទូលំទូលាយ សេចក្តីណែនាំ និងរបាយការណ៍ទាំងនេះគ្របដណ្តប់ពេញលេញទៅលើគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ ការទទួលខុសត្រូវបន្ថែមរបស់មន្ទីរនយោបាយ៨៧០ រួមមាន៖ "ការតាមដានសមាជិកបក្សដែលជាប់សង្ស័យសម្រាប់គណៈអចិន្ត្រៃយ៍" រក្សាឯកសារផ្លូវការ ដោះស្រាយ"កិច្ចការប្រចាំថ្ងៃ" ដើរតួនាទីជាចំណុចទំនាក់ទំនងកណ្តាលរវាងមេដឹកនាំជាន់ខ្ពស់ដែលធ្វើដំណើរទៅបរទេស និងមន្ទីរនានានៅក្រុងភ្នំពេញ រៀបចំការទំនាក់ទំនងជាមួយសម្តេចនរោត្តមសីហនុ គ្រប់គ្រងទៅលើរោងចក្រអគ្គិសនី រដ្ឋាករទឹក និងឃ្លាំងរដ្ឋ និងចែកស្បៀងអាហារ និងឧបត្ថម្ភដល់អង្គភាពនានារបស់កម្ពុជាប្រជាធិបតេយ្យនៅទូទាំងប្រទេស។ ដូចបានពណ៌នានៅក្នុង ផ្នែករចនាសម្ពន្ធគ្រប់គ្រង មន្ទីរនយោបាយ៨៧០ ប្រតិបត្តិការជាមួយមន្ទីរស-៧១ ដែលគ្រប់គ្រងបណ្តាញមន្ទីរ "ក" និងផ្តល់ការគាំទ្រផ្នែកភស្តុភារដល់គណៈអចិន្ត្រៃយ៍ និងសម្របសម្រួលការចាប់ខ្លួនជាមួយ ស-២១។

១០៧៣- **ខៀវ សំផន** គឺជាសមាជិកគណៈមន្ទីរនយោបាយ៨៧០ យ៉ាងហោចណាស់ចាប់ពីខែតុលា ឆ្នាំ ១៩៧៥ និងមានសមាជិកតែម្នាក់ផ្សេងទៀតឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន ដែលជាប្រធានមុនដំបូងគេ។ ដូច **ខៀវ សំផន** ដែរ ឌឿន ជាសមាជិកគណៈមជ្ឈិម និងជាមនុស្សម្នាក់ក្នុងចំណោមមនុស្សតិចតួចដែលបានចូលរួមការប្រជុំគណៈអចិន្ត្រៃយ៍។ ស្របនឹងការរៀបចំនៅតាមអង្គភាពរដ្ឋបាលនានានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** និង ឌឿន បាន

ចែករំលែកការទទួលខុសត្រូវក្នុងការចាត់ចែងមន្ទីរនេះ ចាប់ពីពេលយ៉ាងហោចណាស់ក៏ពីខែតុលា ឆ្នាំ១៩៧៥ដែរ។ ក្នុងចំណោមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍បី ដែល **ខៀវ សំផន** មិនបានចូលរួម មានកិច្ចប្រជុំពីរដែល ខៀន បានចូលរួម។ ក៏នៅមានភស្តុតាងដែលថា **ខៀវ សំផន** បានជួបគ្នា និងបានចេញសេចក្តីណែនាំជាញឹកញាប់ទៅកាន់ ឈឹម សំអោក ហៅ ប៉ង់ ដែលជាប្រធានមន្ទីរស-៧១ រួមទាំងកម្មាភិបាលដែលធ្វើការនៅមន្ទីរ“ក” ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរស-៧១។

១០៧៤- **ខៀវ សំផន** បានក្លាយជាប្រធានមន្ទីរនយោបាយ៨៧០ អាចនឹងនៅខែមេសា ឆ្នាំ១៩៧៦ នៅពេលដែល ខៀន ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬយ៉ាងហោចណាស់ក៏ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពេលដែល ខៀន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១។ [redacted]។ ការប្រមូលក្តោបអំណាចជាប្រធានរបស់ **ខៀវ សំផន** ពី ខៀន ក៏បានឆ្លុះបញ្ចាំងផងដែរនៅក្នុងលិខិតទាក់ទងដែលទាក់ទិននឹងការចរចារពាណិជ្ជកម្មជាមួយកូរ៉េខាងជើង៖ របាយការណ៍ដែលបានដាក់ជូន ខៀន រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៦ គឺផ្ញើទៅឲ្យ **ខៀវ សំផន** ផ្តាច់មុខចាប់ពីខែតុលា ឆ្នាំ១៩៧៦។

## ផ្នែកពាណិជ្ជកម្ម

១០៧៥- ដោយរួមជាមួយកម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដទៃទៀត រួមមាន កុយ ធួន ឌឿន និង វន វ៉េត (អ្នកទាំងនេះ ត្រូវបានបោសសម្អាត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ) ផង នោះ **ខៀវ សំផន** បានគ្រប់គ្រង និងត្រួតត្រាផលិតកម្មក្នុងស្រុក និងវិស័យសេដ្ឋកិច្ចរបស់កម្ពុជាប្រជាធិបតេយ្យ រួមទាំងពាណិជ្ជកម្មក្រៅប្រទេសផង។ គាត់បានពណ៌នាពីភារកិច្ចរបស់ខ្លួននៅមន្ទីរនយោបាយ៨៧០ ដូចជា "ការកំណត់តម្លៃសម្រាប់ផលិតផលដែលបានមកពីសហករណ៍ និងអង្គភាពសេដ្ឋកិច្ចផ្សេងៗទៀត ការអនុវត្តន៍សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ទាក់ទិននឹងការចែកចាយផលិតផលដែលប្រមូលបាននៅក្រុងភ្នំពេញ ទៅកាន់បណ្តាភូមិភាគ និងតំបន់ផ្សេងៗ និងធ្វើការជាមួយផ្នែកពាណិជ្ជកម្មបរទេស ដើម្បីធានានូវការនាំចូលទំនិញជាក់លាក់មួយចំនួន"។

១០៧៦- នៅសម័យប្រជុំពេញអង្គក្នុងខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនបានតែងតាំងជារូបភាពនូវរដ្ឋាភិបាលថ្មីមួយនៃកម្ពុជាប្រជាធិបតេយ្យ រួមមាន ប៉ុល ពត ជានាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីចំនួន៣រូប និងរដ្ឋមន្ត្រីចំនួន៥រូប។ សភានេះក៏បានបង្កើតគណៈកម្មាធិការ (ជាក្រសួងតូចៗយ៉ាងមានប្រសិទ្ធិភាព) ទទួលបន្ទុកផ្នែកកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម គមនាគមន៍ ថាមពល និងចំការកៅស៊ូ ដែលដំណើរការក្រោមការគ្រប់គ្រងរបស់ វន វ៉េត ដែលជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច។ ការតែងតាំងរដ្ឋមន្ត្រីសម្រាប់ទទួលបន្ទុកគណៈកម្មាធិការ ឬក្រសួងចំនួនដប់នៅថ្នាក់នេះ ត្រូវបានផ្តល់សុពលភាពដោយគណៈអចិន្ត្រៃយ៍រវាងថ្ងៃទី១៩ ដល់ទី២១ ខែមេសា ឆ្នាំ១៩៧៦។

១០៧៧- ទោះបីសភាតំណាងប្រជាជនតែងតាំងបែបនេះក៏ពិតមែន តែវាមិនបានឆ្លុះបញ្ចាំងពីការតែងតាំងអំណាចពិតប្រាកដទេ ព្រោះថា **ខៀវ សំផន** មានការទទួលខុសត្រូវគួរឲ្យកត់សម្គាល់រួចជាស្រេចទៅហើយ ចំពោះផ្នែកផលិតកម្មក្នុងស្រុក និងពាណិជ្ជកម្ម។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ ១៩៧៥ គណៈអចិន្ត្រៃយ៍បានតែងតាំងរូបគាត់ឲ្យកាន់តំណែងផ្នែក"ពាណិជ្ជកម្ម **ដោយទទួលខុសត្រូវខាងបញ្ជី** និងតម្លៃ" កុយ ធួន ហៅ ធុច ទទួលខុសត្រូវផ្នែក"ពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ" ហើយ វន វ៉េត ទទួលខុសត្រូវផ្នែក"ឧស្សាហកម្មរទេះភ្លើង និងនេសាទ"។ បន្ទាប់ពីមានការចរចាធ្វើពាណិជ្ជកម្មជាមួយប្រទេសចិននៅខែមីនា ឆ្នាំ១៩៧៦ **ខៀវ សំផន** ត្រូវបានតែងតាំងជាសមាជិកលំដាប់ទីពីរនៅក្នុងគណៈកម្មាធិការមួយ(ដែល កុយ ធួន ជាប្រធានដែលមានតែឈ្មោះ) ទទួលភារកិច្ចពិនិត្យ និងរៀបចំមុខទំនិញដែលត្រូវទិញ និងជាប្រធានគណៈកម្មាធិការមួយដែលទទួលបន្ទុកត្រួតពិនិត្យកិច្ចការធនាគារ។

១០៧៨- នៅដើមខែមេសា ឆ្នាំ១៩៧៦ កុយ ធួន ត្រូវបានស្ថិតក្រោមការឃុំខ្លួនក្នុងផ្ទះ ដោយទុកឲ្យ **ខៀវ សំផន** វន វ៉េត និង ឌឿន កម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកទទួលបន្ទុកផលិតកម្មក្នុងស្រុក និងសេដ្ឋកិច្ច។ គណៈកម្មាធិការ ឬក្រសួងថ្នាក់ទាបជាអ្នករាយការណ៍ជូន **ខៀវ សំផន** និង វន វ៉េត។ គណៈកម្មាធិការ និងក្រសួងពាណិជ្ជកម្មស្ថិតក្រោមការដឹកនាំរបស់ឈ្មោះ វ៉ាន់ រិត។ នៅខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីពេលដក កុយ ធួន គណៈអចិន្ត្រៃយ៍បានសម្រេចថាឈ្មោះ ឌឿន ត្រូវបែងចែកការងាររបស់គាត់រវាងកិច្ចការពាណិជ្ជកម្ម និងមន្ទីរ ៨៧០ រយៈពេលចំនួន៣ខែ និងបានចាត់តាំងឈ្មោះ ជ័យ ជាលេខា ឬប្រធាននៃគណៈកម្មាធិការកសិកម្មឲ្យជួយកិច្ចការពាណិជ្ជកម្ម។ ដូចដែលបានពិភាក្សាពីខាងលើ ឈ្មោះ ឌឿន ត្រូវបានចាប់

ខ្លួននៅខែកុម្ភៈ ឆ្នាំ១៩៧៧។ ក្រោយពេលចាប់ខ្លួនឈ្មោះ ឌឿន មានតែ **ខៀវ សំផន** និង វន វ៉េត ប៉ុណ្ណោះ ដែលបន្តស្ថិតនៅកាន់កាប់សេដ្ឋកិច្ច របស់កម្ពុជាប្រជាធិបតេយ្យក្នុងនាមគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍។ ដូចដែលយើងនឹងលើកយកមករៀបរាប់ខាងក្រោម វន វ៉េត ត្រូវបានបោសសម្អាតនៅខែវិច្ឆិកា ឆ្នាំ១៩៧៨។

## ឥទ្ធិពលផ្ទាល់ខ្លួននៅក្នុងជួរថ្នាក់លើរបស់បក្សកុម្មុយនីស្តកម្ពុជា

១០៧៩- បន្ថែមពីលើការតែងតាំងជាផ្លូវការ និង*តាមព្រឹត្តិន័យ* **ខៀវ សំផន** បានទាញយកសិទ្ធិអំណាច និងឥទ្ធិពលសំខាន់ៗពីចំណងទាក់ទងរឹងមាំ និងយូរអង្វែងជាមួយបណ្តាមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាផ្សេងៗ និងពិសេសគឺ ប៉ុល ពត។ **ខៀវ សំផន** ត្រូវបានចាត់ទុកថាជា "មនុស្សសំខាន់" ដែល "ប៉ុល ពត ទុកចិត្ត" និង"បានដឹងព័ត៌មានសម្ងាត់"។ គាត់គឺជាមនុស្សតែម្នាក់គត់ក្នុងចំណោមឥស្សរជនបក្សកុម្មុយនីស្តកម្ពុជា២នាក់ ដែលបានទទួលការកោតសរសើរជាសាធារណៈពី ប៉ុល ពត។

១០៨០- ក្នុងរយៈកាលសម័យកម្ពុជាប្រជាធិបតេយ្យ ក្នុងខណៈពេលដែលសមាជិកជាន់ខ្ពស់ជាច្រើននៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម ត្រូវបានបោសសម្អាត **ខៀវ សំផន** កាន់តែក្លាយជាមនុស្សសំខាន់។ នៅក្នុងក្រុមថ្នាក់ដឹកនាំមួយដែលចេះតែសល់គ្នាតិចទៅយ៉ាងឆាប់រហ័សនោះ គាត់បានផ្សារភ្ជាប់ខ្លួនគាត់ជាមួយ ប៉ុល ពត និងបានក្លាយខ្លួនជាសម្ពន្ធមិត្តសំខាន់របស់ ប៉ុល ពត ហើយយោងតាមអ្នកជំនាញមួយរូបនិយាយថា **ខៀវ សំផន** "គឺជាមនុស្សទី២ បន្ទាប់ពី **នួន ជា**" ។ ក្នុងករណីខ្លះ **ខៀវ សំផន** បានកេងចំណេញដោយផ្ទាល់ពីការស្លាប់របស់គូប្រជែងរបស់គាត់ ក្នុងនោះមាន វន វ៉េត និង ឌឿន។ កម្មាភិបាលជាន់ខ្ពស់មួយចំនួន

ផ្សេងទៀតដែលស្និទ្ធនឹង **ខៀវ សំផន** ត្រូវបានបោសសម្អាតក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ក្នុងនោះរួមមានគូកនរបស់គាត់ឈ្មោះ ហ៊ូ យន់ និង ហ៊ូ នឹម ដែលបានប្រឆាំងទៅនឹងគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ អនុគណៈប្រធានរដ្ឋរបស់គាត់ឈ្មោះ វស់ ញឹម និង សោ ភឹម ដែលអ្នកទាំងពីរជាលេខាភូមិភាគ និងជាសមាជិកជាន់ខ្ពស់របស់បក្ស ក៏បានក្លាយខ្លួនជាជនរងគ្រោះនៃការបោសសម្អាតដែរ។ សមាជិកជាន់ខ្ពស់មួយចំនួនទៀតនៃបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានបោសសម្អាតមានដូចជា កុយ ធួន, នៃ សារ៉ាន *ហៅ* យ៉ា, លេខាភូមិភាគឦសាន។ ដូចដែលយើងនឹងលើកយកមកបង្ហាញនៅក្នុងផ្នែកការបោសសម្អាតកម្មាភិបាលខាងក្រោម **ខៀវ សំផន** ជាអ្នកគាំទ្រពេញទំហឹងនូវការបោសសម្អាតទាំងនេះ។

១០៨១- នៅឆ្នាំ១៩៧៨ [redacted] ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មជ្ឈិមបក្ស។ [redacted]។ បន្ទាប់មក មនុស្សទាំងពីរនាក់នោះត្រូវបានដោះលែង។ ឌុច បានលើកឡើងថាការចាប់ខ្លួន កង ចាប *ហៅ* សែ លេខាភូមិភាគឧត្តរ ក្នុងពេលបន្ទាប់ មួយផ្នែកគឺបណ្តាលមកពីកំហុសឆ្គងរបស់ឈ្មោះ សែ ក្នុងការបញ្ជាឲ្យចាប់ខ្លួន [redacted] របស់ **ខៀវ សំផន**។

## ការចូលរួម និងការរួមចំណែក

## ការចូលរួមជាទូទៅក្នុងផែនការឧក្រិដ្ឋកម្ម

# ការជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា

១០៨២- នៅពេញមួយរយៈកាលកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** បានរស់នៅ ធ្វើការ និងសហការជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងៗនៃបក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់ពីពេលចូលភ្នំពេញ **ខៀវ សំផន** បានរស់នៅក្នុងព្រះវិហារព្រះកែវមរកត បន្ទាប់មកនៅ ក១ អស់រយៈពី២ ទៅ៣ខែ មុនពេលបានមករស់នៅក្នុងអគ្គភាពមានលេខកូដឈ្មោះ ក-៣។ គាត់បានរស់នៅក្នុងអគ្គភាពនេះជាមួយ **នួន ជា** ដែលជាកន្លែងស្នាក់នៅ និងកន្លែងធ្វើការសំខាន់។ ប៉ុល ពត តែងបានចុះទៅអគ្គភាព ក-៣ ជាញឹកញាប់ ហើយជួនកាលបានស្នាក់នៅទីនោះទៀតផង។ យោងតាម **ខៀវ សំផន** "មេដឹកនាំភាគច្រើនបានរស់នៅក្នុង ក-៣" ហើយមន្ទីរ ក-១ និង ក-៣ គឺជា"កន្លែងរស់នៅ ឬកន្លែងធ្វើការរបស់សមាជិកគណៈអចិន្ត្រៃយ៍" ។

១០៨៣- ការប្រជុំគណៈអចិន្ត្រៃយ៍តែងបានធ្វើឡើងនៅ ក-១ ប៉ុន្តែ ជួនកាលគណៈកម្មាធិការនេះ ក៏បើកអង្គប្រជុំនៅ ក-៣ ដែរ។ កិច្ចប្រជុំខ្លះគឺជា "កិច្ចប្រជុំពិសេស" មាន ប៉ុល ពត **នួន ជា អៀង សារី** និង **ខៀវ សំផន** ដែលបានចូលប្រជុំ។ **ខៀវ សំផន** បានចូលប្រជុំនៅ ក-៣ ដែលក្នុងនោះរដ្ឋមន្ត្រីនានាដូចជា **អៀង ធីរិទ្ធ** បានរាយការណ៍ជូនគាត់ ជូន **អៀង សារី** និង **នួន ជា**។ **ខៀវ សំផន** ក៏ធ្លាប់បានធ្វើដំណើរទៅកាន់ ក-១ ដែរ ដែលទីនោះជាផ្ទះដំបូងរបស់ ប៉ុល ពត ក្នុងចំនួន២ ទៅ៣ដងក្នុងមួយសប្តាហ៍ និងបានធ្វើការនៅទីនោះជាមួយ ប៉ុល ពត និង **នួន ជា**។

១០៨៤- បន្ថែមពីលើការចូលរួមក្នុងអង្គប្រជុំខាងលើ **ខៀវ សំផន** បានសម្របសម្រួលដល់ការបំពេញមុខងាររបស់គណៈអចិន្ត្រៃយ៍ ឬមជ្ឈិមបក្សក្នុងតួនាទីរបស់គាត់នៅមន្ទីរនយោបាយ៨៧០។ គាត់ជាអ្នកត្រួតពិនិត្យការទទួល និងការបែងចែកការប្រាស្រ័យទាក់ទងគ្នារវាងមជ្ឈិមបក្ស និងអគ្គភាព

ផ្សេងៗនៅទូទាំងប្រទេស និងអាចពិនិត្យមើលការប្រាស្រ័យទាក់ទងគ្នាទាំងនោះ។ [redacted]។ **ខៀវ សំផន** ក៏ជាអ្នករៀបចំកំណត់ហេតុអង្គប្រជុំថ្នាក់ដឹកនាំ និងបានរក្សាទុកច្បាប់ចម្លងនៅ ក-៣។ [redacted]។ បន្ថែមពីលើការចូលរួមក្នុងកិច្ចការរបស់គណៈអចិន្ត្រៃយ៍ **ខៀវ សំផន** បានចូលរួមក្នុងអង្គប្រជុំគណៈមជ្ឈិម[redacted]។

## ការជួបប្រជុំ និងការត្រួតពិនិត្យកម្មាភិបាលថ្នាក់ក្រោម

១០៨៥- **ខៀវ សំផន** បានធ្វើការយ៉ាងជិតស្និទ្ធជាមួយកម្មាភិបាលថ្នាក់ក្រោម និងបានត្រួតពិនិត្យពួកគេតាមរយៈការចូលប្រជុំដែលក្នុងនោះពួកគេបានរាយការណ៍អំពីព័ត៌មានផ្សេងៗ ជូនមជ្ឈិមបក្ស។ ការជួបប្រជុំជាមួយគណៈភូមិភាគ តំបន់ និងស្រុក ត្រូវបានធ្វើឡើងនៅ ក-១ ក្នុងរយៈពេល១ខែម្តង និងបានការចូលរួមពីបណ្តាសំណាក់មេដឹកនាំជាន់ខ្ពស់ ក្នុងនោះមាន ប៉ុល ពត **នួន ជា អៀង សារី** និង **ខៀវ សំផន**។ [redacted] បានធ្វើដំណើរទៅភ្នំពេញដើម្បីជួបប្រជុំជាមួយ **ខៀវ សំផន** និងមេដឹកនាំជាន់ខ្ពស់ផ្សេងៗទៀត ដើម្បីរាយការណ៍អំពីសកម្មភាពនៅតំបន់របស់គាត់។ **ខៀវ សំផន** ក៏មានឱកាសធ្វើការជិតស្និទ្ធជាមួយកម្មាភិបាលនានាមកពីភូមិភាគ និងតំបន់ផ្សេងៗផងដែរ នៅក្នុងអង្គប្រជុំធំៗនៅភ្នំពេញ។

១០៨៦- **ខៀវ សំផន** ក៏បានថែរក្សាការប្រាស្រ័យទាក់ទងគ្នាជាមួយតំបន់តាមរយៈលិខិតឆ្លើយឆ្លងដែលគេបានផ្ញើជូនមន្ទីរ៨៧០។ ដូចដែលបានពិភាក្សា ក្នុងផ្នែករចនាសម្ព័ន្ធគ្រប់គ្រង (បណ្តាញទំនាក់ទំនង) រដ្ឋអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា បានដាក់របាយការណ៍ជាទៀងទាត់ជូនមន្ទីរនយោបាយ៨៧០ ហើយក្នុងឋានៈជាប្រធានមន្ទីរនេះ **ខៀវ សំផន** ជាអ្នកបានទទួលឯកសារទាំងអស់នេះ។ នៅឆ្នាំ១៩៧៨ គាត់បានណែនាំឲ្យ [redacted] ដែលទើបតែងតាំងថ្មី ឲ្យរាយការណ៍ផ្ទាល់ជូនគាត់ទាក់ទិននឹងការចាប់ខ្លួន និងស្ថានភាពរស់នៅក្នុងតំបន់នេះ។ ភាពញឹកញាប់នៃការរាយការណ៍ គឺពឹងផ្អែកទៅលើសភាពការណ៍សន្តិសុខ ជួនកាលគេផ្ញើទូរលេខរាល់សប្តាហ៍ ជួនកាលជាប្រចាំខែ។ **ខៀវ សំផន** ក៏ "ធ្លាប់បាន"ចុះពិនិត្យតំបន់នេះជាមួយ **នួន ជា** ចំនួនប៉ុន្មានលើកផងដែរ។ ស្រដៀងគ្នានេះ ទូរលេខត្រូវបានគេផ្ញើរវាង[redacted] និង **ខៀវ សំផន** និង **នួន ជា** នៅឯមន្ទីរក-៣។ ទូរលេខទាំងនេះពាក់ព័ន្ធនឹង "ឱវាទណែនាំ ផែនការការងារ ការផលិតស្បៀង" និងរបាយការណ៍អំពី"បញ្ហាផ្ទៃក្នុង ការចាត់ចែងកម្លាំង និងសកម្មភាព យោធា"។

១០៨៧- **ខៀវ សំផន** តែងតែបានចុះពិនិត្យជាទៀងទាត់ និងបានត្រួតពិនិត្យមន្ទីររដ្ឋ ការដ្ឋាន រោងចក្រ សហករណ៍ និងតំបន់កសិកម្ម នៅទូទាំងប្រទេស ក្នុងនោះមាន៖

១. ការកសាងប្រឡាយពីព្រៃស ទៅវត្តក្នុង

២. ការដ្ឋានអាងស្តុកទឹកកំពីងពួយ

៣. ការដ្ឋានទំនប់ត្រពាំងថ្ម នៅទីនោះគាត់បានណែនាំឲ្យពលករខំប្រឹងធ្វើការបន្ត

៤. ការដ្ឋានទំនប់ និងប្រឡាយនៅភូមិធ្លក

៥. ការដ្ឋានទំនប់១មករា នៅភូមិភាគកណ្តាល

៦. កំពង់ផែកំពង់សោម

៧. ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង

៨. ឃ្លាំងរដ្ឋ នៅទីនោះគាត់បានត្រួតពិនិត្យទំនិញសម្រាប់នាំចេញ ជួនកាល គាត់បានទៅទីនោះជាមួយ វ៉ាន់ រិត

៩. សហករណ៍នៅតាមប៉ែកផ្សេងៗនៃប្រទេស (ក្នុងនោះមាន សៀមរាប បាត់ដំបង កំពង់សោម កំពត កណ្តាល តាកែវ កំពង់ចាម និងភ្នំពេញ) ជួនកាលអមដំណើរសម្តេចនរោត្តម សីហនុ និង

១០.រោងចក្រកាត់ដេរនៅភ្នំពេញ

១០៨៨- **ខៀវ សំផន** ក៏បានចុះពិនិត្យតាមមន្ទីរ និងការដ្ឋាននានាក្រោមការគ្រប់គ្រងរបស់ក្រសួងផ្សេងៗ។ គាត់បានចុះពិនិត្យតាមមន្ទីរពេទ្យនានាក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច ក្រសួងឃោសនាការ រោងចក្រកាត់ដេររដ្ឋនៅអូរឫស្សី ក្រសួងការបរទេស និងរោងចក្រក្រោមក្រសួងឧស្សាហកម្ម។ ក្នុងអំឡុងពេលចុះពិនិត្យមន្ទីរពេទ្យ១៧មេសា ជាមួយ **អៀង សារី** ប៉ុល ពត **នួន ជា ខៀវ សំផន** បានណែនាំឲ្យបុគ្គលិកមន្ទីរពេទ្យព្យាបាលកម្មាភិបាលឲ្យបានល្អ និងមិនអនុញ្ញាតឲ្យបុគ្គលិកចូល ឬចេញពីទីកន្លែងនេះឡើយ។

## វគ្គសិក្សា និងបំពាក់បំប៉នឧបាយាយ

១០៨៩- **ខៀវ សំផន** គឺជាអ្នកមនោគមវិជ្ជានាំមុខគេមួយរូបនៃរបបកម្ពុជាកម្ពុជាប្រជាធិបតេយ្យ ដែលបានបំពាក់បំប៉ននយោបាយជាច្រើនសន្និកសន្ទាប់ដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និង

បញ្ញវន្តដែលត្រឡប់មកពីបរទេសនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ជាមធ្យោបាយមួយក្នុងការរក្សាមនោគមវិជ្ជាដាច់ខាតរបស់បក្សកុម្មុយនីស្តកម្ពុជា ការបង្រៀននយោបាយមានសារសំខាន់ចាំបាច់ដល់ការអនុវត្តន៍ប្រកបដោយជោគជ័យនៃគោលនយោបាយ ពីសំណាក់កម្មាភិបាលទូទាំងប្រទេស ដូចដែល **ខៀវ សំផន** បានបញ្ជាក់នៅក្នុងសុន្ទរកថាមួយរបស់គាត់ "ប្រសិនបើយើងបណ្តុះបណ្តាលកម្មាភិបាលរបស់យើងនៅតាមសាលារៀន ផ្តាច់ខ្លួនចេញពីចលនាបដិវត្តន៍មហាជន យើងនឹងពុំអាចបំពេញតម្រូវការចលនាបដិវត្តន៍បានឡើយ"។ **ខៀវ សំផន** បានទទួលស្គាល់ថា ការជួបប្រជុំរបស់គណៈមជ្ឈិម"ពាក់ព័ន្ធនឹងការបំពាក់បំប៉នមនោគមវិជ្ជាដែលបានរៀបចំឱ្យកម្មាភិបាលអនុវត្តសេចក្តីសម្រេចរបស់គណៈ[អចិន្ត្រៃយ៍]"។ [redacted]។

១០៩០- **ខៀវ សំផន** បានបង្រៀនវគ្គនយោបាយជាច្រើននៅតាមកន្លែងធ្វើពលកម្មដោយបង្ខំរបស់បញ្ញវន្តដែលត្រឡប់មកពីបរទេសវិញ។ បញ្ញវន្តចំនួនជាង១០០០នាក់បានវិលត្រឡប់មកកម្ពុជា ពីបរទេសនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប៉ុន្តែពួកគេស្ទើរតែទាំងអស់ត្រូវបានបញ្ជូនទៅរៀនសូត្រនយោបាយរយៈពេលពីពីរបីថ្ងៃ ទៅពីរបីខែ មុនពេលយកទៅសម្លាប់ បញ្ជូនទៅការដ្ឋានពលកម្មដោយបង្ខំ ឬត្រូវបានប្រគល់មុខដំណែងផ្សេងៗនៅក្នុងរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ។ គោលបំណងនៃដំណើរការការបំពាក់បំប៉ននយោបាយនេះ គឺដើម្បីវាយតម្លៃថាតើគេអាចអូសទាញបញ្ញវន្តឱ្យចូលរួមជាមួយបដិវត្តន៍ ឬត្រូវដក ឬកម្ទេចពួកគេ។

១០៩១- វគ្គរៀនសូត្រសម្រាប់បញ្ញវន្តត្រូវបានធ្វើឡើងនៅតាមទីតាំងមួយចំនួននៅភ្នំពេញក្នុងនោះរួមមាន ទីតាំងអតីតវិទ្យាស្ថានបច្ចេកទេសខ្មែរសូវៀត សាលាបូរីកីឡា ស្ថិតនៅចន្លោះបូរីកីឡា និងវិថីសហព័ន្ធរុស្សី ពហុកីឡាដ្ឋានអូឡាំពិក និងនៅតាមក្រសួងផ្សេងៗ ដូចជាក្រសួង កសិកម្ម និងក្រសួងការពារជាតិ។ ជាការបន្ថែមពីលើ **ខៀវ សំផន** វគ្គរៀនសូត្រមួយ មេដឹកនាំជាន់ខ្ពស់ផ្សេងៗ ទៀតផងដែររួមមាន ប៉ុល ពត **នួន ជា** និង **អៀង សារី**។

១០៩២- វគ្គបង្រៀនរបស់ **ខៀវ សំផន** បាននិយាយអំពីបញ្ហានយោបាយទូលំទូលាយដូចជា ទំនាក់ទំនងការបរទេស ប៉ុន្តែក៏បាននិយាយអំពីបញ្ហានានាដូចជាវិន័យផ្ទៃក្នុងបក្សផងដែរ។ ដោយបានចាត់ទុកបញ្ញវន្តថាជា"កាកសំណល់នៃរបបអាណានិគម" **ខៀវ សំផន** បានបង្រៀនពួកគេអំពីវិធីធ្វើបដិវត្តកុម្មុយនីស្ត រួមទាំងសារសំខាន់នៃការកំចាត់ចោលទ្រព្យសម្បត្តិកម្មសិទ្ធិឯកជន និងសតិអារម្មណ៍ឯកជន។ គេបានរាយការណ៍ថាគាត់បានបញ្ជាក់ថា "ដើម្បីកំចាត់កម្មសិទ្ធិឯកជនវិធីសាស្ត្រសមស្របគឺការជម្លៀសប្រជាជនចេញពីទីក្រុង...ប៉ុន្តែទ្រព្យសម្បត្តិឯកជន នៅតែបង្កឲ្យ មានសតិអារម្មណ៍ កាន់តែមានគ្រោះថ្នាក់ជាងនេះទៀត។ ទ្រព្យនេះគឺជាអ្វីៗដែលយើងគិតថាជារបស់ខ្លួនយើង"។ គាត់បានការពារការបំបែកបុរស ស្ត្រី និងកុមារដោយបង្ហំដែលសុទ្ធតែ "ស្ថិតក្រោមការគាំពាររបស់អង្គការ" គាត់បានគូសបញ្ជាក់ថា ចំណេះដឹង ដែល "បានមកពីការបង្រៀនរបស់ពួកអាណានិគម និងពួកចក្រពត្តិ...ត្រូវតែបំផ្លាញឲ្យអស់"។ គាត់ក៏បានក្រើនរំលឹកបញ្ញវន្តឲ្យប្រកាន់យកគំនិតទាំងនេះ ដោយព្រមាន ទុកជាមុនថា "ប្រសិនបើមហាជនដឹងនូវអ្វី ដែលយើងបាននឹងកំពុងពិភាក្សា ពួកគេអាច បាក់ទឹកចិត្ត" ។

១០៩៣- ក្នុងវគ្គរៀនសូត្រមួយដែលមានរយៈពេល៣ថ្ងៃ សម្រាប់បញ្ញវន្តដែលបានធ្វើមាតុភូមិនិវត្តន៍នៅខែធ្នូ ឆ្នាំ១៩៧៥ **ខៀវ សំផន** បាននិយាយអំពីគំរូនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងនោះមានការផ្តល់ហេតុផលដល់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការបង្ហើបអំពី "បញ្ហាស្មុគស្មាញទៅថ្ងៃមុខ" ជាមួយ "ប្រទេសជិតខាង" (ការនិយាយសំដៅទៅដល់ប្រទេសវៀតណាម)។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួមមាន រឿងរ៉ាវរៀបរាប់អំពីវគ្គរៀនសូត្រមួយដែល **ខៀវ សំផន** បានបង្រៀនបញ្ញវន្តចំនួនរាប់រយនាក់ស្តីអំពីសារសំខាន់នៃការរៀន"ធ្វើការហាលភ្លៀង និងហាលខ្យល់" និងការលះបង់គ្រួសារ និងកម្មសិទ្ធិ។ គាត់បានផ្តល់ឱវាទណែនាំដល់អ្នកដែលបានចូលរួមថា "កុំនឹកប្រពន្ធកូនរបស់មិត្ត...រៀនលះបង់ [ទ្រព្យសម្បត្តិ និងសម្ភារៈ]"។ បញ្ញវន្តភាគច្រើនត្រូវបានបញ្ជូនឲ្យទៅធ្វើពលកម្មដោយដៃ។

១០៩៤- **ខៀវ សំផន** ក៏បានបង្រៀនគោលនយោបាយទាំងនេះនៅក្នុងវគ្គរៀនសូត្រនយោបាយសម្រាប់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក្នុងនោះមានមន្ត្រីក្រសួង និងមន្ត្រីយោធា។ គាត់បានបង្រៀនយ៉ាងទូលំទូលាយអំពី"ការពង្រឹងចលនាមហាជន" ដោយនិយាយអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដូចជាការផលិតស្រូវចំនួន៣តោនក្នុងមួយហិកតា និងការការពារបូរណភាពប្រឆាំងនឹង"យួន"។ [redacted]។ គាត់ក៏បានចុះពិនិត្យមន្ទីរបឹងត្របែករៀងរាល់សប្តាហ៍ ឬកន្លះខែម្តង និងបានបង្រៀនកម្មាភិបាល [redacted] ក្នុង

វគ្គរៀនសូត្រមួយនៅឯបូរីកីឡា គាត់បានប្រកាសថា ឈឹម សំអោក *ហៅ* ប៉ង់ អតីតប្រធានមន្ទីរស-៧១ ត្រូវបានចាប់ខ្លួន យកទៅក្នុងនាមជាជនក្បត់ចូលដៃជាមួយ"យួន"។ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ពោលគឺ២ថ្ងៃ នៅមុនពេលនៃការវាយលុកពីសំណាក់វៀតណាម **ខៀវ សំផន** បានដឹកនាំវគ្គរៀនសូត្រមួយនៅបូរីកីឡា ដែលក្នុងពេលនោះគាត់បានបញ្ជាក់ឲ្យអ្នកចូលរួមចំនួនរាប់រយនាក់រត់ចូលជាមួយយួន [redacted]។

## សុន្ទរកថា

១០៩៥- ក្នុងអំឡុងពេលមានតួនាទីជាប្រធានគណៈប្រធានរដ្ឋ **ខៀវ សំផន** បានថ្លែងសុន្ទរកថាជាសាធារណៈយ៉ាងហោចណាស់ចំនួន៧លើកទាំងក្នុងកម្ពុជាប្រជាធិបតេយ្យ និងបរទេស ដោយបានលើកកម្ពស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងញុះញង់ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ ក្នុងអំឡុងរយៈកាលនៃសម័យកម្ពុជាប្រជាធិបតេយ្យ គាត់ក៏បានដើរតួនាទីជាអ្នកនាំពាក្យម្នាក់ក្នុងចំណោមអ្នកនាំពាក្យសំខាន់ៗនៃរបបនេះ ជាអ្នកសូមអភ័យទោស និងជាអ្នកបដិសេធនូវឧក្រិដ្ឋកម្មរបស់ខ្លួន។

១០៩៦- នៅក្នុងទស្សនៈយោបល់របស់គាត់ទៅលើរដ្ឋធម្មនុញ្ញថ្មី **ខៀវ សំផន** បានប្រកាសអំពីការប្ដេជ្ញាចិត្តរបស់ប្រជាជនកម្ពុជា ក្នុងការ"វាយប្រយុទ្ធ"ប្រឆាំងនឹងពួកចក្រពត្តិបរទេសដែលកំពុងធ្វើវិទ្ធង្សនា និងជ្រៀតចូលប្រទេសកម្ពុជា។ នៅខែសីហា ឆ្នាំ១៩៧៦ ក្នុងឱកាសថ្លែងនៅក្នុងសន្និសីទនៃចលនាមិនចូលបក្សសម្ព័ន្ធនៅកូឡុំបូ ប្រទេសស្រីលង្កា គាត់បានលើកឡើងថាជោគជ័យរបស់កម្ពុជាប្រជាធិបតេយ្យគឺបានមកពី"សន្តិសុខផ្ទៃក្នុងនៅទូទាំងប្រទេសរបស់យើង"

គាត់បានបញ្ជាក់អំពីសារសំខាន់នៃ"ការប្រុងប្រយ័ត្នបដិវត្តន៍"ជាប់ជាប្រចាំ ដោយសារតែ "ខ្មាំងនឹងមិនបោះបង់ចេតនាបំផ្លាញបដិវត្តន៍របស់យើងឡើយ"។ មានភស្តុតាងបញ្ជាក់ថានៅក្នុងការប្រជុំមួយនៅពហុកីឡាដ្ឋានអូឡាំពិកនៅចុងឆ្នាំ១៩៧៦ គាត់បានអានចម្លើយសារភាពរបស់ឈ្មោះនៃ សារ៉ាន់ *ហៅ* យ៉ា របស់មន្ទីរស-២១ អតីតលេខាភូមិភាគីឦសាន។ ក្នុងសន្ទរកថារំលឹកខួបនៅខែមេសា ឆ្នាំ១៩៧៧ របស់គាត់ដែលកាលនោះ កម្មាភិបាលរាប់ពាន់នាក់កំពុងត្រូវបានបោសសម្អាតនៅតាមមន្ទីរសន្តិសុខនៅទូទាំងប្រទេស **ខៀវ សំផន** បានបញ្ជាក់ថា "យើងត្រូវបោសសម្អាតខ្មាំងក្នុងឋានៈយើងជាម្ចាស់សភាពការណ៍... អ្វីៗត្រូវធ្វើដោយផ្ចិតផ្ចង់និងល្អិតល្អន់"។ គាត់បានកោតសរសើរដល់ជ័យជំនះរបស់របបនេះក្នុងការទប់ស្កាត់ខ្មាំង"មិនថាខ្មាំងខាងក្រៅ ឬខ្មាំងខាងក្នុងឡើយ" មិនឱ្យបំផ្លាញបដិវត្តន៍។ ដោយបានលើកឡើងអំពីការគំរាមកំហែងដែលកម្ពុជាប្រជាធិបតេយ្យបានប្រឈមមុខ គាត់បានទទូចសុំឱ្យអ្នកស្តាប់ថែរក្សានូវ"ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍" គ្រប់ពេលវេលាប្រឆាំងនឹង"ខ្មាំងគ្រប់ប្រភេទ ទាំងខ្មាំងក្នុងប្រទេសនិងក្រៅប្រទេស"។ ក្នុងសន្ទរកថារំលឹកខួបឆ្នាំ១៩៧៨ របស់គាត់ **ខៀវ សំផន** បានបញ្ជាក់ថា "សកម្មភាពធ្វើវិទ្ធង្សនា ចារកម្ម និងបង្កើតក្រុម និងការប៉ុនប៉ងធ្វើរដ្ឋប្រហារផ្តួលរំលំ[បក្សកុម្មុយនីស្តកម្ពុជា] និង[រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ] ត្រូវបានទទួលបរាជ័យយ៉ាងជូរចត់"។ បន្ទាប់មក គាត់បានអះអាង"តាមលក្ខខណ្ឌជាក់ស្តែង" ថា"យើងអាចបានជោគជ័យលុះត្រាយើងអនុវត្តមាគ៌ាបក្សឱ្យបានត្រឹមត្រូវ ទាំងការការពារផ្ទៃក្នុង និងខាងក្រៅ" និងបានទទូចឱ្យមហាជនរួមគ្នាខិតខំ "ដើម្បីកម្ចាត់ឱ្យអស់ជារៀងរហូតពីទឹកដីកម្ពុជា...នូវពួកវៀតណាមឈ្លានពាន"។

១០៩៧- សុន្ទរកថារបស់ **ខៀវ សំផន** ក៏បានលើកទឹកចិត្ត និងបានជម្រុញឱ្យមានការប្រើប្រាស់ការធ្វើពលកម្មដោយបង្ខំ។ នៅក្នុងការថ្លែងទៅកាន់មហាសន្និបាតលើកទី៣ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ សុន្ទរកថារលើកខួបលើកទី១ របស់គាត់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៦ និងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ គាត់បានលើកទឹកចិត្ត និងបានកោតសរសើរដល់ការប្រើប្រាស់កុមារជាកម្លាំងពលកម្ម។ ក្នុងពេលដែលប្រជាជនកម្ពុជាមួយចំនួនធំ បានស្លាប់ដោយសារការធ្វើការហួសកម្រិត ភាពអត់ឃ្លាន និងការស្ថិតក្រោមកម្ដៅថ្ងៃ ភ្លៀង ខ្យល់ និងជំងឺដង្កាត់ផ្សេងៗ (ដែលទាំងអស់នេះ គឺជាការពិតដែល **ខៀវ សំផន** បានដឹង ដូចដែលបានបញ្ជាក់ក្នុងផ្នែកពលកម្មដោយបង្ខំ) គាត់បានបញ្ជាក់ថា "[អង្ករ] ក្នុងចំនួនសមស្របគឺ៣កំប៉ុង ២កំប៉ុងកន្លះ ឬ ២កំប៉ុងតូចត្រូវបានគេចែកឱ្យប្រជាជនជារៀងរាល់ថ្ងៃ"។ គាត់ក៏បានកោតសរសើររបបនេះចំពោះការផ្គត់ផ្គង់ថ្នាំសង្កូវ និងឱសថ ដែលបានធ្វើឱ្យមានភាពល្អប្រសើរ និងសុខភាពរបស់ប្រជាជន "ដែលមានភាពល្អប្រសើរខ្លាំង"។

១០៩៨- **ខៀវ សំផន** ក៏បានកោតសរសើរដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការមិនស្តាប់ការណែនាំរបស់បរទេស ឬលោកខាងលិច ដែលផ្សំជាមួយគោលនយោបាយនៃការដាក់មនុស្សជាទាសករ និងការធ្វើពលកម្មដោយបង្ខំ និងការប្រកែកពុំព្រមផ្ដល់អាហារ និងថ្នាំសង្កូវឱ្យបានគ្រប់គ្រាន់ បណ្ដាលឱ្យមានការស្លាប់ និងទុក្ខវេទនាគ្រប់ទីកន្លែងនៅតាមការដ្ឋានទូទាំងប្រទេស។ ក្នុងសុន្ទរកថាឆ្នាំ១៩៧៦ របស់គាត់នៅ កូឡុំប្ញ គាត់បានទទួលស្គាល់ថា "សមាជិកនៃចលនារបស់យើងជួបការខ្វះខាត និងទន់ខ្សោយ" និងមានការលំបាកក្នុងការចិញ្ចឹមខ្លួនឯង "ដោយចាប់ផ្ដើមពីដៃទទេ" ប៉ុន្តែគាត់បានឯកភាពទៅនឹងការបដិសេធដាច់អហង្ការរបស់រដ្ឋាភិ

បាលកម្ពុជាប្រជាធិបតេយ្យនូវជំនួយពីខាងក្រៅ និងការសម្រេចចិត្តរបស់ខ្លួនក្នុងការ"សម្រេចវាសនាខ្លួនដោយខ្លួនឯង"។ ការបដិសេធមិនព្រមទទួលយកអ្នកជំនាញបច្ចេកទេសពីបរទេសសម្រាប់គម្រោងហេដ្ឋារចនា សម្ពន្ធ ក្នុងសន្ទរកថាឆ្នាំ១៩៧៧របស់គាត់ គាត់បានបញ្ជាក់ថា "ទោះបីទំនប់ និងអាងទឹកដែលយើងសាងសង់នៅគង់វង្សតែរយៈពេល៥ឆ្នាំ ឬ១០ឆ្នាំក្តី ក៏អត់បញ្ហា"។ នៅខែមេសា ឆ្នាំ១៩៧៨ នៅពេលដែលស្ថានភាពរស់នៅដ៏វេទនានៅទូទាំងប្រទេសរឹតតែមានសភាពយ៉ាប់យ៉ឺនថែមទៀតនោះ **ខៀវ សំផន** បានកោតសរសើរគោលនយោបាយនៃការផលិតឱសថរបស់"មហាជន"នៅតាមសហករណ៍ ដោយប្រើប្រាស់តែ"វត្ថុធាតុដើមក្នុងស្រុក" ដោយគូសបញ្ជាក់ថា "មានតែតាមរយៈមធ្យោបាយនេះទេ ទើបយើងអាចអនុវត្តគោលនយោបាយឯករាជ្យ អធិបតេយ្យភាព និងខ្លួនទីពឹងខ្លួន ក្នុងការផលិតឱសថ ដូចក្នុងវិស័យផ្សេងៗដែរ"។ នៅឆ្នាំ១៩៨០ បន្ទាប់ពីរបបនេះត្រូវបានផ្តួលរំលំ គាត់បែរជាបានអះអាងផ្ទុយពីនេះទៅវិញ។

១០៩៩- [redacted]។ ភ័ស្តុតាងក៏បានបង្ហាញថា **ខៀវ សំផន** បានជាប់ពាក់ព័ន្ធនឹងការរៀបចំសន្ទរកថានេះ ដោយក្តែងគាត់បានទៅកាន់ក្រសួងការបរទេស[redacted]។

# ការចូលរួមក្នុងហេតុការណ៍ឧក្រិដ្ឋកម្មជាក់លាក់

## ការជម្លៀសដោយបង្ខំ

១១០០- ដូចដែលបានពិភាក្សានៅក្នុងផ្នែក **នួន ជា** នៅក្នុងជំពូកស្តីពីអង្គហេតុជាក់ស្តែង នៅខែមេសា ឆ្នាំ១៩៧៥ **ខៀវ សំផន** បានចូលរួមអង្គប្រជុំគណៈកម្មាធិការសមរភូមិជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ប.ក.ក នៅមន្ទីរ ប៥ ស្ថិតនៅភូមិតាំងពោន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលនៅក្នុងអង្គប្រជុំនោះ ផែនការជម្លៀសប្រជាជនចេញពីទីក្រុងធំៗ ត្រូវបានលើកយកមកពិភាក្សា។ គាត់បានលើកពីទស្សនៈផ្ទាល់ខ្លួននានារបស់គាត់ចំពោះ ការជម្លៀសប្រជាជនដែលត្រូវបានស្នើឡើង ហើយគាត់ក៏បានយល់ព្រមជាមួយសំណើនោះផងដែរ។

១១០១- ទោះបីជា **ខៀវ សំផន** អះអាងថា មិនបានដឹងឮពីការសម្រេចឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មិនលើសពីអ្វីដែលគាត់បានឮតាមរយៈការពិភាក្សារបស់ទាហានតែម្យ៉ាងនោះក៏ដោយ [redacted]។ **ខៀវ សំផន** បានបញ្ជាក់ដោយផ្ទាល់ផងដែរថា កិច្ចពិភាក្សាពាក់ព័ន្ធនឹងការជម្លៀសប្រជាជននោះ បានធ្វើឡើងនៅទីកន្លែង ព្រមទាំងតាមពេលវេលា ដូចដែលសាក្សីបានរៀបរាប់ដូច្នោះដែរ។ គាត់ក៏បានបញ្ជាក់ប្រាប់ផងដែរថា គាត់នៅជាមួយ ប៉ុល ពត ក្នុងរយៈពេលពាក់ព័ន្ធដែលមានចំនួនដប់ថ្ងៃ នៅមន្ទីរ ប៥ ហើយប៉ុល ពត បាន និយាយប្រាប់គាត់ដោយសង្ខេបពីស្ថានភាពនៅឯសមរភូមិ។

១១០២- មានភស្តុតាងបញ្ជាក់ថា ហ៊ូ យន់ ដែលត្រូវជាសហការីជិតដិតរបស់ **ខៀវ សំផន** បានបដិសេធចំពោះការសម្រេចឲ្យជម្លៀសប្រជាជននោះ។ [redacted]។

១១០៣- **ខៀវ សំផន** បានចូលទីក្រុងភ្នំពេញ ព្រមជាមួយក្បួនឃាមហែរហមយ៉ាងសម្បើម ដោយរួមដំណើរជាមួយ ប៉ុល ពត **នួន ជា** និងមេបញ្ជាការយោធា ព្រមទាំងមេបញ្ជាការភូមិភាគជាច្រើនទៀត នៅ ឬក្នុងអំឡុងថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។ គាត់បានចុះត្រួតពិនិត្យកន្លែងត្រួតពិនិត្យភូមិភាគឧត្តរដែលស្ថិតនៅព្រែកក្ដាមជាមួយនឹង **នួន ជា** ហើយបានរាយការណ៍ថា "ការជម្លៀសបានប្រព្រឹត្តទៅដោយរលូន"។

១១០៤- នៅក្នុងកិច្ចសម្ភាសន៍ក្នុងឆ្នាំ១៩៨២ **ខៀវ សំផន** បានទទួលស្គាល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កើតឡើងដោយមានការសម្រេចជារួមមួយ ដែលគាត់បានចូលរួមនៅក្នុងការសម្រេចនោះដែរ។ សម្ដេចនរោត្តមសីហនុបាននិយាយផងដែរថា **ខៀវ សំផន** បានប្រាប់គាត់មិនឲ្យវិលត្រលប់មកទីក្រុងភ្នំពេញវិញ ក្នុងខែមេសា ឆ្នាំ១៩៧៥ ដោយសារតែខ្មែរក្រហមបានដាក់ផែនការជម្លៀសប្រជាជនចេញពីទីក្រុង ហើយនេះជាការប្រុងប្រយ័ត្នមួយដើម្បីទប់ស្កាត់ "ការរីករាលដាលជំងឺឆ្លង" ដ៏សាហាវមួយនោះ។ ដូចមានបញ្ជាក់នៅក្នុងផ្នែកស្ដីពីការបំពាក់បំប៉នននយោបាយ និងវគ្គរៀនសូត្រខាងក្រោមនេះ **ខៀវ សំផន** បានការពារការសម្រេចឲ្យជម្លៀសប្រជាជនចេញពីទីក្រុងនានា ជាច្រើនលើកច្រើនគ្រា

ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងសៀវភៅ របស់គាត់ដែលបោះពុម្ពក្នុងឆ្នាំ២០០៧ គាត់បានសម្តែងពីកាគាំទ្រចំពោះការគិតគូរពិចារណា ឲ្យមានការជម្លៀសប្រជាជនចេញដោយ គាត់បាននិយាយថា៖ "ការជម្លៀសប្រជាជនចេញពីទី ក្រុងនានា អាចនឹងជាវិធានការតែម្យ៉ាង ដែលតម្រូវឲ្យប្រើសម្រាប់ស្ថានការណ៍នាពេលនោះ ដោយមិនអាចជៀសបាន"។ គាត់បានពន្យល់ថា៖ "ជនបទ គឺជាមូលដ្ឋានសំខាន់សម្រាប់បដិវត្តន៍ ព្រោះនៅប្រទេសកម្ពុជា ក៏ដូចនៅប្រទេសមិនទាន់រីកលូតលាស់ផ្សេងទៀត បដិវត្តន៍ជាតិ គឺជាបដិវត្តន៍កសិករ" ចំណែកឯទីក្រុងជា"ក្បាលម៉ាស៊ីនសម្រាប់វណ្ណៈកាន់អំណាច និងពួកចក្រពត្តិ ជាទីកន្លែងដែល សត្រូវបដិវត្តន៍អាចប្រមូលកម្លាំងកម្ទេចយើង"។

## ពលកម្មដោយបង្ខំ

១១០៥- ដូចបានរៀបរាប់រួចមកហើយនៅក្នុងផ្នែកការជម្លៀសដោយបង្ខំ បន្ទាប់ពីបានជម្លៀសប្រជាជន ចេញពីទីក្រុង និងការបង្ខាំងប្រជាជនទាំងអស់ ឲ្យស្ថិតនៅក្នុងសហករណ៍ជនបទដោយបង្ខំនោះ បក្សបានលុបបំបាត់កម្មសិទ្ធលើទ្រព្យសម្បត្តិឯកជន លុបបំបាត់នូវសិទ្ធមនុស្ស ទាំងអស់ ព្រម ទាំងបានបង្កើតនូវកម្មវិធីដាក់ប្រជាជនជាទាសករក្នុងទ្រង់ទ្រាយធំមួយវិញ។ ជនស៊ីវិល ត្រូវគេ បង្ខំឲ្យធ្វើការដោយដៃយ៉ាងលំបាក ក្នុងស្ថានភាពអមនុស្សធម៌នៅ តាមកសិដ្ឋាន និងតាម ការដ្ឋានគម្រោងហេដ្ឋារចនាសម្ពន្ធធំៗនានា។ បក្សជាអ្នកគ្រប់គ្រងលើគ្រប់វិស័យនៃ

ការរស់នៅរបស់ប្រជាជនដែលត្រូវគេធ្វើឱ្យទៅជាទាសករ ដូច **ឡៅ សំផន** បានអះអាង នៅក្នុងឆ្នាំ១៩៧៧ ដោយបក្សធ្វើការកំណត់ស្ទួម្បីតែរបបអាហារសម្រាប់បុគ្គលម្នាក់ៗ។

១១០៦- ចំណែកមួយនៃគោលនយោបាយធ្វើឱ្យទៅជាទាសករ និងប្រើពលកម្មដោយបង្ខំទាំងនេះ ថ្នាក់ដឹកនាំរបស់ ប.ក.ក បាន៖

១) ដកហូតទិន្នផលដែលមានបរិមាណលើសចំនួនពីសហករណ៍ និងការដ្ឋាននានា បណ្តាលឱ្យមានការផ្គត់ផ្គង់មិនគ្រប់គ្រាន់

២) រារាំងប្រជាជនក្នុងស្រុកមិនឱ្យមានការបែងចែកអាហារ និងថ្នាំសង្កូវគ្រប់គ្រាន់ទៅកាន់តំបន់នានាដែលទទួលរងការខ្វះខាតធ្ងន់ធ្ងរ

៣) ហាមប្រាមមិនឱ្យជនស៊ីវិលប្រមូលយកអាហារដោយខ្លួនឯង ឬផ្តល់ម្ហូបអាហារ សម្រាប់ពួកគេ

៤) ដាក់បញ្ហា និងយល់ព្រមលើការចាប់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម និងសម្លាប់ តាមតែអំពើចិត្តទៅលើជនទាំងឡាយដែលជំទាស់ ឬមិនបានគោរពតាមវិន័យដែលបក្សបានដាក់ ចេញ។

១១០៧- គោលនយោបាយទាំងនេះ បានបង្កឱ្យមានការស្លាប់យ៉ាងច្រើន ដោយសារការអត់ឃ្លាន ជំងឺ ការរំលោភបំពានលើរាងកាយ និងការសម្លាប់ទូទាំងប្រទេស ដោយរួមទាំងទីតាំងនានា ដែលស្ថិតក្រោមការស៊ើបអង្កេតផងដែរ។ តាមរយៈការដឹកនាំ និងមើលខុសត្រូវទិន្នផលក្នុងស្រុករបស់កម្ពុជាប្រជាធិបតេយ្យ ការបែងចែកក្នុងស្រុក និងពាណិជ្ជកម្មក្រៅប្រទេស ព្រមទាំងការចូលរួមចំណែកនៅក្នុងការធ្វើសេចក្តីសម្រេចនានា ដែលបណ្តាលឱ្យកើតមាន ការរំលោភបំពាន

ដូចបានរៀបរាប់ពីខាងលើនោះ **ខៀវ សំផន** បានចូលរួមចំណែកដោយផ្ទាល់ក្នុងអំពើឧក្រិដ្ឋនានា ដែលស្ថិតក្រោមការស៊ើបអង្កេត។

១១០៨- **ខៀវ សំផន** រួមជាមួយនឹងកម្មាភិបាលជាន់ខ្ពស់ផ្សេងៗទៀត (រួមមាន វន វ៉េត កុយ ធួន និង ឌឿន រហូតដល់ពេលដែលពួកគេត្រូវគេបោសសម្អាត) បានដឹកនាំ និងត្រួតពិនិត្យពាណិជ្ជកម្ម ក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ។ គាត់បានរៀបចំការនាំចេញទិន្នផលរបស់កម្ពុជា ប្រជាធិបតេយ្យ និងការនាំចូលសម្រាប់ការផ្គត់ផ្គង់នានា ព្រមទាំងគ្រឿងបំលាស់ផ្សេងៗ ទៀត។ ការដឹកជញ្ជូនផលិតផលនាំចូលទាំងនោះ រួមមានការផ្គត់ផ្គង់ថ្នាំពេទ្យ និងគ្រឿងបរិក្ខារ ប្រេង សម្ភារៈសំណង់ និងគ្រឿងម៉ាស៊ីន ត្រូវបានផ្ញើទៅគាត់ដោយផ្ទាល់។ គាត់បាន ទទួលរបាយការណ៍លម្អិតស្តីពីការធ្វើពាណិជ្ជកម្មជាមួយនឹងប្រទេសចិន យូហ្គោស្លាវី កូរ៉េខាងជើង និងប្រទេសជប៉ុន។ ក្នុងនាមជាសមាជិកតាមព្រឹត្តិន័យ នៅក្នុងកិច្ចប្រជុំនានា របស់គណៈអចិន្ត្រៃយ៍ គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំ និងធ្វើការសម្រេច ចិត្តទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ ក្នុងឋានៈជាសមាជិកតាម ព្រឹត្តន័យ (*de facto*) ម្នាក់ នៃការប្រជុំនានារបស់គណៈអចិន្ត្រៃយ៍ គាត់បានចូលរួមនៅក្នុង ការប្រជុំ និងសេចក្តីសម្រេចនានា ពាក់ព័ន្ធនឹងការកសាងទីតាំងការដ្ឋានសាងសង់ព្រលាន យន្តហោះកំពង់ឆ្នាំង ។

១១០៩- បន្ថែមលើពាណិជ្ជកម្មអន្តរជាតិ **ខៀវ សំផន** បានរៀបចំ និងមើលខុសត្រូវការបែងចែកអាហារ គ្រឿងបរិក្ខារ និងការផ្គត់ផ្គង់នៅក្នុងប្រទេស។ គាត់បានដាក់ការណែនាំអំពី "ថាតើបរិ មាណរបស់អំបិលមានប៉ុន្មាន ស្រូវពូជប៉ុន្មាន ខោអាវចំនួនប៉ុន្មាន ស្បែកជើងប៉ុន្មាន និង

សម្ភារៈផ្សេងៗទៀត ដែលត្រូវផ្ញើទៅអង្គភាពនេះ និងអង្គភាពនោះ ដើម្បីបែងចែកទៅឱ្យប្រជាជន"។ គាត់បានទទួលសំណើពីបណ្តាតំបន់ផ្សេងៗជាទៀងទាត់ ដែលធ្វើការស្នើសុំសម្ភារៈមួយចំនួន ដូចជា ប្រេងសាំង គ្រឿងម៉ាស៊ីន ថ្នាំពេទ្យ ខោអាវ កន្ទក់ និងសម្ភារៈផ្សេងៗទៀតសម្រាប់សង់ទំនប់ទឹក និងប្រឡាយទឹក ហើយគាត់ជាអ្នកទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការផ្តល់សម្ភារៈទៅឱ្យពួកគេទាំងនោះ។ ឧទាហរណ៍ ពលករនៅក្រសួងសង្គមកិច្ចបានដាក់គម្រោងរបស់ខ្លួន ស្នើសុំឱ្យផ្តល់វត្ថុធាតុដើម ដោយផ្ទាល់ទៅគាត់ដើម្បីសុំការសម្រេច និងដើម្បីបានទទួលការណែនាំពីគាត់។ គាត់ក៏បានប្រើសិទ្ធិអំណាចរបស់ខ្លួន នៅតាមកន្លែងផលិតមួយចំនួនរបស់កម្ពុជាប្រជាធិបតេយ្យផងដែរ ដូចជា ដូចជា រោងចក្រអគ្គិសនី និងឃ្លាំងរដ្ឋនានាជាដើម។

១១១០- ដូចមានកត់សម្គាល់ក្នុងផ្នែករងនៃវគ្គសិក្សា និងការបំពាក់បំប៉នឧបាយ **ខៀវសំផន** បានគាំទ្រគោល នយោបាយឧក្រិដ្ឋកម្មរបស់ ប.ក.ក ក្នុងការបង្ខំងជនស៊ីវិលទាំងឡាយឱ្យស្ថិតក្នុងសហករណ៍ បំបែកពីក្រុមគ្រួសារ បង្ខំពួកគេទាំងនោះឱ្យធ្វើការងារដោយដៃដោយបង្ខំ និងបដិសេធរាល់សិទ្ធជាមូលដ្ឋានរបស់ជនស៊ីវិលទាំងនោះទៀតផង។ នៅក្នុងសន្ទរកថារបស់គាត់ក្នុងឱកាសរំលឹកខួបអនុស្សាវរីយ៍ក្នុងឆ្នាំ១៩៧៨ គាត់បានអួតអាងពី"អំណាចរបស់ របបមួយនេះ ដែលអាចការពារ និងកសាងប្រទេសប្រកបដោយប្រសិទ្ធភាព តាមរយៈ ការប្រើកម្លាំង"។ ក្នុងឆ្នាំ១៩៧៧ នៅក្នុងការបរិយាយពីគម្រោងធំៗនានា ដែលតម្រូវឱ្យប្រើពលកម្មដោយដៃ បង្កើតឡើងដោយ ប.ក.ក នោះ គាត់បានថ្លែងថា៖ "ទេ យើងគ្មានគ្រឿងម៉ាស៊ីនទេ។ យើងធ្វើអ្វីគ្រប់សព្វបែបយ៉ាងដោយពឹងផ្អែកទៅលើកម្លាំងរបស់ប្រជាជនយើង"។

១១១១- ក្នុងពេលជាមួយគ្នានោះដែរ *ក្នុងចំណោមនោះ* **ខៀវ សំផន** ក៏បានដឹងពីប្រសិទ្ធភាពដ៏គួរឱ្យភ័យរន្ធត់របស់គោលនយោបាយនានា ដែលគាត់បានជួយជ្រោមជ្រែងបង្កើតឡើង និងអនុវត្តតាមរយៈតួនាទីផ្សេងៗរបស់គាត់នៅក្នុងគណៈកម្មាធិការកណ្តាល និងនៅក្នុងគណៈ អចិន្ត្រៃយ៍ ក៏ដូចជានៅក្នុងរបាយការណ៍ដែលគាត់បានទទួលក្នុងឋានៈជាប្រធានមន្ទីរនយោបាយ៨៧០ផងដែរ។ ឧទាហរណ៍ គាត់មានវត្តមាននៅក្នុងគណៈ អចិន្ត្រៃយ៍កាលពីថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលនៅពេលនោះ គេបានពិភាក្សាពី"បញ្ហាពាក់ព័ន្ធនឹងប្រជាជនដែលធ្លាក់ខ្លួនឈឺជាច្រើននាក់នៅក្នុងការដ្ឋាន ដោយបណ្តាលឱ្យមានការខាតបង់កម្លាំងពលកម្មអស់ចំនួន ៤០ភាគរយ"។ របាយការណ៍មួយរបស់ក្រសួងពាណិជ្ជកម្មធ្វើនៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ផ្ញើជូន **ខៀវ សំផន** បានបញ្ជាក់ថា ក្រសួងមិនអាចទទួលការបញ្ជាទិញល្ងរបស់ប្រទេសកូរ៉េខាងជើងបានទៀតទេ ដោយសារតែការផ្គត់ផ្គង់ល្ងនៅក្នុងប្រទេសកម្ពុជាជួបប្រទះការខ្វះខាត។ វ៉ាន់ រិត ក្នុងឋានៈជាលេខាក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ បានជូនដំណឹងទៅ **ខៀវ សំផន** ថា "យ៉ាងតិច មានតំបន់២៥មួយ ដែលគ្មានអ្វីសម្រាប់ហូប" ហើយគាត់បានសួរថា មូលហេតុអ្វីបានជាប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យធ្វើការដោះដូរទិន្នផលរបស់ខ្លួនជាមួយនឹងអង្ករដែលមាននៅក្នុងបណ្តាខេត្តឯទៀត ឬហេតុអ្វីប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យហូបចេក និងត្រីនោះ។ វ៉ាន់ រិត បានបញ្ជាក់ប្រាប់ទៅ **ខៀវ សំផន** ពី "ការលំបាកវេទនារបស់ប្រជាជន ដែលគេព្យាយាមលាក់បាំងការពិតនេះ ត្រូវបានលាតត្រដាងនៅពេលដែលវិទ្យុធ្វើការផ្សព្វផ្សាយពីភាពមហាលោតផ្លោះមហាអស្ចារ្យនោះ"។ បន្ថែមលើនេះទៀត របាយការណ៍នានាដែលមានរៀបរាប់លម្អិតពីកង្វះអាហារនៅតាមតំបន់ និងភូមិភាគផ្សេងៗនោះ ត្រូវបានផ្ញើទៅកាន់មន្ទីរ៨៧០។

១១១២- ទោះបីជារបាយការណ៍ទាំងនេះមានរៀបរាប់លម្អិតពីអ្វីដែលកំពុងកើតមានក៏ដោយ ក៏ **ខៀវ សំផន** នៅតែបន្តអនុវត្តផែនការឧក្រិដ្ឋរបស់ ប.ក.ក ដដែល តាមរយៈសុន្ទរកថានានារបស់ខ្លួន ដើម្បីរាយការណ៍ថាការប្រមូលផលមានទិន្នផលខ្ពស់ មានម្ហូបអាហារគ្រប់គ្រាន់ទូទាំងប្រទេស ព្រមទាំងរាយការណ៍ពីការនាំចេញនូវទិន្នផលដែលនៅសល់ លើសពីតម្រូវការផងដែរ។ [redacted]។

[redacted] ដូចបានលើកយកមកពិភាក្សារួចមកហើយនៅក្នុងផ្នែកនៃវគ្គសិក្សា និងការបំពាក់បំប៉នឧយោបាយ**ខៀវ សំផន** ក៏បានចូលរួមចំណែក ក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះផងដែរ តាមរយៈការបំពាក់បំប៉នគោល នយោបាយដល់បញ្ញវន្តដែលវិលត្រឡប់ពីបរទេសដែលពួកគេទាំងនោះ ត្រូវបាន ប.ក.ក ឃុំឃាំងខ្លួនយ៉ាងតឹងរឹង នៅក្នុង ជំរំធ្វើពលកម្មដោយបង្ខំនានា។ [redacted]

[redacted]។

## ការបោសសម្អាតកម្មាភិបាល

១១១៤- **ខៀវ សំផន** បានទាំងឯកភាព និងបានចូលរួមក្នុងការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការបោសសម្អាតមនុស្សដែលគេចាត់ទុកថាជាខ្មាំង។ [redacted]។

*ការជាប់ពាក់ព័ន្ធនឹងការបោសសម្អាតជាទូទៅ និងកម្រិតខ្ពស់តាមរយៈមន្ទីរ៨៧០*

១១១៥- **ខៀវ សំផន** បានទទួលស្គាល់ថាគណៈអចិន្ត្រៃយ៍ គឺជាអ្នកធ្វើរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ស្តីពីបញ្ហាសំខាន់ៗដូចជាការចាប់ខ្លួន និងការប្រហារជីវិតមនុស្សដែលគេជឿថាជាខ្មាំង បើទោះបីជាយ៉ាងដូច្នេះក្តី គាត់បដិសេធថាគាត់ពុំដែលបានចូលរួមក្នុងអង្គប្រជុំដែលគណៈ

អចិន្ត្រៃយ៍ដែលបានពិភាក្សាអំពីការចាប់ខ្លួនឡើយ។ យោងតាមសម្តីគាត់ មានន័យថា គាត់ពុំអាចដឹងអំពីការចាប់ខ្លួនទេ។ ដូចដែលបានបញ្ជាក់ក្នុងផ្នែក សមាជិកភាពរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា កំណត់ហេតុអង្គប្រជុំដែលនៅសល់បង្ហាញថា **ខៀវ សំផន** ពិតជាបានចូលរួមក្នុងអង្គប្រជុំមួយចំនួនដែលក្នុងនោះគេបានពិភាក្សាអំពីការបោសសម្អាត។

១១១៦- **ខៀវ សំផន** បានជាប់ពាក់ព័ន្ធក្នុងការបោសសម្អាតខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាទាំងមុនពេល និងក្រោយពេលការឡើងកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងឋានៈគាត់ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធ **ខៀវ សំផន** បានធ្វើជាគណៈអធិបតីនៃសមាជជាតិលើកទី២ របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឬរណសិរ្សរួបរួមជាតិកម្ពុជា នៅថ្ងៃទី២៤ និង២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ដែលបានអនុម័តសេចក្តីសម្រេចមួយ ដើម្បីប្រហារជីវិត"ជនក្បត់ទាំង៧" (គឺ លន់ នល់ សិរីមតៈ សឺន ង៉ុកថាញ់ ចេង ហេង អ៊ិន តាំ ឡុង បូរ៉េត និង សុសស្តែន ហ្វែណង់ដេស) នៅពេលផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ។ ដូចដែលបានពិពណ៌នានៅក្នុងផ្នែក ការជម្លៀស ដោយបង្ខំ (ដំណាក់ការទី១៖ ពីទីក្រុងភ្នំពេញ) ក្នុងចំណោមមនុស្សទាំង៧នាក់នោះ មានតែ ឡុង បូរ៉េត និង សិរីមតៈ ប៉ុណ្ណោះដែលបានស្ថិតនៅកម្ពុជា ក្នុងពេលដែលកងកម្លាំងខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ សិរីមតៈបានទៅជ្រកកោននៅស្ថានទូតបារាំង ក៏ប៉ុន្តែត្រូវបានគេបដិសេធ សិទ្ធិជ្រកកោន ហើយត្រូវបានប្រគល់ឲ្យទៅ បកក នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥។ ឡុង បូរ៉េត បានប្រគល់ខ្លួនឲ្យកងកម្លាំងខ្មែរក្រហមនៅឯក្រសួងព័ត៌មាន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយបន្ទាប់មកត្រូវបានប្រហារជីវិតភ្លាមៗ។ ក្នុងអំឡុង

ទស្សនកិច្ចជាផ្លូវការ មួយទៅកាន់ទីក្រុងបាងកកនៅខែវិច្ឆិកា ឆ្នាំ១៩៧៥ **អៀង សារី** បានបញ្ជាក់អះអាងថា អ្នកទាំង ពីរនាក់នេះត្រូវបានគេសម្លាប់ហើយ។

១១១៧- នៅដំណាក់កាលដំបូងនៃការគ្រប់គ្រងអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា **ខៀវ សំផន** បានចូលរួម ក្នុងការចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការចាប់ខ្លួនសមាជិករបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា។ ជាក់ស្តែង ក្រោយពីបានទទួលភារកិច្ចឱ្យទទួលខុសត្រូវរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គាត់បានចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដែលក្នុងអង្គប្រជុំនោះគេបានពិភាក្សាអំពីការមិនទុកចិត្តព្រះអង្គម្ចាស់នរោត្តមភូរីស្សរា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវបានគេលើកយកមកពិភាក្សា។ បន្ទាប់មក ព្រះអង្គម្ចាស់អង្គនេះ ត្រូវបានបញ្ជូនទៅធ្វើពលកម្មដោយបង្ខំនៅព្រះវិហារ និងប្រហារជីវិតក្នុងគ្រាក្រោយមកទៀត។ នៅខែកញ្ញា ឆ្នាំ១៩៧៦ **ខៀវ សំផន** បានអួតអាងអំពីការសម្លាប់សមាជិកនៃរបបមុន ដោយបានប្រកាសក្នុងកិច្ចសម្ភាសន៍មួយថា “ជនក្បត់នៅកម្ពុជាត្រូវបានសម្លាប់ហើយ” ។

១១១៨- នៅពេញមួយរយៈកាលនៃរបបដែលស្ថិតក្រោមកិច្ចស៊ើបសួរនេះ រដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ បានដាក់របាយការណ៍ជាទៀងទាត់អំពីការចាប់ខ្លួនជូនមន្ទីរ ៨៧០ សម្រាប់គណៈអចិន្ត្រៃយ៍ធ្វើការពិចារណា។ ក្នុងករណីខ្លះ ចម្លើយសារភាពរបស់ខ្មាំងដែលគេបានចាប់ខ្លួន ត្រូវបានបញ្ជូនឱ្យសមាជិកគណៈអចិន្ត្រៃយ៍ត្រួតពិនិត្យ។ [redacted]។

១១១៩- **ខៀវ សំផន** បានចូលរួមក្នុងការស៊ើបអង្កេតកម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ដែលបាននាំមកនូវការចាប់ខ្លួន និងការបោសសម្អាតអង្គភាពរបស់ពួកគេ។ គាត់បានស៊ើបអង្កេតអំពីជម្លោះរវាងលេខាភូមិភាគបស្ចិមឈ្មោះ ជូ ជេត *ហៅ* ស៊ី និងអនុរបស់គាត់ឈ្មោះ ហេង ប៉ាល់។ ឈ្មោះ ជូ ជេត ត្រូវបានបោសសម្អាតបន្ទាប់ពី **ខៀវ សំផន** បានរាយការណ៍ជូន ប៉ុល ពត។ **ខៀវ សំផន** បានទទួលស្គាល់អំពីការចុះពិនិត្យភូមិភាគបស្ចិម ប៉ុន្តែគាត់បដិសេធថាការចុះពិនិត្យនោះ គឺពុំមែនដើម្បីស៊ើបអង្កេតអំពីជម្លោះនោះឡើយ។ មានភ័ស្តុតាងបញ្ជាក់ថា **ខៀវ សំផន** បានចូលរួមក្នុងអង្គប្រជុំគណៈអចិន្ត្រៃយ៍ដែលក្នុងអង្គប្រជុំនោះ គេបានសម្រេចចាប់ខ្លួន ជូ ជេត។ [redacted]។ ខៀវ សំផន ក៏បានចូលរួមក្នុងកិច្ចប្រជុំសម្ងាត់មួយ ដែលកិច្ចប្រជុំនោះមជ្ឈិមបក្សពិភាក្សាអំពីការបោសសម្អាតកម្មាភិបាល ប.ក.ក រាប់ពាន់នាក់ នៅភូមិភាគបូព៌ា។ ចុងក្រោយនេះ មានភ័ស្តុតាងបញ្ជាក់ថា គាត់បានចូលរួមក្នុងអង្គប្រជុំមួយដែលគេបានពិភាក្សាអំពីការចាប់ខ្លួន វន វេត។

១១២០- អគ្គលេខានៃអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានសរសេរលិខិតជូន **ខៀវ សំផន** នៅខែកុម្ភៈ ឆ្នាំ១៩៧៧ បន្ទាប់ពីបានសរសេរលិខិតមួយជូនគាត់កាលពីខែឧសភា ឆ្នាំ១៩៧៦។ គាត់បានចង្អុលបង្ហាញអំពីការចោទប្រកាន់អំពីអំពើយង់ឃ្នងទ្រង់ទ្រាយធំដែលកម្ពុជាប្រជាធិបតេយ្យកំពុងបានប្រព្រឹត្ត ក្នុងនោះមានការប្រហារជីវិតក្រៅប្រព័ន្ធច្បាប់ទៅលើមនុស្សដែលចាត់ទុកថាជា "ខ្មាំង" និងបានសម្តែងកង្វល់អំពីការខ្វះការឆ្លើយតបពី **ខៀវ**

**សំផន** និងបានស្នើសុំការអនុញ្ញាតឲ្យគណៈប្រតិភូលើកលែងទោសអន្តរជាតិ អាចធ្វើទស្សនកិច្ច នៅ កម្ពុជា។ **ខៀវ សំផន** ពុំដែលបានឆ្លើយតបទៅនឹងសំណើទាំងនោះឡើយ។ អាកប្បកិរិយារបស់គាត់កាលពីពេលនោះ ត្រូវបានបង្ហាញតាមរយៈហេតុការណ៍ដូចខាងក្រោម ៖ នៅខែកញ្ញា ឆ្នាំ១៩៧៦ ក្នុងពេលចូលរួមសន្និសីទនៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅ កូឡុំបូ ប្រទេសស្រីលង្កា **ខៀវ សំផន** ត្រូវបានអ្នកសារព័ត៌មានធ្វើការសាកសួរពាក់ព័ន្ធទៅនឹងភ័ស្តុតាង ដែលបញ្ជាក់អំពីការស្លាប់របស់មនុស្សរាប់រយពាន់នាក់នៅកម្ពុជា។ គាត់បានបញ្ជាក់អះអាងអំពី ការប្រហារជីវិត"ជនក្បត់" និងបានបញ្ជាក់បន្ថែមថា "វាជារឿងមិនគួរឲ្យជឿដែលប្រទេស លោកខាងលិច ដូចជាអស់លោក លោកស្រី មានការបារម្ភអំពីឧក្រិដ្ឋជនសង្គ្រាម"។

*មន្ទីរនានាក្រោមការគ្រប់គ្រងរបស់ ខៀវ សំផន*

១១២១- **ខៀវ សំផន** ក៏មានសិទ្ធិអំណាចមួយចំនួនទៅលើការបោសសម្អាតនៅជុំវិញមជ្ឈិមបក្ស ដែលជាផ្នែកមួយនៃសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ស្តីពី"សិទ្ធិកម្ទេចក្នុងជួរ និងក្រៅជួរ"។ មន្ទីរនយោបាយ៨៧០ ត្រូវបានគេផ្តល់សិទ្ធិឲ្យកម្ទេចមនុស្សនៅក្នុងតំបន់ "ជុំវិញ មន្ទីរមជ្ឈិម"។ ចំណុចនេះហើយដែលបានផ្តល់ឲ្យមន្ទីរ៨៧០នូវសិទ្ធិអំណាចផ្តួចផ្តើម និងត្រួត ពិនិត្យការបោសសម្អាតអង្គភាពជាច្រើននៅក្នុង និងជុំវិញទីក្រុងភ្នំពេញ។ ឥស្សរជនជាន់ ខ្ពស់ដែលត្រូវបានចាប់ខ្លួនយកមកពីតាមបណ្តាមន្ទីរនានានៅជុំវិញមជ្ឈិមបក្ស រួមមានឈ្មោះ ភោគ ឆាយ (កម្មាភិបាលមន្ទីរ៨៧០ និងជាអ្នកកត់ត្រាឲ្យគណៈអចិន្ត្រៃយ៍ ដែលត្រូវបានចាប់ខ្លួន នៅខែមីនា ឆ្នាំ១៩៧៧) ម៉ៅ ខេមនឿន ហៅ ភុំ (អនុប្រធានមន្ទីរស-៧១ ដែលត្រូវបានចាប់ខ្លួន នៅខែមេសា ឆ្នាំ១៩៧៧) និងឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ (ប្រធានមន្ទីរ ស-៧១ ដែលត្រូវ

បានចាប់ខ្លួននៅខែឧសភា ឆ្នាំ១៩៧៨)។ កម្មាភិបាលជាន់ខ្ពស់ផ្សេងៗជាច្រើននាក់ទៀតនៃមន្ទីរ ក ក៏មានវាសនាដូចគ្នានេះដែរ។

១១២២- អនុលោមតាមសេចក្តីសម្រេចខាងលើ គេបានស្នើសុំការអនុញ្ញាតពី **ខៀវ សំផន** ដើម្បីចាប់ខ្លួនកម្មាភិបាលក្រោមសិទ្ធិអំណាចរបស់គាត់។ [redacted]។

១១២៣- ដូចដែលបានបញ្ជាក់ក្នុងផ្នែកពាណិជ្ជកម្ម ការបោសសម្អាតធំៗត្រូវបានអនុវត្តនៅក្នុងក្រសួងពាណិជ្ជកម្មដែលបានប្រតិបត្តិការក្រោមការណែនាំ និងគ្រប់គ្រងរបស់ **ខៀវ សំផន**។ វ៉ាន់ រិត រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអនុវត្តការចាប់ខ្លួនជាច្រើន ដោយយ៉ាងហោចណាស់ បុគ្គលិកចំនួន៤៨៧នាក់ ត្រូវបានចាប់ខ្លួន ឃុំឃាំង និងសម្លាប់នៅមន្ទីរស-២១ ក្នុងអំឡុងរយៈកាលពីខែសីហា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ ការចាប់ខ្លួនត្រូវបានធ្វើឡើងសំដៅលើទាំងកម្មាភិបាលថ្នាក់លើ និងថ្នាក់ក្រោមក្នុងអង្គភាពក្រសួងពាណិជ្ជកម្ម។ កម្មាភិបាលជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្មដែលត្រូវបានចាប់ខ្លួន រួមមានអនុលេខាឈ្មោះ តាន់ ទ្រី *ហៅ* ឈឿន បន្ទាប់ មកអនុលេខាឈ្មោះ ង៉ែត យូ *ហៅ* ហុង អតីតអនុប្រធានគណៈពាណិជ្ជកម្មរដ្ឋឈ្មោះ ទិត សុន *ហៅ* ញ៉ែម និងកម្មាភិបាលជាន់ខ្ពស់ឈ្មោះ សូ ជា *ហៅ* សូ *ហៅ* សូ ជួន។

បុគ្គលិកជាច្រើននាក់ទៀតដែលមកពីក្រសួងពាណិជ្ជកម្មត្រូវបានបញ្ជូនទៅលត់ដំ និងទៅកាន់ការដ្ឋានធ្វើពលកម្មដោយបង្ខំ មានដូចជា ការដ្ឋានពេជ្រនិលតាមបណ្ដោយផ្លូវជាតិលេខ៤ ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងស្រែអំបិល ដែលនៅទីនោះបុគ្គលិកមួយចំនួនត្រូវបានប្រហារជីវិត ហើយផ្សេងទៀតបានស្លាប់។

១១២៤- របាយការណ៍ដែលធ្វើរយៈពេល១០ថ្ងៃម្ដង របស់"គណៈពាណិជ្ជកម្ម" ផ្ញើជូនក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ រៀបរាប់អំពី"សភាពការណ៍ខ្មាំង" និងបញ្ជាក់ថា"យើងបានដកក្រុមមិនល្អមួយចំនួនចេញពីក្រសួង"។ របាយការណ៍នេះរៀបរាប់លម្អិតអំពីសេចក្ដីសម្រេចរបស់គណៈពាណិជ្ជកម្មក្នុងការឃុំឃាំង និងសួរចម្លើយពលករ និងបញ្ជូនពួកគេទៅកាន់"មន្ទីរលត់ដំ" និង"មន្ទីរសន្តិសុខ"។ របាយការណ៍នេះក៏មានឈ្មោះខ្មាំងជាប់សង្ស័យដែលត្រូវពិនិត្យតាមដាន។ ឯកសារនេះបញ្ជាក់ថាបញ្ហាទាំងអស់នេះកំពុងត្រូវបានរាយការណ៍ឲ្យអង្គការបានដឹង។ កំណត់ត្រានៃសេចក្ដីសម្រេចមួយរបស់"គណៈក្រសួងពាណិជ្ជកម្ម" ដែលត្រូវបានធ្វើកាលពី២ថ្ងៃមុននោះ មានបញ្ជីឈ្មោះពលករចំនួន៦នាក់ ដែលមកពីផ្នែកនានាតាមបណ្ដាក្រសួងដែលត្រូវបានចាប់ខ្លួន បញ្ជូនទៅកាន់ "មន្ទីរសន្តិសុខដើម្បីសួរចម្លើយ" ។

*ការគាំទ្រគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការបោសសម្អាតខ្មាំងរបស់ខ្លួន*

១១២៥- នៅដើមឆ្នាំ១៩៨០ ខៀវ សំផន បានបង្ហាញការគាំទ្រពេញទំហឹងរបស់គាត់ចំពោះសេចក្ដីសម្រេចនានា ក្នុងការបោសសម្អាតសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ដោយគាត់បានគូសបញ្ជាក់ថា សមាជិកទាំងអស់នេះត្រូវបានស៊ើបអង្កេតតាមដានយ៉ាងពេញលេញ។ គាត់បានគូសបញ្ជាក់ថា ភ្នាក់ងារវៀតណាមបានទទួលតួនាទីសំខាន់ៗក្នុងជួរបក្ស (ដោយចង់សំដៅ

ទៅដល់លេខាភូមិភាគ និងសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមដែលបានវាយប្រហារបក្ស "ពីខាងក្នុង") ប៉ុន្តែគាត់ បានលើកឡើងថា "មកដល់ឆ្នាំ១៩៧៧ដល់ ១៩៧៨ ទើបយើងអាចចាត់ការមនុស្សទាំងនោះបានទាំងស្រុង និងបាននាំយកសណ្តាប់ធ្នាប់មកឱ្យប្រទេសវិញ"។ ចំពោះបញ្ហានេះ គាត់បានគូសបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំ២០០៤ ថា"នៅពេលដែលសមាជិកមួយរូបនៃគណៈមជ្ឈិម និងក្រោយមកជាសមាជិកនៃគណៈអចិន្ត្រៃយ៍ត្រូវបានចាប់ខ្លួន ទំនុកចិត្តរបស់ថ្នាក់ដឹកនាំគណៈកម្មាធិការនេះ ចំពោះ ប៉ុល ពត ពុំមានការកែប្រែឡើយ។ គណៈកម្មាធិការនេះបានចាត់ទុកការបាត់ខ្លួនរបស់មនុស្សម្នាក់ៗថាជាករណីដោយឡែកពីគ្នា និងមានបញ្ជាក់ហេតុផលត្រឹមត្រូវតាមទស្សនៈរបស់មនុស្សក្នុងជួរបក្ស"។ [redacted]"។

១១២៦- **ខៀវ សំផន** បានរៀបរាប់លម្អិតអំពីការដឹងឮរបស់គាត់អំពីការវិវត្តន៍នាគ្រាដំបូងនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់ខ្មាំងមនោគមវិជ្ជារបស់ខ្លួន រាប់ទាំងការប្តេជ្ញាចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ថា"ប្រជាជនកម្ពុជាត្រូវកម្ទេច "របបសក្តិភូមិ" ទោះបីតាមសន្តិវិធី ឬតាមវិធីអ្វីក៏ដោយ" ។ សៀវភៅរបស់គាត់ដែលបានបោះពុម្ពកាលពីឆ្នាំ២០០៧ បញ្ជាក់បន្ថែមអំពីការដឹងឮល្អិតល្អន់របស់គាត់អំពីហេតុផលរបស់មជ្ឈិមបក្ស ដែលជម្រុញការបោសសម្អាតឱ្យកាន់តែខ្លាំងឡើង។ សៀវភៅនេះក៏បានបង្ហាញការការពារនូវអ្វីដែល **ខៀវ សំផន** ចាត់ទុកថាជាសេចក្តីសម្រេចរបស់ ប៉ុល ពត ពាក់ព័ន្ធនឹងការបោសសម្អាត៖

“ភស្តុតាងដែល Philip Short បានផ្តល់ឱ្យ រួមនឹងភស្តុតាងដែលអ្នកស្រាវជ្រាវផ្សេងទៀត បានរកឃើញ បញ្ជាក់ច្បាស់ថា **ការតាមដានទាំងអស់ របស់ ប៉ុល ពត** តាមគោលការណ៍ ៣-៧-៨ របស់គាត់ ទៅលើឈ្មោះចក្រី, ឈូក, យ៉ា, និងកម្មាភិបាលផ្សេងៗ ដែលបាន សហការជាមួយវៀតមិញ **គឺពិតជាត្រឹមត្រូវ**” ។ (បន្ថែមការបញ្ជាក់សេចក្តី)

## ឧក្រិដ្ឋកម្មទៅលើប្រជាជនវៀតណាម

១១២៧- **ខៀវ សំផន** ក៏បានចូលរួមចំណែកនៅក្នុងអំពើឧក្រិដ្ឋនានាទៅលើប្រជាជនវៀតណាម នៅក្នុងប្រទេសផងដែរ។ នៅក្នុងសុន្ទរកថានានារបស់គាត់ **ខៀវ សំផន** បានព្យាយាមញុះញង់ម្តងហើយម្តងទៀត ឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋយ៉ាងទូលំទូលាយ ទៅលើប្រជាជនវៀតណាម ទាំងនៅក្នុងប្រទេសកម្ពុជា និងក្នុងពេលដែលមានជម្លោះប្រដាប់អាវុធ។ **ខៀវ សំផន** បានលើកឡើងពីប្រជាជនវៀតណាមជាដដែលៗ នៅក្នុងសុន្ទរកថារបស់ខ្លួន ថាជា “ខ្មាំង” “ឧក្រិដ្ឋជនអាក្រក់បំផុតដែលមិនធ្លាប់មាន” “ជាពួកស្រែកឃ្លានលេបយកទឹកដីកម្ពុជា” “ជាពួកចក្រពត្តិនិយម វាតទីនិយមលេបទឹកដី” “គ្មានធម៌មេត្តា ខ្មាំងអន្តរជាតិព្រៃផ្សៃ” ដែលប្រើ “ការឈ្លានពានប្រល័យពូជសាសន៍កម្ពុជា” និង“ស្មៀតគ្រប់បែបយ៉ាង...ក្នុងការលបលួច បោកបញ្ឆោត ធ្វើវិទ្ធង្សនា... រដ្ឋប្រហារ ជ្រៀតជ្រែក និងឈ្លានពានទាំងស្រុងមកលើប្រជាជាតិ និងប្រជាជនកម្ពុជា”។ ក្នុងឆ្នាំ១៩៧៨ គាត់បានអំពាវនាវឱ្យមាន “កំហឹងជាតិ និងកំហឹងវណ្ណៈ” ប្រឆាំងប្រជាជនវៀតណាម និងបានលើកសរសើរកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យដែលបាន “កម្ទេចពួកឈ្លានពានវៀតណាម” ព្រមទាំង“ធ្វើឱ្យខ្ចាត់ខ្ចាយសកម្មភាពនានារបស់...ពួកឈ្លានពានវៀតណាម ដោយជោគជ័យ”។

១១២៨- នៅក្នុងខែមករា ឆ្នាំ១៩៧៨ និងក្នុងខែមករា ឆ្នាំ១៩៧៩ នៅពេលដែល **ខៀវ សំផន** កាន់តួនាទីជាប្រធានមន្ទីរនយោបាយ៨៧០ សារាចរណែនាំនានាត្រូវបានផ្ញើចេញ អំពាវនាវឲ្យមានការប្រព្រឹត្តិអំពើឧក្រិដ្ឋដ៏ទូលំទូលាយទៅលើប្រជាជនវៀតណាម។ មន្ទីរនេះក៏បានចេញបញ្ជាផ្សេងៗទៀត ទៅកាន់ថ្នាក់ដឹកនាំភូមិភាគ និងយោធាតំបន់នានា ដោយណែនាំឲ្យថ្នាក់ដឹកនាំទាំងនោះ ឲ្យបញ្ជូនពួកវៀតណាម និងអ្នកមានសមានចិត្តចំពោះវៀតណាមទាំងនោះ ទៅមន្ទីរសន្តិសុខនានា។ សាក្សីមួយរូបបានឃើញទូរលេខមួយដែលមានចំណងជើងថា "សេចក្តីណែនាំពី៨៧០" នៅឯមន្ទីរស្រុកមួយបានរំឮកថាទូរលេខមានបញ្ជាទៅកាន់ស្រុកនោះថាប្រជាជនវៀតណាម និងអ្នកដែលនិយាយភាសាវៀតណាម ឬប្រជាជនខ្មែរដែលរាប់អានជាមួយប្រជាជនវៀតណាមទាំងអស់ នឹងត្រូវសម្លាប់ចោល។ ដូចបានលើកយកមកពិភាក្សានៅក្នុងផ្នែកជម្លោះប្រដាប់អាវុធ ស្ថិតក្នុងអំឡុងរយៈពេលនៃការស៊ើបអង្កេត មន្ទីរ៨៧០ និងតាមរយៈមន្ទីរផ្ទាល់ **ខៀវ សំផន** ត្រូវបានគេជូនដំណឹងជាបន្តបន្ទាប់ ពីការកើនឡើងនូវជម្លោះព្រំដែនជាមួយប្រទេសវៀតណាម ក៏ដូចជា ការចាប់ខ្លួន និងការសម្លាប់ប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា។

## ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

១១២៩- ការរៀបរាប់ដែលបានធ្វើកន្លងមកបង្ហាញពីរបត់ស៊ីសង្វាក់មួយនៃការប្រព្រឹត្តសកម្មភាពនានារបស់ **ខៀវ សំផន** បន្ទាប់ពីការដកហូត ប.ក.ក ចេញពីអំណាច បានពង្រឹងនូវភស្តុតាងនៃការចូលរួមប្រព្រឹត្តអំពើឧក្រិដ្ឋ ព្រមទាំងចេតនារបស់គាត់ក្នុងអំឡុងរយៈពេលដែលស្ថិតក្រោមការស៊ើប។ រយៈពេលប្រមាណ២០ឆ្នាំ ក្រោយពីរូបគាត់ និងសមាជិកឯទៀតនៃ សហកម្មឧក្រិដ្ឋរួម

ត្រូវបានគេបណ្តេញចេញ គាត់នៅបន្តតស៊ូដើម្បីឱ្យមានការវិលត្រឡប់មកវិញ នៃការកាន់អំណាចរបស់ ប.ក.ក ហើយគាត់បានបដិសេធភ័ស្តុតាងនៃអំពើឧក្រិដ្ឋនានារបស់ ប.ក.ក។ គួរឱ្យកត់សម្គាល់ផងដែរនោះ សូម្បីតែនៅក្នុងសៀវភៅដែលជាស្នាដៃរបស់គាត់នាពេលថ្មីៗនេះ គាត់នៅតែព្យាយាមបន្តនៅខាង ប.ក.ក ដោយបានគាំទ្រការដោះសារនានាចំពោះអំពើព្រៃផ្សៃទាំងឡាយដែលបានប្រព្រឹត្តឡើងយ៉ាងទូលំទូលាយរបស់ខ្លួន។

**សកម្មភាពនានា និងតួនាទី**

១១៣០- នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ក្នុងពេលដែលកងទ័ពវៀតណាមបានធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងភ្នំពេញនោះ **ខៀវ សំផន** បានរត់ចេញពីទីក្រុង តាមរយៈរថយន្តផ្លូវការរបស់រដ្ឋមួយ។ ក្រោយមក គាត់បានជួបនឹង ប៉ុល ពត **នួន ជា** នៅទីរួមខេត្តពោធិ៍សាត់។ បន្ទាប់ពីនោះមក គាត់បានធ្វើដំណើរទៅខេត្តបាត់ដំបង និងខេត្តប៉ៃលិន។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ ទោះបីអៀង សារី បានភៀសខ្លួនចេញពីប្រទេសកម្ពុជា ប៉ុន្តែ ខៀវ សំផន ត្រូវបានគេរាយការណ៍ថាបានស្នាក់នៅក្នុងប្រទេសកម្ពុជា ជាមួយ ប៉ុល ពត។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ អ្នកទាំងពីរ នេះបានបានដឹកនាំការប្រយុទ្ធនានាទៅលើកងទ័ពវៀតណាមទៀតផង។ ការប្រយុទ្ធបានបន្តរហូតដល់ខែមីនា ហើយនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៩ **ខៀវ សំផន** បានធ្វើការស្បថសច្ចាជាសាធារណៈថានឹងបន្តសង្គ្រាមល្បែបប្រឆាំងនឹងរដ្ឋបាលថ្មីទីក្រុងភ្នំពេញ ដែលមានការគាំទ្រពីសំណាក់វៀតណាម។

១១៣១- ក្នុងខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៩ **ខៀវ សំផន** បានចូលរួមបានចូលរួមជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ ប.ក.ក ផ្សេងទៀតនៅក្នុងអង្គប្រជុំគណៈកម្មាធិការមជ្ឈិមកម្ពុជាប្រជាធិបតេយ្យលើកដំបូង

ជាមួយនឹងពួកមេដឹកនាំជាន់ខ្ពស់ បកក ដទៃទៀត បន្ទាប់ពីបែកភ្នំពេញ ដែលនៅក្នុងអង្គប្រជុំនោះ គាត់ត្រូវបានគេបញ្ជាក់តួនាទីជាគណៈប្រធានរដ្ឋ។ ក្នុងរយៈពេលប្រាំមួយឆ្នាំក្រោយមក **ខៀវ សំផន** រួមជា មួយនឹងមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ផ្សេងៗទៀត បានបន្តគាំទ្រកងកម្លាំងយោធាខ្មែរក្រហម ក្នុងការបន្តការតស៊ូដើម្បីអំណាច តាមរយៈការប្រើយុទ្ធសាស្ត្រនានា ប្រឆាំងនឹងវៀតណាម តាមរយៈការចុះត្រួតពិនិត្យ និងចែកចាយសម្ភារៈផ្គត់ផ្គង់ដល់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងតាមរយៈការបង្កើតសម្ព័ន្ធមិត្តនានាជាមួយក្រុមទ័ពព្រៃនានា។ ក្នុងឆ្នាំ១៩៨៥ **ខៀវ សំផន** បានលើកឡើងថា ការតស៊ូអាចផ្តល់កម្លាំងគ្រប់គ្រាន់ល្មមនៅភូមិភាគកណ្តាលប្រទេសកម្ពុជា ដើម្បី“កាត់ផ្តាច់បំពង់ករបស់ខ្មាំង”។ នាចុងឆ្នាំ១៩៨៧ **ខៀវ សំផន** ក៏ត្រូវបានគេតែងតាំងផ្លូវការជាសមាជិកគណៈអចិន្ត្រៃយ៍ ប.ក.ក ផងដែរ។

១១៣២- **ខៀវ សំផន** ត្រូវបានបានចូលរួមក្នុងសម្ពន្ធភាពនយោបាយជាមួយ ប៉ុល ពត យ៉ាងយូរណាស់ក៏នៅខែមីនា ឆ្នាំ១៩៩៨ដែរ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ គាត់បានចូលរួម និងធ្វើបាឋកថាក្នុងវគ្គសិក្សានយោបាយនានាជាច្រើន ដែលប្រមូលផ្តុំដោយ ប៉ុល ពត នៅមន្ទីរ៨៧ មានទីតាំងស្ថិតនៅទីក្រុងត្រាត ជាប់ព្រំដែនប្រទេសថៃ។

១១៣៣- ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ **ខៀវ សំផន** បានចូលរួមជាអធិបតីក្នុងសមាជមួយរបស់សមាជិកខ្មែរក្រហម និងក្រុមប្រជាជនកម្ពុជាផ្សេងទៀត ដែលមាននិន្នាការប្រឆាំងនឹងពួកវៀតណាម ដែលនៅក្នុងសមាជនោះ គាត់ត្រូវបានគេជ្រើសតាំងជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនិងជាប្រធានបណ្តោះអាសន្ននៃរណសិរ្សស្នេហាជាតិ និងប្រជាធិបតេយ្យ

ដើម្បីមហាបង្រួបបង្រួមជាតិ(the Patriotic and Democratic Front of Great National Union of Kampuchea (PDFGNUK))។ សមាជដែលបានធ្វើឡើងនៅក្នុងខែធ្នូនោះក៏បានតែងតាំង **នួន ជា** ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន **អៀង សារី** ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុក កិច្ចការបរទេស និង **អៀង ធីរិទ្ធ** ជារដ្ឋមន្ត្រីសង្គមកិច្ច។

១១៣៤- នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៨១ ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ និងជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងជាប្រធានបណ្ដោះអាសន្ននៃPDFGNUK **ខៀវ សំផន** ជាមួយនិង **នួន ជា** បានចាប់ផ្ដើមស្វះស្វែងឱ្យមានកិច្ចចរចារវេទិកានយោបាយសាមញ្ញមួយជាមួយនឹងរណសិរ្សរំដោះពលរដ្ឋខ្មែរ (KPNLF) ដឹកនាំដោយ សឺន សាន និងពួករាជានិយមដែលដឹកនាំដោយសម្ដេចនរោត្តមសីហនុ។ នៅខែកុម្ភៈ ក្នុងឆ្នាំ១៩៨២ ក្រុមទាំងនោះបានឈានដល់កិច្ចព្រមព្រៀងជាបឋមមួយ ក្នុងការបង្កើតរដ្ឋាភិបាលចម្រុះមួយរវាងសម្ដេចនរោត្តមសីហនុ **ខៀវ សំផន** ដែលមាន សឺន សាន ជានាយករដ្ឋមន្ត្រី។ នៅពេលនោះ **ខៀវ សំផន** តំណាងឱ្យកម្លាំងខ្មែរក្រហមដែលមានចំនួនលើសពី៣០.០០០នាក់ ជាចំនួនដែលច្រើនជាងគេក្នុងចំណោមក្រុមតស៊ូទាំងបីភាគីនោះ។ គាត់ក៏មានវត្តមាននៅពេលឈានដល់កិច្ចព្រមព្រៀងពេញលេញ ក្នុងការបង្រួបបង្រួមអំណាចយោធានៅឯកិច្ចប្រជុំកំពូលនៅប្រទេសថៃ នាចុងខែមករា ឆ្នាំ១៩៨៥។

១១៣៥- **ខៀវ សំផន** ក៏បានធ្វើសកម្មភាពការទូតជាច្រើនទៀតផងដែរ ក្នុងគោលបំណងឱ្យខ្មែរក្រហមវិលមកកាន់អំណាចវិញ ក្នុងរយៈកាលក្រោយឆ្នាំ១៩៧៩។ ចាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៨៦

គាត់បានចូលរួមក្នុងបេសកកម្មការទូតនានា ព្រមទាំងបានជួបជាមួយអ្នកតំណាង និង មេដឹកនាំថ្នាក់ជាតិនានា រួមមានប្រទេសថៃ សិង្ហបុរី ចិន ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិត កូរ៉េ យូហ្គោស្លាវី អេហ្ស៊ីប កេនយ៉ា វ៉ាន់ដា ប៊ូរុនឌី បួគីណាហ្វាសូ ហ្គាណា ហ្គីណេ និង លីបេរីយ៉ា។ គាត់ជាមេដឹកនាំខ្មែរក្រហម តំណាងឲ្យប្រទេសកម្ពុជា នៅកិច្ចប្រជុំសន្និសីទ នានារបស់អង្គការសហប្រជាជាតិដែលធ្វើនៅទីក្រុងញូវយ៉កក្នុងឆ្នាំ១៩៨២ និងក្នុងឆ្នាំ១៩៨៤។ គាត់ក៏ជាអ្នកតំណាងឲ្យខ្មែរក្រហមផងដែរ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានមួយ ស្តីពីជម្លោះកម្ពុជា និងវៀតណាម ដែលបានប្រព្រឹត្តទៅនៅក្នុងឆ្នាំ ១៩៨៥។

១១៣៦- នៅថ្ងៃទី១៧ ខែមីនាឆ្នាំ១៩៨៦ ក្រោយពីមានយុទ្ធនាការយោធា ដើម្បីដណ្តើមយកអំណាចមិន ជោគជ័យមួយនោះ រដ្ឋាភិបាលចម្រុះបានអំពាវនាវឲ្យមានការរួមសហការក្នុងភាពជាដៃគូ ពី សំណាក់រដ្ឋាភិបាលកម្ពុជាដែលគាំទ្រដោយវៀតណាម ហើយនឹងការដកកងទ័ពវៀតណាម ជា បន្តបន្ទាប់ក្រោមបទឈប់បាញ់មួយ ដែលមានអង្គការសហប្រជាជាតិជាអ្នកមើលការខុសត្រូវ។ ប៉ុន្តែ ផែនការសន្តិភាពមិនបានលេចចេញជារូបរាងពេញលេញនោះទេ ហើយនៅដើម ទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារខ្មែរក្រហមបានបែកបាក់ទៅជាក្រុមតូចៗនោះ **ខៀវ សំផន** ក៏បាន លាក់ខ្លួននៅក្នុងខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ។ គាត់បានបន្តស្ថិតនៅក្នុងតំបន់នោះរហូត ដល់ឆ្នាំ១៩៩៧ នៅពេលដែល **នួន ជា** និង ប៉ុល ពត ត្រូវគេចាប់ខ្លួន ពីសំណាក់បក្ស ប្រឆាំងនឹងពួកគេ។ នៅពេលនោះ គាត់បានផ្លាស់ទៅអន្លង់វែង ព្រមទាំងចាប់យកតួនាទីជាអ្នក នាំពាក្យសម្រាប់ទ័ពព្រៃខ្មែរក្រហមប្រចាំនៅតំបន់នោះវិញ។

១១៣៧- នៅពេលដែលកងកម្លាំងរាជរដ្ឋាភិបាល វាយយកអន្លង់វែងបាននៅខែមីនា ឆ្នាំ១៩៩៨ **ខៀវ សំផន** បានរត់ទៅប្រទេសថៃ។ នៅក្នុងខែដដែលនេះ រដ្ឋាភិបាលចម្រុះបានលើកឡើងជាសាធារណៈពីផែនការមួយដែលបានរៀបចំឡើងដើម្បីចាប់ខ្លួន **ខៀវ សំផន** ប៉ុល ពត **នួន ជា** និង តា ម៉ុក ព្រមទាំងបញ្ជូនបុគ្គលទាំងនោះ ទៅកាត់សេចក្ដីនៅចំពោះមុខសាលាក្ដីអន្តរជាតិសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមផងដែរ។ ចុងបញ្ចប់ **ខៀវ សំផន** បានចុះចូលជាមួយនឹងរាជរដ្ឋាភិបាលព្រមគ្នាជាមួយនឹង **នួន ជា** ក្នុងខែធ្នូ ឆ្នាំ១៩៩៨។

### ការដឹងឮ និងការបដិសេធអំពើឧក្រិដ្ឋ

១១៣៨- ជាច្រើនលើកច្រើនគ្រា **ខៀវ សំផន** បានបដិសេធអំពើឧក្រិដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានទទួលស្គាល់អំពើឧក្រិដ្ឋទាំងនោះដោយស្ទាក់ស្ទើរក្នុងគោលបំណងធ្វើឲ្យការចូលរួមចំណែក និងការទទួលខុសត្រូវរបស់គាត់ ត្រូវបានកាត់បន្ថយ ហើយចុងក្រោយបំផុតគាត់បានព្យាយាមកែប្រែអំពើឧក្រិដ្ឋទាំងនោះ តាមរយៈការលើកឡើងពីការគម្រាមកំហែងរបស់វៀតណាមដែលកម្ពុជាប្រជាធិបតេយ្យបានប្រឈម។

១១៣៩- នៅក្នុងរយៈកាលប៉ុន្មានឆ្នាំ ក្រោយពី ប.ក.ក ត្រូវបានគេផ្ដួលរំលំ **ខៀវ សំផន** បានធ្វើការបដិសេធយ៉ាងដាច់អហង្ការចំពោះវិសាលភាពព្រៃផ្សៃរបស់ ប.ក.ក នោះ តាមរយៈការចោទប្រកាន់ពួកវៀតណាមដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ព្រមទាំងការវាយប្រហាររដ្ឋាភិបាលទីក្រុងភ្នំពេញដែលដឹកនាំដោយ "ហេង សំរិន" ជាអាយ៉ងពួកវៀតណាមជាដើម។ ក្នុងឆ្នាំ១៩៨៥ គាត់បានស្វះស្វែងការពារគោលនយោបាយនានារបស់ ប.ក.ក ដោយគាត់បាននិយាយថាៈ"យើងចង់លុបបំបាត់ភាពក្រីក្រ។ ជាអកុសល វៀតណាមបានរារាំងយើង

មិនឱ្យបន្តគោលនយោបាយរបស់យើង"។ នៅខែមេសា ឆ្នាំ១៩៨៦ គាត់ទទួលសារភាពថា ខ្មែរក្រហម"បានប្រព្រឹត្តកំហុសមួយចំនួន"។

១១៨០- ក្នុងខែកក្កដា ឆ្នាំ១៩៨៧ ក្នុងការប៉ុនប៉ងឱ្យមានការលើកលែងទោសដល់ខ្លួនគាត់ និងសមាជិកជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ពីការទទួលខុសត្រូវចំពោះ"ការសម្លាប់ក្នុងទ្រង់ទ្រាយធំ"នោះ តាមរយៈ អនុប្រធាននៃកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកការងារបរទេស **ខៀវ សំផន** បានដាក់ចេញនូវឯកសារមួយ ដោយព្រមសុខចិត្តទទួលថា ប.ក.ក បានសម្លាប់ប្រជាជនចំនួន១១០០០នាក់ដែលស្ថិតក្នុងការចោទប្រកាន់ថាជាភ្នាក់ងាររបស់ពួកវៀតណាម។ គាត់បានលើកឡើងថា មានតែមនុស្សចំនួន៨.០០០នាក់ជាខ្មាំង រីឯប្រជាជនដែលនៅសេសសល់ចំនួន៣០០០នាក់ទៀត"បានស្លាប់ដោយសារការភ័ន្តច្រឡំរបស់យើង" ហើយត្រូវបានគេសម្លាប់ដោយពួកគេទាំងនោះគ្រាន់តែ"បានប្រព្រឹត្តកំហុសតូចតាច ឬជាជនស៊ីវិលដែលមិនបានប្រព្រឹត្តកំហុសអ្វីទាំងអស់"។ ហេតុផលដែលបានលើកឡើងនេះ គឺផ្ទុយយ៉ាងដាក់ស្តែងទៅនឹងឋានៈរបស់ **ខៀវ សំផន** ដែលមានពីខាងដើម បញ្ជាក់យ៉ាងច្បាស់នៅក្នុងកិច្ចសម្ភាសន៍ក្នុងឆ្នាំ១៩៨០ ក្នុងអំឡុងពេលដែលគាត់បានអះអាងថា គ្មានជនស៊ីវិលដែលមិនបានប្រព្រឹត្តកំហុស ត្រូវបានគេសម្លាប់នោះទេ ហើយជនទាំងឡាយដែលត្រូវគេសម្លាប់នោះ គឺជា"ភ្នាក់ងាររបស់យួន"។

១១៨១- ឯកសារឆ្នាំ១៩៨៧ ក៏បានកត់សម្គាល់ផងដែរថា មានប្រជាជនក្នុងចំនួនលើសពី២០.០០០នាក់បានស្លាប់ដោយសារតែការអត់ឃ្លាន និងជំងឺ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ "ដែលក្នុងចំណោមនោះ ប្រជាជនភាគច្រើនត្រូវគេជម្លៀសចេញពីទីក្រុង ដោយប្រជាជនទាំងនោះ មិនទម្លាប់ទៅនឹងកិច្ចការលំបាកនានានៅតាមជនបទ"។ ប៉ុន្តែ ឯកសារនោះ បានលើកឡើងពី

បញ្ហាខ្វះ ម្ហូបអាហារ ដោយសារតែ“ភ្នាក់ងារពួកវៀតណាមបានបង្កប់ខ្លួននៅក្នុង ស្ថាប័នរដ្ឋរបស់យើង ព្រមទាំងបានប្រព្រឹត្តនូវសកម្មភាពវិទ្ធង្សនានានាផងដែរ”។ នេះគឺ ជាការបកស្រាយមួយទៀតដែលផ្ទុយទៅនឹងកិច្ចសម្ភាសន៍របស់គាត់ក្នុងឆ្នាំ១៩៨០ នៅពេលដែលគាត់បានលើកឡើងថា “ចាប់ពីចន្លោះឆ្នាំ១៩៧៥ដល់១៩៧៨ គ្មានការកើតមាននូវករណីដែលប្រជាជនស្លាប់ដោយសារការអត់ឃ្លាននោះទេ”។

១១៤២- បន្ទាប់ពីការចុះចូលរបស់គាត់ឲ្យរាជរដ្ឋាភិបាលនៅភ្នំពេញ ក្នុងខែធ្នូ ឆ្នាំ១៩៩៨ **ខៀវ សំផន** បានប្រកាសថាគាត់មាន “ ការសោកស្ដាយយ៉ាងខ្លាំង” ចំពោះឧក្រិដ្ឋកម្មនានាដែល បកកបានប្រព្រឹត្ត តែក្នុងពេលនោះ គាត់បានបដិសេធមិនយល់ព្រមធ្វើការទទួលខុសត្រូវជាបុគ្គលផ្ទាល់ខ្លួនគាត់នោះទេ។ នៅក្នុងរយៈកាលនេះ គាត់ក៏បានស្វះស្វែងរកការធានាផ្ទាល់មាត់ថាគាត់នឹងមិនត្រូវគេយកទៅវិនិច្ឆ័យចំពោះ អំពើឧក្រិដ្ឋនានាដែលបានកើតមាននោះទេ ព្រមទាំងបានបដិសេធជាសាធារណៈចំពោះទស្សនៈគាំទ្រឲ្យមានសវនាការចំពោះមេដឹកនាំខ្មែរក្រហមទៀតផង៖ នៅសន្និសីទសាព័ត៌មានមួយដែលបានប្រព្រឹត្តទៅក្រោយការប្រគល់ខ្លួនរបស់គាត់ ដោយគាត់បានលើកឡើងថា៖“អ្វីដែលកើតឡើងហួសទៅហើយឲ្យវាហួសទៅចុះ ធ្វើដូច្នេះទើបជាដំណោះស្រាយដ៏ប្រសើរបំផុតសម្រាប់ប្រទេសរបស់យើង”។

១១៤៣- នៅក្នុងលិខិតមួយច្បាប់ផ្ញើទៅប្រជាជនកម្ពុជា ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ **ខៀវ សំផន** បានលើកឡើងថា “គាត់មិនដែលត្រូវបានគេផ្ដល់ពត៌មានអំពីការសម្លាប់មនុស្សយ៉ាងរង្គាលនោះទេ” នៅអំឡុងក្នុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថាគាត់ទើបតែបានដឹងអំពីឧក្រិដ្ឋកម្មទាំងនេះបន្ទាប់ពីរបបត្រូវបានដួលរលំតែប៉ុណ្ណោះ”។ ចម្លើយនេះ គឺជាចម្លើយ

ដ៏សោះកក្រោះដែលផ្ទុយគ្នានឹងភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់អំពី ការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មនានាក៏ដូចជាទាំងការបដិសេធដ៏រឹងត្អឹងរបស់គាត់ជាសាធារណៈចំពោះឧក្រដ្ឋកម្មនានាជាច្រើនឆ្នាំបន្ទាប់ពីព្រឹត្តិការណ៍ទាំងនេះ ដូចដែលបានលើកយកមកពិភាក្សាខាងលើស្រាប់។

១១៨៤- [redacted]។

១១៨៥- **ខៀវ សំផន** អះអាងថា គាត់មិនធ្លាប់ទទួលបន្ទុកមន្ទីរនយោបាយ៨៧០នោះទេ ហើយគាត់មិនបានដឹងថានរណាដែលត្រូវមកជំនួស ឌឿន ដែរ។ គាត់នៅបានបន្តបដិសេធមិនបានដឹងពីហេតុការណ៍ដែលបានកើតឡើងទៅលើ ឌឿន នោះទេ ហើយគាត់មិនបានដឹង សូម្បីតែឈ្មោះពិតរបស់ ឌឿន រហូតដល់ក្រោយឆ្នាំ១៩៧៩ ទើបបានដឹង។ នៅក្នុងមន្ទីរ៨៧០ គាត់ក៏ត្រូវគេចោទប្រកាន់ថា គាត់ជាអ្នកទទួលខុសត្រូវតែម្នាក់គត់លើបញ្ហាសេដ្ឋកិច្ច ដូចជា ការនាំចូល ការកំណត់តម្លៃ និងការបែងចែកទំនិញ បន្ថែមលើការទទួលខុសត្រូវរបស់គាត់ដែលត្រូវរក្សាទំនាក់ទំនងជាមួយនឹងសម្តេចនរោត្តមសីហនុ។ ផ្ទុយទៅវិញ ភស្តុតាងដែល លើកយកមកពិភាក្សាក្នុងផ្នែកការចូលរួម និងការរួមចំណែក បង្ហាញថា គាត់បានចូលរួមនៅក្នុងការរៀបចំ និងអនុវត្តរាល់គោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក ទាំងអស់។

១១៤៦- **ខៀវ សំផន** បដិសេធថាមិនបានស្គាល់ **ឌុច** នោះទេ នៅក្នុងរយៈពេលដែលស្ថិតក្រោមការស៊ើបអង្កេត ឬមិនបានដឹងសូម្បីតែអត្ថិភាពនៃមន្ទីរស-២១។ [redacted]។ បន្ថែមលើនេះទៀត មានភស្តុតាងដែលបញ្ជាក់ថា នៅក្នុង ឆ្នាំ១៩៧៦ **ខៀវ សំផន** បានចូលរួមពិធីរៀបការមួយ ដែលស្ថិតនៅក្នុងបរិវេណមន្ទីរស-២១ ដោយពិធីនោះជាពិធីរៀបការរបស់ នុន ហ៊ុយ *ហៅ* ហ៊ុយ ស្រែ (ប្រធានមន្ទីរស-២៤) និង ឃឹម វ៉ាត *ហៅ* ហ៊ោ (អនុប្រធានរបស់ ឌុច)។

១១៤៧- គួរឱ្យកត់សម្គាល់នោះ នៅចុងឆ្នាំ២០០៤ និងចុងឆ្នាំ២០០៧ **ខៀវ សំផន** បានស្វះស្វែងការពារគោលនយោបាយរបស់ ប.ក.ក។ ឧទាហរណ៍ នៅក្នុងសៀវភៅរបស់គាត់ដែលបោះពុម្ពក្នុងឆ្នាំ២០០៤ គាត់បានលើកឡើងថា ទោះបីជា“ពេលនេះ របបខ្មែរក្រហមត្រូវជាប់ពាក់ព័ន្ធតែជាមួយនឹងរូបភាពព្រៃផ្សៃក៏ដោយ... រូបខ្ញុំ ព្រមទាំងអ្នកផ្សេងទៀតបានចាត់ទុកថា វាគឺជាមធ្យោបាយដ៏ល្អប្រសើរបំផុតក្នុងការស្វែងរកដំណោះស្រាយសម្រាប់ប្រទេសជាតិ”។ *នៅក្នុងចំណោម* ការបង្ហាញទានាក្នុងសៀវភៅដែលបោះពុម្ពក្នុងឆ្នាំ២០០៤របស់គាត់នោះ គាត់បាន

ព្យាយាមសម្រាលអំពើឧក្រិដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការដាក់អំពើឧក្រិដ្ឋទាំងនោះទៅក្នុងបរិបទទូលាយមួយរបស់វៀតណាម ដែលមានគំនិតក្បត់ក្នុងការកាន់កាប់ប្រទេសកម្ពុជា។ ដែលសំខាន់នោះ សូម្បីតែស្ថិតក្នុងខណៈនោះក៏ដោយ គាត់“នៅតែគាំទ្រយ៉ាងជ្រាលជ្រៅចំពោះការដឹកនាំជីវិតរបស់គាត់” ពោលគឺគំនិតដែលថានៅពេលដែលការគោរពចំពោះសិទ្ធិមនុស្ស និងការការពារអធិបតេយ្យភាពជាតិ“មានការប្រទាំងប្រទើសគ្នា”នោះ ការការពារអធិបតេយ្យជាតិ “តែងតែត្រឹមត្រូវតាមច្បាប់ និងមានភាពចាំបាច់ជានិច្ច”។

១១៤៨- នៅក្នុងសៀវភៅស្នាដៃរបស់គាត់បោះពុម្ពក្នុងឆ្នាំ២០០៧ គាត់បានលើកឡើងថា ការតស៊ូដើម្បីឯករាជ្យពីវៀតណាម“ទាមទារការទ្រាំទ្រការលំបាកវេទនាយ៉ាងខ្លាំង និងការឈឺចាប់ និងការធ្វើពលិកម្មលះបង់អាយុជីវិតខ្លាំងណាស់” ដោយបានលើកឡើងថា សកម្មភាពនានារបស់របបកម្ពុជាប្រជាធិបតេយ្យបណ្ដាលឱ្យមានការតស៊ូទ្រាំទ្រការលំបាក និងការបាត់បង់ជីវិតដែលជាការចាំបាច់ និងដែលអាចឱ្យអាចទទួលយកបានដើម្បីទប់ស្កាត់កុំឱ្យចុះចាញ់វៀតណាមទាំងស្រុង។ នៅក្នុងសៀវភៅស្នាដៃរបស់គាត់បោះពុម្ព ក្នុងឆ្នាំ ២០០៧ **ខៀវ សំផន** បានលើកឡើងថា គាត់គ្មានវិប្បដិសារីទេនៅក្នុងជីវិត ហើយបាន និយាយទៀតថា “ខ្ញុំមិនបានធ្វើអ្វីដែលធ្វើឱ្យខ្ញុំត្រូវខ្មាស់អៀនចំពោះមុខនរណាម្នាក់ឡើយ””។

គាត់ក៏បាននិយាយដោយការពេញចិត្តនូវសំដី របស់ ប៉ុល ពត និង ប.ក.ក ដែរ ដែលបានលើកឡើងថា “ចលនាកម្ពុជាប្រជាធិបតេយ្យ បានដើរតួសំខាន់យ៉ាងសំខាន់មួយនៅក្នុងរយៈកាលមួយនៃប្រវត្តិសាស្ត្ររបស់ជាតិដែលគ្មាននរណាអាចនឹងកោស ឬលុបបានទេ។ បើមាននរណាកោស ឬលុប ឬកែប្រែវានោះ ស្នាមកោស ឬលុប ក៏អាចនៅតែមើលឃើញ។ ព្រោះហេតុអ្វី? ព្រោះរឿងវាច្បាស់ណាស់ថា សាឡុតស ឬប៉ុល ពត បានបូជាអស់មួយជីវិត

របស់គាត់ដើម្បីប្រយុទ្ធតស៊ូជាមួយអាមេរិកផង ជាមួយនឹងពួកកុម្មុយនីស្តវៀតណាមផង ដើម្បីការពារអធិបតេយ្យរបស់ជាតិ"។

# អៀង ធីរិទ្ធ

## ទិដ្ឋភាពទូទៅ

១១៤៩- ផ្នែកខាងក្រោមនេះរៀបរាប់ដោយសង្ខេបអំពីការចូលរួម និងការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ របស់ **អៀង ធីរិទ្ធ** ចំពោះបទឧក្រិដ្ឋនានាដែលស្ថិតក្រោមកិច្ចស៊ើបសួរ ។

១១៥០- **អៀង ធីរិទ្ធ** គឺជាសមាជិកដ៏មានឥទ្ធិពលម្នាក់របស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យនៅក្នុងសម័យកាលដែលស្ថិតក្រោមកិច្ចស៊ើបសួរ និងជាអ្នកចូលរួមមួយរូបនៅក្នុងការបង្កើត និងការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួម(JCE)។ គាត់ជាសមាជិកសកម្មមួយរូបរបស់ខ្មែរក្រហម តាំងពីរបបនេះចាប់បដិសន្ធិ ដោយបានចូលរួមពាក់ព័ន្ធនៅក្នុងគោលនយោបាយបដិវត្តន៍ ជាមួយនឹង**អៀង សារី** បងស្រីរបស់គាត់ឈ្មោះ ខៀវ ប៉ុណ្ណារី និងបងថ្លៃប្រុសរបស់គាត់គឺ ប៉ុល ពត នៅឯទីក្រុងប៉ារីស ក្នុងទសវត្សរ៍១៩៥០ ។ **អៀង ធីរិទ្ធ** បានធ្វើឱ្យខ្លួនគាត់លេចធ្លោនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា រដ្ឋាភិបាលរួបរួមជាតិកម្ពុជា(GRUNK) និងរណសិរ្សរួបរួមជាតិកម្ពុជា(FUNK)នៅក្នុងសម័យកាលដែលគាត់នៅក្នុងព្រៃម៉ាគី ដោយកាន់មុខតំណែងជាន់ខ្ពស់មួយចំនួន រួមទាំងជារដ្ឋមន្ត្រីក្រសួងអប់រំ និងយុវជន និងជានាយកស្ថានីយឃោសនាការនៃបក្សកុម្មុយនីស្តកម្ពុជានៃវិទ្យុរបស់ FUNK ។

១១៥១- បន្ទាប់ពីការឡើងកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងខែ មេសា ឆ្នាំ **អៀង ធីរិទ្ធ** បានទទួលយកមុខតំណែងមួយចំនួនជាអ្នកមានភារៈកិច្ចទទួលខុសត្រូវនិងបានធ្វើឱ្យឋានៈអធិ

ន្ត្រីយ៍ របស់គាត់ ចាក់គ្រឹះយ៉ាងរឹងមាំ ជាសមាជិកស្ត្រីដ៏លេចធ្លោបំផុតមួយរូប នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្វីដែលគួរឲ្យកត់សំគាល់បំផុតនោះ គឺគាត់ទទួលបាន ភារកិច្ច ចំពោះការទទួលខុសត្រូវ លើមុខតំណែងកំរិតរដ្ឋមន្ត្រីដែលទទួលបន្ទុកលើកិច្ចការដ៏ទូលំ ទូលាយខាងផ្នែកសុខាភិបាល និង សង្គមកិច្ច នៅពេលគាត់ត្រូវបានតែងតាំង ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។ ក្នុងតួនាទីនេះ **អៀង ធីរិទ្ធ** មានភារៈកិច្ចលើការងារគ្រប់គ្រង បណ្តុះបណ្តាល និងត្រួតត្រា បុគ្គលិកពេទ្យ កម្មាភិបាល និងមន្ទីរពេទ្យស៊ីវិល ការផ្គត់ផ្គង់ និង ការផលិត និងការចែកចាយ ផលិតផលឱសថ និងមើលការខុសត្រូវចំពោះរោងចក្រវាយណ ភណ្ឌមួយចំនួន និងការផលិត ម្ហូបអាហារ។ មុខតំណែងនេះ អនុញ្ញាត ឲ្យគាត់ត្រួតត្រាក្រសួងសង្គមកិច្ចដែលជាក្រសួងដ៏ធំ និងសំខាន់បំផុតមួយរបស់កម្ពុជា ប្រជាធិតេយ្យ និងបុគ្គលិករបស់ក្រសួងនេះដែលមានចំនួន ជាង១០០០នាក់។ គាត់នៅបន្តធ្វើ អន្តរសកម្មភាពឥតដាច់ជាមួយមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ធ្វើរបាយការណ៍ជូន គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្ត ក១ ក៣ និងគណៈរដ្ឋមន្ត្រី។ **អៀង ធីរិទ្ធ** ក៏ធ្វើ តំណាងជាទៀងទាត់ឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផងដែរ នៅពេលមានទស្សនៈកិច្ច របស់គណៈប្រតិភូបរទេស។ មុខតំណែងនៃសិទ្ធិអំណាចរបស់គាត់បានធ្វើឲ្យគាត់រក្សាបាន នូវឥទ្ធិពលលើការងារអភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិតេយ្យ ។

១១៥២- អំពើនានាដែលជាការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ **អៀង ធីរិទ្ធ** ចំពោះឧក្រិដ្ឋកម្មដែល ស្ថិតនៅក្រោមកិច្ចស៊ើបសួរ គឺត្រូវបានរកឃើញ តែមិនកំណត់ត្រឹមអំពើដូចតទៅប៉ុណ្ណោះទេ រួមមាន៖ ការចូលរួមដោយផ្ទាល់ និងរួមចំណែកដល់កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍

បក្សកុម្មុយនីស្ត កម្ពុជារបស់គណៈរដ្ឋមន្ត្រី និងរបស់មេដឹកនាំជាន់ខ្ពស់នានា នៅ ក១ និង ក៣ ការដឹកនាំ និងជួយនៅក្នុងការបោសសម្អាតនៅក្នុងក្រសួងសង្គមកិច្ច រួមទាំងការចង្អុលបង្ហាញអត្តសញ្ញាណទាំងបុគ្គលិក និងកម្មាភិបាលថ្នាក់ខ្ពស់និងសាមញ្ញ ការអនុម័ត និងការបញ្ជាឲ្យចាប់ខ្លួន ការប្រាស្រ័យទាក់ទងជាមួយមន្ទីរស-២១ ដើម្បីជួយសម្រួលដល់ការចាប់ខ្លួនទាំងនោះ និងការលើកទឹកចិត្តសមាជិកបុគ្គលិកឲ្យតាមដានជនសង្ស័យ ការបំពេញការងារក្នុងក្រសួងសង្គមកិច្ច និងចាត់ចែងក្រសួងនេះតាមរយៈការចេញសារាចរណែនាំ ការបំពាក់បំប៉នមនោគមវិជ្ជា និងថ្កោលទោសបុគ្គលិក ការទទួលរបាយការណ៍ និងការត្រួតពិនិត្យលើការអនុវត្តន៍គោលនយោបាយ ឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ការចូលរួមប្រព្រឹត្តនូវឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ដូចជាការចាត់ចែងឲ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបញ្ជូនដោយបង្ខំនៃបុគ្គលិកក្រសួងសង្គមកិច្ចទៅកាន់ការដ្ឋានលត់ដំ និងអប់រំនានា ការបញ្ជា និងការញុះញុងឲ្យមានឧក្រិដ្ឋកម្មទាំងនេះ ក្នុងអម្លុងពេលនៃការបើកវគ្គអប់រំបំពាក់បំប៉នគោលនយោបាយ និងកិច្ចប្រជុំក្នុងក្រសួងសង្គមកិច្ច មន្ទីរពេទ្យ សាលាពេទ្យនិងរោងចក្រផលិតឱសថនានា និងការបន្តធ្វើតំណាងឲ្យកម្ពុជាប្រជាធិតេយ្យនៅថ្នាក់ជាតិ និងអន្តរជាតិ ដោយបដិសេធចោលរាល់ភស្តុតាងនានានៃឧក្រិដ្ឋកម្មរបស់ខ្លួន ។

១១៥៣- ដោយសារមុខតំណែងរបស់គាត់ ទាំងក្នុងក្រសួងសង្គមកិច្ច និងភាពជាមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាដែលធំទូលាយជាង **អៀង ធីរិទ្ធ** ទទួលបានសិទ្ធិរួចជាស្រេចចំពោះព័ត៌មានបុព្វសិទ្ធិ និងដែលលំអិតអំពីឧក្រិដ្ឋកម្ម ព្រមទាំងត្រូវបានគេធ្វើឲ្យជ្រួតជ្រាបយ៉ាងប្រសើរនៅទូទាំងសម័យកាលដែលស្ថិតក្រោមកិច្ចស៊ើបសួរ។ ទោះជាយ៉ាងនេះក្តី និងទោះជាមុខតំណែងដ៏មានឥទ្ធពលរបស់គាត់នៅក្នុងជួរមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងការត្រួតត្រាដ៏មានប្រសិទ្ធភាព

របស់គាត់លើក្រសួងសង្គមកិច្ចនិងស្ថាប័នសំខាន់ៗនៃក្រសួងនេះក៏ដោយ ក៏គាត់ខកខានមិនបានរារាំងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងធ្វើការស៊ើបអង្កេតនិងផ្តន្ទាទោសជនដៃដល់ដែរ។ ផ្ទុយទៅវិញ **អៀង ធីរិទ្ធ** បានប្រើមុខតំណែងនៃអំណាចរបស់ខ្លួន ដើម្បីអនុវត្តយ៉ាងពេញលេញនូវផែនការឧក្រិដ្ឋនៅក្នុង ក្រសួងសង្គមកិច្ច។ នៅក្រោមការបង្គាប់បញ្ជា និងភាពជាអ្នកដឹកនាំរបស់ **អៀង ធីរិទ្ធ** កម្មាភិបាលមួយចំនួនធំនៅក្នុងក្រសួងសង្គមកិច្ចត្រូវបានបោសសម្អាតគិតមកដល់ចុងបញ្ចប់នៃរបប កម្ពុជាប្រជាធិបតេយ្យ ។

១១៥៤- **អៀង ធីរិទ្ធ** នៅតែបន្តការចូលរួមយ៉ាងសកម្មជាមួយបក្សកុម្មុយនីស្តកម្ពុជា និងសមាជិកនានានៃសហកម្មឧក្រិដ្ឋកម្ម រួមជាតទៅទៀត ទោះបីជាកម្ពុជាប្រជាធិបតេយ្យធ្លាក់ពីអំណាចក៏ដោយ។ ក្នុងតួនាទីរបស់គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងក្រោយមកជាអគ្គលេខាធិការនៃក្រសួងការបរទេស គាត់នៅបន្តធ្វើជាតំណាងឲ្យបក្សកុម្មុយនីស្តកម្ពុជា ជារឿយៗ នៅក្នុងកិច្ចប្រជុំនានាជាមួយគណៈប្រតិភូបរទេស។ គាត់ធ្វើដំណើរយ៉ាងទូលំទូលាយ តស៊ូមតិ ដើម្បីស្តារអំណាចរបស់ បក្សកុម្មុយនីស្តកម្ពុជាឡើងវិញ ថ្កោលទោសចំពោះការដណ្តើមកាន់កាប់របស់វៀតណាម និង ទម្លាក់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើវៀតណាម។ ក្នុងពេល ជាមួយគ្នានេះដែរ **អៀង ធីរិទ្ធ** បានបដិសេធម្តងហើយម្តងទៀតពីការចូលរួមពាក់ព័ន្ធក្នុងឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា និងនៅតែទទូចថាគាត់គ្រាន់តែគឺជាសមាជិកបក្សដែលមានអំណាចតិចតួចតែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់បានភ្ជាប់រូបគាត់ដោយផ្ទាល់ទៅក្នុងការបោសសម្អាតនៅក្នុងក្រសួងសង្គមកិច្ច និងភស្តុតាងដទៃទៀតបង្ហាញឲ្យឃើញពីការទទួលស្គាល់របស់គាត់អំពីចំនួនមនុស្សស្លាប់ដ៏ច្រើន និងការបោសសំអាត ដ៏ធំ។ គាត់មិនគ្រាន់តែបានដឹងអំពីឧក្រិដ្ឋកម្មផ្សេងៗដែលកំពុងត្រូវបាន

ប្រព្រឹត្តតែប៉ុណ្ណោះទេ ប៉ុន្តែ គាត់ថែមទាំង បានដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការរៀបចំ ធ្វើផែនការ និងអនុវត្តនូវឧក្រិដ្ឋទាំង នោះទៀតផង។

**តួនាទីនៅមុនឆ្នាំ១៩៧៥**

១១៥៥- **អៀង ធីរិទ្ធមានឈ្មោះពីកំណើតថា ខៀវ ធីរិទ្ធ** កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅភ្នំពេញ ហើយ គាត់ គឺជាកូន ស្រីចៅក្រមមួយរូបនៃខេត្តបាត់ដំបង និងជានាយកសាលា បានធំដឹងក្តីក្នុង ត្រកូលខ្ពង់ខ្ពស់មួយ **អៀង ធីរិទ្ធ** បានសិក្សាគ្រប់កំរិតនៅភ្នំពេញ ដោយបានចូលសិក្សានៅ សាលាបឋមសិក្សា *Ecole Barbie* សម្រាប់រយ: ពេលបីឆ្នាំដំបូង និងបានបញ្ចប់ថ្នាក់ បឋមសិក្សានៅ សាលានរោត្តម ក្នុងនាមជាយុវសិស្សម្នាក់នៃសាលាមធ្យមសិក្សាតែមួយគត់ នៅភ្នំពេញ គឺវិទ្យាល័យស៊ីសុវត្ថិ គាត់បានក្លាយ ជាមនុស្សសកម្មក្នុងរឿងនយោបាយតាំងពីឆ្នាំ១៩៤៦ ដោយបានបះបោរប្រឆាំងនឹងអាណានិគម បារាំងនៅក្នុងក្រុមយុវជន យុវនារីបដិវត្តន៍។ គាត់ បានជួប **អៀង សារី** ដែលជា ប្រធានសិស្សនៅវិទ្យាល័យស៊ីសុវត្ថិ និងបានក្លាយជាគូដណ្តឹង របស់ អៀង សារី មុនពេលដែល អៀង សារី ចាកចេញទៅទីក្រុងប៉ារីស ក្នុងឆ្នាំ១៩៥១។ អៀង ធីរិទ្ធ បានចាកចេញពី កម្ពុជាក្នុងឆ្នាំ១៩៥២ ដើម្បីសិក្សាអក្សរសាស្ត្រភាសាអង់គ្លេសនៅ មហាវិទ្យាល័យ La Sorbonne University នៅទីក្រុងប៉ារីស។ គាត់ទទួលបានអាហារ រូបករណ៍ដែលគេបម្រុង ទុកសម្រាប់អ្នកដែលទទួលបានបាក់កាឡូរ៉េអា*(Baccalaur"at)* ដែលគាត់ជានិស្សិតម្នាក់ក្នុង ចំណោមនិស្សិតស្ត្រីតែពីរបីនាក់ប៉ុណ្ណោះ ដែលបានទទួល។ ទោះបីជាអាហាររូបករណ៍

របស់គាត់ត្រូវបានដកហូតវិញក៏ដោយ ក៏ **អៀង ធីរិទ្ធ** អាចចាត់ចែងបញ្ចប់ ការសិក្សានៅបរទេសរបស់គាត់ដោយជោគជ័យ តាមរយៈជំនួយហិរញ្ញវត្ថុពីម្ដាយរបស់គាត់។

១១៩៦- នៅទីក្រុងប៉ារីស **ខៀវ** ធីរិទ្ធ បានចូលរួមជាមួយក្រុមម៉ាស៊ីស-ឡេនីន (Marxist-Leninist Circle)ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៥១ ដោយ **អៀង សារី**។ ភាគច្រើននៃនិស្សិតកម្ពុជាជាង១០០នាក់ នៅទីក្រុងប៉ារីស គឺជាសមាជិកនៃក្រុមនេះ។ សមាជិកលេចធ្លោដទៃទៀតនៃក្រុមនេះរួមមានសាឡុត ស (ប៉ុល ពត) ខៀវ ប៉ុណ្ណារី **ខៀវ សំផន** និង សុន សេន។ ក្រុមនេះប្រកាន់យកគំនិតប្រឆាំងអាណានិគមនិយម គំនិតជាតិនិយម និងសាធារណរដ្ឋនិយម និងមានទំនាក់ទំនងជាមួយគណបក្សកុម្មុយនីស្តបារាំង។ ជម្រើសរបស់ **អៀង ធីរិទ្ធ** ក្នុងការចាប់យកការសិក្សាអក្សរសាស្រ្តភាសាអង់គ្លេស នៅទីក្រុងប៉ារីស តាមពិតគឺជម្រុញទឹកចិត្តដោយ សារការប្រឆាំងរបស់ខ្លួននឹងអាណានិគមនិយមបារាំង ដែលជាអ្នកជំរុញទឹកចិត្ត ។

១១៩៧- **អៀង សារី** និង **ខៀវ ធីរិទ្ធ** បានរៀបការនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៣ នៅទីក្រុងប៉ារីស។ អាពាហ៍ពិពាហ៍របស់ពួកគេ គឺជាឱកាសដ៏ធំដែលបានចូលរួមដោយនិស្សិតកម្ពុជា និងបរទេសដែលជាអ្នកស្មោះស្ម័គ្រទៅនឹងបុព្វហេតុកុម្មុយនីស្ត។ សាឡុត ស បានរៀបការជាមួយ ខៀវ ប៉ុណ្ណារី (ដែលក្រោយមកត្រូវបានគេស្គាល់ថា បងយ៉ឹម) ក្នុងឆ្នាំ១៩៥៦។ បងប្អូនស្រីទាំងពីរនាក់ និងប្ដីរបស់ពួកគេដែលត្រូវជាមិត្តនឹងគ្នាដ៏ជិតស្និត នឹងត្រូវលេចមុខជាប្ដីប្រពន្ធពីរគូរដ៏មានឥទ្ធិពល បំផុត នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។

១១៩៨- នៅពេលត្រឡប់មកភ្នំពេញវិញ ក្នុងខែមករា ឆ្នាំ១៩៥៧ **អៀង សារី** និង **អៀង ធីរិទ្ធ** បានរស់នៅជាមួយ សាឡុត ស និងប្រពន្ធរបស់គាត់។ **អៀង ធីរិទ្ធ** បានទទួលមុខតំណែងមួយចំនួនជា

គ្រូបង្រៀននៅទីក្រុងភ្នំពេញ នៅចន្លោះឆ្នាំ១៩៥៧ និង១៩៦៥ រួមទាំងការងារនៅអតីតសាលារបស់គាត់គឺវិទ្យាល័យស៊ីសុវត្ថិផង។ ពេលគណបក្សពលករកម្ពុជា (WPK) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ គាត់បានប្រើប្រាស់បៀវត្សជាគ្រូបង្រៀនរបស់គាត់ជាជំនួយឧបត្ថម្ភដល់បក្ស និងមួយចំណែកធំទៀតចំណាយលើប្រតិបត្តការកាសែត *L'Observateur* ដែលជាកាសែតឆ្វេងនិយម បង្កើតឡើងដោយ **ខៀវ សំផន** ក្នុងខែកញ្ញា ឆ្នាំ១៩៥៩។ **អៀង ធីរិទ្ធ** ដោយសារគ្រួសារគាត់ស្គាល់សម្តេចសីហនុ ក៏ត្រូវបានផ្តល់តំណែងជាសមាជិករដ្ឋសភាផងដែរ។ ប៉ុន្តែដោយមានការផ្តល់យោបល់ពីបក្ស **អៀង ធីរិទ្ធ** បដិសេធមិនទទួលយកមុខតំណែងនេះទេ។

១១៥៩- ក្នុងឆ្នាំ១៩៦៥ **អៀង ធីរិទ្ធ** បានចាកចេញចោលកូនទាំងបួននាក់របស់ខ្លួន ដើម្បីរត់ចូលព្រៃម៉ាគី។ ក្នុងអំឡុងពេលនេះ គាត់ជាសមាជិកម្នាក់នៃមន្ទីរ១០០ ដែលជាជំរុំឃោធានៅតាម ព្រំដែនកម្ពុជា-វៀតណាម ហើយគាត់មានឈ្មោះបដិវត្តន៍យ៉ាងសាមញ្ញធម្មតាបំផុត គឺ ភា។ សមាជិកលេចធ្លោដទៃទៀតនៃមន្ទីរ១០០ គឺមាន ប៉ុល ពត **អៀង សារី** សុន សេន ចាន់ ចក្រី យុន យ៉ាត និង ណៃ សារ៉ាន់

១១៦០- នៅចន្លោះឆ្នាំ១៩៧០ និង ខែមេសា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** បានកាន់កាប់នូវមុខតំណែងនៃសិទ្ធិអំណាចមួយចំនួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងបានឡើងជាបន្តបន្ទាប់នៅក្នុងឋានានុក្រមរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ក្នុងខែសីហា ឆ្នាំ១៩៧០ អៀង ធិរិទ្ធ ត្រូវបានផ្តល់តំណែងជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងយុវជន ក្នុងផ្នែកនៃការតែងតាំងអនុរដ្ឋមន្ត្រីថ្មីចំនួនប្រាំពីររូប

នៃ រដ្ឋាភិបាលរួបរួមជាតិកម្ពុជាចំពោះអ្នកដែលត្រូវបានគេពិពណ៌នាថា "មានប្រវត្តិតស៊ូយូរមកហើយ" និងជាអ្នកដែលគេវាយតម្លៃថា "ជាបញ្ញវន្តទីមួយ" ។

១១៦១- នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៧៣ **អៀង ធីរិទ្ធ** ត្រូវបានដំឡើងតំណែងជារដ្ឋមន្ត្រីក្រសួងអប់រំ និងយុវជននៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (ជំនួស ចាន់ យូរ៉ាន់ *ហៅ* វ៉ន) ជាមុខតំណែងដែលគាត់បានរក្សារហូតដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦។ នៅពេលតែងតាំងរូបគាត់ គាត់ត្រូវបានគេពិពណ៌នាថាជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា និងជារដ្ឋមន្ត្រី "ក្នុងប្រទេស"។

១១៦២- នៅចន្លោះឆ្នាំ១៩៧០ និងខែមេសា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** ក៏កាន់មុខតំណែងជានាយកស្ថានីយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជាផងដែរ គឺ*វិទ្យុផ្សាយសម្លេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា (La Voix du Front Uni National du Kampuch"a)* មានកូដសម្ងាត់ថា ក-៣០០ និងមានមូលដ្ឋានសម្ងាត់នៅទីក្រុងហាណូយប្រទេសវៀតណាម។ វិទ្យុនេះបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការផ្សព្វផ្សាយ ពីរណសិរ្សរួបរួមជាតិកម្ពុជា ការឃោសនា និងសេចក្តីណែនាំគោលនយោបាយនិងយោធារបស់ប.ក.ក។ ដោយមានកម្មាភិបាលក្មេងៗបំពេញការងារដោយ ជោគជ័យនៅ ក-៣០០ មានពេលមួយនោះ**អៀង ធីរិទ្ធ** ទទួលខុសត្រូវចំពោះបុគ្គលិកពី២០-៣០នាក់។ ការទទួលខុសត្រូវរបស់ ក-៣០០ រួមមានការបកប្រែលេខកូដសម្ងាត់សារដែលបានបញ្ជូនពីតំបន់រំដោះនានា ក្នុងប្រទេសកម្ពុជាសម្រាប់គោលបំណងផ្សព្វផ្សាយ។ ក្នុងឆ្នាំ១៩៧៣ អៀង ធិរិទ្ធជាមួយនឹង **អៀង សារី** និង **ខៀវ សំផន** បានជួបជាមួយកម្មាភិបាល ពី២០ទៅ៣០នាក់មកពីសាខាបក្សកុម្មុយនីស្តកម្ពុជាភាគខាងជើងប្រទេសវៀតណាម ដើម្បីបញ្ចុះបញ្ចូល ពួកគេ

ឲ្យត្រឡប់មកកម្ពុជាវិញ។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលទទួលបានការហ្វឹកហ្វឺន នៅវៀតណាមខាងជើង ត្រូវបានបោសសម្អាតនៅពេលពួកគេត្រឡប់មកដល់កម្ពុជា ។

១១៦៣- ទោះបីមានមូលដ្ឋាននៅហាណូយ ក្នុងចន្លោះឆ្នាំ១៩៧០ និង១៩៧៥ ក៏ **អៀង ធីរិទ្ធ** ក្នុងនាមជារដ្ឋមន្ត្រីក្រសួងអប់រំ និងយុវជន ក៏បានធ្វើទស្សនកិច្ចជាទៀងទាត់មកកាន់ភូមិភាគនានាដែលស្ថិតក្រោមការកាន់កាប់របស់រណសិរ្សរួបរួមជាតិកម្ពុជា នៅកម្ពុជាផងដែរ។ ឧទាហរណ៍ **អៀង ធីរិទ្ធ** បានធ្វើទស្សនកិច្ចមួយមកកាន់មូលដ្ឋានគណៈមជ្ឈិមក្នុងខេត្តកំពង់ចាម នៅចន្លោះឆ្នាំ១៩៧៣ និង១៩៧៥។ គាត់ក៏បានស្នាក់នៅក្នុងប្រទេសកម្ពុជាប្រាំមួយខែផងដែរ ក្នុងចន្លោះខែកុម្ភៈ និង សីហា ឆ្នាំ១៩៧៣ ។

១១៦៤- ក្នុងពេលដូចគ្នានេះដែរ ក្នុងនាមរដ្ឋមន្ត្រីក្រសួងអប់រំ និងយុវជន **អៀង ធីរិទ្ធ** បានដើរតួនាទីការទូតដ៏សំខាន់ ។ ក្នុងខែកក្កដា ឆ្នាំ១៩៧២ **អៀង សារី** និង **អៀង ធីរិទ្ធ** បានចូលរួមក្នុងពិធីបុណ្យសព សឺន ង៉ុកមិញ នៅហាណូយ ប្រទេសវៀតណាម ។ អៀង ធិរិទ្ធជាមួយ **អៀង សារី** និង **ខៀវ សំផន** បានបំពេញបេសកកម្មផ្លូវការលើកដំបូងរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឬរណសិរ្ស រួបរួមជាតិកម្ពុជា នៅវៀតណាម (២៧ មីនា - ១ មេសា ១៩៧៤) នៅចិន (១ មេសា -៥ មេសា ១៩៧៤ ៨-១៩ មេសា និងដើមខែឧសភា -២៥ ឧសភា ១៩៧៤) និងនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (៥-៨ មេសា ១៩៧៤)។ គាត់មានឱកាសបានជួបបណ្ដាតំណាងប្រទេសអ៊ឺរ៉ុបខាងកើត និងអាហ្វ្រិក (រួមមាន អាល់បានី យូហ្គូស្លាវី រ៉ូម៉ានី អាល់ហ្សេរី ម៉ូរីតានៀ និងកាមេរូន នៅចន្លោះថ្ងៃទី១៩ មេសា និងដើមខែឧសភា ១៩៧៤) ។

## មុខតំណែង និងសិទ្ធិអំណាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

១១៦៥- ដោយស៊ីសង្វាក់គ្នានឹងអតីតភាព និងតួនាទីនយោបាយនៅក្នុងចលនាកុម្មុយនីស្តកម្ពុជា តាំងពីមុនខែមេសា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** គឺជាសមាជិកដ៏មានឥទ្ធិពលម្នាក់របស់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអម្តុងពេលដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។ គាត់បាន កាន់កាប់មុខតំណែងនៃសិទ្ធិអំណាចមួយចំនួន ដែលមុខតំណែងទាំងនោះ សុទ្ធតែបានផ្តល់លទ្ធភាព ឲ្យគាត់គ្រប់គ្រងរក្សាបាននូវឥទ្ធិពល និងចូលរួមប្រព្រឹត្តនៅក្នុងការ អភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ។

## ការចូលរួមពាក់ព័ន្ធក្នុងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ

### មុខតំណែងនៃសិទ្ធិអំណាចផ្លូវការ

១១៦៦- បន្ទាប់ពីការវិលត្រឡប់របស់ខ្លួនមកកម្ពុជាវិញនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៥ **អៀង ធីរិទ្ធ** ត្រូវបានតែងតាំងមុខតំណែងសំខាន់ៗមួយចំនួនក្នុងរដ្ឋាភិបាល។ មុខតំណែងថ្នាក់រដ្ឋមន្ត្រីដំបូងរបស់គាត់ គឺកិច្ចការសុខាភិបាល និងសង្គមកិច្ច។ គាត់បានចាប់ផ្តើមធ្វើការនៅ ក-២ ភ្លាមបន្ទាប់ពីគាត់បានវិលត្រឡប់មកដល់កម្ពុជាវិញ និងត្រូវបានប្រគល់ជាផ្លូវការនូវការទទួលខុសត្រូវខាងកិច្ចការវប្បធម៌ សង្គមកិច្ច និងការបរទេស យ៉ាងហោចណាស់ចាប់ពីថ្ងៃទី៩ តុលា ១៩៧៥ ដោយគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ដែលតំណែងថ្នាក់រដ្ឋមន្ត្រីក្រោយមកត្រូវបានចែករំលែកជាមួយ **អៀង សារី**។ នៅថ្ងៃទី១៤ មេសា ១៩៧៦ **អៀង ធីរិទ្ធ** ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចជាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ។

តាមរយៈភាពជាមេដឹកនាំនៃក្រសួងដ៏សំខាន់មួយនេះ **អៀង ធីរិទ្ធ** មាន សិទ្ធិអំណាចពេញលេញលើមន្ទីរពេទ្យស៊ីវិល សហគ្រាសឱសថ និងរោងចក្រផលិតថ្នាំពេទ្យ ហើយនិងនៅលើកិច្ចការសង្គមកិច្ចយ៉ាងទូលំទូលាយ ដូចដែលយើងនឹងលើកយកមកពិភាក្សាក្នុងផ្នែកតួនាទីជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចខាងក្រោម ។

១១៦៧- បន្ថែមលើមុខតំណែងលេចធ្លោរបស់គាត់ទាក់ទិននឹងកិច្ចការសុខាភិបាល និងសង្គមកិច្ច **អៀង ធីរិទ្ធ** ក៏បានរក្សាមុខតំណែងជារដ្ឋមន្ត្រីក្រសួងអប់រំ និងយុវជន នៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជាផងដែរ រហូតដល់ថ្ងៃទី១៤ មេសា ១៩៧៦។ ក្នុងសមត្ថកិច្ចនេះ និងក្នុងនាមជាសមាជិកា ដ៏លេចធ្លោបំផុតម្នាក់នៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា គាត់បានធ្វើដំណើរបេសកកម្មការទូតមួយទៅកាន់ប្រទេសចិន ក្នុងខែសីហា ឆ្នាំ១៩៧៥ ដើម្បីពង្រឹងទំនាក់ទំនងបក្សកុម្មុយនីស្តកម្ពុជាជាមួយមេដឹកនាំកុម្មុយនីស្តចិន ជូ អេនឡាយ និងម៉ៅ សេទុង។ គាត់ក៏បានធ្វើដំណើរទៅកាន់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ជាមួយ **ខៀវ សំផន** ផងដែរ ដើម្បីសុំយាងជាផ្លូវការ សម្តេចនរោត្តមសីហនុ និងមហេសី ម៉ូនិក (ដែលជាមិត្តភ័ក្តិរបស់ **អៀង ធីរិទ្ធ** តាំងពីនៅសាលា ជាមួយគ្នា) ត្រឡប់មកកម្ពុជាវិញ ។ បន្ទាប់មក **អៀង ធីរិទ្ធ** និង **ខៀវ សំផន** បានអមដំណើរយាងសម្តេចសីហនុ និងមហេសីត្រឡប់មកកម្ពុជា កាត់តាមប្រទេសចិននៅដើម ខែកញ្ញា ។

១១៦៨- ទាក់ទិននឹងសមាជិកភាពរបស់គាត់ ក្នុងអង្គការដែលធ្វើសេចក្តីសម្រេចចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជា **អៀង ធីរិទ្ធ** ត្រូវបានគិតថាជាសមាជិកម្នាក់នៃគណៈកម្មាធិការមជ្ឈិម។ គាត់ជា

សមាជិកគណៈរដ្ឋមន្ត្រីដែរ និងបានចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដោយផ្ទាល់ យ៉ាងហោចណាស់ក៏ម្តងដែរ ដែលមាននៅក្នុងកំណត់ហេតុរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ។

១១៦៩- ក្នុងខែមីនា ឆ្នាំ១៩៧៦ **អៀង ធីរិទ្ធ** ត្រូវបាន "បោះឆ្នោតជ្រើសរើស" ជាតំណាងពលករោងចក្រនៅភ្នំពេញនៃសភាតំណាងប្រជាជនកម្ពុជា។ ទោះបីសភាតំណាងប្រជាជនមិនមានអំណាចប្រកបដោយប្រសិទ្ធភាពណាមួយក្តី ការបង្កើតស្ថាប័ននេះឡើងជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្ររបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដើម្បីធ្វើមជ្ឈការ និងបង្រួមអំណាចទាំងអស់ ក្នុងខណៈដែលកំពុងថែរក្សាមុខមាត់នៃលិទ្ធិប្រជាធិបតេយ្យ។ **អៀង ធីរិទ្ធ** ក៏ជាអនុប្រធានសមាគមនារីកម្ពុជាប្រជាធិបតេយ្យផងដែរ យ៉ាងហោចណាស់ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៧ ដោយធ្វើតំណាងឲ្យសមាគមនេះជារឿយៗ នៅតាមបណ្តាការរៀបចំជាសាធារណៈផ្សេងៗ។ **អៀង ធីរិទ្ធ** បានបង្ហាញ ខ្លួនជាមេដឹកនាំរបស់សមាគម *តាមព្រឹត្តន័យ* ខណៈពេលដែល ខៀវ ប៉ុណ្ណារី មានជម្ងឺផ្លូវចិត្ត ដែល គេកម្របានឃើញនៅក្នុងការប្រព្រឹត្តិទៅរបស់សមាគម។ សមាគមនេះមិនចាប់អារម្មណ៍នឹងការលើកកំពស់សិទ្ធិនារីទេ ហើយបានបំពេញមុខងាររបស់ខ្លួនជាផ្នែកដ៏សំខាន់នៃម៉ាស៊ីនឃោសនា របស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងតួនាទីនេះ **អៀង ធីរិទ្ធ** បានទទួលគណៈប្រតិភូនៃអង្គការស្ត្រីបរទេស យ៉ាងហោចណាស់ចំនួនពីរលើក (គណៈប្រតិភូវៀតណាម និងឡាវ) និងបានចុះធ្វើទស្សនកិច្ចក្នុង ប្រទេសជាមួយគណៈប្រតិភូទាំងពីរនេះ ដោយបង្ហាញពីសមិទ្ធិផលនានារបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានអះអាង។

## ដំណើរការនយោបាយ និងអំណាចទូលំទូលាយ

១១៧០- បន្ថែមលើការតែងតាំងជាផ្លូវការរបស់គាត់ **អៀង ធីរិទ្ធ** បានកាន់កាប់ និងអនុវត្តសិទ្ធិអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងនាមជាសមាជិកបដិវត្តរយៈពេលយូរ និងជាន់ខ្ពស់ម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងនាមជាមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ស្ត្រីដំបូងគេដែលបានកាន់កាប់មុខតំណែងរដ្ឋមន្ត្រី និងជា"ស្ត្រីទីមួយ"*តាមព្រឹត្តន័យ*នៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់គឺជាសមាជិកាដែលលេចធ្លោបំផុតរបស់បក្សនេះ។ មុខតំណែងរដ្ឋមន្ត្រីតួនាទីការទូត និង សម្ព័ន្ធភាពគ្រួសារទាំងជាមួយ **អៀង សារី** និង **ប៉ុល** ពត បានធ្វើឱ្យគាត់ទទួលបានឧត្តមភាព ខាងនយោបាយខ្ពស់ជាង យុន យ៉ាត ។ រួមជាមួយ ប៉ុល ពត បងស្រីរបស់គាត់ ខៀវ ប៉ុណ្ណារី និង **អៀង សារី** **អៀង ធីរិទ្ធ** ត្រូវបានគេពិពណ៌នាថាជាសមាជិកម្នាក់នៃ "បនទាំងបួនរបស់កម្ពុជា" (Cambodia's Gang of Four)។

១១៧១- មុខតំណែងនៃអំណាច និងឥទ្ធិពលរបស់ **អៀង ធីរិទ្ធ** ក៏ត្រូវបានបង្ហាញឱ្យឃើញផងដែរ តាមរយៈបុព្វសិទ្ធិដ៏សន្ធឹកសន្ធាប់ដែលបានផ្តល់ឱ្យគាត់។ **អៀង ធីរិទ្ធ** បានរស់នៅក្នុងជីវិតយ៉ាងស្រណុកសុខស្រួលនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាគាត់រស់នៅក្នុងភូមិគ្រឹះដែលមានការរៀបចំ យ៉ាងល្អ និងមានលទ្ធភាពទទួលបានម្ហូបអាហារយ៉ាងសម្បូរណ៍បែប។ គាត់ក៏មានលទ្ធភាព ដែលគេបានរៀបចំរួចជាស្រេចចំពោះបញ្ហាសន្តិសុខ និងភាពស្រណុកសុខស្រួល ដែលបានផ្តល់ ដោយទាំង ក២ និងក៣ ជាកន្លែងធ្វើការ និងជាលំនៅដ្ឋាន។ គាត់មានបុគ្គលិកបំរើនៅ ផ្ទះជាច្រើនតាមចិត្តរបស់គាត់ ដែលរួមមានអ្នកបើកបររថយន្ត អ្នករត់សំបុត្រ ឬនិរសារ ចុងភៅ អ្នកបោសសម្អាត និងអ្នកថែទាំសួន។ ទោះបីច្បាប់លក្ខន្តិកៈរបស់បក្សកុម្មុយនីស្ត កម្ពុជា ហាមឃាត់មិនឱ្យមានញាតិបក្សពួកនិយមក៏ដោយ ក៏ **អៀង ធីរិទ្ធ**

នៅតែអាចប្រើប្រាស់ នូវសិទ្ធិអំណាចរបស់ខ្លួន ដើម្បីតែងតាំងកូនស្រីជំទង់បីនាក់ និងកូនប្រសារប្រុសរបស់គាត់ទៅ កាន់មុខតំណែងថ្នាក់ខ្ពស់នៅក្នុងក្រសួងសង្គមកិច្ចបានដែរ ព្រមទាំងចាត់ចែងឲ្យកូនរបស់គាត់ បានរស់នៅក្បែរគាត់ និងមានជីវិតរស់នៅប្រកបដោយភាពស្រណុកសុខស្រួល។ ទោះបីវិធាន នៃបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេអះអាងថា បាននិងកំពុងអនុវត្តនៅគ្រប់ថ្នាក់ទាំងអស់ក្តី ក៏ **អៀង ធីរិទ្ធ** មិនធ្លាប់ត្រូវបានគេដាក់ទណ្ឌកម្ម ចំពោះការរំលោភលើគំនិតប្រឆាំងពួកគបាបតីរបស់ បក្សកុម្មុយនីស្តកម្ពុជានោះដែរ។

## មុខតំណែងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច

### មុខងារជារដ្ឋមន្ត្រី

១១៧២- ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បាន“ទទួលបន្ទុក” នៅក្រសួងសង្គមកិច្ច និងត្រូវបានគេស្គាល់ថាជា“ប្រធាន”នៃក្រសួងសង្គមកិច្ច។ ក្នុងតួនាទីនេះ គាត់មានភារកិច្ច ចម្បងជាអ្នកគ្រប់គ្រងលើមន្ទីរពេទ្យនានា និងលើរោងចក្រផលិតឱសថនានា នៅក្នុងទីក្រុង ភ្នំពេញព្រមទាំងលើការងារទាំងអស់ដែលទាក់ទងនឹងសង្គមកិច្ច។ តាមពិត **អៀង ធីរិទ្ធ** ត្រូវបានគេពិពណ៌នាថាជា “មន្ត្រីផ្លូវការណ៍នៃគណៈរដ្ឋមន្ត្រីដែលទទួលខុសត្រូវ ខ្ពស់ជាងគេបំផុតចំពោះសុខមាលភាពរបស់ប្រជាជន” ។

១១៧៣- ជាក់លាក់ជាងនេះ ការទទួលខុសត្រូវរបស់ **អៀង ធីរិទ្ធ** ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច គឺលាតសន្ធឹងឆ្លងកាត់ទៅកាន់វិស័យនានាជាច្រើន ដែលរួមមានការគ្រប់គ្រង និងត្រួតពិនិត្យលើរាល់បុគ្គលិកពេទ្យ កម្មាភិបាល និងមន្ទីរពេទ្យទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យ លើការផ្គត់ផ្គង់សំភារៈបរិក្ខាពេទ្យដល់មន្ទីរពេទ្យ ឱសថាល័យ និងមន្ទីរពិសោធន៍នានា ការ

ផលិតអាហារសម្រាប់បុគ្គលិករបស់គាត់និងអ្នកជម្ងឺ និងការត្រួតពិនិត្យមើលពីលើរោងចក្រវាយនភណ្ឌមួយចំនួន។ គាត់ក៏បានទទួលខុសត្រូវផងដែរចំពោះការផលិត និងផ្គត់ផ្គង់ផលិតផលថ្នាំពេទ្យ ហើយនិងការចែកចាយថ្នាំពេទ្យក្នុងចំណោមភូមិភាគនានា។ ក្នុងនាមជាប្រធាននៃក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** ក៏ត្រូវបានប្រគល់ភារកិច្ចឱ្យទទួលខុសត្រូវផងដែរក្នុងការចែកចាយជាតិគីមី និងវត្ថុធាតុដើមផ្សេងៗ សម្រាប់ផលិតថ្នាំពេទ្យនៅក្នុងស្រុក ក៏ដូចជាក្នុងការផ្គត់ផ្គង់ថ្នាំពេទ្យ និងសំភារៈបរិក្ខាពេទ្យដែលផលិតពីរោងចក្រ ទៅឱ្យមន្ទីរពេទ្យយោធានានា។ មន្ទីរ៨៧០ ត្រូវបានគេតម្រូវឱ្យស្នើសុំការយល់ព្រមជាមុនពី **អៀង ធីរិទ្ធ** មុននឹងធ្វើការចែកចាយទៅឱ្យមន្ទីរពេទ្យយោធាណាមួយ ។

## ការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច

១១៧៤- ក្រសួងសង្គមកិច្ច មានតួនាទីដ៏សំខាន់មួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារខ្លួនមានភារកិច្ចទទួលខុសត្រូវលើ "ភារកិច្ចសំខាន់ដែលត្រូវដោះស្រាយឱ្យបាន អំពីកំរិតជីវភាពរបស់ប្រជាជន" និងអនុវត្តគោលនយោបាយសុខភាព និងអនាម័យ ។ សុខាភិបាល និងសង្គមកិច្ចជាផ្នែក មួយនៃផែនការបួនឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជានិងដែលទទួលបាននូវការយកចិត្តទុកដាក់ជាប្រចាំនៅក្នុងអង្គប្រជុំគណៈកម្មាធិការ អចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា។ មានគណៈកម្មាធិការសភាតំណាងរបស់ប្រជាជនមួយក៏ត្រូវបានគេ ផ្តល់សម្រាប់ត្រួតពិនិត្យបញ្ហាទាំងនេះដែរ។

១១៧៥- ក្រសួងនេះត្រូវបានប្រគល់ភារកិច្ចឱ្យទទួលខុសត្រូវលើការគ្រប់គ្រងមន្ទីរពេទ្យនានា ការផលិតនិងការចែកចាយផលិតផលថ្នាំពេទ្យ ការផ្គត់ផ្គង់ថ្នាំពេទ្យទៅឱ្យបណ្តាភូមិភាគនានា ហើយនិង

ការផលិតខាងកសិកម្ម។ ទោះបីជាក្រសួងសុខាភិបាលមានឈ្មោះក៏ដោយ ក៏វាស្ទើរនឹងសំបកទទេតែប៉ុណ្ណោះ។ តាមការពិតជាក់ស្ដែង **អៀង ធីរិទ្ធ** បានត្រួតត្រាលើវិស័យសុខាភិបាលសាធារណៈទាំងមូល។ ចំណែកឯរដ្ឋមន្ត្រីក្រសួងសុខាភិបាល សាធារណៈ ឈ្មោះ ជួន ជឿន *ហៅ* តា ប៉ែន គ្រាន់តែជាគ្រូពេទ្យខាងរះកាត់ម្នាក់ ដែលស្ថិត នៅក្រោមអំណាចរបស់ប្រធានមន្ទីរពេទ្យ ព-១៧ តែប៉ុណ្ណោះ ហើយឈ្មោះ ពឿន ដែលជាកូនប្រសារប្រុសរបស់ **អៀង ធីរិទ្ធ** ឯណោះវិញទេ ដែលជាអ្នកអាចឆ្លើយតបបានដោយផ្ទាល់ទៅនឹង **អៀង ធីរិទ្ធ** តែម្ដង។

## រចនាសម្ពន្ធ និងអង្គការចាត់តាំងរបស់ក្រសួងសង្គមកិច្ច

១១៧៦- ក្រោមការចាត់ចែងគ្រប់គ្រង និងត្រួតត្រារបស់ **អៀង ធីរិទ្ធ** ក្រសួងសង្គមកិច្ចមានឋានានុក្រមរចនាសម្ពន្ធដ៏ខ្ពស់ ហើយដែលមានការរីកធំឡើងខាងទំហំ និងសារៈសំខាន់នៅក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការពង្រីករបស់ក្រសួងនេះសំខាន់ គឺដោយសារមូលហេតុចំនួនអ្នកជម្ងឺមានការកើនឡើងយ៉ាងសម្បើម ដែលចំនួននេះមានសន្ទុះកើនឡើង ដោយសារជម្លោះប្រដាប់អាវុធរបស់កម្ពុជាប្រជាធិបតេយ្យ ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម មានសភាពរឹតតែខ្លាំងឡើង។

## គណៈកម្មាធិការក្រសួងសង្គមកិច្ច

១១៧៧- មន្ទីរកណ្ដាលរបស់ក្រសួងសង្គមកិច្ច (ក-២) ត្រូវបានដឹកនាំដោយ **អៀង ធីរិទ្ធ**។ ស៊ិន ផល្គុណ *ហៅ* ស៊ូ និង ឡេង ពិសី *ហៅ* ឡេង ស៊ីមហាក់ *ហៅ* សី គឺជាអនុប្រធានទាំងពីររូបរបស់ **អៀង ធីរិទ្ធ** និងដែលជាសមាជិកដើមរបស់គណៈកម្មាធិការសង្គមកិច្ច។ ស៊ូ គឺជាអនុប្រធានដឹកនាំនៃក្រសួងសង្គមកិច្ច ជាប្រធានមន្ទីរក-២ និងធ្លាប់ជាកម្មាភិបាលមួយរូប នៅក-៣០០

ដែលជាស្ថានីយវិទ្យុផ្សាយសម្លេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា(FUNK) នៅទីក្រុងហាណូយ។ សី គឺជាប្រធាននៃមន្ទីរពេទ្យ ព-១៧ មេសា។

១១៧៨- សមាសភាពនៃគណៈកម្មាធិការសង្គមកិច្ច មានការផ្លាស់ប្តូរជាញឹកញាប់ ដោយសារសមាជិករបស់ខ្លួនត្រូវបានគេចាប់ខ្លួន ឬធ្វើការបោសសំអាត៖

ក. សី ត្រូវបានគេឃុំខ្លួននៅក្នុងលំនៅដ្ឋាននៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ និងបញ្ជូនទៅមន្ទីរស-២១ កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៧។ ប្រហែលមួយសប្តាហ៍ក្រោយមកប្រធានថ្មីនៃមន្ទីរពេទ្យព-១៧មេសា បានប្រកាសថា សី គឺជាជនក្បត់មួយរូបដែលគេសន្មត់ថាជាផ្នែករបស់ពួកសេអ៊ីអា។

ខ. ទោះបីជា ស៊ូ ធ្លាប់មានការជិតសិទ្ធិជាមួយ **អៀង ធីរិទ្ធ** នោះក្តី ក៏រូបគាត់ត្រូវបានគេយកទៅកាន់ ក-៧ ដែរ តាមបញ្ជារបស់ **អៀង ធីរិទ្ធ** ។ គាត់ត្រូវបានគេចាប់ខ្លួន និងយកទៅដាក់ក្នុងមន្ទីរស-២១ កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៨ និងត្រូវបានគេសម្លាប់ចោលកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨។

គ. ឈុន អតីតអនុប្រធាននៅក-២ ត្រូវបានតែងតាំងដោយ **អៀង ធីរិទ្ធ** ឲ្យធ្វើជាអ្នកជំនួស ស៊ូ ហើយត្រូវបានគេឲ្យធ្វើការងារស្ថិតក្រោមការពិនិត្យដ៏តឹងរឹងរបស់ **អៀង ធីរិទ្ធ**។ ឈុន ត្រូវបានគេរាយការណ៍មកថាបានរក្សាមុខតំណែងដដែលរហូតមកដល់ខែមករា ឆ្នាំ១៩៧៩ ទោះបីជាមានភស្តុតាងថា គាត់ត្រូវបានបាត់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៨ នោះហើយក្តី។

## **មន្ទីរនានានៃក្រសួងសង្គមកិច្ច**

១១៧៩- ក្រៅពីគណៈកម្មាធិការសង្គមកិច្ច ក្រសួងសង្គមកិច្ច រួមមានមន្ទីរសំខាន់ៗចំនួនបី៖ (១)មន្ទីរកណ្ដាលរបស់ក្រសួង(ក-២) (២)មន្ទីរពេទ្យនានានៅភ្នំពេញ និង(៣)សាលាពេទ្យ និងរោងចក្រផលិតឱសថ ឬមន្ទីរពិសោធន៍នានា។ មកទល់ឆ្នាំ១៩៧៨ មានបុគ្គលិកប្រមាណពី១.៣០០ ទៅ២០០០នាក់ ភាគច្រើនជាស្ត្រីបានធ្វើការងារនៅតាមអង្គភាពនានារបស់ ក-២ មន្ទីរពេទ្យនានាក្នុងទីក្រុងភ្នំពេញ និងរោងចក្រផលិតឱសថ។

១១៨០- មន្ទីរកណ្ដាលរបស់ក្រសួងសង្គមកិច្ច (ក-២) កាលពីដើមស្ថិតនៅក្បែរស្ពាតអូឡាំពិក បន្ទាប់មកក្នុងឆ្នាំ១៩៧៧ បានរើទៅក្នុងអាគារមួយកំពស់បីជាន់ នៅតាមដងមហាវិថីកម្ពុជាក្រោម។ ការិយាល័យផ្ទាល់ខ្លួនរបស់ **អៀង ធីរិទ្ធ** ស្ថិតនៅត្រង់មន្ទីរក-២ ។ ការប្រជុំ នានាជាប្រចាំនៃប្រធានអង្គភាពទាំងអស់របស់ក្រសួងសង្គមកិច្ច ដែលស្ថិតក្រោមអធិបតីភាពរបស់ **អៀង ធីរិទ្ធ** ត្រូវ បានគេធ្វើឡើងនៅទីនោះ។ មន្ទីរក-២ ត្រូវបានដឹកនាំជាបន្តបន្ទាប់ដោយ ស៊ូ និងឈុន ដែលមានបុគ្គលិករាប់រយនាក់ធ្វើការតាមផ្នែកនានាដែលមានចំនួនយ៉ាងតិចក៏ដប់មួយផ្នែកដែរ ។

## មន្ទីរពេទ្យ និងកន្លែងផលិតឱសថនានាដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច

១១៨១- **អៀង ធីរិទ្ធ**មានមន្ទីរពេទ្យស៊ីវិលនៅភ្នំពេញចំនួន៦កន្លែង ដែលស្ថិតនៅក្រោមការត្រួតត្រាដោយផ្ទាល់របស់គាត់ ។ មន្ទីរពេទ្យទាំងនេះរួមមាន ព-១៧ ឬមន្ទីរពេទ្យ ១៧មេសា និងព៦ ឬ មន្ទីរពេទ្យ៦មករា ដែលបន្តិចម្ដងៗបានក្លាយទៅជាកន្លែងទទួលខុសត្រូវសម្រាប់ព្យាបាលជម្ងឺភាគច្រើនដល់យោធាដែលរងរបួស។ ព-៦ កាលពីដើមឡើយ គឺជាមន្ទីរពេទ្យយោធា ដែល បានដាក់ឲ្យស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **អៀង ធីរិទ្ធ** នៅដើមឆ្នាំ១៩៧៧ បន្ទាប់ពីការបោសសំអាតមួយទៅលើបុគ្គលិកគ្រប់មន្ទីរពេទ្យយោធាទាំងអស់ ដែលមកពីភូមិភាគឧត្តរ។ ទោះ

បីជាមន្ទីរពេទ្យឃោធា ភូមិភាគ តំបន់ និងមន្ទីរពេទ្យស្រុកនានា ដែលតាមផ្នែកបច្ចេកទេស ត្រូវបានដកចេញពី ក្នុងរង្វង់សមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ក៏ក្រសួងសង្គមកិច្ចបាន ពង្រីកទំនាក់ទំនងការងារគ្នា យ៉ាងជិតស្និទ្ធជាមួយមន្ទីរពេទ្យឃោធា ភូមិភាគ តំបន់ និងស្រុក និងជាមួយរោងចក្រផលិតឱសថ ក្នុងស្រុកនានានា ជាពិសេសលើការងារស្តីពីការបំពាក់បំប៉ន ទ្រឹស្តីខាងនយោបាយ និងការហ្វឹក ហ្វឺនផ្នែកពេទ្យ ការបែងចែកវត្ថុធាតុដើមថ្នាំពេទ្យ និងសំភារៈបរិក្ខារដែលផលិតចេញពីរោង ចក្រដោយក្រសួងសង្គមកិច្ច ហើយនិងការផ្ទេរបញ្ជូន អ្នកជម្ងឺពីមន្ទីរពេទ្យឃោធាទាំងនោះ ទៅកាន់មន្ទីរពេទ្យស៊ីវិលនានានៅភ្នំពេញ។

១១៨២- ក្រសួងសង្គមកិច្ចក៏មានផងដែរនូវរោងចក្រផលិតថ្នាំពេទ្យ និងមន្ទីរពិសោធន៍ចំនួន៦ដែលស្ថិត នៅក្រោមការត្រួតត្រារបស់ខ្លួន (ផ-១ ដល់ផ-៤, ផ-៦ ដល់ផ-៧) ព្រមទាំងមន្ទីរពិសោធន៍ សម្រាប់កំចាត់ជម្ងឺគ្រុនចាញ់ និងសាលាហ្វឹកហ្វឺនផ្នែកពេទ្យ (ផ-៥)។

## ការគ្រប់គ្រងមិនត្រឹមត្រូវរបស់ក្រសួងសង្គមកិច្ច

១១៨៣- **អៀង ធីរិទ្ធ** បានអភិវឌ្ឍន៍ និងធ្វើជាមេដឹកនាំលើប្រព័ន្ធសុខាភិបាលមួយដែលដំណើរការដោយ មិនមានភាពត្រឹមត្រូវ ដែលមិនគ្រាន់តែខកខានមិនបានបំពេញគោលដៅសំខាន់ ជាសារវ័ន្តរបស់ ខ្លួនប៉ុណ្ណោះទេ ក៏ប៉ុន្តែក្នុងករណីជាច្រើនជាសំខាន់គឺបានធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ទៅៗ ចំពោះអ្នកដែលស្ថិតនៅក្រោមការថែទាំរបស់ខ្លួនទៀតផង។ ក្រោមការគ្រប់គ្រងរបស់ **អៀង ធីរិទ្ធ** លក្ខណៈ សម្បត្តិដែលធ្វើឲ្យជឿទុកចិត្ត និងវណ្ណៈដើមរបស់កម្មាភិបាល គឺវាមាន សារសំខាន់ជាងការហ្វឹកហ្វឺន និងបទពិសោធន៍ខាងផ្នែកពេទ្យទៅទៀត។ នៅក្នុងពេល

ដែលក្រសួងសង្គមកិច្ច បានរក្សាទុកនូវអ្នកបច្ចេកទេសផ្នែកពេទ្យជនជាតិចិនមួយចំនួននោះ **អៀង ធីរិទ្ធ** ភាគច្រើនបានចាត់តាំងកម្មាភិបាលក្មេងៗ ដែលមិនចេះអក្សរ និង/ឬ មិនមានគុណវុឌ្ឍិឲ្យកាន់មុខតំណែងផ្សេងៗនៅក្នុងក្រសួងសង្គមកិច្ច។ មានកូនស្រីវ័យជំទង់របស់ **អៀង ធីរិទ្ធ** ចំនួន៣នាក់ ហើយនិងកូនប្រសារប្រុសរបស់គាត់ដែលគ្មានគុណវុឌ្ឍិ ក៏ត្រូវបានតែងតាំងឲ្យកាន់មុខតំណែងជាន់ខ្ពស់ នៅក្នុងមន្ទីរពេទ្យ និងមន្ទីរពិសោធន៍នានាផងដែរ។ ការតែងតាំងកម្មាភិបាលបែបនេះជាបុគ្គលិកពេទ្យនៅក្នុងមន្ទីរពេទ្យនានា និងនៅតាមមន្ទីរ ពិសោធន៍នានាផង បានបណ្តាលឲ្យអ្នកជម្ងឺស្លាប់ មួយចំនួន និងឲ្យមានការកើនឡើងនូវការឈឺចាប់វេទនាដល់អ្នកជំងឺជាច្រើនទៀត។ អ្នកទាំងឡាយដែលត្រូវបានគេយកមកថែទាំព្យាបាលក្នុងមន្ទីរពេទ្យនានាដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច គឺស្ថិតក្នុងហានិភ័យអំពីស្ថានភាពជម្ងឺរបស់ខ្លួនកាន់តែអាក្រក់ទៅៗ។

១១៨៤- ក្រោមការដឹកនាំរបស់ **អៀង ធីរិទ្ធ** នៃក្រសួងសង្គមកិច្ច មានការពិសោធន៍ស្រាវជ្រាវលើមនុស្សដែលនៅរស់។ ថ្នាំពេទ្យដែលគេធ្វើការស្រាវជ្រាវពិសោធន៍ ត្រូវបានយកមកធ្វើតេស្តសាកល្បងជាមួយអ្នកជម្ងឺនៅតាមមន្ទីរពេទ្យនានា និងនៅពេលខ្លះជាមួយបុគ្គលិក។ ជនរងគ្រោះទាំងឡាយមិនគ្រាន់តែត្រូវបានគេប្រើសម្រាប់ធ្វើតេស្តសាកល្បង អំពីថ្នាំពេទ្យប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានទៅក្លាយជាកម្មវត្ថុសម្រាប់យកទៅធ្វើការបង្ហាញជូននៅក្នុងការហ្វឹកហ្វឺនដល់បុគ្គលិកនានាដែលមកពីទីជនបទ។ ដោយមកពីលទ្ធផលនៃការចាក់បញ្ចូលថ្នាំមិនបានត្រឹមត្រូវ ការប្រើប្រាស់ម្ជុលដែលមិនបានលាងសំអាតសម្លាប់មេរោគ និង/ឬ ការចាក់បញ្ចូលនូវសារធាតុផ្សេងៗ ដូចជាទឹក ឬទឹកដូង ធ្វើឲ្យអ្នកជម្ងឺមួយចំនួនស្លាប់ ឬកើតជម្ងឺបូស(អាប់សែ) ហើម និងឈឺថ្កាត់។

## ការចូលរួម និងការរួមចំណែក

### ការចូលរួមជាទូទៅនៅក្នុងផែនការឧក្រិដ្ឋកម្ម

### ការជួបប្រជុំជាមួយមេដឹកនាំជាន់ខ្ពស់ បកក ដទៃទៀត និងជាមួយមន្ត្រីការទូតនានា

១១៨៥- **អៀង ធីរិទ្ធ** បានធ្វើអន្តរសកម្មភាពជាទៀងទាត់ ជាមួយមេដឹកនាំជាន់ខ្ពស់នានាផ្សេងៗទៀតនៃកម្ពុជាប្រជាធិបតេយ្យ និងបានចូលរួមនៅក្នុងអង្គប្រជុំកម្រិតខ្ពស់នានា ដែលក្នុងនោះគាត់បានចូលរួមចំណែកនៅក្នុងការបង្កើត និងការអនុវត្តន៍នូវគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក។ ទោះជាគាត់មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ក្តី ក៏គាត់បានចូលរួមផ្ទាល់ជាញឹកញាប់ជាមួយនឹងសមាជិកនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែរ។ គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំជាទៀងទាត់នៅ ក-១ ដែលដឹកនាំដោយ ប៉ុល ពត ដែលអមជាមួយដោយ **នួន ជា** **អៀង សារី** និង **ខៀវ សំផន** នៅពេលដែលមានបញ្ហានានាពាក់ព័ន្ធនឹងសង្គមកិច្ច។ គាត់បានចុះទៅពិនិត្យមើល ក-១ ជាញឹកញាប់ ។ លើសពីនេះ គាត់បានចូលរួមនៅក្នុងការប្រជុំប្រចាំខែនៅ ក-៣ ជាមួយ **នួន ជា** **អៀង សារី** និង **ខៀវ សំផន** ។ **អៀង ធីរិទ្ធ** ក៏បានចូលរួមផងដែរនៅក្នុងការប្រជុំជាប្រក្រតីជាមួយ ប៉ុល ពត **នួន ជា** **ខៀវ សំផន** និង **អៀង សារី** នៅឯរដ្ឋសភា។ គាត់បានចូលរួមប្រជុំនៅក្នុង មហាសន្និបាតបក្សក្នុងឆ្នាំ១៩៧៥ ក្នុងការ ប្រជុំនយោបាយនៅបូរីកីឡានៅក្នុងចន្លោះឆ្នាំ១៩៧៦ និង១៩៧៨ ក៏ដូចជានៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីដែលអង្គប្រជុំទាំងនេះបានដាក់ចេញនូវ "សេចក្តីណែនាំផ្សេងៗ" ខាងនយោ បាយ។

១១៨៦- ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងជាមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក មួយរូប **អៀង ធីរិទ្ធ** បានរួមចំណែកនៅក្នុងការអភិវឌ្ឍន៍ និងអនុវត្តនូវគោលនយោបាយរបស់ ប.ក.ក ជាពិសេសនៅ

ក្នុងវិស័យសុខាភិបាល និងសង្គមកិច្ច។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ គាត់បានឡើងថ្លែងនៅក្នុងវេទិកា និងផ្តល់របាយការណ៍នានា យ៉ាងទូលំទូលាយនៅក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក ដែលលើកឡើងផ្តោតតែលើវិស័យសុខាភិបាល និងសង្គមកិច្ច។ តាមរបាយការណ៍នេះ **អៀង ធីរិទ្ធ** បង្ហាញឱ្យឃើញពីការដឹងយ៉ាងទូលំទូលាយ របស់គាត់ទៅលើគ្រប់ផ្នែកទាំងអស់របស់ក្រសួងសង្គមកិច្ច និងបានលើកសំណើជាគោលនយោបាយជាក់ស្តែងដើម្បីសុំឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍អនុម័ត។ គាត់បានលើកឡើងបង្ហាញពីបញ្ហានានាទាក់ទងនឹងសុខាភិបាលក្នុងអង្គប្រជុំលើកទី២នៃគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ដែលជាថ្មីម្តងទៀតបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីសិទ្ធិអំណាច និងការបានដឹងឮរបស់គាត់ក្នុងវិស័យនេះ។ **អៀង ធីរិទ្ធ** ក៏បានរាយការណ៍ផងដែរ អំពីការងារសង្គមកិច្ច នៅឯអង្គប្រជុំរួមនៃមន្ទីរនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជាមានពេល ខ្លះមានការលើកយកបញ្ហាតូចតាចទាក់ទងនឹងសុខាភិបាលមកពិភាក្សាត្រួសៗ នៅក្នុងអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដោយគ្មានវត្តមានរបស់គាត់ក៏ដោយ ក៏ការលើកឡើងបង្ហាញរបស់ **អៀង ធិរិទ្ធ** ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈរដ្ឋមន្ត្រីបានបញ្ជាក់ច្បាស់ថាមុខតំណែងរបស់គាត់គឺជាមន្ត្រីផ្លូវការនៃ ប.ក.ក ដ៏ចំបងមួយរូប ដែលទទួលបន្ទុកខាងសុខាភិបាល និងសង្គមកិច្ចដែរ។

១១៨៧- ក្នុងឋានៈគាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** ក៏តំណាងឱ្យផលប្រយោជន៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផងដែរនៅលើឆាកនៃការងារការទូត។ គាត់គឺជាមេដឹកនាំមួយរូបក្នុងចំណោម "មេដឹកនាំកម្ពុជានានា" ដែលមន្ត្រីការទូតបរទេសទាំងឡាយ ត្រូវជួបជាមួយ ហើយគាត់បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំ ពិធីជប់លៀង ពិធីបុណ្យ និងកិច្ចចរចាយ៉ាង

ច្រើន នៅពេលមកធ្វើទស្សនៈកិច្ចជាផ្លូវការ។ គាត់បានរៀបចំជាដំណើរទស្សកិច្ចជាច្រើន សម្រាប់អ្នកមកធ្វើទស្សនៈកិច្ចនៅតាមតំបន់នានារបស់កម្ពុជាប្រជាធិបតេយ្យ និងរួមទាំងរោងចក្រផលិតឱសថ និងវាយនភណ្ឌ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។ **អៀង ធីរិទ្ធ** បានថ្លែងសន្ទរកថាទៅកាន់ឥស្សរជនបរទេសនានា នៅក្នុងពិធីទទួលភ្ញៀវជាផ្លូវការជាច្រើនលើកច្រើនសារ ។

## ការជួបប្រជុំនានាជាមួយ ឬការចាត់ចែងគ្រប់គ្រងកម្មាភិបាលថ្នាក់ក្រោម

១១៨៨- វិសាលភាពដ៏ទូលំទូលាយនៃតំណែងរបស់ក្រសួងសង្គមកិច្ច និងមុខតំណែងដ៏មានឥទ្ធិពល របស់ **អៀង ធីរិទ្ធ** នៅក្នុងក្រសួងនេះ ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ដោយលក្ខណៈ និងកម្រិតនៃសកម្មភាពផ្សេងៗរបស់គាត់។ ក្នុងការកាន់តួនាទីរបស់គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច គាត់បានអនុវត្តនូវឥទ្ធិពលក្នុងកំរិតយ៉ាងធំធេងទៅលើមន្ទីរពេទ្យ និងកន្លែងផលិត ឱសថនានានៅក្នុងទីក្រុងភ្នំពេញ ជាពិសេស សកម្មភាពនេះស្តែងឡើងតាមរយៈការប្រជុំជាទៀងទាត់ ការធ្វើអធិការកិច្ច និងការត្រួតមើលពីលើជាប្រចាំ ។

## ទស្សនកិច្ចតាមមន្ទីរពេទ្យ ការចុះពិនិត្យតាមរោងចក្រ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី

១១៨៩- **អៀង ធីរិទ្ធ** បានចុះធ្វើទស្សនកិច្ចនៅតាមបណ្តាមន្ទីរពេទ្យនានានៅទីក្រុងភ្នំពេញ ស្ទើរតែរៀងរាល់ថ្ងៃ។ ពេលទស្សនកិច្ច គាត់បានពិនិត្យមើលមន្ទីរពេទ្យទាំងនោះ និងសួរសុខទុក្ខអ្នកជម្ងឺ។ ក្នុងអំឡុងពេលនៃទស្សនៈកិច្ចរបស់គាត់ទៅកាន់មន្ទីរពេទ្យក្រុង គាត់បានចូលរួមដោយផ្ទាល់ និងធ្វើជាប្រធានកិច្ចប្រជុំយ៉ាងទៀងទាត់ ដែលនៅក្នុងកិច្ចប្រជុំទាំងនេះ គាត់បានផ្តល់ការណែនាំអំពីការងាររបស់មន្ទីរពេទ្យ និងបំផុសបុគ្គលិកពេទ្យឲ្យខំធ្វើការ **អៀង**

**ធីរិទ្ធ** ក៏បានជួបជាមួយផ្នែកគ្រប់គ្រងមន្ទីរពេទ្យនីមួយៗជាទៀងទាត់ផងដែរ។ គាត់ មានសិទ្ធិដក និងចាត់តាំងបុគ្គលិកមន្ទីរពេទ្យ ហើយគាត់បានធ្វើដូច្នេះយ៉ាងទៀងទាត់ ព្រមទាំងចេញបញ្ជាផ្សេងៗទាក់ទិនប្រតិបត្តិការរបស់មន្ទីរពេទ្យ។ គាត់ក៏បានធ្វើការប្រជុំនៅមន្ទីរពេទ្យដែរដោយប្រកាសថា មានបុគ្គលិកមួយចំនួនត្រូវបានចាត់ទុកថា"ជនក្បត់" និងរំពឹងទុកថា បុគ្គលិកពេទ្យនឹងរាយការណ៍ជូនគាត់អំពីការងាររបស់ពួកគេ។ គាត់បានទទួលរបាយការណ៍ និងសេចក្ដីឆ្លើយឆ្លងផ្សេងៗពីគ្រប់មន្ទីរពេទ្យ សាលាពេទ្យ និងរោងចក្រផលិតឱសថទាំងអស់។ **អៀង ធីរិទ្ធ** ក៏បានចុះទស្សនកិច្ចសហគ្រាសឱសថជាច្រើនផងដែរ។

១១៩០- បន្ថែមលើកិច្ចប្រជុំជាញឹកញាប់ជាមួយបុគ្គលិក និងអ្នកគ្រប់គ្រងមន្ទីរពេទ្យ និងការហ្វឹកហ្វឺនដល់បុគ្គលិក និងអ្នកគ្រប់គ្រងមន្ទីរពេទ្យ **អៀង ធីរិទ្ធ** បានទាមទារឲ្យមានវត្តមានរបស់បុគ្គលិកក្រសួងនិងមន្ទីរពេទ្យពេលប្រជុំទៀងទាត់នៅក្រសួងសង្គមកិច្ច។ ក្នុងពេលប្រជុំគាត់ស្នើរបាយការណ៍អំពីប្រតិបត្តិការរបស់មន្ទីរពេទ្យ ចេញសេចក្ដីណែនាំទាក់ទងនឹងការងាររួមមាន ការស្នើឲ្យបុគ្គលិកពេទ្យតាមដានលើអ្នកដទៃ និងបានប្រកាសឈ្មោះបុគ្គលិកពេទ្យណាដែលត្រូវបានចាប់ខ្លួន។ គាត់បានទូន្មានឲ្យបុគ្គលិកសកម្មការងារ និងផ្ដល់យោបល់អំពីរបៀបថែទាំអ្នកជម្ងឺ។ **អៀង ធីរិទ្ធ** បានបំពេញបន្ថែមលើកិច្ចប្រជុំទាំងនេះ តាមរយៈការបង្រៀនវគ្គអប់រំគោលនយោបាយដោយផ្ទាល់នៅក្រសួងសង្គមកិច្ច ដូចបានពិភាក្សានៅក្នុងផ្នែកបំពាក់បំប៉នយោបាយ និងវគ្គរៀនសូត្រ ។

## ទស្សនៈកិច្ចតាមការដ្ឋាន

១១៩១- **អៀង ធីរិទ្ធ** បានចុះពិនិត្យតាមការដ្ឋាននានានៅជនបទ និងបានឃើញលក្ខខណ្ឌអមនុស្សធម៌នានានៅលើអ្នកធ្វើការ ដូចនេះក៏បានឃើញការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា កំពុងត្រូវបានដាក់ឱ្យអនុវត្ត។ គាត់បានជួយសម្រួលដល់ដំណើរទស្សនកិច្ចនានាទៅកាន់ផ្នែកផ្សេងៗនៃប្រទេសដើម្បីអមដំណើរគណៈប្រតិភូបរទេស ចិន ឡាវ វៀតណាម ឬរ៉ូម៉ានី។ គាត់បានអមដំណើរគណៈប្រតិភូឡាវ ទៅកាន់ភូមិភាគបូព៌ា កំពង់ចាម កំពង់ធំ សៀមរាប និងអង្គរវត្ត។ ក្នុងទស្សនកិច្ចនេះ គាត់បានទៅពិនិត្យ ផ្ទាល់នៅការដ្ឋានទំនប់ ១មករាជាទីកន្លែងដែលគាត់បានឃើញអ្នកធ្វើការដោយបង្ខំកំពុងធ្វើការងារ និងនៅស្រុកចំការលើ។ បក្សក៏បានចុះពិនិត្យតាមសហករណ៍ជាកន្លែងដែលគេបានឃើញវាលស្រែ និងការចាត់ចែងជីវភាពប្រមូលផល ការដ្ឋានអាងទឹកបឹងក្រចាប់ រោងចក្រចំការកៅស៊ូជប់ និងចំការកៅស៊ូចំការអណ្តូង។ **អៀង ធីរិទ្ធ** បានធ្វើដំណើរ ជាមួយគណៈប្រតិភូវៀតណាម ទៅពិនិត្យមើលភូមិភាគបូព៌ា និងឧត្តរ រួមទាំង ខេត្តសៀមរាប។ ក្នុងដំណើរទស្សនកិច្ចនេះ គាត់បានសង្កេតឃើញនារីៗទើបតែបានបញ្ចប់ ការងារដកស្ទូងស្រូវរដូវវស្សា លើកទំបន់ ជីកប្រឡាយ អាងទឹក និងបណ្តាញភ្លឺស្រែ។ ជាការបន្ថែម គាត់បានធ្វើដំណើរទៅសៀមរាបជាមួយ **អៀង សារី** ជាមួយគណៈប្រតិភូឡាវ និងក៏បានធ្វើដំណើរទៅកំពង់ចាមដោយខ្លួនឯងផងដែរ ។

### ការបំពាក់បំប៉នគោលនយោបាយ និងវគ្គអប់រំគោលនយោបាយ

១១៩២- ក្នុងនាមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បានដឹកនាំការប្រជុំ និងវគ្គសិក្សាអប់រំជាញឹកញាប់ដើម្បីអនុវត្តគោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា និងដើម្បីពង្រឹងការអនុវត្តន៍វិន័យនៅក្នុងក្រសួងសង្គមកិច្ច។ វគ្គសិក្សាអប់រំ សន្និបាត និងកិច្ចប្រជុំនានា ត្រូវបានគេធ្វើឡើងជា

ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំត្រីមាស ឬប្រចាំឆ្នាំ អាស្រ័យតាមបំណង។ កិច្ចប្រជុំខ្លះនៃកិច្ចប្រជុំទាំងនេះ ត្រូវបានធ្វើឡើងនៅតាមផ្នែកខុសៗគ្នានៃក្រសួងសង្គមកិច្ច ដូចជា ធ២ ធ៥ ក១ ក២ និងមន្ទីរពេទ្យ១៧មេសា។ យ៉ាងហោចណាស់ សន្និបាតប្រចាំឆ្នាំមួយរបស់ក្រសួងសង្គមកិច្ច ដែលបាននាំធ្វើដោយ **អៀង ធីរិទ្ធ** ត្រូវបានចូលរួមដោយមន្ត្រីថ្នាក់ខ្ពស់ដូចជា ប៉ុល ពត និង នួន ជា ។

១១៩៣- តាមវគ្គសិក្សាអប់រំគោលនយោបាយទាំងនេះ តាំងពីដើមខែមិថុនា ១៩៧៥ មក **អៀង ធីរិទ្ធ** បានអនុម័តយល់ព្រម និងធ្វើយុត្តិកម្មចំពោះការជម្លៀសដោយបង្ខំនូវទីក្រុងនានា ការបង្កើតសហករណ៍ និងការបំបាត់ចោលលុយកាក់ ដើម្បីជាឧបករណ៍ប្រឆាំងនឹងនាយទុន និងខ្មាំង។ **អៀង ធីរិទ្ធ** ក៏បានធ្វើយុត្តិកម្មចំពោះការបណ្ដេញចេញនូវប្រជាជនវៀតណាម ផ្ដល់បាឋកថាពីការវាយប្រហារប្រឆាំងនឹងវៀតណាម [redacted]។ នៅក្នុងកិច្ចប្រជុំរួមមួយរបស់មន្ទីរ **អៀង ធីរិទ្ធ** បានថ្លែងថា: "សមមិត្តយកគោលការណ៍របស់បក្សយកមកដាក់លើក្បាលគ្រែរបស់មិត្តអនុវត្តទៅ។ នៅខាងបក្ស ឬនៅខាងយួន"។

១១៩៤- ស្ថិតនៅក្រោមការដឹកនាំរបស់ **អៀង ធីរិទ្ធ** នៃក្រសួងសង្គមកិច្ច គឺមានការពង្រឹងការអនុវត្តន៍វិន័យ និងគោលនយោបាយរបស់បក្សដែលស៊ីសង្វាក់គ្នា ដោយមានការតម្រូវឲ្យកម្មាភិបាលនានាយកចិត្តទុកដាក់ទៅលើសកម្មភាពនានារបស់ពួកខ្មាំង និងបើកឲ្យធ្វើការទិទៀន។ នៅក្នុងវគ្គបំពាក់បំប៉នននយោបាយនានា **អៀង ធីរិទ្ធ** បានពិភាក្សាអំពីពួកដែលត្រូវបានគេចោទថាក្បត់ និងអំពីការចាប់ខ្លួនពួកគេ ។ **អៀង ធីរិទ្ធ** ក៏បានធ្វើការប្រកាសបកអាក្រាតដោយជាក់លាក់ផងដែរដល់កម្មាភិបាលជាន់ខ្ពស់នៃក្រសួងសង្គមកិច្ច ដែលត្រូវបានគេផ្ដោតមុខសញ្ញាថាជា

ពួកក្បត់។ ដែលរួមមាន ឡេងពីសី *ហៅ* សី ដែលជាប្រធានពេទ្យ១៧ មេសា និងជាសមាជិកនៃគណៈកម្មាធិការក្រសួងសង្គមកិច្ច និង ស៊ូ ប្រធាន ក-២ និងជាសមាជិកនៃគណៈកម្មាធិការក្រសួងសង្គមកិច្ច។ គាត់ក៏បានប្រកាសបកអាក្រាតផងដែរ អំពីមេដឹកនាំនៃ ប.ក.ក នានាដែលត្រូវបានគេចោទប្រកាន់ថាជាពួកក្បត់ដែលរួមមាន សោ ភឹម លេខានៃភូមិភាគបូព៌ា, មូល សម្បត្តិ *ហៅ* រស់ ញឹម លេខាភូមិភាគពាយ័ព្យ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ ហើយនិងមេដឹកនាំដទៃជាច្រើនទៀត។ **អៀង ធីរិទ្ធ** បានធ្វើការណែនាំដល់ពួកពលករទាំងឡាយកុំឱ្យធ្វើតាមគំរូរបស់ពួកដែលគេចោទប្រកាន់ថាក្បត់ ណែនាំដល់ផ្នែកជំនាញនីមួយៗ"ឱ្យតាមដានការងាររបស់ខ្លួន"ឱ្យលួចយកការណ៍ពីគ្នាទៅវិញទៅមក និងឱ្យប្រកាសបកអាក្រាតពួកក្បត់។ ក្រោយពេលដែលឈ្មោះរបស់ពួកក្បត់ត្រូវបានគេប្រកាសនៅក្នុងពេលប្រជុំទាំងនេះ អ្នកដែលជាប់ពាក់ព័ន្ធនឹងពួកក្បត់ត្រូវបានគេឱ្យក្រោកឈរ និងធ្វើការសន្យាចំពោះបក្ស។ នៅក្នុងពេលប្រជុំបែបនេះ បុគ្គលិកពេទ្យ និងប្រធានៗមន្ទីរពេទ្យមកពីបណ្តាខេត្តនានាបានសរសេរប្រវត្តិរូបរបស់ខ្លួននិងធ្វើស្វ័យទិទៀន និងទិតៀនពីគុណសម្បត្តិគុណ និងវិបត្តិរបស់ខ្លួន និងអ្នកធ្វើការជាមួយខ្លួន និងត្រូវបានគេប្រាប់ឱ្យប្រុងប្រយ័ត្នចំពោះខ្មាំង និងឱ្យស្មោះត្រង់ចំពោះបក្ស ។

១១៩៥- **អៀង ធីរិទ្ធ** ក៏បានបើកការប្រជុំ និងវគ្គសិក្សានយោបាយនានាផងដែរ ដើម្បីចាត់ចែងគ្រប់គ្រងលើកម្លាំងពលករ ហើយនិងមន្ទីរនានារបស់ក្រសួងសង្គមកិច្ច។ គាត់បានចូលរួមបើកវគ្គបានកោះអញ្ជើញ និងបានណែនាំ អំពីវគ្គហ្វឹកហ្វឺនផ្នែកពេទ្យ និងនយោបាយនានាក៏ដូចជាបានធ្វើជាអធិបតីដឹកនាំជាញឹកញាប់នៅក្នុងកិច្ចប្រជុំនានា ជាប្រចាំជាមួយបុគ្គលិកពេទ្យ។ គោលបំណងនៃកិច្ចប្រជុំទាំងនេះគឺសំដៅ "ធ្វើការលាងជម្រះសតិអារម្មណ៍

របស់ប្រជាជន"។ បុគ្គលិកមកពីបណ្ដាមន្ទីរពេទ្យតំបន់ ហើយនិងរោងចក្រផលិតឱសថនានា ត្រូវបានគេបញ្ជូនមកកាន់ទីក្រុងភ្នំពេញ ដើម្បីធ្វើការបំពាក់បំប៉នផ្នែកនយោបាយ និងហ្វឹកហ្វឺនផ្នែកពេទ្យដោយក្រសួងសង្គមកិច្ច (ហើយនៅក្នុងចំណោមពួកគេទាំងនេះ មានខ្លះត្រូវបានជ្រើសរើសដោយ **អៀង ធីរិទ្ធ**)។ នៅក្នុងកិច្ចប្រជុំទាំងនេះនៅក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បានធ្វើការប្រកាសជូនដំណឹងអំពីឈ្មោះរបស់អ្នកជំនាញផ្នែកសុខាភិបាល ដែលត្រូវបានគេដាក់ឈ្មោះថាជា "ពួកក្បត់" ។

## ការចូលរួមប្រព្រឹត្តិនៅក្នុងព្រឹត្តិការណ៍ឧក្រិដ្ឋជាក់លាក់

## ការជម្លៀសដោយបង្ខំ

១១៩៦- **អៀង ធីរិទ្ធ** គឺបានទាំងដឹង បានទាំងគាំទ្រនូវសេចក្ដីសម្រេចរបស់ ប.ក.ក ដើម្បីធ្វើការជម្លៀសទីក្រុងភ្នំពេញដោយបង្ខំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គាត់បានទទួលស្គាល់ថា រដ្ឋាភិបាលរបស់គាត់មានគោលនយោបាយដែលកំណត់យ៉ាងច្បាស់លាស់មួយ ស្ដីពីការជម្លៀសនៅក្នុងឱកាសពីរដាច់ដោយឡែកពីគ្នានៅឆ្នាំ១៩៨០គាត់បានទទួលសារភាពថាគោលនយោបាយនេះ បានបណ្ដាលឲ្យមានការកើតឡើងនូវការជម្លៀសប្រជាជន។ គាត់បានថ្លែងថាគាត់ "មិនបដិសេធទេថាយើងបានធ្វើការជម្លៀសប្រជាជនទីក្រុងភ្នំពេញទាំងអស់ ឲ្យទៅកាន់ទីជនបទ"។ **អៀង ធីរិទ្ធ** ក៏បានទទួលស្គាល់ផងដែរថា ពួកអ្នកជម្លៀសមិនចង់ និងមិនពេញចិត្តនឹងការជម្លៀសនេះទេ។

## ពលកម្មដោយបង្ខំ

១១៩៧- **អៀង ធីរិទ្ធ** បានសម្រេចចិត្ត បានធ្វើផែនការ ឬ បានរៀបចំឱ្យមានការជម្លៀសបុគ្គលិកក្រសួង ដោយបង្ខំឱ្យទៅកាន់ការដ្ឋានលត់ដំ ឬការដ្ឋានកសាងខ្លួន ដោយរួមទាំងអាកាសយានដ្ឋាន ខេត្តកំពង់ឆ្នាំង ពេជ្រនិល ស្រែអំបិល និងវាលរិញ។ ការដ្ឋានកសិកម្មរបស់ក្រសួងសង្គមកិច្ចនៅតាខ្មៅ និងព្រែកក្តាម ក៏ត្រូវបានគេប្រើប្រាស់សម្រាប់ដាក់ទណ្ឌកម្ម ឬធ្វើការកសាងខ្លួនដល់ពួកកម្មាភិបាល តាមរយៈពលកម្មដោយបង្ខំ។ មូលហេតុនានាដែលបុគ្គលិកក្រសួងនេះអាចនឹងត្រូវបានបញ្ជូនឱ្យទៅធ្វើការលត់ដំ ឬធ្វើការកសាងខ្លួន រួមមានការធ្វើឱ្យមានកំហុសឆ្គង ការមិនស្តាប់តាមបញ្ជាផ្សេងៗ ការបំពានលើវិន័យ ជាអ្នកដែលមកពីភូមិភាគបូព៌ាជាអ្នកដែលមានពាក់ព័ន្ធជាមួយនឹងមនុស្សដែលមាននិន្នាការជាអ្នកខុសសីលធម៌ ឬដោយបានរស់នៅក្នុងតំបន់ដែលត្រួតត្រាដោយសាធារណរដ្ឋខ្មែរ ឬដោយបានធ្វើការឱ្យរបបសាធារណរដ្ឋខ្មែរ។ នៅពេលដែលគោលនយោបាយបោសសម្អាតពួកភូមិភាគបូព៌ាឱ្យអស់ លើកលែងតែបុគ្គល "ស្អាតស្អំ" ដែលបានជ្រើសរើសមួយចំនួនប៉ុណ្ណោះត្រូវបានអនុវត្តនោះ ពួកកម្មាភិបាលក្រសួងសង្គមកិច្ចមួយចំនួនធំមកពីភូមិភាគបូព៌ាត្រូវបានបង្ខំឱ្យឡើងឡានធំៗចាកចេញឱ្យអស់។ នៅក្នុងអង្គភាពមួយនោះ មនុស្សទាំងអស់ចំនួន១២០នាក់មកពីភូមិភាគបូព៌ាត្រូវបានបញ្ជូនដើម្បីឱ្យទៅធ្វើការលត់ដំ។ នៅក្នុងអង្គភាពមួយផ្សេងទៀតដែលមានសមាជិកទាំងអស់ចំនួន៣០០នាក់ដែលមកពីភូមិភាគបូព៌ាត្រូវបានដកចេញ លើកលែងតែប្រាំនាក់ប៉ុណ្ណោះ ។

## ការធ្វើឱ្យទៅជាទាសករ និងលក្ខខណ្ឌអមនុស្សធម៌

១១៩៨- ដូចដែលបានពិពណ៌នានៅក្នុងផ្នែកការជម្លៀស និងពលកម្មដោយបង្ខំ កម្មវិធីធ្វើឱ្យមហាជនក្លាយទៅជាទាសករ ដែលស្ថាបនាឡើងដោយ ប.ក.ក បានចេញជាលទ្ធផលទៅជាការបង្ខាំងដោយបង្ខំមួយ ទៅលើប្រជាជនទាំងមូលឱ្យនៅក្នុងសហករណ៍នានាតាមទីជនបទផ្សេងៗ ដែលចាត់ចែងគ្រប់គ្រងដោយប.ក.កដែលនៅក្នុងនោះបក្សបានត្រួតត្រាទាំងស្រុង លើការរស់នៅរបស់ពួកទាសករទាំងនោះ។ លក្ខខណ្ឌនានាដែលនៅក្រោមលក្ខខណ្ឌទាំងនោះ ប្រជាជនដែលត្រូវបានគេធ្វើឱ្យទៅជាទាសករ ត្រូវបានគេបង្ខំឱ្យរស់នៅ និងបង្ខំឱ្យធ្វើការ បណ្តាលឱ្យមានការស្លាប់យ៉ាងច្រើននៅតាមទីតាំងនានាដែលឋិតនៅក្រោមកិច្ចស៊ើបសួរ។ ភាគច្រើននៃការស្លាប់ទាំង នោះ គឺបណ្តាលមកពីកង្វះខាតនូវការថែទាំផ្នែកវេជ្ជសាស្ត្រ និងថ្នាំពេទ្យ។ **អៀង ធីរិទ្ធ** បានធ្វើវិភាគទានចូលរួមនៅក្នុងលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗ ដែលមានលើសលប់ នៅតាមជំរំ និងការដ្ឋានពលកម្មដោយបង្ខំទាំងឡាយ ដោយរួមទាំងទីតាំងនានា ដែលឋិតនៅក្រោមកិច្ចស៊ើបសួរផងដែរ តាមរយៈការខកខានដោយចេតនារបស់គាត់ក្នុងការផ្តល់នូវថ្នាំពេទ្យឱ្យបានគ្រប់គ្រាន់ និងដោយប្រសិទ្ធភាពជូនដល់ប្រជាជនដែលត្រូវបានចាប់បង្ខំឱ្យនៅទីនោះ ។

១១៩៩- ខណៈដែលកម្មាភិបាលរបស់ បកក ត្រូវបានដាក់បន្ទុកឱ្យទទួលខុសត្រូវលើផ្នែកថ្នាំពេទ្យ និងការថែទាំ សុខភាព **អៀង ធីរិទ្ធ** បានទទួលខុសត្រូវចំពោះ ការផលិត ការផ្គត់ផ្គង់ និងការចែកចាយឱសថ នៅទូទាំងប្រទេស។ តាមរយៈការផ្តល់ថ្នាំពេទ្យមិនឱ្យគ្រប់គ្រាន់ និងដែលគ្មានប្រសិទ្ធភាព គាត់បានចូលរួមចំណែកនៅក្នុងការរីកសាយកាន់តែច្រើនឡើងនូវលក្ខខណ្ឌអមនុស្សធម៌ នៅក្នុងភូមិភាគ។ ជាញឹកញយ ថ្នាំពេទ្យដែលត្រូវបានចែកចាយទៅតាម

តំបន់នានា គឺជាថ្នាំពេទ្យដែលពុំមានប្រសិទ្ធភាព ឬដែលមានគ្រោះថ្នាក់ ដោយហេតុថា **អៀង ធីរិទ្ធ** បានជំរុញឱ្យមានការប្រើប្រាស់នូវឱសថបុរាណ និងឱសថដែលត្រូវធ្វើពិសោធន៍ ដោយពុំមានការនាំចូលថ្នាំពេទ្យ ឬការផលិតថ្នាំពេទ្យណាមួយដែលមានប្រសិទ្ធភាព ទុកដើម្បីធ្វើការចែកចាយឡើយ។ **អៀង ធីរិទ្ធ** បានបញ្ជាឱ្យមានការផលិតថ្នាំជារបៀបពិសោធ ដែលជាញឹកញយត្រូវបានគេហៅថាជា "ថ្នាំអាចម៍ទន្សាយ ឬគ្រាប់ថ្នាំអាចម៍ទន្សាយ" ដែលធ្វើឡើងដោយការចម្រាញ់ពីដើមឈើ ដូចជាដើមដំឡូងមីជាដើម។ គាត់ក៏បានជំរុញផងដែរឱ្យមានការចែកចាយ និងការប្រើប្រាស់នូវផលិតផលបែបនេះនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ បើទោះបីជាគាត់បានដឹងថាផលិតផលទាំងនោះ ពុំមានប្រសិទ្ធភាពអ្វីទាល់តែសោះ ឬមានគុណភាពទាបបំផុត និងដោយពុំត្រូវបានយកទៅធ្វើពិសោធន៍ឱ្យបានត្រឹមត្រូវសម្រាប់ជាការប្រើប្រាស់របស់មនុស្សក៏ឡើយ

១២០០- **អៀង ធីរិទ្ធ** ត្រូវបានគេឱ្យដឹងជាមុនអំពីកង្វះខាតយ៉ាងធ្ងន់ធ្ងរនូវការផ្គត់ផ្គង់ថ្នាំពេទ្យ និងលក្ខខណ្ឌមិនល្អប្រសើរនៅតាមការដ្ឋាន និងនៅតាមជំរំពលកម្មដោយបង្ខំនានា នៅក្នុងអំឡុងពេលដែលឋិតនៅក្រោមការស៊ើបសួរនេះ។ ដូចដែលបានកត់សម្គាល់ខាងលើ គាត់បានទៅធ្វើទស្សនកិច្ចជាញឹកញាប់នៅតាមការដ្ឋានផ្សេងៗ និងអាចមានលទ្ធភាពនៅក្នុងការបានឃើញពួកពលករបានទទួលរងនូវលក្ខខណ្ឌទាំងនោះ។ នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់គាត់ទៅកាន់ទំនប់១មករា គាត់ត្រូវបានគេប្រាប់ព័ត៌មានថាមានការខ្វះខាតថ្នាំពេទ្យ ប៉ុន្តែជាការឆ្លើយតប គាត់បែរជាបានបញ្ជាឱ្យមានការផលិតថ្នាំដែលពុំមានសុវត្ថិភាពទៅវិញ។ ក្រោយមកទៀត នៅក្នុងដំណើរទស្សនកិច្ចរបស់គាត់ទៅកាន់ភូមិភាគពាយ័ព្យនៅពាក់កណ្តាល ឆ្នាំ១៩៧៦ **អៀង ធីរិទ្ធ** បានឃើញផ្ទាល់នូវលក្ខខណ្ឌដ៏គួរឱ្យរន្ធត់នានា ដែលប្រជាជនមូលដ្ឋាន

បានរស់នៅ។ លើសពីអ្វីៗទាំងអស់ គាត់បានឃើញគេបង្ខំពួកប្រជាជនឱ្យធ្វើការនៅក្រោមកំដៅយ៉ាងខ្លាំងបំផុត ដោយមិនគិតអំពីស្ថានភាពសុខភាព ពិការភាព ឬអាយុរបស់ពួកគេឡើយ និងដោយពុំបានផ្តល់នូវកន្លែងស្នាក់នៅឱ្យបានត្រឹមត្រូវទេ។ គាត់ក៏បានឃើញដោយផ្ទាល់ផងដែរថាមានជម្ងឺផ្សេងៗបានរីករាលដាល ដោយមានមនុស្សជាច្រើននាក់ បានទទួលរងនូវការឈឺចាប់ដោយសារជម្ងឺរាគរូស និងជម្ងឺគ្រុនចាញ់។ ដូចដែលបានពិពណ៌នានៅក្នុងផ្នែកជម្លៀសដោយបង្ខំ គឺមានជនស៊ីវិលច្រើនប្រមាណជាមួយលាននាក់ ត្រូវបាន ប.ក.ក ជម្លៀសដោយបង្ខំឱ្យទៅកាន់ភាគពាយ័ព្យ ដែលជាផ្នែកមួយនៃគោលនយោបាយ ប្រមូលផ្តុំមហាជននិងពលកម្មដោយបង្ខំ។ **អៀង ធីរិទ្ធ** បានសន្និដ្ឋានថាលក្ខខណ្ឌទាំងនេះ គឺបណ្តាលមកពីពួកខ្មាំងដែលបានជ្រៀតចូលទៅក្នុងភូមិភាគពាយ័ព្យ។ គាត់ពុំដែលបានចាត់វិធានការណាមួយដើម្បីជួយដោះស្រាយលក្ខខណ្ឌនានា ដែលគាត់បានឃើញដោយផ្ទាល់ឡើយ។

## អាពាហ៍ពិពាហ៍ដោយបង្ខំ

១២០១- **អៀង ធីរិទ្ធ** បានអនុវត្តនៅក្នុងក្រសួងសង្គមកិច្ចនូវគោលនយោបាយរបស់ ប.ក.ក ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ គោលនយោបាយ បានផ្តល់នូវការរៀបចំឱ្យមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលធ្វើឡើងដោយប្រធានអង្គភាព និងពួកកម្មាភិបាល ហើយដែលមានមូលដ្ឋាននៅលើសញ្ញាណមួយដែលថា បក្សគឺល្អប្រសើរបំផុតក្នុងការវាយតម្លៃពីភាពសមស្របនៃអាពាហ៍ពិពាហ៍។ **អៀង ធីរិទ្ធ** ខ្លួនគាត់ផ្ទាល់បានរៀបចំ និងយល់ព្រមអនុញ្ញាតឱ្យមានការអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមានការជាប់ទាក់ទងទៅនឹងឯកត្តជននានាដែលធ្វើការនៅក្រោមការគ្រប់គ្រងរបស់គាត់នៅឯក្រសួងសង្គមកិច្ច ក៏ដូចជាសមាជិកនានានៃបុគ្គលិករបស់គាត់ផ្ទាល់

ផងដែរ។ [redacted]។ ការស្តែងចេញឲ្យឃើញមួយទៀតពីគោលនយោបាយ ស្តីពីអាពាហ៍ពិពាហ៍ ដោយបង្ខំគឺ ការគាបសង្កត់ខាងផ្លូវភេទ ដែលត្រូវបានអនុវត្តនៅក្នុងក្រសួងសង្គមកិច្ចផងដែរ មានភស្តុតាងដែលថា ពួកទាំងឡាយណាដែលមានជាប់ទាក់ទិននឹងការមានទំនាក់ទំនងខាងផ្លូវភេទដោយពុំមានការអនុញ្ញាតនៅឯមន្ទីរពេទ្យ៦មករា ត្រូវបានចាប់ខ្លួនភ្លាមៗ ហើយបន្ទាប់មកត្រូវបានសម្លាប់ជាចំហរនៅចំពោះមុខពួកអ្នកជម្ងឺ និងពួកបុគ្គលិក។

## ការបោសសម្អាតកម្មាភិបាល

១២០២- **អៀង ធីរិទ្ធ** បានអនុវត្តនូវគោលនយោបាយរបស់ ប.ក.ក ស្តីពីការចាប់ខ្លួន និងសម្លាប់ជន ដែលគេសង្ស័យថាក្បត់ និងពួកខ្មាំងអង្គភាពផ្សេងៗ នៅក្នុងក្រសួងសង្គមកិច្ច។ គាត់មានសិទ្ធិអំណាចនៅក្នុងការបោសសម្អាត និងស៊ើបការណ៍ពីបុគ្គលិកក្រសួងសង្គមកិច្ច ព្រមទាំងចាត់ការផ្ទាល់ធ្វើការបោសសម្អាតដោយការកំណត់អត្តសញ្ញាណបុគ្គលិក ដើម្បីធ្វើការដកចេញ និងចាប់ខ្លួនពីអង្គភាពផ្សេងៗនៅក្នុងក្រសួងសង្គមកិច្ច។ ការបោសសម្អាតទាំងនេះ គឺមានលក្ខណៈធំទូលាយ និងគ្របដណ្តប់ទៅលើបុគ្គលិកក្រសួងសង្គមកិច្ចធម្មតានៅទូទាំងប្រទេស ក៏ដូចជាពួកកម្មាភិបាលជាន់ខ្ពស់ផងដែរ។ ការចាប់ខ្លួនភ្លាមៗ និងការបាត់ខ្លួនពួកបុគ្គលិកនៅតាមមន្ទីរពេទ្យមួយចំនួននៅក្នុងក្រសួងសង្គមកិច្ចរបស់ **អៀង ធីរិទ្ធ** បានកើតឡើងជាបន្តបន្ទាប់ទាំងយប់ទាំងថ្ងៃ។ ការចាប់ខ្លួននៅក្នុងអង្គភាពនានានៃក្រសួងសង្គមកិច្ច បាន

កើតឡើងទៅតាមអ្វីដែល ឌុច បានយោងថាជា "ប្រព័ន្ធមួយតាមធម្មតា" ដែលគេត្រូវដកកម្មាភិបាលជាន់ខ្ពស់ចេញជាមុនសិន ទើបមានការចាប់ខ្លួនទាំងក្រុមៗជាខាងក្រោយ។ ដូចជាគ្រប់អង្គភាពទាំងអស់នៃប.ក.ក ឬកម្ពុជាប្រជាធិបតេយ្យដូច្នោះដែរ ចម្លើយសារភាពនានាត្រូវបានគេផ្ញើមកពីមន្ទីរស-២១ ជូនទៅឱ្យ **អៀងធីរិទ្ធ** ដើម្បីជូនព័ត៌មានដល់គាត់អំពីសកម្មភាពខ្មាំងនៅតាមបណ្ដាអង្គភាពផ្សេងៗដែលឋិតនៅក្រោមការត្រួតត្រារបស់គាត់ និងដើម្បីឱ្យគាត់អាចសម្រេចចិត្តបាន ថាតើចាំបាច់ត្រូវមានការចាប់ខ្លួននៅលើកក្រោយទៀតដែរ ឬមួយយ៉ាងណា។ គាត់បានណែនាំបុគ្គលិកម្នាក់ៗ ឱ្យតាមឃ្លាំមើលសកម្មភាពរបស់អ្នកផ្សេងទៀតដែលមានឈ្មោះនៅក្នុងចម្លើយសារភាព ឬដែលត្រូវបានគេសង្ស័យថាជាពួកក្បត់។ ការបោសសម្អាតទាំងនេះមានរាប់បញ្ចូលទាំងការចាប់ខ្លួន និងការដកពួកកម្មាភិបាលភាគច្រើននៃក្រសួងសង្គមកិច្ចដែលមកពីភូមិភាគបូព៌ា។ បុគ្គលិកក្រសួងសង្គមកិច្ចត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់ការដ្ឋានការងារនានា ឬទៅជំរំលត់ដំ ឬទៅមន្ទីរស-២១ នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ **អៀង ធីរិទ្ធ** ។

១២០៣- យ៉ាងហោចណាស់ មានបុគ្គលិកក្រសួងសង្គមកិច្ចចំនួន ១២០ នាក់ ត្រូវបានជាប់ឃុំឃាំង និងត្រូវបានសម្លាប់នៅមន្ទីរស-២១។ **អៀង ធីរិទ្ធ** បានត្រួតត្រា និងបានជួយសម្រួលដោយផ្ទាល់ក្នុងការចាប់ខ្លួនកម្មាភិបាលបែបនេះ ដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយនឹងមន្ទីរស-២១។

[redacted]

[redacted] អៀងធីរិទ្ធ បានផ្ញើលិខិតឆ្លើយឆ្លងទៅកាន់មន្ទីរស-២១ ហើយចម្លើយសារភាពមួយចំនួននៅមន្ទីរស-២១បានភ្ជាប់រូបគាត់ដោយផ្ទាល់ ទៅនឹងមន្ទីរសន្តិសុខនេះ។ ចម្លើយសារភាពមួយនោះមានចំណារមួយដែលសរសេរថា៖ "សង្គមកិច្ចដោះស្រាយបញ្ហារួចហើយ" ដែលបញ្ជាក់ថារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចគឺជាអ្នកទទួលខុសត្រូវលើការចាប់ខ្លួនទាំងនេះ។ ចម្លើយសារភាពមួយទៀតមានចំណារមួយដែលយោងដល់ឈ្មោះ "សមមិត្ត ភា" ដែលបញ្ជាក់ភស្តុតាងពីអង្គហេតុដែលថា វាត្រូវបានគេផ្ញើទៅឱ្យ **អៀង ធីរិទ្ធ**។ [redacted]។ វិសាលភាពនៃការត្រួតត្រារបស់ **អៀង ធីរិទ្ធ** ទៅលើបុគ្គលិកក្រសួងសង្គមកិច្ច ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរតាមរយៈរឿងរ៉ាវមួយដែលគាត់បានឱ្យរួចផុតពីការចាប់ខ្លួនស្ត្រីវ័យក្មេងម្នាក់ ដែលគាត់បានស្គាល់យ៉ាងជិតស្និទ្ធមែនទែន ក៏ប៉ុន្តែត្រូវបានគេចោទថាជាជនក្បត់។ បន្ថែមលើនេះ នៅពេលថ្មីៗនេះគាត់បានទទួលសារភាពថាគាត់បានដឹងឮថាសមាជិកនានាជាបុគ្គលិកក្រសួងសង្គមកិច្ច ត្រូវបានគេចាប់ខ្លួនដាក់ក្នុងឡានដឹកចេញទៅ ហើយត្រូវបានសម្លាប់ចោល នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ **អៀង ធីរិទ្ធ** បន្ទោសទៅលើ **នួន ជា** ពីការចាប់ខ្លួនទាំងនេះ ដែលបានកើតឡើងនៅក្រោមការដាក់ទិស និងការត្រួតត្រារបស់គាត់ ។

១២០៤- កម្មាភិបាលជាន់ខ្ពស់ដែលត្រូវបានបោសសម្អាតពីអង្គភាព និងមន្ទីរនានាដែលឋិតនៅក្រោមការត្រួតត្រារបស់ **អៀង ធីរិទ្ធ** រួមមាន៖

(១)ឡេង ពីសី *ហៅ* ឡេង សឹមហាក់ *ហៅ* សី សមាជិកគណៈក្រសួងសង្គមកិច្ច និងជាប្រធានមន្ទីរពេទ្យ១៧ មេសា (ព-១៧) ពីថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៥ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧។ អ្នកបន្តការងារពីគាត់ឈ្មោះ ធាត។

(២) ស៊ិន ផលគុណ *ហៅ* ស៊ូ ប្រធានក-២ សមាជិកគណៈក្រសួងសង្គមកិច្ច និងជាអនុរបស់ **អៀង ធីរិទ្ធ**។

(៣) កង យ៉ាន *ហៅ* វ៉ាត់ ឬ វ៉ាត់ ប្រធាន ព-២

(៤)មួន ប្រធាន ព-២

(៥)ម៉ី នួន *ហៅ* ហាន ប្រធាន ព-៤

(៦)ភី អនុប្រធាន ព-៦

(៧) ម៉ែន តុល *ហៅ* សាត សមាជិកគណៈ ព-១៧

(៨)ទុយ ជិម *ហៅ* ម៉ៅ សមាជិកគណៈ ព-១៧

(៩) ឌី ផុន *ហៅ* ធុក ពេទ្យធ្មេញនៅ ព-១៧ និងជាប្រធាន ផ-៥ ដែលអាចនឹងនៅរស់រានមានជីវិតពីមន្ទីរស-២១ ។

(១០) ស្រី អ៊ឹម *ហៅ* ឆុង ប្រធាន ផ-១ និងអ្នកបន្តការងារ ពីគាត់ឈ្មោះ ទេព សារូ *ហៅ* សា ។

(១១) ស៊ឹម សុវណ្ណ ប្រធាន ផ-២

(១២) ប៉ែន វ៉ាសែ *ហៅ* សែ ជំនួយការបច្ចេកទេស ធ្វើការជាបន្តបន្ទាប់នៅអតីតរោងចក្រផលិតឱសថខ្មុយម៉ិច និងនៅ ក-២

(១៣) អ៊ុយ ភីរូ *ហៅ* ប៉ក់ ប្រធាន ផ-៤

(១៤) ម៉ុក សំអុល *ហៅ* ហុង អតីតអនុប្រធាន ព-១៧ និងជា ប្រធាន ផ-៥

(១៥) ហង់ សុង *ហៅ* គិន ប្រធាន ផ-៦

(១៦) ប៉ុល ឡាក់ផេង ប្រធាន ផ-១១ ។

១២០៥- បន្ទាប់ពីដំណើរទស្សនៈកិច្ចរបស់ **អៀង ធីរិទ្ធ** ទៅកាន់ភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៦ ដូចដែលបានពិពណ៌នានៅក្នុងផ្នែកការដាក់ឱ្យទៅជាទាសករ និងលក្ខខណ្ឌបែបអមនុស្សធម៌ ខាងក្រោម គាត់បានធ្វើវិភាគទានរួមចំណែកដោយផ្ទាល់ នៅក្នុងសេចក្តីសម្រេចមគ្គុទ្ទេសក៍របស់ ប.ក.ក ដើម្បីធ្វើការបោសសម្អាតភូមិភាគពាយ័ព្យ។ **អៀង ធីរិទ្ធ** បានរាយការណ៍ដោយខ្លួនគាត់ផ្ទាល់ឱ្យទៅ ប៉ុល ពត អំពីស្ថានភាពអាសន្នផ្សេងៗដែលគាត់បានទៅឃើញផ្ទាល់នៅភូមិភាគពាយ័ព្យ ដោយបានលើកសម្អាងថាស្ថានភាព អាសន្នទាំងនោះបណ្តាលមកពី "ពួកខ្មាំង" ដែលទំនងជាបានជ្រៀតចូលទៅក្នុងភូមិភាគពាយ័ព្យ។ ដោយជំនួសការអំពាវនាវឱ្យមានការពិនិត្យឡើងវិញនូវគោលនយោបាយនានា ដែលមានផលប៉ះពាល់ជាមហន្តរាយទៅលើកសិករចំនួន១លាននាក់ (មួយលាននាក់) នៅភូមិភាគពាយ័ព្យ **អៀង ធីរិទ្ធ** បែរជាបានចូលរួមនៅក្នុងសេចក្តីសម្រេចរបស់គណៈមជ្ឈិម ក្នុងការបោសសម្អាតភូមិភាគនោះទៅវិញ។ យ៉ាងហោចណាស់ ក៏មានមនុស្សចំនួន១២១១នាក់ដែរ ដោយរួមទាំង រស់ ញឹម លេខាភូមិភាគផង ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១។

## តួនាទីក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

១២០៦- សកម្មភាពរបស់ **អៀង ធីរិទ្ធ** បន្ទាប់ពីការ**ដួលរលំរបស់** ប.ក.ក តាមដែលភស្តុតាងនានាបានបង្ហាញពីលំនាំនៃអាកប្បកិរិយាជាប្រចាំ**របស់គាត់** បានពង្រឹងនូវភស្តុតាងស្តីពីចេតនា និង

ការចូលរួមប្រព្រឹត្តិរបស់គាត់ នៅក្នុងអំឡុងពេលដែលឋិតនៅក្រោមការស៊ើបសួរនេះ។ ប្រមាណជា២០ឆ្នាំក្រោយពី ប.ក.ក បានដួលរលំមក **អៀង ធីរិទ្ធ នៅ**តែបន្តលើកស្ទួយដល់ ប.ក.ក និងបុព្វហេតុរបស់វា**ដោយ**ប្រកាសជំទាស់យ៉ាងខ្លាំងអំពីការកាន់កាប់របស់វៀតណាម និងបដិសេធថាពុំមានឧក្រិដ្ឋកម្មណាមួយបានកើតឡើងនោះទេ។ គាត់ក៏បានស្វែងរកជាប់ជាប្រចាំផងដែរ ដើម្បីកាត់បន្ថយនូវការចូលរួមប្រព្រឹត្តិរបស់គាត់ផ្ទាល់ នៅក្នុងឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តដោយកម្ពុជាប្រជាធិបតេយ្យ ។

**តួនាទី និងសកម្មភាព**

១២០៧- **អៀង ធីរិទ្ធ** នៅតែជាមេដឹកនាំជាន់ខ្ពស់មួយរូបនៃ ប.ក.ក បន្ទាប់ពីទីក្រុងភ្នំពេញបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ មុខតំណែងរបស់គាត់ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានពោលអះអាងជាថ្មីឡើងវិញ នៅឯសន្និបាតសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើឡើងនៅថ្ងៃទី១៥-១៧ ខែធ្នូ ឆ្នាំ១៩៧៩ហើយគាត់នៅបន្តរក្សាមុខតំណែងនេះយ៉ាងហោចណាស់ក៏រហូតដល់ខែឧសភា ឆ្នាំ១៩៨២ដែរ។ គាត់ក៏ត្រូវបានតែងតាំងបន្ថែមក្នុងមុខតំណែងរដ្ឋមន្ត្រី៖ យ៉ាងហោចណាស់ក៏ រហូតដល់ខែកញ្ញា ឆ្នាំ១៩៨២ដែរ ដែល **អៀង ធីរិទ្ធ** ត្រូវបាន**គេផ្តល់តួនាទី**ជាអគ្គលេខាធិការ នៅក្នុងក្រសួងការបរទេសនៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ។ គាត់បាននៅបន្តរក្សាតួនាទីនេះក្នុងឋានៈជាកម្មាភិបាលជាន់ខ្ពស់លំដាប់ទីពីរនៅក្នុងក្រសួងនេះ យ៉ាងហោចណាស់ក៏រហូតដល់ចុងខែសីហា ឆ្នាំ១៩៨៥ដែរ។ បន្ថែមលើនេះ **អៀង ធីរិទ្ធ** នៅតែជាអនុប្រធាននៃសមាគមនារីកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ក៏រហូតដល់ពាក់កណ្តាលឆ្នាំ១៩៨៥ដែរ ដោយបាន

បន្តធ្វើជាតំណាងឱ្យសមាគមនេះ ក្នុងឋានៈជាប្រធានគណៈប្រតិភូទៅឯសន្និសីទមួយចំនួន។ គាត់ក៏ធ្លាប់បានធ្វើជាប្រធានកាកបាទក្រហមកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ក៏ក្នុងរវាងឆ្នាំ១៩៨០ និងខែមេសា ឆ្នាំ១៩៨៥ផងដែរ។

១២០៨- អតីតភាពនៃមុខតំណែងរបស់ **អៀង ធីរិទ្ធ** ទាំងនៅក្នុងក្របខណ្ឌកម្ពុជាប្រជាធិបតេយ្យ និងទាំងនៅក្នុងក្របខណ្ឌរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានដាក់បន្ទុកឱ្យគាត់មានការទទួលខុសត្រូវជាច្រើននៅក្នុងការតំណាងឱ្យអង្គភាពទាំងនេះនៅលើឆាកអន្តរជាតិ។ គាត់បានចូលរួមនៅក្នុងមហាសន្និបាតនៃ អ.ស.ប ជាច្រើន ក៏ដូចជានៅក្នុងសន្និសីទអន្តរជាតិដទៃទៀតផង ដែរ ដែលត្រូវបានរៀបចំយ៉ាងពិសេស ដើម្បីលើកស្ទួយដល់ផលប្រយោជន៍ទាំងឡាយរបស់ ប.ក.ក និងដោយសំពៀងពីប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ។ ជាក់ស្តែង នៅឆ្នាំ១៩៧៩ គាត់បានដឹកនាំគណៈប្រតិភូទៅឯសន្និសីទអន្តរជាតិមួយ ស្តីពីសាមគ្គីភាពជាមួយនឹងកម្ពុជា ដោយបានធ្វើការបរិហារវៀតណាម និងបានសុំឱ្យមានការគាំទ្រនូវការធ្វើឱ្យ ប.ក.ក ដូចដើមឡើងវិញ។ គាត់ក៏បានអមដំណើរ **ខៀវ សំផន** ដែលជាអនុប្រធាននៃគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេសទៅចូលរួមប្រជុំជាច្រើនដងនៅ ចំពោះមុខមហាសន្និបាត អ.ស.ប និងបានដើរតួជាទីប្រឹក្សាពិសេសរបស់គណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យផងដែរ។ បន្ថែមលើនេះ នៅមុនពេលមានការចាត់តាំងរូបគាត់ឱ្យទៅក្រសួងការបរទេស គាត់បានធ្វើដំណើរយ៉ាងច្រើនលើសលុបក្នុងឋានៈជាប្រេសិតពិសេសរបស់ **ខៀវ សំផន** ដែលជាប្រធាននៃគណៈប្រធានរដ្ឋ ឬក្នុងឋានៈជាប្រធានគណៈប្រតិភូនៃកម្ពុជាប្រជាធិបតេយ្យចូលរួមប្រជុំជាមួយនឹងពួកអ្នកតំណាងប្រទេសផ្សេងៗទៀត ហើយបានជំរុញលើកទឹកចិត្តពួកទាំងនោះ ឱ្យថ្កោលទោសលើការកាន់កាប់របស់ពួកវៀតណាម ឱ្យគាំទ្រនូវការវិលត្រឡប់មក

កាន់អំណាចឡើងវិញរបស់ខ្មែរក្រហម។ គាត់បានធ្វើដំណើរទៅកាន់ប្រទេសអ៊ីតាលី ប្រទេសរ៉ូម៉ានីប្រទេសអេស្ប៉ាញប្រទេសជប៉ុន និងប្រទេសអាហ្វ្រិកចំនួន ១៣។

១២០៩- **អៀង ធីរិទ្ធ** ក៏បានដើរតួនាទីខាងផ្នែកនយោបាយដ៏សំខាន់ផងដែរ នៅក្នុងលំដាប់ថ្នាក់ជាតិនៅក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់នានា គាត់គឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់ដែលមានការជាប់ពាក់ព័ន្ធយ៉ាងច្រើន នៅក្នុងការបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ។ ក៏ដូចជាការចូលរួមនៅក្នុងការប្រជុំមួយក្នុងឆ្នាំ១៩៧៩ ជាមួយនឹងរដ្ឋមន្ត្រីការបរទេសនៃប្រទេសថៃ និងប្រទេស**សិង្ហបុរី** ស្តីពីការបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ **អៀង ធីរិទ្ធ** ក៏បានបំពេញការងារក្នុងឋានៈជាអ្នកដឹកនាំគណៈប្រតិភូនៃកម្ពុជាប្រជាធិបតេយ្យនៅក្នុងគណៈកម្មការពិសេសត្រីភាគី (the Tripartite Ad Hoc Committee) និងបានចូលរួមនៅក្នុងការប្រជុំមួយចំនួនដើម្បីពិភាក្សាអំពីគោលការណ៍ផ្សេងៗ និងទម្រង់នានា ដែលអាចនឹងបង្កើតបានជារដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ នៅក្នុងខែកញ្ញា ឆ្នាំ១៩៨១។

១២១០- **អៀង ធីរិទ្ធ** បានបន្តមុខងារជាតំណាងកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ដោយបានទទួលគណៈប្រតិភូបរទេសជាច្រើនក្នុងនាមរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ គណៈប្រតិភូបរទេសទាំងនេះ រាប់បញ្ចូលទាំងគណៈប្រតិភូប្រទេសជប៉ុន ប្រទេសចិន ប្រទេសនានានៅអឺរ៉ុប និងគណៈប្រតិភូប្រទេសផ្សេងៗទៀតផងដែរ។ **អៀង ធីរិទ្ធ** បានរក្សាឋានៈរបស់គាត់ ដូចជាសមាជិកស្ត្រីម្នាក់ដែលលេចធ្លោរជាងគេបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈស្ថានភាពដ៏ខ្ពង់ខ្ពស់របស់គាត់នៅក្នុងបណ្តាញសារព័ត៌មាន។ គាត់ក៏បាន

ជួបជាទៀងទាត់ជាមួយនឹងអ្នកសារព័ត៌មាននានាផងដែរ ក្នុងចន្លោះឆ្នាំ ១៩៧៩ និង១៩៨៥៖ អ្នកសារព័ត៌មានចិន ជប៉ុន អាមេរិកាំង អឺរ៉ុបខាងលិច និងអ្នកសារព័ត៌មានជាច្រើននាក់ផ្សេងទៀត។ **អៀង ធីរិទ្ធ** ក៏បានផ្តល់កិច្ចសម្ភាសន៍ជាច្រើន ដែលបានថតជាខ្សែភាពយន្តឱ្យទៅបណ្ដាញសារព័ត៌មានបរទេសផងដែរ។

១២១១- **អៀង ធីរិទ្ធ** និង **អៀង សារី** បានចុះចូល នៅពេលដែលរដ្ឋាភិបាលកម្ពុជាបានផ្តល់នូវការលើកលែងទោសនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦។ នៅក្រោយពេលចុះចូល **អៀង ធីរិទ្ធ** បានបន្តរក្សានូវភាពលេចធ្លោរខាងនយោបាយរបស់គាត់តាមរយៈសមាជិកភាពរបស់គាត់ នៅក្នុងគណបក្សចលនារួបរួមជាតិប្រជាធិបតេយ្យ - ដែល **អៀង សារី** បានបង្កើតឡើងនៅក្នុង**ទសវត្សរ៍**៩០។

## ការទទួលដឹងឮ និងការបដិសេធអំពីឧក្រិដ្ឋកម្ម

១២១២- **នៅ**ពេលផ្សេងៗគ្នា **អៀង ធីរិទ្ធ** បានបដិសេធទៅនឹងឧក្រិដ្ឋកម្មនានា**របស់**កម្ពុជាប្រជាធិបតេយ្យ ហើយធ្លាប់បានស្ទាក់ស្ទើរក្នុងការទទួលស្គាល់ឧក្រិដ្ឋកម្មទាំងនោះ ក្នុងវិសាលភាពមួយដែលមានកម្រិត។ គាត់ក៏ធ្លាប់បានស្វែងរកជាប្រចាំពីការកាត់បន្ថយនូវការចូលរួមប្រព្រឹត្ត និងការទទួលខុសត្រូវរបស់គាត់ដោយបានស្តីបន្ទោស ទៅលើអ្នកដទៃពីការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងឡាយនេះ។

១២១៣- ជាញឹកញាប់ **អៀង ធីរិទ្ធ** ធ្លាប់បានភ្ជាប់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងកម្ពុជាប្រជាធិបតេយ្យទៅលើប្រទេសវៀតណាម។ នៅក្នុងបទឧទ្ទេសនាមមួយរបស់គាត់នៅឯសន្និសីទអន្តរជាតិមួយ ស្តីពីសាមគ្គីភាពជាមួយនឹងកម្ពុជានៅខែវិច្ឆិកា ឆ្នាំ

១៩៧៩ គាត់បានស្ដីបន្ទោសជាសាធារណៈទៅលើប្រទេសវៀតណាម ចំពោះឧក្រិដ្ឋកម្មជាច្រើន ក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលវបានប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយបាន ពិព័ណ៌នាអំពីកងកម្លាំងដែលកំពុងកាន់កាប់ ថាបានធ្វើឱ្យខ្មែរចខ្មីវនូវ“ការបំផ្លិចបំផ្លាញទាំង ស្រុង” **ហើយ**“បានប្រព្រឹត្តនូវអំពើថោកទាបរាប់មិនអស់ និងឧក្រិដ្ឋកម្មដែលមិនអាចពិព័ណ៌នា បានសំដៅប្រឆាំងនឹងប្រជាជនយើង”។ គាត់បានហៅពួកទាំងនោះថាជា “ពួកឧក្រិដ្ឋជនដ៏ធំ បំផុតនៅក្នុងសម័យយើងនេះ”។ គាត់បានចោទប្រកាន់វៀតណាម អំពីការទទួលខុសត្រូវ ចំពោះការស្លាប់របស់ប្រជាជនកម្ពុជាចំនួនពីមួយលាន ទៅពីរលាននាក់។

១២១៤- បន្ថែមលើនេះ **អៀងធីរិទ្ធ** ធ្លាប់បានបដិសេធយ៉ាងសកម្ម ពីឧក្រិដ្ឋកម្មទាំងនោះដែលថាត្រូវបាន ប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ គាត់នៅបានរក្សាថាការស្លាប់ចំនួនប្រមាណ រាប់លាននាក់នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ គឺគ្រាន់តែជាការឃោសនារបស់ វៀតណាមតែប៉ុណ្ណោះ ហើយថាមានតែជនរងគ្រោះចំនួន៣០០០០នាក់ប៉ុណ្ណោះ ដែលបាន ស្លាប់នៅក្នុងសម័យខ្មែរក្រហម ដែលនៅក្នុងនោះការស្លាប់ចំនួន១០០០០នាក់ គឺបណ្ដាលមកពី ពួកភ្នាក់ងារវៀតណាម និងមានការស្លាប់បន្ថែមចំនួន២០០០០នាក់ទៀត បណ្ដាលមកពីទុរ្ភិក្ស ឬបណ្ដាលមកពីជម្ងឺ។ គាត់បានអះអាងថាព្រឹត្តិការណ៍នៅមន្ទីរស-២១ គឺជាការប្រឌិតរបស់ ពួកវៀតណាម។ **អៀង ធីរិទ្ធ** ក៏ធ្លាប់បានបញ្ចេញនូវការមិនគោរពយ៉ាងដាច់ខាត ចំពោះ អាយុជីវិតរបស់ពួកដែលត្រូវបានសម្លាប់ដោយប.ក.ក ផងដែរ ដោយការស្ដែងចេញយ៉ាងចំហរ នូវការហួសចិត្តទៅនឹងការលើកឡើងថាមានសាកសពចំនួន៣០០០នាក់ នៅតាមមន្ទីរពេទ្យនានា របស់ក្រសួងសង្គមកិច្ច **និង**ថា ប.ក.ក បានសម្លាប់ប្រជាជនកម្ពុជាអស់រាប់លាននាក់។

១២១៥- ទោះជាយ៉ាងណាក៏ដោយក៏ **អៀង ធីរិទ្ធ** ធ្លាប់បានធ្វើសម្បទានជាក់លាក់មួយចំនួនផងដែរ អំពីឧក្រិដ្ឋកម្មនានានៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ គាត់ធ្លាប់បានទទួលសារភាពថា មានការបំពានខ្លះ ត្រូវបានប្រព្រឹត្តឡើងពីសំណាក់ពួកខ្មែរក្រហម ចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៩។ នៅក្នុងបទសម្ភាសន៍មួយកាលពីឆ្នាំ១៩៧៩ គាត់ធ្លាប់បានទទួលស្គាល់ថា កម្ពុជាប្រជាធិបតេយ្យ គឺត្រូវទទួលខុសត្រូវចំពោះការស្លាប់មនុស្សចំនួន១០០០០នាក់។ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៨១ **អៀង ធីរិទ្ធ** បានទទួលសារភាពថា “វាអាចនឹងមានអ្វីដែលគេហៅថាការបោសសម្អាតដែលផ្តោតទៅលើគោលដៅ ដែលគេហៅថាពួកក្បត់” ក៏ប៉ុន្តែនៅតែបានរក្សាគំនិតថាអំពើប្រល័យពូជសាសន៍ ពុំមានកើតឡើងនោះទេ។ គាត់បានថ្លែងថា៖ “តាមការពិតវាមានការបំពានមែន ក៏ប៉ុន្តែការបំពាននេះវាបានកើតឡើងនៅគ្រប់បដិវត្តនីមួយៗ”។

១២១៦- **អៀង ធីរិទ្ធ** ធ្លាប់បានព្យាយាម ម្តងហើយម្តងទៀត អំពីការចូលរួមប្រព្រឹត្តិរបស់គាត់ដ៏តិចតួចនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងឧក្រិដ្ឋកម្មនានារបស់ ប.ក.ក ។ នៅខែកុម្ភៈ ឆ្នាំ១៩៨៩ គាត់បានអះអាងថាគាត់គ្រាន់តែជា “សមាជិកធម្មតារបស់បក្សតែប៉ុណ្ណោះ”។ ទោះបីជាការចូលរួមប្រព្រឹត្តិរបស់គាត់ នៅក្នុងគោលនយោបាយឧក្រិដ្ឋយ៉ាងទូលំទូលាយ ដែលអាចបង្ហាញបានយ៉ាងណាក៏ដោយ ក៏គាត់នៅតែបានអះអាងនៅដើមឆ្នាំ១៩៨០ និងពេលថ្មីៗនេះនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ថាការចូលរួមចំណែករបស់គាត់ នៅក្នុងគោលនយោបាយកសាងកម្ពុជាប្រជាធិបតេយ្យ ពុំបានហួសពីតួនាទីរបស់គាត់ នៅក្នុងកិច្ចការសង្គមកិច្ចនោះឡើយ។ នាពេលថ្មីបំផុតនេះដែរ **អៀង ធីរិទ្ធ** ធ្លាប់បានស្វែងរកនូវការភ្ជាប់ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានារបស់ ប.ក.ក ទៅនឹងជនត្រូវចោទដទៃទៀត។ គាត់បានបន្ទោសទៅលើ

នួន ជា និង ឌុច ដែលបានធ្វើការចាប់ខ្លួន និងសម្លាប់សមាជិកនានា ដែលជាបុគ្គលិករបស់គាត់ នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ការភ្ជាប់ការទទួលខុសត្រូវនេះ ត្រូវបានធ្វើឡើង ទោះបីជាការអះអាងរបស់គាត់នាពេលថ្មីៗនេះថា រូបគាត់មិនបានដឹងអ្វីសោះអំពីឧក្រិដ្ឋកម្ម នានានៅមន្ទីរស-២១ក៏ដោយ។

# V. ច្បាប់

## ក- បទឧក្រិដ្ឋ

### អំពើប្រល័យពូជសាសន៍ [ច្បាប់ អ.វ.ត.ក មាត្រា ៤]

១២១៧- មាត្រា៤ នៃច្បាប់ អ.វ.ត.ក ផ្តល់អំណាចយុត្តាធិការឲ្យតុលាការនេះកាត់សេចក្តីជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ("អនុសញ្ញាប្រល័យពូជសាសន៍")។ តាមមាត្រា៤ អំពើប្រល័យពូជសាសន៍មានន័យថាជា "អំពើទាំងឡាយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា (១) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម (២) ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាយកាយ ឬសតិបញ្ញា សមាជិកនៃក្រុម (៣)ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញ

រាងកាយ ទាំងស្រុង ឬមួយផ្នែក (៤)ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតដល់ទារក និង (៥)ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀត"។

១២១៨- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានធាតុផ្សំអត្តនោម័ត (ចេតនាបំផ្លិចបំផ្លាញក្រុមនោះតែម្តង) និងធាតុផ្សំសត្យានុម័ត (ការប្រព្រឹត្តិអំពើយ៉ាងហោចណាស់ចំនួន១ ក្នុងចំណោមអំពើទាំងឡាយដែលបានរៀបរាប់)។

## ធាតុផ្សំអត្តនោម័ត

## ចេតនាបំផ្លិចបំផ្លាញ

១២១៩- អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មមួយ ដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនាជាក់លាក់។ ក្នុងការប្រព្រឹត្តិអំពើមួយក្នុងចំណោមអំពើទាំងឡាយដែលបានរៀបរាប់ ចារីប្រាកដជាមានចេតនាជាក់លាក់ក្នុងការបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែក នៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ។ អវត្តមាននៃការរៀបចំផែនការ ឬការគិតទុកជាមុន ពុំបានផាត់ចោលនូវអត្ថិភាពនៃចេតនាក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ឡើយ បើទោះបីអត្ថិភាពនៃផែនការ ឬគោលនយោបាយណាមួយ អាចនាំឱ្យមានភស្តុតាងបញ្ជាក់អំពីចេតនា និងឧក្រិដ្ឋកម្មនេះក្តី។ ប្រហាក់ប្រហែលគ្នានេះ ការខកខានរបស់ចារីក្នុងការអនុវត្តចេតនារបស់ខ្លួនឱ្យបានទាំងស្រុង ដោយទុកឱ្យអំពើបំផ្លិចបំផ្លាញនៅពុំទាន់ពេញលេញ ពុំបញ្ឈប់ការស្វែងរកឱ្យឃើញនូវចេតនាក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍បានឡើយ។

១២២០- ក្នុងពេលគ្មាន ចម្លើយសារភាព គេអាចសន្និដ្ឋានអំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តាមរយៈអង្គហេតុ និងកាលៈទេសៈមួយចំនួននៃរឿងក្ដីនោះ។ ចំណុចទាំងនោះរួមមាន៖ បរិបទទូទៅ ការប្រព្រឹត្តិបទល្មើសផ្សេងៗ ដែលត្រូវបានប្រព្រឹត្តឡើងជាប្រព័ន្ធសំដៅប្រឆាំងនឹងក្រុមតែមួយ ទំហំនៃអំពើឃោរឃៅ អាវុធដែលត្រូវបានយកមកប្រើប្រាស់ និងវិសាលភាពនៃព្យសនកម្មខាងរូបរាងកាយដែលបានបង្កឡើង ការយកជនរងគ្រោះធ្វើជាគោលដៅជាលក្ខណៈប្រព័ន្ធដោយសារសមាជិកភាពនៃក្រុមណាមួយ ការពុំទទួលស្គាល់នូវសមាជិកនៃក្រុមផ្សេងៗ ការប្រព្រឹត្តិដ្ឋនៗនូវអំពើបំផ្លិចបំផ្លាញនិងរើសអើង ការប្រើប្រាស់ភាសាប្រមាថមាក់ងាយទៅកាន់សមាជិកក្រុមគោលដៅ និងការរៀបចំផែនការច្បាស់លាស់ក្នុងការកាប់សម្លាប់ជាលក្ខណៈប្រព័ន្ធ។ គេក៏អាចស្វែងរកឃើញផងដែរ នូវភស្តុតាងបញ្ជាក់អំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ នៅក្នុងសន្ទរកថា ឬសកម្មភាពនានាដែលជាមូលដ្ឋាន និងការផ្ដល់យុត្តិកម្មដល់អំពើនានាដែលសំដៅបំផ្លិចបំផ្លាញមូលដ្ឋានគ្រឹះនៃក្រុមគោលដៅ។ បើទោះបីជាយ៉ាងដូច្នេះក្ដី គេត្រូវបញ្ជាក់ច្បាស់អំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍។ ភស្តុតាងដែលជនជាប់ចោទបានដឹងអំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍របស់សហចារីរបស់ខ្លួន ហើយពុំបានធ្វើអ្វីមួយដើម្បីទប់ស្កាត់ការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ គឺពុំគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថាវាជាចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ។

១២២១- "ការបំផ្លិចបំផ្លាញ" ក្នុងបរិបទនៃនិយមន័យនៃពាក្យថាអំពើប្រល័យពូជសាសន៍ មានន័យថាជាការបំផ្លិចបំផ្លាញផ្នែកជីវសាស្ត្រ ឬរូបរាងកាយរបស់ក្រុមមនុស្សណាមួយ ពុំមែនជាការបំផ្លិចបំផ្លាញផ្នែកវប្បធម៌ សង្គមវិទ្យា ឬអត្តសញ្ញាណផ្សេងៗនៃក្រុមណាមួយឡើយ។ ការបំផ្លិច

បំផ្លាញជាក់ស្តែងនូវក្រុម ឬមនុស្សមួយចំនួនធំ គឺពុំមែនជាបុរេលក្ខខណ្ឌចំពោះការស្វែងរកឱ្យឃើញនូវចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ។ ប្រសិនបើគេបានប្រព្រឹត្តត្រឹមតែការសម្លាប់តែមួយករណីដោយមានចេតនាចាំបាច់ក្នុងការបំផ្លិចបំផ្លាញក្រុមនោះទាំងស្រុង ឬមួយផ្នែក ក៏អាចរាប់ថាជាអំពើប្រល័យពូជសាសន៍ដែរ។ ចំណុចចុងក្រោយ ចារីពុំចាំបាច់មានចេតនាបង្កឱ្យមានការស្លាប់ក្នុងដំណាក់កាលណាមួយក្រោមកិច្ចស៊ើបសួរឡើយ។ ឧទាហរណ៍ អំពើហិង្សាផ្លូវភេទអាចបង្កើតបានជាផ្នែកសំខាន់មួយនៃដំណើរការនៃការបំផ្លិចបំផ្លាញ ក្នុងករណីដែលអំពើហិង្សានេះរួមចំណែកដល់ការបំផ្លិចបំផ្លាញស្ត្រី ក្នុងក្រុមគោលដៅនោះ និងស្ត្រីនៃក្រុមនោះទាំងមូល។

## ទាំងស្រុង ឬមួយផ្នែក

១២២២- ដូចដែលបានកត់សម្គាល់ខាងលើ ជនណាប្រព្រឹត្តអំពើមួយក្នុងចំណោមអំពើទាំងឡាយដែលបានហាមឃាត់នឹងមានទោសពីបទអំពើប្រល័យពូជសាសន៍ ប្រសិនបើជននោះ មានចេតនាឱ្យ មានការបំផ្លិចបំផ្លាញក្រុមគោលដៅទាំងស្រុង *ឬ* មួយផ្នែក។ ក្នុងករណីដែលគេបានចោទប្រកាន់ថាចារីបានមានចេតនាបំផ្លិចបំផ្លាញក្រុមណាមួយ *ទាំងស្រុង* គេពុំចាំបាច់បង្ហាញឱ្យឃើញថាចារីពិតជាបានមានចេតនាកម្ចាត់ក្រុមនោះទាំងស្រុងឱ្យវិនាសសាបសូន្យឡើយ។

១២២៣- ចំពោះចេតនាបំផ្លិចបំផ្លាញក្រុមណាមួយ *មួយផ្នែក* គេពុំមានការកំណត់ចំនួនជនរងគ្រោះឡើយ ប៉ុន្តែគេត្រូវបង្ហាញឱ្យឃើញថាជនជាប់ចោទពិតជាបានមានចេតនាបំផ្លិចបំផ្លាញមួយផ្នែក*ធំ* នៃក្រុមនោះប្រាកដមែន។ ការកំណត់ថាតើផ្នែកគោលដៅនោះជាផ្នែកធំឬយ៉ាងណានឹងអាស្រ័យទៅតាមកត្តាមួយចំនួន រួមទាំងទំហំរបស់វាផងដែរ។ ទំហំនោះគួរត្រូវបានវាយតម្លៃ

មិនត្រឹមតែឲ្យបានច្បាស់លាស់ប៉ុណ្ណោះទេ ប៉ុន្តែគេត្រូវវាយតម្លៃពាក់ព័ន្ធនឹងចំនួនប្រជាជនសរុបនៃក្រុមនោះផងដែរ។ ប្រសិនបើផ្នែកនោះមានទំហំធំល្មមអាចឲ្យគេដឹងពីចំនួនពិតប្រាកដ ហើយតំណាងឲ្យក្រុមទាំងមូល ឬមានភាពចាំបាច់ដល់ការរស់រាននោះ គេអាចចាត់ទុកផ្នែកនោះថាជាផ្នែកធំ។ ផ្នែកនេះត្រូវមានទំហំធំល្មម ពោលគឺការបំផ្លិចបំផ្លាញផ្នែកនេះនឹងជះផលប៉ះពាល់ ឬគំរាមកំហែងដល់ការរស់រានរបស់ក្រុមទាំងមូល។ គេអាចបង្កើតឲ្យមានលក្ខខណ្ឌតម្រូវនេះ ឧទាហរណ៍ ប្រសិនបើថ្នាក់ដឹកនាំទាំងមូលរបស់ក្រុមណាមួយត្រូវបានគេកំណត់យកជាគោលដៅនៃការបំផ្លិចបំផ្លាញ។

១២២៤- ចេតនាបំផ្លិចបំផ្លាញក្រុមណាមួយ មួយផ្នែក អាចគ្របដណ្តប់លើតំបន់ភូមិសាស្ត្រមួយចំនួនតូចប៉ុណ្ណោះ ដូចជា តំបន់នៃប្រទេស ឬទីក្រុងមួយ។ ការពិតដែលថាចេតនារបស់ជនជាប់ចោទត្រូវបានកំណត់ដោយឱកាសដែលជនជាប់ចោទមាន គឺជាកត្តាពាក់ព័ន្ធមួយក្នុងការវាយតម្លៃថាតើជនជាប់ចោទពិតជាបានមានចេតនាបំផ្លិចបំផ្លាញមួយផ្នែកធំនៃក្រុម ដែលត្រូវទទួលបានការការពារដែរឬយ៉ាងណា។

## ក្រុមដែលត្រូវទទួលបានការការពារ

១២២៥- ដូចដែលបានកត់សម្គាល់ខាងលើ ស្របតាមអនុសញ្ញាប្រល័យពូជសាសន៍ ច្បាប់ អ.វ.ត.ក បានចែកក្រុមដែលត្រូវទទួលបានការការពារជា៤ប្រភេទគឺៈក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ ប្រភេទក្រុមផ្សេងៗដូចជា ក្រុមនយោបាយ ពុំបានទទួលការការពារដោយអនុសញ្ញានេះទេ។ ក្រុម ***ជាតិ*** ត្រូវបានកំណត់និយមន័យថាជា "ក្រុមមនុស្សដែលគេចាត់ទុកថាមានចំណងគតិយុត្តិផ្អែកតាមសញ្ជាតិរួម រួមនឹងការមានសិទ្ធិ និងករណីយកិច្ចចំពោះគ្នាទៅវិញទៅ

មក"។ ក្រុម ***ជាតិពន្ធុ*** គឺជាក្រុម "ដែលសមាជិករបស់ខ្លួនមានភាសា ឬវប្បធម៌រួមគ្នា"។ ក្រុម ***ពូជសាសន៍*** គឺក្រុមដែលមាន "អត្តសញ្ញាណខាងរូបរាងកាយតំណរពូជ ដែលតែងត្រូវបានសម្គាល់ដោយតំបន់ភូមិសាស្ត្រ ដោយមិនគិតអំពីកត្តាភាសា វប្បធម៌ ជាតិ ឬសាសនា" ។ ក្រុម ***សាសនា*** គឺជាក្រុម "ដែលសមាជិករបស់ខ្លួនមានសាសនា និកាយ ឬទម្រង់នៃការគោរពបូជាដូចគ្នា"។

១២២៦- ទោះក្នុងករណីណាក្តី ការកំណត់ថាក្រុមណាមួយដែលត្រូវទទួលបានការការពារគឺត្រូវធ្វើឡើងផ្អែកតាមលក្ខណៈវិនិច្ឆ័យសត្យានុម័ត និងអត្តនោម័ត។ លក្ខណៈវិនិច្ឆ័យសត្យានុម័តរួមមានបរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ រីឯលក្ខណៈវិនិច្ឆ័យអត្តនោម័តរួមមាន ការរើសអើង ឬការកំណត់មុខសញ្ញាក្រុមណាមួយ ពីសំណាក់ចារី ផ្អែកតាមអត្តសញ្ញាណ ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ បញ្ហាមួយទៀតដែលថាតើជនរងគ្រោះណាម្នាក់ស្ថិតក្នុង ក្រុមគោលដៅណាមួយដែរឬទេនោះ ជាសំខាន់បញ្ហានេះត្រូវបានកំណត់ដោយលក្ខណៈ វិនិច្ឆ័យអត្តនោម័ត នោះគឺការកំណត់តាមការយល់ឃើញរបស់ចារីចំពោះជនរងគ្រោះ។

## ដូចជា (SUCH AS/ AS SUCH)

១២២៧- និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅមាត្រា II នៃអនុសញ្ញាប្រល័យពូជសាសន៍ និងក្នុងលក្ខន្តិកៈតុលាការ ICTY ICTR និង ICC មានឃ្លាថា "as such" បន្ទាប់ពីពាក្យថា "ក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"។ ឃ្លានេះឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវដែលថាអំពើដែលបានហាមឃាត់នឹងរាប់ថាជាអំពើប្រល័យពូជសាសន៍តែមួយគត់ ប្រសិនបើអំពើនេះត្រូវបានគេប្រព្រឹត្តមកលើជនរងគ្រោះ "ពិសេសដោយសារ" សមាជិកភាពរបស់ជនរងគ្រោះ

ក្នុងក្រុម ដែលត្រូវបានទទួលការការពារណាមួយ។ ចំណុចនេះ“បង្ហាញឱ្យឃើញថាបទល្មើសនេះត្រូវតម្រូវឱ្យមានចេតនាបំផ្លិចបំផ្លាញមនុស្សមួយក្រុម ដែលមានអត្តសញ្ញាណក្រុមជាក់លាក់”។ ចំណុចនេះក៏បញ្ជាក់ផងដែរនូវមូលហេតុសំខាន់នៃនិយមន័យនៃអំពើប្រល័យពូជសាសន៍ថា បើទោះបីការបំផ្លិចបំផ្លាញចាំបាច់ទាមទារឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិកក្រុមណាមួយក្តី ក៏“ជនរងគ្រោះចុងក្រោយនៃអំពើប្រល័យពូជសាសន៍ គឺជាក្រុមនោះ”។ បើទោះបីជាយ៉ាងដូច្នេះក្តី ការប្រើប្រាស់ពាក្យថា “as such” ពុំតម្រូវថា “ចេតនាបំផ្លិចបំផ្លាញក្រុមណាមួយ ត្រូវផ្អែកតែម្យ៉ាងតាមមូលហេតុមួយក្នុងចំណោមមូលហេតុ សញ្ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ដូចដែលបានរៀបរាប់ឡើយ”។

១២២៨- មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ប្រើប្រាស់ឃ្លាថា “such as” ជំនួសពាក្យ “as such” ក្នុងការកំណត់និយមន័យអំពើប្រល័យពូជសាសន៍។ បើទោះបីជាយ៉ាងដូច្នេះក្តី មាត្រានេះផ្តល់យុត្តាធិការឱ្យ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មនេះ ពិសេស “ដូចដែលមានចែងក្នុង” អនុសញ្ញាប្រល័យពូជសាសន៍។ ចំណុចនេះបញ្ជាក់ថា ទោះបីជាមានភាពខុសគ្នាបន្តិចបន្តួចត្រង់ពាក្យពេចន៍ក្តី ក៏មាត្រា៤ តម្រូវឱ្យតុលាការយកនិយមន័យនៃអំពើប្រល័យពូជសសាសន៍មកអនុវត្តឱ្យបានស៊ីសង្វាក់ជាមួយនិយមន័យទូទៅនៃឧក្រិដ្ឋកម្មនេះក្នុងច្បាប់អន្តរជាតិ។ ដូច្នេះលក្ខខណ្ឌតម្រូវខាងលើ (ដែលថាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ត្រូវតែបានស្ថិតក្រោមគោលដៅ ដោយសារសមាជិកភាពរបស់ខ្លួនក្នុងក្រុមដែលត្រូវទទួលបានការការពារ ដែលថារីមានចេតនាបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែក) អាចយកមកអនុវត្ត ដូចគ្នាទៅចំពោះ អ.វ.ត.ក។

## អំពើជាក់លាក់មួយចំនួន

### ការសម្លាប់សមាជិកក្រុម

១២២៩- អំពើនេះត្រូវបានផ្ដល់និយមន័យថាជាការសម្លាប់ "សមាជិកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដែលគេបានយកធ្វើជាគោលដៅនៃការសម្លាប់" ដែលត្រូវបានប្រព្រឹត្តក្នុងចេតនាបង្កឲ្យមានការស្លាប់ ប៉ុន្តែពុំចាំបាច់មានការគិតទុកជាមុនឡើយ។

### ការបង្កព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយ ឬផ្លូវចិត្ត ដល់សមាជិកក្រុម

១២៣០- អំពើប្រល័យពូជសាសន៍ប្រភេទនេះ រាប់បញ្ចូលការបង្កព្យសនកម្មធ្ងន់ធ្ងរដែលពុំចាំបាច់បណ្ដាលឲ្យជនរងគ្រោះស្លាប់ឡើយ ឬពុំចាំបាច់បណ្ដាលឲ្យមានរបួសស្នាមជាអចិន្ត្រៃយ៍ ឬពុំអាចព្យាបាលជាសះស្បើយឡើយ។ បើទោះបីជាយ៉ាងដូច្នេះក្ដី ព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តដែលគេបានបង្កមកលើសមាជិកក្រុមគោលដៅ "ត្រូវមានសភាពធ្ងន់ធ្ងរ ដែលជាការគំរាមកំហែងដល់ការវិនាស [របស់ក្រុម] ទាំងស្រុង ឬមួយផ្នែក"។ ព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយត្រូវបានគេកំណត់និយមន័យថាជា "ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវកាយដែលមិនបណ្ដាលឲ្យស្លាប់ ដែលបានបង្កឲ្យមានវិការៈ ឬរបួសស្នាមធ្ងន់ធ្ងរ ដល់សរីរាង្គខាងក្នុង ឬខាងក្រៅ"។ ព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវចិត្តគឺជាព្យសនកម្មដែលបង្កឲ្យមានរបួសធ្ងន់ធ្ងរដល់សភាពផ្លូវចិត្តរបស់ជនរងគ្រោះ និងរួមបញ្ចូលទាំងពិការសតិអារម្មណ៍លើសពីកម្រិតស្រាល ឬបណ្ដោះអាសន្ន ដូចជា ការទទួលរងការភិតភ័យ ការបន្ទាច ការសម្លុត ឬការគំរាមកំហែងជាដើម។ អំពើទាំងឡាយដែលបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយ និង/ឬ ផ្លូវចិត្ត រួមមាន "ការធ្វើឲ្យទៅជាទាសករ ភាពអត់ឃ្លាន ការជម្លៀស និងការធ្វើទុក្ខបុកម្នេញ [...] និង ...ការ

ឃុំឃាំងក្នុងតំបន់គោកយ៉ាក ជំរំបណ្តោះអាសន្ន និងជំរំ ប្រមូលផ្តុំក្រោមស្ថានភាពដែលបាន បង្កើតឡើងដើម្បីបង្កឱ្យមានការបន្ថោកបន្ទាប [ជនរងគ្រោះ] ការដកហូតសិទ្ធិជាមនុស្សនិងជិះជាន់ពួកគេ និងបង្កទុក្ខវេទនា និងការធ្វើទារុណកម្មដ៏អមនុស្សធម៌ទៅលើពួកគេ"។

១២៣១- ធាតុផ្សំអត្តនោម័តដែលតម្រូវឱ្យមានជាចាំបាច់សម្រាប់អំពើប្រល័យពូជសាសន៍នេះ គឺចេតនានេះឯង ពោលគឺបន្ថែមពីលើការមានចេតនាចាំបាច់ ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គេត្រូវបង្ហាញឱ្យឃើញថាជនជាប់ចោទបានប្រព្រឹត្តអំពើនេះ ក្នុងចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយ ឬផ្លូវចិត្តដល់សមាជិកម្នាក់ ឬច្រើននៃក្រុមដែលត្រូវទទួលបានការការពារ។

## ការធ្វើដោយចេតនាឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក

១២៣២- អំពើប្រល័យពូជសាសន៍ប្រភេទនេះ រាប់បញ្ចូលនូវ"វិធីសាស្ត្រនៃការបំផ្លិចបំផ្លាញ ដែលចារីពុំសម្លាប់សមាជិកក្រុមភ្លាមៗឡើយ ប៉ុន្តែទីបំផុតគឺចង់បំផ្លិចបំផ្លាញរាងកាយ"។ គេត្រូវបង្ហាញឱ្យឃើញថាចារីបានមានចេតនាឱ្យមាន *ស្ថានភាពទាំងនេះ* (ឧទាហរណ៍ ខុសពីការប្រហារជីវិតជនរងគ្រោះក្នុងពេលបន្ទាប់) សម្រាប់បំផ្លិចបំផ្លាញរាងកាយនៃក្រុមគោលដៅទាំងស្រុងឬមួយផ្នែក។ ស្ថានភាពជាក់លាក់ទាំងប៉ុន្មាន ដែលស្ថិតក្នុងប្រភេទនៃអំពើប្រល័យពូជសាសន៍នេះ រួមមាន (១)ការខ្វះទីកន្លែងស្នាក់នៅ សម្លៀកបំពាក់ អនាម័យ និងការថែទាំវេជ្ជសាស្ត្រត្រឹមត្រូវ ឬការកាត់បន្ថយសេវាវេជ្ជសាស្ត្រចាំបាច់ ដែលពុំគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវអប្បបរមា។ (២)ការងារ ឬពលកម្មច្រើនហួសចំនួន (៣)ការរំលោភសេពសន្ថវៈ (៤)ការធ្វើឱ្យប្រជាជនអត់ឃ្លាន ឬឱ្យពួកគេទទួលបានអាហារត្រឹមមួយរស់ និង(៥)ការជម្លៀសប្រជាជនជាលក្ខណៈ

ប្រព័ន្ធចេញពីផ្ទះសម្បែងរបស់ពួកគាត់។ គេពុំចាំបាច់បង្ហាញនូវភស្តុតាងបញ្ជាក់ថាមានការបំផ្លិចបំផ្លាញរាងកាយជាក់ស្តែងនៃក្រុមគោលដៅទាំងស្រុង ឬមួយផ្នែកឡើយ។

## ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតដល់ទារកក្នុងក្រុម

១២៣៣- អំពើប្រល័យពូជសាសន៍ប្រភេទនេះរាប់បញ្ចូល ការកាត់សរីរាង្គបន្តពូជ ការធ្វើមិនឱ្យមានកូន ការគ្រប់គ្រងកំណើតទារកដោយបង្ខំ ការបំបែកបុរសនិងស្ត្រីមិនឱ្យនៅជាមួយគ្នា និងការហាមឃាត់ការរៀបការ។ វិធានការនានាក្នុងចេតនាទប់ស្កាត់កំណើត ទារកក្នុងក្រុមក៏អាចជាព្យសនកម្មផ្លូវចិត្តដែរ។ ការរំលោភសេពសន្ថវៈ ឬការមានគភ៌ដោយបង្ខំ អាចរាប់ថាជាវិធានការដើម្បីទប់ស្កាត់កំណើតទារកក្នុងក្រុម ក្នុងករណីយ៉ាងហោចណាស់ ចំនួន ២ប្រភេទ៖ (១)ក្នុងករណីស្ត្រីណាម្នាក់ក្នុងក្រុមណាមួយ ដែលសមាជិកភាពត្រូវបានកំណត់ដោយអត្តសញ្ញាណរបស់ឪពុក ត្រូវបានគេរំលោភសេពសន្ថវៈ និងធ្វើឱ្យមានគភ៌ដោយបានគិតទុកជាមុនពីសំណាក់បុរសណាម្នាក់នៃក្រុមមួយផ្សេងទៀត ក្នុងចេតនាឱ្យស្ត្រីនោះបង្កើតកូន ដែលកូននោះនឹងពុំត្រូវបានគេចាត់ទុកថាជាសមាជិកនៃក្រុមរបស់ស្ត្រីនោះ (២)ក្នុងករណីរំលោភសេពសន្ថវៈ នៅពេលជនរងគ្រោះប្រកែកជាបន្តបន្ទាប់ពុំព្រមបង្កើតកូន តាមមធ្យោបាយតែមួយដែលនាំឱ្យជនរងគ្រោះពុំអាចបង្កើតកូនបាន តាមរយៈការគំរាមកំហែង ឬការប៉ះទង្គិចផ្លូវចិត្ត។

## ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយ ទៅឱ្យក្រុមមួយផ្សេងទៀត

១២៣៤- និយមន័យនៃអំពើប្រល័យពូជសាសន៍នេះ ក្នុងមាត្រា៤ ខុសប្លែកគ្នាបន្តិចបន្តួចពីបទប្បញ្ញត្តិ ក្នុងមាត្រា II នៃអនុសញ្ញាប្រល័យពូជសាសន៍ (ដែលបានសរសេរថា “ការបញ្ជូនកុមារនៃក្រុមមួយទៅក្រុមមួយដោយបង្ខំ”)។ ប៉ុន្តែអត្ថន័យគឺតែមួយ។ គោលបំណងនៃបទប្បញ្ញត្តិនេះគឺការ ដាក់

ទណ្ឌកម្ម "ពុំត្រឹមតែទៅលើអំពើផ្ទាល់នៃការជម្លៀសដោយបង្ខំណាមួយឡើយ ប៉ុន្តែទៅលើអំពើគំរាមកំហែង ឬការបង្កការប៉ះទង្គិចផ្លូវចិត្តណាមួយដែលបណ្តាលនាំឱ្យមានការជម្លៀសដោយបង្ខំ"។

## បទល្មើសដែលអាចផ្តន្ទាទោសបាន

## សេចក្តីផ្តើមទាក់ទិននឹងទម្រង់នៃការចូលរួម

១២៣៥- មាត្រា៤ នៃច្បាប់ អ.វ.ត.ក រៀបរាប់នូវអំពើទាំងឡាយដែលអាចផ្តន្ទាទោសបាន ដែលអំពើទាំងនោះខុសគ្នាពីអំពើនានាដែលមានក្នុងមាត្រាII នៃអនុសញ្ញាប្រល័យពូជសាសន៍។ អំពើមួយចំនួនដូចជា (១)"អំពើប្រល័យពូជសាសន៍" (២)"ការញុះញង់ជាសាធារណៈ និងដោយផ្ទាល់ឱ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍" និង (៣)"ការសមគំនិតក្នុងអំពើប្រល័យពូជសាសន៍" ពុំមានរៀបរាប់ក្នុងមាត្រា៤ឡើយ។ បើទោះបីជាយ៉ាងដូច្នេះក្តី ដូចដែលនឹងលើកយកមកបង្ហាញខាងក្រោម ទម្រង់ទូទៅនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម(ការរៀបចំផែនការ ការបញ្ជា ការជួយនិងជម្រុញ, និងការប្រព្រឹត្តិ) អាចយកមកអនុវត្តបានចំពោះមាត្រា៤។

១២៣៦- មាត្រា៤ នៃច្បាប់ អ.វ.ត.ក បញ្ជាក់ថាអំពើខាងក្រោមនេះអាចផ្តន្ទាទោសបាន (ដោយមានចំណុចខុសគ្នាខ្លះពីបទប្បញ្ញត្តិដែលស្រដៀងគ្នានេះក្នុងអនុសញ្ញាប្រល័យពូជសាសន៍)៖

(ក) ការប៉ុនប៉ងប្រព្រឹត្តអំពើនៃការប្រល័យពូជសាសន៍ (ក្នុងអនុសញ្ញាប្រល័យពូជសាសន៍ "ការប៉ុនប៉ងប្រព្រឹត្តប្រល័យពូជសាសន៍")

(ខ) ការឃុបឃិតប្រព្រឹត្តអំពើនៃការប្រល័យពូជសាសន៍ (ក្នុងអនុសញ្ញាប្រល័យពូជសាសន៍ "ការឃុបឃិតប្រព្រឹត្តប្រល័យពូជសាសន៍") និង

(គ) ការចូលរួមក្នុងអំពើនៃការប្រល័យពូជសាសន៍ (ពុំមានក្នុងអនុសញ្ញាប្រល័យពូជសាសន៍ទេ)។

## ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍

១២៣៧- ការប៉ុនប៉ងប្រព្រឹត្តប្រល័យពូជសាសន៍ គឺជាបទល្មើសបឋមដែលផ្តន្ទាទោស "ការប្រព្រឹត្តិអំពើមួយចំនួនដែលអាចរាប់ថាជាជំហានមួយក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយទៀត បើទោះបីជាតាមការពិតឧក្រិដ្ឋកម្មនោះពុំត្រូវបានប្រព្រឹត្តក្តី"។ មាត្រា២៥(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូមដែលបានដាក់បញ្ចូលការប៉ុនប៉ង ជាទម្រង់មួយនៃការទទួលខុសត្រូវជាធរមានចំពោះអំពើប្រល័យពូជសាសន៍ គូសបញ្ជាក់ថា "ជនម្នាក់ត្រូវទទួលខុសត្រូវ និងទទួលទណ្ឌកម្មជាលក្ខណៈបុគ្គលចំពោះបទល្មើសព្រហ្មទណ្ឌដែលស្ថិតក្នុងយុត្តាធិការតុលាការប្រសិនបើជននោះ៖ មាត្រា ២៥(៣)(ច) ប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ ដោយការធ្វើសកម្មភាពដែលចាប់ផ្តើមការអនុវត្តដោយជំហានជាសារវន្ត ប៉ុន្តែបទល្មើសព្រហ្មទណ្ឌមិនបានកើតមានឡើងដោយសារតែកាលៈទេសៈ មិនពាក់ព័ន្ធនឹងចេតនារបស់ជននោះទេ។ ទោះបីជាយ៉ាងណាក្តី ជនដែលបោះបង់សេចក្តីខិតខំប្រឹងប្រែងក្នុងការប្រព្រឹត្តិបទល្មើសនោះ ឬទប់ស្កាត់ការប្រព្រឹត្តិបទល្មើសនោះមិនត្រូវទទួលទោសទណ្ឌក្រោមច្បាប់លក្ខន្តិកៈនេះ ចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ ប្រសិនបើជននោះបានបោះបង់ចោលទាំងស្រុង និងដោយស្ម័គ្រចិត្តនូវគោលបំណងឧក្រិដ្ឋនោះ"។

## ការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍

១២៣៨- ការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺជា "ការឯកភាពគ្នារវាងមនុស្ស២នាក់ ឬច្រើនដើម្បីប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍"។ មិនខុសគ្នាពីការប៉ុនប៉ងប្រព្រឹត្តប្រល័យពូជ

សាសន៍ទេ ការឃុបឃិតគឺជាបទល្មើសបឋម ពោលគឺគេអាចផ្តន្ទាទោសអំពើឃុបឃិតនេះបាន បើទោះបីជាតាមការពិតអំពើប្រល័យពូជសាសន៍ពុំបានកើតឡើងក្តី។ ការមានការឯកភាពគ្នានេះ តំណាងឱ្យអំពើឧក្រិដ្ឋនៃឧក្រិដ្ឋកម្ម ហើយគេអាចរកឃើញនូវអំពើនេះតាមរយៈការបញ្ជាក់ឱ្យ ឃើញថាមានការប្រជុំរៀបចំផែនការសម្រាប់ប្រល័យពូជសាសន៍។ គេក៏អាចសន្និដ្ឋានបានផង ដែរថាមានការឯកភាពគ្នា និងវាពុំចាំបាច់ជាការឯកភាពគ្នាជាផ្លូវការឡើយ។ ភស្តុតាងបញ្ជាក់ អំពីអំពើរួមគ្នា ឬសហការគ្នារបស់មនុស្សមួយក្រុម អាចគ្រប់គ្រាន់ក្នុងការបញ្ជាក់ថាមានការ យល់ព្រមឯកភាពគ្នា។ ធាតុផ្សំអត្តនោម័តនៃបទល្មើសឃុបឃិតគឺ "ចេតនាបំផ្លិចបំផ្លាញទាំង ស្រុង ឬមួយផ្នែក នៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនាណាមួយ"។

## ការចូលរួមក្នុងអំពើប្រល័យពូជសាសន៍

១២៣៩- ឃ្លាថា "ការចូលរួមក្នុងអំពើប្រល័យពូជសាសន៍" ពុំឃើញមានប្រើប្រាស់ក្នុងអនុសញ្ញាប្រល័យ ពូជសាសន៍ឡើយ។ ការប្រើប្រាស់ឃ្លានេះក្នុងមាត្រា៤ គួរត្រូវចាត់ទុកថាជាការបញ្ជាក់អះអាង អំពីអង្គហេតុដែលទម្រង់បទដ្ឋាននៃការចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលមានក្នុងមាត្រា២៩ យកមក អនុវត្តចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ពាក្យថា "ការចូលរួម" គឺពុំមែនជាពាក្យដែលមាន អត្ថន័យពិសេសឡើយ។ អត្ថន័យធម្មតារបស់វាគឺ "អំពើនៃការចូលរួមក្នុងអ្វីមួយដូចជា ... ឧក្រិដ្ឋកម្មណាមួយ..."។ តាមយុត្តិសាស្ត្រ "ការចូលរួម" ត្រូវបានប្រើប្រាស់សំដៅជារួមទៅដល់ ទម្រង់នៃការទទួលខុសត្រូវក្នុងការប្រព្រឹត្ត ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និង ការជួយនិងជម្រុញ រួមទាំងពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍។

១២៤០- មាត្រា ២៩ ធ្វើឱ្យទម្រង់នៃការចូលរួមក្នុងឧក្រិដ្ឋកម្មមួយចំនួនខាងលើ អាចយកមកអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ "ជនសង្ស័យណាមួយដែលបានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជម្រុញ ឬប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងមាត្រា...៤...នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ"។ ប្រហាក់ប្រហែលគ្នានេះ បន្ថែមពីលើការរៀបរាប់អំពើទាំងឡាយ ដែលអាចផ្តន្ទាទោសបានក្នុងបទប្បញ្ញត្តិស្តីពីអំពើប្រល័យពូជសាសន៍របស់ខ្លួន លក្ខន្តិកៈនៃតុលាការ*ពិសេស* មានចែងអំពីទម្រង់នានានៃការចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលទម្រង់ទាំងនោះស្រដៀងគ្នានឹងទម្រង់នានាក្នុងមាត្រា២៩ [សម្រាប់តុលាការ ICTY ទម្រង់ទាំងនោះស្ថិតក្នុងមាត្រា ៧ (១)]។ ក្នុងការដោះស្រាយបញ្ហា "ត្រួតគ្នា" អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា "ទម្រង់នៃការចូលរួម" នៃមាត្រា ៧(១) គួរត្រូវបានគេ "សន្និដ្ឋានពី" បទប្បញ្ញត្តិស្តីពីអំពើប្រល័យពូជសាសន៍របស់លក្ខន្តិកៈតុលាការ ICTY [មាត្រា៤(៣)] ។ តាមលក្ខណៈនេះ ការជួយនិងជម្រុញ ដែលជាទម្រង់មួយនៃការទទួលខុសត្រូវដែលមានចែងច្បាស់ក្នុងមាត្រា៤(៣) ត្រូវបានចាត់ទុកថាអាចយកមកអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ម្យ៉ាងទៀត "ដោយហេតុថាមនុស្សសំខាន់សម្រាប់ការទទួលខុសត្រូវដែលបានរៀបរាប់ក្នុងមាត្រា៧(១) មានលក្ខណៈជាក់លាក់ និងមានការកំណត់វិតត្បិតជាងមាត្រា៤(៣) មាត្រា៧(១) អាចមានប្រយោជន៍ក្នុងការកំណត់ទម្រង់នៃការចូលរួមរបស់ជនជាប់ចោទក្នុងកម្រិតជាក់លាក់ណាមួយ"។

១២៤១- ក្នុងការយកទម្រង់នៃការទទួលខុសត្រូវចំពោះ ការជួយនិងជម្រុញ មកអនុវត្តចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តុលាការ ICTY បានសម្រេចថាអ្នកជួយ និងជម្រុញ ត្រូវតែដឹងអំពីចេតនា

ប្រល័យពូជសាសន៍របស់ចារី ប៉ុន្តែអ្នកជួយនិងជម្រុញពុំចាំបាច់ត្រូវមានចេតនាប្រល័យពូជសាសន៍ឡើយ។ ក្នុង "ការប្រព្រឹត្ត" អំពើប្រល័យពូជសាសន៍ ជនជាប់ចោទពុំចាំបាច់បានប្រព្រឹត្តអំពើទាំងនោះ "ដោយផ្ទាល់ដៃឡើយ"។ ប៉ុន្តែ គេអាចរកឃើញថាជនជាប់ចោទបាន "ប្រព្រឹត្ត" អំពើប្រល័យពូជសាសន៍ ដរាបណាអំពើរបស់ខ្លួន "គឺជាផ្នែកសំខាន់មួយនៃអំពើប្រល័យពូជសាសន៍ ដូចការជម្រុញឲ្យមានការសម្លាប់ដែរ"។ បើទោះបីជាយ៉ាងដូច្នេះក្តី អនុសញ្ញាប្រល័យពូជសាសន៍ពុំតម្រូវឲ្យមានការចាត់តាំង ឬប្រព័ន្ធណាមួយដែលបម្រើដល់គោលបំណងប្រល័យពូជសាសន៍ឡើយ ហើយក៏ពុំផាត់ចោលនូវលទ្ធភាពរបស់ "បុគ្គលម្នាក់ដែលប៉ុនប៉ងបំផ្លិចបំផ្លាញក្រុមណាមួយដែរ"។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ [មាត្រា ៥ នៃច្បាប់ អ.វ.ត.ក]

១២៤២- មាត្រា ៥ នៃច្បាប់ អ.វ.ត.ក បានផ្តល់យុត្តាធិការដល់ អ.វ.ត.ក ក្នុងការកាត់សេចក្តីជនជាប់សង្ស័យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ បទល្មើសទាំងនោះរួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ,ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ធាតុផ្សំនៃបទល្មើសនីមួយៗ ត្រូវបានលើកយកមកពិភាក្សាដូចខាងក្រោម។

១២៤៣- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមមាត្រា៥ ត្រូវបានសម្គាល់ដោយលក្ខខណ្ឌតម្រូវទូទៅដែលថាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត "ជាផ្នែកមួយនៃការវាយប្រហារជាទូទៅឬលក្ខណៈជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ

សាសនា"។ ធាតុផ្សំទាំង៥ នៃលក្ខខណ្ឌតម្រូវនេះនឹងលើកយកមកពិភាក្សាទៅតាមលំដាប់លំដោយ។

## លក្ខខណ្ឌតម្រូវទូទៅ

### ការវាយប្រហារ

១២៤៤- ការវាយប្រហារគឺជា "ដំណើរនៃការប្រព្រឹត្តិមួយ ពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើ ហេតុការណ៍ណាមួយ ឬអំពើហឹង្សាមួយចំនួន"។ សញ្ញាណនៃ "ការវាយប្រហារ" សម្រាប់គោលបំណងបង្កើតឱ្យមានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺពុំកំណត់ត្រឹមតែការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធឡើយ ពោលគឺរាប់បញ្ចូលទាំងការធ្វើបាបប្រជាជនស៊ីវិលផង។ "ការវាយប្រហារ" ពុំចាំបាច់ជាការវាយប្រហារខាងយោធា ឬការវាយប្រហារជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធឡើយ។ ក្នុងការវាយប្រហារមួយអាចមានការផ្សំចូលគ្នានូវឧក្រិដ្ឋកម្មទាំងប៉ុន្មានដែលបានរៀបរាប់ខាងលើដូចជា ការធ្វើមនុស្សឃាត ការរំលោភផ្លូវភេទ និងការនិរទេស ជាដើម ។

### ជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ

១២៤៥- ការវាយប្រហារត្រូវមានលក្ខណៈជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ។ លក្ខខណ្ឌតម្រូវទាំងនេះគឺខុសប្លែកពីគេ។ ពាក្យ "ទូទៅ" សំដៅទៅដល់ "លក្ខណៈទ្រង់ទ្រាយធំនៃការវាយប្រហារ និងចំនួននៃមនុស្សដែលគេបានយកធ្វើជាគោលដៅនៃការវាយប្រហារ" ហើយគេអាចបញ្ជាក់ឱ្យឃើញអំពីលក្ខណៈទូទៅនេះតាមរយៈ "អានុភាពត្រួតនៃអំពើអមនុស្សធម៌មួយចំនួន ឬអានុភាពទោលនៃអំពើអមនុស្សធម៌ដែលមានទំហំធំធេង"។ ដូច្នេះ ការវាយប្រហារអាចផ្សំឡើងដោយអំពើតែមួយ

ប៉ុន្តែអំពើនោះត្រូវមានផលវិបាក ឬប៉ះពាល់ដល់មនុស្សមួយចំនួនធំ។ ឧក្រិដ្ឋកម្មនេះពុំចាំបាច់មានលក្ខណៈទូទៅ ឬជាប្រព័ន្ធឡើយ។

១២៤៦- ពាក្យថា "ជាលក្ខណៈប្រព័ន្ធ" ពុំតម្រូវឲ្យមានការវាយប្រហារជាទ្រង់ទ្រាយធំឡើយ ប៉ុន្តែជាការវាយប្រហារពាក់ព័ន្ធនឹង "ប្រភេទនៃអំពើហិង្សាដែលបានរៀបចំទុកជាមុន និងលទ្ធភាព មិនអាចមានក្នុងការកើតឡើងដោយចៃដន្យនូវអំពើទាំងនោះ"។ គេអាចបញ្ជាក់ឲ្យឃើញនូវភាពជាលក្ខណៈប្រព័ន្ធតាមរយៈភស្តុតាងដែលបញ្ជាក់អំពី"ការកើតឡើងដដែលៗនូវអំពើឧក្រិដ្ឋស្រដៀងគ្នាដែលពុំមែនតាមការចៃដន្យ"។

១២៤៧- សញ្ញាបញ្ជាក់ផ្សេងៗ ដែលនាំទៅដល់ការបង្ហាញថាមានការកើតឡើងនូវការវាយប្រហារជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ គឺ "ផលវិបាកនៃការវាយប្រហារទៅលើប្រជាជនគោលដៅ ចំនួននៃជនរងគ្រោះ ប្រភេទនៃអំពើ ការចូលរួមដែលអាចមានពីសំណាក់កម្មាភិបាល ឬរដ្ឋអំណាច ឬគំរូនៃឧក្រិដ្ឋកម្មណាមួយដែលអាចសម្គាល់បាន"។ បើទោះបីជាគេពុំចាំបាច់មានផែនការ ឬគោលនយោបាយណាមួយ ដើម្បីបង្ហាញឲ្យឃើញអំពីការវាយប្រហារជាទូទៅ ឬជាលក្ខណៈប្រព័ន្ធណាមួយក្តី ក៏ការមានផែនការនោះអាចជាភស្តុតាងមួយថែមទៀតដែលបញ្ជាក់អំពីប្រភេទនៃការវាយប្រហារនោះ។ ប្រហាក់ប្រហែលគ្នានេះ បើទោះបីជាក្នុងការបញ្ជាក់ថាមានការវាយប្រហារជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ គេពុំតម្រូវឲ្យមានការប្រើប្រាស់ធនធានសាធារណជន ឬឯកជនច្រើនក្តី ក៏ការប្រើប្រាស់ធនធានទាំងនោះ អាចមានប្រយោជន៍ដល់ការបញ្ជាក់អំពីលក្ខណៈនៃការវាយប្រហារនោះដែរ។

## សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល

១២៤៨- ការវាយប្រហារត្រូវ "សំដៅប្រឆាំងនឹង" ប្រជាជនស៊ីវិល។ ចំណុចនេះតម្រូវថាប្រជាជនស៊ីវិល ត្រូវតែជាគោលដៅចម្បងនៃការវាយប្រហារ ពុំមែនជាជនរងគ្រោះចៃដន្យដោយសារការវាយប្រហារនោះឡើយ។ កត្តានានាដែលកំណត់ថាតើការវាយប្រហារណាមួយ គឺជាការវាយប្រហារសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលរួមមាន៖ មធ្យោបាយ និងវិធីសាស្ត្រដែលគេបាន យកមកប្រើប្រាស់ក្នុងដំណើរនៃការវាយប្រហារ ឋានៈរបស់ជនរងគ្រោះ ចំនួនជនរងគ្រោះ លក្ខណៈរើសអើងនៃការវាយប្រហារ លក្ខណៈនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងដំណើរនៃឧក្រិដ្ឋកម្មនោះ ការប្រឆាំងតបតនឹងអ្នកវាយប្រហារកាលពីពេលនោះ និងក្នុងវិសាលភាពមួយ ដែលគេអាចនិយាយថាកងកម្លាំងដែលធ្វើការវាយប្រហារនោះបានអនុវត្តតាម ឬបានប៉ុនប៉ងអនុវត្តតាមលក្ខខណ្ឌតម្រូវនៃច្បាប់សង្គ្រាម។

១២៤៩- សញ្ញាណស្តីពី "ប្រជាជនស៊ីវិល" សម្រាប់គោលបំណងនៃធាតុផ្សំនេះ សំដៅទៅដល់រាល់មនុស្សទាំងអស់ដែលពុំមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ និងរាប់បញ្ចូលទាំងមនុស្សដែលពុំបានចូលរួមយ៉ាងសកម្មណាមួយក្នុងអរិភាពដូចជា សមាជិកកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ និងមនុស្សដែលគេបានដាក់ឱ្យស្ថិតនៅក្រៅការវាយប្រហារដោយមូលហេតុជំងឺ របួស ការជាប់ឃុំឃាំង ឬបុព្វហេតុផ្សេងៗ។ ពាក្យថា "ណាមួយ" បញ្ជាក់ថាក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពុំត្រូវបានកំណត់ត្រឹមតែចំពោះក្រុមប្រជាជនស៊ីវិលដែលសម្គាល់ដោយសញ្ជាតិ ឬជាតិពន្ធុឡើយ។ បន្ថែមពីលើនេះ "ប្រជាជនស៊ីវិល" ពុំចាំបាច់រាប់បញ្ចូលឡើយនូវប្រជាជនស៊ីវិលទាំងអស់នៃតំបន់ភូមិសាស្ត្រ ដែលរងការវាយប្រហារនោះទេ។ "ប្រជាជនស៊ីវិល" ក៏អាចរាប់បញ្ចូលប្រជាជន

ពុំមែនស៊ីវិល ដែលពុំបានរក្សាអត្តសញ្ញាណជាប្រជាជនស៊ីវិលរបស់ខ្លួន ដរាបណាប្រជាជនទាំងនេះភាគច្រើនជាប្រជាជនស៊ីវិល។

## មូលហេតុរើសអើង

១២៥០- មាត្រា៥ នៃច្បាប់ អ.វ.ត.ក តម្រូវឱ្យការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលនៅក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវផ្អែកតាមមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ ធាតុផ្សំនេះសំដៅទៅលើលក្ខណៈនៃការវាយប្រហារ និងពុំមែនជាធាតុផ្សំនៃបទល្មើសណាមួយជាក់លាក់ឡើយ។ ក្នុងការអនុវត្តការវាយប្រហារ គេត្រូវតែមានចេតនារើសអើង។

## អំពើរបស់ជនជាប់ចោទត្រូវផ្សំបានជាផ្នែកមួយនៃការវាយប្រហារ

១២៥១- អំពើរបស់ជនជាប់ចោទត្រូវបង្កើតបានជាផ្នែកមួយនៃការវាយប្រហារ។ ចំណងពាក់ព័ន្ធចាំបាច់រវាងអំពើរបស់ជនជាប់ចោទ និងការវាយប្រហារ មានធាតុផ្សំចំនួន២៖ ការប្រព្រឹត្តិអំពើមួយដែលតាមលក្ខណៈ ឬផលវិបាករបស់វា ជាផ្នែកមួយនៃការវាយប្រហារ គួបផ្សំនឹងការដឹងឮរបស់ជនជាប់ចោទថាមានការវាយប្រហារលើប្រជាជនស៊ីវិល និងអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនោះ។ ពាក់ព័ន្ធនឹងធាតុផ្សំទី១ គេពុំចាំបាច់ប្រព្រឹត្តអំពើទាំងនោះនៅពេលណាមួយក្នុងអំឡុងពេលវាយប្រហារ ដើម្បីឱ្យគេអាចភ្ជាប់អំពើទាំងនោះទៅនឹងការវាយប្រហារឡើយ។ អំពើណាមួយដែលត្រូវបានប្រព្រឹត្តនៅមុនពេល ឬក្រោយពេលវាយប្រហារ អាចនៅតែត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃការវាយប្រហារដដែល ប្រសិនបើអំពើនោះពុំស្ថិតនៅដាច់ដោយឡែកពីការវាយប្រហារ។ ចំពោះធាតុផ្សំទី២ ពុំតម្រូវឱ្យមានការដឹងឮ លម្អិតអំពីការ

វាយប្រហារទេ។ វាគ្រាន់តែត្រឹមថា ចារីបានដឹងអំពីបរិបទទូទៅដែលអំពើរបស់គាត់បានកើតមានក្នុងបរិបទនោះ គឺគ្រប់គ្រាន់ហើយ។ មូលហេតុដែលជម្រុញឱ្យចារីប្រព្រឹត្តអំពើទាំងនោះគឺពុំជាប់ពាក់ព័ន្ធទេ ហើយចារីពុំចាំបាច់បានយល់ព្រមឯកភាពទៅនឹងការវាយប្រហារនោះឡើយ។

## បទល្មើសជាក់លាក់មួយចំនួន

### ការធ្វើមនុស្សឃាត

១២៩២- ការធ្វើមនុស្សឃាត ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តម្រូវឱ្យមានភស្តុតាងបញ្ជាក់អំពីធាតុផ្សំចំនួន ៣ គឺ (១)ការស្លាប់របស់ជនរងគ្រោះ (២)ការស្លាប់បណ្តាលមកពីអំពើសកម្ម ឬអកម្ម របស់ជនជាប់ចោទ ឬរបស់មនុស្ស ដែលអំពើសកម្ម ឬអកម្មរបស់ខ្លួន ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និង (៣)ជនជាប់ចោទបានប្រព្រឹត្តអំពើសកម្ម និងអំពើអកម្ម ឬរបស់មនុស្សដែលអំពើសកម្ម ឬអកម្មរបស់ខ្លួន ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្នុងចេតនាសម្លាប់ ឬបង្កព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយ ឬរបួសស្នាមធ្ងន់ធ្ងរ ដោយដឹងថាអំពើសកម្ម ឬអកម្មទាំងនេះទំនងជាអាចបង្កឱ្យមានការស្លាប់។ ការបង្កព្យសនកម្មធ្ងន់ធ្ងរផ្នែករាងកាយដោយចេតនា ដោយការធ្វេសប្រហែសពុំបានគិតថាតើអាចនឹងបណ្តាលឱ្យមានការស្លាប់ ឬយ៉ាងណានោះ ត្រូវបានគេយល់ថាគ្រប់គ្រាន់ដើម្បីផ្សំបានជា *ចេតនាឧក្រិដ្ឋ* សម្រាប់ការធ្វើមនុស្សឃាត និងការសម្លាប់ដោយខុសច្បាប់។ គេពុំចាំបាច់យកសាកសពជនរងគ្រោះធ្វើជាភស្តុតាងបញ្ជាក់អំពីការស្លាប់ឡើយ។

### ការសម្លាប់រង្គាល

១២៥៣- ការសម្លាប់រង្គាល ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តម្រូវឱ្យធាតុផ្សំចំនួន២ ដើម្បីបញ្ជាក់ថាពិតជាមានបទល្មើសនេះ គឺ (១)អំពើសកម្ម ឬអកម្ម ឬការផ្សំចូលគ្នានៃអំពើ បានរួមចំណែកដល់ការសម្លាប់មនុស្សមួយចំនួនធំ និង(២)ចារីមានចេតនាសម្លាប់ បង្កព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវកាយ ឬបង្ករបួសស្នាមធ្ងន់ធ្ងរ ដោយបានដឹងថាអំពើសកម្ម ឬអំពើអកម្មទាំងនោះអាចបង្កឱ្យមានការស្លាប់ ឬមានចេតនាចូលរួមក្នុងការកម្ចាត់មនុស្សមួយចំនួន ដោយបានដឹងថាអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃ ការសម្លាប់ដ៏ធំមួយ ដែលក្នុងនោះមនុស្ស មួយចំនួនធំត្រូវបានកំណត់អត្តសញ្ញាណជាលក្ខណៈប្រព័ន្ធដើម្បីសម្លាប់ ឬមនុស្សទាំងនោះត្រូវបានសម្លាប់ជាលក្ខណៈប្រព័ន្ធ។ គេអាចបញ្ជាក់ថាមានការសម្លាប់ជាទ្រង់ទ្រាយធំតាមរយៈភស្តុតាង ដែលថាជនរងគ្រោះបានត្រូវទទួលរងស្ថានភាព ដែលរួមចំណែកដល់ការស្លាប់របស់ពួកគេដូចជាការពុំ ផ្តល់ម្ហូបអាហារ ឬថ្នាំសង្កូវ ដែលត្រូវបានគិតទុកដើម្បីបង្កការវិនាសមួយផ្នែកនៃប្រជាជន។

១២៥៤- ការសម្លាប់រង្គាល និងការធ្វើមនុស្សឃាតពុំខុសគ្នានៅត្រង់តែចំនួនប៉ុណ្ណោះទេ ប៉ុន្តែគឺពាក់ព័ន្ធទៅនឹងជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះ និងលក្ខណៈដែលពួកគេត្រូវបានកំណត់យកធ្វើជាគោលដៅនៃឧក្រិដ្ឋកម្មទៀតផង។ ខុសគ្នាពីអំពើមនុស្សឃាត ការសម្លាប់រង្គាលត្រូវបានអនុវត្តសំដៅប្រឆាំងនឹងប្រជាជនទាំងមូលពុំមែនបុគ្គលណាម្នាក់ទេ។ បើទោះបីជាយ៉ាងដូច្នេះក្តី ពុំមានចំនួនអប្បបរមានៃជនរងគ្រោះ ដើម្បីបំពេញលក្ខខណ្ឌតម្រូវដែលថាការស្លាប់ត្រូវតែមាន“ទំហំធំធេង” ឡើយ។ គេត្រូវវាយតម្លៃចំនួនមនុស្សស្លាប់តាមមួយករណីម្តងដោយពិចារណាអំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលគេបានរកឃើញ និងកត្តាពាក់ព័ន្ធផ្សេងៗ។ ជនរងគ្រោះមួយចំនួនធំ

អាចជាស្ថានទម្ងន់ទោស ពាក់ព័ន្ធនឹងការវិនិច្ឆ័យទោសឧក្រិដ្ឋកម្មនេះ ប្រសិនបើទំហំនៃការសម្លាប់នេះធំជាងទំហំនៃការសម្លាប់ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ ការសម្លាប់រង្គាល។

**ការធ្វើឱ្យទៅជាទាសករ**

១២៩៥- ការធ្វើឱ្យទៅជាទាសករត្រូវបានឱ្យនិយមន័យថាជាការប្រើប្រាស់ដោយចេតនា នូវអំណាចកម្មសិទ្ធិទៅលើមនុស្សណាម្នាក់។ កត្តាទាំងឡាយដែលបញ្ជាក់ថាមានការដាក់ជាទាសករ រួមមាន "ការគ្រប់គ្រងការដើរហើររបស់មនុស្សណាម្នាក់ ការគ្រប់គ្រងបរិស្ថានរាងកាយ ការគ្រប់គ្រងផ្លូវចិត្ត ការដាក់វិធានការទប់ស្កាត់ ឬបង្អាក់ការរត់គេចខ្លួន ការបង្ខំ ការគំរាមប្រើកម្លាំង ឬការចាប់បង្ខំ ថិរវេលា ការកំណត់សិទ្ធិផ្តាច់មុខ ការធ្វើបាប និងបំពារបំពាន ការគ្រប់គ្រងជីវិតផ្លូវភេទ និងការធ្វើការងារពលកម្មដោយបង្ខំ"។ ការដាក់ជាទាសករអាចខុសពីការបង្ខាំង ត្រង់កត្តាមួយចំនួនដូចជា ការប្រើប្រាស់ការងារពលកម្មដោយបង្ខំ ការងារលំបាកយ៉ាប់យ៉ឺន និងការខ្វះការផ្តល់រង្វាន់។ រយៈកាលនៃការដាក់ជាទាសករគឺពុំមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្ម ប៉ុន្តែវាជាកត្តាមួយក្នុងការបញ្ជាក់អំពីធាតុផ្សំនៃឧក្រិដ្ឋកម្មនេះ ពោលគឺ ការធ្វើឱ្យទៅជាទាសករកាន់តែយូរ បទល្មើសកាន់តែធ្ងន់។ ការខ្វះការព្រមព្រៀងក៏ពុំមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករដែរ ប៉ុន្តែវាអាចពាក់ព័ន្ធដល់ការបញ្ជាក់អំពីការប្រើប្រាស់សិទ្ធិអំណាចកម្មសិទ្ធិនៃជនជាប់ចោទ។ ដូចដែលបានកត់សម្គាល់ខាងលើ ការធ្វើការងារពលកម្មដោយបង្ខំ ឬតាមការបញ្ជា គឺជាសញ្ញាបញ្ជាក់អំពីការដាក់ជាទាសករ និងជាកត្តាមួយដែលគេត្រូវយកមកពិចារណាក្នុងការសម្រេចថាតើការធ្វើឱ្យទៅជាទាសករត្រូវបាន

ប្រព្រឹត្តដែរឬទេ។ តាមវិធីនេះ ការចោទប្រកាន់ពី "បទចាត់តាំងពលកម្មដោយបង្ខំ" អាចផ្សំបានជាមូលដ្ឋាននៃឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ។

## ការដាក់ក្នុងមន្ទីរឃុំឃាំង

១២៥៦- ការដាក់ក្នុងមន្ទីរឃុំឃាំង ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តម្រូវឱ្យគេបញ្ជាក់ នូវធាតុផ្សំចំនួន ៣ គឺ (១)ជនណាម្នាក់ត្រូវបានដកហូតសេរីភាព (២)ការដកហូតសេរីភាព ត្រូវបានធ្វើឡើងតាមទំនើងចិត្ត និង (៣)ជនជាប់ចោទបានប្រព្រឹត្តអំពើសកម្ម ឬអកម្ម ដោយបានដកហូតពីជននោះនូវសេរីភាពរបស់គេ ក្នុងចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពផ្លូវកាយ ឬទាំងបានដឹងថាអំពើសកម្ម ឬអកម្មរបស់ខ្លួន អាចបង្កឱ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពផ្លូវកាយរបស់មនុស្ស។ ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានចាត់ទុកថាជាអំពើធ្វើតាមទំនើងចិត្ត ប្រសិនបើអំពើនេះត្រូវបានធ្វើឡើងពុំមានមូលដ្ឋានគតិយុត្តិត្រឹមត្រូវ និងគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់។ អ្នកទទួលបន្ទុកគុកដែលបានដឹងតាមការសន្មត ឬដោយជាក់ស្តែងថាអ្នកទោសត្រូវបានឃុំឃាំងដោយខុសច្បាប់ ក៏អាចត្រូវទទួលខុសត្រូវចំពោះការដាក់ក្នុងមន្ទីរឃុំឃាំង ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

១២៥៧- ក្នុងការវាយតម្លៃថាតើការដាក់ក្នុងមន្ទីរឃុំឃាំង គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែរ ឬយ៉ាងណា តុលាការអាចពិចារណាថាតើការចាប់ខ្លួនដំបូងគឺខុសច្បាប់ ដូចជាតាមរយៈការពិចារណាថាតើការចាប់ខ្លួននោះបានធ្វើឡើងផ្អែកតាមដីកាចាប់ខ្លួនដែរឬទេ ថាតើអ្នកជាប់ឃុំឃាំងបានដឹងអំពីមូលហេតុនៃការឃុំឃាំងដែរឬទេ ថាតើអ្នកជាប់ឃុំឃាំងបានរងការចោទប្រកាន់ជាផ្លូវការដែរ ឬទេ ថាតើពួកគេបានដឹងអំពីសិទ្ធិនីតិវិធីណាមួយដែរឬទេ ហើយថាតើការ

បន្តឃុំឃាំងជាអំពើស្របច្បាប់ដែរឬទេ។ នៅពេលគេពឹងផ្អែកលើច្បាប់ជាតិណាមួយ ដើម្បីពន្យល់មូលហេតុនៃការដកហូតសេរីភាព ច្បាប់ជាតិនោះមិនត្រូវរំលោភលើច្បាប់អន្តរជាតិឡើយ។

## ការធ្វើទារុណកម្ម

១២៥៨- ការធ្វើទារុណកម្មក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានធាតុផ្សំចំនួន ៣ គឺ (១)ត្រូវមានអំពើសកម្ម ឬអកម្ម ដែលបានបង្កឲ្យមានការឈឺចាប់ ឬទុក្ខវេទនាធ្ងន់ធ្ងរ មិនថាផ្លូវកាយ ឬផ្លូវចិត្ត (២)អំពើសកម្ម ឬអកម្មត្រូវជាអំពើចេតនា និង (៣)អំពើសកម្ម ឬអកម្ម ត្រូវធ្វើឡើងដើម្បីយកព័ត៌មាន ឬ "ការឆ្លើយសារភាព" ការផ្តន្ទាទោស ការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ជនរងគ្រោះ ឬតតិយជន ឬការរើសអើង តាមហេតុផលណាមួយ ប្រឆាំងនឹងជនរងគ្រោះ ឬតតិយជន។ របួសស្នាមជាអចិន្ត្រៃយ៍ពុំមែនជាលក្ខខណ្ឌតម្រូវសម្រាប់ការធ្វើទារុណកម្មទេ ហើយគេក៏ពុំចាំបាច់បង្ហាញ អំពីកម្រិតនៃការឈឺចាប់ដែលបានបង្កឡើងនោះដែរ ពោលគឺការធ្វើទារុណកម្មអាស្រ័យតាមកាលៈទេសៈរបស់មនុស្សម្នាក់ៗ។ លើសពីនេះ ចារីពុំចាំបាច់បានប្រព្រឹត្តអំពើទាំងនោះ ក្នុងនាមជាមនុស្សមានតួនាទីផ្លូវការណាមួយដែរ ។

១២៥៩- ក្នុងករណីពាក់ព័ន្ធនឹងការដាក់ជនរងគ្រោះក្នុងជំរំឃុំឃាំង ស្ថានភាពនៃការឃុំឃាំង ការពុំមានការថែទាំវេជ្ជសាស្ត្រ និងការបំពារបំពានអ្នកទោសជាច្រើនដង និងជាលក្ខណៈប្រព័ន្ធអាចជាសញ្ញាបញ្ជាក់អំពីការធ្វើទារុណកម្ម។ ការបំពារបំពានធ្ងន់ធ្ងរក្នុងអំឡុងពេលសួរចម្លើយ ផ្សំនឹងការចង់យក "ចម្លើយសារភាព" ឬ ព័ត៌មានណាមួយពីអ្នកទោសក៏រាប់ថាជាការធ្វើទារុណកម្ម

ផងដែរ។ អំពើរំលោភផ្លូវភេទក៏ត្រូវបានចាត់ទុកថាបំពេញលក្ខខណ្ឌនៃការឈឺចាប់ធ្ងន់ធ្ងរ និង ទុក្ខវេទនា និងស្មើនឹងការធ្វើទារុណកម្ម។

## ការរំលោភសេពសន្ថវៈ

១២៦០- កន្លងមក មានការខ្វែងយោបល់គ្នាខ្លះ ទៅលើការកំណត់និយមន័យនៃការរំលោភផ្លូវភេទ ក្នុងចំណោមតុលាការអន្តរជាតិ។ នៅពេលដែលតុលាការ ICTR បានអនុម័តយកន័យទូលាយនៃការរំលោភផ្លូវភេទគឺជា "ការឈ្លានពានទៅលើរាងកាយជាលក្ខណៈផ្លូវភេទ ដែលបានប្រព្រឹត្តដោយមនុស្សម្នាក់ ក្រោមកាលៈទេសៈបែបចាប់បង្ខំ" តុលាការ ICTY និង តុលាការ ICC បានអនុម័តយកវិធីសាស្ត្រដែលឆ្លុះបញ្ចាំងយ៉ាងជិតស្និទ្ធទៅនឹងច្បាប់ក្នុងស្រុកជាង។ ជាពិសេសជាងនេះទៅទៀត តុលាការ ICTY បានសម្រេចថា "កត្តាអត្តនោម័តនៃបទល្មើសរំលោភផ្លូវភេទ នៅក្នុងច្បាប់អន្តរជាតិគឺបង្កើតឡើងដោយ៖ ការបញ្ចូលផ្លូវភេទ ទោះបីតិចតួចក៏ដោយ៖ (ក)ទៅក្នុងរន្ធយោនី ឬ ទ្វារលាមកជនរងគ្រោះ ដោយប្រើលិង្គរបស់ចារី ឬ វត្ថុផ្សេងទៀតដែលចារីយកទៅប្រើ ឬ (ខ)ទៅក្នុងមាត់ជនរងគ្រោះ ប្រើលិង្គរបស់ចារី នៅពេលដែលការបញ្ចូលផ្លូវភេទនេះកើតឡើងដោយគ្មានការព្រមព្រៀងពីជនរងគ្រោះ។ ការព្រមព្រៀងនៅក្នុងគោលបំណងនេះ ត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត គឺជាលទ្ធផលដែលកើតចេញពីឆន្ទៈសេរីរបស់ជនរងគ្រោះ ដោយត្រូវបានវាយតម្លៃទៅតាមបរិបទនៃកាលៈទេសៈនៅជុំវិញ។ បំណងឧក្រិដ្ឋជាចេតនាដែលធ្វើឲ្យការបញ្ចូលអង្គជាតិនោះបានសម្រេច និងការយល់ដឹងថា ទង្វើនេះកើតឡើងដោយគ្មានការព្រមព្រៀងពីជនរងគ្រោះ"។ ការកំណត់និយមន័យស្រដៀងគ្នាក៏ត្រូវបានអនុម័តនៅក្នុងធាតុផ្សំបទឧក្រិដ្ឋ ចំពោះការរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងមាត្រា

៧(ឆ)(១)-១ នៃលក្ខន្តិកៈទីក្រុងរ៉ូម និងដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL។ ជាចុងក្រោយ ការកំណត់និយមន័យរបស់តុលាការ ICTY ក៏បានទទួលការគាំទ្រដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ផងដែរ។

១២៦១- ការបង្ខំ ឬ ការគម្រាមប្រើកម្លាំង បានបង្ហាញភ័ស្តុតាងយ៉ាងច្បាស់ពីការមិនព្រមព្រៀង តែការបង្ខំមិនមែនជាធាតុផ្សំមួយនៃបទល្មើសរំលោភសេពសន្ថវៈទេ និងមានកត្តាផ្សេងទៀតជាច្រើនជាជាងការបង្ខំ "ដែលនឹងបញ្ចេញនូវអំពើបញ្ចូលអង្គជាតិដោយគ្មានការព្រមព្រៀង ឬដោយគ្មានការស្ម័គ្រចិត្តពីភាគីជនរងគ្រោះ"។ មិនតម្រូវឱ្យមានភ័ស្តុតាងនៃការរើបម្រះតតាំងវិញពីជនរងគ្រោះទេ។ ប្រការដែលគួរឱ្យកត់សម្គាល់ផងដែរនោះគឺថា កាលៈទេសៈនានាដែលបានស្តែងចេញនៅក្នុងរឿងក្តីភាគច្រើនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋប្រល័យពូជសាសន៍ "ស្ទើរតែនឹងជាការបង្ខំជាសាកលទៅហើយ" ហេតុនេះពិបាកនឹងបង្ហាញឱ្យឃើញពីការព្រមព្រៀងពិតប្រាកដណាស់។ ស្រដៀងគ្នានេះដែរ ស្ថានភាពនៃការចាប់ខ្លួន ឬ ការឃុំឃាំង ត្រូវបានគេទទួលស្គាល់ថា ជាការធ្វើឱ្យចុះថយនូវការព្រមព្រៀងពិតប្រាកដ។ ភ័ស្តុតាងប្រយោលអាចយកមកប្រើដើម្បីបង្ហាញពីអំពីពិរុទ្ធនៃបទល្មើសរំលោភសេពសន្ថវៈបាន។

### ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា

១២៦២- ការធ្វើទុក្ខបុកម្នេញ ត្រូវបានគេកំណត់និយមន័យថាជា "ការបដិសេធដោយកម្រោល ឬ ដោយឥតលាក់លៀម ដោយមូលហេតុនៃការរើសអើង ចំពោះសិទ្ធិជាសារវ័ន្ត ដែលមានចែងក្នុងទម្លាប់អន្តរជាតិ ឬសន្ធិសញ្ញាអន្តរជាតិដោយមានកម្រិតជាស្ថានទម្ងន់ដូចអំពើដទៃទៀត [ដែលបង្កើត

ជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ដែរ"។ ដើម្បីបង្ហាញជាភស្តុតាងចំពោះបទល្មើសនេះ ត្រូវបំពេញទៅតាមធាតុផ្សំពីរគឺ៖ (១)អំពើសកម្ម ឬអកម្ម ដែលការពិតមានការរើសអើងដោយមូលហេតុមួយក្នុងចំណោមមូលដ្ឋានដែលបានរៀបរាប់មកហើយ និង ទាំងការបដិសេធផង ឬ ការបន្ថុចបង្អាក់ នូវសិទ្ធិជាសារវ័ន្ត ដែលមានចែងកំណត់នៅក្នុងទម្លាប់អន្តរជាតិ ឬសន្ធិសញ្ញាអន្តរជាតិនិង (២)អំពើសកម្ម ឬ អកម្ម ដែលត្រូវបានគេអនុវត្ត ដោយមានចេតនារើសអើងដោយមូលហេតុមួយក្នុងចំណោមមូលដ្ឋានដែលបានរៀបរាប់មក។ អំពើតែមួយអាចគ្រប់គ្រាន់ ក្នុងការបង្កើតការធ្វើទុក្ខបុកម្នេញបាន លុះត្រាតែគេបង្ហាញពីធាតុផ្សំទាំងពីរនេះ។

១២៦៣- "អំពើធ្វើទុក្ខបុកម្នេញ" រួមមានបទឧក្រិដ្ឋនានាដែលមានចែងក្នុងមាត្រា៥ រួមទាំងអំពើផ្សេងទៀតដែលមានស្ថានទម្ងន់ទោសស្មើគ្នា ដូចជាអំពើនៃការធ្វើទុក្ខបុកម្នេញនានាដូចតទៅ៖ "ការបំផ្លិចបំផ្លាញជាប្រព័ន្ធនូវវិមាន ឬ អគារដែលតំណាងឱ្យសង្គម សាសនា វប្បធម៌ ឬ ក្រុមណាផ្សេងទៀតជាក់លាក់" ការបៀតបៀន ការប្រព្រឹត្តដោយធ្វើឱ្យអាប់ឱន ការបន្ទាបបន្ថោក និងការធ្វើឱ្យប៉ះពាល់ដល់ផ្នែកចិត្តសាស្ត្រ ការបង្ខំជនរងគ្រោះណាម្នាក់ឱ្យមើលផ្ទាល់នឹងភ្នែក ឬស្តាប់ឮនឹងត្រចៀកនូវការធ្វើទារុណកម្ម ការស្ទួរចម្លើយ និងការប្រព្រឹត្តិអំពើព្រៃផ្សៃនៅក្នុងជំរំពន្ធនាគារណាមួយ ការចាប់ខ្លួនដោយខុសច្បាប់ ការឃុំខ្លួនដោយខុសច្បាប់ ការបង្ខាំងដោយខុសច្បាប់ និងការដាក់គុកដោយខុសច្បាប់ ការបម្លាស់ទីមនុស្សដោយបង្ខំ ការនិរទេស និងការជម្លៀសមនុស្សដោយបង្ខំនៅក្នុងរដ្ឋមួយ ឬ ឆ្លងកាត់ព្រំដែនប្រទេស ការធ្វើការងារពលកម្មដោយបង្ខំ ការធ្វើទារុណកម្ម ការប្រព្រឹត្តយ៉ាងសាហាវព្រៃផ្សៃ និងបែបអមនុស្សធម៌។

១២៦៤- ចេតនាក្នុងការរើសអើង ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញ អាចសំដៅទៅដល់ភ័ស្តុតាងប្រយោលបាន ដូចជាលក្ខណៈនៃការវាយប្រហារ និងកាលៈទេសៈដែលនៅជុំវិញ។ ចេតនាបែបនេះត្រូវបានគេយល់ឃើញ "តាមរយៈការចូលរួមដោយដឹងជាមុនរបស់ចារី ទៅក្នុងប្រព័ន្ធមួយ ឬក្រុមមួយ ដែលមានការរើសអើងដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"។ ជនរងគ្រោះមិនចាំបាច់ចូលរួមជាមួយក្រុមនយោបាយ ពូជសាសន៍ ឬសាសនាទេ ដរាបណាជនរងគ្រោះទាំងនោះ "ត្រូវបានកំណត់ដោយចារីថា ជាសមាជិកក្រុមជនរងគ្រោះនោះ ដោយសារពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ឬមានទំនោរទៅរកក្រុមជនរងគ្រោះទាំងនោះ"។ មិនមានលក្ខខណ្ឌតម្រូវថា ត្រូវតែមានគោលនយោបាយរើសអើងណាមួយកើតឡើងដើម្បីប្រព្រឹត្តការធ្វើទុក្ខបុកម្នេញទេ ឬថា ចារីត្រូវតែមានចេតនាក្នុងការធ្វើទុក្ខបុកម្នេញលើសពីចេតនាដែលមានការរើសអើងឡើយ។

## អំពើអមនុស្សធម៌ផ្សេងទៀត

១២៦៥- "អំពើអមនុស្សធម៌ផ្សេងទៀត" គឺជាប្រភេទនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលនៅសល់ ដែលចាត់ទុកជាបទឧក្រិដ្ឋនូវអំពើដែលមានស្ថានទម្ងន់ស្រដៀងគ្នា ចំពោះអំពើដែលមានរៀបរាប់ជាពិសេស និងជាផ្នែកមួយនៃទម្រង់នៅក្នុងទម្លាប់អន្តរជាតិ។ តទៅនេះជាធាតុផ្សំដែលគេតម្រូវចំពោះអំពើមួយ ដែលត្រូវបានគេចាត់ទុកថាមានលក្ខណៈអមនុស្សធម៌គឺៈ (១)ជនរងគ្រោះទទួលរងព្យសនកម្មផ្នែករាងកាយ ឬ ផ្លូវចិត្តធ្ងន់ធ្ងរ (កម្រិតនៃភាពធ្ងន់ធ្ងរ ត្រូវបានគេវាយតម្លៃទៅតាមករណីជាក់ស្តែង អាស្រ័យទៅតាមកាលៈទេសលៈរបស់បុគ្គល) (២)ការទទួលរងព្យសនកម្មនោះត្រូវតែជាលទ្ធផលពីអំពើសកម្ម ឬអកម្ម របស់ជនជាប់ចោទ ឬ អ្នកនៅក្រោម

បង្គាប់របស់ខ្លួន និង (៣)នៅពេលដែលបទល្មើសណាមួយត្រូវបានប្រព្រឹត្ត ជនជាប់ចោទ ឬអ្នកនៅក្រោមបង្គាប់ ត្រូវបានជំរុញដោយចេតនាមួយ ដែលបណ្តាលឲ្យមានព្យសនកម្មផ្នែករាងកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ដល់ជនរងគ្រោះ។ លក្ខខណ្ឌនៃបំណង ឧក្រិដ្ឋក៏បានបំពេញផងដែរ នៅពេលចារីបានដឹងថា អំពើសកម្ម ឬអកម្មរបស់ខ្លួនទំនងជានឹងបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរផ្នែករាងកាយ ឬផ្លូវចិត្ត ឬជាការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូរជាមនុស្ស។ ភាពធ្ងន់ធ្ងររបស់អំពើនោះ ត្រូវតែជា ភាពធ្ងន់ធ្ងរនៃ "ភាពប្រាកដប្រជាស្រដៀងគ្នា" ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដើម្បីឲ្យអំពើនោះជាអំពើអមនុស្សធម៌បាន តែជនរងគ្រោះមិនចាំបាច់ត្រូវទទួលរងផលប៉ះពាល់រយៈពេលវែងទេ។ គេត្រូវពិចារណាទៅគ្រប់កាលៈទេសៈនៃអង្គហេតុទាំងអស់ ដើម្បីសម្រេចថាតើ ការប្រព្រឹត្តអំពើអមនុស្សធម៌នានានៃបទឧក្រិដ្ឋនោះដូចជា៖ លក្ខណៈនៃអំពើសកម្ម ឬអកម្ម បរិបទដែលអំពើនោះកើតឡើង កាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះរួមមាន អាយុ ភេទនិងសុខភាព និងផលប៉ះពាល់ផ្នែករាងកាយ ផ្លូវចិត្ត និងសីលធម៌ កើតមានចំពោះជនរងគ្រោះឬទេ។

១២៦៦- អំពើអមនុស្សធម៌ដែលគេបានរកឃើញរួមមាន៖ ការបម្លាស់ទីដោយបង្ខំ និងការបញ្ជូនដោយបង្ខំ ការវះកាត់ និងប្រភេទផ្សេងទៀតនៃការបង្កព្យសនកម្មដល់រាងកាយ ការវាយដំ និងអំពើហិង្សាផ្សេងទៀត ការបង្ករបួសស្នាមធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្ត ប្រព្រឹត្តបែបអមនុស្សធម៌ និងការបន្ទាបបន្ថោក ការបង្ខំឲ្យប្រព្រឹត្តអំពើពេស្យាចារ និងការបាត់ខ្លួនដោយបង្ខំ របួសស្នាមធ្ងន់ធ្ងរដល់រាងកាយ និងផ្លូវចិត្ត ការវះកាត់ ការវាយដំ និងប្រភេទផ្សេងទៀតនៃការបង្កព្យសនកម្មដល់រាងកាយ អំពើហិង្សាផ្លូវភេទ និងការឃុំឃាំងក្នុងសភាពសាហាវព្រៃផ្សៃ និង អាក្រក់ជួរជាតិ។ ដោយសារកើតចេញនូវបំណងឧក្រិដ្ឋហើយនោះ ការបង្កការឈឺចាប់ផ្លូវចិត្តដល់តតិយជន (ឧ.

ភាគីនោះបានមើលឃើញផ្ទាល់នឹងភ្នែកនូវការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ប្រឆាំងនឹងគ្រួសារ ឬមិត្តភក្តិរបស់ខ្លួន) ក៏អាចបង្កើតជា "អំពើអមនុស្សធម៌ផ្សេងទៀត" បានដែរ។

១២៦៧- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានកំណត់ដោយការបង្គាប់ឱ្យជនរងគ្រោះ ឈានចូលការរៀបអាពាហ៍ពិពាហ៍ដោយប្រើកម្លាំង គម្រាមប្រើកម្លាំង ឬការបង្ខិតបង្ខំ ត្រូវបានចាត់ទុកថាធ្លាក់ទៅក្នុងកម្រិតនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែរ។ កត្តាសត្យានុម័តនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តម្រូវឱ្យមានការបង្ខំឱ្យទទួលយក "ការរួម សម្ពន្ធភាពជាស្វាមីភរិយាដោយបង្ខំ" ដែលអាចនឹងពាក់ព័ន្ធដល់ករណីយកិច្ចជាច្រើនដូចជា ការរួមសមគ្គសង្វាសដោយគ្មានការព្រមព្រៀង ធ្វើការងារក្នុងគ្រួសារដោយបង្ខំ ការមានផ្ទៃពោះដោយបង្ខំ និងការថែទាំកូនចៅដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍នេះ។ ចារីត្រូវមានចេតនាក្នុងការបង្ខំជនរងគ្រោះឱ្យរួម សម្ពន្ធជាស្វាមីភរិយា ដោយបានដឹងថាទង្វើរបស់ខ្លួន នឹងបណ្តាលឱ្យមានរបួសស្នាមធ្ងន់ធ្ងរផ្នែករាងកាយ ផ្លូវចិត្ត ឬស្មារតី ដល់ជនរងគ្រោះ។ ដោយសារបទល្មើសក៏មានចែងនៅក្នុងផ្នែកនៃបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមដែរនោះ ការមានផ្ទៃពោះដោយបង្ខំក៏ចាត់ទុកនៅក្នុងកម្រិតនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ដែរ។

## អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ [អ.វ.ត.ក មាត្រា៦]

១២៦៨- មាត្រា៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អនុញ្ញាតឱ្យអ.វ.ត.កនាំយកជន សង្ស័យដែលបានប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ មកកាត់ទោស(តទៅនេះហៅថា "អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ")។ បទល្មើសជាក់លាក់ដែលមានចែងក្នុងមាត្រា៦

រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងទៀងទាត់ និងការនិរទេសជនស៊ីវិលដោយខុសច្បាប់។ ធាតុផ្សំនៃបទល្មើសទាំងនេះនឹងត្រូវបានពិភាក្សាដូចខាងក្រោម។

១២៦៩- ចំពោះការប្រព្រឹត្តបទល្មើសទាំងនេះ ដើម្បីបង្កើតបានជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវមានលក្ខខណ្ឌទូទៅមួយចំនួនដូចជា៖ (១)បទល្មើសពិសេសត្រូវបានប្រព្រឹត្តឡើង នៅក្នុងបរិបទដែលមានជម្លោះប្រដាប់អាវុធជាអន្តរជាតិ (២)ចារីត្រូវតែបានដឹងពីកាលៈទេសៈនៃអង្គហេតុដែលបង្កើតឱ្យមានជម្លោះប្រដាប់អាវុធ (៣)អំពើទាំងនោះត្រូវតែបានប្រព្រឹត្តឡើងចំពោះមនុស្ស ឬទ្រព្យសម្បត្តិដែលទទួលការការពារ ក្រោមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មួយ ឬច្រើន និង (៤)ចារីត្រូវតែបានដឹងពីកាលៈទេសៈនៃអង្គហេតុ ដែលបង្កើតនូវឋានៈដែលទទួលការការពារនេះ។

## លក្ខខណ្ឌទូទៅ

## ជម្លោះប្រដាប់អាវុធជាអន្តរជាតិ

១២៧០- លក្ខខណ្ឌជម្លោះប្រដាប់អាវុធជាអន្តរជាតិ មានធាតុផ្សំពីរ៖ ១)ត្រូវតែមានជម្លោះប្រដាប់អាវុធជាអន្តរជាតិ និង ២)ត្រូវតែមានចំណងទាក់ទងរវាងជម្លោះនោះ និងបទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

១២៧១- ជម្លោះប្រដាប់អាវុធជាអន្តរជាតិត្រូវតែមានពិតប្រាកដ។ ជម្លោះប្រដាប់អាវុធមួយមានអត្ថិភាព "នៅពេលណាដែលមានការពឹងប្រយុទ្ធដោយប្រើកងកម្លាំងប្រដាប់អាវុធ រវាងរដ្ឋនិងរដ្ឋ ឬមានអំពើ ហិង្សាប្រដាប់អាវុធដែលអូសបន្លាយពេលវេលា រវាងអាជ្ញាធររដ្ឋាភិបាល និងក្រុមប្រដាប់អាវុធដែលមានការរៀបចំ ឬរវាងក្រុមប្រដាប់អាវុធទាំងនេះនៅក្នុងរដ្ឋមួយ"។ ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ នៅពេលដែលជម្លោះនេះពាក់ព័ន្ធដល់រដ្ឋពីរ ឬច្រើន ហើយ "ច្បាប់មនុស្សធម៌អន្តរជាតិអនុវត្តតាំងពីពេលចាប់ផ្តើមនៃជម្លោះប្រដាប់អាវុធបែបនោះ ហើយបានអូសបន្លាយ រហូតបញ្ចប់អរិភាព ទាល់តែមានកិច្ចព្រមព្រៀងសន្តិភាព"។ បន្ថែមលើនេះទៅទៀត ជម្លោះប្រដាប់អាវុធដែលស្ថិតក្នុងទឹកដីនៃរដ្ឋតែមួយ អាចមានលក្ខណៈជា "អន្តរជាតិបាន (ឬ ដោយអាស្រ័យទៅលើកាលៈទេសៈផង អាចមានលក្ខណៈជាអន្តរជាតិ រួមជាមួយនឹងជម្លោះប្រដាប់អាវុធផ្ទៃក្នុង) ប្រសិនបើ (i)រដ្ឋមួយទៀតធ្វើអន្តរាគមន៍ក្នុងជម្លោះនោះ តាមរយៈកងទ័ពរបស់ខ្លួន ឬ និយាយម៉្យាងទៀត ប្រសិនបើ (ii)អ្នកចូលរួមមួយចំនួននៅក្នុងជម្លោះប្រដាប់អាវុធផ្ទៃក្នុង ធ្វើសកម្មភាពក្នុងនាមរដ្ឋដទៃនោះ"។

១២៧២- ត្រូវមានចំណងទាក់ទងរវាងជម្លោះប្រដាប់អាវុធជាអន្តរជាតិ និងបទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ លក្ខខណ្ឌនៃចំណងទាក់ទងនោះ មិនតម្រូវឲ្យបង្ហាញភស្តុតាងដែលថា បទឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើង ក្នុងវិស័យតែមួយដូចជាសកម្មភាពប្រយុទ្ធជាក់ស្តែង លក្ខខណ្ឌនេះត្រូវបានបំពេញ នៅពេលដែលបង្ហាញថា បទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ "មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ" ទៅនឹងអរិភាពទាំងនោះ។ ទាក់ទិននឹងទិដ្ឋភាពនេះដែរ "ជម្លោះ

ប្រដាប់អាវុធមិនតម្រូវថាជាមូលហេតុ ដែលនាំឱ្យមានការប្រព្រឹត្តអំពើឧក្រិដ្ឋនោះទេ តែយ៉ាងហោចណាស់អត្ថិភាពនៃជម្លោះប្រដាប់អាវុធ បានដើរតួនាទីយ៉ាងសំខាន់ ឱ្យចារីមានលទ្ធភាពប្រព្រឹត្តអំពើនោះ ការសម្រេចចិត្តរបស់គាត់ក្នុងការប្រព្រឹត្តអំពើនោះ លក្ខណៈដែលអំពើនោះត្រូវបានប្រព្រឹត្ត ឬគោលបំណងនៃការប្រព្រឹត្តអំពើនោះ"។

## ជនដែលទទួលការការពារ

១២៧៣- អនុសញ្ញាទីក្រុងហ្សឺណែវទីបួន ពន្លាតឋានៈជា "ជនដែលទទួលការការពារ" ទៅដល់ជនស៊ីវិលដែល "នៅក្នុងដៃភាគីមួយក្នុងជម្លោះ ឬភាគីមានអំណាចគ្រប់គ្រង ដែលជនស៊ីវិលទាំងនោះមិនមានសញ្ជាតិនោះ"។ ចំណុចនេះការពារជនស៊ីវិលដែលស្ថិតនៅក្នុងទឹកដី ដែលគ្រប់គ្រងដោយរដ្ឋជា បច្ចាមិត្ត។ ជាធម្មតា ឋានៈជាជនដែលទទួលការការពារត្រូវបានសម្រេចដោយ លក្ខណៈសញ្ជាតិរបស់ជននោះ តែវាក៏អាចត្រូវបានកំណត់ដោយការអនុវត្តន៍លក្ខខណ្ឌ "ភក្តីភាព" ដែលផ្តោតទៅលើភក្តីភាពរបស់ជននោះ ចំពោះរដ្ឋណាមួយ (ឧ. ភាគីមួយនៅក្នុងជម្លោះប្រដាប់អាវុធ) ជាជាងសញ្ជាតិដើមរបស់ខ្លួន។ តាមវិធីនេះ ជនជាតិភាគតិច អាចជាមធ្យោបាយដែលមានភាពប្រាកដនិយមជាង ក្នុងការសំដែងចេញពីភក្តីភាពចំពោះរដ្ឋមួយយ៉ាងមានប្រសិទ្ធិភាព ហើយជនរងគ្រោះអាចមានឋានៈជា "ជនដែលទទួលការការពារ" សូម្បីតែពេលអ្នកទាំងនោះមានសញ្ជាតិរួមជាមួយចារីក៏ដោយ។

១២៧៤- តាមវិធីនៃការពន្យល់ នៅក្នុងរឿងក្តី *Aleksovski* ដែលអនុវត្តអនុសញ្ញាទីក្រុងហ្សឺណែវទីបួន តុលាការ ICTY បានសម្រេចថា ពួកមូស្លីម បូស្នី គឺជាជនដែលទទួលការការពារ នៅពេលពួកគេនៅក្នុងទឹកដីដែលគ្រប់គ្រងដោយកងទ័ពក្រូអាស៊ី។ នៅក្នុងរឿងក្តី *Delali□* ដែលអនុវត្តការ

សាកល្បងពីភក្តីភាព តុលាការ ICTY បានសម្រេចថា ពួកស៊ែ ប្ញូស្នី គឺជាជនដែលទទួលការការពារ នៅពេលពួកគេនៅក្នុងដៃអាជ្ញាធរបូ ស្នី ដោយសារពួកគេត្រូវបានចាប់ខ្លួន និងឃុំឃាំងដោយមូលហេតុពួកគេមានអត្តសញ្ញាណស៊ែប៊ី។

១២៧៥- អនុសញ្ញាទីក្រុងហ្សឺណែវទីបី ក៏ពន្លាតការការពារផងដែរចំពោះ "សមាជិកកងម្លាំងប្រដាប់អាវុធរបស់ភាគីមួយក្នុងជម្លោះ" ដែលបាន "ធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់បច្ចាមិត្ត"។ ជាធម្មតាឋានៈរបស់ជនដែលទទួលការការពារនេះ ត្រូវបានគេហៅថាជា "ពួកឈ្លើយសឹក"។

## ការដឹងអំពីកាលៈទេសៈជាក់ស្ដែង

១២៧៦- បន្ថែមលើលក្ខខណ្ឌកត្តាអន្តោម័ត សម្រាប់បទឧក្រិដ្ឋកម្មពិសេសៗ ចារីត្រូវ៖ (១)ដឹងអំពីកាលៈទេសៈជាក់ស្ដែងនៃអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាអន្តរជាតិ និង (២)ដឹងអំពីកាលៈទេសៈដែលបង្កើតឋានៈទទួលការការពាររបស់ជនរងគ្រោះ។ ការដឹងថា រដ្ឋបរទេសមួយជាប់ពាក់ព័ន្ធនៅក្នុងជម្លោះប្រដាប់អាវុធនឹងបំពេញតាមធាតុផ្សំទីមួយ។ ការដឹងថា ជនរងគ្រោះដែលជាសមាជិករបស់ភាគីជាសត្រូវក្នុងជម្លោះនឹងបំពេញតាមធាតុផ្សំទីពីរ (ទោះបីដូចបានកត់សម្គាល់ខាងលើថា វាមិនមែនជាយន្តការតែមួយដែលកំណត់ដោយអនុសញ្ញានេះទេ)។ នៅពេលធ្វើការវិភាគទៅលើ បំណងឧក្រិដ្ឋ ត្រូវធ្វើការបែងចែកឱ្យដាច់រវាងចេតនា និងមូលហេតុ នៅពេលដែល "អត្ថិភាពនៃមូលហេតុបុគ្គលមិនបានរារាំងមិនឱ្យចារីមានចេតនាពិសេស [...]" ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ។

## បទល្មើសជាក់លាក់

### ការធ្វើមនុស្សឃាតដោយចេតនា

១២៧៧- ការធ្វើមនុស្សឃាតដោយចេតនា មានធាតុផ្សំបីសំខាន់គឺ៖ ១)ការស្លាប់របស់ជនរងគ្រោះ ដែលជាលទ្ធផលនៃសកម្មភាពរបស់ជនជាប់ចោទ ២)ជនជាប់ចោទមានចេតនាបណ្តាលឱ្យស្លាប់ ឬរបួសស្នាមធ្ងន់ធ្ងរដល់រាងកាយដែលទំនងបណ្តាលឱ្យស្លាប់ និង ៣)អ្នករងគ្រោះគឺជាជនដែលទទួលការការពារ។

### ការធ្វើទារុណកម្ម

១២៧៨- ដោយសារនិយមន័យនៃការធ្វើទារុណកម្មនៅក្នុងច្បាប់អន្តរជាតិ នៅមិនទាន់មានភាពស៊ីសង្វាក់ជាមួយប្រភេទបទល្មើសនោះ បណ្តាធាតុផ្សំដែលបានពណ៌នាទាក់ទិននឹងការធ្វើទារុណកម្ម ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលនៅជាធរមាននៅទីនេះ។

### ការធ្វើបាបដោយអមនុស្សធម៌

១២៧៩- ការធ្វើបាបដោយអមនុស្សធម៌ត្រូវបានកំណត់និយមន័យថា ជាអំពើសកម្ម ឬអកម្មដោយចេតនាដែលបណ្តាលឱ្យមានព្យសនកម្មធ្ងន់ធ្ងរផ្នែកផ្លូវចិត្ត ការឈឺចាប់ ឬរបួសស្នាមរាងកាយ ឬ បង្កើតការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូរជាមនុស្ស ដែលត្រូវបានប្រព្រឹត្តមកលើជនដែលទទួលការការពារ។ និយមន័យប្រភេទនេះគឺជាបញ្ញត្តិកំពូលដែលការរំលោភបំពានធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលមិនបានចែងក្នុងមាត្រា៦ ក៏អាចចាត់ទុកថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដែរ។ ឧទាហរណ៍ ការធ្វើបាបដោយអមនុស្សធម៌ទៅលើជនជាប់ឃុំឃាំង ត្រូវបានគេចាត់ទុកថាត្រូវ

ធ្លាក់ទៅក្នុងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរប្រភេទនេះហើយ។ អំពើនានាដែលមិនដល់កម្រិតនៃការធ្វើទារុណកម្ម ដោយសារការខកខានមិនបានបង្ហាញថា អំពើទាំងនោះត្រូវបានគេអនុវត្ត ដើម្បីគោលបំណងមួយដែលគេហាមឃាត់ ក៏អាចបង្កើតជាការធ្វើបាបដោយអមនុស្សធម៌ដែរ។ បញ្ហាចោទមួយផ្នែកអង្គហេតុដែលត្រូវធ្វើការវិនិច្ឆ័យ ទៅលើគ្រប់កាលៈទេសៈនោះគឺថាតើ អំពើពិសេសនានាបង្កើតជាការធ្វើបាបដោយអមនុស្សធម៌ ដែរឬទេ។

### ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

១២៨០- បទឧក្រិដ្ឋកម្មនេះត្រូវបានកំណត់និយមន័យថាជា អំពើសកម្ម ឬអកម្ម ដែលបានប្រព្រឹត្តមកលើជនដែលទទួលការការពារ ដោយបណ្តាលឲ្យមានការឈឺចាប់ ឬរបួសស្នាមធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព។ ចំណុចនេះរួមមាន អំពើដែលមិនបានបំពេញតាមលក្ខខណ្ឌនៃការធ្វើទារុណកម្ម ទោះបីរាល់អំពើនៃការធ្វើទារុណកម្មទាំងអស់ អាចធ្លាក់នៅក្នុងវិសាលភាព នៃបទល្មើសនេះក៏ដោយ។ ទោះបីជនរងគ្រោះ ត្រូវទទួលរងព្យសនកម្ម "ធ្ងន់ធ្ងរ" ក៏ដោយ តែមិនចាំបាច់បង្ហាញថារបួសស្នាមមួយ ឬច្រើននោះត្រូវទទួលរងការឈឺចាប់ជាអចិន្ត្រៃយ៍ ឬមិនអាចព្យាបាលបាន នោះទេ។ ដោយសារបទល្មើសនេះតម្រូវឲ្យបង្ហាញភស្តុតាងពីការឈឺចាប់ ឬរបួសស្នាមក្នុងកម្រិតធ្ងន់ធ្ងរនោះ ព្យសនកម្មដែលទាក់ទិននឹងសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ជនរងគ្រោះ មិនបានរាប់បញ្ចូលនៅក្នុងបទល្មើសនេះទេ។

### ការដកហូតនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយ យុត្តិធម៌ និង ទៀងទាត់

១២៨១- ការដកហូតពីជនដែលទទួលការការពារ នូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយ យុត្តិធម៌ និងទៀងទាត់ ដោយបដិសេធការធានាតាមប្រព័ន្ធយុត្តិធម៌ ត្រូវបានកំណត់និយមន័យជាពិសេស

នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ទី៣ និងទី៤ ថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទាំងនោះ។ បណ្ដាសិទ្ធិដែលគេមិនអាចបដិសេធបានគឺ៖ (១)សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការកាត់សេចក្ដីដោយតុលាការមួយដែលឯករាជ្យ និងមាន អនាគតិ (២)សិទ្ធិទទួលបានព័ត៌មានសមរម្យអំពីបទល្មើសនានា ដែលជនជាប់ចោទត្រូវ ទទួលការចោទប្រកាន់ (៣)ការការពារប្រឆាំងនឹងការដាក់ទោសជារួម (៤)សិទ្ធិទទួលបានការការពារក្រោមគោលការណ៍នីត្យានុកូលភាព (៥)សិទ្ធិមិនត្រូវទទួលការផ្ដន្ទាទោសលើសពី២ម្ដង ចំពោះអំពើតែមួយ ឬចំពោះបទចោទប្រកាន់តែមួយ (*ne bis in idem*) (៦)សិទ្ធិទទួលបានព័ត៌មានអំពីសិទ្ធិប្ដឹងឧទ្ធរណ៍ និង (៧)សិទ្ធិមិនត្រូវទទួលការដាក់ពន្ធនាគារ ឬ ប្រហារជីវិត ដោយមិនបានប្រកាសសាលក្រមមុន ដោយតុលាការដែលដំណើរការជាទៀងទាត់ទេ។

## ការនិរទេស ឬការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

១២៨២- ឧក្រិដ្ឋកម្មនេះរួមមានបទល្មើសតូចៗចំនួនពីរដាច់ពីគ្នាគឺ៖ (ក)ការនិរទេសឬការជម្លៀសដោយខុសច្បាប់ និង (ខ)ការឃុំខ្លួនដោយខុសច្បាប់។

## ការនិរទេស ឬការជម្លៀសដោយខុសច្បាប់

១២៨៣- មាត្រា១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបួន កំណត់ថា "ការនិរទេស ឬការជម្លៀស ឬការឃុំខ្លួនជនដែលទទួលការការពារដោយខុសច្បាប់" ជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានោះ។ ខណៈដែលការនិរទេសដោយខុសច្បាប់ និងការជម្លៀសដោយខុសច្បាប់ ទាក់ទងទៅនឹងការបន្លាស់ដោយខុសច្បាប់និងដោយគ្មានការស្ម័គ្រចិត្តពីជនដែលទទួលការការពារ ពីកន្លែងដែលពួកគេរស់នៅ ទ្រឹស្ដីទាំងពីរនេះដាច់ពីគ្នា។ នៅពេលដែលការនិរទេសតម្រូវឱ្យមានការជម្លៀស

ចេញឆ្ងាយពីព្រំដែនរដ្ឋ ការជម្លៀសគឺទាក់ទងនឹងការផ្លាស់ប្តូរទីកន្លែងនៅក្នុងរដ្ឋ។ នៅពេលដែលការផ្លាស់ប្តូរទីកន្លែងរបស់មនុស្ស ត្រឹមតែត្រូវបានកំណត់ថាខុសច្បាប់ នៅពេលមានធាតុផ្សំនៃការបង្ខិតបង្ខំ ចំណែកឯការផ្លាស់ប្តូរទីកន្លែងដោយស្ម័គ្រចិត្ត គឺមានលក្ខណៈស្របច្បាប់។ ជាងនេះទៅទៀត ការជម្លៀស ឬការនិរទេស មិនត្រូវបានកំណត់ថាខុសច្បាប់ទេ ប្រសិនបើវាកើតឡើងដោយសារមូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ។ ជាការពិត អនុសញ្ញាទីក្រុងហ្សឺណែវទីបួន មិនបានហាមឃាត់ ការផ្លាស់ប្តូរទីកន្លែង ដោយសារមូលហេតុផ្នែកសន្តិសុខរបស់ប្រជាជន ឬភាពចាំបាច់ផ្នែកយោធាទេ។

១២៨៤- ដើម្បីកំណត់ថា ជាការជម្លៀសដោយខុសច្បាប់ជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ គេត្រូវបង្ហាញថា៖ ជនជាប់ចោទបានអនុវត្តអំពើសកម្ម ឬអកម្មមួយ មិនមែនដោយសារមូលហេតុផ្នែកសន្តិសុខរបស់ប្រជាជន ឬហេតុផលផ្នែកយោធាដាច់ខាត ដែលនាំទៅរកការជម្លៀសមនុស្សដោយបង្ខំ ហើយថា ជននោះមានចេតនាក្នុងការជម្លៀសមនុស្សនោះផង។ លក្ខខណ្ឌទូទៅសម្រាប់មាត្រា៦ ក៏ត្រូវតែបង្ហាញផងដែរ។ ការនិរទេសដោយខុសច្បាប់ ជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ អនុវត្តតាមនិយមន័យដូចគ្នាដែលអាចអនុវត្តបានផងដែរចំពោះ ការនិរទេសដែលជាបទឧក្រិដ្ឋ ប្រឆាំងមនុស្សជាតិ ពោលគឺការផ្លាស់ប្តូរទីកន្លែងមនុស្សដោយបង្ខំ ដោយការបណ្តេញចេញ ឬអំពើដោយបង្ខំផ្សេងទៀត ពីតំបន់ដែលពួកគេតាំងនៅស្របច្បាប់ ដោយគ្មានមូលហេតុនានាដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ។ ការនិរទេស មានធាតុផ្សំសំខាន់ៗដូចការជម្លៀសដោយបង្ខំដែរ។

## ការឃុំខ្លួនដោយខុសច្បាប់

១២៨៥- ធាតុផ្សំនៃការឃុំខ្លួនដោយខុសច្បាប់ ដែលចាត់ទុកថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ មានលក្ខណៈដូចគ្នាបេះបិទនឹងធាតុផ្សំនានានៃការដាក់មនុស្សក្នុងមន្ទីរឃុំឃាំង ដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលត្រូវបានកំណត់ថាជា "ទម្រង់នៃការដកហូតសេរីភាពរបស់បុគ្គលណាម្នាក់ តាមអំពើចិត្ត"។

១២៨៦- ការឃុំខ្លួនជនស៊ីវិលណាម្នាក់ "នឹងស្របច្បាប់បាន លុះត្រាតែស្របតាមលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា៤២ [នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបួន]" និង "នៅពេលប្រតិបត្តិតាមបញ្ញត្តិនៃមាត្រា៤៣ [នៃអនុសញ្ញាទីក្រុងហ្សឺណែវទីបួន]"។ ហេតុនេះ ការឃុំខ្លួនជនស៊ីវិលណាម្នាក់ ជាការខុសច្បាប់ នៅពេលដែលជនស៊ីវិលនោះ "ត្រូវបានឃុំខ្លួនដោយគ្មានមូលហេតុសមរម្យ ដើម្បីឱ្យជឿបានថា សន្តិសុខរបស់អំណាចនៃការឃុំខ្លួនមានលក្ខណៈចាំបាច់ដាច់ខាត" ក្នុងការប្រព្រឹត្តល្មើសមាត្រា៤២ ឬ "នៅពេលដែលការធានាតាមនីតិវិធីដែលតម្រូវដោយមាត្រា៤៣ ... មិនត្រូវបានអនុវត្តតាម ... សូម្បីតែនៅពេលដែលការឃុំខ្លួនបឋមត្រូវបានធ្វើយុត្តិកម្មក៏ដោយ"។

១២៨៧- ក្នុងការសម្រេចពីនីត្យានុកូលភាពនៃការឃុំខ្លួនបឋម ការវិភាគក្រោមមាត្រា៤២ ត្រូវបានជូនដំណឹងដោយបទប្បញ្ញត្តិដទៃទៀតនៃអនុសញ្ញាទីក្រុងហ្សឺណែវទីបួន ដែលអនុញ្ញាតឱ្យព្យួរទុកនូវសិទ្ធិមួយចំនួនរបស់ជនស៊ីវិល ក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ជាពិសេសមាត្រា៥ និងមាត្រា២៧(៤)។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានរកឃើញថា អនុសញ្ញាទីក្រុងហ្សឺណែវមិនបានអនុញ្ញាតឱ្យ "អំណាចដាច់ណាត់ អាចឃុំឃាំងប្រជាជនទាំងមូលរបស់ភាគីមួយនៅក្នុងជម្លោះ បានទេ" "ត្រូវមានការវាយតម្លៃថា ជនស៊ីវិលម្នាក់ដែលត្រូវបានគេនាំទៅឃុំឃាំង អាចបង្កនូវមហន្តរាយដល់សន្តិសុខរបស់រដ្ឋនោះ"។

# ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ [អ.វ.ត.ក មាត្រា៣]

## បទល្មើសជាក់លាក់

១២៨៨- មាត្រា៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ប្រគល់យុត្តាធិការដល់តុលាការនេះ ដើម្បីធ្វើការជំនុំជម្រះបទឧក្រិដ្ឋ នានា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ កម្ពុជាឆ្នាំ១៩៥៦ ដូចខាងក្រោម៖ មនុស្សឃាត (មាត្រា៥០១ ៥០៣ ៥០៤ ៥០៥ ៥០៦ ៥០៧ និង៥០៨) ទារុណកម្ម (មាត្រា៥០០) និង ការប្រឆាំងនឹងសាសនា (មាត្រា២០៩ និង២១០)។

## មនុស្សឃាត

១២៨៩- មនុស្សឃាតអាចធ្វើដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត អាស្រ័យទៅលើករណីថាតើ ការស្លាប់នោះជាលទ្ធផលនៃអំពើដែលបានប្រព្រឹត្ត ដោយមាន ឬគ្មានចេតនាដែលបណ្តាលឲ្យស្លាប់។ មានមនុស្សឃាតចំនួនបីប្រភេទ ដែល អ.វ.ត.ក មានយុត្តាធិការ ដូចជា៖

ក. ***មនុស្សឃាតជាបទឧក្រិដ្ឋថ្នាក់ទីបី*** (ជាមនុស្សឃាតធ្ងន់ធ្ងរ)៖ នេះជាមនុស្សឃាតបណ្តាលមកពី អំពើគិតទុកជាមុន ដែលប្រព្រឹត្តដោយចេតនា បណ្តាលឲ្យស្លាប់ (មនុស្សឃាតធ្ងន់ធ្ងរដោយមានការប៉ុនប៉ង ត្រូវបានបង្កើតដោយការប្រព្រឹត្តអំពើគិតទុកជាមុនដែលបណ្តាលឲ្យស្លាប់ដោយមានចេតនាបណ្តាលឲ្យស្លាប់តែម្តង)។ ការគិតទុកជាមុនត្រូវបានកំណត់និយមន័យថា គឺជា "ការតាំងចិត្តជាស្រេចថា នឹងប្រព្រឹត្តនូវអំពើណាមួយ មុនពេលដែលប្រព្រឹត្តនូវអំពើនោះ គឺថាពេលដែលសម្រេចចិត្ត នឹងពេលដែលប្រព្រឹត្ត មានចន្លោះឃ្លាតពីគ្នាល្មមឲ្យចារីរៀបចំដំណើរការនោះបាន"។

ខ. ***មនុស្សឃាតជាបទឧក្រិដ្ឋថ្នាក់ទីពីរ៖*** នេះជាមនុស្សឃាតដែលបណ្តាលមក ពីអំពើប្រព្រឹត្តដោយមានចេតនាភ្លាមៗដែលបណ្តាលឱ្យស្លាប់ (មនុស្សឃាតថ្នាក់ទីពីរដែលមានការប៉ុនប៉ង ត្រូវបានបង្កើតឡើងដោយ ការប្រព្រឹត្តអំពើដែលអាចបណ្តាលឱ្យស្លាប់ ដោយមានចេតនាភ្លាមៗ ដែលបណ្តាលឱ្យស្លាប់)។

គ. ***មនុស្សឃាតជាបទឧក្រិដ្ឋថ្នាក់ទីមួយ៖*** នេះជាមនុស្សឃាតដែលបណ្តាលដោយអំពើដែលបានប្រព្រឹត្ត ដោយមានចេតនាត្រឹមតែឱ្យឈឺរូបកាយជនរងគ្រោះ តែគ្មានចេតនាបណ្តាលឱ្យស្លាប់ទេ។

១២៩០- ចេតនាបណ្តាលឱ្យស្លាប់គឺត្រូវបានសន្មតទៅលើស្ថានការណ៍ នៅពេលមានប្រើសាស្ត្រាវុធគួរដល់ស្លាប់ ហើយអំពើហិង្សាបានកើតឡើង និងចំនួនរបួសដែលបានបង្ក។

១២៩១- មនុស្សឃាតដោយការបំពុលបង្កើតជាបទឧក្រិដ្ឋថ្នាក់ទីបី នៅពេលដែលការស្លាប់បណ្តាលមកពីការចាត់ចែងលើសារធាតុដែលបណ្តាលឱ្យស្លាប់ដោយចេតនា។ នៅពេលដែលសារធាតុដែលត្រូវបានចាត់ចែងដោយចេតនា មានគ្រោះថ្នាក់ដល់សុខភាព តែពុំបណ្តាលឱ្យស្លាប់ តែបែរជាមានស្លាប់មនុស្សទៅវិញ ចារីមានពិរុទ្ធភាពពីបទមនុស្សឃាត ដែលអាចផ្តន្ទាទោសជាបទឧក្រិដ្ឋថ្នាក់ទីពីរ។ មាត្រា៥០៨ ចែងថា “វត្ថុមានជាតិពុលនោះ ទោះបីមានប្រភេទដូចម្តេចក្តី ទោះមានវិធីដែលដាក់នោះដូចម្តេចក្តី ទោះរយៈវេលាដែលត្រូវពុលស្លាប់នោះមានកំណត់ប៉ុន្មានៗក្តី ក៏ត្រូវទុកជាវត្ថុនោះមានជាតិពុលដល់ស្លាប់ដែរ”។

## ទារុណកម្ម

១២៩២- មាត្រា៥០០ នៃក្រមព្រហ្មទណ្ឌ កម្ពុជានោះបានកំណត់ថា ទារុណកម្មអាចផ្តន្ទាទោសជាបទឧក្រិដ្ឋថ្នាក់ទីបី នៅពេលដែលចារីប្រព្រឹត្តអំពើទារុណកម្មដល់មនុស្សម្នាក់ទៀតៈ

ក. ឲ្យឈឺ ដើម្បីទទួលបានព័ត៌មានផ្សេងៗ ដែលមានប្រយោជន៍ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬមជ្ឈិមកម្មណាមួយ

ខ. ដើម្បីសងសឹក ឬ

គ. ដោយអំពើចិត្តព្រៃរបស់ខ្លួន។

## ការប្រឆាំងនឹងសាសនា

១២៩៣- មាត្រា២០៩ នៃក្រមព្រហ្មទណ្ឌ កម្ពុជានោះ ចែងអំពីការព្យាបាទដល់ជីវិតរបស់បព្វជិតក្នុងសាសនាមួយ នៅពេលដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬនៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិតាមច្បាប់សាសនា ត្រូវមាន ទោសឧក្រិដ្ឋ ថ្នាក់ទីបី។ តាមមាត្រា២១០ ការព្យាបាទដល់រូបកាយរបស់បព្វជិតក្នុងសាសនាមួយ នៅពេលដែលលោកកំពុងធ្វើវត្តប្រតិបត្តិ ឬនៅឱកាសដែលលោកធ្វើវត្តប្រតិបត្តិ តាមច្បាប់សាសនា ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីពីរ។ ក្នុងករណីនៃបទប្បញ្ញត្តិទីពីរនេះ ជនរងគ្រោះត្រូវតែកំពុងធ្វើវត្តប្រតិបត្តិសាសនាមួយដែលទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា។

## ខ- ការទទួលខុសត្រូវជាបុគ្គល

## យុត្តាធិការទៅលើមនុស្ស [អ.វ.ត.ក មាត្រា២]

១២៩៤- ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានកំហិតព្រំដែនយុត្តាធិការរបស់តុលាការនេះទៅលើមនុស្សគឺត្រឹមតែ “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិ ដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយសារទម្លាប់នៃការអនុវត្តដូច្នេះ មិនមែនជាកម្មវត្ថុនៃការពិចារណាដ៏ទូលំទូលាយនៅកម្ពុជាទេ វាជាការសមស្របដែលត្រូវពិចារណាទៅលើការអនុវត្តវិធានស្រដៀងគ្នានៅកំរិតអន្តរជាតិ ។

១២៩៥- យុទ្ធសាស្ត្រនៃការបញ្ចប់របស់តុលាការ ICTY បានតម្រូវឲ្យតុលាការនេះធ្វើការកាត់ទោសតែទៅលើ “មេដឹកនាំជាន់ខ្ពស់ដែលជាប់សង្ស័យពីការទទួលខុសត្រូវខ្ពស់បំផុត”។ សេចក្តីសម្រេចនេះធ្វើឡើង ដោយពិចារណាតែទៅលើករណីដែរ៖ (១)ស្ថានទម្ងន់នៃបទឧក្រិដ្ឋ ដែលចោទប្រកាន់ និង (២)កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ។

១២៩៦- ទាក់ទិននឹងកម្រិតនៃការទទួលខុសត្រូវ តុលាការ ICTY មិនមានកំហិតត្រឹមតែ “មេដឹកនាំជាន់ខ្ពស់បំផុត” ឬត្រឹមមេដឹកនាំផ្នែកគោលនយោបាយប៉ុណ្ណោះទេ តែនៅមានកត្តាពាក់ព័ន្ធមួយចំនួនដែលត្រូវយកមកពិចារណា ដូចជាភាពជាអចិន្ត្រៃយ៍នៃតួនាទី វិសាលភាពនៃពេលវេលា ចំនួនអ្នកនៅក្រោមបង្គាប់ ឋានៈរបស់ជនជាប់ចោទនៅក្នុងរចនាសម្ព័ន្ធឋានានុក្រម និងតួនាទីឧក្រិដ្ឋជាក់ស្តែងរបស់ជនជាប់ចោទ។ កត្តានានាដែលត្រូវយកមកពិចារណា ក្នុងការវិភាគទៅលើស្ថានទម្ងន់នៃបទឧក្រិដ្ឋ ដែលបានចោទប្រកាន់រួមមាន៖ វិសាលភាពនៃពេលវេលា វិសាលភាពនៃភូមិ

សាស្ត្រ ចំនួនជនរងគ្រោះដែលទទួលផលប៉ះពាល់ ចំនួនឧបទ្ទវហេតុដាច់ពីគ្នាដែលជនជាប់ចោទត្រូវទទួលការចោទប្រកាន់ និងលក្ខណៈនៃការប្រព្រឹត្តិបទឧក្រិដ្ឋនោះ។

## ទម្រង់នៃការទទួលខុសត្រូវ

១២៩៧- មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីការខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរួមមាន៖ ១)ជនសង្ស័យដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ អ.វ.ត.ក និង ២)ថ្នាក់លើដែលខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មដល់អ្នកក្រោមបង្គាប់របស់ខ្លួន មិនឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នេះ។ ពីមាត្រា៨២ ដល់មាត្រា៨៨ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ បានពណ៌នាពីទម្រង់នៃការខុសត្រូវ ដែលមានចែងក្នុងច្បាប់នោះ។ ទម្រង់នៃការចូលរួម ឬការខុសត្រូវឧក្រិដ្ឋកម្ម មានរៀបរាប់ពិស្តារដូចខាងក្រោម។

### មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

### បានប្រព្រឹត្ត

### ការប្រព្រឹត្តិ ឬការខកខានស្តែង

១២៩៨- ជនណាម្នាក់*ប្រព្រឹត្ត*បទឧក្រិដ្ឋមួយ នៅពេលដែលជននោះ "ប្រព្រឹត្តជាក់ស្តែងនូវអំពើឧក្រិដ្ឋដែលពាក់ព័ន្ធ ឬធ្វើឲ្យគ្រោះថ្នាក់ដោយសារអំពើការខកខានរបស់ខ្លួន ដែលមានពិរុទ្ធ រំលោភទៅលើវិធានណាមួយនៃច្បាប់ព្រហ្មទណ្ឌ"។ ក៏ប៉ុន្តែ ជនជាប់ចោទមិនចាំបាច់ត្រូវតែបានចូលរួមគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះទេ។ មានចារីជាច្រើន

នាក់អាចនឹងមានពិរុទ្ធភាពពីបទប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ប្រសិនបើ "ចារីម្នាក់បំពេញតាមធាតុផ្សំ" នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។ ការខុសត្រូវខាងព្រហ្មទណ្ឌ ក៏នឹងកើតឡើងផងដែរពីការខកខាន ដែលជនជាប់ចោទស្ថិតក្រោមតួនាទីស្របច្បាប់មួយ ក្នុងការធ្វើសកម្មភាព ហើយខ្លួនបែរជាខកខានមិនបានបំពេញតាមតួនាទីនោះទៅវិញ។ សម្រាប់ជាធាតុផ្សំអន្តោម័ត្តនៃទម្រង់ការខុសត្រូវនេះវិញ បន្ថែមទៅលើចំណុចដែលថា មានចេតនាឧក្រិដ្ឋដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មដែលកំពុងពិភាក្សានោះ ចារីត្រូវមានចេតនាចំពោះអំពើសកម្ម ឬការខកខាននោះ ឬត្រូវតែបានដឹងពីភាពសមទំនងជាសំខាន់ ដែលថា អំពើឧក្រិដ្ឋសកម្ម ឬការខកខានមួយនឹងកើតចេញពីការប្រព្រឹត្តរបស់ខ្លួន។ ជាចុងក្រោយ សម្រាប់បទឧក្រិដ្ឋប្រល័យពូជសាសន៍ *ការប្រព្រឹត្ត*មិនតម្រូវឱ្យមានចារីកម្មដោយផ្ទាល់ និងជាក់ស្តែងទេ បញ្ហាគឺនៅត្រង់ថាតើ សកម្មភាពរបស់ជនជាប់ចោទគឺ "ជាផ្នែកដែលខ្លួនបានចូលរួម ក្នុងប្រល័យពូជសាសន៍ ដូច [អំពើប្រល័យពូជសាសន៍]ដែរ"។

## សហកម្មឧក្រិដ្ឋកម្មរួម

១២៩៩- ការប្រព្រឹត្តិបទល្មើសមួយ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ("JCE") ត្រូវបានទទួលស្គាល់នៅក្នុងយុត្តិសាស្ត្ររបស់តុលាការ ICTY ICTR SCSL និង អ.វ.ត.ក។ **សហកម្មឧក្រិដ្ឋកម្មរួម** ជាទម្រង់នៃទំនួលខុសត្រូវមួយ ដែលដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើបុគ្គល ចំពោះសកម្មភាពដែលបានប្រព្រឹត្តដោយមនុស្សមួយក្រុម ដើម្បីអនុវត្តតាមគម្រោងការឧក្រិដ្ឋកម្មរួមមួយ។

១៣០០- មានទម្រង់ សហកម្មឧក្រិដ្ឋកម្មរួមបី ខុសៗគ្នាតែមានទំនាក់ទំនងរវាងគ្នាគឺ (១)***ជាមូលដ្ឋាន៖*** អ្នកចូលរួមជាជនជាប់ចោទទាំងអស់ ធ្វើសកម្មភាពទៅតាមគម្រោងការឧក្រិដ្ឋរួមមួយ និងមានចេតនាឧក្រិដ្ឋដូចគ្នានៅពេលសកម្មភាព ដើម្បីបំពេញនូវគម្រោងការណ៍ឧក្រិដ្ឋកម្មរួម។ (២)***ជាប្រព័ន្ធ៖*** អ្នកចូលរួមជាជនជាប់ចោទទាំងអស់ ធ្វើសកម្មភាពទៅតាមគម្រោងការឧក្រិដ្ឋរួមមួយ អ្នកទាំងនោះមានចេតនាឧក្រិដ្ឋដូចគ្នា នៅពេលប្រព្រឹត្ត ដើម្បីបំពេញទៅតាមគម្រោងការមួយនោះ ហើយឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះ កើតឡើងនៅក្នុងបរិបទនៃគម្រោងការឧក្រិដ្ឋរួមមួយ *ជាធម្មតា* ត្រូវបានប្រតិបត្តិដោយសមាជិកអង្គភាពយោធា ឬរដ្ឋបាល។ ជាតួយ៉ាង ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមនេះមានភ្ជាប់ទំនាក់ទំនងជាមួយជំរំប្រមូលផ្ដុំ ឬសម្លាប់ផ្ដាច់ពូជ ឬ "ការរៀបចំជាប្រព័ន្ធនៃការធ្វើបាប"។ អត្ថិភាព និង/ឬ ការចូលជាសមាជិកទៅក្នុងអង្គភាពយោធា ឬរដ្ឋបាលណាមួយ មិនមែនជាលក្ខខណ្ឌផ្លូវការទេ តែវាជាការបង្ហាញពីការរៀបចំជាប្រព័ន្ធនៃការធ្វើបាបតែប៉ុណ្ណោះ។ (៣)***ទម្រង់ទូលាយ៖*** អ្នកចូលរួមជាជនជាប់ចោទទាំងអស់ ធ្វើសកម្មភាពទៅតាមគម្រោងការឧក្រិដ្ឋកម្មរួមមួយ អ្នកទាំងនោះមានចេតនាឧក្រិដ្ឋដូចគ្នា នៅពេលប្រព្រឹត្ត ដើម្បីបំពេញទៅតាមគម្រោងការមួយនោះ ហើយមានអ្នកចូលរួមម្នាក់ *ឬច្រើននាក់* អនុវត្តអំពើមួយ ដែលបានចែករំលែកទៅសមាជិកផ្សេងទៀត ទោះបីនៅខាងក្រៅគោលបំណងឧក្រិដ្ឋកម្មដើមក៏ដោយ ពីព្រោះអំពើនោះជា "ផលវិបាកជាធម្មជាតិ និងដែលអាចមើលឃើញបាន" នៃគម្រោងការឧក្រិដ្ឋកម្ម ហើយជនជាប់ចោទមានបំណងប្រថុយប្រថាន ដើម្បីឱ្យអំពើឧក្រិដ្ឋកម្មណាមួយអាចប្រព្រឹត្តទៅបាន។

១៣០១- កត្តាសត្យានុម័ត នៃប្រភេទទាំងអស់របស់ សហកម្មឧក្រិដ្ឋកម្មរួមមានធាតុផ្សំចំនួនបី។ ទីមួយគឺ តម្រូវឲ្យមាន "ពហុភាពនៃបុគ្គល"។ ក្រុមមនុស្សមិនចាំបាច់ត្រូវបានរៀបចំជារចនាសម្ពន្ធផ្លូវការ ឬមិនផ្លូវការ ដូចជារចនាសម្ពន្ធចាត់តាំងផ្នែកយោធា នយោបាយ ឬរដ្ឋបាល ទេ។

១៣០២- ទីពីរ គម្រោងការ ឬគោលបំណងឧក្រិដ្ឋរួមមួយ តម្រូវឲ្យមានសកម្មភាពឧក្រិដ្ឋកម្ម ដែលហាមឃាត់នៅក្រោមលក្ខន្តិកៈនៃតុលាការ ដែលមានយុត្តាធិការទៅលើជនជាប់ចោទ។ គោលបំណង គម្រោងការ ឬផែនការឧក្រិដ្ឋរួមនោះ មិនតម្រូវឲ្យមានការរៀបចំ ឬបង្កើតជាមុនទេ។ ចារីនៃបទឧក្រិដ្ឋ និងជនជាប់ចោទមិនចាំបាច់សំដែងពីការដឹង ឬព្រមព្រៀងរវាងពួកគេ ទាក់ទិននឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទេ។ បន្ថែមទៅទៀត ផែនការ ឬគោលបំណងឧក្រិដ្ឋកម្មរួមនោះ អាចកើតឡើងដោយឥតព្រាងទុក ហើយអាចទាញចេញពីអង្គហេតុបាន។

១៣០៣- ទីបី ជនត្រូវចោទត្រូវរួមចំណែកខ្លះ នៅក្នុងផែនការឧក្រិដ្ឋកម្មរួម។ ការចូលរួមចំណែករបស់ជនត្រូវចោទនោះ មិនចាំបាច់ត្រូវមានសារៈសំខាន់ ឬមិនអាចអត់បាននោះទេ ប៉ុន្តែយ៉ាងហោចណាស់ ត្រូវតែមានសារៈប្រយោជន៍ដល់អំពើឧក្រិដ្ឋទាំងឡាយ ដែលជនត្រូវចោទត្រូវបានរកឃើញឲ្យត្រូវទទួលខុសត្រូវ។ អំពើសកម្ម ឬការខកខាន អាចនឹងមានសារៈសំខាន់ប្រសិនបើអំពើទាំងនោះ "ធ្វើឲ្យសហកម្មមួយមានសមត្ថភាព និងប្រសិទ្ធភាព៖ ឧទាហរណ៍ ការចូលរួមចំណែកដែលបណ្តាលឲ្យប្រព័ន្ធមួយប្រព្រឹត្តទៅដោយរលូន ឬគ្មានការរំខាន"។ ការចូលរួមចំណែក អាចស្ថិតក្នុងចរិតលក្ខណៈផ្ទាល់ ឬមិនផ្ទាល់ ឲ្យតែជនត្រូវចោទបាន "ប្រព្រឹត្តសកម្មភាព ដែលអាចនាំមុខដល់ការជួយជ្រោមជ្រែងផែនការ ឬគោលបំណងរួម"។

វត្ថុមានរបស់ជនត្រូវចោទ នៅពេលដែលអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តនោះ មិនមានសារៈសំខាន់ទេ។

១៣០៤- ស្ថានភាពនានាជុំវិញអំពើឧក្រិដ្ឋ ជួយក្នុងការកំណត់ ថាតើសហាកម្មឧក្រិដ្ឋកម្មរួមមួយនឹងការប្រព្រឹត្តិនោះ បង្កឲ្យមានឧក្រិដ្ឋកម្មបែបនោះកើតមាន ឬយ៉ាងណា។ ឧទាហរណ៍ ក្នុងរឿងក្តី *Blagojevic* តុលាការ ICTY បានធ្វើសេចក្តីសន្និដ្ឋានថា បុរស និងក្មេងប្រុសៗ មូស្លីម ជាច្រើនត្រូវឃុំខ្លួន សម្លាប់ ព្រមទាំងកប់នៅក្នុងរយៈពេលមួយខ្លីនោះ បានបង្ហាញពីការកើតមាននូវសហាកម្មឧក្រិដ្ឋកម្មរួមមួយ ក្នុងការលុបបំបាត់ចោលនូវជនជាតិមូស្លីម។ តុលាការក៏បានធ្វើសេចក្តីសន្និដ្ឋានស្រដៀងគ្នានេះដែរ ចំពោះរឿងក្តី *Krajisnik* ដោយយល់ឃើញថា សុន្ទរកថារួមជាមួយការសន្ទនាជាច្រើន រវាងសមាជិកសហាកម្មឧក្រិដ្ឋកម្មរួម អំពីការបែងចែក ព្រមទាំងការជម្លៀសជនជាតិមូស្លីម និងប្រជាជនក្រូអាស៊ីរាប់ពាន់នាក់ ចេញក្នុងទ្រង់ទ្រាយមួយធំនោះ បានបង្ហាញពីការកើតមាននូវផែនការឧក្រិដ្ឋកម្មរួមមួយ។

១៣០៥- គោលបំណងសហាកម្មឧក្រិដ្ឋកម្មរួម អាចនឹងមិនមានការប្រែប្រួល និងអាចវិវឌ្ឍនៅក្នុងដំណាក់កាលក្រោយ ដើម្បីបញ្ចូលឧក្រិដ្ឋកម្មថ្មីឬឧក្រិដ្ឋកម្មទម្រង់ទូលាយ។ ដើម្បីឲ្យសមាជិកសហាកម្មឧក្រិដ្ឋកម្មរួម ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានពង្រីកនោះ តម្រូវឲ្យតុលាការរកឃើញ ដូចជា (១) ថាតើសមាជិកសហាកម្មឧក្រិដ្ឋកម្មរួមបានដឹងពីឧក្រិដ្ឋកម្មទាំងនោះដែរឬទេ (២)ថាតើ ពួកគេមិនបានធ្វើអ្វីទាំងអស់ក្នុងការរារាំងទប់ស្កាត់ការកើតមាននូវឧក្រិដ្ឋកម្មទាំងនោះ ហើយពួកគេបានមានៈក្នុងការអនុវត្តទៅតាមផែនការពង្រីកនេះ ស្របតាមគោលបំណងរួមមួយឬ យ៉ាងណានោះ (៣)នៅពេលណាដែលឧក្រិដ្ឋកម្មដែលបានលាតសន្ធឹងទាំងនោះ ត្រូវ

បានប្រែក្លាយទៅជាផែនការរួមមួយនោះ។ តើឧក្រិដ្ឋកម្មជាក់លាក់នានា (ក្នុងទម្រង់ដើម ឬលាតសន្ធឹង) ដែលអាចត្រូវចាត់ទុកថាជាផ្នែកមួយនៃសហកម្មឧក្រិដ្ឋកម្មរួមមួយ ឬមិនមែននោះ ដោយអាស្រ័យលើកត្តានានា ដូចជា៖ តើចារីដែរដល់ជាសមាជិករបស់ស្ថាប័ន ដែលមានការរៀបចំ ហើយមានទំនាក់ទំនងនឹងសហកម្មឧក្រិដ្ឋកម្មរួមនោះឬយ៉ាងណាតើអំពើសកម្មនានារបស់សមាជិក បានជួយជម្រុញគោលបំណងនានា របស់សហកម្មឧក្រិដ្ឋកម្មរួម ដែរឬយ៉ាងណា តើសមាជិកបានចូលរួមក្នុងការប្រព្រឹត្តិនៅក្នុងពេលជាមួយគ្នា ដូចចារីដែរដល់ ដែរឬយ៉ាងណា តើសមាជិកបានប្រព្រឹត្តសកម្មភាពដោយភ្ជាប់ជាមួយ ឬចូលរួមសហការជាមួយគ្នាដែរ ឬយ៉ាងណា ហើយតើការប្រព្រឹត្តបានកើតឡើងនៅក្នុងបរិបទនៃការវាយប្រហារជាប្រព័ន្ធ ឬយ៉ាងណា។

១៣០៦- "ឋានៈ *ជាក់ស្តែង* ឬ *ស្របច្បាប់*" របស់ជនត្រូវចោទ និង"ក្នុងឋានៈជាអ្នកដឹកនាំ" មានការពាក់ព័ន្ធក្នុងការកំណត់ ថាតើការចូលរួមរបស់ជនត្រូវចោទនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម គឺមាន "សារៈសំខាន់"។ លក្ខណៈដែលសំខាន់ ជនត្រូវចោទថាមាន "អំណាច ឬឥទ្ធិពលជាក់លាក់ដែលបុគ្គលនេះ មានចេតនាខកខានមិនបានត្អូញត្អែរ ឬរារាំងទប់ស្កាត់នោះ គឺជាជំនួយ ឬគាំទ្រយ៉ាងសំខាន់ដោយស្វ័យប្រវត្តិចំពោះសកម្មភាពឧក្រិដ្ឋ តាមរយៈការនៅស្ងៀមដែលជាការបង្ហាញពីការព្រមព្រៀង"។ កត្តាដែលមានការពាក់ព័ន្ធផ្សេងៗទៀតនោះ គឺទំហំ និងវិសាលភាពនៃផែនការឧក្រិដ្ឋកម្ម មុខងារដែលបានបំពេញ ព្រមជាមួយឋានៈដែលខ្លួនមាន បរិមាណពេលវេលាដែលបានប្រើ ដើម្បីចូលរួមបន្ទាប់ពីបានដឹងពីផែនការឧក្រិដ្ឋកម្ម វិសាលភាព និងភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋដែលបានប្រព្រឹត្ត ការចូលប្រឡូករបស់ជនត្រូវចោទជាច្រើនលើកច្រើនសារជាបន្តបន្ទាប់ និងយ៉ាងទូលំទូលាយ ព្រមទាំងការថ្លែងមតិរបស់ជនត្រូវចោទជាសាធារណៈ ដែលមានការពាក់ព័ន្ធនានា។

១៣០៧- ក្នុងរឿងក្តី *Krajisnik* ជនត្រូវចោទគឺជាប្រធានសភាស៊ែប៊ី-បូស្នី ជាសមាជិកមួយរូបរបស់ក្រុមប្រឹក្សាសន្តិសុខជាតិ និងជាអ្នកដឹកនាំស៊ែប៊ី-បូស្នី "លេខពីរ" *តាមព្រឹត្តិន័យ*។ សាលាដំបូងនៃតុលាការ ICTY បានយល់ឃើញថា ជនត្រូវចោទបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម *ក្នុងចំណោមនោះ* រួមមានតាមរយៈការចូលរួមចំណែកបង្កើតគោលនយោបាយឧក្រិដ្ឋរបស់រដ្ឋាភិបាល ការធ្វើអត្ថាធិប្បាយជាសាធារណៈ ដែលបានជម្រុញឱ្យមានការប្រព្រឹត្តទៅនៃអំពើឧក្រិដ្ឋនានា ការជួយរៀបចំរចនាសម្ពន្ធយោធា និងនយោបាយរបស់សាធារណរដ្ឋស៊ែប៊ី-បូស្នី និងការដែលមិនបានប្រឆាំងជំទាស់ ក្រោយពីសមាជិកនានានៃសហកម្មឧក្រិដ្ឋកម្មរួមបានបង្ហាញពីចេតនាឧក្រិដ្ឋរបស់ពួកគេរួចហើយនោះ។ នៅក្នុងរឿងក្តី *Martic* ជនត្រូវចោទមានតួនាទីជារដ្ឋមន្ត្រីស៊ីវិលផ្សេងៗជាច្រើន នៅ Krajina ហើយជនត្រូវចោទក៏ជា "បុគ្គលនយោបាយដ៏សំខាន់ និងមានឥទ្ធិពលខ្លាំងនៅ [Krajina] " ដែរ។ នៅក្នុងការយល់ឃើញថាជនត្រូវចោទបានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសន្និដ្ឋានចំពោះការចូលរួមរបស់ជនត្រូវចោទ *នៅក្នុងចំណោមនោះ* ដោយផ្អែកលើ សន្ទរកថានានារបស់ជនត្រូវចោទដែលគាត់បានថ្លែង និងផ្សព្វផ្សាយ តាមរយៈវិទ្យុ ព្រមជាមួយនឹងការបានដឹងឮរបស់គាត់ពីឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំដែលគាត់ខកខានមិនបានជំទាស់រារាំង។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្តី *Babic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានយល់ឃើញថា ជនត្រូវចោទដែលជាប្រធានាធិបតីនៃ Krajina បានចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមតាមរយៈការដឹងឮរបស់គាត់ពីការកើតមាននូវឧក្រិដ្ឋកម្ម ក្នុងទ្រង់ទ្រាយធំ និងការខកខានរបស់គាត់មិនបាន "ជំទាស់រារាំងឱ្យបានសមរម្យ"។

១៣០៨- ផ្ទុយទៅវិញ ទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម មាន*ធាតុផ្សំសត្យានុម័តដូចគ្នា* ប៉ុន្តែមិនមានចេតនាឧក្រិដ្ឋដូចគ្នានោះឡើយ។ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមជាមូលដ្ឋាន តម្រូវឱ្យជនត្រូវចោទមានចេតនាក្នុងការប្រព្រឹត្តិអំពើឧក្រិដ្ឋដែលទទួលរងការចោទប្រកាន់ ហើយជនទាំងឡាយដែលចូលរួមនៅក្នុងផែនការឧក្រិដ្ឋកម្មរួមនេះ ត្រូវមានចេតនាដូចគ្នានេះដែរ។ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមជាប្រព័ន្ធ តម្រូវឱ្យមានចេតនាឧក្រិដ្ឋក្នុងកម្រិតប្រហាក់ប្រហែលគ្នា៖ ជនត្រូវចោទត្រូវមានការដឹងឮដោយផ្ទាល់ ពីប្រព័ន្ធនៃការធ្វើបាប ព្រមជាមួយចេតនាក្នុងការបន្តប្រព័ន្ធនោះ។ សមាជិករបស់សហកម្មឧក្រិដ្ឋកម្មរួម អាចទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋដែលជនស្ថិតនៅខាងក្រៅសហកម្មឧក្រិដ្ឋកម្មរួមនោះបានប្រព្រឹត្ត ប្រសិនបើអំពើឧក្រិដ្ឋទាំងអស់នេះបង្កើតបានជាផ្នែកមួយនៃគោលបំណងឧក្រិដ្ឋរួម ហើយសមាជិកមួយរូបនៃសហកម្មឧក្រិដ្ឋកម្មរួមបានប្រើប្រាស់ចារីខាងក្រៅ ជាឧបករណ៍ក្នុងការសម្រេចនូវគោលបំណងឧក្រិដ្ឋរួមនោះ។

១៣០៩- ចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទូលាយ ជនត្រូវចោទត្រូវតែមានចេតនាក្នុងការប្រឡូក និងរួមចំណែកនៅក្នុងគោលបំណងឧក្រិដ្ឋរួមនោះ។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះមិនមែនជាចំណែកមួយនៃគោលបំណងឧក្រិដ្ឋទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយបច្ច័យតាមលក្ខណៈធម្មជាតិ និងអាចគិតទុកជាមុននៃឧក្រិដ្ឋកម្មនោះ តម្រូវឱ្យមានធាតុផ្សំបន្ថែមពីរទៀត។ ជនត្រូវចោទត្រូវតែដឹងថាឧក្រិដ្ឋកម្មបែបនោះ អាចនឹងត្រូវប្រព្រឹត្តដោយសមាជិកនៃក្រុម ហើយជនត្រូវចោទ មានចេតនាទទួលយកហានិភ័យក្នុងការចូលរួម ឬបន្តចូលរួមនៅក្នុងសហកម្មនោះ។ ប្រសិនបើចារីខាងក្រៅជាអ្នកបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ដែលលើសពីវិសាលភាពនៃ

សហកម្មឧក្រិដ្ឋកម្មរួមវិញនោះ ជនត្រូវចោទត្រូវទទួលខុសត្រូវក្រោមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម នៅពេលដែលៈ

(ក)ជនត្រូវចោទបានចូលរួមនៅក្នុងផែនការឧក្រិដ្ឋរួម ជាមួយចេតនាដែលតម្រូវឱ្យមាន

(ខ)ការប្រព្រឹត្តិនូវបទឧក្រិដ្ឋបែបនោះ របស់ចារីខាងក្រៅ គឺជាបច្ច័យតាមលក្ខណៈធម្មជាតិ និងអាចគិតទុកជាមុនពីគោលបំណងឧក្រិដ្ឋរួម និង

(គ)យ៉ាងណាក៏ដោយ ជនត្រូវចោទបានទទួលយកហានិភ័យនេះដោយដឹងមុន ព្រមទាំងបានសម្រេចចិត្តចូលរួមនៅក្នុងគោលបំណងឧក្រិដ្ឋរួមនេះ។

១៣១០- អង្គបុរេជំនុំជម្រះ អ.វ.ត.ក បានយល់ឃើញថា សមត្ថកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចដ៏មានសារៈសំខាន់របស់សាលាឧទ្ធរណ៍នៃតុលាការ ICTY នៅក្នុងរឿងក្តី *Tadic* មិនបានផ្តល់ជាមូលដ្ឋានរឹងមាំគ្រប់គ្រាន់ ដើម្បីធ្វើការសន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទូលាយសន្ធឹងជាចំណែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងរយៈពេលដែលស្ថិតក្នុងយុត្តាធិការបណ្តោះអាសន្នរបស់ អ.វ.ត.ក នោះឡើយ។ នៅពេលធ្វើការទទួលស្គាល់ថា យុត្តិសាស្ត្រកំណត់ពីទម្រង់ទាំងបី នៃសហកម្មឧក្រិដ្ឋកម្មរួម ដូចបានរៀបរាប់ពីខាងលើនោះ អង្គជំនុំជម្រះសាលាដំបូង បានរក្សាទុកឱ្យនៅចំហរចំពោះបញ្ហា ថាតើសហកម្មឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទូលាយ ត្រូវយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ឬយ៉ាងណានោះ។

## បានធ្វើផែនការ

១៣១១- ការធ្វើផែនការឧក្រិដ្ឋកម្មមួយ ត្រូវបង្កប់នូវការរៀបចំនៃការប្រព្រឹត្តអំពើឧក្រិដ្ឋ ដោយរួមមានបទឧក្រិដ្ឋផ្លូវច្បាប់មួយ ឬច្រើនដែលត្រូវបានប្រព្រឹត្តនៅពេលបន្ទាប់។ សកម្មភាពនៃការ

រៀបចំផែនការ ត្រូវតែជាកត្តាមួយដែល“ចូលរួមចំណែកយ៉ាងសំខាន់” ចំពោះការប្រព្រឹត្តិអំពើឧក្រិដ្ឋ។ *ក្នុងចំណោមនោះ* វាអាចបង្កឡើងតាមរយៈ “ការបង្កើតឡើងនូវផែនការឧក្រិដ្ឋមួយ ឬការយល់ស្របនឹងផែនការមួយ ដែលស្នើឡើងដោយជនម្នាក់ទៀត”។ ភស្តុតាងនៃការរៀបចំផែនការឧក្រិដ្ឋមួយនោះ អាចនឹងមានលក្ខណៈជាប្រយោល។ *ចេតនាឧក្រិដ្ឋ* ដែលអាចយកមកអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវនេះ គឺចេតនាក្នុងការរៀបចំផែនការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយ ឬយ៉ាងហោចណាស់ ការដឹងឮអំពីអំពើសកម្ម ឬការខកខានផ្សេងៗ ដែលបានរៀបចំទុក។ *ចេតនាឧក្រិដ្ឋ*របស់ជនត្រូវចោទ អាចនឹងស្តែងចេញពីកាលៈទេសៈទាំងនោះ។

១៣១២- ការរៀបចំផែនការបង្កើតឲ្យមានទម្រង់ឯករាជ្យមួយ ក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ហើយ ជនត្រូវចោទអាចនឹងត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះ សម្រាប់ការរៀបចំផែនការតែម្នាក់ឯង។ ប៉ុន្តែ ប្រសិនបើជនត្រូវចោទត្រូវបានរកឃើញថាមានពិរុទ្ធ ដោយបានប្រព្រឹត្តអំពើឧក្រិដ្ឋមួយនោះ ជនត្រូវចោទមិនអាចរងការចោទប្រកាន់ពីបទរៀបចំផែនការនៃឧក្រិដ្ឋកម្មដដែលនោះឡើយ។ នៅក្នុងករណីបែបនេះ អង្គហេតុនៃការរៀបចំផែនការ ត្រូវបានពិចារណាជាស្ថានទម្ងន់ទោស។

១៣១៣- នៅក្នុងរឿងក្តី *Nahimana* តុលាការ ICTR បានរកឃើញថា Barayagwiza មានពិរុទ្ធពីបទរៀបចំផែនការសម្លាប់រង្គាលចំពោះ “តួនាទីដឹកនាំ” របស់គាត់ក្នុងការចែកចាយអាវុធប្រើប្រាស់សម្រាប់សម្លាប់ពួក ទុតស៊ីស។ Barayagwiza ដែលជាអ្នកផ្តួចផ្តើមបង្កើតបក្សនយោបាយហ៊ូទូ ជ្រុលនិយម សម្ព័ន្ធការពារសាធារណរដ្ឋ CDR ត្រូវបានរកឃើញថាបានដឹកជញ្ជូន និងផ្ទុក

អាវុធ ពេញៗរថយន្តទៅចំណុចមួយនៅ Gisenyi ដែលនៅទីនោះ អ្នកគាំទ្រជាច្រើនបានទទួលការណែនាំ ឲ្យមកទទួលយកអាវុធទាំងនោះ ដើម្បីចូលរួមការសម្លាប់ពួក ទុតស៊ី។ សាលាក្តីបានរកឃើញថា សកម្មភាព "សម្របសម្រួល" របស់ Barayagwiza បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះការសម្លាប់ ដែលកើតមានភ្លាមៗបន្ទាប់ពីមានការប្រើប្រាស់អាវុធទាំងនេះ ហើយតុលាការយល់ឃើញថា ជនត្រូវចោទមានទោសក្នុងការរៀបចំ ទោះបីជាគ្មានភស្តុតាងផ្ទាល់បញ្ជាក់ពីការចូលរួមរបស់ជនត្រូវចោទ នៅក្នុងកិច្ចពិភាក្សានានាពីផែនការក៏ដោយ។

១៣១៤- នៅក្នុងរឿងក្តី *Kordic* តុលាការ ICTY បានចោទប្រកាន់ជនត្រូវចោទ ដែលជាអ្នកដឹកនាំនយោបាយជាន់ខ្ពស់ជនជាតិ ក្រូអាស៊ី-បូស្នី មួយរូប ដោយសារបានរៀបចំផែនការឧក្រិដ្ឋវាយប្រហារទៅលើអ្នកភូមិនៃជ្រលង Lasva ដែលបានរៀបចំឡើងដើម្បី "បោសសម្អាត" តំបន់របស់ពួកម៉ូស្លីម។ ការយល់ឃើញនេះ គឺផ្អែកលើឋានៈជាអ្នកដឹកនាំក្នុងតំបន់របស់ Kordic និងវត្តមានរបស់ជនត្រូវចោទ ចូលរួមអង្គប្រជុំយុទ្ធសាស្ត្រមួយ ដែលនៅក្នុងអង្គប្រជុំបានពិភាក្សាលម្អិតពីឧក្រិដ្ឋកម្មដែលនឹង ត្រូវប្រព្រឹត្តនៅក្នុងការវាយប្រហារមួយដែលជិតកើតមានរួមមានការសម្លាប់បុរសទាំងឡាយដែលស្ថិតក្នុងវ័យធ្វើទាហាន ការបណ្តេញជនស៊ីវិលចេញ និងការវាយកម្ទេចផ្ទះសម្បែងជាដើម។

១៣១៥- នៅក្នុងរឿងក្តី *Sesay* តុលាការ SCSL បានចោទប្រកាន់ ជនត្រូវចោទ Sesay ចំពោះការរៀបចំផែន ការធ្វើឲ្យជនស៊ីវិលឲ្យទៅជាទាសករ ដោយសារ "លក្ខណៈ និងទំហំ"នៃការជីករ៉ែដោយបង្ខំដែលនៅក្នុងនោះ ជនត្រូវចោទ"បានចូលរួមពាក់ព័ន្ធយ៉ាងជិតស្និទ្ធ និងយ៉ាងសកម្ម"

ហើយផែនការនោះ បានតម្រូវឱ្យមានការរៀបចំផែនការយ៉ាងទូលំទូលាយជាបន្តបន្ទាប់។ ដោយផ្អែកលើ ការពាក់ព័ន្ធរបស់ជនត្រូវចោទ នៅក្នុងសកម្មភាពរុករករ៉ែ រួមទាំងការចេញបញ្ជាឱ្យចាប់ពង្រត់ និងដឹកជញ្ជូនជនស៊ីវិលទៅកាន់កន្លែងរករ៉ែ តុលាការពិសេសបានរកឃើញថា "ការប្រព្រឹត្តិរបស់ Sesay គឺជាកត្តាចូលរួមចំណែកមួយយ៉ាងសំខាន់ដល់ការកើតមាននូវការធ្វើឱ្យទៅជាទាសករ" ហើយនៅក្នុងនោះ តុលាការបានធ្វើការសន្និដ្ឋានថា Sesay ជាមួយអ្នកផ្សេងទៀតបាន "បានរៀបចំការពង្រត់ និងការធ្វើឱ្យទៅជាទាសករ" ចំពោះជនស៊ីវិលដែលជាហេតុផល ដែលជនត្រូវចោទត្រូវទទួលខុសត្រូវចំពោះការរៀបចំផែនការឧក្រិដ្ឋកម្មនោះ។

## បានញុះញង់

១៣១៦- ការញុះញង់ឱ្យមានឧក្រិដ្ឋកម្មមួយ មានន័យថា ពន្យុះជនម្នាក់ទៀតឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋនោះ។ ទម្រង់នៃការទទួលខុសត្រូវក៏ត្រូវបានបរិយាយថាជា "ការជម្រុញ ឬការលើកទឹកចិត្ត"។ ដើម្បីឱ្យជនត្រូវចោទម្នាក់ ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដោយផ្អែកលើការញុះញង់ជាមូលដ្ឋាននោះ ឧក្រិដ្ឋកម្មមួយ ត្រូវតែបង្ហាញថាបានប្រព្រឹត្តដោយជាក់ស្តែង។ ការញុះញង់របស់ជនត្រូវចោទត្រូវតែបង្ហាញថា "បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិអំពើឧក្រិដ្ឋ ប៉ុន្តែមិនចាំបាច់ត្រូវមាន *ធាតុផ្សំមិនអាចខ្វះបាន* សម្រាប់ការប្រព្រឹត្តិអំពើឧក្រិដ្ឋនោះទេ" ក្នុងន័យមួយផ្សេងទៀត វាមិនមានសារៈសំខាន់ ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មនឹងមិនអាចកើតមាននោះទេ ប្រសិនបើគ្មានការចូលរួមពីសំណាក់ជនត្រូវចោទ។

១៣១៧- ទាំងអំពើសកម្ម និងការខកខាន សុទ្ធតែអាចបង្កជាការញុះញង់ ហើយវាមិនមានការចាំបាច់ក្នុងការបញ្ជាក់ភាសាញុះញង់ជាក់ស្តែង ដែលជនត្រូវចោទបានប្រើ។ គ្រាន់តែវត្តមានរបស់បុគ្គល

ដែលកាន់អំណាចម្នាក់តែម្យ៉ាង ដែលខកខានមិនបានសកម្មភាពរបស់ខ្លួននោះ ត្រូវចាត់ទុកជាអំពើញុះញង់ ទោះបីជាជនត្រូវចោទដែលបានញុះញង់ឱ្យមានអំពើឧក្រិដ្ឋនោះ មិនតម្រូវឱ្យមានវត្តមានជាក់ស្តែងនៅក្នុងការប្រព្រឹត្តិអំពើឧក្រិដ្ឋនោះក៏ដោយ។ វាក៏មិនជាការចាំបាច់អ្វីដែរ ក្នុងការបញ្ជាក់ថា ជនត្រូវចោទមានការគ្រប់គ្រងដោយប្រសិទ្ធភាពទៅលើចារីដែលដល់នោះ។ ចំពោះ*ចេតនាឧក្រិដ្ឋ*វិញ ជនត្រូវចោទត្រូវតែបង្ហាញថាជនជាប់ចោទចេតនាក្នុងការញុះញង់បុគ្គលមួយផ្សេងទៀតឱ្យប្រព្រឹត្តអំពើឧក្រិដ្ឋ ឬយ៉ាងហោចណាស់ត្រូវមានការដឹងឮពីភវនីយ ហេតុដ៏សំខាន់ ថាអំពើឧក្រិដ្ឋមួយនឹងប្រព្រឹត្តឡើង តាមរយៈការប្រព្រឹត្ត អំពើសកម្ម ឬការខកខានដែលបានញុះញង់នោះ។

១៣១៨- ក្នុងរឿងក្តី *Bradanin* តុលាការ ICTY បានចោទប្រកាន់ជនត្រូវចោទ ដែលជាអនុប្រធានសភានៃតំបន់ស្វ័យត Krajina (ARK) និងជាប្រធាន Crisis Staff នៃតំបន់ស្វយយ័ត ARK ពីបទញុះញង់ឱ្យកើតមាននូវឧក្រិដ្ឋកម្មនៃការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗ (ដូចជាការជម្លៀសដោយបង្ខំ) ដោយផ្អែកលើសេចក្តីថ្លែងការណ៍អុជអាល និងរើសអើង *ដែលនៅក្នុងចំណោមនោះ* មានការថ្កោលទោសការរៀបអាពាហ៍ពិពាហ៍ចម្រុះជាតិសាសន៍ ជម្រុញឱ្យជនដែលមិនមែនជាជនជាតិស៊ែប៊ីលះបង់ការងាររបស់ពួកគេចោល និងបានលើកឡើងថា ពួកដែលមិនមែនជាជនជាតិស៊ែប៊ី នឹងមិនអនុញ្ញាតឱ្យរស់នៅក្នុងតំបន់នេះទៀតឡើយ។ ការប្រកាន់យកផែនការយុទ្ធសាស្ត្ររបស់ជនត្រូវចោទ ដែលមានការនិរទេស និងការជម្លៀសដោយបង្ខំ ជាឧក្រិដ្ឋកម្មបង្កជាផ្នែកសំខាន់មួយ ហើយការអនុវត្តន៏ផែនការនេះរបស់គាត់បានបន្តបង្ហាញថាគាត់មានចេតនាញុះញង់ឱ្យមានឧក្រិដ្ឋកម្មទាំងនេះកើតឡើង។

១៣១៩- នៅក្នុងរឿងក្តី *Nahimana* តុលាការ ICTR បានរកឃើញថា Barayagwiza ជាសមាជិក ផ្តួចផ្តើមគំនិតនៃសម្ព័ន្ធការពារសាធារណរដ្ឋ (CDR) មានពិរុទ្ធពីបទញុះញង់ឱ្យមានអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល ដោយផ្អែកលើសកម្មភាពនានារបស់គាត់ ដែលរួមមានការត្រួតពិនិត្យមើលការសាងសង់របាំងផ្លូវ ក្នុងអំឡុងដែលកើតមានអំពើប្រល័យពូជសាសន៍ និងការដាក់ចេញនូវការណែនាំនានា (ដែលត្រូវគេប្រតិបត្តិតាមជាបន្តបន្ទាប់) ចំពោះអ្នកដែលកំពុងធ្វើរបាំងផ្លូវនោះឱ្យឈប់ ហើយមកសម្លាប់ពួកទុតស៊ីស។ សកម្មភាពទាំងនេះ ត្រូវបានប្រព្រឹត្តទៅជាមួយនឹងចេតនាប្រល័យពូជសាសន៍ដែលតម្រូវឱ្យមាន។

១៣២០- នៅក្នុងរឿងក្តី *Ndindadbahizi* តុលាការ ICTR បានរកឃើញថា ជនត្រូវចោទ ដែលមានឋានៈជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នៃរដ្ឋាភិបាលបណ្តោះអាសន្ននៃប្រទេសរ៉្វាន់ដា មានពិរុទ្ធ ពីបទញុះញង់ឱ្យមានអំពើប្រល័យពូជសាសន៍ តាមរយៈការផ្តល់នូវពាក្យពេជន៍លើកទឹកចិត្ត ដល់ក្រុមអ្នកវាយប្រហារ ដែលក្រោយមកបានសម្លាប់ពួកទុតស៊ីសអស់រាប់ពាន់នាក់។ សាលាក្តីបានរកឃើញថា ឋានៈរបស់ជនត្រូវចោទ "អាចប្រើពាក្យសម្តីរបស់ខ្លួនជាអំណាចបានច្រើនសន្ធឹក"។ បន្ថែមលើនេះទៀត គាត់បានដឹងច្បាស់ហើយថា ពាក្យពេជន៍របស់គាត់ គឺជាចំណែកមួយនៃបរិបទដ៏ទូលំទូលាយចំពោះអំពើហិង្សា និងការសម្លាប់នៅរ៉្វាន់ដា ក្នុងអំឡុងរយៈពេលនោះ ហើយតាមរយៈការលើកទឹកចិត្តឱ្យមានការសម្លាប់កាន់តែច្រើននោះ គឺគាត់មានចេតនាបំផ្លាញទាំងស្រុង ឬដោយផ្នែក ទៅលើក្រុម ទុតស៊ីស។

១៣២១- នៅក្នុងរឿងក្តី *Sesay* តុលាការ SCSL បានរកឃើញថា ជនត្រូវចោទ ដែលជាអ្នកដឹកនាំម្នាក់នៃរណសិរ្សរួបរួមបដិវត្តន៍នោះ មានពិរុទ្ធពីបទញុះញង់ឱ្យមានឃាតកម្ម។ ជនត្រូវចោទបានសួរ

ទៅកាន់ចារីដែដល់ជាដដែលៗ អំពីជនរងគ្រោះនៅក្នុងឥរិយាបទដែលបញ្ជាក់យ៉ាងច្បាស់ថា គាត់បានចាត់ទុកជនរងគ្រោះជាសត្រូវ។ ក្រោយពីការសាកសួរមិនយូរប៉ុន្មាន ចារីដែដល់បាន ចេញបញ្ជាឲ្យសម្លាប់ជនរងគ្រោះ។ ដោយការប្រព្រឹត្តិអំពើញុះញង់របស់ជនត្រូវចោទ បណ្តាល ឲ្យមានការប្រព្រឹត្តិនូវឧក្រិដ្ឋកម្ម នោះវាមានការពាក់ព័ន្ធគ្រប់គ្រាន់ទៅនឹងឧក្រិដ្ឋកម្ម។ បន្ថែមលើ នេះទៀត ជនត្រូវចោទមានគោលបំណងឲ្យអំពើរបស់ខ្លួន មានផលប៉ះពាល់បែបនោះ ឬបានដឹង រួចទៅហើយ ឬមានមូលហេតុក្នុងការដឹងថា អំពើរបស់គាត់អាចញុះញង់ឲ្យមានការប្រព្រឹត្តិ ឧក្រិដ្ឋកម្ម។

## បានចេញបញ្ជា

១៣២២- សកម្មភាពនៃការចេញបញ្ជា កើតមាននៅពេល "បុគ្គលម្នាក់ដែលមានឋានៈជាអ្នកគ្រប់គ្រង បានចេញការណែនាំឲ្យបុគ្គលម្នាក់ផ្សេងទៀតប្រព្រឹត្តបទល្មើសមួយ"។ មិនតម្រូវឲ្យបុគ្គលដែលជា អ្នកចេញបញ្ជា និងចារីដែដល់ ត្រូវតែមានទំនាក់ទំនងជាថ្នាក់លើ និងអ្នកក្រោមបង្គាប់ជាផ្លូវការ នោះទេ៖ "វាមានភាពគ្រប់គ្រាន់ហើយ ដែលអ្នកដែលចេញបញ្ជាគឺជាអ្នកមានអំណាច ទោះបីជា អំណាចជាក់ស្តែង ឬអំណាចស្របច្បាប់ក៏ដោយ ក្នុងការចេញបញ្ជាឲ្យមាន ការប្រព្រឹត្តិទៅនៃ បទល្មើសមួយ ឬអំណាចរបស់គាត់ អាចនឹងត្រូវកំណត់ដោយសាកសមនោះ"។ សិទ្ធិអំណាច អាចស្ថិតក្នុងលក្ខណៈមិនផ្លូវការ ឬស្ថិតក្នុងសភាពលក្ខណៈបណ្តោះអាសន្នសុទ្ធសាធ។ សកម្មភាពនានា ដូចជាការកោះហៅឲ្យមានការប្រជុំ និងការសាកសួរអ្នកដែលចូលរួមឲ្យរៀប ចំអង្គប្រជុំបន្តទៀត ដើម្បីណែនាំដល់មនុស្សឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ការបញ្ជាក់ពីពេលវេលាដែល អង្គប្រជុំរបៀបនោះបានប្រព្រឹត្តទៅ និងការណែនាំដោយផ្ទាល់ទៅកាន់ប្រជាជនឲ្យប្រព្រឹត្ត

ឧក្រិដ្ឋកម្ម ត្រូវបានរកឃើញជាការបង្ហាញពីអំណាចទៅលើចារីទាំងនោះ។ ទម្រង់ដែលមានលក្ខណៈស្រដៀងគ្នាមួយនៅក្នុងយុទ្ធនាការប្រឆាំងនឹងជនស៊ីវិល បានកើតមានអស់រយៈពេលជាយូរ ដែលពេលវេលានោះ អាចមានលក្ខណៈគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថាសកម្មភាពបែបនោះ មានឫសគល់ចេញពីបញ្ជារបស់អាជ្ញាធរថ្នាក់លើ។ សម្រាប់ធាតុផ្សំអត្តនោម័ត វាមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញថា ជនត្រូវចោទបានដឹងពីភាវនីយហេតុដ៏សំខាន់ ដែលឧក្រិដ្ឋកម្មដែលនឹងប្រព្រឹត្តឡើង ជាការប្រតិបត្តិតាមបញ្ជា។

១៣២៣- វាមិនមានការចាំបាច់ក្នុងការបញ្ជាក់ថា បញ្ជាមិនស្របច្បាប់ដោយប្រយោល ឬបញ្ជានោះ ត្រូវបានផ្តល់ដោយផ្ទាល់ ឬជាបុគ្គលពីជនត្រូវចោទទៅកាន់ចារី។ បញ្ជាមិនចាំបាច់ផ្តល់ឱ្យជាលាយលក្ខណ៍អក្សរ ឬជាទម្រង់ជាក់លាក់នោះទេ។ បញ្ជាអាចធ្វើឡើងក្នុងលក្ខណៈចំហរ ឬមិនបើកចំហរ ហើយអាចត្រូវបញ្ជាក់អាស្រ័យទៅតាមកាលៈទេសៈ។ បញ្ជាក៏អាចស្តែងចេញពីកត្តាផ្សេងៗជាច្រើន រួមមាន ចំនួននៃសកម្មភាពខុសច្បាប់ ចំនួន និងប្រភេទបុគ្គលិកដែលចូលរួមពាក់ព័ន្ធ ការគ្រប់គ្រង និងការបញ្ជាប្រកបដោយប្រសិទ្ធភាព ដែលបានប្រើទៅលើបុគ្គលិកទាំងនេះ ភស្តុភារដែលពាក់ព័ន្ធ ការកើតមានយ៉ាងទូលំទូលាយនូវសកម្មភាពខុសច្បាប់ ចង្វាក់យុទ្ធសាស្ត្រនៃប្រតិបត្តិការ *របៀបបំពេញកិច្ច*ចំពោះសកម្មភាពស្រដៀងគ្នា ទីតាំងរបស់ថ្នាក់ដឹកនាំនៅពេលដែលគាត់បានដឹងឮពីការប្រព្រឹត្តិទៅនៃអំពើឧក្រិដ្ឋ ក្រោមអំណាចរបស់គាត់។ ការដាក់ចេញជាថ្មីនូវបញ្ជាខុសច្បាប់មួយ តាមរយៈការបញ្ជូនបញ្ជានោះទៅក្រោមតាមបណ្តាញបញ្ជាការ បង្កើតជាការទទួលខុសត្រូវឧក្រិដ្ឋកម្ម។ ចំពោះការបង្កើតនូវខ្សែរយៈទំនាក់ទំនងធម្មតាមួយរវាងបញ្ជា និងឧក្រិដ្ឋកម្មនោះ វិធានគឺមានលក្ខណៈដូចគ្នានឹង

ការអនុវត្តន៍ជាមួយនឹងការញុះញង់៖ វាមិនមានការចាំបាច់ឡើយក្នុងការបង្ហាញថា ឧក្រិដ្ឋកម្មនោះនឹងមិនអាចកើតមានបានទេ ប្រសិនបើគ្មានវត្តមាននៃការបញ្ជានោះ។

១៣២៤- នៅក្នុងរឿងក្តី *Semanza* តុលាការ ICTR បានរកឃើញថា ជនត្រូវចោទមានពិរុទ្ធពីបទចេញបញ្ជាឲ្យធ្វើអំពើប្រល័យពូជសាសន៍ និងសម្លាប់រង្គាល តាមរយៈតួនាទីរបស់គាត់នៅក្នុងការសម្លាប់រង្គាលជនភៀសខ្លួនទុតស៊ីស នៅព្រះវិហារ Musha ដោយយល់ឃើញថា ភាពមិនគ្រប់គ្រាន់នៃទំនាក់ទំនងជាអ្នកដឹកនាំ និងអ្នកក្រោមបង្គាប់ជាផ្លូវការមួយ រវាង Semanza និងអ្នកវាយប្រហារទាំងនោះ មិនបានរារាំងការទទួលខុសត្រូវរបស់គាត់ ចំពោះការចេញបញ្ជា ឲ្យមានការប្រព្រឹត្តិនូវបទឧក្រិដ្ឋទាំងនោះទេ។ សាលាក្តីបានកំណត់ថា Semanza បានមកកាន់ព្រះវិហារ Musha ជាមួយនឹងទាហាន និងសមាជិកឃោជានានា ហើយបានប្រាប់ទៅជនភៀសខ្លួន ហ៊ូទូឲ្យផ្តាច់ខ្លួនពួកគេពីពួកទុតស៊ីស រួចបន្ទាប់មកបានចេញការណែនាំឲ្យអ្នកវាយប្រហារទាំងនោះសម្លាប់ពួកទុតស៊ីសចោល។ ការគោរពទៅតាមបញ្ជា ពីសំណាក់អ្នកវាយប្រហារចំពោះការណែនាំរបស់ Semanza ដែលបញ្ជាឲ្យសម្លាប់ពួកទុតស៊ី បានបង្ហាញថាគាត់មានអំណាចដែលតម្រូវឲ្យមាន ក្នុងការទទួលខុសត្រូវចំពោះការចេញបញ្ជានោះរួចទៅហើយ។

១៣២៥- នៅក្នុងរឿងក្តី *Dragomir Milosevic* តុលាការ ICTY បានចោទប្រកាន់ជនត្រូវចោទ ចំពោះការចេញបញ្ជាឲ្យវាយប្រហារដោយការបាញ់កាំភ្លើងធំ ទៅលើ Sarajevo ដោយតុលាការយល់ឃើញថា ជនត្រូវចោទអាចទទួលខុសត្រូវចំពោះការចេញបញ្ជាឲ្យវាយប្រហារទាំងនោះដែលជាផ្នែកមួយនៃយុទ្ធនាការទូលំទូលាយ ទោះបីជាគ្មានភស្តុតាងជាក់ស្តែងពីការចេញបញ្ជាឲ្យបានជាក់លាក់ក៏ដោយ។ មានការយល់ឃើញថា Milosevic បានប្រើអំណាច គ្រប់គ្រង

ជាទូទៅដោយប្រសិទ្ធភាពទៅលើកងកាំភ្លើងធំដែលបាញ់ផ្តក់ទៅលើ Sarajevo ហើយមានភស្តុតាងជាក់ស្តែងពីការចេញបញ្ជារបស់គាត់ចំពោះ ការបាញ់កាំភ្លើងធំចំនួន២លើក ទៅលើតំបន់ដែលមានជនស៊ីវិល។ សាលាក្តីបានសម្រេចថា ការយល់ឃើញទាំងនេះ មានលក្ខណៈគ្រប់គ្រាន់ ក្នុងការបង្ហាញពីការទទួលខុសត្រូវរបស់គាត់ចំពោះការចេញបញ្ជាឱ្យបាញ់កាំភ្លើងធំទៅលើ Sarajevo របស់កងកម្លាំងទាំងនេះ ក្នុងអំឡុងពេលដែលរងការចោទប្រកាន់នោះ។

១៣២៦- នៅក្នុងរឿងក្តី *Blaskic* តុលាការ ICTY បានធ្វើការចោទប្រកាន់ទៅលើជនត្រូវចោទពីបទចេញបញ្ជាឱ្យអ្នកជាប់ឃុំដែលមិនមែនជាអ្នកប្រយុទ្ធត្រូវប្រើពលកម្មដោយបង្ខំ។ សាលាក្តី ICTY យល់ឃើញថា នៅក្នុងការចេញបញ្ជាឱ្យកងអនុសេនាតូច ការងាររបស់អ្នកជាប់ឃុំឃាំង ត្រូវបង្ខំឱ្យជីកលេណដ្ឋាននោះ ជម្រុញឱ្យមាន "ការវាយប្រហារដ៏ធ្ងន់ធ្ងរមួយចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ" ដែលបង្កឱ្យមានការឈឺចាប់ ឬរបួសលើរូបរាងកាយ និងផ្នែកស្មារតីយ៉ាងធ្ងន់ធ្ងរដែលអំពើនេះផ្ទុយពីអនុសញ្ញាទីក្រុងហ្សឺណែវ ដូច្នេះ ជនត្រូវចោទត្រូវទទួលខុសត្រូវចំពោះការចេញបញ្ជាឱ្យមានការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មនោះ។

## ការជួយ និងជម្រុញ

១៣២៧- ការជួយ និងជម្រុញ គឺជាទម្រង់នៃការទទួលខុសត្រូវបន្ទាប់បន្សំ។ ការជួយ និង ជម្រុញឱ្យកើតមានឧក្រិដ្ឋកម្មមួយនោះ គឺជាការប្រព្រឹត្តិនូវសកម្មភាពនានា "ដែលជួយទំនុកបម្រុងលើកទឹកចិត្តដោយផ្ទាល់ ឬផ្តល់ការគាំទ្រជាស្មារតីដោយជាក់លាក់ជាដើម" ទៅ ដល់ចារី ដោយការគាំទ្របែបនោះផ្តល់នូវ "ប្រសិទ្ធភាពយ៉ាងសំខាន់" ទៅលើការប្រព្រឹត្តនៃឧក្រិដ្ឋកម្ម។ ការជួយ និងជម្រុញ មិនមែនជាសទិសន័យនោះទេ ការជួយពាក់ព័ន្ធនឹងការផ្តល់ជាជំនួយ

រឹងការជម្រុញ ពាក់ព័ន្ធនឹងការសម្របសម្រួល លើកទឹកចិត្ត ឬផ្តល់ប្រឹក្សា ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ជនត្រូវចោទ អាចត្រូវគេរកឃើញថា បានផ្តល់ទម្រង់តែមួយ ក្នុងចំណោមទម្រង់ទាំងពីរប៉ុណ្ណោះ ក្នុងការទទួលខុសត្រូវចំពោះបទ ការជួយ និងជម្រុញ។

១៣២៨- ភស្តុតាងបញ្ជាក់ពីទំនាក់ទំនងរវាងហេតុ និងបច្ច័យរវាងការប្រព្រឹត្តរបស់អ្នកជួយ និងអ្នកជម្រុញ និងចំពោះការប្រព្រឹត្តិនូវបទឧក្រិដ្ឋ ឬភ័ស្តុតាងដែលបង្ហាញថាការប្រព្រឹត្តិបែបនោះគឺជាលក្ខខណ្ឌជាអាទិភាពចំពោះការប្រព្រឹត្តិនៃបទឧក្រិដ្ឋ គឺមិនតម្រូវឲ្យមាននោះទេ។ ការជួយ និងជម្រុញ អាចកើតឡើងនៅមុនពេល ក្នុងអំឡុងពេល ឬបន្ទាប់ពីការប្រព្រឹត្តិឡើងនូវបទឧក្រិដ្ឋ។ វាអាចរួមផ្សំនូវសកម្មភាពជារូបវន្ត សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬគ្រាន់តែមានវត្តមានរបស់ជនត្រូវចោទតែម្យ៉ាងប៉ុណ្ណោះ។ ចំពោះករណី ចុងក្រោយបង្អស់នោះ វត្តមានរបស់ជនត្រូវចោទត្រូវតែបង្ហាញថាបានប្រើប្រាស់អំណាច ដោយស្របច្បាប់ទៅលើ ឬបានផ្តល់ការលើកទឹកចិត្តទៅដល់ចារី។ នៅក្នុងករណីបែបនេះ អំណាចរបស់ជនត្រូវចោទគឺជាកត្តាសំខាន់មួយ ម្យ៉ាងវិញទៀត វាមិនមានសារៈសំខាន់ទេ ក្នុងការបង្ហាញថាជនត្រូវចោទមួយរូបដែលរងការចោទប្រកាន់ពីបទ ជួយ និងជម្រុញ មានអំណាចដោយផ្ទាល់ទៅលើចារីនោះ។

១៣២៩- ថ្នាក់លើម្នាក់ ដែលអនុញ្ញាតឲ្យមានការប្រើប្រាស់ធនធានក្រោមការគ្រប់គ្រងរបស់ខ្លួន ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មមួយ គឺពិតជារួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មនោះ។ អភិបាលក្រុងមួយរូប ដែលខកខានមិនបានរក្សាច្បាប់ និងសណ្តាប់ធ្នាប់នៅក្នុងតំបន់ដែលស្ថិតក្រោមការត្រួតត្រារបស់ខ្លួននោះ បានខកខានមិនបាន

ប្រើប្រាស់ឋានៈដែលមានអំណាចរបស់ខ្លួន ដើម្បីជំទាស់ទៅនឹងការសម្លាប់ ហើយមានវត្តមាននៅពេលដែលឧក្រិដ្ឋកម្មជាក់លាក់នានា ត្រូវបានប្រព្រឹត្តឡើងនោះ ត្រូវបានរកឃើញថាបានលើកទឹកចិត្តដោយតុណ្ហីភាព ចំពោះការសម្លាប់ដែលអំពើនេះ ជាការជួយ និងជម្រុញដល់ការកើតមាននូវការសម្លាប់ និងឧក្រិដ្ឋកម្មផ្សេងៗទៀត។ ដូចគ្នានេះដែរ ថ្នាក់លើដែលបានដឹងថាឧក្រិដ្ឋកម្មនានា កំពុងត្រូវបានប្រព្រឹត្ត ប៉ុន្តែមិនបានចាត់វិធានការរារាំងទប់ស្កាត់ ឬដាក់ទោសចំពោះចារីទេនោះ អាចនឹងត្រូវយល់ឃើញថា បានជួយ និងជម្រុញដល់ឧក្រិដ្ឋកម្មទាំងនោះ។ គ្មានភស្តុតាងបញ្ជាក់ពីផែនការ ឬការព្រមព្រៀងតម្រូវឱ្យមាននោះទេ ជាក់ស្តែងគឺចារីមិនចាំបាច់ដឹងឮពីការចូលរួមចំណែករបស់ជនត្រូវចោទផង។

១៣៣០- វត្តមានជារូបវន្ត របស់បុគ្គលដែលជាអ្នកជួយ និងជម្រុញ នៅទីកន្លែងដែលឧក្រិដ្ឋកម្មកើតមាន គឺមិនតម្រូវឱ្យមាននោះទេ។ ឧទាហរណ៍ ការលើកទឹកចិត្តដល់ឧក្រិដ្ឋកម្មសង្គ្រាម តាមរយៈការបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មាន ដោយមិនចាំបាច់មានវត្តមាននៅពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តនោះ គឺមានលក្ខណៈគ្រប់គ្រាន់ជាមូលដ្ឋានសម្រាប់បទចោទ ការជួយ និងជម្រុញហើយ ដោយសារ *ការធ្វើតាមចិត្តចង់* ជាអាកប្បកិរិយាសាធារណៈចំពោះការប្រព្រឹត្តិឡើងនូវឧក្រិដ្ឋកម្ម រួមជាមួយនឹងការខកខានមិនបានចេញបញ្ជាឱ្យបញ្ឈប់ ឧក្រិដ្ឋកម្មបែបនោះ។

១៣៣១- ចំពោះធាតុផ្សំអត្តនោម័តដែលបានតម្រូវវិញ ជនត្រូវចោទមិនតម្រូវឱ្យមាន *ចេតនាឧក្រិដ្ឋ* ជាមួយនឹងចារីនោះទេ និងមិនចាំបាច់ត្រូវដឹងពីឧក្រិដ្ឋកម្មដែលចារីមានបំណងនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តរួចឱ្យបានពិតប្រាកដនោះដែរ។ ប៉ុន្តែ ជនត្រូវចោទត្រូវតែដឹងថា អំពើរបស់ខ្លួនទាំង

ឡាយ នឹងជួយជម្រុញដល់ការប្រព្រឹត្តិទៅនៃឧក្រិដ្ឋកម្ម ហើយចេតនាក្នុងការផ្តល់ជំនួយ ឬយ៉ាងហោចណាស់ ទទួលយកនូវការជួយបែបនេះនោះ អាចនឹង"ជាបច្ច័យដែលអាចធ្វើបាន និងអាចគិតទុកជាមុនពីការប្រព្រឹត្តិរបស់គាត់"។ ជនត្រូវចោទត្រូវតែបានដឹងឮផងដែរ ពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្ម។ ត្រូវបង្ហាញថាមាន*ចេតនាឧក្រិដ្ឋ* កើតមាន នៅពេលដែលប្រព្រឹត្តអំពើដែលបង្កឱ្យមានការជួយ និងជម្រុញ។ ក្នុងករណីដែលមានចេតនាឧក្រិដ្ឋ កម្មជាក់លាក់នោះ ដូចជាអំពើប្រល័យពូជាសាសន៍ ជនត្រូវចោទមិនចាំបាច់បង្ហាញថាខ្លួនមានចេតនារួមជាមួយនឹងចារីនោះទេ ប៉ុន្តែជនត្រូវចោទបានដឹងឮពីចេតនានោះ។

១៣៣២- ក្នុងរឿងក្តី *Krstic* ជនត្រូវចោទ ដែលជានាយសេនាធិការឬអនុមេបញ្ជាការនៃកង Drina Corps នោះ ត្រូវបានតុលាការ ICTY រកឃើញថាមានពិរុទ្ធ ពីបទជួយ និងជម្រុញចំពោះអំពើប្រល័យពូជសាសន៍ ដោយបានអនុញ្ញាតឱ្យបុគ្គលិក និងធនធានស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ត្រូវយកទៅប្រើប្រាស់ ដើម្បីសម្របសម្រួលដល់ការសម្លាប់ក្នុងទ្រង់ទ្រាយធំ។ ជនត្រូវចោទបានដឹងថា បើគ្មានការប្រើប្រាស់ធនធានអស់ទាំងនេះទេនោះ ចារីនឹងមិនអាចសម្រេចផែនការប្រល័យពូជសាសន៍របស់ពួកគេបាននោះទេ ហើយអំពើដែលផ្តល់លទ្ធភាពឱ្យធនធានទាំងនេះ អាចយកទៅប្រើប្រាស់បាននោះ គឺគាត់បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។

១៣៣៣- នៅក្នុងរឿងក្តី *Blagojevic* ជនត្រូវចោទ គឺជាអនុមេបញ្ជាការ ឬនាយសេនាធិការ របស់កងពលតូច Bratunac។ គាត់ត្រូវបានរកឃើញថាមានពិរុទ្ធ *នៅក្នុងចំណោមនោះ* ពីបទការជួយ និងជម្រុញឱ្យមានឃាតកម្ម ការធ្វើទុក្ខបុកម្នេញ និងការប្រព្រឹត្តសកម្មភាពអមនុស្សធម៌

ផ្សេងៗទៀត (ដូចជាការជម្លៀសដោយបង្ខំ) ដោយគាត់បានអនុញ្ញាតឱ្យយកធនធានរបស់កងពលតូច Bratunac ទៅប្រើប្រាស់ក្នុងការប្រព្រឹត្តិនូវសកម្មភាពអស់ទាំងនោះ។ ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ធនធានទាំងនេះ ជនត្រូវចោទបានដឹងហើយថា គាត់កំពុងចូលរួមចំណែកយ៉ាងសំខាន់ ចំពោះការសម្លាប់បុរសៗដែលជាជនជាតិបូស្នី ព្រមទាំងបង្កឱ្យមានការឈឺចាប់ទាំងផ្នែកស្មារតី និងដល់រូបរាងកាយ ទៅប្រជាជនមូស្លីម-បូស្នីទាំងមូល។

១៣៣៤- នៅក្នុងរឿងក្តី *Brdanin* តុលាការ ICTY បានរកឃើញថា ជនត្រូវចោទមានពិរុទ្ធពីបទ ជួយ និងជម្រុញឱ្យកើតមាននូវឧក្រិដ្ឋកម្មនានា *ដែលក្នុងចំណោមនោះ* មានការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទុក្ខបុកម្នេញ ការនិរទេស និងជម្លៀសដោយបង្ខំ ដើម្បីទាមទារឱ្យពួកដែលមិនមែនជាជនជាតិស៊ែប៊ី ទម្លាក់អាវុធ ព្រមទាំងដាក់នូវរយៈពេលកំណត់ ចំពោះការទម្លាក់ចោលអាវុធបែបនោះ ដែលបណ្តាលឱ្យមានការជួយជ្រោមជ្រែងជាក់ស្តែងនៅក្នុងការប្រព្រឹត្តិទៅនៃឧក្រិដ្ឋកម្ម។ បន្ថែមលើនេះទៀត តុលាការបានរកឃើញថា សេចក្តីថ្លែងការណ៍អុជអាល និងរើសអើងនានា ដែលជនត្រូវចោទបានធ្វើឡើង ជម្រុញឱ្យមានការគាំទ្រ និងការលើកទឹកចិត្តផ្នែកស្មារតី ដល់ចារីដែលដល់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម។

១៣៣៥- នៅក្នុងរឿងក្តី *Akayesu* ជនត្រូវចោទគឺជា *Bourgmestre* នៃឃុំ Taba ដែលនៅទីនោះ គាត់ទទួលបន្ទុកអនុវត្តច្បាប់ និងសណ្តាប់ធ្នាប់ និងជាទីកន្លែងដែលគាត់ទទួលបានការគោរព ហើយបញ្ជារបស់គាត់ត្រូវបានប្រតិបត្តិតាម។ តុលាការ ICTR បានរកឃើញថា ការខកខានរបស់គាត់ក្នុងការអនុវត្តន៍ច្បាប់ និងសណ្តាប់ធ្នាប់ និងការខកខានមិនបានរារាំងចំពោះការសម្លាប់ ដែលកើតមាននៅក្នុងតំបន់ដែលរងឥទ្ធិពលរបស់គាត់នោះ រួមជាមួយនឹងវត្តមានរបស់គាត់ផ្ទាល់នៅ

នឹងកន្លែងដែលមនុស្សឃាតកើតមានផង បង្កឱ្យមានការជួយ និងជម្រុញដល់ឧក្រិដ្ឋកម្មទាំងនេះ។

១៣៣៦- នៅក្នុងរឿងក្តី *Fofana* ជនត្រូវចោទគឺជាអ្នកដឹកនាំកងកម្លាំងការពារជនស៊ីវិលម្នាក់។ គាត់ត្រូវតុលាការ SCSL រកឃើញថាបានប្រព្រឹត្តបទជួយ និងជម្រុញ ដែលជាការរំលោភបំពានមាត្រា៣ រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ ដោយផ្អែកជាមូលដ្ឋានលើ សុន្ទរកថាដែលគាត់បានថ្លែងទៅកាន់អ្នកប្រយុទ្ធ ដែលពួកគេនឹងត្រូវស្លាប់ ប្រសិនបើពួកគេមិនគោរពតាមបញ្ជានានារបស់មេបញ្ជាការមួយផ្សេងទៀត។ ជនត្រូវចោទបានដឹងហើយថា បញ្ជាទាំងនេះ គឺរួមមានការធ្វើមនុស្សឃាត និងបង្កឱ្យមានរបួសស្នាមលើរាងកាយ ហេតុដូច្នេះ ជនត្រូវចោទបានដឹងឮរួចទៅហើយថា យ៉ាងហោចណាស់ មានឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវតែប្រព្រឹត្តដោយគោរពតាមបញ្ជាទាំងនេះ។

១៣៣៧- នៅក្នុងរឿងក្តី *Kambanda* ជនត្រូវចោទ គឺជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលបណ្តោះអាសន្នរបស់ប្រទេសរ៉្វាន់ដា។ គាត់បានថ្លែងពីពិរុទ្ធក្នុងការប្រព្រឹត្តនូវអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ដូចជា មនុស្សឃាត និងការសម្លាប់រង្គាល)។ *នៅក្នុងចំណោមនោះ* បទចោទនេះត្រូវបានគាំទ្រតាមរយៈសកម្មភាពនានារបស់គាត់ ដែលគាំទ្រការផ្សព្វផ្សាយរបស់វិទ្យុ *ទូរទស្សន៍សេរីនៃកូនភ្នំមួយរយ*ដោយបានដឹងថា គឺជាការញុះញង់ឱ្យមានការសម្លាប់ដោយការចុះត្រួតពិនិត្យតំបន់នានានៅក្នុងប្រទេស និងការលើកទឹកចិត្តប្រជាជនឱ្យបន្តធ្វើមនុស្សឃាតដោយលើកសរសើរដល់ជនទាំងឡាយណាដែលបានប្រព្រឹត្តអំពើមនុស្សឃាត។ ហើយបាន

ខកខានមិនបានធ្វើការរារាំងទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មដែលគាត់បានដឹង ឬគួរតែបានដឹងថាកំពុងត្រូវបានប្រព្រឹត្តឡើង។

## ការទទួលខុសត្រូវរបស់ ថ្នាក់លើ

១៣៣៨- មាត្រា២៩ នៃច្បាប់អ.វ.ត.ក ចែងថា៖ "ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាព ដែលមានចែងក្នុងមាត្រា៣ថ្មី ៤ ៥ ៦ ៧ និងមាត្រា៨ នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ ប្រសិនបើថ្នាក់លើមានបញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលបានដឹង ថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយខ្លួនមិនបានចាត់វិធានការចាំបាច់ និងសម្របសម្រួល ដើម្បីបង្ការអំពើបែបនេះ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះ"។ អំពើនេះបង្កើតឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលគេស្គាល់ថា ជាការទទួលខុសត្រូវរបស់អ្នកបញ្ជា ឬថ្នាក់លើ គឺមានមូលដ្ឋានរឹងមាំនៅក្នុងច្បាប់អនុសញ្ញាអន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិផ្សេងៗ ព្រមទាំងគ្របដណ្តប់បន្ថែមលើថ្នាក់ដឹកនាំផ្នែកយោធា ថ្នាក់ដឹកនាំនយោបាយ និងអ្នកគ្រប់គ្រងជនស៊ីវិល ផ្សេងៗទៀត ដែលស្ថិតនៅក្នុងឋានៈជាអ្នកគ្រប់គ្រងអំណាច។ វាមិនបានផ្អែកលើការមិនចោទប្រកាន់ថ្នាក់លើនឹងអំពើឧក្រិដ្ឋដែលអ្នកក្រោមបង្គាប់របស់គាត់ បានប្រព្រឹត្តនោះទេ ប៉ុន្តែគឺផ្អែកទៅលើការដាក់ទោស ចំពោះការខកខានរបស់គាត់មិនបានប្រើតួនាទីរបស់ខ្លួនជាអ្នកគ្រប់គ្រងក្នុងការចេញ

បញ្ហា។ នៅករណីនានាដែលមានពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ អាចយកមកអនុវត្ត បានដោយមិនគិតថាតើជម្លោះនោះជាលក្ខណៈជាតិ ឬអន្តរជាតិនោះទេ។

១៣៣៩- ក្រោមលក្ខន្តិកៈច្បាប់របស់សាលាក្តីពិសេសនានា ការទទួលខុសត្រូវរបស់ថ្នាក់លើគឺផ្អែកលើ ការកើតមាននូវធាតុផ្សំចំនួនបី ដូចតទៅនេះ៖

(ក) ទំនាក់ទំនងរវាង ថ្នាក់លើ និងអ្នកក្រោមបង្គាប់

(ខ) ថ្នាក់លើបានដឹង និងមានហេតុផលបានដឹង ថាអ្នកនៅក្រោមបង្គាប់ បានប្រព្រឹត្ត ឬបម្រុង នឹងប្រព្រឹត្តនូវបទឧក្រិដ្ឋ

(គ) ហើយថ្នាក់លើខកខានមិនបានរារាំងការប្រព្រឹត្តិទៅនៃឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មដល់ ចារី។

១៣៤០- ទំនាក់ទំនងថ្នាក់លើ និងអ្នកក្រោមបង្គាប់ រវាងជនត្រូវចោទ និងចារីដែលត្រូវចោទប្រកាន់ពីបទ ឧក្រិដ្ឋនោះ អាចមានទាំងក្នុងលក្ខណៈផ្លូវការ និងមិនផ្លូវការ *ទាំងតាមច្បាប់ ឬជាក់ស្តែង* ហើយអាចមានលក្ខណៈផ្ទាល់ ឬមិនផ្ទាល់។ ដូចមានបញ្ជាក់ពីខាងលើ និយមន័យមាត្រា២៩ ចែងយ៉ាងច្បាស់នូវលក្ខខណ្ឌជាក់លាក់ ដែលថ្នាក់លើត្រូវតែមាន "ការគ្រប់គ្រង និងការបញ្ជា ប្រកបដោយប្រសិទ្ធភាព ព្រមជាមួយអំណាច និងការគ្រប់គ្រងទៅលើអ្នកក្រោមបង្គាប់"។ ចំណុចនេះមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងករណីយុត្តិសាស្ត្ររបស់តុលាការពិសេសនានា ដែលបានលើកឡើងថា ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌដែលកើតមាន ដោយផ្អែកលើទំនាក់ ទំនងថ្នាក់លើ និងអ្នកក្រោមបង្គាប់ជាមូលដ្ឋាននោះ ត្រូវតែបង្ហាញឲ្យឃើញថា អ្នកគ្រប់គ្រង មាន "ការគ្រប់គ្រងដោយប្រសិទ្ធភាព" ទៅលើចារី។

១៣៤១- ចំណុចដែលបង្ហាញពីការគ្រប់គ្រងដោយប្រសិទ្ធភាពនោះ គឺ “ត្រូវកំណត់ក្នុងការបង្ហាញថា ជនត្រូវចោទមានអំណាច ក្នុងការរារាំង ដាក់ទណ្ឌកម្ម ឬដាក់ចេញនូវវិធានការដឹកនាំកិច្ចដំណើរការជំទាស់នឹងចារីដែលរងការចោទប្រកាន់ ចំពោះករណីដែលសមស្រប”។ អំណាចនេះបានបន្ថែមឱ្យមានការបកស្រាយ ថាបុគ្គលម្នាក់ត្រូវទទួលខុសត្រូវចំពោះ *លទ្ធភាពសំខាន់* ក្នុងការរារាំងឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិ។ ជនត្រូវចោទអាចមាន “ការគ្រប់គ្រងដោយប្រសិទ្ធភាព” ទៅលើចារី ទាំងក្នុងលក្ខណៈអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្ន ប៉ុន្តែការគ្រប់គ្រងនោះ ក៏ត្រូវមានពិតប្រាកដផងដែរនៅពេលដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើង។ ថ្នាក់លើ២នាក់ ឬច្រើនជាងនេះ អាចមានលទ្ធភាពគ្រប់គ្រងដោយប្រសិទ្ធភាពទៅលើចារី ហេតុដូច្នេះ បង្កឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈ ការទទួលខុសត្រូវរបស់ថ្នាក់លើ។ នៅពេលការទទួលខុសត្រូវរបស់ ថ្នាក់លើ ត្រូវយកទៅអនុវត្តលើជនស៊ីវិលមិនមានលក្ខខណ្ឌលើកឡើងថា ថ្នាក់លើត្រូវតែអនុវត្ត ការគ្រប់គ្រងក្នុងសភាពលក្ខណៈដូចគ្នា ដូចជាការអនុវត្តន៍ការគ្រប់គ្រងរបស់មេបញ្ជាការយោធានោះទេ។

១៣៤២- ចំពោះករណីដែលការតម្រូវឱ្យមានការដឹងឮ ពាក្យថា “បានដឹង” សំដៅដល់ការដឹងឮជាក់ស្តែងដែលអាចបង្កើតឡើងតាមរយៈភ័ស្តុតាងផ្ទាល់ ឬភ័ស្តុតាងប្រយោល។ លក្ខខណ្ឌតម្រូវអំពីពាក្យថា “មានមូលហេតុក្នុងការដឹងឮ” តម្រូវឱ្យមានភ័ស្តុតាងបញ្ជាក់ថា ជនត្រូវចោទ “មានផ្ទុកនូវព័ត៌មានទូទៅ ដែលអាចផ្តល់ជាការជូនដំណឹងដល់ជនត្រូវចោទ ពីលទ្ធភាពដែលអាចកើតមាននូវអំពើខុសច្បាប់ដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់ខ្លួន”។ ព័ត៌មាននោះអាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ និង“មិនតម្រូវឱ្យមានទម្រង់ជាសេចក្តីរាយការណ៍ជាក់លាក់

ដែលត្រូវដាក់ជូន ដោយគោរពទៅតាមប្រព័ន្ធគ្រប់គ្រងមួយនោះទេ។ វាមិនចាំបាច់ផ្តល់នូវព័ត៌មានជាក់លាក់ អំពីអំពើខុសច្បាប់នានាដែលត្រូវបានប្រព្រឹត្ត ឬបម្រុងនឹងប្រព្រឹត្តនោះឡើយ"។ ចំពោះគោលបំណងនានាក្នុងការបង្ហាញថាព័ត៌មានស្ថិតនៅក្នុងដៃរបស់ថ្នាក់លើ វាមិនចាំបាច់ក្នុងការបង្ហាញថា "ថ្នាក់លើបានដឹងជាក់ស្តែងពីព័ត៌មាននោះ"។ ឋានៈជាអ្នកបញ្ជារបស់ជនត្រូវចោទអាចបង្ហាញពីការដឹងឮរបស់គាត់ពីការប្រព្រឹត្ត អំពើឧក្រិដ្ឋរបស់អ្នកក្រោមបង្គាប់បាន។

១៣៤៣- ទោះបីជា លក្ខខណ្ឌនៃពាក្យថា "មានមូលហេតុក្នុងការដឹង" មិនបានដាក់បង្ខំជាកាតព្វកិច្ចឱ្យទទួលយកនូវព័ត៌មានក៏ដោយ ក៏ការទទួលខុសត្រូវព្រហ្មទណ្ឌ នឹងត្រូវដាក់បង្ខំទៅលើជនត្រូវចោទដែលមានចេតនារារាំងមិនឱ្យស្វែងរកព័ត៌មានដែលពាក់ព័ន្ធ។ និយាយម្យ៉ាងទៀត គឺថាការខកខានដោយធ្វេសប្រហែស ក្នុងការរកព័ត៌មានមិនទាមទារឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ចំណែកឯការដឹងឮដែលតម្រូវឱ្យមានអាចនឹងត្រូវសន្មតថាមានការទទួលខុសត្រូវ ប្រសិនបើជនត្រូវចោទមានមធ្យោបាយក្នុងការរកការដឹងឮ ប៉ុន្តែត្រូវបានគេចវេសដោយចេតនា មិនឱ្យធ្វើការស្វែងរក។

១៣៤៤- "ការខកខានក្នុងការរារាំង ឬដាក់ទណ្ឌកម្ម" បង្ហាញឱ្យឃើញនូវកាតព្វកិច្ចដែលជាការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងការ"ដាក់ចេញនូវវិធានការណ៍សមស្រប និងមានសារៈសំខាន់ក្នុងការរារាំង ឬដាក់ទណ្ឌកម្ម" ទៅលើអំពើឧក្រិដ្ឋនានារបស់អ្នកក្រោមបង្គាប់របស់គាត់។ វិធានការទាំងនេះ អនុវត្តចំពោះតែជនទាំងឡាយដែលស្ថិតនៅក្រោមបង្គាប់ ឬលទ្ធភាពសំខាន់របស់ថ្នាក់លើតែប៉ុណ្ណោះ។ អំណាចបែបនោះ ត្រូវវាយតម្លៃទៅតាមកម្រិតប្រសិទ្ធភាពនៃ

ការគ្រប់គ្រង ដែលថ្នាក់លើមានទៅលើអ្នកក្រោមបង្គាប់របស់គាត់។ ការប្រតិបត្តិទៅតាមតួនាទីផ្ទាល់របស់ថ្នាក់លើ នឹងត្រូវវាយតម្លៃដោយផ្អែកលើ "សមត្ថភាព ប្រកបដោយប្រសិទ្ធភាព" ក្នុងការដាក់ចេញនូវវិធានការ ដែលតម្រូវឱ្យមានការទទួលខុសត្រូវលើសពីសមត្ថភាពផ្លូវការទៅទៀត។ មិនចាំបាច់បង្ហាញឱ្យឃើញពីទំនាក់ទំនងសាមញ្ញ រវាងការខកខានរបស់ថ្នាក់លើក្នុងការរារាំងអំពើឧក្រិដ្ឋរបស់អ្នកក្រោមបង្គាប់ ជាមួយនឹងការប្រព្រឹត្តទៅនៃអំពើឧក្រិដ្ឋទាំងនោះ។

## ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ [ច្បាប់ អ.វ.ត.ក មាត្រា៣]

## ការចូលរួមដោយផ្ទាល់

១៣៨៥- មាត្រា៨២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា ជនណាចូលរួមប្រព្រឹត្តដោយចេតនា នូវឧក្រិដ្ឋកម្មទោសកម្មណាមួយ ដោយផ្ទាល់ក្ដី ដោយប្រយោលក្ដី ជននោះត្រូវមានទោស ដូចជាអាទិចារី។ ការរួមប្រព្រឹត្តិដោយផ្ទាល់នោះ ទុកជាសហចារី ឯការរួមប្រព្រឹត្តិដោយប្រយោល ទុកជាសមគំនិត។

## ការរួមប្រព្រឹត្តិដោយប្រយោល

១៣៨៦- ការរួមប្រព្រឹត្តិដោយប្រយោល អាចនឹងមានទោសបាន លុះតែអំពើនោះបានសម្រេចមកពីការនាំអាទិ៍ ការឱ្យអនុទ្ទេស ការផ្ដល់មធ្យោបាយ ការជួយ ឬការទំនុកបម្រុង៖

១៣៨៧- ការនាំអាទិ៍ គឺការចាក់រុក អុជអាល ឱ្យអ្នកដទៃប្រព្រឹត្តនូវអំពើណាមួយ ដោយសារ ពាក្យទូន្មាន បង្គាប់ ឬណែនាំ។ ការទូន្មាន ឬការចេញបញ្ជា ត្រូវតែចេញមកពីអ្នកដែលមាន

អំណាចទៅលើអ្នកប្រព្រឹត្តបទល្មើសនោះ ឬតាមរយៈការផ្តល់សន្យា អំណោយ ការគម្រាមកំហែង ឬបង្ខំផ្សេងៗ។ ពាក្យណែនាំ ត្រូវតែជាឧបាយកលណាមួយ សម្រាប់ញុំាងចិត្តចារីឱ្យញាប់ញ័រ ហើយជម្រុញជននោះ ឱ្យប្រព្រឹត្តបទល្មើសនោះ ខានមិនបាន។

១៣៤៨- អនុទ្ទេស គឺជាព័ត៌មានដែលឱ្យដោយដឹងច្បាស់ ក្នុងចិត្តឯងជាមុនថា ចារី នឹងយកព័ត៌មាននេះទៅប្រើប្រាស់ក្នុងការប្រព្រឹត្តិបទល្មើសនោះ ជាមិនខាន។

១៣៤៩- ដោយការរួមប្រព្រឹត្តិដោយប្រយោល ត្រូវបានចោទប្រកាន់ ដោយផ្អែកលើការផ្តល់ជាមធ្យោបាយ នោះមធ្យោបាយ គឺជាសម្ភារៈដែលអាចយកទៅសម្រេចបទល្មើសនោះបាន ហើយកាលឱ្យគ្រឿងប្រដាប់នោះ ក៏បានដឹងថា របស់នេះមុខជាចារីនឹងយកទៅប្រព្រឹត្តបទល្មើសនោះហើយ។

១៣៥០- ជំនួយ ឬការទំនុកបម្រុង គឺការជួយដោយដឹងច្បាស់ថា នឹងសម្រួល ឬធ្វើឱ្យងាយប្រព្រឹត្តអំពើល្មើសនោះ។

## VI. ការកំណត់បទល្មើស

### ក- បទឧក្រិដ្ឋ

### អំពើប្រល័យពូជសាសន៍

១៣៥១- ភ័ស្តុតាងនៅក្នុងសំណុំរឿង និងដែលនិយាយយោងនៅក្នុងផ្នែកអង្គហេតុសត្យានុម័តនៃដីកានេះ បង្ហាញថា អំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអាចផ្តន្ទា

ទោសបានតាមមាត្រា៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ អំពើប្រល័យពូជសាសន៍នេះបាន ប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមជាតិពន្ធុវៀតណាម និង ក្រុមជាតិពន្ធុចាម ឬក្រុមសាសនាចាម។ ចំណុចសំខាន់មួយនៃអង្គហេតុនានាដែលបង្ហាញពីអំពើពាក់ព័ន្ធ និងលក្ខខណ្ឌនៃចេតនាឧក្រិដ្ឋដូច រៀបរាប់ដូចខាងក្រោមនេះ៖

## អំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម

១៣៥២- នៅដើម ឬ ក្នុងខែមេសា ឆ្នាំ១៩៧៧ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំផែនការមួយ ក្នុងការសម្លាប់រង្គាល ជនជាតិវៀតណាមដែលបានរស់នៅប្រទេសកម្ពុជា ដោយមានចេតនា កម្ទេចក្រុមជាតិពន្ធុនេះតែម្តង។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាយល់ឃើញថា ពួកវៀតណាម ដែលរស់នៅគ្រប់ទីកន្លែងក្នុងប្រទេសនេះ ជាការគម្រាមកំហែងដល់ការរស់នៅរបស់កម្ពុជា និង ពូជសាសន៍ខ្មែរ។ ទស្សនៈនេះបញ្ចេញឡើងមួយផ្នែកដោយសារមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជឿថា ប្រទេសវៀតណាមចង់ត្រួតត្រាប្រទេសកម្ពុជា និងបញ្ចូលប្រទេសនេះទៅក្រោមការគ្រប់ គ្រងផ្តាច់មុខរបស់វៀតណាម។

១៣៥៣- ជនជាតិវៀតណាមជាក្រុមជាតិពន្ធុមួយដោយឡែកនៅប្រទេសកម្ពុជា ខុសពីក្រុមជាតិពន្ធុផ្សេង ទៀតទាំងលក្ខណៈរូបរាង សាសនា ភាសា និង ទំនៀមទម្លាប់។ ពួកគេក៏ជាក្រុមដែលខុសពីជន ជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសវៀតណាមដែរ ដោយសារតែទីតាំងភូមិសាស្ត្រ។ នៅ ឆ្នាំ១៩៧០ ក្រុមនេះមានចំនួនមនុស្សពី ៤០០០០០ នាក់ ទៅ ៤៥០០០០ នាក់ តែដោយសារតែ របបសាធារណរដ្ឋខ្មែរបានបណ្តេញពួកគេនោះ នៅខែមេសា ឆ្នាំ១៩៧៥ ពួកគេនៅសេសសល់

ក្នុងប្រទេសពី ២០០០០០ នាក់ ទៅ ២៥០០០០ នាក់។ នៅពេលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាចភ្លាម ក៏មានការបណ្តេញពួកគេជាទ្រង់ទ្រាយធំ ដោយបញ្ជូនជនជាតិវៀតណាមចំនួនពី ១៥០០០០ នាក់ ទៅ ២០០០០០ នាក់ ឲ្យវិលត្រឡប់ទៅប្រទេសវៀតណាមវិញ ដោយបន្ថយចំនួនក្រុមជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជាប្រមាណ ២០០០០ នាក់ នៅឆ្នាំ១៩៧៧។ នៅក្នុងដំណាក់កាលនេះ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងជនជាតិវៀតណាមមានការផ្លាស់ប្តូរ ហើយចំនួនជនជាតិវៀតណាមដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា ក្លាយជាគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយលែងបញ្ជូនចេញពីប្រទេសទៀតហើយ។ គិតមកដល់ចុងសម័យកម្ពុជាប្រជាធិបតេយ្យ គោលដៅនៃអំពើប្រល័យពូជសាសន៍ស្ទើរតែសម្រេចបាន។

**អំពើ**

១៣៥៤- ជនត្រូវចោទបានប្រើប្រាស់មនុស្សដែលស្ថិតក្រោមការត្រួតត្រា និង ឥទ្ធិពលរបស់ខ្លួនឲ្យប្រព្រឹត្តតាមកម្មវិធីប្រល័យពូជសាសន៍ នៅទូទាំងប្រទេសចាប់ពីឆ្នាំ១៩៧៧ រហូតមក។ ភាពស៊ីសង្វាក់គ្នានឹងទង្វើនេះដែរ បន្ថែមទៅលើតំបន់នានាដែលស្ថិតក្រោមការស៊ើបអង្កេត (ដូចមានបង្ហាញជូនខាងក្រោម) មានភស្តុតាងជាច្រើនដែលប្រមូលបាន បង្ហាញពីជនជាតិវៀតណាមដែលក្លាយជាគោលដៅនៅក្នុងខេត្តក្រចេះ បាត់ដំបង កំពង់ឆ្នាំង កំពត កំពង់ចាម កំពង់ធំ កណ្តាល ពោធិ៍សាត់ និងសៀមរាប។

**ការសម្លាប់សមាជិកនៅក្នុងក្រុមនេះ**

១៣៥៥- យ៉ាងហោចណាស់ក៏ចាប់ពីឆ្នាំ១៩៧៧មកដែរ ដែលការសម្លាប់ជនស៊ីវិលជាតិពន្ធុវៀតណាម បានកើតឡើងនៅតាមតំបន់ និងទីតាំងដែលស្ថិតក្រោមការស៊ើបអង្កេត ដូចខាងក្រោម៖

(១) ខេត្ត**ព្រៃវែង** និង **ស្វាយរៀង** និង

(២) មន្ទីរសន្តិសុខ ស-២១ **កោះខ្សែង** **ក្រាំងតាចាន់** **គោកក្តួច** **វត្តធ្លក** និង **ភ្នំក្រោល** ជាកន្លែងដែលជនរងគ្រោះជាតិពន្ធុវៀតណាម និង/ឬ អ្នកដែលមានទំនាក់ទំនង ឬ ជាគ្រួសារជាមួយជនជាតិវៀតណាម ត្រូវបានគេឃុំឃាំង និង សម្លាប់។

១៣៥៦- ការសម្លាប់ជនជាតិវៀតណាមនៅខេត្ត **ព្រៃវែង** និង **ស្វាយរៀង** ត្រូវបានប្រព្រឹត្តឡើងដោយអាជ្ញាធរ និង ឈ្លបមូលដ្ឋាន ទៅតាមការបញ្ជា និងសហការជាមួយថ្នាក់លើបក្សកុម្មុយនីស្តកម្ពុជា។ ជនជាតិវៀតណាមដែលរស់នៅទីនោះត្រូវបានយកចេញពីភូមិ ឬ ឃុំរបស់ខ្លួន ហើយបន្ទាប់មកត្រូវបានគេយកទៅសម្លាប់នៅកន្លែងពិឃាតនានារួមមាន **វាលត្បូច** ក្នុងស្រុកព្រៃវែង។ ក្នុងករណីខ្លះទៀត អ្នកទាំងនោះត្រូវបានចុះឈ្មោះរួចហើយដោយអាជ្ញាធរទាំងនោះ ជាគំរូមួយដែលឆ្លុះបញ្ចាំងពីផ្នែកដទៃទៀតនៅក្នុងប្រទេស (ដូចជាក្នុងករណីជនរងគ្រោះវៀតណាមត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខកោះខ្សែងជាដើម)។ មានសាកសពចំនួនជាង ៩០០ នាក់ ត្រូវបានគាស់ចេញពី **វាលត្បូច** តែមួយកន្លែង ក្នុងនោះមានទាំងសាកសពជនរងគ្រោះវៀតណាមផង និងក្រុមផ្សេងទៀតដែលជាគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា។

១៣៥៧- ក្នុងករណីមានគ្រួសារចម្រុះជាតិសាសន៍ក្នុងខេត្ត **ព្រៃវែង** និង **ស្វាយរៀង** ចារីបានសម្លាប់ប្រពន្ធ និង កូន ដែលជាជនជាតិវៀតណាម ដោយទុកឲ្យប្តីជាជនជាតិខ្មែរនៅរស់។ ប្រសិនបើប្តីជាជនជាតិវៀតណាម គេសម្លាប់ចោលប្តី ដោយទុកឲ្យប្រពន្ធនិងកូនជាជនជាតិខ្មែរនៅរស់។ ការស៊ើប

អង្កេតមិនបានរកឃើញពីឧទាហរណ៍ណាមួយនៅក្នុងខេត្ត ព្រៃវែង ឬ ខេត្តស្វាយរៀង ដែលសមាជិកជនជាតិវៀតណាមនៅក្នុងគ្រួសារចម្រុះជាតិសាសន៍ ឬ អ្នករស់នៅផ្សេងទៀត ដែលត្រូវកំណត់អត្តសញ្ញាណដោយចារី ថាជាជនជាតិវៀតណាម ត្រូវបានទុកឱ្យរស់រានមានជីវិតនោះទេ។

១៣៥៨- ការសម្លាប់ជនជាតិវៀតណាម ក៏បានកើតឡើងយ៉ាងហោចណាស់ក៏នៅក្នុងមន្ទីរសន្តិសុខចំនួន ៦ ដែលបានរៀបរាប់ខាងលើដែរ។ មានលក្ខណៈរួមគ្នានៅក្នុងមន្ទីរសន្តិសុខទាំងនេះគឺថា អ្នកណាដែលមានជាតិពន្ធុវៀតណាម គឺជាមូលដ្ឋានពិសេសសម្រាប់ចាប់ខ្លួន និង យកទៅសម្លាប់ (ឧទាហរណ៍ ក្រៅពីហេតុផលផ្សេងទៀត អ្នកនោះត្រូវបានចោទថាជាពួកក្បត់ ឬ ខ្មាំងបដិវត្ត)។ ពួកវៀតណាមគឺជាក្រុមធំជាងគេ ក្នុងចំណោមអ្នកទោសដែលមិនមែនជាជនជាតិខ្មែរនៅស-២១ ។ ក្នុងចំណោមអ្នកទោសវៀតណាមចំនួន ៧៩ នាក់ ដែលបានកត់ត្រាថាជាជនស៊ីវិលនៅស-២១ យ៉ាងហោចណាស់ក៏មានចំនួន ២៩ នាក់ដែរ ដែលត្រូវបានចាប់ខ្លួនពីផ្នែកផ្សេងៗនៃប្រទេសកម្ពុជា រួមមានពីខេត្ត ព្រៃវែង (ក្នុងចំណោមនោះ ២៦ នាក់ត្រូវបានចាប់ខ្លួនក្រោយថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧)។ អ្នកទោសចំនួន ១៤៤ នាក់នៅស-២១ (ភាគច្រើនត្រូវបានចាប់ខ្លួនពីក្នុងប្រទេសកម្ពុជា) ត្រូវបានពណ៌នាថាជា "គិញ"។ នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយបានបញ្ជាក់ថា ជនរងគ្រោះទាំងនោះត្រូវបានគេសួរចម្លើយក្រោមការធ្វើទារុណកម្ម ដើម្បីកំណត់អត្តសញ្ញាណជនជាតិវៀតណាមផ្សេងទៀត នៅក្នុងប្រទេសនេះ។ ដោយការឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ចំពោះជនជាតិវៀតណាម សូម្បីតែអ្នកទោសដែលជាជនជាតិខ្មែរត្រូវបានធ្វើទារុណ្ណកម្មនៅស-២១ ក្នុង

ឆ្នាំ១៩៧៨ ក៏ត្រូវបានគេបង្ខំឲ្យឆ្លើយសារភាពថាជាតិញ ឬ អ្នកមានទំនោរទៅរកជនជាតិវៀតណាមដែរ។

## ចេតនា

១៣៥៩- ជនត្រូវចោទបានបញ្ជា ជំរុញ ញុះញង់ លើកទឹកចិត្ត និង ត្រួតត្រាការសម្លាប់ជនជាតិវៀតណាម រួមទាំងជនដែលស្ថិតក្នុងជាតិពន្ធុចម្រុះផងដែរ ដោយមានចេតនាពិសេសដើម្បីបំផ្លាញជនជាតិវៀតណាមដែលនៅសេសសល់រស់នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងសុន្ទរកថា និង សេចក្តីថ្លែងការណ៍ផ្លូវការរបស់ខ្លួន (ដូចជាទស្សនាវដ្តី *ទង់បដិវត្ត* ជាដើម) និង ការជួបប្រជុំជាមួយកម្មាភិបាលថ្នាក់ក្រោម មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានគូសបញ្ជាក់ម្តងហើយម្តងទៀត ពីគោលនយោបាយរបស់ខ្លួនក្នុងការកម្ទេចជនជាតិវៀតណាម។ ចេតនារបស់ពួកគេក្នុងការកម្ទេចក្រុមជាតិពន្ធុនេះ ក៏អាចឲ្យគេសន្និដ្ឋានបានអំពីវិធីដែលជនជាតិវៀតណាមក្លាយជាគោលដៅដែរ។ ខុសពីប្រជាជនទូទៅ ជនជាតិវៀតណាមរូបណាក៏ដោយ ដែលអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជាចាប់ខ្លួនបាន ត្រូវយកទៅសម្លាប់ចោល ដោយមិនគិតដល់ករណីថាតើ អ្នកនោះជាអ្នកត្រូវយកទៅឃុំឃាំង និងធ្វើការសួរចម្លើយ ឬ មួយយ៉ាងណានោះទេ។

១៣៦០- មានភស្តុតាងផ្សេងទៀតស្តីពីចេតនារបស់ជនត្រូវចោទ ដើម្បីកម្ទេចក្រុមជាតិពន្ធុវៀតណាមនៅក្នុងប្រទេសកម្ពុជា រួមមាន៖

(១) ការអនុវត្តគោលនយោបាយខាងលើនៅទូទាំងប្រទេស លក្ខណៈស៊ីសង្វាក់គ្នាដែលបទឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង អំពើសាហាវព្រៃផ្សៃជាទ្រង់ទ្រាយធំ និង លទ្ធផលនៃការ

ប្រព្រឹត្តិទាំងនោះ បានធ្វើឱ្យជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ២០០០០ នាក់ ស្ទើរតែត្រូវបានកម្ទេចទាំងស្រុង គិតត្រឹមពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ។

(២) ការខិតខំប្រឹងប្រែងយ៉ាងស៊ីសង្វាក់គ្នារបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីលើកទឹកចិត្តឱ្យស្អប់ជនជាតិវៀតណាម ធ្វើឱ្យបាត់បង់សេចក្តីថ្លៃថ្នូជាមនុស្ស និង បន្ទាបបន្ថោកអ្នកទាំងនោះ និង ធ្វើឱ្យចារីផ្ទាល់មានគំនិតជ្រុលនិយម។

(៣) ការជាប់ពាក់ព័ន្ធរបស់កម្មាភិបាលជាន់ខ្ពស់នៅក្នុងភូមិភាគ (ដូចជាគណៈស្រុកជាដើម) ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីកំណត់អត្តសញ្ញាណ និង សម្លាប់ជនជាតិវៀតណាម។

(៤) ពិនិត្យតាមដានជនជាតិវៀតណាមដែលរស់នៅផ្នែកផ្សេងៗនៃប្រទេស និង ការប្រើប្រាស់កំណត់ហេតុដើម្បីកំណត់អត្តសញ្ញាណ និង សម្លាប់អ្នកទាំងនោះ។

(៥) ការសម្រិតសម្រាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅលើជនជាតិខ្មែរដែលជាប់ពាក់ព័ន្ធនឹងប្រទេសវៀតណាម ដូចជាអ្នកដែលត្រូវបានគេសង្ស័យថាមានទំនោរទៅរកវៀតណាមនៅភូមិភាគបូព៌ា និង សមាជិកក្រុមខ្មែរក្រោម (អ្នកដែលត្រូវបានគេពណ៌នាថាមានក្បាលយួនខ្លួនខ្មែរ)។

(៦) ការពិតគឺថា ពួកវៀតណាមត្រូវបានគេស្រាវជ្រាវ និង យកទៅសម្លាប់ចោលដោយចារីផ្ទាល់ ផ្អែកលើមូលដ្ឋានជាតិពន្ធុសុទ្ធសាធ ដោយមិនគិតដល់អាយុ ភេទ ឬ ឋានៈសង្គមអ្វីឡើយ។

(៧) ការសម្លាប់ជនជាតិវៀតណាមដែលជាសមាជិកទាំងអស់នៅក្នុងគ្រួសារចម្រុះជាតិសាសន៍។

(៨) អង្គហេតុដែលថា ការចាប់ខ្លួន និង ការសម្លាប់ជនជាតិវៀតណាមត្រូវបាន រាយការណ៍ និង ពិនិត្យតាមដានដោយគណៈអចិន្ត្រៃយ៍ និង

(៩) នៅក្នុងបរិបទដែលមានការសម្លាប់ជនជាតិវៀតណាមបានកើតឡើង រួមមានកម្ម វិធីពីមុនរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការនិរទេសជនជាតិវៀតណាមដោយបង្ខំចេញពី ប្រទេសកម្ពុជា។

១៣៦១- ចេតនារបស់ជនត្រូវចោទដើម្បីសម្លាប់ជនជាតិវៀតណាមទាំងអស់ ដែលរស់នៅក្នុងប្រទេស កម្ពុជានៅឆ្នាំ១៩៧៧ បានបង្កើតជាចេតនាមួយក្នុងការកម្ទេចក្រុមជាតិពន្ធុនេះ *ទាំងស្រុង* តែម្តង។ ការសម្រេចបាននូវការកាត់បន្ថយចំនួនមនុស្សនៅក្នុងក្រុមនេះ តាមរយៈការនិរទេស ដោយបង្ខំ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំឡើង ដើម្បីសម្លាប់ជាប្រព័ន្ធនូវជនជាតិ វៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា និង ដើម្បីកម្ចាត់ចោលសូម្បីតែលទ្ធភាពដែលថា សហគមន៍ដែលអាចបង្កើតក្រុមនោះឡើងវិញក៏ដោយ។ និយាយម្យ៉ាងទៀត ស.ច.ស អាច សន្និដ្ឋានថា ចេតនាដើម្បីកម្ទេចក្រុមនោះ*ជាផ្នែក* ប្រសិនបើពួកគេរកឃើញថា ចេតនាប្រល័យ ពូជសាសន៍ត្រូវបានដឹកនាំធ្វើតែទៅលើប្រជាជនវៀតណាម*ដែលនៅសេសសល់* ក្នុងប្រទេស នេះ។ ប្រសិនបើវិធីសាស្ត្រខាងក្រោយនេះត្រូវបានគេឯកភាពតាម នោះវាច្បាស់លាស់ណាស់ ដែលថា ចេតនាដើម្បីសម្លាប់សមាជិកចំនួន ២០០០០ នាក់ នៃក្រុមធំមួយដែលមានចំនួន ប្រមាណ ៤៥០០០០ (ឬ ២៥០០០០) នាក់ បង្កើតជាចេតនាមួយដើម្បីកម្ទេចមួយ*ផ្នែកយ៉ាង សំខាន់(មួយផ្នែកធំ)* នៃក្រុមនោះហើយ។

## អំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាម

១៣៦២- ចាប់ផ្តើមពីឆ្នាំ១៩៧៧មក បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំការសម្លាប់យ៉ាងទូលំទូលាយទៅលើជនជាតិចាមនៅក្នុងប្រទេសកម្ពុជា ដោយមានចេតនាកម្ទេចចោលក្រុមនេះតែម្តង។ ជនជាតិចាមជាក្រុមជាតិពន្ធុ និង សាសនាដោយឡែកមួយ នៅក្នុងប្រទេសកម្ពុជា ខុសប្លែកពីគេដោយសារការប្រតិបត្តិសាសនាអ៊ីស្លាម ទំនៀមទម្លាប់ ភាសា សម្លៀកបំពាក់ប្រពៃណី និង ការរស់នៅក្នុងភូមិដាច់ពីគ្នា ភាគច្រើននៅក្នុងខេត្តកំពង់ចាម។ មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកពួកគេមានឋានៈទាបជាងជនជាតិខ្មែរ ហើយបង្កើតនូវយុទ្ធនាការមួយដើម្បីធ្វើទុក្ខបុកម្នេញចាប់ពីដើមសម័យកម្ពុជាប្រជាធិបតេយ្យមក។ ជនជាតិចាមត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីកន្លែង និង បំបែកចេញពីគ្នា ហើយមេដឹកនាំជនជាតិនេះត្រូវបានក្លាយជាគោលដៅនៃការសម្លាប់។ របបនេះក៏បានគាបសង្កត់មិនឲ្យមានការប្រតិបត្តិវប្បធម៌ ទំនៀមទម្លាប់ និង ភាសាចាម។ នៅឆ្នាំ១៩៧៧ គោលនយោបាយនេះបានវិវត្តទៅជាចេតនាមួយ ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងការកម្ទេចក្រុមនេះទាំងមូល។

### អំពើ

១៣៦៣- ជនត្រូវចោទបានប្រើប្រាស់មនុស្សដែលក្រោមការត្រួតត្រា និងឥទ្ធិពលរបស់ខ្លួនឲ្យប្រព្រឹត្តតាមកម្មវិធីប្រល័យពូជសាសន៍នៅទូទាំងប្រទេស។

### ការសម្លាប់សមាជិកនៅក្នុងក្រុមនេះ

១៣៦៤- ការស៊ើបអង្កេតបានរកឃើញពីការសម្លាប់រង្គាលជនជាតិចាម ដោយមានការរៀបចំពីអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជា យ៉ាងហោចក៏ក្នុងស្រុកបីដែរនៃខេត្តកំពង់ចាម ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ រួមមាន៖

(១) ***ស្រុកកងមាស*** មានជនជាតិចាមរាប់ពាន់នាក់ រួមមានបុរស ស្ត្រី និង កុមារ ត្រូវបានគេប្រមូលផ្តុំពីឃុំ និង ភូមិជាច្រើន ហើយយកទៅសម្លាប់ចោលនៅគុក**វត្តអូរត្រកួន** ក្នុងឆ្នាំ ១៩៧៧ និង ឆ្នាំ១៩៧៨។ ក្នុងការសម្លាប់រង្គាលមួយដែលបានកើតឡើងនៅក្នុង ឬ អំឡុងខែសីហា ឆ្នាំ១៩៧៧ ជនស៊ីវិលជនជាតិចាមទាំងអស់ដែលមកពីឃុំពាមជីកង (ប្រហែល ៣០០នាក់) ត្រូវបានគេយកទៅសម្លាប់។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានសម្លាប់កុមារជនជាតិចាមដោយបោកផ្ទប់នឹងដើមឈើ។ នៅពេលកំពុងប្រមូលផ្តុំមនុស្សនោះ ការសម្លាប់ជាទ្រង់ទ្រាយធំទៅលើជនជាតិចាមក៏បានបន្តនៅក្នុងស្រុកនោះដែរ ក្នុងករណីខ្លះ (ឃុំរកាគយ និង ភូមិមួយនៅអង្គរបាន) ជនរងគ្រោះនៃការសម្លាប់រង្គាលនោះ សុទ្ធសឹងជាស្ត្រីនិងកុមារជនជាតិចាម ដោយបុរសៗត្រូវបានគេបំបែកចេញពីគ្រួសាររួចទៅហើយ។ ការពិឃាតជនជាតិចាមនៅទូទាំងស្រុកកងមាស គឺអនុវត្តតាមការណែនាំដែលចេញដោយលេខា និង អនុលេខាតំបន់។

(២) ***ស្រុកក្រូចឆ្មារ*** មានជនជាតិចាមរាប់រយនាក់ត្រូវបានប្រមូលផ្តុំនៅ**វត្តខ្សាច់ប្រឆេះ**។ មនុស្សចំណាស់ៗ និង កុមារមកពី ៨០ គ្រួសារត្រូវបានដឹកចេញទៅតាមទូក រួចលែងឃើញត្រឡប់មកវិញរហូត។ ក្នុងចំណោមស្ត្រីនៅលើវមួយក្រុមដែលមានចំនួនពី ៤០នាក់ ទៅ ២០០នាក់ ដែលគេកំណត់អត្តសញ្ញាណថាជាជនជាតិចាម ត្រូវបានគេចាប់រំលោភនិងសម្លាប់ចោលដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងឧបទ្ទវហេតុដោយឡែកមួយក្នុងឆ្នាំ១៩៧៨ ជនជាតិចាមដែលមកពីតំបន់មួយចំនួនក្នុងស្រុកនេះ ត្រូវពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបញ្ជាឲ្យ

ចេញទៅនៅភូមិទ្រា ដែលនៅទីនោះ បុរសៗត្រូវបានគេបំបែកចេញ រួចអូសតាមទូកយកទៅជ្រមុកទឹកសម្លាប់ចោលនៅតាមដងទន្លេមេគង្គ។

(៣) ***ស្រុកស្ទឹងត្រង់៖*** នៅចុងឆ្នាំ១៩៧៨ ប្រជាជនចាមនៅឃុំជំនីក (ស្រុកក្រូចឆ្មារ) ត្រូវបានគេប្រមូលផ្តុំ និង បញ្ជូនតាមទូកទៅភូមិបឹងកាចូត ក្នុងស្រុកស្ទឹងត្រង់។ អ្នកដែលព្យាយាមគេចខ្លួនត្រូវគេបាញ់សម្លាប់ចោល។ ពេលទៅដល់ទីនោះ ជនរងគ្រោះត្រូវបានគេបណ្តើរកាត់ភូមិ ហើយលែងឃើញត្រឡប់មកវិញជារៀងរហូត។ សាកសពជនជាតិចាមរួមមានកុមារផង ត្រូវបានគេបោះចូលទៅក្នុងទន្លេមេគង្គ។ មានរណ្តៅសាកសពរួមជាច្រើនត្រូវបានគេរកឃើញនៅក្បែរច្រាំងទន្លេ និង ជិតភូមិបឹងកាចូតនោះ។

១៣៦៥- ការសម្លាប់ជនជាតិចាមក៏បានធ្វើឡើងនៅតំបន់៥ (ភូមិភាគពាយ័ព្យ) ផងដែរ ក្នុងខែឧសភា ឆ្នាំ ១៩៧៧ តែវាទំនងជាលេចឡើងថា ការសម្លាប់ទាំងនោះធ្វើឡើងមុនពេលចាប់ផ្តើមយុទ្ធនាការប្រល័យពូជសាសន៍ទៅទៀត ហើយវាជាផ្នែកមួយនៃគោលនយោបាយធ្វើទុក្ខបុកម្នេញ ដែលកើតមានមុននោះទៅទៀត។ ការសម្លាប់ជាពិសេសទាំងនេះបង្កើតជាមូលដ្ឋាននៃការចោទប្រកាន់ទោសពីបទមនុស្សឃាត និងការសម្លាប់រង្គាលដែលជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចដែលនឹងពណ៌នាខាងក្រោម៖

**ចេតនា**

១៣៦៦- ក្នុងការចេញបញ្ជាឲ្យមានការសម្លាប់រង្គាល ប្រជាជនចាម ជនត្រូវចោទមានចេតនាជាពិសេសដើម្បីកម្ទេចក្រុមសាសនា និងជាតិពន្ធុនេះតែម្តង។ ចេតនានេះត្រូវបានបង្ហាញឲ្យឃើញតាម

រយៈសេចក្តីថ្លែងការណ៍ និងការណែនាំនានា ដែលចេញដោយសមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ទៅដល់កម្មាភិបាលថ្នាក់ក្រោម។ចេតនាដើម្បីកម្ទេចនេះក៏អាចរកឃើញផងដែរ ពីអង្គហេតុនានាដូចខាងក្រោម៖

(១) លក្ខណៈជាប្រព័ន្ធ និង មានការរៀបចំត្រឹមត្រូវនៃការពិឃាតមនុស្សនៅតាមតំបន់ដែលមានជនជាតិចាមរស់នៅជាប្រវត្តិសាស្ត្រ លក្ខណៈស៊ីសង្វាក់គ្នា និង សាហាវឃោរឃៅនៃឧក្រិដ្ឋកម្មដែលធ្វើឡើងប្រឆាំងនឹងសហគមន៍ជនជាតិចាម អំពើសាហាវយង់ឃ្នងជាទ្រង់ទ្រាយធំ និង លទ្ធផលនៃអំពើទាំងនោះ គឺមានជនជាតិចាមរាប់ម៉ឺននាក់ត្រូវបានសម្លាប់ដោយបក្សកុម្មុយនីស្តកម្ពុជា។

(២) ការខិតខំប្រឹងប្រែងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសង្កត់សង្កិនទៅលើវប្បធម៌ និង សាសនាចាមនៅទូទាំងប្រទេស និងការបំផ្លិចបំផ្លាញជាទូទៅទៅលើទ្រព្យសម្បត្តិវប្បធម៌ ជនជាតិចាម ដែលបានអនុវត្តស្របជាមួយនឹងកម្មវិធីប្រល័យពូជសាសន៍។

(៣) តាមអង្គហេតុបង្ហាញថា ជនជាតិចាមត្រូវបានគេស្រាវជ្រាវរក និងយកទៅសម្លាប់ចោលដោយផ្អែកលើមូលដ្ឋានជាតិពន្ធុសុទ្ធសាធ និងដោយមិនគិតពីអាយុ ភេទ ឬឋានៈសង្គមអ្វីទេ។

(៤) តាមអង្គហេតុបង្ហាញថា ជនជាតិចាមមិនត្រូវបានគេសួរចម្លើយទេ មុននឹងយកទៅសម្លាប់។

(៥) ការចូលរួមរបស់កម្មាភិបាលយោធា ដោយមានការបើកដៃពីមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា (រួមមានអង្គភាពអន្តរាគមន៍ពិសេស) និង ពួកកម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជានៅតាមភូមិភាគ (ដូចជាលេខាភូមិភាគ និង លេខាស្រុក) ក្នុងការខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណ ចាប់ខ្លួន និង សម្លាប់ជនជាតិចាម។

(៦) តាមអង្គហេតុបង្ហាញថា ការចាប់ខ្លួន និង ការសម្លាប់ជនជាតិចាមត្រូវបានរាយការណ៍ និង ពិនិត្យតាមដានដោយមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។ និង

(៧) នៅក្នុងបរិបទដែលមានការសម្លាប់ជនជាតិចាមបានកើតឡើង រួមមានយុទ្ធនាការធ្វើទុក្ខបុកម្នេញជនជាតិចាមជាទូទៅ ដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៧៥។

១៣៦៧- ចេតនារបស់ជនត្រូវចោទក្នុងការសម្លាប់ជនជាតិចាមទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជាបានបង្កើតជាចេតនាមួយដើម្បីកម្ទេចក្រុមជាតិពន្ធុនេះ*ទាំងស្រុង* តែម្តង។ និយាយម្យ៉ាងទៀតចំពោះទិដ្ឋភាពដែលថា (១)ការស៊ើបអង្កេតមិនបានគ្របដណ្តប់ទៅលើការធ្វើបាបប្រឆាំងនឹងជនជាតិចាមនៅគ្រប់ទីកន្លែងនៃប្រទេសនេះឡើយ និង (២)ក្នុងករណីខ្លះដែលមានការប្រមូលផ្តុំជនជាតិចាមនោះ បុរសៗមិនត្រូវបានគេយកទៅសម្លាប់ទេ តែត្រូវបានគេបញ្ជូនឲ្យទៅធ្វើការងារដោយបង្ខំនៅតាមការដ្ឋាននានា (ហើយបន្ទាប់មក វាសនារបស់អ្នកទាំងនោះក៏មិនត្រូវបានគេដឹងដែរ) ស.ច.ស អាចធ្វើការសន្និដ្ឋានថា ចេតនាដើម្បីកម្ទេចជនជាតិចាមគឺយ៉ាងហោចណាស់ក៏ជាចេតនាដើម្បីកម្ទេចក្រុមនេះមួយផ្នែកដែរ។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

១៣៦៨- ភ័ស្តុតាងនៅក្នុងសំណុំរឿង និងដែលនិយាយយោងនៅក្នុងផ្នែកអង្គហេតុសត្យានុម័តនៃដីកានេះបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអាចផ្តន្ទាទោសបានតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ចំណុចសំខាន់មួយនៃអង្គហេតុដែលបង្ហាញពីអំពើពាក់ព័ន្ធនឹងធាតុផ្សំយុត្តាធិការ និង បទឧក្រិដ្ឋពិសេសមានរៀបរាប់ដូចខាងក្រោម៖

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស*

## យុត្តាធិការ

## ការវាយប្រហារ

១៣៦៩- ព្រឹត្តិការណ៍នានាស្ថិតក្រោមការស៊ើបអង្កេត គឺជាផ្នែកនៃការវាយប្រហារដែលពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើហិង្សាជាច្រើន ដែលបានកើតឡើងនៅក្នុងប្រព័ន្ធនៃការបង្ក្រាបមួយ ដែលមានការរៀបចំត្រឹមត្រូវ។ អំពើហិង្សាទាំងនេះកើតឡើង បន្ទាប់ពីឡើងកាន់អំណាចដោយហិង្សា បង្កើតជារបបផ្តាច់ការរបស់បក្សកុម្មុយនីស្តកម្ពុជា និង រចនាសម្ព័ន្ធ។ អំពើទាំងនោះរួមមាន៖ (១)ការបណ្តេញប្រជាជនដោយបង្ខំចេញពីទីប្រជុំជន (២)ការប្រព្រឹត្តិអំពើទាសភាពទៅលើប្រជាជនទាំងមូល នៅតាមសហករណ៍ និង ការដ្ឋានដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា (៣)ការប្រើប្រាស់ការងារពលកម្មដោយបង្ខំ (៤)ការប្រើប្រាស់ការគៀបសង្កត់ផ្លូវភេទ និង ការអនុវត្តការរៀបការដោយបង្ខំទៅលើប្រជាជនកម្ពុជារាប់សែននាក់ (៥)ការរឹបអូសកម្មសិទ្ធិឯកជន (៦)ការបដិសេធនូវសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរួមមាន សិទ្ធិរស់រានមានជីវិត និងសន្តិសុខរបស់មនុស្ស សិទ្ធិបញ្ចេញមតិ បង្កើតក្រុមគ្រួសារ និងជំនឿសាសនាដោយសេរី និង (៧)អនុវត្តការគៀបសង្កត់តាមរូបភាពទាំងនេះ តាមរយៈការចាប់ខ្លួន ការធ្វើទារុណ្ណកម្ម ការឃុំឃាំង និង ការសម្លាប់តាមអំពើចិត្ត។

## ជាទូទៅ ឬ ជាប្រព័ន្ធ

១៣៧០- ការវាយប្រហារនោះធ្វើឡើងជាទូទៅផង និងជាប្រព័ន្ធផង។ វាមានលក្ខណៈទូទៅដោយសារលក្ខណៈជាទ្រង់ទ្រាយធំ មានរយៈពេលអូសបន្លាយយូរ កើតឡើងនៅក្នុងតំបន់ភូមិសាស្ត្រទូលំ

ទូលាយ និង មានចំនួនជនរងគ្រោះច្រើនដោយសារការវាយប្រហារនោះ។ ការវាយប្រហារនោះ មានគោលដៅទៅលើប្រជាជនស៊ីវិលចំនួនច្រើន នៅក្នុងប្រទេស ដែលមានចំនួនប្រជាជនពី ៧,៨ លាននាក់ ទៅ ៨,១ លាននាក់ នៅខែមេសា ឆ្នាំ១៩៧៥។ ការវាយប្រហារបានធ្វើឡើង រយៈពេលជាងបីឆ្នាំ និងប្រាំបីខែ។ ការវាយប្រហារនេះកើតឡើងនៅទូទាំងទឹកដីនៃប្រទេស កម្ពុជាទាំងមូល និងទាក់ទិននឹងការប្រើប្រាស់ធនធានយ៉ាងទូលំទូលាយ ដែលជាការចំណាយ របស់របបនេះ រួមមានកងទ័ពដែលស្ថិតក្រោមការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាផង និង កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេសផង និងអាជ្ញាធររដ្ឋាភិបាលកម្ពុជាប្រជាធិប តេយ្យផង។

១៣៧១- ការវាយប្រហារនេះពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ដល់ជនស៊ីវិលជាងពីរលាននាក់ ចេញពីទីប្រជុំជន និងដាក់ប្រជាជនទាំងមូលនៅតាមសហករណ៍ ក្លាយជាជនរងគ្រោះនៃការ អនុវត្តអំពើទាសភាព ដែលជនរងគ្រោះទាំងនោះត្រូវដាក់ឱ្យទទួលរងនូវការងារពលកម្មដោយ បង្ខំ ការចាប់ខ្លួនតាមអំពើចិត្ត ការធ្វើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ក្នុងចំណោម អំពើឧក្រិដ្ឋកម្មផ្សេងៗទៀត ។ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើត និងប្រតិបត្តិការទៅតាមមន្ទីរ សន្តិសុខចំនួនប្រមាណ ២៦០ នៅក្នុងប្រទេសកម្ពុជា ដែលមានតួនាទីជាផ្នែកសំខាន់នៃការវាយ ប្រហារទៅលើប្រជាជនស៊ីវិល។ មានមនុស្សរាប់សែននាក់ត្រូវជាប់ឃុំឃាំង រងអំពើទារុណកម្ម និងត្រូវបានសម្លាប់នៅតាមគុកទាំងនោះ និងនៅតាមទីតាំងផ្សេងៗទៀត ដូចជាវាលពិឃាតរួម ជាដើម។ ចំនួនអ្នកស្លាប់ដោយសារការវាយប្រហារនេះ ត្រូវបានគេប៉ាន់ស្មានថាមានចន្លោះពី ១,៧ លាននាក់ ទៅ ២,២ លាននាក់ រួមទាំងការស្លាប់ដោយអំពើហិង្សាពី ៨០០០០០ នាក់ ទៅ ១,៣ លាននាក់ផងដែរ។

១៣៧២- ការវាយប្រហារទៅលើប្រជាជនស៊ីវិលនៅប្រទេសកម្ពុជា គឺធ្វើឡើងជាលក្ខណៈប្រព័ន្ធ ដោយសារវាអនុវត្តទៅតាមគោលនយោបាយមួយដែលបង្កើតឡើងនៅថ្នាក់មជ្ឈិម និងសម្របសម្រួលដោយគោលនយោបាយរដ្ឋាភិបាល ដើម្បីប្រព្រឹត្តអំពើហិង្សាជាទ្រង់ទ្រាយធំនៅទូទាំងប្រទេស។ ការវាយប្រហារនេះគឺមានផែនការ និងរៀបចំកម្រិតខ្ពស់ ហើយបន្ទាប់មកថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាអ្នកចេញសារាចរណែនាំអនុវត្ត។ មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាជាអ្នកពិនិត្យតាមដានការអនុវត្តផែនការនេះ តាមរយៈការទទួលរបាយការណ៍ជាទៀងទាត់ និងចេញសេចក្តីណែនាំទៅចារីដែដល់។

១៣៧៣- លក្ខណៈជាប្រព័ន្ធនៃការវាយប្រហារនេះ ត្រូវបានបង្ហាញបន្ថែមទៀតដោយ៖ (១)សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយ ដែលចេញដោយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលដឹកនាំនិងលើកទឹកចិត្តឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ (២)មានគំរូស៊ីសង្វាក់គ្នាកម្រិតខ្ពស់ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅទូទាំងប្រទេសកម្ពុជា (ឧទាហរណ៍ ការប្រើប្រាស់អំពើទាសភាព ការងារពលកម្មដោយបង្ខំ ការបៀតបៀនរាងកាយ និងការចាប់ខ្លួននិងការសម្លាប់មនុស្សតាមអំពើចិត្ត) (៣)ការចូលរួមរបស់មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា ទៅក្នុងឧក្រិដ្ឋកម្មនៅគ្រប់ជាន់ថ្នាក់ (៤)អង្គហេតុបានបង្ហាញថា អំពើឧក្រិដ្ឋដែលប្រព្រឹត្តដោយចារីដែដល់ ឆ្លុះបញ្ចាំងពីគោលនយោបាយនានា ដែលបានដាក់ចេញដោយមជ្ឈិមបក្ស (៥)ការចំណាយធនធានសាធារណៈយ៉ាងទូលំទូលាយ (៦)និងប្រការដែលប្រជាជនទាំងមូលមិនអាចគេចចេញពីការវាយប្រហារនេះបាន។

## សំដៅទៅលើប្រជាជនស៊ីវិល

១៣៧៤- ការវាយប្រហារទូទៅ និងជាប្រព័ន្ធត្រូវបានដឹកនាំប្រឆាំងនឹងប្រជាជនស៊ីវិលកម្ពុជា។ ប្រជាជនស៊ីវិលដែលក្លាយជាគោលដៅរួមមាន ក្រុមជនជាតិភាគតិចផ្នែកជាតិពន្ធុ និងជនជាតិភាគតិចផ្នែកសាសនាដែលជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញបន្ថែមទៀត ដូចដែលនឹងពណ៌នាដូចខាងក្រោម។ ទោះបីការបៀតបៀនក៏ត្រូវបានប្រព្រឹត្តទៅលើពួកយោធា (ដូចជាសមាជិកកងទ័ពបដិវត្តកម្ពុជាដែលជាប់ឃុំឃាំងនៅ ស-២១) ក៏ដោយ ក៏ប្រជាជនស៊ីវិលក្លាយជាគោលដៅទីមួយនៃការវាយប្រហារដែរ ហើយក៏មានជនរងគ្រោះក្នុងចំនួនដ៏ច្រើនក៏ជាជនស៊ីវិលដែរ។

## មូលហេតុនៃការរើសអើង

១៣៧៥- ការវាយប្រហារទៅលើប្រជាជនស៊ីវិលមានមូលដ្ឋានផ្អែកលើបញ្ហានយោបាយ សាសនា និង/ឬជាតិពន្ធុ។

## មូលហេតុនយោបាយ

១៣៧៦- បន្ទាប់ពីបានធ្វើឱ្យប្រជាជនស៊ីវិលនៅក្នុងប្រទេសទាំងមូល ធ្លាក់ទៅក្នុងអំពើទាសភាពយ៉ាងមានប្រសិទ្ធិភាព និងការលុបបំបាត់ចោលសិទ្ធិមនុស្សនិងសេរីភាពហើយ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាស្វែងរកការពង្រឹងបដិវត្តនយោបាយមួយ និងកម្ចាត់ចោលនូវអ្នកប្រឆាំងនយោបាយ ក្នុងអំណាចរបស់ខ្លួន។ ប្រជាជនស៊ីវិលទាំងអស់ដែលត្រូវបានបក្សដាក់ទៅក្នុងអំពើទាសភាពត្រូវបានគេចាត់ទុកថាជាខ្មាំងសត្រូវពិតប្រាកដ ឬមានសក្តានុពល ហើយត្រូវបានទទួលការរើសអើងដោយផ្អែកលើមូលដ្ឋាននេះ។ នៅតាមសហករណ៍និងការដ្ឋាន អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជា បានស្រាវជ្រាវរកចាប់ខ្លួន ដាក់ឃុំឃាំង និងសម្លាប់ជាប្រព័ន្ធ នូវខ្មាំងសត្រូវពិតប្រាកដ និងជាប់សង្ស័យថាជាខ្មាំងសត្រូវផ្នែកនយោបាយ។ អ្នកដែលសល់ពីកម្មវត្ថុនៃអំពើទាសភាព

ត្រូវស្ថិតនៅក្រោមកម្មវិធី អប់រំកែប្រែនយោបាយ និងការងារពលកម្មដោយបង្ខំ។ ជាបណ្ដើរៗ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏ចាប់ផ្ដើមសង្ស័យទៅលើកម្មាភិបាល ដែលនៅក្នុងលំដាប់ថ្នាក់ជាមួយគ្នា និងនៅតាមមូលដ្ឋានដោយសង្ស័យថាបានធ្វើការឱ្យខ្មាំង ឬប្រឆាំងបដិវត្ត ហើយអ្នកទាំងនោះក៏ក្លាយជាកម្មវត្ថុនៃការចាប់ខ្លួន ដាក់ឃុំឃាំង និងយកទៅសម្លាប់ ដោយផ្អែកលើមូលដ្ឋាននយោបាយដែរ។ ទាំងអស់នេះ ធ្វើការពណ៌នាពិស្ដារដូចខាងក្រោម៖

(១) ខណៈដែលមានការជម្លៀសមនុស្សដោយបង្ខំចេញពីទីប្រជុំជននានា អាជ្ញាធរបានប្រមូលផ្ដុំមនុស្ស និងបានសម្លាប់ក្រៅច្បាប់នូវពួកអតីតសមាជិកនៃរបបសាធារណរដ្ឋខ្មែរភ្លាមៗ និងអ្នកដែលពាក់ព័ន្ធនឹងពួកគេ។ អាជ្ញាធរក៏បានដៅតម្រង់ទៅលើសមាជិកដែលគេហៅថាជាវណ្ណៈមូលធន ឬសក្តិភូមិ ឬគហបតី។ លើសពីនេះ អតីតអ្នកដែលធ្លាប់រស់នៅក្នុងទីក្រុង ឬទីប្រជុំជននានាដែលត្រូវបានគេឱ្យឈ្មោះថាជា "ប្រជាជន ១៧ មេសា" ឬ "ប្រជាជនថ្មី" ដែលត្រូវបានគេដាក់ឱ្យទទួលរងនូវអំពើបំពារបំពាន និងការធ្វើបាបតាមគ្រប់ទម្រង់ទាំងអស់ ដោយសារទស្សនរបស់ បកក ដែលថា ពួកអ្នកទាំងនេះមាន ឬជាប់ពាក់ព័ន្ធជាមួយនឹងនិន្នាការពួកវណ្ណៈមូលធន ឬសក្តិភូមិ ឬគហបតី។ ប្រជាជនថ្មីត្រូវបានគេប្រមូលផ្តុំមុនគេនៅពេលត្រូវបានគេដាក់ទៅជាទាសភាពហើយនោះ ប្រជាជនថ្មីត្រូវស្ថិតនៅក្រោមការធ្វើបាបយ៉ាងឃោរឃៅនៅតាមបណ្ដាសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំនានាហើយជារឿយៗ អ្នកទាំងនោះក្លាយជាកម្មវត្ថុការចាប់ខ្លួន ការដាក់នៅក្នុងមន្ទីរឃុំឃាំង និងយកទៅសម្លាប់តាមទំនើងចិត្ត។

(២) បន្ទាប់មកបក្សកុម្មុយនីស្តកម្ពុជាបានពង្រឹងអំណាចរបស់ខ្លួន ដោយកំណត់អត្តសញ្ញាណ និងសម្លាប់អ្នកណាដែលគេយល់ថាជាខ្មាំងពិតប្រាកដ និងខ្មាំងនយោបាយ ជាធម្មតា

អ្នកទាំងនោះត្រូវបានគេចោទប្រកាន់ថាជាគិញច្ចិរដ្ឋាភិបាល ឬទីភ្នាក់ងារបរទេស ឬប្រឆាំងនឹងបដិវត្ត។ ដោយពួកគេមានជំនឿថា ខ្មាំងដែលបង្កប់ខាងក្នុងកំពុងធ្វើឱ្យអន្តរាយដល់បដិវត្ត ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានផ្តួចផ្តើមឱ្យមានការសម្រិតសម្រាំងយ៉ាងទូលំទូលាយនូវពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា នៅថ្នាក់ភូមិភាគ កងទ័ពបដិវត្តកម្ពុជា និងក្រសួងនានានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជនចាស់ក៏ក្លាយជាគោលដៅនៃការវាយប្រហារនេះដែរ។

(៣) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជូនជនស៊ីវិលទាំងអស់ទៅក្នុងការបង្ក្រាបផ្នែកនយោបាយ តាមមធ្យោបាយនានាដូចជា កម្មវិធីស្វ័យទិតៀនជាបន្តបន្ទាប់ និងការបញ្ចូលមនោគមវិជ្ជានយោបាយ។ វិធីនេះបានជួយសម្រួលដល់ដំណើរការបំបែកចេញនូវពួកដែលមានប្រវត្តិរូបណ្ណភាពមិនត្រឹមត្រូវ ឬអ្នកមានទិន្នាការនយោបាយមិនល្អ ហើយដាក់អ្នកទាំងនោះឱ្យទទួលការលត់ដំបន្ថែមទៀត ឬត្រូវចាប់ខ្លួន និងយកទៅសម្លាប់តែម្តង។

១៣៧៧- តាមលក្ខណៈបែបនេះ បក្សកុម្មុយនីស្តកម្ពុជាដាក់ប្រជាជនស៊ីវិលកម្ពុជាទាំងមូល ជាគោលដៅដោយផ្អែកលើមូលដ្ឋាននយោបាយ។ ជនស៊ីវិលទាំងអស់ ត្រូវស្ថិតក្រោមការពិនិត្យតាមដានរៀងរាល់ពេល ហើយចំពោះអ្នកណាដែលគេសង្ស័យថា ប្រឆាំងនឹងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាឬចូលដៃជាមួយខ្មាំងរបស់បក្ស នឹងត្រូវបានគេធ្វើការបោសសំអាតជាលក្ខណៈប្រព័ន្ធ។ ប្រសិនបើមិនត្រូវបានគេយកទៅសម្លាប់ទេនោះ អ្នកដែលត្រូវគេសង្ស័យថាមិនអនុវត្តតាម ឬគ្មានភាពស្មោះត្រង់នឹងបដិវត្ត ក្លាយជាកម្មវត្ថុនៃការធ្វើបាបជាប្រព័ន្ធក្នុងទម្រង់អាក្រក់បំផុត។

## មូលហេតុសាសនា និង ជាតិពន្ធុ

១៣៧៨- ការវាយប្រហារនេះក៏ផ្អែកលើ (១)មូលហេតុសាសនា ដោយធ្វើការលុបបំបាត់សាសនាទាំងអស់ ការសង្កត់សង្កិនទៅលើការប្រតិបត្តិសាសនា និងការបំផ្លិចបំផ្លាញ ឬ ការប្រែក្លាយអគារ និងទ្រព្យសម្បត្តិសាសនាទាំងមូល (២)មូលហេតុជាតិពន្ធុ និងសាសនា ដោយចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការបំផ្លិចបំផ្លាញជនជាតិភាគតិច រួមមានជនជាតិចាម និងជនជាតិវៀតណាម។

## ការដឹងឮអំពីការវាយប្រហារ

១៣៧៩- ភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា ទាំងជនត្រូវចោទ ទាំងចារីផ្ទាល់ សុទ្ធតែបានដឹងពីការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល និង បានដឹងបន្ថែមទៀតថា អំពើរបស់ពួកគេបានបង្កើតជាផ្នែកនៃការវាយប្រហារ។ ជនត្រូវចោទបានចូលរួមនៅក្នុងការបង្កើតនូវគោលនយោបាយនានា ដែលជាលំអានសម្រាប់ប្រព្រឹត្តការវាយប្រហារនោះ។ បន្ទាប់មក ពួកគេជាអ្នកត្រួតត្រាមើលការអនុវត្តគោលនយោបាយទាំងនោះ ហើយបានចែករំលែកដោយផ្ទាល់ខ្លួនទៅក្នុងគោលនយោបាយទាំងនោះតាមរយៈវិធីនានាជាច្រើន រួមមាន ដោយការ៖ ចេញផែនការ បទបញ្ជាមាគ៌ាគោលនយោបាយ និងការណែនាំ ញុះញង់ និង លើកទឹកចិត្តឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងការវាយប្រហារនោះ រក្សាទស្សនវិស័យជាបន្តដល់ចារីផ្ទាល់ ទទួលរបាយការណ៍ស្តីពីឧក្រិដ្ឋកម្មទាំងនោះ និងចូលរួមដោយផ្ទាល់ខ្លួនទៅក្នុងឧក្រិដ្ឋកម្មមួយចំនួន ដូចជាការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ និងការសម្រិតសម្រាំងពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាជាដើម។

១៣៨០- មានភស្តុតាងនានាបន្ថែមទៀត ដែលបង្ហាញពីការ ដឹងឮរបស់ជនត្រូវចោទ ចំពោះការវាយប្រហារនោះថា សកម្មភាពរបស់ពួកគេបានបង្កើតជាផ្នែក គឺស្តែងឡើងតាមរយៈការរៀបចំការវាយប្រហារនោះពីថ្នាក់មជ្ឈិមជាន់ខ្ពស់ ការអនុវត្តយ៉ាងស៊ីសង្វាក់គ្នានៃគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ការចូលរួមរបស់អាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជានៅគ្រប់លំដាប់ថ្នាក់ អង្គហេតុបង្ហាញថា ចារីដែលប្រព្រឹត្តនៅក្នុងសមត្ថភាពជាផ្លូវការរបស់ខ្លួន ហើយនៅក្នុងករណីភាគច្រើនគឺក្រោមការចង្អុលបង្ហាញពីពួកកម្មាភិបាលជាន់ខ្ពស់ ពាក្យសម្តីរបស់ជនត្រូវចោទនៅក្នុងអំឡុងពេលដែលស្ថិតក្រោមការស៊ើបអង្កេត និងពេលបន្តបន្ទាប់មកទៀត រយៈពេលនៃការវាយប្រហារជាទ្រង់ទ្រាយធំ និងអូសបន្លាយពេល ការពិនិត្យតាមដានដោយអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងការផ្សព្វផ្សាយរបស់អន្តរជាតិចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងនៅទូទាំងប្រទេស។

## បទឧក្រិដ្ឋជាក់លាក់

## ការធ្វើមនុស្សឃាត

១៣៨១- ភស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា ការធ្វើមនុស្សឃាតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

## អំពើសកម្ម និងអំពើអកម្ម

### *នៅក្នុងការជម្លៀសដោយបង្ខំ*

១៣៨២- មានជនរងគ្រោះរាប់ពាន់នាក់ត្រូវបានគេយកទៅសម្លាប់ ក្នុងអំឡុងពេលមានព្រឹត្តិការណ៍ជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំចំនួនបីលើកសំខាន់ៗ ដែលស្ថិតក្រោមការស៊ើបអង្កេត។

១៣៨៣- ***ការជម្លៀសដោយបង្ខំលើកទីមួយៈ*** មុនពេល ក្នុងពេល និងក្រោយពេលមានការជម្លៀសប្រជាជនចេញពីទីប្រជុំជនភ្លាម កងទ័ពខ្មែរក្រហមបានសម្លាប់អតីតមន្ត្រីរដ្ឋការ និងទាហានរបបចាស់ ដូចជា "ប្រជាជនថ្មី" រាប់ពាន់នាក់។ ការសម្លាប់ជនរងគ្រោះទាំងនេះកើតឡើងនៅតាមទីប្រជុំជនសំខាន់ៗ (**ភ្នំពេញ សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង និង ប៉ៃលិន**) និងនៅតាមទីតាំងជាច្រើននៃវិថីដែលចេញទីប្រជុំជនទាំងនោះ។ ការសម្លាប់រង្គាលក៏បានកើតឡើងផងដែរនៅ**ទួលពោធិ៍ជ្រៃ** (ខេត្តពោធិ៍សាត់) ដែលនៅទីនោះមានមនុស្សពី២០០០ នាក់ ទៅ ៣០០០ នាក់ត្រូវបានសម្លាប់ និងនៅ**ស្រុកកំពង់ត្រឡាចលើ** (ខេត្តកំពង់ឆ្នាំង) ដែលមានមនុស្សជាង ២០០០ នាក់ត្រូវបានសម្លាប់។ ជនស៊ីវិលជាច្រើននាក់ក៏ត្រូវបានគេយកទៅសម្លាប់ផងដែរក្នុងអំឡុងពេលជម្លៀសដោយបង្ខំ ដោយសារអ្នកទាំងនោះជំទាស់ ឬមិនអាចធ្វើតាមបញ្ជារបស់ពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបាន។ ក៏មានភ័ស្តុតាងនៃករណីផ្សេងៗទៀតជាច្រើនដែរបញ្ជាក់អំពីការធ្វើអត្តឃាត ដោយសារជនស៊ីវិលទាំងនោះត្រូវទទួលរងនូវស្ថានភាពអមនុស្សធម៌។

១៣៨៤- ***ការជម្លៀសដោយបង្ខំលើកទីពីរៈ*** មនុស្សជាច្រើនត្រូវបានសម្លាប់ដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេល និងបន្ទាប់ពីមានការជម្លៀសជាទ្រង់ទ្រាយធំ ចំពោះមនុស្សប្រមាណ៥០០០០០នាក់ដែលភាគច្រើនជា "ប្រជាជនថ្មី" ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរចាស់។ នៅក្នុងភូមិភាគពាយ័ព្យទាំងមូល ពេលជនចំណូលថ្មីទៅដល់ភ្លាម ពួកគេត្រូវបាន

ចាប់ខ្លួនភ្លាម រួចបញ្ជូនទៅមន្ទីរសន្តិសុខនានា។ មូលហេតុនៃការចាប់ខ្លួនរួមមាន ការចោទប្រកាន់ថាជាសមាជិក (ឬមានទំនាក់ទំនងជិតស្និទ្ធិជាមួយ) អតីតរបបសាធារណរដ្ឋខ្មែរ ការមិនប្រឹងប្រែងធ្វើការងារ ឬរអ៊ូរទាំពីរបបអាហារ ជាដើម។

១៣៨៥- ***ការជម្លៀសដោយបង្ខំលើកទីបីៈ*** មានជនស៊ីវិលរាប់ពាន់នាក់ត្រូវបានយកទៅសម្លាប់ដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងសមាជិកកងទ័ពបដិវត្តកម្ពុជា ក្នុងអំឡុងពេល និងក្រោយពេលជម្លៀសដោយបង្ខំ ដែលបានចូលរួមក្នុងដំណាក់កាលចុងក្រោយនៃការសម្រិតសម្រាំងនៅភូមិភាគបូព៌ា។ អ្នកដែលត្រូវគេជម្លៀសរូបណាដែលតវ៉ាក្នុងពេលជម្លៀសនោះ នឹងត្រូវគេសម្លាប់ចោលភ្លាម។ ជាងនេះទៅទៀត អ្នកត្រូវគេជម្លៀសពីភូមិភាគបូព៌ាទាំងអស់ ត្រូវបានគេបង្ខំឲ្យបង់ក្រមាពណ៌ខៀវ ដើម្បីងាយស្រួលឲ្យគេចំណាំសម្រាប់យកទៅសម្លាប់ចោល ពេលទៅដល់គោលដៅរួចហើយ។ មានមនុស្សជាច្រើន (ជាពិសេសអតីតប្រធានភូមិ ឬ ប្រធានឃុំជំទប់ គ្រូបង្រៀន នគរបាល និង ទាហាន) ត្រូវបានគេចាប់ខ្លួន និង យកទៅសម្លាប់ ពេលទៅដល់គោលដៅនៅក្នុងភូមិភាគផ្សេងភ្លាមៗ។ មានមនុស្សរាប់ពាន់នាក់ត្រូវបានយកទៅសម្លាប់នៅតាមវាលពិឃាតនានា រួមមាន **វាលបាក់ចិញ្ចៀន** (ខេត្តពោធិ៍សាត់) និង**វត្តច័ន្ទរង្សី** នៅក្នុងឃុំរំលេច (ស្រុកបាកាន ខេត្តពោធិ៍សាត់)។

១៣៨៦- ខណៈដែលជនស៊ីវិលរាប់ពាន់នាក់ត្រូវបានសម្លាប់ ជាផ្នែកមួយនៃព្រឹត្តិការណ៍ខាងលើ នៅមានមនុស្សរាប់ពាន់នាក់ទៀតបានស្លាប់ ក្នុងអំឡុងពេលជម្លៀសដោយបង្ខំនោះផងដែរ ដែលជាលទ្ធផលនៃការបង្អត់អាហារ បាក់កម្លាំង និងការដាក់ឲ្យធ្វើការងារហាលវាលហាលខ្យល់ ជាលក្ខខណ្ឌដែលអនុវត្តដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ មានមនុស្សរាប់ពាន់នាក់

បន្ថែមទៀតបានស្លាប់ដោយសារមូលហេតុទាំងនេះ បន្ទាប់ពីអ្នកទាំងនោះទៅដល់គោលដៅ ហើយមួយចំនួនទៀតស្លាប់ដោយការងារពលកម្មដោយបង្ខំ ដែលកំណត់ដោយអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជា។ ចំពោះស្ថានភាពនានាដែលបណ្តាលឲ្យមានការស្លាប់មនុស្សបែបនេះ នឹងពណ៌នាពិស្តារបន្ថែមទៀត នៅផ្នែកអំពើអមនុស្សធម៌ ខាងក្រោម។

*នៅការដ្ឋានធ្វើពលកម្មដោយបង្ខំ*

១៣៨៧- មានមនុស្សរាប់ពាន់នាក់ដែលត្រូវស្ថិតក្នុងលក្ខណៈទាសភាព នៅតាមសហករណ៍ និងការដ្ឋានធ្វើការងារពលកម្មដោយបង្ខំ ត្រូវស្លាប់បាត់បង់ជីវិតដោយសារការសម្លាប់ និងស្ថានភាពអមនុស្សធម៌។ ជនរងគ្រោះខ្លះត្រូវបានចាប់ខ្លួន ក្នុងពេលមានការសម្រិតសម្រាំង ដោយបក្សកុម្មុយនីស្តកម្ពុជា ហើយត្រូវបានបញ្ជូនទៅការដ្ឋានការងារពលកម្មដោយបង្ខំ ដើម្បីលត់ដំ (ជនរងគ្រោះដោយការសម្រិតសម្រាំងនៅភូមិភាគឧត្តរ និងនៅស្រែអំបិល ជនរងគ្រោះដោយការសារសម្រិតសម្រាំងនៅភូមិភាគឧត្តរ និងភូមិភាគបូព៌ា នៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង)។

១៣៨៨- ពលករដែលធ្វើការនៅស្រែអំបិល សហករណ៍ត្រាំកក់ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងទំនប់ ១ មករា ត្រូវបានចាប់ខ្លួន និងបញ្ជូនដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា យកទៅសម្លាប់នៅតាមមន្ទីរសន្តិសុខនានា ឬទីកន្លែងផ្សេងៗទៀត។ មានពលករជាង ២០០០ នាក់ត្រូវបានគេសម្លាប់នៅជិត ឬក្នុងការដ្ឋានទំនប់ត្រពាំងថ្ម។ ជនរងគ្រោះនៅតាមការដ្ឋានធ្វើការងារពលកម្មដោយបង្ខំត្រូវបានគេប្រមូលយកទៅសម្លាប់ ដោយសារមូលហេតុផ្សេងៗ រួមមានដូចជាថា ពួកប្រជាជនថ្មី បម្រុងគេចខ្លួន ធ្វើខុស ឬធ្វើឱ្យខូចខាតសម្ភារៈពេលកំពុងធ្វើការ មិនអាចអនុវត្តតាម

ផែនការការងារដែល*អង្គការ*ដាក់ចុះ ស្ថិតក្រោមការសង្ស័យថាជាខ្សែរយៈសេអ៊ីអា ឬភ្នាក់ងារវៀតណាម ត្រូវគេចោទថាខុសសីលធម៌ គ្មានវិន័យក្នុងការនិយាយស្តី ខ្ជិលច្រអូស មានជំងឺសតិអារម្មណ៍ ឬ ឧស្សាហ៍ឈឺញឹកញាប់ពេក និងលួចអាហារ ឬថ្នាំជក់។

១៣៨៩- មានពលកររាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិត ដោយសារការបាក់កម្លាំង ជំងឺតម្កាត់ ការអត់ឃ្លាន អត្តឃាត និង បម្រុងគេចខ្លួនដោយបង្ខំ (**នៅទំនប់ត្រពាំងថ្ម ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងស្រែអំបិល**)។ អ្នកទាំងនោះស្លាប់ដោយសារស្ថានភាព ដែលធ្វើឡើងដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ ដូចដែលពិភាក្សានៅផ្នែកអំពើអមនុស្សធម៌ផ្សេងទៀត គឺថាស្ថានភាពទាំងនោះរួមមានៈ បង្ខំឱ្យធ្វើការងារដោយដៃយ៉ាងធ្ងន់ធ្ងរពី ១០ ម៉ោង ទៅ ១២ ម៉ោង ឬក្នុងករណីខ្លះរហូតដល់ទៅ ១៥ ម៉ោង ក្នុងមួយថ្ងៃ មិនត្រូវបានគេផ្តល់អាហារគ្រប់គ្រាន់ និងហាមឃាត់មិនឱ្យដើររកអាហារដោយខ្លួនឯង ស្ថានភាពគ្មានអនាម័យ ដោយគ្មានជម្រកនិងថ្នាំសង្កូវសមរម្យ មិនបានទទួលសម្លៀកបំពាក់ និងការការពារពីវត្ថុផ្សេងៗ និងក្លាយជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មតាមអំពើចិត្ត ដូចជាបន្ថែមបន្ទុកការងារ ឬបន្ថយរបបអាហារជាដើម។ ក្នុងចំណោមប្រជាជនទូទៅ អ្នកដែលត្រូវបានគេចាត់ទុកថាជាសមាសភាពដែលគេមិនពេញចិត្ត (ដូចជា ប្រជាជនថ្មី អ្នកដែលមកពីភូមិភាគបូព៌ា និងអ្នកដែលគេសង្ស័យថាប្រឆាំង) ក្លាយជាកម្មវត្ថុនៃស្ថានភាពធ្ងន់ធ្ងរជាងគេ ហើយភាគច្រើនគឺត្រូវស្លាប់ផង។

*ការកើតមានទូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

១៣៩០- មានជនរងគ្រោះជាច្រើនត្រូវបានសម្លាប់ ដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដោយសារអ្នកទាំងនោះមិនព្រមចូលរួមការរៀបការដោយបង្ខំ ដែលបញ្ជាឱ្យធ្វើដោយរបបនេះ

និង/ឬ ដោយសារពួកគេជាប់សង្ស័យថាបានប្រព្រឹត្តការរួមភេទក្រៅអាពាហ៍ពិពាហ៍ ដែលបក្សកុម្មុយនីស្តកម្ពុជាជាអ្នករៀបចំឲ្យ។

*នៅតាមមន្ទីរសន្តិសុខ*

១៣៩១- មានអ្នកទោសរាប់ពាន់នាក់ត្រូវបានសម្លាប់ នៅតាមមន្ទីរសន្តិសុខនានារបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជានៅ **ស-២១ កោះខ្យង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លកអូរកន្សែង វត្តគិរីរម្យ** និង**សៀមរាប**។ ជនរងគ្រោះទាំងនោះ រួមមាន អ្នកដែលត្រូវបានគេចាប់ខ្លួនក្នុងការសម្រិតសម្រាំងផ្ទៃក្នុងជាទ្រង់ទ្រាយធំរបស់បក្សកុម្មុយនីស្តកម្ពុជា (ដូចជាការសម្រិតសម្រាំងនៅភូមិភាគឧត្តរ និងភូមិភាគបូព៌ា)។ អំពើ និងការខកខានមិនបានរារាំងភាគច្រើនដែលបណ្តាលឲ្យស្លាប់មនុស្ស នឹងមានពណ៌នាដូចខាងក្រោម។

១៣៩២- ជនរងគ្រោះភាគច្រើនត្រូវបានសម្លាប់ នៅក្នុងការសម្លាប់រង្គាលរាប់រយករណី ជាពិសេសនៅតាមទីកន្លែងនានា ដែលមានដំណើរជាទូទៅបំផុតនោះគឺថា សន្តិសុខត្រូវយកដំបងសំពងក្បាលជនរងគ្រោះពីក្រោយ រួចច្រានជនរងគ្រោះទម្លាក់រណ្តៅដែលគេជីកទុកជាស្រេច។ នៅតាមមន្ទីរសន្តិសុខខ្លះទៀត ដំណើរការសម្លាប់នេះដោយអារកជនរងគ្រោះ (នៅ **ស-២១ ក្រាំងតាចាន់**) និង/ឬ វះពោះ (គុក**សង់**) ដើម្បីឲ្យប្រាកដថាពិតជាស្លាប់មែន។ មានកុមាររាប់រយនាក់ក៏ត្រូវបានគេសម្លាប់នៅតាមវាលពិឃាតនានាដែរ ដោយបោកផ្ទប់នឹងគល់ឈើទាល់តែស្លាប់ (នៅ **ស-២១ ក្រាំងតាចាន់** និងគុក**សង់**)។ ការសម្លាប់ក្រោយពេលចាប់ខ្លួនបានភ្លាមក៏មានដែរ នៅក្រៅមន្ទីរសន្តិសុខ៖ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជាជាអ្នកអនុវត្ត ការសម្លាប់មនុស្សជាសាធារណៈ ត្រូវបាន

គេធ្វើឡើងនៅតាមមន្ទីរសន្តិសុខនានា ដូចជាស្រុកភ្នំសំពៅ ចំពោះអ្នកដែលត្រូវគេសង្ស័យថាជាអ្នកប្រឆាំង និង អ្នកដែលគេចាត់ទុកថាជាខ្មាំង។

១៣៩៣- អ្នកទោសក៏ត្រូវបានគេយកទៅសម្លាប់ ឬវាយរហូតទាល់តែស្លាប់ផងដែរ នៅក្នុងបរិវេណគុកតែម្តង។ ការសម្លាប់ខ្លះ (ដូចជានៅកោះខ្យង) ត្រូវបានធ្វើឡើងជាសាធារណៈ ចំពោះមុខអ្នកទោសផ្សេងទៀត។ មានអ្នកទោសរាប់រយនាក់រួមទាំងកុមារផង ត្រូវបានគេយកទៅសម្លាប់នៅក្នុងបរិវេណដ៏ធំនៃ ស-២១។ មានភស្តុតាងបង្ហាញពីការសម្លាប់គួរឱ្យខ្ពើមរអើម ដូចជា រំលោភ និងកាត់អវៈយវៈភេទជនរងគ្រោះជាស្ត្រី មុននឹងសម្លាប់ (នៅ សៀមរាប វត្តធ្លក អូរកន្សែង)។

១៣៩៤- មានអ្នកទោសជាច្រើនស្លាប់ដោយការវាយដំ ទារុណកម្ម ជំងឺតម្កាត់ ការអត់អាហារ បាក់កម្លាំង និង/ឬ ធ្វើការហួសកម្លាំង (នៅស-២១ គោកក្ដួច គុកសង់ និងសៀមរាប)។

១៣៩៥- ការស្លាប់អ្នកទោសក៏បានកើតឡើងផងដែរទៅតាមវិធីនានាដូចខាងក្រោម៖

(១) ជាលទ្ធផលពីការធ្វើពិសោធវេជ្ជសាស្ត្រ និងការបូមឈាមនៅ ស-២១។

(២) តាមរយៈការធ្វើអត្តឃាត (នៅ ស-២១, អូរកន្សែង) ដែលនៅទីនោះជនរងគ្រោះផ្តាច់ជីវិតខ្លួនឯង ដើម្បីគេចចេញពីស្ថានភាពអមនុស្សធម៌ ទារុណកម្ម និងការសម្លាប់ដែលកំពុងរង់ចាំពួកគេ។ ការស្លាប់របស់អ្នកទាំងនោះកើតឡើងដោយផ្ទាល់ ដោយសារការធ្វើបាបទៅលើអ្នកទោស និងស្ថានភាពដែលចារីបានធ្វើទៅលើពួកគេ។

### *ក្នុងការសម្រិតសម្រាំងនៅភូមិភាគបូព៌ា*

១៣៩៦- ការសម្រិតសម្រាំងនេះបណ្តាលឱ្យមនុស្សស្លាប់ចំនួន១០០០០០ នាក់យ៉ាងតិច និងប្រជាជនសាមញ្ញ ព្រមទាំង ពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅភូមិភាគបូព៌ាដល់ទៅ ២៥០០០០

នាក់។ ជនរងគ្រោះទាំងនោះរួមទាំង មេដឹកនាំ និងសមាជិកយោធា និងអង្គភាពរដ្ឋបាលទាំងអស់នៅក្នុងភូមិភាគបូព៌ាទាំងមូលផងដែរ។ បន្ថែមលើចំនួនអ្នកដែលត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខ និងការដ្ឋានធ្វើការដោយបង្ខំ មានមនុស្សរាប់រយនាក់ត្រូវបានគេយកទៅសម្លាប់ នៅតាមវាលពិឃាតនានានៅក្នុងមូលដ្ឋាន ដូចជានៅវត្តកណ្តាលជ្រុំ ជាដើម។ អ្នកទោសទាំងនោះរួមទាំងប្រពន្ធកូន ពួកកម្មាភិបាលដែលត្រូវគេចាប់ខ្លួនផងដែរ។ មានជនស៊ីវិលពីភូមិភាគបូព៌ាប្រមាណ ១២៩នាក់ ដែលមកពីភូមិបុស (ខេត្តកំពង់ចាម) ត្រូវបានគេសម្លាប់រង្គាលនៅវាយពិឃាតស្ទឹងតូច។ ដូចបានកត់សម្គាល់ខាងលើរួចមកហើយគឺថា ជនស៊ីវិលពីភូមិភាគបូព៌ា ត្រូវបានគេធ្វើកំណត់សម្គាល់យ៉ាងពិសេសសម្រាប់យកទៅសម្លាប់ ដោយឲ្យបង់ក្រមាពណ៌ខៀវ ហើយមានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ បន្ទាប់ពីពួកគេបានមកដល់គោលដៅភ្លាម។

*អំពីពុទ្ធសាសនិក*

១៣៩៧- បទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងពុទ្ធសាសនិករួមមាន ការធ្វើគតព្រះសង្ឃ និងអ្នកដែលប្រឆាំងនឹងការលុបបំបាត់ព្រះពុទ្ធសាសនា។ មានព្រះសង្ឃនៅថ្នាក់កំពូលជាច្រើនអង្គត្រូវបានគេធ្វើគតភ្លាមៗ បន្ទាប់ពីពួកខ្មែរក្រហមចូលកាន់កាប់បានក្រុងភ្នំពេញ។ ព្រះសង្ឃព្រះពុទ្ធសាសនាត្រូវបានគេធ្វើគតដោយមិនព្រមលាចាកសិក្ខាបទនៅវត្តអន្លង់វៀន (ស្រុកក្រចេះ ខេត្តក្រចេះ) និងវត្តជ័យមង្គល (ស្រុកសេសាន ខេត្តស្ទឹងត្រែង)។ មានប្រជាជនមួយចំនួនដែលប៉ុនប៉ងប្រតិបត្តិព្រះពុទ្ធសាសនានៅវត្តតាគាត់មង្គល (ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល) ក៏ត្រូវបានគេយកទៅសម្លាប់ចោលដែរ។

*អំពីជនជាតិចាម*

១៣៩៨- ដូចបានពណ៌នារួចមកហើយនៅផ្នែកប្រល័យពូជសាសន៍ គឺថានៅឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ពួកមន្ត្រីបក្សកុម្មុយនីស្តកម្ពុជាបានរៀបចំ និងអនុវត្តការសម្លាប់រង្គាលដល់សមាជិកដែលនៅក្នុងសហគមន៍ជនជាតិចាមនៅស្រុកកងមាស ស្រុកក្រូចឆ្មារ និងស្រុកស្ទឹងត្រង់ (ខេត្តកំពង់ចាម)។ បន្ថែមលើការសម្លាប់ទាំងនេះ នៅខែឧសភា ឆ្នាំ១៩៧៧ គណៈតំបន់៥ (នៃភូមិភាគពាយ័ព្យ) បានសម្លាប់ "ខ្សែបណ្ដាញ" ចាម និងមេដឹកនាំ បន្ទាប់ពីមានការបះបោរដោយជនជាតិចាម ទាក់ទិននឹងអាហារនៅក្នុងសហករណ៍នោះ។

*អំពីជនជាតិវៀតណាម*

១៣៩៩- ដូចបានពណ៌នារួចមកហើយនៅផ្នែកប្រល័យពូជសាសន៍ គឺថាមានប្រជាជនចំនួន២០០០០ នាក់ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ដោយអាជ្ញាធរបក្សកុម្មុយនីស្តកម្ពុជា នៅទូទាំងប្រទេសក្នុងអំឡុងឆ្នាំ១៩៧៧ រហូតខែមករា ឆ្នាំ១៩៧៩។ ការសម្លាប់ជនជាតិវៀតណាមបានកើតឡើងនៅតាមទីតាំងនានាដែលស្ថិតក្រោមការស៊ើបអង្កេត ដូចតទៅៈ ខេត្តព្រៃវែង និងខេត្តស្វាយរៀង និងនៅមន្ទីរសន្តិសុខនានាដូចជា **ស-២១ កោះខ្សែង ក្រាំងតាចាន់ គោកក្ដួច វត្តធ្លក** និង**ភ្នំក្រោល**។

**ចេតនា**

១៤០០- រាល់ការសម្លាប់មនុស្សដែលបានរៀបរាប់ខាងលើ ត្រូវបានធ្វើឡើងដោយមានចេតនាក្នុងការសម្លាប់ទាំងស្រុង។ ចារីដែលអនុវត្តតាមបទបញ្ជា និងគោលនយោបាយរបស់មជ្ឈិមបក្សដើម្បីសម្លាប់ ឬ "កម្ទេច" ខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា។ គោលនយោបាយនោះ គឺសម្លាប់មនុស្សដោយមានការរៀបចំ មានភាពស៊ីសង្វាក់គ្នានៃវិធីសម្លាប់មនុស្ស និងការរាយការណ៍ពី

ការសម្លាប់ទៅថ្នាក់លើ ដែលបានបញ្ជាក់ច្បាស់ពីចេតនានេះ។ ការសម្លាប់ជនជាតិចាម និងជនជាតិវៀតណាមក៏ត្រូវបានអនុវត្តស្រដៀងគ្នាដែរជាលក្ខណៈជាប្រព័ន្ធ និងអនុលោមតាមគោលនយោបាយដែលដាក់ចេញនៅថ្នាក់មជ្ឈិម ដើម្បីស្រាវជ្រាវ និងសម្លាប់សមាជិកក្រុមទាំងនេះ។ នៅក្នុងករណីដែលជនរងគ្រោះស្លាប់ ដោយសារលទ្ធផលនៃការវាយដំ ឬ ទារុណ្ឌកម្ម និងពេលដែលជនរងគ្រោះត្រូវស្លាប់ភ្លាម មិនមែនជាចេតនាពិសេសទេ ចារីមានចេតនាបង្កឱ្យមានអន្តរាយ ឬរបួសស្នាមលើរាងកាយធ្ងន់ធ្ងរ ដែលពួកគេបានដឹង ឬគួរតែដឹងថានឹងបណ្តាលឱ្យស្លាប់មិនខាន។

១៨០១- នៅក្នុងករណីដែលមនុស្សស្លាប់បណ្តាលមកពីធ្វើការងារដោយបង្ខំ ស្ថានភាពអមនុស្សធម៌ ការធ្វើអត្តឃាត និងការប៉ុនប៉ងគេចខ្លួន ចារី បាន(១) ធ្វើឱ្យមានស្ថានភាពបែបនោះ ដែលបណ្តាលឱ្យមានមនុស្សស្លាប់ ដោយមានចេតនាបង្កអន្តរាយផ្លូវកាយធ្ងន់ធ្ងរ ទៅលើជនរងគ្រោះដែលពួកគេបានដឹង ឬគួរតែបានដឹងថាអាចបណ្តាលឱ្យស្លាប់ផង ឬ (២) ខកខានមិនបានធ្វើសកម្មភាពណាមួយ ដើម្បីដោះស្រាយចំពោះស្ថានភាពអមនុស្សធម៌ផងទេ ទោះបីពួកគេដឹងថា ការខកខានមិនបានធ្វើសកម្មភាពនោះ អាចបណ្តាលឱ្យមានមនុស្សស្លាប់ក៏ដោយ។

១៨០២- មានភ័ស្តុតាងដែលបង្ហាញពីចេតនាឧក្រិដ្ឋរបស់ចារី តាមរយៈអង្គហេតុដែលថា ស្ថានភាពដែលបណ្តាលឱ្យមានមនុស្សស្លាប់ ត្រូវបានបង្កើតឡើង និងរក្សាទុកជាលក្ខណៈប្រព័ន្ធ។ នៅក្នុងករណីជម្លៀសមនុស្សដោយបង្ខំ ការដ្ឋានធ្វើការដោយបង្ខំ និងមន្ទីរសន្តិសុខនានា ការស្លាប់កើតឡើងជាញឹកញាប់ និងទូទៅនៅតាមកន្លែងនីមួយៗ។ ក្រៅពីនេះ ស្ថានភាពរបស់ជនស៊ីវិលដែលធ្វើឡើង ដោយពួកកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ត្រូវនៅដដែលឥតមានប្រែប្រួលឡើយ។

តាមការពិត ស្ថានភាពលំបាកលំបិនក៏ជាទណ្ឌកម្ម ដែលគេធ្វើឡើងចំពោះអ្នកដែលគេចាត់ទុកថាជាខ្មាំងដែលមានសក្តានុពល អ្នកដែលមិនអនុវត្តតាមការណែនាំ ឬអ្នកដែលត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តកំហុសមួយចំនួន ដូចជាលួចអាហារ ឬខ្ជិលច្រអូសក្នុងការងារ ឬខស្សាហ៍ឈឺជាដើម។

## ការសម្លាប់រង្គាល

១៤០៣- ភ័ស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា ការសម្លាប់រង្គាលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

## អំពើសកម្ម និង អំពើអកម្ម

១៤០៤- ក្រោមការស៊ើបអង្កេត មានមនុស្សរាប់សែននាក់ត្រូវបានស្លាប់ ក្នុងពេលមានការជម្លៀសដោយបង្ខំ នៅតាមមន្ទីរសន្តិសុខនានា និងការដ្ឋានធ្វើការដោយបង្ខំ និងជាផ្នែកនៃការសម្រិតសម្រាំងដែលបណ្តាលឲ្យមានការស្លាប់ជនស៊ីវិលជាទ្រង់ទ្រាយធំ។ ការស្លាប់មនុស្សទាំងនោះកើតឡើងដោយសារការវាយប្រហារទៅលើប្រជាជនស៊ីវិលកម្ពុជា ដែលគិតជាមធ្យម មានមនុស្សម្នាក់ក្នុងចំណោមបួននាក់ត្រូវស្លាប់នៅទូទាំងប្រទេស។ ការស្លាប់នេះកើតចេញដោយផ្ទាល់ពីគោលនយោបាយ ដែលបានរៀបចំ និងសម្របសម្រួលដោយអាជ្ញាធរនៅថ្នាក់មជ្ឈិម (មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា) និងអនុវត្តដោយចារីនៅតាមទីតាំងឧក្រិដ្ឋកម្មជាច្រើន។

១៤០៥- ការសម្លាប់មនុស្សជាទ្រង់ទ្រាយធំរួមមាន៖

(១) ការសម្លាប់ជនស៊ីវិលរាប់ពាន់នាក់ដោយមានការរៀបចំ(ករណីខ្លះនៅទីតាំងតែមួយ) និងការសម្លាប់មនុស្សតាមរយៈ ការវាយដំ ទារុណកម្ម ការពិសោធវេជ្ជសាស្ត្រ ការបូមឈាម និងការធ្វើបាបតាមរូបភាពផ្សេងៗទៀត ដែលធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ និង

(២) ការស្លាប់មនុស្សរាប់ពាន់នាក់តាមរយៈការអត់ឃ្លាន ជម្ងឺ បាក់កម្លាំង ស្ថានភាពអមនុស្សធម៌ ដែលធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។

១៤០៦- ភ័ស្តុតាងនៃការសម្លាប់ដែលមានទ្រង់ទ្រាយធំ និង/ឬ ចរិតលក្ខណៈរបស់ការសម្លាប់ដែលមានការរៀបចំនោះ រួមមាន៖ (១)ការប្រើកំណត់ហេតុនានាដើម្បីចាត់ចែងការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់នៅតាមបណ្តាមន្ទីរសន្តិសុខ (ស-២១ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លក អូរកន្សែង) (២)ចរិតលក្ខណៈជាប្រព័ន្ធក្នុងកម្រិតខ្ពស់នៃការសម្លាប់ ដោយអ្នកទោសត្រូវដឹកជញ្ជូនទៅទីពិឃាតនានា ដែលនៅទីនោះគេបានជីករណ្តៅធំៗជាច្រើន សម្រាប់ទុកប្រើប្រាស់ ជារណ្តៅសាកសពរួម (ស-២១ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លក អូរកន្សែង សៀមរាប) (៣) មនុស្សជាច្រើនបានស្លាប់បណ្តាលមកពីការធ្វើទារុណកម្ម នៅមន្ទីរសន្តិសុខនានា (ស-២១ ក្រាំងតាចាន់ សង់ គោកក្តួច សៀមរាប) (៤)ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ដែលបានកើតមាននៅក្នុងអំឡុងពេលបោសសម្អាតភូមិភាគបូព៌ា (វត្តកណ្តាលជ្រុំ ស្ទឹងតូច វាលបាក់ចិញ្ចៀន និងវត្តច័ន្ទរង្សី) (៥) ការសម្លាប់ប្រជាជនចាមក្នុងទ្រង់ទ្រាយធំ (ស្រុកកងមាស ស្រុកក្រូចឆ្មារ ស្រុកស្ទឹងត្រង់ និងតំបន់៥) និង(៦)ការសម្លាប់ជនជាតិវៀតណាម ដែលកើតមានទូទាំងប្រទេស (ព្រៃវែង ស្វាយរៀង និងនៅតាមបណ្តាមន្ទីរសន្តិសុខផ្សេងៗដូចមានបង្ហាញនៅក្នុងផ្នែកអំពើប្រល័យពូជ

សាសន៍)។ រដ្ឋអំណាចថ្នាក់ទាបត្រូវរាយការណ៍អំពីការសម្លាប់ទាំងនេះ ព្រមទាំងព្រឹត្តិការណ៍ផ្សេងៗយ៉ាងទៀងទាត់ទៅឲ្យថ្នាក់ដឹកនាំ ប.ក.ក។

១៨០៧- ដូចមានកត់សម្គាល់នៅក្នុងផ្នែកសម្លាប់ និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត ជនស៊ីវិលក្នុងចំនួនដ៏ច្រើនលើសលប់ត្រូវស្លាប់បណ្តាលមកពីស្ថានភាពអមនុស្សធម៌នានា ដែលកម្មាភិបាល ប.ក.ក បានប្រព្រឹត្តក្នុងអំឡុងពេលជម្លៀសដោយបង្ខំ និងស្លាប់នៅតាមទីតាំងនានាដែលប្រើកម្លាំងពលកម្មដោយបង្ខំ ព្រមទាំងនៅក្នុងមន្ទីរសន្តិសុខផ្សេងៗទៀត។ មនុស្សរាប់សិបម៉ឺននាក់ដែលបានស្លាប់ដោយសារការអត់ឃ្លាន ជំងឺ បាក់កម្លាំង ស្ថិតនៅក្នុងស្ថានភាពអមនុស្សធម៌ដែលមាននៅតាមបណ្តាទីតាំងស្ថិតក្រោមការស៊ើបអង្កេតនានា។ ភ័ស្តុតាងដែលបានលើកយកមកពិភាក្សានៅក្នុងផ្នែកសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត ដែលបង្ហាញថា ការស្លាប់ទាំងនេះគឺបណ្តាលមកពីបទល្មើសសកម្ម និងអកម្មរបស់កម្មាភិបាល ប.ក.ក។

## ចេតនា

១៨០៨- ភ័ស្តុតាងនានាជុំវិញស្ថានការណ៍នៃព្រឹត្តិការណ៍ ដូចបានរៀបរាប់ទាំងអស់ខាងលើនេះ បង្ហាញថាក្នុងការប្រព្រឹត្តិសកម្មភាព ព្រមទាំងបង្កើតឲ្យមានអំពើអកម្មដែលបណ្តាលឲ្យមានមនុស្សស្លាប់អស់ជាច្រើននាក់នោះ ចារីទាំងនោះ៖

(១) មានចេតនាប្រព្រឹត្តនូវការសម្លាប់ក្នុងទ្រង់ទ្រាយធំ និង/ឬ

(២) មានចេតនាបង្កើតស្ថានភាពរស់នៅនានា ដែលបណ្តាលឲ្យមានការស្លាប់ក្នុងចំនួនដ៏ច្រើន (ឬមានចេតនាបង្កើតស្ថានភាពទាំងឡាយ ទោះបីជាមានការយល់ដឹងថា ស្ថានភាពទាំងនោះ អាចនឹងបង្កឲ្យមានមនុស្សស្លាប់ក្នុងចំនួនដ៏ច្រើនមួយនោះ)។

១៤០៩- ចំពោះករណីការសម្លាប់ ព្រមទាំងការស្លាប់នៅតាមបណ្តាមន្ទីរសន្តិសុខ ភ័ស្តុតាងពីចេតនាចារីដែលដល់ដែលបង្កឱ្យមានមនុស្សស្លាប់ក្នុងចំនួនដ៏ច្រើននោះ មានយ៉ាងលើសលប់។ ក្នុងចំណោមភ័ស្តុតាងទាំងនោះ រួមមាន ឯកសារស្តីពីគោលនយោបាយរបស់ ប.ក.ក ក្នុងការសម្លាប់សមាជិកដែលជាក្រុមគោលដៅ ការសម្លាប់ដែលមានលក្ខណៈគិតទុកជាមុនព្រមទាំងប្រព្រឹត្តទៅក្នុងសណ្ឋានដូចៗគ្នា ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងលក្ខណៈដូចៗគ្នារបាយការណ៍រៀបរាប់ពីការសម្លាប់ និងតួលេខរបស់ជនរងគ្រោះក្នុងចំនួនមួយពិតប្រាកដ។

១៤១០- ចំពោះករណីការស្លាប់ដែលបណ្តាលមកពីស្ថានភាពអមនុស្សធម៌ បង្កឡើងដោយ ប.ក.ក ដូចមាន បង្ហាញនៅក្នុងផ្នែកមនុស្សឃាតខាងលើនោះ ចារីដែលដល់ទាំងឡាយបានធ្វើសកម្មភាពដោយមានការយល់ដឹងល្មមគ្រប់គ្រាន់ថាស្ថានភាពនានា ដែលពួកគេបង្កឡើងអាចបណ្តាលឱ្យមានមនុស្សស្លាប់ក្នុងចំនួនដ៏ច្រើនមួយ។ បន្ថែមលើនេះទៀត ចេតនាក្នុងការបង្កឱ្យមានស្ថានភាពជម្រុញឱ្យមានការស្លាប់ ក្នុងចំនួនដ៏ច្រើននោះ បានយល់បានតាមរយៈអង្គហេតុដែលថា ទោះបីជាចារីដែលដល់បានដឹងជាមុនពីការស្លាប់ ក្នុងចំនួនដ៏ច្រើនដែលអាចកើតមានដោយសារស្ថានភាពទាំងនេះក៏ដោយ ក៏ពួកគេនៅតែបន្តការប្រព្រឹត្តដដែល។ យោងលើការអនុវត្តគោលនយោបាយ ប.ក.ក នានាក្នុងលក្ខណៈដូចៗគ្នា ពេញផ្ទៃប្រទេសនោះ ចំពោះគ្រប់ករណីទាំងអស់ដែលស្ថិតនៅក្រោមការស៊ើបអង្កេត ចារីទាំងឡាយបានដឹងរួចហើយពីផែនការឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំដែលពួកគេបានចូលរួម និងបានដឹងរួចហើយផងដែរពីអង្គហេតុដែលជនស៊ីវិលរាប់ពាន់នាក់ កំពុងត្រូវបានគេសម្លាប់ថាជាផ្នែកមួយនៃផែនការនោះ។

## ការធ្វើឱ្យទៅជាទាសករ

១៤១១- ភស្តុតាងនៅក្នុងសំណុំរឿងក្តី បានបង្ហាញពីការកើតមាននូវការដាក់ជាទាសករ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដែលអំពើឧក្រិដ្ឋនេះបានប្រព្រឹត្តឡើងក្នុងអំឡុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ។

## អំពើសកម្ម និងអំពើអកម្ម

១៤១២- ដូចមានកត់សម្គាល់នៅក្នុងផ្នែកយុត្តាធិការខាងលើ ក្នុងអំឡុងរយៈពេលស្ថិតក្រោមការស៊ើបអង្កេត ប.ក.ក បានដាក់ប្រជាជនក្នុងប្រទេសកម្ពុជាទាំងមូលជាទាសករប្រកបដោយប្រសិទ្ធភាព ហើយរាល់ឧក្រិដ្ឋកម្មដែលស្ថិតក្រោមការស៊ើបអង្កេតទាំងអស់ គឺបានប្រព្រឹត្តឡើងក្នុងបរិបទនៃការអនុវត្តនយោបាយដាក់ជាទាសករនេះ។

១៤១៣- នយោបាយធ្វើឱ្យទៅជាទាសករនេះ បានចាប់ផ្តើមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាមួយនូវការដាក់ចេញនូវបញ្ជាឱ្យប្រជាជនដែលរស់នៅទីប្រជុំជនទាំងអស់ ចាកចេញពីទីលំនៅ ព្រមទាំងទៅស្នាក់អាស្រ័យនៅទីជនបទតាមបណ្តាការដ្ឋាន និងសហករណ៍នានា ដែលស្ថិតក្រោមការកាន់កាប់របស់ ប.ក.ក។ ជនស៊ីវិលត្រូវបានប្រមូលទាំងហ្វូង ឱ្យចេញពីទីប្រជុំជននានាចាប់តាំងពីពេលដំបូងនៃការជម្លៀសដោយបង្ខំ ដោយ ប.ក.ក បានអនុវត្តសិទ្ធិគ្រប់បែបយ៉ាងទាំងអស់ ជាម្ចាស់ជាក់ស្តែងទៅលើប្រជាជនទាំងនោះ តាមរយៈការដាក់ជនស៊ីវិលទាំងឡាយឱ្យស្ថិតនៅក្រោម ការត្រួតត្រារបស់ខ្លួនទាំងស្រុង ដោយមិនទុកឱ្យពួកគេមានសិទ្ធិលើគ្រប់វិស័យនៃជីវិតរបស់ពួកគេ ។

១៤១៤- នៅពេលធ្វើដំណើរទៅដល់គោលដៅរបស់ពួកគេ ក្រុមគ្រួសារភាគច្រើនត្រូវគេបំបែក ហើយកូនត្រូវពង្រត់ពីឪពុកម្តាយ បុគ្គលគ្រប់ៗរូបត្រូវបានបញ្ចូលយ៉ាងសកម្មទៅក្នុងបណ្តាកងបង្កបង្កើន

ផលផ្សេងៗ។ អាជ្ញាធរត្រួតត្រាទាំងស្រុងលើគ្រប់វិស័យនៃជីវភាពរស់នៅប្រចាំថ្ងៃ រួមទាំងការស្នាក់នៅ ការផ្តល់ម្ហូបអាហារ និងថ្នាំសង្កូវ ក៏ដូចជាកន្លែងនិងពេលវេលាធ្វើការ កន្លែងស្នាក់នៅ និងសម្រាកជាដើម។ ពួកគេត្រូវបានហាមប្រាមមិនឲ្យប្រតិបត្តិទំនៀមទម្លាប់ ការធ្វើដំណើរ ការបញ្ចេញមតិចូលរួមជាសមាគមន៍ រួមទាំងការកំសាន្តដោយសេរីផ្សេងៗ ព្រមទាំងត្រូវធ្វើតាមទម្រង់នៃការប្រព្រឹត្តដែលគេប្រាប់ថាអាចទទួលយកបាន និងត្រូវគោរពដាច់ខាតគ្រប់ពេលវេលាទាំងអស់។ ប.ក.ក ក៏ បានដាក់ផងដែរ នូវគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចំពោះជនស៊ីវិលទាំងនោះ ដែលនៅក្នុងនោះគូភាគីម្ខាងនៃការរៀបអាពាហ៍ពិពាហ៍នោះត្រូវកម្មាភិបាល ប.ក.ក ជាអ្នករៀបចំ ឬជ្រើសរើសឲ្យ។ នយោបាយដាក់ជាទាសករ ក៏បានរួមបញ្ចូលផងដែរនូវការអនុវត្តការត្រួតត្រាលើរូបរាងកាយទៅលើជនរងគ្រោះទាំងនោះ។ ជនស៊ីវិលទាំងអស់ ត្រូវគេនាំយកទៅបំពាក់បំប៉ននយោបាយ តាមរយៈវគ្គទិតៀន និងស្វ័យទិតៀនដែលប្រព្រឹត្តទៅជាញឹកញាប់។

១៤១៥- ការជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំនៅលើកទីពីរ និងទីបី ក៏បានបង្ហាញឲ្យឃើញពីការត្រួតត្រា ដាច់អហង្ការរបស់អាជ្ញាធរ ប.ក.ក ទៅលើប្រជាជនទាំងមូលផងដែរ។ ការចេញបញ្ជាឲ្យមានការជម្លៀសលើកទីពីរ ដែលជាការផ្លាស់ដោយប៉ាន់ស្មានមួយ ដើម្បីបង្កើនទិន្នផលស្បៀងអាហារនៅភាគពាយ័ព្យនោះ ការបញ្ជាឲ្យជម្លៀសលើកទីបី គឺប្រព្រឹត្តទៅក្នុងគោលបំណងបង្ខំឲ្យមានការដាក់ជាទាសករទៅលើប្រជាជន កាន់តែច្រើនថែមទៀត តាមរយៈការធ្វើឲ្យខ្ចាត់ខ្ចាយសមាសធាតុសំខាន់ៗដែលមិនមានអំណោយផលនានា មកពីភូមិភាគបូព៌ា។

១៤១៦- ដូចមានរៀបរាប់នៅក្នុងផ្នែកឃុំឃាំងខ្លួន រំលោភផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការដាក់ជាទាសករត្រូវបានប្រព្រឹត្តទៅដោយមិនមានការលើកលែង ទាំងនៅក្នុងសហករណ៍ ព្រមទាំងនៅតាមទីតាំងប្រើពលកម្មដោយបង្ខំនានា ដែលស្ថិតក្រោមការស៊ើបអង្កេត។ កម្មាភិបាលបក្ស បានប្រើការស៊ើបយកការណ៍ និងវគ្គទិតៀននានាដើម្បីជម្រុះ សម្រេចដាក់ទោសលើបុគ្គលទាំងឡាយណាដែលត្រូវសង្ស័យថាមិនស្តាប់តាមបង្គាប់ ឬមានប្រវត្តិ នយោបាយ ឬវណ្ណៈមិនត្រឹមត្រូវ។ ជនទាំងឡាយណាដែលមិនបានគោរពទៅតាមវិន័យដែលប្រើសម្រាប់គ្រប់គ្រងការរស់នៅ និងធ្វើការងារនោះ ត្រូវទទួលការដាក់ទោស និង/ឬការលត់ដំ និងមានករណីចាប់ខ្លួន និងសម្លាប់ជាច្រើនទៀតផងដែរ។ ដូចមានបង្ហាញនៅក្នុងផ្នែកអំពើអមនុស្សធម៌ផ្សេងៗទៀត ជនស៊ីវិលដែលត្រូវដាក់ជាទាសករនៅសហករណ៍ និងនៅតាមការដ្ឋាននោះ ត្រូវឃុំឃាំងខ្លួនទៅតាមបទល្មើសផ្សេងៗ ដូចជា ស្វែងរកស្បៀង ការរអ៊ូរទាំ មិនគោរពតាមការណែនាំការងារ ប្រព្រឹត្តកំហុស ខ្ជិល ឬសូម្បីតែឈរនៅខាងក្រៅនាពេលយប់ ក៏ត្រូវមានទោសដែរ។ ប្រជាជនតែមួយប្រភេទ ដែលមិនទទួលរងនូវការដាក់ជាទាសករជាប្រព័ន្ធនោះ គឺជនទាំងឡាយដែលទទួលភារកិច្ចក្នុងការអនុវត្តគោលនយោបាយនេះ។ ដូចបានកត់សម្គាល់ នៅក្នុងផ្នែកយុត្តាធិការពីដំបូងឡើយប្រជាជនក្រុមនេះ គឺមានតែ "ប្រជាជនចាស់" ប៉ុណ្ណោះ ប៉ុន្តែក្រោយពីចាប់ផ្តើមមានការបោសសម្អាតផ្ទៃក្នុងនាដើមឆ្នាំ១៩៧៦ សមាជិករបស់ក្រុមនេះ ក៏បានក្លាយជាទិសដៅនៃគោលនយោបាយធ្វើឲ្យទៅជាទាសករផងដែរ។

**ចេតនា**

១៤១៧- ភ័ស្តុតាងនៅក្នុងសំណុំរឿងគឺ បង្ហាញថា កម្មាភិបាល ប.ក.ក មានចេតនាអនុវត្តន៍ជាម្ចាស់ គ្រប់បែបយ៉ាងទាំងអស់ទៅលើបុគ្គលទាំងនោះ ឱ្យស្ថិតក្រោមការត្រួតត្រារបស់ពួកគេ ដើម្បីឱ្យស្រប ទៅនឹងគោលនយោបាយនានា ដែលមជ្ឈិមបក្សបានកំណត់។ ភ័ស្តុតាងបញ្ជាក់ពីចេតនាក្នុងការធ្វើឱ្យទៅជាទាសករ ទៅលើប្រជាជននោះ អាចនឹងបង្ហាញ ឬអាចសន្និដ្ឋានបាននោះ រួមមាន៖ ឯកសារអំពីគោលនយោបាយនានារបស់ ប.ក.ក កម្រិតនៃការត្រួតត្រាលើរូបរាងកាយ និងលើស្មារតី ដែលបានអនុវត្តទៅលើជនស៊ីវិល ការអនុវត្តតាមបញ្ជាដែលមានលក្ខណៈដូចគ្នាក្នុងអំឡុងពេលជម្លៀសដោយបង្ខំ នៅតាមបណ្ដាសហករណ៍ផ្សេងៗ ព្រមទាំងទីតាំងប្រើពលកម្មដោយបង្ខំ ការប្រើគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងការដាក់នូវទណ្ឌកម្មធ្ងន់ធ្ងរ ទៅលើជនទាំងឡាយណា ដែលមិនគោរពតាមការណែនាំរបស់បក្ស។

## ការឃុំខ្លួន

១៤១៨- ភ័ស្តុតាងបង្ហាញថា ការឃុំខ្លួន គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

## អំពើសកម្ម និងអំពើអកម្ម

១៤១៩- ជនរងគ្រោះរាប់ពាន់នាក់ ត្រូវបានឃុំខ្លួន ក្នុងអំឡុងការជម្លៀសដោយបង្ខំ នៅតាមទីតាំងប្រើពលកម្មដោយបង្ខំ តាមសហករណ៍ និងនៅតាមមន្ទីរសន្តិសុខរបស់ ប.ក.ក ព្រមទាំងតាមបណ្ដាទីតាំងផ្សេងៗទៀត ដែលស្ថិតក្រោមការស៊ើបអង្កេត។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមានប្រព័ន្ធច្បាប់ដំណើរការនៅក្នុងប្រទេសកម្ពុជាទេ។ បុគ្គលទាំងឡាយត្រូវកម្មាភិបាលដកហូតសេរីភាព ដោយអនុវត្តតាមគោលនយោបាយ និងការណែនាំនានា របស់

មជ្ឈិមបក្ស ប.ក.ក។ ការឃុំខ្លួនត្រូវប្រព្រឹត្តតាមអំពើចិត្ត ដោយសារការឃុំខ្លួននោះត្រូវធ្វើឡើងដោយគ្មានវត្ថុមានជាមូលដ្ឋានច្បាប់ ឬនីតិវិធីត្រឹមត្រូវតាមច្បាប់អ្វីទាំងអស់។ បុគ្គលទាំងឡាយ ដែលត្រូវគេដកហូតសេរីភាព របស់ខ្លួន មិនអាចមានលទ្ធភាពប្រឈមតតាំងនឹងការចាប់ខ្លួន និង/ឬ ការឃុំខ្លួនរបស់ពួកគេ នៅចំពោះមុខសមត្ថកិច្ចតុលាការណាមួយឡើយ។

*នៅក្នុងការជម្លៀសដោយបង្ខំ*

១៤២០- ជនរងគ្រោះរាប់លាននាក់ ត្រូវកម្មាភិបាល ប.ក.ក និងកងទ័ពខ្មែរក្រហម ឬកងទ័ពបដិវត្តកម្ពុជា ឃុំខ្លួនក្នុងអំឡុងពេលមានព្រឹត្តិការណ៍ជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំ ចំនួន៣លើកផ្សេងៗគ្នា ដែលស្ថិតក្រោមការស៊ើបអង្កេត៖

១៤២១- ***ការជម្លៀសដោយបង្ខំលើកទីមួយ៖*** ក្រោយពីមានការដាក់បញ្ជាឲ្យជម្លៀសចេញដោយបង្ខំទៅលើអ្នករស់នៅក្នុងទីក្រុងភ្នំពេញ និងអ្នកដែលរស់នៅតាមទីប្រជុំជននានានោះ (រួមមាន **កំពង់សោម កំពត តាកែវ ស្ទឹងត្រែង ប៉ៃលិន បាត់ដំបង សិរីសោភ័ណ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ ស្វាយរៀង និងព្រៃវែង**) ប្រជាជនស៊ីវិលទាំងអស់ ដែលរស់នៅតាមបណ្តាទីក្រុង និងទីប្រជុំជនទាំងនោះ ត្រូវបានកម្មាភិបាល ប.ក.ក និងកងទ័ពខ្មែរក្រហម ឃុំខ្លួនជាក់ស្តែង និងមានប្រសិទ្ធភាព។ ជនរងគ្រោះត្រូវគេដកហូតសេរីភាពរបស់ខ្លួន ដោយគ្មានមូលដ្ឋានច្បាប់ ឬនីតិវិធីត្រឹមត្រូវតាមច្បាប់ឡើយ។ ការជម្លៀស ត្រូវធ្វើឡើងដោយចុងកាំភ្លើង និងគ្មានករណីលើកលែង។ ទាហានខ្មែរក្រហម បានធ្វើបាបលើរាងកាយ ឬសម្លាប់ប្រជាជននៅនឹងកន្លែងតែម្តង ចំពោះជនទាំងឡាយណាដែលមិនព្រមធ្វើតាម។ រយៈពេលនៃការឃុំខ្លួនដោយប្រសិទ្ធភាព មានចំនួនជាច្រើនថ្ងៃ ឬច្រើនសប្តាហ៍ រហូតដល់ប្រជាជនទាំងនោះធ្វើដំណើរដល់

គោលដៅរបស់ខ្លួន ព្រមទាំងឃុំខ្លួននៅតាមបណ្តាសហករណ៍ ឬនៅតាមទីតាំងប្រើពលកម្ម ដោយបង្ខំនានា ដោយស្ថិតក្រោមការត្រួតត្រារបស់អាជ្ញាធរមូលដ្ឋាន។

១៤២២- ***ការជម្លៀសចេញដោយបង្ខំលើកទីពីរ៖*** ដូចមានរៀបរាប់នៅក្នុងអនុផ្នែកស្តីពីអំពើអមនុស្សធម៌ផ្សេងៗទៀតនោះយ៉ាងតិចមានប្រជាជនមានចំនួនយ៉ាងហោចណាស់ ៥០០០០០នាក់ ជាអ្នកទោសដោយសារកម្មាភិបាល ប.ក.ក នៅក្នុងអំឡុងពេលជម្លៀសដោយបង្ខំពីភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគបស្ចិម ឲ្យទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរចាស់។ បុគ្គលទាំងនេះត្រូវបានដាក់ជាទាសកររួចទៅហើយនៅក្នុងសហករណ៍ និងការដ្ឋាននានាដែលពួកគេត្រូវបានជម្លៀសចេញ។ ក្នុងអំឡុងពេលជម្លៀស ជនស៊ីវិលត្រូវធ្វើដំណើរដោយថ្មើរជើង ព្រមទាំងដឹកជញ្ជូនតាមទូក រថយន្ត និងរថភ្លើង ដោយមានអ្នកយាមប្រដាប់ដោយអាវុធ។ ពួកគេក៏ត្រូវគេឃុំខ្លួន ដោយមានអ្នកយាម ប្រដាប់ដោយអាវុធផងដែរ ក្នុងពេលដែលស្នាក់នៅពាក់កណ្តាលផ្លូវ ឬនៅតាមទីកន្លែងដែលត្រូវបញ្ជូនទៅផ្សេងៗ មុននឹងបន្តដំណើររបស់ខ្លួនទៅកាន់ភូមិភាគពាយ័ព្យ។ ការជម្លៀសមានរយៈពេលប្រមាណជាប្រាំមួយខែ។ ដូចជាករណីក្នុងអំឡុងពេលកើតមានព្រឹត្តិការណ៍ជម្លៀសដោយបង្ខំនៅលើកទីមួយដែរ សកម្មភាពនៃការឃុំខ្លួនទាំងនេះ ប្រព្រឹត្តទៅដោយគ្មានមូលដ្ឋានច្បាប់ និងគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់ឡើយ។

១៤២៣- ***ការជម្លៀសដោយបង្ខំលើកទីបី៖*** ជនស៊ីវិលរាប់រយរាប់ពាន់នាក់ត្រូវឃុំខ្លួន ក្នុងអំឡុងពេលជម្លៀសដោយបង្ខំពីភូមិភាគបូព៌ា ដែលជាការជម្លៀសកើតមាននៅដំណាក់កាលចុងក្រោយនៃការបោសសម្អាតភូមិភាគបូព៌ានោះ។ ជនស៊ីវិលទាំងនោះ ភាគច្រើនពួកគេត្រូវបានដាក់ជាទាសកររួចទៅហើយនៅក្នុងភូមិភាគបូព៌ា ត្រូវបានកម្មាភិបាល ប.ក.ក និងកងទ័ពបដិវត្តន៍

កម្ពុជានាំចេញទៅ នឹងកាណុងកាំភ្លើង។ ពួកគេត្រូវបានធ្វើដំណើរដោយថ្មើរជើង ព្រមទាំងជម្លៀសតាមរយៈទូក រថភ្លើង ឬរថយន្តទៅកាន់ភូមិភាគឧត្តរថ្មី ភូមិភាគពាយ័ព្យ ភូមិភាគឦសាន្ត ភូមិភាគបស្ចិម និងភូមិភាគកណ្តាល។ ដូចនឹងព្រឹត្តិការណ៍នៃការជម្លៀសដោយបង្ខំមុនៗដែរ ការជម្លៀសនេះប្រព្រឹត្តទៅដោយគ្មានមូលដ្ឋានច្បាប់ ឬនីតិវិធីច្បាប់អ្វីទាំងអស់សម្រាប់អំពើឃុំខ្លួននេះ។ បុគ្គលទាំងឡាយណាដែលរឹងទទឹង ត្រូវបានគេសម្លាប់។ មនុស្សជាច្រើនត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ នៅពេលពួកគេធ្វើដំណើរទៅដល់គោលដៅរបស់ខ្លួន។

*នៅទីតាំងប្រើពលកម្មដោយបង្ខំ*

១៤២៤- ជនរងគ្រោះជាច្រើនពាន់នាក់ ត្រូវជាប់ឃុំឃាំងនៅតាមទីតាំងប្រើពលកម្មដោយបង្ខំរបស់ ប.ក.ក ដូចជា **សហករណ៍ត្រាំកក់ វាលស្រែអំបិល ទំនប់១មករា ទំនប់ត្រពាំងថ្ម** និង **ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង**។ ជនរងគ្រោះដែលជាប់ឃុំនៅតាមបណ្តាទីតាំងទាំងនោះមួយចំនួន រួមបញ្ចូលទាំងជនទាំងឡាយ ដែលត្រូវចាប់ខ្លួនក្នុងអំឡុងពេលបោសសម្អាតនៅភូមិភាគឧត្តរផងដែរ (ការដ្ឋានសាងសង់ **ព្រលានយន្តហោះកំពង់ឆ្នាំង វាលស្រែអំបិល**) និងការបោសសម្អាតនៅភូមិភាគបូព៌ា (ការដ្ឋានសាងសង់**ព្រលានយន្តហោះកំពង់ឆ្នាំង**)។

១៤២៥- ***ការឃុំខ្លួន និងការបាបព្រាមផ្សេងៗ៖*** បុគ្គលទាំងឡាយដែលត្រូវឃុំខ្លួននៅតាមបណ្តាទីតាំងខាងលើ ត្រូវបានគេដកហូតសេរីភាពក្នុងការធ្វើសកម្មភាពផ្សេងៗរបស់ពួកគេ។ គេមិនអនុញ្ញាតឱ្យពួកគេធ្វើសកម្មភាពដោយសេរី ព្រមទាំងត្រូវស្ថិតក្រោមការត្រួតពិនិត្យពីអ្នកយាមដែលប្រដាប់ដោយអាវុធ។ ដូចមានរៀបរាប់នៅក្នុងផ្នែកដាក់ជាទាសករខាងលើអាជ្ញាធរ ប.ក.ក បានត្រួតត្រាលើ គ្រប់វិស័យនៃការរស់នៅរបស់ពួកគេទាំងអស់ រួមមាន ទីកន្លែង និងរបៀបដែលពួក

គេត្រូវធ្វើការងារ សម្រាក និងដេក ពេលវេលា និងកំរិតដែលពួកត្រូវបានអនុញ្ញាតឱ្យផឹកទឹក និងហូបចុក ព្រមទាំងពេលណាដែលពួកគេត្រូវបានអនុញ្ញាតឱ្យនិយាយផងដែរ។

១៤២៦- ***ស្ថានភាពនៃការឃុំខ្លួន និងការរំលោភបំពានដទៃទៀត៖*** ដូចមានរៀបរាប់នៅក្នុងផ្នែកអំពើអមនុស្សធម៌ផ្សេងៗទៀតរួចមកហើយ ភាគច្រើននៃបុគ្គលទាំងនោះដែលស្ថិតនៅតាមទីតាំងប្រើពលកម្មដោយបង្ខំ និងនៅតាមសហករណ៍នានា ដែលស្ថិតក្រោមការស៊ើបអង្កេតនោះ ត្រូវស្ថិតក្នុងស្ថានភាពដែលលំបាកជាទីបំផុត រួមមាន៖ ការបង្ខំឱ្យប្រើពលកម្មដោយដៃក្នុងរយៈពេលយូរ ការដកហូតសិទ្ធិមិនឱ្យមានការថែទាំតាមបែបវេជ្ជសាស្ត្រ ស្ថានភាពរស់នៅគ្មានអនាម័យគ្រប់គ្រាន់ជាដើម។ ពួកគេក៏ត្រូវរស់នៅក្រោមការភ័យខ្លាចជាដរាបចំពោះការដាក់ទោស ដែលអាចកើតមានដោយសារតែមិនគោរពទៅតាមសេចក្តីណែនាំនានារបស់ ប.ក.ក។ ការដាក់ទោស រួមមាន ការកាត់បន្ថយរបបអាហារ វាយដំ ធ្វើទារុណកម្ម និងសម្លាប់។ អ្នកទោសក៏ត្រូវគេបង្ខំឱ្យចូលរួម រៀនសូត្រ និងចូលរួមក្នុងវគ្គទិតៀន និងស្វ័យទិតៀនផ្សេងៗផងដែរ។

*នៅតាមមន្ទីរសន្តិសុខ*

១៤២៧- មនុស្សរាប់ពាន់នាក់ ត្រូវបានឃុំខ្លួននៅតាមមន្ទីរសន្តិសុខនានា ដូចជា **ស-២១ កោះខ្យង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច ភ្នំក្រោល វត្តធ្លក អូរកន្សែង វត្តគីរីរម្យ** (រួមទាំង **ចន្លោះក្តោង**) **និង សៀមរាប** ផងដែរ។ ជនរងគ្រោះដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខទាំងនេះមួយចំនួន គឺរួមទាំងជនទាំងឡាយដែលត្រូវចាប់ខ្លួនក្នុងអំឡុងពេលបោសសម្អាតនៅភូមិភាគឧត្តរ និងភូមិភាគបូព៌ាផងដែរ ដែលជាព្រឹត្តិការណ៍ដោយឡែកស្ថិតក្រោមការស៊ើបអង្កេត។

១៤២៨- មូលហេតុសម្រាប់ការចាប់ខ្លួន និងឃុំខ្លួននៅតាមមន្ទីរសន្តិសុខរបស់ ប.ក.ក ទាំងនោះ រួមមាន៖ ជាសមាជិករបស់របបសាធារណរដ្ឋខ្មែរ មាននិន្នាការជាគហបតី ឬសក្តិភូមិ ឬមានប្រវត្តិរូបជាវណ្ណៈមិនត្រឹមត្រូវ មិនគោរពតាមបទវិន័យរបស់បក្ស ការធ្វើដំណើរដោយគ្មានការអនុញ្ញាត ការរអ៊ូរទាំពីការហូបមិនគ្រប់គ្រាន់ លួចម្ហូប ឬគ្រឿងចាំបាច់ដទៃទៀត ដាំគ្រាប់ពូជខុសនៅការដ្ឋាន មានជាប់ពាក់ព័ន្ធនឹងអ្នកទោស ជាជនជាតិវៀតណាម និងមានទំនាក់ទំនង ឬពាក់ព័ន្ធជាមួយ "ខ្មាំង" ដូចជាវៀតណាម "សេអ៊ីអា" ឬ "កាហ្សេបេ" ជាដើម។ មានករណីជាច្រើន ការចាប់ខ្លួន ត្រូវបានប្រព្រឹត្ត ដោយផ្អែកលើ "ចម្លើយសារភាព" ដែលបានមកពីជនរងគ្រោះ តាមរយៈការធ្វើទារុណកម្ម។

១៤២៩- ***ការឃុំខ្លួន និងការបោមព្រោមផ្សេងៗ៖*** អ្នកទោសតែងត្រូវគេឃុំខ្លួននៅក្នុងបន្ទប់ឃុំខ្លួនដាច់ដោយឡែក បន្ទប់ឃុំខ្លួនរួមគ្នា ក្នុងបន្ទប់ឃុំខ្លួនដែលមានទំហំធំ ឬក្នុងអគាររួម។ អ្នកទោសទាំងអស់ត្រូវស្ថិតក្រោមការតាមដានជាប្រចាំ របស់អ្នកយាមដែលប្រដាប់ដោយអាវុធ ហើយពួកគេមិនត្រូវបានអនុញ្ញាតឱ្យធ្វើចលនាដោយសេរីទេ។ ដូចមានបញ្ជាក់នៅក្នុងផ្នែកអំពើអមនុស្សធម៌ផ្សេងៗ ទៀតរួចមកហើយ ខ្នោះដៃ និង/ឬ ខ្នោះជើងត្រូវគេប្រើដើម្បីឃុំខ្លួនអ្នកទោស (នៅ**កោះខ្សែង មន្ទីរស-២១ ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លក អូរកន្សែង** ចន្លោះក្តោង (វត្តគិរីរម្យ) និង**សៀមរាប**)។ ពួកអ្នកទោសក៏ទទួលរងការឈឺចាប់ផងដែរ ដោយបណ្តាលមកពីការដកហូតនូវសិទ្ធិក្នុងការទទួលបាននូវ ពេទ្យព្យាបាលសុខភាព និងការរស់នៅក្នុងភាពភ័យខ្លាចជាប់ជានិច្ចអំពីការដាក់ទណ្ឌកម្ម និងការសម្លាប់។

១៤៣០- ***ស្ថានភាពអមនុស្សធម៌ និងការរំលោភបំពានផ្សេងទៀត៖*** ដូចមានរៀបរាប់រួចមកហើយនៅក្នុងផ្នែក អំពើអមនុស្សធម៌ផ្សេងៗទៀត ស្ថានភាពដែលអ្នកទោសត្រូវបានគេឃុំខ្លួន រួមមាន៖ ត្រូវគេរំលោភបំពានទាំងលើរាងកាយ និងស្មារតី រួមមានការធ្វើទារុណកម្មក្នុងពេលកំពុងសួរចម្លើយ ត្រូវគេឃុំខ្លួននៅក្នុងស្ថានភាពដែលគ្មានអនាម័យគ្រប់គ្រាន់ មិនត្រូវបានអនុញ្ញាតឱ្យនិយាយក្នុងចំណោមអ្នកទោសដូចគ្នា ឬជាមួយអ្នកយាម ហើយទទួលនូវរបបអាហារដែលមានកម្រិតតឹងតែង និងមានករណីជាច្រើនទៀត អ្នកទោសត្រូវគេបង្ខំឱ្យប្រើពលកម្មដោយដៃក្នុងរយៈពេលដ៏យូរ [**មន្ទីរស-២៤ (ស-២១) កោះខ្សង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច ភ្នំក្រោល វត្តធ្លក អូរកន្សែង ចន្លោះក្ដោង (វត្តគិរីរម្យ) សៀមរាប**]។ អ្នកទោសក៏ត្រូវទទួលរងការដកហូតនូវការថែទាំបែបវេជ្ជសាស្ត្រ ព្រមទាំងរស់នៅក្រោមភាពភ័យខ្លាចជានិច្ចចំពោះការដាក់ទោស និងការសម្លាប់។

### ចេតនា

១៤៣១- ភស្តុតាងបង្ហាញថា ចារីដែលបានប្រព្រឹត្តអំពើផ្សេងៗដែលបណ្ដាលឱ្យមានការឃុំខ្លួន ជាមួយនឹងចេតនាដកហូតតាមតែអំពើចិត្ត នូវសេរីភាពក្នុងការធ្វើសកម្មភាពពីជនរងគ្រោះ។ ចារីបានប្រើ ការបង្ខំលើរូបរាងកាយ ការហាមប្រាម ការដាក់កំហិតធ្ងន់ធ្ងរ ទៅលើសេរីភាពជាមូលដ្ឋានរបស់ជនរងគ្រោះ (ដូចជាសិទ្ធិក្នុងការមានមតិ និងការធ្វើដំណើរ) ការដាក់ទណ្ឌកម្មលើរាងកាយ និងការសម្លាប់ ដើម្បីអនុវត្តការឃុំខ្លួនឱ្យកើតមានក្នុងលក្ខណៈជាប្រព័ន្ធ។

### ការធ្វើទារុណកម្ម

១៤៣២- ភស្តុតាងនៅក្នុងសំណុំរឿងក្តី បង្ហាញថា ការធ្វើទារុណកម្ម គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចត្រូវគេផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដែលត្រូវបានប្រព្រឹត្ត ឡើងក្នុង អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ផ្នែកខាងក្រោមទាំងនេះ បង្ហាញនូវអង្គហេតុនានា ដែលបង្កបានជាធាតុផ្សំនៃបទឧក្រិដ្ឋការធ្វើទារុណកម្មចំនួនបី ដូចជា៖ (១) អំពើសកម្ម ឬ អំពើអកម្ម (២)ចេតនា (៣)ធាតុផ្សំគោលបំណងបន្ថែមដែលមានលក្ខណៈពិសេសតែមួយគត់ ដើម្បីធ្វើទារុណកម្មបន្ថែមទៀត។

**អំពើសកម្ម**

*នៅតាមបណ្តាទីតាំងប្រើពលកម្មដោយបង្ខំនានា*

១៤៣៣- ការវាយដំត្រូវបានគេចាត់ទុកថាជាការដាក់ទោសទៅលើពលករ នៅឯការដ្ឋានសាងសង់ **ទំនប់ ទឹក១ មករា** និង **វាលស្រែអំបិល**។ ពលករនៅទីតាំង**ទំនប់ទឹក១មករា** ក៏ត្រូវគេចាប់ខ្លួន និង ឃុំខ្លួននៅ **វត្តបារាយជាន់ដែក** ជាកន្លែងដែលពួកគេត្រូវគេសួរចម្លើយ ធ្វើទារុណកម្ម និងវាយដំ ផងដែរ។

*នៅតាមបណ្តាមន្ទីរសន្តិសុខនានា*

១៤៣៤- អ្នកទោសរាប់ពាន់នាក់ ត្រូវបានគេធ្វើទារុណកម្មក្នុងពេលសួរចម្លើយជាប្រព័ន្ធ នៅតាមបណ្តា មន្ទីរសន្តិសុខនានារបស់ ប.ក.ក ដូចជា **ស-២១ ស-២៤ កោះខ្យង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លក អូរកន្សែង** និង**សៀមរាប**។ នៅតាមមន្ទីរសន្តិសុខជាច្រើន (ដូចជា **ស-២១ កោះខ្យង ព្រៃដំរីស្រុត និងសៀមរាប**) អ្នកទោសត្រូវគេសួរចម្លើយសារចុះ សារឡើងជាច្រើនលើកច្រើនគ្រា ហើយជាញឹកញាប់ការសួរចម្លើយនោះមានរយៈពេលវែងៗ

ទៀតផង។ សាក្សីជាច្រើនតែងតែបានឮសម្រែកឈឺចាប់ក្នុងពេលសួរចម្លើយ នៅតាមបណ្ដាមន្ទីរសន្តិសុខនានាជាច្រើន (ស-២១ កោះខ្សែង វត្តធ្លក អូរកន្សែង វត្តគិរីរម្យ និងសៀមរាប)។ អ្នកទោសដែលវិលត្រឡប់ពីការសួរចម្លើយមកវិញ ត្រូវគេឃើញមានស្នាមឈាម និង/ឬមានរបួស (គោកក្ដួច អូរកន្សែង និងស-២១)។

១៤៣៥- អ្នកសួរចម្លើយបានបង្កើតឲ្យមានវិធីសាស្ត្រ សម្រាប់ធ្វើទារុណរួមមួយទៅលើអ្នកទោស៖

(១) ការវាយដោយដែករបារ កាំភ្លើង រំពាត់ ឬផ្ដៅ គឺជាវិធីសាស្ត្រសាមញ្ញមួយសម្រាប់ការធ្វើទារុណកម្ម ក្នុងពេលសួរចម្លើយ (ស-២១ រួមមាន ស-២៤ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច ភ្នំក្រោល វត្តធ្លក អូរកន្សែង និងសៀមរាប)។

(២) ការប្រើខ្សែភ្លើងឆក់ ក្នុងពេលសួរចម្លើយនៅមន្ទីរសន្តិសុខស-២១ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ គោកក្ដួច អូរកន្សែង និងសៀមរាបជាដើម។ មានករណីខ្លះ អ្នកទោសត្រូវគេឆក់ខ្សែភ្លើងរហូតដល់សន្លប់បាត់ស្មារតី ឬរហូតដល់ស្លាប់។

(៣) ទារុណកម្មធ្វើឲ្យថប់ដង្ហើមដោយថង់ផ្លាស្ទិក តែងតែត្រូវបានគេប្រើនៅរៀងរាល់ ពេលសួរចម្លើយនៅមន្ទីរសន្តិសុខស-២១ សង់ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ គោកក្ដួច និងសៀមរាប។ អ្នកសួរចម្លើយ បានប្រើថង់ផ្លាស្ទិកទៅគ្របលើក្បាលរបស់អ្នកទោសនឹងបណ្ដាលឲ្យអ្នកទោសថប់ដង្ហើម (ស-២១ ព្រៃដំរីស្រុត សង់ និងក្រាំងតាចាន់)។

(៤) ជាញឹកញាប់ ក្រចកដៃ និងក្រចកជើង ត្រូវគេដកក្នុងពេលសួរចម្លើយនៅមន្ទីរសន្តិសុខស-២១ ព្រៃដំរីស្រុត ក្រាំងតាចាន់ និងសៀមរាប។ ការអនុវត្តស្រដៀងគ្នាផ្សេងៗទៀត រួមមាន ការវាយបំបែកម្រាមដៃ (ព្រៃដំរីស្រុត) យកដង្កាប់ហែកសាច់ (ស-២១) ព្រមទាំងយកដង្កៀបកៀបច្រមុះ (ក្រាំងតាចាន់) ជាដើម។

១៨៣៦- វិធីសាស្ត្រក្នុងការធ្វើទារុណកម្មដទៃទៀតក៏ត្រូវបានគេយកមកប្រើផងដែរ។ នៅមន្ទីរសន្តិសុខ **ស-២១** ការធ្វើទារុណកម្មរួមមាន៖ អុជនឹងកន្ទុយបារី ព្រមទាំងដុតនឹងអំពូលអគ្គិសនី ត្រាំទឹក ត្រជាក់ ព្រមទាំងប្រើកង្ហារអគ្គិសនីធ្វើឲ្យឈ្លក់ទឹក បង្ខំឲ្យអ្នកទោសវាយគ្នាទៅវិញទៅមក បង្ខំឲ្យស៊ីលាមក និងផឹកទឹកនោម ព្រមទាំងប្រើឈើរុកចូលទៅក្នុងអវៈយវៈភេទស្ត្រី។ អ្នកទោសស្ត្រី ក៏ត្រូវគេរំលោភផ្លូវភេទផងដែរ ក្នុងពេលសួរចម្លើយនៅមន្ទីរសន្តិសុខ **សង់**។ ទាំងនៅ **ស-២១** និង **ក្រាំងតាចាន់** អ្នកទោសតែងតែត្រូវចងព្យួរនឹងខ្សែពួរ ដោយចងដៃ ជើង និង ក ក្នុងរយៈពេលយ៉ាងយូរ។ ភ័ស្តុតាងនៃការប្រើអំពើទារុណកម្មនេះ ក៏ត្រូវគេរកឃើញផង ដែរនៅ**វត្តគិរីរម្យ**។ ទារុណកម្ម ព្រមទាំងឧបករណ៍សម្លាប់ជាច្រើន មានជាប់ស្នាមឈាម ត្រូវបានគេរកឃើញនៅមន្ទីរសន្តិសុខនេះ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់មួយ រយៈខ្លីមក។

១៨៣៧- វិធីសាស្ត្រធ្វើទារុណកម្មផ្នែកស្មារតី និងបែប "ត្រជាក់" ត្រូវបានប្រើ រួមមានការប្រើការគំរាម កំហែង ព្រមទាំងឧបាយកលផ្សេង (**ស-២១ ក្រាំងតាចាន់ គោកក្ដួច** និង**សៀមរាប**)។ នៅ មន្ទីរសន្តិសុខស២១ ការរំលោភបំពាន និងការគម្រាមកំហែងផ្នែកស្មារតី (រួមមាន ការបង្ខំឲ្យ អ្នកទោសថ្វាយបង្គំជញ្ជាំង តុ ឬកៅអី ឬរូបថត្ដ) គឺជាផ្នែកសំខាន់នៃនីតិវិធីសួរចម្លើយជា បទដ្ឋាន។

១៨៣៨- គោលនយោបាយក្នុងការកំណត់អត្តសញ្ញាណ និងការបោសសម្អាតខ្មាំងរបស់ ប.ក.ក រួមមាន ភាពស៊ីសង្វាក់គ្នានៃវិធីសាស្ត្រធ្វើទារុណកម្ម ព្រមទាំងលក្ខណៈជាប្រព័ន្ធនៅក្នុងការធ្វើទារុណកម្ម ដែលបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខនានា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់ សុទ្ធ

តែបញ្ជាក់ពីចេតនាបង្កឲ្យមានការធ្វើទារុណកម្មរបស់អ្នកសួរចម្លើយ។ អ្នកសួរចម្លើយ ត្រូវបានគេបង្វឹក ព្រមទាំងណែនាំពីការធ្វើទារុណកម្ម បន្ទាប់មក ទើបយកការណែនាំទាំងនោះទៅអនុវត្តជាច្រើនលើកជាច្រើនសារ និងតាមអំពើចិត្ត ដើម្បីគោរពតាមគោលនយោបាយរបស់មជ្ឈិមបក្សដោយផ្ទាល់។

១៤៣៩- សកម្មភាពនៃការធ្វើទារុណកម្មនានា ដែលត្រូវបានប្រព្រឹត្តនៅតាមការដ្ឋាននោះ ក៏ត្រូវបានគេប្រើតាមអំពើចិត្តផងដែរ។ ចេតនារបស់ចារី គឺត្រូវបានបង្ហាញតាមរយៈអង្គហេតុដែលការវាយដំត្រូវបានប្រព្រឹត្តជាប្រចាំជាការដាក់ទោសចំពោះជនទាំងឡាយណាដែលរំលោភបំពានលើវិន័យដែល ប.ក.ក បានដាក់ចេញ។

## គោលបំណង

១៤៤០- គោលបំណងជាចំបងនៃការបង្កើតឲ្យមានមន្ទីរសន្តិសុខជាបណ្តាញរបស់ ប.ក.កនោះ គឺដើម្បីកំណត់អត្តសញ្ញាណ និងដើម្បី "កម្ទេច" ជនទាំងឡាយដែលគេចាត់ទុកថាជាខ្មាំង ព្រមទាំងសមាសភាពមិនល្អផ្សេងៗទៀត ដូចជា ពួកវៀតណាមជាដើម។ ការទទួលបានព័ត៌មានតាមរយៈការគំរាមកំហែង ការប្រើហឹង្សាព្រមទាំងការបង្ខិតបង្ខំ គឺជាវិធីសាស្ត្រសំខាន់មួយ ដែលមន្ទីរសន្តិសុខ យកមកប្រើដើម្បីសម្រេចឲ្យបានបេសសកម្មរបស់គេ។ អំពើទារុណកម្មដូចដែលបានរៀបរាប់ខាងលើ ត្រូវបានប្រព្រឹត្តទៅក្នុងគោលបំណងទាញយកចម្លើយសារភាពពីអ្នកទោសពីសកម្មភាពប្រឆាំងនឹង ប.ក.ក ក៏ដូចជាការការបង្ខិតបង្ខំ ទៅលើពួកគេដើម្បីឲ្យគេបង្ហាញនូវអត្តសញ្ញាណ "ជនក្បត់" សេអ៊ីអា កាហ្សេបេ និង"ខ្សែបណ្តាញ"វៀតណាមបន្ថែមទៀត។

១៨៤១- ទារុណកម្មត្រូវបានគេប្រើជាឧបករណ៍សម្រាប់ការគម្រាមកំហែង ព្រមទាំងធ្វើទារុណកម្ម នៅតាមមន្ទីរសន្តិសុខនានា (ដូចជា **សៀមរាប** និង **មន្ទីរស-២៤** “**ស-២១**”) និងនៅតាមការដ្ឋាននានា (រួមមាន **ស្រែអំបិល** **ទំនប់១មករា** និង**ទំនប់ត្រពាំងថ្ម**)។ នៅមន្ទីរសន្តិសុខ**សៀមរាប** និងមន្ទីរសន្តិសុខ**ស-២៤** អ្នកទោសត្រូវគេដាក់ទោសដោយវាយនឹងរំពាត់ វាយដំ និងធ្វើទារុណកម្មចំពោះការបំពេញការងារមិនបានល្អ។ មានករណីមួយនោះ ការធ្វើទារុណកម្មលើរូបរាងកាយ និងការវាយដំ ត្រូវបានគេអនុវត្តនៅចំពោះមុខវត្តមានរបស់អ្នកទោសផ្សេងៗទៀត (មន្ទីរសន្តិសុខ**សៀមរាប**)។ ពលករនៅ**ទំនប់១មករា** ត្រូវបានគម្រាមកំហែង និងដាក់ទោសដោយវាយដំព្រោះមិនបានបំពេញទៅតាមគោលការណ៍ការងាររបស់ពួកគេមិនបានបង្ហាញពីការ “រីកចម្រើន” ឲ្យបានគ្រប់គ្រាន់ និងដោយគេសន្មតថាមានទំនាក់ទំនងជាមួយ សេអ៊ីអា ប្រជាជនថ្មី និងប្រជាជនចាម។ ពលករនៅ**ស្រែអំបិល** ត្រូវបានគេធ្វើទារុណកម្ម ដោយសារតែកំហុសដែលគេចោទប្រកាន់។ ជនទាំងឡាយដែលត្រូវបានដាក់ជាទាសករនៅការដ្ឋាន **ទំនប់ត្រពាំងថ្ម** ត្រូវដាក់ទោសដោយវាយដំ និងរំលោភបំពានលើរាងកាយ ចំពោះការមិនខិតខំប្រឹងប្រែងធ្វើការងារ។

១៨៤២- ទារុណកម្មក៏ត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងរើសអើងផងដែរ។ អំពើហិង្សាទៅលើអ្នកទោសជាប្រជាជនវៀតណាមនៅមន្ទីរ**ស-២១** ត្រូវបានប្រព្រឹត្តឡើងដោយមានការរើសអើងពូជសាសន៍ ឬជាតិពន្ធុជាដើមចម។ ដោយសារតែប្រវត្តិរបស់ពួកគេតែម្យ៉ាង អ្នកទោសវៀតណាមត្រូវបានគេធ្វើទារុណកម្មជាប្រព័ន្ធ ដើម្បីប្រាប់ព័ត៌មានពី “ខ្សែបណ្ដាញ” វៀតណាមនៅក្នុងប្រទេសកម្ពុជា និងដើម្បីសារភាពពីការដឹងឮផែនការវាតទីនិយមសន្មតរបស់វៀតណាម។

ស្រដៀងគ្នានេះដែរ ទារុណកម្មត្រូវបានគេបង្កឡើងដោយសារប្រវត្តិរើសអើងនយោបាយទៅលើ ជនទាំងឡាយណា ដែលត្រូវគេសង្ស័យថាយកការណ៍ ឬជាប់ពាក់ព័ន្ធ ជាមួយខ្មាំងរបស់ ប.ក.ក។ ភ័ស្តុតាងបញ្ជាក់ពីចេតនារើសអើងគឺមានក្នុងចំណោមប្រភពផ្សេងៗ ទៀតនោះមាន នៅក្នុងសៀវភៅកំណត់ហេតុរបស់កម្មាភិបាល ដែលរៀបរាប់ពីការបណ្ដុះបណ្ដាលនយោបាយ ចំពោះអ្នកសួរចម្លើយនៅមន្ទីរស-២១។

## ការរំលោភផ្លូវភេទ

១៤៤៣- ភ័ស្តុតាងនៅក្នុងសំណុំរឿងបានបង្ហាញថា ការរំលោភផ្លូវភេទជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដែលបានប្រព្រឹត្តក្នុងអំឡុងរយៈ ពេលកម្ពុជាប្រជាធិបតេយ្យ។

## អំពើសកម្ម និងអំពើអកម្ម

១៤៤៤- ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនស៊ីវិលរាប់ពាន់នាក់ គឺជាជនរងគ្រោះនៃអំពើ រំលោភបំពានផ្លូវភេទ និងការដាក់ទណ្ឌកម្មផ្លូវភេទយ៉ាងឃោរឃៅ ដែលរដ្ឋអំណាចនេះបាន ប្រព្រឹត្ត បានយល់ព្រម ឬបានបណ្តោតបណ្តោយឲ្យកើតមានឡើង។

### *ការកើតមាននូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

១៤៤៥- ប្រជាជនរាប់ពាន់នាក់ គឺជាជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ ដែលបានប្រព្រឹត្ត និងបង្ខំដោយ រដ្ឋអំណាចរបស់ ប.ក.ក ដោយការអនុវត្តនូវគោលនយោបាយរបស់បក្សឲ្យមានការរៀប អាពាហ៍ពិពាហ៍ដោយបង្ខំ។ ការរំលោភផ្លូវភេទកើតឡើង៖ (១)ក្នុងពេលដែលមានការរៀប

អាពាហ៍ពិពាហ៍ដោយបង្ខំ ធ្វើឡើងរវាងគូភាគីដែលមិនព្រមព្រៀងគ្នា និង(២) ករណីដែលស្ត្រីត្រូវបង្ខំឱ្យរៀបការ ជាមួយយុទ្ធជន ឬកម្មាភិបាលដែលពួកគេបានជ្រើសរើសស្ត្រីទាំងនោះ។

១៨៤៦- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំធ្វើឡើងនៅតាមភូមិ-ឃុំនានា នៅតាមអង្គភាពយោធា និងនៅតាមក្រសួងផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ។ មានករណីជាច្រើន ដែលពួកគេមានការពាក់ព័ន្ធជាមួយនឹងការរៀបចំដៃគូរៀបការដោយគ្មានការព្រាងទុក ធ្វើឡើងដោយកម្មាភិបាល ប.ក.ក ជាន់ខ្ពស់នៅក្នុងពិធីផ្សំផ្គុំអាពាហ៍ពិពាហ៍ធំៗ។ ជាទូទៅការចាប់រំលោភផ្លូវភេទកើតឡើងបន្ទាប់ពីការធ្វើពិធីទាំងនោះ ដែលយ៉ាងហោចណាស់ ដៃគូរៀបការដែលមិនបានព្រមព្រៀងនោះ ហើយមានករណីជាច្រើនដៃគូទាំងពីរនាក់នោះ ត្រូវបង្ខំឱ្យប្រព្រឹត្តផ្លូវភេទដោយមិនមានការយល់ព្រម។ ទោះបីជាគូស្វាមីភរិយាទាំងនោះ បានរស់នៅបែកគ្នាក៏ដោយ ក៏ពួកគេត្រូវបានមេឃុំបង្ខំជាហូរហែរ ឱ្យប្រតិព័ទ្ធនាពេលរាត្រី (ករណីដូចជាសហករណ៍ស្រុកត្រាំកក់)។

១៨៤៧- ជនរងគ្រោះបានប្រព្រឹត្តនូវការស៊កបញ្ចូលប្រដាប់ភេទ ដោយភាពភ័យខ្លាចចំពោះការដាក់ទោសធ្ងន់ធ្ងរ។ អ្នកដែលមិនព្រមធ្វើតាម ត្រូវទទួលការដាក់ទណ្ឌកម្មផ្សេងៗទៀត ដូចជា ការវាយដំទារុណកម្ម រំលោភផ្លូវភេទ ឬក៏ករណីខ្លះត្រូវប្រហារជីវិត។ មានករណីមួយចំនួន ពួកឈ្លបមូលដ្ឋានបានមកលួចស្តាប់នៅឯផ្ទះរបស់ជនរងគ្រោះ ដែលគេបានរៀបចំសម្រាប់ដៃគូអាពាហ៍ពិពាហ៍ដោយបង្ខំដើម្បីបង្ខំឱ្យមានការរួមសង្វាស។ មានការរាយការណ៍ឱ្យថ្នាក់មជ្ឈិមបក្ស អំពីការចុះសម្រុងក្នុងការរួមសង្វាសរវាងដៃគូដែលគេរៀបការឱ្យនោះ ឬយ៉ាងណានោះ ព្រមទាំងរាយការណ៍លម្អិតពីការជំទាស់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ។

១៤៤៨- មានករណីជាច្រើនដែលរដ្ឋអំណាច ប.ក.ក បានអនុញ្ញាតឱ្យទាហាន ឬកម្មាភិបាលខ្លួនជ្រើសរើស ដៃគូរៀបការដោយបង្ខំម្នាក់ ជារង្វាន់ចំពោះការដែលពួកគេបានលះបង់ និងរួមចំណែកសម្រាប់បដិវត្ត។ ស្ត្រីមួយចំនួនមកពីឃុំផ្សេងៗនៃស្រុកត្រាំកក់ ត្រូវបានបញ្ជូនទៅកំពង់សោមដើម្បីរៀបការជាមួយយុទ្ធជនពិការ តាមសំណូមពររបស់យុទ្ធជន។ នៅតាមអង្គភាព និងឃុំផ្សេងៗ សំណូមពររបស់យុទ្ធជន ដើម្បីរៀបការជាមួយស្ត្រីតាមបំណងរបស់ខ្លួននោះ ត្រូវបានប្រធានអង្គភាពនារី ឬមជ្ឈិមបក្សទទួលយល់ព្រម។

*នៅតាមមន្ទីរសន្តិសុខនានា*

១៤៤៩- ករណីរំលោភផ្លូវភេទនៅតាមមន្ទីរសន្តិសុខផ្សេងៗ (ជួនកាលប្រព្រឹត្តឡើងដោយរដ្ឋអំណាចរបស់ ប.ក.ក នៅតាមមូលដ្ឋាន) ត្រូវបានធ្វើការស៊ើបអង្កេតរកឃើញថា៖ មានការរំលោភផ្លូវភេទលើអ្នកទោសជាស្ត្រីភេទ ធ្វើឡើងដោយអ្នកសួរចម្លើយ និងអ្នកយាម ដូចជា (**មន្ទីរសន្តិសុខសង់ ក្រាំងតាចាន់**) មានការជ្រើសរើសស្ត្រីដែលគេចោទថាបានលួច ដែលបណ្តាលអោយគេចាប់យកទៅរំលោភផ្លូវភេទ (**ខេត្តសៀមរាប**) រំលោភហើយ និង/ឬកាត់អវៈយវៈភេទរបស់ជនរងគ្រោះមុនធ្វើការប្រហារជីវិតពួកគេ (**មន្ទីរសន្តិសុខព្រៃដំរីស្រុត វត្តធ្លក សៀមរាប** និង**នៅស្រុកភ្នំសំពៅ**) ឬយកឈើរុកចូលទៅក្នុងប្រដាប់ភេទស្ត្រី ដែលជាជនរងគ្រោះ (**សហ-២១**) និងការរំលោភផ្លូវភេទលើបុគ្គលិកដែលជានារីភេទ (**សហ-២១**)។

*ចំពោះពុទ្ធសាសនិក*

១៤៥០- ជាផ្នែកមួយនៃគោលនយោបាយរបស់ ប.ក.ក ឱ្យមានការរៀបការដោយបង្ខំ ព្រមទាំងគោលនយោបាយឱ្យលុបបំបាត់ព្រះពុទ្ធសាសនានោះ ព្រះសង្ឃត្រូវបង្ខំឱ្យរៀបការ និងឱ្យប្រព្រឹត្តការរួមសង្វាស ដែលអំពើនេះ បំពាននឹងវិន័យមិនឱ្យព្រះសង្ឃសេពមេថុន។

*ចំពោះជនជាតិចាម*

១៤៥១- ភ័ស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា រដ្ឋអំណាចរបស់ ប.ក.ក បានដាក់ទណ្ឌកម្មប្រឆាំងនឹងជនជាតិចាម តាមរយៈការបង្ខំស្ត្រីចាមឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងដៃគូដែលមិនមែនជាជនជាតិចាម។ ជាងនេះទៅទៀត ដូចមានការរៀបរាប់ពីខាងលើនៅក្នុងផ្នែកការធ្វើមនុស្សឃាត មានស្ត្រីចាមក្មេងៗជាច្រើននាក់ ត្រូវបានរំលោភផ្លូវភេទមុនពេលគេប្រហារជីវិត នៅក្នុងស្រុកក្រូចឆ្មារ។

**ចេតនា**

១៤៥២- ការរួមសង្វាសដោយបង្ខំ ត្រូវបានអនុវត្តឡើងជាប្រព័ន្ធ ដែលជាការអនុវត្តនូវគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ រដ្ឋអំណាច ប.ក.ក មានគោលបំណងឱ្យអនុវត្ត ឱ្យមានប្រសិទ្ធភាពលើការរួមសង្វាស ហើយខ្លួនបានដឹងថា ឬអាចដឹងថា ឬដឹងពីផលវិបាកថា អំពើរួមសង្វាស នោះបានកើតឡើងដោយគ្មានការព្រមព្រៀងពីជនរងគ្រោះឡើយ។ ការមិនមានការព្រមព្រៀងគ្មានេះ វាមានលក្ខណៈច្បាស់លាស់ដែលរដ្ឋអំណាច ប.ក.ក បានដាក់ឱ្យជនរងគ្រោះទៅជាទាសករ ហើយខ្លួនបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត ចំពោះអ្នកដែលមិនអនុវត្តតាម។

១៤៥៣- ពួកអ្នកស្លូរចម្លើយ អ្នកយាម ព្រមទាំងកម្មាភិបាល ប.ក.ក ដែលបានប្រព្រឹត្តអំពើរំលោភផ្លូវភេទទាំងនោះមានគោលបំណងប្រព្រឹត្តអំពើរំលោភផ្លូវភេទលើជនរងគ្រោះ ហើយខ្លួនបានដឹងថាជនរងគ្រោះមិនបានព្រមព្រៀងឱ្យមានការរំលោភផ្លូវភេទនោះទេ។ ក្នុងនោះ ការមិនព្រមព្រៀងពីជនរងគ្រោះ បានបង្ហាញតាមរយៈ ការឃុំខ្លួនជនរងគ្រោះ ការប្រើកម្លាំង ឬបង្ខំដើម្បីរំលោភ

ផ្លូវភេទឲ្យបានសម្រេច ព្រមទាំងឆ្លៀតឱកាសបង្ខំឲ្យយល់ព្រម បើសិនជាជនរងគ្រោះមិនយល់ព្រមទេនោះ។

## ការធ្វើទុក្ខបុកម្នេញ

១៤៥៤- ភស្តុតាងក្នុងសំណុំរឿងក្តីបង្ហាញពីការធ្វើទុក្ខបុកម្នេញ ផ្អែកនយោបាយ ជាតិសាសន៍ និង/ឬសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។

១៤៥៥- អំពើជាច្រើនដែលបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សនឹងជាតិផ្សេងៗទៀតនោះ ត្រូវបានរៀបរាប់នៅក្នុងផ្នែកនេះ ក៏ជាអំពើរួមចំណែកចំពោះការធ្វើទុក្ខបុកម្នេញ ដែលជាញឹកញាប់ ពួកគេតែងតែបដិសេធសិទ្ធិជាមូលដ្ឋាននានារបស់ជនរងគ្រោះ ដោយផ្អែកលើទស្សនៈនយោបាយយល់ឃើញ ឬទស្សជាក់ស្តែងរបស់ពួកគេ ដោយផ្អែកទៅលើសាសនា និង/ឬពូជសាសន៍ជាដើម។ អំពើទាំងនេះរួមមាន ការឃុំខ្លួន ការធ្វើទារុណកម្ម មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការរំលោភផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងៗជាច្រើនទៀត។

### ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ

*អំពើសកម្ម និងអំពើអកម្ម*

១៤៥៦- ទោះបីជា ប.ក.ក បានចាត់ទុកថា ប្រជាជនស៊ីវិលទាំងអស់គឺជាខ្មាំងនយោបាយដ៏មានសក្តានុពលក៏ដោយ ក៏ប្រជាជនថ្មី អតីតមន្ត្រីសាធារណរដ្ឋខ្មែរ និងបណ្តា "ខ្មាំង" នយោបាយផ្សេងៗទៀត ព្រមទាំង "ជនក្បត់" ត្រូវបានរើសអើងដោយសារគោលនយោបាយរបស់ពួកគេប្រឆាំងទៅនឹង ប.ក.ក។ ដូចមានរៀបរាប់នៅក្នុងផ្នែកមនុស្សឃាតរួចមកហើយ ក្នុងអំឡុងពេលនៃការជម្លៀស

លើកទីមួយ មន្ត្រីសាធារណរដ្ឋខ្មែរ និងប្រជាជនថ្មីជាច្រើនពាន់នាក់ ត្រូវបានជ្រើសរើស និងសម្លាប់ចោលដោយឡែក ឬជារួម (រួមមាន **ទួលពោធិ៍ជ្រៃ** និងស្រុកកំពង់**ត្រឡាចលើ**)។ ប្រជាជនថ្មីភាគច្រើនគឺជាជនស៊ីវិលដែលមានចំនួនច្រើនជាងមួយលាននាក់ ត្រូវបានបង្ខំឱ្យជម្លៀសចេញក្នុងអំឡុងពេលជម្លៀសចេញលើកទីពីរ។ អតីតកម្មាភិបាលខ្មែរក្រហម និងប្រជាជនថ្មី ត្រូវបានគេចាត់ទុកជាគោលដៅពិសេសសម្រាប់ការចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរសន្តិសុខនានា នៅពេលដែលពួកគេ ទៅដល់ភូមិភាគឧត្តរ ភូមិភាគកណ្តាល និងភូមិភាគពាយ័ព្យ ហើយពួកគេគឺជាទិសដៅនៃការបោសសម្អាតលក្ខណៈជាប្រព័ន្ធនៅក្នុងភូមិភាគឧត្តរថ្មីក្នុងឆ្នាំ១៩៧៨។ ប្រជាជនថ្មីដែលត្រូវធ្វើការជាពលករប្រើកម្លាំងដោយបង្ខំនៅតាមបណ្តាការដ្ឋាននានារបស់ ប.ក.ក នោះ ត្រូវបានជ្រើសយកទៅសម្លាប់ (**ទំនប់១មករា** និង **ទំនប់ត្រពាំងថ្ម**)។ មន្ទីរសន្តិសុខនានា ក៏បានចាប់ខ្លួន ធ្វើទារុណកម្ម ព្រមទាំងសម្លាប់ប្រជាជនថ្មី (រួមមាន **មន្ទីរស-២១ កោះខ្យង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច និងសៀមរាប**) ព្រមទាំងកម្មាភិបាលខ្មែរក្រហម (**ស-២១ ព្រៃដំរីស្រុត ចន្លោះក្តោង សៀមរាប**)។

១៤៩៧- ដូចមានរៀបរាប់នៅក្នុងផ្នែកធ្វើទារុណកម្មខាងលើរួចមកហើយ មន្ទីរសន្តិសុខនានា (ដែលមានតួនាទីជាស្ថាប័នមជ្ឈិមនៃក្បាលម៉ាស៊ីនរបស់ប.ក.ក ក្នុងការកម្ចាត់ចោលគូបដិបក្ខនយោបាយនោះ) បានដាក់គុក ធ្វើទារុណកម្ម និងសម្លាប់ខ្មាំងនយោបាយសក្តានុពល ជនដែលគេយល់ឃើញថា ជាខ្មាំងជាក់ស្តែង របស់ប.ក.ក។ ខ្មាំងទាំងនេះ ត្រូវបានមជ្ឈិមបក្សរបស់ ប.ក.ក កំណត់មួយផ្នែក ដោយផ្អែកលើចម្លើយសារភាពដែលធ្វើឡើងដោយបង្ខំនៅមន្ទីរស-២១។ គោលបំណងនៃការឃុំខ្លួន ដែលបានរៀបរាប់នៅក្នុងផ្នែកឃុំខ្លួននោះ បញ្ជាក់ពីមូលហេតុជម្រុញផ្នែកនយោបាយ ឱ្យមានការចាប់ខ្លួនជនរងគ្រោះមួយចំនួនធំ។ ជនទាំងឡាយដែលជាប់ឃុំ

ត្រូវបង្ខិតបង្ខំឱ្យបង្ហាញប្រាប់ពីព័ត៌មានអំពីខ្មាំងនយោបាយ ដែលគេសន្មតផ្សេងៗទៀត តាមរយៈការធ្វើទារុណកម្ម (**មន្ទីរស-២១ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច ភ្នំក្រោល វត្តធ្លក អូរកន្សែង** និង**សៀមរាប**)។ ការបោសសម្អាតមួយចំនួនធំដែលស្ថិតក្រោមការស៊ើបអង្កេត (ស្ថិតក្នុង**ភូមិភាគឧត្តរ** និង**ភូមិភាគបូព៌ា**នោះ) ត្រូវបានប្រព្រឹត្តឡើងដើម្បីកំណត់អត្តសញ្ញាណ ព្រមទាំងសម្លាប់ខ្មាំងនយោបាយដែលមានសក្ដានុពលពិតប្រាកដរបស់ ប.ក.ក ផងដែរ។

១៤៥៨- ជាចុងក្រោយ ដូចមានរៀបរាប់នៅក្នុងផ្នែកអំពើអមនុស្សធម៌ផ្សេងៗទៀត នៅតាមទីតាំងប្រើកម្លាំងពលកម្មដោយបង្ខំ កម្មាភិបាលប.ក.ក បានជ្រើសរើសជនទាំងឡាយណា ដែលចាត់ទុកថាជាខ្មាំងនយោបាយរបស់ ប.ក.ក (**សហករណ៍ត្រាំកក់** និង **ទំនប់ត្រពាំងថ្ម**) សម្រាប់ការប្រព្រឹត្តិអំពើរើសអើង ព្រមជាមួយនឹងការដាក់ទោសចំពោះពួកគេ។ ពលករជាច្រើនត្រូវចាប់ខ្លួន និងយកចេញពីទីតាំងប្រើពលកម្មដោយបង្ខំ (**សហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម ស្រែអំបិល ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង**) ដោយផ្អែកលើមូលហេតុនយោបាយផ្សេងៗជាច្រើន។

*ចេតនា*

១៤៥៩- ភស្តុតាងបានបង្ហាញថា ចារីទាំងឡាយមានឆន្ទៈក្នុងការប្រព្រឹត្តអំពើធ្វើទុក្ខបុកម្នេញនានា ដូចមានរៀបរាប់ពីខាងលើ ព្រមជាមួយនឹងចេតនារើសអើងចំពោះជនរងគ្រោះនានាដោយផ្អែកលើមូលហេតុនយោបាយ។ អំពើទាំងនេះត្រូវបានប្រព្រឹត្តតាមរយៈការអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់អត្តសញ្ញាណ ដាក់ការគាបសង្កត់ និង លុបបំបាត់ចោលនូវពួកសត្រូវ

នយោបាយរបស់ខ្លួន និងជនទាំងឡាយដែលមិនដើរតាមមនោគមនយោបាយរបស់ខ្លួន រួមមាន (១)ប្រជាជនថ្មី និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និង(២)កម្មាភិបាល ប.ក.ក និងសាមាជិកនានានៃប្រជាជនទូទៅ ដែលត្រូវចោទប្រកាន់ពីការប្រឆាំង ឬស្មោះភក្ដីចំពោះខ្មាំងខាងនយោបាយរបស់ ប.ក.ក។

## ការធ្វើទុក្ខបុកម្នេញសាសនា

### *អំពើសកម្ម និងអំពើអកម្ម*

១៤៦០- អំពើធ្វើទុកបុកម្នេញ ដែលត្រូវបានរើសអើងដោយផ្អែកលើសាសនា ក៏ត្រូវបានប្រព្រឹត្តទៅលើសមាជិកនៃប្រជាជនស៊ីវិលទាំងមូលផងដែរ។ ពុទ្ធសាសនិកទាំងពីរប្រភេទ ត្រូវបានធ្វើទុក្ខបុកម្នេញ តាមរយៈឧក្រិដ្ឋកម្មជាក់លាក់ផ្សេងៗជាច្រើន ដែលបានរៀបរាប់រួចមកហើយ (មនុស្សឃាត ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការឃុំខ្លួន ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) ក៏ដូចជាតាមរយៈការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបំផ្លិចបំផ្លាញយ៉ាងទូលំទូលាយ ទៅលើទ្រព្យសម្បត្តិសាសនា។ អំពើទាំងនេះបានបង្ហាញឲ្យ ឃើញនូវការបដិសេធដោយឥតលាក់លៀម ចំពោះសិទ្ធិមនុស្សជាមូលដ្ឋាននានារបស់ជនរងគ្រោះ រួមមានសិទ្ធិមានសេរីភាព និងសុវត្ថិភាពរបស់បុគ្គល សិទ្ធិមានសេរីភាពក្នុងការធ្វើសកម្មភាព ព្រមទាំងសិទ្ធិចំពោះសាសនា។ មូលហេតុនៃការរើសអើងចំពោះអំពើដូចបានរៀបរាប់ពីខាងលើ គឺជាភស្តុតាងពីការធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក ព្រមទាំងជនជាតិចាមមូស្លីមគោលដៅក្នុងលក្ខណៈជាប្រព័ន្ធ។

*ចំពោះពុទ្ធសាសនិក*

១៤៦១- ពុទ្ធសាសនិក និងព្រះសង្ឃដែលប្រតិបត្តិពុទ្ធសាសនា ត្រូវបានសម្លាប់ ក្រោយពី ប.ក.ក បានចូលកាន់អំណាច (**វត្តអន្លង់វៀន វត្តជ័យមង្គល វត្តតាគាត់មង្គល** និង**ភ្នំពេញ**)។ ព្រះសង្ឃត្រូវបានបង្ខំ ឱ្យផ្សឹក ដោយត្រូវគេគម្រាមសម្លាប់ (**វត្តអន្លង់វៀន វត្តចម្បក់ធំ វត្តដំណាក់ត្រយឹង វត្តសំរោងក្នុង វត្តតាគាត់មង្គល**) ត្រូវគេបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ព្រមទាំងត្រូវគេបង្ខំឱ្យប្រើពលកម្មដោយបង្ខំ និងឃុំខ្លួន (រួមមាន **ស្រុកឯកភ្នំ ស្រុកបន្ទាយមាស ស្រុកក្រចេះ** និង **ស្រុកសេសាន**)។ ព្រះសង្ឃ ក៏ត្រូវគេបង្ខំឱ្យចូលរួមក្នុងការប្រកបរបរ ដែលជាការហាមប្រាមពួកគាត់ ដូចជា បម្រើជាទាហាន និងធ្វើស្រែចម្ការ (**វត្តអន្លង់វៀន វត្តសំរោងក្នុង**)។ ទីសក្ការៈតាមបែបពុទ្ធសាសនានានាត្រូវបានបំផ្លាញ និងប្រែក្លាយទៅជាកន្លែងប្រើប្រាស់មិនមែនសម្រាប់សាសនា (រួមមាន **វត្តអន្លង់វៀន វត្តចម្បក់ធំ វត្តដំណាក់ត្រយឹង វត្តសំរោងក្នុង វត្តតាគាត់មង្គល** និង**ស្ថិតនៅក្នុងសហករណ៍ត្រាំកក់**) និងគ្រឿងជាទីសក្ការៈសម្រាប់បូជាតាមបែបព្រះពុទ្ធសាសនា ត្រូវបានបំផ្លាញ (នៅ**វត្តអន្លង់វៀន វត្តដំណាក់ត្រយឹង វត្តសំរោងក្នុង**)។

*ចំពោះជនជាតិចាម*

១៤៦២- ភូមិកររបស់ជនជាតិចាមត្រូវបានបំផ្លាញ ហើយអ្នកភូមិរបស់ពួកគេ ត្រូវបានបង្ខំឱ្យបែកចេញពីសហគមន៍របស់ខ្លួន។ បុរសចាមត្រូវបានគេបំបែកចេញពីស្ត្រី និងកុមារចាម។ ស្ត្រីចាមជាច្រើន ត្រូវបានបង្ខំឱ្យរៀបការជាមួយបុរសដែលមិនមែនជាជនជាតិចាម។ ប្រពៃណី ព្រមទាំងជំនឿសាសនាផ្សេងៗទាំងអស់របស់ជនជាតិចាម ក៏ដូចជាភាសាចាមផងដែរ ត្រូវបានហាមឃាត់ ហើយទ្រព្យសម្បត្តិសាសនារបស់ចាម (ដូចជាគម្ពីរឥស្លាម) ត្រូវបានបំផ្លាញ។ ថ្នាក់ដឹកនាំនៃក្រុមជនជាតិចាម បានក្លាយជាក្រុមគោលដៅជាប្រព័ន្ធក្នុងការសម្លាប់។ ដូចបានរៀបរាប់រួចមកហើយ

ស្តីពីអំពើប្រល័យពូជសាសន៍ និងអំពើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការចាប់ខ្លួន និងការសម្លាប់ទៅលើសហគមន៍ជនជាតិចាមទាំងមូលក្នុងទ្រង់ទ្រាយដ៏ធំ បានចាប់ផ្តើមឡើងពីឆ្នាំ១៩៧៧ ជាបន្តបន្ទាប់មក។ ជនជាតិចាមត្រូវបានចាប់ខ្លួន និងសម្លាប់នៅតាមបណ្តាការដ្ឋាននានា (ដូចជា **ការដ្ឋានទំនប់១មករា**) និងនៅតាមមន្ទីរសន្តិសុខផ្សេងៗ (ដូចជា **មន្ទីរសន្តិសុខក្រាំងតាចាន់**)។ ស្ត្រីចាមត្រូវបានគេរំលោភផ្លូវភេទមុនពេលសម្លាប់ (នៅក្នុង**ស្រុកក្រូចឆ្មារ**)។

*ចេតនា*

១៤៦៣- អំពើធ្វើទុក្ខបុកម្នេញដូចបានរៀបរាប់ខាងលើ បានប្រព្រឹត្តឡើងដោយមានចេតនាក្នុងការរើសអើងផ្នែកសាសនា។ ជាងនេះទៅទៀត ការដាក់ចេញនូវគោលនយោបាយ លុបបំបាត់សាសនា ប.ក.ក បានកំណត់ទិសដៅសម្លាប់ចំពោះព្រះសង្ឃអង្គណាដែលមិនគោរពតាមខ្លួន ហើយចាប់តាំងពីឆ្នាំ១៩៧៧ ប.ក.ក បានដាក់ចេញនូវគោលនយោបាយមួយក្នុងការសម្លាប់បំផុតពូជជនជាតិចាមទាំងអស់។ ចារីបានប្រព្រឹត្តអំពើដោយផ្ទាល់ ដោយផ្អែកលើគោលនយោបាយដែលមជ្ឈិមបក្សនៃប.ក.ក បានណែនាំ ហើយខ្លួនបានអនុវត្តនូវអំពើធ្វើទុក្ខបុកម្នេញទៅលើពុទ្ធសាសនិក និងជនជាតិចាម ដោយបានរៀបចំទុកជាមុន និងមានលក្ខណៈជាប្រព័ន្ធ។

## ការធ្វើទុក្ខបុកម្នេញទៅលើជាតិពន្ធុ

*អំពើសកម្ម និងអំពើអកម្ម*

១៤៦៤- ជនជាតិភាគតិច វៀតណាម និងចាម ត្រូវបានគេធ្វើទុក្ខបុកម្នេញ ដោយសារតែទស្សនៈរបស់ ប.ក.ក យល់ឃើញថា ជនជាតិទាំងនោះ មានជាតិសាសន៍ខុសគ្នាដាច់ស្រឡះពីជនជាតិខ្មែរ។

*អំពើប្រឆាំងទៅលើជនជាតិវៀតណាម*

១៤៦៥- ដូចបានរៀបរាប់រួមមកហើយនៅក្នុងផ្នែកស្តីពីអំពើប្រល័យពូជសាសន៍ មានជនជាតិវៀតណាម ក្នុងចំនួន ២០.០០០នាក់ ត្រូវបានសម្លាប់នៅក្នុងយុទ្ធនាការដ៏ធំមួយ នៅទូទាំងប្រទេស ដែលបាន ចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៧។ ការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាម បានកើតមាននៅ តាមតំបន់ផ្សេងៗ និងតំបន់ដែលស្ថិតក្រោមការស៊ើបអង្កេតដូចជាៈ **ខេត្តព្រៃវែង និងខេត្ត ស្វាយរៀង មន្ទីរសន្តិសុខស-២១ កោះខ្យង ក្រាំងតាចាន់ គោកក្ដួច វត្តផ្គក** និងភ្នំក្រោល។ ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាម ដែលបង្កឡើងដោយប.ក.ក បានរាលដាលរហូត ដល់ទីតាំងប្រើពលកម្មដោយបង្ខំ ដែលនៅទីនោះ មានជនស៊ីវិលត្រូវចាប់ខ្លួន ដោយសារពួកគេ មានទំនាក់ទំនងនឹងជនជាតិវៀតណាម ឬ "យួន" (**ទំនប់១មករា ការដ្ឋានព្រលានយន្តហោះ កំពង់ឆ្នាំង ទំនប់ត្រពាំងថ្ម**)។ ជនជាតិវៀតណាមត្រូវបានគេធ្វើទុក្ខបុកម្នេញផងដែរ នៅតាម តំបន់ផ្សេងៗ ក្រៅពីតំបន់ជាក់លាក់ទាំងនោះ ដែលស្ថិតនៅក្រោមការស៊ើបអង្កេតផងដែរ ដូចជា (ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តកំពត ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ និងខេត្តសៀមរាប)។

*អំពើប្រឆាំងនឹងជនជាតិចាម*

១៤៦៦- អំពើធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាមដូចបានរៀបរាប់ពីខាងលើ ត្រូវបានប្រព្រឹត្តឡើងដោយ សារតែរបបនេះ មានទស្សនៈយល់ឃើញថា ជនជាតិចាម គឺជាជនជាតិមួយផ្សេងខុសពី ជនជាតិខ្មែរ។

*ចេតនា*

១៤៦៧- អំពើធ្វើទុក្ខបុកម្នេញប្រឆាំងទៅលើជនជាតិចាម និងជនជាតិវៀតណាម បានប្រព្រឹត្តឡើង ដោយមានចេតនា និងជាប្រព័ន្ធ ហើយមានចេតនាក្នុងការរើសអើង ប្រឆាំងនឹងជនរងគ្រោះ ដោយសារតែសមាជិកភាពរបស់ពួកគេខុសពីជនជាតិខ្មែរ។ ក្នុងការប្រព្រឹត្តិនូវអំពើទាំងនោះ ចារីយល់ឃើញថា ពួកគេបានអនុវត្តនូវគោលនយោបាយរើសអើងជាតិសាសន៍ដែលមជ្ឈិមបក្ស ជាអ្នកកំណត់។

## អំពើអមនុស្សធម៌ផ្សេងៗទៀត

១៤៦៨- ភ័ស្តុតាងនៅក្នុងសំណុំរឿងបានបង្ហាញថា អំពើអមនុស្សធម៌ផ្សេងៗទៀត គឺជាឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា៥ នៃច្បាប់អ.វ.ត.ក ដែលអំពើ ទាំងនោះ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។

## អំពើសកម្ម និងអំពើអកម្ម

*ចំពោះការជម្លៀសដោយបង្ខំ*

១៤៦៩- ការជម្លៀសដោយបង្ខំ បង្កើតបានជាការប្រព្រឹត្តនូវអំពើអមនុស្សធម៌ក្នុងទ្រង់ទ្រាយធំ ទៅលើ ជនស៊ីវិល ដែល ប.ក.ក បានដាក់ពួកគេជាទាសករ។ ក្នុងអំឡុងពេលមានការជម្លៀសនោះ កម្មាភិបាល ប.ក.ក បានដាក់ជនស៊ីវិលជាច្រើនអោយទទួលរងនូវស្ថានភាពរស់នៅមួយដ៏សែន លំបាក ហើយប្រជាជនរាប់ពាន់នាក់ បានទទួលរងនូវអំពើឃោរឃៅ ថោកទាប និងអំពើ សាហាវយង់ឃ្នង ដែលបណ្តាលឱ្យពួកគេទទួលរងនូវការឈឺចាប់រាងកាយ ព្រមទាំងស្មារតី យ៉ាងធ្ងន់ធ្ងរ។

១៤៧០- ***ការជម្លៀសដោយបង្ខំលើកទីមួយ៖*** នៅខែមេសា ឆ្នាំ១៩៧៥ មានការជម្លៀសដោយបង្ខំ នូវប្រជាជនរស់នៅតាមបណ្តាទីប្រជុំជននានា បណ្តាលឱ្យប្រជាជនដែលត្រូវគេជម្លៀសទាំងនោះ ទទួលរងនូវស្ថានភាពរស់នៅដ៏អមនុស្សធម៌ដ៏ធ្ងន់ធ្ងរយ៉ាងខ្លាំង។ អ្នកដែលមានទីលំនៅដ្ឋាននៅតាមទីប្រជុំជននានា ត្រូវបានគេបង្ខំឱ្យចាកចេញយ៉ាងទាន់ហន់។ មិនមានការលើកលែងណាមួយនោះទេ សូម្បីតែអ្នកជម្ងឺ ក៏ត្រូវជម្លៀសចេញពីមន្ទីរពេទ្យដែរ ដោយរួមទាំងអ្នកជំងឺធ្ងន់ ឬរងរបួសធ្ងន់ធ្ងរក្តី ស្ត្រីដែលទើបតែសម្រាលកូនរួច ក៏ត្រូវបង្ខំឱ្យចូលរួមក្នុងការធ្វើដំណើរដោយថ្មើរជើងនេះដែរ។ ជនស៊ីវិលមិនត្រូវបានអនុញ្ញាតឱ្យយកមកជាមួយនូវរបស់របរ ឬធ្វើការត្រៀមលក្ខណៈនានាសម្រាប់ការធ្វើដំណើរនេះឡើយ។ ពួកគេត្រូវបានគេបង្ខំឱ្យធ្វើដំណើរក្នុងចម្ងាយឆ្ងាយ ដោយថ្មើរជើង ក្នុងអំឡុងខែដែលក្តៅខ្លាំងជាងគេបំផុតប្រចាំឆ្នាំ ដោយគ្មានការផ្តល់ទឹក ស្បៀងអាហារ ឬជម្រកឡើយ។ គ្មានការត្រៀមលក្ខណៈឱ្យមានការថែទាំតាមបែបវេជ្ជសាស្ត្រគ្រប់គ្រាន់ ដើម្បីផ្តល់ឱ្យអ្នកមានជំងឺ និងជនចាស់ជរាឡើយ។ ជនរងគ្រោះត្រូវស្ថិតនៅក្នុងសភាពភ័យខ្លាច ដោយសារតែការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ដែលបានកើតមាននៅនឹងកន្លែងចំពោះជនទាំងឡាយណាដែលមិនព្រមគោរពតាម។ ផលវិបាកនៃស្ថានភាពរបស់ជនរងគ្រោះទាំងនេះ ត្រូវបានបង្ហាញតាមរយៈការស្លាប់ក្នុងចំនួនរាប់ពាន់ ដែលបណ្តាលមកពីការអត់ឃ្លាន ការបាក់កម្លាំង ស្ថិតក្នុងស្ថានភាពរងគ្រោះ ជំងឺ និងការសម្លាប់ក្នុងអំឡុងនៃការជម្លៀសចេញ។

១៤៧១- ***ការជម្លៀសលើកទីពីរ៖*** ក្នុងអំឡុង និងភ្លាមៗក្រោយពីការជម្លៀសដោយបង្ខំ ដែលចាប់ផ្តើមក្នុងខែ កញ្ញា ឬដើមខែតុលា ឆ្នាំ១៩៧៥ ជនស៊ីវិលរាប់រយរាប់ពាន់នាក់ ត្រូវបានគេប្រព្រឹត្តអំពើអមនុស្សធម៌យ៉ាងកម្រោល និងស្ថានភាពដែលឆ្លុះបញ្ចាំងពីអំពើទាំងឡាយដែលបានរៀបរាប់ពី

ខាងលើ។ ជនស៊ីវិលបានស្លាប់ដោយសារការអត់ឃ្លាន ជំងឺ ស្ថិតក្នុងស្ថានភាពរងគ្រោះ និង បាក់កម្លាំង។ មានករណីជាច្រើនប្រជាជនត្រូវបានគេរុញចូលក្នុងទូររថភ្លើង និងឡាន បណ្តាល អោយស្លាប់ដោយថប់ដង្ហើម។ ប.ក.ក បានបន្តដាក់ចេញនូវស្ថានភាពអមនុស្សធម៌យ៉ាងកម្រោល ទៅលើជនរងគ្រោះ ក្រោយពីពួកគេបានធ្វើដំណើរមកដល់ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ។ គ្មានការផ្តល់នូវស្បៀងអាហារ ជម្រក ជំនួយជាថ្នាំសង្កូវ និងអនាម័យឲ្យបានគ្រប់គ្រាន់ឡើយ។ ជនស៊ីវិលចំនួនរាប់ម៉ឺននាក់ ត្រូវបង្ខំឲ្យជម្លៀសទៅតាមភូមិនានា ភូមិកំណើតទាំងនោះ មុនថ្ងៃ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានប្រជាជនរស់នៅតែប៉ុន្មានរយនាក់ប៉ុណ្ណោះ (ស្រុកភ្នំស្រុក ស្រុក ព្រះនេត្រព្រះ ភូមិភាគពាយ័ព្យ)។ ប្រជាជនក្នុងចំនួន២០០០០នាក់ បានអត់ឃ្លានរហូតដល់ស្លាប់ ក្រោយពីការជម្លៀសពួកគាត់ទៅស្រុកព្រះនេត្រព្រះ (ភូមិភាគពាយ័ព្យ)។ ការជម្លៀសនេះត្រូវ បានប្រព្រឹត្តទៅដោយបង្ខំ និងមានអ្នកយាមប្រដាប់ដោយអាវុធ ជាមួយនឹងការប្រើប្រាស់នូវការ គំរាមកំហែង ព្រមទាំងដាក់ទណ្ឌកម្មនានា រួមមានការសម្លាប់ ចំពោះបុគ្គលទាំងឡាយ ដែលបដិសេធមិនព្រមធ្វើតាម។

១៤៧២- **ការជម្លៀសដោយបង្ខំលើកទី៣៖** ប្រជាជនសាមញ្ញ និងកម្មាភិបាលចំនួនរាប់ពាន់នាក់ ដែលខ្មែរ ក្រហមបានជម្លៀសក្រោមកាណុងកាំភ្លើងចេញពីភូមិភាគបូព៌ាទៅឆ្នាំ១៩៧៨ គឺជាជនរងគ្រោះពី រលកចុងក្រោយនៃការបោសសម្អាត ក្រោមគំនិតផ្តួចផ្តើមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា។ មនុស្សទាំងនេះជាប់សង្ស័យពីបទក្បត់ ដោយសារពួកគាត់ រស់នៅទីនោះ និងត្រូវបានខ្មែរក្រហមចាត់ទុកថាជាមនុស្ស "ក្បាលយួន ខ្លួនខ្មែរ"។ ដូច្នេះក្នុង អំឡុងពេលនៃការជម្លៀសដោយបង្ខំនេះ ប្រជាជនទាំងអស់ស្ថិតក្រោមស្ថានភាពអមនុស្សធម៌ ដូចដែលបានរៀបរាប់ពីខាងលើផង និងបានរងគ្រោះពីការធ្វើបាប និងការគំរាមសម្លាប់ជាប់ជា

ប្រចាំផង។ ពួកគេត្រូវបានបំបែកទៅកាន់ភូមិភាគផ្សេងៗទូទាំងប្រទេសដូចជា ភូមិភាគកណ្ដាល ភូមិភាគឧត្ដរ ភូមិភាគព្លៀសាន និងភូមិភាគពាយ័ព្យជាដើម។ ប្រជាជនរាប់ម៉ឺននាក់បានស្លាប់ ដោយភាពអត់ឃ្លាន ការបាក់កម្លាំង នៅពេលពួកគាត់បានធ្វើដំណើរមកដល់គោលដៅកំណត់ ដែលការស្លាប់ទាំងនេះបណ្ដាលមកពីរដ្ឋអំណាចពុំព្រម ឬពុំបានផ្ដល់អាហារគ្រប់គ្រាន់ដល់ ពួកគាត់ដែលត្រូវបានជម្លៀសដោយបង្ខំក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់។

*នៅតាមការដ្ឋានធ្វើការងារពលកម្មដោយបង្ខំ*

១៤៧៣- កម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា បានដាក់ប្រជាជនស៊ីវិលបង្ខាំងតាមការដ្ឋានធ្វើពលកម្មដោយ បង្ខំនានា ក្រោមកិច្ចស៊ើបសួរ (**សហករណ៍ត្រាំកក់ ស្រែអំបិល ទំនប់១មករា ទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្ដហោះកំពង់ឆ្នាំង**) ឱ្យទទួលរងគ្រោះក្រោមស្ថានភាពដ៏អមនុស្សធម៌ និងការរំលោភបំពានផ្លូវចិត្ត និងផ្លូវកាយ ដែលបានបណ្ដាលឱ្យជនរងគ្រោះចំនួនរាប់ពាន់នាក់ បានទទួលរងព្យសនកម្មយ៉ាងធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្ត។

១៤៧៤- គោលនយោបាយមួយក្នុងចំណោមបណ្ដាគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ដែល បានផ្សព្វផ្សាយជាសាធារណៈនោះ គឺការប្រកែកពុំព្រមនាំចូលនូវម៉ាស៊ីនគ្រឿងចក្រ និងសម្ភារៈ បច្ចេកទេសឱ្យបានគ្រប់គ្រាន់ និងការមានៈក្នុងការប្រើប្រាស់កម្លាំងពលកម្មមនុស្សធ្វើដោយដៃ ដោយបង្ខំ។ ពលករដែលខ្មែរក្រហមយកធ្វើជាទាសករនៅតាមការដ្ឋានក្រោមកិច្ចស៊ើបសួរ បាន ត្រូវខ្មែរក្រហមដាក់ឱ្យស្ថិតនៅក្រោមការធ្វើការងារពលកម្មយ៉ាប់យ៉ឺនជាច្រើនរូបភាព ដូចជា៖ រែកដី ជីកដី រើសអាចម៍គោ លើកទំនប់ និងសាងសង់ស្ពាន (សហករណ៍ត្រាំកក់) ជីកប្រឡាយ លើកភ្លឺ គាស់ដី ភ្ជួររាស់ រែកអំបិលបាវធំៗ (**ស្រែអំបិល**) ជីកប្រឡាយ និងអាងស្ដុកទឹក និងរែកដី

(**ទំនប់១មករា**) រែកដី និងភ្ជិតទំនប់ (**ទំនប់ត្រពាំងថ្ម**) និង ធ្វើស្រែ ឆ្ការព្រៃ វាយបំបែកថ្ម រែកថ្ម និងក្រាលថ្ម ពង្រាបដី រែកស៊ីម៉ង់ត៍ ខ្សាច់ បេតុង ជីកប្រឡាយ និងសង់បំពង់លូទឹកស្អុយ (**ព្រលានយន្តហោះកំពង់ឆ្នាំង**)។ មនុស្សធ្វើការងារពលកម្មដោយបង្ខំទាំងនោះមានប្រុស មានស្រី (រួមទាំងស្ត្រីមានគភ៌) កុមារ និងមនុស្សចាស់។ ពលករត្រូវបានបង្ខំឲ្យធ្វើការជាច្រើនម៉ោង (ចំនួន១០ ទៅ១២ម៉ោង ឬជួនកាលមួយថ្ងៃលើស១៥ម៉ោង) ដោយធ្វើការហាលវាលហាលខ្យល់ ឬគ្មានម្ហូបអាហារ និងគ្មានពេលសម្រាកគ្រប់គ្រាន់។

១៨៧៥- ស្ថានភាពការងារ និងអនាម័យ មានលក្ខណៈពុំគ្រប់គ្រាន់ខ្លាំង និងអមនុស្សធម៌។ ពលករពុំអនុញ្ញាតឲ្យដើរហើរ ឬប្រាស្រ័យទាក់ទងគ្នាដោយសេរីឡើយ ហើយឆ្មាំប្រដាប់អាវុធជាអ្នកតាមដាន និង/ឬ ត្រួតពិនិត្យ (**ស្រែអំបិល ទំនប់១មករា ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង**)។ ការដ្ឋានការងារត្រូវបានទុកឲ្យស្ថិតនៅក្រោមស្ថានភាពគ្មានអនាម័យ និងរំខានទៅដោយសត្វល្អិត (**ទំនប់១មករា ទំនប់ត្រពាំងថ្ម**)។ កន្លែងរស់នៅមានមនុស្សច្រើនលើសចំនួន និងស្ថិតនៅហាលវាលហាលខ្យល់ ឬការរំខានពីសត្វល្អិតចង្រៃ (**ទំនប់១មករា ទំនប់ត្រពាំងថ្ម ស្រែអំបិល**)។ ពុំមានការផ្តល់ម្ហូបអាហារឲ្យបានគ្រប់គ្រាន់ ជាទូទៅក្នុងរបបអាហារចំនួន២ពេល មានបបររាវ ឬបាយ បន្លែ ត្រីងៀត ត្រីប្រឡាក់ ក្នុងបរិមាណតិចតួចស្តួចស្តើង។ ពលករនៅ**ទំនប់១មករា** ដែលបានជាប់ឃុំឃាំងនៅ **វត្តបារាយជាន់ដែក** បានទទួលអង្ករមួយកំប៉ុង ឬបបរពីរបីវែក សម្រាប់មនុស្ស៥នាក់។ **នៅស្រែអំបិល** អ្នកណាដែលគ្មានកម្លាំងធ្វើការងារដោយសាររបួស ឬជំងឺ ត្រូវបានកាត់បន្ថយរបបអាហារមួយចំនួនធំ ឬពុំឲ្យអាហារហូបសោះតែម្តង។

១៤៧៦- ស្ថានភាពទាំងនេះបានបណ្តាលឱ្យសុខភាពពលករទាំងអស់ធ្លាក់ទ្រុឌទ្រោម។ របួស និងមានជំងឺផ្សេងៗដូចជា គ្រុនចាញ់ អាសន្នរោគ និងរាគមួល បានរីករាលដាលគ្រប់ទីកន្លែង (**ស្រែអំបិល ទំនប់១មករា ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង**)។ ដោយសារការគ្មាន ឬកង្វះការថែទាំវេជ្ជសាស្ត្រ ទើបបានធ្វើឱ្យស្ថានភាពទាំងអស់នេះកាន់តែមានលក្ខណៈយ៉ាប់យ៉ឺនថែមមួយកម្រិតទៀត។ បើទោះបីជាមានថ្នាំសង្កូវ ក៏ថ្នាំទាំងនោះគ្មានប្រសិទ្ធភាពដែរ (**ព្រលានយន្តហោះកំពង់ឆ្នាំង ស្រែអំបិល សហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម**)។ ក្នុងករណីមានការផ្តល់ថ្នាំសង្កូវ បុគ្គលិកពេទ្យដែលគ្មានការបណ្តុះបណ្តាលជាអ្នកត្រួតពិនិត្យ (**កំពង់ឆ្នាំង ស្រែអំបិល ទំនប់ត្រពាំងថ្ម**)។ ទីបំផុត ការស្លាប់របស់មនុស្សរាប់ពាន់នាក់ត្រូវបានបង្កឡើងដោយភាពអត់ឃ្លាន ការធ្វើការបាក់កម្លាំង និងជំងឺតម្កាត់ ហើយអ្នកទោសក៏បានស្លាប់ដោយសារការប៉ុនប៉ងលួចរត់ដែលមិនបានសម្រេច និងការធ្វើអត្តឃាត (**ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង និងស្រែអំបិល**)។

១៤៧៧- ពលករបានស្ថិតក្រោមការបំភិតបំភ័យ ការបន្ទាបបន្ថោក និងការដាក់ទណ្ឌកម្មតាមអំពើចិត្តជាប្រចាំពីកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ ពួកគាត់ត្រូវបានបង្ខំឱ្យចូលរួមប្រជុំមហាជនដែលក្នុងអង្គប្រជុំ ពួកគាត់បានរងការទិតៀនថាខ្ជិល និងត្រូវបានបង្ខំឱ្យធ្វើស្វ័យទិតៀន និងទិតៀនអ្នកដទៃ និង/ឬទទួលការណែនាំឱ្យខំប្រឹងធ្វើការ (**សហករណ៍ត្រាំកក់ ស្រែអំបិល ព្រលានយន្តហោះកំពង់ឆ្នាំង**)។ ក្នុងចំណោមប្រការផ្សេងៗ ពួកគាត់ត្រូវបានដាក់ទណ្ឌកម្មចំពោះការពុំបានបំពេញតាមបរិមាណកំណត់ និងការលួច ឬការស្វែងរកម្ហូបអាហារ។ ទណ្ឌកម្មនានារួមមានដូចជាការចាត់តាំងឱ្យបំពេញការងារបន្ថែម ឬការងារលំបាកៗ ការវាយដំ ការកាត់របបអាហារ និងការឃុំឃាំង (**សហករណ៍ត្រាំកក់ ទំនប់១មករា ទំនប់ត្រពាំងថ្ម ស្រែអំបិល**)។

១៨៧៨- ពលករក៏ត្រូវបានចាប់ខ្លួន ឃុំឃាំង និងប្រហារជីវិតចំពោះ "បទល្មើស" ជាច្រើនដូចជា ការជាប់សង្ស័យថាប្រឆាំងបដិវត្តន៍ ជាសមាជិករបបសាធារណរដ្ឋខ្មែរ ឬប្រជាជនថ្មី ការត្អូញត្អែរអំពីស្ថានភាពរស់នៅឬការងារ (**ត្រាំកក់ ត្រពាំងថ្ម ស្រែអំបិល**) ការប្រព្រឹត្តិកំហុសនៅតាមកន្លែងការងារ ជាប់ចោទថាជាមនុស្សខ្ជិល ឬខុសសីលធម៌ ការប៉ុនប៉ងលួចរត់ ការប្រឹងប្រែងរកអាហារបន្ថែម ជានាយទុន ឬសក្តិភូមិ មានទំនោរទៅរក "យួន" ជាប្រជាជន "១៧មេសា" ឬចាម និងខ្ជិលច្រអូស ឬត្អូញត្អែរ(**ទំនប់១មករា**)ជាបណ្តាញសេអ៊ីអា ឬវៀតណាម ប្រជាជនថ្មី ឬប្រជាជនចាម ឬខកខានពុំបានអនុវត្តតាមសេចក្តីណែនាំរបស់ថ្នាក់លើ (**ព្រលានយន្តហោះកំពង់ឆ្នាំង**) ឬគ្រាន់តែឈរខាងក្រៅនៅពេលយប់ (**ស្រែអំបិល**)។ ក្រុមប្រជាជនស៊ីវិលមួយចំនួនបានរងការរើសអើងបន្ថែមពីលើនេះទៀត ដោយសារលក្ខណៈវិនិច្ឆ័យរបស់បក្សដូចជាមនុស្សដែលត្រូវបានគេចាត់ទុកថាជា "បរាសិត" ឬ "បញ្ញើក្អែក" (**សហករណ៍ត្រាំកក់**) និងប្រជាជនថ្មី (**ទំនប់ត្រពាំងថ្ម**)។ ក្រុមមនុស្សទាំងនេះត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើការងារលំបាកលំបិនជាងគេ ទទួលបានអាហារតិចជាងគេ និងរងទណ្ឌកម្មញឹកញាប់ជាងគេ។

### *ការកើតមានឡើងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*

១៨៧៩- ដូចដែលបានរៀបរាប់ត្រង់ផ្នែកការរំលោភផ្លូវភេទ បក្សកុម្មុយនីស្តកម្ពុជាបានដាក់គោលការណ៍ នៃការរៀបការដោយបង្ខំមកលើប្រជាជន រួមទាំងនៅតាមទីកន្លែងចំនួន២ ក្រោមកិច្ចស៊ើបសួរ (**ទំនប់១មករា សហករណ៍ត្រាំកក់**)។ គោលនយោបាយនេះបានបង្កព្យសនកម្មផ្លូវចិត្ត និងផ្លូវកាយយ៉ាងធ្ងន់ធ្ងរដល់ជនរងគ្រោះ។

១៨៨០- ការអនុវត្តគោលនយោបាយនៃការរៀបការដោយបង្ខំ ពាក់ព័ន្ធនឹងការលុបបំបាត់ទំនៀមទម្លាប់ប្រពៃណីដ៏សំខាន់នៅក្នុងសង្គមកម្ពុជា និងបានប៉ះពាល់ដោយផ្ទាល់ដល់ជនរងគ្រោះរាប់សែននាក់។ ដូចដែលបានរៀបរាប់ត្រង់ផ្នែកការរំលោភផ្លូវភេទ ប្រជាជនជាច្រើន រួមទាំងព្រះសង្ឃផង ត្រូវបានបង្ខំឲ្យរៀបការជាមួយមនុស្សដែលរដ្ឋអំណាចបានជ្រើសរើសឲ្យ និងត្រូវរួមភេទជាមួយដៃគូរបស់ពួកគាត់។ ក្នុងករណីជាច្រើន មនុស្សក្មេងៗពុំបានស្គាល់ប្តី ឬប្រពន្ធដែលខ្លួនត្រូវបង្ខំឲ្យរៀបការ និងរួមភេទជាមួយឡើយ។ ស្ត្រីត្រូវបានបង្ខំឲ្យមានផ្ទៃពោះ និងបង្កើតកូន ហើយកូនរបស់ពួកគាត់ត្រូវបានបក្សយកទៅឃុំគ្រងទាំងនៅវ័យក្មេង។ ស្ត្រីខ្លះត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការជាមួយយុទ្ធជនពិការសម្រាប់ជាការដាក់ទណ្ឌកម្ម ឬតាមសំណើរបស់កងទ័ព។

១៨៨១- គោលនយោបាយនៃការរៀបការដោយបង្ខំត្រូវបានអនុវត្តតាមការគំរាមកំហែង និងការដាក់ទណ្ឌកម្មនានាដូចជា ការលត់ដំ ការវាយដំ ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការចាប់ខ្លួន និង/ឬ ការប្រហារជីវិត។ ជនរងគ្រោះមួយចំនួននៃគោលនយោបាយនេះបានធ្វើអត្តឃាត។

*នៅតាមមន្ទីរសន្តិសុខ*

១៨៨២- អ្នកទោសរាប់ម៉ឺននាក់បានទទួលរងព្យសនកម្មផ្លូវចិត្ត និងផ្លូវកាយធ្ងន់ធ្ងរនៅតាមមន្ទីរសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជាក្រោមកិច្ចស៊ើបសួរ [មន្ទីរស-២១ កោះខ្សែង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លក អូរកន្សែង វត្តគិរីរម្យ (រួមទាំង មន្ទីរសន្តិសុខចន្លោះក្តាង) និងសៀមរាប]។ ដូចដែលបានកត់សម្គាល់ត្រង់ផ្នែក ការឃុំឃាំង ជនរងគ្រោះទាំងនេះត្រូវបានចាប់ខ្លួន និងដាក់គុកផ្អែកតាមលក្ខណៈវិនិច្ឆ័យរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និង

ដោយគ្មាននីតិវិធីត្រឹមត្រូវ។ តាមគោលការណ៍ ពួកគាត់ទទួលរងការធ្វើបាបបន្ថោកបន្ទាប និងក្រោមស្ថានភាពព្រៃផ្សៃអមនុស្សធម៌ក្រៃលែង ដូចជាតាមរយៈ៖ ការធ្វើទារុណកម្ម និង ការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត ការឃុំឃាំងក្នុងគុកដែលរំខានទៅដោយសត្វល្អិត ឬជំងឺ តម្កាត់ និងគ្មានអនាម័យ ភាពអត់ឃ្លាន ការធ្វើការងារពលកម្មដោយបង្ខំ ការរំលោភផ្លូវភេទ និងការផ្តាច់ទំនាក់ទំនងជាមួយមនុស្សខាងក្រៅ ឬការគ្មានសង្ឃឹមថានឹងត្រូវបានដោះលែង។

១៤៨៣- អ្នកទោសត្រូវបានឃុំឃាំងក្នុងបន្ទប់ចាក់សោ ក្រោមការឃោមកាមពីឆ្មាំប្រដាប់អាវុធ។ ក្នុងករណី ជាច្រើន អ្នកដែលប៉ុនប៉ងលួចរត់ត្រូវបានសម្លាប់ (**អូរកន្សែងក្រាំងតាចាន់ ព្រៃដំរីស្រុត សង់**)។ អ្នកទោសតែងតែត្រូវបានខ្នែរក្របាមដាក់ខ្នោះជើង និង/ឬខ្នោះដៃ។ ការអនុវត្តនេះត្រូវបានយក មកអនុវត្តផ្សេងៗគ្នាចំពោះ៖ រាល់គ្រប់អ្នកទោសទាំងអស់ (**កោះខ្សែង**) អ្នកទោសប្រុសទាំងអស់ (**មន្ទីរស-២១**) "អ្នកទោសធ្ងន់" (**ព្រៃដំរីស្រុត** អ្នកទោស"ស្រាល" ត្រូវគេដោះខ្នោះជើងចេញនៅ ពេលថ្ងៃ) អ្នកទោសប្រុស ស្រីពេញវ័យទាំងអស់ (**ក្រាំងតាចាន់**) អ្នកទោសប្រុសទាំងអស់នៅ ពេលយប់ (**សង់ សៀមរាប**) មនុស្សប្រុសទាំងអស់ និងអ្នកទោស "ធ្ងន់" (**គោកក្តួច** អ្នកទោស ធ្ងន់ត្រូវគេដាក់ខ្នោះជើងនៅពេលយប់នៅកោះសំតូច) អ្នកទោសធ្ងន់ត្រូវជាប់ខ្នោះទាំងថ្ងៃទាំងយប់ និងមនុស្សផ្សេងទៀតជាប់ខ្នោះនៅពេលយប់ (**ភ្នំក្រោល**) និង "អ្នកទោសធ្ងន់" (**វត្តធ្លក** និង **អូរកន្សែង**)។ ទោះបីជាក្នុងករណីជាច្រើន អ្នកទោសត្រូវបានគេចាក់សោឃុំឃាំងជាក្រុមក្តី ក៏ មានអ្នកទោសបានជាប់ឃុំឃាំងនៅបន្ទប់តូចៗ ដាច់ដោយឡែកពីគ្នាដែរ (មន្ទីរស-២១) និង "គុកងងឹត" (**សង់**)។ នៅ**មន្ទីរស-២១** និង**ភ្នំក្រោល** អ្នកទោសពុំមានសិទ្ធិជជែកគ្នា ឬនិយាយស្តី ទៅកាន់ឆ្មាំឡើយ។

១៤៨៤- អ្នកទោសត្រូវបានបដិសេធ (ឬត្រូវបានផ្តល់ឱ្យមិនគ្រប់គ្រាន់ទាល់តែសោះ) នូវទីកន្លែងមានអនាម័យ។ ជាទូទៅអ្នកទោសត្រូវបានបង្ខំឱ្យនោម និង/ឬ ជុះដាក់កេសគ្រាប់ត្រឡោកដូង ម្ចូកដែកឆ្នាំង និងកំប៉ុង ទាំងជើងជាប់ខ្នោះ (**អូរកន្សែង ក្រាំងតាចាន់ កោះខ្សង ភ្នំក្រោល មន្ទីរស-២១ សង់ និងសៀមរាប**)។ បន្ទប់ឃុំឃាំងត្រូវបានរំខានទៅដោយ សត្វចៃឆ្កែ សត្វចៃ និងសត្វល្អិតផ្សេងៗ និងជាទូទៅពោរពេញទៅដោយក្លិនស្អុយអសោច (**ភ្នំក្រោល មន្ទីរស-២១ កោះខ្សង សៀមរាប**)។ អ្នកទោសពុំត្រូវបានអនុញ្ញាតឱ្យងូតទឹក ឬមានកន្លែងងូតទឹកឡើយ (**គោកក្តួច មន្ទីរស-២១ ក្រាំងតាចាន់**)។

១៤៨៥- ម្ហូបអាហារដែលខ្មែរក្រហមបានផ្តល់ទៅឱ្យអ្នកទោស មានបរិមាណតិចតួចពុំគ្រប់គ្រាន់។ របបអាហារកំណត់ដែលមាន២ពេលក្នុងមួយថ្ងៃ មានបាយ បបរ ទឹកសម្ល ឬអាហារទាំងនេះលាយឡំគ្នា ក្នុងចំនួនតិចតួចស្តួចស្តើង។ នៅតាមមន្ទីរសន្តិសុខមួយចំនួន របបអាហារដ៏ស្តួចស្តើងនេះត្រូវបានកាត់បន្ថយ ឬកាត់ទាំងស្រុង ដើម្បីជាការដាក់ទណ្ឌកម្ម (**កោះខ្សង មន្ទីរស-២១**)។ ទឹកសម្រាប់ទទួលទានក៏តែងតែមានការខ្វះខាតដែរ។ ប្រសិនបើឆ្មាំមិនផ្តល់ទឹកឱ្យអ្នកទោស អ្នកទោសពុំដែលហ៊ានសុំទេ ឬបើអ្នកទោស ស្នើសុំក៏ត្រូវបានបដិសេធដែរ (**មន្ទីរស-២១, សៀមរាប**)។ នៅមន្ទីរស-២១ អ្នកទោសត្រូវបានផ្តល់របបអាហារតិចតួចបំផុត បើទោះពេលនោះ ផលិតផលអាហារលើស ដែលមន្ទីរស-២៤ ផលិតបាន ត្រូវបានផ្តល់ទៅឱ្យគណៈមជ្ឈិមក្តី។

១៤៨៦- ទោះបីជាមានជំងឺតម្កាត់ និងជំងឺឆ្លងរាតត្បាតអ្នកទោសក្តី ក៏ការថែទាំវេជ្ជសាស្ត្រពុំមានលក្ខណៈគ្រប់គ្រាន់ ឬគ្មានសោះតែម្តង។ ក្នុងករណីខ្លះ ពេទ្យបានពិនិត្យព្យាបាលតែបុគ្គលិកគុក (**ព្រៃដំរីស្រុត**) ប៉ុណ្ណោះ ឬអ្នកទោសណាដែលមានកម្លាំងធ្វើការតែប៉ុណ្ណោះ (**សង់**)។ ពេទ្យដែលភាគច្រើនជា

កុមារ ឬមនុស្សដែលពុំបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ជាអ្នកចែកចាយថ្នាំសង្កូវដែលគ្មានប្រសិទ្ធភាព ដូចជាថ្នាំអាចម៍ទន្សាយជាដើម (**គោកក្តួចមន្ទីរស-២១**)។ នៅមន្ទីរស-២១ អ្នកទោសរបួសធ្ងន់ក្នុងពេលធ្វើទារុណកម្ម បានទទួលការព្យាបាលដើម្បីឲ្យការសួរចម្លើយចប់សព្វគ្រប់តែប៉ុណ្ណោះ។ អ្នកទោសជាច្រើននាក់បានត្រូវរងគ្រោះពីការធ្វើពិសោធន៍វេជ្ជសាស្ត្រដ៏ព្រៃផ្សៃ និងការបូមឈាម ដែលបានបណ្តាលឲ្យអ្នកទោសរាប់រយនាក់ស្លាប់ (**មន្ទីរស-២១**)។

១៤៨៧- នៅពេញមួយរយៈពេលនៃការជាប់ឃុំឃាំង អ្នកទោសបានរស់នៅក្នុងសភាពភ័យខ្លាចជាប់ជាប្រចាំពីការធ្វើទារុណកម្ម និងការប្រហារជីវិត។ អ្នកទោសដែលត្រូវគេចោទថាល្មើសនឹងវិន័យគុកត្រូវទទួលរងទណ្ឌកម្មធ្ងន់ធ្ងររួមមានដូចជា ការវាយនឹងរំពាត់ខ្សែតីការវាយដំ ការធ្វើទារុណកម្ម ការកាត់បន្ថយរបបអាហារ និង/ឬ ការប្រហារជីវិត (**សង់ វត្តធ្លក ព្រៃដំរីស្រុត មន្ទីរស-២១**)។ អ្នកទោសត្រូវបានហាមឃាត់មិនឲ្យនិយាយប្រាស្រ័យទាក់ទងគ្នា (**អូរកន្សែង មន្ទីរស-២១**)។ នៅតាមគុកខ្លះ អ្នកទោសបានឃើញ ឬបានឮសំឡេងអ្នកទោសផ្សេងដែលកំពុងរងទារុណកម្ម ឬបានឃើញពួកគេត្រឡប់មកបន្ទប់ឃុំឃាំងវិញដោយមានរបួសស្នាម (**មន្ទីរស-២១ សៀមរាប**)។ ចុងក្រោយ អ្នកទោសត្រូវបានបង្ខំឲ្យធ្វើការងារពលកម្មដោយដៃនៅតាមមន្ទីរសន្តិសុខភាគច្រើន [**មន្ទីរស-២៤ (មន្ទីរស-២១) កោះខ្យង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្តួច ភ្នំក្រោល វត្តធ្លក អូរកន្សែង ចន្លោះក្តោង (វត្តគិរីរម្យ) សៀមរាប**]។

១៤៨៨- ដូចដែលបានរៀបរាប់ត្រង់ផ្នែក ការធ្វើមនុស្សឃាត បន្ថែមពីលើមនុស្សដែលត្រូវបានប្រហារជីវិត នៅមានអ្នកទោសជាច្រើនទៀតបានស្លាប់ដោយសារការវាយដំ ភាពអត់ឃ្លាន ជំងឺតម្កាត់ និងការបាក់កម្លាំង (**កោះខ្យង សៀមរាប វត្តធ្លក អូរកន្សែង គោកក្តួច សង់**)។ នៅតាមមន្ទីរ

សន្តិសុខយ៉ាងហោចណាស់ចំនួន២ អ្នកទោសមួយចំនួនបានធ្វើអត្តឃាត (**មន្ទីរស-២១** និង **អូរកន្សែង**)។

*ការប្រឆាំងនឹងពុទ្ធសាសនិក*

១៤៨៩- ដូចដែលបានរៀបរាប់ត្រង់ផ្នែក ការធ្វើទុក្ខបុកម្នេញ រដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជាបានប្រព្រឹត្តអំពើអមនុស្សធម៌ជាច្រើនមកលើពុទ្ធសាសនិក និងព្រះសង្ឃ ដែលតែងតែបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរ ខាងផ្លូវកាយ និង/ឬ ផ្លូវចិត្ត។ ការគោរពប្រណិប័តន៍ពុទ្ធសាសនាត្រូវបានលុបបំបាត់។ ក្នុងចំណោមប្រការផ្សេងៗ ព្រះសង្ឃត្រូវបានចាត់ទុកជា "ល្អឹង" និង "ព្រូនជញ្ជក់ឈាម" និងត្រូវបានផ្សឹកដោយបង្ខំ។ ព្រះសង្ឃណាដែលប្រកែកពុំព្រមលាចាកសិក្ខាបទត្រូវបានប្រហារជីវិត។ ក្រោយពេលផ្សឹករួច ព្រះសង្ឃត្រូវបានបង្ខំឱ្យចូលរួមធ្វើការងារដែលពុំមែនជាការងាររបស់ព្រះសង្ឃ និងបង្ខំឱ្យព្រះសង្ឃរៀបការដោយរំលោភបំពានលើការត្រូវរក្សាភាពនៅលីវពុំយកគូស្រករបស់ពួកគាត់។ នៅទូទាំងប្រទេសកម្ពុជា ទីកន្លែងគោរពសក្ការៈរបស់ព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ ឬប្រែក្លាយទៅជាកន្លែងពុំគួរគប្បី ហើយព្រះពុទ្ធបដិមាត្រូវបានបំផ្លិចបំផ្លាញ ដែលទាំងអស់នេះបានបង្កព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរដល់(ពុទ្ធសាសនិក)។

*ចំពោះជនជាតិចាម*

១៤៩០- ដូចដែលបានរៀបរាប់ក្នុងផ្នែក ការធ្វើទុក្ខបុកម្នេញ នៃប្រជាជនចាមបានទទួលរងអំពើអមនុស្សធម៌ជាច្រើន ដែលបានបង្កទុក្ខវេទនាធ្ងន់ធ្ងរខាងផ្លូវកាយ និងផ្លូវចិត្ត។ អំពើអមនុស្សធម៌ទាំងនេះរួមមាន ការបំបែកភូមិចាម និងការបំបែកប្រជាជនចាមដោយបង្ខំក្នុងចំណោមសហគមន៍

ផ្សេងៗ ការហាមឃាត់ប្រពៃណីចាម ការគោរពប្រណិប័តន៍សាសនា និងភាសា ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ សាសនាចាម (ក្នុងនោះរួមមាន គម្ពីរធម៌) និងការរៀបការដោយបង្ខំរវាងស្ត្រីចាម និងបុរសមិនមានជនជាតិចាម។

**ចេតនា**

១៤៩១- ភ័ស្តុតាងបញ្ជាក់អំពីទំហំទុក្ខវេទនាដែលខ្មែរក្រហមបានបង្កឡើង តាមទីកន្លែងនីមួយៗ និងហេតុការណ៍នានាដែលបានរៀបរាប់ខាងលើបង្ហាញថា ចារីពិតជាមានចេតនាបង្កព្យសនកម្មធ្ងន់ធ្ងរខាងផ្លូវកាយ និង/ឬ ផ្លូវចិត្តដល់ជនរងគ្រោះប្រាកដមែន។ ដូចដែលបង្ហាញត្រង់ផ្នែកការសម្លាប់រង្គាល ស្ថានភាពដ៏សែនអមនុស្សធម៌ដែលប្រជាជនស៊ីវិលបានទទួលរង (ក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំ តាមការដ្ឋានធ្វើការងារដោយបង្ខំ តាមមន្ទីរសន្តិសុខ និងក្នុងអំឡុងហេតុការណ៍ផ្សេងៗដែលបានរៀបរាប់ខាងលើ) ពុំមានអ្វីប្រែប្រួលឡើយ បើទោះបីចារីបានឃើញអំពីទំហំនៃទុក្ខវេទនាដែលពួកគេកំពុងបង្កឡើងក្តី។ នៅតាមទីកន្លែង និងនៅក្នុងហេតុការណ៍នីមួយៗ ចារីផ្ទាល់តែងបានអនុវត្តជាប់លាប់នូវគោលនយោបាយរបស់បក្សក្នុងការធ្វើបាបយ៉ាងព្រៃផ្សៃ និងអមនុស្សធម៌ រាប់ទាំងការរំលោភបំពានផ្លូវកាយ មកលើសមាជិកប្រជាជនដែលរដ្ឋអំណាចបានរក្សាទុកធ្វើជាទាសករ និង/ឬ ដាក់គុក ផង។

## ការបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ

១៤៩២- ភ័ស្តុតាងក្នុងសំណុំរឿង និងភ័ស្តុតាងដែលបានលើកឡើងក្នុង ផ្នែកភ័ស្តុតាង នៃដីកាសន្និដ្ឋាននេះបញ្ជាក់ថាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ សេចក្តីព្រាងនៃ

អង្គហេតុនានាដែលបញ្ជាក់អំពីធាតុផ្សំយុត្តាធិការ និងឧក្រិដ្ឋកម្មមួយចំនួននឹងបង្ហាញដូចខាងក្រោមនេះ។

## យុត្តាធិការ

## ជម្លោះប្រដាប់អាវុធអន្តរជាតិ

១៤៩៣- ដូចដែលបានរៀបរាប់ត្រង់ផ្នែកស្តីពីជម្លោះប្រដាប់អាវុធ នៃដីកាសន្និដ្ឋានស្ថាពរនេះ ភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថាមានជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិរវាងកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (SRV) ពីខែឧសភា ឆ្នាំ១៩៧៥ រហូតដល់ពេលបញ្ចប់នៃរយៈកាលក្រោមកិច្ចស៊ើបសួរ។ ជម្លោះនេះបានចាប់ផ្តើមចេញពីការវាយលុក និងការវាយបកពីសំណាក់កងកម្លាំងប្រដាប់អាវុធនៃប្រទេសទាំងពីរក្នុងខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៧៥ និងបានកើតឡើងជាបន្តបន្ទាប់ដោយការប្រឈមមុខខាងយោធាជាច្រើនលើកនៅពេញមួយឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៦ បើទោះបីជាមានការខិតខំស្វះស្វែងរកដំណោះស្រាយតាមផ្លូវនយោបាយក្តី។ ក្នុងអំឡុងពេលនេះ ទោះបីស្ថិតក្នុងកាលៈទេសៈណាក្តី ក៏គេពុំអាចស្តារសន្តិភាពវិញទាំងស្រុងដែរ។ ភាពធ្ងន់ធ្ងរនៃជម្លោះនេះរីកធំធាត់ក្នុងឆ្នាំ១៩៧៧ តាមរយៈការវាយប្រហារចូលព្រំដែនគ្នាទៅវិញទៅមក និងការវាយលុកជាទ្រង់ទ្រាយធំមួយចូលទឹកដីកម្ពុជាពីសំណាក់កងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាមនៅចុងឆ្នាំ១៩៧៧។ កម្ពុជាប្រជាធិបតេយ្យបានផ្តាច់ចំណងការទូតជាផ្លូវការជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ និងការវាយប្រយុទ្ធគ្នាបានកើតមានជាប់ជាបន្តបន្ទាប់នៅតាមបណ្តោយព្រំដែនប្រទេសទាំង២នៅពេញមួយឆ្នាំ១៩៧៨។ ការចូលលុកលុយកម្ពុជាជាទ្រង់ទ្រាយធំពីសំណាក់កងទ័ពសាធារណរដ្ឋសង្គម

និយមវៀតណាមនៅខែធ្នូ ឆ្នាំ១៩៧៨ គឺជាដំណាក់កាលចុងក្រោយនៃជម្លោះប្រដាប់អាវុធរវាងប្រទេសទាំងពីរ។

១៤៩៤- សញ្ញាបញ្ជាក់អំពីសភាពនៃជម្លោះប្រដាប់អាវុធជាបន្តបន្ទាប់រួមមានដូចជា៖ ការពង្រាយទ័ពកងពលធំនៃកងទ័ពបដិវត្តន៍កម្ពុជារបស់បណ្តាភូមិភាគ ទ័ពមជ្ឈិមបក្ស និងកងឈ្លបបានប្រឆាំងនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ការវាយប្រហាររបស់កងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាម ការចេញសេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាស្តីពីបញ្ហាយោធា និងការសម្រេចប្រឈមមុខនឹងការទន្ទ្រានចូលទឹកដីកម្ពុជាពីសំណាក់ប្រទេសវៀតណាម ការប៉ះទង្គិចគ្នាជាច្រើនលើកច្រើនសារ រវាងកងកម្លាំងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និងការវាយលុកចូលទឹកដីគ្នាទៅវិញទៅមក ការរាយការណ៍ជាទៀងទាត់របស់ថ្នាក់ដឹកនាំភូមិភាគ និងកងទ័ពបដិវត្តន៍កម្ពុជា ជូនមជ្ឈិមបក្សស្តីពីសភាពការណ៍យោធាពីឆ្នាំ១៩៧៥ និងការបង្កើតមន្ទីរពេទ្យយោធា សម្រាប់ព្យាបាលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យដែលបានរងរបួសដោយសារការវាយប្រហារ និងការអនុញ្ញាតឲ្យយោធារបួសទទួលការព្យាបាលនៅតាមមន្ទីរពេទ្យស៊ីវិលនៅភ្នំពេញ។

១៤៩៥- ឧក្រិដ្ឋកម្មដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តប្រឆាំងនឹងប្រជាជនវៀតណាម ក្នុងអំឡុងពេលក្រោមកិច្ចស៊ើបសួរ ជាប់ពាក់ព័ន្ធជិតស្និទ្ធទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិនេះ។ ចំណងពាក់ព័ន្ធរវាងឧក្រិដ្ឋកម្ម និងជម្លោះប្រដាប់អាវុធ ក្នុងចំណោមប្រការផ្សេងៗ ត្រូវបានបង្ហាញឡើងតាមរយៈអង្គហេតុ ដែលថាឧក្រិដ្ឋកម្មអស់ទាំងនេះត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ដែលជាយុទ្ធជនក្នុងជម្លោះប្រដាប់អាវុធនេះប្រឆាំង

នឹងសមាជិកនៃរដ្ឋបច្ចាមិត្ត។ លើសពីនេះ ឧក្រិដ្ឋកម្មអស់ទាំងនេះត្រូវបានចាត់ទុកថាជាការជួយឱ្យសម្រេចគោលដៅឃោធារបស់បក្សកុម្មុយនីស្តកម្ពុជា ប្រឆាំងនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម និងត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលនៃការវាយប្រហារ ដែលបានរៀបចំឡើងដោយកងទ័ពបដិវត្តន៍កម្ពុជា ចូលទៅក្នុងទឹកដីវៀតណាម។ ចារីនៃឧក្រិដ្ឋកម្មទាំងនោះ បាននិងកំពុងអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្លាប់រង្គាលជនជាតិវៀតណាម ដែលកើតឡើងចេញពីចេតនារបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការតស៊ូប្រឆាំងនឹងអ្វី ដែលខ្លួនចាត់ទុកថាជាការវាតទឹកដីពីសំណាក់ប្រទេសវៀតណាម។ ដូចដែលបានបង្ហាញខាងក្រោម ជនរងគ្រោះជាច្រើននៃឧក្រិដ្ឋកម្មទាំងនេះ គឺជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

## ជនដែលត្រូវទទួលបានការការពារ

១៤៩៦- ទាហាន និងប្រជាជនស៊ីវិលវៀតណាម ដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះ បានរៀបរាប់ខាងក្រោម គឺជាជនដែលត្រូវទទួលបានការការពារ តាមអនុសញ្ញាក្រុងហ្សឺណែវ III និង IV។ ប្រជាជនស៊ីវិលវៀតណាម ស្ថិតក្នុងកណ្ដាប់ដៃរបស់ភាគីមួយនៃជម្លោះ ដែលពុំមែនជាជនជាតិរបស់ខ្លួន (កម្ពុជាប្រជាធិបតេយ្យ) ហើយមានឋានៈជាជនដែលត្រូវទទួលបានការការពារតាមអនុសញ្ញាក្រុងហ្សឺណែវ IV។ ទាហានសាធារណរដ្ឋសង្គមនិយមវៀតណាមដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួន គឺជាឈ្លើយសឹកដែលស្ថិតក្រោមអំណាចរបស់ខ្មាំង ហើយមានឋានៈជាជនដែលត្រូវទទួលបានការការពារតាមអនុសញ្ញាក្រុងហ្សឺណែវ III។

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស*

## ការដឹងឮអំពីជម្លោះប្រដាប់អាវុធ

១៤៩៧- អំពើបំពារបំពានធ្ងន់ធ្ងរមកលើប្រជាជនវៀតណាមត្រូវបានប្រព្រឹត្តដោយ៖ (១) សមាជិកកងទ័ពបដិវត្តន៍កម្ពុជា ដែលបានប្រឈមមុខផ្នែកប្រដាប់អាវុធជាមួយវៀតណាម និងការវាយលុកចូលទឹកដីវៀតណាម និង(២) អ្នកសួរចម្លើយ និងឆ្មាំនៅតាមមន្ទីរសន្តិសុខនានា ដែលឈ្លើយសឹកវៀតណាម និងប្រជាជនស៊ីវិល ត្រូវជាប់ឃុំឃាំង និងប្រហារជីវិត។ ភ័ស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថាចារីទាំង២ក្រុមនេះ បានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជានៅតាមមន្ទីរសន្តិសុខបានយល់ជ្រួតជ្រាបថាពួកគេកំពុងឃុំឃាំង ធ្វើទារុណកម្ម និងប្រហារជីវិតជនរងគ្រោះវៀតណាមក្នុងបរិបទនៃជម្លោះប្រដាប់អាវុធនេះ។ ជាក់ស្តែង ទាហានវៀតណាមដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ត្រូវបានទទួលរងការធ្វើទារុណកម្មឲ្យឆ្លើយសារភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងគោលបំណងលេបទឹកដីរបស់វៀតណាម តាមការសន្មតរបស់ខ្មែរក្រហម។ ឈ្លើយសឹកវៀតណាមដែលត្រូវបានចាប់ខ្លួន និងនាំខ្លួនទៅកាន់មន្ទីរស-២១ ត្រូវបានកត់ត្រាទុកនូវការរៀបរាប់អំពីឋានន្តរសក្តិ និងអង្គភាពយោធា និងទីកន្លែងចាប់ខ្លួន។

១៤៩៨- ទាហានកម្ពុជាប្រជាធិបតេយ្យដែលបានបើកការវាយលុកចូលទឹកដីវៀតណាម បានដឹងច្បាស់អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ និងអង្គហេតុដែលថាប្រជាជនស៊ីវិលដែលពួកគេបានចាប់ខ្លួន និងសម្លាប់គឺជាប្រជាជននៃរដ្ឋបរទេសមួយ។ ពួកគេក៏បានដឹងថាទាហានវៀតណាមដែលពួកគេបានចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងនៅភ្នំពេញ គឺជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៃ

សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជារដ្ឋមួយដែលកម្ពុជាប្រជាធិបតេយ្យកំពុងធ្វើសង្គ្រាមជាមួយ។

**បទល្មើសជាក់លាក់មួយចំនួន**

**ការសម្លាប់ដោយចេតនា**

១៤៩៩- ភ័ស្តុតាងក្នុងសំណុំរឿងបង្ហាញថាការសម្លាប់ដោយចេតនា ជាការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលអាចផ្តន្ទាទោសបានតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

**អំពើសកម្ម និង អំពើអកម្ម**

*ការវាយលុកចូលទឹកដីប្រទេសវៀតណាម*

១៥០០- កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានសម្លាប់ប្រជាជនស៊ីវិលចំនួនរាប់រយនាក់ ក្នុងអំឡុងពេលដែលពួកគេបានបើកការវាយលុកចូលទឹកដីវៀតណាម និងបានចាប់ខ្លួនប្រជាជនស៊ីវិលចំនួនរាប់រយនាក់ថែមទៀត។ ក្នុងហេតុការណ៍លើកដំបូង នៅខែឧសភា ឆ្នាំ១៩៧៥ ទ័ពខ្មែរក្រហមបានវាយប្រហារលើកោះចំនួន២គឺ កោះត្រល់ (Phu Quoc) និងកោះក្រចកសេះ (Tho Chu) និងបានជម្លៀសប្រជាជនស៊ីវិលវៀតណាមចំនួន៥០០នាក់ ក្រោមកាណុងកាំភ្លើង។ បន្ទាប់មកប្រជាជនទាំងនេះបានបាត់ខ្លួន។ ពីខែមករា ឆ្នាំ១៩៧៧ ដល់ដំណាច់ឆ្នាំ១៩៧៨ កងទ័ពបដិវត្តន៍កម្ពុជាបានបើកការវាយលុកជាច្រើនលើកចូលទឹកដីវៀតណាម ទៅលើភូមិនានារបស់វៀតណាម (រួមមាន ភូមិ Ha Tien, Chau Doc, Tinh Bien, Prey Tameang, Ap Sase, Naxia,

Kylo និង Hong Ngu) និងបានសម្លាប់រង្គាលអ្នកភូមិវៀតណាមក្នុងចំនួនដ៏ច្រើន។ ទាហាន កម្ពុជាប្រជាធិបតេយ្យបានសម្លាប់ប្រជាជនស៊ីវិលវៀតណាមយ៉ាងព្រៃផ្សៃតាមវិធីវះពោះ វះថ្លើម ការវាយដំ និងការកាត់ក។ មនុស្សជាច្រើនរយនាក់ រួមទាំងអ្នកភូមិខ្មែរក្រោមនៅវៀតណាម ត្រូវបានចាប់ខ្លួន និងបញ្ជូនត្រឡប់មកកម្ពុជាវិញ។ ពួកគេមួយចំនួនត្រូវបានប្រគល់ទៅឱ្យមន្ទីរ ស-២១។

*ស-២១*

១៥០១- ប្រជាជនស៊ីវិល និងឈ្លើយសឹកវៀតណាម ដែលជាប់ឃុំឃាំងនៅឯមន្ទីរស-២១ សុទ្ធតែត្រូវ បានប្រហារជីវិតទាំងអស់។ ក្នុងបញ្ជីអ្នកទោសកែសម្រួលរបស់មន្ទីរស-២១ មានការរៀបរាប់ ជាលម្អិតអំពីអ្នកទោសចំនួន៣៤៥នាក់ ដែលខ្មែរក្រហមបានចាត់ទុកថាជាជនជាតិវៀតណាម។ ក្នុងចំណោមពួកគេទាំងនោះ មនុស្ស១២២ នាក់គឺជាឈ្លើយសឹក ហើយមនុស្សប្រហែល៥០នាក់ ទៀត ត្រូវបានចាត់ទុកថាជាប្រជាជនស៊ីវិល (ដោយប្រជាជនស៊ីវិលចំនួន២៥នាក់ទៀត មាន ដើមកំណើតនៅកម្ពុជា)។ នេះមានន័យថាមនុស្សដែលត្រូវទទួលបានការការពារយ៉ាងហោច ណាស់ចំនួន១៧២នាក់ ត្រូវបានប្រហារជីវិតនៅឯមន្ទីរស-២១។ ចំនួនពិតប្រាកដអាចលើស ច្រើនពីនេះ។ ជាក់ស្តែង មានអ្នកទោសចំនួន១៤៤នាក់ដែលខ្មែរក្រហមចាត់ទុកថា "គិញ" ទំនងជារាប់បញ្ចូលទាំងប្រជាជនស៊ីវិលវៀតណាម ឬឈ្លើយសឹក។ ជាមួយគ្នានេះ ដូចដែលបាន បង្ហាញក្នុងផ្នែកអង្គហេតុសត្យានុមត័ (ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម) សំណុំរឿងនេះ មានភ័ស្តុតាងរបស់អ្នកទោសជនជាតិវៀតណាមយ៉ាងហោចណាស់ចំនួន៧០នាក់ បន្ថែមពីលើ អ្នកទោសចំនួន៣៤៥ទៀត ដែលមានក្នុងបញ្ជីអ្នកទោសមន្ទីរស-២១ កែសម្រួល។

## ចេតនា

១៥០២- ភ័ស្តុតាងបញ្ជាក់ថាកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ និងបុគ្គលិកមន្ទីរស-២១ បានសម្លាប់ប្រជាជនវៀតណាមដោយចេតនា។ ការធ្វើដូច្នេះ ពួកគេបានអនុវត្តតាមគោលនយោបាយរបស់មជ្ឈិមបក្សដែលខ្លួនបានយល់ជ្រួតជ្រាបច្បាស់លាស់។

## ការធ្វើទារុណកម្ម

១៥០៣- ភ័ស្តុតាងក្នុងសំណុំរឿងបង្ហាញថាការធ្វើទារុណកម្ម ជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

## អំពើ

១៥០៤- ដូចដែលបានកត់សម្គាល់ពីខាងលើ ប្រជាជនវៀតណាមចំនួនរាប់រយនាក់ ដែលក្នុងនោះយ៉ាងហោចណាស់ ១៧២នាក់ គឺជាជនដែលត្រូវទទួលបានការការពារ ត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១។ ភាគច្រើននៃជនរងគ្រោះទាំងនោះបានទទួលរងការធ្វើទារុណកម្ម ដូចដែលបានរៀបរាប់ពីខាងលើ ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## ចេតនា

១៥០៥- ការធ្វើទារុណកម្មដែលបានធ្វើឡើងមកលើអ្នកទោសជនជាតិវៀតណាម នៅឯមន្ទីរស-២១ គឺមានលក្ខណៈជាចេតនា។ ការធ្វើទារុណកម្មត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធ ច្រើនដង និងមានការរៀបចំគិតគូរល្អិតល្អន់ ក្នុងបំណងបំពេញតាមគោលនយោបាយរបស់មជ្ឈិមបក្ស។

## គោលបំណង

១៥០៦- គោលបំណងសំខាន់នៃការធ្វើទារុណកម្មមកលើប្រជាជនវៀតណាម ដែលត្រូវទទួលបានការការពារគឺដើម្បីបង្ខំឲ្យពួកគេរែកមុខ "គិញ" និង "បណ្ដាញ" វៀតណាមនៅកម្ពុជា និងសារភាពអំពីគោលនយោបាយវាតទីរបស់វៀតណាម។ ចម្លើយសារភាពជាច្រើនរបស់ប្រជាជនវៀតណាមត្រូវបានចាក់ផ្សាយដោយរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងលក្ខណៈជាភស្តុតាងនៃការឈ្លានពានរបស់វៀតណាមមកលើកម្ពុជា។

១៥០៧- ការធ្វើទារុណកម្មឈ្លើយសឹក និងប្រជាជនស៊ីវិលវៀតណាមក៏ត្រូវបានប្រព្រឹត្តក្នុងគោលបំណងរើសអើង ដោយហេតុថាជនជាតិវៀតណាមត្រូវបានកំណត់យកជាគោលដៅនៃការវាយប្រហារផ្អែកតាមអត្តសញ្ញាណពូជសាសន៍ ជាតិពន្ធុ និងសញ្ជាតិ។ ដូចដែលបានកត់សម្គាល់ពីខាងលើ ជនរងគ្រោះទាំងនេះត្រូវបានសួរចម្លើយ ដើម្បីជួយដល់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់អត្តសញ្ញាណ និងការសម្លាប់ផ្ដាច់ពូជជនជាតិវៀតណាមផ្សេងៗទៀត។

## ស្ថានភាពអមនុស្សធម៌

១៥០៨- ភ័ស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថាស្ថានភាពអមនុស្សធម៌ ដែលជាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្ដន្ទាទោសបានតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តមកលើឈ្លើយសឹក និងប្រជាជនស៊ីវិលវៀតណាម ដែលត្រូវបានជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

## អំពើ និងការខកខាន

១៥០៩- អ្នកទោសជនជាតិវៀតណាមបានទទួលរងការធ្វើបាបដ៏សែនអមនុស្សធម៌ និងស្ថានភាពនៃការឃុំឃាំងនៅមន្ទីរស-២១។ ដូចដែលបានរៀបរាប់ខាងលើពាក់ព័ន្ធនឹងអំពើអមនុស្សធម៌ផ្សេងៗក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អ្នកទោសនៅមន្ទីរស-២១ ត្រូវបានឃុំឃាំងក្នុងបន្ទប់ដែលមានអ្នកទោសលើសចំនួន ឬតាមបន្ទប់ឃុំឃាំងតូចៗដាច់ដោយឡែក និងរងការបង្អត់អាហារ សម្លៀកបំពាក់ ទឹក អនាម័យ និងការថែទាំវេជ្ជសាស្ត្រ។ អ្នកទោសប្រុសត្រូវបានដាក់ខ្នោះគ្រប់ពេលជាប្រចាំ។ អ្នកទោសបានរស់នៅក្នុងសភាពភ័យខ្លាចការធ្វើបាបរូបរាងកាយ ការធ្វើទារុណកម្ម និងការស្លាប់ជាប់ជាប្រចាំ។ ស្ថានភាពទាំងនេះបានបណ្តាលឱ្យជនជាតិវៀតណាមដែលត្រូវទទួលបានការការពារទទួលរងព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ និង/ឬ ទុក្ខវេទនាខាងផ្លូវកាយ និងបង្កើតបានជាការវាយប្រហារដ៏ធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

## ចេតនា

១៥១០- ការធ្វើបាបដ៏អមនុស្សធម៌ជាប់ជាប្រចាំ និងស្ថានភាពនៃការឃុំឃាំងដែលប្រជាជនវៀតណាមបានទទួលរងនៅឯមន្ទីរស-២១ បញ្ជាក់នូវចេតនារបស់ចារីក្នុងការប្រព្រឹត្តិអំពើទាំងឡាយដែលបានបង្កព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ និង/ឬ ទុក្ខវេទនាខាងផ្លូវកាយដល់ជនរងគ្រោះ។

## ការបង្កឱ្យមានទុក្ខវេទនា ឬរបួសធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព

១៥១១- ភ័ស្តុតាងក្នុងសំណុំរឿងបង្ហាញថាបទល្មើសឧក្រិដ្ឋនៃការបង្កឱ្យមានទុក្ខវេទនា ឬរបួសធ្ងន់ធ្ងរដល់រូបរាយកាយ ឬសុខភាព ក្នុងប្រភេទជាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលអាចផ្តន្ទាទោសបានតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តមកលើប្រជាជនវៀតណាម ដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

អំពើ និងចេតនាដូចដែលបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងការធ្វើបាបដ៏អមនុស្សធម៌ គឺអាចយក មកអនុវត្តបានដូចគ្នាចំពោះឧក្រិដ្ឋកម្មនេះ។

## ការដកហូតដោយចេតនានូវការកាត់សេចក្តីដោយយុត្តិធម៌ និងទៀងទាត់

១៥១២- ភ័ស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា បទល្មើសឧក្រិដ្ឋនៃការដកហូតដោយចេតនានូវសិទ្ធិរបស់ ឈ្លើយសឹក ឬប្រជាជនស៊ីវិលក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌និងតាមបទដ្ឋាន ត្រឹមត្រូវ ជាអំពើបំពារបំពានលើអនុសញ្ញាក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តមកលើប្រជាជនវៀតណាម ដែលបានជាប់ឃុំឃាំងនៅមន្ទីរ ស-២១ ក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

## អំពើ និងការខកខាន

១៥១៣- អ្នកទោសមន្ទីរ ស-២១ ត្រូវបានបដិសេធសិទ្ធិមិនឱ្យមានការធានាតាមផ្លូវច្បាប់ ដូចមានចែងក្នុង អនុសញ្ញាទីក្រុងហ្សឺណែវ III និង IV។ ប្រតិបត្តិការរបស់មន្ទីរស-២១ ទាំងមូល និងការធ្វើ បាបដែលអ្នកទោសជនជាតិវៀតណាមបានទទួលរង គឺពុំស្របទាំងស្រុងក្នុងការអនុវត្តនូវសិទ្ធិ ទាំងនោះឡើយ។ អ្នកទោសជនជាតិវៀតណាមមិនត្រឹមតែពុំត្រូវបានគេផ្តល់សិទ្ធិក្នុងការទទួល បានការកាត់សេចក្តីដោយតុលាការឯករាជ្យ និងពុំលម្អៀង សម្រាប់បទល្មើសណាមួយ ដែល បានចោទប្រកាន់ប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែចម្លើយសារភាពដោយបង្ខំ របស់ពួកគេត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាក់ផ្សាយ ក្នុងលក្ខណៈជាភ័ស្តុតាងនៃបទល្មើស របស់ពួកគេថែមទៀតផង។

## ចេតនា

១៥១៤- ភ័ស្តុតាងបញ្ជាក់ថាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលបានឃុំឃាំងឈ្លើយសឹក និងប្រជាជនស៊ីវិលវៀតណាម តាមអំពើចិត្តនៅមន្ទីរស-២១ ពិតជាមានចេតនាដកហូតសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងតាមបទដ្ឋានត្រឹមត្រូវ។ ដូចដែលបានកត់សម្គាល់ពីខាងលើ ការដកហូតសិទ្ធិនេះត្រូវបានធ្វើឡើងស្របតាមគោលនយោបាយរើសអើងវៀតណាមរបស់មជ្ឈិមបក្ស ដែលខ្លួនបានយល់ជ្រួតជ្រាបច្បាស់។

## ការជម្លៀស ឬការបង្ខាំងប្រជាជនស៊ីវិលដោយខុសច្បាប់

១៥១៥- ភ័ស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថាបទល្មើសឧក្រិដ្ឋនៃការជម្លៀសប្រជាជនស៊ីវិល ឬការបង្ខាំងប្រជាជនស៊ីវិលដោយខុសច្បាប់ ជាអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានតាមមាត្រា៦នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តមកលើប្រជាជនស៊ីវិលវៀតណាមដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

## អំពើសកម្ម និងអកម្ម

១៥១៦- ដូចបានរៀបរាប់ក្នុងផ្នែកការសម្លាប់ដោយចេតនា ទ័ពខ្មែរក្រហម ឬទ័ពកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួនប្រជាជនស៊ីវិលវៀតណាមចំនួនរាប់រយនាក់ ក្នុងអំឡុងពេលដែលពួកគេបានវាយលុកចូលទឹកដីវៀតណាម។ ប្រជាជនស៊ីវិលទាំងអស់នេះត្រូវបានជម្លៀសដោយបង្ខំមកកាន់កម្ពុជាជាអចិន្ត្រៃយ៍។ ការជម្លៀសត្រូវបានធ្វើឡើងក្រោមហេតុផលដែលពុំពាក់ព័ន្ធនឹងសន្តិសុខរបស់ប្រជាជនស៊ីវិល ឬគោលដៅយោធាណាមួយឡើយ។

១៥១៧- ភ័ស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា ប្រជាជនវៀតណាមមួយចំនួនដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួន ត្រូវបានឃុំឃាំង និងប្រហារជីវិតនៅតាមមូលដ្ឋាន ក្នុងពេលដែលអ្នកមួយចំនួនទៀត ត្រូវបានបញ្ជូនទៅកាន់មន្ទីរស-២១។ ពុំមានហេតុផលសមស្របឱ្យគេជឿជាក់ថាមកពីមូលហេតុសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ទើបធ្វើឱ្យការបង្ខាំងប្រជាជនស៊ីវិលវៀតណាម ជាការចាំបាច់នោះឡើយ ឬការវាយតម្លៃអំពីគ្រោះថ្នាក់ដែលប្រជាជនស៊ីវិលវៀតណាមអាចបង្កមកលើសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យនោះក៏ទេដែរ។ ផ្ទុយទៅវិញប្រជាជនស៊ីវិលវៀតណាមត្រូវបានចាប់ខ្លួន និងបង្ខាំងដើម្បីអាចសួរចម្លើយ ធ្វើទារុណកម្ម និងប្រហារជីវិតពួកគេ។ ខ្មែរក្រហមពុំបានអនុវត្តឡើយនូវគោលការណ៍គាំពារតាមនីតិវិធីស្របតាមអនុសញ្ញាក្រុងហ្សឺណែវ IV ដែលប្រជាជនស៊ីវិលមានសិទ្ធិទទួលបាន។

**ចេតនា**

១៥១៨- តាមរយៈភ័ស្តុតាង យើងឃើញច្បាស់ថាអំពើឧក្រិដ្ឋនៃការជម្លៀស និងការបង្ខាំង ពិតជាត្រូវបានប្រព្រឹត្តដោយចេតនាយ៉ាងពិតប្រាកដមែន។ ដូចឧក្រិដ្ឋកម្មផ្សេងៗទៀតដែរ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តផ្ទួនៗ និងជាលក្ខណៈប្រព័ន្ធ ដើម្បីសម្រេចគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះវៀតណាម។

## ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦

១៥១៩- ភ័ស្តុតាងក្នុងសំណុំរឿងនេះ និងភ័ស្តុតាងដែលបានលើកឡើងក្នុងផ្នែក អង្គហេតុសត្យានុមត័ នៃដីកាសន្និដ្ឋាននេះបង្ហាញថា មានអំពើមនុស្សឃាត និងការធ្វើទារុណកម្ម តាមក្រមព្រហ្មទណ្ឌកម្ពុជា ដែលអាចផ្តន្ទាទោសបានតាមមាត្រា៣ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តក្នុងអំឡុងពេល

សម័យកម្ពុជាប្រជាធិបតេយ្យ។ សេចក្ដីសង្ខេបត្រួសៗនៃអង្គហេតុដែលបញ្ជាក់អំពីឧក្រិដ្ឋកម្ម ជាក់លាក់មួយចំនួន និងបង្ហាញដូចខាងក្រោម។

**អំពើមនុស្សឃាត**

១៥២០- ផ្នែកខាងក្រោមនេះរៀបរាប់អំពីអង្គហេតុ ដែលបង្ហាញអំពីការប្រព្រឹត្តទម្រង់ទាំង៣នៃអំពើ មនុស្សឃាត ដែលមានក្នុងមាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នោះគឺអំពើមនុស្សឃាតថ្នាក់ទី៣ ទី២ និងទី១។

**អំពើមនុស្សឃាតថ្នាក់ទី៣**

**អំពើសកម្ម និងអកម្ម**

១៥២១- ការប្រហារជីវិតដែលបានរៀបចំទុកជាមុន ដែលត្រូវបានប្រព្រឹត្តនៅពេញមួយរយៈកាលក្រោម កិច្ចស៊ើបសួរគឺជាអំពើដែលបានគិតទុកជាមុន។ ដូចដែលបានលើកយកមកពិភាក្សាក្នុងផ្នែកស្ដីពី មនុស្សឃាត និងការសម្លាប់រង្គាល ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការប្រហារជីវិតទាំង នេះបានកើតឡើង៖

(១) ក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំលើកទី១ លើកទី២ និងលើកទី៣ (រួមមាននៅ **ទួលពោធិ៍ជ្រៃ ស្រុកកំពង់ត្រឡាចលើ វាលបាក់ជញ្ជីង និងវត្តច័ន្ទរង្សី**)

(២) នៅតាមការដ្ឋានធ្វើការងារពលកម្មដោយបង្ខំ (រួមទាំង **ទំនប់ត្រពាំងថ្ម**)

(៣) នៅតាមមន្ទីរសន្តិសុខនានា (**មន្ទីរស-២១ កោះខ្សឹង ព្រៃដំរីស្រុត ក្រាំងតាចាន់ សង់ គោកក្ដួច ភ្នំក្រោល វត្តធ្លក អូរកន្សែង វត្តគិរីរម្យ និងសៀមរាប**)

(៤)ក្នុងអំឡុងពេលបោសសម្អាតភូមិភាគបូព៌ា (រួមទាំង នៅទីតាំង**វត្តកណ្តាលជ្រុំ** និង**ស្ទឹងតូច**)

(៥)ជាផ្នែកមួយនៃការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការលុបបំបាត់ព្រះពុទ្ធសាសនា (នៅ **វត្តអន្ទង់វៀន វត្តជ័យមង្គល វត្តតាគាត់មង្គល** និងនៅ**ភ្នំពេញ**) ការរៀបការដោយបង្ខំ។ និង

(៦)ក្នុងការអនុវត្តគោលនយោបាយសំដៅកម្ទេចជនជាតិចាម (នៅ**ស្រុកកងមាស ស្រុកក្រូចឆ្មារ និងស្រុកស្ទឹងត្រង់** និងនៅ**តំបន់ ៥**) និងប្រជាជនវៀតណាម (នៅខេត្ត **ព្រៃវែង** និង**ស្វាយរៀង និងមន្ទីរស-២១ កោះខ្យង ក្រាំងតាចាន់ គោកក្តួច វត្តផ្លុក និងភ្នំក្រោល**)។

១៥២២- ភស្តុតាងបញ្ជាក់ថាក្នុងករណីជាច្រើននៃការស្លាប់ ដែលត្រូវបានបង្កឡើងដោយវិធីសាស្ត្រផ្សេងៗក្រៅពីការប្រហារជីវិត (ដូចជា ការបួមឈាម និងការពិសោធន៍វេជ្ជសាស្ត្រនៅ**មន្ទីរស-២១**) ការសម្លាប់ទាំងនេះគឺជាអំពើដែលបានគិតទុកជាមុនក្នុងលក្ខណៈស្រដៀងៗគ្នា។

*ចេតនា*

១៥២៣- ការសម្លាប់ដែលបានរៀបរាប់ខាងលើ ត្រូវបានអនុវត្តដោយចេតនាបង្កឲ្យមានការស្លាប់ និងដើម្បីសម្រេចគោលនយោបាយមួយចំនួនដែលមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតឡើង។ ក្នុងចំណោមប្រការផ្សេងៗ គេអាចទាញសន្និដ្ឋានឲ្យឃើញអំពីចេតនានោះតាមរយៈការអនុវត្តទូទាំងប្រទេសនូវគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា លក្ខណៈនៃការប្រហារជីវិតដែលបានរៀបចំទុកជាមុន និងការរាយការណ៍អំពីការប្រហារជីវិតទាំងនោះជូនមជ្ឈិមបក្ស។

## អំពើមនុស្សឃាតថ្នាក់ទី២

## អំពើសកម្ម និងអកម្ម

១៥២៤- បន្ថែមពីលើការសម្លាប់ដែលបានគិតទុកជាមុន ការស្លាប់នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវបានបង្កឡើងដោយមធ្យោបាយផ្សេងៗ។ មធ្យោបាយទាំងនេះរួមមាន ការសម្លាប់ប្រជាជនស៊ីវិលដែលបានខកខានពុំបានគោរពបញ្ជា ក្នុងអំឡុងពេលនៃការជម្លៀសដោយបង្ខំ និងការសម្លាប់មនុស្សដែលប៉ុនប៉ងលួចរត់ ឬលួចអាហារនៅតាមមន្ទីរសន្តិសុខ ឬការដ្ឋានធ្វើការងារពលកម្មដោយបង្ខំ (មន្ទីរសន្តិសុខ**អូរកន្សែង** ការដ្ឋានសាងសង់**ព្រលានយន្តហោះកំពង់ឆ្នាំង**)។

## ចេតនា

១៥២៥- ដោយពិចារណាឃើញថាការសម្លាប់ដូចដែលបានរៀបរាប់ខាងលើ ត្រូវបានអនុវត្តជាទណ្ឌកម្មសម្រាប់ការរំលោភវិន័យ ឬការប៉ុនប៉ងលួចរត់ យើងឃើញជាក់ស្តែងថាក្នុងករណីនីមួយៗ ចារីពិតជាមានចេតនាបង្កអោយជនរងគ្រោះស្លាប់ប្រាកដមែន។

## អំពើមនុស្សឃាតថ្នាក់ទី១

## អំពើ និងការខកខាន

១៥២៦- ដូចដែលបានលើកឡើងក្នុងផ្នែក មនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗ ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រជាជនស៊ីវិលរាប់ម៉ឺននាក់បានស្លាប់ដោយសារភាពអត់ឃ្លាន ការបាក់កម្លាំង អាកាសធាតុ កង្វះការថែទាំវេជ្ជសាស្ត្រ និងស្ថានភាពអមនុស្សធម៌ផ្សេងៗ ដោយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើង (១) អំឡុងពេលនៃការជម្លៀសដោយបង្ខំទាំង៣លើក (២)នៅតាមមន្ទីរសន្តិសុខ(**ស-២១ កោះខ្សាង សៀមរាប វត្តធ្លក អូរកន្សែង គោកក្ដួច និងសង់**) និង(៣) នៅតាមការដ្ឋានធ្វើការងារដោយបង្ខំ (ក្នុងនោះរួមមាន

**ទំនប់ត្រពាំងថ្ម ព្រលានយន្តហោះកំពង់ឆ្នាំង** និង**ស្រែអំបិល**)។ ការស្លាប់មួយចំនួនធំក៏បានបណ្តាលមកពីការធ្វើទារុណកម្ម និងការវាយដំនៅតាមមន្ទីរសន្តិសុខ(**មន្ទីរស-២១ ក្រាំងតាចាន់ សង់ គោកក្តួច សៀមរាប កោះខ្យង វត្តធ្លក អូរកន្សែង**)។ ការធ្វើអត្តឃាតក៏ត្រូវបានបង្កឡើងដោយការរំលោភបំពានអ្នកទោស និងស្ថានភាពដែលអ្នកទោសបានទទួលរងពីសំណាក់ចារី (**មន្ទីរស-២១** និង**អូរកន្សែង**)។ ការស្លាប់មួយចំនួនបានបណ្តាលមកពីការប៉ុនប៉ងលួចរត់ពុំបានសម្រេច (**ការដ្ឋានស្រែអំបិល**)។

## ចេតនា

១៥២៧- ដូចដែលបានពិភាក្សាពាក់ព័ន្ធនឹងចេតនាចាំបាច់សម្រាប់មនុស្សឃាត ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការស្លាប់ភាគច្រើនដែលបានរៀបរាប់ខាងលើ ត្រូវបានបង្កឡើងដោយចារីដែលមានចេតនាជាក់លាក់ក្នុងការបង្ករបួសស្នាមដល់ជនរងគ្រោះ បើទោះបីចារីពុំចាំបាច់មានចេតនាបង្កឱ្យមានការស្លាប់ក្តី។ ស្ថានភាពអមនុស្សធម៌ និងការរំលោភបំពានត្រូវបានដាក់ជាប្រព័ន្ធទៅលើជនរងគ្រោះ និងនៅតែពុំមានការប្រែប្រួល បើទោះបីមានផលវិបាកជាក់ស្តែងដល់ជនរងគ្រោះក្តី (រួមទាំង ការស្លាប់)។

## ការធ្វើទារុណកម្ម

១៥២៨- ភស្តុតាងក្នុងសំណុំរឿងបង្ហាញថា ការធ្វើទារុណកម្មដែលអាចផ្តន្ទាទោសបានតាមមាត្រា៣ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ។

## អំពើសកម្ម និងអំពើអកម្ម

១៥២៩- អំពើសកម្ម និងអំពើអកម្មដែលបានរៀបរាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺអាចយកមកអនុវត្តបានដូចគ្នា ចំពោះការធ្វើទារុណកម្មតាមមាត្រា៣។

## ចេតនា

១៥៣០- ធាតុផ្សំនៃចេតនាដែលបានរៀបរាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ក្នុងប្រភេទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺអាចយកមកអនុវត្តបានដូចគ្នាចំពោះការធ្វើទារុណកម្មតាមមាត្រា៣។

## គោលបំណង

១៥៣១- ដូចបានរៀបរាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហេតុផលចម្បងនៃការធ្វើទារុណកម្មជនរងគ្រោះ ក្នុងអំឡុងពេលហេតុការណ៍ក្រោមកិច្ចស៊ើបសួរគឺដើម្បីកំណត់អត្តសញ្ញាណ និងកម្ទេចក្រុមផ្សេងៗ ដែលបក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅក្នុងយុទ្ធនាការកាប់សម្លាប់របស់ខ្លួន។ ការធ្វើទារុណកម្មក៏ត្រូវបានប្រើប្រាស់ ដើម្បីស្រង់ព័ត៌មាន ដែលបញ្ជាក់អំពីបទល្មើសរបស់អ្នកទោស ដែលគេបានចោទប្រកាន់ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា និងដើម្បីផ្តល់ភាពសមស្របដល់ការប្រហារជីវិតរបស់ពួកគេ។ ដូច្នេះការធ្វើទារុណកម្មត្រូវបានយកមកអនុវត្ត ដើម្បីទទួលបានព័ត៌មានមានប្រយោជន៍សម្រាប់ការប្រព្រឹត្តិបទល្មើសនោះ។

១៥៣២- នៅតាមមន្ទីរសន្តិសុខនានា ការធ្វើទារុណកម្មក៏ត្រូវបានប្រើប្រាស់សម្រាប់ជាការសងសឹក ក្នុងពេលដែលអ្នកទោសត្រូវបានទទួលរងទារុណកម្មជាទណ្ឌកម្មសម្រាប់បទល្មើស ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។ ភ័ស្តុតាងពាក់ព័ន្ធនឹងការបណ្តុះបណ្តាលអ្នកសួរចម្លើយនៅមន្ទីរ ស-២១ បញ្ជាក់អះអាងអំពីគោលបំណងនេះ។ ខ្មែរក្រហមតម្រូវឱ្យអ្នកសួរចម្លើយបន្ថោក និងចាត់ទុកអ្នកទោសដូចសត្វ ដោយហេតុថាអ្នកទោសត្រូវបានចាត់ទុកថាជាខ្មាំងនៃរបបនេះ។

១៥៣៣- លើសពីនេះ ទារុណកម្មត្រូវបានប្រព្រឹត្តយ៉ាងឃោរឃៅនៅតាមមន្ទីរសន្តិសុខ និងការដ្ឋានធ្វើការងារដោយបង្ខំ ដោយហេតុថាជនរងគ្រោះត្រូវទទួលរងក្នុងលក្ខណៈជាប្រព័ន្ធនូវអំពើសាហាវយង់ឃ្នងក្រៃលែង។ ទារុណកម្មក៏ត្រូវបានធ្វើឡើងដើម្បីបង្កការឈឺចាប់ធំធេង និងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរដល់ជនរងគ្រោះ ទោះបីទារុណកម្មនេះត្រូវបានអនុវត្តដើម្បីយកព័ត៌មាន ឬដាក់ទណ្ឌកម្មក្តី។ ចំណុចនេះត្រូវបានបញ្ជាក់អះអាងដោយភ័ស្តុតាងនៃប្រភេទទារុណកម្មដែលបានយកមកអនុវត្ត របួសស្នាមធ្ងន់ធ្ងរដែលបានបង្កឡើង និងកាលៈទេសៈនៃការធ្វើទារុណកម្មជនរងគ្រោះ។ ករណីធ្ងន់ធ្ងរនៃអំពើសាហាវយង់ឃ្នងរួមមាន ការវាយដំ និងការធ្វើទារុណកម្មផ្លូវកាយនៅចំពោះមុខអ្នកទោសផ្សេងៗ(**សៀមរាប**) ការធ្វើអោយអ្នកទោសបាក់ស្បាត ក្រោមរូបភាពជាការរំលោភបំពានផ្លូវចិត្ត ការគំរាមកំហែង និងការបំភិតបំភ័យ តាមរយៈការធ្វើទារុណកម្មផ្លូវកាយធ្ងន់ធ្ងរ (**មន្ទីរស-២១**) ការប្រើប្រាស់វិធីសាស្ត្រសាហាវព្រៃផ្សៃក្នុងការធ្វើទារុណកម្មដូចជាការបង្ខំអ្នកទោសឱ្យស៊ីលាមក (**មន្ទីរស-២១**) ឬដេកជាមួយសាកសព ឬមនុស្សជិតស្លាប់ (**សង់**) ការកប់អ្នកទោសទាំងរស់ (**វត្តធ្លក**) និងការបញ្ជាឱ្យមានការវាយដំធ្ងន់ធ្ងរនៅតាមការដ្ឋាន

ដោយសារមូលហេតុពុំសម្រេចតាមបរិមាណការងារ ការប្រព្រឹត្តិគ្នាំឆ្គង និងការខកខានពុំព្រម "កែខ្លួន" (ទំនប់១មករា ស្រែអំបិល)។

## ខ-ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

## នួន ជា

### សេចក្តីសង្ខេប

១៩៣៤- ភស្តុតាងនៅក្នុងសំណុំរឿង និងដែលត្រូវបានយកមកធ្វើជាសំអាងនៅក្នុងផ្នែកអង្គហេតុសត្យានុម័តនានា បញ្ជាក់ថា **នួន ជា** ជាអ្នកទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះ*ការរំលោភបំពានក្រុមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩* អនុលោមតាមមាត្រា ៣(ថ្មី) ៤, ៥, ៦, និង ២៩ នៃច្បាប់ អ.វ.ត.ក។

១៩៣៥- ជាពិសេស **នួន ជា** ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌជាលក្ខណៈបុគ្គលអនុលោមតាមមាត្រា ២៩៖ ១) ពីព្រោះគាត់បានប្រព្រឹត្ត បានធ្វើផែនការ បានញុះញង់ បានបញ្ជា និង/ឬបានជួយនិងជម្រុញចំពោះឧក្រិដ្ឋកម្មទាំងនេះ និង ២) ដោយសារតែការខកខានរបស់គាត់ដែលក្នុងនាមជាថ្នាក់លើម្នាក់ដែលបានដឹងថាអ្នកក្រោមបង្គាប់គាត់ហៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ មិនបានធ្វើការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬមិនបានដាក់ទណ្ឌកម្មដល់ចារី ។

១៩៣៦- តាមរយៈការប្រើពាក្យថា "បានប្រព្រឹត្ត" នៅក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញា មិនបានចោទប្រកាន់ថា **នួន ជា អៀង សារី ខៀវ សំផន** និង **អៀង ធីរិទ្ធ** ពិតជា បានប្រព្រឹត្តដោយផ្ទាល់

នូវឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនេះឡើយ។ ការប្រព្រឹត្តិនៅក្នុងដីកាសន្និដ្ឋាននេះ នៅពេលដែលគេប្រើទាក់ទិនទៅនឹងជនត្រូវចោទទាំងនេះ គឺសំដៅទៅលើការចូលរួមដោយផ្ទាល់ ឬដោយប្រយោលជាសហចារី នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

## ទម្រង់នៃការទទួលខុសត្រូវ

## ការប្រព្រឹត្តិតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម

១៥៣៧- **នួន ជា** ជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ក្នុងទម្រង់ជាមូលដ្ឋាន និងជាប្រព័ន្ធ។

### សហកម្មឧក្រិដ្ឋកម្មរួម ១ (មូលដ្ឋាន)

*រយៈពេល*

១៥៣៨- សហកម្មឧក្រិដ្ឋកម្មរួមនេះ **មានអត្ថិភាព** យ៉ាងហោចណាស់នៅត្រឹមខែមិថុនា ឆ្នាំ១៩៧៤ និងបន្តពេញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ដែលក្នុងអំឡុងពេលនោះ ឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ ត្រូវបានប្រព្រឹត្តឡើង។

*គោលបំណង*

១៥៣៩- គោលដៅជាចំបង នៃសហកម្មឧក្រិដ្ឋកម្មរួមនេះទាក់ទងទៅនឹងចេតនារបស់ជនត្រូវចោទក្នុងការចង់ពង្រឹងការអនុវត្តនូវបដិវត្តន៍នយោបាយមួយ និងបំផ្លាញចោលនូវអ្នកនយោបាយប្រឆាំងណាមួយនឹងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្ត (បកក)។ មានគោលដៅសំខាន់ៗចំនួន៣នៅក្នុង

សហកម្មឧក្រិដ្ឋកម្មរួមៈ (១) គឺដើម្បីចង់ដាក់ប្រជាជនស៊ីវិលចំនួនភាគច្រើនបំផុតឱ្យទៅជាទាសករនៅតាមបណ្ដាសហករណ៍កសិកម្ម និងការដ្ឋានពលកម្មនានា ។ (២) ដើម្បីធ្វើការលុបបំបាត់ចោលឱ្យអស់នូវរាល់សិទ្ធិមនុស្ស និងសេរីភាពរបស់ប្រជាជនដែលរួមមាន សិទ្ធិក្នុងការមានសេរីភាព និងសន្តិសុខ, សិទ្ធិក្នុងការនិយាយស្ដីដោយសេរី, សិទ្ធិមានគ្រួសារ និងសិទ្ធិខាងសាសនា។ និង (៣) ដើម្បីស្រាវជ្រាវរកក្នុងលក្ខណៈជាប្រព័ន្ធ និងដើម្បីសម្លាប់ជនទាំងឡាយណាដែលត្រូវបានស្គាល់អត្តសញ្ញាណថាជាសត្រូវឬ អ្នកប្រឆាំងពិតប្រាកដ និងដ៏មានសក្ដានុពលរបស់ បកក ។ គោលដៅទាំងនេះដែលមានលក្ខណៈឧក្រិដ្ឋ ត្រូវបានគេព្រមព្រៀងគ្នាថាត្រូវសំរេចឱ្យបានតាំងតែពីដំបូងមកដោយមធ្យោបាយនានាដែលរួមមាន ការប្រព្រឹត្តិនូវបទឧក្រិដ្ឋកម្មផ្សេងៗដូចជា ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការជម្លៀសចេញដោយការប្រើកម្លាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើពលកម្មដោយបង្ខំ ការឱ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការចាប់រំលោភសេពសន្ថវៈ ការធ្វើទារុណកម្ម ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ អំពើអមនុស្សធម៌ និងឧក្រិដ្ឋកម្មដទៃទៀតដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះស្រាប់។ ឧក្រិដ្ឋកម្មទាំងនេះត្រូវផ្ដន្ទាទោសផ្អែកតាមមាត្រា៣(ថ្មី) , មាត្រា៤, ៥ និងមាត្រា ៦ នៃច្បាប់អវតក។

១៥៤០- នៅក្នុងឆ្នាំ១៩៧៧ ជនត្រូវចោទទាំងនេះ និងសមាជិកដទៃៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួមបានពង្រីកមធ្យោបាយនៃឧក្រិដ្ឋកម្មរបស់ខ្លួន ដោយរួមបញ្ចូលនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើក្រុមជនជាតិចាម និងវៀតណាមដែលនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះ ទោះបីជាគោលដៅឧក្រិដ្ឋក្នុងការដកចេញ ឬបំផ្លាញចោលនូវពួកអ្នកដែលគេយល់ឃើញថាជាសត្រូវឬអ្នកប្រឆាំងពិតប្រាកដឬដ៏មានសក្ដានុពល គឺស្ថិតនៅដដែលមិនមានការប្រែប្រួលទេនៅក្នុងទូទាំងអម្លុងពេល

ទាំងមូលនៃសហាកម្មឧក្រិដ្ឋកម្មរួមនោះក៏ដោយ ក៏ការផ្ដោតរបស់មជ្ឈិមបក្សបានប្ដូរទិសសំដៅផ្ដោះទៅរកពួកក្បត់ផ្ទៃក្នុងវិញដែរ។ ក្នុងការចាប់ផ្ដើមដំបូង ផ្នែកនេះនៃសហាកម្មក្រិដ្ឋកម្មរួមបានផ្ដោតជាសំខាន់ទៅលើសមាជិកនានានៃរបបសាធារណៈរដ្ឋខ្មែរ និងជនដទៃៗទៀត ដែលត្រូវបានគេយល់ឃើញថា មានការជាប់ទាក់ទងទៅនឹងវណ្ណៈមូលធន សក្ដិភូមិ ចក្រពត្តិ ហើយនិងអភិជន។ នៅក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ មជ្ឈិមបក្សបានខំប្រឹងផ្ដោតការប្រមូលផ្ដុំរបស់ខ្លួនលើការសម្លាប់ពួកអ្នកដែលត្រូវបានគេចោទថាជា ភ្នាក់ងារសេអ៊ីអា កាហ្សេបេ និងវៀតណាម និងអ្នកចូលដៃ ដែលត្រូវបានគេសន្មត់ថា បានជ្រៀតចូលនៅតាមមូលដ្ឋាននានា និងនៅក្នុងជួរបក្សនៅគ្រប់លំដាប់ថ្នាក់។

*សមាជិកភាព*

១៥៤១- សមាជិនានានៃសហាកម្មឧក្រិដ្ឋកម្មរួម រួមមាន៖ សមាជិកទាំងឡាយនៃ គណៈអចិន្ត្រៃយ៍នៃ បកក ដែលជាក់ស្ដែង និង*កំពុងកាន់តំណែងក្នុងពេលនោះ(តាមព្រឹត្តន័យ)* ពោលគឺៈ ប៉ុល ពត **នួន ជា អៀង សារី ខៀវ សំផន** សុន សេន តា ម៉ុក សោ ភឹម វន វេត និង សឿ វ៉ាស៊ី។ សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សនៃ បកក ប្រធាន និងសមាជិកគណៈកម្មការនានានៃ បណ្ដាក្រសួងនានានៃ បកក ដែលក្នុងនោះរួមមាន **អៀង ធីរិទ្ធ** និងប្រធាន ហើយនិងសមាជិកនានានៃបណ្ដាកងពលធំយោធា ភូមិភាគ តំបន់ ស្រុក និងមន្ទីរសន្ដិសុខនានា ដែលក្នុងនោះរួមមាន **ឌុច** ។ ជនម្នាក់ៗក្នុងចំណោមជនទាំងនេះ ដោយសារតែអំពើ ឬការខាកខានរបស់ខ្លួនបានរួមចំណែកនៅក្នុងការធ្វើឱ្យបានសម្រេច នូវការចែករំលែកនូវគោលដៅនៃសហាកម្មឧក្រិដ្ឋកម្មរួម។ ផ្ទុយទៅវិញ ជនមួយចំនួននៅក្នុងចំណោមជនទាំងនេះ គឺមិនមែនជាសមាជិកនៃ

សហករណ៍ឧក្រិដ្ឋកម្មរួមទទែតែត្រូវបានសមាជិកនៅក្នុងសហករណ៍នេះ ប្រើប្រាស់ដើម្បីឱ្យអនុវត្តនូវឧក្រិដ្ឋកម្មផ្សេងៗ ដែលត្រូវបានប្រព្រឹត្តដើម្បីជួយជំរុញគោលដៅរបស់ខ្លួនឱ្យបានស្ថិតនៅជាបន្តទៅទៀត។

១៥៤២- សមាជិកភាពរបស់ **នួន ជា អៀង សារី ខៀវ សំផន** និង**អៀង ធិរិទ្ធ** នៅក្នុងសហករណ៍ឧក្រិដ្ឋកម្មរួម ត្រូវបានបង្ហាញឱ្យឃើញតាមរយៈ៖ ការចូលរួមវិភាគទាននានានិងចេតនាក្នុងការចូលរួមរបស់ពួកគាត់នៅក្នុងសហករណ៍ឧក្រិដ្ឋកម្មរួម ការកាន់មុខដំណែងដ៏មានអំណាចក្នុងរយៈពេលយូរ និងឥទ្ធិពលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានិងស្ថាប័នដែលពាក់ព័ន្ធដទៃទៀត ហើយនិងការទំនាក់ទំនងការងារដ៏ជិតស្និទ្ធជាមួយគ្នាទៅវិញទៅមក និងជាមួយសមាជិកនៃសហករណ៍ឧក្រិដ្ឋកម្មរួមដទៃទៀត។ ជនត្រូវចោទទាំងនេះបានចូលរួមនៅក្នុងគំនិតយល់ឃើញពីដំបូងនៃសហករណ៍ឧក្រិដ្ឋកម្មរួម នៅមុនរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្រោយពីបានឡើងកាន់អំណាចដែលបានធ្វើសកម្មភាព នានាទាំងអស់គ្នាដើម្បីជំរុញការអនុវត្តនូវសហករណ៍ឧក្រិដ្ឋកម្មរួមឱ្យបានបន្តទៅមុខទៀត។ តាមតួនាទីជាក់លាក់ដែលបានកាន់ និងតួនាទីដែលជនត្រូវចោទទាំងនេះបានដើរតួនៅក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ កាន់តែបង្ហាញឱ្យឃើញជាបន្ថែមទៀតពី មុខតំណែងលំដាប់ដ៏ខ្ពស់បំផុតរបស់ពួកគេនៅក្នុង បកក ឬកម្ពុជាប្រជាធិបតេយ្យ និងសមាជិកភាពរបស់ពួកគេនៅក្នុងសហករណ៍ឧក្រិដ្ឋរួម៖

(១) មុខតំណែងរបស់ **នួន ជា** គឺអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកខ្ពស់បំផុតលំដាប់ទីពីររបស់បក្សកុម្មុយនីស្តកម្ពុជា សមាជិកនៃគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការយោធា ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន នាយករដ្ឋមន្ត្រីស្តីទី និងរដ្ឋមន្ត្រីក្រសួងឃោសនាការ។

(២) មុខតំណែងរបស់ **អៀង សារី** គឺសមាជិកនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ហើយ និងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។

(៣) មុខតំណែងរបស់ **ខៀវ សំផន** គឺសមាជិកនៃគណៈមជ្ឈិម *តាមជាក់ស្តែង* ជាសមាជិកនៃគណៈគណៈកម្មាការធិការអចិន្ត្រៃយ៍ ប្រធាននៃគណៈប្រធានរដ្ឋ សមាជិកនិងជាប្រធានមន្ទីរនយោបាយ៨៧០ និងសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាទទួលបន្ទុកកិច្ចការសេដ្ឋកិច្ច។ និង

(៤) មុខតំណែងរបស់ **អៀង ធីរិទ្ធ** គឺរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច សមាជិកសភាតំណាងប្រជាជន និងអនុប្រធាននៃសមាគមស្ត្រី ។

១៥៤៣- ដូចបានពោលខាងលើ និងជាការបន្ថែមទៅលើមុខនាទីផ្លូវការខាងលើ ជនត្រូវចោទម្នាក់ៗបានអនុវត្តនូវអំណាច និងឥទ្ធិពលយ៉ាងទូលំទូលាយ តាមរយៈឋានៈរបស់ខ្លួនក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា អស់ពេលដ៏យូរ, សម្ព័ន្ធមិត្តជិតស្និទ្ធរបស់ ប៉ុល ពត និងសកម្មភាពលេចធ្លោរនានារាប់ទសវត្សរ៍មកហើយនៅមុនពេលនៃការចាប់ផ្តើមសម័យកាលកម្ពុជាប្រជាធិបតេយ្យ ។

## *ការរួមចំណែក*

១៥៤៤- **នួន** ជា ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល តាមរយៈទំនាក់ទំនង តួនាទី និងសមាជិកភាព របស់គាត់ ដែលត្រូវបានរៀបរាប់នៅក្នុងផ្នែកនេះ និងជាមួយនឹងសមាជិកដទៃទៀត នៃសហកម្មឧក្រិដ្ឋកម្មរួម បានរួមចំណែកយ៉ាងសំខាន់ចំពោះសកម្មភាពទាំងនេះ តាមរយៈ ៖

(១) **ចូលរួមក្នុងការបង្កើតមាគ៌ានយោបាយរបស់បក្ស** និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនាំឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដូចដែលមាននៅក្នុងដីកាសន្និដ្ឋាននេះ។

(២) **ការចូលរួមក្នុងការបង្កើត រៀបចំ និង/ឬ** គ្រប់គ្រងស្ថាប័នរបស់បក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា រួមមាន គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការយោធា គណៈកម្មាធិការមន្ទីរ៨៧០ គណៈកម្មាធិការភូមិភាគ គណៈកម្មាធិការតំបន់ គណៈកម្មាធិការស្រុក និងគណៈកម្មាធិការថ្នាក់ក្រោម អគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា កងពលធំ និងកងវរសេនាធំ និងគណៈកម្មាធិការដទៃទៀត ក្រសួងនានា និងកងឈ្លប ដែលទទួលខុសត្រូវចំពោះមុខមជ្ឈិមបក្ស ដែលតាមរយៈនេះ បទឧក្រិដ្ឋនានានៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានប្រព្រឹត្តឡើង។

(៣) **ការធ្វើផែនការ និងការសម្របសម្រួលនូវកាប្រព្រឹត្តិបទឧក្រិដ្ឋ** តាមរយៈការចូលរួមក្នុងកិច្ចប្រជុំកិច្ចពិភាក្សា និងនៅក្នុងការធ្វើសេចក្តីសម្រេចរបស់មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។

(៤) **ការបញ្ជា ការអនុវត្តការត្រួតត្រាទៅលើ និងផ្សេងពីនេះការដឹកនាំទៅកម្មាភិបាលនានា** ដោយមានអង្គភាពយោធា និងរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជា ដើម្បីប្រព្រឹត្តឧក្រិដ្ឋនានាដែលរួមមាន តាមរយៈការចូលរួមក្នុងការបង្កើត និងការចេញបទបញ្ជារបស់មន្ទីរ៨៧០ ការចូលរួមប្រជុំជាមួយកម្មាភិបាលថ្នាក់ក្រោមដែលដែលពាក់ព័ន្ធក្នុងបទឧក្រិដ្ឋ ការទទួលរបាយការណ៍របស់ពួកគេ និងរក្សាការត្រួតត្រាទៅលើពួកគេ។

(៥) **ការជាប់ពាក់ព័ន្ធដោយផ្ទាល់នៅក្នុងបទឧក្រិដ្ឋ** ដែលរួមមានតាមរយៈ៖ការចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើផែនការចុងក្រោយនៃការជម្លៀសមណ្ឌលប្រជុំជនដោយបង្ខំ។ បានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការបង្កើតមុខងាររបស់ម៉ាស៊ីនសន្តិសុខ តាមរយៈការទទួល របាយការណ៍នានាស្តីពីបញ្ហាសន្តិសុខ (ដូចជារបាយការណ៍ពីមន្ទីរសន្តិសុខនៅតាមភូមិភាគ តំបន់ស្រុកនានា) និងការផ្តល់នូវសេចក្តីណែនាំអំពីការចាប់ខ្លួន និងការកម្ទេចខ្មាំង។ ការត្រួតពិនិត្យ និងការចេញសេចក្តីណែនាំដល់ **ឌុច** ទាក់ទិននឹងការចាប់ខ្លួន ការធ្វើទារុណកម្ម និងការប្រហារជីវិតខ្មាំងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា **នៅមន្ទីរស២១**។ ការបញ្ជា និងការសម្រប សម្រួលក្នុងការបញ្ជូនចម្លើយសារភាពនៅ**មន្ទីរស២១** និងឈ្មោះកម្មាភិបាលដែលមានជាប់ពាក់ព័ន្ធទៅកាន់ប្រធានអង្គភាពនានានៅទូទាំងប្រទេស និងការផ្តល់អំណាច និងការបង្គាប់ឲ្យប្រធានយោធា និងរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទាំងប្រទេស កម្ទេច "ខ្មាំង" នៅក្នុងមូលដ្ឋានរបស់ពួកគេ។

(៦) **ការញុះញង់ ការជម្រុញ និងការលើកទឹកចិត្ត** ឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ រួមទាំងតាមរយៈការចុះពិនិត្យតាមទីតាំងប្រព្រឹត្តបទល្មើស (ដូចជា **ព្រលានយន្តហោះកំពង់ឆ្នាំង ទំនប់១មករា** និង **កន្លែងផលិតអំបិលនៅស្រែអំបិល**) ការចេញសេចក្តីណែនាំគោលនយោបាយ និងការបំពាន់បំប៉នគោលនយោបាយកម្មាភិបាល និងមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា ដែលជាប់ពាក់ព័ន្ធក្នុងប្រព្រឹត្តបទឧក្រិដ្ឋ ការថ្កោលទោសអ្នកទាំងឡាយណាដែលមិនអនុវត្តតាមមាគ៌ានយោបាយបក្សកុម្មុយនីស្តកម្ពុជា ការត្រៀមរៀបចំ និង/ឬ ការអនុម័តលើការបោះពុម្ពផ្សាយផ្ទៃក្នុងបក្សដែលត្រូវបានគេបញ្ជូនទៅកម្មាភិបាលផ្សេងៗ (ដូចជា ទស្សនាវដ្តីទង់បដិវត្តន៍) ការផ្តល់សេចក្តី

ថ្លែងការណ៍ និងសុន្ទរកថាសាធារណៈដោយការពារ និងអនុម័តគោនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា និងលើកទឹកចិត្តឱ្យជនដែលប្រព្រឹត្តបទឧក្រិដ្ឋនានា។

(៧) **ការធ្វើតំណាងឱ្យ**បក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធជាមួយគណៈប្រតិភូបរទេស និងការធ្វើយុត្តិកម្មចំពោះគោលនយោបាយរបស់ខ្លួនដែលបាន **ខកខានមិនបានបញ្ឈប់** ការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួម ទោះបីជាដឹងថាបទឧក្រិដ្ឋ ដែលកំពុងត្រូវបានប្រព្រឹត្តនោះស្របទៅនឹងសហកម្មឧក្រិដ្ឋកម្មរួមយ៉ាងណាក៏ដោយ និងទោះបីជាគាត់មានអំណាចបញ្ឈប់បទឧក្រិដ្ឋទាំងនោះ ឬដាក់ទណ្ឌកម្មជនល់ចារីយ៉ាងណាក៏ដោយ និង

(៨) ផ្សេងពីនេះ **ការធ្វើផែនការ ការញុះញង់ ការបញ្ជា** និង **ការជួយ និងជម្រុញ** ឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ ដូចដែលបានរៀបរាប់ខាងក្រោមនេះ ៖

*ចេតនា*

១៥៤៥- **នួន ជា** ដែលមានចេតនារួម ជាមួយសមាជិកផ្សេងៗទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋនីមួយៗនៃបទឧក្រិដ្ឋទាំងឡាយ ដែលត្រូវបានឯកភាពពីដំបូង និងសម្រាប់ការព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានឯកភាពជាបន្តបន្ទាប់មកទៀត [ដូចបានរៀបរាប់នៅក្នុងផ្នែកផែនការឧក្រិដ្ឋកម្មរួម និងផ្នែកការកំណត់បទចោទ (ឧក្រិដ្ឋកម្ម)] ជាមធ្យោបាយចាំបាច់ដើម្បីសម្រេចឱ្យបាននូវគោលបំណងឧក្រិដ្ឋកម្មរួម។ ចេតនារបស់ **នួន ជា** អាចត្រូវបានកំណត់ និង/ឬ ទាញសេចក្តីសន្និដ្ឋានចេញពីអង្គហេតុដូចខាងក្រោមនេះ ក្នុងចំណោមបញ្ហាផ្សេងទៀត ៖

(១) ការទទួលយកដោយស្ម័គ្រចិត្ត និងការយល់ព្រមចូលរួមរបស់គាត់នៅក្នុងការចាត់តាំងមុខតំណែង និងតួនាទីជាន់ខ្ពស់ ដែលអាចឱ្យគាត់ចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

(២) សកម្មភាពរបស់គាត់នៅក្នុងការចាប់ផ្តើមឱ្យមានបទឧក្រិដ្ឋ ជាមួយនឹងសហចារីទាំងឡាយរបស់គាត់ និងធ្វើឱ្យមានការប្រព្រឹត្តិរបស់ពួកគេជាបន្តទៀត ដូចបានរៀបរាប់តាមរយៈការរួមចំណែកដែលបានរៀបរាប់ខាងលើ។

(៣) សុន្ទរកថា និងសេចក្តីថ្លែងការណ៍របស់គាត់ នៅមុន និងក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន សេចក្តីថ្លែងការណ៍ និងសន្ទរកថាទាំងនោះ ដែលគាត់បានបញ្ជាក់ថាប្រទេសជាតិកំពុងញាំញីដោយ "ខ្មាំង" បង្កប់ផ្ទៃក្នុងដែលវត្តមានរបស់ខ្មាំងទាំងអស់នោះចាំបាច់តម្រូវឱ្យមានការចាប់ខ្លួន និងការសម្លាប់យ៉ាងរីករាលដាល និងបដិសេធសិទ្ធិជាមូលដ្ឋានចំពោះសមាជិកដទៃទៀតរបស់ប្រជាជនទាំងនោះ។

(៤) ការរួមចំណែករបស់គាត់នៅក្នុងការបង្កើត ការផ្សព្វផ្សាយ និងការគាំទ្រការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា (រួមមាន សេចក្តីថ្លែងការណ៍នៅក្នុងទស្សនាវដ្តី *ទង់បដិវត្ត*)។

(៥) សេចក្តីថ្លែងការណ៍របស់គាត់ ក្នុងអំឡុងការបំពាក់បំប៉នឧនយោបាយដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និង

(៦) សេចក្តីថ្លែងការណ៍របស់របស់គាត់នៅក្រោយសម័យកាលនេះ ដែលឋិតនៅក្រោមកិច្ចស៊ើបសួរ បានបង្ហាញឱ្យឃើញពីការគាំទ្រជាបន្តបន្ទាប់របស់គាត់ ចំពោះគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្ត សូម្បីតែប៉ុន្មានទសវត្សរ៍នៅក្រោយការដកអំណាចរបស់គាត់ក៏ដោយ។

## សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ)

១៥៤៦- លើសពីនេះទៀត **នួន ជា** ទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ដោយអនុវត្តស្របទៅនឹងប្រព័ន្ធធ្វើបាប

ដែលបានរៀបចំមកលើប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធនៃការធ្វើបាបប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងការបង្កើតជាប្រព័ន្ធ និងទូទាំងប្រទេស នូវសហករណ៍ ជំរំធ្វើពលកម្មដោយបង្ខំ មណ្ឌលលត់ដំ និងមន្ទីរសន្តិសុខនានាដូចបានរៀបរាប់នៅក្នុងជំពូកអង្គហេតុជាក់ស្តែង។ នួន ជា បានដឹងអំពីលក្ខណៈនៃប្រព័ន្ធនៃការបង្ក្រាប បានចូលរួមនៅក្នុងការអនុវត្តប្រព័ន្ធនេះ និងមានចេតនាដើម្បីជ្រោមជ្រែងដល់ផែនការនៃការធ្វើបាបជាប្រព័ន្ធនេះ។

## ការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជម្រុញ

### សេចក្តីផ្តើម

១៥៤៧- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ដោយសារតែការចូលរួមរបស់គាត់នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ក្រឡែតអំពីការទទួលខុសត្រូវរបស់គាត់ ចំពោះបទឧក្រិដ្ឋទាំងឡាយដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ ម្យ៉ាងទៀត នួន ជា ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះ ការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយ និងជម្រុញឲ្យមានបទឧក្រិដ្ឋទាំងនេះ តាមមាត្រា ២៩ កថាខណ្ឌ ១ នៃច្បាប់ អ.វ.ត.ក។

### ការធ្វើផែនការ

១៥៤៨- នួន ជា បានធ្វើផែនការបទឧក្រិដ្ឋ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ គាត់គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលមួយចំនួនទៀតដែលបានរៀបចំបទឧក្រិដ្ឋ និងបង្កើតនូវវិធីសាស្ត្រអនុវត្តបទឧក្រិដ្ឋទាំងនោះ។ ក្រៅពីការធ្វើផែនការបទឧក្រិដ្ឋដោយខ្លួនគាត់ផ្ទាល់នោះ គាត់បាន

យល់ស្រប ឬអនុម័តគោលនយោបាយឧក្រិដ្ឋ ដែលបានបង្កើតឡើងដោយសមាជិកផ្សេងៗទៀតរបស់មជ្ឈិមបក្ស។

១៩៤៩- បទឧក្រិដ្ឋទាំងឡាយត្រូវបានរៀបចំបង្កើត និងដឹកនាំនៅថ្នាក់មជ្ឈិម។ ដោយពិចារណាទៅលើតួនាទីរបស់គណៈអចិន្ត្រៃយ៍ដែលជាអាជ្ញាធរធ្វើសេចក្តីសម្រេចចុងក្រោយ ទៅលើបញ្ហាសំខាន់ៗទាំងអស់ សមាជិករបស់គណៈអចិន្ត្រៃយ៍នេះ រួមទាំង **នួន ជា** មានអំណាចបង្កើតគោលនយោបាយ និងមាគ៌ានានា ដែលអាជ្ញាធររបស់បក្សកុម្មុយនីស្តកម្ពុជា បានអនុវត្តនៅទូទាំងប្រទេស។ ការប្រើប្រាស់អំណាចនេះ **នួន ជា** និងសមាជិកផ្សេងៗទៀតរបស់មជ្ឈិមបក្សបានរៀបចំគម្រោងបទឧក្រិដ្ឋជាក់លាក់ និងបានចាត់តាំងកម្មាភិបាល និងធនធានដទៃទៀតដែលចាំបាច់សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋរបស់ពួកគេ។ ដើម្បីធានា នូវការអនុវត្តផែនការរបស់ពួកគេ ពួកគេបានជួបគ្នាជារឿយៗជាមួយប្រធាន និងបានចេញសេចក្តីណែនាំទៅកាន់ប្រធានស្ថាប័នយោធា និងរដ្ឋបាលនានារបស់បក្សកុម្មុយនីស្តកម្ពុជា។ លក្ខណៈនៃបទឧក្រិដ្ឋដែលត្រូវបានដឹកនាំ និងរៀបចំយ៉ាងលម្អិត ត្រូវបានបង្ហាញ ក្នុងចំណោមបញ្ហាផ្សេងទៀត តាមរយៈភាពស៊ីសង្វាក់គ្នា ចំនួន វិសាលភាព និងលក្ខណៈទូលំទូលាយនៃអំពើឧក្រិដ្ឋ ព្រមទាំងការរាយការណ៍ជាបន្តបន្ទាប់របស់ពួកគេទៅកាន់មជ្ឈិមបក្ស។

១៩៥០- សកម្មភាពរបស់ **នួន ជា** នៅក្នុងការរៀបចំគម្រោងបទឧក្រិដ្ឋ ដែលស្ថិតក្រោមការស៊ើបអង្កេតបានរួមចំណែកយ៉ាងធំដល់ការប្រព្រឹត្តរបស់ពួកគេ។ គាត់បានចូលរួមនៅក្នុង និង/ឬ បានគាំទ្រការរៀបចំ និងការបង្កើតគោលនយោបាយឧក្រិដ្ឋជាច្រើន រួមមាន ៖ ការកម្ទេចខ្មាំង ការបណ្តេញប្រជាជនស៊ីវិលដោយបង្ខំទ្រង់ទ្រាយធំចេញពីទីក្រុង និងការផ្លាស់ប្តូរទីលំនៅដោយ

បង្ខំជាបន្តបន្ទាប់ ការដាក់ប្រជាជនជាទាសករនៅក្នុងសហករណ៍ និងការដ្ឋានធ្វើការនានា ការលុបបំបាត់ចោលព្រះពុទ្ធសាសនា និងការកម្ទេចជនជាតិវៀតណាម និងជនជាតិចាម។ លើសពីនេះទៀត ក្នុងនាមជាសមាជិកម្នាក់នៃគណៈកម្មាធិការឃោសា និងជាសមាជិកគណៈអចិន្ត្រៃយ៍ ទទួលបន្ទុកសន្តិសុខតំបន់ និងវិន័យបក្ស នួន ជា បានរៀបចំ និងបានបង្កើតឲ្យមានការចាប់ខ្លួន ការឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម និងការប្រហារជីវិតអ្នកទាំងឡាយដែលគេយល់ថាជាខ្មាំងនៅមន្ទីរស២១ និងនៅមន្ទីរសន្តិសុខផ្សេងៗទៀត រួមមានតាមរយៈការចូលរួមនៅក្នុងការសម្របសម្រួល ក្នុងការបោសសំអាតទ្រង់ទ្រាយធំនៅក្នុងអង្គភាពកងទ័ពបដិវត្តកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា ព្រមទាំងនៅក្នុងភូមិភាគកណ្តាល ភូមិភាគឧត្តរ ភូមិភាគបស្ចិម ភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨។

១៩៥១- **នួន ជា** មានចេតនារៀបគម្រោងប្រព្រឹត្តបទឧក្រិដ្ឋ ឬដោយសារតែតួនាទី និងមុខតំណែងរបស់គាត់ គាត់បានដឹងអំពីភវនីយភាពយ៉ាងច្រើន ដែលបទឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តឡើងនៅក្នុងការអនុវត្តអំពើដែលគាត់បានរៀបចំ។ ករណីនេះត្រូវបានបង្ហាញតាមរយៈ សេចក្តីថ្លែងការណ៍ស្របគ្នាជាច្រើនរបស់គាត់ ដែលឯកភាពឲ្យមានបទឧក្រិដ្ឋ និងបញ្ជាក់អំពីសេចក្តីណែនាំរបស់របបនោះ ដល់ពួកចារីទាំងឡាយ។ ចេតនារបស់ **នួន ជា** ក្នុងការរៀបគម្រោងបទឧក្រិដ្ឋក៏អាចត្រូវបានទាញសេចក្តីសន្និដ្ឋានផងដែរពីការដឹងឮរបស់គាត់ អំពីការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា និងទម្រង់នៃប្រតិបត្តិការ (រួមមាន ការអនុវត្តដាច់ខាតនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា) និងរបាយការណ៍ដែលគាត់ទទួលបានស្តីអំពីការអនុវត្តសេចក្តីណែនាំ និងមាគ៌ាបក្ស។

# ការញុះញង់

១៥៥២- នួន ជា បានញុះញង់ឲ្យមានបទឧក្រិដ្ឋ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ គាត់បានញ៉ាំង បានជម្រុញ បានលើកទឹកចិត្ត បាននាំអាទិ៍ និងបានចាក់រុកចារីផ្ទាល់ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ។ ការញុះញង់របស់គាត់ឲ្យមានបទឧក្រិដ្ឋទាំងនេះ បានរួមចំណែកយ៉ាងធំដល់ការប្រព្រឹត្តរបស់ពួកគេ។

១៥៥៣- នួន ជា បានលើកទឹកចិត្ត និងបានញ៉ាំងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឲ្យប្រព្រឹត្ត បទឧក្រិដ្ឋតាមរយៈ *ក្នុងចំណោមប្រការផ្សេងទៀត*៖ ការធ្វើសេចក្តីព្រាងសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានផ្តល់ទៅឲ្យពួកកម្មាភិបាល (ដូចជា *ទស្សនាវដ្តីទង់បដិវត្តន៍* ឬសារាចរដែលបានចេញដោយមន្ទីរ៨៧០)។ ការរៀបចំ និងធ្វើជាប្រធានវគ្គរៀនសូត្រនយោបាយ ដែលនៅពេលនោះកម្មាភិបាលត្រូវបានទទួចឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ការចូលរួមប្រជុំជាមួយកម្មាភិបាល ថ្នាក់ក្រោមដែលក្នុងអំឡុងពេលនោះគាត់បានពង្រឹងគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានទទូចឲ្យពួកគេអនុវត្តយ៉ាងតឹងរ៉ឹង។ ការចុះទៅទស្សនកិច្ចនៅទីតាំងឧក្រិដ្ឋកម្ម និងផ្តល់ការលើកទឹកចិត្តដល់ចារីផ្ទាល់តាមរយៈវត្តមានរបស់គាត់ និងតាមរយៈ ពាក្យសំដីរបស់គាត់ ការថ្លែងសុន្ទរកថា និងការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ទទួចឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តបទឧក្រិដ្ឋ។ នៅក្នុងសុន្ទរកថារបស់គាត់តាមរយៈនៃការចង្អុលបង្ហាញ ដែលតែងតែត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តី*ទង់បដិវត្តលើកទី៩* និង/ឬផ្សាយតាមប្រព័ន្ធវិទ្យុ ដែលប្រតិបត្តិការដោយក្រសួងឃោសនាការនោះ នួន ជា បានព្រមានថា ខ្មាំងដែលព្យាយាមបំផ្លាញបដិវត្តន៍គឺមានវត្តមាននៅ

ពាសពេញកម្ពុជាប្រជាធិបតេយ្យ។ គាត់បានអំពាវនាវឱ្យកម្មាភិបាលចាត់វិធានការដាច់ខាត ដោយគ្មានស្ទាក់ស្ទើរឡើយ ដើម្បីលុបបំបាត់ចោលខ្មាំងស៊ីរូងផ្ទៃក្នុងទាំងនេះ។ គាត់បានសំដៅចំពោះ ខ្មាំងទាំងនោះ ថាជាមេរោគ និងជាដង្កូវ ដែលត្រូវតែឆ្កឹះយកចេញពីសាច់របស់បក្ស។

១៥៥៤- ខ្លឹមសារ និងភាពញឹកញាប់នៃសេចក្តីថ្លែងការណ៍របស់ **នួន ជា** បង្ហាញថា គាត់មានចេតនាបង្ករហេតុ និងញុះញង់ចារីផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬយ៉ាងហោចណាស់ គាត់បានដឹងអំពីភាវនីយភាពយ៉ាងច្រើនដែលបទឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តឡើង នៅក្នុងការអនុវត្តអំពើដែលគាត់បានញុះញង់។ គាត់បានថ្លែងសុន្ទរកថា និងធ្វើសេចក្តីថ្លែងការណ៍នានា ដោយដឹងថាកម្មាភិបាលត្រូវបានតម្រូវឱ្យអនុវត្តយ៉ាងតឹងរ៉ឹង នូវគោលនយោបាយរបស់មជ្ឈិមបក្ស ទាក់ទិនទៅនឹងការដាក់ប្រជាជនជាទាសករ ការកំណត់មុខសញ្ញាជនជាតិភាគតិច និងការកម្ទេចខ្មាំង។

## ការបញ្ជា

១៥៥៥- **នួន ជា** បានបញ្ជាឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ ដោយផ្អែកទៅលើមុខតំណែងមានអំណាចរបស់គាត់នៅក្នុងគណៈអចិន្ត្រៃយ៍ និងស្ថាប័នធ្វើសេចក្តីសម្រេចដទៃទៀត ទាំងផ្លូវការ និងក្រៅផ្លូវការ និងជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា **នួន ជា** បានបង្កើត និងបានចេញបទបញ្ជា និងសេចក្តីបង្គាប់ ដែលណែនាំឱ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។

១៥៥៦- លក្ខណៈរួមនៃបទឧក្រិដ្ឋទាំងនេះ គឺថាបទឧក្រិដ្ឋទាំងនេះត្រូវបានប្រព្រឹត្តតាមបទបញ្ជា និងសេចក្តីបង្គាប់ដែលចេញពីមជ្ឈិមបក្ស។ បក្សកុម្មុយនីស្តកម្ពុជា បានដាក់ចេញនូវប្រព័ន្ធរដ្ឋាភិបាល

ដែលមានលក្ខណៈមជ្ឈការបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអង្គភាពយោធា និងរដ្ឋបាលទាំងអស់ត្រូវស្ថិតនៅក្រោមការបញ្ជា និងការណែនាំរបស់មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។ សមាជិកនៃមជ្ឈិមបក្ស រួមទាំង នួន ជា បានចេញបទបញ្ជារួម បានទទួលរបាយការណ៍ និងបានជួបជាទៀតទាត់ជាមួយកម្មាភិបាលថ្នាក់ក្រោម។ បទបញ្ជាត្រូវបានជូនដំណឹងនៅក្នុងទម្រង់ជាសេចក្តីណែនាំ និងសេចក្តីបង្គាប់ពីមន្ទីរ៨៧០ ដែលជាស្ថាប័នមួយផ្តល់ភារកិច្ចដោយគណៈអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យមើលការអនុវត្តសេចក្តីណែនាំរបស់គណៈកម្មាធិការ នៅទូទាំងប្រទេស។

១៥៩៧- មុខតំណែងមានអំណាចរបស់ នួន ជា រួមមាន ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិកនៃគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម និងគណៈកម្មាធិការយោធា។ គាត់បានប្រើប្រាស់មុខតំណែងទាំងនេះដើម្បីណែនាំកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឱ្យប្រព្រឹត្ត បទឧក្រិដ្ឋតាមវិធីដូចខាងក្រោមនេះ ៖ តាមរយៈការចូលរួមក្នុងការបង្កើត និងការចេញបទបញ្ជា ដូចជាបទបញ្ជាឱ្យមានការជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ ការបិទវត្តអារ៉ាម និងការផ្សឹកព្រះសង្ឃ ការកំចាត់ចោលប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា ការជម្លៀសប្រជាជនដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ និងការបោសសំអាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា តាមរយៈការរៀបចំវគ្គបំពាក់បំប៉ននយោបាយដែល ក្នុងអំឡុងពេលនោះ គាត់បានចេញសេចក្តីបង្គាប់ឱ្យអនុវត្តមាគ៌ាបក្ស និងតាមរយៈ ការណែនាំដោយផ្ទាល់ខ្លួនគាត់ដល់កម្មាភិបាលឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ មន្ទីរ ស២១ គឺជា មន្ទីរមួយក្នុងចំណោមមន្ទីរជាច្រើន ចំណុះឱ្យមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា និងក្រោមបង្គាប់របស់ នួន ជា ដោយផ្ទាល់។ គាត់បានចេញបទបញ្ជាជាច្រើនទៅឱ្យ ឌុច ដែលបង្គាប់ឱ្យ ឌុច និងបុគ្គលិកមន្ទីរស២១ ប្រព្រឹត្តបទឧក្រិដ្ឋទៅលើ

អ្នកទោស។ បទបញ្ជាទាំងនេះ រួមមាន សេចក្តីបង្គាប់ជាអចិន្ត្រៃយ៍ ដែលថាមនុស្សទាំងអស់ ដែលត្រូវ បានបញ្ជូនទៅមន្ទីរ ស២១ ត្រូវតែប្រហារជីវិតបន្ទាប់ពីការសួរចម្លើយ។ បទបញ្ជាឲ្យ ធ្វើទារុណកម្មអ្នកទោសសំខាន់ៗ។ បទបញ្ជាឲ្យប្រហារជីវិតយ៉ាងទាន់ហាន់ទៅលើអ្នកទោស ចំនួន៣០០នាក់ មកពីភូមិភាគបូព៌ា ដោយមិនចាំបាច់សួរចម្លើយ។ និងបទបញ្ជាឲ្យសម្លាប់ អ្នកទោសដែលនៅសល់ទាំងអស់នៅមន្ទីរស២១ នៅដើមខែមករា ឆ្នាំ១៩៧៩។

១៥៥៨- ក្នុងខណៈដែលកំពុងចូលរួមនៅក្នុងការបង្កើត និងការចេញបទបញ្ជា ដែលបានរៀបរាប់ខាងលើ **នួន ជា** មានចេតនាធ្វើឲ្យអ្នកទាំងឡាយនៅក្រោមអំណាចរបស់គាត់ ប្រព្រឹត្តបទឧក្រិដ្ឋ ឬយ៉ាង ហោចណាស់ បានដឹងអំពីភវនីយភាពយ៉ាងច្រើន ដែលបទឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តនៅក្នុងការ អនុវត្តបទបញ្ជាទាំងនោះ។ គាត់បានដឹងអំពីអំណាចរបស់គណៈអចិន្ត្រៃយ៍មន្ទីរ៨៧០ និងបាន ដឹងអំពីអំណាចពិតប្រាកដ និងជាផ្លូវការផ្ទាល់ខ្លួនរបស់គាត់ និងបានដឹងថា គាត់មានអំណាច ជម្រុញកម្មាភិបាលថ្នាក់ក្រោមឲ្យអនុវត្ត។

១៥៥៩- ដោយមិនគិតអំពីថាតើ **នួន ជា** ស្ថិតនៅក្នុងទំនាក់ទំនងជាផ្លូវការរវាងអ្នកក្រោមបង្គាប់ និង ថ្នាក់លើ ទាក់ទិននឹងចារីផ្ទាល់ ឬយ៉ាងណានោះ ដោយសារតែមុខតំណែងជាន់ខ្ពស់របស់គាត់ គាត់មានអំណាចជម្រុញឲ្យចារីប្រព្រឹត្តបទឧក្រិដ្ឋ និងបានជម្រុញពួកគេឲ្យប្រព្រឹត្តបែបនោះ។ ប្រសិនបើភស្តុតាងនៃបទបញ្ជាដោយផ្ទាល់ដែលបានចេញដោយ មជ្ឈិមបក្សមិនមាននៅសល់ អត្ថិភាពនៃបទបញ្ជាក៏អាចត្រូវបានទាញសេចក្តីសន្និដ្ឋានផងដែរ ពីកត្តាជាច្រើនរួមមានចំនួននៃ បទឧក្រិដ្ឋ និងព្រឹត្តការណ៍ជាប្រព័ន្ធ និងវិសាលភាពនៃបទឧក្រិដ្ឋទាំងនោះ អត្តសញ្ញាណ និងប្រភេទ នៃចារីប្រព្រឹត្តផ្ទាល់ ដែលជាប់ពាក់ព័ន្ធការត្រួតត្រាដែល បានដាក់ទៅលើកម្មាភិបាលទាំងនោះពី

សំណាក់គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា និងមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ភ័ស្តុភារដែលពាក់ព័ន្ធចង្វាក់យុទ្ធសាស្ត្រនៃប្រតិបត្តិការ និង*វិធីសាស្ត្រប្រតិបត្តិ* នៃអំពើស្រដៀងគ្នា និងសេចក្តីរាយការណ៍ ត្រឡប់ទៅមន្ទីរ៨៧០ ដែលមានលក្ខណៈស៊ីសង្វាក់គ្នា។

១៥៦០- ឧទាហរណ៍ អង្គហេតុនៃការសម្លាប់រង្គាលដែលមានការរៀបចំ ទៅលើសហគមន៍ជនជាតិចាមទាំងមូល បានកើតឡើងនៅទីតាំងជាច្រើនក្នុងភូមិភាគពីរផ្សេងៗគ្នា ដែលត្រូវបានអនុវត្តដោយកងសេនាជនស្រុករបស់បក្សកុម្មុយនីស្តកម្ពុជា និងអង្គភាព អន្តរាគមន៍ពិសេសរបស់មជ្ឈិមបក្សបង្ហាញឱ្យឃើញថា ការសម្លាប់ទាំងនេះមិនមែនជាបទឧក្រិដ្ឋដែលកើតឡើងដោយចៃដន្យឡើយប៉ុន្តែផ្ទុយទៅវិញគឺជាលទ្ធផលនៃបទបញ្ជាដែលចេញមកពីគណៈអចិន្ត្រៃយ៍។ អង្គហេតុដែលជាបទបញ្ជារបស់គណៈអចិន្ត្រៃយ៍ បានរុញឱ្យកម្មាភិបាលប្រព្រឹត្តបទឧក្រិដ្ឋនានាដែលស្ថិតនៅក្រោមការស៊ើបអង្កេត ត្រូវបានបញ្ជាក់ *ក្នុងចំណោមប្រការផ្សេងទៀត* តាមរយៈការអនុវត្តវិន័យបក្សយ៉ាងតឹងរ៉ឹង និងរបាយការណ៍ដែលបញ្ជូនទៅមជ្ឈិមបក្ស ដែលជម្រាបជូនមជ្ឈិមបក្សយ៉ាងលម្អិតអំពីការអនុវត្តសេចក្តី បង្គាប់របស់មជ្ឈិមបក្ស។

## ការជួយ និងជម្រុញ

១៥៦១- **នួន ជា** បានជួយ និងជម្រុញឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ គាត់ពិតបានធ្វើបែបនេះ តាមរយៈ ការផ្តល់នូវការលើកទឹកចិត្ត ការផ្តល់នូវជំនួយផ្នែកស្មារតី និងការផ្តល់នូវជំនួយសំរាប់ការអនុវត្តជាក់ស្តែងដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ការជួយ និងជម្រុញរបស់គាត់ មានអានុភាពយ៉ាងខ្លាំងទៅលើបទឧក្រិដ្ឋ នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពីការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

១៥៦២- *ក្នុងចំណោមប្រការផ្សេងទៀត* **នួន ជា** បានលើកទឹកចិត្តឱ្យមានការបង្ក្រាបសហគមន៍ជនជាតិចាម និងការសម្លាប់ទ្រង់ទ្រាយធំជាបន្តបន្ទាប់ទៅលើពួកគេ ការកំណត់មុខសញ្ញា និងការសម្លាប់ជនជាតិវៀតណាម និងការចាប់ខ្លួនជាលក្ខណៈប្រព័ន្ធ និងរីករាលដាល ការឃុំខ្លួន និងការប្រហារជីវិតអ្នកទាំងឡាយដែលគេយល់ថាជាខ្មាំង។ គាត់បានផ្តល់ការយល់ព្រមឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនៅមន្ទីរស២១ និងមន្ទីរសន្តិសុខដទៃទៀត តាមរយៈ *ក្នុងចំណោមប្រការផ្សេងទៀត* ការបញ្ជូនឈ្មោះកម្មាភិបាលដែលពាក់ព័ន្ធទៅប្រធានអង្គភាពរបស់ពួកគេ ដើម្បីចាត់វិធានការបន្ថែមទៀតក្នុងការត្រួតពិនិត្យ និង/ឬចាប់ខ្លួនបុគ្គលទាំងនោះ។ លើសពីនេះទៀត គាត់បានដក និងដាក់វិន័យ និងធ្វើការលត់ដំដល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលមិនអនុវត្តតាមមាគ៌ា និងគោលនយោបាយឧក្រិដ្ឋរបស់បក្ស ដូច្នេះគាត់បានផ្តល់នូវជំនួយសំរាប់ការអនុវត្តជាក់ស្តែង និងជំនួយស្មារតី ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះនៅទូទាំងប្រទេសកម្ពុជា។ គាត់ក៏បានជួយ និងជម្រុញផងដែរឱ្យមានការអនុវត្តគោលនយោបាយ ដាក់ប្រជាជនជាទាសករនៅតាមការដ្ឋានធ្វើការ និងសហករណ៍នានារបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការចុះទៅទស្សនកិច្ចទីកន្លែងទាំងនោះ ការលើកទឹកចិត្តអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ និងការបញ្ចុះបញ្ចូលឱ្យប្រជាជនខិតខំធ្វើការកាន់តែខ្លាំងថែមទៀត ដើម្បីបំពេញឱ្យបាននូវបរិមាណកំណត់របស់បក្ស។ គាត់បានអនុម័ត និងបានគាំទ្រគោលនយោបាយក្នុងការដាក់ជនស៊ីវិលឱ្យជាទាសករ នៅតាមការដ្ឋាន និងសហករណ៍នានា មិនឱ្យទទួលបាននូវអាហារគ្រប់គ្រាន់ និងការថែទាំផ្នែកវេជ្ជសាស្ត្រ និងផ្សេងពីនេះ ដាក់ជនស៊ីវិលទាំងនោះឱ្យស្ថិតក្រោមលក្ខខណ្ឌ អមនុស្សធម៌ដែលបណ្តាលឱ្យមានការឈឺស្គមស្គាំងដោយសារអត់អាហារ ជំងឺ និងភាពអត់ឃ្លាន ព្រមទាំងបង្កឱ្យមានបរិយាកាសនៃការភ័យខ្លាច។

១៥៦៣- នៅពេលថ្លែងទៅកាន់កម្មាភិបាលនៅក្នុងកិច្ចប្រជុំ វគ្គបំពាក់បំប៉នននយោបាយ និងសុន្ទរកថានានា **នួន ជា** បានផ្តល់យុត្តិកម្មចំពោះបទឧក្រិដ្ឋទាំងនោះ ដូច្នេះត្រូវបានគេជឿជាក់ថា ជាការផ្តល់នូវភាពត្រឹមត្រូវស្របច្បាប់ទៅលើបទឧក្រិដ្ឋទាំងនោះ។ ដោយពិចារណាទៅលើរចនាសម្ពន្ធឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា និងការផ្តែកទៅលើកម្មាភិបាល ទាំងឡាយនៅទូទាំងប្រទេសកម្ពុជាឲ្យអនុវត្តយ៉ាងដាច់ខាតនូវ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ការលើកទឹកចិត្ត និងជំនួយស្មារតីពីសមាជិកជាន់ខ្ពស់របស់បក្ស មានអានុភាពយ៉ាងខ្លាំងទៅលើការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនេះ។

១៥៦៤- ក្នុងនាមជាសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា **នួន ជា** បានដឹងថា អំពើរបស់គាត់ក្នុងការលើកទឹកចិត្ត និងជំនួយសំរាប់ការអនុវត្តជាក់ស្តែង និងជំនួយស្មារតី គឺជាការជួយក្នុងការអនុវត្តបទឧក្រិដ្ឋ និងមានចេតនាផ្តល់នូវជំនួយបែបនោះ ឬយ៉ាងហោចណាស់បានទទួលស្គាល់ថាជំនួយបែបនោះ គឺជាផលវិបាកដែលអាចកើតមាន និងអាចដឹងជាមុនបាននៃអំពើរបស់គាត់។ ដោយសារតែមុខតំណែងរបស់គាត់ **នួន ជា** ក៏បានដឹងផងដែរអំពីធាតុផ្សំសំខាន់នៃបទឧក្រិដ្ឋដែលគាត់កំពុងជួយ និងជម្រុញ ពីព្រោះគាត់បានទទួលព័ត៌មានរហូត ឥតដាច់ឡើយអំពីសកម្មភាពរបស់ចារីផ្ទាល់នៅគ្រប់ថ្នាក់ទាំងអស់។

## តាមរយៈការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ

១៥៦៥- លើសពីនេះទៀត និងម៉្យាងវិញទៀត **នួន ជា** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្នុងនាមជាថ្នាក់លើម្នាក់ តាមមាត្រា ២៩ កថាខណ្ឌ ១ នៃច្បាប់ អ.វ.ត.ក ដោយសារតែ (១)មុខតំណែងរបស់គាត់ជាថ្នាក់លើម្នាក់របស់ចារីដែលប្រព្រឹត្តបទឧក្រិដ្ឋផ្ទាល់ ដែលបានរៀប

រាប់នៅក្នុងដីកាសន្និដ្ឋាននេះ (២)ការដឹងឮពិតប្រាកដរបស់គាត់ ឬការទទួលបានព័ត៌មានដែលផ្អែកលើព័ត៌មានទាំងនោះ គាត់មានហេតុផលក្នុងការដឹងថា អ្នកក្រោមបង្គាប់គាត់បានប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តបទឧក្រិដ្ឋ និង(៣)ការខកខានរបស់គាត់ ក្នុងការទប់ស្កាត់មិនឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬមិនបានដាក់ទណ្ឌកម្មដល់ចារី។

**ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់**

១៥៦៦- ទំនាក់ទំនងរវាងថ្នាក់លើនិងអ្នកក្រោមបង្គាប់ បានកើតឡើងរវាង **នួន ជា** និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់នៅក្នុងបទឧក្រិដ្ឋ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ រួមមាន កងទ័ពបដិវត្តកម្ពុជា កម្មាភិបាល និងសមាជិកគណៈកម្មាធិការស្រុក តំបន់ និងភូមិភាគ មន្ត្រីក្រសួង បុគ្គលិកមន្ទីរសន្តិសុខ កងឈ្លប និងអ្នកគ្រប់គ្រង និងប្រធានកងការងារនៅតាមការដ្ឋានធ្វើពលកម្មដោយបង្ខំ។ ទោះបីជាទំនាក់ទំនងខ្លះក្នុងចំណោមទំនាក់ទំនងទាំងនេះគឺធ្វើឡើងដោយប្រយោល ឬ*តាមព្រឹត្តិន័យ* យ៉ាងណាក៏ដោយ **នួន ជា** គឺជាថ្នាក់លើរបស់បុគ្គលទាំងនោះ ដោយសារតែការត្រួតត្រា ដ៏មានប្រសិទ្ធភាពរបស់គាត់ទៅលើពួកគេ។ ជាមេដឹកនាំជាន់ខ្ពស់ម្នាក់ ក្នុងចំណោមមេដឹកនាំ ជាន់ខ្ពស់ជាច្រើនរបស់បក្ស និងជាសមាជិកមួយរូបនៃគណៈកម្មាធិការឃោធា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ **នួន ជា** បានប្រើប្រាស់អំណាចដ៏ធំ មហិមាទៅលើអ្នកក្រោមបង្គាប់របស់គាត់។

១៥៦៧- គាត់មានអំណាចយ៉ាងសំខាន់ ដើម្បីទប់ស្កាត់ពួកគេកុំឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ផ្តួចផ្តើមឱ្យមានការស៊ើបអង្កេត ឬមានវិធានការ ដែលនាំឱ្យមានដំណើរការនីតិវិធីប្រឆាំងនឹងពួកគេ ដកពួកគេចេញ ឬផ្សេងពីនេះ ដាក់វិន័យ និងដាក់ទណ្ឌកម្មដល់ពួកគេបន្ទាប់ពីមានការប្រព្រឹត្តិបទឧក្រិដ្ឋ។

លទ្ធភាពនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈ ៖ (១)លទ្ធភាពរបស់គាត់ ដែលជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ក្នុងការចេញសេចក្ដីបង្គាប់ ទៅកាន់គ្រប់អង្គភាពទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (២)ការចូលរួមរបស់គាត់ នៅក្នុងការធ្វើសេចក្ដីសម្រេចរបស់គណៈមជ្ឈិម ដើម្បីធ្វើការស៊ើបអង្កេត និង/ឬ ដាក់ទណ្ឌកម្មដល់កម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាប់សង្ស័យថា ខ្វះវិន័យ ឬភក្ដីភាពចំពោះបក្ស និង (៣)តួនាទីរបស់គាត់នៅក្នុងការត្រួតពិនិត្យមើល ដោយផ្ទាល់ទៅលើការបោសសំអាតកម្មាភិបាលទាំងនៅក្នុងមន្ទីរស២១ និងបើនិយាយឲ្យទូលាយជាងនេះទៀត គឺនៅក្នុងមន្ទីរសន្តិសុខតំបន់ ស្ថាប័នយោធា និងរដ្ឋបាលរបស់ បក្សកុម្មុយនីស្តកម្ពុជា។

**ការដឹងឮ**

១៥៦៨- **នួន ជា** មានការដឹងពិតប្រាកដអំពីបទឧក្រិដ្ឋ ដែលកំពុងត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់។ ជាលទ្ធផលនៃអង្គហេតុដែលគាត់បានបង្កើត និងដឹកនាំការប្រព្រឹត្តិបទឧក្រិដ្ឋទាំង ក្នុងនាមជាសមាជិករបស់មជ្ឈិមបក្ស គាត់ពិតជាបានដឹងថា បទឧក្រិដ្ឋទាំងនោះ ពិតជាត្រូវបានប្រព្រឹត្តឡើង។ ការដឹងនេះ ត្រូវបានអះអាងបញ្ជាក់ជាបន្តបន្ទាប់តាមរយៈ ការទទួលរបាយការណ៍ជាទៀតទាត់របស់ **នួន ជា** ស្ដីពីការអនុវត្តសេចក្ដីបង្គាប់របស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈប្រព័ន្ធរាយការណ៍តាមខ្សែបណ្ដោយ និងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។ ការដឹងឮរបស់ **នួន ជា** អំពីបទឧក្រិដ្ឋនៅពេលវេលាដែលពាក់ព័ន្ធ ក៏ត្រូវបានអះអាងបញ្ជាក់ផងដែរតាមរយៈសេចក្ដីថ្លែងការណ៍របស់គាត់នៅកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ នៅវគ្គបំពាក់បំប៉នឧយោបាយ នៅក្នុងសុន្ទរកថាជាសាធារណៈ និងកិច្ចសម្ភាសន៍របស់គាត់ ក្នុងអំឡុងពេលស្ថិតក្រោមការស៊ើបអង្កេត។

ក្នុងករណីដែលមិនមានសេសសល់ភស្តុតាងអំពីការទទួលរបាយការណ៍ផ្ទាល់របស់ នួន ជា អំពីបទឧក្រិដ្ឋជាក់លាក់នោះ ក៏ប៉ុន្តែគាត់បានទទួលព័ត៌មានដែលធ្វើឲ្យគាត់ឲ្យដឹងថា បទឧក្រិដ្ឋកំពុងត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់។ ព័ត៌មាននេះ រួមមាន ៖ របាយការណ៍ទូទៅពី អង្គភាពយោធា និងរដ្ឋបាលនានា បញ្ជូនទៅមន្ទីរ៨៧០ និងគណៈអចិន្ត្រៃយ៍។ ព័ត៌មានដែល នួន ជា បានទទួលនៅក្នុងទំនាក់ទំនងរបស់គាត់ជាមួយនឹងអ្នកក្រោមបង្គាប់ និងក្នុងអំឡុងការចុះទៅទស្សនកិច្ចរបស់គាត់នៅកន្លែងដែលបទឧក្រិដ្ឋបានកើតឡើង។ លក្ខណៈជាប្រព័ន្ធភាពស៊ីសង្វាក់គ្នា និងលក្ខណៈរីករាលដាលនៃបទឧក្រិដ្ឋ ព្រមទាំងការប្រព្រឹត្តិជាបន្តរហូតរបស់ពួកគេ នៅក្នុងអំឡុងរយៈពេលស្ថិតក្រោមការស៊ើបអង្កេត។

## ការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្ម

១៥៦៩- នួន ជា ខកខានមិនបានប្រើកាតព្វកិច្ចរបស់គាត់ដើម្បីទប់ស្កាត់មិនឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬមិនបានដាក់ទណ្ឌកម្មអ្នកទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋ។ ក្នុងនាមជាស្ថាបនិកចម្បងម្នាក់ក្នុងចំណោមស្ថាបនិកចម្បងជាច្រើនទៀត ដែលបង្កើតឲ្យមានបទឧក្រិដ្ឋ គាត់មិនបានទប់ស្កាត់ការប្រព្រឹត្តរបស់ពួកគេឡើយ។ ប៉ុន្តែផ្ទុយទៅវិញ បានលើកសរសើរអ្នកក្រោមបង្គាប់ទាំងនោះ ដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តិរបស់ពួកគេ។ ទោះបីជាគាត់មានសមត្ថភាពដ៏មានប្រសិទ្ធភាពក្នុងការធ្វើបែបនេះយ៉ាងណាក៏ដោយ នួន ជា ខកខានទាំងស្រុងមិនបានចាត់វិធានការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម ដូចដែលច្បាប់បានតម្រូវឡើយ។

# អៀង សារី

## សេចក្តីសង្ខេប

១៥៧០- ភស្តុតាងនៅក្នុងសំណុំរឿង និងភស្តុតាងដែលបានយោងនៅក្នុងផ្នែកអង្គហេតុសត្យានុម័ត នៃដីកាសន្និដ្ឋាននេះបង្ហាញថា **អៀង សារី** ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ អនុលោមតាមមាត្រា ៣(ថ្មី) ៤ ៥ ៦ និង ២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

១៥៧១- ជាពិសេស **អៀង សារី** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ស្របតាមមាត្រា ២៩៖ ១) ពីព្រោះគាត់បានប្រព្រឹត្ត បានរៀបចំផែនការ បានញុះញង់ បានបញ្ជា និង/ឬ បានជួយជ្រោមជ្រែង និងបានជួយជម្រុញឲ្យកើតមាននូវបទឧក្រិដ្ឋទាំងអស់នេះ។ លើសពីនេះទៀត ២) ដោយសារតែការខកខានរបស់គាត់ក្នុងការរារាំងមិនឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងការដាក់ទណ្ឌកម្មលើចារីទាំងឡាយក្នុងនាមជាថ្នាក់លើដែលបានដឹងថាអ្នកនៅក្រោមបង្គាប់របស់ខ្លួន ប្រហែលជាអាចនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ។

## ទម្រង់នៃការទទួលខុសត្រូវ

### តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម

### សហកម្មឧក្រិដ្ឋកម្មរួម ១ (មូលដ្ឋាន)

១៥៧២- **អៀង សារី** ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ ដែលបានចោទ ប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ក្នុងទម្រង់ជាមូលដ្ឋាន និងជាប្រព័ន្ធ ។ គោលបំណង រយៈពេល និងសមាជិកភាពនៃសហកម្មឧក្រិដ្ឋកម្មរួមនេះ ត្រូវបានរៀបរាប់ខាងលើពាក់ព័ន្ធនឹង **នួន ជា**។

*ការរួមចំណែក*

១៥៧៣- សកម្មភាពជាលក្ខណៈបុគ្គល តាមរយៈការចូលរួម តួនាទី និងសមាជិកភាព ដូចបាន រៀបរាប់នៅក្នុងផ្នែកនេះ និងក្នុងការរួមគ្នាជាមួយសមាជិកផ្សេងទៀត នៃសហកម្មឧក្រិដ្ឋកម្មរួម អៀង សារី បានរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មនោះតាមមធ្យោបាយដូចខាងក្រោម ដោយ៖

(១) **រួមចំណែកក្នុងការបង្កើត** មាគ៌ា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនាំឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនានា ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះ។

(២) **ចូលរួមក្នុងការបង្កើត ការរៀបចំ និងការដឹកនាំ**ស្ថាប័នបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា រួមមាន គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ មន្ទីរ៨៧០ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក ព្រមទាំងគណៈកម្មាធិការជាន់ទាបនានា អគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា កងពលធំ និងកងវរសេនាធំនានា ព្រមទាំងគណៈកម្មាធិការ ក្រសួង និងកងឈ្លបផ្សេងទៀត ដែលអាចឆ្លើយតបចំពោះមជ្ឈិមបក្ស ដែលតាមរយៈនេះ បទឧក្រិដ្ឋទាំងឡាយដែលស្ថិតក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានប្រព្រឹត្តឡើង។

(៣) **រៀបចំផែនការ និងធ្វើការសម្របសម្រួល** ដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនានា តាមរយៈការចូលរួមក្នុងការប្រជុំ ការពិភាក្សាដេញដោល និងការធ្វើសេចក្តីសម្រេចរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។

(៤) **ការបញ្ជា ការអនុវត្តការត្រួតពិនិត្យ និង ណែនាំ** ដល់កម្មាភិបាលនៅក្នុង អង្គភាពរដ្ឋបាល និងយោធារបស់បក្សកុម្មុយនីស្តកម្ពុជា ឲ្យប្រព្រឹត្តបទឧក្រិដ្ឋនានា រួមទាំងចូលរួមក្នុងការបង្កើត និងក្នុងការចេញបញ្ជារបស់មន្ទីរ៨៧០ផងដែរ ព្រមទាំង ជួបប្រជុំជាមួយកម្មាភិបាលថ្នាក់ក្រោមទាក់ទិននឹងបទឧក្រិដ្ឋនានា ទទួលរបាយការណ៍ពីពួកគេ និងរក្សាការត្រួតត្រាលើពួកគេ។

(៥) **ពាក់ព័ន្ធផ្ទាល់ក្នុងបទឧក្រិដ្ឋ** រួមមានតាមរយៈ៖ ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចជាក់លាក់លើការចាប់ខ្លួនថ្នាក់ដឹកនាំជាន់ខ្ពស់ និងប្រហារជីវិតថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ស្វែងរកខ្មាំងសត្រូវតាមការសន្មតនៅក្នុងក្រសួងផ្ទាល់របស់ខ្លួន។ ពិនិត្យមើលចម្លើយសារភាពរបស់បុគ្គលដែលត្រូវបានចាប់ខ្លួនដោយមន្ទីរស២១ និង បញ្ជា និង/ឬយល់ព្រមឲ្យមានការចាប់ខ្លួនបន្ថែមទៀត។ អំពាវនាវឲ្យឯកអគ្គរដ្ឋទូតនានា បុគ្គលិកទូត និងបញ្ញវន្តដែលនៅឯបរទេសវិលត្រលប់មកវិញ និងរៀបចំ ឬយល់ព្រមឲ្យមានការចាប់ខ្លួន និងការប្រហារជីវិតមនុស្សភាគច្រើនក្នុងចំណោមពួកគេ។ អនុញ្ញាតឲ្យប្រើប្រាស់ក្រសួងរបស់ខ្លួនធ្វើជាមណ្ឌលឃុំឃាំងសម្រាប់កម្មាភិបាលជាន់ខ្ពស់ មុនពេលបញ្ជូនពួកគេទៅកាន់មន្ទីរស២១។

(៦) **ញុះញង់ អុជអាល និងជម្រុញ** ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ រួមទាំង៖ ធ្វើទស្សនកិច្ចទីតាំងឧក្រិដ្ឋកម្មនានា (ដូចជា **ទំនប់ត្រពាំងថ្ម ទំនប់១មករា** និង **ព្រលានយន្តហោះកំពង់ឆ្នាំង**

ជាដើម)។ បំពាក់បំប៉នកម្មាភិបាលដែលពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនានា និងធ្វើជាអធិបតីក្នុងកិច្ចប្រជុំនៅក្រសួងការបរទេស និងសន្និបាតដែលពេលនោះគាត់បានថ្កោលទោសលើអ្នកទាំងឡាយណា ដែលត្រូវបានកំណត់ថាជាខ្មាំងសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា អានចម្លើយសារភាពរបស់បុគ្គលដែលត្រូវបានចាប់ខ្លួន និងបានអំពាវនាវឱ្យកម្មាភិបាលរក្សាការប្រុងប្រយ័ត្ននៅក្នុងការអនុវត្តន៍គោលនយោបាយរបស់បក្ស។

(៧) **ញុះញង់ និងលើកទឹកចិត្ត** ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដោយរៀបចំ ឬគាំទ្រការបោះពុម្ពផ្សាយផ្ទៃក្នុងសេចក្តីណែនាំផ្ទៃក្នុងរបស់បក្សទៅកម្មាភិបាលនានា (ដូចជា *ទង់បដិវត្ត* ជាដើម) ថ្លែងសន្ទរកថាសាធារណៈ និងការចេញសេចក្តីថ្លែងការណ៍នានា (ដូចជា *សៀវភៅខ្មៅ* ជាដើម) ការពារ និងគាំទ្រគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។

(៨) **តំណាង**ឱ្យបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យទាំងនៅក្នុងប្រទេស និងក្រៅប្រទេស បដិសេធបទឧក្រិដ្ឋរបស់ខ្លួន និងធ្វើយុត្តិកម្មគោលនយោបាយ របស់ខ្លួននៅចំពោះមុខស្ថាប័នច្បាប់អន្តរជាតិ និងស្ថាប័ននយោបាយនានា ដូចជា អង្គការសហប្រជាជាតិ និងអង្គការចលនាមិនចូលបក្សសម្ព័ន្ធ ក៏ដូចជាអង្គការព័ត៌មាន ពិភពលោក ជាដើម។

(៩) **ខកខានមិនបាន**បញ្ឈប់ការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ទោះបីជាដឹងថាបទឧក្រិដ្ឋទាំងឡាយកំពុងត្រូវបានប្រព្រឹត្តស្របតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួមក៏ដោយ និងទោះបីជាគាត់មានអំណាចធ្វើការរារាំង ឬបញ្ឈប់បទឧក្រិដ្ឋទាំងនោះ ឬដាក់ទណ្ឌកម្មលើចារីក៏ដោយ និង

(១០) មួយវិញទៀត **រៀបចំផែនការ ញុះញង់ បញ្ជា និងជួយជ្រោមជ្រែង ព្រមទាំង ជួយជម្រុញ**ឱ្យប្រព្រឹត្តបទឧក្រិដ្ឋនានាដូចបានរៀបរាប់ខាងក្រោម។

*ចេតនា*

១៩៧៤- ជាមួយនឹងសមាជិកផ្សេងទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម **អៀង សារី** បានរួមចំណែក មានចេតនាប្រព្រឹត្តទាំងបទឧក្រិដ្ឋនិមួយៗដែលបានព្រមព្រៀងគ្នាដំបូង ដូចបានរៀបរាប់នៅក្នុងផ្នែកផែនការឧក្រិដ្ឋកម្មរួម និងផ្នែកការកំណត់បទចោទ (ឧក្រិដ្ឋកម្ម) ជាមធ្យោបាយចាំបាច់ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងឧក្រិដ្ឋកម្មរួម ដែលមានលក្ខណៈទូលំទូលាយ។ ចេតនារបស់ **អៀង សារី** អាចទាញចេញមកពីអង្គហេតុ និងកាលៈទេសៈជាច្រើន រួមមាន៖

(១) ការយល់ព្រមដោយស្ម័គ្រចិត្ត និងការចូលរួមដោយចេតនារបស់គាត់នៅក្នុងការងារទាំងឡាយក្នុងតួនាទីជាន់ខ្ពស់ និងមុខងារទាំងឡាយដែលអាចធ្វើឱ្យគាត់ ចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

(២) សកម្មភាពរបស់គាត់នៅក្នុងការបង្កើតបទឧក្រិដ្ឋនានាជាមួយនឹងសហចារី និងជួយជ្រោមជ្រែងការប្រព្រឹត្តិរបស់ពួកគេ ដោយក្នុងនោះមានការជួបប្រជុំគ្នា និងការចេញសេចក្តីណែនាំដល់កម្មាភិបាលថ្នាក់ក្រោមរបស់បក្សកុម្មុយនីស្តកម្ពុជា ចុះទស្សនកិច្ចទីតាំងឧក្រិដ្ឋកម្មនានា និងរួមចំណែកផ្ទាល់ក្នុងបទឧក្រិដ្ឋទាំងឡាយ។

(៣) សន្ទរកថា និងសេចក្តីថ្លែងការណ៍របស់គាត់ ដែលបានលើកទឹកចិត្តឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនានា និងការពារគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា មុនពេល និងក្នុងពេលកំពុងស៊ើបអង្កេត។

(៤) ការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគាត់បានរួមចំណែក និងដែលគាត់បានយល់ព្រម និងគាំទ្រ។

(៥) សេចក្តីថ្លែងការណ៍របស់គាត់ក្នុងពេលបញ្ចុះបញ្ចូលគោលនយោបាយ និងលត់ដំ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និង

(៦) សកម្មភាព ការសរសេរ និងការថ្លែងរបស់គាត់ នៅក្រោយរយៈកាលដែលស្ថិតក្រោមកិច្ចស៊ើបសួរ រួមទាំងសេចក្តីថ្លែងការណ៍ដែលគាត់បានស្វែងរក ដើម្បីរារាំងមិនលាតត្រដាងឧក្រិដ្ឋកម្មទាំងនោះ។

## សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ)

១៥៧៥- លើសពីនេះទៀត **អៀង សារី** ទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ដោយអនុវត្តស្របទៅនឹងប្រព័ន្ធធ្វើបាបដែលបានរៀបចំមកលើប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធនៃការធ្វើបាបប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងការបង្កើតជាប្រព័ន្ធនិងទូទាំងប្រទេស នូវសហករណ៍ ជំរំធ្វើពលកម្មដោយបង្ខំ មណ្ឌលលត់ដំ និងមន្ទីរសន្តិសុខនានាដូចបានរៀបរាប់នៅក្នុងជំពូកអង្គហេតុជាក់ស្តែង។ **អៀង សារី** បានដឹងអំពីលក្ខណៈនៃប្រព័ន្ធនៃការបង្ក្រាប បានចូលរួមនៅក្នុងការអនុវត្តប្រព័ន្ធនេះ និងមានចេតនាដើម្បីជ្រោមជ្រែងដល់ផែនការនៃការធ្វើបាបជាប្រព័ន្ធនេះ។

## តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយជ្រោមជ្រែង ព្រមទាំងការជួយជម្រុញ

## សេចក្តីផ្តើម

១៥៧៦- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ **អៀង សារី** តាមរយៈសមាជិកភាពរបស់គាត់ក្នុងសហកម្មឧក្រិដ្ឋកម្មរួម ឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដ អំពីការទទួលខុសត្រូវរបស់គាត់ចំពោះបទឧក្រិដ្ឋនានា ដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ។ ទោះបីជាយ៉ាងណាក៏ដោយ **អៀង សារី** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះតួនាទីរបស់គាត់ក្នុង ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និង/ឬ ការជួយជ្រោមជ្រែង និងការជួយជម្រុញបទឧក្រិដ្ឋនានា អនុលោមតាមមាត្រា ២៩ កថាខណ្ឌ១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## ការរៀបចំផែនការ

១៥៧៧- **អៀង សារី** បានរៀបចំផែនការឧក្រិដ្ឋកម្មនានា ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានេះ។ គាត់គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលទាំងឡាយ ដែលបានរៀបគម្រោងឧក្រិដ្ឋកម្មទាំងអស់នោះ និងបានបង្កើតវិធីសាស្ត្រនៃការប្រព្រឹត្តិទៅចំពោះឧក្រិដ្ឋកម្មទាំងនោះ។ គាត់ក៏បានធ្វើការរៀបចំផែនការឧក្រិដ្ឋដោយផ្ទាល់គាត់បានគាំទ្រ និងបានគ្រាំទ្រ ឬយល់ព្រមចំពោះផែនការឧក្រិដ្ឋ និងគោលនយោបាយ ដែលបានបង្កើតឡើងដោយសមាជិកផ្សេងទៀតរបស់មជ្ឈិមបក្ស។

១៥៧៨- ដូចដែលបានរៀបរាប់ខាងលើទាក់ទិននឹង **នួន ជា** បទឧក្រិដ្ឋទាំងឡាយត្រូវបានរៀបគម្រោងបង្កើត និងសម្របសម្រួលដោយថ្នាក់លើ។ ក្នុងនាមជាសមាជិកម្នាក់នៃគណៈអចិន្ត្រៃយ៍ **អៀង សារី** មានអំណាចក្នុងការរួមចំណែកបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងបានប្រើប្រាស់អំណាចនោះដើម្បីរួមចំណែកក្នុងការរៀបគម្រោងឧក្រិដ្ឋកម្មនានា។ គាត់បានចូលរួមក្នុងការពិភាក្សាដេញដោល និងក្នុងការសម្រេចសេចក្តីដែលនាំឲ្យមានការបង្កើតកម្មវត្ថុនៃបទល្មើសព្រហ្មទណ្ឌ ការចាត់តាំងកម្មាភិបាល ការចែករំលែកការណែនាំ និងការបង្កើតយន្តការផ្សេងទៀត

ដើម្បីអនុវត្តសេចក្តីបង្គាប់បញ្ជាឧក្រិដ្ឋរបស់មជ្ឈិមបក្ស។ បន្ថែមពីលើនេះទៀត តាមរយៈភាពជាអ្នកដឹកនាំក្រសួងការបរទេសរបស់ខ្លួន **អៀង សារី** បានចូលរួមក្នុងការរៀបចំផែនការចាប់ខ្លួនកម្មាភិបាលក្រសួងការបរទេស និងបានអំពាវនាវហៅបញ្ញវន្ត ឯកអគ្គរដ្ឋទូត និងបុគ្គលិក ទូតនានាឲ្យត្រឡប់មកវិញ ដែលក្រោយមកបានក្លាយជាទាសករ និង/ឬ រងនូវការធ្វើទារុណកម្ម និងទទួលនូវការប្រហារជីវិត។ នៅក្នុងលក្ខណៈនេះ តាមរយៈការរួមចំណែក ក្នុងការបង្កើតគោលនយោបាយរបស់មជ្ឈិមបក្ស ការចូលរួមក្នុងការបង្កើតផែនការ ដើម្បីអនុវត្តគោលនយោបាយទាំងនោះ និងការរៀបចំផែនការអនុវត្តឧក្រិដ្ឋកម្មដោយផ្ទាល់ **អៀង សារី** បានរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនានា។

១៥៧៥- អៀង សារី មានចេតនារៀបចំផែនការប្រព្រឹត្តបទឧក្រិដ្ឋនានា ឬបើគិតអំពីមុខងារ និងតួនាទីរបស់គាត់ គាត់បានដឹងអំពីភវនីយភាពសំខាន់ដែលបទឧក្រិដ្ឋនានានឹងត្រូវបានប្រព្រឹត្តក្នុងការអនុវត្តអំពើទាំងឡាយដែលគាត់បានគ្រោងទុក។ បញ្ហានេះបង្ហាញជាក់ស្តែងតាមរយៈការគាំទ្ររបស់គាត់ចំពោះបទឧក្រិដ្ឋនានា និងការបញ្ជាក់អំពីការណែនាំរបស់មជ្ឈិមបក្សក្នុងអំឡុងពេលបំពាក់បំប៉នគោលនយោបាយ ដល់កម្មាភិបាលក្រសួងការបរទេស។ ចេតនារបស់ អៀង សារី ក្នុងការរៀបចំផែនការឧក្រិដ្ឋកម្មនានា ក៏អាចទាញចេញមកពីការយល់ដឹងរបស់គាត់អំពីការអនុវត្ត និងទម្រង់ទាំងឡាយនៃប្រតិបត្តិការរបស់បក្សកុម្មុយនីស្តកម្ពុជា (រួមទាំងការអនុវត្តគោលនយោបាយនានារបស់បក្សជាដាច់ខាត) និងរបាយការណ៍នានាដែលគាត់បានទទួលស្តីពីការអនុវត្តមាគ៌ា និងសេចក្តីបង្គាប់បញ្ជារបស់បក្សផងដែរ។

## ការញុះញង់

១៥៨០- **អៀង សារី** បានញុះញង់ឱ្យមានបទឧក្រិដ្ឋនានា ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ គាត់បានជម្រុញ បានលើកទឹកចិត្ត បានញុំាង បាននាំអាទិ៍ និងបានអុជអាលចារីដែលផ្ទាល់ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់នោះ។ ការញុះញង់ឱ្យមានបទឧក្រិដ្ឋនានា បានរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះ។

១៥៨១- **អៀង សារី** បានលើកទឹកចិត្ត និងបានជម្រុញឱ្យកម្មាភិបាលប្រព្រឹត្តបទឧក្រិដ្ឋនានាតាមរយៈអំពើទាំងឡាយ រួមមាន៖ ដឹកនាំ និងជាគណៈអធិបតីក្នុងវគ្គបំពាក់បំប៉នឧបាយនយោបាយនានា និងកិច្ចប្រជុំផ្សេងៗទៀតជាមួយកម្មាភិបាលក្រសួងការបរទេស និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលនៅក្នុងពេលនោះអ្នកចូលរួមទាំងឡាយ ត្រូវបានបង្ខំឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងការចុះទស្សនកិច្ចទីតាំងឧក្រិដ្ឋកម្មនានា ដែលបានផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្នែកស្មារតីដល់ចារីនៅតាមទីកន្លែងទាំងអស់នោះ។ **អៀង សារី** ក៏បានបង្កឱ្យមានការបោសសម្អាត ការចាប់ខ្លួន ការធ្វើទារុណកម្ម និងការប្រហារជីវិតកម្មាភិបាលក្រសួងការបរទេសផងដែរ។ គាត់ក៏បានលើកទឹកចិត្តឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋថែមទៀត ដោយបានធ្វើយុត្តិកម្មជាសាធារណៈ និងគាំទ្រដល់គោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំង គោលនយោបាយទាំងឡាយណាដែលពាក់ព័ន្ធនឹងការធ្វើឱ្យទៅជាទាសករ និងសន្តិសុខផ្ទៃក្នុង។

១៥៨២- ខ្លឹមសារ និងសេចក្តីថ្លែងការណ៍ញឹកញាប់របស់ **អៀង សារី** បង្ហាញថា គាត់មានចេតនាជម្រុញ និងញុះញង់ចារីដែលផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬក៏យ៉ាងហោចណាស់ក៏គាត់បានដឹងអំពីភវនីយភាពសំខាន់ដែលថា ការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយកើតឡើងបាន គឺដោយសារតែការ

លើកទឹកចិត្តរបស់គាត់។ សេចក្តីថ្លែងការណ៍របស់គាត់ត្រូវបានធ្វើឡើងដោយដឹងយ៉ាងច្បាស់ណាស់ថា កម្មាភិបាលនានាត្រូវបានតម្រូវឲ្យអនុវត្តគោលនយោបាយមជ្ឈិមបក្សយ៉ាងតឹងរ៉ឹង។

## ការបញ្ជា

១៥៨៣- **អៀង សារី** បានបញ្ជាឲ្យមានឧក្រិដ្ឋកម្មទាំងឡាយដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ ការអនុវត្តនូវសិទ្ធិអំណាចរបស់គាត់ ទាំងសិទ្ធិអំណាចផ្លូវការ ទាំងក្រៅផ្លូវការ និងបានដើរតួនាទីក្នុងការរួបរួមជាមួយនឹងមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត គាត់បានបង្កើត និងបានចេញបទបញ្ជាព្រមទាំងសេចក្តីបង្គាប់ ដោយណែនាំឲ្យកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះ។ ដូចដែលបានពន្យល់ខាងលើទាក់ទិននឹង **នួន ជា** បទឧក្រិដ្ឋទាំងឡាយត្រូវបានប្រព្រឹត្តឡើងស្របតាម បទបញ្ជារ និងសេចក្តីបង្គាប់ដែលបានដាក់ចេញដោយថ្នាក់លើ។ **អៀង សារី** ក្នុងនាមជាសមាជិកនៃមជ្ឈិមបក្ស បានចូលរួមក្នុងការចេញបទបញ្ជារួមគ្នាទាំងនេះ និងបានទទួលសេចក្តីរាយការណ៍ស្តីពីការអនុវត្តបទបញ្ជាទាំងនេះ។

១៥៨៤- តួនាទីរបស់ **អៀង សារី** ដែលពោរពេញដោយអំណាច និងសិទ្ធិអំណាចនានា រួមមានសមាជិកភាពនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់គាត់ ព្រមទាំងតួនាទីរបស់គាត់ជាឧបនាយករដ្ឋមន្ត្រីនៃក្រសួងការបរទេស។ គាត់បានប្រើប្រាស់តួនាទីទាំងអស់នេះ ដើម្បីណែនាំកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះតាមមធ្យោបាយដូចខាងក្រោម៖ តាមរយៈការចូលរួមក្នុងការបង្កើត និងការចេញបទបញ្ជារួមទាំងបទបញ្ជាទាំងឡាយដែលបានរៀបរាប់ខាងលើទាក់ទិននឹង **នួន ជា** តាមរយៈការជួបប្រជុំជាមួយកម្មាភិបាលថ្នាក់ក្រោមដែលទទួលខុសត្រូវចំពោះការអនុវត្តន៍តាមបទបញ្ជា និងសេចក្តី

ណែនាំនានា ដើម្បីអនុវត្តមាគ៌ារបស់បក្ស និងលើសពីនេះទៀត តាមរយៈការណែនាំផ្ទាល់ដល់កម្មាភិបាលក្រសួងការបរទេសឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ។

១៥៨៥- **អៀង សារី** មានចេតនាបង្កឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋនានាតាមរយៈបទបញ្ជារបស់ខ្លួន ឬក៏យ៉ាងហោចណាស់ គាត់បានដឹងអំពីភវនីយភាពសំខាន់ដែលការប្រព្រឹត្តិបទល្មើសទាំងឡាយកើតឡើងតាមការអនុវត្តបទបញ្ជាទាំងអស់នោះ។ ភស្តុតាងអំពីការបញ្ជាផ្ទាល់ដែលចេញដោយមជ្ឈិមបក្ស ក៏ដូចជាកត្តាដែលបានរកឃើញ និងបានយោងខាងលើទាក់ទិននឹង **នួន ជា** ជាការបញ្ជាក់អំពីចេតនានេះ។

១៥៨៦- ដោយមិនគិតអំពីបញ្ហាថាតើ **អៀង សារី** មានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ជាផ្លូវការទាក់ទិននឹងចារីដែលផ្ទាល់ដែរឬទេ តាមការយល់ឃើញអំពីតួនាទីជាន់ខ្ពស់របស់គាត់ គាត់មានសិទ្ធិអំណាចក្នុងការអូសទាញចារីដែលឲ្យប្រព្រឹត្តបទឧក្រិដ្ឋនានា ហើយគាត់បានធ្វើការអូសទាញបែបនេះមែន។ ដូចដែលបានកត់សម្គាល់ពាក់ព័ន្ធនឹង **នួន ជា** នៅពេលដែលមិនមាននៅសល់ភស្តុតាង អំពីការចេញបទបញ្ជាផ្ទាល់ពី **អៀង សារី** និងពីមជ្ឈិមបក្សនោះ អត្ថិភាពនៃបទបញ្ជានានាអាចទាញចេញមកពីកត្តាដូចជា ចំនួន និងលក្ខណៈទូលំទូលាយ និងលក្ខណៈជាប្រព័ន្ធនៃបទឧក្រិដ្ឋ អត្តសញ្ញាណ និងប្រភេទរបស់ចារីដែលជាក់ស្តែងដែលពាក់ព័ន្ធការត្រួតពិនិត្យរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា លើកម្មាភិបាលទាំងអស់នោះ និងសេចក្តីរាយការណ៍ដែលស៊ីសង្វាក់គ្នាស្តីពីបទឧក្រិដ្ឋនានា មកកាន់មន្ទីរ៨៧០។ ភស្តុតាងបង្ហាញថាបទឧក្រិដ្ឋទាំងឡាយដែលបានកើតឡើងនៅទូទាំងប្រទេស (រួមទាំងបទឧក្រិដ្ឋទាំងឡាយណាដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃគោលនយោបាយទាសភាព ការបោសសម្អាតខ្មាំងសត្រូវ និង

ការធ្វើទុក្ខបុកម្នេញ ឬការលុបបំបាត់ជនជាតិភាគតិច) ដែលស៊ីសង្វាក់គ្នាយ៉ាងខ្លាំង និងជាលទ្ធផល នៃការចេញបទបញ្ជារួម ដែលផ្ទុយទៅនឹងអំពើទាំងឡាយដែលប្រព្រឹត្តឡើងដោយចៃដន្យ។

## ការជួយជ្រោមជ្រែង និងការជួយជម្រុញ

១៥៨៧- **អៀង សារី** បានជួយជ្រោមជ្រែង និងបានជួយជម្រុញឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ ដោយបានជួយលើកទឹកចិត្ត ជួយគាំទ្រផ្នែកស្មារតី និងផ្តល់ជំនួយផ្នែកអនុវត្តដល់កម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ការជួយជ្រោមជ្រែង និងការជួយ ជម្រុញរបស់គាត់មានឥទ្ធិពលយ៉ាងសំខាន់លើបទឧក្រិដ្ឋទាំងឡាយ មុនពេល ក្នុងអំឡុងពេល និង ក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

១៥៨៨- **អៀង សារី** បានលើកទឹកចិត្តឲ្យមានការអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់មជ្ឈិមបក្ស តាមរយៈការគាំទ្រគោលនយោបាយទាំងនោះ ក្នុងនាមជាសមាជិកមួយរូបនៃគណៈមជ្ឈិម និង គណៈអចិន្ត្រៃយ៍។ គាត់បានផ្តល់ជំនួយផ្នែកអនុវត្ត និងគាំទ្រដល់ឧក្រិដ្ឋកម្មទាំងឡាយ ដែលបាន កើតឡើងនៅមន្ទីរស២១ ដោយបានយល់ព្រមឲ្យមានការចាប់ខ្លួននិងការផ្ទេរកម្មាភិបាលក្រសួង ការបរទេសទៅមន្ទីរសន្តិសុខនោះ និងបានលើកទឹកចិត្ត និងជួយគាំទ្រផ្នែកស្មារតីដល់កម្មាភិបាល ក្រសួងការបរទេសដែលមានការពាក់ព័ន្ធក្នុងការចាប់ខ្លួននោះ។ ស្រដៀងគ្នានេះដែរ គាត់បានជួយ ជ្រោមជ្រែង និងជួយជម្រុញឲ្យមានឧក្រិដ្ឋកម្មនៅមន្ទីរស២១ ដោយបានចូលរួមក្នុងដំណើការ អំពាវនាវហៅអ្នកការទូត បញ្ញវន្ត និងសិស្ស និស្សិត ឲ្យត្រឡប់មកពីបរទេសវិញ និងក្នុងការ កំណត់អត្តសញ្ញាណអ្នកទាំងឡាយណាដែលនឹងត្រូវចាប់ខ្លួន និងត្រូវឃុំខ្លួននៅមន្ទីរស២១។ គាត់បានលើកទឹកចិត្តដល់ ការប្រព្រឹត្តិបទឧក្រិដ្ឋនានាឲ្យកើតមានឡើង ជាផ្នែកមួយនៃគោល

នយោបាយទាសភាព និងការធ្វើពលកម្មដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការធ្វើទស្សនកិច្ចតាមការដ្ឋាននានា (រួមទាំង **ទំនប់ត្រពាំងថ្ម ទំនប់១មករា** និង**ព្រលានយន្តហោះកំពង់ឆ្នាំង**ផងដែរ) និងតាមរយៈការថ្លែងសន្ទរកថា និងការធ្វើសេចក្ដីថ្លែងការណ៍គាំទ្រគោលនយោបាយទាំងអស់នោះនៅតាមវេទិកាអន្តរជាតិ ដូចជា នៅអង្គការសហប្រជាជាតិជាដើម។

១៩៨៩- ក្នុងនាមជាសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា និងជាប្រមុខក្រសួងការបរទេស **អៀង សារី** បានដឹងថាទង្វើនៃការលើកទឹកចិត្ត និងគាំទ្រផ្នែកស្មារតី និងការអនុវត្តន៍របស់គាត់ គឺជាការជួយដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនានា និងមានចេតនាក្នុងការផ្ដល់ជំនួយនោះ ឬយ៉ាងហោចណាស់ ក៏គាត់បានទទួលស្គាល់ថា ជំនួយនោះអាចជាផលវិបាកនៃការប្រព្រឹត្តិរបស់ខ្លួនដែលអាចកើតមាន និងអាចដឹងជាមុនបាន។ **អៀង សារី** ក៏បានដឹងផងដែរអំពីធាតុផ្សំសំខាន់នៃបទឧក្រិដ្ឋដែលគាត់បានជួយជ្រោមជ្រែង និងជួយជម្រុញ ពីព្រោះគាត់ត្រូវបានគេជូនដំណឹងជាបន្តបន្ទាប់អំពីសកម្មភាពទាំងឡាយរបស់ចារីដែលដល់ផ្ទាល់នៅគ្រប់លំដាប់ថ្នាក់ តាមរយៈតួនាទីរបស់គាត់នៅក្នុងគណៈអចិន្ត្រៃយ៍ និងក្នុងនាមជាសមាជិកជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ។

## តាមរយៈការទទួលខុសត្រូវក្នុងនាមថ្នាក់ដឹកនាំ

១៩៩០- លើសពីនេះទៀត **អៀង សារី** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្នុងនាមជាថ្នាក់ដឹកនាំមួយរូប អនុលោមតាមមាត្រា ២៩ កថាខណ្ឌ១ នៃច្បាប់ អ.វ.ត.ក ដោយគិតអំពី៖ (១)តួនាទីរបស់គាត់ជាមេដឹកនាំនៃចារីដែលដល់ ដែលប្រព្រឹត្តបទឧក្រិដ្ឋផ្ទាល់ ដូចបានរៀបរាប់នៅក្នុងផ្នែកអង្គហេតុសត្យានុម័ត។ (២)ការដឹងពិតប្រាកដ ឬដឹងតាមការសន្និតរបស់គាត់ថា

អ្នកនៅក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្ត ឬប្រហែលជាអាចនឹងប្រព្រឹត្តបទឧក្រិដ្ឋ។ និង (៣)ការខកខានមិនបានរារាំងមិនឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬមិនបានដាក់ទោសលើចារីនានា។

## ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់

១៩៩១- ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់កើតមានឡើងរវាង **អៀង សារី** និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទាំងអស់ ដែលមានការពាក់ព័ន្ធផ្ទាល់ក្នុងបទឧក្រិដ្ឋទាំងឡាយ រួមទាំងសមាជិក និងកម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជា គណៈភូមិភាគ គណៈតំបន់ និងគណៈស្រុក កម្មាភិបាលតាមក្រសួង បុគ្គលិកមន្ទីរសន្តិសុខ កងឈ្លបតាមមូលដ្ឋាន និងអ្នកមើលខុសត្រូវព្រមទាំងប្រធានកងការងារនៅទីកន្លែងធ្វើពលកម្មដោយបង្ខំផងដែរ។ ទោះបីជាទំនាក់ទំនងនេះមួយចំនួនមានលក្ខណៈប្រយោល ឬ *តាមព្រឹត្តិន័យ*ក្តី ក៏ **អៀង សារី** គឺជាថ្នាក់លើរបស់បុគ្គលទាំងអស់នេះ ផ្អែកតាមការត្រួតត្រាដោយមានប្រសិទ្ធភាពរបស់គាត់លើពួកគេ។ ក្នុងនាមជាសមាជិកខ្ពស់របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជាឧបនាយករដ្ឋមន្ត្រីនៃក្រសួងការបរទេស និងជាសមាជិកនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ គាត់គឺជាថ្នាក់លើរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទាំងអស់គិតតាមឋានានុក្រម។ គាត់មានលទ្ធភាពជាក់ស្តែងក្នុងការរារាំងពួកគេមិនឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ផ្តួចផ្តើមការស៊ើបអង្កេត ឬចាត់វិធានការដែលឈានដល់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេ ដកពួកគេចេញ ឬ ដាក់វិន័យ ឬដាក់ទណ្ឌកម្ម លើពួកគេ បន្ទាប់ពីមានការប្រព្រឹត្តិបទឧក្រិដ្ឋ។ លទ្ធភាពនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ តាមរយៈ៖ ១)លទ្ធភាពរបស់គាត់ក្នុងការចេញសេចក្តីបង្គាប់ទៅគ្រប់អង្គភាព នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងនាមជាសមាជិកនៃគណៈអចិន្ត្រៃយ៍។ ២)ការចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់គណៈ

អចិន្ត្រៃយ៍ធ្វើការស៊ើបអង្កេត និង/ឬដាក់ទណ្ឌកម្មកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានសង្ស័យពីការខ្វះវិន័យ ឬខ្វះភាពស្មោះត្រង់ចំពោះបក្ស និង ៣)តួនាទីរបស់គាត់ ក្នុងការយល់ព្រមឱ្យមានការបោសសម្អាតកម្មាភិបាលនៅក្នុងក្រសួងការបរទេសដោយផ្ទាល់។

## ការដឹងឮ

១៥៩២- **អៀង សារី** មានការដឹងឮយ៉ាងជាក់ស្តែងអំពីបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានប្រព្រឹត្ត ឡើងដោយអ្នកនៅក្រោមបង្គាប់របស់គាត់។ ជាលទ្ធផលនៃអង្គហេតុដែលថា គាត់បានបែងចែក និងបានណែនាំឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ ក្នុងនាមជាសមាជិកមជ្ឈិមបក្សមួយរូប ចាំបាច់គាត់បានដឹងថាបទឧក្រិដ្ឋទាំងនោះត្រូវបានគេប្រព្រឹត្ត។ ការដឹងឮនេះ ត្រូវបានបញ្ជាក់នៅពេលក្រោយមកទៀត តាមរយៈការទទួលរបស់ **អៀង សារី** នូវរបាយការណ៍ដែលធ្វើតាមពេលកំណត់ ស្តីពីការអនុវត្តសេចក្តីបង្គាប់បញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈប្រព័ន្ធរាយការណ៍តាមខ្សែបណ្តោយរបស់បក្ស និងការប្រជុំរបស់គណៈអចិន្ត្រៃយ៍។ ការដឹងឮអំពីបទឧក្រិដ្ឋនានារបស់ **អៀង សារី** នៅរាល់ពេលពាក់ព័ន្ធទាំងអស់ ក៏ត្រូវបានបញ្ជាក់ផងដែរ តាមរយៈការណែនាំរបស់គាត់ដល់កម្មាភិបាលក្រសួងការបរទេស នៅវគ្គបំពាក់បំប៉ននយោបាយនានា និងតាមរយៈការទទួលស្គាល់ដោយផ្ទាល់ខ្លួនរបស់គាត់។

១៥៩៣- ក្នុងករណីដែលភស្តុតាងមិនមាននៅសេសសល់ អំពីការទទួលបានរបស់ **អៀង សារី** នូវរបាយការណ៍ផ្ទាល់អំពីបទឧក្រិដ្ឋជាក់លាក់នោះ ទោះបីជាយ៉ាងណាក៏ដោយ ក៏គាត់មានព័ត៌មានដែលអាចឱ្យគេដឹងអំពីគាត់បានថា បទឧក្រិដ្ឋទាំងឡាយត្រូវបានប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់របស់គាត់។ ព័ត៌មាននេះរួមមាន៖ របាយការណ៍ទូទៅធ្វើដោយអង្គភាពរដ្ឋបាល

និងអង្គភាពយោធា ជូនទៅមន្ទីរ៨៧០ និងគណៈអចិន្ត្រៃយ៍។ ព័ត៌មានដែល **អៀង សារី** បានទទួលពាក់ព័ន្ធទៅនឹងអ្នកនៅក្រោមបង្គាប់ និងក្នុងពេលគាត់ចុះទស្សនកិច្ចនៅទីតាំងឧក្រិដ្ឋកម្មលក្ខណៈជាប្រព័ន្ធ ភាពស៊ីសង្វាក់គ្នា និងលក្ខណៈទូលំទូលាយនៃបទឧក្រិដ្ឋ ព្រមទាំងការប្រព្រឹត្តិបទឧក្រិដ្ឋបន្តទៀត ពេញមួយរយៈពេលក្រោមកិច្ចស៊ើបសួរ។

### ការខកខានមិនបានរារាំង ឬដាក់ទណ្ឌកម្ម

១៥៩៤- **អៀង សារី** ខកខានមិនបានប្រតិបត្តិតួនាទីរបស់ខ្លួន ក្នុងការរារាំងមិនឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ ឬមិនបានដាក់ទណ្ឌកម្មលើអ្នកទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ក្នុងនាមជាស្ថាបនិកដ៏សំខាន់នៃបទឧក្រិដ្ឋទាំងឡាយ **អៀង សារី** មិនបានរារាំងមិនឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះដោយចៀសមិនរួចឡើយ។ ម្យ៉ាងទៀត គាត់បានលើកសរសើរចារី និងបានផ្សាយព័ត៌មានមិនពិតស្ដីពីឧក្រិដ្ឋកម្មទាំងឡាយ តាមរយៈការបដិសេធអំពីការកើតឡើងនៃឧក្រិដ្ឋកម្មទាំងនោះ ក្នុងពេលផ្ដល់បទសម្ភាសន៍ និងក្នុងពេលបំពេញបេសកកម្មការទូត។ ហេតុនេះហើយ ទោះបីជាគាត់មានសមត្ថភាពជាក់ស្ដែងក្នុងការរារាំងនោះក៏ដោយ **អៀង សារី** បានខកខានទាំងស្រុង មិនបានចាត់វិធានការក្នុងការរារាំង ឬការដាក់ទណ្ឌកម្មនោះឡើយ។

# ខៀវ សំផន

## សេចក្តីសង្ខេប

១៩៩៥- ភ័ស្តុតាងនៅក្នុងសំណុំរឿង និងភ័ស្តុតាងដែលបានយោង នៅក្នុងផ្នែកអង្គហេតុសត្យានុម័តនានា នៃដីកាសន្និដ្ឋាននេះ បង្ហាញថា **ខៀវ សំផន** ត្រូវទទួលខុសត្រូវជាលក្ខណៈបុគ្គល ចំពោះការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃ ទី១២ ខែសីហា ឆ្នាំ១៩៤៩ អនុលោមតាមមាត្រា ៣(ថ្មី) មាត្រា ៤, ៥, ៦ និង ២៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

១៩៩៦- ជាពិសេស **ខៀវ សំផន** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ស្របតាមមាត្រា ២៩៖ ១)ពីព្រោះគាត់បានប្រព្រឹត្ត បានរៀបចំផែនការ បានញុះញង់ បានបញ្ជា និង/ឬ បានជួយ ជ្រោមជ្រែង និងបានជួយជម្រុញឱ្យកើតមាននូវបទឧក្រិដ្ឋទាំងអស់នេះ។ ២)ដោយសារតែការខកខានរបស់គាត់ក្នុងការរារាំងមិនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងការដាក់ទណ្ឌកម្មលើចារីដែលដល់ទាំងឡាយ ក្នុងនាមជាថ្នាក់លើដែលបានដឹងថា អ្នកនៅក្រោមបង្គាប់របស់ខ្លួន ប្រហែលជាប្រព្រឹត្ត ឬបានប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ។

## ទម្រង់នៃការទទួលខុសត្រូវ

## តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម

### សហកម្មឧក្រិដ្ឋកម្មរួម ១ (មូលដ្ឋាន)

១៥៩៧- **ខៀវ សំផន** ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ក្នុងទម្រង់ជាមូលដ្ឋាន និងជាប្រព័ន្ធ។ គោលបំណង រយៈពេល និងសមាជិកភាព នៃសហកម្មឧក្រិដ្ឋកម្មរួមនេះ ត្រូវបានរៀបរាប់ខាងលើពាក់ព័ន្ធនឹង **នួន ជា**។

*ការរួមចំណែក*

១៥៩៨- ក្នុងតួនាទីជាលក្ខណៈបុគ្គល តាមរយៈការចូលរួម តួនាទី និងសមាជិកភាព ដូចបានរៀបរាប់នៅក្នុងផ្នែកនេះ និងក្នុងការរួបរួមគ្នាជាមួយសមាជិកផ្សេងទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម **ខៀវ សំផន** បានរួមចំណែកយ៉ាងសំខាន់ក្នុងសហកម្មឧក្រិដ្ឋកម្មនោះយ៉ាងសំខាន់ ដោយ៖

(១) **រួមចំណែកក្នុងការបង្កើតមាគ៌ា** និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនាំឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនានា ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះ។

(២) **ចូលរួមក្នុងការបង្កើត ការរៀបចំ និងការដឹកនាំ**ស្ថាប័នរបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា រួមមាន គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ មន្ទីរ៨៧០ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក ព្រមទាំងគណៈកម្មាធិការជាន់ទាបនានា សេនាធិការកងទ័ពបដិវត្តកម្ពុជា កងពលធំ និងកងវរសេនាធំនានា ព្រមទាំងគណៈកម្មាធិការ ក្រសួង និងកងឈ្លបផ្សេងទៀត ដែលអាចឆ្លើយតបចំពោះមជ្ឈិមបក្ស ដែលតាមរយៈនេះ បទឧក្រិដ្ឋទាំងឡាយដែលស្ថិតក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានប្រព្រឹត្តឡើង។

(៣) **រៀបចំផែនការ និងធ្វើការសម្របសម្រួល** ដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនានា តាមរយៈ ការចូលរួមក្នុងការប្រជុំ ការពិភាក្សាដេញដោល និងការធ្វើសេចក្ដីសម្រេចរបស់មជ្ឈិម បក្សកុម្មុយនីស្ដកម្ពុជា។

(៤) **ការបញ្ជា ការអនុវត្តការត្រួតពិនិត្យ និងការណែនាំ**ដល់កម្មាភិបាលនៅក្នុង អង្គភាពរដ្ឋបាល និងយោធារបស់បក្សកុម្មុយនីស្ដកម្ពុជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋនានា រួមទាំងចូលរួមក្នុងការ បង្កើត និងក្នុងការចេញបញ្ជារបស់មន្ទីរ៨៧០ផងដែរ ព្រមទាំងជួបប្រជុំជាមួយកម្មាភិបាល ថ្នាក់ក្រោមទាក់ទិននឹងបទឧក្រិដ្ឋនានា ទទួលរបាយការណ៍ពីពួកគេ និងមើលការខុសត្រូវ លើពួកគេ។

(៥) **ពាក់ព័ន្ធផ្ទាល់ក្នុងបទឧក្រិដ្ឋ** រួមមានតាមរយៈ៖ ការចូលរួមក្នុងការធ្វើសេចក្ដីសម្រេច ជាក់លាក់លើការចាប់ខ្លួនថ្នាក់ដឹកនាំជាន់ខ្ពស់ និងប្រហារជីវិតថ្នាក់ដឹកនាំជាន់ខ្ពស់តាមរយៈ គណៈអចិន្ត្រៃយ៍។ ណែនាំ និងត្រួតពិនិត្យមើលការអនុវត្តគោលនយោបាយឧក្រិដ្ឋនៃការ ប្រើពលកម្មដោយបង្ខំ និងទាសភាព របស់បក្សកុម្មុយនីស្ដកម្ពុជាក្នុងតួនាទី របស់គាត់ជា សមាជិកនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ដែលទទួលខុសត្រូវចំពោះពាណិជ្ជកម្ម និង ការបង្កបង្កើនផលរបស់រដ្ឋ។ ចេញសេចក្ដីបង្គាប់បញ្ជា ទទួលរបាយការណ៍ និងត្រួតពិនិត្យ មើលការអនុវត្តគោលនយោបាយឧក្រិដ្ឋ របស់បក្សកុម្មុយនីស្ដកម្ពុជា តាមរយៈតួនាទីរបស់ គាត់នៅក្នុងមន្ទីរនយោបាយ៨៧០ ដោយបានបញ្ជាក និង/ឬយល់ព្រមឲ្យមានការចាប់ខ្លួន កម្មាភិបាលនានាក្រោមសិទ្ធិអំណាចរបស់គាត់ ព្រមទាំងរួមចំណែក ក្នុងការប្រព្រឹត្តិ បទឧក្រិដ្ឋជាក់លាក់ ដូចជា ការត្រួតពិនិត្យលើដំណោះស្រាយដើម្បីប្រហារជីវិត "ជនក្បត់

ប្រាំពីរនាក់” និងរៀបចំផែនការ ព្រមទាំងត្រួតពិនិត្យលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

(៦) **ញុះញង់ ឣុជអាល ជម្រុញ និងលើកទឹកចិត្ត** ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ រួមទាំង៖ ការធ្វើទស្សនកិច្ចទីកន្លែងឧក្រិដ្ឋកម្មនានា (ដូចជាទំនប់ត្រពាំងថ្ម ទំនប់១មករា និងព្រលានយន្តហោះកំពង់ឆ្នាំង ជាដើម)។ បំពាក់បំប៉នកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា កម្មាភិបាលក្រសួង និងកម្មាភិបាលយោធាដែលពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋនានា។ ការរៀបចំ និង/ឬការអនុម័ត លើការបោះពុម្ពផ្សាយផ្ទៃក្នុងបក្សដែលបានចែកឱ្យកម្មាភិបាលនានា (ដូចជាទស្សនាវដ្តី*ទង់បដិវត្ត* ជាដើម) និងចេញសេចក្តីថ្លែងការណ៍សាធារណៈ ព្រមទាំងថ្លែងសុន្ទរកថានានា ដោយការពារ និងគាំទ្រគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា និងលើកទឹកចិត្តចារីឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ។

(៧) **តំណាង**ឱ្យបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ ទាំងនៅក្នុងប្រទេស និងនៅលើឆាកអន្តរជាតិ ដោយបដិសេធបទឧក្រិដ្ឋរបស់ខ្លួន និងធ្វើយុត្តិកម្មគោលនយោបាយរបស់ខ្លួននៅចំពោះមុខស្ថាប័នច្បាប់ និងស្ថាប័ននយោបាយ ជាតិនិងអន្តរជាតិនានា ក៏ដូចជាអង្គការព័ត៌មានពិភពលោកផងដែរ។

(៨) **ខកខានមិនបាន**បញ្ឈប់ការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ទោះបីជាដឹងថាបទឧក្រិដ្ឋទាំងឡាយកំពុងត្រូវបានប្រព្រឹត្តស្របតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួមក៏ដោយ និងទោះបីជា គាត់មានអំណាចធ្វើការរារាំង ឬបញ្ឈប់បទឧក្រិដ្ឋទាំងនោះ ឬដាក់ទណ្ឌកម្មលើចារីក៏ដោយ និង

(៩) មួយវិញទៀត **រៀបចំផែនការ ញុះញង់ បញ្ជា និងជួយជ្រោមជ្រែង** ព្រមទាំងជួយជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋនានាដូចបានរៀបរាប់ខាងក្រោម។

*ចេតនា*

១៥៩៩- ជាមួយនឹងសមាជិកផ្សេងទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម **ខៀវ សំផន** បានរួមចំណែក ក្នុងចេតនាប្រព្រឹត្តបទឧក្រិដ្ឋនីមួយៗដែលបានព្រមព្រៀងគ្នាដំបូង និងទាំងបទឧក្រិដ្ឋដែលបានព្រមព្រៀងគ្នាក្រោយៗមកទៀត [ដូចបានរៀបរាប់នៅក្នុងផ្នែក ផែនការឧក្រិដ្ឋកម្មរួម និងផ្នែកការកំណត់បទចោទ (ឧក្រិដ្ឋកម្ម)] ជាមធ្យោបាយចាំបាច់ដើម្បីធ្វើឲ្យសម្រេចបាន គោលបំណងឧក្រិដ្ឋកម្មរួម ដែលមានលក្ខណៈទូលំទូលាយ។ ចេតនារបស់ **ខៀវ សំផន** អាចទាញចេញមកពីអង្គហេតុ និងកាលៈទេសៈជាច្រើន រួមមាន៖

(១) ការយល់ព្រមដោយស្ម័គ្រចិត្ត និងការចូលរួមដោយចេតនារបស់គាត់នៅក្នុង ការងារទាំងឡាយ ក្នុងតួនាទីជាន់ខ្ពស់ និងមុខងារទាំងឡាយដែលអាចធ្វើឲ្យគាត់ ចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

(២) សកម្មភាពរបស់គាត់នៅក្នុងការបង្កើតបទឧក្រិដ្ឋនានា ជាមួយនឹងសហចារី និងជួយជ្រោមជ្រែងការប្រព្រឹត្តិរបស់ពួកគេ ដូចបានមានតាមរយៈការរួមចំណែក ដែលបានរៀបរាប់ខាងលើ។

(៣) សន្ទរកថា និងសេចក្ដីថ្លែងការណ៍របស់គាត់ មុន និងក្នុងអំឡុងពេល ក្រោមកិច្ចស៊ើបសួរ ដែលក្នុងនោះគាត់បានបញ្ជាក់ការគាំទ្រម្ដងហើយម្ដងទៀត ចំពោះគោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា និងអំពាវនាវ ទៅកាន់កម្មាភិបាលនានា អោយពង្រឹង និងអនុវត្តសេចក្ដីថ្លែងការណ៍ទាំងនោះ។

(៤) ការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជាដែលគាត់បានរួមចំណែក និងដែលគាត់បានយល់ព្រម និងគាំទ្រ។

(៥) សេចក្តីថ្លែងការណ៍របស់គាត់ក្នុងវគ្គបំពាក់បំប៉នននយោបាយ និងលត់ដំកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និង

(៦) សកម្មភាព ការសរសេរ និងការថ្លែងរបស់គាត់ ក្រោយពេលស៊ើបអង្កេត រួមទាំងចេតនារបស់គាត់ក្នុងការធ្វើយុត្តិកម្មចំពោះបទឧក្រិដ្ឋទាំងឡាយ។

## សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ)

១៦០០- លើសពីនេះទៀត **ខៀវ សំផន** ទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ដោយអនុវត្តស្របទៅនឹងប្រព័ន្ធធ្វើបាបដែលបានរៀបចំមកលើប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធនៃការធ្វើបាបប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងការបង្កើតជាប្រព័ន្ធនិងទូទាំងប្រទេស នូវសហករណ៍ ការដ្ឋានធ្វើពលកម្មដោយបង្ខំ មណ្ឌលលត់ដំ និងមន្ទីរសន្តិសុខនានាដូចបានរៀបរាប់នៅក្នុងជំពូកអង្គហេតុសត្យានុម័ត។ **ខៀវ សំផន** បានដឹងអំពីលក្ខណៈនៃប្រព័ន្ធនៃការបង្ក្រាប បានចូលរួមនៅក្នុងការអនុវត្តប្រព័ន្ធនេះ និងមានចេតនាដើម្បីជ្រោមជ្រែងដល់ផែនការនៃការធ្វើបាបជាប្រព័ន្ធនេះ។

## តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយជ្រោមជ្រែង ព្រមទាំងការជួយជម្រុញ

## សេចក្តីផ្តើម

១៦០១- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ **ខៀវ សំផន** តាមរយៈសមាជិកភាពរបស់ខ្លួនក្នុងសហកម្មឧក្រិដ្ឋកម្មរួម ឆ្លុះបញ្ចាំងពិតប្រាកដបំផុតអំពីការទទួលខុសត្រូវរបស់គាត់ចំពោះបទឧក្រិដ្ឋនានា

ដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ។ ទោះបីជាយ៉ាងណាក៏ដោយ **ខៀវ សំផន** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះតួនាទីរបស់គាត់ ក្នុងការរៀបចំផែនការ ការញុះញង់ ការបញ្ជា និង/ឬ ការជួយ និងការជម្រុញបទឧក្រិដ្ឋនានា អនុលោមតាមមាត្រា២៩ កថាខណ្ឌ១ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## ការរៀបចំផែនការ

១៦០២- **ខៀវ សំផន** បានរៀបចំផែនការបទឧក្រិដ្ឋដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ គាត់គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលទាំងឡាយ ដែលបានរៀបគម្រោងឧក្រិដ្ឋទាំងអស់នោះ និងបានបង្កើតវិធីសាស្ត្រនៃការអនុវត្តបទឧក្រិដ្ឋទាំងនោះ។ ក៏ដូចជាការរៀបចំផែនការឧក្រិដ្ឋដោយផ្ទាល់ គាត់បានគាំទ្រ ឬយល់ព្រមចំពោះផែនការឧក្រិដ្ឋ និងគោលនយោបាយ ដែលបានកែលំអដោយសមាជិកផ្សេងទៀត របស់មជ្ឈិមបក្ស។

១៦០៣- ដូចដែលបានរៀបរាប់ខាងលើទាក់ទិននឹង **នួន ជា** បទឧក្រិដ្ឋទាំងឡាយ ត្រូវបានរៀប គម្រោង ត្រូវបានបង្កើត និងត្រូវបានសម្របសម្រួលជារួម។ ក្នុងនាមជាសមាជិកម្នាក់នៃគណៈមជ្ឈិម *តាមព្រឹត្តិន័យ* ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ និងជាសមាជិក ព្រមទាំងជាប្រធានមន្ទីរនយោបាយ៨៧០ **ខៀវ សំផន** មានអំណាចក្នុងការរួមចំណែកបង្កើតគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា និងបានប្រើប្រាស់អំណាចនោះ ដើម្បីរួមចំណែកក្នុងការរៀបគម្រោងឧក្រិដ្ឋនានា។ គាត់បានចូលរួមក្នុងការពិភាក្សាដេញដោល និងក្នុងការសម្រេចសេចក្តីដែលនាំឲ្យមានការបង្កើតគោលដៅឧក្រិដ្ឋកម្ម ការចាត់តាំងកម្មាភិបាល ការផ្សព្វផ្សាយការណែនាំ និងការបង្កើតយន្តការផ្សេងទៀត ដើម្បីអនុវត្តសេចក្តីបង្គាប់បញ្ជាឧក្រិដ្ឋកម្មរបស់មជ្ឈិមបក្ស។ គាត់បានចូល

រួមក្នុងការរៀបចំផែនការ ជម្លៀសប្រជាជនចេញពីទីប្រជុំជនធំៗដោយបង្ខំ។ គាត់ក៏បានចូលរួមក្នុងការរៀបចំផែនការចាប់ខ្លួន និងការប្រហារជីវិតមន្ត្រីជាន់ខ្ពស់ផងដែរ រួមទាំងអ្នកទាំងឡាយណាដែលជាអតីតសហសេវិករបស់ FUNK និង GRUNK អ្នកនយោបាយ និងកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ បន្ថែមពីលើនេះទៀត ក្នុងនាមជាថ្នាក់ដឹកនាំដែលទទួលខុសត្រូវផ្នែកពាណិជ្ជកម្មរដ្ឋ និងការបង្កបង្កើនផល គាត់បានចូលរួមក្នុងការបង្កើតគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការធ្វើពលកម្មដោយបង្ខំ និងទាសភាព រួមទាំងការធ្វើ ឬរួមចំណែកក្នុងការសម្រេចអំពីការងារធ្វើដោយដៃ និងលក្ខខណ្ឌការងារ កម្រិតនៃការបង្កបង្កើនផល និងការចែកចាយទំនិញនិង សម្ភារៈផ្គត់ផ្គង់នានា។ សកម្មភាពទាំងអស់នេះរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្ត បទឧក្រិដ្ឋទាំងឡាយ។

១៦០៤- **ខៀវ សំផន** មានចេតនារៀបចំផែនការប្រព្រឹត្តិបទឧក្រិដ្ឋនានា ឬក៏បើគិតអំពីមុខងារ និងតួនាទីរបស់គាត់ គាត់បានដឹងអំពីភវនីយភាពសំខាន់ដែលបទឧក្រិដ្ឋនានា នឹងត្រូវបានប្រព្រឹត្តក្នុងការអនុវត្តអំពើទាំងឡាយដែលគាត់បានគ្រោងទុក។ បញ្ហានេះបង្ហាញជាក់ស្តែងតាមរយៈការគាំទ្ររបស់គាត់ចំពោះបទឧក្រិដ្ឋនានា ការអនុវត្តអំពើទាំងនោះយ៉ាងសកម្មតាមរយៈតួនាទីរបស់គាត់នៅក្នុងមន្ទីរនយោបាយ៨៧០ និងការពង្រឹងគោលនយោបាយរបស់មជ្ឈិមបក្ស នៅក្នុងសម័យប្រជុំបំពាក់បំប៉នគោលនយោបាយនានា។ ចេតនារបស់ **ខៀវ សំផន** ក្នុងការរៀបចំផែនការឧក្រិដ្ឋនានា ក៏អាចសន្និដ្ឋានបានអំពីការដឹងឮរបស់គាត់ អំពីការអនុវត្ត និងទម្រង់ទាំងឡាយនៃប្រតិបត្តិការរបស់បក្សកុម្មុយនីស្តកម្ពុជា (រួមទាំងការអនុវត្តគោលនយោបាយរបស់បក្សដាច់ខាត) និងសេចក្តីរាយការណ៍ជាទៀងទាត់ដែលគាត់បានទទួលស្តីពីការអនុវត្តមាគ៌ា និង

សេចក្ដីបង្គាប់បញ្ជារបស់បក្ស តាមរយៈគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ និងមន្ទីរនយោបាយ ៨៧០ផងដែរ។

## ការញុះញង់

១៦០៥- **ខៀវ សំផន** បានញុះញង់ឲ្យមានបទឧក្រិដ្ឋ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ ដោយបានជម្រុញ បានលើកទឹកចិត្ត បានញ៉ុាង បាននាំអាទិ៍ និងបានអុជអាលចារី ដែលនេះជាការរួមចំណែកយ៉ាងសំខាន់ ចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះ។

១៦០៦- **ខៀវ សំផន** បានលើកទឹកចិត្ត និងបានពន្យុះកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ តាមរយៈ ការរៀបចំ និងការធ្វើជាប្រធានវគ្គបំពាក់បំប៉ននយោបាយ សម្រាប់បញ្ញវន្តដែលបានធ្វើមាតុភូមិនិវត្តន៍ និងកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា។ ក្នុងអំឡុងវគ្គបំពាក់បំប៉ននោះ គាត់បានឯកភាព និងធ្វើយុត្តិកម្មលើសេចក្ដីសម្រេច និងគោលនយោបាយឧក្រិដ្ឋនានារបស់បក្សកុម្មុយនីស្ដកម្ពុជា រួមមាន ការជម្លៀសប្រជាជនដោយ បង្ខំចេញពីទីក្រុង ការដាក់ជាទាសករ និងការធ្វើពលកម្មដោយបង្ខំ ការកម្ទេចខ្មាំង និងការធ្វើទុក្ខបុកម្នេញជនជាតិវៀតណាម។ **ខៀវ សំផន** បានទទូចឲ្យអ្នកចូលរួមទាំងនោះត្រួតពិនិត្យឥរិយាបថគ្នាទៅវិញទៅមក និងប្ដេជ្ញាដើរតាមមាគ៌ាបក្ស។ តាមរយៈការចុះទៅទស្សនទីតាំងឧក្រិដ្ឋកម្មនានា (រួមមាន **ទំនប់១មករា ព្រលានយន្ដហោះខេត្តកំពង់ឆ្នាំង និងទំនប់ត្រពាំងថ្ម**) គាត់បានផ្ដល់នូវការលើកទឹកចិត្ត និងជំនួយស្មារតីដល់ចារីផ្ទាល់ នៅកន្លែងទាំងនោះ។ លើសពីនេះទៀត **ខៀវ សំផន** បានលើកទឹកចិត្តឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋតាមរយៈការធ្វើយុត្តិកម្ម និងការឯកភាពទៅលើគោលនយោបាយឧក្រិដ្ឋយ៉ាងច្រើនរបស់បក្សកុម្មុយនីស្ដកម្ពុជា ក្នុងនាមជាប្រមុខរដ្ឋនៅក្នុង

សុន្ទរកថាជាសាធារណៈនៅក្នុងវេទិកាជាតិ និងអន្តរជាតិ។ នៅក្នុងសុន្ទរកថាថ្លែងទៅកាន់អ្នកស្តាប់ក្នុងស្រុក គាត់បានញុះញង់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឱ្យស្វែងរក និងកម្ទេចខ្មាំង និងបានលើកសរសើរដល់ជោគជ័យរបស់របបនោះ ក្នុងការអនុវត្តការចាប់ខ្លួន និងការប្រហារជីវិតក្រៅប្រព័ន្ធច្បាប់ និងបានលើកទឹកចិត្តឱ្យមានការអនុវត្ត ការធ្វើពលកម្មដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា ការប្រើប្រាស់កុមារ ឱ្យធ្វើពលកម្មដោយបង្ខំ និងការចែកចាយឱសថ ដែលគ្មានប្រសិទ្ធភាព និងគ្មានសុវត្ថិភាព។

១៦០៧- ខ្លឹមសារ ភាពស៊ីសង្វាក់គ្នា និងភាពញឹកញាប់នៃសេចក្តីថ្លែងការណ៍ និងសកម្មភាពនានារបស់ **ខៀវ សំផន** បង្ហាញថា គាត់មានចេតនាបង្កហេតុ និងញុះញង់ចារីផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬយ៉ាងហោចណាស់ គាត់បានដឹងអំពីភវនីយភាពយ៉ាងច្រើនដែលបទឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តឡើង ដែលជាលទ្ធផលកើតចេញពីការលើកទឹកចិត្តរបស់គាត់។ គាត់បានដឹងយ៉ាងច្បាស់អំពីការអនុវត្តយ៉ាងតឹងរ៉ឹងនូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងអំពីឥទ្ធិពលនៃសេចក្តីថ្លែងការណ៍របស់មេដឹកនាំជាន់ខ្ពស់ ដូចជារូបគាត់ជាដើមមានទៅលើចារីផ្ទាល់នៅទូទាំងប្រទេស។

## ការបញ្ជា

១៦០៨- **ខៀវ សំផន** បានបញ្ជាឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ ការអនុវត្តអំណាចរបស់គាត់ទាំងលក្ខណៈផ្លូវការ និងក្រៅផ្លូវការ និងការប្រព្រឹត្តិជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា គាត់បានបង្កើតបានចេញ

និងបានផ្សព្វផ្សាយបទបញ្ជា និងសេចក្ដីបង្គាប់នានា ដែលណែនាំឲ្យកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា ឲ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

១៦០៩- **ដូចបានពន្យល់ខាងលើទាក់ទងនឹង នួន ជា បទឧក្រិដ្ឋនានាត្រូវបានប្រព្រឹត្តតាមការបទបញ្ជា និងសេចក្ដីណែនាំរបស់ថ្នាក់លើ។ ខៀវ សំផន** ក្នុងនាមជាសមាជិកមជ្ឈិមបក្ស បានចូលរួមក្នុងបទបញ្ជារួមទាំងនេះ និងបានទទួលរបាយការណ៍ស្ដីពីការអនុវត្តបទបញ្ជារួមនោះ។ មុខតំណែងដ៏មានអំណាចរបស់គាត់ រួមមាន ជាសមាជិកនៃគណៈមជ្ឈិម *គាមព្រឹត្តិន័យ* ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ជាសមាជិក និងជាប្រធាននៃមន្ទីរនយោបាយ៨៧០ តួនាទីរបស់គាត់ជាគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ និងការទទួលខុសត្រូវរបស់គាត់ចំពោះសេដ្ឋកិច្ច និងផលិតផលក្នុងស្រុករបស់កម្ពុជាប្រជាធិបតេយ្យ។ **ខៀវ សំផន** បានប្រើប្រាស់មុខតំណែងទាំងនេះ ដើម្បីណែនាំកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋតាមវិធីដូចខាងក្រោមនេះ ៖ តាមរយៈ

-ការចូលរួមក្នុងការបង្កើត និងការចេញបទបញ្ជា រួមមានបទបញ្ជាទាំងឡាយដែលបានរៀបរាប់ពីខាងលើទាក់ទិនទៅនឹង **នួន ជា** ព្រមទាំងសេចក្ដីសម្រេចឲ្យប្រហារជីវិត "ជនក្បត់៧នាក់"

- ការចេញបទបញ្ជា និងសេចក្ដីបង្គាប់តាមរយៈមន្ទីរនយោបាយ៨៧០។

-ការចូលរួមប្រជុំរវាងមជ្ឈិមបក្ស និងកម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជា ដែលក្នុងអំឡុងពេលនោះ កម្មាភិបាលបក្សកុម្មុយនីស្ដកម្ពុជាត្រូវបានមជ្ឈិមបក្សផ្ដល់ការណែនាំទាក់ទិននឹងការអនុវត្តមាគ៌ាបក្ស ។ និង

- ការចេញសេចក្តីណែនាំដោយផ្ទាល់ខ្លួនគាត់ ដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលបានពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋ និងការឯកភាព ឱ្យមានការចាប់ខ្លួនកម្មាភិបាលដែលស្ថិតនៅក្រោមអំណាចរបស់គាត់។

១៦១០- **ខៀវ សំផន** មានចេតនាបង្ករឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ តាមរយៈបទបញ្ជា និងសេចក្តីណែនាំដែលបានរៀបរាប់នៅខាងលើ ឬយ៉ាងហោចណាស់ បានដឹងអំពីភវនីយភាពយ៉ាងច្រើនដែលបទឧក្រិដ្ឋទាំងឡាយនឹងត្រូវបានប្រព្រឹត្តនៅក្នុងការអនុវត្តបទបញ្ជាទាំងនោះ។ ភ័ស្តុតាងអំពីបទបញ្ជាផ្ទាល់ ដែលបានចេញដោយមជ្ឈិមបក្ស ព្រមទាំងកត្តានានាដែលអាចទាញសេចក្តីសន្និដ្ឋានបានដែលត្រូវបានយកមកធ្វើជាសំអាងនៅខាងលើ ទាក់ទិននឹង **នួន ជា** បានបញ្ជាក់អំពីចេតនានេះ។

១៦១១- ដោយមិនគិតអំពីថាតើ **ខៀវ សំផន** មានទំនាក់ទំនងជាផ្លូវការរវាងអ្នកក្រោមបង្គាប់ និងថ្នាក់លើទាក់ទិននឹងចារីផ្ទាល់ ឬយ៉ាងណានោះ ដោយសារតែមុខតំណែងជាន់ខ្ពស់របស់គាត់ គាត់មានអំណាចជំរុញឱ្យចារីប្រព្រឹត្តបទឧក្រិដ្ឋ និងបានជំរុញពួកគេឱ្យប្រព្រឹត្តបែបនោះ។ ដូចដែលបានកត់សម្គាល់ទាក់ទិននឹង **នួន ជា** នៅពេលភ័ស្តុតាងនៃបទបញ្ជាដោយផ្ទាល់ដែលបានចេញដោយ **ខៀវ សំផន** និងមជ្ឈិមបក្ស ទាក់ទិននឹងបទឧក្រិដ្ឋ មិនមាននៅសេសសល់នោះ អត្ថិភាពនៃបទបញ្ជាទាំងនោះអាចត្រូវបានទាញសេចក្តីសន្និដ្ឋានពីភ័ស្តុតាង និងអង្គហេតុនានា ដូចជា៖ បទបញ្ជាដែលនៅសល់របស់មន្ទីរ៨៧០ មានភាពស៊ីសង្វាក់គ្នា នូវចំនួននៃបទឧក្រិដ្ឋ និងលក្ខណៈជាប្រព័ន្ធ និងរីករាលដាលនៃបទឧក្រិដ្ឋទាំងនោះ អត្តសញ្ញាណ និងប្រភេទនៃចារីប្រព្រឹត្តផ្ទាល់ដែលជាប់ពាក់ព័ន្ធការត្រួតត្រាដែលបានដាក់ទៅលើចារីទាំងនោះ ពីសំណាក់មជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា និងការធ្វើសេចក្តីរាយការណ៍ស្តីពីបទឧក្រិដ្ឋទាំងនោះទៅមន្ទីរ៨៧០ ដែល

មានលក្ខណៈស៊ីសង្វាក់គ្នា។ ភ័ស្តុតាងបង្ហាញថា បទឧក្រិដ្ឋ ដែលបានកើតឡើងទូទាំងប្រទេស (រួមមានបទឧក្រិដ្ឋនៃការដាក់ឱ្យទៅជាទាសករ ការបោសសំអាតខ្មាំង ការធ្វើទុក្ខបុកម្នេញ និងការបំផ្លាញជនជាតិភាគតិច) មានលំនាំស៊ីសង្វាក់គ្នាយ៉ាងខ្លាំង និងជាលទ្ធផលនៃបទបញ្ជា ដែលត្រូវបានចេញពីមជ្ឈិមបក្ស ដែលវាខុសគ្នាទៅនឹងអំពើដែលកើតឡើងដោយចៃដន្យ។

## ការជួយ និងការជម្រុញ

១៦១២- **ខៀវ សំផន** បានជួយ និងបានជម្រុញឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ ដោយបានជួយលើកទឹកចិត្ត ជួយគាំទ្រផ្នែកស្មារតី និងផ្តល់ជំនួយក្នុងការអនុវត្តដល់កម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជាដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ការជួយ និងការជម្រុញ របស់គាត់មានឥទ្ធិពលយ៉ាងសំខាន់លើបទឧក្រិដ្ឋទាំងឡាយ មុនពេល ក្នុងអំឡុងពេល និង ក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។

១៦១៣- **ខៀវ សំផន** បានលើកទឹកចិត្តឱ្យមានការអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់មជ្ឈិមបក្ស តាមរយៈការគាំទ្រគោលនយោបាយទាំងនោះ ក្នុងនាមជាសមាជិកមួយរូបនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ព្រមទាំងជាគណៈប្រធានរដ្ឋ។ គាត់បានសម្របសម្រួល និងបានជួយដល់ការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ តាមរយៈការបំពេញការងារនៅក្នុងមន្ទីរនយោបាយ៨៧០ និងការគ្រប់គ្រងមន្ទីរនយោបាយ៨៧០។ **ខៀវ សំផន** បានផ្តល់ជំនួយក្នុងការអនុវត្ត និងគាំទ្រដល់ឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅមន្ទីរសន្តិសុខនានា រួមទាំង មន្ទីរស២១ផងដែរ ដោយបានយល់ព្រមឱ្យមានការចាប់ខ្លួន និងការប្រហារជីវិតកម្មាភិបាល និងដោយបានកំណត់អត្តសញ្ញាណកម្មាភិបាលបក្សកុម្មុយនីស្តជាន់ខ្ពស់ ដើម្បីធ្វើការចាប់ខ្លួន។ បន្ថែមពីលើនេះទៀត

នៅក្នុងការថ្លែងសន្ទរកថា និងការធ្វើសេចក្តីថ្លែងការណ៍ក្នុងវគ្គបំពាក់បំប៉ននយោបាយ គាត់បានផ្តល់ការលើកទឹកចិត្តដល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ **ខៀវ សំផន** ក៏បានជួយ និងជម្រុញឲ្យមានបទឧក្រិដ្ឋកើតឡើង ដែលជាផ្នែកមួយនៃគោលនយោបាយទាសភាព និងគោលនយោបាយធ្វើពលកម្មដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈ៖ ការចុះទស្សនកិច្ចតាមការដ្ឋាននានា (រួមមាន **ទំនប់ត្រពាំងថ្ម ទំនប់១មករា** និង**ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង**ផងដែរ) និងតាមរយៈការជួយគាំទ្រផ្នែកស្មារតីដល់ចារីផ្ទាល់ ព្រមទាំងតាមរយៈការធ្វើសេចក្តីសម្រេច (ឬចូលរួមក្នុងការធ្វើសេចក្តីសម្រេច) លើកម្រិតនៃការបង្កបង្កើនផល និងការចែកផលិតផល និងសម្ភារៈផ្គត់ផ្គង់ផ្ទៃក្នុង។

១៦១៤- ក្នុងនាមជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា និងជាសមាជិក ឬប្រធានមន្ទីរនយោបាយ៨៧០ **ខៀវ សំផន** បានដឹងថា ទង្វើនៃការលើកទឹកចិត្ត និងគាំទ្រផ្នែកស្មារតី និងការអនុវត្តរបស់គាត់ គឺជាការជួយ ដល់ការប្រព្រឹត្តិបទឧក្រិដ្ឋនានា និងមានចេតនាក្នុងការផ្តល់ជំនួយនោះ ឬយ៉ាងហោចណាស់ ក៏គាត់បានទទួលស្គាល់ថា ជំនួយនោះជាផលវិបាកនៃការប្រព្រឹត្តរបស់ខ្លួនដែល អាចកើតមាន និងអាចដឹងជាមុនបាន។ **ខៀវ សំផន** ក៏បានដឹងផងដែរអំពីធាតុផ្សំ សំខាន់នៃបទឧក្រិដ្ឋដែលគាត់បានជួយជ្រោមជ្រែង និងជួយជម្រុញ ពីព្រោះគាត់ត្រូវបាន គេជូនដំណឹងជាបន្តបន្ទាប់អំពីសកម្មភាពទាំងឡាយរបស់ចារីផ្ទាល់នៅគ្រប់លំដាប់ថ្នាក់ តាមរយៈសេចក្តីរាយការណ៍ដែលបានដាក់ជូនគាត់ តាមរយៈមន្ទីរនយោបាយ៨៧០ គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ។

## ការទទួលខុសត្រូវក្នុងនាមថ្នាក់ដឹកនាំ

១៦១៥- លើសពីនេះទៀត និងជាជម្រើសម្យ៉ាងទៀត **ខៀវ សំផន** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលក្នុងនាមជាថ្នាក់ដឹកនាំមួយរូប អនុលោមតាមមាត្រា ២៩ កថាខណ្ឌ១ នៃច្បាប់ អ.វ.ត.ក ដោយគិតអំពី៖ (១)តួនាទីរបស់គាត់ជាមេដឹកនាំចារី ដែលប្រព្រឹត្តបទឧក្រិដ្ឋផ្ទាល់ ដូចបានរៀបរាប់នៅក្នុងផ្នែកអង្គហេតុសត្យានុម័ត។ (២)ការដឹងពិតប្រាកដ ឬដឹងតាមការសន្និដ្ឋានរបស់គាត់ថា អ្នកនៅក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្ត ឬប្រហែលជាបានប្រព្រឹត្តបទឧក្រិដ្ឋ និង (៣)ការខកខានមិនបានរារាំងមិនឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬមិនបានដាក់ទោសលើចារីដៃដល់។

## ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់

១៦១៦- ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ កើតមានឡើងរវាង **ខៀវ សំផន** និងកម្មាភិបាលទាំងអស់ ដែលមានការពាក់ព័ន្ធផ្ទាល់ក្នុងបទឧក្រិដ្ឋទាំងឡាយ រួមទាំង សមាជិកគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជា នៅតាមថ្នាក់ភូមិភាគ ថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ទាប មន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ បុគ្គលិកមន្ទីរសន្តិសុខ អង្គភាពកងទ័ពបដិវត្តកម្ពុជា កងឈ្លបតាមមូលដ្ឋាន និងអ្នកមើលខុសត្រូវ ព្រមទាំងប្រធានកងនៅទីកន្លែងធ្វើពលកម្មដោយបង្ខំផងដែរ។ ចារីមួយចំនួនអាចធ្វើការឆ្លើយតបដោយផ្ទាល់ទៅ **ខៀវ សំផន** ចំពោះករណីណាដែលទាក់ទិននឹងក្រសួងពាណិជ្ជកម្ម ដែលក្នុងនោះការបោសសម្អាតដែលមានលក្ខណៈទូលំទូលាយត្រូវបានធ្វើឡើង។

១៦១៧- ទោះបីជាទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ រវាង **ខៀវ សំផន** និងចារីផ្ទាល់ មានលក្ខណៈប្រយោល ឬ *តាមព្រឹត្តិន័យ* ក្ដី ក៏គាត់គឺជាថ្នាក់លើ របស់ចារីដែលទាំងនេះផ្អែក តាមការត្រួតត្រាដ៏មានប្រសិទ្ធភាពរបស់គាត់លើពួកគេ។ ក្នុងនាមជាសមាជិកជាន់ខ្ពស់របស់ មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិក និងជាប្រធានមន្ទីរនយោបាយ៨៧០ និងជាសមាជិក នៃគណៈមជ្ឈិម និងសមាជិក*តាមព្រឹត្តិន័យ* គណៈអចិន្ត្រៃយ៍ គាត់គឺជាថ្នាក់លើរបស់កម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា ទាំងអស់គិតតាមឋានានុក្រម។ គាត់មានលទ្ធភាពជាក់ស្ដែងក្នុងការរារាំង ពួកគេ មិនឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ផ្ដួចផ្ដើមការស៊ើបអង្កេត ឬចាត់វិធានការដែលឈានដល់កិច្ច ដំណើរការនីតិវិធីប្រឆាំងនឹងពួកគេ ដកពួកគេចេញ ឬម៉្យាងទៀត ដាក់វិន័យ និងដាក់ទណ្ឌកម្ម លើពួកគេបន្ទាប់ពីមានការប្រព្រឹត្តបទឧក្រិដ្ឋ លទ្ធភាពនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ តាមរយៈ៖ ១)អំណាចដាច់ខាតរបស់មជ្ឈិមបក្ស ដែលក្នុងនោះគាត់ជាសមាជិកក្នុងការចេញ បទបញ្ជា និងសេចក្ដីបង្គាប់ ទៅគ្រប់អង្គភាពរដ្ឋាភិបាល អង្គភាពរដ្ឋបាល និងអង្គភាពយោធានៅ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលក្នុងនោះគាត់ក៏ជាសមាជិកមួយរូបដែរ ២)ការចូលរួមក្នុង ការពិភាក្សាដេញដោល និងសេចក្ដីសម្រេចរបស់គាត់ រួមទាំងការពិភាក្សា និងការសម្រេចលើ ការស៊ើបអង្កេត និង/ឬ ដាក់ទណ្ឌកម្មលើកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានសង្ស័យ ថាខ្វះវិន័យ ឬខ្វះភាពស្មោះត្រង់ចំពោះបក្ស។ និង ៣)តួនាទីរបស់គាត់ ក្នុងការយល់ព្រម និង/ឬ បញ្ជាឲ្យមានការបោសសម្អាតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ក្រោមសិទ្ធិអំណាចផ្ទាល់របស់គាត់។

## ការដឹងឮ

១៦១៨- **ខៀវ សំផន** មានការដឹងឮយ៉ាងជាក់ស្ដែងអំពីបទឧក្រិដ្ឋទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើង ដោយអ្នកនៅក្រោមបង្គាប់របស់គាត់។ ជាលទ្ធផលនៃអង្គហេតុដែលថា គាត់បានបែងចែក និង បានណែនាំឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយ ក្នុងនាមជាសមាជិកមជ្ឈិមបក្សមួយរូប គាត់តោង បានដឹងថាបទឧក្រិដ្ឋទាំងនោះត្រូវគេប្រព្រឹត្ត។ ការដឹងឮនេះត្រូវបានបញ្ជាក់នៅពេលក្រោយ មកទៀត តាមរយៈការទទួលដោយផ្ទាល់របស់ **ខៀវ សំផន** នូវរបាយការណ៍ដែលធ្វើតាមពេល កំណត់ស្ដីពីការអនុវត្តសេចក្ដីបង្គាប់បញ្ជារបស់បក្សកុម្មុយនីស្ដកម្ពុជា តាមរយៈមន្ទីរនយោបាយ ៨៧០ ការចូលរួមរបស់គាត់ក្នុងការប្រជុំនានារបស់គណៈអចិន្ត្រៃយ៍ និងការជួបប្រជុំជាមួយ មជ្ឈិមបក្ស និងកម្មាភិបាលជាន់ទាបព្រមទាំងការងាររបស់គាត់ ជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេង ទៀត។ ការដឹងឮអំពីបទឧក្រិដ្ឋនានារបស់ **ខៀវ សំផន** នៅរាល់ពេលពាក់ព័ន្ធទាំងអស់ ក៏ត្រូវ បានបញ្ជាក់ផងដែរ តាមរយៈសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់គាត់ និងតាមរយៈ ការទទួលស្គាល់ដោយផ្ទាល់ខ្លួនរបស់គាត់ ក្នុងអំឡុងពេល និងក្រោយពេលស៊ើបអង្កេត។

១៦១៩- ក្នុងករណីដែលភស្ដុតាងមិនមាននៅសល់អំពីការទទួលបានរបស់ **ខៀវ សំផន** នូវរបាយ ការណ៍ផ្ទាល់អំពីបទឧក្រិដ្ឋជាក់លាក់នោះ ទោះបីជាយ៉ាងណាក៏ដោយ គាត់មានព័ត៌មានដែល អាចឱ្យគេដឹងអំពីគាត់បានថា បទឧក្រិដ្ឋទាំងឡាយត្រូវបានប្រព្រឹត្តឡើង ដោយអ្នកនៅក្រោម បង្គាប់របស់គាត់។ ព័ត៌មាននេះរួមមាន៖ របាយការណ៍ទូទៅធ្វើដោយអង្គភាពរដ្ឋបាល និង អង្គភាពយោធា ជូនទៅមន្ទីរ៨៧០ និងគណៈអចិន្ត្រៃយ៍។ ព័ត៌មានដែល **ខៀវ សំផន** មាន តាមរយៈការពាក់ព័ន្ធជាមួយសមាជិកបក្សកុម្មុយនីស្ដកម្ពុជាផ្សេងទៀត។ លក្ខខណ្ឌទាំងឡាយ

ដែលគាត់អាចសង្កេតឃើញ នៅពេលចុះទស្សនកិច្ចនៅទីតាំងឧក្រិដ្ឋកម្មនានា មានលក្ខណៈជាប្រព័ន្ធ ភាពស៊ីសង្វាក់គ្នា និងលក្ខណៈទូលំទូលាយនៃបទឧក្រិដ្ឋ ព្រមទាំងការប្រព្រឹត្តិបទឧក្រិដ្ឋបន្តទៀតនៅក្នុងរយៈពេលនៃការស៊ើបអង្កេត។

**ការខកខានមិនបានរារាំង ឬដាក់ទណ្ឌកម្ម**

១៦២០- **ខៀវ សំផន** ខកខានមិនបានប្រតិបត្តិតួនាទីរបស់ខ្លួន ក្នុងការរារាំងមិនឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយ ឬមិនបានដាក់ទណ្ឌកម្មលើអ្នកទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ក្នុងនាមជាស្ថាបនិកចម្បងនៃបទឧក្រិដ្ឋទាំងឡាយ គាត់មិនបានរារាំងមិនឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋទាំងនោះដោយចៀសមិនរួចឡើយ។ ម្យ៉ាងទៀត គាត់បានលើកសរសើរចារី និងបានលើកទឹកចិត្តពួកគេ ឱ្យបន្តប្រព្រឹត្តតទៅទៀត ស្របតាម គោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហេតុនេះហើយ ទោះបីជាគាត់មានសមត្ថភាពជាក់ស្តែងក្នុងការរារាំងនោះក៏ដោយ **ខៀវ សំផន** បានខកខានទាំងស្រុង មិនបានចាត់វិធានការក្នុងការរារាំង ឬការដាក់ទណ្ឌកម្ម។

# អៀង ធីរិទ្ធ

## សេចក្តីសង្ខេប

១៦២១- ភស្តុតាងក្នុងសំណុំរឿង និងដែលបានលើកឡើងក្នុងផ្នែកអង្គហេតុសំខាន់ៗ នៃដីកាសន្និដ្ឋាននេះបញ្ជាក់ថា អៀង ធីរិទ្ធ ពិតជាទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការរំលោភក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារ

បំពានធ្ងន់ធ្ងរលើ អនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ អនុលោម តាម មាត្រា៣ (ថ្មី) ៤ ៥ ៦ និង ២៩ នៃច្បាប់ អ.វ.ត.ក។

១៦២២- ពិសេស **អៀង ធីរិទ្ធ** ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតាមមាត្រា២៩ ១) ដោយហេតុថា គាត់បានប្រព្រឹត្ត រៀបចំផែនការ ញុះញង់ បញ្ជា និង/ឬ ជួយនិងជម្រុញ ឧក្រិដ្ឋកម្មទាំងនេះ និង ២) ដោយហេតុថា ក្នុងនាមជាថ្នាក់លើដែលបានដឹងថាមនុស្សក្រោមបង្គាប់របស់ខ្លួនបម្រុងនឹង ប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ គាត់បានខកខានពុំបានទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ទាំងនេះ ឬដាក់ទោសទណ្ឌទៅលើជនល្មើស។

## ទម្រង់នៃការទទួលខុសត្រូវ

## ការប្រព្រឹត្តិតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម

## សហកម្មឧក្រិដ្ឋកម្មរួម ១(មូលដ្ឋាន)

១៦២៣- **អៀង ធីរិទ្ធ** គឺជាអ្នកទទួលខុសត្រូវចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទ ប្រកាន់ក្នុងដីកាសន្និដ្ឋាននេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម (JCE)ក្នុងទម្រង់ជាមូលដ្ឋាន និងជា ប្រព័ន្ធ។ គោលបំណង ចិរវេលា និងសមាជិកភាពនៃសហកម្មឧក្រិដ្ឋកម្មរួម មានរៀបរាប់ខាង លើពាក់ព័ន្ធនឹង **នួន ជា**។

## ការរួមចំណែក

១៦២៤- **អៀង ធីរិទ្ធ** ដែលបានប្រព្រឹត្តក្នុងលក្ខណៈបុគ្គល តាមរយៈការចូលរួម តួនាទី និងសមាជិកភាព ដូចដែលបានរៀបរាប់ក្នុងផ្នែកនេះ និងការសហការជាមួយសមាជិកផ្សេងៗនៃសហកម្ម ឧក្រិដ្ឋកម្មរួម បានរួមចំណែកយ៉ាងសំខាន់ដល់ក្រុមនោះ តាមមធ្យោបាយដូចខាងក្រោម៖

(១) ការចូលរួមក្នុងការតាក់តែងមាគ៌ា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបាននាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយ ដែលត្រូវបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋាននេះ។

(២) ការចូលរួមក្នុងការងាររបស់ស្ថាប័ននានារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលតាមរយៈការចូលរួមនេះ ឧក្រិដ្ឋកម្មទាំងឡាយក្នុងសហកម្មឧក្រិដ្ឋកម្មរួម ត្រូវបានសម្របសម្រួល និងអនុវត្ត រួមទាំងគណៈអចិន្ត្រៃយ៍ គណៈរដ្ឋមន្ត្រី និងក្រសួងសង្គមកិច្ច។

(៣) ការរៀបចំផែនការ និងការសម្របសម្រួល ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាក្នុងរង្វង់ក្រសួងសង្គមកិច្ច។

(៤) ការបញ្ជា ការអនុវត្តការគ្រប់គ្រងលើ និងការណែនាំឱ្យកម្មាភិបាលក្រសួងសង្គមកិច្ចប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

(៥) ការជាប់ពាក់ព័ន្ធផ្ទាល់ខ្លួនក្នុងឧក្រិដ្ឋកម្មទាំងនេះ រួមមានតាមរយៈ ការកំណត់អត្តសញ្ញាណខ្មាំងក្នុងរង្វង់ក្រសួងសង្គមកិច្ច ការពិនិត្យមើលចម្លើយសារភាពពីមន្ទីរ ស២១ របស់មនុស្សដែលគេបានចាប់ខ្លួន ការបញ្ជា ការឯកភាព និង/ឬការសម្របសម្រួលឱ្យមានការចាប់ខ្លួនកម្មាភិបាលថែមទៀត ការរៀបចំ និង/ឬ ការឯកភាពលើការរៀបការដោយបង្ខំ ក្នុងរង្វង់ក្រសួងសង្គមកិច្ច ការដាក់បុគ្គលិកក្រសួងសង្គមកិច្ចឱ្យក្លាយជាទាសករ ការលត់ដំ និងការធ្វើការងារពលកម្មដោយបង្ខំនៅតាមការដ្ឋាននានា (ក្នុងនោះរួមមាន ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានស្រែអំបិល) ការបញ្ជា និងការឯកភាពលើការផលិត និងចែកចាយឱសថគ្មានសុវត្ថិភាពសម្រាប់ផ្តល់ឱ្យប្រជាជនស៊ីវិលដែលបានដាក់ឱ្យក្លាយជាទាសករ។

(៦) ការញុះញង់ ការអុជអាល ការជម្រុញ និងការលើកទឹកចិត្ត ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ទាំងនេះ ក្នុងនោះរួមមានតាមរយៈការធ្វើជាអធិបតីនៃអង្គប្រជុំនៅក្នុងក្រសួងសង្គមកិច្ច និងវគ្គបំពាក់បំប៉នននយោបាយ ដែលក្នុងនោះ គាត់បានបកអាក្រាតមនុស្សដែលគេបាន ចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា គាំទ្រគោលនយោបាយរបស់បក្សក្នុងការ ចាប់ខ្លួន និងការប្រហារជីវិតខ្មាំងរបស់បក្ស និងអំពាវនាវឲ្យកម្មាភិបាលទាំងនោះវែកមុខ ជនក្បត់។

(៧) ការញុះញង់ និងការលើកទឹកចិត្ត ឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មតាមរយៈ ការរៀបចំ ឬ ការគាំទ្រការឃោសនាផ្ទៃក្នុងរបស់បក្ស ការចុះពិនិត្យទីកន្លែងឧក្រិដ្ឋកម្ម (ក្នុងនោះមាន ទំនប់១មករា) និងការចូលរួមក្នុងកិច្ចខិតខំពន្យល់ទៅកាន់អ្នកការទូតបរទេសតាមរយៈការ បដិសេធ ឬការផ្តល់ភាពត្រឹមត្រូវដល់ឧក្រិដ្ឋកម្មទាំងនោះ ក្នុងខណៈពេល ដែលគាត់តំណាងឲ្យ បក្សកុម្មុយនីស្ត កម្ពុជា។

(៨) ការខកខានពុំបានធ្វើអ្វីមួយដើម្បីបញ្ឈប់ការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម បើទោះបីជា គាត់បានដឹងថាឧក្រិដ្ឋកម្មទាំងនេះ កំពុងត្រូវបានប្រព្រឹត្តស្របតាមសហកម្មឧក្រិដ្ឋកម្មរួម ក្តី និងបើទោះបីជាគាត់មានសិទ្ធិអំណាចទប់ស្កាត់ ឬបញ្ឈប់ឧក្រិដ្ឋកម្មទាំងនេះ ឬផ្តន្ទាទោស ចារីក្តី។

(៩) ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និង ការជួយនិងជម្រុញ ឲ្យមានការប្រព្រឹត្តិ ឧក្រិដ្ឋកម្មទាំងនេះ ដូចដែលយើងនឹងលើកយកមករៀបរាប់ខាងក្រោម។

## ចេតនា

១៦២៥- រួមជាមួយសមាជិកដទៃទៀតនៃសហកម្មឧក្រិដ្ឋកម្មរួម **អៀង ធីរិទ្ធ** បានមានចេតនាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនិមួយៗដែលគេបានឯកភាពពីដើមដំបូង និងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានគេព្រមព្រៀងជាបន្តបន្ទាប់មកទៀត [ដូចបានរៀបរាប់នៅក្នុងផ្នែក ផែនការឧក្រិដ្ឋកម្មរួម និងផ្នែកការកំណត់បទចោទ (ឧក្រិដ្ឋកម្ម)] ជាមធ្យោបាយចាំបាច់ដើម្បីធ្វើឲ្យសម្រេចបានគោលដៅឧក្រិដ្ឋកម្មរួម។ ចេតនានេះមាននៅក្នុងកត្តាមួយចំនួន ឬគេអាចសន្និដ្ឋានតាមរយៈកត្តាមួយចំនួន ក្នុងចំណោមកត្តាផ្សេងៗ ដែលមានដូចខាងក្រោម៖

(១) ការព្រមទទួលយកភារកិច្ចចាត់តាំងដោយស្ម័គ្រចិត្ត និងការចូលរួមដោយស្ម័គ្រចិត្តក្នុងភារកិច្ចចាត់តាំងរបស់គាត់ មុខនាទីជាន់ខ្ពស់ និងតួនាទីនានាដែលបានបង្កលទ្ធភាពឲ្យគាត់អាចចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

(២) អំពើរបស់គាត់ក្នុងការបង្កើតឲ្យមានឧក្រិដ្ឋកម្ម រួមជាមួយនឹងសហចារីរបស់គាត់ និងការជម្រុញការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

(៣) សេចក្តីថ្លែងការណ៍របស់គាត់ ដែលបានលើកទឹកចិត្តឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ និងការការពារគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមុនពេល និងក្នុងអំឡុងពេលរយៈកាលក្រោមកិច្ចស៊ើបសួរ។

(៤) ការគាំទ្ររបស់គាត់ចំពោះការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា។

(៥) ការចុះពិនិត្យដល់ទីកន្លែងឧក្រិដ្ឋកម្មរបស់គាត់ ។

(៦) សេចក្តីថ្លែងការណ៍របស់គាត់ ក្នុងអំឡុងពេលវគ្គបំពាក់បំប៉ននយោបាយដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និង

(៧) អំពើ និងសម្តីរបស់គាត់ នៅក្រោយរយៈកាលដែលស្ថិតក្រោមកិច្ចស៊ើបសួរ

## សហកម្មឧក្រិដ្ឋកម្មរួម ២ (ជាប្រព័ន្ធ)

១៦២៦- លើសពីនេះទៀត **អៀង ធីរិទ្ធ** ទទួលខុសត្រូវក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម ដោយអនុវត្តស្របទៅនឹងប្រព័ន្ធធ្វើបាបដែលបានរៀបចំមកលើប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រព័ន្ធនៃការធ្វើបាបប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងការបង្កើតជាប្រព័ន្ធ និងទូទាំងប្រទេស នូវសហករណ៍ ជំរំធ្វើពលកម្មដោយបង្ខំ មណ្ឌលលត់ដំ និងមន្ទីរសន្តិសុខនានា ដូចបានរៀបរាប់នៅក្នុងជំពូកអង្គហេតុជាក់ស្តែង។ **អៀង ធីរិទ្ធ** បានដឹងអំពីលក្ខណៈនៃប្រព័ន្ធនៃការបង្ក្រាប បានចូលរួមនៅក្នុងការអនុវត្តប្រព័ន្ធនេះ និងមានចេតនាដើម្បីជ្រោមជ្រែងដល់ផែនការនៃការធ្វើបាបជាប្រព័ន្ធនេះ។

## តាមរយៈការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងជម្រុញ

## សេចក្តីផ្តើម

១៦២៧- ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ **អៀង ធីរិទ្ធ** តាមរយៈសមាជិករបស់ខ្លួនក្នុងសហកម្មឧក្រិដ្ឋកម្មរួម ឆ្លុះបញ្ចាំងត្រឹមត្រូវបំផុតអំពីការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ។ ប៉ុន្តែម្យ៉ាងទៀត **អៀង ធីរិទ្ធ** ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះតួនាទីរបស់ខ្លួន ក្នុងការរៀបចំផែនការ ការញុះញង់ ការបញ្ជា និង/ឬ ការជួយ និងការជម្រុញ ឧក្រិដ្ឋកម្មទាំងនេះអនុលោមតាមមាត្រា២៩ កថាខណ្ឌ១ នៃច្បាប់ អ.វ.ត.ក។

## ការរៀបចំផែនការ

១៦២៨- **អៀង ធីរិទ្ធ** បានរៀបចំផែនការឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋាននេះ តាមរយៈការរៀបចំអំពើឧក្រិដ្ឋ និងការតាក់តែងវិធីសាស្ត្រប្រហារជីវិត ព្រមទាំងតាមរយៈការគាំទ្រ ឬឯកភាពទៅនឹងផែនការ និងគោលនយោបាយឧក្រិដ្ឋកម្ម ដែលគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍បានបង្កើតឡើង។ ដូច្នេះគាត់បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

១៦២៩- **អៀង ធីរិទ្ធ** បានឯកភាព និងគាំទ្រការបង្កើតគោលនយោបាយឧក្រិដ្ឋជាច្រើនរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ (ក្នុងនោះរួមទាំង ការកំណត់គោលដៅលើជនដែលសង្ស័យថាជាខ្មាំង ការដាក់មនុស្សជាទាសករ ការរៀបការដោយបង្ខំ និងការធ្វើការងារពលកម្មដោយបង្ខំ) និងបានបង្កើត មធ្យោបាយនានាក្នុងការអនុវត្តវិធានការទាំងនោះក្នុងវង្វង់នៃការទទួលខុសត្រូវរបស់ខ្លួន។ គាត់បានរៀបចំផែនការបោសសម្អាតបុគ្គលិកក្រសួងសង្គមកិច្ច តាមរយៈការពិនិត្យមើលចម្លើយសាររបស់អ្នកទោសមន្ទីរ ស២១ ដែលបានឆ្លើយដាក់មនុស្សក្រោមបង្គាប់របស់ខ្លួន ការណែនាំឲ្យបុគ្គលិកតាមដានមនុស្សដែលគេសង្ស័យ និងការចាត់វិធានការណាមួយក្នុងការឲ្យមានការចាប់ខ្លួនមនុស្សដែលគេបានចាត់ទុកថាជាខ្មាំង ឬជនក្បត់ និងប្រគល់ទៅឲ្យមន្ទីរស២១។ ស្រដៀងគ្នានេះ គាត់បានរៀបចំផែនការចាប់ខ្លួន និងការដក កម្មាភិបាលមួយចំនួនពីភូមិភាគបូព៌ា ក្នុងអំឡុងពេលមជ្ឈិមបក្សបោសសម្អាតភូមិភាគនោះ។ ជាលទ្ធផលនៃការរៀបចំផែនការឧក្រិដ្ឋកម្មទាំងនេះរបស់គាត់ បុគ្គលិករបស់គាត់ជាច្រើននាក់ត្រូវបានបញ្ជូនទៅមន្ទីរស២១ និងការដ្ឋានពលកម្មដោយបង្ខំ។

១៦៣០- **អៀង ធីរិទ្ធ** មានចេតនារៀបចំផែនការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ ឬ តាមរយៈតួនាទី និងឋានៈរបស់ខ្លួន បានដឹងអំពីលទ្ធភាពដែលថាឧក្រិដ្ឋកម្មទាំងនេះនឹងអាចត្រូវបានប្រព្រឹត្តក្នុងការអនុវត្តអំពើនានាដែលខ្លួនបានរៀបចំឡើង។ ចំណុចនេះត្រូវបានបញ្ជាក់ដោយ ១) ការឯកភាពរបស់គាត់ទៅលើគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា២) ការប្រាស្រ័យទាក់ទងរបស់គាត់អំពីគោលនយោបាយទាំងនេះ និងការផ្តល់ឱវាទណែនាំនានាក្នុងអំឡុងវគ្គបំពាក់បំប៉ននយោបាយ និងការជួបប្រជុំជាមួយកម្មាភិបាលក្រសួងសង្គមកិច្ច និង ៣) ការទទួលចម្លើយសារភាពពីមន្ទីរ ស២១។ គេក៏អាចសន្និដ្ឋានអំពីចេតនារបស់ **អៀង ធីរិទ្ធ** ក្នុងការរៀបចំផែនការឧក្រិដ្ឋកម្ម តាមរយៈការចាប់ខ្លួនកម្មាភិបាលជាច្រើននាក់ ក្រោមការគ្រប់គ្រងរបស់គាត់ ការដឹងអំពីការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា និងទម្រង់នៃប្រតិបត្តិការ និងព័ត៌មានដែលគាត់បានដឹងក្នុងនាមជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា។

## ការញុះញង់

១៦៣១- **អៀង ធីរិទ្ធ** បានញុះញង់ឲ្យមានឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋាននេះ តាមរយៈការជម្រុញ ការលើកទឹកចិត្ត ការញុំាង ការនាំអាទិ៍ និងការញុះញង់ ចារីដែលដល់ដែលទង្វើទាំងនេះបានរួមចំណែកធំដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

១៦៣២- **អៀង ធីរិទ្ធ** បានលើកទឹកចិត្ត និងបានញុំាងឲ្យកម្មាភិបាលក្រសួងសង្គមកិច្ច ប្រព្រឹត្តបទឧក្រិដ្ឋតាមរយៈការបើកវគ្គបំពាក់បំប៉ននយោបាយជាទៀងទាត់ និងបានធ្វើជាអធិបតីនៃអង្គប្រជុំនៅក្រសួងដែលក្នុងអំឡុងពេលនោះ គាត់បានឯកភាពគាំទ្រ និងផ្តល់ភាពសមហេតុផលដល់គោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងនោះរួមមាន ការជម្លៀសចេញពីទីក្រុង

ដោយបង្ខំ ការដាក់ប្រជាជនជាទាសករ ការគៀបសង្កត់ទៅលើខ្មាំង និងការធ្វើទុក្ខបុកម្នេញប្រជាជនវៀតណាម។ គាត់បានជម្រុញឱ្យអ្នកចូលរួមវែកមុខខ្មាំងផ្ទៃក្នុង និងសម្រេចរវាងភក្តីភាពជាមួយបក្ស និងខ្មាំងវៀតណាម។ គាត់ថែមទាំងបានញុះញង់កម្មាភិបាលក្រោមបញ្ជារបស់ខ្លួនផ្ទាល់ឱ្យចូលរួមក្នុងការកំណត់អត្តសញ្ញាណខ្មាំងតាមរយៈការបញ្ជា និង/ឬ ឯកភាពចំពោះការចាប់ខ្លួន និងការបញ្ជូនមនុស្សដែលគេបានចាត់ទុកថាជាខ្មាំងទៅមន្ទីរ ស២១ និងការដ្ឋានការងារពលកម្មដោយបង្ខំ (ក្នុងនោះមានការដ្ឋាន**ព្រលានយន្តហោះកំពង់ឆ្នាំង** និង**ស្រែអំបិល**)។ **អៀង ធីរិទ្ធ** ក៏បានរួមចំណែកដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្រៅរង្វង់ក្រសួងសង្គមកិច្ច តាមរយៈការចុះត្រួតពិនិត្យទីកតាំងឧក្រិដ្ឋកម្មនានា (ក្នុងនោះរួមមាន ទំនប់១មករា) និងការផ្តល់ការលើកទឹកចិត្តដល់ចារី។

១៦៣៣- សម្តី និងទង្វើរបស់ **អៀង ធីរិទ្ធ** ទាំងក្នុងអំឡុងពេល និងក្រោយរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ បញ្ជាក់ថាជននេះមានចេតនានាំអាទិ៍ និងអុជអាលចារីដែលដល់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ឬយ៉ាងហោចណាស់ ក៏បានដឹងអំពីលទ្ធភាពដែលថាឧក្រិដ្ឋកម្មទាំងនេះនឹងត្រូវបានប្រព្រឹត្តដោយសារអំពើ និងពាក្យសម្តីលើកទឹកចិត្តរបស់ខ្លួន។

## ការបញ្ជា

១៦៣៤- **អៀង ធីរិទ្ធ** បានបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានពណ៌នាក្នុងដីកាសន្និដ្ឋាននេះ។ គាត់បានប្រើអំណាចរបស់ខ្លួនជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ក្នុងការចេញសេចក្តីណែនាំឱ្យចាប់ខ្លួន និងបញ្ជូនអ្នកដែលជាប់សង្ស័យថាជាខ្មាំង ចេញពីអង្គភាពនានាក្រោមការគ្រប់គ្រងរបស់គាត់ ទៅ**ស២១** និងការដ្ឋានធ្វើការងារពលកម្មដោយបង្ខំ។ តាមលក្ខណៈនេះ គាត់បានបញ្ជាឱ្យចាប់ខ្លួន ដកហូត

ចេញពីតំណែង និងសម្លាប់បុគ្គលិកជាងមួយរយនាក់ចេញពីអង្គភាពនានារបស់ក្រសួងនេះ។ គាត់បានផ្តល់ការណែនាំ ឱ្យផលិត និងចែកចាយថ្នាំពេទ្យដែលគ្មានសុវត្ថិភាព និង/ឬ គ្មានប្រសិទ្ធភាពទៅតាមភូមិភាគ ដែលថ្នាំទាំងនោះត្រូវបានយកទៅប្រើសម្រាប់ជនស៊ីវិល ដែលត្រូវគេបង្ខំឱ្យធ្វើជាទាសករ និង បានធ្វើឱ្យលាប់ជម្ងឺ ឬបន្ថែមពសន្ទ្បកម្មដល់រាងកាយ និងផ្លូវចិត្ត ដែលពួកគេបានទទួលស្រាប់។ គាត់ក៏បានបញ្ជាឱ្យមានការរៀបការដោយបង្ខំ រវាងបុគ្គលិកដែលនៅក្រោមអំណាច និងការគ្រប់គ្រងរបស់គាត់។

១៦៣៥- អត្ថិភាពនៃបញ្ជារបស់ **អៀង ធីរិទ្ធ** អាចទាញការសន្និដ្ឋានពីកត្តានានាជាច្រើន រួមមាន ចំនួន និងភាពជាប្រព័ន្ធនៃការចាប់ខ្លួន និងការបញ្ជូនដោយបង្ខំនូវកម្មាភិបាលពីក្រសួងសង្គមកិច្ច ផលិតកម្មនៅក្នុងក្រសួងសង្គមកិច្ច និងការចែកចាយយ៉ាងទូលំទូលាយនៅទូទាំងកម្ពុជាប្រជាធិបតេយ្យនូវថ្នាំពេទ្យដែលគ្មានសុវត្ថិភាព ការគ្រប់គ្រងរបស់គាត់ទៅលើកម្មាភិបាល និងបុគ្គលិកនៅក្រសួងសង្គមកិច្ច និងការរាយការណ៍ជាបន្តបន្ទាប់រវាងអង្គភាពនានានៅក្រសួងសង្គមកិច្ច និងថ្នាក់លើ។

១៦៣៦- **អៀង ធីរិទ្ធ** មានចេតនាបណ្តាលឱ្យការប្រព្រឹត្តិឧក្រិដ្ឋកម្ម តាមរយៈបទបញ្ជា និងសេចក្តីណែនាំរបស់គាត់ ឬ យ៉ាងហោចណាស់ក៏គាត់បានដឹងពីភាពសមទំនងជាសំខាន់ដែលថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តក្នុងការប្រតិបត្តិតាមបញ្ជាទាំងនោះ។ ភ័ស្តុតាងស្តីពីការសម្រេចសម្រួលរបស់គាត់ជាមួយ ស២១ បានបញ្ជាក់ពីចេតនារបស់គាត់ក្នុងការបោសសំអាតកម្មាភិបាល នៅក្រសួងសង្គមកិច្ច។ គាត់ក៏បានដឹងដែរថា ដោយសារតំណែងរបស់គាត់នៅក្នុងក្រសួងនេះ និងឧត្តមភាពរបស់គាត់នៅក្នុងរបបនេះ និងក្នុងបក្សកុម្មុយនីស្តកម្ពុជា បញ្ជាទាំងអស់របស់គាត់នឹងត្រូវគេ

អនុវត្តតាមដោយតឹងរ៉ឹងបំផុត។ ជាចុងក្រោយ តាមរយៈរបាយការណ៍ និងព័ត៌មានដែលគាត់បានទទួល រួមទាំងទស្សនកិច្ចដែលគាត់បានធ្វើទៅតាមទីកន្លែងនានានៅទូទាំងប្រទេស គាត់ក៏បានដឹងពីទុក្ខវេទនាដែលធ្លាក់ទៅលើជនស៊ីវិល ដែលត្រូវបានគេដាក់នៅក្នុងភាពជាទាសករ នៅតាមការដ្ឋានធ្វើការងារពលកម្មដោយបង្ខំ និង តាមសហករណ៍ផងដែរ រួមទាំងអង្គហេតុដែលថា ការគ្រប់គ្រងថ្នាំពេទ្យដែលគ្មានសុវត្ថិភាព និង/ឬ គ្មានប្រសិទ្ធភាព ធ្វើឲ្យទុក្ខវេទនានោះកាន់តែមានលក្ខណៈធ្ងន់ធ្ងរថែមទៀត។

## ការជួយ និងជម្រុញ

១៦៣៧- **អៀង ធីរិទ្ធ** បានជួយ និងជំរុញការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយការលើកទឹកចិត្ត ការគាំទ្រផ្នែកស្មារតី និងជំរុញការអនុវត្តដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។ ការជួយនិងជម្រុញ របស់គាត់មានឥទ្ធិពលយ៉ាងខ្លាំងទៅលើឧក្រិដ្ឋកម្មទាំងមុនពេល អំឡុងពេល និងក្រោយពេលប្រព្រឹត្តបទឧក្រិដ្ឋ។

១៦៣៨- **អៀង ធីរិទ្ធ** បានគាំទ្រគោលនយោបាយឧក្រិដ្ឋរបស់មជ្ឈិមបក្ស និងផ្តល់ការគាំទ្រផ្នែកស្មារតីដល់អ្នកដែលចូលរួមក្នុងការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនកម្មាភិបាលនៅក្នុងក្រសួងរបស់គាត់។ គាត់ក៏ជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅមន្ទីរស២១ដែរ តាមរយៈការបញ្ជាផ្ទាល់ឲ្យមានចាប់ខ្លួន និងបញ្ជូនកម្មាភិបាលក្រសួងសង្គមកិច្ច។ គាត់ក៏បានបន្តជួយអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបង្កើតទាសភាព ការងារពលកម្មដោយបង្ខំ និងបានអប់រំកែប្រែ ដោយយល់ព្រមបញ្ជូនកម្មាភិបាលក្រសួងសង្គមកិច្ចទៅការដ្ឋាន និងដោយការធ្វើទស្សនកិច្ចរបស់គាត់នៅតាមការដ្ឋាននានា។ គាត់ក៏បានជួយសម្រួលយ៉ាងសកម្ម នូវការអនុវត្តគោល

នយោបាយ ស្តីពីការរៀបការដោយបង្ខំនៅក្នុងក្រសួងសង្គមកិច្ច និងការប្រើថ្នាំពេទ្យដែលគ្មានសុវត្ថិភាពតាមទីតាំងឧក្រិដ្ឋកម្មនានា។ ជាងនេះទៅទៀត **អៀង ធីរិទ្ធ** បានផ្តល់ការគាំទ្រដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយធ្វើយុត្តិកម្ម និងការពារគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងពេលមានការបំពេញទស្សនកិច្ចរបស់អ្នកការទូតបរទេស។ ជាចុងក្រោយ បន្ទាប់ពីការធ្វើទស្សនកិច្ចទៅភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៦ ការផ្តល់យោបល់របស់គាត់ទៅមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាគឺថា មានខ្មាំងបង្កប់ និងគិញកំពុងធ្វើឱ្យអន្តរាយដល់ផែនការបក្សនៅក្នុងភូមិភាគនោះ ដែលជាលទ្ធផលនាំឱ្យមានការបោសសម្អាតជាទ្រង់ទ្រាយធំនៅក្នុងភូមិភាគនោះ។

១៦៣៩- ក្នុងឋានៈជាសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា និងជាប្រមុខក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** បានដឹងថាអំពើរបស់គាត់ក្នុងការលើកទឹកចិត្ត និងផ្តល់ការគាំទ្រទាំងស្មារតី និងការអនុវត្ត កំពុងជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយគាត់មានចេតនាផ្តល់ការគាំទ្រ ឬយ៉ាងហោចណាស់ក៏ទទួលស្គាល់ថា ការជួយបែបនេះនឹងផ្តល់ផលវិបាកមួយដែលអាចដឹងជាមុនបានអំពីទង្វើរបស់គាត់។ **អៀង ធីរិទ្ធ** ក៏បានដឹងពីធាតុសំខាន់ៗនៃឧក្រិដ្ឋកម្មដែលគាត់កំពុងជួយ និងជំរុញ នៅពេលគាត់បន្តទទួលព័ត៌មានពីសកម្មភាពរបស់ចារីផ្ទាល់ តាមរយៈការប្រជុំនិងការប្រាស្រ័យទាក់ទងជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត គណៈរដ្ឋមន្ត្រី និងរបាយការណ៍នានាដែលគាត់បានទទួល និង/ឬ ទទួលបាន។

## ការទទួលខុសត្រូវក្នុងនាមថ្នាក់លើ

១៦៤០- បន្ថែមលើនេះ និងនិយាយម្យ៉ាងទៀតគឺថា **អៀង ធីរិទ្ធ** ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ក្នុងនាមជាថ្នាក់លើម្នាក់ អនុលោមតាមមាត្រា២៩ កថាខណ្ឌ១ នៃច្បាប់ស្តីពីការបង្កើត

អ.វ.ត.ក ដោយសារៈ (១)តួនាទីរបស់គាត់ជាមេដឹកនាំរបស់ចារីផ្ទាល់ ចំពោះឧក្រិដ្ឋកម្មដែលមានពណ៌នានៅផ្នែកអង្គហេតុសត្យានុម័ត (២)ការយល់ដឹងជាក់ស្ដែង ដែលថាអ្នកក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬនឹងប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និង (៣)ការខកខានរបស់គាត់មិនបានទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬមិនបានដាក់ទោសចារី។

**ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកក្រោមបង្គាប់**

១៦៤១- **អៀង ធីរិទ្ធ** គឺជាថ្នាក់លើរបស់កម្មាភិបាលនៅក្រសួងសង្គមកិច្ច រួមទាំងសមាជិកគណៈកម្មាធិការសង្គមកិច្ច កម្មាភិបាលក្រសួង កម្មាភិបាលពេទ្យ និងពលករខាងផលិតថ្នាំពេទ្យផងដែរ។ ទោះបីមានទំនាក់ទំនងខ្លះមានលក្ខណៈដោយផ្ទាល់ ឬតាមសភាពជាក់ស្តែងក៏ដោយ ក៏ **អៀង ធីរិទ្ធ** ជាថ្នាក់លើរបស់អ្នកទាំងនោះដែរ ដោយគាត់គ្រប់គ្រងពួកគេយ៉ាងមានប្រសិទ្ធភាព។ ក្នុងឋានៈជារដ្ឋមន្ត្រីមួយរូប គាត់ស្ថិតនៅឋានានុក្រមខ្ពស់ជាងគេនៅក្នុងក្រសួងសង្គមកិច្ច និងមានលទ្ធភាពខាងសម្ភារៈ ក្នុងការទប់ស្កាត់មិនឱ្យកម្មាភិបាលនៅតាមអង្គភាពទាំងអស់របស់ក្រសួងប្រព្រឹត្តឧក្រិដ្ឋកម្ម ផ្តួចផ្តើមស៊ើបអង្កេត ឬចាត់វិធានការនានា ដែលនាំទៅរកដំណើរការនីតិវិធីប្រឆាំងនឹងពួកគេ ដកពួកគេចេញពីតំណែង ឬ ដាក់ទណ្ឌកម្មវិន័យ និងផ្តន្ទាទោសពួកអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋ។ លទ្ធភាពនេះបានលាតត្រដាងយ៉ាងច្បាស់ដោយសារៈ ១)ក្នុងនាមជារដ្ឋមន្ត្រី គាត់ចេញសារាចរ សេចក្តីណែនាំ និងបទបញ្ជាទៅកម្មាភិបាល និងបុគ្គលិកក្រសួងសង្គមកិច្ច ២)ការបន្តគ្រប់គ្រង និង ទស្សនកិច្ចរបស់គាត់នៅតាមអង្គភាពនានារបស់ក្រសួងសង្គមកិច្ច មន្ទីរពេទ្យ និងរោងចក្រផលិតថ្នាំពេទ្យ និង ៣)តួនាទីរបស់គាត់ក្នុងការអនុម័តយល់ព្រមជា

លក្ខណៈបុគ្គល ឱ្យធ្វើការបោសសម្អាត និង ដកហូតចេញពីតំណែងនូវកម្មាភិបាលនៅក្នុងក្រសួងសង្គមកិច្ច។

**ការដឹងឮ**

១៦៤២- **អៀង ធីរិទ្ធ** មានការយល់ដឹងដោយពិតប្រាកដ ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់។ ជាផលវិបាកដែលកើតចេញពីការដែលគាត់បញ្ជា រៀបផែនការ ឬឯកភាពទៅលើឧក្រិដ្ឋកម្មទាំងនោះ គាត់បានដឹងជាចាំបាច់ថា ឧក្រិដ្ឋកម្មទាំងនោះនឹងត្រូវគេប្រព្រឹត្តមិនខាន។ ការយល់ដឹងនេះ ត្រូវបានបញ្ជាក់តាមរយៈការប្រជុំ និង ការប្រាស្រ័យទាក់ទងជាមួយកម្មាភិបាលក្រសួងសង្គមកិច្ច ទស្សនកិច្ចរបស់គាត់នៅតាមអង្គភាពនានារបស់ក្រសួងសង្គមកិច្ច ព្រមទាំងបានទទួលរបាយការណ៍របស់ក្រសួង និង ការប្រាស័យទាក់ទង និងចម្លើយសារភាពពី**មន្ទីរស២១**។ ការដឹងឮជាក់ស្តែងរបស់ **អៀង ធីរិទ្ធ** អំពីឧក្រិដ្ឋកម្មនៅពេលវេលាដែលពាក់ព័ន្ធក៏ត្រូវបានបញ្ជាក់ដោយសេចក្តីថ្លែងការណ៍របស់គាត់មួយរយៈពេលខ្លី ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ។

១៦៤៣- ក្នុងករណីដែលភ័ស្តុតាងពុំមានសេសសល់ថា **អៀង ធីរិទ្ធ** បានទទួលរបាយការណ៍ផ្ទាល់នូវឧក្រិដ្ឋកម្មជាក់លាក់ ឬមានការពាក់ព័ន្ធក្នុងការប្រតិបត្តិឧក្រិដ្ឋកម្មទាំងនេះក៏ដោយ តែគាត់ពិតជាបានទទួលព័ត៌មាន ដែលតម្រូវឱ្យគាត់ត្រូវកត់សម្គាល់ថា ឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់គាត់ដែរ។ ព័ត៌មានទាំងនោះរួមមាន របាយការណ៍ដែលគាត់បានទទួលពីអង្គភាពនានានៃក្រសួងសង្គមកិច្ច ព័ត៌មានដែលគាត់បានទទួលក្នុងពេលប្រជុំជាមួយអ្នកក្រោមបង្គាប់ និងការប្រជុំនិងប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត (រួមមាន

សមាជិកគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ និងគណៈរដ្ឋមន្ត្រី) ភាពជាប្រព័ន្ធ ភាពស៊ីសង្វាក់គ្នា និងលក្ខណៈទូលំទូលាយនៃឧក្រិដ្ឋកម្ម និងការប្រព្រឹត្តិជាបន្តបន្ទាប់ពេញក្នុងអំឡុងពេលពាក់ព័ន្ធ។

**ការខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្ម**

១៦៤៤- **អៀង ធីរិទ្ធ** ខកខានមិនបានប្រើប្រាស់តួនាទីរបស់គាត់ ដើម្បីទប់ស្កាត់មិនឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ ឬមិនបានដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះទេ។ ក្នុងនាមគាត់ជាអ្នកស្ថាបនិកមួយរូបដ៏សំខាន់ នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកម្មាភិបាលនៅក្រសួងសង្គមកិច្ច **អៀង ធីរិទ្ធ** មិនបានរារាំងចំពោះការប្រព្រឹត្តិរបស់កម្មាភិបាលទាំងនោះឡើយ។ ផ្ទុយទៅវិញ គាត់បានលើកសរសើរដល់ចារី និងជំរុញឱ្យពួកគេបន្តប្រព្រឹត្តឧក្រិដ្ឋកម្មតទៅទៀត។ ក្រៅពីសមត្ថភាពរបស់គាត់យ៉ាងមានប្រសិទ្ធភាពក្នុងការធ្វើបែបនេះ **អៀង ធីរិទ្ធ** ខកខានទាំងស្រុងក្នុងការចាត់វិធានការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម។

## VII. **បទចោទ**

១៦៤៥- ដោយពិចារណាទៅលើអង្គហេតុជាក់ស្តែង និងការកំណត់បទចោទនៃអង្គហេតុទាំងនេះ ដូចបានរៀបរាប់ក្នុងដីកាសន្និដ្ឋាន សហព្រះរាជអាជ្ញាស្នើឱ្យសហចៅក្រមស៊ើបអង្កេត នាំខ្លួនមកជំនុំជម្រះជនដែលមានឈ្មោះដូចខាងក្រោម ៖

(១) នួន ជា

(២) អៀង សារី

(៣) ខៀវ សំផន និង

(៤) អៀង ធីរិទ្ធ

ចំពោះអំពើដែលបានធ្វើផែនការ ញុះញង់ បញ្ជា ជួយជ្រោមជ្រែង និងជម្រុញ និងដែលបានប្រព្រឹត្ត តាមរយៈសហកម្មឧក្រិដ្ឋកម្មរួម មានឧក្រិដ្ឋកម្មដូចខាងក្រោម ដែលត្រូវផ្តន្ទាទោស តាមមាត្រា២៩ ៖

(១) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវផ្តន្ទាទោសតាមមាត្រា៤ មាត្រា២៩ថ្មី និង មាត្រា៣៩ថ្មី នៃច្បាប់ អ.វ.ត.ក ជាពិសេស ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទៅលើ៖

(ក) ជនជាតិចាម

(ខ) ជនជាតិវៀតណាម

(២) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវផ្តន្ទាទោសតាមមាត្រា៥ មាត្រា២៩ថ្មី និងមាត្រា៣៩ថ្មី នៃច្បាប់ អ.វ.ត.ក ជាពិសេស៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការធ្វើឱ្យទៅជាទាសករ

(ឃ) ការដាក់ក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ច) ការរំលោភផ្លូវភេទ

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និង/ឬ សាសនា

(ជ) អំពើអមនុស្សធម៌ផ្សេងៗទៀត ។

(៣) អំពីបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ដែលត្រូវផ្តន្ទាទោសតាមមាត្រា៦ មាត្រា២៩ថ្មី និងមាត្រា៣៩ថ្មី នៃច្បាប់ អ.វ.ត.ក ជាពិសេស៖

(ក) ការធ្វើមនុស្សឃាតដោយចេតនា

(ខ) ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌

(គ) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

(ឃ) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង) ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(៤) ការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ដែលត្រូវផ្តន្ទាទោសតាមមាត្រា៣ មាត្រា២៩ថ្មី និងមាត្រា៣៩ថ្មី នៃច្បាប់ អ.វ.ត.ក ជាពិសេស៖

(ក) មនុស្សឃាត (មាត្រា៥០១ ៥០៣ និង ៥០៦)

(ខ) ទារុណកម្ម (មាត្រា ៥០០)

១៦៤៦- បន្ថែមលើនេះ អនុលោមតាមមាត្រា ២៩ សូមសន្និដ្ឋានថា ជនត្រូវចោទទាំងនេះគួរត្រូវបានបញ្ជូនទៅធ្វើការជំនុំជម្រះពីឧក្រិដ្ឋកម្មទាំងអស់ដែលបានបញ្ជាក់ខាងលើ ក្នុងឋានៈជាថ្នាក់លើ ដោយហេតុថាពួកគេបានដឹងឮ ឬ មានហេតុផលក្នុងការបានដឹងឮថាថ្នាក់ក្រោមនានារបស់ពួកគេហៀបនឹងបានប្រព្រឹត្ត ឬមួយក៏បានប្រព្រឹត្ត នូវឧក្រិដ្ឋកម្មទាំងនោះរួចហើយ ហើយពួកគេបានខកខានក្នុងការចាត់វិធានការចាំបាច់ និងសមហេតុផលនានា ដើម្បីរារាំងនូវឧក្រិដ្ឋកម្មបែបទាំងនេះ ឬបានខកខាននៅក្នុងការដាក់ទណ្ឌកម្មដល់ចារីទាំងនោះ ។

១៦៤៧- ហេតុដូច្នេះហើយ សហព្រះរាជអាជ្ញា សូមដាក់សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/ អវតក-កសចស ជូនទៅសហចៅក្រមស៊ើបអង្កេត និងសូមស្នើថាជនត្រូវចោទទាំងនេះគួរត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ន រហូតទាល់តែពួកគេត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមមាត្រា៦៨.១ ដរាបណានៅតែមានទទ្បីករណ៍នានាសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្ន ដែលមានចែងក្នុងវិធាន ៦៣.៣ ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | |
| | **លោក Andrew CAYLEY**<br>**សហព្រះរាជអាជ្ញា** | | |

# ឧបសម្ព័ន្ធ ៥: សន្ទានុក្រម

| | |
|---|---|
| ប្រជាជន ១៧ មេសា | ឈ្មោះផ្សេងដែលគេដាក់ឲ្យ "ប្រជាជនថ្មី" ឬ"ប្រជាជនបញ្ញើ" ដែលជាជនស៊ីវិលទាំងឡាយ ដែលត្រូវបានគេជម្លៀសចេញពីទីក្រុង/ទីប្រជុំជននានា បន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ ក្នុងខែមេសា ឆ្នាំ១៩៧៥។ |
| AEK | សមាគមនិស្សិតខ្មែរ |
| AI | អង្គការលើកលែងទោសអន្តរជាតិ |
| អង្គការ | ឈ្មោះសម្រាប់មជ្ឈិមបក្ស ឬ"បងៗថ្នាក់លើ" ដែលជារឿយៗ គឺដើម្បីរៀបរាប់ពីភាពជាមេដឹកនាំរបស់បក្សកុម្មុនីស្តកម្ពុជា និងជាពាក្យមានន័យត្រង់ដូចពាក្យអង់គ្លេសថា "the Organisation" ដែលមានន័យថា "អង្គការ" ដែរ។ |
| ASEAN | សមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍ |
| ប១ | មន្ទីរនៃក្រសួងការបរទេស។ |
| ប៥ | មន្ទីរនៅភូមិតាំងប៉ុន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលជារដ្ឋបាលថ្នាក់កណ្តាលរបស់ខ្មែរក្រហម មុនខែមេសា ឆ្នាំ១៩៧៥ ។ |
| ប៣០, ប៣១, ប៣២ | ជំរំអប់រំកែប្រែសម្រាប់បញ្ញវន្ត អ្នកការទូត និងនិស្សិត ដែលធ្វើមាតុភូមិនិវត្តន៍ មានទីតាំងស្ថិតនៅបឹងត្របែកក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានប្តូរ |

| | |
|---|---|
| | ឈ្មោះដោយភ្ជាប់លេខកូដអក្សរ "ប" បន្ទាប់ពីបានផ្ទេរការគ្រប់គ្រងពីមន្ទីរ៨៧០ មកឲ្យក្រសួងការបរទេស ហើយដែលពីមុនត្រូវបានគេស្គាល់ថា ក១៥ ក១៦ និង ក១៧។ |
| សាខា | អង្គភាពតូចបំផុតនៃឋានានុក្រមរបស់ បកក |
| គណៈកម្មាធិការមជ្ឈិម | អង្គការគ្រប់គ្រងអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា។ |
| CGDK | រដ្ឋាភិបាលចម្រុះនៃកម្ពុជាប្រជាធិបតេយ្យ |
| ចាម | ក្រុមជនជាតិភាគតិចមួយនៅកម្ពុជា ដែលប្រកាន់យ៉ាងខ្ជាប់ខ្ជួនចំពោះសាសនាមូស្លីម និងដែលមានដើមកំណើតពីអាណាចក្រចំប៉ា ដែលត្រូវបានបញ្ចូលដោយអ្នកគ្រប់គ្រងអំណាចនាសម័យអង្គរ ក្នុងសតវត្សរ៍ទី១២។ |
| សេអ៊ីអា | ទីភ្នាក់ងារចារកម្មកណ្តាលដែលជាអង្គការប្រមូលព័ត៌មានសម្ងាត់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ |
| ស.ច.ស | សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ |
| ឃុំ | ថ្នាក់រដ្ឋបាលទាបជាងគេ នៅក្រោមភូមិភាគ តំបន់ ស្រុក ដែលសំដៅទៅលើទីតាំងភូមិសាស្ត្ររបស់វា ។ |
| សហករណ៍ | អង្គភាពរដ្ឋបាលសង្គមមួយ ដែលបានបង្កើតឡើងបន្ទាប់ពីការរំលាយចោលរចនាសម្ពន្ធរដ្ឋបាលភូមិ ឃុំ ដោយមានសមាសភាព ១០០០ គ្រួសារ ដែលបានធ្វើឡើងបន្ទាប់ពីមានការធ្វើសមូហភាវូបនីយកម្មនៃសង្គមខ្មែរ នៅក្រោមរបបខ្មែរក្រហម។ |

| | |
|---|---|
| បកក | បក្សកុម្មុយនីស្តកម្ពុជាដែលជាអង្គការនយោបាយរបស់ខ្មែរក្រហម និងពីអតីតកាលត្រូវបានគេស្គាល់ថា បក្សពលករកម្ពុជា។ |
| ឌីស៊ីខាំ (DC-Cam) | មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាបណ្ណសារថ្នាក់កណ្តាលមួយសម្រាប់រក្សាឯកសារសហកាលកម្ពុជាប្រជាធិបតេយ្យ ដែលទទួលបានពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារជាតិកម្ពុជា និងសមូហភណ្ឌឯកជន។ |
| អនុ | ការទទួលបន្ទុកថ្នាក់ទីពីររបស់អង្គភាពណាមួយនៃ អង្គការរបស់បក្សកុម្មុយនីស្តកម្ពុជា ឬកងទ័ពបដិវត្តន៍កម្ពុជា ដែលជាធម្មតាទទួលខុសត្រូវខាងសន្តិសុខ និងរាយការណ៍ជូនលេខាអង្គភាពនោះ។ |
| ស្រុក | ថ្នាក់រដ្ឋបាលទីបី ក្រោមភូមិភាគ និងតំបន់ សំដៅលើទីតាំងភូមិសាស្ត្ររបស់វានៅក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែក៏អាចសំដៅទៅលើការកំណត់សំគាល់ជាលេខណាមួយផងដែរ។ |
| កម្ពុជាប្រជាធិបតេយ្យ | កម្ពុជាប្រជាធិបតេយ្យ ជាឈ្មោះដែលគេបានដាក់ឱ្យប្រទេសកម្ពុជា ក្នុងអំឡុងរបបខ្មែរក្រហម និងបានអនុម័តទទួលយកជាផ្លូវការតាមរយៈការផ្តល់សច្ចាប័នរដ្ឋធម្មនុញ្ញ ក្នុងខែមករា ឆ្នាំ១៩៧៦។ |
| អ.វ.ត.ក | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| ច្បាប់ អ.វ.ត.ក | ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។ |

| | |
|---|---|
| ថ្នាក់ | កំរិត ឬ ជាន់ថ្នាក់ នៃអង្គភាពយោធា ឬស៊ីវិលណាមួយ។ |
| កិច្ចព្រមព្រៀងស្តីពីការបង្កើត | កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តិឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។ |
| សមាជិកពេញសិទ្ធិ | សមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា, ឬសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការណាមួយ។ |
| FUNK | *រណសិរ្សរួបរួមជាតិកម្ពុជា (Front Uni National du Kampuchea*, or the National United Front of Kampuchea), គឺជាអង្គការ “រណសិរ្ស” មួយដែលត្រូវបានប្រើប្រាស់សម្រាប់ប្រមូលផ្តុំជនដែលមិនមែនកុម្មុយនីស្ត ដើម្បីគាំទ្រដល់បដិវត្តន៍ និងដល់អង្គការនយោបាយដែលស្ថិតនៅពីក្រោយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) នៅចន្លោះរវាងខែមីនា ឆ្នាំ១៩៧០ និងខែមីនា ឆ្នាំ១៩៧៦។ |
| អគ្គសេនាធិការ | ទីបញ្ជាការជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជា (RAK) ដែលដឹកនាំដោយ សុន សេន និងដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ |
| វណ្ណៈមូលដ្ឋាន | គឺជាពាក្យដែលគេប្រើសម្រាប់សំគាល់ថ្នាក់ទាបបំផុតក្នុងសង្គម នៅក្រោមរបបខ្មែរក្រហម ដែលតាមន័យត្រង់ គឺមានន័យថា “វណ្ណៈកសិករ” ។ ក៏ប៉ុន្តែនៅពេលដែលសមាជិករបស់មជ្ឈិមបក្សនានាយកមកប្រើ ពាក្យនេះក៏អាចសំដៅចំពោះថ្នាក់ភូមិភាគ និង ថ្នាក់ក្រោមរបស់ បកក បានដែរ ។ |

| | |
|---|---|
| GRUNK | *រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា* (*Gouvernement Royal d'Union Nationale du Kampuch"a*, or the Royal Government of National Union of Kampuchea), ដែលជារដ្ឋាភិបាលនិរទេសខ្លួនដែលត្រូវបានបង្កើតឡើងដោយសម្តេចនរោត្តមសីហនុ ក្រោយពីព្រះអង្គត្រូវបានគេទម្លាក់ចេញពីតំណែងក្នុងឆ្នាំ១៩៧០ ដែលមានអត្ថិភាពរហូតមកទល់នឹងខែមីនា ឆ្នាំ១៩៧៦។ |
| ICC | តុលាការព្រហ្មទណ្ឌអន្តរជាតិ |
| ICP | បក្សកុម្មុយនីស្តឥណ្ឌូចិន (Indochinese Communist Party) គឺជាអង្គការមួយដែលបង្កើតឡើងដោយ ហូ ជីមិញនៅក្នុងឆ្នាំ១៩៣០ ហើយត្រូវបានរំសាយនៅក្នុងឆ្នាំ១៩៥១ទៅជាគណបក្សរបស់ជាតិនីមួយៗរៀងៗខ្លួនសម្រាប់ប្រទេសវៀតណាម ឡាវ និងកម្ពុជា ។ |
| ICRC | គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ |
| ICTR | តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា |
| ICTY | តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី |
| IS | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (Introductory Submission), ដែលជាឯកសារមួយដែលការិយាល័យសហព្រះរាជអាជ្ញាបានបង្កើតឡើងសម្រាប់ស្នើសុំទៅការិយាល័យសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលតំណាងឱ្យបទល្មើសព្រហ្មទណ្ឌមួយចំនួន ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយសុំឱ្យធ្វើ |

| | |
|---|---|
| | ការចាប់ខ្លួន និងឃុំខ្លួន **នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ** និង **ឌុច** ជាបណ្តោះអាសន្ន ។ |
| IS ឧបសម្ព័ន្ធ គ | ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលមានចំណងជើងថា "ភស្តុតាងជាក់ស្តែង", ឧបសម្ព័ន្ធឯកសារនៃភស្តុតាងជាក់ស្តែង ដែលមានភ្ជាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ |
| ក-១ | លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ ប៉ុល ពត។ |
| ក-២ | លេខកូដសំគាល់សម្រាប់ក្រសួងសង្គមកិច្ច។ |
| ក-៣ | លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ **នួន ជា** និង **ខៀវ សំផន**។ |
| ក-៧ | មន្ទីរនិរសារ (មន្ទីរបញ្ជូនសារ) នៅក្នុងទីក្រុងភ្នំពេញ ដែលទទួលខុសត្រូវក្នុងការបញ្ជូនឯកសារជាក្រដាសស្នាមផ្សេងៗរវាងបណ្តាក្រសួងនានា និងពីមជ្ឈិមបក្សទៅឲ្យកាន់ភូមិភាគនានា  ក៏ដូចជាទីកន្លែងសម្រាប់ប្រមូលផ្តុំមនុស្សដែលនឹងត្រូវបានគេចាប់ខ្លួន និងត្រូវបញ្ជូនទៅកាន់មន្ទីរស២១។ |
| ក-១៨ | មជ្ឈមណ្ឌលគមនាគមន៍ដែលមានទីតាំងស្ថិតនៅអតីតស្ថានទូតសហរដ្ឋអាមេរិក ត្រង់កែងមហាវិថីនរោត្តម និងសុធារស, ក្នុងទីក្រុងភ្នំពេញ។ |
| កាហ្សេបេ (KGB) | *Komitet Gosudarstvennoi Bezopasnosti* គឺជាប៉ូលីសសម្ងាត់របស់សូវៀត និងជាអង្គការប្រមូលផ្តុំការស៊ើបការសម្ងាត់ពីក្រៅប្រទេស របស់សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត។ |

| | |
|---|---|
| ខ្មែរក្រោម | ជនជាតិខ្មែរដែលរស់នៅតាមតំបន់ដីសណ្តទន្លេមេគង្គភាគខាងត្បូង ប្រទេសវៀតណាម ដែលត្រូវបានគេស្គាល់ផងដែរថា ជាខ្មែរកម្ពុជាក្រោម ។ |
| ខ្មែរក្រហម | ឈ្មោះដែល សម្តេចនរោត្តមសីហនុ បានដាក់ឲ្យពួកខ្មែរកុម្មុយនីស្ត នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ |
| KPRP | បក្សបដិវត្តន៍ប្រជាជនខ្មែរ (Khmer People"s Revolutionary Party) ដែលជាចលនាកុម្មុយនីស្តបន្ទាប់ពីការរំលាយបក្សឥណ្ឌូចិន (ICP)មក ដែលបានស្ថិតនៅចាប់តាំងពីឆ្នាំ១៩៥១ រហូតដល់ឆ្នាំ១៩៦០។ |
| ក្រមា | កន្សែងសម្រាប់ប្រើប្រាស់តាមប្រពៃណី ដែលខ្មែរទាំងប្រុស ទាំងស្រី ប្រើ។ |
| ម | អក្សរកាត់សម្រាប់ពាក្យ "មន្ទីរ", (office)។ |
| ម-៤០១ (M-401) | មន្ទីររបស់លេខាភូមិភាគបស្ចិម ឬ របស់លេខាភូមិភាគផ្ទាល់ ដូចដែលបានបញ្ជាក់ឲ្យដឹងនៅក្នុងទូរលេខនានា(ឧទាហរណ៍ដូចជា: ហត្ថលេខា "៤០១") |
| ម-៥៦០ (M-560) | មន្ទីររបស់លេខាភូមិភាគពាយព្យ ឬ របស់លេខាភូមិភាគផ្ទាល់ ដូចដែលបានបញ្ជាក់ឲ្យដឹងនៅក្នុងទូរលេខនានា។ |
| កបទ (MFA) | ក្រសួងការបរទេស ក្រសួងរបស់រដ្ឋាភិបាលដែលដឹកនាំដោយ **អៀង សារី** និងដែលទាក់ទងទៅនឹងកិច្ចការអន្តរជាតិ។ |
| ជនបាត់ខ្លួនក្នុងពេលបំពេញបេសកកម្ម (MIA) | ជនបាត់ខ្លួនក្នុងពេលបំពេញបេសកកម្ម (Missing in Action), គឺជាពាក្យដែលទាក់ទងទៅនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធណាម្នាក់ ឬជន |

ដទៃទៀតដែលត្រូវបានគេរាយការណ៍ថា បានបាត់ខ្លួននៅក្នុងអំឡុងពេលនៃជម្លោះណាមួយ។

| | |
|---|---|
| កងឈ្លប (សេនាជន) | កងកម្លាំងក្រៅពីកងទ័ពអាជីពរបស់ជាតិ ដែលត្រួតត្រានៅថ្នាក់ឃុំ តំបន់ ឬថ្នាក់ស្រុក។ |
| ងចល័ត | ក្រុមពលករ ដែលជាតួយ៉ាង គឺជាមនុស្សនៅលីវដែលមានអាយុចាប់ពីក្រោយវ័យជំទង់ទៅដល់ម្ភៃឆ្នាំប្លាយ ដែលត្រូវមានភារកិច្ចធ្វើដំណើរចល័តទៅបំពេញការងារពីកន្លែងមួយទៅកន្លែងមួយទៀត ក្នុងគំរោងការណ៍នានាខាងវិស័យកសិកម្ម និងសំណង់។ |
| MSA | ក្រសួងសង្គមកិច្ច (The Ministry of Social Affairs)។ |
| NCF | មិនមាននៅក្នុងសំណុំរឿង |
| NCFPD | ឯកសារសាធារណៈដែលមិនមាននៅក្នុងសំណុំរឿង |
| កសចស (OCIJ) | ការិយាល័យសហចៅក្រមស៊ើបអង្កេត នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| កសព (OCP) | ការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |
| មន្ទីរ១៥ (Office 15) | មន្ទីរសន្តិសុខនៃតំបន់២៥ ដែលស្ថិតនៅក្នុងស្រុកកោះធំ ខេត្តកណ្តាល។ |
| PDFGNUK | រណសិរ្សមហារួបរួមជាតិកម្ពុជាដើម្បីប្រជាធិបតេយ្យ និងស្នេហាជាតិ |
| វិទ្យុផ្សាយសម្លេងភ្នំពេញ | ការផ្សាយសម្លេងតាមវិទ្យុដោយក្រសួងឃោសនាការ ដែលព័ត៌មានពាក់ព័ន្ធទៅនឹងរបប ត្រូវបានផ្សាយទៅកាន់ពិភពលោក ហើយដែលត្រូវបានឃ្លាំ |

| | |
|---|---|
| | មើល និងរាយការណ៍ដោយសាជីវកម្មផ្សាយសម្លេងអង់គ្លេស និងសេវាផ្សាយសម្លេងព័ត៌មានបរទេស។ |
| PNLAFK | កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ |
| PRA | សភាតំណាងប្រជាជន (People"s Representative Assembly) គឺជាអង្គសភាដែលបានអះអាងថាបានតំណាងឱ្យ ប្រជាជននៃកម្ពុជា ប្រជាធិបតេយ្យ ដឹកនាំដោយ នួន ជា។ |
| PRC | សាធារណរដ្ឋប្រជាមានិតចិន (People"s Republic of China)។ |
| RAK | កងទ័ពបដិវត្តកម្ពុជា (Revolutionary Army of Kampuchea) ជាកងពលធំយោធានានាដែលជាកម្លាំងសំខាន់ ដែលអាចធ្វើការឆ្លើយតបបាន ទៅតាមអគ្គសេនាធិការ។ |
| ទង់បដិវត្ត | ការបោះពុម្ពផ្សាយ(ទស្សនាវដ្តី)ជាផ្លូវការរបស់ បកក ដែលគេប្រើប្រាស់ដើម្បីផ្សព្វផ្សាយពីគោលនយោបាយទៅដល់កម្មាភិបាល បកក ដែលគេបានកម្រិត ការចែកចាយឱ្យត្រឹមតែ សមាជិកពេញសិទ្ធិរបស់បក្ស។ |
| យុវជន-យុវនារីបដិវត្ត | ការបោះពុម្ពផ្សាយ (ទស្សនាវដ្តី) ជាផ្លូវការរបស់ បកក ដែលគេប្រើប្រាស់ដើម្បី ផ្សព្វផ្សាយពីគោលនយោបាយទៅដល់សមាជិកនានា នៃសម្ព័ន្ធយុវជន-យុវនារី កុម្មុយនីស្ត។ |
| វិធាន | វិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ |

| | |
|---|---|
| ស-២១ | មន្ទីរសន្តិបាល ២១ គឺជាមន្ទីរសន្តិសុខសម្ងាត់របស់នគរបាល ដែលមានទីតាំង នៅទីក្រុងភ្នំពេញ។ |
| សង្គមរាស្ត្រនិយម | ចលនានយោបាយរបស់សម្តេចនរោត្តមសីហនុ ចាប់ពីចន្លោះឆ្នាំ១៩៥៥ រហូត ដល់ឆ្នាំ១៩៧០។ |
| សន្តិបាល | ពាក្យខ្មែរបំព្រួញចូលគ្នារបស់ បកក សម្រាប់ពាក្យថា “សន្តិសុខ” និង “នគរបាល” ដែលមានន័យថា “នគរបាលសន្តិសុខ” ឬ “នគរបាលសម្ងាត់”។ |
| SCSL | តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន |
| លេខា | កម្មាភិបាលនានាដែលដាក់ឱ្យទទួលខុសត្រូវលើអង្គភាពមួយនៅក្នុង បកក ឬនៅ ក្នុងរចនាសម្ព័ន្ធនៃកងទ័ពបដិវត្តកម្ពុជា។ |
| តំបន់ | កម្រិតទីពីរនៃការគ្រប់គ្រងផ្នែករដ្ឋបាល នៅក្រោមថ្នាក់ភូមិភាគ ដែលតំបន់នីមួយៗត្រូវបានដាក់លេខកំណត់ការសម្គាល់មួយដោយឡែកៗពីគ្នា។ |
| កម្ទេច | វាក្យស័ព្ទដែលប្រើប្រាស់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដែល មានន័យថាជា ការសម្លាប់ ឬការប្រហារជីវិតបុគ្គលណាមួយ។ |
| SRV | សាធារណរដ្ឋសង្គមនិយមវៀតណាម (Socialist Republic of Vietnam), រដ្ឋាភិបាលឯកភាពវៀតណាម បន្ទាប់ពីរបបធៀវគីដួលរលំ ក្នុងឆ្នាំ១៩៧៥ និង ការរួបរួមរវាងខាងជើង និង ខាងត្បូង។ |
| ចេតិយ | សំណង់រំឭកតាមបែបព្រះពុទ្ធសាសនា ទុកប្រើសម្រាប់តម្កល់អដ្ឋិធាតុមនុស្ស។ |
| អនុស្រុក | ឈ្មោះផ្សេងមួយទៀតសម្រាប់ពាក្យថា ឃុំ។ |

| | |
|---|---|
| ពុទ្ធសាសនាថេរវាទ | និកាយព្រះពុទ្ធសាសនាមួយដែលអនុវត្តនៅប្រទេសកម្ពុជា។ |
| អសប (UN) | អង្គការសហប្រជាជាតិ។ |
| វត្ត(Wat) | ពាក្យខ្មែរហៅថា វត្ត ជាញឹកញាប់ត្រូវបានសរសេរជាអក្សរថា Vatt គឺជាទីកន្លែងគោរពប្រតិបត្តិរបស់ពុទ្ធសាសនិកក្នុងប្រទេសកម្ពុជា។ |
| WPK | បក្សពលករកម្ពុជា (Workers party of Kampuchea) ជាអ្នកស្នងបន្តពីបក្សប្រជាជនបដិវត្តន៍ខ្មែរ(KPRP) ដែលបានប្តូរឈ្មោះរបស់ខ្លួននៅឆ្នាំ ១៩៧១ ទៅជា ប.ក.ក (CPK)។ |
| ភូមិភាគ | លំដាប់ខ្ពស់បំផុតនៃការគ្រប់គ្រងរដ្ឋបាលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ |